រំលឹកប្រវត្តិសាស្ត្រ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ភាគ ៣

ខុទ្ទកាល័យសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
ក្រុមការងារជំរុញការផ្សាយព័ត៌មាននិងទិន្នន័យជាតិ កម្ពុជាឆ្ពោះទៅមុខ
បោះពុម្ពលើកទីមួយ - មិថុនា ២០២៥

រំលឹកប្រសាសន៍

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

ជាឯកសារដកស្រង់អត្ថបទចម្លងប្រសាសន៍ ចងក្រង និងបោះពុម្ព
ភាគ២ លើកទីមួយ ដោយខុទ្ទកាល័យសម្តេចមហាបវរធិបតី សំរាប់
ប្រើប្រាស់ជាជំនួយស្មារតី។ ខុទ្ទកាល័យសម្តេចមហាបវរធិបតី
មិនទទួលខុសត្រូវចំពោះការដកស្រង់ និងប្រើប្រាស់ឡើងវិញនូវផ្នែក
ឬទាំងស្រុង ដោយសរសេរ ដោយមធ្យោបាយអេឡិចត្រូនិច
និង/ឬដោយការថតចម្លង ផ្ទុយពីគំនិតនិងគោលបំណង
ដែលបានជំរាបជូននេះឡើយ។

បោះពុម្ពលើកទីមួយ មិថុនា ២០២៥
ច្បាប់ជា PDF មាននៅក្នុងជំពូក ការបោះពុម្ពផ្សាយ
នៃវែបសាយត៍ kh.cnv.org.kh និង kh.cmf-cnv.org.kh

បុព្វកថា

បណ្ណាល័យអត្ថបទចម្លងប្រសាសន៍ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន "កម្ពុជាទស្សនៈថ្មី" ត្រូវបានរៀបចំឡើងតាំងពីក្នុងឆ្នាំ២០១១ ដោយក្រុមការងារទី ៤ នៃខុទ្ទកាល័យសម្តេចតេជោ និងបន្តរក្សានិងធ្វើបច្ចុប្បន្នភាពដោយក្រុមការងារ ទី៤នៃខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ក្រុមការងារទី ៤ មានភារកិច្ចចម្លង ចងក្រង ធ្វើគន្ថនិទ្ទេសឌីជីថល ផ្សព្វផ្សាយតាមវែបសាយត៍និងបណ្តាញសង្គម ព្រមទាំងរក្សាទុកក្នុងទិន្នន័យដ្ឋាន គ្រប់គ្រងនិងអាចហៅរកមកប្រើប្រាស់ នូវអត្ថបទចម្លងប្រសាសន៍មានចំនួន ១៩៦៦ ចំណងជើង គិតពីឆ្នាំ២០០២ មកដល់ឆ្នាំ២០២៣ និងប្រធានបទខ្លះដល់មេសា២០២៤។

សៀវភៅ "**រំលឹកប្រសាសន៍ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន៖ ភាគ១**" ត្រូវបានបោះពុម្ពពីរលើក មានចំនួនសរុប ៤ ០៣០ក្បាល ដោយបានលើកយកខ្លឹមសារចំនួន ៤៤៨ចំណុច ដកស្រង់ពីសង្កថានិងឬសេចក្តីអធិប្បាយបន្ថែមលើសុន្ទរកថាជាង ៥០០ចំណងជើង នៅតាមស្ថាប័នចំនួន២៥។

សៀវភៅ "**រំលឹកប្រសាសន៍ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន៖ ភាគ២**" ត្រូវបានបោះពុម្ព ដោយបានបញ្ចូលខ្លឹមសារដកស្រង់ ១ ២៤៨ ពីអត្ថបទ ៧៥០ ចំណងជើងថ្មីទៀតដែលបានចម្លង កត់ត្រានិងរក្សាទុក ក្នុងរវាងឆ្នាំ២០១៧ ដល់ឆ្នាំ ២០២៣ និងសំរាប់ប្រធានបទខ្លះដល់ខែមេសា ឆ្នាំ២០២៤ ពី៣១ក្រសួង/ស្ថាប័ន។

តាមកំណត់ត្រានេះ សៀវភៅ "**រំលឹកប្រសាសន៍ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន**" ភាគ១និងភាគ២ បានដកស្រង់ខ្លឹមសារសរុបចំនួន ១ ៦៩៦ ពីសង្កថា/សេចក្តីអធិប្បាយចំនួន ១ ៩៦៦ នៅចន្លោះឆ្នាំ២០០២ ដល់២០២៤។

ក្រៅពីបោះពុម្ពនិងចែកផ្សាយជាសៀវភៅ ច្បាប់ឌីជីថលនៃសៀវភៅទាំងពីរ មានផ្សាយផ្ទាល់តាមវែបសាយត៍ kh.cnv.org.kh (កម្ពុជាទស្សនៈថ្មី) និងតំណភ្ជាប់ពី kh.cmf-cnv.org.kh (កម្ពុជាឆ្ពោះទៅមុខ)។

ទិន្នន័យដ្ឋាន "កម្ពុជាទស្សនៈថ្មី" បានកត់ត្រាថានៅឆ្នាំ២០១៧ "សន្តិភាព" ជា

ពាក្យភ្ជាប់ ដែលត្រូវបានប្រើច្រើនដាងគេ(៣៧/១០៦) ដោយ "ការងារ" និង "អប់រំ" ឈរនៅលំដាប់បន្ទាប់។ នៅឆ្នាំ២០១៨, "ការងារ" ជាពាក្យភ្ជាប់ដែលបានឈរទីមួយ(៥២/១៦០) ដោយ "អប់រំ" និង "សុខាភិបាល" បានឈរនៅលំដាប់បន្ទាប់។ នៅឆ្នាំ២០១៩ "សេដ្ឋកិច្ច" បានឡើងទៅឈរលើគេ(២៩/៩១) ដោយ "អប់រំ" និង "ការងារ" នៅតែក្សាបានលំដាប់បន្ទាប់។

នៅឆ្នាំ២០២០, ២០២១ និង២០២២ ដោយប្រឈមនឹងវិបត្តិនិងវិបាកជំងឺកូវីដ ១៩ ពាក្យភ្ជាប់ "សុខាភិបាល" បានឈរលើគេរៀងឆ្នាំ(២២/៦៦, ៦៤/១២១ និង ៥២/១០៧) ដោយ "ការងារ" "អប់រំ" និង "សាធារណការ" ជាវិស័យសំខាន់បន្ទាប់។ នៅឆ្នាំ២០២២ ពាក្យភ្ជាប់ "ការងារ" មានរហូតដល់ ៨០/៩៩ ចំណងជើង ហើយ "បោះឆ្នោត" និង "អប់រំ" ឈរនៅលំដាប់បន្ទប់។

ផ្អែកតាមរបាប់ទិន្នន័យនេះ អាចអះអាងបានថា ក្នុងរវាងឆ្នាំ២០១៧ ដល់ឆ្នាំ ២០២៣ ពាក្យភ្ជាប់ឬពាក្យមេ ដែលសម្តេចតេជោ បានប្រើក្នុងការថ្លែងសង្កថានិង ការអធិប្បាយដែលបានកត់ត្រាមាន "សន្តិភាព" "ការងារ" "អប់រំ" "សុខាភិបាល" "សាធារណការ" និង "បោះឆ្នោត" ញឹកញាប់ ធៀបទៅរវាងឆ្នាំ២០០៩ និង២០១៦ ដែលសម្តេចតេជោបានប្រើពាក្យភ្ជាប់ ដែលបង្ហាញពីសារៈសំខាន់នៃវិស័យអប់រំ ការយកចិត្តទុកដាក់ដល់ជីវភាពគ្រូបង្រៀន ការប្រើប្រាស់បណ្តាញសង្គម តួនាទីគណបក្សប្រជាជន តួនាទីរួមចំណែកនៃពុទ្ធសាសនា សារប្រយោជន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការប្រែប្រួលអាកាសធាតុ និងភាពតានតឹងស្តីពីសមុទ្រចិនខាងត្បូង។

"កម្ពុជាទស្សនៈថ្មី" ជាប្រភពឯកសារជាសារវន្តសំរាប់ក្រុមការងារដកស្រង់ខ្លឹមសារតាមស្ថាប័ន/អន្តរស្ថាប័ន រៀបរៀងជា "រំលឹកប្រសាសន៍" ជូនសម្តេចតេជោ ស្របទៅតាមកម្មវិធីការងារនិងប្រធានបទពាក់ព័ន្ធ ជាក់ស្តែង សៀវភៅរំលឹកប្រសាសន៍ ភាគ១ និងភាគ២ ជាការប្រមូលផ្តុំផលិតផលដែលបានរៀបរាប់ជូនមកខាងលើ៕

មាតិកា

	បុព្វកថា	i
	មាតិកា	iii
១	កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	១
២	កាកបាទក្រហមកម្ពុជា	២៩
៣	ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	៤១
៤	ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	៧៥
៥	ការពារជាតិ	១១៧
៦	កិច្ចការនារី	១៣៥
៧	គ្រោះមហន្តរាយ	១៤៧
៨	ទេសចរណ៍	១៥៩
៩	ធនធានទឹក និងឧតុនិយម	១៧៧
១០	ធម្មការ និងសាសនា	១៨៧
១១	បរិស្ថាន	២០៥
១២	ប្រៃសណីយ៍ និងទូរគមនាគមន៍	២១៥
១៣	ផែនការ	២២៣
១៤	ពាណិជ្ជកម្ម	២២៩
១៥	ព័ត៌មាន	២៤៩
១៦	មហាផ្ទៃ	២៦៥
១៧	កិច្ចការមីន និងគ្រាប់មិនទាន់ផ្ទុះ	៣១៣
១៨	មុខងារសាធារណៈ	៣២៧
១៩	យុត្តិធម៌	៣៥១
២០	រាជបណ្ឌិត្យសភា	៣៧៩
២១	រៀបចំដែនដី នគរូបនីយ៍កម្ម និងសំណង់	៣៩៧
២២	រ៉ែ និងថាមពល	៤១៥
២៣	វប្បធម៌ និងវិចិត្រសិល្បៈ	៤៣៣

២៤	សង្គមកិច្ច និងយុវនីតិសម្បទា	៤៦៩
២៥	សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	៤៨៧
២៦	សាធារណការនិងដឹកជញ្ជូន	៥២៣
២៧	សុខាភិបាល	៥៧៩
២៨	អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក)	៦២៥
២៩	អប់រំ យុវជន និងកីឡា	៦៤៣
៣០	អភិវឌ្ឍន៍ជនបទ	៦៦៧
៣១	ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	៦៨៥

១. កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១	ផលិតពូជស្រូវឱ្យបានល្អ គ្មានជាតិគីមី មិនខ្លាចបាត់បង់ទីផ្សារ	៣
២	កំណត់តំបន់ដាំដុះពូជស្រូវសម្រាប់ផលិតនាំចេញ	៣
៣	បង្កើនការផលិត និងគុណភាព ដើម្បីកសិផលបានតម្លៃខ្ពស់	៣
៤	នយោបាយផលិតកម្មស្រូវបានជោគជ័យ ការនាំចេញអង្ករនៅមិនទាន់ជោគជ័យ	៤
៥	ដឹកនាំប្រទេសកសិកម្ម មើលរំលងកសិកម្ម ជាកំហុសដ៏ធ្ងន់ធ្ងរខាងយុទ្ធសាស្ត្រ	៤
៦	ត្រៀមពូជស្រូវ និងបន្លែបង្ការ ចែកប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់	៥
៧	ការក្សារាស់ដោយគោក្របីនៅសល់តែប្រមាណជា៣,៥%	៥
៨	ជំរុញផលិតកម្មកសិកម្មតាមស្តង់ដារអន្តរជាតិដើម្បីនាំចេញ	៦
៩	យន្តតូបនីយ៍កម្មកសិកម្ម ធ្វើអោយតម្លៃដើមផលិតផលកសិកម្មឡើងខ្ពស់	៦
១០	ការផ្តើលតាមទីផ្សារ រហូតកាប់ដំណាំមួយ ដាំដំណាំមួយទៀត នាំអោយខាតបង់	៦
១១	គប្បីណែនាំប្រជាពលរដ្ឋកុំលង់តាមចរន្តទីផ្សារតាមដំណាក់កាលមួយៗ	៧
១២	អង្ករសិប្បនិម្មិតជាសង្គ្រាមចិត្តសាស្ត្រ	៧
១៣	ទីផ្សារអង្ករសរីរាង្គជាចំណុចខ្លាំងរបស់កម្ពុជា	៨
១៤	ដាំដុះដោយប្រើជីធម្មជាតិ ដើម្បីសុខភាពប្រជាពលរដ្ឋនិងទីផ្សារ	៨
១៥	អ្នកស្ពប់កុម្មុយនីស្ត ឱ្យរាជរដ្ឋាភិបាលកំណត់តម្លៃស្រូវ ខុសពីយន្តការទីផ្សារ	៨
១៦	កម្មករកម្ពុជាមិនបានផ្តាច់ខ្លួនចេញពីកិច្ចការកសិកម្មទាំងស្រុងទេ	៩
១៧	ប្រជាជនកម្ពុជាស្មើរតែ៨0% ហូបអង្ករ/ស្រូវជង្រុក មិនមែនអង្ករ/ស្រូវគីឡូ	៩
១៨	ការនាំផ្លែស្វាយទៅចិននឹងផ្តល់ការងារនិងប្រាក់ចំណូលកាន់តែច្រើន	១0
១៩	កម្ពុជានឹងមិនមានអសន្តិសុខស្បៀងទេ	១0
២0	កម្ពុជាចូលរួមផ្គត់ផ្គង់ស្បៀងនៅក្នុងតំបន់និងពិភពលោក	១១
២១	ជំរុញការដាំដុះនិងចិញ្ចឹមសត្វ ដើម្បីការហូបចុកនិងនាំចេញ	១១
២២	ផលិតពូជស្រូវតម្រូវទៅតាមតម្រូវការនិងស្ថានភាពដី	១២
២៣	ផលិតពូជស្រូវមានគុណភាពចែកជូនប្រជាពលរដ្ឋ	១២
២៤	រដ្ឋ វិស័យឯកជន និងប្រជាពលរដ្ឋ រួមគ្នាសិក្សានិងកំណត់តំបន់ផលិតពូជស្រូវ	១២
២៥	យុទ្ធសាស្ត្រប្តូរពូជស្រូវ ចាប់ផ្តើមនាទសវត្សឆ្នាំ ១៩៨0	១៣
២៦	ច្រូតស្រូវក្នុងទឹក ប្រសើរជាងគ្មានស្រូវច្រូត រដ្ឋត្រូវអន្តរាគមន៍លើប្រឡាយមេ	១៣
២៧	កាត់បន្ថយការធ្វើស្រូវធ្ងន់ បង្កើនការធ្វើស្រូវស្រាលមានទិន្នផលខ្ពស់	១៤

២៨	អភិវឌ្ឍដំណាំស្រូវបែបស៊ីជំពៅ គឺប្រើពូជថ្មី បង្កើនរដូវ និងមានប្រព័ន្ធស្រោចស្រព	១៤
២៩	អាចចែករំលែកពូជស្រូវរយៈខ្លីទៅក្រៅប្រទេស តែត្រូវជោគជ័យខាងក្នុងសិន	១៥
៣០	ជ្រើសរើសអ្នកជំនាញកសិកម្ម អោយទៅកាន់ឃុំ/ស្រុក/ខេត្តកំណើត	១៥
៣១	មន្ត្រីកសិកម្មត្រូវកោះប្រជុំនិងសហការគ្នាដើម្បីប្រមូលនិងចែករំលែកធាតុចូល	១៦
៣២	ជំរុញដាំដុះ ដាក់ទុនកែច្នៃនិងវេចខ្ចប់ ដើម្បីក្លាយជាអ្នកផ្គត់ផ្គង់ស្វាយចន្ទីពិតប្រាកដ	១៦
៣៣	ជំរុញគំនិតផ្តើមរៀបចំសមាគមកសិករ	១៧
៣៤	ឆ្នាំ២០២២ កសិកម្មចយចំណែកក្នុង ផសស តែនាំអង្ករចេញទៅ ៧៣ប្រទេស	១៧
៣៥	ចំនួនមនុស្សកើនឡើងតម្រូវឱ្យមានការកាប់ព្រៃ/ឈើរានដីធ្វើស្រែចំការនិងសង់ផ្ទះ	១៨
៣៦	សិក្សាការដាំដើមឈើ បណ្តុះកូនឈើ ចិញ្ចឹមពូជគោ ដើម្បីផ្គត់ផ្គង់ពូជដល់ប្រជាពលរដ្ឋ	១៨
៣៧	តម្រូវការដីធ្លីបង្កបង្កើនផលនាំដល់ការបាត់ព្រៃ តែចេញជាស្រែចំការនិងដំណាំ	១៩
៣៨	មិនអាចជៀសពីការប្រើប្រាស់អុសនិងធ្យូង មុនពេលមានឧស្ម័នប្រើប្រាស់ទូទៅ	១៩
៣៩	រកវិធី/ប្រភពដែលផ្តល់កំដៅក្រៅពីឧស/ធ្យូងថ្ម សម្រាប់ឡនិងគុក	២០
៤០	ក្រៅពីត្រីក្នុងបឹង/ទន្លេ មានការធ្វើវារីវប្បកម្ម	២០
៤១	ឈប់ប្រើគោក្របី ឈប់ចិញ្ចឹមយកសាច់និងប្រើប្រាស់ដឹកជញ្ជូន ជាមហន្តរាយ	២១
៤២	ទាក់ទាញវិនិយោគរួមចំណែកផលិតចំណីបម្រើការចិញ្ចឹមសត្វ	២១
៤៣	នាំសាច់សត្វចូលពីបរទេសលើសលប់ គឺសម្លាប់ការចិញ្ចឹមផ្ទៃក្នុង	២១
៤៤	រក្សាកំណើនត្រីចិញ្ចឹម២០%/ឆ្នាំថេរ អាចចូលរួមផ្គត់ផ្គង់តំបន់និងពិភពលោក	២២
៤៥	រៀបប្រតិទិនវារីវប្បកម្មដើម្បីចៀសពី "ការផ្គត់ផ្គង់មានច្រើនលើសពីតម្រូវការ"	២២
៤៦	ព្រលែងកូនត្រីនិងការដាំដើមឈើ អាចធ្វើបានរាល់ថ្ងៃនិងគ្រប់ទីកន្លែង	២៣
៤៧	ទឹកអាក់ ត្រីតិច ប្រជាជនច្រើន	២៣
៤៨	ជំនន់រដូវ ស្លឹករឹលជ្រុះ ធ្វើឱ្យបឹងបួគោកាក់ ប៉ះពាល់ដល់បរិស្ថានត្រីរស់នៅ	២៤
៤៩	បំផុសចលនាព្រលែងត្រីក្នុងបឹងបួធម្មជាតិ និងចិញ្ចឹមត្រីឆ្លើយតបតម្រូវទីផ្សារ	២៤
៥០	រៀបចំតំបន់ស្នូលអចិន្ត្រៃយ៍ដើម្បីអភិរក្សផ្សោត	២៥
៥១	ធ្វើវិសោធនកម្មច្បាប់ ប្តូរពីរឹតត្បិតទៅលើកទឹកចិត្តឱ្យចិញ្ចឹមសត្វជិតផុតពូជ	២៥
៥២	បើមានចន្លោះប្រហោង ត្រូវធ្វើវិសោធនកម្មច្បាប់អំពីការចិញ្ចឹមសត្វកម្រ	២៦
៥៣	គួរតែរៀបចំជាចលនាចិញ្ចឹមសត្វដែលជិតផុតពូជ	២៦
៥៤	ពិនិត្យច្បាប់ពាក់ព័ន្ធ ធ្វើវិសោធនកម្ម ប្តូរពីរឹតត្បិតទៅលើកទឹកចិត្តដើម្បីបង្កើនសត្វព្រៃ	២៧

១. ផលិតពូជស្រូវឱ្យបានល្អ គ្មានជាតិគីមី មិនខ្លាចបាត់បង់ទីផ្សារ

បិទសន្និបាតបូកសរុបការងារ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ២០១៦-២០១៧
និងទិសដៅការងារ ឆ្នាំ ២០១៧-២០១៨, ១០ មេសា ២០១៧

... រាជរដ្ឋាភិបាលចង់បើកទីផ្សារណាស់។ ហេតុអ្វីយើងនាំអង្ករចេញទៅអឺរ៉ុបបាន ... ដោយសារអង្ករបស់យើងជាអង្ករក្រអូបនិងអង្ករសីរាង្គ យើងនាំចេញទៅស្រួល។ ដូច្នេះហើយបានជាស្នើអោយកសិកររបស់យើង**ផលិតពូជ(ស្រូវ)អោយបានល្អ កុំឱ្យមានសារធាតុពុលកើតឡើង ដែលអាចធ្វើឱ្យយើងបាត់បង់ទីផ្សារ**។ ដូចជាតែងតែឮថាមានករណីបង្កប់សារធាតុនេះសារធាតុនោះជាមួយ។ ការបាត់បង់ទីផ្សារ គឺជាមហន្តរាយមួយទៀត។ យើងនាំអង្ករក្រអូបទៅអឺរ៉ុប ... ឯនៅតំបន់អាស៊ីយើងបានចរចានាំអង្ករកម្ពុជាទៅវៀតណាម ទៅចិន ... ។

២. កំណត់តំបន់ដាំដុះពូជស្រូវសម្រាប់ផលិតនាំចេញ

បិទសន្និបាតបូកសរុបការងារ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ២០១៦-២០១៧
និងទិសដៅការងារ ឆ្នាំ ២០១៧-២០១៨, ១០ មេសា ២០១៧

... នៅពេលខាងមុខ យើងនឹងមានតម្រូវការកាន់តែធំក្នុងការកំណត់តំបន់ដាំដុះ។ **បើមិនទាន់និយាយពីតំបន់ដាំដុះកសិផលដទៃទៀត យើងក៏គួរតែខិតខំកំណត់តំបន់ដាំដុះពូជស្រូវសម្រាប់នាំចេញ** ព្រោះកសិករក៏ដឹង ហើយអ្នកបច្ចេកទេសក៏ដឹង។ (បើមានផ្ទៃដី)១ម៉ឺនហិកតាសម្រាប់ដាំពូជស្រូវនាំចេញ សូម្បីមានតែ ៤ទៅ៥ ហិកតា ក្នុងដី ១ម៉ឺនហិកតានេះ ក៏អាចបម្លងធ្វើអោយខូចពូជដែរ ... ។

៣. បង្កើនការផលិត និងគុណភាព ដើម្បីកសិផលបានតម្លៃខ្ពស់

បិទសន្និបាតបូកសរុបការងារ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ២០១៦-២០១៧
និងទិសដៅការងារ ឆ្នាំ ២០១៧-២០១៨, ១០ មេសា ២០១៧

... យើងត្រូវឃើញថា ដំណាក់កាលផលិតរបស់កសិករបានឆ្លងផុតពីការផលិតត្រឹមតែដើម្បីទទួលទានក្នុងគ្រួសារ មកកាន់ការផលិតដើម្បីបម្រើតម្រូវការនៅក្នុងទីផ្សារក្នុងស្រុកផង និងតម្រូវការនាំចេញទៅក្រៅប្រទេសផង។ ដូច្នេះ **ដើម្បីចង់**

បានតម្លៃស្រូវខ្ពស់ កសិកររបស់យើងក៏ត្រូវប្រឹងខ្លួនឯងផលិត(ដោយរើសយក) ពូជដែលល្អ ពូជដែលមានគុណភាព ដើម្បីធានាការនាំចេញមានតម្លៃខ្ពស់ ហើយអ្នកដែលទិញនោះ ក៏ឱ្យតម្លៃខ្ពស់ ។ នេះជាការខិតខំរួម ដើម្បីការអភិវឌ្ឍកសិកម្ម របស់ប្រទេសយើង ... ៕

៤. នយោបាយផលិតកម្មស្រូវបានជោគជ័យ ការនាំចេញអង្ករនៅមិនទាន់ជោគជ័យ

សំណេះសំណាលជាមួយបងប្អូនខ្មែរនៅប្រទេសអូស្ត្រាលី និងណូវែលហ្សេឡង់, ១៦ មីនា ២០១៨

... មានគោលនយោបាយធំពីរដែលបានដាក់ចេញនិងកំពុងអនុវត្ត។ **ទី១ នយោបាយផលិតកម្មស្រូវ និងទី២ ការនាំចេញអង្ករ ... នយោបាយនេះទទួលបានជោគជ័យពាក់កណ្តាល។** ហេតុអីបានខ្ញុំនិយាយអញ្ចឹង? មុនពេលដាក់ចេញគោលនយោបាយផលិតកម្មស្រូវ និងការនាំចេញអង្ករ យើងមានសល់ស្រូវតិចតួចរហូតមានពេលខ្វះផង។ ពេលដែលយើងដាក់ចេញនិងអនុវត្តនូវយុទ្ធសាស្ត្រនេះ យើងសល់ស្រូវជាង៥ លានតោនសម្រាប់ការនាំចេញទៅបរទេស ... **ប៉ុន្តែគោលដៅនាំចេញអង្ករឲ្យបាន ១លានតោន គឺយើងនាំចេញបានត្រឹមតែពី ៥០ទៅ ៦០ ម៉ឺនតោនប៉ុននោះ** ... យ៉ាងណាក៏ដោយ យើងបានរុញប្រទេសឲ្យចេញផុតពីអស្ថេរភាពស្បៀង ទៅជាប្រទេសដែលមានសន្តិសុខស្បៀង ដោយមានស្បៀងសំរាប់ការនាំចេញ និងមានស្បៀងបម្រុងទុកក្នុងសភាពការណ៍ចាំបាច់ ... ៕

៥. ដឹកនាំប្រទេសកសិកម្ម មើលរំលងកសិកម្ម ជាកំហុសដ៏ធ្ងន់ធ្ងរខាងយុទ្ធសាស្ត្រ

សំណេះសំណាលជាមួយកម្មករ និយោជិត ស្រុកអង្គស្នួល ខេត្តកណ្តាល, ៤ កក្កដា ២០១៨

... គេក៏បានឃើញពូធ្វើសកម្មភាពទាក់ទងនឹងវិស័យកសិកម្ម។ **កម្ពុជាជាប្រទេសកសិកម្ម។ យើងមិនត្រូវមើលរំលងទេ។ វានឹងជាកំហុសដ៏ធ្ងន់ធ្ងរខាងយុទ្ធសាស្ត្រដឹកនាំ បើសិនជាប្រទេសកសិកម្ម ហើយយើងបែរជាមើលរំលងវិស័យកសិកម្ម។** យើងបានប្រឹងប្រែងដើម្បីអភិវឌ្ឍវិស័យកសិកម្ម ដែលក្មួយៗ គង់នឹងមើលឃើញរូបភាពជាច្រើនដែលបង្ហាញសកម្មភាពរបស់ពូនៅតាមមូលដ្ឋាន ទាក់

ទងនឹងការកែទម្រង់ជីធ្លី ការផ្តល់កម្មសិទ្ធិឱ្យប្រជាពលរដ្ឋ បន្ទាប់ពីរបប ប៉ុល ពត បានដកហូតកម្មសិទ្ធិប្រជាពលរដ្ឋ ... ៕

៦. ត្រៀមពូជស្រូវ និងបន្លែបង្ការ ចែកប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់

សំណេះសំណាលជាមួយកម្មករ និយោជិត ស្រុកកៀនស្វាយ ខេត្តកណ្តាល, ២៣ សីហា ២០១៨

...យើងកំពុងជួបគ្រោះជំនន់ទឹកភ្លៀងនៅឯខេត្តពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ កំពង់ស្ពឺ ... និងមួយភាគរបស់ខេត្តកណ្តាល។ ឯខេត្តប៉ៃលិន ដោយជំនន់មេគង្គរួមមានស្ទឹងត្រែង ក្រចេះ កំពង់ចាម និងខេត្តកណ្តាល ... សូមអាជ្ញាធរគ្រប់លំដាប់ថ្នាក់ បន្តចាត់វិធានការណ៍ដោះស្រាយបញ្ហាទាក់ទងនឹងសុខទុក្ខរបស់ប្រជាពលរដ្ឋដែលកំពុងលិចលង់។ **សូមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រៀមរៀបចំបញ្ចេញគ្រាប់ពូជដែលប្រជាជនត្រូវការ។ ស្រូវមានការខូចខាតមួយចំនួន។ ពួកគាត់ត្រូវធ្វើឡើងវិញ។ យើងក៏ត្រូវបញ្ចេញគ្រាប់ពូជ។ យើងក៏ត្រូវដោះស្រាយគ្រាប់ពូជបន្លែបង្ការឲ្យកសិកររនៅតំបន់ជន់លិច** ... ជានិច្ចកាលយើងមិនដែលចាយថវិកាបម្រុងទុកសម្រាប់គ្រោះមហន្តរាយទេ ... ៕

៧. ការក្ហួរាស់ដោយគោក្របីនៅសល់តែប្រមាណជា៣,៥%

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ, ១៩ កញ្ញា ២០១៨

... រាជរដ្ឋាភិបាលបានប្រឹងប្រែងបង្កើតការងារឲ្យប្រជាពលរដ្ឋធ្វើ។ **មកដល់ពេលនេះ សម្រាប់វិស័យកសិកម្ម សូម្បីតែការក្ហួរាស់ដែលប្រើគោក្របីនៅសល់តែប្រមាណ៣,៥% ប៉ុននោះ។** ឯ ៩៦,៥% ទៀត បានក្ហួរាស់ដោយគ្រឿងចក្រកសិកម្មមានត្រាក់ទ័រ ឬដោយគោយន្ត។ តើប្រាក់កាសទាំងនោះបានមកពីណា? មួយភាគធំបានពី(កូនចៅជា)កម្មករ/ការិនីធ្វើការនៅតាមបណ្តារោងចក្រ ដែលយកប្រាក់ទៅជួលគោយន្ត ជួលត្រាក់ទ័រ ដើម្បីក្ហួរាស់ ឬជួលឧបករណ៍កសិកម្មដទៃទៀតដូចជាការច្រូតកាត់ជាដើម ដើម្បីជំនួសឲ្យកម្លាំងពលកម្ម ... ៕

៨. ជំរុញផលិតកម្មកសិកម្មតាមស្តង់ដារអន្តរជាតិដើម្បីនាំចេញ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅខេត្តកំពត, ២៥ មករា ២០១៩

... ម្រេចកំពតនេះល្បីល្បាញ។ បានចូលទីផ្សារជប៉ុន។ នៅពេលដែលខ្ញុំទៅប្រជុំមេគង្គ-ជប៉ុន មានការដាក់តាំងបង្ហាញម្រេចខេត្តកំពតក្នុងទីផ្សារជប៉ុន។ **យើងនៅមានផលិតផលច្រើនសម្រាប់ការនាំចេញ គ្រាន់តែត្រូវរៀបចំឲ្យស្របទៅនឹងស្តង់ដារនិងតម្រូវការរបស់ប្រទេសនីមួយៗ ដូចជាត្រូវចុះហត្ថលេខា(កិច្ចព្រមព្រៀង)ចត្តាឡីស័កភូតគាមអនាម័យ** ... សព្វថ្ងៃនេះ យើងនាំផ្លែស្វាយទៅចិនផង ទៅកូរ៉េខាងត្បូង និងទៅបារាំង។ ប្រទេសចិនមានតំបន់ដែលផលិតផ្លែឈើបានប៉ុន្តែ ក៏មានតំបន់ខ្លះមិនអាចផលិតបាន ... ហ្វីលីពីននាំចេកចូលប្រទេសមិនតិចទេ ... ៕

៩. យន្តតូបនីយ៍កម្មកសិកម្ម ធ្វើអោយតម្លៃដើមផលិតផលកសិកម្មឡើងខ្ពស់

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល, ២០ កុម្ភៈ ២០១៩

... **កិច្ចការក្នុងវិស័យកសិកម្មឈានចូលយន្តតូបនីយ៍កម្មហើយ។ ដូច្នេះ តម្លៃដើមនៃផលិតផលកសិកម្មគឺពិតជាខ្ពស់។** កាលពីដើមយើងប្រើគោ ប្រើក្របីដើម្បីភ្ជួររាស់ យើងប្រើការច្រូតកាត់/បោក/បែន ដោយកម្លាំងពលកម្មរបស់មនុស្ស។ ឥឡូវនេះ ភ្ជួរក៏ដោយម៉ាស៊ីនរាស់ក៏ដោយម៉ាស៊ីន បន្ទាប់ទៅពេលច្រូត/បោក/បែន ក៏ប្រើម៉ាស៊ីន ... ទោះបីទឹកនៅក្បែរ ក៏លែងប្រើប្រាស់មធ្យោបាយដាស្នាចបាចទឹកចូលស្រែ ... អញ្ចឹង តម្លៃដើមក្នុងផលិតកម្មរបស់យើងគឺខ្ពស់ ... ៕

១០. ការផ្តើលតាមទីផ្សារហួសពេក កាប់ដំណាំមួយដាំដំណាំមួយទៀត នាំឱ្យខាតបង់

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល, ២០ កុម្ភៈ ២០១៩

... ពូគ្រាន់តែលើកអំពីចំណុចជាក្របខណ្ឌរួម នៃស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសដែលមិនចំណុះឲ្យវិស័យណាមួយ។ ត្រូវធ្វើពហុវិស័យ។ ក្នុងវិស័យ

កសិកម្ម មិនសំដៅតែទៅលើស្រូវ(មួយមុខ) ដូច ប៉ុល ពត ថា មានស្រូវមានអ្វីៗទាំងអស់នោះទេ។ យើងមានគោលដៅរបស់យើង។ **បម្រើឲ្យសេចក្តីត្រូវការនៅក្នុងប្រទេសផង និងជាពិសេសតាមចន្លោះនៃសេដ្ឋកិច្ចទីផ្សារ។ យ៉ាងណាក្តី ការដែលនាំគ្នាផ្តើលទៅតាមសេដ្ឋកិច្ចទីផ្សារហួសហេតុពេកក៏វាមិននាំមកនូវការលូតលាស់ខាងសេដ្ឋកិច្ចដែរ។** ឧទាហរណ៍ ឃើញថាកៅស៊ូឡើងថ្លៃ នាំគ្នាដាំកៅស៊ូ។ ដល់ទៅកៅស៊ូចុះថ្លៃ ស្វាយចន្ទីឡើងថ្លៃ កាប់កៅស៊ូ ដាំស្វាយចន្ទី ... ធ្វើបែបនេះមិនបានផលទេ ... ៕

១១. គប្បីណែនាំប្រជាពលរដ្ឋកុំលង់តាមចរន្តទីផ្សារតាមដំណាក់កាលមួយៗ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល, ២០ កុម្ភៈ ២០១៩

... **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គប្បីចង្អុលណែនាំប្រជាពលរដ្ឋរបស់យើងកុំឲ្យលង់ទៅតាមចរន្តទីផ្សារតាមដំណាក់កាលមួយៗ**។ នៅប្រទេសថៃពេលដែលដំរកៅស៊ូចុះថោក ដំណាំកៅស៊ូរាប់ម៉ឺនរាប់សែនហិកតា មិនត្រូវបានចៀរដំរទេ។ តែគេក៏មិនកាប់ដើមកៅស៊ូចោលដែរ។ បើសិនចៀរដំរមិនរួចថ្លៃដើមសម្រាប់ប្រាក់កម្មករទេ ក៏ប៉ុន្តែគេក៏មិនកាប់ដើមកៅស៊ូនេះចេញ ជំនួសដោយដំណាំផ្សេងដែរ។ គេទុកដើមកៅស៊ូ។ នៅពេលកៅស៊ូឡើងថ្លៃ គេទទួលផលពីកៅស៊ូហ្នឹងត្រឡប់មកវិញ។ កសិករខ្មែរយើងគួរតែសិក្សា ប៉ុន្តែក៏ត្រូវមានការគាំទ្រខាងបច្ចេកទេស ... **កុំឲ្យលុះដោយចរន្តទីផ្សារមួយដងមួយកាល** ... ៕

១២. អង្គរសិប្បនិម្មិតជាសង្គ្រាមចិត្តសាស្ត្រ

ពិធីចែកសញ្ញាបត្រជូនិស្សិត នៃសាកលវិទ្យាល័យ ពុទ្ធិសាស្ត្រ, ៦ មិថុនា ២០១៩

... នៅលើពិភពលោកនេះ បើទោះបីជាមានការប្រែប្រួលភូមិសាស្ត្រនយោបាយ ពីរបបមួយទៅរបបមួយ ពីរដ្ឋាភិបាលមួយទៅកាន់រដ្ឋាភិបាលមួយក៏ដោយ រឿងស៊ីចុកនេះនៅតែបន្តមិនឈប់ទេ។ អត់មាននរណាចេះធ្វើអង្គរសិប្បនិម្មិតទេ។ ពេលខ្លះ គេថាមានអង្គរសិប្បនិម្មិតយកទៅលក់នៅកន្លែងនេះ/នោះ។ ខ្ញុំចេះតែចោទសួរថា **បើគ្រាន់តែផលិតអង្គរធម្មតាក៏វាថោកណាស់ទៅហើយ ទំរាំ**

ទៅផលិតអង្ករសិប្បនិម្មិត ដែលត្រូវឆ្លងកាត់សង្វាក់ឧស្សាហកម្ម សិប្បកម្មទៀត ... **យកទៅលក់ ធ្វើម៉េចនឹងចំណេញ? នេះជាសង្គ្រាមចិត្តសាស្ត្រមួយ** ...។

១៣. ទីផ្សារអង្ករសីវាំងជាចំណុចខ្លាំងរបស់កម្ពុជា

ពិធីចែកសញ្ញាបត្រដល់និស្សិត នៃសាកលវិទ្យាល័យ ពុទ្ធិសាស្ត្រ, ៦ មិថុនា ២០១៩

... ស្រូវអង្ករបស់យើងប្រកួតប្រជែងក្នុងក្របខណ្ឌអនុតំបន់មេគង្គ។ អនុតំបន់មេគង្គផលិតដូចគ្នា។ មីយ៉ាន់ម៉ាផលិតអង្ករ។ ឡាវផលិតអង្ករ។ ថៃផលិតអង្ករ។ វៀតណាមផលិតអង្ករ។ កម្ពុជាផលិតអង្ករ ... ប្រកួតប្រជែងគ្នាឯងត្រង់ហ្នឹង។ ក្រៅពីនោះ មានឥណ្ឌាក៏ជាអ្នកនាំចេញអង្ករធំដែរ។ សម្រាប់យើង **ចំណុចខ្លាំងរបស់កម្ពុជានៅត្រង់ថា យើងមានទីផ្សារដែលទទួលទិញ ដោយសារតែប្រទេសមួយចំនួនត្រូវការអង្ករបស់យើងព្រោះអង្ករយើងមិនប្រើជាតិគីមី។ ប្រទេសទាំងនោះត្រូវការការផលិតដោយមិនប្រើ(ជីនិងថ្នាំ)គីមី។ អង្ករសីវាំង** ...។

១៤. ដាំដុះដោយប្រើជីធម្មជាតិ ដើម្បីសុខភាពប្រជាពលរដ្ឋនិងទីផ្សារ

ពិធីចែកសញ្ញាបត្រដល់និស្សិត នៃសាកលវិទ្យាល័យ ពុទ្ធិសាស្ត្រ, ៦ មិថុនា ២០១៩

... ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ត្រូវខិតខំជំរុញប្រជាពលរដ្ឋឱ្យអនុវត្តការផលិតដោយប្រើជីធម្មជាតិ ជំនួសដោយការប្រើជីគីមី ដែលវាមិនមែនគ្រាន់តែជាបញ្ហាទីផ្សារខាងក្រៅទេ ក៏ប៉ុន្តែពាក់ព័ន្ធនឹងប្រជាពលរដ្ឋរបស់យើងតែម្តង។ ក្នុងហ្នឹងការដាំដុះបន្លែបង្គារ ក៏សូមប្រជាពលរដ្ឋប្រើប្រាស់ជីធម្មជាតិ កាត់បន្ថយការនាំចូលផលិតផលប្រើជាតិគីមី ដែលវានាំទៅដល់ការបំផ្លាញសុខភាពប្រជាពលរដ្ឋរបស់យើង។** យើងមានលទ្ធភាពអាចធ្វើទៅបាន ព្រោះដីរបស់យើងនៅមានសេសសល់ច្រើនណាស់ ហើយប្រជាពលរដ្ឋរបស់យើងក៏មានលទ្ធភាពដើម្បីបង្កើន(ទិន្នផល)ដោយប្រើប្រាស់ដីធម្មជាតិ ...។

១៥. អ្នកស្អប់កុម្មុយនីស្ត ឱ្យរាជរដ្ឋាភិបាលកំណត់តម្លៃស្រូវ ខុសពីយន្តការទីផ្សារ

ពិធីចែកសញ្ញាបត្រដល់និស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២៦ ធ្នូ ២០១៩

... យ៉ាងណាក៏ដោយអាចមានការគាំពារមួយ។ តែខ្ញុំព្រះករុណាខ្ញុំមិនយល់នៅត្រង់ថាអ្នកខ្លះស្អប់កុម្មុយនីស្តណាស់ ប៉ុន្តែអំពាវនាវឬក៏ជំរុញឱ្យខ្ញុំព្រះករុណាខ្ញុំធ្វើកុម្មុយនីស្ត។ គឺឱ្យយើងកំណត់ថ្លៃស្រូវ។ ខ្លួនឯងដេរគេថាកុម្មុយនីស្ត ប៉ុន្តែខ្លួនជាអ្នកមកចាប់បង្ខំគេឱ្យគេអនុវត្តសេដ្ឋកិច្ចបែបកុម្មុយនីស្ត ... **សម័យមុននោះមានសេដ្ឋកិច្ចទីផ្សារនិងសេដ្ឋកិច្ចផែនការ។ ពួកសេដ្ឋកិច្ចផែនការ គឺអ្នកកំណត់ថ្លៃ ឬរដ្ឋកំណត់ថ្លៃតែម្តង។ សូម្បីតែប្រព័ន្ធគ្រប់គ្រងមិនទាំងច្បាស់ខ្លួនឯងផង មកខ្ចានគេឱ្យគេធ្វើនូវកិច្ចការដែលខ្លួនឯងកំពុងស្អប់។ ចង់ឱ្យរដ្ឋកំណត់ថ្លៃស្រូវ។ បើធ្វើយ៉ាងដូច្នេះ វាជាការអនុវត្តតាមប្រព័ន្ធសេដ្ឋកិច្ចផែនការ ដែលអតីតប្រទេសសង្គមនិយមធ្លាប់បានធ្វើ ... យន្តការទីផ្សារមិនតម្រូវឱ្យរដ្ឋធ្វើការកំណត់ថ្លៃទេ** ...។

១៦. កម្មករកម្ពុជាមិនបានផ្តាច់ខ្លួនចេញពីកិច្ចការកសិកម្មទាំងស្រុងទេ

សំណេះសំណាលជាមួយនឹងមន្ត្រីរាជការ និងក្រុមការងារបច្ចេកទេសស្តាបនា
ហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុង ក្នុងខេត្តព្រះសីហនុ, ១ មិថុនា ២០២០

... អំពាវនាវឱ្យប្រជាពលរដ្ឋជំរុញវិស័យកសិកម្មដើម្បីជានាស្បៀងអាហារ។ តើអ្វីទៅជាចំណុចខ្លាំងរបស់កម្ពុជា? អ្នកឯងអាចមិនទិញសំលៀកបំពាក់ ធ្វើឱ្យកម្មការបាត់បង់ការងារ ក៏ប៉ុន្តែសូមអ្នកយល់ថា **កម្មករកម្ពុជាមិនបានផ្តាច់ខ្លួនចេញពីកសិកម្មនៅឡើយទេ។ ឪពុកម្តាយគេប្រកបវិស័យកសិកម្មនៅឡើយ។ កម្ពុជាមានបទពិសោធន៍ពីវិបត្តិសេដ្ឋកិច្ចពិភពលោកឆ្នាំ២០០៨។ លើការជាក់ស្តែង ដែលកម្មករ១៣ម៉ឺននាក់បាត់បង់ការងារ មួយភាគធំកំពុងរួមចំណែកជាមួយគ្រួសារឡើងវិញ លើវិស័យកសិកម្ម** ...។

១៧. ប្រជាជនកម្ពុជាស្ទើរតែ៨0% ហូបអង្ករ/ស្រូវជង្រុក មិនមែនអង្ករ/ស្រូវគីឡូ

សំណេះសំណាលជាមួយនឹងមន្ត្រីរាជការ និងក្រុមការងារបច្ចេកទេសស្តាបនា
ហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុង ក្នុងខេត្តព្រះសីហនុ, ១ មិថុនា ២០២០

... អ្នកឯងមិនទិញខោអាវ ប៉ុន្តែអ្នកមិនអាចមិនទិញស្បៀងដើម្បីហូបទេ ... ខ្ញុំបានប្រកាសហាមឃាត់ការនាំចេញអង្ករសនិងស្រូវមួយរយៈ។ បន្ទាប់ទៅ ហាមឃាត់ការនាំចេញត្រី។ ទុកត្រីផ្គត់ផ្គង់ក្នុងស្រុក។ ក្រោយការពិនិត្យ យើងឃើញ

ថា **ប្រជាជនកម្ពុជាស្ទើរតែ៨០% ស៊ីស្រូវជែង្រុក មិនមែនស៊ីស្រូវគីឡូទេ។ ឯអ្នកស៊ីស្រូវគីឡូស៊ីអង្ករគីឡូ កន្លងទៅផ្តើលទិញអង្ករ** ... ឥឡូវតម្លៃទំនិញតាមទីផ្សារខ្លះថយចុះ ... កន្លែងខ្លះក៏ឡើងថ្លៃ កន្លែងខ្លះក៏តម្លៃថេរ ... យើងសម្រុកជាំដុះ ដើម្បីផ្គត់ផ្គង់ស្បៀងអាហារក្នុងស្រុក ធ្វើកុំឱ្យអត់អង្ករច្រកធ្នាំង ...។

១៨. ការនាំផ្លែស្វាយទៅចិននឹងផ្តល់ការងារនិងប្រាក់ចំណូលកាន់តែច្រើន

សារលើហ្វេសប៊ុក អំពីការបើកទីផ្សារនាំស្វាយស្រស់ កម្ពុជា ទៅកាន់ប្រទេសចិន, ៩ មិថុនា ២០២០

... ខ្ញុំសូមអបអរសាទរ និងកោតសរសើរចំពោះការខិតខំរបស់ក្រសួងកសិកម្ម ក្នុងការបើកទីផ្សារស្វាយស្រស់កម្ពុជា ទៅកាន់ប្រទេសចិន។ ថ្ងៃទី៩ មិថុនា ២០២០ នេះ កម្ពុជានិងចិនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្លូវការ "លក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ការនាំចេញផ្លែស្វាយស្រស់ ពីកម្ពុជាទៅប្រទេសចិន" ... **ការនាំផ្លែស្វាយទៅចិននឹងផ្តល់ការងារនិងប្រាក់ចំណូលកាន់តែច្រើនសំរាប់ប្រជាពលរដ្ឋ ពិសេសក្នុងដំណាក់កាលដែលប្រទេសកំពុងប្រឈមនឹងជំងឺកូវីដ១៩ ... ការពង្រឹងបច្ចេកទេសជាំដុះឲ្យមានគុណភាពខ្ពស់ បង្កើតរោងចក្រវេចខ្ចប់ឲ្យបានត្រឹមត្រូវ អាចអោយមានលទ្ធភាពទទួលបានផលប្រយោជន៍កាន់តែច្រើន** ...។

១៩. កម្ពុជានឹងមិនមានអសន្តិសុខស្បៀងទេ

ពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ «កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺ កូវីដ ១៩ », ២៤ មិថុនា ២០២០

... យើងកំពុងតែជំរុញវិស័យកសិកម្ម ដែលឆ្នាំនេះ ក្នុងស្ថានភាព កូវីដ១៩ ការនាំចេញអង្ករមានការកើនឡើងគួរកត់សម្គាល់។ មុននេះយើងនាំចេញបានប្រមាណ ៤០ទៅ ៥០ ម៉ឺនតោនក្នុងមួយឆ្នាំ។ ឆ្នាំនេះអាចនឹងឈានទៅដល់ ៨០ម៉ឺនតោន ឬលើសពីនេះ ... បើទោះបីកម្ពុជាយ៉ាងម៉េចក៏ដោយ **កម្ពុជាមានចំណុចខ្លាំងមួយត្រង់ថា រៀងរាល់ឆ្នាំមានអតិរេកស្រូវប្រមាណជិត ៦លានតោនឯណោះ។ ខ្លះគេថា កម្ពុជាងាយរងគ្រោះពីអសន្តិសុខស្បៀង។ យើងគ្រាន់តែបញ្ជាក់ត្រឡប់ទៅវិញថា យើងមានផ្ទៃដីជាំដុះរាប់លានហិកតា ... កម្ពុជាគ្មានអសន្តិសុខស្បៀងទេ** ...។

២០. កម្ពុជាចូលរួមផ្គត់ផ្គង់ស្បៀងនៅក្នុងតំបន់និងពិភពលោក

អញ្ជើញទស្សនកិច្ចមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ពូជត្រី បាទី និង ជួបសំណេះសំណាលជាមួយនឹងកសិកររនៅខេត្តព្រៃវែង, ១៤ កក្កដា ២០២០

... អត្ថបទនៃសារព័ត៌មានប្រទេសខ្លះបានលើកជាកង្វល់ថា សង្វាក់ផ្គត់ផ្គង់ស្បៀងនៅក្នុងតំបន់អាស៊ីនឹងមានការពិបាកដោយសារភាពតឹងរ៉ឹងរបស់ថៃ កម្ពុជា ភូមា និងឥណ្ឌា ហើយបានចង្អុលទៅរុស្សីពីស្រូវស្រូវសាលីទៀត។ សូមបញ្ជាក់ឡើងវិញថា **កម្ពុជានឹងចូលរួមក្នុងសង្វាក់ផ្គត់ផ្គង់ក្នុងតំបន់ ព្រោះកម្ពុជាមានសល់ស្រូវជិត ៦លានតោន គិតជាអង្ករជិត ៤លានតោនក្នុងមួយឆ្នាំ។ ដូចនេះកម្ពុជាមិនត្រឹមតែដោះស្រាយបញ្ហាស្បៀងខ្លួនឯងបានទេ ប៉ុន្តែមានសមត្ថភាពនាំចេញចូលរួមផ្គត់ផ្គង់ស្បៀង ដែលសូមឱ្យមិត្តភក្តិបរទេស** ... បានដឹង។ ថ្ងៃនេះ ខ្ញុំចង់បញ្ជាក់ទៅអ្នកសារព័ត៌មានទាំងនោះថា **កម្ពុជានឹងចូលរួមក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ស្បៀងក្នុងតំបន់ និងក្នុងពិភពលោកផង** ... ។

២១. ជំរុញការជាំដុះនិងចិញ្ចឹមសត្វ ដើម្បីការហូបចុកនិងនាំចេញ

អញ្ជើញទស្សនកិច្ចមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ពូជត្រី បាទី និង ជួបសំណេះសំណាលជាមួយនឹងកសិកររនៅខេត្តព្រៃវែង, ១៤ កក្កដា ២០២០

... កូវីដ១៩ មិនអាចសម្លាប់ប្រជាជនកម្ពុជា ដោយជាប់បាយស្លាប់ទេ ព្រោះជីពចរសេដ្ឋកិច្ចរបស់យើងមិនមែនពឹងតែលើវិស័យសេវា ដូចជាទេសចរណ៍ ដឹកជញ្ជូនផ្លូវអាកាស ឬផ្លូវទឹកផ្លូវគោកទេ ហើយក៏មិនពឹងពាក់តែលើវិស័យឧស្សាហកម្មមួយប្រភេទណាដែរ។ ជីពចរសេដ្ឋកិច្ចដែលចិញ្ចឹមប្រជាជនឱ្យរស់ គឺស្ថិតនៅត្រង់ធ្វើម៉េចឲ្យមានអង្ករច្រកធ្នាំង ឱ្យមានត្រីទទួលទាន ... **ទោះបីកូវីដ ១៩រីករាលដាលអូសបន្លាយពេលក្តី យើងនៅតែប្រកាន់យកវិធានការកសិកម្ម ... ជំរុញការជាំដុះ ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ... ដើម្បីប្រជាជនមានហូបចុក និងឈានទៅដល់ការកែច្នៃនាំចេញ** ... ។

២២. ផលិតពូជស្រូវតម្រូវទៅតាមតម្រូវការនិងស្ថានភាពដី

អញ្ជើញចែកពូជស្រូវជូនប្រជាជននៅខេត្តបាត់ដំបង, ២៤ តុលា ២០២២

... ពេលមានបញ្ហា យើងក៏ឆក់កណ្តៀតពូជពីកន្លែងនេះកន្លែងនោះមកចែកឲ្យអ្នកនៅបាត់ដំបង។ យើងគួរតែរកវិធីថាផលិតពូជនៅបាត់ដំបង ដែលអាចសមស្របនឹងស្ថានភាពដីរបស់ខេត្តបាត់ដំបងផង ខេត្តបន្ទាយមានជ័យផង ខេត្តពោធិ៍សាត់ផង។ បើសិនជាសិក្សាទៅឃើញថា (ខេត្តទាំងនេះ)ប្រើពូជប្រហាក់ប្រហែលគ្នាទេ យើងអាចផលិតពូជនៅបាត់ដំបង និងស្តុកនៅបាត់ដំបង។ ពេលមានសភាពការណ៍ យើងបញ្ចេញពូជពីបាត់ដំបង ... រីឯខាងព្រៃវែង ខាងស្វាយរៀង និងកំពង់ចាមនៅភាគខាងកើត មានតម្រូវការពូជមិនដូចគ្នាទេ ... **ត្រូវសិក្សាថាប្រជាពលរដ្ឋ និងដីកន្លែងណា ប្រើពូជអី ... ដើម្បីបែងចែកតំបន់ដាំដុះ ដាក់ពូជឲ្យវាត្រូវ** ... ៕

២៣. ផលិតពូជស្រូវមានគុណភាពចែកជូនប្រជាពលរដ្ឋ

អញ្ជើញចែកពូជស្រូវជូនប្រជាជននៅខេត្តបាត់ដំបង, ២៤ តុលា ២០២២

...ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយផ្នែកពាក់ព័ន្ធ ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលទទួលបន្ទុកត្រៀមស្បៀងបំរុង ថ្មីនេះបានសិក្សាលើប្រធានបទ តើធ្វើម៉េចដើម្បីអាចដោះស្រាយពូជជូនប្រជាពលរដ្ឋបានប្រសិទ្ធភាព ... បើយើងមានពូជល្អ ប្រជាពលរដ្ឋដែលធ្វើពូជមិនល្អ នឹងយកស្រូវរបស់គាត់មកដូរពូជពីយើង។ **បើសិនជាថាសល់ពូជ(ស្រូវ) វាប្រសើរជាងអត់ពូជ(ស្រូវ) ... ខ្ញុំមិនឲ្យផ្ទាំកិបាលទទួលងាយថា "អត់ពូជ" ទេ ដែលសំដៅថាផ្ទាំកិបាលមួយគ្មានស្រូវពូជ ឬស៊ីអស់ទាំងស្រូវពូជនោះទេ។ តែឥឡូវជាផ្ទាំកិបាលមានស្រូវពូជគ្រប់គ្រាន់ដើម្បីចែកជូនប្រជាពលរដ្ឋ ក៏ប៉ុន្តែគុណភាពនៅជាបញ្ហា** ... ៕

២៤. រដ្ឋ វិស័យឯកជន និងប្រជាពលរដ្ឋ រួមគ្នាសិក្សានិងកំណត់តំបន់ផលិតពូជស្រូវ

អញ្ជើញចែកពូជស្រូវជូនប្រជាជននៅខេត្តបាត់ដំបង, ២៤ តុលា ២០២២

... នៅពេលខាងមុខនេះ ភារកិច្ចខាងផ្នែកកសិកម្ម គឺមិនគ្រាន់តែដំណើរការផលិតធម្មតាទេ ក៏ប៉ុន្តែធ្វើយ៉ាងម៉េចឲ្យប្រជាជនមានប្រាក់ចំណេញ។ សូម្បីតែបច្ចេក ទេសនៃការព្រោះស្រូវពូជ កន្លែងខ្លះត្រូវការត្រឹម ៣០គីឡូ/ហិកតាឬ ៥០ គីឡូ/ហិកតា តែអ្នកខ្វះបច្ចេកទេស ប្រើពូជអស់ ១០០គីឡូ/ហិកតា ... ការប្រើដីក៏ដូចគ្នា។ ប្រើកម្រិតណាទទួលបានផល។ ប្រើជ្រុលពេក វាក៏បង្កើតនូវបញ្ហាដែរ។ អញ្ចឹង ទុកលទ្ធភាពឲ្យផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សិក្សា **លើកសំណើឡើងបង្កើតគំនិតផ្តួចផ្តើមរួមគ្នារវាងរដ្ឋនិងវិស័យឯកជន រួមជាមួយប្រជាពលរដ្ឋ កំណត់ជាតំបន់ផលិតពូជ ដែលអាចធានាពេលមានអាសន្នអន់ក្រអញ្ចឹង** ... ៕

២៥. យុទ្ធសាស្ត្រប្តូរពូជស្រូវ ចាប់ផ្តើមនាទសវត្សឆ្នាំ ១៩៨០

បិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ឆ្នាំ ២០២២ និងលើកទិសដៅឆ្នាំ ២០២៣, ២៤ មីនា ២០២៣

... សូមអបអរសាទរការស្រាវជ្រាវបច្ចេកទេសជាបន្តបន្ទាប់ ដែលផ្សារភ្ជាប់ជាមួយនឹងការស្រាវជ្រាវនិងការដាំដុះ។ **ជាប្រវត្តិ ចាប់ផ្តើមនៅក្នុងទសវត្សរ៍៨០ បើខ្ញុំមិនច្រឡំទេ គឺមានយុទ្ធនាការប្តូរពូជស្រូវ**។ ពេលដែលខ្ញុំទៅកាន់កន្លែងនេះ កន្លែងនោះ និយាយពីបញ្ហាពូជស្រូវនេះ ឪពុករបស់ខ្ញុំលើកឡើងថា "អញចិញ្ចឹមក្បាលហ្អែងរស់ អញប្រើតែពូជពីដើមទេ"។ យើង(បានផលិតនិងប្រឹងប្រែងផ្លាស់ប្តូរ)ពូជនេះរហូតមកដល់ឆ្នាំ២០០៤ ... ជាមួយ ឯកឧត្តម លឹម គានហោ យើងធ្វើដំណើរទៅភ្នំក្រវ៉ាញនិងកន្លែងខ្លះទៀតនៅខេត្តពោធិ៍សាត់ ។ **ប្រជាពលរដ្ឋនៅប្រើប្រាស់ពូជ(ពីជូនតា)នៅឡើយ ដែល(ការដាំដុះរហូតច្រូតកាត់ត្រូវការរយៈពេលយូរ) បានធ្វើឱ្យទឹកជំនន់ចុងរដូវ លិចលង់ស្រូវ។ ខ្ញុំបាននិយាយគ្រានោះថា "សូមកុំធ្វើពូជនាងពួន សូមធ្វើពូជនាងសង្ហា"** ... ៕

២៦. ច្រូតស្រូវក្នុងទឹក ប្រសើរជាងគ្មានស្រូវច្រូត រដ្ឋត្រូវអន្តរាគមន៍លើប្រឡាយមេ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ, ៧ វិច្ឆិកា ២០១៨

... ខ្ញុំប្រកាសនៅកន្លែងហ្នឹងតែម្តងថា **រដ្ឋត្រូវអន្តរាគមន៍លើប្រឡាយមេ។ សេដ្ឋកិច្ចផ្សារមិនអាចបោះបង់ចោលការជួយចំពោះកសិកររនោះទេ។ ពេលនោះហើយដែលចាប់ផ្តើមមានពាក្យស្លោកថា "ច្រូតស្រូវក្នុងទឹក ប្រសើរជាងគ្មានស្រូវច្រូត"។ ហ្នឹងសុទ្ធតែជាទ្រឹស្តី ហ៊ុន សែន។** គ្មានទ្រឹស្តីចេញពីត្រង់ណា(ផ្សេង)ទេ។ កសិករយើងពីជំនាន់នោះ មិនចូលចិត្តធ្វើស្រូវស្រាលទេ ធ្វើតែស្រូវធ្ងន់ (ហើយក៏) ចំកន្លែងដែលអត់ទឹក។ ដល់គាត់ធ្វើស្រូវស្រាល គឺវាត្រូវប្រឈមនឹងការច្រូតស្រូវក្នុងទឹក។ បានខ្ញុំឆ្លើយជាមួយគាត់ថា ច្រូតស្រូវក្នុងទឹក ប្រសើរជាងអត់ស្រូវច្រូត។ ដោយហេតុនេះហើយបានជាមានខ្លឹមសារចម្រៀងមួយចំនួន ច្រូតស្រូវក្នុងទឹក ប្រសើរជាងអត់ស្រូវច្រូត។ រឿងចំរៀងទាក់ទងជាមួយនឹង សំណាងព្រៃស្វាវាសនាពត់សរ គឺទាក់ទងហ្នឹង(ហេតុការណ៍នេះ) ...៕

២៧. កាត់បន្ថយការធ្វើស្រូវធ្ងន់ បង្កើនការធ្វើស្រូវស្រាលមានទិន្នផលខ្ពស់

បិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ឆ្នាំ២០២២ និង លើកទិសដៅឆ្នាំ ២០២៣, ២៤ មីនា ២០២៣

... **យើងចង់កាត់បន្ថយការធ្វើស្រូវធ្ងន់ ហើយបង្កើនការធ្វើស្រូវស្រាលដែលផ្តល់ផលច្រើន។ (ការផលិត)ពូជថ្មី មានរយៈពេលខ្លីនេះ ជាសមិទ្ធផលថ្មីមួយដែលខ្ញុំគិតថា កម្ពុជាបានបោះមួយជំហានទៅមុខក្នុងការជ្រើសរើសពូជខ្លួនឯង បង្កាត់ពូជខ្លួនឯង ហើយជាប់ចំណាត់ថ្នាក់ទៀតផង** ... ខ្ញុំបាននិយាយជាបន្តបន្ទាប់ពីកិច្ចការនេះ ក្នុងយុទ្ធសាស្ត្រផ្នែរពីការអភិវឌ្ឍ(ដំណាំស្រូវ)តាមបែបបើកទូលាយទៅកាន់ការអភិវឌ្ឍតាមបែបស៊ីជម្រៅ។ ការពិត នេះគឺជាដំណើរការនៃការអនុវត្តយុទ្ធសាស្ត្រនោះហើយ គ្រាន់តែយើងមិនបានរំលឹកវាតែប៉ុននោះ ...៕

២៨. អភិវឌ្ឍដំណាំស្រូវបែបស៊ីជំរៅ គឺប្រើពូជថ្មី បង្កើនរដូវ និងមានប្រព័ន្ធស្រោចស្រព

បិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ឆ្នាំ២០២២ និង លើកទិសដៅឆ្នាំ ២០២៣, ២៤ មីនា ២០២៣

... អ្វីជាការអភិវឌ្ឍតាមបែបបើកទូលាយ ហើយអ្វីទៅដែលជាការអភិវឌ្ឍតាមបែបស៊ីជម្រៅ? ជាប្រពៃណីខ្មែរយើង កាលពីដើម បើគ្រួសារមានគ្នា ៥នាក់ ត្រូវ

ការមានផ្ទៃដី ២ហិកតា និងបើឡើងដល់ ១០នាក់ ត្រូវតែមានដី ៤ហិកតា។ បើសិនជាទុកឱ្យធ្វើបែបនេះរហូតទៅ ច្បាស់ណាស់ថា ព្រៃឈើនៅកម្ពុជានឹងត្រូវកាប់យកដីដើម្បីបង្កបង្កើនផល(ដំណាំស្រូវ)។ ដូច្នេះ **ជម្រើសដែលល្អជាងគេគឺផ្នែរពីការអភិវឌ្ឍតាមបែបបើកទូលាយ ទៅកាន់ការអភិវឌ្ឍបែបស៊ីជម្រៅ ដោយរៀបចំប្រព័ន្ធស្រោចស្រប់ បង្កើនពីការធ្វើមួយរដូវទៅកាន់ ២រដូវឬ៣រដូវ និង(ប្រើពូជថ្មី)ប្រពលវប្បកម្មដើម្បីទទួលបានទិន្នផលខ្ពស់។ ផ្ទៃដី ១ហិកតាដែលដែលធ្លាប់ពីមុនចិញ្ចឹមបាន ៥នាក់ ត្រូវខិតខំឱ្យអាចចិញ្ចឹមបាន ១៥ឬ២០នាក់** ...៕

២៩. អាចចែករំលែកពូជស្រូវរយៈខ្លីទៅក្រៅប្រទេស តែត្រូវជោគជ័យខាងក្នុងសិន

បិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ឆ្នាំ២០២២ និង លើកទិសដៅឆ្នាំ ២០២៣, ២៤ មីនា ២០២៣

... យើងធ្លាប់ខ្វះអង្ករ។ ពេលនេះ យើងមិនខ្វះអង្ករទេ ឬនិយាយរួមថាមិនអាចខ្វះស្បៀង ... ឆ្នាំ២០០២ ហើយ យើងនៅខ្វះ(ស្បៀង)។ ឥណ្ឌាបានជួយយើង ២ម៉ឺនតោន។ ពេលនេះ យើងអត់ត្រូវការ(ជំនួយស្បៀង)ពីក្រៅទេ។ យើងបានសហការជាមួយគូបា ... **យើងអាចនាំពូជស្រូវរយៈពេលខ្លីនេះទៅគូបា។ ឥឡូវថាមានកូឌីរួមួយទៀត។ យើងចង់ចែករំលែកទៅឱ្យមិត្តភក្តិ ក៏ប៉ុន្តែយើងត្រូវតែធ្វើឱ្យជោគជ័យខាងក្នុងសិន។ រឿងនេះ ទាក់ទងនឹងកត្តាអាកាសធាតុផងដែរ។ ការស្រាវជ្រាវពូជនានាត្រូវតែជើរស្របនឹងការប្រែប្រួលអាកាសធាតុ**។ តើវាធន់នឹងការឡើងកំដៅឬទេ។ ត្រូវស្រាវជ្រាវឱ្យបានហ្មត់ចត់។ សូមកាតសរសើរវិទ្យាស្ថាន CARDI ក៏ដូចជាផ្នែកស្រាវជ្រាវដទៃទៀតដែលផ្តល់ឱ្យយើងមានធនធាន(ពូជស្រូវ) ...៕

៣០. ជ្រើសរើសអ្នកជំនាញកសិកម្ម អោយទៅកាន់ឃុំ/ស្រុក/ខេត្តកំណើត

បិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ឆ្នាំ២០២២ និង លើកទិសដៅឆ្នាំ ២០២៣, ២៤ មីនា ២០២៣

... **យើងត្រូវជ្រើសរើស(អ្នកជំនាញ)ឱ្យបានត្រឹមត្រូវ ហើយបើជានិស្សិតកសិកម្ម អ្នកជំនាញកសិកម្ម អាចថា(អោយ)ទៅឃុំណា ទៅខេត្តណា ដែលជាខេត្តរបស់ពួកគាត់ស្រាប់** ... ជាបទពិសោធន៍ក្នុងការជ្រើសរើស(ធនធាន)មនុស្ស

ទៅកាន់មូលដ្ឋាន បើយកទៅតំបន់ជាភូមិសាស្ត្ររបស់ពួកគាត់គឺជាការងាយស្រួលជាង ... កុំថាឡើយមន្ត្រីកសិកម្មដែលនៅខាងក្រោម សូម្បីតែអភិបាលរង ខេត្ត អភិបាលរងស្រុក បើយើងយកពីកន្លែងដទៃទៅ ថ្ងៃសៅរ៍ថ្ងៃអាទិត្យ មិនមានមនុស្សប្រចាំការទេ ...៕

៣១. មន្ត្រីកសិកម្មត្រូវកោះប្រជុំនិងសហការគ្នាដើម្បីប្រមូលនិងចែករំលែកធាតុចូល

បិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ឆ្នាំ២០២២ និង លើកទិសដៅឆ្នាំ ២០២៣, ២៤ មីនា ២០២៣

... បើទុកឱ្យមន្ត្រីកសិកម្មម្នាក់ៗ ធ្វើសកម្មភាពតាមឃុំមួយៗ ដាច់ដោយឡែកពីគ្នា ដោយមិនមានកិច្ចសហការនៃមន្ត្រីតាមឃុំនានានិងខេត្ត វាស្មើនឹង "ដំដែល" អត់មានលើសអត់មានខ្វះ។ អញ្ចឹងទេ **ត្រូវឆ្លៀតយកធាតុចូល។ ឧទាហរណ៍ថា មួយស្រុកហ្នឹងមាន១២ ឃុំ។ អញ្ចឹងឧស្សាហ៍កោះប្រជុំ ហើយសហការគ្នា។ ឃុំមួយកើតហេតុ ឧទាហរណ៍ថា ទាក់ទិនជាមួយនឹងជំងឺស្រូវឬក៏ជំងឺសត្វ ប្រមូលមន្ត្រីកសិកម្មដែលនៅឃុំផ្សេងមកជួយគ្នា។ អភិបាលស្រុក អភិបាលខេត្ត ឧស្សាហ៍ជួបអ្នកទាំងហ្នឹង។** និយាយដល់កសិកម្ម មិនមែនបានសេចក្តីថា ចាំខ្សែបណ្តោយទៅទេ។ យើងកំពុងផ្ទេរអំណាចទៅឱ្យមូលដ្ឋានហើយ។ ត្រូវចេះគ្រប់គ្រង ...៕

៣២. ជំរុញជាំដុះ ដាក់ទុនកែច្នៃនិងវេចខ្ចប់ ដើម្បីក្លាយជាអ្នកផ្គត់ផ្គង់ស្វាយចន្ទីពិតប្រាកដ

បិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ឆ្នាំ២០២២ និង លើកទិសដៅឆ្នាំ ២០២៣, ២៤ មីនា ២០២៣

... មានតម្រូវការស្វាយចន្ទីនៅលើពិភពលោក។ វៀតណាមនិងឥណ្ឌា ជាប្រទេសដែលចែកចាយគ្រាប់ស្វាយចន្ទីច្រើនជាងគេ។ ប៉ុន្តែប្រទេសទាំងពីរនេះនាំវត្ថុជាតុដើមពីប្រទេសក្រៅមកកែច្នៃក្នុងប្រទេសខ្លួន។ **ឯកម្ពុជាមានវត្ថុជាតុដើមដែលកសិកររយើងដាំ។ ត្រូវជំរុញសមត្ថភាពកែច្នៃដោយពង្រឹងការស្រាវជ្រាវ ការវេចខ្ចប់ឲ្យបានត្រឹមត្រូវ។ អ្វីដែលជាកង្វល់គឺទុន។ ខ្ញុំសង្ឃឹមថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា នឹងធ្វើកិច្ចការនេះ ... យើងត្រូវទម្លាក់ទុន ...**

ដើម្បីជានាថាគោលនយោបាយស្វាយចន្ទីដែលបានអនុម័តកន្លងទៅនេះ (នឹងសំរេចបាន)ជោគជ័យ ហើយក្លាយទៅជាអ្នកផ្គត់ផ្គង់ពិតប្រាកដ ...៕

៣៣. ជំរុញគំនិតផ្តើមរៀបចំសមាគមកសិករ

ពិធីចែកសញ្ញាបត្រគ្រឹះស្ថានឧត្តមសិក្សាកសិកម្ម ៣ គឺភូមិន្ទកសិកម្ម, កសិកម្មព្រៃកលាប, កសិកម្មកំពង់ចាម, ១៥ ឧសភា ២០២៣

... ក្រសួង(កសិកម្ម រុក្ខាប្រមាញ់និងនេសាទ) ត្រូវបន្តយកចិត្តទុកដាក់ស្រាវជ្រាវនិងជំរុញបច្ចេកទេស ផ្សារភ្ជាប់ជាមួយកសិករ តាមរយៈការពង្រាយអ្នកបច្ចេកទេសកសិកម្មទៅជាប់ជាមួយនឹងកសិករ។ ក្រៅពីចំនួនអ្នកបច្ចេកទេសដែលនឹងត្រូវបញ្ជូនទៅគ្រប់ឃុំ យើងក៏នៅមានអ្នកបច្ចេកទេសដែលត្រូវទៅបង្រៀនកសិករអំពីបច្ចេកទេសថ្មីៗលើការដាំដុះ ការប្រើពូជក៏ដូចជាការចិញ្ចឹមសត្វជាដើម។ (យើងមាន)យន្តការក្នុងក្រសួងកសិកម្ម ... **ប៉ុន្តែក៏អាចបន្ថែមបែបបទអន្តរាគមន៍ និងបង្កើត/ជំរុញគំនិតផ្តួចផ្តើមដែរ ឧទាហរណ៍ ដូចជាសមាគមកសិករជាដើម ... យើងមិនហៅសហករណ៍ទេ។ យើងហៅសមាគមកសិករក៏បាន ...៕**

៣៤. ឆ្នាំ២០២២ កសិកម្មចុយចំណែកក្នុង ផសស តែនាំអង្ករចេញទៅ ៧៣ប្រទេស

សំណេះសំណាលជាមួយកម្មករ និយោជិត នៅរោងចក្រចំនួន៨១ ក្នុងតំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់ គ្រុប ភ្នំពេញ (ថ្ងៃទី២), ២៧ ឧសភា ២០២៣

... និយាយពីផលិតផលសរុបក្នុងស្រុក មានចំណែកអ្វីខ្លះដែលយើងត្រូវគួរកត់សំគាល់។ **នៅឆ្នាំ២០២២ កសិកម្មមានចំណែក២១,៣% ប្រៀបទៅឆ្នាំ២០០០ ដែលមានចំណែកដល់៣៧%។** ពេលនេះ ឧស្សាហកម្មបានកើនដល់៣៨% ក្នុងពេលដែលឆ្នាំ២០០០ យើងមានត្រឹមតែ២២%។ ឯសេវាកម្មយើងមាន២៥% និងឆ្នាំ២០០០ មានដល់៣៦%។ ហេតុអីកសិកម្មធ្លាក់ពី៣៧% មកនៅ២១,៣%? ខ្ញុំសូមទាញការចាប់អារម្មណ៍ថា ពេលដែលកសិកម្មមាន(ចំណែក)៣៧% យើងនៅមានអង្ករមិនគ្រប់ហូបចុក។ ដល់ឆ្នាំ២០០២ ហើយ យើងនៅខ្វះអង្ករ ... **ដែល (កសិកម្មមានចំណែកក្នុង ផសស)តែ ២១,៣% យើងនៅសល់ស្រូវជាង ៦លានតោន ឬជាង ៤លានតោនអង្ករ នាំចេញទៅ ៧៣ប្រទេស** ...៕

៣៥. ចំនួនមនុស្សកើនឡើងតម្រូវឱ្យមានការកាប់ព្រៃ/ឈើរានដីធ្វើស្រែចំការនិងសង់ផ្ទះ

បើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុង ខ្សែទី៣ (ផ្លូវជាតិលេខ៤ ដល់១),
១៤ មករា ២០១៩

... មានពេលណាមួយត្រូវដោះស្រាយជាមួយគ្នា។ (ពួកប្រឆាំង)ដេរ(រដ្ឋាភិបាល) រឿងបាត់ព្រៃឈើ ក្នុងពេលដែលពួកខ្លួនទៅធ្វើចំការពេញ(ណាពេញណី)។ ហ្នឹងមួយទៅ។ មួយទៀត ដេររឿងបាត់ព្រៃឈើ ក្នុងពេលដែលផ្ទះពួកខ្លួនធ្វើជញ្ជាំងសុទ្ធតែឈើ (និងគ្រឿងសង្ហារឹម)ខាងក្នុង(ផ្ទះ)សុទ្ធតែឈើ។ **អញ្ចឹងទេ** ថ្ងៃណាមួយ អោយតែមុខសញ្ញាពួកប្រឆាំង ខ្ញុំឱ្យដើររុះផ្ទះទាំងអស់យកឈើ ត្បិតអ្នកឯងថា(ធ្វើឱ្យ)បាត់ឈើ។ ចុះឈើដែលអ្នកឯងយកមកធ្វើផ្ទះហ្នឹងបានពីណា ... **ចំនួនមនុស្សកើនឡើង ធ្វើឱ្យមានការកាប់ព្រៃដើម្បីរានដីធ្វើស្រែធ្វើចំការ ចិញ្ចឹមជីវិតតែមួយទៀតកាប់ឈើយកមកធ្វើសំណង់ធ្វើផ្ទះ**។ ផ្ទះរបស់ពួកប្រឆាំងធ្វើសុទ្ធតែពីឈើប្រណីត តាំងពី បេង នាងនួន ធ្នង់ ... ប្រើអោយពេញតែផ្ទះ រួចមកដេរឯងថាគ្រប់គ្រងប្រទេសធ្វើអោយបាត់ឈើ ...។

៣៦. សិក្សាដាំដើមឈើ បណ្តុះកូនឈើ ចិញ្ចឹមពូជគោ ដើម្បីផ្តត់ផ្គង់ពូជដល់ប្រជាពលរដ្ឋ

ពិធីដាំកូនឈើនៅឧទ្យានរាជបណ្ឌិតសភាកម្ពុជា តេជោសែន ឫស្សីត្រឹប,
១៨ ឧសភា ២០១៨

... បណ្ឌិតសភាចារ្យ រស់ ចន្ត្រាបុត្រ ជាអ្នកស្រាវជ្រាវម្នាក់ក្នុងចំណោមអ្នកស្រាវជ្រាវអំពីប្រវត្តិសាស្ត្រ ប៉ុន្តែយើងត្រូវដាក់លំដាប់អាទិភាពនៃការសិក្សា ... ឧទាហរណ៍ មកទីនេះសិក្សាអំពីការដាំដើមឈើ បណ្តុះកូនឈើ ដែលក្រសួងកសិកម្មនិងក្រសួងបរិស្ថានត្រូវចូលរួមក្នុងដំណើរការនេះ។ ទាក់ទងនឹងការចិញ្ចឹមសត្វ រាប់ទាំងការអភិរក្សពូជសត្វកម្រ ក៏ត្រូវរៀបចំគោលដៅ ឧទាហរណ៍ ការចិញ្ចឹមសត្វគោយកទឹកដោះ និងដំហានបន្តឈានទៅចិញ្ចឹមគោយកសាច់ ដើម្បីចែកចាយ(ពូជ)ទៅដល់ប្រជាពលរដ្ឋ ... **កន្លែង(ឧទ្យានរាជបណ្ឌិតសភាកម្ពុជា តេជោសែន ឫស្សីត្រឹប)នេះ ជាមូលដ្ឋាននៃការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់នូវចំណេះដឹងចំណេះធ្វើជូនប្រជាពលរដ្ឋ ហើយអាចឈានទៅជួយផ្តត់ផ្គង់ពូជឲ្យពួកគាត់** ... ។

៣៧. តម្រូវការដីធ្លីបង្កបង្កើនផលនាំដល់ការបាត់ព្រៃ តែចេញជាស្រែចំការនិងដំណាំ

ទិវាមច្ឆជាតិ អាងទឹកត្រពាំងថ្ម ភូមិត្រពាំងថ្ម ឃុំប៉ោយចារ ខេត្តបន្ទាយមានជ័យ,
១ កក្កដា ២០២២

... សួរថា ព្រៃឈើបាត់ទៅណា? **បើកុំមានប្រជាជនកើនឡើង ព្រៃឈើក៏មិនមានបាត់ទៅណាទេ។ វាបាត់ព្រៃ ប៉ុន្តែវានៅដី។ ហេតុអ្វីបានកាប់ព្រៃ? គឺដោយសារតែមានតម្រូវការដើម្បីបង្កបង្កើនផលហ្នឹងហើយ** ដែលធ្វើឱ្យបាត់បង់ព្រៃឈើ ... រដ្ឋាភិបាលបានកាត់ដីពីគម្របព្រៃឈើចែកជូនប្រជាជនមិនតិចទេ។ តាមខ្ញុំនៅចាំ ក្នុងឆ្នាំ១៩៧៩ ប្រជាជនបង្កបង្កើនផលលើផ្ទៃដីក្នុងរង្វង់ ១លាន ៦សែន ទៅ ១លាន ៨សែនហិកតាប៉ុននោះ។ ឥឡូវ ផ្ទៃដីបង្កបង្កើនផលទាំងស្រែទាំងចំការ មានរហូតដល់ជាង ៤លានហិកតា ... **វាបាត់ព្រៃឈើ ប៉ុន្តែវាដុះមក(វិញនូវ)ផលដំណាំរបស់ប្រជាពលរដ្ឋយើងជាដែលទេ** ...។

៣៨. មិនអាចជៀសពីការប្រើប្រាស់អុសនិងធ្យូង មុនពេលមានឧស្ម័នប្រើប្រាស់ទូទៅ

វេទិកាថ្នាក់ជាតិលើកទី ២ ស្តីពី «ការការពារ និងអភិរក្សធនធានធម្មជាតិ»,
២២ សីហា ២០១៧

... អំពីការកាប់ឈើនេះ យើងយល់បញ្ហាមួយចំនួន។ ដែលថាជាមុខរបរដើមរបស់ប្រជាពលរដ្ឋ ក៏មួយផ្នែកហើយ ប៉ុន្តែមួយផ្នែកទៀត យើងត្រូវយល់អោយបានថា តើអ្នកទាំងអស់គ្នានៅទីនេះ រាប់ទាំងអង្គការក្រៅរដ្ឋាភិបាល ដែលដេរប្រទេច និង(ដាក់)បណ្តាសារាជរដ្ឋាភិបាល **ធ្វើការចម្អិនអាហារដោយអ្វី? ច្បាស់ជាចម្អិនអាហារដោយប្រើអុស និងធ្យូងនោះឯង ... ចំណុចនេះមួយ មិនមែនត្រូវដោះស្រាយមួយឆ្នាំ ពីរឆ្នាំ ឬដប់ឆ្នាំទេ ត្រូវដោះស្រាយរហូតដល់ពេលដែលកម្ពុជាមានឧស្ម័ន សម្រាប់ប្រជាជនប្រើប្រាស់គ្រប់រូប។** សូម្បីតែមានអ្នកប្រើប្រាស់ gas ចម្អិនអាហារក្តី ក៏នៅសល់ប្រជាពលរដ្ឋមួយចំនួនដែលប្រើអុសសម្រាប់អាំងសាច់ដែរ ...។

៣៩. រកវិធី/ប្រភពដែលផ្តល់កំដៅសម្រាប់ឡនិងគុក

វេទិកាថ្នាក់ជាតិលើកទី ២ ស្តីពី «ការការពារ និងអភិរក្សធនធានធម្មជាតិ», ២២ សីហា ២០១៧

... ឈើមិនមែនជាបញ្ហាតូចតាចទេ។ និយាយពីឈើមួយម៉ាត់ ត្រូវត្រៀមស្មារតីយូរអង្វែង ត្រូវដុំរុញល្បឿននៃការសាងសង់បង្ហូរឧស្ម័នមកកន្លែងដែលប្រជាជនត្រូវការប្រើប្រាស់។ ម្យ៉ាងទៀត ការប្រើប្រាស់ធ្យូងថ្មជំនួសអុស ដើម្បីរម្ងាស់ស្តរគ្នាតក៏ជាបញ្ហាដែរ។ **យើងរកវិធីប្រើប្រាស់អ្វីផ្សេង ដែលផ្តល់កំដៅ។ ឡថ្នាំ (ជក់) ក៏សុទ្ធតែប្រើប្រាស់អុស។ ឡឥដ្ឋ ឡក្បឿងនេះ បើសិនជាបណ្តោយអោយផលិតនៅហ្នឹង ឈើនឹងមានការប្រឈម** ... យើងត្រូវធ្វើការជាមួយគ្នា ត្បិតនៅក្រោមដំបូលតែមួយជាមួយគ្នា និងជិះទូកជាមួយគ្នា ... នេះជាធាតុចូលមួយសម្រាប់ការជជែក ...៕

៤០. ក្រៅពីត្រីក្នុងបឹង/ទន្លេ មានការធ្វើវារីវប្បកម្ម

សំណេះសំណាលជាមួយកម្មករ និយោជិត ស្រុកអង្គស្នួល ខេត្តកណ្តាល, ៤ កក្កដា ២០១៨

... **មិនគ្រាន់តែពឹងពាក់ទៅលើត្រីក្នុងបឹង ឬទន្លេនោះទេ សព្វថ្ងៃយើងបានឈានដល់ដំណាក់កាលក្សាស់កូនត្រីរាប់រយលានក្បាលក្នុងមួយឆ្នាំៗ។ យើងបានក្សាស់ជាបង្គងសម្រាប់ប្រជាពលរដ្ឋចិញ្ចឹម។** ពីដំហានមួយទៅកាន់ដំហានមួយ យើងបានធ្វើកិច្ចការច្រើនក្នុងវិស័យកសិកម្ម តែនៅមិនទាន់គ្រប់គ្រាន់តាមតម្រូវការទេ សូម្បីតែប្រព័ន្ធស្រោចស្រប់ក៏មិនទាន់គ្រប់គ្រាន់ដែរ ... យ៉ាងណាក្តី អាចនិយាយបានថា យើងទទួលជោគជ័យមួយដំហានធំលើការដោះស្រាយស្បៀង ដែលពីមុន(កម្ពុជា)ជាប្រទេសខ្វះស្បៀង ឥឡូវក្លាយជាប្រទេសមានស្បៀងទទួលទានគ្រប់គ្រាន់ និងមានស្រូវជាង ៥លានតោនស្រូវនាំចេញទៅក្រៅប្រទេស ...៕

៤១. ឈប់ប្រើគោក្របី ឈប់ចិញ្ចឹមយកសាច់និងប្រើប្រាស់ដឹកជញ្ជូន ជាមហន្តរាយ

ពិធីបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៨-១៩ និងទិសដៅការងារឆ្នាំ ២០១៩-២០២០, ១៤ មីនា ២០១៩

... បច្ចុប្បន្ន កសិកររបស់យើងប្រើប្រាស់គោក្របីតិចតួចណាស់។ ពួកគាត់ចិញ្ចឹមគោសំរាប់ការប្រើប្រាស់សាច់ត្រឡប់ទៅវិញទេ។ មិនជាខុសអ្វីទេ។ ក៏ប៉ុន្តែយើងត្រូវឃើញចំណុចត្រង់នេះ។ **ប្រសិនបើត្រឹមតែផ្ទេរពីការប្រើប្រាស់គោក្របីក្នុងការភ្ជួរាស់ ទៅប្រើប្រាស់គ្រឿងយន្ត ប៉ុន្តែនៅរក្សាការចិញ្ចឹមគោ/ក្របីដើម្បីផ្គត់ផ្គង់ទីផ្សារ ក៏វាមិនជាអាក្រក់នោះទេ។ ប៉ុន្តែ អ្វីដែលគួរឲ្យបារម្ភ គឺពេលដែលឈប់ប្រើគោ ពួកគាត់ឈប់ចិញ្ចឹមទោះជាយកសាច់ ឬដឹកជញ្ជូនជាដើម ហ្នឹង យើងត្រូវមើលឃើញថាជាមហន្តរាយមួយ** ...៕

៤២. ទាក់ទាញវិនិយោគរួមចំណែកផលិតចំណីបម្រើការចិញ្ចឹមសត្វ

ពិធីបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៨-១៩ និងទិសដៅការងារឆ្នាំ ២០១៩-២០២០, ១៤ មីនា ២០១៩

... **អំពីការចិញ្ចឹមសត្វ វិធីដែលល្អគឺទាក់ទាញអ្នកវិនិយោគ ...រួមចំណែកផលិតចំណីសម្រាប់ការចិញ្ចឹមសត្វក្នុងប្រទេសរបស់យើង** ... មិនមែនកម្ពុជាគ្មានសេដ្ឋីពាន់លាននិងសេដ្ឋីរយលាននោះទេ។ អ្នកដែលមានប្រាក់ពី ១លានដុល្លារឡើងលើ មានច្រើន។ ខ្ញុំមិនមែនចង់សំដៅថាសាច់ប្រាក់ទេ។ យើងពិនិត្យមើល ផ្ទះមួយកន្លែងនៅទីក្រុងភ្នំពេញតម្លៃលើសពី ១លានបាត់ទៅហើយ ... ពីដើមរកតែស្បែកជើងពាក់មិនបាន។ ឥឡូវជិះទាំងឡានទៀត ហើយនិយាយតាមវីដេអូហ្វេសប៊ុកថា កាន់តែក្រទៅៗ ...៕

៤៣. នាំសាច់សត្វចូលពីបរទេសលើសលប់ គឺសម្លាប់ការចិញ្ចឹមផ្ទៃក្នុង

អញ្ជើញទស្សនកិច្ចមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ពូជត្រី បាទី និង ជួបសំណេះសំណាលជាមួយនឹងកសិករនៅខេត្តព្រៃវែង, ១៤ កក្កដា ២០២០

... និយាយពីតម្រូវការសាច់ យើងត្រូវការជិត ២៩ម៉ឺនតោនក្នុងមួយឆ្នាំ។ យើងទើបនឹងផ្គត់ផ្គង់ខ្លួនឯងបាន ២៣៩ ០០០ តោន ស្មើនឹង ៨២% តែប៉ុនោះ។ ដូច្នេះ យើងត្រូវជំរុញការចិញ្ចឹមសត្វជាបន្តទៀត។ **ក្រុមហ៊ុនមួយបានបញ្ជូនសំណើមក ... សុំនាំចូលជ្រូករស់ពីថៃ ១លានក្បាលមក ដែលអាចផ្គត់ផ្គង់ក្នុងប្រទេសកម្ពុជា និងអាចនាំចេញទៅវៀតណាម។ ខ្ញុំចារទៅឱ្យអ្នកបច្ចេកទេសសិក្សា ប៉ុន្តែគំនិតរបស់ខ្ញុំ គឺកុំនាំចូលពីគេ ហើយសម្លាប់ការចិញ្ចឹមសត្វក្នុងប្រទេសរបស់ខ្លួន។ ខ្ញុំមិនយល់ស្រប(វិធី)ហ្នឹងទេ។** ទីចុងបំផុត ការងារធ្វើបានទៅប្រទេសថៃ ឬប្រទេសវៀតណាម។ បើត្រូវការនាំចូល យើងនាំចូលតែចំណុចដែលខ្វះ។ បើថាខ្វះ១៨% យើងចិញ្ចឹមឱ្យគ្រប់ មិនបាច់នាំចូលពីគេទេ ...។

៤៤. រក្សាកំណើនត្រីចិញ្ចឹម២០%/ឆ្នាំវេរ អាចចូលរួមផ្គត់ផ្គង់តំបន់និងពិភពលោក

អញ្ជើញទស្សនកិច្ចមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ពូជត្រី បាទី និង ជួបសំណេះសំណាលជាមួយនឹងកសិករនៅខេត្តព្រៃវែង, ១៤ កក្កដា ២០២០

... នេះជាពេលដែលអ្នកចិញ្ចឹមត្រីត្រូវគន់គូរមើល ... នៅឆ្នាំ២០០៩ យើងចិញ្ចឹម(ត្រី)បានតែ ៥ម៉ឺនតោនទេ។ ដល់ឆ្នាំ២០១៩ កន្លងទៅ យើង(ចិញ្ចឹមត្រី)បាន ៣០៧ ៤០៨តោន។ ភ្ញាស់ពូជត្រីបាន ២២២ លានក្បាល តែឆ្នាំ ២០០៩ (ភ្ញាស់)បានតែ ៦៩ លានក្បាលទេ។ អញ្ចឹង ជាមធ្យម ៥ឆ្នាំចុងក្រោយនេះ មានកំណើន ២០%ក្នុងមួយឆ្នាំ។ **បើយើងរក្សាកំណើន២០% ក្នុងមួយឆ្នាំវេរ ឬឡើងខ្ពស់ជាងហ្នឹង យើងមិនត្រឹមតែមានសមត្ថភាពផ្គត់ផ្គង់ត្រី សម្រាប់ ប្រជាពលរដ្ឋយើងទេ តែមានសមត្ថភាពចូលរួមក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ក្នុងតំបន់និងពិភពលោក** ... ។

៤៥. រៀបប្រតិទិនវារីវប្បកម្មដើម្បីចៀសពី "ការផ្គត់ផ្គង់មានច្រើនលើសពីតម្រូវការ"

អញ្ជើញទស្សនកិច្ចមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ពូជត្រី បាទី និងជួប សំណេះសំណាលជាមួយនឹងកសិករនៅខេត្តព្រៃវែង, ១៤ កក្កដា ២០២០

... នេះជាឱកាសសំរាប់កសិកដែលចិញ្ចឹមត្រីផ្គត់ផ្គង់ត្រីលើទីផ្សារ។ **បើយើងមិនផ្លាស់ប្តូរស្ថានភាពដូវ ហើយរៀបចំប្រតិទិននៃការចិញ្ចឹម ដើម្បីឱ្យវាស៊ីសង្វាក់**

គ្នា ដើម្បីកុំឱ្យវាជាប់គ្នាផ្លួនៗ ទេ អាចធ្វើឱ្យតម្លៃត្រីធ្លាក់ចុះ។ ពេលធ្លាក់ខ្យល់ពីជើងត្រឹប ត្រី(ក្នុងលំហរធម្មជាតិ)ក៏មកដល់ ត្រីក្នុងស្រះក៏មកដល់ដែរ ដូចនេះវាធ្លាក់ថ្លៃហើយ។ ហ្នឹងគឺការផ្គត់ផ្គង់មានច្រើនលើសតម្រូវការ។ ការផ្គត់ផ្គង់ត្រីសម្បូរពីទន្លេមេគង្គ ទន្លេបាសាក់ ទន្លេសាប ការផ្គត់ផ្គង់ពីក្នុងស្រះក៏សម្បូរទៀត (វានាំឱ្យមានហេតុការណ៍នេះ) ... គ្រាន់តែផ្តល់ជាអនុសាសន៍ដើម្បីពេលណាបិទទ្វត៍នេសាទ ត្រីរបស់បងប្អូនល្មមផ្គត់ផ្គង់ទីផ្សារបាន ... ។

៤៦. ព្រលែងកូនត្រីនិងការដាំដើមឈើ អាចធ្វើបានរាល់ថ្ងៃនិងគ្រប់ទីកន្លែង

ទិវាមច្ឆជាតិ អាងទឹកត្រពាំងថ្ម ភូមិត្រពាំងថ្ម ឃុំប៉ោយចារ ខេត្តបន្ទាយមានជ័យ, ១ កក្កដា ២០២២

... វិលមកការព្រលែងកូនត្រីនៅទីនេះ។ ហេតុអ្វីបានជាយើងត្រូវព្រលែងកូនត្រី? ព្រឹត្តិការណ៍នេះចាប់ផ្តើមពីពេលណា? ខ្ញុំសូមបញ្ជាក់ថា ការព្រលែងកូនត្រីនេះជាគំនិតផ្តួចផ្តើមចាំបាច់មួយ ដើម្បីឱ្យធនធានត្រីមានការកើនឡើង សម្រាប់ដោះស្រាយជីវភាពប្រជាពលរដ្ឋ ... ការព្រលែងកូនត្រីមិនមែនធ្វើតែមួយថ្ងៃ (គឺនៅ)ថ្ងៃ១ កក្កដា នោះទេ។ **ព្រលែងពេលណាក៏បានដែរ រាល់ថ្ងៃក៏បានដែរ ឱ្យតែមានកូនត្រីនិងទីតាំងមានទឹកដើម្បីព្រលែង ... ពិធីនេះជានិមិត្តរូបនៃយុទ្ធនាការព្រលែងកូនត្រីទៅក្នុងបឹងបួ ក្នុងស្រះត្រពាំង ដើម្បីប្រជាពលរដ្ឋទទួលបានត្រឡប់មកវិញនូវចំណីអាហារ។ ដាំកូនឈើក៏ដូចគ្នាដែរ មិនមែនដាំត្រឹមតែថ្ងៃ៩កក្កដាតែមួយថ្ងៃនោះទេ គឺដាំបានរាល់ថ្ងៃ គ្រប់ទីកន្លែង តាមតែអាចធ្វើទៅបាន** ...។

៤៧. ទឹកវាក់ ត្រីតិច ប្រជាជនច្រើន

ទិវាមច្ឆជាតិ អាងទឹកត្រពាំងថ្ម ភូមិត្រពាំងថ្ម ឃុំប៉ោយចារ ខេត្តបន្ទាយមានជ័យ, ១ កក្កដា ២០២២

... ស្ថានភាពប្រទេសយើងមិនដូចកាលពីពេលមុនទេ ... កាលពីសម័យមុនដែលខ្មែរនិយាយថា "មានទឹកមានត្រី" (នោះក៏ដោយសារថា) ប្រជាជនមានចំនួនតិចឯទឹកនៅជ្រៅ ដូចនេះមានត្រីច្រើន។ នេះជារឿងពិតក្នុងប្រទេសរបស់យើង។ នៅសម័យកាលមួយ ប្រជាជនខ្មែរមានប្រមាណជាង ១លាននាក់។ បន្តបន្ទាប់មក

ដល់ទសវត្សរ៍៦០ មុនឆ្នាំ១៩៧០ យើងថាមានប្រជាពលរដ្ឋត្រឹមតែ ៦ ទៅ ៧លាន នាក់ ... **បច្ចុប្បន្ន ទឹកមានជំរៅរាក់ ឯត្រីក៏មានតិច ហើយចំនួនប្រជាជនក៏ច្រើន។ នេះជាចំណុចខុសគ្នា។** បើមានសារធាតុជាមនុស្ស ... មិនមានការកេងប្រវ័ញ្ចខាង នយោបាយ គេត្រូវទទួលស្គាល់នូវការពិតដែលបានកើតឡើង ...។

៤៨. ជំនន់រដូវ ស្លឹកឈើជ្រុះ ធ្វើឱ្យបឹងបួគោករាក់ ប៉ះពាល់ដល់បរិស្ថានត្រីរស់នៅ

ទិវាមច្ឆជាតិ អាងទឹកត្រពាំងថ្ម ភូមិត្រពាំងថ្ម ឃុំប៉ោយចារ ខេត្តបន្ទាយមានជ័យ, ១ កក្កដា ២០២២

... **ក្នុងឆ្នាំនីមួយៗ នៅខែនេះ ទឹកចាប់ផ្តើមឡើង ហើយបាននាំជីល្បាប់ចូលទៅកាន់(គ្រប់)ទីកន្លែង។ បឹងបួបន្ថែមទៅដោយ(ល្បាប់) ក៏គោករាក់ (រួមជាមួយគំនរ)ស្លឹកឈើជ្រុះ។ ក្នុងបឹងនីមួយៗ តែងមានដើមឈើ ជាដើមរាំង ជាដើមត្រស់ ដើមឈើផ្សេងៗ ដែលធ្លាក់ស្លឹកជាប្រចាំ។ រៀងរាល់ឆ្នាំ បឹងបួនានារាប់ទាំងទន្លេសាបផង តែងតែជួបនឹងស្ថានភាពនេះ។** ដូច្នេះ ចំនួនត្រីក្នុងផ្ទៃទឹកដែលកាន់តែរាក់ ក៏មានចំនួនកាន់តែតិច ក្នុងពេលដែលប្រជាពលរដ្ឋរបស់យើង, ដែលបើគិតត្រឹមរំដោះឆ្នាំ១៩៧៩ មានប្រជាជនត្រឹមប្រមាណជុំវិញ ៥លាននាក់, បានឡើងដល់ ១៧លាននាក់ គឺកើន ១២លាននាក់ក្នុងរយៈពេល ៤៣ឆ្នាំ ... ។

៤៩. បំផុសចលនាព្រលែងត្រីក្នុងបឹងបួរធម្មជាតិ និងចិញ្ចឹមត្រីឆ្លើយតបតម្រូវទីផ្សារ

ទិវាមច្ឆជាតិ អាងទឹកត្រពាំងថ្ម ភូមិត្រពាំងថ្ម ឃុំប៉ោយចារ ខេត្តបន្ទាយមានជ័យ, ១ កក្កដា ២០២២

... **ជំរុញនិងលើកទឹកចិត្តឱ្យបង្កើនផលត្រីបំពេញតម្រូវការហូបចុក តាមរយៈការបំផុសចលនាភ្ញាស់កូនត្រី និងព្រលែងចូលទៅក្នុងបឹងបួ ព្រែក ទន្លេឲ្យបានច្រើន តាមដែលអាចធ្វើទៅបាន ក៏ដូចជាជំរុញចលនាចិញ្ចឹមត្រីដើម្បីផ្គត់ផ្គង់ទីផ្សារ** ...ខ្មែរបច្ចុប្បន្នខុសពីខ្មែរសម័យ ២០ ទៅ ៣០ឆ្នាំមុន។ ខ្មែរសម័យមុនទទួលឲ្យតែបានឆ្អែត។ ឥឡូវមិនអញ្ចឹងទេ។ ទទួលទានយ៉ាងម៉េចឲ្យឆ្អែតហើយឲ្យឆ្ងាញ់។ អញ្ចឹង មានចំណូលចិត្តមាន់ស្រែ មិនចូលចិត្តមាន់កសិកម្មចិញ្ចឹម។ អ្នកណាមានលទ្ធភាពហូបអីហូបហ្នឹងទៅ។ គ្មានការហាមឃាត់ទេ ... ។

៥០. រៀបចំតំបន់ស្នូលអចិន្ត្រៃយ៍ដើម្បីអភិរក្សផ្សោត

បើកការដ្ឋានសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គពីស្រុកចិត្របុរី ទៅស្រុកព្រៃកប្រសព្វ ខេត្តក្រចេះ, ២ មករា ២០២៣

... ក្រសួងកសិកម្ម ត្រូវយកចិត្តទុកដាក់រៀបចំ(ការពារតំបន់អភិរក្សផ្សោត)។ រឿងហ្នឹងនៅក្នុងដៃនសមត្ថកិច្ចទទួលខុសត្រូវរបស់ក្រសួងកសិកម្ម ប៉ុន្តែអ្នកដែលត្រូវនៅផ្ទាល់គឺអភិបាលខេត្ត អាជ្ញាធរ ... **ជានាថាផ្សោតទាំងនេះមិនត្រូវបានជាប់មងឬក៏ត្រូវបានរំខានទេ។ ត្រូវសហការរៀបចំតាមអ្នកបច្ចេកទេស ... ត្រូវមានតំបន់ស្នូលអចិន្ត្រៃយ៍ ដែលនៅក្នុងទន្លេអញ្ចឹង យើងគួរដាក់យុថ្កា ទម្លាក់ពោងដើម្បីឲ្យប្រជាជនបានដឹង។ មិនឲ្យចូល មិនឲ្យនេសាទអ្វីទាំងអស់ ... ត្រូវធ្វើឲ្យជាក់លាក់។ ម៉េចបានជាហៅថាតំបន់ស្នូលអចិន្ត្រៃយ៍?** គឺដោយសារមានស្ថានភាពទឹកស្រកនិងទឹកឡើង ... ទំហំប៉ុន្មាន តំបន់ណា ពីត្រឹមណាទៅត្រឹមណា ហាមមិនឲ្យមានការរាយមងទេ ... **សូមជាសំគាល់ពីការអភិរក្សត្រីផ្សោតក្នុងតំបន់នេះ ដើម្បីជានាថា យើងអាចអភិរក្សទីនេះជាតំបន់ទេសចរណ៍** ...។

៥១. ធ្វើវិសោធនកម្មច្បាប់ពាក់ព័ន្ធ ប្តូរពីរឹតត្បិតទៅលើកទឹកចិត្តឱ្យចិញ្ចឹមសត្វជិតផុតពូជ

សម្ពោធដាក់ឱ្យប្រើប្រាស់អគារសិក្សាចំនួន២ ខ្នង និងប្រគល់សញ្ញាបត្រជូន និស្សិតនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ជិត ៥ ៣ន់នាក់, ១ មីនា ២០២៣

... ខ្ញុំចង់ឱ្យប្រជាពលរដ្ឋរបស់យើងចិញ្ចឹមសត្វដែលជិតផុតពូជ ... ខ្ញុំនិយាយដល់រឿងក្ងោក។ ខ្ញុំបាន**ដាក់(បទបញ្ជា)ចេញហើយ ឱ្យពិនិត្យបន្ទាន់លើបញ្ហាច្បាប់ដែលមានការពាក់ព័ន្ធ ដោយត្រូវធ្វើវិសោធនកម្ម ប្តូរពីការឹតត្បិតទៅជាការលើកទឹកចិត្ត(អោយចិញ្ចឹម) ដើម្បីបង្កើនបរិមាណសត្វព្រៃឡើងវិញ។ សត្វហ្នឹងយើងចិញ្ចឹម(បាន)។ យើងអាចយកទៅលែងនៅក្នុងព្រៃ ឱ្យសម្បុរទៅដោយសត្វក្ងោកពេញតែព្រៃមើល។** បើថាក្ងោកវាកាក់កបជាមួយនឹងការរស់នៅក្នុងជីវបស់កម្ពុជា យើងអាចយកក្ងោកទៅលែងក្នុងព្រៃ។ យើងអាចចិញ្ចឹមសត្វមួយចំនួនរួចហើយយកទៅលែងក្នុងព្រៃ ដើម្បីបង្កើតជាស្ថានភាពល្អប្រសើរក្នុងប្រទេសយើង ...។

៥២. បើមានចន្លោះប្រហោង ត្រូវធ្វើវិសោធនកម្មច្បាប់អំពីការចិញ្ចឹមសត្វកម្រ

ដាក់ឱ្យប្រើប្រាស់អគារសិក្សាចំនួន២ ខ្នង និងប្រគល់សញ្ញាបត្រជូននិស្សិតនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ១ មីនា ២០២៣

រឿងនេះ វាកើតឡើងប៉ុន្មានថ្ងៃ(មក)ហើយ។ ខ្ញុំមិនដាក់កំហុសលើនរណាទេ តែខ្ញុំឱ្យសិក្សាបន្ទាន់ទៅលើច្បាប់។ មន្ត្រីអនុវត្តច្បាប់របស់យើងអនុវត្តទៅតាមច្បាប់។ បើច្បាប់ហ្នឹងវាហួសសម័យវាមិនសមស្របយើងអាចកែច្បាប់ហ្នឹងបាន។ ម្សិលមិញខ្ញុំក៏ថា បញ្ហាស្ទឹកដោយត្រូវទុកមួយអន្លើ។ យកក្មេកហ្នឹងទៅសងដល់ម្ចាស់ ព្រោះគាត់ទារប៉ុន្មានថ្ងៃមកហើយ ... **(មានការចាំបាច់ខ្ញុំ)ត្រូវបញ្ជេញសារសម្តែងទៅ ព្រោះត្រូវធ្វើម៉េចនាំសត្វក្មេកបញ្ជូនទៅឱ្យក្រុមគ្រួសារនោះវិញ។ ខ្ញុំមិនដឹងថាបានចែងនៅក្នុងច្បាប់មួយណាទេ ក្រែងលោថាខ្ញុំចន្លោះប្រហោង តែខ្ញុំបានស្ថិតនៅក្នុងព្រឹត្តិការណ៍ហ្នឹងទាំងអស់។ បើមានចន្លោះប្រហោង យើងអាចធ្វើវិសោធនកម្មច្បាប់បើកឱកាសឱ្យប្រជាជនមានលទ្ធភាពចិញ្ចឹមសត្វកម្រ ...**៕

៥៣. គួរតែរៀបចំជាចលនាចិញ្ចឹមសត្វដែលជិតផុតពូជ

ដាក់ឱ្យប្រើប្រាស់អគារសិក្សាចំនួន២ ខ្នង និងប្រគល់សញ្ញាបត្រជូននិស្សិតនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ១ មីនា ២០២៣

បើនិយាយពីជាប់ទោសវិញ អ្នកជាប់ទោសមុនគេអ្នកណា? គឺនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាប់ទោសមុនគេ (ព្រោះបាន)ចិញ្ចឹមក្មេកច្រើនជាងក្មេកអ្នកកំពង់ឆ្នាំង។ ចៅខ្ញុំវាចូលចិត្តក្មេក វាទៅប្រឡែងលេងជាមួយក្មេក។ ដោយខ្លាចក្មេកហ្នឹងចឹកភ្នែក ក៏បានឱ្យ(ហ៊ុន)ម៉ានិតយកអាក្មេកទៅដាក់ទ្រុងនៅមណ្ឌលគិរី។ ហ្នឹងទី(១)អ្នកដែលត្រូវមានទោសគឺ ហ៊ុន សែន។ ទី២ គឺ ហ៊ុន ម៉ានិត។ ទី៣ គឺ ហ៊ុន តូ ចិញ្ចឹមមិនដឹងប៉ុន្មានទេ តាំងពីកេងកង គឺថាហើរពេញទីក្រុង។ ទី៤ គឺ ហ៊ុន ម៉ាលី កូនស្រីពៅរបស់ខ្ញុំ។ ផ្ទះគាត់សុទ្ធតែសត្វ។ អញ្ចឹង **ប្រភេទសត្វដែលជិតផុតពូជនេះគឺមកពីការដែលយើងរឹតត្បិត។ គួរតែរៀបចំឱ្យទៅជាចលនាចិញ្ចឹមសត្វដែលជិតផុតពូជវិញ។ រឿងហ្នឹងអត់មានខាតអីទាល់តែសោះ**។ (និយាយ)ថាចិញ្ចឹមដើម្បីយកសាច់។ អ្នកណាស៊ីសាច់ក្មេក? ប្រជាពលរដ្ឋអាចយកទីកន្លែងចិញ្ចឹមហ្នឹង ដាក់(ជា)ទីតាំងមួយសម្រាប់ការចូលមើលរបស់ប្រជាជន ដែលគាត់អាចទទួលបានកម្រៃពីទេសចរដែលចង់មើល ...៕

៥៤.ពិនិត្យច្បាប់ពាក់ព័ន្ធបន្ទាន់ ធ្វើវិសោធនកម្ម ប្តូរពីការរឹតត្បិតទៅលើកទឹកចិត្តដើម្បីបង្កើនសត្វព្រៃ

ដាក់ឱ្យប្រើប្រាស់អគារសិក្សាចំនួន២ ខ្នង និងប្រគល់សញ្ញាបត្រជូននិស្សិតនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ១ មីនា ២០២៣

... ខ្ញុំបានផ្ញើលុយ ១០លានរៀលទៅឱ្យគ្រួសារនោះ។ គោលដៅរបស់ខ្ញុំ ក្រៅពីជីវភាព គឺចង់ឱ្យគ្រួសារហ្នឹងប្រើប្រាស់ថវិកាកែសម្រួលកន្លែង(ចិញ្ចឹមក្មេកនោះ)ដើម្បីឱ្យប្រជាជនទៅមើលឱ្យបានល្អ។ **ខ្ញុំចង់បង្វែរការយកចិត្តទុកដាក់ ឱ្យប្រជាពលរដ្ឋយើងចិញ្ចឹមសត្វដែលជិតផុតពូជ** ... និយាយដល់ក្មេកនេះ **ខ្ញុំបានដាក់បទបញ្ជាហើយ សូមឱ្យពិនិត្យបន្ទាន់លើច្បាប់ដែលមានការពាក់ព័ន្ធ។ ត្រូវធ្វើវិសោធនកម្ម ដោយប្តូរពីការរឹតត្បិតទៅជាការលើកទឹកចិត្ត ដើម្បីបង្កើនសត្វព្រៃឡើងវិញ។ សត្វហ្នឹងយើងចិញ្ចឹម។ យើងអាចយកទៅលែងនៅក្នុងព្រៃឱ្យសម្បូរទៅដោយសត្វក្មេកពេញព្រៃ** ... សត្វទាំងឡាយដែលយើងអាចចិញ្ចឹមបាន ចិញ្ចឹមរួចហើយយកទៅលែងនៅព្រៃ រួចហើយវាបង្កើតជាស្ថានភាពល្អប្រសើរសម្រាប់សត្វនៅក្នុងប្រទេសរបស់យើង ...៕

២. ភាកច្ចាទក្រហមកម្ពុជា

១	ក្រុមការសមាជិកស្ថាបនិក សមាជិកកិត្តិយស សមាជិកគាំទ្រ ក្បៀតឈើភាគទាន	៣១
២	រាសមាជិកគាំទ្រ មូលនិធិគន្ធបុប្ផា តាមរបៀបអង្គរតស៊ូ	៣១
៣	កាកបាទក្រហម "មានគ្រប់ទីកន្លែង និងសំរាប់ទាំងអស់គ្នា"	៣១
៤	បង្កើតកាកបាទក្រហមដើមទស៊ត្សវ៍៥០ បង្រួបបង្រួមពី៤ មកតែ១ ក្នុងទស៊ត្សវ៍១៩៩០	៣២
៥	ព្រះមហាក្សត្រួមជាមួយសម្តេចម៉ែ បន្តជួយគាំទ្រសកម្មភាពកាកបាទក្រហមកម្ពុជា	៣២
៦	យុវជនកាកបាទក្រហមធ្វើសកម្មភាពបច្ចុប្បន្ន និងក្លាយជាអ្នកបន្តវេនទៅអនាគត	៣៣
៧	មិនត្រឹមជួយជំនួយម្តងម្កាលតែសង់ផ្ទះសំបុងនិងជីកអណ្តូងទឹក ជូនពលរដ្ឋក្រីក្រ	៣៣
៨	តម្លាភាព ប្រើថវិកាចំគោលដៅ នាំឱ្យមានការគាំទ្រពីសប្បុរសជនក្នុងនិងក្រៅប្រទេស	៣៤
៩	ជំនឿទុកចិត្តលើការប្រើថវិកា ការមិនភ្លេចទុក្ខលំបាកពីអតីតកាល នាំដល់ការគាំទ្រថវិកា	៣៤
១០	ឈរជើងរឹងមាំជួយសង្គ្រោះ និងផ្តល់ប្រយោជន៍ ដល់អ្នកត្រូវការចាំបាច់	៣៥
១១	រៀបចំគោលដៅសកម្មភាពទៅតាមដំណាក់កាល	៣៥
១២	ជួយជនរងគ្រោះ ជាផ្នែកមួយនៃគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល	៣៥
១៣	អន្តរាគមន៍របស់អាជ្ញាធរនិងសកម្មភាពកាកបាទក្រហម ... ជាការបំពេញអោយគ្នា	៣៦
១៤	កាកបាទក្រហមតែមួយ ហេដ្ឋារចនាសម្ព័ន្ធល្អ សំរួលដល់ការអន្តរាគមន៍	៣៦
១៥	យុវជនកាកបាទក្រហមកម្ពុជា ជួយដល់ការគ្រប់គ្រងរបស់រដ្ឋ លើកិច្ចការចរាចរណ៍	៣៧
១៦	កាកបាទក្រហមរួមនឹងរាជរដ្ឋាភិបាល ត្រៀមបំរុងឆ្លើយតបនឹងបាតុភូតធម្មជាតិ	៣៧
១៧	ពី «មិនទុកឲ្យនរណាម្នាក់ស្លាប់ដោយអត់បាយ» មក «មិនទុកនរណាម្នាក់ចោល»	៣៧
១៨	សិល្បៈចែករំលែកក្នុងក្របខណ្ឌជាតិនិងក្របខណ្ឌប្រទេសមានការលំបាកជាង	៣៨
១៩	"ខ្ញុំស្រឡាញ់កាកបាទក្រហមកម្ពុជា" បង្កើតសុខដុមភាពជាមួយអ្នកមាននិងអ្នកគ្មានលទ្ធភាព	៣៨
២០	រក្សាសន្តិភាព ធានាការអភិវឌ្ឍ ដើម្បីកាកបាទក្រហមបន្តដំណើរការ	៣៩
២១	កាកបាទក្រហមកម្ពុជាជាជំនួយការឲ្យអាជ្ញាធរសាធារណៈក្នុងវិស័យមនុស្សធម៌	៣៩

១. ត្រូវការសមាជិកស្ថាបនិក សមាជិកកិត្តិយស សមាជិកគាំទ្រ ដើម្បីកៀរគរវិភាគទាន

ពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវ «មូលនិធិគន្ធបុប្ផាកម្ពុជា»,
១១ មេសា ២០១៨

... មុននឹងចូលដល់ខ្លឹមសារ ខ្ញុំព្រះករុណាខ្ញុំសូមប្រកាសជាមុនថា កាកបាទក្រហមកម្ពុជា ដែលមុននេះធ្លាប់ជូនទៅមន្ទីរពេទ្យគន្ធបុប្ផាក្នុងមួយឆ្នាំ ១ លានដុល្លារ ឥឡូវនេះ គឺសូមផ្ទេរនូវចំរិកាមួយលានដុល្លារនោះមកកាន់មូលនិធិសម្រាប់មួយឆ្នាំ១ លានដុល្លារបន្តទៀត។ ខ្ញុំ និងភរិយា បានពិភាក្សា គ្នាមុននឹងចេញមកទីនេះ ក៏សូមប្រកាសផ្តល់នូវការចូលរួមវិភាគទានក្នុងមួយឆ្នាំ៥ ម៉ឺនដុល្លារ រយៈពេល ៥ ឆ្នាំ ... **យើងអាចកៀរគរបានទូលាយក្នុងក្របខណ្ឌទូទាំងប្រទេស មិនមែនគ្រាន់តែសមាជិកស្ថាបនិក ឬសមាជិកកិត្តិយសទេ យើងចង់បានសមាជិកគាំទ្រដែរ** ...។

២. រកសមាជិកគាំទ្រ មូលនិធិគន្ធបុប្ផា តាមរបៀបអង្គរតស៊ូ

ពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវ «មូលនិធិគន្ធបុប្ផាកម្ពុជា»,
១១ មេសា ២០១៨

...ដំណាក់កាលនៃ**ការតស៊ូរំដោះប្រទេស ហៅថាអង្គរតស៊ូ។ បានសេចក្តីថា បើជាក់៥ កំប៉ុងទៅក្នុងឆ្នាំងដាំបាយសំរាប់គ្រួសារមួយ (គេ)ច្បិចមួយក្តាប់យកមកធ្វើជាអង្គរផ្តត់ផ្តង់ដល់កងទ័ព ...** យើងប្រើពេល៣ ខែប្រមូលអ្នកចង់ចូលជាសមាជិកស្ថាបនិក ... ទី២ សមាជិកកិត្តិយស ផ្តល់វិភាគទានអប្បបរមាចាប់ពី២០លានរៀល ឬស្មើនឹង៥ ពាន់ដុល្លារឡើងទៅ ... ទី៣ គឺសមាជិកគាំទ្រ ផ្តល់វិភាគទានអប្បបរមាចាប់ពី៥ ពាន់រៀល/ខែ ឬ៦ ម៉ឺនរៀល/ឆ្នាំ ... សង្ឃឹមថា ប្រជាពលរដ្ឋ មន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធក៏អាចក្លាយទៅជាសមាជិកគាំទ្រ (មូលនិធិគន្ធបុប្ផា)បាន ...។

៣. កាកបាទក្រហម "មានគ្រប់ទីកន្លែង និងសំរាប់ទាំងអស់គ្នា"

ទិវាកាកបាទក្រហមកម្ពុជា, ០៨ ឧសភា ២០១៨

... ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមសំដែងការស្វាគមន៍ ... ទិវាកាកបាទក្រហមក្រោមប្រធានបទ **"កាកបាទក្រហម មានគ្រប់ទីកន្លែង សម្រាប់គ្រប់គ្នា និងមិនទុកអ្នកណាម្នាក់ចោល"។ ក្នុងរយៈពេលមួយឆ្នាំកន្លងផុតទៅ តាមរយៈបាយការណ៍ប្រធានកាកបាទក្រហម បានបង្ហាញអំពីជោគជ័យដ៏ធំធេងនៅក្នុងស្មារតីសាមគ្គីភាពនិងមនុស្សធម៌ទុកសម្រាប់ប្រជាជនទូទៅ។** ក្នុងឱកាសនេះ សូមរំលេចបន្តិចពីជោគជ័យដែលយើងទទួលបានក្នុងរយៈពេលកន្លងទៅ ក្នុងក្របខណ្ឌកាកបាទក្រហមកម្ពុជាជាជំនួយការឲ្យអាជ្ញាធរសាធារណៈលើវិស័យមនុស្សធម៌...។

៤. ព្រះបាទនរោត្តមសីហនុ បង្កើតកាកបាទក្រហម នាដើមទសវត្សរ៍៥០ និងបង្រួបបង្រួមពី ៤ មកតែ១ នៅក្នុងទសវត្សរ៍១៩៩០

ទិវាកាកបាទក្រហមកម្ពុជា, ០៨ ឧសភា ២០១៨

... ជាអ្នកជំនាន់ក្រោយ យើងផឹកទឹកត្រូវនឹកដល់ប្រភព ទទួលទានផ្លែឈើក៏ត្រូវនឹកដល់អ្នកដាំដើម។ គឺជាព្រះរាជតួទាទីដ៏ធំធេងរបស់ព្រះបរមរតនកោដ្ឋ **ព្រះបិតាជាតិ ព្រះបាទនរោត្តមសីហនុ ដែលព្រះអង្គបានបង្កើតនូវកាកបាទក្រហមនេះឡើងកាលពីដើមទសវត្សរ៍៥០ ... កាកបាទក្រហមកម្ពុជា ត្រូវបានចែកជាផ្នែកៗបន្ទាប់ពីប្រទេសត្រូវបែកបាក់។ ក្នុងចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៤ កាកបាទក្រហមរបស់យើងមានរហូតទៅដល់៤។ ទោះបីមានព្រះរាជកិច្ចច្រើន ព្រះអង្គមិនបានបោះបង់ចោលការយកចិត្តទុកដាក់ចំពោះ ការបង្រួបបង្រួមកាកបាទក្រហមពីកាកបាទក្រហម៤ផ្នែកទៅជាកាកបាទក្រហមតែមួយ** ដូចមានមកដល់សព្វថ្ងៃ។ បន្ថែមលើនោះ មុនពេលសោយទិវង្គតរួមជាមួយសម្តេចម៉ែ ព្រះអង្គបានខិតខំបន្តព្រះរាជបេសកកម្មជួយដល់កាកបាទក្រហមកម្ពុជា ...។

៥. ព្រះមហាក្សត្រីរួមជាមួយសម្តេចម៉ែ បន្តជួយគាំទ្រសកម្មភាពកាកបាទក្រហមកម្ពុជា

ទិវាកាកបាទក្រហមកម្ពុជា, ០៨ ឧសភា ២០១៨

... ក្នុងចំណោមព្រះឆាយាលក្ខណ៍របស់ព្រះអង្គ បើសង្កេតមើល មានព្រះឆាយាលក្ខណ៍មួយដែលព្រះអង្គពាក់សញ្ញាកាកបាទក្រហម។ ជាព្រះឆាយាក្ខណ៍ស្អាតបំផុត ក្នុងចំណោមព្រះឆាយាលក្ខណ៍សម្តេចឪសម្តេចតាទួត។ **ក្រៅពីព្រះរាជបិតាជាតិ ព្រះបរមរតនកោដ្ឋ ព្រះមហាក្សត្របច្ចុប្បន្ន ព្រះអង្គបានបន្តវេនរួមជាមួយសម្តេចម៉ែបន្តទៀត ជួយឧបត្ថម្ភគាំទ្រដល់សកម្មភាពកាកបាទក្រហមកម្ពុជា។** ចំណុចនេះ **ធ្វើអោយយើងជាកូនចៅជំនាន់ក្រោយ កាន់តែមានមោទនភាពចូលរួមថែរក្សាសមិទ្ធផលដែលបន្សល់ទុកដោយអ្នកជំនាន់មុន ...។**

៦. យុវជនកាកបាទក្រហមធ្វើសកម្មភាពបច្ចុប្បន្ន និងក្លាយជាអ្នកបន្តវេនទៅអនាគត

ខួបលើកទី១៥៤ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម,
០៨ ឧសភា ២០១៧

... សូមកោតសរសើរចៅៗ ក្មួយៗ ជាយុវជនកាកបាទក្រហមកម្ពុជា ដែលមានវត្តមាននៅគ្រប់ទីកន្លែង។ កាលពីប៉ុន្មានខែមុននេះ ខ្ញុំបានធ្វើដំណើរទៅគ្រប់ខេត្តដោយឋិយន្ត (លើចម្ងាយផ្លូវ)ជាង៥០០០ គីឡូម៉ែត្រ ហើយបានចូលតាមវិទ្យាល័យមួយចំនួនធំ។ **នៅគ្រប់ទីកន្លែងមានវត្តមាននៃយុវជនកាកបាទក្រហម។ នោះគឺជាកម្លាំងដែលធ្វើសកម្មភាពបច្ចុប្បន្ន ហើយក៏នឹងក្លាយទៅជាកម្លាំងបន្តវេន សំរាប់ចលនាកាកបាទក្រហមនាពេលអនាគតផង។** កម្លាំងដ៏មានវិន័យនៃយុវជនកាកបាទក្រហម ពិតជាបាននាំមកនូវការចូលរួមចំណែកជួយអប់រំមិត្តក្នុងក្របខណ្ឌភូមិ/ឃុំ ពិសេសក្នុងថ្នាក់រៀនជាមួយគ្នា បញ្ចៀសគ្រោះថ្នាក់ស្តីពីគ្រឿងញៀន និងភាពមិនប្រក្រតីផ្សេងទៀត គឺមិត្តជួយមិត្ត ...។

៧. មិនត្រឹមជួយជំនួយម្តងម្កាល តែសង់ផ្ទះសំបែងនិងជីកអណ្តូងទឹក ជូនពលរដ្ឋក្រីក្រ

ទិវាកាកបាទក្រហមកម្ពុជា, ០៨ ឧសភា ២០១៨

... ខ្ញុំមានការពេញចិត្តជាមួយនឹងការខិតខំរបស់យើងទាំងអស់គ្នា រក្សាសមិទ្ធផលទាំងឡាយដែលបន្សល់ទុកដោយអ្នកជំនាន់មុន តាមរយៈសកម្មភាពព្រមៗគ្នាក្នុងវប្បធម៌នៃការចែករំលែក។ សូមយកឱកាសនេះថ្លែងការកោតសរសើរចំពោះសកម្មភាពកាកបាទក្រហមកម្ពុជា ដែលក្នុងរយៈពេលពីមួយឆ្នាំទៅឆ្នាំ ចេះតែមានការកើនឡើង ... **មិនមែនគ្រាន់តែការចែកជំនួយម្តងម្កាលនោះទេ ក៏ប៉ុន្តែបានឈានទៅមុខយ៉ាងច្រើនក្នុងការកសាងផ្ទះសំបែងជូនប្រជាពលរដ្ឋទីទាល់ក្រ ជាពិសេស**

រួមចំណែកដោះស្រាយអណ្តូងទឹកស្អាតសំរាប់ប្រជាជនគ្រប់ទីកន្លែង ផ្តល់ជាផលដល់រាប់មឺនគ្រួសារ ...។

៨. តម្លាភាព ប្រើថវិកាចំគោលដៅ នាំឱ្យមានការគាំទ្រពីសប្បុរសជនក្នុងនិងក្រៅប្រទេស

ទិវាកាកបាទក្រហមកម្ពុជា, ០៨ ឧសភា ២០១៨

... ជោគជ័យរបស់កាកបាទក្រហមមិនអាចកាត់ផ្តាច់ចេញពីការចូលរួមចំណែកការជួយឧបត្ថម្ភ ... ជាវិភាគទានប្រចាំឆ្នាំនិងប្រចាំខែ។ **ក្នុងរយៈពេលកន្លងទៅ កាកបាទក្រហមបានទទួលថវិការាប់លានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំៗ ជាការចូលរួមពីមិត្តភក្តិ ពីសប្បុរសជនក្នុងប្រទេសនិងសប្បុរសជនមកពីក្រៅប្រទេស។ ចំណុចនេះបង្ហាញនូវការជឿជាក់ ។ បើមិនមានការជឿជាក់លើការចំណាយរបស់កាកបាទក្រហមទេ ច្បាស់ណាស់ថាអ្នកដែលចូលរួមវិភាគទានសំរាប់កាកបាទក្រហម នឹងគ្មានទឹកចិត្តចូលរួមបន្ថែមទៀតទេ។ ដូច្នេះ បញ្ហាតម្លាភាព និងប្រើប្រាស់ថវិកាចំគោលដៅជាចំណុចសំខាន់ ដើម្បីរក្សាបាននូវការគាំទ្រទាំងឡាយពីសប្បុរសជនទាំងក្នុងប្រទេសទាំងក្រៅប្រទេស**។ នេះជាការចូលរួមចំណែកតាមរយៈនៃវប្បធម៌ចែករំលែក ឬសិល្បៈនៃការចែករំលែក ...។

៩. ជំនឿទុកចិត្តលើការប្រើថវិកា និងការមិនភ្លេចទុក្ខលំបាកពីអតីតកាល ធ្វើអោយកាកបាទក្រហមទទួលបានការគាំទ្រថវិកា

ទិវាកាកបាទក្រហមកម្ពុជា, ០៨ ឧសភា ២០១៨

... ខ្ញុំតែងចោទសួរខ្លួនឯងថា **"ហេតុអ្វីបានជាកាកបាទក្រហមកម្ពុជា ទទួលបានថវិកា"។ ច្បាស់ណាស់ថា ម្ខាងគឺជំនឿទុកចិត្តនៃការប្រើប្រាស់ថវិកា ចំគោលដៅ និងមានតម្លាភាព។ ប៉ុន្តែម្ខាងទៀត អ្នកមានធនធាននៅប្រទេសកម្ពុជារបស់យើង សុទ្ធតែបានឆ្លងកាត់នូវការលំបាកនិងទុក្ខវេទនាពីអតីតកាល សម័យសង្គ្រាមនិងក្រោយរបបប្រល័យពូជសាសន៍ ប៉ុល ពត**។ អ្នកមានធនធានចូលកាកបាទក្រហមពិតជាបានស្គាល់នូវរសជាតិនៃការលំបាកកាលពីអតីតកាល។ ដូច្នេះ នៅពេលខ្លួនមានបាន ពួកគេមិនបានភ្លេចគិតដល់ការលំបាកដែលខ្លួនបានជួបប្រទះក្នុងអតីតកាលនោះទេ ...។

១០. ឈរជើងរឹងមាំជួយសង្គ្រោះនិងផ្តល់ប្រយោជន៍ដល់អ្នកត្រូវការចាំបាច់

ទិវាកាកបាទក្រហមកម្ពុជា, ០៨ ឧសភា ២០១៨

... ខ្ញុំមានមោទនភាពចំពោះសប្បុរសជនក្នុងប្រទេស ដែលមានធនធាន ហើយបានចូលរួមចំណែកជាមួយកាកបាទក្រហមកម្ពុជា។ ខ្ញុំក៏មានមោទនភាពផងដែរចំពោះ**ក្រុមហ៊ុននិនិយោគទុនមកពីក្រៅប្រទេសដែលបានរួមចំណែកផ្តល់ថវិកាតាមរយៈកាកបាទក្រហមកម្ពុជាផងនិងធ្វើសកម្មភាពមនុស្សធម៌តាមទីកន្លែងដែលខ្លួនធ្វើវិនិយោគនោះផង។ សង្ឃឹមថាកាកបាទក្រហមបន្តឈរជើងរឹងមាំជាអ្នកជួយសង្គ្រោះ និងផ្តល់ផលប្រយោជន៍ទៅឲ្យអ្នកដែលត្រូវការសង្គ្រោះជាចាំបាច់** ...។

១១. រៀបចំគោលដៅសកម្មភាពទៅតាមដំណាក់កាល

ខួបលើកទី១៥៦ នៃទិវាកាកបាទក្រហម និងអឌ្ឍចន្ទក្រហម, ៨ ឧសភា ២០១៩

... ជាភ័ព្វសំណាងមួយរបស់កម្ពុជាដែលព្រះករុណាព្រះបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ សម្តេចព្រះ នរោត្តម សីហនុ **ព្រះអង្គបានបង្កើតឡើងនូវចលនាមួយដ៏ធំ ហើយដែលបានឆ្លងកាត់ដំណាក់កាលនីមួយៗ ខុសៗគ្នា ... ក្នុងសម័យសង្គ្រាម សកម្មភាពរបស់កាកបាទក្រហមកម្ពុជាមានគោលដៅផ្សេង។ បន្ទាប់ពីពេលដែលប្រទេសជាតិទទួលបានសន្តិភាព យើងក៏បានរៀបចំគោលដៅផ្សេងដើម្បីបន្តជំហានឆ្ពោះទៅមុខ** ... សភាពការណ៍នៅប្រទេសមួយចំនួនដូចជាស៊ីរី ការបាក់ទំនប់នៅប្រទេសឡាវ និងគ្រោះធម្មជាតិនៅឥណ្ឌូនេស៊ី សុទ្ធតែត្រូវឱ្យមានការដោះស្រាយ។ ប៉ុន្តែវិធីមិនដូចគ្នានោះទេ ... កន្លែងដែលមានសង្គ្រាមត្រូវដោះស្រាយរបៀបផ្សេង។ ដូចដែលយើងបានជួបប្រទះរួចមកហើយពីអតីតកាល និងគោលដៅដោះស្រាយរបស់កាកបាទក្រហមនៅក្នុងដំណាក់កាលនីមួយៗ ...។

១២. ជួយជនរងគ្រោះត្រូវការជំនួយ ជាផ្នែកមួយនៃគោលនយោបាយគាំពារសង្គមរបស់ រាជរដ្ឋាភិបាល

ខួបលើកទី១៥៦ នៃទិវាកាកបាទក្រហម និងអឌ្ឍចន្ទក្រហម, ៨ ឧសភា ២០១៩

... ប្រធានកាកបាទក្រហមកម្ពុជាបានធ្វើរបាយការណ៍ស្តីពីសកម្មភាពមនុស្សធម៌ ... ទោះបីជារបាយការណ៍សង្ខេប តែយើងបានដឹងពីការធ្វើសកម្មភាពយ៉ាងធំ

ធេង ... ប្រមាណជិត១៤ ម៉ឺនគ្រួសារបាន**ទទួលជំនួយសង្គ្រោះពីកាកបាទក្រហមកម្ពុជា។ នេះជាសកម្មភាពដ៏អង់អាច និងឆ្ពោះទៅកាន់ជនដែលងាយរងគ្រោះជាគោលដៅ។ ខ្ញុំមានមោទនភាពចំពោះការចូលរួមរបស់កាកបាទក្រហមកម្ពុជា រួមចំណែកធំធេង ក្នុងការអនុវត្តគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល។ ជនរងគ្រោះត្រូវការជំនួយ ជាផ្នែកមួយនៃគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល មិនតែក្នុងឆ្នាំ២០១៨ តែក៏ពីនេះតទៅទេ** ... កាកបាទក្រហមកម្ពុជាបានចាប់ផ្តើមធ្វើសកម្មភាពឡើងវិញ តាំងពីក្រោយថ្ងៃ៧ មករា ១៩៧៩ ...។

១៣. អន្តរាគមន៍របស់អាជ្ញាធរនិងសកម្មភាពរបស់កាកបាទក្រហម ជួយអ្នករងគ្រោះនិងងាយរងគ្រោះ ជាការបំពេញអោយគ្នា

ខួបលើកទី១៥៦ នៃទិវាកាកបាទក្រហម និងអឌ្ឍចន្ទក្រហម, ៨ ឧសភា ២០១៩

... វិធីសាស្ត្រក្នុងការចាត់ចែងដឹកនាំគ្រប់គ្រងនៅឯថ្នាក់មូលដ្ឋាន គឺកាកបាទក្រហមមានភាពឈ្លាសវៃប្រើប្រាស់តួនាទីរបស់អភិបាលខេត្ត ប្រធានក្រុមប្រឹក្សាខេត្ត ឬថ្នាក់ដឹកនាំរបស់ខេត្ត ចូលរួមនៅក្នុងចលនារបស់កាកបាទក្រហមកម្ពុជា។ មន្ត្រីសាធារណៈមួយចំនួន ជាពិសេសនៅតាមខេត្ត បានក្លាយទៅជាសមាជិក និងជាអ្នកបម្រើ(ការ)របស់កាកបាទក្រហមកម្ពុជា។ យើងត្រូវដឹងថា ភារកិច្ចទាំងនេះក៏ជាភារកិច្ចរបស់អាជ្ញាធរដែលត្រូវដោះស្រាយ។ ដូច្នេះ **វាជាការបំពេញអោយគ្នាទៅវិញទៅមកវាងអន្តរាគមន៍របស់អាជ្ញាធរ ក៏ដូចជាការធ្វើសកម្មភាពរបស់កាកបាទក្រហមកម្ពុជា គឺមានទិសដៅតែមួយ "ដោះស្រាយការលំបាករបស់ប្រជាពលរដ្ឋ ជាពិសេសសម្រាប់អ្នកដែលរងគ្រោះ និងអ្នកដែលងាយរងគ្រោះ" ...។**

១៤. កាកបាទក្រហមតែមួយ ហេដ្ឋារចនាសម្ព័ន្ធល្អ សំរួលដល់ការអន្តរាគមន៍

ទិវាកាកបាទក្រហមកម្ពុជា, ០៨ ឧសភា ២០១៨

... បើប្រៀបធៀបទៅរយៈពេលមុន ដែលកម្ពុជាមានការបែងចែកជាតំបន់ត្រួតត្រាទៅដល់៤ និងមានកាកបាទក្រហម៤ បច្ចុប្បន្ន **សភាពការណ៍ងាយស្រួលជាងពេលមុន ដោយសារប្រទេសជាតិមានការឯកភាពជាកម្ពុជាតែមួយ តំបន់ត្រួតត្រាតែមួយ កាកបាទក្រហមកម្ពុជាក៏តែមួយផងដែរ។ ម្យ៉ាងទៀត ហេដ្ឋារចនាសម្ព័ន្ធ**

កាន់តែល្អប្រសើរ ងាយស្រួលយកជំនួយទៅចែកចាយ និងធ្វើអន្តរាគមន៍ភ្លាមៗ ដោយកាកបាទក្រហមកម្ពុជា និងដោយផ្នែកពាក់ព័ន្ធដទៃទៀត។ យើងនៅមើលឃើញរូបភាពកាលពីអតីតកាល ជំនាន់ដឹកជញ្ជូនស្បៀងអាហារទៅចែកជូនប្រជាជននៅមណ្ឌលគិរី ដែលមន្ត្រីកាកបាទក្រហមកម្ពុជាត្រូវដើកតាមព្រៃ ធ្វើដំណើរច្រើនថ្ងៃ ចុះជ្រោះឡើងភ្នំ ទម្រាំទៅដល់គោលដៅ ...។

១៥. យុវជនកាកបាទក្រហមកម្ពុជា ជួយដល់ការគ្រប់គ្រងរបស់រដ្ឋ លើកិច្ចការចរាចរណ៍

ទិវាកាកបាទក្រហមកម្ពុជា, ០៨ ឧសភា ២០១៨

... នៅមានសកម្មភាពដទៃទៀត ដែលខ្ញុំយល់ថាអ្នកបើកបរក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬក៏អ្នកបើកបរដោយបំពានច្បាប់គួរតែមានការខ្មាសអៀនចំពោះយុវជនកាកបាទក្រហមកម្ពុជា ដែលឈរនៅតាមដងផ្លូវអប់រំអ្នកបើកបរខុសច្បាប់។ ប្រទេសយើងកំពុងទទួលផលអាក្រក់ អំពីការគ្រោះថ្នាក់ចរាចរណ៍។ **យុវជនកាកបាទក្រហមកម្ពុជាបានស្រុះគ្នាធ្វើសកម្មភាព ចាត់ជាផ្នែកមួយដ៏សំខាន់ជួយដល់ការគ្រប់គ្រងរបស់រដ្ឋទៅលើបញ្ហាចរាចរណ៍ ... គួបផ្សំជាមួយសកម្មភាពរបស់អាជ្ញាធរនៅឯមូលដ្ឋាន បានជួយកាត់បន្ថយគ្រោះថ្នាក់មួយចំនួន ...។**

១៦. កាកបាទក្រហម រួមនឹងរាជរដ្ឋាភិបាល ត្រៀមបំរុងឆ្លើយតបនឹងបាតុភូតធម្មជាតិ

ទិវាកាកបាទក្រហមកម្ពុជា, ០៨ ឧសភា ២០១៨

... យោងតាមការព្យាករណ៍របស់ក្រសួងធនធានទឹកនិងឧតុនិយម ប្រសិនបើវាមិនខុសទេ ដោយសារច្រើនឆ្នាំកន្លងទឹកតែងតែតូច ឆ្នាំនេះអាចមានទឹកធំក្លាយជាជំនន់ ដែលត្រូវប្រុងប្រៀបដោះស្រាយ តាមរយៈយន្តការនៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ តាមរយៈយន្តការកាកបាទក្រហមកម្ពុជា និងតាមរយៈយន្តការរបស់រដ្ឋនៅគ្រប់កម្រិត។ រាជរដ្ឋាភិបាលបានត្រៀមបម្រុងទុកថវិកានិងស្បៀងអាហារមួយចំនួន ... **កាកបាទក្រហមក៏ត្រូវត្រៀមបម្រុងដូចគ្នាដែរ ដើម្បីឆ្លើយទៅបាតុភូតធម្មជាតិណាមួយ ដែលគំរាមកំហែងប្រទេសនិងប្រជាជនរបស់យើង។**

១៧. ពី «មិនទុកឲ្យនរណាម្នាក់ស្លាប់ដោយអត់បាយ» មក «មិនទុកនរណាម្នាក់ចោល»

ទិវាកាកបាទក្រហមកម្ពុជា, ០៨ ឧសភា ២០១៨

... ចាំបានថា ថ្ងៃទី ១៤ មករា ១៩៨៥ ពេលដែលរដ្ឋសភាបោះឆ្នោតឲ្យខ្ញុំក្លាយជានាយករដ្ឋមន្ត្រីជាផ្លូវការ ខ្ញុំបានថ្លែងទៅកាន់សភាថា "មិនត្រូវទុកឲ្យនរណាមួយស្លាប់ដោយអត់បាយ ហើយយើងមិនបានដឹងនិងមិនបានដោះស្រាយ" ឡើយ។ **ថ្ងៃនេះយើងបានឃើញនូវពាក្យស្លោក «កាកបាទក្រហមកម្ពុជាមានគ្រប់ទីកន្លែងសម្រាប់គ្រប់គ្នា និងមិនទុកនរណាម្នាក់ចោល»។ ចំណុចនេះហាក់ដូចជាមានការគាប់ជួនគ្នានឹងអ្វីដែលយើងបានយកចិត្តទុកពីជាង ៣០ ឆ្នាំរួចមកហើយ ដែលយើងមិនបណ្តោយឲ្យប្រជាជនណាម្នាក់ស្លាប់ដោយអត់បាយនោះទេ ...។**

១៨. សិល្បៈចែករំលែកក្នុងក្របខណ្ឌជាតិនិងក្របខណ្ឌប្រទេសមានការលំបាកជាង

ខួបលើកទី ១៥៦ នៃទិវាកាកបាទក្រហម និងអឌ្ឍចន្ទក្រហម, ៨ ឧសភា ២០១៩

... **សិល្បៈនៃការចែករំលែក មិនមែនអនុវត្តតែនៅក្នុងក្របខណ្ឌជាតិរបស់យើងប៉ុនោះទេ តែនៅបានអនុវត្តជាទូទៅពីប្រទេសមួយចែករំលែកទៅកាន់ប្រទេសមួយចំនួនទៀតដែលមានការលំបាកជាង តាមរយៈទំនាក់ទំនងទ្វេភាគី ឬតាមរយៈនៃយន្តការពហុភាគី ... សភាពការណ៍ពិភពលោកបានប្រែប្រួល ក្នុងស្ថានភាពភូមិសាស្ត្រនយោបាយ សង្គ្រាម និងការប្រែប្រួលអាកាសធាតុផង**។ សង្គ្រាមគឺមនុស្សជាអ្នកបង្កើត។ វាបង្កើតជាទំនង់យ៉ាងធ្ងន់ដូចជាវិបត្តិជនភៀសខ្លួនពីមជ្ឈិមបូព៌ាទៅកាន់អឺរ៉ុប សម្រាប់ពិភពលោកដោះស្រាយ។ មិនតែប៉ុណ្ណោះ ក្នុងក្របខណ្ឌប្រទេសនីមួយៗ ក៏មានជនភៀសសឹកដែលគេចេញពីសង្គ្រាម ពីកន្លែងមួយទៅកាន់កន្លែងមួយ។ វិបត្តិមនុស្សធម៌បានកើតឡើងនៅច្រើនកន្លែង រាប់ទាំងនៅក្នុងតំបន់របស់យើងផង ... កម្ពុជាត្រូវមានកាតព្វកិច្ចផ្នែកណាមួយ ជួយដោះស្រាយបញ្ហា ដូចដែលយើងបានធ្វើចំពោះមិត្តឡាវចំពោះឥណ្ឌូនេស៊ី និងចំពោះប្រទេសផ្សេងទៀត ... នោះជាសិល្បៈនៃការចែករំលែក ...។

១៩. អនុវត្ត "ខ្ញុំស្រឡាញ់កាកបាទក្រហមកម្ពុជា" បង្កើតភាពសុខដុមរមនារវាងអ្នកមាន និងអ្នកដែលគ្មានលទ្ធភាព

ខួបលើកទី ១៥៦ នៃទិវាកាកបាទក្រហម និងអឌ្ឍចន្ទក្រហម, ៨ ឧសភា ២០១៩

... សូមអំពាវនាវ (ប្រឹងប្រែង) ធ្វើអោយប្រធានបទ **"ខ្ញុំស្រឡាញ់កាកបាទក្រហមកម្ពុជា" ក្លាយទៅជាចលនា ក្លាយទៅជាសកម្មភាពអនុវត្តជាក់ស្តែង និងក្លាយទៅជាចលនារបស់ជាតិទាំងមូល**។ ខ្ញុំស្រឡាញ់កាកបាទក្រហមកម្ពុជា មិនមែនគ្រាន់តែស្ថិតនៅលើក្រដាសនោះទេ ក៏ប៉ុន្តែត្រូវធ្វើអោយចេញជាសកម្មភាពជាក់ស្តែង ហើយត្រូវក្លាយទៅជាចលនាជាតិ តាំងពីថ្នាក់កំពូលរហូតដល់ប្រជាជនធម្មតា រាប់ទាំងប្រជាជនដែលត្រូវការជំនួយសង្គ្រោះ និងប្រជាជនដែលបានចូលរួមក្នុងចលនាសកម្មភាពមនុស្សធម៌ទាំងនេះ។ ខ្ញុំជឿជាក់ថា **ប្រជាពលរដ្ឋរបស់យើងអាចអនុវត្តទ្រឹស្តីមួយនេះបាន ដោយវាបានបង្កើតភាពសុខដុមរមនារវាងអ្នកដែលមានលទ្ធភាពនិងរវាងអ្នកដែលគ្មានលទ្ធភាព** ...។

២០. រក្សាសន្តិភាព ធានាការអភិវឌ្ឍ ដើម្បីកាកបាទក្រហមបន្តដំណើរការ

ទិវាកាកបាទក្រហម និងអឌ្ឍចន្ទក្រហម, ៨ ឧសភា ២០១៨

... យើងត្រូវរក្សាសុខសន្តិភាពដើម្បីធានាការអភិវឌ្ឍបន្ត។ ប្រទេសស៊ីរីបច្ចុប្បន្នមានយ៉ាងច្រើន ដែលសូម្បីតែមានជំនួយមនុស្សធម៌ហើយ ក៏មិនអាចចូលទៅដល់ដោយសារមានការកាត់ផ្តាច់ពីការវាយប្រហារគ្នា។ ដោយហេតុនេះ មិនត្រូវឲ្យអតីតកាលដ៏ឈឺចាប់វិលត្រឡប់មកកាន់ប្រទេសរបស់យើងបន្តទៀតទេ។ **យើងត្រូវរក្សាស្ថានភាពសន្តិភាព ក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយ ព្រះមហាក្សត្រតែមួយ រាជរដ្ឋាភិបាលតែមួយ កម្លាំងប្រដាប់អាវុធតែមួយ ក្នុងនោះក៏មានកាកបាទក្រហមកម្ពុជាតែមួយផងដែរ មិនត្រូវឲ្យកាកបាទក្រហមកម្ពុជាមាន ២, ៣, ៤ ដូចកាលពីអតីតកាលទេ** ...។

២១. កាកបាទក្រហមកម្ពុជាជាជំនួយការឲ្យអាជ្ញាធរសាធារណៈក្នុងវិស័យមនុស្សធម៌

ទិវាកាកបាទក្រហម និងអឌ្ឍចន្ទក្រហម, ៨ ឧសភា ២០១៨

... សារថ្លែងតំណាងកាកបាទក្រហម និងអឌ្ឍចន្ទក្រហម (អន្តរជាតិ) បានលើកទឹកចិត្តសកម្មភាពមនុស្សធម៌របស់កាកបាទក្រហមកម្ពុជាផង និងរាជរដ្ឋាភិបាលផង ... (រាជរដ្ឋាភិបាល) គោរពជានិច្ចនូវតួនាទីនិងចំណុចទាំង ៧ របស់កាកបាទក្រហមកម្ពុជា។ **យើងមិនដែលជាក់ចេញបទបញ្ជាណាមួយលើកាកបាទក្រហម**

ដោយរំលោភបំពានលើឯករាជ្យភាពរបស់កាកបាទក្រហមកម្ពុជានោះទេ។ ថ្វីបើកាកបាទក្រហមកម្ពុជាមិនធ្វើសកម្មភាពជាមួយអាជ្ញាធរក្តី យើងបានដឹងច្បាស់ថាកាកបាទក្រហមកម្ពុជាជាជំនួយការឲ្យអាជ្ញាធរសាធារណៈក្នុងវិស័យមនុស្សធម៌។ ការធ្វើសកម្មភាពរួមគ្នាមិនជាការខុសឆ្គងទេ ផ្ទុយទៅវិញជាកម្លាំងជួយជល់ការរីកចម្រើន និងដោះស្រាយការប្រឈមសម្រាប់ប្រជាជន ...។

៣. ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១	យកការជួបកម្មករ/ការិនី ជាគោលដៅសកម្មភាពរបស់នាយករដ្ឋមន្ត្រី	៤៥
២	«ថ្ពាល់ផ្អែមសន្តិភាព» លើកទឹកចិត្តការដឹកនាំប្រទេសដែលមានសុខសន្តិភាព	៤៥
៣	ជំនួបជុំទី១ ដោះស្រាយបញ្ហាមួយចំនួនទាក់ទងនឹងអត្ថប្រយោជន៍របស់កម្មករ	៤៥
៤	ជំនួបជុំទី២ ក្រោយកូវីដ-១៩ ពិនិត្យការអនុវត្តអនុសាសន៍១០ និងលទ្ធផលជំនួបទី១	៤៦
៥	ផ្លាស់ប្តូរពីជី១ ហិកតា ចិញ្ចឹមបាន៤ ឬ៥នាក់ ទៅជាចិញ្ចឹមបាន៤ ឬ៥ពាន់នាក់	៤៦
៦	ទស្សនៈ ហ៊ុន សែន៖ ពីភ្នំពេញទៅកំពង់សោម ផ្លូវជាតិលេខ៤ មានរោងចក្រហូរហៀ	៤៧
៧	ប្រែក្លាយសមរភូមិ ទៅជាភូមិដ្ឋាន ការដាំដុះ រោងចក្រ ទីផ្សារ	៤៧
៨	វត្តមានតាមកន្លែងផ្សេងគ្នា តាមសភាពការណ៍ និងដំណាក់កាលថ្មីគឺជួបកម្មកររាល់	៤៧
៩	ផ្តុំវិស័យទាំងបី កសិកម្ម ឧស្សាហកម្ម និងសេវា ដើម្បីប្រទេសរីកលូតលាស់	៤៨
១០	ឆ្ពោះទៅឧស្សាហកម្មតម្លៃបន្ថែមខ្ពស់ និងរក្សាឧស្សាហកម្មអតិពលកម្ម	៤៨
១១	កិច្ចការ៥ ជាក្របខ័ណ្ឌគោលនយោបាយសម្រាប់ការអភិវឌ្ឍ	៤៩
១២	អនុវត្តគោលនយោបាយឧស្សាហកម្ម ព្រមគ្នាជំរុញគោលនយោបាយជាតិគាំពារសង្គម	៤៩
១៣	រដ្ឋ ម្ចាស់រោងចក្រ និងកម្មករ ជាមុំចង្រ្កាន ៣ នៃការអភិវឌ្ឍប្រទេស	៥០
១៤	គោរពច្បាប់ការងារ ចៀសវាងវិវាទ យោគយល់គ្នាស្រាយបញ្ហាដោយសន្តិវិធី	៥០
១៥	ថ្នាក់ដឹកនាំខេត្តត្រូវនាំមុខដោះស្រាយវិវាទកម្មការជាមួយថៅកែ/រោងចក្រ	៥១
១៦	ស្វែងរកដំណោះស្រាយតាមការសន្ទនានិងអប់រំ ជាងបណ្តេញកម្មការចេញ	៥១
១៧	បំបាត់ស្ថានភាពបងធំក្នុងរោងចក្រ រក្សាភាពសុខដុមរមនារវាងថៅកែនិងកម្មករ	៥១
១៨	ធ្វើឲ្យរោងចក្រក្លាយជាសហគមន៍មានសុវត្ថិភាព	៥២
១៩	រោងចក្រជាសហគមន៍សុខសាន្ត ឈានទៅជោគជ័យនយោបាយភូមិឃុំមានសុវត្ថិភាព	៥២
២០	មិនមានការចាំបាច់ ដើម្បីបង្កើតឡើងតុលាការការងារ	៥៣
២១	យកលុយរដ្ឋដោះស្រាយ និងរកការងារឲ្យកម្មការដែលថៅកែរាត់ចោល	៥៣
២២	កែសម្រួលច្បាប់បញ្ចប់ឬកាត់បន្ថយបញ្ហាថៅកែរាត់ចោល ធ្លាក់បន្ទុកលើរាជរដ្ឋាភិបាល	៥៣
២៣	វិបត្តិសេដ្ឋកិច្ចសកល២០០៨ រោងចក្របិទទ្វារ រដ្ឋបង្កើតកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ	៥៤
២៤	ពង្រាយរោងចក្រមកតាមមូលដ្ឋាន សម្រួលការដោះស្រាយពលកម្ម	៥៤
២៥	ខំកសាងហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែកទន់និងរឹង ដើម្បីព្យួរោងចក្រមកកាន់មូលដ្ឋាន	៥៥
២៦	កំណើននិងការងារ មុំពីរនៃយុទ្ធសាស្ត្រចតុកោណ	៥៥
២៧	គ្មានរោងចក្រនៅមូលដ្ឋាន ឬមួយបន្តជាកសិករ ឬជាកម្មការដែលឃ្លាតឆ្ងាយពីគ្រួសារ	៥៦

២៨	រក្សាការងារចាស់និងបង្កើតការងារថ្មីបន្ថែមផង	៥៦
២៩	ពង្រីកសមត្ថភាពអ្នកវិនិយោគមានស្រាប់ និងទាក់ទាញអ្នកវិនិយោគថ្មី	៥៦
៣០	រកមធ្យោបាយឲ្យធាងចក្រចំណាយតិច យកប្រាក់ចំណេញបង្កើនបៀវត្ស	៥៧
៣១	ធ្វើច្បាប់ទាក់ទងនឹងបៀវត្ស៍អប្បបរមា ជាមូលដ្ឋានឱ្យយន្តការត្រីភាគីធ្វើការចរចា	៥៧
៣២	មិនឲ្យបៀវត្ស៍អ្នកទីក្រុងនិងអ្នកជនបទខុសគ្នាទេ	៥៨
៣៣	ក្នុងស្ថានភាពកូវីដ១៩ ឆ្នាំ២០២១/២០២២ កម្មការបន្តទទួលបានការដំឡើងប្រាក់បៀវត្ស	៥៨
៣៤	ក្នុងអំឡុងកូវីដ១៩រដ្ឋាភិបាលផ្តល់កម្រៃទ្រទ្រង់៧០ដុល្លារ/ខែ លើកលែងភាគហ៊ុនកិច្ចមួយចំនួន	៥៩
៣៥	រំកិលពិដានប្រាក់បៀវត្ស៍ជាប់ពន្ធទៅចាប់ពី១លាន២សែនរៀល ឬ៣០០ ដុល្លារឡើង	៥៩
៣៦	ត្រូវពិនិត្យប្រាក់ឈ្នួលកម្មការប្រទេសជិទៃឲ្យទៀងទាត់ ព្រោះជាការប្រកួតប្រជែង	៥៩
៣៧	ប្រាក់ចំណូលកម្មការកម្ពុជាបានធ្លាងជុតបន្ទាត់នៃភាពក្រីក្រ	៦០
៣៨	ចាប់ពីឆ្នាំ២០១៩ បើកបៀវត្ស៍ប្រចាំសប្តាហ៍ម្តង (ពីរអាទិត្យបើកម្តង)	៦០
៣៩	អនុញ្ញាតបើកប្រាក់ខែជារូបិយបណ្ណបរទេស ការពារមិនឲ្យបាត់បង់កម្លាំងទិញ	៦១
៤០	ទាមទារហួសហេតុ ធាងចក្រប្តូរទៅប្រទេសជិទៃ កម្មការជាអ្នកខាតបង់	៦១
៤១	កម្មករ/ការិនី និងកីឡាករ/ការិនី ពិនិត្យសុខភាព និងជិះឡានក្រុងឥតគិតថ្លៃ	៦១
៤២	សូមអនុញ្ញាតកម្មការិនីមានផ្ទៃពោះ/ជនពិការ ចេញមុនម៉ោងយ៉ាងហោច១៥ នាទី	៦២
៤៣	កម្មការិនីឆ្លងទន្លេបានបៀវត្ស៍១២០% សម្រាកពី៣ ខែ និងឧបត្ថម្ភជាសាច់ប្រាក់	៦២
៤៤	ផ្តល់សាច់ប្រាក់ចំពោះស្ត្រីមានផ្ទៃពោះ ៤០ម៉ឺនរៀល ពេលសម្រាលកូនមួយ	៦៣
៤៥	ទោះកូនរស់ឬស្លាប់ ស្ត្រីឆ្លងទន្លេត្រូវទទួលបានការឧបត្ថម្ភ	៦៣
៤៦	ឈានទៅឧបត្ថម្ភស្ត្រីក្រីក្រមានផ្ទៃពោះ ចាប់ពីពេលមានផ្ទៃពោះរហូតកូនអាយុ២ ឆ្នាំ	៦៤
៤៧	សូមបណ្តាធាងចក្របន្តពង្រីកគិលានដ្ឋាន កន្លែងហូបបាយ និងទារកដ្ឋាន	៦៤
៤៨	Hunsenomics បង្កើនអាហារូបត្ថម្ភ កាត់បន្ថយអត្រាមរណភាពមាតានិងទារក	៦៤
៤៩	Hunsenomics ប្រជុំចបាននឹងគោលនយោបាយសេដ្ឋកិច្ចផ្តាយព្រឹកមិនអស្តង្គត	៦៥
៥០	បន្ថយចំណាយ តាមរយៈការក្សាអតិផរណាឲ្យនៅទាប និងបន្ទាបថ្លៃទឹក/ភ្លើង	៦៥
៥១	សូមកុំឡើងថ្លៃជួលផ្ទះច្រើនហួស ខណៈកម្មករ/ការិនីទទួលការដំឡើងប្រាក់ឈ្នួល	៦៦
៥២	បង្កើនការយកចិត្តទុកដាក់អំពីសុវត្ថិភាពការដឹកជញ្ជូនកម្មករ/ការិនី	៦៦
៥៣	យកចិត្តទុកដាក់លើអ្នកធ្វើការតាមផ្ទះ ដែលជាកម្មការក្រៅប្រព័ន្ធផងដែរ	៦៦
៥៤	ការរស់នានមានជីវិតរបស់កម្ពុជា ចាប់ផ្តើមពីការរស់នានមានជីវិតនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ	៦៧
៥៥	សូមយោគយល់ដល់កម្មការិនីជនជាតិឥស្លាមក្នុងការស្លៀកពាក់	៦៧

៥៦	ប្រាក់សោធននិវត្តន៍វិស័យឯកជនចាប់អនុវត្តពី២០១៩ ត្រូវមានសៀវភៅការងារ	៦៧
៥៧	រដ្ឋទាក់ទាញធាងចក្រ បង្កើតការងារ ផ្តល់ការគាំពារ ហែរជាថានាំរាស្ត្រមកធ្វើកញ្ចះ	៦៨
៥៨	ក្រសួងការងារគួរតាមដាននិងធ្វើរបាយការណ៍ពីតួលេខការងារដែលបានបង្កើតនិងបាត់បង់	៦៨
៥៩	កិច្ចការ៥ កំពុងធ្វើសម្រួលដល់ពលការធ្វើការនៅក្រៅប្រទេស	៦៩
៦០	ប្រាក់ចំណូលពីពលករ ក្នុងនិងក្រៅប្រទេស ប្រមាណ ៦ពាន់លានដុល្លារ/ឆ្នាំ	៦៩
៦១	ចរន្ត៣ "សុំ" របស់រាជរដ្ឋាភិបាល ត្រូវបានរារាំងដោយចរន្ត៣ "កុំ" របស់ពួកប្រឆាំង	៦៩
៦២	បើបាត់ EBA តែមានការងារធ្វើ មានប្រាក់ចំណូល/ខែ វាស្មើនឹងសម្លាប់បក្សប្រឆាំង	៧០
៦៣	ស្ថានភាពសេដ្ឋកិច្ចសកលមិនច្បាស់លាស់ វាយនភណ្ឌចមថយ តែកម្មន្តសាលកើន	៧០
៦៤	រំពឹងកំណើននាំចេញរាប់ពាន់លានដុល្លារ ដើម្បីក្លាយជាប្រទេសមានចំណូលខ្ពស់	៧១
៦៥	ក្រោយរំដោះ៧ មក៣១៧៩ បានរៀបចំការបណ្តុះបណ្តាលគ្រប់វិស័យឡើងវិញ	៧១
៦៦	ទោះរៀនបានតិច ក៏អាចទទួលការបណ្តុះបណ្តាល	៧២
៦៧	កុំមើលស្រាលការបណ្តុះបណ្តាលវិជ្ជាជីវៈ បើចេះពិតប្រាកដ ការងារអ្វីក៏រកលុយបាន	៧២
៦៨	រាជរដ្ឋាភិបាលចេញថវិកាបណ្តុះបណ្តាលវិជ្ជាជីវៈយុវជនក្នុងគ្រួសារក្រីក្រ១,៥ លាននាក់	៧២
៦៩	ក្រ.ការងារគ្រប់គ្រងការបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រ.ស្បៀងមិគ្រប់គ្រងផ្នែកមរតកវិជ្ជាជីវៈដូនតា	៧៣
៧០	ការបណ្តុះបណ្តាលវិជ្ជាជីវៈ ជួយពលរដ្ឋចូលរួមអភិវឌ្ឍ ឆ្ពោះទៅសេដ្ឋកិច្ចចំណេះដឹង	៧៣
៧១	ជំរុញការបណ្តុះបណ្តាលវិជ្ជាជីវៈ ទាក់ទាញវិនិយោគ បំពេញតម្រូវការវិនិយោគិន	៧៤

១. យកការជួបកម្មករ/ការិនី ជាគោលដៅសកម្មភាពរបស់នាយករដ្ឋមន្ត្រី

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល, ២៨ វិច្ឆិកា ២០១៨

... ពាក់ព័ន្ធការអភិវឌ្ឍវិស័យឧស្សាហកម្ម២០១៥-២០២៥ ហើយជាបន្តទៀត នឹងមិនមែនបញ្ចប់ត្រឹមឆ្នាំ២០២៥ ក្នុងវិស័យឧស្សាហកម្មនោះទេ (ហើយក៏) មិនមែនបានន័យថា យើងភ្លេចកសិកររនោះដែរ ... (តែ)ឱកាសបានមកដល់សម្រាប់ការជំរុញវិស័យឧស្សាហកម្ម។ ការជួបជាមួយកម្មករមិនមែនជារឿងថ្មីដែលទើបនឹងកើតមានក្នុងរយៈកាលឆ្នាំ២០១៧-២០១៨ នោះទេ។ ពូបានជួបជាមួយកម្មកររាល់ឆ្នាំ ... (គ្រាន់តែ)ឥឡូវ**ពូយកការជួបនេះធ្វើជាគោលដៅនៃសកម្មភាពរបស់នាយករដ្ឋមន្ត្រី ... ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរការងារ និងផ្នែកពាក់ព័ន្ធបានយកចិត្តទុកដាក់ហើយ ប៉ុន្តែនាយករដ្ឋមន្ត្រីបានចាប់យកសកម្មភាពចំពោះកម្មករធ្វើជាគោលដៅនៃសកម្មភាពជាប្រចាំ** ឆ្លើយតបនឹងបញ្ហាដែលបានកើតឡើង និងបញ្ហាដែលយើងត្រូវជំរុញបន្តទៀត ...។

២. «ថ្ពាល់ផ្អែមសន្តិភាព» លើកទឹកចិត្តការដឹកនាំប្រទេសដែលមានសុខសន្តិភាព

សំណេះសំណាលជាមួយកម្មករ និយោជិត នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ(ថ្ងៃទី១), ១៣ មិថុនា ២០២៣

... ក្នុងឱកាសសម្ពោធសមិទ្ធផលកងពលលេខ៧០ **សម្តេច ម៉ែន សំអន បានឃើញហើយ គេដាក់ថា «ថ្ពាល់ផ្អែមសន្តិភាព»។ គេដាក់រូបពូមានកម្មការិនីចាប់ថើប ...** ឯកូនប្រុសដែល(អ្នកទាំងអស់គ្នា)ស្រែកគាំទ្រធ្វើបេក្ខភាពនាយករដ្ឋមន្ត្រីសម្រាប់ពេលអនាគតនោះ ចាស់ៗចាប់ថើប។ គេដាក់រូបទាំងពីរហ្នឹង ហើយថា "ថ្ពាល់ផ្អែមសន្តិភាព" ... **នេះគឺជាទំនាក់ទំនងមិនត្រឹមតែនាយករដ្ឋមន្ត្រី និងកម្មករ/ការិនី ប៉ុន្តែក្មួយៗ កូនៗ ចៅៗ ទុកពូ តា អ៊ំ គឺជាសាច់ញាតិនៅក្នុងគ្រួសារ ... នេះជាការលើកទឹកចិត្តធំណាស់សម្រាប់ការដឹកនាំប្រទេសមួយ** ដែលធ្លាប់តែបែកបាក់ កាប់សម្លាប់គ្នា ឲ្យក្លាយជាប្រទេសមានសុខសន្តិភាព សុខដុមរមនា ...។

៣. ជំនួបជុំទី១ ដោះស្រាយបញ្ហាមួយចំនួនទាក់ទងនឹងអត្ថប្រយោជន៍របស់កម្មករ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកពញាឮ ខេត្តកណ្តាល, ២៦ ធ្នូ ២០១៨

... ពូបានបញ្ជាក់ហើយ ដំណើរជួបនេះឈប់តែក្នុងរយៈពេលនៃការធ្វើយុទ្ធនាការ(ឃោសនា និង)បោះឆ្នោតតែប៉ុណ្ណោះ។ ពេលនោះ ខ្ញុំក៏បានប្រកាសបញ្ជាក់ប្រាប់ថា ប្រសិនបើគណបក្សប្រជាជនកម្ពុជាជាប់ឆ្នោត ហើយពូក្លាយទៅជានាយករដ្ឋមន្ត្រីឡើងវិញ ដំណើរការជួបនឹងត្រូវបន្ត ... **ក្រោយការបោះឆ្នោតយើងជួបបានជាង១០ ដង ... មិនទាន់ដោះស្រាយបញ្ហាអស់ទាំងស្រុងទេ ក៏ប៉ុន្តែយ៉ាងណាក៏យើងបានដោះស្រាយបញ្ហាមួយចំនួនទាក់ទងជាមួយនឹងផលប្រយោជន៍របស់កម្មករ/ការិនី**របស់យើងដែរ ...។

៤. ជំនួបជុំទី២ ក្រោយកូវីដ-១៩ ពិនិត្យការអនុវត្តអនុសាសន៍១០ និងលទ្ធផលជំនួបទី១

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់គ្រុប ភ្នំពេញ (ថ្ងៃទី២), ២៧ ឧសភា ២០២៣

... ខ្ញុំបានជម្រាបជូនពីគោលបំណងការមកជួបជុំទី២ ដែលជំបូងឡើយគ្រោងធ្វើនៅឆ្នាំ២០២០ ប៉ុន្តែយើងជួបកូវីដ-១៩។ ២០២១, ២០២២ ក៏នៅជួបកូវីដ-១៩។ **២០២៣ មុនពេលយើងដកចេញវិធានការនៃការធ្វើតេស្តសម្រាប់ការជួបជុំគ្នា យើងក៏មិនទាន់បានជួប។ ចាប់ពីថ្ងៃទី២២មក នៅខេត្តព្រះសីហនុ និងថ្ងៃនេះយើងបានជួបជុំគ្នា។ បើគិតសរុបទាំងនៅខេត្តព្រះសីហនុ និងនៅទីនេះ យើងបានជួបប្រមាណជា៦ ម៉ឺននាក់។ គោលដៅជាក់លាក់នៃជំនួបនៅត្រង់ថាពិនិត្យការអនុវត្តអនុសាសន៍ទាំង១០ និងពិនិត្យអ្វីដែលទទួលបានមុនពេលជំនួបទី១ និងការទទួលផលចេញពីជំនួបទី១ រហូតមកដល់ពេលនេះ** ...។

៥. ផ្លាស់ប្តូរពីដី១ ហិកតា ចិញ្ចឹមបាន៤ ឬ៥នាក់ ទៅជាចិញ្ចឹមបាន៤ ឬ៥ពាន់នាក់

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់កំបូល ផ្លូវជាតិលេខ៤, ៤ តុលា ២០១៧

... មានមនុស្សមួយចំនួនមិនបានគិតរំលែងធ្វាយ គិតតែពីផ្តល់ការទិតៀន បានលើកឡើងពីការបណ្តែតបណ្តោយឱ្យប្រជាជនលក់ដីនៅតាមបណ្តោយផ្លូវជាតិលេខ៤ ... ខ្ញុំក៏បានឆ្លើយតបជាមួយពួកគេថា សូមគិតឱ្យបានច្បាស់ **ដី១ ហិកតា ធ្វើកសិកម្មចិញ្ចឹមត្រឹមមនុស្សមួយគ្រួសារមាន៤ ឬ៥នាក់តែប៉ុណ្ណោះ។ ប្រសិនបើដីនោះត្រូវបានទិញ ហើយកសាងទៅជារោងចក្រ ដីដែលធ្លាប់ចិញ្ចឹមបានតែមនុស្ស៤ ឬ៥នាក់ អាចនឹងចិញ្ចឹមបានមនុស្ស៤ ឬ៥ ពាន់នាក់ជំនួសវិញ** ...

ម្យ៉ាងទៀតដីដែលត្រូវប៉ាន់កសាងរោងចក្រគឺជាដីដែលមានតម្លៃខ្ពស់។ ដូច្នេះម្ចាស់ដីនឹងបានប្រាក់ទៅទិញដីថ្មី១០ ហិកតាក៏បាន។ ឥឡូវ រឿងរ៉ាវរបានិងកំពុងក្លាយទៅជាការពិត ...។

៦. ទស្សនៈ ហ៊ុន សែន៖ ពីភ្នំពេញទៅកំពង់សោម ផ្លូវជាតិលេខ៤ មានរោងចក្រហ្សាវហែ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅរោងចក្រ Wing Star Shoe ស្រុកគងពិសី ខេត្តកំពង់ស្ពឺ, ៤ មិថុនា ២០២៣

... កាលពីដើម តាមផ្លូវជាតិលេខ៤ ចេញតែពីពេជ៍ចិនតុងមក សងខាងផ្លូវសុទ្ធតែវាលស្រែល្វឹងល្វើយ ... ឆ្នាំ២០០០ ២០០១ ២០០២ អត់ទាន់មានអីមែន។ **ពេលដែលមានការវិនិយោគ ... ខ្ញុំចង់ឲ្យតភ្ជាប់តំបន់រោងចក្រនៅតាមផ្លូវជាតិលេខ៤ ពីភ្នំពេញធ្លាក់រហូតទៅកំពង់សោម ... នេះជាទស្សនៈរបស់ ហ៊ុន សែន។ រឿងនេះបានក្លាយទៅជាការពិត។ បើទោះបីជាឥឡូវហ្នឹង តាមផ្លូវទៅដល់ខេត្តព្រះសីហនុមិនទាន់មានរោងចក្រគ្រប់គ្រាន់ ក៏ប៉ុន្តែយ៉ាងហោចណាស់ភ្នំពេញ-កំពង់ស្ពឺ ភ្ជាប់ដោយរោងចក្រហើយ។** អ្នកឯងត្រូវឃើញចក្ខុវិស័យរំលែងធ្វាយផង ...។

៧. ប្រែក្លាយសមរភូមិ ទៅជាភូមិដ្ឋាន ការដាំដុះ ឆាងចក្រ ទីផ្សារ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅក្រុងបាវិត ខេត្តស្វាយរៀង, ១០ ឧសភា ២០១៨

... កាលដែលវៀតណាមមិនទាន់មានការឯកភាពរវាងខាងត្បូងនិងខាងជើង ... ជានិច្চកាលតែងមានការវាយប្រហាររវាងកម្ពុជានិងវៀតណាម ... (ក្នុង)របបប៉ុល ពត ក៏ជាតំបន់ដែលមានការប្រយុទ្ធគ្នា ដែលក្រោយយើងរំដោះឆ្នាំ១៩៧៩ បានបន្សល់នូវតំបន់មួយចំនួនតាមព្រំដែនសម្បូរទៅដោយគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ... **យើងប្រែក្លាយតំបន់ធ្លាប់វាយគ្នាកាលពីមុនឱ្យទៅជាកន្លែងដាំដុះ ជាតំបន់រោងចក្រ ជាទីផ្សារហើយ មិនថានៅផ្ទៃក្នុងប្រទេស និងមិនថានៅតាមព្រំដែនទេ ... ដើម្បីរួមគ្នាអភិវឌ្ឍសេដ្ឋកិច្চសង្គម កាត់បន្ថយភាពក្រីក្រ** ...។

៨. វត្តមានតាមកន្លែងផ្សេងគ្នា តាមសភាពការណ៍ និងដំណាក់កាលថ្មីគឺជួបកម្មករផ្ទាល់

សំណេះសំណាលជាមួយកម្មករ និយោជិត នៅសួនឧស្សាហកម្មវឌ្ឍនៈទី១, ១៥ កញ្ញា ២០១៧

... ក្នុងសម័យកាលសង្គ្រាម ខ្ញុំតែងមានវត្តមាននៅជួរមុខនៃខ្សែត្រៀម ពិនិត្យមើលស្ថានភាពទប់ស្កាត់ការវិលត្រឡប់នៃរបប ប៉ុល ពត ហើយគេក៏បានឃើញ

វត្តមានរបស់ខ្ញុំក្នុងការចូលរួមចរចានៅក្រៅប្រទេស ដើម្បីស្វែងរកដំណោះស្រាយនយោបាយសន្តិភាពសម្រាប់កម្ពុជា។ គេក៏បានឃើញវត្តមានរបស់ខ្ញុំនៅតំបន់អតីតគ្រប់គ្រងដោយកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហម ដើម្បីអនុវត្តនូវនយោបាយឈ្នះឈ្នះ នាំមកនូវការបង្រួបបង្រួមជាតិ និងឯកភាពទឹកដីជាលើកដំបូង ... ខ្ញុំមានវត្តមានច្រើនជាមួយកសិករឯវាលស្រែ ក្នុងដំណាក់កាល យើងផ្តល់អាទិភាពទៅលើការអភិវឌ្ឍវិស័យកសិកម្ម យកចិត្តទុកដាក់ទៅលើការផលិតស្បៀង និងការនាំចេញអង្ករ។ **ដល់ដំណាក់កាលថ្មី ទាមទារឱ្យខ្ញុំត្រូវធ្វើការមួយអាទិត្យពីរដងជាមួយប្រធានផ្នែករដ្ឋបាល ជំនួយការ ក៏ដូចជាប្រធានផ្នែក ប្រធានក្រុមនៃបណ្តារោងចក្រ និងជំនួបផ្ទាល់ជាមួយនឹងកម្មករ** ...។

៩. ផ្តុំវិស័យទាំងបី កសិកម្ម ឧស្សាហកម្ម និងសេវា ដើម្បីប្រទេសរីកលូតលាស់

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល, ៤ កក្តដា ២០១៨

... ទោះបីចូលមកដល់ដំណាក់កាលជំរុញវិស័យឧស្សាហកម្ម ២០១៥-២៥ ក៏យើងមិនបានបោះបង់ចោលការយកចិត្តទុកដាក់ទៅលើវិស័យកសិកម្មនោះទេ។ យើងត្រូវជំរុញ។ ប្រទេសដែលធ្វើតែកសិកម្មសុទ្ធដូចជា ប៉ុល ពត មិនអាចធ្វើអ្នកមាន មិនអាចរីកលូតលាស់បានទេ។ **ត្រូវផ្តុំវិស័យទាំង៣ គឺកសិកម្ម ឧស្សាហកម្ម និងវិស័យសេវា ... ប្រទេសមានការជឿនលឿន សេវាហ្នឹងរីកធំជាងគេ មានតាំងពីទេសចរណ៍ មានតាំងពីធនាគារ មានតាំងពីការលក់ដូរស្តើៗ ហ្នឹង** ទាក់ទងជាមួយនឹងវិស័យសេវា ...។

១០. ឆ្ពោះទៅឧស្សាហកម្មតម្លៃបន្ថែមខ្ពស់ និងរក្សាឧស្សាហកម្មអតិពលកម្ម

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ(ថ្ងៃទី២), ៤ មីនា ២០១៨

... ប្រហែលក្មួយៗធ្លាប់បានឃើញពូធ្វើវេទិកាសាធារណៈជជែកគ្នា ពិភាក្សាគ្នារវាងពូក្នុងឋានៈជានាយករដ្ឋមន្ត្រី ជាមួយនឹងកសិករនៅតាមវាលស្រែ។ ដំណាក់កាលនោះ ពូចូលរួមជាមួយកសិករ និងផ្តល់ឲ្យកសិកររូវប្រឡាយទឹក ទំនប់ទឹក ដើម្បីគាត់មានលទ្ធភាពកាន់តែប្រសើរ បង្កបង្កើនផល។ មកដល់ពេលនេះ **ផលិតផលកសិកម្មរបស់យើង និយាយតែស្រូវមួយមុខ ... នៅសល់ជាង៥ លានតោន ...**

យើងត្រូវដាក់ចេញគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម ធ្វើឲ្យឧស្សាហកម្មនៅក្នុងប្រទេសកាន់តែមានភាពលូតលាស់ ធ្វើឲ្យឧស្សាហកម្មមានតម្លៃបន្ថែមខ្ពស់។ ប៉ុន្តែ ក៏មិនមែនបោះបង់ចោលឧស្សាហកម្មអតិពលកម្ម ឬដែលប្រើកម្លាំងមនុស្សច្រើននោះទេ ...។

១១. កិច្ចការ៥ ជាក្របខ័ណ្ឌគោលនយោបាយសម្រាប់ការអភិវឌ្ឍ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅសួនឧស្សាហកម្មកាណាឌីយ៉ា, ៦ កញ្ញា ២០១៧

... **កិច្ចការទី១ រួមគ្នារក្សាសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម ដើម្បីសុវត្ថិភាព និងស្ថិរភាពការងារ ... ទី២ រួមគ្នារក្សាការងារ និងបង្កើតការងារ**។ ការងារដែលយើងមានរួចមកហើយ ត្រូវតែខិតខំរក្សាវា ព្រមដោយការបង្កើតការងារថ្មីថែមទៀត តាមរបៀបរក្សាចាស់ និងបន្ថែមថ្មី ... **ទី៣ រួមគ្នាបង្កើនប្រាក់ចំណូល និងបង្កើនការចេះដឹង** ... បៀវត្សរ៍ត្រូវឡើងជារៀងរាល់ឆ្នាំ ហើយឆ្នាំ២០១៨ នេះ មិនឱ្យទាបជាង ១៦០ ដុល្លារសហរដ្ឋអាមេរិកទេ ... **ទី៤ គាំពារសង្គម លក្ខខណ្ឌការងារ និងសុវត្ថិភាពការងារ** ... របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពកន្លងទៅ ក្មួយៗកម្មករបង់ ៥០% ឯនិយោជកម្ចាស់រោងចក្របង់ ៥០% ប៉ុន្តែចាប់ពីខែមករា ឆ្នាំ២០១៨ ទៅ ក្មួយៗបញ្ឈប់ការបង់ចុះ ហើយទុកឱ្យថៅកែជាអ្នកបង់ជួស ... **ទី៥ ដោះស្រាយបញ្ហាពលករកំពុងធ្វើការនៅក្រៅប្រទេសទាំងស្របច្បាប់ ទាំងមិនស្របច្បាប់** ... ដោយបងប្អូនត្រូវដឹងថា ដើម្បីអាចនៅបរទេសបាន តម្រូវឲ្យមានការចរចានិងធ្វើការងារជាច្រើន ...។

១២. អនុវត្តគោលនយោបាយឧស្សាហកម្ម ព្រមគ្នាជំរុញគោលនយោបាយជាតិគាំពារសង្គម

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ទួលពង្រ, ២០ ធ្នូ ២០១៧

... យើងបានខិតខំធ្វើឲ្យប្រទេសចាកផុតពីមានប្រាក់ចំណូលទាប ទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ យើងមានមហិច្ឆតាសម្រេចឲ្យប្រទេសក្លាយទៅជាមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានគោលដៅជំរុញឲ្យប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ ... ដូច្នេះហើយ **យើងដើរព្រមៗគ្នាជាមួយនឹងការអនុវត្តគោលនយោបាយឧស្សាហកម្ម ម្ខាង ម្ខាងទៀត យើងក៏កំពុងជំរុញអនុវត្តនូវគោលនយោបាយជាតិគាំពារសង្គម**

ដែលចាប់ផ្តើមអនុវត្តដំហានដំបូង គឺនៅក្នុងក្របខ័ណ្ឌកម្មករ ... ជាពិសេស នៅក្នុងក្របខ័ណ្ឌស្ត្រីដែលមានផ្ទៃពោះ ស្ត្រីដែលឆ្លងទន្លេ រហូតទៅដល់មានកម្មវិធីផ្តល់សាច់ប្រាក់ជាជំនួយរបស់រដ្ឋចំពោះស្ត្រី សំដៅកាត់បន្ថយអត្រាស្លាប់របស់មាតា និងទារក និងការបង្កើនអាហារូបត្ថម្ភសម្រាប់កម្មការិនី ក៏ដូចជាមន្ត្រីរាជការរបស់យើងដែលជាស្ត្រី កីឡាការិនីជាស្ត្រីផងដែរ ...។

១៣. រដ្ឋ ម្ចាស់ហាងចក្រ និងកម្មករ ជាមុំចង្រ្កាន ៣ នៃការអភិវឌ្ឍប្រទេស

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់អូដឹម, ៦ ធ្នូ ២០១៧

... សុខដុមភាវូបនីយ៍កម្មវាងម្ចាស់រោងចក្រ កម្មករ/ការិនី ក៏ដូចជាផ្នែករាជរដ្ឋាភិបាល អាចចាត់ទុកថាជា**មុំចង្រ្កាននៃការអភិវឌ្ឍសម្រាប់ប្រទេស។ មុំចង្រ្កាននោះមាន៖ ទី១ គឺផ្នែករដ្ឋ ដែលតំណាងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ផ្នែកទី២ គឺតំណាងដោយផ្នែកឯកជន។ ឯទី៣ គឺមានកម្មករ/ការិនីរបស់យើងនេះតែម្តង។** ទាំង ៣ ផ្នែកនេះ គឺមិនអាចបាត់បង់ផ្នែកណាមួយនោះបានទេ ប៉ុន្តែផ្នែកដែលសំខាន់ជាងគេ គឺផ្នែករដ្ឋតែម្តង។ បើរដ្ឋអស្ថិរភាពហើយ មុំ២ ទៀត គឺមុំកម្មករ និងមុំវិស័យឯកជនដែលធ្វើការនិនិយោគច្បាស់ជាមិនអាចគង់វង្សបាននោះទេ ... (មុំ)ទាំង ៣ នេះ ត្រូវបំពេញឲ្យគ្នាទៅវិញទៅមក។ អ្នកដើរតួគន្លឹះ គឺរាជរដ្ឋាភិបាល។ បើរាជរដ្ឋាភិបាលមិនសម្រេច មិនផ្តល់ឱកាស គ្មានការងារ គ្មានអ្នកវិនិយោគ គ្មានរោងចក្រឲ្យកម្មករ/ការិនីធ្វើ ...។

១៤. គោរពច្បាប់ការងារ ចៀសវាងវិវាទ យោគយល់គ្នាស្រាយបញ្ហាដោយសន្តិវិធី

សំណេះសំណាលជាមួយកម្មករ និយោជិត នៅសួនឧស្សាហកម្មវ្ឌន:ទី១, ១៥ កញ្ញា ២០១៧

... ខ្ញុំរីករាយ ដោយពិនិត្យឃើញថា រយៈពេលចុងក្រោយនេះ លក្ខខណ្ឌការងារតាមរោងចក្រត្រូវបានកែលម្អច្រើន។ ជាមួយនោះ ការដោះស្រាយវិវាទនានា ក៏ត្រូវបានធ្វើ។ ទោះបីថានៅសេសសល់ ក៏ប៉ុន្តែភាពសេសសល់នោះតិចតួច។ តែយើងមិនត្រូវមើលស្រាលរឿងវ៉ាវតិចតួចនោះទេ ... **តាមរយៈទំនាក់ទំនងវិជ្ជាជីវៈទំនាក់ទំនងការងារដែលក្តួយៗបានបំពេញជារៀងរាល់ថ្ងៃ ជាមួយអ្នកគ្រប់គ្រងជាថ្នាក់ក្រុម ថ្នាក់ផ្នែក ជារដ្ឋបាល ឬម្ចាស់រោងចក្រ ពីមួយថ្ងៃៗ ការយល់គ្នា គឺជារឿងល្អ។ បន្តអំពាវនាវឱ្យមានការដោះស្រាយបញ្ហាជាមួយគ្នាដោយសន្តិវិធី ដោយការយោគយល់ និងដោយការស្រឡាញ់គ្នា។ ការបណ្តេញចេញពីការងារ មិនមែនជាដំណោះស្រាយពិតប្រាកដទេ ... វិធីដែលល្អជាងគេ គឺវិធីដែលយើងគោរពច្បាប់ការងារទាំងអស់គ្នា** ...។

១៥. ថ្នាក់ដឹកនាំខេត្តត្រូវនាំមុខដោះស្រាយវិវាទកម្មការជាមួយថៅកែ/ម្ចាងចក្រ

សំណេះសំណាលកម្មករ នៅស្រុកពញាឮ ខេត្តកណ្តាល, ៣ មិថុនា ២០២៣

... សូមបញ្ជាក់ជាមួយ**អស់លោកខេត្តទាំងអស់។ កិច្ចការដែលត្រូវបានប្រគល់ជាបន្តបន្ទាប់ សូមខិតខំដោះស្រាយការមិនចុះសម្រុងណាមួយរវាងកម្មការជាមួយម្ចាស់រោងចក្រ ឱ្យបានលឿនបំផុត។ កុំរង់ចាំតែក្រសួងការងារ។ អស់លោកចៅហ្វាយខេត្តហ្នឹងត្រូវតែនាំមុខ ប្រគល់ឱ្យអនុខេត្តណាមួយធ្វើ។** តាមដានរឿងឱ្យជាប់ជាមួយនឹងមន្ទីរការងារ។ ពេលដែលឃើញថា សំណុំរឿងហ្នឹងត្រូវធ្វើការហ៍ស ត្រូវអញ្ជើញថៅកែរោងចក្រមកនិយាយដោយស្ងាត់ស្ងៀម និងអញ្ជើញកម្មករមកជួបជុំគ្នាដើម្បីដោះស្រាយ។ មានតែវិធីហ្នឹងទេ។ កុំឡើងតុលាការ វារឿងវ៉ាវរ៉ែងធ្ងាយណាស់ ...។

១៦. ស្វែងរកដំណោះស្រាយតាមការសន្ទនានិងអប់រំ ជាងបណ្តេញកម្មការចេញ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល, ២០ កុម្ភៈ ២០១៩

... អំពាវនាវម្ចាស់រោងចក្រកុំប្រើប្រាស់វិធានការបណ្តេញចេញ។ មិនមែនជាមធ្យោបាយទេ។ ការសន្ទនារវាងម្ចាស់រោងចក្រជាមួយសហជីព ជាមួយតំណាងកម្មករ គឺពិតជាវិធីសាស្ត្រដ៏ល្អបំផុត ... **ស្នើឲ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើការងារនេះជាមួយនឹងម្ចាស់រោងចក្រ និងសូមកុំប្រញាប់ប្រញាល់យកវិធានការបញ្ឈប់កម្មករ។ វាមិនមែនជាប្រភេទនៃកំហុសព្រហ្មទណ្ឌនោះទេ។ បើជាកំហុសព្រហ្មទណ្ឌ គឺតុលាការនឹងចាត់វិធានការ ... ប៉ុន្តែ ក្នុងវិវាទការងារ មិនគួរឈានទៅដល់ការបណ្តេញចេញឡើយ ... វិធានការសន្ទនា និងអប់រំ គឺជាវិធានការចាំបាច់** ...។

១៧. បំបាត់ស្ថានភាពបងធំក្នុងរោងចក្រ រក្សាភាពសុខដុមរមនារវាងថៅកែនិងកម្មករ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់កប់ស្រូវ, ១៣ ធ្នូ ២០១៧

... ពូមានការរីករាយ ដោយសង្កេតឃើញថា ពីមួយថ្ងៃទៅមួយថ្ងៃ ការដោះស្រាយបញ្ហាក្នុងចំណោមរោងចក្រសហគ្រាស ភាពសុខដុមរមនារវាងម្ចាស់រោងចក្រ និងកម្មករ/ការិនី រវាងអ្នកដឹកនាំគ្រប់កម្រិតជាមួយកម្មករ/ការិនី កាន់តែល្អទៅៗ ... **ស្ថានភាពបងធំប្រចាំរោងចក្រ ហាក់ដូចជាបានដល់ទីបញ្ចប់ហើយ ... មិនត្រូវឲ្យវាកើតត្រឡប់មកវិញទេ ... បងធំនៅតាមរោងចក្រតែងមានបង្កែបក្សប្រឆាំងនៅក្រោយខ្នង នេះនិយាយឲ្យចំៗ ឬក៏សហជីពមាននិន្នាការប្រឆាំង ... ប៉ុន្តែ រឿងបែបនេះ ក្លួយៗកម្មករ/ការិនីកាន់តែយល់ ហើយការយោគយល់គ្នារវាងម្ចាស់រោងចក្រ ហើយការដោះស្រាយកាន់តែយល់ កាន់តែរហ័ស កាន់តែល្អ** ...៕

១៨. ធ្វើឲ្យរោងចក្រក្លាយជាសហគមន៍មានសុវត្ថិភាព

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់កប់ស្រូវ, ៧ កុម្ភៈ ២០១៨

... ប្រធានរដ្ឋបាល ប្រធានផ្នែក និងប្រធានក្រុមប៉ុន្មានរយនាក់ បានទៅជួបពួយចហើយ។ អ្វីដែលពូចង់និយាយ គឺ**ទំនាក់ទំនងក្នុងការងារ ត្រូវធ្វើយ៉ាងណាធានាថារោងចក្រដែលយើងកំពុងធ្វើការ ក្លាយទៅជាសហគមន៍មួយដែលមានសុវត្ថិភាព គឺទាំងម្ចាស់រោងចក្រ ទាំងអ្នកគ្រប់គ្រង គ្រប់កម្រិត តាំងពីថ្នាក់ក្រម ថ្នាក់ផ្នែក រហូតដល់រដ្ឋបាល ត្រូវមានទំនាក់ទំនងល្អជាមួយកម្មករ។ កម្មករត្រូវមានភាពជាតំណាង ដោយធ្វើឲ្យមានការបំពេញឲ្យគ្នាទៅវិញទៅមក** ... ទាំងអស់គ្នាត្រូវរួមគ្នាដើម្បីការពារនូវឆ្នាំងបាយរបស់ខ្លួន គឺរោងចក្រដែលខ្លួនកំពុងមាននេះ ធ្វើយ៉ាងម៉េចឲ្យរោងចក្រនេះដំណើរការទៅដោយស្រួល ...៕

១៩. រោងចក្រជាសហគមន៍សុខសាន្ត ឈានទៅជោគជ័យនយោបាយភូមិឃុំមានសុវត្ថិភាព

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល, ៤ កក្តដា ២០១៨

... **ទំនាក់ទំនងរវាងកម្មករ និងម្ចាស់រោងចក្រសាមគ្គីគ្នា ទើបអាចក្លាយទៅជាសហគមន៍មួយដ៏សុខសាន្ត** ... ដោយថៅកែរោងចក្រ អ្នកគ្រប់គ្រងរោងចក្រយកចិត្តទុកដាក់ចំពោះកម្មករ។ កម្មករ/ការិនីក៏ត្រូវយកចិត្តទុកដាក់ធ្វើការងារ បង្កើនសមត្ថភាព ហើយក្លាយទៅជាទំនាក់ទំនងដែលពឹងអាស្រ័យគ្នាទៅវិញទៅមក។ ប្រសិនបើយើងធ្វើបានយ៉ាងដូច្នេះ **នយោបាយភូមិឃុំមានសុវត្ថិភាពរបស់យើងវានឹងទទួលជោគជ័យ បើទោះបីជាភូមិឃុំខ្លះមានបញ្ហា ក៏ប៉ុន្តែនៅតាមបណ្តារោងចក្រវាគ្មានបញ្ហានោះទេ** ...៕

២០. មិនមានការចាំបាច់ ដើម្បីបង្កើតឡើងតុលាការការងារ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់កប់ស្រូវ, ៧ កុម្ភៈ ២០១៨

... **យើងមិនមានការចាំបាច់បង្កើតឡើងនូវតុលាការការងារទេ ដោយសារតែយន្តការត្រីភាគី និងបទពិសោធនៃការដោះស្រាយរយៈពេលកន្លងទៅ តាមរយៈការសម្រុះសម្រួលគឺវាគ្រប់គ្រាន់ហើយ។ មិនមានការចាំបាច់ដើម្បីនឹងបង្កើតតុលាការការងារទេ ត្បិតតែបង្កើតតុលាការកាត់ក្តី វាមានអ្នកឈ្នះ មានអ្នកចាញ់។ ដូច្នេះ វាត្រូវរកវិធីដោះស្រាយ ឲ្យបានឈ្នះទាំងអស់គ្នា** ... សង្ឃឹមថាម្ចាស់រោងចក្រ អ្នកគ្រប់គ្រងគ្រប់កម្រិត និងកម្មកររនឹងបន្តរួបរួមគ្នានៅក្នុងក្របខ័ណ្ឌរោងចក្ររបស់ខ្លួន ... ពេលចុះទៅសួរសុខទុក្ខ ខ្ញុំបានពិនិត្យឃើញថា គេមានការសាមគ្គីភាពគ្នាខ្ពស់ ...៕

២១. យកលុយរដ្ឋដោះស្រាយ និងរកការងារឲ្យកម្មកដែលថៅកែរត់ចោល

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ, ២៨ កុម្ភៈ ២០១៨

... ផ្តាំទៅកម្មករ/ការិនីដែលថៅកែរត់ចោលថា **រាជរដ្ឋាភិបាលបានបុរេប្រទានប្រាក់ប្រមាណ៤ លាន៦ សែនដុល្លារ ទៅបើកផ្តល់ឲ្យកម្មករ/ការិនីដែលថៅកែរត់ចោល ... យើងធ្លាប់ធ្វើរឿងនេះកាលពី២០០៧, ២០០៨, ២០០៩ ... ប៉ុន្តែកន្លងទៅទុកឲ្យវាវែយូរបន្តិច ... ឥឡូវ ធ្វើម៉េចឲ្យលុយហ្នឹងបានទៅកម្មករ/ការិនីដែលថៅកែរត់ចោល។ ក្រៅពីនោះ ផ្តៀតរកការងារ ដើម្បីឲ្យក្លួយៗបានធ្វើឡើងវិញ** ... យើងដោះស្រាយជាមួយពួកថៅកែក្រោយ។ យើងចាប់ផ្តើមយកប្រាក់នេះបើកភ្លាម បើកចប់ចុងអាទិត្យហ្នឹងទេមើលទៅ? ... **រដ្ឋសុខចិត្តយកលុយរបស់រដ្ឋ បើកឲ្យក្លួយៗសិនរួចហើយចាំយើងខ្សែឡុងរោងចក្រ** ...៕

២២. កែសម្រួលច្បាប់ដើម្បីបញ្ចប់ ឬកាត់បន្ថយបញ្ហាថៅកែរត់ចោលរោងចក្រ ធ្លាក់បន្ទុកមកលើរាជរដ្ឋាភិបាល

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកពញាឮ ខេត្តកណ្តាល, ២៦ ធ្នូ ២០១៨

... យើងបានកែសម្រួល(ច្បាប់) **ដើម្បីបញ្ចប់ឬកាត់បន្ថយការខាតបង់សម្រាប់កម្មករ/ការិនី ហើយការខាតបង់នោះ វាតែងតែធ្លាក់មកលើរាជរដ្ឋាភិបាល ជាបន្ទុករបស់រាជរដ្ឋាភិបាល ដោយសារករណីម្ចាស់រោងចក្រខ្លះរត់ចោលរោងចក្រ** ... ដែលជំពាក់ប្រាក់ខែកម្មករ និងជំពាក់ប្រាក់អត្ថប្រយោជន៍របស់កម្មករ។ យើងត្រូវ**ធ្វើវិសោធនកម្មច្បាប់ មិនពន្យារនូវការផ្តល់អត្ថប្រយោជន៍សម្រាប់កម្មករ/ការិនីទៀតទេ គឺយើងផ្តល់ឱកាសសម្រាប់រយៈពេល ៦ ខែ ត្រូវទូទាត់ម្តង** ... មកដល់ពេលនេះ បានចុះហត្ថលេខាបញ្ចេញទឹកប្រាក់មួយចំនួន ដែលបានបុរេប្រទានកាលពីពេលមុន ... ចាប់ពីឆ្នាំក្រោយទៅ ហានិភ័យសម្រាប់កម្មករ និងហានិភ័យនោះដែលធ្លាក់ជាបន្ទុករបស់រាជរដ្ឋាភិបាល នឹងត្រូវកាត់បន្ថយ ...៕

២៣. វិបត្តិសេដ្ឋកិច្ចសកល២០០៨ រោងចក្របិទទ្វារ រដ្ឋាភិបាលបង្កើតបន្ទាន់ការបណ្តុះបណ្តាលវិជ្ជាជីវៈ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល, ២០ កុម្ភៈ ២០១៩

... ក្មួយៗ កំពុងទទួលផលប្រយោជន៍ហើយ។ ត្រូវរក្សាផលប្រយោជន៍ក្នុងដៃឲ្យជាប់។ **ឆ្នាំ២០០៨ ពេលវិបត្តិសេដ្ឋកិច្ចហិរញ្ញវត្ថុសកលបានមកដល់។ ការបញ្ចាទិញពីខាងក្រៅជួបប្រទះបញ្ហា ធ្វើឲ្យរោងចក្រមួយចំនួនបិទទ្វារ។ យើងក៏បានបង្កើតជាបន្ទាន់ការបណ្តុះបណ្តាលវិជ្ជាជីវៈ បង្កើតដើមទុនដើម្បីឲ្យកម្មកររកការងារថ្មីនៅកន្លែងថ្មី ទៅបង្កើតមុខរបរថ្មី។ មិនមែនរឿងយើងមិនធ្លាប់ជួបប្រទះទេ កាលពីវិបត្តិសេដ្ឋកិច្ចហិរញ្ញវត្ថុ២០០៨-២០០៩។** ពេលនោះ យើងបិទរោងចក្រមួយចំនួនដែលកម្មករបាត់បង់ការងារ។ ឥឡូវយើងមិនទុកឲ្យរោងចក្រត្រូវបិទទ្វារទេ។ យើងត្រូវរកដំណោះស្រាយ។ ថ្ងៃទី២៩ ខែមីនា ខាងមុខនេះ វេទិការាជរដ្ឋាភិបាល និងវិស័យឯកជនត្រូវចាប់ផ្តើមពិភាក្សាថែមទៀត ...៕

២៤. ពង្រាយរោងចក្រមកតាមមូលដ្ឋាន សម្រួលការដោះស្រាយពលកម្ម

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់7NG, ១៦ វិច្ឆិកា ២០១៧

... **ឆ្នាំ១៩៩៩ យើងបានផ្តួចផ្តើមគំនិតធ្វើវេទិការាជរដ្ឋាភិបាលជាមួយវិស័យឯកជន។ យើងក៏បានចាប់ផ្តើមនិយាយពីការពង្រាយបណ្តារោងចក្រទៅកាន់មូលដ្ឋាន កុំឲ្យប្រមូលផ្តុំតែនៅក្នុងទីក្រុងភ្នំពេញ គឺត្រូវរៀបចំឲ្យមានតាមខេត្តដើម្បីងាយដោះស្រាយកម្លាំងពលកម្ម** ... មុននោះយើងគ្រាន់តែធ្វើកម្មវិធីបញ្ជូននូវសាលារៀន ឲ្យទៅកៀកបំផុតជាមួយនឹងកូនសិស្សនៅតាមមូលដ្ឋាន ... បន្ទាប់ពីការបញ្ជូនសាលា យើងក៏ចាប់ផ្តើមមានចក្ខុវិស័យស្តីពីការផ្តើមបញ្ជូនរោងចក្រទៅកាន់តំបន់ដែលអាចធ្វើបាន ... ការពង្រាយរោងចក្រចេញពីក្រុង ... មិនមែនបានសេចក្តីថា ត្រូវតែរើរោងចក្រចេញពីទីក្រុងភ្នំពេញ និងធ្វើឲ្យកម្មករដែលមានចំនួនច្រើននៅទីក្រុងភ្នំពេញបាត់បង់ការងារធ្វើនោះទេ ... យើងលើកទឹកចិត្តបង្កើតរោងចក្រតាមខេត្ត ...៕

២៥. ខំកសាងហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែកទន់និងរឹង ដើម្បីរុញរោងចក្រមកកាន់មូលដ្ឋាន

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់កប់ស្រូវ, ១៣ ធ្នូ ២០១៧

... តាមរយៈការខំស្វែងរកសន្តិភាព **ខិតខំកសាងនូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង ដែលរួមមានផ្លូវ មានកំពង់ផែ មានអាកាសយានដ្ឋាន មានអគ្គិសនី និងមានផ្នែកដទៃទៀត បម្រើឲ្យការទាក់ទាញវិនិយោគ យើងក៏បានខិតខំកសាងនូវហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ ទាក់ទងនឹងការកសាងច្បាប់ ទាក់ទងនឹងលិខិតបទដ្ឋាននានា ហើយជាពិសេស គឺការបណ្តុះបណ្តាលធនធានមនុស្ស** ... ឥឡូវនេះ មានខេត្តមួយចំនួន រោងចក្របានទៅដល់ មិនចាំបាច់ក្មួយៗមកធ្វើការនៅទីក្រុងភ្នំពេញទេ ... វត្តមានរោងចក្រទាំងនេះចាំបាច់ ដើម្បីផ្តល់ឱកាសការងារធ្វើសម្រាប់ប្រជាពលរដ្ឋរបស់យើង ...៕

២៦. កំណើននិងការងារ មុំពីរនៃយុទ្ធសាស្ត្រចតុកោណ

សំណេះសំណាលជាមួយកម្មករ និយោជិត មកពីខេត្តកណ្តាល និងភ្នំពេញ នៅពហុកីឡដ្ឋានមរតកតេជោ, ២៤ មិថុនា ២០២៣

... រាជរដ្ឋាភិបាលត្រូវបង្កើតឱកាសការងារសម្រាប់ប្រជាពលរដ្ឋ។ **យុទ្ធសាស្ត្រចតុកោណ មានមុំកំណើននិងការងារ ... មុំពីរដំបូងរុញឱ្យមានកំណើនសេដ្ឋកិច្ច និងបង្កើតការងារធ្វើ។ មិនមែនជារឿងកញ្ជក់កណ្តៀតទេ។ គណបក្សប្រជាជនមានការគិតគូច្បាស់លាស់។ សូម្បីតែការទាក់ទាញវិនិយោគទៅតាមខេត្តក៏បានតម្រង់ទិសជាបន្តបន្ទាប់។** ឥឡូវផ្តល់សិទ្ធិអំណាចទៅខេត្តកាន់តែច្រើន ដើម្បីឲ្យខេត្តមានសិទ្ធិសម្រេចទៅលើបញ្ហាការបង្កើតរោងចក្រ សហគ្រាសនៅតាមខេត្ត

ក្នុងទុនមិនលើសពី ៥លានដុល្លារ ដោយសុំការអនុម័តត្រឹមតែខេត្តនោះបានហើយ។ យើងត្រូវឃើញចំណុចនេះ ...៕

២៧. គ្មានរោងចក្រនៅមូលដ្ឋាន ឬមួយបន្តជាកសិករ ឬជាកម្មការដែលឃ្លាតឆ្ងាយពីគ្រួសារ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅក្រុងដូនកែវ ខេត្តតាកែវ, ២០ មិថុនា ២០១៨

... សន្តិភាពនោះហើយ ដែលមានឱកាសទាក់ទាញអ្នកវិនិយោគទាំងឡាយមកវិនិយោគនៅកម្ពុជា។ ពេលនេះ រោងចក្របានមកដល់ទីកន្លែងរបស់ក្មួយៗ ផ្តល់ឱកាសឲ្យក្មួយៗបានរកការងារធ្វើ មិននៅឆ្ងាយពីផ្ទះពេក ... **ប្រសិនបើមិនមានរោងចក្រនៅតាមបណ្តាស្រុក ក្នុងខេត្តទេ តើក្មួយៗកម្មករ/ការិនីនៅពេលនេះកំពុងធ្វើអី ? មានចម្លើយតែពីរទេ។ ទី១ ពេលនេះ ក្មួយកំពុងស្ថិតនៅក្នុងក្រុងភ្នំពេញ ចាកចេញពីស្រុកកំណើតទៅរកការងារធ្វើ ... ឯទី២ គឺក្មួយកំពុងតែធ្វើស្រែចម្ការជាមួយឪពុកម្តាយ និងក្រុមគ្រួសារ** មិនមែនជាកម្មករតាមរោងចក្រដែលមានប្រាក់បៀវត្សកាន់តែខ្ពស់ទៅៗនោះទេ ...៕

២៨. រក្សាការងារចាស់និងបង្កើតការងារថ្មីបន្ថែមផង

សំណេះសំណាលជាមួយកម្មករ និយោជិត នៅក្រុងបាវិត ខេត្តស្វាយរៀង, ៩ ឧសភា ២០១៨

... **យើងត្រូវបន្តខិតខំរក្សាការងារនិងបង្កើតការងារ។** ក្មួយៗមានការងារធ្វើហើយ តែត្រូវខិតខំជានាថា ការងារទាំងនោះនៅតែបន្ត និងនៅតែទទួលបានប្រាក់ចំណូល។ យើងមានការចាំបាច់នឹងទាក់ទាញមកនូវរោងចក្រថ្មីៗបន្ថែមទៀត ដើម្បីបង្កើតការងារធ្វើ។ ក្នុងរយៈកាល ៤ ខែ ដើមឆ្នាំកន្លងទៅ យើងទទួលបានការវិនិយោគ ដែលដោះស្រាយកម្មករប្រមាណជាជិត២ ម៉ឺននាក់បន្ថែម ... **ក្មួយៗមានការងារធ្វើហើយ ប៉ុន្តែប្អូនរបស់ក្មួយៗ ឬក៏មិត្តភក្តិរបស់ក្មួយៗ មិនទាន់មានការងារធ្វើទេ។ ដូច្នេះ យើងត្រូវទាក់ទាញការវិនិយោគបន្ថែមទៀតមកកាន់កម្ពុជា ហើយដើម្បីឲ្យមានការវិនិយោគ គឺត្រូវឲ្យមានសន្តិភាព** ...៕

២៩. ពង្រីកសមត្ថភាពអ្នកវិនិយោគមានស្រាប់ និងទាក់ទាញអ្នកវិនិយោគថ្មី

សំណេះសំណាលជាមួយកម្មករ និយោជិត មកពីខេត្តកណ្តាល និងភ្នំពេញ នៅពហុកីឡដ្ឋានមរតកតេជោ, ២៤ មិថុនា ២០២៣

... ត្រូវខិតខំធ្វើម៉េច**ពង្រីកសមត្ថភាពកន្លែងចាស់និងទាញមកថែមថ្មី។ យើងត្រូវធ្វើដោយដៃទាំងពីរ។ មួយផ្នែក រោងចក្រដែលមានស្រាប់ តាមរយៈវិធានការពន្ធជារួមយ៉ាងណាមួយ លើកទឹកចិត្តឲ្យគេពង្រីកថែម ដោយយកប្រាក់ដែលចំណេញនោះ ឬទាញយកផលប្រយោជន៍ពីវិនិយោគនៅប្រទេសនេះ/នោះ មកវិនិយោគបន្ថែមនៅក្នុងប្រទេសកម្ពុជា**។ ពីដើមគេទទួលកម្មករតែ ៥ពាន់នាក់ទេ។ ពេលគេពង្រីកសមត្ថភាព គេអាចទទួលកម្មករបានរហូត ១ម៉ឺននាក់។ **ឯមួយផ្នែកទៀត ទាញអ្នកវិនិយោគថ្មីៗ មកបង្កើតរោងចក្រ សហគ្រាសនៅក្នុងស្រុក។** បើយោងទៅលើការពិនិត្យ ធ្វើយ៉ាងម៉េចឲ្យបង្កើតការងារធ្វើបានក្នុងចន្លោះពី ២០ទៅ៣០ ម៉ឺនកន្លែងក្នុងមួយឆ្នាំ ទើប(អាចដោះស្រាយ)វិបត្តិអត់ការងារធ្វើ ...៕

៣០. រកមធ្យោបាយឲ្យរោងចក្រចំណាយតិច យកប្រាក់ចំណេញបង្កើនបៀវត្ស

សំណេះសំណាលជាមួយកម្មករ និយោជិត នៅក្រុងដូនកែវ, ២០ មិថុនា ២០១៨

... រាជរដ្ឋាភិបាលកំពុង**រកគ្រប់វិធីធ្វើឲ្យម្ចាស់រោងចក្រចំណាយកាន់តែតិច ដើម្បីជួយឲ្យម្ចាស់រោងចក្រនោះប្រើប្រាស់ប្រាក់ចំណេញបង្កើនបៀវត្សរ៍ចំពោះកម្មករ។ ដូចជាយើងកំពុងគិតគូរអំពីថ្លៃអគ្គិសនីសម្រាប់វិស័យឧស្សាហកម្ម ដើម្បីធ្វើឲ្យអគ្គិសនីមានតម្លៃថោក ដែលអាចអគ្គិសនីក៏រស់រានបាន និងផ្នែកឧស្សាហកម្មក៏អាចរស់រានបាន**។ បន្ថែមលើនោះ យើងគិតគូរទៅលើបញ្ហាដទៃរាប់ទាំងការគិតគូរលើការដឹកជញ្ជូន សម្រួលការធ្វើពាណិជ្ជកម្មជាដើម ដើម្បីកាត់បន្ថយការចំណាយថ្លៃដើមទៅលើការផលិត ...៕

៣១. ធ្វើបា្បប់ទាក់ទងនឹងបៀវត្សរ៍អប្បបរមា ជាមូលដ្ឋានឱ្យយន្តការត្រីភាគីធ្វើការចរចា

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ចាក់អង្រែលើ, ២៧ កញ្ញា ២០១៧

... យន្តការត្រីភាគីបានកំពុងបន្តពិភាក្សាពីបញ្ហាបៀវត្សរបស់កម្មករ/ការិនីសម្រាប់ឆ្នាំ២០១៨។ គួររំលឹកអំពីប្រវត្តិរបស់យើងបន្តិច ដើម្បីឱ្យយើងយល់ថាតើប្រវត្តិនៃវិស័យឧស្សាហកម្មរបស់កម្ពុជារបៀបណា ? កម្មករ/ការិនីរបស់កម្ពុជាមានបៀវត្សរ៍អប្បបរមាចំនួន ១៥៣ ដុល្លារសហរដ្ឋអាមេរិក។ **ខ្ញុំមិនដឹងថា តើនៅពេលខាងមុខនេះ ការចរចារបស់យើងនឹងឡើងដល់ប៉ុន្មាន ? ក៏ប៉ុន្តែ ខ្ញុំហ៊ានប្រកាសថា បៀវត្សរ៍អប្បបរមារបស់កម្មករ/ការិនីមិនត្រូវឱ្យទាបជាង ១៦០ ដុល្លារ**

សហរដ្ឋអាមេរិកនោះទេ។ បៀវត្សរ៍នេះនឹងត្រូវឡើងជារៀងរាល់ឆ្នាំ។ យើងកំពុងតែធ្វើច្បាប់ទាក់ទងនឹងបៀវត្សរ៍អប្បបរមា ជាមូលដ្ឋានឱ្យយន្តការត្រីភាគីសម្រាប់ធ្វើការចរចា ...៕

៣២. មិនឲ្យបៀវត្សរ៍អ្នកទីក្រុងនិងអ្នកជនបទខុសគ្នាទេ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកក្រគរ ខេត្តពោធិ៍សាត់, ៣០ មិថុនា ២០២៣

... ចំណោទដែល**យើងខំដោះ គឺមិនឲ្យមានការខុសគ្នារវាងប្រាក់បៀវត្សទីក្រុងនិងជនបទទេ។** ខុសប្លែកពីប្រទេសដទៃ។ ប្រទេសខ្លះមាន ២តំបន់ ខ្លះទៀតមាន ៣តំបន់។ តំបន់ទីក្រុងប្រាក់ខែខ្ពស់ជាង តំបន់ជនបទប្រាក់ខែទាបជាង។ នៅកម្ពុជាប្រាក់ខែគោល បើថា ២០០ដុល្លារ គឺ ២០០ដុល្លារមួយប្រទេសតែម្តង។ នេះជាចំណុចពិសេស។ ខ្ញុំទៅប្រទេសច្រើន។ ប្រទេសជិតខាងនៅក្នុងតំបន់ ក៏មានការកំណត់ប្រាក់ខែខុសគ្នានៅតាមតំបន់។ **កម្ពុជាយកចិត្តទុកដាក់លើបញ្ហានេះព្រោះបើមិនអញ្ចឹងទេអ្នកជនបទរត់សំដៅទៅនៅទីក្រុងដើម្បីរកការងារ ...៕**

៣៣. ក្នុងស្ថានភាពកូវីដ-១៩ ឆ្នាំ២០២១និង២០២២ កម្មកររនៅតែទទួលបានការដំឡើងប្រាក់បៀវត្ស

សំណេះសំណាលជាមួយកម្មករ និយោជិត និងដាក់ឱ្យដំណើរការរោងចក្រផលិតសំបកកង់ ឧបលើកទី១០គំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ, ២២ ឧសភា ២០២៣

... ដោយសារស្ថានភាពកូវីដ-១៩ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធទូទាំងប្រទេស **នៅឆ្នាំ២០២១ និងឆ្នាំ២០២២ មិនបានដំឡើងបៀវត្សរ៍ទេ។ ប៉ុន្តែសម្រាប់កម្មករ/ការិនីនៅទូទាំងប្រទេស គឺបានទទួលការដំឡើង។** បើទោះបីជាដំឡើងតិចក៏ដោយ តែយើងបានដំឡើង។ រហូតមកដល់ពេលនេះ គឺយើងបានឡើងទៅដល់ចំនួន ២០០ដុល្លារសហរដ្ឋអាមេរិកហើយ។ បើយើងពិនិត្យអំពីការចាប់ផ្តើមរបស់យើងកាលពីដំបូង ... ឧស្សាហកម្មនៅក្នុងប្រទេសចាប់ផ្តើមពីរៀមច្បងរបស់យើង ដែលចូលធ្វើការក្នុងមួយខែបានតែជាង៤០ដុល្លារទេ គឺមួយថ្ងៃបានតែជាង១ ដុល្លារតែប៉ុណ្ណោះ ...៕

៣៤. អំឡុងពេលកូវីដ-១៩ រដ្ឋាភិបាលផ្តល់កម្រៃទ្រទ្រង់ ៧០ដុល្លារ/ខែ លើកលែងកាតព្វកិច្ចមួយចំនួន

សំណេះសំណាលកម្មករ នៅស្រុកពញាឮ ខេត្តកណ្តាល, ៣ មិថុនា ២០២៣

... រាជរដ្ឋាភិបាលបានធ្វើចំណាត់ការដោះស្រាយឲ្យក្លួយៗកម្មករ/ការិនីមានឱកាសទទួលបានប្រាក់កម្រៃក្នុងកម្រិតមួយ ដែលអាចទ្រទ្រង់ជីវភាពក្នុងដំណាក់កាលដ៏លំបាក។ **យើងបានផ្តល់ចំពោះកម្មករ/ការិនីក្នុងវិស័យកាត់ដេរ និងដេរស្បែកជើងចំនួន ៧០ដុល្លារ ដែលក្នុងនោះ ៤០ដុល្លារទទួលពីរាជរដ្ឋាភិបាលនិង ៣០ ដុល្លារទទួលពីនិយោជកពីម្ចាស់រោងចក្រ** ... លើកលែងកាតព្វកិច្ចមួយចំនួនដែលម្ចាស់រោងចក្រត្រូវធ្វើបំពេញ។ យើងមានការបន្ទូរបន្ថយថវិកាបង់ពន្ធឲ្យរដ្ឋ បើមិនដូច្នេះរោងចក្រដំណើរការទៅមិនរួច...៕

៣៥. រំកិលពិដានថ្នាក់ប្រាក់បៀវត្សរ៍ជាប់ពន្ធទៅ ចាប់ពី១ លាន២ សែនរៀលឬ៣០០ ដុល្លារឡើង

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ផ្លូវវែងស្រែង, ១១ តុលា ២០១៧

... ក្នុងគោលបំណងបង្កើនប្រាក់ចំណូលមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ក៏ដូចជាចំពោះកម្មករ/ការិនីដែលមានប្រាក់បៀវត្សទាបជាង១២០ ម៉ឺនរៀល ឬស្មើនឹង ៣០០ ដុល្លារ ... **រាជរដ្ឋាភិបាលនឹងដាក់ទៅក្នុងច្បាប់ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងនៅឆ្នាំ២០១៨ ដំឡើងអត្រាប្រាក់ចំណូលជាប់ពន្ធពីចំនួនពី ១ លានរៀល ទៅកាន់ ១ លាន២ សែន រៀល។ នេះជាផលប្រយោជន៍សម្រាប់អ្នកដែលមានបៀវត្សរ៍ទាបជាង៣០០ ដុល្លារសហរដ្ឋអាមេរិក** ... នេះជាវប្បធម៌បង់ពន្ធសម្រាប់ប្រជាពលរដ្ឋនៅគ្រប់ប្រទេសទាំងអស់។ តាមរយៈពន្ធដារនេះហើយ ដែលរដ្ឋមានប្រាក់ចំណូល ហើយវាក៏ជាផ្នែកនៃការទទួលបាននូវអត្ថប្រយោជន៍នៅពេលដែលយើងចូលនិវត្តន៍ ហើយដែលមានប្រាក់សោធននិវត្តន៍ ...៕

៣៦. ត្រូវពិនិត្យប្រាក់ឈ្នួលកម្មកររប្រទេសដទៃឲ្យទៀងទាត់ ព្រោះជាការប្រកួតប្រជែង

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ព្រៃទា, ១៧ មករា ២០១៨

... បើយើងពិនិត្យមើលកំណើនប្រាក់ចំណូលរបស់ក្លួយៗ ដែលជាកម្មករ/ការិនីជាមួយនឹងប្រាក់ឈ្នួលអប្បបរមា បូកនឹងអត្ថប្រយោជន៍ដទៃទៀត គឺភាគច្រើនទទួលបានលើសពី២០០ ដុល្លារសហរដ្ឋអាមេរិក ក្នុងពេលដែលប្រទេសមួយ

ចំនួនមានប្រាក់ឈ្នួលទាបជាងយើងពាក់កណ្តាលឯណោះ។ ប៉ុន្តែស្ថានភាពប្រទេសនីមួយៗ មិនដូចគ្នាទេ។ ដូចជានៅបង់ក្លាដេស ប្រាក់ឈ្នួលមានត្រឹមតែ ៦៧ ដុល្លារ ... នៅឡាវមានប្រាក់ឈ្នួលត្រឹមតែ ១១០ ដុល្លារ។ **ឥឡូវនេះ គេក៏អាចមានការប្រែប្រួលកើនឡើងដែរ។ យើងត្រូវតាមពិនិត្យទៀងទាត់ ព្រោះនេះក៏ជាការប្រកួតប្រជែងមួយលើវិស័យកាត់ដេរ និងវាយនកណ្តា ជាវិស័យនាំមុខដោះស្រាយការងារធ្វើសម្រាប់ប្រជាពលរដ្ឋ និងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ** ...៕

៣៧. ប្រាក់ចំណូលកម្មករកម្ពុជាបានឆ្លងផុតបន្ទាត់នៃភាពក្រីក្រ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅក្រុងតាខ្មៅ ខេត្តកណ្តាល, ៧ មីនា ២០១៨

... អ្វីទៅដែលគេហៅថា អ្នកលើបន្ទាត់ភាពក្រីក្រ? កាលពីមុននោះ អ្នករកបានចំណូលបាន១ ដុល្លារក្នុងមួយថ្ងៃ ត្រូវបានអង្គការសហប្រជាជាតិចាត់ទុកថារួចផុតពីបន្ទាត់នៃភាពក្រីក្រ។ តាមការកំណត់ថ្មី (ត្រូវរកចំណូលអោយបាន)១ ដុល្លារ ២៥សេន ទើបរួចផុតពីភាពក្រីក្រ។ ឥឡូវនេះ ក្មួយៗអាចរកបានក្នុងមួយថ្ងៃមិនតិចជាង៥ ដុល្លារទេ ... មិនទាន់គិតអំពីប្រាក់អត្ថប្រយោជន៍ដទៃទៀត។ ដូច្នេះ សម្រាប់កម្មករ/ការិនី ដែលធ្វើការនៅតាមបណ្តារោងចក្រ សហគ្រាស នៅតាមបណ្តាក្រុមហ៊ុននានា ទាំងផ្នែកសេវា រាប់ទាំងផ្នែកទេសចរណ៍ **ទទួលប្រាក់បៀវត្សចំនួនលើសអំពីការកំណត់នៃអង្គការសហប្រជាជាតិ**។ និយាយយ៉ាងដូច្នេះ មិនមែនបានសេចក្តីថាវាគ្រប់គ្រាន់ទេ។ យើងត្រូវការប្រាក់ចំណូលច្រើនជាងនេះ ...៕

៣៨. ចាប់ពីឆ្នាំ២០១៩ បើកបៀវត្សរ៍ប្រចាំសប្តាហ៍ម្តង (ពីរអាទិត្យបើកម្តង)

សំណេះសំណាលជាមួយកម្មករ និយោជិត នៅសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ, ២៩ សីហា ២០១៨

... បណ្តាក្រុមហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ត្រៀមទុកឲ្យហើយ **នៅឆ្នាំ២០១៩ យើងមិនបើកបៀវត្សរ៍ប្រចាំខែទេ។ យើងបើកបៀវត្សរ៍ប្រចាំសប្តាហ៍ម្តង។ បានសេចក្តីថា២ អាទិត្យបើកម្តង ... នៅពេលបើកយុទ្ធនាការបោះឆ្នោត ខ្ញុំបានប្រកាសចេញថា ចាប់ពីឆ្នាំ២០១៩ ទៅ ត្រូវបើកបៀវត្សរ៍ពីរអាទិត្យម្តង** ... ត្រូវយកចិត្តទុកដាក់ទៅលើបញ្ហានេះ ដែលយើងត្រូវបន្តឲ្យគ្រប់

មិនមែនគ្រាន់តែធ្វើតែផ្នែករដ្ឋទេណា ខាងវិស័យឯកជនក៏ត្រូវតែបើកបៀវត្សរ៍ឲ្យកម្មកពីរអាទិត្យម្តង ... (ចំពោះ)ប្រាក់ឧបត្ថម្ភ មិនមែនប្រាក់បៀវត្ស ព្រោះមានមន្ត្រីមួយចំនួន និងចាស់ៗមួយចំនួន ខ្ញុំចិញ្ចឹមប្រចាំខែ។ អញ្ចឹងមិនអាចឲ្យគាត់មកបើកពីរអាទិត្យម្តងទេ បើប្រាក់បៀវត្សចាំបើកពីរអាទិត្យម្តង ...៕

៣៩. អនុញ្ញាតបើកប្រាក់ខែជារូបិយបណ្ណបរទេស ការពារមិនឲ្យបាត់បង់កម្លាំងទិញ

សំណេះសំណាលជាមួយកម្មករ មកពីខេត្តកណ្តាលនិងរាជធានីភ្នំពេញ នៅពហុកីឡដ្ឋានមរតកតេជោ, ២៤ មិថុនា ២០២៣

... ក្មួយៗ មិនបាត់បង់តម្លៃ (កម្លាំងទិញ)និងបង្កើតលក្ខណៈងាយស្រួលសំរាប់ថៅកែរោងចក្រផងដែរ ដោយអនុញ្ញាតឲ្យថៅកែរោងចក្រ ម្ចាស់ក្រុមហ៊ុនបើកផ្តល់ប្រាក់បៀវត្សជារូបិយបណ្ណបរទេស។ ប្រទេសដទៃមិនអាចធ្វើដូចប្រទេសយើងទេ ... **នៅកម្ពុជា កម្មករមិនមែនអ្នកខាតទេ ដោយសាររាជរដ្ឋាភិបាលបានឲ្យថៅកែរោងចក្រម្ចាស់ក្រុមហ៊ុនបើកផ្តល់រូបិយបណ្ណបរទេសត្រង់ទៅកម្មករ**។ នៅលើទីផ្សាររបស់យើង សម្បុរូបិយបណ្ណបរទេស មានទាំងដុល្លារ ទាំងអឺរ៉ូ ទាំងដុល្លារសិង្ហបុរី ទាំងប្រាក់បាតនៅតាមតំបន់កៀកព្រំដែនថៃ មានទាំងប្រាក់យន់របស់ចិន មានប្រាក់យេនរបស់ជប៉ុនទៀត ...៕

៤០. ទាមទារហួសហេតុ គេប្តូរោងចក្រទៅប្រទេសដទៃ កម្មករជាអ្នកខាតបង់

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ចាក់អង្រែលើ, ២៧ កញ្ញា ២០១៧

... យើងមិនត្រូវអារកមាន់ សម្លាប់មេមាន់ ដើម្បីធ្វាញ់មួយពេលទេ រួមគ្នាចិញ្ចឹមមេមាន់ឱ្យបានល្អដើម្បីយកពងរបស់វា ឬក៏យក(កូន)របស់វាចិញ្ចឹមបន្ត។ ខ្ញុំចង់និយាយថា **ប្រសិនបើយើងទាមទារហួសហេតុ ម្ចាស់រោងចក្រមិនអាចទ្រាំទ្របាន គេនឹងដករោងចក្រពីប្រទេសយើង**ទៅកាន់ភូមា ទៅកាន់ឡាវ ទៅបង់ក្លាដេស ឬទៅឥណ្ឌា ឬទៅប្រទេសផ្សេងៗ ... **តើផលវិបាកធ្លាក់ទៅអ្នកណា? ផលវិបាកគឺកម្មកររអត់មានការងារធ្វើ ជាមួយនឹងការបាត់បង់ប្រាក់ចំណូលដែលខ្លួនបាននិងកំពុងទទួល** ... គប្បីមានការពិភាក្សាក្នុងស្មារតីស្ថាបនា ...៕

៤១. កម្មករ/ការិនី និងកីឡាករ/ការិនី ពិនិត្យសុខភាព និងជិះឡានក្រុងឥតគិតថ្លៃ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ផ្លូវវែងស្រែង, ១១ តុលា ២០១៧

... សូមប្រកាសជូនថា **ចាប់ពីខែមករា២០១៨ តទៅ កម្មករគ្រប់ផ្នែកទាំងអស់ ទាំងក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ ត្រូវទទួលបានការពិនិត្យព្យាបាលដោយឥតគិតថ្លៃ នៅតាមមន្ទីរពេទ្យរដ្ឋ ដោយរដ្ឋជាអ្នកបង់ថ្លៃជំនួស តាមរយៈមូលនិធិសមធម៌ ដែលបាននិងកំពុងអនុវត្ត មានមនុស្សចូលរួមជាង៣ លាននាក់រួចហើយ**។ សូមអំពាវនាវឲ្យសហគ្រាសនានាមកចុះបញ្ជីបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ដើម្បីឲ្យកម្មករ/ការិនីទទួលបានអត្ថប្រយោជន៍ពីគោលនយោបាយនេះ ... **កីឡាករ/ការិនីដែលមានការទទួលស្គាល់ជាក់លាក់ពីសហព័ន្ធកីឡាជំនាញ និងពីគណៈកម្មាធិការអូឡាំពិកកម្ពុជា នឹងត្រូវបានអនុញ្ញាតឲ្យជិះរថយន្តក្រុងដោយមិនបាច់បង់ប្រាក់ ដូចជាកម្មករ/ការិនី ក្នុងរយៈយ៉ាងតិច២ ឆ្នាំ ... ទទួលបានការពិនិត្យព្យាបាលឥតគិតថ្លៃតាមមន្ទីរពេទ្យរដ្ឋ ដូចកម្មករ/ការិនីផងដែរ** ...។

៤២. សូមអនុញ្ញាតកម្មការិនីមានផ្ទៃពោះ/ជនពិការ ចេញមុនម៉ោងយ៉ាងហោចទី១៥ នាទី

សំណេះសំណាលជាមួយកម្មករ និយោជិត នៅសំរោងទង និងគងពិសី, ខេត្តកំពង់ស្ពឺ, ១៧ មិថុនា ២០២៣

... សំណូមពរឱ្យ**ម្ចាស់រោងចក្រផ្តល់នូវការយោគយល់សម្រាប់កម្មការិនីមានផ្ទៃពោះ ឱ្យបានចេញមុនយ៉ាងតិច ១៥នាទី។ ឥឡូវលឺថា មានរោងចក្រខ្លះគឺឱ្យចេញមុនម៉ោងរហូតដល់ទៅ ១ម៉ោងដើម្បីទៅបំបៅកូន សម្រាប់អ្នកមានកូនខ្ចី** ... កម្មករ/ការិនីជាជនពិការ(ក៏)ត្រូវបានចេញមុនម៉ោង១៥ នាទី ដូចស្ត្រីមានផ្ទៃពោះដែរ។ (ដូចនេះ)មិនមែនដើរមក គ្រាន់តែដើម្បីដើរទេ ប៉ុន្តែជាការដើរពិនិត្យថាមើលតើអ្វីខ្លះដែលបានដាក់ចេញទៅហើយ និងអនុវត្តបានឬទេ? អ្វីដែលនៅខ្វះយើងត្រូវបំពេញ ...។

៤៣. កម្មការិនីឆ្លងទន្លេបានបៀវត្សរ៍១២០% សម្រាក៣ ខែ និងឧបត្ថម្ភជាសាច់ប្រាក់

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ចាក់អង្រែលើ, ២៧ កញ្ញា២០១៧

... ម្យ៉ាងទៀត **កម្មការិនីដែលឆ្លងទន្លេនឹងត្រូវទទួលបានបៀវត្សរ៍១២០% និងការឈប់សម្រាករយៈពេល៣ ខែ ... ក្នុងនោះ ចេញដោយបេឡាជាតិសន្តិសុខសង្គម៧០% និងចេញដោយនិយោជក៥០%** ... មួយផ្នែកទៀត នេះជាការចាប់ផ្តើមអនុវត្តនូវអ្វីដែលខ្ញុំបាននិយាយនៅពេលសម្ពោធដាក់ឲ្យប្រើកម្មវិធីជាតិ

គាំពារសង្គមថា ត្រូវអនុវត្តចំពោះស្ត្រីមានផ្ទៃពោះជាមុន ... **ក្នុងចំណោមកម្មករជាស្ត្រីឆ្លងទន្លេ មានកម្មវិធីផ្តល់សាច់ប្រាក់ក្នុងម្នាក់ សំរាប់បានកូនមួយទទួលបានប្រាក់ចំនួន៤០ ម៉ឺនរៀល ស្មើនឹង១០០ ដុល្លារសហរដ្ឋអាមេរិក** ... យើងត្រៀមបញ្ចូលថវិកាប្រមាណ១០ លានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំក្នុងកញ្ចប់ថវិកាជាតិសម្រាប់ផ្នែកកម្មការិនីឆ្លងទន្លេ ...។

៤៤. ផ្តល់សាច់ប្រាក់ចំពោះស្ត្រីមានផ្ទៃពោះ ៤០ម៉ឺនរៀល ពេលសម្រាលកូនមួយ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ភ្នំពេញថ្មី, ២២ វិច្ឆិកា ២០១៧

... បន្ថែមពីលើនោះ ចាប់ពីសូន្យម៉ោង ថ្ងៃ១ ខែមករា (២០១៨) តទៅ ... រាជរដ្ឋាភិបាលនឹងផ្តល់សាច់ប្រាក់ជូនកម្មការិនីដែលឆ្លងទន្លេ ... **កូនមួយបាន៤០ ម៉ឺនរៀល ស្មើនឹង១០០ ដុល្លារ, បានកូន(ភ្លោះ)២ បាន៨០ ម៉ឺនរៀល, ឯកូនភ្លោះ ៣ គឺបាន១លាន២ សែនរៀលពីរដ្ឋ និងបាន៥ លានរៀលពី ហ៊ុន សែន។ ដោយសារចំនួននេះមិនច្រើន ខ្ញុំសូមប្រកាសថាអ្នកណាបានកូនភ្លោះបីបាន៥ លានរៀល ពី ហ៊ុន សែន តែម្តង។ ទូទាំងប្រទេស តាំងពី១៩៩៥ រហូតមកដល់ឥឡូវ ទើបតែបានជាង៣០០ ករណីទេ។ មិនងាយអ្នកណាបានកូនភ្លោះបីទេ ... កូនភ្លោះ៤ បានដល់១០ លានរៀលឯណោះ**។ ប៉ុន្តែ រឿងរដ្ឋផ្សេង និងរឿងខ្ញុំជាឯកជនផ្សឹង។ ពេលណាខ្ញុំមិននៅបន្ត(កាន់អំណាច)ទេ ខ្ញុំអត់បន្តទេ ...។

៤៥. ទោះកូនរស់ឬស្លាប់ ស្ត្រីឆ្លងទន្លេត្រូវទទួលបានការឧបត្ថម្ភ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ចាក់អង្រែលើ, ២៧ កញ្ញា ២០១៧

... សូមអំពាវនាវចំពោះសហគ្រាសទាំងឡាយ ដែលនៅក្រៅប្រព័ន្ធមិនទាន់បានចុះបញ្ជី ឲ្យប្រញាប់ប្រញាល់មកចុះបញ្ជី ដើម្បីឲ្យកម្មករ/ការិនីទទួលបានផលប្រយោជន៍ពីអ្វីដែលជាគោលនយោបាយរបស់រាជរដ្ឋាភិបាល ទៅលើកិច្ចគាំពារសង្គម ពិសេសលើបញ្ហាការពិនិត្យសុខភាព លើបញ្ហាទាក់ទិនជាមួយនឹងមធ្យោបាយដឹកជញ្ជូន ក៏ដូចជាលើបញ្ហាកម្មការិនីដែលត្រូវឆ្លងទន្លេ។ **ខ្ញុំក៏សូមលើកស្ត្រីខ្លះគ្នាឆ្លងទន្លេទៅ គាប់ជួនកូនមិនរស់។ តើត្រូវបានប្រាក់ ឬអត់? វាពិតជាត្រូវបាន។ ទោះបីកូនរស់ ឬស្លាប់ ប្រាក់គឺត្រូវបានដូចគ្នា** ...។

៤៦. ឈានទៅឧបត្ថម្ភស្ត្រីក្រីក្រមានផ្ទៃពោះ ចាប់ពីពេលមានផ្ទៃពោះរហូតកូនអាយុ២ ឆ្នាំ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកពញាឮ ខេត្តកណ្តាល, ២៦ ធ្នូ ២០១៨

... យើងនឹងឈានទៅបន្តដោះស្រាយសម្រាប់ស្ត្រីមានផ្ទៃពោះក្រីក្រ នៅទូទាំងប្រទេស ដែលនឹងត្រូវអនុវត្តនៅប៉ុន្មានខែខាងមុខ។ នោះគឺ**ការផ្តល់ឲ្យស្ត្រីចាប់ពីមានផ្ទៃពោះ ដល់ពេលឆ្លងទន្លេ (និងក្រោយ) ត្រូវបានទទួលការឧបត្ថម្ភ៤លើក។ នៅថ្ងៃឆ្លងទន្លេត្រូវឧបត្ថម្ភមួយលើក និងក្រោយឆ្លងទន្លេ រហូតកូនអាយុ២ ឆ្នាំ ត្រូវឧបត្ថម្ភ១០ លើក ដោយរាជរដ្ឋាភិបាលនឹងត្រូវចំណាយ សម្រាប់ម្នាក់ចំនួនជិត២០០ ដុល្លារសហរដ្ឋអាមេរិក។** របាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបង្ហាញថា ចាប់ពីពេលរាជរដ្ឋាភិបាលអនុវត្តឈប់សម្រាក ៣ ខែ ជាមួយប្រាក់បៀវត្ស ១២០% បូកនឹងចំនួនប្រាក់ឧបត្ថម្ភ ១០០ ដុល្លារទៀត ចំនួនអ្នកឆ្លងទន្លេមានការកើនរៀងរាល់ខែ ...៕

៤៧. បណ្តាញរោងចក្របន្តពង្រីកគិលានដ្ឋាន កន្លែងហូបបាយ និងទារកដ្ឋាន

សំណេះសំណាលជាមួយកម្មករ និយោជិត នៅសួនឧស្សាហកម្មវ៉ឡុង:ទី១, ១៥ កញ្ញា ២០១៧

... មកដល់ពេលនេះ តួលេខបានបង្ហាញថា រោងចក្រ-សហគ្រាស៨៨% មានគិលានដ្ឋាន ឬបន្ទប់ពេទ្យ, ៣៣% មានកន្លែងហូបបាយ, ២១% មានកន្លែងបំបៅកូន និង២៨% មានទារកដ្ឋាន។ សុំ**បណ្តារោងចក្របន្តការពង្រីកបន្តទៅទៀតនូវអ្វីដែលជាសេចក្តីត្រូវការរបស់កម្មករ ទាក់ទងនឹងសេវាពិនិត្យព្យាបាល។ យើងមាន៨៨%រួចមកហើយ នៅសល់រោងចក្រ ១២% ទៀត ដែលត្រូវរៀបចំ។ កន្លែងមួយចំនួនមានកន្លែងបាយហើយ ត្រូវរៀបចំឲ្យមានកន្លែងបាយសមរម្យ** ប៉ុន្តែនៅតំបន់នេះមានហាងបាយនៅក្រៅ ដូច្នេះវាជិតៗហ្នឹងក៏វាម៉្យាងដែរ ...៕

៤៨. Hunsenomics បង្កើនអាហារូបត្ថម្ភ កាត់បន្ថយអត្រាមរណភាពមាតានិងទារក

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់កប់ស្រូវ, ៧ កុម្ភៈ ២០១៨

... គំនិតផ្តួចផ្តើម(កម្មវិធីផ្តល់សាច់ប្រាក់សម្រាប់ស្ត្រីជាកម្មការិនីឆ្លងទន្លេ) ដែលឯកឧត្តម អ៊ិត សំហេង ហៅ Hunsenomics (ដូចជាគំនិតផ្តើមរបស់នាយករដ្ឋមន្ត្រីជប៉ុន Shinzo) Abe ដែលគេហៅថា Abenomics ... (ឬ)**សេដ្ឋកិច្ចបែបហ៊ុនសែន ព្រោះ ហ៊ុនសែន ដឹកនាំមកតាំងពីស៊ីបហរ ស៊ីគ្រាប់ពោតរហូតមកដល់បច្ចុប្បន្ន យើងមិនមែនស៊ីបហរ ស៊ីគ្រាប់ពោតទៀតទេ។ យើងអត់ចង់ឲ្យអ្នកណាសរសើរទេ ក៏ប៉ុន្តែនេះជាតម្រូវការត្រូវអនុវត្តដើម្បីបង្កើនអាហារូបត្ថម្ភ កាត់បន្ថយអត្រាស្លាប់មាតា និងទារក និងជួយទៅដល់ស្ត្រីឆ្លងទន្លេទាំងឡាយ ដែលជាកម្មការិនីទាំងក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ** ...៕

៤៩. Hunsenomics ប្រដូចបាននឹងគោលនយោបាយសេដ្ឋកិច្ចផ្កាយព្រឹកមិនអស្តង្គត

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល,
២០ កុម្ភៈ ២០១៩

... ក្នុងវិស័យឧស្សាហកម្ម យើងក៏មិនមែនធ្វើតែមួយមុខ។ យើងត្រូវធ្វើច្រើនមុខ មានធុនធ្ងន់មានធុនស្រាល មានធុនតូច មានសិប្បកម្ម មានកម្មន្តសាល ឲ្យមានច្រើនមុខ ច្រើនប្រភេទ។ កុំចំណុះតែមុខណាមួយ។ ការទាញវិនិយោគពីប្រទេសខាងក្រៅ កុំទាញតែពីប្រទេសណាមួយ ទាញឲ្យគ្រប់ ... កុំ(ឱ្យ)មកតែពួកកេរវកម្មបានហើយ។ **(អ្នកវិនិយោគ)មកពីប្រទេសណាក៏កម្ពុជាស្វាគមន៍ ... គោលនយោបាយសេដ្ឋកិច្ចរបស់យើង អាចចាត់ទុកថាជាគោលនយោបាយសេដ្ឋកិច្ចផ្កាយព្រឹកដែលវាគ្មានពេលអស្តង្គតទេ។ គោលនយោបាយ Hunsenomics ប្រៀបដូចជានយោបាយសេដ្ឋកិច្ចផ្កាយព្រឹក ដែលគ្មានពេលនឹងអស្តង្គតទេ** ...៕

៥០. បន្ថយចំណាយ តាមរយៈការរក្សាអតិផរណាឲ្យនៅទាប និងបន្ទាបថ្លៃទឹក/ភ្លើង

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ព្រៃទា, ១៧ មករា ២០១៨

... នៅពេលដែលប្រាក់ចំណូលកាន់តែកើន ហើយដែលមុននេះធ្លាប់មានការចំណាយធំនោះ ក៏ត្រូវកាត់បន្ថយមួយចំណែក តាមរយៈនៃការខិតខំរបស់រាជរដ្ឋាភិបាល ដើម្បីរក្សាស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសអតិផរណា ដែលបានរក្សាប្រាក់ចំណូលនោះ មិនឱ្យមានគម្លាតដែលប្រាក់ចំណូលទប់ទល់នឹងការកើនឡើងថ្លៃទំនិញហួសហេតុមិនបាន ... **ស្ថាប័នរបស់រាជរដ្ឋាភិបាល ដូចជាក្រសួងឧស្សាហកម្មនិងសិប្បកម្ម តាមរយៈរដ្ឋាករទឹកស្វយ័តភ្នំពេញខិតខំ(បណ្តាញ)ទឹកទៅតំបន់ផ្ទះកម្មករ ធ្វើឱ្យតម្លៃទឹកដែលផ្គត់ផ្គង់ត្រូវបានកាត់បន្ថយ ហើយតម្លៃអគ្គិសនីក្រោយតភ្ជាប់ទៅកាន់តំបន់ផ្ទះជួល ក៏ត្រូវបានកាត់បន្ថយ** ...៕

៥១. សូមកុំឡើងថ្លៃជួលផ្ទះច្រើនហួស ខណៈកម្មករ/ការិនីទទួលការដំឡើងប្រាក់ឈ្នួល

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកកំពង់ត្រាច ខេត្តកំពត, ២៥ មករា ២០១៩

... សូមធ្វើសេចក្តីអំពាវនាវដល់**ម្ចាស់ផ្ទះឈ្នួលទាំងអស់ និងសូមអរគុណដែលឆ្នាំទៅមួយឆ្នាំមិនបានដំឡើង(ប្រាក់ឈ្នួល)។ យ៉ាងណាក្តី ឆ្នាំនេះ ក៏សូមមេត្តាកុំដំឡើងហួសមាឌ ដើម្បីឲ្យកម្មករ/ការិនីរបស់យើង ដែលបានទទួលការឡើងបៀវត្សរ៍នេះ ទទួលបានអត្ថប្រយោជន៍**។ ពិតណាស់ថាមានក្តួយៗមួយចំនួន មកធ្វើការនៅពេលថ្ងៃ យប់ទៅសម្រាកឯផ្ទះ។ នេះហើយជានយោបាយជាក់ពង្រាយរោងចក្រនៅតាមជនបទ តាមខេត្ត ...៕

៥២. បង្កើនការយកចិត្តទុកដាក់អំពីសុវត្ថិភាពការដឹកជញ្ជូនកម្មករ/ការិនី

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់លូ៥ ខណ្ឌមានជ័យ, ២ សីហា ២០១៨

... **ជាចំណុចថ្មី តែមិនមែនជាចំណុចចុងក្រោយទេ។ ជាចំណុចអាប់ដេត ឱ្យបង្កើនការយកចិត្តទុកដាក់ទៅលើសុវត្ថិភាពនៃការដឹកជញ្ជូនកម្មករ** ... កន្លងទៅតែងមានឃើញភ្លូកនិងគ្រោះថ្នាក់ចរាចរណ៍ឡានដឹកកម្មករ។ សូមអំពាវនាវចំពោះគ្រប់ទីកន្លែងទាំងអស់ ជាពិសេសអ្នកជាម្ចាស់ដែលទទួលម៉ៅការក្នុងការដឹកជញ្ជូនកម្មករដោយរថយន្ត ត្រូវបង្កើនការយកចិត្តទុកដាក់ ... នៅពេលជិះរថយន្តចង្អៀតគ្នា បើកប្រជែងគ្នា ឬរថយន្តខ្វះសុវត្ថិភាព នឹងធ្វើឲ្យប៉ះពាល់ដល់សុខទុក្ខកម្មករ ជារបួស ឬហូតទៅដល់ស្លាប់ទៀតផង ...៕

៥៣. យកចិត្តទុកដាក់លើអ្នកធ្វើការតាមផ្ទះ ដែលជាកម្មការក្រៅប្រព័ន្ធផងដែរ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ, ២៣ ឧសភា ២០១៨

... សូមអំពាវនាវអ្នកមានលទ្ធភាពយកអ្នកពីក្រៅ ឬក៏កូនក្តួយមកធ្វើជាមេផ្ទះ អ្នកថែទាំផ្ទះ នៅជាមួយ យកចិត្តទុកដាក់ចំពោះអ្នកទាំងនេះ ... គ្នាធ្វើការហត់នឿយណាស់។ **ក្រៅពីការយកចិត្តទុកដាក់លើកម្មករក្នុងប្រព័ន្ធ ក៏ត្រូវមើលការយកចិត្តទុកដាក់ចំពោះកម្មកររនៅក្រៅប្រព័ន្ធដែរ រាប់ទាំងអ្នកធ្វើការបម្រើតាមផ្ទះ ... យើងត្រូវទទួលខុសត្រូវខាងសីលធម៌ចំពោះអ្នកដែលនៅជាមួយ ផ្តល់នូវសេចក្តីសុខសម្រាប់ពួកគាត់ផង និងត្រូវនឹកទៅដល់អ្នកដែលជាកូនរបស់គាត់ ឬម្តាយរបស់គាត់ ឬប្តីរបស់គាត់** ... ត្រូវទទួលការថែទាំធ្វើម៉េចឲ្យគ្នាមានសុខភាពល្អ ...៕

៥៤. ការរស់រានមានជីវិតរបស់កម្ពុជា ចាប់ផ្តើមពីការរស់រានមានជីវិតនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

សម្ពោធអគារព្យាបាលមហារីក និងសម្ពោធ «អគារតេជោសន្តិភាព» មន្ទីរពេទ្យកាល់ម៉ែត, ១៥ មករា ២០១៨

... ខ្ញុំបានប្រាប់ទៅបងប្អូនសេដ្ឋកិច្ចក្រៅប្រព័ន្ធថា **ការរស់រានមានជីវិតរបស់កម្ពុជា គឺចាប់ផ្តើមពីការរស់រានមានជីវិតនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ឥឡូវនេះសេដ្ឋកិច្ចក្រៅប្រព័ន្ធក៏នៅតែដើរតួនាទីសំខាន់ ក្នុងពេលដែលសេដ្ឋកិច្ចក្នុងប្រព័ន្ធមានកម្មករត្រឹមតែ១ លាន៤ សែននាក់ ប៉ុន្តែសេដ្ឋកិច្ចក្រៅប្រព័ន្ធមានពលកររហូតទៅដល់២ លាន៤ សែននាក់ នៅតែជាចំណែកមួយដ៏ធំ ហើយវាធន់នឹងវិបត្តិខាងក្រៅផង**។ ខាងក្រៅចង់មានវិបត្តិអ្វី រឿងវិបត្តិនៅខាងក្រៅ ប៉ុន្តែផលប៉ះពាល់នឹងត្រូវកាត់បន្ថយតាមរយៈនៃការពង្រឹងភាពធន់ក្នុងសេដ្ឋកិច្ចរបស់កម្ពុជា ...៕

៥៥. សូមយោគយល់ដល់កម្មការិនីជនជាតិឥស្លាមក្នុងការស្លៀកពាក់

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ចាក់អង្រែលើ, ២៧ កញ្ញា ២០១៧

... ដោយបានឃើញ**ការត្អូញត្អែររបស់កម្មការិនីដែលជាជនជាតិឥស្លាមអំពីការលំបាករបស់ពួកគាត់ក្នុងការចូលធ្វើការ ដោយតម្រូវឲ្យស្លៀកពាក់ឯកសណ្ឋានរបស់ក្រុមហ៊ុន ... ខ្ញុំសូមសាកល្បងអំពាវនាវចំពោះម្ចាស់រោងចក្រ សហគ្រាសនានាថា តើអាចធ្វើទៅបានទេ ការដែលផ្តល់ឱកាសឲ្យស្ត្រីដែលជាជនជាតិឥស្លាមស្លៀកពាក់តាមរបៀបឥស្លាម?** ... សង្ឃឹមថាក្រុមហ៊ុន(នឹងធ្វើបាន)។ ឯកឧត្តមរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក៏ពិភាក្សាជាមួយក្រុមហ៊ុនផងដែរ ដើម្បីផ្តល់ឱកាសឲ្យស្ត្រីឥស្លាមមានការងារធ្វើ ទាំងក្នុងរោងចក្រ វិស័យធនាគារ ក្នុងវិស័យសេវា និងវិស័យផ្សេងទៀត។ បើសិនជាផ្តល់ឱកាសបែបនេះ ស្ត្រីឥស្លាមរបស់យើងនឹងមានការងារធ្វើកាន់តែច្រើន ...៕

៥៦. ប្រាក់សោធននិវត្តន៍វិស័យឯកជនចាប់អនុវត្តពី២០១៩ ត្រូវមានសៀវភៅការងារ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ចម្ការដូង, ៨ វិច្ឆិកា ២០១៧

... **ចាប់ពីឆ្នាំ២០១៩ តទៅ រាជរដ្ឋាភិបាលនឹងដាក់ឲ្យអនុវត្តនូវរបបសោធននិវត្តន៍ ដែលមន្ត្រីរាជការ កម្មករ និយោជិត ផ្នែកឯកជន នឹងមានរបបសន្តិសុខសង្គមប្រាក់សោធននិវត្តន៍**។ យើងនិយមហៅថា ប្រាក់រ៉ៃត្រែត។ ក្មួយត្រូវប្រឹងធ្វើ

ការពីឥឡូវដើម្បីឲ្យប្រាក់ខែរបស់យើងកើនខ្ពស់ និងគ្រប់លក្ខខណ្ឌសម្រាប់ការទទួលបាននូវប្រាក់ចូលនិវត្តន៍ ... ពេលដែលក្មួយមានប្រាក់បៀវត្ស១៧០ ពេលចូលនិវត្តន៍កាត់ចេញ២០% ទុកបៀវត្សរ៍៨០% ហោចណាស់ក្មួយៗ មានប្រាក់ចិញ្ចឹមខ្លួន១៤០ ដុល្លារ ... ប្រាក់បៀវត្សកាន់តែច្រើន ពេលចូលនិវត្តន៍នៅសល់ប្រាក់បៀវត្សកាន់តែច្រើន ... ក្រសួងការងារត្រូវធ្វើការងារឲ្យជិតដល់ ... **ត្រូវមានសៀវភៅការងារ (ដែល)ជាអាយុជីវិត ជាឧបករណ៍ទទួលប្រាក់បៀវត្ស** ...។

៥៧. រដ្ឋទាក់ទាញរោងចក្រ បង្កើតការងារ ផ្តល់ការគាំពារ បែរជាថានាំរាស្ត្រមកធ្វើកញ្ជះ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ផ្លូវវែងស្រែង, ១១ តុលា ២០១៧

... មាន**អ្នកសរសេរ(រិះគន់)ថា លោក ហ៊ុន សែន ដឹកនាំយូរៗ ធ្វើឱ្យប្រជាជនមកពីស្រុក មកធ្វើកញ្ជះគេនៅតាមរោងចក្រ ... យើងខិតខំទាញរោងចក្រដើម្បីមកបង្កើតការងារឲ្យកម្មករ ហើយយើងប្រឹងចរចាឲ្យកម្មករ(បានការងារធ្វើនិងការគាំពារនានា) គេបែរជាបង្អាប់យើងថានាំក្មួយៗឲ្យមកធ្វើកញ្ជះគេ។ សូមគិតមើលបើក្មួយៗនៅនឹងផ្ទះ ក្មួយៗក៏ត្រូវធ្វើការ គ្មានអ្នកណាយកបាយទៅឲ្យស៊ីទេ**។ តិចលោទៅគិតតាម ប៉ុល ពត ដែលថា ប្រឹងទៅបន្តិចទៀតមានគ្រឿងយន្តបញ្ចុកបាយនោះ ... តើប្រទេសណានៅលើពិភពលោកនេះមានសេដ្ឋីទាំងអស់គ្នា ? តើអ្នកនិយាយហ្នឹងធ្វើការឬអត់ ? ... សូម្បីពួកអាមេរិកាំង ក៏ដើរស៊ីឈ្នួល គ្រាន់តែដើរក្នុងកម្រិតខ្ពស់ ... ដូចជាទូរទស្សន៍BTV ... ក៏ជួលអាមេរិកាំងមកជួយគ្រប់គ្រង ...។

៥៨. ក្រសួងការងារគួរតាមដាននិងធ្វើរបាយការណ៍ពីតួលេខចំនួនការងារដែលបានបង្កើតនិងបាត់បង់

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ផ្លូវវែងស្រែង, ១១ តុលា ២០១៧

... ប្រទេសនានាតែងតែលើកទឹកចិត្តអោយមានការវិនិយោគ ដើម្បីបង្កើតការងារ ដូចជា(សហរដ្ឋ)អាមេរិក និងប្រទេសជឿនលឿននានា។ គេរាប់ហើយ ផ្សាយតួលេខរៀងរាល់ខែ។ ដូចជាក្នុងមួយខែ បង្កើតការងារបានប៉ុន្មានឲ្យពលរដ្ឋរបស់គេ ? ឬក៏ត្រូវបាត់បង់ការងារប៉ុន្មាន ? គេតាមដានខ្លាំងណាស់។ **ក្រសួងការងាររបស់យើងក៏ត្រូវតែបញ្ចេញលទ្ធផលហ្នឹងជារៀងរាល់ខែ ឬក៏ថាបីខែម្តង ឬប្រាំមួយខែម្តង ឬមួយឆ្នាំ**។ តើឆ្នាំ២០១៧ នេះយើងបង្កើតការងារបានប៉ុន្មានកន្លែង ? ត្រូវធ្វើនិងផ្សព្វផ្សាយរបាយការណ៍ហ្នឹង ដើម្បីឲ្យប្រជាជនយើងបានយល់ ...។

៥៩. កិច្ចការ៥ កំពុងធ្វើសម្រួលដល់ពលកររកធ្វើការនៅក្រៅប្រទេស

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ភ្នំពេញថ្មី, ២២ វិច្ឆិកា ២០១៧

... រាជរដ្ឋាភិបាលអនុវត្តសេចក្តីថ្លែងការណ៍អាស៊ានស្តីពីការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ដោយបាន **ទី១ ជួយពលករធ្វើការនៅបរទេសជានាបាននូវផលប្រយោជន៍ស្របច្បាប់ ... ទី២ សហការប្រទេសដៃគូទទួលស្គាល់ជំនាញទៅវិញទៅមក ... ទី៣ សហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងកិច្ចសហប្រតិបត្តិការលើវិស័យរបបសន្តិសុខសង្គមសម្រាប់ពលកររនៅក្រៅប្រទេស ... ទី៤ សហការជាមួយបណ្តាប្រទេសអាស៊ានអនុវត្តរបបសោធននិវត្តន៍** ... និង **ទី៥ សម្រួលបែបបទជូនពលកររនៅបរទេស** អាចផ្ទេរសិទ្ធិជូនគ្រួសាររនៅក្នុងប្រទេសធ្វើជាតំណាងស្នើសុំធ្វើជាលិខិតប្តោលទោស ឬលិខិតរដ្ឋបាល ... ដោយមិនចាំបាច់ឱ្យសាមីខ្លួនវិលមកស្រុកកំណើត ...។

៦០. ប្រាក់ចំណូលពីពលករ ក្នុងនិងក្រៅប្រទេស ប្រមាណ ៦ពាន់លានដុល្លារ/ឆ្នាំ

សំណេះសំណាលជាមួយកម្មករ និយោជិត មកពីខេត្តកណ្តាល និងរាជធានីភ្នំពេញ
នៅពហុកីឡដ្ឋានមរតករតេជោ, ២៤ មិថុនា ២០២៣

... រាជរដ្ឋាភិបាលត្រូវធ្វើការច្រើនដើម្បីទាក់ទាញវិនិយោគពីក្រៅប្រទេស និងទាក់ទាញអ្នកមានទុនក្នុងស្រុកបង្កើតនូវរោងចក្រ សហគ្រាស ឬសិប្បកម្ម ដើម្បី**បង្កើតការងារធ្វើឲ្យប្រជាពលរដ្ឋទទួលបាននូវប្រាក់ចំណូលដែលមានចំនួនសរុបទាំងក្នុងនិងក្រៅស្រុកមានជិត ៦ពាន់លានដុល្លារ/ឆ្នាំ។ ក្មួយៗនៅក្នុងស្រុកដែលធ្វើការនៅតាមរោងចក្រ សហគ្រាសនានា ប្រាក់ចំណូលដែលបានមកគឺមានរហូតទៅដល់ប្រមាណជាង ៣ពាន់លាន/ឆ្នាំ ឯមកពីក្រៅស្រុកមានប្រមាណ ២ ៦០០ ទៅ ២ ៧០០លានដុល្លារ/ឆ្នាំ** ...។

៦១. ចន្ត៣ "សុំ" របស់រាជរដ្ឋាភិបាល ត្រូវបានរារាំងដោយចន្ត៣ "កុំ" របស់ពួកប្រឆាំង

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ចាក់អង្រែលើ, ២៧ កញ្ញា ២០១៧

... រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយវិស័យពន្ធដារដើម្បីសម្រួលឱ្យវិនិយោគិនចូលមកវិនិយោគបាន មានទំនិញសម្រាប់នាំចេញ ហើយសម្រួលការនាំចេញ ដែលយើងមិនគ្រាន់តែធ្វើជាមួយប្រទេសមួយទេ តែយើងធ្វើជាមួយប្រទេសច្រើន ... **យើងបានប្រឹងប្រែងសុំឲ្យគេផ្តល់ជំនួយ សុំឲ្យគេមកវិនិយោគ សុំឲ្យគេជួយទិញទំនិញពីកម្ពុជា តែក៏មានចរន្តរារាំងឱ្យគេកុំជួយដល់កម្ពុជា កុំមកវិនិយោគនៅកម្ពុជា និងកុំទិញទំនិញពីកម្ពុជា ដែលជាទង្វើសម្លាប់កម្មករ/ការិនីរបស់យើង។** ការងារដែលក្មួយៗមានសព្វថ្ងៃ ប្រាក់ចំណូលដែលក្មួយមាន មិនបានធ្លាក់មកពីលើមេឃទេ ហើយក៏មិនបានមកពីបក្សប្រឆាំងដែរ តែបានមកពីការខិតខំរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ...៕

៦២. បើបាត់ EBA តែមានការងារធ្វើ មានប្រាក់ចំណូល/ខែ វាស្មើនឹងសម្លាប់បក្សប្រឆាំង

បិទសន្និបាតក្រសួងមហាផ្ទៃ, ១៤ កុម្ភៈ ២០១៩

... យើងត្រូវយល់ទាំងអស់គ្នា ជាពិសេសកូនក្មួយដែលជាកម្មករ កម្មការិនី និងប្រជាពលរដ្ឋ។ ប្រសិនបើនៅតែមានការងារធ្វើ ប្រសិនបើនៅតែមានប្រាក់ចំណូល កុំខ្វល់ថាអ្នកណានិយាយពីអី។ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និវត្តជន បើនៅតែទទួលបានប្រាក់ខែពីរដ្ឋ បើនៅតែទទួលបានប្រាក់បៀវត្សគឺកុំខ្វល់ថាអ្នកណានិយាយពីអី។ គេកំពុងតែគិតថា បើសិនមានការដកហូតណាមួយ នឹងមានផលប៉ះពាល់រហូតដល់គ្មានប្រាក់បើកបៀវត្ស ... ពេលនេះម៉ោងនេះ **រដ្ឋាភិបាលហ៊ុន សែន មានសមត្ថភាពបើកប្រាក់ខែជូនរយៈពេល ១២ ខែ ដោយមិនមានចំណូលថ្មី ... ចំណូលគយមួយគ្រប់គ្រាន់សម្រាប់បើកប្រាក់ខែ ... ការដក EBA គឺមានតំលៃស្មើនឹងសម្លាប់បក្សប្រឆាំង** ...៕

៦៣. ក្នុងស្ថានភាពសេដ្ឋកិច្ចសកលមិនច្បាស់លាស់ វាយនភណ្ឌថមថយ តែកម្មន្តសាលកើន

សំណេះសំណាលជាមួយកម្មករ នៅតំបន់សេដ្ឋកិច្ចពិសេស Manhattan បាវិត ស្វាយរៀង, ២៥ មិថុនា ២០២៣

... ដរាបណាសង្គ្រាមអ៊ុយក្រែន-រុស្ស៊ីមិនទាន់ចប់ ដរាបណានយោបាយដាក់ទណ្ឌកម្មជាឯកតោភាគីមិនទាន់ត្រូវបានបញ្ចប់ ភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចសកលគឺនៅតែមាន។ **តែយើងត្រូវជម្នះ ... ផ្នែកមួយថមថយ ផ្នែកមួយវាកើន។**

នេះផ្នែកវាយនភណ្ឌគឺការកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងមានការថមថយ ប៉ុន្តែផ្នែកកម្មន្តសាលមិនមែនជាសម្លៀកបំពាក់ ដូចជាបង្គុំនៃគ្រឿងអេឡិកត្រូនិកមានការកើនឡើង។ ដូចនេះ ទំហំនៃការនាំចេញរបស់យើងវា(នៅតែ)កើនដែរ។ ប្រទេសកម្ពុជាតូច ប៉ុន្តែទំហំនៃការនាំចេញមាន ២៩ ០០០ លានដុល្លារ ...៕

៦៤. រំពឹងកំណើននាំចេញដល់៤០ ឬ១០០ ពាន់លានដុល្លារ ដើម្បីក្លាយជាប្រទេសមានចំណូលខ្ពស់

សំណេះសំណាលជាមួយកម្មករ នៅតំបន់សេដ្ឋកិច្ចពិសេស Manhattan បាវិត ស្វាយរៀង, ២៥ មិថុនា ២០២៣

... យើងចង់**បង្កើនការនាំចេញរបស់យើងឲ្យកាន់តែច្រើន ឲ្យកើនដល់៤០ ពាន់លាន ឬដល់១០០ ពាន់លានក្នុងមួយឆ្នាំ** ដែលវានឹងបង្កើនសមត្ថភាពផលិតកម្មរបស់កម្ពុជា។ យើងជឿជាក់ថានឹងអាចសម្រេចគោលដៅនេះ នៅក្នុងរយៈណាមួយជាក់លាក់ ដែលកំណត់ថា**កម្ពុជានឹងចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួចនៅឆ្នាំ២០២៧ ហើយនឹងក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ហើយក្លាយជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ ២០៥០** ...៕

៦៥. ក្រោយរំដោះ៧ មករា១៩៧៩ បានរៀបចំការបណ្តុះបណ្តាលគ្រប់វិស័យឡើងវិញ

ចែកសញ្ញាបត្រជូនដល់និស្សិត/គុនិស្សិត នៃវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស, ២៧ កុម្ភៈ ២០២៣

... ក្រោយថ្ងៃរំដោះ (៧ មករា ១៩៧៩) យើងបានរៀបចំអោយមានការបណ្តុះបណ្តាល ក៏ប៉ុន្តែ**ការបណ្តុះបណ្តាលរបស់យើងទៅមុខមិនលឿន ដោយសារកត្តាទីផ្សារ។** ខ្ញុំនៅចាំ (បានថា) ឆ្នាំ១៩៩៦ ... ផ្លូវទៅពោធិ៍ចិនតុង (មានសាលាបច្ចេកទេសព្រះកុសុមៈ)នៅស្តាំដៃ។ ពីដើម(ជាកន្លែង)ទាយលេខឡាន ... កន្លែងហ្នឹងកាលពីជំនាន់នោះអត់មានផ្ទះទេ។ ឥឡូវ ផ្ទះជាប់ពីហ្នឹងទៅដល់ពោធិ៍ចិនតុង។ ពីដើមពោធិ៍ចិនតុង(ស្ថិត)នៅក្នុងខេត្តកណ្តាល ... **ការបណ្តុះបណ្តាលដែលខ្វះទីផ្សារការងារ មិនទទួលជោគជ័យទេ។ ក្រោយមកប្រទេសរបស់យើងកើន(អ្នកបច្ចេកទេស)បន្តិចម្តងៗ** ...៕

៦៦. ទោះរៀនបានតិច ក៏អាចទទួលការបណ្តុះបណ្តាល

ចែកសញ្ញាបត្រ និងវិញ្ញាបនបត្រជូននិស្សិត នៃវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ, ៣០ មីនា ២០២៣

... ក្រសួងការងារនិងបណ្តុះវិជ្ជាជីវៈមិនទាមទារលក្ខខណ្ឌច្រើនពេកទេ។ អ្នកខ្លះ រៀនបានត្រឹមតែថ្នាក់ទី៧ ទី៨ ទី៩ ក៏អាចមានលទ្ធភាពចូលមកបណ្តុះបណ្តាល។ នៅទីនេះ មានវិញ្ញានបត្រវិជ្ជាជីវៈចំនួន១២២៣ នាក់ មានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ចំនួន៦៦០ នាក់ មានបរិញ្ញាបត្ររងចំនួន១១៣០ នាក់ មានបរិញ្ញាបត្រចំនួន៣០៩៩ នាក់ និងបរិញ្ញាបត្រជាន់ខ្ពស់ចំនួន១៣៩ នាក់។ នេះចង្អុលបង្ហាញថា**អ្នកមានគ្រប់លក្ខខណ្ឌទទួលនូវការបណ្តុះបណ្តាលសម្រាប់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ តម្រូវឱ្យមានសញ្ញាបត្របាក់ឌុប្លឺ ... ក៏ប៉ុន្តែសម្រាប់អ្នកដែលរៀនបានទាបជាងហ្នឹង ក៏ទទួលបានការបណ្តុះបណ្តាល**...។

៦៧. កុំមើលស្រាលការបណ្តុះបណ្តាលវិជ្ជាជីវៈ, ឲ្យតែចេះពិតប្រាកដ ការងារអ្វីក៏អាចរកលុយបាន

ពិធីចែកសញ្ញាបត្រជូននិស្សិត នៃវិទ្យាស្ថានខ្មែរជំនាន់ថ្មី, ១៨ មីនា ២០១៩

... មិនត្រូវមើលស្រាលការបណ្តុះបណ្តាលវិជ្ជាជីវៈទេ។ ការបណ្តុះបណ្តាលវិជ្ជាជីវៈហ្នឹងទៀត ពេលនិយាយ ឧទាហរណ៍ពីការបណ្តុះបណ្តាលចុងភៅ ស្រាប់តែគេនាំគ្នាសើច។ យើងត្រូវមើលឱ្យជ្រៅ។ បើសិនជាអត់ចុងភៅតាមសណ្ឋាគារនិងភោជនីយដ្ឋាន បានស្តីអោយភ្ញៀវទទួលទាន? ពួកថៅកែអស់ហ្នឹងអត់ចេះធ្វើម្ហូបទេ។ គេថ្នាក់ថ្នមណាស់ចុងភៅ។ ថ្នាក់វិជ្ជាជីវៈទាក់ទងនឹងរឿងចុងភៅនិយាយអញ្ចឹង។ ពួកអគតិមួយចំនួន(រិះគន់ថា)លោក ហ៊ុន សែន បណ្តុះបណ្តាលដោយរុញឱ្យទៅធ្វើចុងភៅ។ ប៉ុន្តែ ពួកវាចូលទៅស៊ីដែរ។ ស៊ីមិនធ្លាញ់ វាថាចុងភៅមិនកើត ... **អ្នកដែលធ្វើការតាមផ្ទះទៀត ក៏ត្រូវតែចេះចុងភៅនោះដែរ។ ការងារវាអត់មានអីថោកទេ បើទោះបីការងារអីក៏ដោយ សំខាន់យើងចេះឱ្យប្រាកដអាហ្នឹងមានការងារធ្វើ មានលុយចូលហើយ**...។

៦៨. រាជរដ្ឋាភិបាលចេញវិការបណ្តុះបណ្តាលវិជ្ជាជីវៈយុវជនក្នុងគ្រួសារក្រីក្រ១,៥ លាននាក់

ចែកសញ្ញាបត្រ និងវិញ្ញាបនបត្រជូននិស្សិត នៃវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ, ៣០ មីនា ២០២៣

... នៅពេលខាងមុខ **យើងនឹងផ្តល់ឱកាសសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់គ្រួសារក្រីក្រ យុវជនក្រីក្រចំនួន ១លាន ៥សែននាក់ ដែលក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវទទួលរ៉ាប់រង ជាមួយនឹងការសហការជាមួយនឹងស្ថាប័នដែលទទួលបន្ទុកក្នុងការបណ្តុះបណ្តាល**។ ក្នុងហ្នឹងក៏មានវិជ្ជាជីវៈដូនតា។ វិជ្ជាជីវៈដូនតានេះ សំខាន់ទាក់ទងជាមួយនឹងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលត្រូវតែបានទទួលនូវការបណ្តុះបណ្តាល។ ការបណ្តុះបណ្តាលនេះទៀតសោត រាជរដ្ឋាភិបាលជាអ្នកចេញថវិកាសម្រាប់ផ្តល់ឱ្យសិស្សដើម្បីទទួលបានការរៀនសូត្រ ...។

៦៩. ផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រប់គ្រងដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្នែកមរតកវិជ្ជាជីវៈដូនតា គ្រប់គ្រងដោយក្រសួងវប្បធម៌

ពិធីប្រគល់វិញ្ញាបនបត្រ និងសញ្ញាបត្រជូនដល់សិស្សថ្នាក់វិជ្ជាជីវៈ និងនិស្សិត នៃសកលវិទ្យាល័យធនធានមនុស្ស, ២០ កុម្ភៈ ២០២៣

... សូមស្នើឱ្យ ឯកឧត្តម ហង់ជួន ណារ៉ុន ពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច/ការងារ អំពីគោលដៅបណ្តុះបណ្តាលនិស្សិត/សិស្សក្រីក្រ១ លាន៥ សែននាក់ ដែលក្នុងនេះ គឺខ្ញុំបានបែងចែកជា "វិជ្ជាជីវៈដូនតា" ប្រើពាក្យ "វិជ្ជាជីវៈដូនតា" ក្នុងរង្វង់ ២-៤% ដែលមានតាំងពីតម្បាញ/ចម្លាក់/គំនូរ ឬស្តីៗច្រើន(ទៀត) ដែលក៏ត្រូវការបណ្តុះបណ្តាលដែរ។ អញ្ចឹងទេ អាចពង្រាយការបណ្តុះបណ្តាលនេះ ដោយមួយ**ផ្នែករដ្ឋគ្រប់គ្រងតាមសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលគ្រប់គ្រងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសម្រាប់ផ្នែក "មរតកវិជ្ជាជីវៈដូនតា" គឺត្រូវគ្រប់គ្រងដោយក្រសួងវប្បធម៌** ...។

៧០. ការបណ្តុះបណ្តាលវិជ្ជាជីវៈ ជួយពលរដ្ឋចូលរួមអភិវឌ្ឍឆ្ពោះទៅសេដ្ឋកិច្ចចំណេះដឹង

ពិធីប្រគល់វិញ្ញាបនបត្រ និងសញ្ញាបត្រជូនដល់សិស្សថ្នាក់វិជ្ជាជីវៈ និងនិស្សិតនៃសកលវិទ្យាល័យធនធានមនុស្ស, ២០ កុម្ភៈ ២០២៣

... អាចធ្វើការបែងចែកការបណ្តុះបណ្តាលវិជ្ជាជីវៈសិស្សក្រីក្រ សំរាប់សកលវិទ្យាល័យនានា ដែលបាននិងកំពុងទទួលការបណ្តុះបណ្តាលស្រាប់ ព្រោះអ្នកដែលទទួលការបណ្តុះបណ្តាលក្នុង១ លាន៥ សែននាក់ទទួលការបណ្តុះបណ្តាល

៤. ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

១	កំពុងធ្វើកិច្ចការផ្ទៃក្នុងនិងអន្តរជាតិ ដោយស្មើភាពនិងស្មើសិទ្ធិ	៧៩
២	ឱនក្បាលម្តង ត្រូវជំពាក់ ឱនពីរដង... បីដង... ឱនមួយជីវិត... ខ្មែរនឹងមិនឯកភាជ្យបានទេ	៧៩
៣	កែទម្រង់ខាងក្នុង បង្កើនមិត្តខាងក្រៅ ក្នុងស្មារតីឯកភាជ្យ	៧៩
៤	ប្រទេសរដ្ឋអធិបតេយ្យ គ្មាននរណាអាចគាបសង្កត់បានទេ	៨០
៥	"អ្នកដើរត្រង់ ខ្ញុំដើរត្រង់ អ្នកឯងដើរវាង ខ្ញុំក៏ដើរវាង"	៨០
៦	ការសម្រេចចិត្តខាងនយោបាយក្នុងនិងក្រៅប្រទេស ត្រូវឈរលើផលប្រយោជន៍ជាតិ ...	៨១
៧	ប្រែអតីតសមរភូមិជាតំបន់អភិវឌ្ឍ កសាងព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការអភិវឌ្ឍន៍	៨១
៨	មិនទុកបញ្ហាព្រំដែនជាចំណាប់ខ្មាំងពាណិជ្ជកម្មនិងទំនាក់ទំនងប្រជាជន/ប្រជាជនទេ	៨២
៩	ពីទទួលទំពាបរទេសរក្សាសន្តិភាព ក្លាយជាអ្នកបញ្ជូនទំពាទៅរក្សាសន្តិភាពវិញ	៨២
១០	ទោះមានការលំបាក កម្ពុជាមិនដកកម្លាំងរក្សាសន្តិភាព តែត្រៀមបញ្ជូនបន្ថែម	៨៣
១១	ការចូលរួមរក្សាសន្តិភាព បង្ហាញពីសមត្ថភាពរបស់ទាហានកម្ពុជា	៨៣
១២	កុំយកអធិបតេយ្យជាតិ ទៅដោះដូរនឹងការអនុគ្រោះ ឬជំនួយ	៨៣
១៣	មិនអាចយកច្បាប់ក្រុមប្រទេសមួយ មកឱ្យប្រទេសមួយទៀតគោរពទេ	៨៤
១៤	មាន EBA ក៏មិនក្លាយជាអ្នកមាន បាត់ EBA ក៏មិនស្លាប់	៨៤
១៥	កង្វល់អ្នកជំទែ មិនមែនជាបន្ទាត់នយោបាយដែលត្រូវអនុវត្តទេ	៨៥
១៦	ធម្មនុញ្ញអាស៊ាន រក្សាគោលការណ៍កុងសង់ស៊ីស និងគ្មានការបណ្តេញសមាជិកចេញ	៨៥
១៧	មានគោលការណ៍កុងសង់ស៊ីសនិងមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង អាស៊ានមិនបែកបាក់	៨៦
១៨	បើកប្រជុំអាស៊ាននៅទីក្រុងភ្នំពេញបានដោយសារសុខសុវត្ថិភាពនិងសន្តិភាព	៨៦
១៩	កម្ពុជាសម្រេចបានការងារជាទីពេញចិត្តក្នុងការធ្វើប្រធានអាស៊ានទាំង៣ លើក	៨៧
២០	នៅពេលដែលធ្វើស៊ីហ្គេមនិងអាស៊ានប៉ារ៉ាហ្គេមខាងមុខ គួរយកគំរូតាមកម្ពុជា	៨៧
២១	អាស៊ាន ឬកម្ពុជា មិនតម្រូវឱ្យជ្រើសរើសរវាងអាមេរិកនិងចិនទេ	៨៨
២២	បើអឺរ៉ុបប្រកាន់ឥរិយាបថមិនល្អជាមួយអាស៊ាន តើទំនាក់ទំនងអាស៊ាននិងអឺរ៉ុបដើរលឿនទេ	៨៨
២៣	សូមមើលកម្ពុជាថាជាសមាជិកអាស៊ាន កុំមើលថាកម្ពុជាត្រឹមតែជាកម្ពុជា	៨៩
២៤	សំយោគគំនិតផ្តួចផ្តើមនិងនយោបាយក្នុងតំបន់ដើម្បីផលប្រយោជន៍អាស៊ាន	៨៩
២៥	ជំនួបអាស៊ានបូកបី អនុវត្តពហុភាគីនិយម បន្តយការលំបាកសង្គ្រាមពាណិជ្ជកម្ម	៩០
២៦	កិច្ចព្រមព្រៀង៣ ជាកាលានុវត្តភាពថ្មីក្នុងទំនាក់ទំនងកម្ពុជា-ចិន អាស៊ាន-ចិន និងតំបន់	៩០
២៧	ប្រើឱ្យអស់សក្តានុពលនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន	៩១

ដោយឥតបង់ថ្លៃ ហើយថែមទាំងទទួលបាននូវប្រាក់ឧបត្ថម្ភថែមទៀត ... ស្នើឯកឧត្តម ហង់ជួន ណារ៉ុន ពិនិត្យមើល តើមានសាលាប៉ុន្មាន ដែលកំពុងធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈ? **ខ្ញុំតែងតែលើកទឹកចិត្តឱ្យបន្តក្បាការបណ្តុះបណ្តាលវិជ្ជាជីវៈនេះ ព្រោះនេះជាបញ្ហាធំ ងាយរកការងារធ្វើ ដែលធ្វើឱ្យពលរដ្ឋខ្មែររបស់យើងមានវិជ្ជាជីវៈត្រឹមត្រូវ ដើម្បីបម្រើឱ្យការអភិវឌ្ឍ ដែលកាន់តែលឿន ហើយដែលយើងឆ្ពោះ(ទៅរក)គោលដៅសេដ្ឋកិច្ច(ពឹង)ផ្អែកលើចំណេះដឹង** ...៕

៧១. ជំរុញការបណ្តុះបណ្តាលវិជ្ជាជីវៈ ទាក់ទាញវិនិយោគ បំពេញតម្រូវការវិនិយោគិន

ចែកសញ្ញាបត្រ និងវិញ្ញាបនបត្រ ជូននិស្សិតនៃវិទ្យាស្ថានខ្មែរជំនាន់ថ្មី, ៦ មីនា ២០២៣

... និយាយដូច្នេះ មិនមែនមានន័យថា បោះបង់ការសិក្សាបរិញ្ញាបត្រឯង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ទេ ប៉ុន្តែខ្ញុំ**ចង់ចង្អុលបង្ហាញថា ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងផលិតកម្មក្នុងស្រុក និងទាក់ទងវិនិយោគ ទាមទារឱ្យមានជំនាញ(វិជ្ជាជីវៈ) ... ផែនការ(បណ្តុះបណ្តាលសិស្សក្រីក្រ)១ លាន៥ សែននាក់ ក៏អាចផ្តល់ឱ្យវិទ្យាស្ថាន(ខ្មែរជំនាន់ថ្មី ក៏ដូចជា) សាលាឯកជន ដែលមានការបណ្តុះបណ្តាលវិជ្ជាជីវៈ នូវការបណ្តុះបណ្តាលដើម្បីទាក់ទាញអ្នកវិនិយោគបាន។ មិនមែនបានអ្នកវិនិយោគមកហើយ បែរជាយើងមិនចេះធ្វើអី ឬក៏(យើង)អត់បច្ចេកទេសសោះនោះ** ហើយគេត្រូវទទួលយកយើងឱ្យធ្វើការនោះទេ ...៕

២៨	កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន នាំមកនូវឱកាសទីផ្សារនិងវិនិយោគ	៩១
២៩	យន្តការ២ ឡានឆាង-មេគង្គនិងមហាអនុតំបន់មេគង្គជួយប្រទេសភាគខាងក្រោម	៩២
៣០	របៀបធ្វើការជាមួយគ្នាដោយសមភាព ជាកត្តានាំឲ្យធ្វើទំនាក់ទំនងជាមួយចិន	៩២
៣១	កម្ពុជា-ចិន ចូលជល់ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងជាមិត្តដែកថែប	៩៣
៣២	អនុវត្តនយោបាយចិនមួយ ស្មើនឹងគោរពអធិបតេយ្យភាពកម្ពុជាខ្លួនឯង	៩៣
៣៣	មិនឲ្យតៃវ៉ាន់ដាក់ស្ថានតំណាង និងលើកទង់ជាតិ រាល់បុណ្យជាតិ, រកស៊ីនឹងគ្នាធម្មតា	៩៤
៣៤	គោលនយោបាយចិនមួយ កំពុងចេញផ្លែផ្កាឲ្យកម្ពុជា	៩៤
៣៥	ចិនតែងគោរពការសម្រេចចិត្តរបស់កម្ពុជា	៩៥
៣៦	បម្រើសន្តិភាពនិងអភិវឌ្ឍន៍ មិនប្រឆាំងប្រទេសណាមួយ គោរពមជ្ឈភាពអាស៊ាន	៩៥
៣៧	ស្តាដ ផ្លូវល្បឿនលឿន ព្រលានសៀមរាប ផ្លូវ/ស្ពាន សមិទ្ធផលបានពីខ្សែក្រវាត់និងផ្លូវ	៩៦
៣៨	បុរសសង្ហា(ឈ្លាសវៃ) ដើរបញ្ច្រាស(ផ្ទុយ)ចរន្ត	៩៦
៣៩	បើមិនឲ្យពឹងចិន តើឲ្យពឹងអ្នកណា?	៩៧
៤០	ជំនួយ/កម្ចីពីចិន មិនភ្ជាប់លក្ខខណ្ឌ, កម្ពុជានឹងមិនធ្លាក់ក្នុងអន្ទាក់បំណុលចិនទេ	៩៧
៤១	ខ្មែរមិនព្រមឲ្យចិនត្រួតត្រា ចិនក៏មិនចង់ត្រួតត្រាខ្មែរ ជាចរន្តពីរត្រូវគ្នា	៩៨
៤២	កម្ពុជាគ្មានការចាំបាច់មានវត្តមានកងទ័ពចិននៅលើទឹកដីខ្លួននោះទេ	៩៨
៤៣	គ្មានទ័ពរបរទេសលើទឹកដីកម្ពុជា ទទួលតែការហឹកហាត់រួម និងការចូលចតពីគ្រប់ប្រទេស	៩៨
៤៤	មិនត្រូវការជំនាញការយោធា តែទទួលឱ្យផ្តល់ការហឹកហឺន	៩៩
៤៥	សហប្រតិបត្តិការក្បែងពេជ្រកម្ពុជា-ចិន ដាក់ខេត្ត៤ ជាប៉ុលសេដ្ឋកិច្ចទី៤	៩៩
៤៦	ទំនាក់ទំនងកម្ពុជា-អាមេរិក អាក្រក់តាមមាត់អ្នកប្រឆាំង	១០០
៤៧	ទំនាក់ទំនងកម្ពុជា-អាមេរិក ដើរដល់ចំណុចកំពូលជាប្រវត្តិសាស្ត្រ	១០០
៤៨	ការរីកចម្រើនរបស់កម្ពុជា មិនអាចផ្តាច់ចេញពីជំនួយឧបត្ថម្ភរបស់ជប៉ុន	១០១
៤៩	ចង់បាននិនិយោគិននិងទីផ្សារជប៉ុនកាន់តែធំ ដើម្បីពង្រឹងទំនាក់ទំនងនយោបាយ	១០១
៥០	កម្ពុជា និងកូរ៉ៃ ជាប្រទេសដន្លង, ដោះស្រាយឲ្យកូនកាត់ចេះខ្មែរជេងចេះកូរ៉ៃជង	១០២
៥១	ទំនាក់ទំនងកម្ពុជា-កូរ៉ៃ ត្រូវប្រែប្រួលផ្លាស់ប្តូរតាមស្ថានការណ៍នយោបាយ	១០២
៥២	ទំនាក់ទំនងការទូតជាមួយកូរ៉ៃនាំពលករ/និស្សិត/ប្រជាជនមកធ្វើការ/រៀនសូត្រ/ស្នាក់នៅ	១០៣
៥៣	ទំនាក់ទំនងទន្លេហាន-មេគង្គ កិច្ចសហប្រតិបត្តិការទ្វេនិងពហុភាគី	១០៣
៥៤	ក្រៅពីប្រាក់ចំណូល ពលកររកកូរ៉ៃ យកបច្ចេកវិទ្យានិងជំនាញទៅបង្កើតការងារក្នុងស្រុក	១០៤
៥៥	ស្វាយ/សម្លៀកបំពាក់ ក្នុងទីផ្សារកូរ៉ៃ បញ្ជាក់ពីការរឿនលឿនទៅមុខនៃសេដ្ឋកិច្ចកម្ពុជា	១០៤
៥៦	រៀបចំការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងកម្ពុជានិងកូរ៉ៃ	១០៥
៥៧	ជើងហោះហើរកូរ៉ៃ-កម្ពុជា ១អាទិត្យ ៥០ជើង, ទំហំវិនិយោគកូរ៉ៃជាង ៤ពាន់លាន	១០៥
៥៨	មានអ្វីកើតនៅឧបទ្វីបកូរ៉ៃ ត្រូវស្ថិតនៅជាមួយប្រជាជនកូរ៉ៃ	១០៦
៥៩	នៅតែរក្សាទំនាក់ទំនងជាមួយកូរ៉ៃទាំងពីរ	១០៦
៦០	ឧបទ្វីបកូរ៉ៃគ្មាននុយក្លេអ៊ែរ និងស្រាយទំនាស់តាមផ្លូវចរចាដោយសន្តិវិធី	១០៧
៦១	មិនមែនបោះបង់ចោលឥណ្ឌា តែរង់ចាំពេលវេលាសមស្រប ទទួលចូល ASEM	១០៧
៦២	ភាពជាដៃគូជាមួយអាមេរិកនិងឥណ្ឌា មិនមានសម្ពាធលើភាពជាដៃគូជាមួយចិន	១០៨
៦៣	ចរន្តសកលភាវូបនីយ៍កម្មពហុភាគីនិយម មិនឯកតោនិយម ឬគាំពារនិយម	១០៨
៦៤	ការភ្ជាប់នយោបាយជាមួយពាណិជ្ជកម្ម បំពានក្របខ័ណ្ឌពហុភាគីនិយមនិងWTO	១០៩
៦៥	ពិភពលោកបច្ចុប្បន្នចំណុះឲ្យគ្នាទៅវិញទៅមក	១០៩
៦៦	TPP មានចរិតបំបែកអាស៊ាន ឯ ASEM ជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ	១១០
៦៧	មីយ៉ាន់ម៉ា៖ បំបាត់អំពើហិង្សា, ផ្តល់ជំនួយមនុស្សធម៌ សន្ធនាខាងនយោបាយ	១១០
៦៨	បទពិសោធន៍ការទូត ហ៊ុន សែន - "រក្សាទ្វារចំហសម្រាប់ការសន្ទនា" ជាជាងបិទ	១១១
៦៩	ការដាក់ទណ្ឌកម្មលើរុស្ស៊ី កើតជាវិបត្តិលើសេដ្ឋកិច្ចពិភពលោក	១១១
៧០	សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន បង្កើតឲ្យមានវិបត្តិថាមពល និងអាចមានវិបត្តិស្បៀង	១១២
៧១	មិនលើកទឹកចិត្តបំបែកបំបាក់រដ្ឋ និងគំរាមប្រើកម្លាំង ឬប្រើកម្លាំងក្នុងទំនាក់ទំនងអន្តរជាតិ	១១២
៧២	កម្ពុជាមិនបញ្ជូនជំនួយយោធា តែនឹងជួយការកំចាត់មីននៅអ៊ុយក្រែន	១១៣
៧៣	បញ្ឈប់អរិភាព ស្រាយជម្លោះដោយសន្តិវិធី ផ្តល់ជំនួយមនុស្សធម៌នៅអ៊ុយក្រែន	១១៣
៧៤	គណៈកម្មការព្រំដែនកម្ពុជាវៀតណាមព្រមព្រៀង៦%បន្ថែមលើ៨៤%បានបោះបង្គោលហើយ	១១៤
៧៥	មុងតាញ៉ាមិនមែនជនជាតិភាគតិចនៅកម្ពុជាទេ	១១៤
៧៦	ទោះបី BREXIT ក៏អង់គ្លេសនៅបន្តរបបពាណិជ្ជកម្មដូចធ្លាប់ធ្វើពីមុនមក	១១៤
៧៧	បើកស្ថានទូតនៅតួគី - "កម្ពុជានិងតួគី ធ្លាប់មានប្រវត្តិជាចក្រភព"	១១៥
៧៨	កសាងទំនាក់ទំនងទ្វេភាគីកម្ពុជា-តួគី និងតួគី-អាស៊ាន	១១៥
៧៩	អាស៊ានត្រូវដកពិសោធន៍ពីអឺរ៉ុបទាំងខាងល្អនិងខាងមិនល្អ	១១៦
៨០	មើលគ្រប់ទិស" ជាគោលនយោបាយការបរទេសរបស់កម្ពុជា	១១៦

១. កំពុងធ្វើកិច្ចការផ្ទៃក្នុងនិងអន្តរជាតិ ដោយស្មើភាពនិងស្មើសិទ្ធិ

វេទិការាជរដ្ឋាភិបាលវិស័យឯកជន លើកទី១៨, ២៩ មីនា២០១៩

... ក្នុងចំណោមប្រទេសអាស៊ាន កម្ពុជាក្រ(មែន)ក៏ប៉ុន្តែកម្ពុជាមានសមត្ថភាពបញ្ជូនកម្លាំង(រក្សាសន្តិភាពទៅក្រៅប្រទេស) ប្រមាណជាដប់ឆ្នាំជាងរួចហើយ។ យើងបានបំពេញកាតព្វកិច្ចអន្តរជាតិ ប៉ុន្តែបែរជាអន្តរជាតិខ្លះចាត់ទុកថាយើងដូចជាសត្វចម្លែកមួយ។ សង្ឃឹមថាយើងអាចមានការយល់ពីគ្នា ... ខ្ញុំចង់ឲ្យអ្នកបានដឹងថា **កម្ពុជាកំពុងតែធ្វើកិច្ចការផ្ទៃក្នុងផងនិងទំនាក់ទំនងអន្តរជាតិផង ដោយស្មើភាពនិងស្មើសិទ្ធិ បន្ថែមទៅដោយការជួយឧបត្ថម្ភទៅដល់មិត្តភក្តិ ដែលកំពុងជួបបញ្ហានៅក្រៅប្រទេសក្នុងប្រតិបត្តិការក្រោមឆត្រអង្គការសហប្រជាជាតិ** ...៕

២. ឱនក្បាលម្តង ត្រូវជំពាក់ ឱនពីរដង... បីដង... ឱនមួយជីវិត... ខ្មែរនឹងមិនឯករាជ្យបានទេ

សំណេះសំណាលជាមួយនិស្សិត និងប្រជាពលរដ្ឋខ្មែរ កំពុងសិក្សា និងរស់នៅប្រទេសជប៉ុន, ៧ តុលា២០១៨

... ខ្ញុំបានថ្លែងចំពោះមុខមហាសន្និបាតអង្គការសហប្រជាជាតិថា សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ជាប្រធានបទពេញនិយមសម្រាប់ការជ្រៀតជ្រែករបស់ប្រទេសធំ ប្រទេសមានលុយ លើប្រទេសក្រីក្រ។ (ប្រទេសទាំងនោះ)អាងឡើង (ថាដើម្បី)សិទ្ធិមនុស្ស និង/ឬប្រជាធិបតេយ្យ។ ឥឡូវ តើសិទ្ធិមនុស្ស និងប្រជាធិបតេយ្យនៅស៊ីរី នៅលីប៊ី នៅអ៊ីរ៉ាក់ នៅយេម៉ែន យ៉ាងម៉េចទៅហើយ? កាលដែលកម្ពុជាមានមនុស្សស្លាប់រាប់លាននាក់ តើពួកអ្នកឯងមានបានគិតទេ? ឥឡូវចង់ធ្វើអីធ្វើទៅ ចង់ឲ្យបង់ពន្ធក៏បង់ពន្ធ។ **ឱនក្បាលម្តង ត្រូវជំពាក់ឱនពីរដង ... ហើយត្រូវឱនមួយជីវិត។ ខ្មែរមិនអាចឯករាជ្យបានទេ។ ត្រូវប្រឹងរស់ ងើបឈរឡើង ដើម្បីការពារឯករាជ្យ អធិបតេយ្យរបស់ប្រទេស ...៕**

៣. កែទម្រង់ខាងក្នុង បង្កើនមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ

បើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុង ខ្សែទី៣ (ផ្លូវជាតិលេខ៤ ដល់១), ១៤ មករា ២០១៩

... យើងធ្វើសេដ្ឋកិច្ចមិនមែនពឹងពាក់តែលើវិស័យណាមួយនោះទេ។ យើងធ្វើសេដ្ឋកិច្ចច្រើនផ្នែកច្រើនយ៉ាងនិងច្រើនប្រទេស ... យើងធ្វើសេដ្ឋកិច្ចដោយមិនពឹងពាក់តែលើផ្នែកណាមួយ ហើយនៅពេលដែលគេបិទក្បាលរ៉ាល់ ក៏ធ្វើឲ្យយើងស្លាប់នោះទេ។ បើប្រៀបធៀបជាមួយសរីរាង្គមនុស្ស យើងមានរន្ធច្រមុះពីរនិងមាត់មួយ។ បើគឹងច្រមុះម្ខាង នៅសល់ម្ខាងគ្រាន់នឹងដក។ បើគឹងតាមរន្ធច្រមុះទាំងពីរ អញដកដង្ហើមតាមមាត់ ... **ខ្ញុំបានបញ្ជាក់ច្បាស់នៅក្នុងសន្និបាត(បក្សថា) "កែទម្រង់ខាងក្នុង បង្កើនមិត្តខាងក្រៅក្នុងស្មារតីឯករាជ្យ"។ យើងបន្តពង្រីកដៃគូមិត្តភក្តិក្រៅប្រទេសបន្តទៀត ប៉ុន្តែកុំភ្លេចកែទម្រង់ខាងក្នុងដើម្បីការលូតលាស់នៃសេដ្ឋកិច្ច** ...។

៤. ប្រទេស/រដ្ឋអធិបតេយ្យ គ្មាននរណាអាចគាបសង្កត់បានទេ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់វត្តទឹកថ្លា, ២១ កុម្ភៈ ២០១៨

... មានការជួបប្រជុំពិភាក្សាប្រចាំឆ្នាំ រវាងបណ្តាញអង្គការសហប្រជាជាតិ ដែលមានវត្តមាននៅកម្ពុជា១៩អង្គការ ជាមួយនឹងនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីមួយចំនួនរបស់រាជរដ្ឋាភិបាល។ យើងក៏បានពិភាក្សាពីបញ្ហាយុវជន ការងារធ្វើ និងចំណាកស្រុក ... **គេថាការប្រជុំ(នោះគឺ)អង្គការសហប្រជាជាតិគាបសង្កត់កម្ពុជា។ សូមផ្តាំទៅក្មួយៗថា ប្រទេស/រដ្ឋអធិបតេយ្យ ប្រជានអង្គការនីតិប្រតិបត្តិ គ្មានអ្នកណាគាបសង្កត់បានទេ ហើយក៏គ្មានទម្លាប់នៅលោកនេះ ប្រទេសមួយទៅគាបសង្កត់ប្រទេសមួយ ឬអគ្គលេខាអង្គការសហប្រជាជាតិ ឬអង្គការអន្តរជាតិណាមួយមកធ្វើការគាបសង្កត់លើប្រទេសដែលមានឯករាជ្យ និងអធិបតេយ្យនោះទេ** ...។

៥. "អ្នកជើរត្រង់ ខ្ញុំជើរត្រង់ អ្នកឯងជើរវាង ខ្ញុំក៏ជើរវាង"

បើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុង ខ្សែទី៣ (ផ្លូវជាតិលេខ៤ ដល់១), ១៤ មករា ២០១៩

... ង៉ែចាំមើលថា អ្នកដែលទៅអំពាវនាវឲ្យបរទេសកាត់ជំនួយ តើនឹងមានជោគវាសនាយ៉ាងម៉េច? បានសេចក្តីថា **យើងរង់ចាំជំហានអ្នកខាងនោះដើរ។ បើខាងនោះជើរត្រង់ ខ្ញុំក៏ជើរត្រង់ដែរ បើអ្នកឯងជើរវាងផ្លូវ ខ្ញុំក៏ជើរវាងផ្លូវដែរ** ... រឿងអីយើងត្រូវអត់ឱនឲ្យ។ ការសម្លាប់កម្ពុជាតាមរូបភាពណាមួយ មានតម្លៃស្មើនឹងសម្លាប់ក្រុមដែលអ្នកឯងគាំទ្រឲ្យប្រឆាំងជាមួយរដ្ឋាភិបាល ... ខ្ញុំមិនលើកលែងឲ្យទេ ... ល្បែងមានទៅមានមក ... បើចង់ឲ្យពួកប្រឆាំងរស់ ... ពិភាក្សាគ្នាកែលម្អសភាពការណ៍ជាមួយគ្នា ទៅមុខជាមួយគ្នា ក្នុងភាពជាដៃគូស្មើភាព គោរពឯករាជ្យ និងអធិបតេយ្យ ...។

៦. ការសម្រេចចិត្តខាងនយោបាយក្នុងនិងក្រៅប្រទេស ត្រូវឈរលើផលប្រយោជន៍ជាតិ និងស្មារតីឯករាជ្យពិតប្រាកដ

ពិធីជួបជុំសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពលករ និងនិស្សិតខ្មែរ កំពុងស្នាក់នៅ/ធ្វើការ/សិក្សានៅសាធារណរដ្ឋកូរ៉េ, ៣ កុម្ភៈ ២០២០

... ខ្ញុំតែងតែជាស់តឿនមន្ត្រីការទូត ក៏ដូចជាមន្ត្រីកម្ពុជាគ្រប់ថ្នាក់ថា **"ការសម្រេចចិត្តខាងនយោបាយ ទាំងក្នុងប្រទេស និងក្រៅប្រទេស ត្រូវឈរលើផលប្រយោជន៍ជាតិនិងឈរលើស្មារតីឯករាជ្យពិតប្រាកដ ទៅលើការសម្រេចចិត្តខាងនយោបាយ ក្នុងទំនាក់ទំនងនយោបាយក្រៅប្រទេសរបស់ខ្លួន"**។ ប្រសិនជាពេលនោះ ពូមិនសម្រេចចិត្តធ្វើរឿងបែបនេះទេ ក្មួយៗអត់បានមកយកប្តី(ជាជនជាតិ)កូរ៉េទេ ... និស្សិតដែលមករៀននៅកូរ៉េ ក៏អត់មានវត្តមាននៅថ្ងៃហ្នឹងដែរ ហើយក្មួយៗជាពលករ/ការិនី ក៏អត់មាន(វត្តមាន)នៅថ្ងៃនេះដែរ ...។

៧. ប្រែក្លាយអតីតសមរភូមិជាតំបន់អភិវឌ្ឍ កសាងព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ

សំណេះសំណាលជាមួយកម្មកររោងចក្រនៅតំបន់សេដ្ឋកិច្ចពិសេស Manhattan ក្រុងបាវិត ខេត្តស្វាយរៀង, ២៥ មិថុនា ២០២៣

... តើអ្វីទៅជាគោលដៅ២នោះ? **ទី១ ប្រែក្លាយតំបន់អតីតសមរភូមិឱ្យទៅជាតំបន់អភិវឌ្ឍ និងជាទីផ្សារ។ ទី២ ប្រែក្លាយតំបន់ព្រំដែនជាមួយប្រទេសជិតខាងឱ្យទៅជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការនិងការអភិវឌ្ឍ**។ ផ្តើមចេញពីតំបន់នេះ យើងអាចនិយាយបានថា គោលដៅដែលពូបានដាក់ចេញបានសម្រេចជោគជ័យផ្នែកណា តាមរយៈចំនួនរោងចក្រតំបន់ឧស្សាហកម្មនៅក្នុងខេត្តស្វាយរៀង

ដែលជាប់ជាមួយនឹងព្រំដែនវៀតណាមនេះ មានរហូតដល់៩ កន្លែង។ ចោទចេញជាសំណួរថា បើមានសង្គ្រាមទល់ដែននឹងប្រទេសជិតខាង តើប្រយោជន៍(ដែលយើងនឹងបាន)ទទួលជាអ្វី? គឺការបាញ់សម្លាប់គ្នា។ គ្មានទេកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ ...។

៨. មិនទុកបញ្ហាព្រំដែនជាចំណាប់ខ្មាំងពាណិជ្ជកម្មនិងទំនាក់ទំនងប្រជាជន/ប្រជាជនទេ

សំណេះសំណាលជាមួយសហគមន៍ខ្មែរនៅទ្វីបអឺរ៉ុប, ២១ ឧសភា ២០២២

... ឯតាមព្រំដែនកម្ពុជា-វៀតណាម កម្ពុជា-ថៃ កម្ពុជា-ឡាវ ពិតមែនតែការដោះស្រាយមិនទាន់ជាប់ស្រេចអស់ក្តី យើងដោះស្រាយជាមួយឡាវបាន៨៦% សល់ ១៤%។ ដោះស្រាយជាមួយវៀតណាមបាន៨៤% សល់ ១៦% ឥឡូវឯកភាពគ្នាបាន៦% ទៀត។ ឯថៃ បង្គោលចាស់ យើងដើររកឃើញ និងទទួលស្គាល់ ហើយយើងបង្កើតគណៈកម្មការចម្រុះដើម្បីបន្តលើរឿងនោះ។ **យើងមិនទុកឲ្យបញ្ហា(ព្រំដែន)នេះឱ្យនៅជាចំណាប់ខ្មាំងនៃការធ្វើពាណិជ្ជកម្ម និងទំនាក់ទំនងរវាងប្រជាជន និងប្រជាជនទេ** ...។

៩. ពីធ្លាប់តែទទួលទ័ពឃោទេសមកការក្សាសន្តិភាព ក្លាយជាអ្នកបញ្ជូនទ័ពចេញទៅជួយមិត្តភក្តិរក្សាសន្តិភាពវិញ

បើកការដ្ឋានគម្រោងធ្វើឲ្យប្រសើរឡើងនូវកំណាត់ផ្លូវជាតិលេខ៥ ភាគខាងជើង បាត់ដំបង-សិរីសោភ័ណ, ២៦ មីនា ២០១៨

... ឥឡូវយើងនៅតែបន្តតាមដានកម្លាំងដែលកំពុងប្រតិបត្តិការនៅក្រៅប្រទេសដូចជានៅប្រទេសម៉ាលី ដែលប៉ុន្មានថ្ងៃមុននេះកងទ័ពឧទ្ធាមបានវាយប្រហារបាញ់គ្រាប់ផ្លោងចូលក្នុងបន្ទាយ...ភ័ព្វសំណាងអត់មានរបួសទេ។ នោះហើយជាប្រទេសមានសង្គ្រាម។ **ពីដើម កម្ពុជាមិនដែលបញ្ជូនកងទ័ពចេញក្រៅប្រទេសទេ តែរយៈពេល ១២ឆ្នាំហើយ យើងបានបញ្ជូនកងទ័ពចេញទៅក្រៅប្រទេសដើម្បីជួយមិត្តភក្តិក្រោមឆត្រអង្គការសហប្រជាជាតិ។ ពីដើមយើងធ្លាប់ទទួលភ្ញៀវបរទេសបញ្ជូនមកកាន់កម្ពុជា ដើម្បីជួយរកសន្តិភាពឲ្យកម្ពុជា ប៉ុន្តែឥឡូវនេះយើងក៏បានបញ្ជូនមួកខៀវរបស់យើង និងប្រជាជនកម្ពុជា ទៅធ្វើការនៅក្រៅប្រទេស ជួយប្រទេសជិតខែទៀត ក្នុងការស្វែងរកសន្តិភាព ចូលរួមដោះស្រាយជម្លោះនៅតាមប្រទេសនានា** ...។

១០. ទោះមានការលំបាក កម្ពុជាមិនដកកម្លាំងរក្សាសន្តិភាព តែត្រៀមបញ្ជូនបន្ថែម

វេទិការាជរដ្ឋាភិបាលវិស័យឯកជន លើកទី១៨, ២៩ មីនា ២០១៩

... ទោះបីខ្លួនឯងលំបាក ត្រូវធ្វើកំណែទម្រង់ ត្រូវចំណាយនេះចំណាយនោះ ក៏ប៉ុន្តែខ្លួនបានចាយកម្លាំងមនុស្ស និងធនធានថវិកាមួយចំនួនផ្សេងទៀតដូចជាចាំបាច់ដែលត្រូវបញ្ចេញថវិកាបន្ថែន សម្រាប់ឲ្យទិញរថពាសដែក បញ្ជូនទៅប្រទេសម៉ាលី យើងខ្ញុំមិនដកកម្លាំងចេញពីប្រទេសណាទេ ហើយមិនត្រឹមតែមិនដកកម្លាំងចេញនោះទេ យើងខ្ញុំកំពុងតែត្រៀមគិតគូរថានឹងបញ្ជូនកម្លាំងទៅក្នុងករណីប្រទេសយេមែនមានកិច្ចព្រមព្រៀងសន្តិភាព ដែលតម្រូវឲ្យមានកងរក្សាសន្តិភាពទៅទីនោះ ...។

១១. ការចូលរួមរក្សាសន្តិភាព បង្ហាញពីសមត្ថភាពរបស់ទាហានកម្ពុជា

ពិធីចែកសញ្ញាបត្រនិស្សិតនៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ, ២៥ មីនា ២០១៩

... សម្តេចពិជ័យសេនា ទៀ បាញ់ នឹងទៅប្រជុំនៅឯទីស្នាក់ការអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក ជាមួយនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ និងបណ្តាប្រទេសដែលបានបរិច្ចាគកម្លាំងក្នុងប្រតិបត្តិការរក្សាសន្តិភាព។ **ចំណុចនេះ អាចបង្ហាញថា កម្ពុជាបានចូលរួមនៅក្នុងការរក្សាសន្តិភាពពិភពលោក ដែលសមត្ថភាពរបស់ទាហានកម្ពុជាមិនអន់នោះទេ ... កម្ពុជាមិនមែនគ្រាន់តែដោះស្រាយបញ្ហាផ្ទាល់ខ្លួនទេ យើងត្រូវមានការរួមចំណែក ហើយយើងក៏ត្រូវការធ្វើការប្រកួតប្រជែងទៅលើបញ្ហាសមត្ថភាព** ...។

១២. កុំយកអធិបតេយ្យជាតិ ទៅដោះដូរនឹងការអនុគ្រោះ ឬជំនួយ

បិទសន្និបាតបូកសរុបការងារក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ៣១ មករា ២០២០

... ខ្ញុំនៅបន្តនិយាយថា មិនត្រូវឱ្យអ្នកណាមកដឹកច្រមុះរបស់យើង ហើយក៏

មិនត្រូវយកអធិបតេយ្យជាតិ ទៅដោះដូរជាមួយនឹងការអនុគ្រោះ ឬជំនួយណាទាំងអស់។ វាពិតជាគ្មានតម្លៃ ហើយថោកទាបផង ប្រសិនបើច្បាប់របស់យើងៗ មិនអាចអនុវត្តបាន ហើយតម្រូវឱ្យធ្វើទៅតាមការបង្ខិតបង្ខំរបស់អ្នកដទៃ។ តើយើងជាប្រទេសមានឯករាជ្យនិងអធិបតេយ្យទេ? ជំនាន់មុន ការហ៊ឹមព័ទ្ធសេដ្ឋកិច្ចមានគ្រប់ទិស នៅសល់តែសហភាពសូវៀត និងអឺរ៉ុបខាងកើត ដែលហៅថា Comecon នោះ បូកជាមួយ វៀតណាម ឡាវ ឥណ្ឌា តែប៉ុននោះ ដែលផ្តល់នូវការគាំទ្រសម្រាប់កម្ពុជារស់រានមានជីវិត។ ឥឡូវនេះ យើងមានដៃគូច្រើនដែលរកស៊ីជាមួយគ្នា ...៕

១៣. មិនអាចយកច្បាប់ក្រុមប្រទេសមួយ មកឱ្យប្រទេសមួយទៀតគោរពទេ

ចែកសញ្ញាបត្រជូននិស្សិតសាកលវិទ្យាល័យឯកទេសនៃកម្ពុជា, ១១ ធ្នូ ២០១៩

... អត់យកអធិបតេយ្យជាតិទៅដោះដូរជាមួយជំនួយ ឬក៏ភាពអនុគ្រោះពីអ្នកណាទាំងអស់។ អ្វីដែលធ្វើបាន (គឺ)បាន អ្វីដែលធ្វើមិនបានគឺអត់។ អ្នកដែលមកនិយាយថា ប្រជាធិបតេយ្យត្រូវតែគោរពច្បាប់នោះ ខ្ញុំឯកភាព។ តែខ្ញុំបានបញ្ជាក់ថា គោរពច្បាប់ត្រូវតែគោរពច្បាប់ជាសកល ... ប្រជាធិបតេយ្យ ឬសិទ្ធិមនុស្ស ឬពាណិជ្ជកម្ម ត្រូវគោរពច្បាប់ ប៉ុន្តែមិនអាចយកច្បាប់នៃក្រុមមួយ ឱ្យក្រុមមួយទៀតគោរពទេ។ ច្បាប់នោះត្រូវចេញពីធម្មនុញ្ញសហប្រជាជាតិ។ មិនអាចយកច្បាប់នៃក្រុមប្រទេសមួយយកមកឱ្យប្រទេសមួយនិងក្រុមប្រទេសមួយគោរព ...៕

១៤. មាន EBA ក៏មិនក្លាយជាអ្នកមាន បាត់ EBA ក៏មិនស្លាប់

សំណេះសំណាលជាមួយប្រជាពលរដ្ឋខ្មែរនៅទ្វីបអឺរ៉ុប, ៤ កក្កដា ២០១៩

... ក្នុងការចុះហត្ថលេខាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាង EU ជាមួយវៀតណាម លោកជំទាវ (Cecilia) Malmström បានព្រមានចំពោះកម្ពុជា ចំពោះមីយ៉ាន់ម៉ា និងចំពោះបង់ក្លាដែស។ ខ្ញុំបានមើលបទសម្ភាសន៍របស់គាត់ដោយយកចិត្តទុកដាក់។ ខ្ញុំបានបញ្ជាក់ហើយ មាន EBA ក៏មិនអាចក្លាយទៅជាអ្នកមានបាត់ EBA ក៏វាមិនងាប់ទេ។ តែយើងត្រូវប្រឹងខ្លួនឯងមួយជាពីរ។ អ្វីដែលខ្ញុំបារម្ភមិនមែនការបាត់ EBA ឬមិនបាត់ EBA ទេ តែបារម្ភក្រែងលោមានភាពស្តឹកស្រពន់

ក្នុងចំណោមមន្ត្រីរាជការរបស់យើង ... EBA ជាស្អី? វាជាប្រព័ន្ធអនុគ្រោះសម្រាប់ប្រទេសដែលមិនទាន់រីកចម្រើន។ វានឹងបាត់នៅពេលណាមួយ វាត្រូវតែបាត់។ ឱ្យតែសេដ្ឋកិច្ចយើងឡើងបន្តិច វាបាត់ហើយ។ ក្នុងប្រទេសអាស៊ានមានតែ ៣ ទេដែលទទួល EBA ហ្នឹង ... ប្រទេសនៅអាហ្វ្រិកមួយចំនួន គេអត់លេងចូលទេ ...៕

១៥. កង្វល់អ្នកដទៃ មិនមែនជាបន្ទាត់នយោបាយដែលត្រូវអនុវត្តទេ

វេទិការាជរដ្ឋាភិបាល-វិស័យឯកជន លើកទី ១៨, ២៩ មីនា ២០១៩

... បើទោះបីមានភាពអនុគ្រោះ ឬគ្មានភាពអនុគ្រោះ គឺកម្ពុជា នៅតែទៅមុខ។ កម្ពុជាត្រូវការសហការជាមួយដៃគូ តែកម្ពុជាមិនត្រូវការឱ្យគេខោកក្បាលតាមចិត្តនោះទេ។ ខ្ញុំបានចារទៅ ឯកឧត្តម ប្រាក់ សុខុន បន្ទាប់ពីការសន្ទនារួចហើយថា "កង្វល់អ្នកដទៃ មិនមែនជាបន្ទាត់នយោបាយ ដែលយើងត្រូវអនុវត្តទេ"។ រឿងដែលអ្នកដទៃមានកង្វល់ចំពោះយើងៗ អរគុណហើយ តែមិនមែនជាអ្វីដែលយើងត្រូវធ្វើទេ។ តែបើកង្វល់មានហេតុ/ផលត្រឹមត្រូវ ដោយមិនបំពានលើអធិបតេយ្យរបស់យើង នោះយើងធ្វើ ...៕

១៦. ធម្មនុញ្ញអាស៊ាន រក្សាគោលការណ៍កុងសង់ស៊ីស និងគ្មានការបណ្តេញសមាជិក

ពិធីបិទសន្និបាតប្រចាំឆ្នាំរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ៣១ មករា ២០២០

... យើងត្រូវមើលថា ហេតុអ្វីអាស៊ានមានឯកភាព គោលការណ៍សហគមន៍តាមរយៈស្មារតីសហគមន៍? ដោយអនុវត្តនូវកិច្ចការដែលធ្វើការតាមកុងសង់ស៊ីស គឺជាមូលដ្ឋានធំណាស់។ នេះក៏ជាបទពិសោធនៃបណ្តាមិត្តភក្តិនៃប្រទេសអាស៊ានរបស់យើង។ ពេលដែលយើងធ្វើសេចក្តីសម្រេចចិត្តអំពីធម្មនុញ្ញអាស៊ាន យើងបានពិភាក្សានៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន ដែលមានការលើកឡើងថា ... **ទី១ ប្រសិនបើមិនអាចរកកុងសង់ស៊ីសបាន ត្រូវធ្វើការបោះឆ្នោត និងទី២ សមាជិកអាស៊ានមានសិទ្ធិដេញសមាជិក(ដទៃ)ចេញ។**

ដោយនាំមុខក្នុងការសន្ទនាជាមួយតួអង្គផ្សេងៗ ខ្ញុំបានបញ្ជាក់ប្រាប់ទៅថ្នាក់ដឹកនាំអាស៊ានថា ប្រសិនបើយើងធ្វើការបោះឆ្នោត អាស៊ាននឹងបែកបាក់ ព្រោះវា

នឹងមានសម្លេងភាគច្រើននិងសម្លេងភាគតិច ... ឯទី២ អំពីការដេញសមាជិកចេញ ខ្ញុំបានចោទសួរដោសំណួរថា ដែលថាដេញសមាជិកចេញដោយសារមានកំហុសធ្ងន់ធ្ងរ "តើអ្វីទៅជាកំហុសធ្ងន់ធ្ងរ? តើជារដ្ឋប្រហារយោធាឬ?" និងថាតើអ្នកណាជាអ្នកកំណត់ថាកំហុសនេះធ្ងន់ធ្ងរឬមិនធ្ងន់ធ្ងរ?

... ទីចុងបំផុត យើងរក្សាបានគោលការណ៍ធ្វើការតាមកុងសង់ស៊ីស។ បើទោះបីមានការលំបាកបន្តិច តែយើងទ្រាំការលំបាកនោះ ដើម្បីជានាងកភាពនៅក្នុងក្របខ័ណ្ឌអាស៊ាន។ អាស៊ានមានប្រទេសធំ និងប្រទេសតូច អាស៊ានមានប្រទេសអ្នកមាន និងប្រទេសអ្នកក្រ។ ក៏ប៉ុន្តែអាស៊ានមិនបានបែងចែក ហើយអាស៊ានក៏មិនបានមានបងធំនោះដែរ ...។

១៧. មានគោលការណ៍កុងសង់ស៊ីស និងមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងគ្នា ទើបអាស៊ានមិនបែកបាក់

ពិធីបិទសន្និបាតប្រចាំឆ្នាំរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ៣១ មករា ២០២០

... មិនមែនយកវេទិកានេះនិយាយសំដៅទិតៀនអឺរ៉ុបទេ ប៉ុន្តែខ្ញុំចង់ឲ្យបណ្តាប្រទេសអាស៊ាន ដែល**កម្ពុជាជាតួអង្គមួយដ៏សំខាន់នៅក្នុងនោះដែរ ជាកពិសោធន៍ពីគោលការណ៍កុងសង់ស៊ីស និងការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងគ្នា។ កុងសង់ស៊ីសគឺជាគោលការណ៍គ្រឹះដែលធ្វើឲ្យអាស៊ានមានឯកភាព។ បើទោះបីមានការលំបាកបន្តិចក្នុងការឈានទៅរកការសម្រេចណាមួយក្តី វាមិនបាននាំមកនូវការបែកបាក់នៅក្នុងក្របខ័ណ្ឌអាស៊ាននោះទេ ដោយសារតែត្រូវរកវិធីសម្របសម្រួលគ្នាជាជាងតាមវិធីនៃការបោះឆ្នោត** ...។

១៨. បើកប្រជុំអាស៊ាននៅទីក្រុងភ្នំពេញបានដោយសារសុខសុវត្ថិភាព និងសន្តិភាព

ពិធីទទួលសញ្ញាបត្របណ្ឌិតកិត្តិយសផ្នែកអភិវឌ្ឍន៍នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ៥ សីហា ២០២២

... **កត្តាធំបំផុតដែលយើងប្រជុំ(អាស៊ាននៅកម្ពុជា)បាននិងមានការចូលរួមពីសំណាក់ដៃគូគឺសុវត្ថិភាព។ សុវត្ថិភាពនេះ ... ទី១ គឺសន្តិភាពដែលយើងរកបានដោយលំបាក ហើយដែលយើងបានការពារដោយគត់មត់ ... និងទី(២) ជាអ្វីទៅ? នោះទាក់ទងនឹងការដែលយើងត្រួតត្រាបាននូវជំងឺកូវីដ-១៩** ... នេះហើយដែលខ្ញុំចង់និយាយថាជាជោគជ័យ ដែលផ្តល់ឱ្យយើង(នូវលទ្ធភាពរៀបចំ)ការប្រជុំនេះ(គឺផ្អែកលើ)សុវត្ថិភាព ដែលខ្ញុំបែងចែកជាពីរ គឺសុខសុវត្ថិភាព និងសន្តិភាពស្ថិរភាពនយោបាយ។ (ហើយសុខសុវត្ថិភាពនេះគឺ) សន្តិសុខ សណ្តាប់ធ្នាប់សង្គមនេះម្ខាង និងម្ខាងទៀត គឺការត្រួតត្រាបានកូវីដ-១៩ ...។

១៩. កម្ពុជាសម្រេចបានការងារជាទីពេញចិត្តក្នុងការធ្វើប្រធានអាស៊ានទាំង ៣ លើក

សន្និសីទសារព័ត៌មាន និងសំណួរ/ចម្លើយ ក្រោយកិច្ចប្រជុំកំពូលអាស៊ានទី៤០ និង៤១ នៅកម្ពុជា, ១៣ វិច្ឆិកា ២០២២

... ២០០២ អ្វីដែលបានកើតនៅ(ក្នុងកិច្ចប្រជុំអាស៊ាន)ទីក្រុងភ្នំពេញ គឺការចុះហត្ថលេខាលើ DOC ឬសេចក្តីថ្លែងការណ៍ស្តីពីក្រមប្រតិបត្តិសមុទ្រចិនខាងត្បូង និងជាការចូលជាដំបូងការសន្ទនាប្រចាំឆ្នាំរបស់ឥណ្ឌា ... ឆ្នាំ២០១២ ទោះបីមានបញ្ហាខ្លះ ក៏កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ RCEP ត្រូវបានប្រកាសនៅទីក្រុងភ្នំពេញ ... ឆ្នាំ២០២២ ជាប្រធានអាស៊ានម្តងទៀត ឬ១០ ឆ្នាំក្រោយមក កិច្ចព្រមព្រៀង RCEP ត្រូវបានចូលជាធរមាននិងទទួលទីម័រឡេស្តេជាសមាជិកភាពទី១១ **បូកជាមួយនឹងការលើកកម្ពស់ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយជាមួយសហរដ្ឋអាមេរិក ជាមួយឥណ្ឌា និងការចូលរួមចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាព មិត្តភាព និងសហប្រតិបត្តិការអាស៊ីអាគ្នេយ៍រហូតដល់ ៧ ប្រទេស ... ដូច្នេះ**(កម្ពុជាសម្រេចបានការងារយ៉ាងពេញចិត្តក្នុង)ការធ្វើប្រធានអាស៊ានទាំង ៣ លើក ...។

២០. នៅពេលដែលធ្វើស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេមខាងមុខ គួរយកគំរូតាមកម្ពុជា

សំណេះសំណាលជាមួយកម្មករនៅស្រុកកណ្តាលស្ទឹងខេត្តកណ្តាល, ១០ មិថុនា ២០២៣

...វាជាការចាប់ផ្តើមមួយនៃយុទ្ធសាស្ត្រ ហ៊ុន សែន អំពីការសាមគ្គីភាពរបស់អាស៊ាន។ **រហូតមកដល់ឥឡូវនេះ ខាងផ្នែកប្រព័ន្ធផ្សព្វផ្សាយបាននិយាយថា នៅពេលដែលធ្វើស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេមខាងមុខ គួរយកគំរូតាមកម្ពុជា ព្រោះ**

អត់បង់ថ្លៃសម្រាប់ការផ្សព្វផ្សាយ។ យើងបានចេញប្រាក់ប្រមាណជា ៧លាន ដុល្លារទៀត ចិញ្ចឹមបីបាច់ថែទាំចំពោះកីឡាករ/ការិនី ទាំងមិនពិការ ទាំងពិការ ដែលមកប្រកួតនៅកម្ពុជា។ កីឡាករ/ការិនីតាមប្រទេសនានា មកសម្រាកនៅភូមិកីឡា ខ្នាតសណ្ឋាគារផ្កាយ៥។ យើងមានម្ហូបសម្រាប់អ្នកទទួលទានបានទូទៅ។ ម្ហូបតាមរបៀបថៃគេត្រូវហិរបន្តិច។ តាមឥស្លាមគឺ halal និងម្ហូបសម្រាប់អ្នកហូបបួស គឺមានទាំងអស់ ...ខ្ញុំបាននិយាយហើយ លុយកាក់អាចចាយអស់។ ក្តៅឈ្មោះចាយមិនអស់ទេ តកូនចៅទៅថ្ងៃក្រោយ។ ឥឡូវក្តៅឈ្មោះកម្ពុជា សូម្បីតែ CNN, New York Times ក៏យករឿងស៊ីហ្គេមពីកម្ពុជាទៅផ្សាយ ... ផ្សាយ ប៊ូសំណាង ដែលរត់អត់ឈ្នះមេដាយ ប៉ុន្តែឈ្នះបេះដូង។ ឈ្នះបេះដូងមិនត្រឹមតែឈ្នះបេះដូងប្រជាជនកម្ពុជា ១៧លាននាក់ទេ ឈ្នះបេះដូងលើពិភពលោកទាំងមូលតែម្តង ...។

២១. អាស៊ាន ឬកម្ពុជា មិនតម្រូវឲ្យជ្រើសរើសរវាងអាមេរិក និងចិនទេ

សន្និសីទសារព័ត៌មាន និងសំណួរ/ចម្លើយ ក្រោយកិច្ចប្រជុំកំពូលអាស៊ានទី៤០ និង៤១ នៅកម្ពុជា, ១៣ វិច្ឆិកា ២០២២

... ពាក់ព័ន្ធនឹងភូមិសាស្ត្រនយោបាយ គេតែងតែនិយាយថា ពិភពលោកកំពុងតែមានការបែងចែក។ កាលពីមុន នៅក្នុងសង្គ្រាមត្រជាក់ គេនិយាយពី(ការបែងចែកដែល)ម្ខាងមានសហរដ្ឋអាមេរិក(និង)ម្ខាងទៀត គឺសហភាពសូវៀត។ ឥឡូវគេនិយាយពីម្ខាងជាចិននិងម្ខាងជាសហរដ្ឋអាមេរិក។ **សម្រាប់អាស៊ាន ឬក៏សម្រាប់កម្ពុជា យើងមិនតម្រូវឱ្យមានការជ្រើសរើសអ្នកណាទាំងអស់។ យើងអត់មានតម្រូវការថាជ្រើសរើសចិន ចោលសហរដ្ឋអាមេរិក ឬជ្រើសរើសសហរដ្ឋអាមេរិក ហើយចោលចិននោះឡើយ។ ដូចគ្នាដែរ ទាំងអាមេរិកទាំងចិន បានប្រាប់មកយើងវិញថា គ្មានការតម្រូវឱ្យជ្រើសរើសរវាងអាមេរិកនិងចិននោះទេ** ...។

២២. បើសិនអ៊ឺរ៉ុបនៅប្រកាន់ឥរិយាបថមិនល្អជាមួយអាស៊ាន តើទំនាក់ទំនងរវាងអាស៊ាន និងអ៊ឺរ៉ុប អាចនឹងដើរលឿនទេ?

បិទសន្និបាតបូកសរុបការងារក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ៣១ មករា ២០២០

... អ៊ឺរ៉ុបបច្ចុប្បន្ន មានទំនាក់ទំនងមិនជាល្អទេជាមួយនឹងអាស៊ាន។ មានប្រទេស៥ មានបញ្ហាជាមួយអ៊ឺរ៉ុបធ្ងន់ធ្ងរជាងគេ គឺឥណ្ឌូនេស៊ី និងម៉ាឡេស៊ី ក្រោមហេតុផលនៃការការពារបរិស្ថានប្រឆាំងនឹងការកាប់ព្រៃ ... អ៊ឺរ៉ុបក៏បានឆ្ពោះមកកាន់កម្ពុជា មីយ៉ាន់ម៉ា និងហ្វីលីពីន អំពីបញ្ហាសិទ្ធិមនុស្ស ... ដូច្នេះ **តើទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្ត្ររវាងអាស៊ាននិងអ៊ឺរ៉ុបអាចដើរលឿនទេ ប្រសិនបើឥរិយាបថបែបនេះត្រូវបានប្រកាន់យកជាបន្តពីគណៈកម្មការអ៊ឺរ៉ុប។** (នេះ)មិនមែនក្នុង(ក្របខ័ណ្ឌ)សហភាពអ៊ឺរ៉ុបទេ ... ប្រទេសអ៊ឺរ៉ុបមានទំនាក់ទំនងល្អជាមួយបណ្តាប្រទេសនៅក្នុងក្របខ័ណ្ឌអាស៊ាន ប៉ុន្តែអ៊ឺរ៉ុបមានសភាវៈរបស់អ៊ឺរ៉ុប និងមានគណៈកម្មការអ៊ឺរ៉ុបដែលកំណត់នយោបាយរបស់អ៊ឺរ៉ុបនោះជាបញ្ហាដែលត្រូវគិតគូរ ...។

២៣. សូមមើលកម្ពុជាថាជាសមាជិកអាស៊ាន កុំមើលថាកម្ពុជាត្រឹមតែជាកម្ពុជា

សំណេះសំណាលជាមួយប្រជាពលរដ្ឋខ្មែរនៅទ្វីបអឺរ៉ុប, ១២ ធ្នូ ២០២២

... មិនមែនអាស៊ានមកសម្រាប់ធ្វើកូនដឹងរបស់ពួកអ៊ឺរ៉ុបទេ ... មាន ហ៊ុន សែន មួយគ្រាន់ធ្វើជាសហប្រធានដែរ ... យើងផ្តល់ការគោរពដើម្បីឱ្យទំនាក់ទំនងវាកាន់តែរឹងមាំ ហើយយើងក៏ចង់ឱ្យចេញលទ្ធផលផ្លែផ្កាដែលនឹងឈានទៅដល់កម្រិតនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន-អ៊ឺរ៉ុប។ ខ្ញុំតែងតែរំលឹកអ្នកទៅពីអ៊ឺរ៉ុបថា **សូមកុំមើលប្រទេសមួយៗក្នុងអាស៊ានត្រឹមតែជាប្រទេសមួយ។ ដូចករណីកម្ពុជា កុំមើលកម្ពុជាត្រឹមតែកម្ពុជា ត្រូវមើលកម្ពុជាឱ្យឆ្ងាយជាហ្នឹង គឺកម្ពុជាជាសមាជិកអាស៊ាន។ បើកម្ពុជាមិនយល់ព្រមទេ មិនអាចចេញកិច្ចព្រមព្រៀងបានទេ។ ដូច្នេះ កុំមើលថាកម្ពុជាត្រឹមតែជាកម្ពុជា។ សូមមើលឱ្យផុតពីជាប្រទេសតែមួយ។ ហេតុនេះហើយ បានជាខ្ញុំប្តូរផ្តាច់នាំកម្ពុជាចូលអាស៊ានឲ្យខាងតែបាន** ...។

២៤. សំយោគគំនិតផ្តួចផ្តើមនិងនយោបាយក្នុងតំបន់ដើម្បីផលប្រយោជន៍អាស៊ាន

បិទសន្និបាតបូកសរុបការងារក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ៣១ មករា ២០២០

... ការនិយាយថាប្រទេសធំៗក្នុងតំបន់សម្លឹងមកតំបន់អាស៊ីអាគ្នេយ៍ យើងមិននិយាយដល់យុទ្ធសាស្ត្រឥណ្ឌូ-ប៉ាស៊ីហ្វិក ដែលបានលើកក្នុងឯកសារនេះទេ។ **អាស៊ានក៏មានគំនិតផ្តួចផ្តើមរបស់ខ្លួន អំពីទស្សនទានឥណ្ឌូ-ប៉ាស៊ីហ្វិកដែរ។ យើងចង់ធ្វើសំយោគគំនិតផ្តួចផ្តើមនៅក្នុងតំបន់នេះ រាប់ទាំង «ខ្សែក្រវាត់និងផ្លូវ» និងគំនិតផ្តួចផ្តើមដទៃៗ** ... នយោបាយរបស់ឥណ្ឌាកាលពីរដ្ឋាភិបាល Manmohan Singh បានលើកឡើងត្រឹមតែនយោបាយសម្លឹងមកទិសខាងកើត។ ពេលចូលមកដល់រដ្ឋាភិបាលរបស់ Narendra Modi ឥណ្ឌាបាននិយាយដល់សកម្មភាពមកទិសខាងកើត ... ឯកូរ៉េខាងត្បូងក៏មាននយោបាយសម្លឹងមកទិសខាងត្បូង។ ដោយហេតុនេះ **អាស៊ានត្រូវធ្វើសំយោគនយោបាយទាំងអស់នេះ ដើម្បីរកបានផលប្រយោជន៍ និងធ្វើជាមជ្ឈមណ្ឌលនៃសាមគ្គីភាពរវាងបណ្តារដ្ឋ** ...៕

២៥. ជំនួបអាស៊ានបូកបី អនុវត្តពហុភាគីនិយម បន្តយការលំបាកសង្គ្រាមពាណិជ្ជកម្ម

ចែកសញ្ញាបត្រដល់និស្សិត សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២៦ ធ្នូ ២០១៩

... ជារឿងល្អដែលប៉ុន្មានថ្ងៃមុននេះ **ដៃគូសន្ទនារបស់អាស៊ានទាំង៣ គឺចិន ជប៉ុន កូរ៉េខាងត្បូង បានជួបប្រជុំគ្នានៅប្រទេសចិន។ ឥឡូវ៣ ប្រទេសហ្នឹងត្រូវគ្នាអនុវត្តពហុភាគីនិយមបន្ត ហើយក៏បានកាត់បន្ថយការលំបាកសង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងចិន ក៏ដូចជារវាងសហរដ្ឋអាមេរិកនិងប្រទេសមួយចំនួនផ្សេងទៀត។ ប្រការនេះធ្វើឱ្យក្រុមប្រទេសអាស៊ានមានការងាយស្រួល** ... បើស្ថានភាពរវាងប្រទេសដៃគូទាំង៣ នេះល្អ វាមិនមែនល្អប្រសើរសម្រាប់តែប្រទេសទាំង៣នោះទេ តែក៏សម្រាប់តំបន់របស់យើងដែរ។ ដៃគូទាំង៣នេះក៏ស្ថិតនៅក្នុងកិច្ចព្រមព្រៀងភាពជាដៃគូគ្រប់ជ្រុងជ្រោយក្នុងតំបន់ ...៕

២៦. កិច្ចព្រមព្រៀង៣ ជាកាលានុវត្តភាពថ្មីក្នុងទំនាក់ទំនងកម្ពុជា-ចិន អាស៊ាន-ចិន និងក្របខ័ណ្ឌតំបន់

កិច្ចសម្ភាសន៍ផ្តាច់មុខ ជាមួយវិទ្យុមិត្តភាពកម្ពុជា-ចិន, ១១ កុម្ភៈ ២០២៣

... នេះជាផ្លែផ្កានៃទំនាក់ទំនងរវាងកម្ពុជា-ចិន។ ចិនមានប្រជាជន ១៣០០ លាននាក់។ ជាចំនួនមួយច្រើន ... ខ្ញុំបានស្វះស្វែងរកពីមិត្តចិននូវការនាំចូលដោយផ្ទាល់នូវផលិតផលរបស់កម្ពុជាទៅកាន់ទីផ្សារចិន ... **យើងមានកិច្ចព្រមព្រៀងរហូតដល់ ៣ គឺ(១)កិច្ចព្រមព្រៀង៣ណាជ្ជកម្មសេរីអាស៊ាន-ចិន (២) កិច្ចព្រមព្រៀង RCEP ដែលបានចូលជាធរមានរវាង១៥ ប្រទេសមានទំហំប្រជាជនជិត ២៣ន់លាននាក់ និង(៣)កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន។ នោះជាកាលានុវត្តភាពថ្មីក្នុងទំនាក់ទំនងរវាងកម្ពុជា-ចិនផង រវាងអាស៊ាន-ចិនផង និងរវាងក្របខ័ណ្ឌតំបន់** ...៕

២៧. ប្រើឱ្យអស់សក្តានុពលនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន

សម្ពោធអគារឥន្ទ្រទេវី នៃរាជបណ្ឌិត្យសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... យើងត្រូវ**ប្រើសក្តានុពលនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិនឱ្យអស់លទ្ធភាព។ ឯកឧត្តម សុខ ទូច លើកឡើងហើយទ្រឹស្តី "។គ្នាតមួយដើមត្រូវប្រើឱ្យអស់លទ្ធភាព"...យើងគិតទៅទីឆ្ងាយតែយើងមិនបានគិតទីជិត...កុំមើលងាយពាណិជ្ជកម្មសេវី (និង/ឬ)ពាណិជ្ជកម្មឆ្លងដែន** ... ឯកឧត្តម ង្វៀន ស៊ុនហុក (នាយករដ្ឋមន្ត្រីវៀតណាម) បានប្រកាសថ្ងៃមុននៅបាងកក ពេលប្រជុំអាស៊ាន-ចិនថាពាណិជ្ជកម្មរវាងវៀតណាមនិងចិន មានទំហំដល់១៦០ ពាន់លាន(ដុល្លារអាមេរិក)។ បានសេចក្តីថា ទីផ្សាររបស់វៀតណាម មិនមែនអាមេរិកឬអឺរ៉ុបទេ។ ទីផ្សាររបស់វៀតណាមគឺចិន។ គាត់រកស៊ីតាមទល់ដែនជាមួយគ្នា។ ឯយើងក៏រកស៊ីតាមទល់ដែនជាមួយគ្នាដែរ ...៕

២៨. កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន នាំមកនូវឱកាសទីផ្សារ និងវិនិយោគដល់កម្ពុជា

កិច្ចសម្ភាសន៍ផ្តាច់មុខ ជាមួយវិទ្យុមិត្តភាពកម្ពុជាចិន នៃអគ្គស្ថានីយ៍វិទ្យុ និងទូរទស្សន៍មជ្ឈិមចិន(CMG) និងទីភ្នាក់ងារព័ត៌មានស៊ីនហួរ, ១៨ កញ្ញា ២០១៩

... ក្នុងទស្សនកិច្ចចុងក្រោយរបស់ខ្ញុំ មិត្តចិនបានសន្យាថា នឹងបង្កើតឱ្យមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជានិងចិន បន្ថែមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន។ ពេលនេះ យើងកំពុងប្រើប្រាស់យន្តការកិច្ច

ព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន។ តែខ្ញុំនៅមានការសង្ឃឹមធំមួយគឺ**កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជានិងចិន ដែលអាចលេចចេញជារូបរាងនៅពេលខាងមុខ។ ពេលនោះ កម្ពុជានឹងមានទីផ្សារទំហំធំមួយដែលមានប្រជាជនរហូតទៅដល់១៣០០ លាននាក់ ...ដែលនឹងផ្តល់ឱកាសឱ្យកម្ពុជាអាចបន្តមានការរីកចម្រើន។ ក្រុមហ៊ុនចិនបន្តការវិនិយោគនៅកម្ពុជា។** យើងបានឃើញហើយក្រុមហ៊ុនចិនជាច្រើនកំពុងបណ្តាក់ទុននៅកម្ពុជា ...៕

២៩. យន្តការ២ ឡានឆាង-មេគង្គ និងមហាអនុតំបន់មេគង្គ ជួយប្រទេសភាគខាងក្រោម

កិច្ចសម្ភាសន៍ផ្តាច់មុខ ជាមួយវិទ្យុមិត្តភាពកម្ពុជា-ចិន នៃអគ្គស្ថានីយវិទ្យុ និងទូរទស្សន៍មជ្ឈិមចិន និងទីភ្នាក់ងារព័ត៌មានស៊ីនហួរ, ១៨ កញ្ញា ២០១៩

... យន្តការអាស៊ានបូកចិនគឺជាយន្តការល្អ រួមជាមួយយន្តការអាស៊ាន-ជប៉ុន អាស៊ាន-កូរ៉េខាងត្បូង និងអាស៊ានបូក៣ ដែលរួមមានអាស៊ាន ជាមួយចិន ជប៉ុន កូរ៉េខាងត្បូង។ តែនៅមាន**យន្តការ២ ទៀត ដែលដើរតួនាទីជួយដល់បណ្តាប្រទេសនៅភាគខាងក្រោម។ ទី១ គឺឡានឆាង-មេគង្គ តភ្ជាប់រវាងចិន និងបណ្តាប្រទេសមេគង្គ ... ដែលនៅដើមឆ្នាំ២០២០ នឹងមានការប្រជុំនៅទីក្រុងវៀងចន្ទន៍ ...ជាយន្តការមួយទៀតបំពេញបន្ថែម សម្រាប់កិច្ចសហប្រតិបត្តិការរវាងចិនជាមួយបណ្តាប្រទេសនៅតាមដងទន្លេមេគង្គ។ យន្តការមួយទៀតគឺ មហាអនុតំបន់មេគង្គ ដែលរួមមានបណ្តាប្រទេសតាមដងទន្លេមេគង្គទាំងចិន មីយ៉ាន់ម៉ា ថៃ ឡាវ កម្ពុជា និងវៀតណាម និងធនាគារអភិវឌ្ឍន៍អាស៊ី ...៕**

៣០. របៀបធ្វើការជាមួយគ្នាដោយសមភាព ជាកត្តានាំឲ្យធ្វើទំនាក់ទំនងជាមួយចិន

កិច្ចសម្ភាសន៍ផ្តាច់មុខ ជាមួយវិទ្យុមិត្តភាពកម្ពុជា-ចិន នៃអគ្គស្ថានីយវិទ្យុ និងទូរទស្សន៍មជ្ឈិមចិន និងទីភ្នាក់ងារព័ត៌មានស៊ីនហួរ, ១៨ កញ្ញា ២០១៩

...កត្តាទាក់ទាញ(អោយ)ខ្ញុំ (ធ្វើ)ទំនាក់ទំនងជាមួយចិននៅត្រង់ថា (ថ្វីត្បិតតែ)ចិនជាប្រទេសធំ ជាប្រទេសមានការអភិវឌ្ឍ ក៏ប៉ុន្តែខ្ញុំបានធ្វើការជាមួយនឹងមេដឹកនាំចិនប្រកបដោយសមភាព។ បើទោះបី យើងខ្ញុំជាប្រទេសតូច ដែលត្រូវពឹងពាក់ប្រទេសធំ ហើយខ្ញុំធ្វើការជាមួយអ្នកមានវ័យចំណាស់ជាងខ្ញុំក្តី ដូចជាជំនាន់

ឯកឧត្តម ហ្សាង ស៊ីមិញ, ហ៊ូ ចិនតាវ ... នាយករដ្ឋមន្ត្រី លី ធឺង, ជូ រុងជី, វ៉ែន ជាបាវ ពួកគាត់សុទ្ធតែសម្តែងនូវការគោរព មិនគិតថាយើងជាប្រទេសតូច ឬមានវ័យក្មេងជាងនោះទេ។ **ចិនមានទម្លាប់មួយគឺធ្វើច្រើននិយាយតិច។ នេះជាចំណុចដែលយើងផ្តល់ការគោរព និងធ្វើឱ្យយើងអាចនៅជាមួយគ្នា សាមគ្គីភាពគ្នា ធ្វើការជាមួយគ្នាយូរអង្វែង** ...៕

៣១. ទំនាក់ទំនងកម្ពុជា-ចិន ចូលដល់ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងបានក្លាយទៅជាមិត្តដែកថែប

ជំនួបប្រចាំឆ្នាំ និងពិសាអាហារសាមគ្គីជាមួយសមាគមសម្ព័ន្ធខ្មែរ-ចិននៅកម្ពុជា, ៩ មេសា ២០១៩

... នេះមិនមែនជាបញ្ហាថ្មីថ្មោងរបស់ព្រះរាជាណាចក្រកម្ពុជាទេ។ គោលនយោបាយនេះត្រូវបានដាក់ចេញតាំងពីព្រះរាជបិតាជាតិខ្មែរ សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ... យើងត្រូវ**បន្តថ្នាក់ថ្នមចំណងមិត្តភាពដែលមានមកដល់បច្ចុប្បន្ន និងដែលបានឆ្លងចូលដល់ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងព្រះរាជាណាចក្រកម្ពុជានិងចិន ហើយបានក្លាយទៅជាមិត្តដែកថែប**។ ខែមករា ឆ្នាំ២០១៩ កន្លងទៅ ក្នុងទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន យើងបានពិភាក្សាច្រើនជាមួយប្រធានាធិបតី ស៊ី ជិនភីង និងនាយករដ្ឋមន្ត្រី លី ខឺឈាំង អំពីកិច្ចសហប្រតិបត្តិការនានា។ ក្នុងចុងខែមេសា ខ្ញុំនឹងមានឱកាសទៅចូលរួមកិច្ចប្រជុំលើកទី២ នៃវេទិកាខ្សែក្រវាត់មួយផ្លូវមួយ ... តាមការគ្រោងទុក ខ្ញុំក៏នឹងមានជំនួបពិភាក្សាជាមួយនាយករដ្ឋមន្ត្រី លី ខឺឈាំង និងមានជំនួបពិភាក្សាជាមួយឯកឧត្តមប្រធានាធិបតី ស៊ី ជិនភីង ផងៗ ដូច្នេះ ទំនាក់ទំនងកាន់តែប្រសើរ ...៕

៣២. អនុវត្តនយោបាយចិនមួយ ស្មើនឹងគោរពអធិបតេយ្យភាពកម្ពុជាខ្លួនឯង

បញ្ចុះបឋមសិលាសង់មន្ទីរពេទ្យបង្អែកកម្ពុជា-ចិនត្បូងឃ្មុំ, ១ មីនា ២០១៩

... ខ្ញុំស្គាល់ច្បាស់នយោបាយរបស់ចិន ... ចិន(មានបំណង)ការពារត្រឹមតែឯករាជ្យអធិបតេយ្យភាពរបស់ចិន(ប៉ុណ្ណោះ) ...កុំឲ្យតែមកបំបែកតៃវ៉ាន់ចេញ(ពីចិន) កុំឲ្យបង្កើតបញ្ហានៅទីបេ នៅស៊ីនជាំង គឺចិនពេញចិត្តណាស់ទៅហើយ។

ដោយហេតុនេះ យើង**អនុវត្តគោលនយោបាយចិនមួយជាទៀងទាត់។ តៃវ៉ាន់គ្រាន់តែជាខេត្តមួយរបស់ចិនតែប៉ុននោះ។ យើងអនុញ្ញាតឲ្យក្រុមហ៊ុនតៃវ៉ាន់មករកស៊ីនៅកម្ពុជា ក៏ប៉ុន្តែ មិនអាចមានស្ថានទូត ឬតំណាងតៃវ៉ាន់នៅកម្ពុជាទេ។ មិនអាចឲ្យលើកទង់ជាតិតៃវ៉ាន់ក្នុងសណ្ឋាគារ ឬកន្លែងណាមួយដែលក្រុមហ៊ុនតៃវ៉ាន់ធ្វើការទេ។ នេះជាបទបញ្ជាតាំងពី២០ ឆ្នាំមុន ... ការគោរពអធិបតេយ្យភាពរបស់ចិនមានតម្លៃស្មើនឹងការគោរពអធិបតេយ្យភាពរបស់កម្ពុជា** ...។

៣៣. មិនអនុញ្ញាតតៃវ៉ាន់ដាក់ស្ថានតំណាង និងលើកទង់ជាតិនៅរាល់បុណ្យជាតិ, ការរកស៊ីនឹងគ្នាជារឿងធម្មតា

បើកការដ្ឋានសង់ស្ពានឆ្លងកាត់ទន្លេមេគង្គ ពីស្ទឹងត្រង់ ទៅក្រូចឆ្មារ, ៩ កុម្ភៈ ២០១៨

...ខ្ញុំក៏សូមបញ្ជាក់ ដោយសារតែជិតចូលឆ្នាំចិនមកដល់។ ខ្ញុំបញ្ជាក់ថា **យើងគ្រាន់តែមិនអនុញ្ញាតឲ្យចិនតៃវ៉ាន់ ដាក់ការិយាល័យស្ថានតំណាងនៅទីក្រុងភ្នំពេញ ក៏ដូចជា ការលើកទង់ជាតិតៃវ៉ាន់នៅរាល់បុណ្យជាតិ ឬទីកន្លែងណាក៏ដោយក្នុងប្រទេសរបស់យើង។ ក៏ប៉ុន្តែ យើងមិនបានរារាំងនូវការរកស៊ីជាមួយនឹងអ្នកវិនិយោគិនមកពីតៃវ៉ាន់ទេ រាប់ទាំងការហោះហើររបស់យន្តហោះពីតៃវ៉ាន់មកកាន់កម្ពុជា** ទៅកាន់សៀមរាប ទៅកាន់ភ្នំពេញ គឺគ្រប់កន្លែងយើងរកស៊ីជាមួយតៃវ៉ាន់។ ការរកស៊ីជាមួយគ្នា គឺជារឿងធម្មតា...។

៣៤. គោលនយោបាយចិនមួយ កំពុងចេញផ្លែផ្កាឲ្យកម្ពុជា

បញ្ចុះបឋមសិលាសង់មន្ទីរពេទ្យបង្អែកកម្ពុជា-ចិនត្បូងឃ្មុំ, ១ មីនា ២០១៩

... ក្នុងទសវត្សរ៍៨០ និងដើមទសវត្សរ៍៩០ មានអ្នកបបួលខ្ញុំឲ្យជាក់ទំនាក់ទំនងជាមួយតៃវ៉ាន់។ ខ្ញុំមិនយល់ព្រមជាច់ខាត ... ចិនបានស្គាល់នយោបាយរបស់ ហ៊ុន សែន ... **ឆ្នាំ១៩៩៦ ពេលទស្សនកិច្ចនៅប៉េកាំង ឯកឧត្តម ជាង ហ្សេមិញ អតីតអគ្គលេខាធិការ និងជាប្រធានរដ្ឋរបស់ចិន បានប្រើភាសាមួយជាលើកដំបូងជាមួយខ្ញុំថា "ឯកឧត្តម ហ៊ុន សែន ជាមិត្តចាស់របស់ចិន" ... (គឺនិយាយ)សំដៅគោលនយោបាយ ហ៊ុន សែន តាំងពីមុនមក គឺជាគោលនយោបាយចិនមួយហ្នឹង ... កម្ពុជាបច្ចុប្បន្នកំពុងទទួលបានផ្លែផ្កាពីគោលនយោបាយចិនមួយ** ...។

៣៥. ចិនតែងគោរពការសម្រេចចិត្តរបស់កម្ពុជា

កិច្ចសម្ភាសន៍ផ្តាច់មុខ ជាមួយវិទ្យុមិត្តភាពកម្ពុជា-ចិន, ១១ កុម្ភៈ ២០២៣

... គំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ ហាក់ដូចជាដើរស្របទិសគ្នាជាមួយនឹងយុទ្ធសាស្ត្រចតុកោណរបស់កម្ពុជា។ នេះជាចំណុចដែលយើងអាចនឹងចូលរួមនៅក្នុងក្របខ័ណ្ឌនៃគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ។ លើការដាក់ស្តែង ផ្លូវល្បឿនលឿនវាស្ថិតនៅក្នុងរបៀងនៃការអនុវត្តផ្លូវនៃខ្សែក្រវាត់និងផ្លូវនេះឯង។ **ការពង្រឹងសមត្ថភាពនានាទាក់ទងនឹងខាងបច្ចេកវិទ្យាព័ត៌មានក្តី បណ្តាហេដ្ឋារចនាសម្ព័ន្ធដែលមិត្តចិនបានជួយកសាងក្តី រាប់ទាំងព្រលានយន្តហោះនៅសៀមរាប និងការកសាងហេដ្ឋារចនាសម្ព័ន្ធដទៃទៀត អ្វីដែលយើងកោតសរសើរគឺនៅត្រង់ថា មិត្តចិនបានគោរពការសម្រេចចិត្តរបស់យើង។ មិនថាយើងចង់ធ្វើផ្លូវ ធ្វើស្ពាន ធ្វើប្រឡាយទឹកឬធ្វើមន្ទីរពេទ្យមុន គឺមិត្តចិនគោរពការសម្រេចចិត្តរបស់កម្ពុជា** ...។

៣៦. បម្រើសន្តិភាពនិងអភិវឌ្ឍន៍ មិនប្រឆាំងប្រទេសណាមួយ គោរពមជ្ឈភាពអាស៊ាន

សំណេះសំណាលជាមួយកម្មករ និយោជិត និងដាក់ឱ្យដំណើរការរោងចក្រផលិតសំបកកង់ដើម្បីអបអរសាទរខួបលើកទី១០ នៃគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ នៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ, ២២ ឧសភា ២០២៣

... ហេតុអីបានជាកម្ពុជាស្ថិតក្នុងចំណោមប្រទេស១៥០ និងអង្គការអន្តរជាតិដែលបានចុះហត្ថលេខាលើកិច្ចសហប្រតិបត្តិការ ក្នុងក្របខ័ណ្ឌខ្សែក្រវាត់និងផ្លូវដែលផ្តួចផ្តើមឡើងដោយ ឯកឧត្តម ប្រធានាធិបតី Xi Jinping។ (គំនិតផ្តើមកិច្ចសហប្រតិបត្តិការ)នេះ ស្របគ្នាជាមួយនឹងគោលនយោបាយពីដើមដល់ចប់របស់កម្ពុជា។ មានគំនិតផ្តួចផ្តើមច្រើននៅក្នុងក្របខ័ណ្ឌតំបន់អាស៊ីប៉ាស៊ីហ្វិក ឬឥណ្ឌូប៉ាស៊ីហ្វិក។ ក្នុងរាល់គំនិតផ្តួចផ្តើម កម្ពុជាត្រូវដើរតាមចំណុច៣ ជាគោលការណ៍ គឺ**ទី១៖ បើចង់ឱ្យកម្ពុជាគាំទ្រ អ្វីដែលជាវត្ថុបំណងត្រូវតែបម្រើឱ្យសន្តិភាពនិងការអភិវឌ្ឍ។ ទី២៖ កុំប្រឆាំងជាមួយប្រទេសណា និង ទី៣៖ ត្រូវគោរពមជ្ឈភាពរបស់អាស៊ាន**។ នេះជាគោលការណ៍ធំៗនៃគោលនយោបាយការបរទេសកម្ពុជា ...។

៣៧. ស្ពាដមរតកតេជោ ផ្លូវល្បឿនលឿន ព្រលានយន្តហោះសៀមរាប ផ្លូវ/ស្ពាន សមិទ្ធផលបានពីគំនិតផ្តើមខ្សែក្រវាត់និងផ្លូវ

សំណេះសំណាលជាមួយកម្មករ និយោជិត និងដាក់ឱ្យដំណើរការរោងចក្រផលិតសំបកកង់ដើម្បីអបអរសាទរខួបលើកទី១០ នៃគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ នៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ, ២២ ឧសភា ២០២៣

... តើការគាំទ្រ (គំនិតផ្តើមខ្សែក្រវាត់និងផ្លូវ) នេះ ផ្តល់ផលប្រយោជន៍យ៉ាងណាខ្លះឱ្យកម្ពុជា? គ្រាន់តែនិយាយពី SEA Games ដែលទើបនឹងបញ្ចប់ដោយជោគជ័យនេះ បើមិនមានចំណែកនៃគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវទេ យើងពុំមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីនឹងប្រកួត SEA Games ទេ ... **ខ្ញុំអរគុណសាធារណរដ្ឋប្រជាមានិតចិន រដ្ឋាភិបាលនិងប្រជាជនចិន ពិសេសប្រធានាធិបតី Xi Jinping ដែលជួយកសាងស្ពាដមួយសម្រាប់ធ្វើកម្មវិធីបិទ បើក និងការប្រកួត។ ស្ពាដនោះអាចប្រើបាន១០០ ឆ្នាំទៀត តកូនតចៅ។ នៅមានផ្លូវល្បឿនលឿនតភ្ជាប់ ... ព្រលានយន្តហោះសៀមរាប** ដែលនឹងទទួលការចុះចតយន្តហោះខ្នាតធំ។ **គម្រោងដទៃទៀតាប់ទាំងគម្រោងតភ្ជាប់ប្រព័ន្ធ Internet ខ្សែកាប្តឺក្រោមទឹកកំពង់សោម-ហុងកុង ... ជំនួយឥតសំណង និងកម្ចីអភិវឌ្ឍគម្រោងនានា មានដូចជា ផ្លូវថ្នល់រាប់ពាន់គីឡូម៉ែត្រ ស្ពានឆ្លងទន្លេមេគង្គ ទន្លេសេកុង ទន្លេសាប ទន្លេបាសាក់** ...។

៣៨. បុរសសង្ហា(ឈ្លាសវៃ) ដើរបញ្ច្រាស(ផ្ទុយ)ចរន្ត

សំណេះសំណាលជាមួយកម្មករ និយោជិត និងដាក់ឱ្យដំណើរការរោងចក្រផលិតសំបកកង់ដើម្បីអបអរសាទរខួបលើកទី១០ នៃគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ នៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ, ២២ ឧសភា ២០២៣

... ទស្សនកិច្ចទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ជាប្រទេសទី១ ក្រោយចូលឆ្នាំចិន ហើយក៏ជាខួបលើកទី៣ នៃការដែល**ខ្ញុំធ្វើទស្សនកិច្ចនៅក្នុងប្រទេសចិននៅពេលដែលអ្នកដទៃភ័យខ្លាចរត់ចោលចិន។ ហ៊ុន សែន បានធ្វើដំណើរទៅប្រទេសចិន។ មានអ្នកសរសេរថា "បុរសសង្ហាដើរបញ្ច្រាសទិស" (អ្នកឈ្លាសវៃដើរបញ្ច្រាសទិស) ... បញ្ច្រាសត្រង់ថា ពេលផ្ទុះកូវីដ-១៩ គេនាំគ្នាជម្លៀសពលរដ្ឋ**

រាប់ទាំងនិស្សិត ចេញពីប្រទេសចិន។ អ្នកណាក៏ខ្លាចចិន ... តែ ហ៊ុន សែន ទៅ។ ដោយហេតុនេះ (ទស្សនកិច្ចនេះចំ)ខួប៣ ឆ្នាំនៃការដែលខ្ញុំធ្វើដំណើរទៅប្រទេសចិនដើម្បីបង្ហាញសាមគ្គីភាពជាមួយប្រជាជនចិន ក្នុងការប្រយុទ្ធប្រឆាំងជាមួយកូវីដ-១៩។ សូមផ្ញើសារលើកទឹកចិត្តនិស្សិតកម្ពុជារស់នៅជាមួយប្រជាជនចិន កុំរត់ចោលប្រជាជនចិនក្នុងពេលលំបាកនោះ ...។

៣៩. បើមិនឲ្យពឹងចិន តើឲ្យពឹងអ្នកណា?

កិច្ចសម្ភាសន៍ផ្តាច់មុខ ជាមួយវិទ្យុមិត្តភាពកម្ពុជា-ចិន, ១១ កុម្ភៈ ២០២៣

... ចំណុចនេះ ខ្ញុំបានអះអាងហើយនៅតែនិយាយថា "បើមិនឲ្យខ្ញុំពឹងចិន តើឲ្យខ្ញុំពឹងអ្នកណា"។ អ្នកដែលចោទយើងថាលម្អៀងទៅរកចិន កំពុងតែឈរលើស្ពានមួយចំនួនដែលយើងបានសាងសង់ឆ្លងកាត់ទន្លេមេគង្គ ទន្លេបាសាក់ ទន្លេសាប ទន្លេសេកុង។ សូមទៅឈរលើស្ពានទាំងនោះ ហើយឲ្យពួកគេដាក់ចេញជាសំណួរថា **បើកុំមានចិនជួយ តើយើងមានស្ពានហ្នឹងឆ្លងឬអត់? ការពិត តើអ្នកណាមកជំនួសតួនាទីរបស់ចិន? គេអត់បានធ្វើអ្វីទាំងអស់ តែគេមកចោទយើង។ បើមិនឲ្យខ្ញុំពឹងចិន ពេលនេះក៏ខ្ញុំមិនមានវាក់សាំងចាក់ឲ្យប្រជាជនកម្ពុជាដែរ** ...។

៤០. ជំនួយ/កម្ចីពីចិន មិនភ្ជាប់លក្ខខណ្ឌ, កម្ពុជានឹងមិនធ្លាក់ក្នុងអន្ទាក់បំណុលចិនទេ

កិច្ចសម្ភាសន៍ផ្តាច់មុខ ជាមួយវិទ្យុមិត្តភាពកម្ពុជា-ចិន នៃអគ្គស្ថានីយ៍វិទ្យុ និងទូរទស្សន៍មជ្ឈិមចិន និងទីភ្នាក់ងារព័ត៌មានស៊ីនហួរ, ១៨ កញ្ញា ២០១៩

... ខ្ញុំមានការរីករាយដែលបានធ្វើការជាមួយមិត្តចិនដោយមិនមានការភ្ជាប់លក្ខខណ្ឌតម្រូវ។ មានមនុស្សមួយចំនួននិយាយដាក់ផ្លែដាក់ផ្កាឱ្យយើងថា នឹងជាប់អន្ទាក់បំណុលរបស់ចិន។ **តើប្រទេសប៉ុន្មាន ដែលមិនជំពាក់បំណុលបរទេស? តើប្រទេសប៉ុន្មានដែលមិនជំពាក់បំណុលរបស់ចិន? មានប្រទេសមួយចំនួនជំពាក់បំណុលច្រើនជាងកម្ពុជាទៅទៀត។ ខ្ញុំមិនជឿថា កម្ពុជានឹងធ្លាក់ក្នុងអន្ទាក់បំណុលរបស់ចិន ខណៈយើងមានការខ្វើដោយមានការគ្រប់គ្រងហ្មត់ចត់ ហើយមិត្តចិនក៏បានធ្វើការជាមួយយើងដោយហ្មត់ចត់** ។ អ្នកទាំងនោះហាក់ដូច

ជាមើលស្រាលកម្ពុជា និងចំពោះតវ៉ាយោបាយចិន ក្នុងហានៈជាអ្នកផ្តល់ទុនឱ្យប្រទេសនានាដែលបានទទួលការអភិវឌ្ឍ ...៕

៤១. ខ្មែរមិនព្រមឲ្យចិនត្រួតត្រា ចិនក៏មិនចង់ត្រួតត្រាខ្មែរ ជាចរន្តពីរត្រូវគ្នា

បញ្ចុះបឋមសិលាសង់មន្ទីរពេទ្យបង្អែកកម្ពុជា-ចិនត្បូងឃ្មុំ, ១ មីនា ២០១៩

... (ដែលយើង)កសាងប្រទេសបានប៉ុណ្ណឹង ថាឯងទៅនាំចិនមកត្រួតត្រា ... **ទី ១ ខ្មែរមិនព្រមជាប់ខាតឲ្យចិនត្រួតត្រាខ្លួន។ បញ្ហាក់ចំពោះមុខអគ្គរដ្ឋទូតចិន ក៏ដូចជាប្រិយមិត្តចិនទាំងអស់ _ ទី២ចិនក៏មិនចង់ត្រួតត្រាខ្មែរដែរ។ គោលនយោបាយការបរទេសរបស់ចិន គឺចិនមិនចង់ត្រួតត្រាអ្នកណាទេ។ ចិនគ្រាន់តែចង់ធ្វើមិត្តជាមួយប្រទេសនានាលើពិភពលោក។ ចរន្តពីរនេះ វាត្រូវគ្នា** ... ប្រទេសណាសុខចិត្តហៅគេមកត្រួតត្រា។ ចិនខ្លួនឯងក៏មិនមាននយោបាយទៅត្រួតត្រាអ្នកណា ឬជ្រៀតជ្រែកអ្នកណាទេ ...៕

៤២. កម្ពុជាគ្មានការចាំបាច់មានវត្តមានកងទ័ពចិននៅលើទឹកដីខ្លួននោះទេ

សំណេះសំណាលជាមួយប្រជាពលរដ្ឋ និងនិស្សិតខ្មែរ មកពីបណ្តាប្រទេស ក្នុងសហគមន៍អឺរុប, ៤ កក្កដា ២០១៩

... រឿងយោធារបស់ចិន។ ម្តងហើយម្តងទៀតៗ ថា **កំពង់ផែសមុទ្ររាម ឬក៏តំបន់ទេសចរណ៍តារាសាគរ អាចនឹងក្លាយទៅជាមូលដ្ឋានកងទ័ពជើងទឹកចិន ... សូមជួយពិចារណាជាមួយគ្នាមើល តើយើងត្រូវការវត្តមានកងទ័ពបរទេសមកធ្វើអីនៅស្រុកខ្មែរនេះ។ តើមានការចាំបាច់ទេ។ ទៅវាយជាមួយអ្នកណា? សម្រាប់កម្ពុជា វាគ្មានការចាំបាច់សោះ។ ឯសម្រាប់ចិនវិញ ចាំបាច់អីមកជាក់កងទ័ពនៅស្រុកខ្មែរ បើចិននិងយើង(នៅ)ជិតគ្នាហ្នឹង?** ... បើមានបញ្ហាអ្វីកើតឡើងនៅសមុទ្រចិនខាងត្បូង ឬក៏ស្អី តែមួយភ្លែតចិនចល័តបាន។ ចាំបាច់អីជាក់នៅស្រុកខ្មែរ នាំឱ្យមានរឿង? ...៕

៤៣. មិនមានវត្តមានកងទ័ពបរទេសលើទឹកដីកម្ពុជាទេ ទទួលតែការហ្វឹកហាត់រួម និងការចូលចតនាវាពីគ្រប់ប្រទេស

សំណេះសំណាលជាមួយប្រជាពលរដ្ឋ និងនិស្សិតខ្មែរ មកពីបណ្តាប្រទេស ក្នុងសហគមន៍អឺរុប, ៤ កក្កដា ២០១៩

... **កម្ពុជាខ្លួនឯងមានចំណងក្នុងរដ្ឋធម្មនុញ្ញ ដែលហាមឃាត់ការតាំងទីយោធាបរទេសលើទឹកដីរបស់ខ្លួន ឬទីតាំងយោធាខ្លួននៅក្នុងទឹកដីប្រទេសក្រៅ លើកលែងតែក្រោមឆត្រអង្គការសហប្រជាជាតិ** ដែលមកដល់ពេលនេះ កងទ័ពយើងកំពុងតែមានវត្តមាននៅអាហ្វ្រិកកណ្តាល នៅម៉ាលី នៅស៊ូដង់ នៅស៊ូដង់ខាងត្បូង នៅលីបង់ ... ខ្ញុំសូមបញ្ជាក់ជាឱឡារិក មិនថា(កងទ័ព)ចិន ឬក៏អ្នកណាទេ គឺមិនត្រូវមានវត្តមាននៅលើទឹកដីកម្ពុជាទេ។ **ការហ្វឹកហាត់រួមគ្នា គឺជារឿងធម្មតា ហើយយើងនៅបន្តទទួលការចូលចតនៃនាវាចម្បាំងរបស់ប្រទេសនានា នៅកំពង់ផែក្រុងព្រះសីហនុ។ អាមេរិកមុនគេបង្អស់ចូលស្រុកខ្មែរ** ...៕

៤៤. មិនត្រូវការជំនាញការយោធា តែទទួលឱ្យផ្តល់ការហ្វឹកហ្វឺន

សំណេះសំណាលជាមួយសហគមន៍ខ្មែរនៅសហគមន៍ខ្មែរនៅសហរដ្ឋអាមេរិក/កាណាដា, ១២ ឧសភា ២០២២

... (នាវា)ប្រទេសណាក៏ដោយដែលចង់ចូល(ចត)កម្ពុជាអនុញ្ញាតទាំងអស់។ កន្លងទៅអាមេរិកក៏ចូល, បារាំងក៏ចូល, ចិនក៏ចូល, ជប៉ុនក៏ចូល, អូស្ត្រាលីក៏ចូល, អង់គ្លេសក៏ចូល ... មានការយល់ច្រឡំ។ Mike Pence សរសេរសំបុត្រមួយ ... **ខ្ញុំឆ្លើយបញ្ជាក់រឿងនេះម្តងហើយម្តងទៀត។ កម្ពុជាអត់ត្រូវការកងទ័ពបរទេសលើទឹកដីរបស់ខ្លួន។ ទោះបីកងទ័ពមកពីណាក៏ដោយ ក៏ប៉ុន្តែក្នុងស្ថានទូតរបស់ប្រទេសនានាមានអនុព័ន្ធយោធាចុះ**។ ខ្ញុំបាននិយាយជាមួយ Senator អាមេរិកថា អនុព័ន្ធយោធារបស់ខ្ញុំជានារី ប្រចាំនៅ Washington ... **ខ្ញុំអត់ត្រូវការជំនាញការយោធាអីទេ។ បើផ្តល់ការហ្វឹកហ្វឺនទទួល។** ខ្ញុំទៅជប៉ុនកន្លងទៅ ខ្ញុំក៏ស្នើសុំឱ្យជប៉ុនបន្ថែមនូវការបណ្តុះបណ្តាលនិស្សិតយោធាកម្ពុជា ...៕

៤៥. សហប្រតិបត្តិការត្បូងពេជ្រកម្ពុជា-ចិន ដាក់ខេត្ត៨ ជាប៉ូលសេដ្ឋកិច្ចទី៨

សំណេះសំណាលជាមួយកម្មករ និយោជិត និងដាក់ឱ្យដំណើរការរោងចក្រផលិតសំបកកង់ដើម្បីអបអរសាទរខួបលើកទី១០ នៃគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ នៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ, ២២ ឧសភា ២០២៣

... ខ្ញុំនិងឯកឧត្តម Xi Jinping បានឯកភាព ដូចអ្វីដែលឯកឧត្តម Wang Wentian បានលើកឡើងគឺ **សហប្រតិបត្តិការត្បូងពេជ្រ មានគោលដៅកិច្ចសហប្រតិបត្តិការនយោបាយ គុណភាព សមត្ថភាពផលិតកម្ម កសិកម្ម ថាមពល សន្តិសុខ ការផ្លាស់ប្តូរប្រជាជននិងប្រជាជន អភិវឌ្ឍច្រកបៀង ឧស្សាហកម្មនិងបច្ចេកវិទ្យា។** ត្រង់ហ្នឹង តំបន់សេដ្ឋកិច្ចពិសេសនេះគឺជាកន្លែងអភិវឌ្ឍឧស្សាហកម្ម និងបច្ចេកវិទ្យា។ គោលដៅគឺចំកន្លែងហ្នឹង។ ប៉ុន្តែ នៅ**ច្រកបៀងមួយទៀតនៃសហប្រតិបត្តិការត្បូងពេជ្រ គឺមណ្ឌលអង្គរ ដែលខ្ញុំនឹងជាក់ខេត្ត៤ គឺខេត្តពោធិសាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន ទៅជាប៉ូលសេដ្ឋកិច្ចទី៤** ...៕

៤៦. ទំនាក់ទំនងកម្ពុជា-អាមេរិក អាក្រក់តាមមាត់អ្នកប្រឆាំង

សន្និសីទសារព័ត៌មាន និងសំណួរ/ចម្លើយ ក្រោយកិច្ចប្រជុំកំពូលអាស៊ានទី៤០ និង៤១ នៅកម្ពុជា, ១៣ វិច្ឆិកា ២០២២

... និយាយពីទំនាក់ទំនងរវាងកម្ពុជា-អាមេរិកបន្តិច។ រាជរដ្ឋាភិបាលមិនដែលបាននិយាយថាទំនាក់ទំនងរវាងកម្ពុជានិងអាមេរិកអាក្រក់ទេ។ **ការលេចឮការប្រមាថថា អាមេរិកមិនត្រូវការមេដឹកនាំកម្ពុជាស្អីៗនេះ ចេញមកតែពីពាក្យរបស់ក្រុមអ្នកដែលគេមិនចូលចិត្តយើង** ... គ្រាន់តែលើកពេលប្រជុំនៅឯទីក្រុងវ៉ាស៊ីងតោនប៉ុន្មានថ្ងៃ គេថាមកពី ហ៊ុន សែន បានជាអាមេរិកលើកពេល ... ឥឡូវនេះ វាបានបញ្ជាក់ច្បាស់ Joe Biden មកភ្នំពេញ ... **ជាមេដឹកនាំ គេមានសុជីវធម៌ គេមានសីលធម៌។ ទោះបីជា មានចំណុចមិនត្រូវគ្នាយ៉ាងម៉េចក៏ដោយ ប៉ុន្តែគេមានឥរិយាបថនៅក្នុងការសន្ទនាប្រកបដោយការស្ថាបនា** ...៕

៤៧. ទំនាក់ទំនងកម្ពុជា-អាមេរិក ដើរដល់ចំណុចកំពូលជាប្រវត្តិសាស្ត្រ

សំណេះសំណាលជាមួយសហគមន៍ខ្មែរនៅសហគមន៍ខ្មែរនៅសហរដ្ឋអាមេរិក/កាណាដា, ១២ ឧសភា ២០២២

...អំពីបញ្ហាទំនាក់ទំនងរវាងកម្ពុជា-អាមេរិកតើវាដល់ណាហើយ? ហើយមានស្អីខ្លះ ដែលជាឧបសគ្គ? **ដំបូងគួរតែនិយាយថា ទំនាក់ទំនងកម្ពុជា-អាមេរិក បានដើរដល់ចំណុចកំពូលដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រ**។ ពិតមែនតែថាវាលិច

អណ្តែតៗ ក៏ប៉ុន្តែសូមសង្កេតបញ្ហា២ មុនគេ។ **ទី១ មុនឆ្នាំ២០០០ តើអាមេរិកមានស្ថានទូតផ្ទាល់ខ្លួននៅកម្ពុជាឬអត់? ចម្លើយ គឺអត់មានទេ។ (ស្ថានទូត) អាមេរិកជួលផ្ទះគេនៅទេ។ ក្រោយឆ្នាំ២០០០ ជាពិសេស ក្រោយដំណាក់កាលដែលកម្ពុជារកបានសន្តិភាពពេញលេញ អាមេរិកសាងសង់ស្ថានទូតនៅកម្ពុជា ... ទី២ ពេលនេះទំហំពាណិជ្ជកម្មរីកធំបំផុតក្នុងប្រវត្តិ។ ការនាំចូលមកអាមេរិក មានជាង ៩ ពាន់លានដុល្លារ** ... មិនមែនល្អឥតខ្ចោះទេ។ មានការភាន់ច្រឡំមួយចំនួនដែលផ្តើមចេញពីការមិនយល់គ្នា ...៕

៤៨. ការរីកចម្រើនរបស់កម្ពុជា មិនអាចផ្តាច់ចេញពីជំនួយឧបត្ថម្ភរបស់ជប៉ុន

បើកការដ្ឋានសង់ស្ថានីយ៍ប្រព្រឹត្តិកម្មទឹកកខ្វក់បឹងជើងឯក
ក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងប្រទេសជប៉ុន, ២២ កុម្ភៈ ២០២២

... **ការរីកចម្រើនរបស់កម្ពុជា មិនអាចកាត់ផ្តាច់ចេញពីការរួមចំណែក នៃដៃគូអភិវឌ្ឍន៍និយាយជារួម និងនិយាយដោយឡែក ការផ្តល់ជំនួយឧបត្ថម្ភរបស់ប្រទេសជប៉ុន**។ ប្រទេសជប៉ុនបានដើរតួនាទីជាសហប្រធាន នៃការស្តារឡើងវិញនៃប្រទេសកម្ពុជា ប្រើឈ្មោះថា ICORC នៅពេលនោះ ... ការប្រជុំលើកទី១ ក្នុងឆ្នាំ ១៩៩២ ពិភាក្សាពីការអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីស ប៉ុន្តែបាននិយាយដល់ការកសាងឡើងវិញ ... **កម្ពុជាតែងនឹកឃើញការួមចំណែកពីដៃគូអភិវឌ្ឍទាំងអស់ ក៏ដូចជាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ក្នុងហ្នឹងមួយចំណែកធំបានមកពីការឧបត្ថម្ភគាំទ្ររបស់ជប៉ុនគ្រាដំបូង ដែលផ្តល់ជំនួយច្រើនជាងគេ** ...៕

៤៩. ចង់បាននិនិយោគិននិងទីផ្សារជប៉ុនកាន់តែធំ ដើម្បីពង្រឹងទំនាក់ទំនងនយោបាយ

អបអរសាទរខួប ១០+១ឆ្នាំ នៃប្រតិបត្តិការរបស់ក្រុមហ៊ុនមីនេរៀ, ១ ធ្នូ ២០២២

... ជំនួយជប៉ុនមកដល់ប្រទេសកម្ពុជាមិនតូចទេ ប៉ុន្តែអ្វីដែលយើងចង់បានស្ថិរភាពបំផុត គឺអ្នកវិនិយោគជប៉ុនកាន់តែច្រើនមកកម្ពុជា។ យើងដឹងថាជប៉ុនមានតួនាទីជួយមិនគ្រាន់តែកម្ពុជាទេ តែក៏ប្រទេសដទៃទៀតលើពិភពលោក។ **អ្វីដែលយើងចង់បានគឺអ្នកវិនិយោគជប៉ុនមកកាន់កម្ពុជា និងជប៉ុនបើកទីផ្សារឱ្យធំ ដើម្បីនាំទំនិញកម្ពុជាចូលទៅ ... ឃើញមានកំណើននៃទំហំពាណិជ្ជកម្មរវាងកម្ពុ**

ជា និងជប៉ុន តាមរយៈក្រុមហ៊ុនជប៉ុនមកវិនិយោគនៅកម្ពុជា។ សម្រេចផលិតផលបានហើយ នាំចូលទៅកាន់ប្រទេសជប៉ុន។ យើងអាចធ្វើរបៀបហ្នឹងតទៅទៀត ដើម្បីលើកកម្ពស់កម្រិតទំនាក់ទំនង។ **ក្នុងទំនាក់ទំនងរវាងប្រទេសនិងប្រទេស ទំនាក់ទំនងសេដ្ឋកិច្ចមានច្រើន ទំនាក់ទំនងនយោបាយក៏រឹងមាំតាមនោះដែរ** ...។

៥០. កម្ពុជា និងកូរ៉ែ ជាប្រទេសជន្លង, ដោះស្រាយឲ្យកូនកាត់ចេះខ្មែរផងចេះកូរ៉ែផង

ពិធីជួបជុំសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពលករ និងនិស្សិតខ្មែរ
កំពុងស្នាក់នៅ/ធ្វើការ/សិក្សានៅសាធារណរដ្ឋកូរ៉ែ, ៣ កុម្ភៈ ២០២០

...បញ្ហាដែលត្រូវឆ្លើយតប សម្រាប់ក្មួយៗកម្មករកម្មការិនី ក៏ដូចជានិស្សិត និងអ្នកដែលមានគ្រួសារជាកូរ៉ែ គឺ**កម្ពុជានិងកូរ៉ែបានក្លាយជាប្រទេសជន្លង ដែលមានស្ត្រីនិងបុរស ប៉ុន្មានជាង ៨ពាន់នាក់មានគ្រួសារជាជនជាតិកូរ៉ែ។ បើអញ្ចឹង កូនឡើងជាង ១ម៉ឺននាក់ហើយ។ ខ្ញុំតែងបានពិភាក្សាជាមួយមេដឹកនាំកូរ៉ែ និងចុងក្រោយ ជាមួយប្រធានាធិបតីកូរ៉ែ Moon Jae-in ពេលដែលមកទស្សនកិច្ចនៅកម្ពុជា ថារកវិធីឱ្យកូនៗចៅៗ ដែលបានកើតមក ជាកូនកាត់(ខ្មែរកូរ៉ែ) ឱ្យបានចេះភាសាខ្មែរផង ចេះភាសាកូរ៉ែផង** ... ខ្ញុំអាចលើកបញ្ហានេះ ជាមួយប្រធានាធិបតីកូរ៉ែ សាជាថ្មីម្តងទៀត និងខានស្អែក ជាមួយនាយករដ្ឋមន្ត្រីកូរ៉ែ ...។

៥១. ទំនាក់ទំនងកម្ពុជា-កូរ៉ែ ត្រូវប្រែប្រួលផ្លាស់ប្តូរតាមស្ថានការណ៍នយោបាយ

ពិធីជួបជុំសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពលករ និងនិស្សិតខ្មែរ កំពុងស្នាក់នៅ/ធ្វើការ/សិក្សានៅសាធារណរដ្ឋកូរ៉ែ, ៣ កុម្ភៈ ២០២០

... **ទំនាក់ទំនងកម្ពុជា-កូរ៉ែ បានឆ្លងកាត់ការលិចអណ្តែតៗ ក្នុងអតីតកាល។ ហេតុផលនៃការលិចអណ្តែតៗនោះ មិនមែនចាប់ផ្តើមពីនយោបាយការបរទេសរបស់កម្ពុជាទេ។ វាចាប់ផ្តើមពីស្ថានភាពនៅឯកូរ៉ែ និងចាប់ផ្តើមពីស្ថានភាពនៃសង្គ្រាមត្រជាក់។ នៅប្រទេសកូរ៉ែខ្លួនឯង មានបែងចែកជាកូរ៉ែខាងត្បូង និងកូរ៉ែខាងជើង បន្ទាប់ពីសង្គ្រាមកូរ៉ែហើយ។ ស្ថានភាពនេះ បានជាក់ឱ្យនយោបាយការបរទេសកម្ពុជាត្រូវស្ថិតក្នុងស្ថានភាពប្រែប្រួល នៅពេលកម្ពុជាខ្លួនឯងក៏មានការផ្លាស់ប្តូរដែរ**។ មានដំណាក់កាលមួយ កម្ពុជាមានទំនាក់ទំនងជាមួយកូរ៉ែខាង

ត្បូង និងកូរ៉ែខាងជើង។ ក្រោយមក កូរ៉ែខាងត្បូងបានចាកចេញ នៅសល់(តែទំនាក់ទំនងជាមួយ)កូរ៉ែខាងជើង។ ដល់ឆ្នាំ ១៩៧០-១៩៧៥ ទំនាក់ទំនងជាមួយនឹងកូរ៉ែខាងជើងត្រូវផ្អាក ហើយកូរ៉ែខាងត្បូងចាប់ផ្តើម។ ដល់ដំណាក់កាល ប៉ុលពត(មាន)ទំនាក់ជាមួយកូរ៉ែខាងជើង មិនមានទំនាក់ទំនងនឹងកូរ៉ែខាងត្បូង ...។

៥២. ជោគជ័យនៃការបង្កើតទំនាក់ទំនងការទូតជាមួយកូរ៉ែ គឺនាំពលករ/និស្សិត/ប្រជាជនមកធ្វើការ/រៀនសូត្រ/ស្នាក់នៅ

ពិធីជួបជុំសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពលករ និងនិស្សិតខ្មែរ
កំពុងស្នាក់នៅ/ធ្វើការ/សិក្សានៅសាធារណរដ្ឋកូរ៉ែ, ៣ កុម្ភៈ ២០២០

... ក្នុងហាន:ជាស្ថាបនិកទំនាក់ទំនងជាមួយសាធារណរដ្ឋកូរ៉ែ ហើយដែលមានការគាំទ្រពីព្រះមហាក្សត្រ អាចចាត់ទុកថា **យើងមានជោគជ័យធំណាស់ក្នុងការបង្កើតទំនាក់ទំនងការទូតជាមួយប្រទេសមួយនេះ។ ក្មួយៗ អាចចោទជាសំណួរថាប្រសិនបើពូមិនបានសម្រេចចិត្តឱ្យចុះហត្ថលេខា និងមកទស្សនកិច្ចកូរ៉ែដើម្បីបង្កើតការទូតឡើងវិញ ហើយមានទំនាក់ទំនងតែជាមួយកូរ៉ែខាងជើង តើក្មួយៗអាចមានវត្តមាននៅប្រទេសកូរ៉ែខាងត្បូងនេះទេ? ...** ឥឡូវ យើងជាមួយកូរ៉ែបានឆ្លងកាត់នូវវិញ្ញាសាល្អ ... ក្នុងរយៈពេលជាង ២០ឆ្នាំនៃទំនាក់ទំនងការទូតជាមួយគ្នានេះ មិនមានអ្វីជាស្នាមប្រេះឆានោះទេ ...។

៥៣. ទំនាក់ទំនងទន្លេហាន-មេគង្គ កិច្ចសហប្រតិបត្តិការទ្វេនិងពហុភាគី

ពិធីជួបជុំសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពលករ និងនិស្សិតខ្មែរ
កំពុងស្នាក់នៅ/ធ្វើការ/សិក្សានៅសាធារណរដ្ឋកូរ៉ែ, ៣ កុម្ភៈ ២០២០

... យើងបានខិតខំប្រឹងប្រែងរួមជាមួយនឹងកូរ៉ែ រួមជាមួយនឹងដៃគូអាស៊ានដទៃទៀត ដើម្បីឱ្យមានប្រជុំរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-កូរ៉ែ នៅ Busan កាលពីឆ្នាំទៅ ... បង្ហាញពីតួនាទីសម្របសម្រួលមិនអាចកាត់ថ្លៃបានរបស់កម្ពុជា នោះម៉្យាង។ **ម៉្យាងទៀត ខ្ញុំបានស្នើសុំឱ្យមានការលើកកម្រិតទំនាក់ទំនងក្របខ័ណ្ឌមេគង្គ-កូរ៉ែ ដែលមុននេះត្រឹមកម្រិតថ្នាក់រដ្ឋមន្ត្រីការបរទេស ទៅថ្នាក់ប្រមុខរដ្ឋ/រដ្ឋាភិបាល ឱ្យស្របទៅនឹងនយោបាយឆ្ពោះទៅទិសខាងត្បូងរបស់កូរ៉ែ ... ចិន**

មានឡានឆាង-មេគង្គ ជប៉ុនមានថ្នាក់ប្រមុខរដ្ឋរដ្ឋាភិបាលជប៉ុន-មេគង្គ ... យើងសម្រេចបានជាគំនិតផ្តួចផ្តើមមួយជំរុញទំនាក់ទំនងទន្លេហាន-មេគង្គ ... ជាកិច្ចសហប្រតិបត្តិការរវាងទ្វេភាគីផង និងភាពជាដៃគូរវាងអាស៊ាន-កូរ៉េ និងរវាងមេគង្គ-កូរ៉េ ...។

៥៤. ក្រៅពីប្រាក់ចំណូល ពលកររមកកូរ៉េ ត្រូវយកបច្ចេកវិទ្យានិងជំនាញទៅបង្កើតការងារក្នុងស្រុក

ពិធីជួបជុំសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពលករ និងនិស្សិតខ្មែរ
កំពុងស្នាក់នៅ/ធ្វើការ/សិក្សានៅសាធារណរដ្ឋកូរ៉េ, ៣ កុម្ភៈ ២០២០

... អ្នកទាំងអស់ ដែលបានមកធ្វើការទីនេះ កូរ៉េមានការខ្វះពលកម្មពិតប្រាកដ។ ដូច្នេះ កូរ៉េត្រូវនាំពលកម្មចូល ហើយវាជាភ័ព្វសំណាងនៅពេលដែលកម្មករ/ការិនីរបស់យើង មកធ្វើការដោយមានគោរពច្បាប់ មានសីលធម៌ល្អ ត្រូវបានទទួលការកោតសរសើរល្អពីសំណាក់កាគីកូរ៉េ។ **យើងបានសូមបង្កើនចំនួនពលកររឱ្យបានច្រើនបន្ថែមទៀត ដើម្បីម្ខាងដោះស្រាយការងារធ្វើ តែម្ខាងទៀតយកបច្ចេកវិទ្យាទៅប្រើប្រាស់ក្នុងប្រទេស មិនមែនទទួលតែប្រាក់ខែមួយមុខទេ។ នៅពេលដែលក្មួយៗធ្វើការនៅទីនេះ ក្មួយៗនឹងមានជំនាញ ហើយជំនាញនោះហើយដែលផ្តល់ឱ្យក្មួយៗអាចនឹងទៅរកការងារធ្វើ បើក្រុមហ៊ុនកូរ៉េទៅ ក្មួយៗអាចនឹងមានការងារធ្វើជាមួយក្រុមហ៊ុនកូរ៉េនៅស្រុកខ្មែរទៀតឬក៏អាចបង្កើតការងារ**។ បន្ទាប់ពីបញ្ចប់ការងារជាពលករនៅឯកូរ៉េនេះ មានមួយចំនួនបានទទួលជោគជ័យ ពេលត្រឡប់ទៅបង្កើតការងារ បង្កើតមុខរបរនៅក្នុងប្រទេស ...។

៥៥. ស្វាយ/សម្លៀកបំពាក់ក្នុងទីផ្សារកូរ៉េ បញ្ជាក់ពីការជឿនលឿនទៅមុខនៃសេដ្ឋកិច្ចកម្ពុជា

ពិធីជួបជុំសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពលករ និងនិស្សិតខ្មែរ
កំពុងស្នាក់នៅ/ធ្វើការ/សិក្សានៅសាធារណរដ្ឋកូរ៉េ, ៣ កុម្ភៈ ២០២០

... ក្មួយៗបានទិញស្វាយទទួលទានហើយ ឬនៅទេ? ពីនេះតទៅ ក្មួយៗដែលនឹកស្រុកអាចទៅរកទិញស្វាយខ្មែរទទួលទាន(ស្នូរទេះដៃ)។ **វត្តមានស្វាយខ្មែរនៅក្នុងទីផ្សារកូរ៉េ បង្ហាញពីការជឿនលឿនទៅមុខនៃសេដ្ឋកិច្ចរបស់កម្ពុជាដែលតម្រូវ**

តាមស្តង់ដាក្នុងទីផ្សារនៃប្រទេសជឿនលឿន ហើយនឹងធ្វើឱ្យអ្នកជាំស្វាយនៅកម្ពុជាមានលទ្ធភាពកាន់តែខ្ពស់ ពង្រីកអាជីវកម្មស្វាយកាន់តែធំ។ នេះមិនមែនផ្តត់ផ្តង់កូរ៉េ៥០ លាននាក់នោះទេ ប៉ុន្តែកូរ៉េក៏មានទេសចរច្រើនដែរ ... **ដោយសារពលកម្មនៅកូរ៉េថ្លៃ កូរ៉េទៅផលិតនៅស្រុកខ្មែរ ... ក៏មាននាំចេញសម្លៀកបំពាក់មកផ្តត់ផ្តង់នៅកូរ៉េខាងត្បូង** ...។

៥៦. រៀបចំការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងកម្ពុជានិងកូរ៉េ

ពិធីជួបជុំសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពលករ និងនិស្សិតខ្មែរ
កំពុងស្នាក់នៅ/ធ្វើការ/សិក្សានៅសាធារណរដ្ឋកូរ៉េ, ៣ កុម្ភៈ ២០២០

... នៅថ្ងៃក្រោយ **យើងរកវិធីពង្រីកទីផ្សារនៅកូរ៉េ។ យើងជាមួយកូរ៉េ បានចាប់ផ្តើមរៀបចំការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជានិងកូរ៉េ ដើម្បីពង្រីកទីផ្សារនៅកូរ៉េកាន់តែធំ ... ហេតុអីបានជាកូរ៉េអាចចាប់ដៃជាមួយយើងបាន ហើយយើងអាចចាប់ដៃកូរ៉េបាន? វាទាល់តែសងខាងមានសុច្ឆន្ទៈ។ សុច្ឆន្ទៈតែមួយក៏មិនគ្រប់គ្រាន់ទេ វាទាល់តែកម្ពុជាខ្លួនឯងមានការអភិវឌ្ឍដែរ**។ ដូចជាពាណិជ្ជកម្មមិនមែនត្រូវតែនាំចេញតែពីកូរ៉េទៅកម្ពុជា និងគ្មានទំនិញពីកម្ពុជាបកត្រឡប់មកវិញ ហើយធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េកើតទេ។ **យើងសង្ឃឹងឃើញថា មានលទ្ធភាពដើម្បីនឹងពង្រីកទំនិញពីកម្ពុជានាំចេញមកកូរ៉េ**។ ប្រទេសដែលមានសមត្ថភាពនាំចេញ ជាប្រទេសនោះមានការអភិវឌ្ឍដែរ។ បើអត់មានការអភិវឌ្ឍ ធ្វើម៉េចមានទំនិញនាំចេញ? ... យើងត្រូវខំពង្រីកទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា-កូរ៉េ ទន្ទឹមនឹងពង្រីកទំនាក់ទំនងជាមួយនឹងប្រទេសដទៃ ...។

៥៧. ជើងហោះហើរកូរ៉េ-កម្ពុជា ១អាទិត្យ ៥០ជើង, ទំហំវិនិយោគកូរ៉េជាង ៤ពាន់លាន

ពិធីជួបជុំសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពលករ និងនិស្សិតខ្មែរ
កំពុងស្នាក់នៅ/ធ្វើការ/សិក្សានៅសាធារណរដ្ឋកូរ៉េ, ៣ កុម្ភៈ ២០២០

... **ការហោះហើររវាងកម្ពុជានិងកូរ៉េ ដូចជាមួយអាទិត្យ ៥០ជើង** ... ចិនជាប្រទេសក្រៅតំបន់ ប៉ុន្តែមានជើងហោះហើរច្រើនជាងគេទាំងអស់ ដោយសារហោះពីគ្រប់ទីកន្លែង។ កាលពីពេលមុននេះ កូរ៉េគឺជាប្រទេសនៅក្រៅតំបន់ ដែល

ឆ្ងាយជាងគេ និងដែលមានជើងហោះហើរច្រើនបំផុត។ ជប៉ុនបើកជើងហោះហើរ
ឥឡូវនេះអ្នកធ្វើដំណើរកាន់តែច្រើន ជប៉ុនកំពុងចង់ពង្រីកជើងហោះហើរបន្ថែម។
**វាចំណុះទៅលើការកើនឡើងនៃកិច្ចសហប្រតិបត្តិការក្នុងវិស័យសេដ្ឋកិច្ច ពាណិជ្ជ
កម្ម ពិសេសវិស័យទេសចរណ៍ ដែលយើងត្រូវបន្តខំប្រឹងប្រែងអភិវឌ្ឍកម្ពុជា ទាក់
ទាញការវិនិយោគពីកូរ៉េទៅកាន់កម្ពុជា។ ទំហំទុនវិនិយោគរបស់កូរ៉េទៅកាន់កម្ពុជា
ដូចជាជាង ៤ ពាន់លាន** ...។

៥៨. មានអ្វីកើតនៅឧបទ្វីបកូរ៉ែ ត្រូវស្ថិតនៅជាមួយប្រជាជនកូរ៉ែ

ពិធីជួបជុំសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពលករ និងនិស្សិតខ្មែរ
កំពុងស្នាក់នៅ/ធ្វើការ/សិក្សានៅសាធារណរដ្ឋកូរ៉ែ, ៣ កុម្ភៈ ២០២០

... នៅឧបទ្វីបកូរ៉ែ រាប់ទាំងនៅកូរ៉ែ បើនិយាយតាមមួយបែប អ្នកទាំងអស់គ្នា
នៅកៀកនឹងតំបន់នុយក្លេអ៊ែរ។ កាលពីឆ្នាំ២០១៣-២០១៤ មានការគំរាមគាំយគ្នា
មនុស្សមួយចំនួនទាមទារឱ្យខ្ញុំជម្លៀសពលករខ្មែរ។ ខ្ញុំគិតថាមិនត្រូវយកការភ័យ
ខ្លាចសង្គ្រាមកូរ៉ែដាក់ពីមុខ ហើយចាកចេញ ឬមិនមានទំនាក់ទំនងជាមួយកូរ៉ែទេ
... យ៉ាងណាក្តី យើងសង្ឃឹមថាទំនាក់ទំនងរវាងខាងជើងនិងខាងត្បូងនៅតែបន្ត
ល្អ ដើម្បីជាផ្នែកមួយនៃការធូរស្រាលក្នុងឧបទ្វីបកូរ៉ែ ... **គ្រាន់តែសូមផ្តាំផ្ញើថាបើ
សិនជាមានរឿងអីកើតឡើង ក៏សូមកុំស្លន់ស្លោ។ ប្រជាជនកូរ៉ែគេរស់នៅបាន ក៏
រស់នៅជាមួយគេអញ្ចឹងទៅ។ និយោជកដែលមកទីនេះ ក៏ដូចជាថៅកែៗរោងចក្រ
មានការទទួលខុសត្រូវរបស់គេ។ រដ្ឋាភិបាលកូរ៉ែមានការទទួលខុសត្រូវហើយ**...។

៥៩. នៅតែរក្សាទំនាក់ទំនងជាមួយកូរ៉ែទាំងពីរ

ពិធីជួបជុំសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពលករ និងនិស្សិតខ្មែរ
កំពុងស្នាក់នៅ/ធ្វើការ/សិក្សានៅសាធារណរដ្ឋកូរ៉ែ, ៣ កុម្ភៈ ២០២០

... ទំនាក់ទំនងខាងនយោបាយ ការទូត ទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម និង
ផ្នែកជំទៃទៀតនាំមកនូវការរីកលូតលាស់សម្រាប់កម្ពុជា។ កម្ពុជាទទួលផលច្រើន
ជាងពីការដាក់ទំនាក់ទំនងការទូតរវាងកម្ពុជានិងកូរ៉ែ ... **ខ្ញុំនឹងមានការខកចិត្ត
ប្រសិនបើការដាក់ទំនាក់ទំនងជាមួយកូរ៉ែខាងត្បូង មិនត្រឹមតែធ្វើឱ្យកូរ៉ែខាងជើង**

**ខឹង ប៉ុន្តែថែមទាំងគ្មានកើតមានការលូតលាស់ក្នុងទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម
ដែលផ្តល់ផលប្រយោជន៍ឱ្យកម្ពុជា ... ឥឡូវ ខ្ញុំអាចនិយាយបានដោយមោទនភាព
ថា "ខ្ញុំជាជនជោគជ័យម្នាក់ក្នុងនយោបាយនេះ" ... ទំនាក់ទំនងរវាងកូរ៉ែទាំងពីរ
នៅតែរក្សា**...។

៦០. ឧបទ្វីបកូរ៉ែគ្មាននុយក្លេអ៊ែរ និងស្រាយទំនាស់តាមផ្លូវចរចាដោយសន្តិវិធី

ពិធីជួបជុំសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពលករ និងនិស្សិតខ្មែរ
កំពុងស្នាក់នៅ/ធ្វើការ/សិក្សានៅសាធារណរដ្ឋកូរ៉ែ, ៣ កុម្ភៈ ២០២០

... យើងត្រូវអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ពាក់ព័ន្ធនឹងកូរ៉ែ
ខាងជើង។ អត់មានជម្រើសផ្សេងទេ។ នេះជាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា
សន្តិសុខ ដែលយើងត្រូវតែគោរព។ ក៏ប៉ុន្តែ**ទំនាក់ទំនងរវាងយើងជាមួយកូរ៉ែខាង
ជើងនៅតែបន្តធម្មតា ដោយមិនយកកូរ៉ែខាងជើងធ្វើជាសត្រូវទេ។ យើងនៅតែ
ទទូចឱ្យឧបទ្វីបកូរ៉ែគ្មានអាវុធនុយក្លេអ៊ែរ និងមានដំណោះស្រាយតាមផ្លូវចរចា។
បើទោះបីជាការចរចាកើតឡើងរវាងកូរ៉ែខាងជើងនិងសហរដ្ឋអាមេរិក កូរ៉ែខាង
ជើងជាមួយកូរ៉ែខាងត្បូង ឬការចរចាពហុភាគីកកើតឡើងវិញ ក៏វាសុទ្ធតែជា
ជំរើសដោយសន្តិវិធីទាំងអស់**...។

៦១. មិនមែនបោះបង់ចោលឥណ្ឌា តែរង់ចាំពេលវេលាសមស្រប ទទួលចូល ASEM

បិទសន្និបាតបូកសរុបការងារក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ,
៣១ មករា ២០២០

... យើងគប្បីយោគយល់ចំពោះឥណ្ឌា ដែលនៅទីក្រុងភ្នំពេញឆ្នាំ២០១២ ...
ដោយសារតែមានការលំបាកក្នុងការការពារផលប្រយោជន៍ ឥណ្ឌាមិនទាន់ឈាន
ដល់ដំណាក់កាលដែលខ្លួនត្រូវធ្វើទេ។ **ខ្ញុំបាននិយាយជាមួយនាយករដ្ឋមន្ត្រី
ឥណ្ឌា បន្ទាប់ពីចេញពីសាលប្រជុំថា អាចនិយាយតាមរូបមន្ត ១៥ បូក ១ បានឬ
ទេ? យើងមិនបោះបង់ចោលឥណ្ឌាទេ ក៏ប៉ុន្តែន័យត្រង់កន្លែងនេះ គឺចង់បញ្ជាក់
ថា យើងបើកទ្វារចំហសម្រាប់ពេលវេលាសមស្របណាមួយ ដែលឥណ្ឌានឹងចូល**

រួមនៅក្នុងកិច្ចព្រមព្រៀង ASEM ... យើងត្រូវចរចាជាមួយចិន សាធារណរដ្ឋកូរ៉េ អឺរ៉ាស៊ី ដើម្បីចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ...៕

៦២. ភាពជាដៃគូជាមួយអាមេរិកនិងឥណ្ឌា មិនមានសម្ពាធលើភាពជាដៃគូជាមួយចិន

សន្និសីទសារព័ត៌មាន និងសំណួរ/ចម្លើយ ក្រោយកិច្ចប្រជុំកំពូលអាស៊ានទី៤០ និង៤១ នៅកម្ពុជា, ១៣ វិច្ឆិកា ២០២២

... អំពីការ**បង្កើនដៃគូគ្រប់ជ្រុងជ្រោយជាមួយនឹងអាមេរិកជាមួយឥណ្ឌា តើមានឥទ្ធិពល(សម្ពាធ)អីជាមួយចិន។** ចង់បញ្ជាក់ប្រាប់ថា ចិនក៏ទើបនឹងបានហានៈដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយកាលពីឆ្នាំទៅដែរ។ ដូច្នេះវាមានទៅស្មើនឹងគ្នា។ យើងឲ្យទាំងចិន អូស្ត្រាលី ក្នុងពេលតែមួយ។ ឥឡូវយើងឲ្យទៅអាមេរិកនិងឥណ្ឌាក៏ក្នុងពេលតែមួយ។ អ្វីដែលជាផលចំណេញគឺអាស៊ាននោះឯង ... **អាស៊ានជាចំណុចកណ្តាល ជាស្នូលដែលងាកទៅម្ខាង អាមេរិក, ឥណ្ឌា, ចិន, អូស្ត្រាលីជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរបស់ខ្លួន។ មិនមែនចាប់ចិនដើម្បីរុញអាមេរិក ឬចាប់អាមេរិកដើម្បីរុញចិនទេ។ សូមបំបាត់ចោលការគិតគូរនៅក្នុងអារម្មណ៍នៃអ្នកសារព័ត៌មានរបស់កម្ពុជា ... ឲ្យតែឃើញចាប់ដៃអាមេរិកតែងតែថាទាត់ចោលចិន ចាប់ដៃចិនទាត់ចោលអាមេរិក។ នៅលើពិភពលោកបច្ចុប្បន្ន គេឆ្លាតណាស់ហើយជាវិធីសាស្ត្រនៃការគ្រប់គ្រងទំនាក់ទំនងអន្តរជាតិនៃប្រទេសនីមួយៗ ...៕**

៦៣. ចរន្តសកលភាវូបនីយ៍កម្មពហុភាគីនិយម មិនឯកតោនិយម ឬគាំពារនិយម

ចែកសញ្ញាបត្រដល់និស្សិត សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២៦ ធ្នូ ២០១៩

... មានការចុះផ្សាយពីសង្គ្រាមពាណិជ្ជកម្មរវាងឥណ្ឌានេស៊ីនិងអឺរ៉ុបបានកើតឡើង ដែលក្នុងនោះមានការដាក់ប្តឹងគ្នាទៅវិញទៅមក ហើយការនាំចូលទំនិញពីអឺរ៉ុបត្រូវបានឥណ្ឌានេស៊ីហាមឃាត់ ជាការឆ្លើយតបជាមួយការដែលអឺរ៉ុបបានធ្វើចំពោះទំនិញដូងប្រេងរបស់ឥណ្ឌានេស៊ី ... **គប្បីបន្តតាមមើលការពង្រឹងភាពជាដៃគូ ជប៉ុន ចិន កូរ៉េខាងត្បូង និងការដែលប្រធានាធិបតីសហរដ្ឋអាមេរិកប្រកាសថានឹងចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយប្រធានាធិបតីចិន។ បើ(វាកើត)អញ្ចឹង**

ពិភពលោកនឹងមានស្ថានភាពល្អប្រសើរ ក្នុងដំណើរសាកលភាវូបនីយ៍កម្មជាពហុភាគីនិយម មិនមែនជាឯកតោនិយម ឬគាំពារនិយមនោះទេ ...៕

៦៤. ការភ្ជាប់នយោបាយជាមួយពាណិជ្ជកម្ម បំពានក្របខ័ណ្ឌពហុភាគីនិយម និង WTO

កិច្ចសម្ភាសន៍ផ្តាច់មុខជាមួយវិទ្យុមិត្តភាពកម្ពុជា-ចិន, ១១ កុម្ភៈ ២០២៣

... ប្រទេសអាស៊ាន ទទួលនូវការគំរាមច្រើនណាស់ ដូចជាគំរាមមិនទិញប្រេងដូងពីឥណ្ឌានេស៊ី ពីម៉ាឡេស៊ី ... **ជាអង្គការពាណិជ្ជកម្មពិភពលោក ហេតុអីបានជាក្រុមប្រទេសមួយ ឬក៏ប្រទេសមួយអាចជាក់គំនាប និងគំរាមកំហែងទៅលើប្រទេសដទៃ ដោយផ្សារភ្ជាប់រឿងនយោបាយជាមួយបញ្ហាពាណិជ្ជកម្ម** ... ដោយសារតែទណ្ឌកម្មចុះឡើងៗ ពិភពលោកកំពុងជ្រួលច្របល់ ធ្វើឲ្យប្រទេសទាំងអស់នៅលើពិភពលោកត្រូវដួលប្រទះអតិផរណា។ (ទោះជាថា)វិបត្តិសេដ្ឋកិច្ចមិនទាន់ដើរមកដល់ តែវាហាក់ដូចជាបានដើរដល់ហើយ។ **លើការជាក់ស្តែង ប្រេងឡើងថ្លៃ វិបត្តិថាមពល និងវិបត្តិស្បៀងកំពុងកើតឡើង ...ជាការបំពានលើក្របខ័ណ្ឌពហុភាគីនិយម និងលើក្រឹត្យក្រមអង្គការពាណិជ្ជកម្មពិភពលោកផងដែរ ...៕**

៦៥. ពិភពលោកបច្ចុប្បន្នចំណុះឲ្យគ្នាទៅវិញទៅមក

សំណួរ/ចម្លើយ បន្ទាប់ពីសន្និសីទអន្តរជាតិលើកទី២៥ ស្តីពី «អនាគតអាស៊ី» នៅទីក្រុងតូក្យូ, ជប៉ុន, ៣០ ឧសភា ២០១៩

... **មានពាក្យស្លោកថា «ជំរីជល់គ្នា ស្លាប់ស្មៅឬស្លាប់ស្រមោច/សង្ឃារ»។ ក៏ប៉ុន្តែ ក្នុងតំបន់អាស៊ី ប្រទេសនីមួយៗ មិនគប្បីបណ្តោយខ្លួនឱ្យក្លាយជាស្រមោច/សង្ឃារ ឬស្មៅ សម្រាប់ជំរីជល់គ្នា ហើយមកជាន់យើងឲ្យស្លាប់ទេ។ យើងត្រូវរកវិធីគេចផុតពីជម្លោះនេះ**។ សង្ឃឹមថា សហរដ្ឋអាមេរិកនិងចិន នឹងស្វែងរកនូវដំណោះស្រាយសមស្រប ដើម្បីភាពសុខដុមរមនា ព្រោះ**ពិភពលោកបច្ចុប្បន្ន មិនអាចមាននរណារស់តែម្នាក់ឯងបានទេ។ ពិភពលោកបច្ចុប្បន្ន ចំណុះឲ្យគ្នាទៅវិញទៅមក ដោយស្វែងរកនូវដំណោះស្រាយមួយតាមរយៈស្ថានភាពឈ្នះឈ្នះ ...៕**

៦៦. TPP មានចរិតបំបែកអាស៊ាន ឯ ASEM ជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ

ពិធីបើកកិច្ចប្រជុំតុមូលចិនលើកទី៥, ២០ មីនា ២០១៧

... **អាស៊ានជាតួអង្គដែលធ្វើការសម្របសម្រួល ...** ខ្ញុំសូមនិយាយដោយត្រង់ថា **ខ្ញុំចង់ឲ្យ** TPP (Trans-Pacific Partnership) **ងាប់។ មូលហេតុអីបានជាខ្ញុំចង់ឲ្យវាងាប់? ព្រោះវាមានចរិតបំបែកអាស៊ាន។ អាស៊ានមាន ១០ (ប្រទេស) ម៉េចយកតែ ៤? ... ខ្ញុំពេញចិត្ត និងខិតខំរួមចំណែកជាមួយបណ្តាប្រទេសនានា ដើម្បីធ្វើឲ្យ** ASEM (Asia-Europe Meeting) **ជោគជ័យ ព្រោះវាមានភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់** ដែលបានចុះហត្ថលេខានៅភ្នំពេញ។ មិនមែនដោយសារចុះហត្ថលេខានៅភ្នំពេញ ក្នុងហានៈដែលខ្ញុំធ្វើជាប្រធានអាស៊ាននោះទេ ក៏ប៉ុន្តែវាជាផ្នែកដ៏សំខាន់នៃសេដ្ឋកិច្ច នៃទំនាក់ទំនងក្នុងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគ ...។

៦៧. មីយ៉ាន់ម៉ា៖ បំបាត់អំពើហិង្សា, ផ្តល់ជំនួយមនុស្សធម៌ សន្ទនាខាងនយោបាយ

សំណេះសំណាលជាមួយសហគមន៍ខ្មែរនៅសហគមន៍ខ្មែរ
នៅសហរដ្ឋអាមេរិក/កាណាដា, ១២ ឧសភា ២០២២

... ទាក់ទងនឹងមីយ៉ាន់ម៉ា កម្ពុជាបានខិតខំបំពេញតួនាទីក្នុងហានៈជាសមាជិក និងជាប្រធានអាស៊ានដោយមានការទទួលខុសត្រូវ ... ទស្សនកិច្ចនៅមីយ៉ាន់ម៉ាបន្ទាប់ទៅជួបតាមអនឡាញ ... ជាការបើកផ្លូវសម្រាប់ការសន្ទនានិងការផ្តល់ជំនួយមនុស្សធម៌ សម្រាប់ប្រជាជនមីយ៉ាន់ម៉ា។ អ្វីដែលប្រធានអាស៊ានចង់បានពីក្នុងចំណោមកុងសង់ស៊ីស ៥ចំណុច ដែលថ្នាក់ដឹកនាំអាស៊ានបានសម្រេចនៅ Jakarta កាលពីខែមេសា ឆ្នាំទៅ ... **មាន៣ គឺ ទី១ ការបំបាត់អំពើហិង្សាជាពិសេសជំរុញឱ្យមានការបទឈប់បាញ់ ... ទី២ បើកផ្លូវឱ្យមានការផ្តល់ជំនួយមនុស្សធម៌ទៅកាន់ទីកន្លែងដែលមានការចាំបាច់ ... ឯទី៣ បង្កើតបរិយាកាសអនុគ្រោះសម្រាប់ការសន្ទនាខាងនយោបាយរវាងភាគីពាក់ព័ន្ធ រាប់ទាំងក្រុមប្រដាប់អាវុធនានា** ...។

៦៨. បទពិសោធការទូត ហ៊ុន សែន - "រក្សាទ្វារចំហសម្រាប់ការសន្ទនា" ជាជាងបិទ

សន្និសីទសារព័ត៌មាន និងសំណួរ/ចម្លើយ ក្រោយកិច្ចប្រជុំកំពូលអាស៊ានទី៤០ និង៤១ នៅកម្ពុជា, ១៣ វិច្ឆិកា ២០២២

... ទាក់ទងនឹងមីយ៉ាន់ម៉ា ខ្ញុំចង់សួរថា "អ្នកណាក្តៅ អ្នកណាត្រជាក់"។ ការពិតវិធានការដែលបណ្តាប្រទេសជាសមាជិកអាស៊ាន(ប្រកាន់យក) ... សុទ្ធតែមានគោលបំណងឱ្យមីយ៉ាន់ម៉ាវិលត្រឡប់ទៅរកប្រក្រតីភាពវិញបានឆាប់ ... សួរថាបើចង់ក្តៅ អ្នកឯងធ្វើម៉េចគេ? តើលោកចង់ទៅវាយមីយ៉ាន់ម៉ាឬ? បើត្រជាក់ តើទៅលួងចិត្តមីយ៉ាន់ម៉ាឱ្យស្តុះគ្រាប់ឬ ... បញ្ហាស្ថិតទៅត្រង់ថារកវិធីសាស្ត្រឱ្យពួកគាត់ជាក្រុមកំពុងប្រយុទ្ធគ្នានោះធ្វើការស្រុះស្រួលគ្នា ... **រឿងនេះកម្ពុជាមានពិសោធន៍ខ្លួនឯងហើយ។ យកល្អរក្សាទុកទ្វារចំហជាជាងបិទ។ នេះជាបទពិសោធការទូតហ៊ុន សែន។ កុំបិទទ្វារឱ្យសោះ ដើម្បីទុកលទ្ធភាពធ្វើការសន្ទនាទោះពេលណា? វិធីណា? កម្រិតណា? នៅទីកន្លែងណា? នេះជារឿងមួយតទៅទៀត** ...។

៦៩. ការដាក់ទណ្ឌកម្មលើរុស្ស៊ី កើតជាវិបត្តិលើសេដ្ឋកិច្ចពិភពលោក

ពិធីទទួលសញ្ញាបត្របណ្ឌិតកិត្តិយសផ្នែកអភិវឌ្ឍន៍
នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ៥ សីហា ២០២២

... ខ្ញុំបាន**ស្នើឱ្យទាំងអឺរ៉ុបទាំងសហរដ្ឋអាមេរិកពិនិត្យមើលវិធានការទណ្ឌកម្ម។ យើងដឹងច្បាស់ហើយថា ផ្តើមចេញពីរុស្ស៊ីចូលទៅអ៊ុយក្រែន ... ជាមូលហេតុនាំឱ្យ(មានការ)ដាក់ទណ្ឌកម្ម។ ដល់ទណ្ឌកម្មនេះ វាបង្កើតវិបត្តិមិនមែនតែនៅរុស្ស៊ីឯណា នៅអឺរ៉ុបខ្លួនឯង និងនៅយើងក៏ជួបនឹងវិបត្តិដែលកំពុងឡើងថ្លៃប្រេងនេះ។ ហេតុនេះហើយបានជាស្នើឱ្យពិចារណាឡើងវិញ ដើម្បីកាត់បន្ថយផលប៉ះពាល់លើសេដ្ឋកិច្ចពិភពលោក**។ ថ្វីបើរឿងនេះ ត្រូវបានគិតគូរដោយប្រទេសតូចមួយតែ(យើងមានគោលការណ៍)ស្មើភាពស្មើសិទ្ធិ ... បានជួបមុខផ្ទាល់នឹងអនុប្រធានគណៈកម្មការអឺរ៉ុប ទទួលបន្ទុកកិច្ចការបរទេសនិងសន្តិសុខ ខ្ញុំត្រូវតែនិយាយ។ គាត់បានទទួលស្គាល់ថា មានការកាត់បន្ថយការប្រើប្រាស់ឧស្ម័នប៉ុន្មានភាគរយៗ នៅអឺរ៉ុប សូម្បីមិនទាន់ដល់រដូវត្រជាក់ផង ...។

៧០. សង្គ្រាមរុស្សី-អ៊ុយក្រែន បង្កើតឲ្យមានវិបត្តិថាមពល និងអាចមានវិបត្តិស្បៀង

សំណេះសំណាលជាមួយសហគមន៍ខ្មែរនៅទ្វីបអឺរ៉ុប, ២១ ឧសភា ២០២២

... **នៅអឺរ៉ុបក្តី នៅអាស៊ីក្តី ទោះបីប្រេងឧស្សត្រូវថ្លៃគ្នាយ៉ាងណាក៏ដោយ នោះហើយគឺផលប៉ះពាល់ដែលចេញមកពីវិបត្តិស្តីពីសង្គ្រាមរុស្សីនិងអ៊ុយក្រែន ដែលយើងមិនចង់ឲ្យមានកើតឡើង។ ប្រសិនបើសង្គ្រាមនេះនៅតែបន្តអូសបន្លាយ វានឹងមានផលប៉ះពាល់ធ្ងន់ធ្ងរ។ យើងត្រូវព្យាករទុកឲ្យហើយថាវិបត្តិនេះ នៅដល់ពេលណា? ពេលនេះទើបនឹងរងផលប៉ះពាល់លើបញ្ហាថាមពល ជាពិសេសប្រេងសាំង។ បន្ថែមទៀត អាចមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើបញ្ហាសន្តិសុខស្បៀង។** ដោយសារអី? ប្រទេសរុស្សី និងប្រទេសអ៊ុយក្រែនគឺជាប្រទេសដែលផលិតស្រូវភោជសាលីធំ អាចថាជាជង្រុកស្រូវភោជសាលីរបស់ពិភពលោក។ ប៉ុន្តែរុស្សីត្រូវជាប់ទណ្ឌកម្មនាំចេញអត់រួច។ អ៊ុយក្រែនផលិតអត់បាន។ អញ្ចឹងអនាគតស្តីអំពីវិបត្តិស្បៀងអាហារវាកើតឡើងយ៉ាងម៉េច? ...៕

៧១. មិនលើកទឹកចិត្តបំបែករដ្ឋ និងគំរាមប្រើកម្លាំង ឬប្រើកម្លាំងក្នុងទំនាក់ទំនងអន្តរជាតិ

សំណេះសំណាលជាមួយសហគមន៍ខ្មែរនៅសហគមន៍ខ្មែរ
នៅសហរដ្ឋអាមេរិក/កាណាដា, ១២ ឧសភា ២០២២

... មានរឿងដាច់ដោយឡែកមួយទៀត នោះគឺបញ្ហារុស្សុី-អ៊ុយក្រែន ... កម្ពុជាបានបោះឆ្នោត(នៅអង្គការសហប្រជាជាតិប្រឆាំងរុស្សុីឈ្លានពានអ៊ុយក្រែន) ... ហើយបានធ្វើជា Co-sponsor គាំទ្រសេចក្តីសម្រេចចិត្តប្រឆាំងការឈ្លានពាននោះ។ ខ្ញុំសង្ឃឹមថា រុស្សុីយល់ចំពោះយើង។ យើងមានគោលការណ៍២ សំខាន់នៅទីនេះ។ **ទី១ មិនលើកទឹកចិត្តឲ្យបំបែករដ្ឋទេ មិនថាបំបែករដ្ឋនៅទីណាទេ។** កម្ពុជាអត់ទទួលស្គាល់។ Kosovo ដែលបំបែកចេញពី Serbia ដោយកម្លាំង NATO រាប់ទាំងអាមេរិក ក៏កម្ពុជាអត់ទទួលស្គាល់ដែរ។ តំបន់ Donbas របស់អ៊ុយក្រែន ដែលរុស្សុីទទួលស្គាល់ ក៏យើងអត់ទទួលស្គាល់ដែរ។ **ទី២ ប្រឆាំងចំពោះការប្រើប្រាស់កម្លាំង ឬគំរាមប្រើប្រាស់កម្លាំងក្នុងទំនាក់ទំនងអន្តរជាតិ ជាពិសេសការលើកកងទ័ពចូលឈ្លានពានប្រទេសមួយដោយចំហ ...៕**

៧២. កម្ពុជានឹងមិនបញ្ជូនជំនួយយោធា តែនឹងជួយការពារសន្តិភាពនៅអ៊ុយក្រែន

សន្និសីទសារព័ត៌មាន និងសំណួរ/ចម្លើយ ក្រោយកិច្ចប្រជុំកំពូលអាស៊ានទី៤០ និង៤១ នៅកម្ពុជា, ១៣ វិច្ឆិកា ២០២២

... ទាក់ទងនឹងអ៊ុយក្រែន កម្ពុជាគ្មានអាវុធ/គ្រាប់ ហើយក៏គ្មានចេតនាដើម្បីនឹងបញ្ជូនអាវុធ/គ្រាប់ទៅជួយប្រទេសណាទាំងអស់។ យើងមិនយកសាំងទៅចាក់លើភ្លើងទេ ... បើទោះបីយើងមានអាវុធ/គ្រាប់ ក៏យើងមិនបញ្ជូនទៅកាន់ប្រទេសណាឡើយ ... អ្វីដែលយើងកំពុងតែខិតខំគឺក្នុងគោលដៅមនុស្សធម៌។ យើងធ្លាប់ជាជនរងគ្រោះដោយសារមីន។ ៣០ឆ្នាំហើយ គឺចាប់តាំងពីឆ្នាំ ១៩៩២ យើងបានបើកប្រតិបត្តិការដោះមីន។ រហូតមកដល់ពេលនេះ យើងមិនទាន់អស់មីននៅឡើយទេ។ ដូច្នេះ **យើងបានគិតទុក ហើយបានពិភាក្សាជាមួយដៃគូរបស់យើងគឺប្រទេសជប៉ុន ថានឹងជួយហ្វឹកហាត់អ្នកដោះមីនអ៊ុយក្រែន ដើម្បីឲ្យពួកគេបោសសម្អាតមីននៅលើទឹកដីអ៊ុយក្រែន ...៕**

៧៣. បញ្ឈប់អរិភាព ស្រាយជម្លោះដោយសន្តិវិធី ផ្តល់ជំនួយមនុស្សធម៌នៅអ៊ុយក្រែន

សន្និសីទសារព័ត៌មាន និងសំណួរ/ចម្លើយ ក្រោយកិច្ចប្រជុំកំពូលអាស៊ានទី៤០ និង៤១ នៅកម្ពុជា, ១៣ វិច្ឆិកា ២០២២

... ចំពោះស្ថានការណ៍នៅអ៊ុយក្រែន ខ្ញុំអាចនិយាយបានថាជាជុំថ្មក្តៅបំផុតដែលអាចមើលឃើញថាមានជំហរផ្សេងៗគ្នា ពិសេសក្នុងអំឡុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ... ដែលភាគីមានជំហរផ្សេងៗគ្នា អាចផ្លាស់ប្តូរទស្សនៈដ៏ស្មោះត្រង់លើបញ្ហានេះ។ **យើងបានបញ្ជាក់ឡើងវិញនូវការគោរពចំពោះអធិបតេយ្យភាព ឯការជ្យភាព និងបូរណភាពទឹកដី។ យើងបានបញ្ជាក់អំពីសារៈសំខាន់នៃការបញ្ឈប់ជាបន្ទាន់នូវអរិភាព និងការបង្កើតបរិយាកាសអំណោយផលសម្រាប់ដោះស្រាយជម្លោះដោយសន្តិវិធី។ យើងបានអំពាវនាវឲ្យមានការជួយសម្រួលដល់ការទទួលបាននូវជំនួយមនុស្សធម៌ឆាប់រហ័ស សុវត្ថិភាព និងគ្មានការរារាំងទៅដល់ប្រជាជនដែលត្រូវការជំនួយនៅក្នុងប្រទេសអ៊ុយក្រែន ...៕**

៧៤. គណៈកម្មការព្រំដែន កម្ពុជានិងវៀតណាម ព្រមព្រៀង៦% បន្ថែមលើ៨៤% ដែលបានបោះបង្គោល

សំណេះសំណាលជាមួយសហគមន៍ខ្មែរនៅទ្វីបអឺរ៉ុប, ២១ ឧសភា ២០២២

... យើងបោះបង្គោលទល់ដែនបាន៨៤% នៅសល់១៦% ទៀត ប៉ុន្តែ**គណៈកម្មការព្រំដែននៃប្រទេសទាំងពីរថ្មីៗនេះ បានប្រជុំរួចហើយនិងព្រមព្រៀងគ្នាលើ៦% ទៀតដោយខាងវៀតណាមទៅសុំយោបល់ខាងវៀតណាម ខាងកម្ពុជាសុំយោបល់ខាងកម្ពុជា**។ ខាងកម្ពុជាងាយទេ ព្រោះខ្ញុំជាប្រធានអាជ្ញាធរព្រំដែនស្រាប់ ... បងប្អូនសួរមើល បើគង់តែឲ្យដីគេដដែល តើយើងទៅចរចាធ្វើអី? គេទារត្រឹមណា ឲ្យគេប៉ុណ្ណឹងទៅ ... តាំងពីជំនាន់ប្រធានាធិបតី (François) Hollande កម្ពុជានិងវៀតណាម ឯកភាពគ្នាសុំអ្នកជំនាញការបារាំងជួយផ្ទេរផែនទីពីផែនទីបានខ្នាត 1/100,000 មកផែនទី UTM ខ្នាត 1/50,000 ដើម្បីបោះបង្គោល។ ខ្ញុំគ្មានសិទ្ធិយកដីខ្មែរសូម្បី ១ មីល្លីម៉ែត្រដើម្បីឲ្យប្រទេសណាទេ ...៕

៧៥. មុងតាញ៉ាមិនមែនជនជាតិភាគតិចនៅកម្ពុជាទេ

សំណេះសំណាលជាមួយបងប្អូនខ្មែរនៅប្រទេសអូស្ត្រាលី, ១៦ មីនា ២០១៨

... បើគេជាជនជាតិដើមភាគតិចរបស់ខ្មែរ ចាំបាច់មានទង់ជាតិដោយឡែកធ្វើអី? ក្រោយខ្នងរបស់អ្នកឯងមានទង់ជាតិ៣ មែនទេ ... ទង់អាមេរិកនៅកណ្តាល។ ហ្នឹងនិយាយថាម៉េច? **រដ្ឋធម្មនុញ្ញយើងប្រឆាំងអបគមន៍ មិនឲ្យមានតំបន់អបគមន៍ទេ ប៉ុន្តែត្រូវគោរពជនជាតិដើមភាគតិច តាមតម្រូវការរបស់បងប្អូនជនជាតិភាគតិច ទំនៀមទម្លាប់របស់គេ ... តែម៉ុងតាញ៉ាមិនមែនជាជនជាតិដើមភាគតិចរបស់កម្ពុជាទេ ... អ្នកឯងបានច្បាប់ពីណាមកទទួលស្គាល់ម៉ុងតាញ៉ាជាជនជាតិភាគតិចកម្ពុជា? អ្នកឯងបកស្រាយឲ្យច្បាស់មក ... សូមបងប្អូនកុំច្រឡំរវាងជនជាតិដើមភាគតិចនៅកម្ពុជា និងជនជាតិដើមភាគតិចនៅក្នុងប្រទេសផ្សេង។ ជនជាតិដើមភាគតិចម៉ុងតាញ៉ា ដែលបង្កើតរដ្ឋដៃហ្គានេះ នៅក្នុងប្រទេសវៀតណាម** ...៕

៧៦. ទោះបី BREXIT ក៏អង់គ្លេសនៅបន្តរបបពាណិជ្ជកម្មដូចធ្លាប់ធ្វើពីមុនមក

វេទិការាជរដ្ឋាភិបាល-វិស័យឯកជន លើកទី ១៨, ២៩ មីនា ២០១៩

... ករណីអង់គ្លេស ទោះបីជា Brexit (មិនទាន់សម្រេចនៅឡើយក្តី) ក៏ប៉ុន្តែអង់គ្លេសបានបញ្ជូនមន្ត្រីមកទីក្រុងភ្នំពេញ(ជូនដំណឹង)ថា ទោះបីអង់គ្លេសចាកចេញពី EU ក៏អង់គ្លេសនៅបន្តអនុវត្តរបបពាណិជ្ជកម្មដូចអ្វីដែលធ្លាប់ធ្វើ។ ពេលទទួលទានអាហារគុបាយជាមួយគ្នានៅប្រ៊ុចសែល នាយករដ្ឋមន្ត្រី លោកស្រី មេយ៍ ដែលគាត់ថានឹងលាលែងចេញពីតំណែងក្នុងប៉ុន្មានថ្ងៃខាងមុខនេះ ដោយសារការចាកចេញពី EU បានបញ្ជាក់ជាមួយខ្ញុំថា **អង់គ្លេសនឹងបន្តជាមួយកម្ពុជា ដោយមិនមានការផ្លាស់ប្តូរទេ** ...៕

៧៧. បើកស្ថានទូតនៅតួគី - "កម្ពុជានិងតួគី ធ្លាប់មានប្រវត្តិជាចក្រភព"

សំណេះសំណាលជាមួយយុវជន សិស្ស និស្សិត ដែលកំពុងសិក្សានៅប្រទេសតួគី, ២១ តុលា ២០១៨

... តួគីមានសុចន្ទៈក្នុងការបើកស្ថានទូតនៅទីក្រុងភ្នំពេញ តាំងពីឆ្នាំ២០១៣។ ឥឡូវយើងក៏ត្រូវឆ្លើយតបវិញជាការបើកស្ថានទូតនៅទីនេះ។ យើងមិនត្រូវភ្លេចថា តួគីគឺជាចក្រភពមួយ។ ប្រទេសទាំងពីរធ្លាប់ជាចក្រភពដូចគ្នា។ យើងចក្រភពអង្គរនៅនេះចក្រភពអូតូម៉ង់ ដែលចាត់ទុកថាជាប្រទេសអស្ចារ្យក្នុងតំបន់ សម័យពីអតីតកាល។ នៅអឺស្តានប៊ុលនេះ យើងកំពុងតែនៅចុងទឹកដីអឺរ៉ុប ហើយនៅមិនឆ្ងាយពីទីនេះគឺទឹកដីរបស់អាស៊ី ជាតំបន់មួយដែលយើងធ្លាប់តែនិយាយពីគម្រោងតភ្ជាប់រវាងអាស៊ីនិងអឺរ៉ុបឆ្លងកាត់ច្រកទ្វារអឺស្តានប៊ុលហ្នឹង គឺនៅតួគី ...៕

៧៨. កសាងទំនាក់ទំនងទ្វេភាគីកម្ពុជា-តួគី និងតួគី-អាស៊ាន

សំណេះសំណាលជាមួយយុវជន សិស្ស និស្សិត ដែលកំពុងសិក្សានៅប្រទេសតួគី, ២១ តុលា ២០១៨

... ទោះបីអាស៊ីឬអឺរ៉ុប គឺតួគីជាប្រទេសមួយមានការីកលូតលាស់ខ្លាំង។ បើនិយាយពីចំណាត់ថ្នាក់ខាងសេដ្ឋកិច្ច គឺទី១៧ ... **ទន្ទឹមនឹងទំនាក់ទំនងទ្វេភាគីតួគីបានភ្លាយទៅជាដៃគូសន្ទនាតាមវិស័យរបស់អាស៊ាន កាលពីឆ្នាំ២០១៧កន្លងទៅ។ នេះជាចំណែកមួយនៃការកសាងទំនាក់ទំនងទ្វេភាគីរវាងកម្ពុជា និងតួគី និងម៉្យាងទៀតរវាងតួគីជាមួយនឹងអាស៊ាន។** ប្រសិនបើពេលណាមួយ ឈាន

ទៅដល់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ានជាមួយតួគី វាកាន់តែល្អក្នុងការជំរុញក្នុងទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ និងវិស័យដទៃទៀតរវាងតួគីជាមួយកម្ពុជា ឬរវាងតួគីជាមួយនឹងក្របខ័ណ្ឌអាស៊ានផងដែរ ...៕

៧៩. អាស៊ានត្រូវដកពិសោធន៍ពីអឺរ៉ុបទាំងខាងល្អ និងខាងមិនល្អ

ពិធីបិទសន្និបាតប្រចាំឆ្នាំរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ៣១ មករា ២០២០

... ក្នុងសំណុំបញ្ហាទាំងឡាយ អង់គ្លេសជាស្ថាបនិកនៃសហភាពអឺរ៉ុបតែម្តង។ ប៉ុន្តែ អ្វីដែលយើងបានឃើញតាមរយៈការបោះឆ្នោតនៅអង់គ្លេសចុងក្រោយនេះ គឺការគាំទ្រភ្លូកទឹកភ្លូកដីរបស់ប្រជាជនអង់គ្លេស ... ដើម្បីចាកចេញពីអឺរ៉ុបដែលបង្ហាញឲ្យឃើញថា ប្រជាជនអង់គ្លេសបានធុញទ្រាន់នឹងអឺរុប។ **អាស៊ានគួររៀនសូត្រពីបទពិសោធរបស់អឺរ៉ុប។ នេះជាបទពិសោធល្អផង និងជាបទពិសោធមិនល្អផងដែរ សម្រាប់យើងដែលមានតួនាទីស្ថាបនាអាស៊ានមួយមានសាមគ្គីភាព និងជំរុញសុខដុមរមនាក្នុងតំបន់** ...៕

៨០. មើលគ្រប់ទិស" ជាគោលនយោបាយការបរទេសរបស់កម្ពុជា

បើកការដ្ឋានសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង និងសម្ពោធរោងចក្រប្រព្រឹត្តកម្មទឹកស្អាតចំការមន, ១ កុម្ភៈ ២០២១

ខ្ញុំសូមអំពាវនាវខាងសហភាពអឺរ៉ុប រាប់ទាំងលោកជំទាវអគ្គរដ្ឋទូតបារាំង ប្រាប់ទៅប្រធានាធិបតី Emmanuel Macron ថា កម្ពុជាក៏ត្រូវការជំនួយដ៏សប្បុរសពីបារាំងដែរ កុំមើលថាកម្ពុជាត្រូវការតែចិន។ ត្រូវការតែទាំងអស់ហ្នឹង។ **មិនមែនស្អីឡើងក៏ចិនៗ ទេ។ កម្ពុជាមើលគ្រប់ជ្រុងទាំងអស់។ បានសេចក្តីថា មើលជុំវិញខ្លួន មិនមែនមើលតែទិសណាមួយទេ។ ឥណ្ឌាមាននយោបាយសម្លឹងមើលមកទិសខាងកើត។ បន្ទាប់មកជំនាន់នាយករដ្ឋមន្ត្រី Narendra Modi ឥណ្ឌាប្រើពាក្យថា សកម្មភាពមកទិសខាងកើត។ ប្រធានាធិបតីកូរ៉េខាងត្បូង Moon Jae-in ប្រើពាក្យថា សកម្មភាពមកទិសខាងត្បូង។ ឯសម្រាប់ខ្ញុំ សកម្មភាពជុំវិញខ្លួន។ មើលគ្រប់ទិស។ នេះជាគោលនយោបាយការបរទេសរបស់យើង** ...៕

៥. ការពារជាតិ

១	ឋានន្តរសក្តិ Général Hors Classe	១១៩
២	ចាប់ពី ២០ មិថុនា ១៩៧៧ ក្លាយជាមេដឹកនាំផ្សារភ្ជាប់ដំណើរជាតិឥតដាច់សង្វាក់	១១៩
៣	យកថ្ងៃ ៩ វិច្ឆិកា ១៩៥៣ ជាថ្ងៃបង្កើតកងខេមរភូមិន្ទ ដើម្បីងាយក្នុងការឯកភាពកម្លាំង	១១៩
៤	១២ ឧសភា ១៩៧៨ ជាថ្ងៃបង្កើតអង្គភាពរៀបរយលើកដំបូង	១២០
៥	មិនមែនជាមេទ័ព តែជាអ្នកបង្កើតកងទ័ព និងជាបញ្ជាការកងទ័ព	១២០
៦	រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ត្រូវបានបង្កើតឡើងលើមូលដ្ឋាននៃកម្លាំង៥	១២១
៧	ឆ្លងកាត់ការរំលំរបបប្រល័យពូជសាសន៍ ការពារ/ស្តារ/កសាងជាតិ និងរក្សាសន្តិភាព	១២១
៨	ការចាប់ផ្តើមចលនាតស៊ូ យកដីតធ្វើជាដើមទុនរំដោះប្រទេស	១២២
៩	ដំណើរទៅវៀតណាម ៤៥ឆ្នាំមុន រៀបចំការតស៊ូសាជាថ្មី ជាម្រើស១ក្នុងចំណោមជាម្រើស៤	១២២
១០	សមាជិកបក្ស ៦២នាក់ ជ្រើសរើសមនុស្ស ៧នាក់ ដឹកនាំបក្សឡើងវិញ	១២៣
១១	ចលនានយោបាយឈ្នះឈ្នះ ចាប់ផ្តើមពីខែមីនាដើមឆ្នាំ១៩៩៦	១២៣
១២	ជំនាញការវៀតណាមដក ថ្ងៃ២ មិថុនា ១៩៨៨, កងទ័ពវៀតណាមដក កញ្ញា ១៩៨៩	១២៤
១៣	ពង្រឹងសមត្ថភាពកម្លាំងត្រូវបញ្ជាផ្ទាល់ ចៀសវាងភាពច្រំដែលនៃប្រវត្តិសាស្ត្រ	១២៤
១៤	ពង្រឹងសមត្ថភាពកម្លាំងប្រដាប់អាវុធ ធានាគ្មានការដណ្តើមអំណាចក្រៅក្របខ័ណ្ឌច្បាប់	១២៥
១៥	អ្នកការពារប្រទេសនិងរដ្ឋធម្មនុញ្ញ ត្រូវក្តាប់កម្លាំងប្រដាប់អាវុធនិងរដ្ឋបាលស៊ីវិល	១២៥
១៦	មិនបណ្តោយឲ្យមានបដិវត្តពណ៌នៅលើទឹកដីកំសត់	១២៥
១៧	ក្នុងដំណាក់កាលកាន់អំណាច មិនអនុញ្ញាតឲ្យមានរដ្ឋប្រហារកើតឡើង	១២៦
១៨	បង្កើតសាលាហ្វឹកហ្វឺនចារកម្ម ចៀសវាងការបែកធ្លាយអត្តសញ្ញាណចារបុរស	១២៦
១៩	"សំណាញ់មេឃ" យុទ្ធសាស្ត្រការពារដែនអាកាស	១២៧
២០	ពិភពលោកសព្វថ្ងៃប្រឡងប្រណាំងសព្វាវុធខ្លាំងជាងជំនាន់សង្គ្រាមត្រជាក់	១២៧
២១	រកវិធីគ្រប់គ្រងទំនាក់ទំនង ដើម្បីចៀសពីការកកើតឡើងវិញនូវសង្គ្រាមត្រជាក់	១២៧
២២	បន្តយចំណាយយោធាបាន៥0% ពិភពលោកអាចធ្វើឱ្យសេដ្ឋកិច្ចនិងសង្គមបានប្រសើរ	១២៨
២៣	ដែលថា "កម្ពុជារៀបចំមូលដ្ឋានកងទ័ពជើងទឹកបរទេស" ជាការចោទដ៏អយុត្តិធម៌	១២៨
២៤	ទិញអាវុធបន្ថែមពីចិន ពង្រឹងសមត្ថភាពកងទ័ព	១២៩
២៥	កម្ពុជាមិនមានផែនការដូរប្រព័ន្ធអាវុធទេ	១២៩
២៦	មិនផ្លាស់ប្តូរប្រព័ន្ធអាវុធកម្ពុជា ... ជាការសម្រេចចិត្តត្រឹមត្រូវ	១៣0
២៧	បញ្ចូល ទិវាបញ្ចប់សង្គ្រាមតាមរយៈនយោបាយឈ្នះឈ្នះ" ២៩ ធ្នូ ក្នុងប្រតិទិន	១៣0
២៨	ភារកិច្ច ១0 ត្រូវយកចិត្តទុកដាក់សម្រាប់កងទ័ព	១៣0

២៩	**មានវត្តមាន ហ៊ុន សែន សូមកុំបារម្ភពីការកើតសង្គ្រាម**	១៣១
៣០	**មិនអាចទទួលយកបានពាក្យសម្តីប្រមាថចំពោះកងទ័ពជាតិ**	១៣១
៣១	**ការបញ្ជាលើកងកម្លាំងប្រដាប់អាវុធជាសិទ្ធិស្របច្បាប់របស់នាយករដ្ឋមន្ត្រី**	១៣២
៣២	**នយោបាយខឿនការពារជាតិប្រជាជន ភ្ជាប់ទំនាក់ទំនងរវាងកងទ័ពនិងប្រជាជន**	១៣២

១. ឋានន្តរសក្តិ Général Hors Classe

ពិធីអបអរខួបទី២០ កងទ័ពជើងគោក, ២៤ មករា ២០១៩

... ពេលដឹងថាមានការគាំទ្រយ៉ាងដូច្នេះ ដោយសារខ្ញុំត្រូវកាន់តួនាទីជានាយករដ្ឋមន្ត្រីផង ជាសហរដ្ឋមន្ត្រីការពារជាតិផង ... **ព្រះករុណាជាអម្ចាស់ជីវិតម្តល់លើត្បូងបានប្រទានឋានន្តរសក្តិជា Général Hors Classe ដោយព្រះអង្គបាននិយាយជាភាសាបារាំង ... និងដែលមានន័យថា "ឧត្តមសេនីយ៍ផុតលេខ" នៅពេលនោះ។ យប់នោះហើយដែលសម្តេច ជា ស៊ីម និងខ្ញុំបានពាក់សក្តិជាលើកដំបូង។** ព្រះរាជក្រឹត្យចេញមកមាន ៣ នាក់ គឺសម្តេច ជា ស៊ីម សម្តេច ហេង សំរិន និងខ្ញុំ ជាឧត្តមសេនីយ៍ផ្កាយមាស៥ ... ៕

២. ចាប់ពី ២០ មិថុនា ១៩៧៧ ក្លាយជាមេដឹកនាំផ្សារភ្ជាប់ដំណើរជាតិឥតដាច់សង្វាក់

ទិវានៃការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត គម្រប់ ៤០ ឆ្នាំ (២០ មិថុនា ១៩៧៧ – ២០ មិថុនា ២០១៧) – ភូមិកោះឫស្សី ឃុំទន្លូង ស្រុកមេមត់, ២០ មិថុនា ២០១៧

... ក្នុងឯកសារដែលមានបន្សល់រូបថតជាច្រើនបានបង្ហាញតួអង្គនៃការបង្កើតកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា។ ខ្ញុំជាមេបញ្ជាការខ្ពស់បំផុត។ មុនថ្ងៃទី២០ មិថុនា ១៩៧៧ ខ្ញុំជាទាហានដែលទទួលបញ្ជាពីខាងលើ **ប៉ុន្តែចាប់ពីថ្ងៃទី២០ មិថុនា ១៩៧៧ រហូតមកដល់ពេលនេះ ខ្ញុំក្លាយទៅជាមេដឹកនាំផ្សារភ្ជាប់ជាមួយនឹងដំណើរជាតិរបស់កម្ពុជារៀងរហូត ដោយមិនដាច់ខ្សែរយៈម្តងណាទេ។ ក្រោយចាកចេញតែប៉ុន្មានខែ ខ្ញុំបានវិលត្រឡប់ចូលមកកម្ពុជាវិញ។** នៅសំរោង នៅដា នាខែវិច្ឆិកា និងខែ ធ្នូ ១៩៧៧, នៅក្នុងខែមេសា ១៩៧៨ ខ្ញុំមកដល់កោះឫស្សីហ្នឹង ប៉ុន្តែមិនបានចូលភូមិ និងទីបញ្ជាការនៅកន្លែងនេះទេ ... ៕

៣. យកថ្ងៃ ៩ វិច្ឆិកា ១៩៥៣ ជាថ្ងៃបង្កើតកងខេមរភូមិន្ទ ងាយក្នុងការឯកភាពកម្លាំង

ពិធីអបអរខួបទី២០ កងទ័ពជើងគោក, ២៤ មករា ២០១៩

... ហេតុអ្វីបានជាកងទ័ពជើងគោកទើបនឹងមានអាយុ ២០ឆ្នាំ ក្នុងពេលដែលកងទ័ពរបស់យើងមានប្រវត្តិអាយុទៅដល់ ៦៥ឆ្នាំ ? យើងបានកំណត់**យកថ្ងៃទី៩**

ខែវិច្ឆិកា ១៩៥៣ ថ្ងៃឯករាជ្យរបស់កម្ពុជាពីអាណានិគមនិយមបារាំងជាថ្ងៃកំណើតកងទ័ព ... ពេលដែលកម្ពុជាទទួលបានឯករាជ្យ កងយោធពលខេមរភូមិន្ទក៏ត្រូវបានបង្កើតឡើង ហើយការយកថ្ងៃ(ឯករាជ្យជាតិជាថ្ងៃកំណើតកងទ័ព)នោះដែលវាងាយស្រួលក្នុងការឯកភាពគ្រប់កម្លាំង ព្រោះថាមិនមែនមានតែកម្លាំងដែលនៅក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុនោះទេ គឺនៅមានកម្លាំងផ្សេងទៀត ដូចជាខ្មែរឥស្សរៈផងដែរ ...៕

៤. ១២ ឧសភា ១៩៧៨ ជាថ្ងៃបង្កើតអង្គភាពរៀបរយលើកដំបូង

ពិធីអបអរខួបទី ២០ កងទ័ពជើងគោក, ២៤ មករា ២០១៩

... ខ្ញុំក៏មានថ្ងៃកំណើតនៃការកសាងកងទ័ពដោយឡែកមួយដែរ គឺនៅថ្ងៃទី ១២ ខែឧសភា ១៩៧៨។ គឺជាថ្ងៃបង្កើតអង្គភាពរៀបរយជាលើកដំបូង បន្ទាប់ពីកម្លាំងដែលមានរួចហើយ។ អង្គភាពរៀបរយដំបូងជាផ្លូវការ ដែលមានឈ្មោះថាអង្គភាព ១២៥ គឺជាថ្ងៃកំណើតរបស់កងទ័ពរបស់ខ្ញុំ ... នេះជាប្រវត្តិអតីតកាលនៃកម្លាំងប្រដាប់អាវុធរបស់កម្ពុជា។ កម្លាំងខ្មែរក្រហមក៏មានប្រវត្តិមួយដាច់ដោយឡែក។ សាធារណរដ្ឋខ្មែររបស់ពូក លន់ នល់ ក៏មានប្រវត្តិកងទ័ពដោយឡែក។ កម្លាំងតស៊ូនៅជាយដែនក៏មានប្រវត្តិមួយដោយឡែក ... កងទ័ពរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរក៏មានប្រវត្តិមួយទៅ ហ៊ុនសុិនបុិចក៏មានប្រវត្តិមួយទៅ។ ថ្ងៃទី៩ វិច្ឆិកា ឆ្នាំ ១៩៥៣ គឺជាថ្ងៃងាយស្រួលបំផុតក្នុងការឯកភាពគ្នា ...៕

៥. មិនមែនជាមេទ័ព តែជាអ្នកបង្កើតកងទ័ព និងជាបញ្ជាការកងទ័ព

ពិធីសម្ពោធអគាររដ្ឋបាលនិងសាលប្រជុំនៃក្រសួងការពារជាតិ, ២៩ ធ្នូ ២០២១

... ប្រវត្តិកងទ័ពពិតប្រាកដដែលកំពុងមានសព្វថ្ងៃនេះ ចាប់ផ្តើមពីអ្វី? ដើម្បីបង្កើតអង្គការចាត់តាំងនយោបាយនិងយោធារំដោះប្រទេសចេញពីរបប ប៉ុល ពត យើងបានកសាងកងទ័ពមួយ ... (ដែល)មាន ២៣កងវរសេនាតូច និង ១០០ក្រុមប្រតិបត្តិការកម្លាំងប្រដាប់អាវុធចូលផ្ទៃក្នុងប្រទេស។ **ខ្លួនខ្ញុំមិនមែនជាមេទ័ពទេ ក៏ប៉ុន្តែជាអ្នកបង្កើតកងទ័ពនេះឡើង ហើយក៏កាន់ជាបញ្ជាការកងទ័ពនេះតែម្តង។**

ហានន្តរស័ក្តិដែលខ្ញុំពាក់លើស្មានេះ មិនមែនពាក់ដោយចៃដន្យនោះទេ។ គឺជាព្រះរាជទានរបស់ព្រះមហាក្សត្រ ...៕

៦. រណសិរ្យសាមគ្គីសង្គ្រោះជាតិកម្ពុជា ត្រូវបានបង្កើតឡើងលើមូលដ្ឋាននៃកម្លាំង៥

សារសម្លេងបំភ្លឺព្រឹត្តការណ៍ប្រវត្តិសាស្ត្រស្តីពីការតស៊ូរំដោះកម្ពុជានិងការចាប់ខ្លួនប៉ែន សុវណ្ណ, ១៦ មករា ២០២២

... រណសិរ្យ(សាមគ្គី)សង្គ្រោះជាតិ(កម្ពុជាក្រោម)បានបង្កើតឡើងលើមូលដ្ឋាននៃកម្លាំង៥ ដោយកម្លាំងមួយដឹកនាំដោយឯកឧត្តម សាយ ភូថង សម្តេចពិជ័យសេនា ទៀ បាញ់ ស្ថិតនៅក្នុងប្រទេសថៃ (កម្លាំងនេះ)មិនអាចចេញមុខនៅក្នុងថ្ងៃទី ២ធ្នូ ១៩៧៨ទេ។ អ្នកដែលចេញមុខថ្ងៃទី២ ធ្នូ ១៩៧៨ នោះមានតែ៤ ភាគីប៉ុណ្ណោះ ... ភាគីទី១ គឺភាគីនៃកម្លាំងបះបោរនៅភូមិភាគបូព៌ាទិសដឹកនាំដោយសម្តេច ហេង សំរិន ជាប្រធាន សម្តេច ជា ស៊ីម ជាអនុប្រធាន ... កម្លាំងទី២ ដឹកនាំដោយឯកឧត្តម ប៊ុន មី និងឯកឧត្តម ប៊ូ ថង ... កម្លាំងទី៣ ជាកម្លាំងរបស់ខ្ញុំដែលធ្វើចលនាតស៊ូចាប់ពីថ្ងៃទី២០ ខែ មិថុនា ឆ្នាំ ១៩៧៧ ... កម្លាំងទី ៤ គឺជាកម្លាំងដែលគេនិយមហៅថា ជាកម្លាំងប្រមូលផ្តុំ ...៕

៧. ឆ្លងកាត់ការផ្លាស់រំលែរបបប្រល័យពូជសាសន៍ ការពារ/ស្តារ/កសាងប្រទេស និងរក្សាសន្តិភាព

ពិធីសម្ពោធអគាររដ្ឋបាលនិងសាលប្រជុំនៃក្រសួងការពារជាតិ, ២៩ ធ្នូ ២០២១

... **យើងបានឆ្លងកាត់នូវដំណាក់កាល ៣ ហើយ ... ទី១ គឺដំណាក់កាលផ្លាស់រំលែរបបប្រល័យពូជសាសន៍** ដែលខ្ញុំបាននិយាយពីការរៀបចំកម្លាំងប្រដាប់អាវុធនិងបន្ទាប់ទៅការរៀបចំអង្គការចាត់តាំងខាងនយោបាយ ហៅថា រណសិរ្យសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា ... **ទី២ ដំណាក់កាលការពារនិងស្តារកសាងប្រទេសឡើងវិញ** ដែលចែកចេញជា **២ផ្នែក**គឺ **(២.១) សង្គ្រាមទាំងស្រុងតែម្តង។ អត់មាននិយាយគ្នាបានទេ គឺគិតតែពីវាយគ្នា និង(២.២) គឺវាយផង និងចរចាផង ... និងទី៣ ការបើកឡើងនូវទំព័រប្រវត្តិសាស្ត្រ**

ថ្មី ប្តូរផ្តាច់ប្រឆាំងបដិវត្តពណ៌ ថែរក្សាសន្តិភាព និងភាពសុខសាន្តរបស់ប្រជាជន ជានាការអភិវឌ្ឍប្រទេស ...៕

៨. ការចាប់ផ្តើមចលនាតស៊ូ យកជីវិតធ្វើជាដើមទុនរំដោះប្រទេស

ពិធីសម្ពោធ និងប្រគល់ទទួលផ្សារគំរូព្រំដែនកម្ពុជា ផ្សារដោ, ២៤ ធ្នូ ២០១៩

... ខ្ញុំក៏ចាប់ផ្តើមតស៊ូពីដំណាក់កាលនៅលើផ្លូវជាតិលេខ៧ នៃចលនារំដោះជាតិ ហើយក៏ជាចំណុចចាប់ផ្តើមនៃការតស៊ូនៃការរំដោះជាតិចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែរ។ ពីនេះទៅផ្ទះសពកូនរបស់ខ្ញុំនៅស្រុកមេមត់ ប្រមាណជា ១៣ គីឡូម៉ែត្រតែប៉ុណ្ណោះ។ គឺជាផ្ទះកូនច្បង ដែលបានស្លាប់នៅថ្ងៃទី ១០ វិច្ឆិកា ១៩៧៦។ តំបន់នេះបានក្លាយជាទីតាំងចាប់ផ្តើមចលនាតស៊ូ ដែលខ្ញុំបានយកជីវិតធ្វើជាដើមទុនដើម្បីរំដោះប្រទេស ... ការឈឺចាប់នៅកន្លែងនោះបានជំរុញឲ្យខ្ញុំបង្កើនល្បឿនសម្រេចចិត្ត ធ្វើការតស៊ូប្រឆាំងនឹងរបបប្រល័យពូជសាសន៍ ប៉ុល ពត ហើយឃ្លាតពីស្រុកមេមត់ទៅដល់ភូមិកោះឬ ឃុំទន្លូង ...៕

៩. ដំណើរទៅវៀតណាម ៤៥ឆ្នាំមុន រៀបចំការតស៊ូសាជាថ្មី ជាជម្រើសមួយក្នុងចំណោមជម្រើស៤

ខួបលើកទី៤៥ ទិវាការចងចាំដំណើរឆ្ពោះទៅកាន់ការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត (២០ មិថុនា ១៩៧៧ – ២០ មិថុនា ២០២២) និងសម្ពោធសមិទ្ធផលនានានៅតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះឬ X16 ភូមិកោះឬ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ, ២០ មិថុនា ២០២២

...ខ្ញុំមានជម្រើសបួននៅពេលនោះ។ ទី១ ប្រើប្រាស់នូវកម្លាំងប្រជាប់អាវុធ។ ខ្ញុំគ្រប់គ្រងមួយកងវរសេនាធំ ... ក្រោយរំដោះក្រុងភ្នំពេញ កងវរសេនាធំនេះមានជាង ២០០០នាក់ ក៏ប៉ុន្តែបានធ្វើការបែងចែកកម្លាំងនេះ ទៅបង្កើតកម្លាំងថ្មីមួយចំនួន និងមួយចំនួនតូចត្រូវពួកខ្មែរក្រហមចាប់យកទៅសម្លាប់។ យ៉ាងណាក៏ដោយ ខ្ញុំមានលទ្ធភាពប្រើប្រាស់កម្លាំងប្រមាណ ១៥០០នាក់ ដើម្បីវាយកាន់កាប់ស្រុកមេមត់ ស្រុកស្នួល និងនៅតំបន់ជិតខាងផ្សេងទៀត ... ប៉ុន្តែការធ្វើរបៀបនេះ ជាការប្រថុយប្រថាន ដែលអាចប៉ាន់ស្មានបានថា ក្នុងរង្វង់មួយអាទិត្យ ឬកន្លះខែ កងទ័ពនេះនឹងត្រូវស្លាប់ក្នុងប្តូកឈាម... **ជម្រើសទី២ គឺខ្ញុំដកខ្លួនចេញឆ្លងទៅសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីរៀបចំការតស៊ូសាជាថ្មីទៀត។ ឯជម្រើសទី៣ គឺមិនធ្វើអ្វីទាំងអស់ ដោយទុកឱ្យ ប៉ុល ពត ចាប់យកទៅសម្លាប់ដូចអ្នកដទៃទៀត និងជម្រើសទី៤ គឺធ្វើអត្តឃាត ...៕**

១០. សមាជិកបក្ស ៦២នាក់ ជ្រើសរើសមនុស្ស ៧នាក់ ដឹកនាំបក្សឡើងវិញ

សារសម្លេងបំភ្លឺព្រឹត្តិការណ៍ប្រវត្តិសាស្ត្រស្តីពីការតស៊ូរំដោះកម្ពុជា និងការចាប់ខ្លួនប៉ែន សុវណ្ណ, ១៦ មករា ២០២២

... សូមបញ្ជាក់ថា ទន្ទឹមនឹងបង្កើតបានរណសិរ្សហើយ យើងឆ្ពោះទៅដល់ការរៀបចំបក្សឡើងវិញ។ **ពេលនោះយើងប្រមូលផ្តុំបានមនុស្ស ៦២នាក់ ដើម្បីទៅរៀបចំគណបក្សឡើងវិញ ហៅថាគណៈកសាងបក្ស។ អ្នកដែលបានជាប់ឆ្នោតនៅក្នុងមហាសន្និបាត ចាត់ទុកថា មហាសន្និបាតបក្សលើកទី៣ ដែលប្រព្រឹត្តទៅពីថ្ងៃទី៥ មករា រហូតដល់ថ្ងៃទី៨ មករា គឺមានការបោះឆ្នោតជ្រើសតាំងមនុស្ស ៧ នាក់ចេញពីមហាសន្និបាតនេះ។** ក្នុងហ្នឹងមាន ប៉ែន សុវណ្ណ, ហេង សំរិន, ជា ស៊ីម, ហ៊ុន សែន, ប៊ូ ថង, ចាន់ គិរី, វ៉ាន់ សន។ មានតែ ៧រូបហ្នឹងទេ ដែល(ត្រូវបាន)បោះឆ្នោតចេញ(ពី)សមាជបក្សដែលមានសមាជិកចូលរួម ៦២នាក់ ...៕

១១. ចលនានយោបាយឈ្នះឈ្នះ ចាប់ផ្តើមពីខែមករា ដើមឆ្នាំ១៩៩៦

សំណេះសំណាលជាមួយកម្មករ នៅរោងចក្រ Wing Star Shoe ស្រុកគងពិសី ខេត្តកំពង់ស្ពឺ, ៤ មិថុនា ២០២៣

...ដើមឆ្នាំ១៩៩៦ ខ្ញុំបានមកធ្វើសមាហរណកម្មកងពលលេខ១៨របស់ កែវ ពង្ស ... នេះជាការចាប់ផ្តើមនៃចលនាអនុវត្តនយោបាយឈ្នះឈ្នះ។ សូមកុំភ្លេចថា នយោបាយឈ្នះឈ្នះចាប់ផ្តើមនៅថ្ងៃ២៩ ធ្នូ ឆ្នាំ១៩៩៨។ **មិនមែនទេ។ ចលនានេះចាប់ផ្តើមជំរុញចាប់ពីខែមករាគឺដើមឆ្នាំ១៩៩៦ ដែលធ្វើឲ្យមានការបះបោរឡើងនៅប៉ៃលិន និងម៉ាឡៃ ជាកម្លាំងចលករមួយដ៏ធំដឹកនាំដោយ អ៊ឹ ឈាន និង សុខ ភាព បង្កើតឡើងនូវចលនាផ្តាច់ខ្លួនចេញពីខ្មែរក្រហម ហើយយើង**

អនុវត្តនយោបាយឈ្នះ-ឈ្នះ បង្រួបបង្រួមជាតិ បង្រួបបង្រួមទឹកដី ឯកភាពជាលើកដំបូងនៅក្នុងប្រវត្តិសាស្ត្រ ដែលមានការបែកបាក់ច្រើនឆ្នាំ ...។

១២. ជំនាញការវៀតណាមដកថ្ងៃ ២ មិថុនា ១៩៨៨, កងទ័ពវៀតណាមដក កញ្ញា ១៩៨៩

បើកការដ្ឋានស្ពាននិងលើកកម្ពស់កម្រិតគុណភាពផ្លូវជាតិលេខ៣១ និងផ្លូវជាតិលេខ៣៣, ៣០ ធ្នូ ២០២២

...(យើង) ក៏បានដាក់ចេញនូវផែនការដកជំនាញការវៀតណាមចេញពីកម្ពុជា ហើយដែលប្រធានជំនាញការវៀតណាមបានមកប្រាប់ការណ៍ឱ្យខ្ញុំនៅថ្ងៃ២ មិថុនា ១៩៨៨ ថាជំនាញការវៀតណាមគ្រប់ផ្នែកដកចេញពីកម្ពុជា ឯកងទ័ពវៀតណាមដក(ចេញពីកម្ពុជា)នៅខែកញ្ញា ១៩៨៩។ ជំនាញការវៀតណាម បានដកចេញពីកម្ពុជា មុនពេលកងទ័ពវៀតណាមដកចេញ។ ដោយសារតែរឿងហ្នឹងហើយបានជាខ្ញុំប្រាប់ទៅអ្នកដែលមកចរចាក្រោយៗ ថា ពេលដែលកងទ័ពវៀតណាមនៅកម្ពុជា ខ្ញុំមានសិទ្ធិសម្រេចច្រើនជាងដែលអស់លោកកំពុងធ្វើការជាមួយខ្ញុំ។ ខ្ញុំចង់ធ្វើរឿងនេះ លោកឯងថាធ្វើរឿងនោះ ខ្ញុំចង់ធ្វើរឿងនោះ លោកឯងថាធ្វើរឿងនោះ។ បើខ្ញុំមិនធ្វើតាមលោកឯងកាត់ជំនួយខ្ញុំ ...។

១៣. ពង្រឹងសមត្ថភាពកម្លាំងត្រូវបញ្ចាផ្ទាល់ ចៀសវាងភាពច្រំដែលនៃប្រវត្តិសាស្ត្រ

ពិធីអបអរខួបទី ២០ កងទ័ពជើងគោក, ២៤ មករា ២០១៩

... ការប៉ុនប៉ងចាប់ខ្លួន ហ៊ុន សែន គឺដើម្បីសម្រេចគោលបំណងបំផ្លាញចោលលទ្ធផលការបោះឆ្នោតឆ្នាំ១៩៩៣ រៀបចំដោយអ៊ុនតាក់ ... ឯកឧត្តម ទៀ បាញ់, កែ គឹមយ៉ាន, ឯកឧត្តម ប៉ុល សារឿន គ្មានលទ្ធភាព(រំដោះខ្ញុំ)ទេព្រោះ(ពួកគាត់)ត្រូវបានគេចាប់មុនខ្ញុំប៉ុន្មានម៉ោងរួចហើយ។ នេះជាការទម្លាយអាថ៌កំបាំងមួយ។ **(ដោយសារតែ)បញ្ហានេះហើយ ទើបបានជាខ្ញុំពង្រឹងសមត្ថភាពកម្លាំងដែលខ្ញុំត្រូវបញ្ចាផ្ទាល់ដើម្បីចៀសវាងភាពច្រំដែលនៃប្រវត្តិសាស្ត្រដូចថ្ងៃ២ មិថុនា១៩៩៣។ ដល់ថ្ងៃ៤ កក្កដា ឆ្នាំ១៩៩៤ ក៏មានការប៉ុនប៉ងធ្វើរដ្ឋប្រហារចាប់ខ្លួនខ្ញុំសាជាថ្មីម្តងទៀត** ... ដែលការប៉ុនប៉ងទាំងនោះ សុទ្ធតែមានបំណងបំផ្លាញចោលសមិទ្ធផលសន្តិភាព ...។

១៤. ពង្រឹងសមត្ថភាពកម្លាំងប្រដាប់អាវុធ ធានាគ្មានការដណ្តើមអំណាចក្រៅក្របខ័ណ្ឌច្បាប់

ពិធីអបអរខួបទី ២០ កងទ័ពជើងគោក, ២៤ មករា ២០១៩

... សារសម្លេងរបស់ខ្ញុំ មិនមែនជាការគំរាមកំហែងចំពោះអ្នកណាទាំងអស់។ នេះជា**ការពង្រឹងសមត្ថភាពកងកម្លាំងប្រដាប់អាវុធ ដើម្បីធានាថាប្រទេសគ្មានភេរវកម្ម និងគ្មានការដណ្តើមអំណាចក្រៅក្របខ័ណ្ឌច្បាប់។ ពិតមែនតែកងទ័ពកម្ពុជាតិច អាវុធតូចតាច ទន់ខ្សោយ តែយើងមានសមត្ថភាពការពារជាតិ។** យើងមិនព្រមឲ្យឧទ្ធាមទាំងទីក្រុងទាំងក្នុងព្រៃផ្តួលរំលំរដ្ឋបានទេ។ ប្រទេសបារាំងបច្ចុប្បន្នប្រកាសដាក់ប្រទេសក្នុងគ្រាអាសន្ន ដើម្បីទប់ស្កាត់ចលនាអាវាកាត់ពណ៌លឿង។ ហេតុអ្វីបានបារាំងអាចធ្វើបាន តែកម្ពុជាមិនអាចធ្វើបាន? នៅទីនេះយើងគ្រាន់តែការពាររដ្ឋ។ ប្រទេសខ្លះប្រើកងទ័ពដណ្តើមយករដ្ឋ ហើយគ្មានបញ្ហាទៀតផង។ យើងគ្រាន់តែការពាររដ្ឋ បែជាមានឈ្មោះថាជាជនផ្តាច់ការ។ វាមិនយុត្តិធម៌ទេ ...។

១៥. អ្នកការពារប្រទេសនិងរដ្ឋធម្មនុញ្ញ ត្រូវក្តាប់កម្លាំងប្រដាប់អាវុធនិងរដ្ឋបាលស៊ីវិល

សម្ពោធអគាររដ្ឋបាលនិងសាលប្រជុំនៃក្រសួងការពារជាតិ, ២៩ ធ្នូ ២០២១

... ចំណុចស្នូលនៃបដិវត្តពណ៌ ឬពួកដើរផ្តួលរំលំគេ គឺធ្វើអព្យាក្រឹត្យកម្លាំងប្រដាប់អាវុធនិងរដ្ឋបាលស៊ីវិល។ សម័យមុន គេលើកទ័ពចូលឈ្លានពាន។ សម័យក្រោយនេះ គឺសម័យបដិវត្តពណ៌។ (ចលនា)បដិវត្តពណ៌ ជាដំបូងឡើងគេធ្វើឲ្យមានអព្យាក្រឹត្យកម្លាំងប្រដាប់អាវុធនិងរដ្ឋបាលស៊ីវិល ... យើងឲ្យ(កម្លាំងប្រដាប់អាវុធ)អព្យាក្រឹត្យតែជាមួយបក្សនយោបាយនិងបក្សនយោបាយទេ ... សូមកុំមកបំពានលើក្រសួងការពារជាតិ ស្ថាប័នរដ្ឋ សាលាខេត្ត ទីស្តីការគណៈរដ្ឋមន្ត្រី ឬលុកលុយចូលរដ្ឋសភា ... **គន្លឹះរបស់មេបដិវត្តពណ៌គឺអព្យាក្រឹត្យប្រដាប់អាវុធនិងរដ្ឋបាលស៊ីវិល។ ឯគន្លឹះនៃអ្នកការពារប្រទេស និងរដ្ឋធម្មនុញ្ញ គឺត្រូវក្តាប់ឲ្យជាប់កម្លាំងប្រដាប់អាវុធនិងរដ្ឋបាលស៊ីវិល ...។**

១៦. មិនបណ្តោយឲ្យមានបដិវត្តពណ៌នៅលើទឹកដីកម្ពុជា

សម្ពោធអគាររដ្ឋបាល និងសាលប្រជុំក្រសួងការពារជាតិ, ២៩ ធ្នូ ២០២១

... សូមមិត្តភក្តិដែលមានអនុពន្ធយោធានៅទីនេះ ស្តាប់សម្លេងខ្ញុំឱ្យបានច្បាស់ថា **យើងមិនបណ្តែតបណ្តោយឲ្យអ្នកណាធ្វើបដិវត្តពណ៌ លើទឹកដីកម្ស័ត់នេះទេ។ យើងស្គាល់រសជាតិឈឺចាប់នៃប្រទេសដែលកើតសង្គ្រាម។ យើងមិនធ្វេសប្រហែសចំពោះការគិតគូរទាំងឡាយអំពីសន្តិសុខជាតិរបស់យើងទេ។** គ្រាន់តែយើងប្រកាសថ្ងៃ២៣ (តុលា) ខួប៣០ ឆ្នាំនៃកិច្ចព្រមព្រៀងប៉ារីស ពួកគេប្រកាសថាត្រូវរំលាយចោលរាជានិយម ... បង្កើតសាធារណរដ្ឋ។ ត្រូវចាំ ដោយសារតែរដ្ឋប្រហារនោះហើយ បានជាប្រទេសកម្ពុជាមានបញ្ហារហូតមកដល់សព្វថ្ងៃ ...៕

១៧. ក្នុងដំណាក់កាលកាន់អំណាច មិនអនុញ្ញាតឲ្យមានរដ្ឋប្រហារកើតឡើង

ពិធីអបអរខួបទី ២០ កងទ័ពជើងគោក, ២៤ មករា ២០១៩

...រដ្ឋប្រហារដែលបានកើតឡើងតែមិនទាន់ផ្ទុះអាវុធ ត្រូវបានបង្ក្រាបទាន់ពេលវេលា។ ក្រៅពីត្រូវកម្ទេច សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ បានត្រៀមរៀបចំចាប់ខ្លួនខ្ញុំយកទៅទុកនៅឯខេត្តព្រៃវែង។ ហេតុការនេះបានកើតឡើងក្នុងខែកក្កដា ឆ្នាំ ១៩៩៤ ... ខ្ញុំសូមនិយាយម្តងទៀតថា **ក្នុងដំណាក់កាលដែល ហ៊ុន សែន កាន់អំណាច មិនអនុញ្ញាតឲ្យមានរដ្ឋប្រហារកើតឡើងទេ។ រដ្ឋប្រហារថ្ងៃ ១៨មីនា ១៩៧០ បានបំផ្លិចបំផ្លាញកម្ពុជា ហើយដែលទីបំផុត កងទ័ពដែលបង្កើតដោយសម្តេចព្រះ នរោត្តម សីហនុ បានបង្វិលចុងកាណុងទម្លាក់សម្តេចវិញ ...៕**

១៨. បង្កើតសាលាហ្វឹកហ្វឺនចារកម្ម ចៀសវាងការបែកធ្លាយអត្តសញ្ញាណចារជន

សម្ពោធដាក់អោយប្រើប្រាស់នូវអគារហ្វឹកហ្វឺនជំនាញចារកម្ម និងការបើកការដ្ឋាន សាងសង់អគារសាលប្រជុំថ្មីរបស់អគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ច, ១២ ធ្នូ ២០១៧

...ពាក្យស៊ើបការណ៍ បន្ទាប់ទៅពាក្យចារកម្ម ប៉ុន្តែការធ្វើចារកម្មរបស់យើងនៅពេលនេះ ក៏ធ្វើចារកម្មប្រឆាំងនឹងចារកម្មដែរ ... ខ្ញុំគាំទ្រអោយមានសាលាហ្វឹកហ្វឺនចារកម្មនៅក្នុងប្រទេស តាមរយៈការចងក្រងបទពិសោធដែលយើងមាន មិនមែនត្រឹមតែក្នុងកងទ័ពទេ តែក៏ទាំងក្នុងនគរបាលនិងអាវុធហត្ថ ... ហើយបង្កើតនូវការហ្វឹកហ្វឺនដោយឡែករបស់ចារកម្មកម្ពុជា ... យើងត្រូវមានចារកម្មថ្មើរជើង ចារកម្មតាមរបៀបច្រើនប្រភេទ ... ការបញ្ជូនទៅរៀនមិនខុសពីក្លាយទៅជាមុខសញ្ញានោះ

ទេ ... មិនចង់ឱ្យទៅសិក្សា(ក្រៅប្រទេសទេ តែទៅ)ដកបទពិសោធបាន។ យ៉ាងណាក្តី ក្នុងក្របខ័ណ្ឌជាទាហានគួរតែហ្វឹកហ្វឺននៅសាលាខ្លួនឯង។ បើមិនដូច្នោះចារកម្មនេះអាចត្រូវគេទិញទុកឆ្អែចទៅហើយ ...៕

១៩. "សំណាញ់មេឃ" យុទ្ធសាស្ត្រការពារដែនអាកាស

ដាក់ឱ្យប្រើប្រាស់អគារមិត្តភាពកម្ពុជា-កូរ៉េ មន្ទីរពេទ្យអង្គឌួង, ២៨ មីនា ២០២២

...ខ្ញុំមិនលេងទេ។ ទិញយន្តហោះ MiGមួយគ្រឿង ស្មើនឹងកសាងមន្ទីរពេទ្យនេះមួយ ... មន្ទីរពេទ្យសង់អស់តែ ៨លានដុល្លារទេ។ MiGមួយគ្រឿង ២០ទៅ ៣០ លានដុល្លារ...ខ្ញុំលេងត្រឹមតែឧទ្ធម្ភាគចក្រសម្រាប់ការជីកជញ្ជួន...**អ្នកណាមានអីក៏មានទៅ។ (តែបើអ្នក)ឯងចូលដែនអាកាសខ្ញុំគឺជាក់ពីក្រោមទៅហើយ។ គេហៅថាសំណាញ់មេឃ។ចូលដែនអាកាសដោយគ្មានការសុំច្បាប់ រំលោភលើដែនអាកាស (យើងនឹងរាយ)សំណាញ់មេឃឡើងទៅពីក្រោម។ មិនដឹងថាឡើងពីត្រង់ណាទៅត្រង់ណាទេ...** កុំនាំយកយន្តហោះទៅបាញ់គ្នាលើអាកាស ...៕

២០. ពិភពលោកសព្វថ្ងៃប្រឡងប្រណាំងសព្វាវុធខ្លាំងជាងជំនាន់សង្គ្រាមត្រជាក់

ពិធីចែកសញ្ញាបត្រនៃវិទ្យាស្ថាន វ៉ាន់ដា គណនេយ្យ, ៣ មេសា ២០១៨

... **(ការគំរាមកំហែងនៃអាវុធ)នុយក្លេអ៊ែរលើពិភពលោកនៅតែជាបញ្ហាផុយស្រួយនៅឡើយ។ ឥឡូវនេះ ពិភពលោកហាក់ដូចជាកំពុងស្ថិតក្នុងដំណាក់កាលរត់ប្រណាំងសព្វាវុធ លើសពីសម័យដែលហៅថាសង្គ្រាមត្រជាក់នោះទៅទៀត។** ពេលនោះ មានតែអតីតសហភាពសូវៀត និងអាមេរិកទេ ដែលជាអ្នកដាក់ប្រព័ន្ធមីស៊ីលទៅវិញទៅមក ឬប្រព័ន្ធការពារទៅវិញទៅមក។ ឥឡូវនេះ មានប្រទេសច្រើនលើសពី២ ... ឬបើនិយាយពីការគំរាមកំហែងនៃសង្គ្រាមនុយក្លេអ៊ែរ ឬសង្គ្រាមទ្រង់ទ្រាយធំចំពោះមុខ សន្តិភាពកំពុងមានភាពផុយស្រួយ ហើយពិភពលោកហាក់កំពុងស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់ ...៕

២១. រកវិធីគ្រប់គ្រងទំនាក់ទំនង ដើម្បីចៀសពីការកកើតឡើងវិញនូវសង្គ្រាមត្រជាក់

ប្រគល់សញ្ញាបត្រនិស្សិតនៃសាកលវិទ្យាល័យកូមិន្ទនីតិសាស្ត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច, ៥ មិថុនា ២០២៣

... យើងនៅតែមានសុឆន្ទៈថា ពិភពលោកនឹងរកការស្រុះស្រួលគ្នាមួយដើម្បីគ្រប់គ្រងទំនាក់ទំនង ជាពិសេសភាពតានតឹងរវាងសហរដ្ឋអាមេរិកនិងចិន។ **ត្រូវរកវិធីគ្រប់គ្រងទំនាក់ទំនងនេះ ដើម្បីនឹងចៀសវាងឱ្យបានការកកើតឡើងវិញ(នូវសង្គ្រាមត្រជាក់)។ សង្គ្រាមត្រជាក់បានកើតរួចទៅហើយ ក៏ប៉ុន្តែទប់ស្កាត់វាកុំឱ្យក្លាយទៅជាមានហានិភ័យសង្គ្រាម ឈានទៅដល់ការប៉ះទង្គិចគ្នាដោយអាវុធណាមួយ។ NATO ផ្តាប់តែនៅខាងលិច។ ឥឡូវ NATO ហាក់ដូចជាឆ្ពោះមកកាន់អាស៊ីប៉ាស៊ីហ្វិក ក្រោមរូបភាពនេះ**ឯនោះ។ ជាកង្វល់ ...៕

២២. បើបន្តយចំណាយយោធាបាន៥0% ពិភពលោកអាចធ្វើឱ្យសេដ្ឋកិច្ចនិងសង្គមបានប្រសើរជាមិនខាន

ពិធីប្រគល់សញ្ញាបត្រនិស្សិតសាកលវិទ្យាល័យសុខាភិបាល, ១៨ ឧសភា ២0២៣

... ពេលប្រជុំអាស៊ានកន្លងទៅ ក្នុងកិច្ចសន្ទនារវាងអាស៊ាននិងAIPA (ASEAN Inter-Parliamentary Assembly), អាស៊ាននិងយុវជន និងអាស៊ាននិងផ្នែកធុរកិច្ចដែលមានប្រមុខរដ្ឋប្រមុខរដ្ឋាភិបាលគណៈប្រតិភូចូលរួមជាពិសេសផ្នែកធនធានខួរក្បាលខាងស្រាវជ្រាវ ខ្ញុំបានលើកខ្លីថា **"បើសិនជាពិភពលោកកាត់បន្តយចំណាយលើយោធាបានត្រឹមតែ ៥0% ហើយបង្វិលមកបម្រើឱ្យវិស័យសេដ្ឋកិច្ចនិងសង្គម ថ្នាំពេទ្យក៏ចុះថ្លៃ ឧបករណ៍ពេទ្យក៏ចុះថ្លៃ"។ ប៉ុន្តែ គេនាំគ្នារត់ប្រណាំងគ្នាលើការបង្កើតសព្វាវុធដើម្បីសម្លាប់គ្នា ជាជាងការស្រាវជ្រាវផលិតថ្នាំពេទ្យឱ្យបានថោក ឧបករណ៍ពេទ្យឲ្យបានថោក"** ... (ប្រទេសខ្លះកំពុង)ប្រមូលអាវុធបញ្ជូនទៅឱ្យអ៊ុយក្រែនវាយរុស្សី ...៕

២៣. ដែលថា "កម្ពុជារៀបចំមូលដ្ឋានកងទ័ពជើងទឹកបរទេស" ជាការចោទដ៏អយុត្តិធម៌

ពិធីបុណ្យសមុទ្រលើកទី៧ ជុំទី២ ខេត្តកោះកុង, ១៥ ធ្នូ ២0១៨

... តាមរយៈនៃការផ្សាយបន្តផ្ទាល់ចេញពីទីនេះ ខ្ញុំចង់បញ្ជូនសារចំពោះប្រិយមិត្តបរទេសឱ្យបានជ្រាបថា មួយរយៈចុងក្រោយនេះ វាជារឿងអយុត្តិធម៌ពេក ដែល(មានអ្នក)**ចោទប្រកាន់ថា កម្ពុជារៀបចំមូលដ្ឋានកងទ័ពជើងទឹកបរទេសនៅតំបន់តារាសាគរ ខេត្តកោះកុងនិងនៅខេត្តព្រះសីហនុ ហើយថែមទាំងប្រើពាក្យថា ហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ទាំងនេះ (អាច)ប្រើបានទាំងស៊ីវិលនិងយោធា**។ ខ្ញុំសូមបញ្ជាក់ថា **"រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេស មិនថាជើងទឹកមិនថាជើងគោក មិនថាជើងអាកាស នៅលើទឹកដីរបស់ខ្លួនទេ"** ...៕

២៤. ទិញអាវុធបន្ថែមពីចិន ពង្រឹងសមត្ថភាពកងទ័ព

ដំណើរពិនិត្យការដ្ឋានសាងសង់ពហុកីឡដ្ឋានមរតកតេជោ, ២៩ កក្កដា ២0១៩

... ឆ្នាំនេះខ្ញុំឱ្យជកលុយជិត ៤0លានដុល្លារ(អាមេរិក)ទិញអាវុធមួយចំនួនពីចិន បន្ថែមលើ ២00លានដុល្លារដែលឱ្យពីមុនសម្រាប់ការទិញ(អាវុធ)និង ៩0លានដុល្លារដែលឱ្យលើកក្រោយ ... ខ្ញុំចង់ពង្រឹងសមត្ថភាពកងទ័ព ... មកដល់កំពង់សោមអ្នកឯងមើលក៏មើលទៅ។ ឃើញក៏ឃើញទៅ។ នៅលើលោកនេះប្រទេសណាមួយដែលអត់កាំភ្លើង? កាំភ្លើងរបស់កម្ពុជារាងចាស់បន្តិចហើយ។ ខ្ញុំឱ្យទិញប៉ុន្មានមុឺនដើមមកស្តុកទុក។ ដកអាចាស់បញ្ចេញអាថ្មី ... ប្រទេសមួយអត់មានកាំភ្លើងម្តេចបាន។ ឆ្នាំមុននោះ ទៀ បាញ់ សុំតែ ២៥ពាន់លាន(រៀល)ទេ តែលើកនេះ ខ្ញុំហៅទូរស័ព្ទឱ្យរៀបចំគម្រោងស្នើលុយទិញអាវុធពីចិន ...៕

២៥. កម្ពុជាមិនមានផែនការជួរប្រព័ន្ធអាវុធទេ

ដំណើរពិនិត្យការដ្ឋានសាងសង់ពហុកីឡដ្ឋានមរតកតេជោ, ២៩ កក្កដា ២0១៩

... ខ្ញុំអត់មានផែនការជួរប្រព័ន្ធអាវុធទេ។ អ្នកខ្លះថាត្រូវប្តូរប្រព័ន្ធអាវុធទៅយកតាមបែបនេះឯនោះ។ **ខ្ញុំថា "អត់"។ ចាយលុយច្រើនណាស់។ ម្យ៉ាងទៀត ប្រព័ន្ធអាវុធធុននោះ ជួនកាលគេធ្វើកិកកុកបន្តិច មិនលក់ឱ្យ ចប់រឿង។ តែប្រព័ន្ធអាវុធដែលយើងប្រើរាល់ថ្ងៃ ទិញពីប្រទេសណាក៏បានដែរ។ សម្បុរបែប។ រាប់ទាំងប្រទេសនៅអឺរ៉ុបដែលស្ថិតនៅក្នុងអតីតសហភាពសូវៀត។ ទិញបានតាមចិត្ត**។ ខ្ញុំត្រូវគិតគូរដែរព្រោះខ្ញុំអ្នកដឹកនាំប្រទេស។ ព្រះមហាក្សត្រ ព្រះអង្គជាប្រធានឧត្តមក្រុមប្រឹក្សាការពារជាតិ ឯនាយករដ្ឋមន្ត្រីក៏ជាអនុប្រធានឧត្តមក្រុមប្រឹក្សាការពារជាតិ។ ការដឹកនាំនយោបាយទាំងក្នុង/ក្រៅប្រទេស គឺជាកិច្ចការប្រតិបត្តិរបស់នាយករដ្ឋមន្ត្រី។ ខ្ញុំមានភារកិច្ចនឹងធ្វើលើកិច្ចការទាំងអស់ ...៕

២៦. មិនផ្លាស់ប្តូរប្រព័ន្ធអាវុធកម្ពុជា ... ជាការសម្រេចចិត្តត្រឹមត្រូវ

ហ្វេសប៊ុកផេចសម្តេចតេជោ, ១០ ធ្នូ ២០២១

... ប៉ុន្មានថ្ងៃកន្លងទៅនេះ **សហរដ្ឋអាមេរិកបានសម្រេចអំពីការពិតត្បិតការលក់ដូរអាវុធនិងសម្ភារយោធាជាដៃគូកម្ពុជា ... ការសម្រេចរបស់សហរដ្ឋអាមេរិកលើបំរាមការលក់ដូរអាវុធ និងសម្ភារយោធាមកកម្ពុជានាពេលនេះ បានឆ្លុះបញ្ចាំងពីភាពត្រឹមត្រូវ កាលពីឆ្នាំ១៩៩៤ ដែលខ្ញុំបានធ្វើការសម្រេចចិត្តមិនផ្លាស់ប្តូរប្រព័ន្ធអាវុធកម្ពុជា ...** ទៅទិញប្រព័ន្ធអាវុធអាមេរិក ... ខ្ញុំសូមដាក់ចេញបទបញ្ជាដៃអង្គភាពប្រដាប់អាវុធទាំងអស់ ឱ្យធ្វើការត្រួតពិនិត្យឡើងវិញជាបន្ទាន់អំពីអាវុធ **និងសម្ភារយោធាដែលកម្ពុជាមានបច្ចុប្បន្ន ហើយត្រូវប្រមូលអាវុធ និងសម្ភារយោធាអាមេរិកទាំងអស់ ប្រសិនបើមាន យកទៅក្សាទុកក្នុងឃ្លាំង ឬយកទៅកម្ទេចចោល** តាមការដាក់ស្តែង ... ៕

២៧. បញ្ចូល ទិវាបញ្ចប់សង្គ្រាម តាមរយៈនយោបាយឈ្នះ-ឈ្នះ ២៩ ធ្នូ ក្នុងប្រតិទិន

សម្ពោធអគាររដ្ឋបាលនិងសាលប្រជុំនៃក្រសួងការពារជាតិ, ២៩ ធ្នូ ២០២១

... **ខ្ញុំស្នើឱ្យពិនិត្យថា តើយើងអាចដាក់ចូលក្នុងប្រតិទិន ប៉ុន្តែមិនមែនជាការសម្រាកប្រចាំឆ្នាំបានទេ។ ចាប់ពីឆ្នាំក្រោយទៅគួរដាក់ថា "អបអរសាទរទិវាបញ្ចប់សង្គ្រាមតាមរយៈនយោបាយឈ្នះឈ្នះ ឬអបអរសាទរនយោបាយឈ្នះឈ្នះ" ក្នុងប្រតិទិន ហើយមិនចាំបាច់ឱ្យមានការឈប់សម្រាកអីទេ ... ដាក់ថ្ងៃទី២៩ ធ្នូ ដើម្បីឱ្យដឹងថា ហ្នឹងជាថ្ងៃដែលយើងបញ្ចប់សង្គ្រាមទាំងស្រុង នាំមកនូវសន្តិភាព។** រឿងនេះ មិនមែនជារឿងតូចតាចទេ។ វាជារឿងធំណាស់។ (តើមាន)ប្រទេសប៉ុន្មាននៅលើពិភពលោកដែលកំពុងបន្តមានសង្គ្រាម? ... ៕

២៨. ភារកិច្ច ១០ ត្រូវយកចិត្តទុកដាក់សម្រាប់កងទ័ព

ពិធីអបអរខួបទី២០ កងទ័ពជើងគោក, ២៤ មករា ២០១៩

... សូមរំលឹកភារកិច្ច១០ យ៉ាងសម្រាប់កងទ័ពមិនថាជើងគោកជើងទឹកឬជើងអាកាស មិនថាអាវុធហត្ថ មិនថាកងទ័ពជំនាញ **... ទី១ ត្រៀមខ្លួនជាស្រេចការពារឯករាជ្យអធិបតេយ្យជាតិ អនុវត្តនយោបាយខឿនការពារជាតិប្រជាជន ... ទី២ រក្សាសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សង្គម ... ទី៣ ប្រយុទ្ធប្រឆាំងភេរវកម្ម និងវាយកម្ទេចឱ្យទាន់ពេលវេលាឧបាយកលបដិវត្តពណ៌ ... និងការពារផ្ទៃ ... ទី៤ ជួយប្រជាជន ពិសេសពេលមានគ្រោះមហន្តរាយ ... ទី៥ គាំទ្រកម្លាំងអនុវត្តច្បាប់ជានាការការពារព្រៃឈើ ដីលផែ ធនធានធម្មជាតិ ... ទី៦ គាំទ្រការប្រមូលចំណូលថវិកាជាតិ ទាំងថ្នាក់ជាតិទាំងថ្នាក់ក្រោមជាតិ ... ទី៧ ពង្រឹងវិន័យ បង្កើនសមត្ថភាពគ្រប់ផ្នែក ... ទី៨ ថែទាំសម្ភារយុទ្ធោបករណ៍គ្រប់ប្រភេទ ... ទី៩ យកចិត្តទុកដាក់ដល់ជីវភាពកងទ័ព ពិសេសនៅតំបន់ជាច់ស្រយាល ... ទី១០ ជើរតួនាទីជាអ្នកការទូត កសាងទំនាក់ទំនងល្អជាមួយប្រទេសជិតខាង និងប្រទេសជាមិត្តទាំងអស់** ... ៕

២៩. មានវត្តមាន ហ៊ុន សែន សូមកុំបារម្ភពីការកើតសង្គ្រាម

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់អូដឹម, ៦ ធ្នូ ២០១៧

... សូមនិយាយជាមួយប្រជាជនកម្ពុជាទាំងឡាយថា នៅពេលមាន **វត្តមាន ហ៊ុន សែន សូមកុំបារម្ភពីសង្គ្រាមកើតឡើងឱ្យសោះ។ ហ៊ុន សែន រួមជាមួយនឹងថ្នាក់ដឹកនាំនៃគណបក្សប្រជាជនគឺជាអ្នកធានាតែមួយគត់ចំពោះសន្តិភាពនិងការអភិវឌ្ឍរបស់ប្រទេសនេះជាបន្ត** ។ មនុស្សម្នាក់នេះ បានឈរនៅជាបង្គោល ជាមួយនឹងថ្នាក់ដឹកនាំដទៃទៀត តាំងពីរំដោះប្រជាជន និងទប់ស្កាត់ការវិលត្រឡប់របស់ប៉ុល ពត ស្វែងរកសន្តិភាព និងទប់ស្កាត់សង្គ្រាមដែលគេបង្កមិនចប់មិនហើយ ពិសេស ទប់ស្កាត់បដិវត្តពណ៌នៅឆ្នាំ២០១៣ និងដើមឆ្នាំ២០១៤ និងជាបន្តបន្ទាប់ ... **ការវាយប្រហារចំពោះ ហ៊ុន សែន មិនមែនជារឿងចំឡែកទេ ត្បិតថា (ហ៊ុន សែន)ម្នាក់នេះគឺជាឧបសគ្គដល់ដំណើរដណ្តើមអំណាចរបស់ពួកគេតាមផ្លូវងងឹត។ មានវត្តមាន ហ៊ុន សែន គឺមានវត្តមានសន្តិភាព** ... ៕

៣០. មិនអាចទទួលយកបាន ពាក្យសំដីប្រមាថចំពោះកងទ័ពជាតិ

ចែកសញ្ញាបត្រ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៤ សីហា ២០១៧

ហេតុអីបានមានរឿងអញ្ចឹង? សូមអ្នកធ្វើអត្ថាធិប្បាយទាំងឡាយដឹងថា**ការប្រមាថរបស់អ្នក មិនអាចទទួលបានទេ ... ការប្រមាថមេទ័ពថាសុទ្ធតែជាមេទ័ព**

ចោរ មិអាចទទួលយកបានទេ ហើយនេះជាបទល្មើសជាក់ស្តែង។ កុំថាអ្នកឯងប្រធានបក្ស អ្នកឯងស្តីក៏ដោយ មានអភ័យឯកសិទ្ធិសភាក៏ដោយ ព្រឹទ្ធសភាក៏ដោយ ឱ្យតែមានបទល្មើសជាក់ស្តែង ត្រូវតែវាយខ្នោះ។ សន្តិសុខរបស់ជាតិ មិនត្រូវបានប្រមាថទេ។ គេប្រើសម្តីមិនខុសពីកាលដែលឡើងប៉ុស្តិ៍អាវលឿង(ថៃ)ទេ។ ខ្ញុំជាអ្នកសម្របសម្រួលឱ្យមានការលើកលែងទោស។ តែមិននឹកស្មានថា គេមិនព្រមចោលភាពជម្លើយ ... **រឿងអ្នកឯងប្រមាថកងទ័ពជាតិមិនអាចទុកបានទេ** ...៕

៣១. ការបញ្ជាលើកងកម្លាំងប្រដាប់អាវុធជាសិទ្ធិស្របច្បាប់របស់នាយករដ្ឋមន្ត្រី

ចែកសញ្ញាបត្រ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៤ សីហា ២០១៧

... គ្មានអ្នកណាមានសិទ្ធិបញ្ជូនកម្លាំងទេ។ អ្នកខ្លះថា លោក ហ៊ុន សែន ប្រើអំណាចធំហួស(ដែលទៅ)បញ្ជាទ័ព ... សូម្បីចៅអធិការវត្តក៏ត្រូវបញ្ជាគ្រូសូត្រស្តាំ គ្រូសូត្រឆ្វេង ទាំងសង្ឃទាំងអាចារ្យ យាយជីទាំងអស់ដែរ។ **បើធ្វើនាយករដ្ឋមន្ត្រី មិនអាចបញ្ជាទ័ព មិនអាចបញ្ជាកម្លាំងប្រដាប់អាវុធបាន កុំធ្វើ ... ខ្ញុំមានអំណាចគ្រប់គ្រាន់ក្នុងហានៈជាប្រមុខរដ្ឋាភិបាល ដែលត្រូវអនុវត្តនយោបាយទាំងប្រទេស និងក្រៅប្រទេស នៅមិនទាន់គិតដល់(ហានន្តរសក្តិ)នាយឧត្តមសេនីយ៍ផុតលេខផ្កាយមាសប្រាំ នៅក្នុងឧត្តមក្រុមប្រឹក្សាការពារជាតិផង** ... នៅក្នុងប្រទេសកម្ពុជាអត់មាននរណាវឹងទទឹងជាមួយ ហ៊ុន សែន បានទេ ...៕

៣២. នយោបាយខឿនការពារជាតិប្រជាជន ភ្ជាប់ទំនាក់ទំនងរវាងកងទ័ពនិងប្រជាជន

ពិនិត្យមើលការដ្ឋានសាងសង់ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី, ២២ មិថុនា ២០២០

... ហេតុអី បានទិញរថយន្ត ២៩០គ្រឿងបំពាក់ឱ្យកងទ័ព ... ខ្ញុំឱ្យបញ្ជាទិញតាំងពីខែកុម្ភៈ ប៉ុន្តែដោយសារ COVID-19 ... ត្រូវចាំឱ្យមានការស្ងប់នៅខាងចិនសិន។ រឿងនេះចាប់ផ្តើមពីអ្វី? ... មិនអាចប្រើថវិកាជាតិទេ។ ត្រូវចលនាសប្បុរសជនរកវិធីបំពាក់មធ្យោបាយឱ្យថ្នាក់យោធភូមិភាគ បណ្តាកងពលនៅភាគខាងលើ(នៃប្រទេស) ... កងពល៩៩ របស់ក្រសួងការពារជាតិ និងកងពល៩០ របស់កងទ័ពជើងគោក មានរថយន្តជាង ២០០គ្រឿង ... ប៉ុន្តែអ្នកដែលប្រតិបត្តិការលឿនរហ័ស គឺនៅភូមិភាគ និងកងពលឯណោះ ... **នយោបាយខឿនការពារជាតិប្រជាជន**

ដែល ហ៊ុន សែន បានធ្វើ មិនមែនជារឿងថ្មីទេ។ ពេលមានសភាពការណ៍ម្តងៗ វិស័យឯកជនចូលរួមជួយកងទ័ព ... ដោយមានអង្គភាពធ្វើសម្ព័ន្ធភាព ... ក្រុមហ៊ុនធ្វើសម្ព័នភាពជាមួយកងពល ផ្សារភ្ជាប់ទំនាក់ទំនងរវាងកងទ័ព និងប្រជាជន បេះមិនជាច់។ ក្រុមហ៊ុនខ្លះបានធ្វើសម្ព័នភាពជាមួយកងការពារព្រំដែន ...៕

៦. កច្ចការនារី

១	សូមបុរសជាស្វាមីផ្តល់ឱកាសអោយភរិយាបានទៅបន្តការសិក្សា	១៣៧
២	អតុល្យភាពការសិក្សានៅមហាវិទ្យាល័យនាំដល់អតុល្យភាពមុខតំណែងក្នុងស្ថាប័ន	១៣៧
៣	លក្ខខណ្ឌជ្រើសរើស អាចឱ្យស្ត្រីបាត់បង់ឱកាស	១៣៨
៤	ស្ត្រីប្រឹងប្រែងផ្ទាល់ខ្លួន និងការជ្រាមជ្រែងពីគ្រួសារទៅថ្នាក់ក្រោយឧត្តមសិក្សា	១៣៨
៥	ផ្តល់ទិដ្ឋាការឲ្យរដ្ឋមន្ត្រីតែងតាំងស្ត្រី ក្នុងថ្នាក់អនុប្រធាននាយកដ្ឋានចុះក្រោម	១៣៨
៦	គួរឲ្យមានអភិបាលខេត្ត ឬអភិបាលរាជធានីជាស្ត្រី	១៣៩
៧	គួរមានស្ត្រីមួយនាក់យ៉ាងតិច ក្នុងជួរដឹកនាំខេត្ត/ស្រុក និងតាមស្ថាប័ននានា	១៣៩
៨	គួរមានស្ត្រីយ៉ាងហោចម្នាក់ ក្នុងតំណែងដឹកនាំនៃកងកម្លាំងប្រដាប់អាវុធ	១៤០
៩	តែងតាំងស្ត្រីក្នុងមុខតំណែង ហើយផ្តល់ការងារដែលចូលរួមធ្វើការសម្រេចចិត្ត	១៤០
១០	សូមបណ្តារដ្ឋមន្ត្រីនានា ជួបនិងស្តាប់មតិដើម្បីកែលំអស្ថានភាពស្ត្រីក្នុងស្ថាប័ន	១៤១
១១	កម្មវិធីជួបជុំ ៨មីនា ត្រូវធ្វើមុនថ្ងៃ ៨មីនា ដើម្បីឲ្យស្ត្រីមានពេលសម្រាក	១៤១
១២	ក្រុមមេធាវីសម្តេច តេជោ ការពារក្តីស្ត្រីក្រីក្រ ពិសេសស្ត្រីក្នុងមន្ទីរឃុំឃាំង	១៤១
១៣	ពង្រឹងអំណាចសេដ្ឋកិច្ច គឺពង្រឹងអំណាចនយោបាយរបស់ស្ត្រី	១៤២
១៤	ម្ចាស់អាជីវកម្មខ្នាតតូច និងមធ្យម៦៥% ជាស្ត្រី	១៤២
១៥	ចលនាជាតិកសាងអន្តេវាសិកដ្ឋានសម្រាប់សិស្សនិងនិស្សិតជាស្ត្រី	១៤២
១៦	ស្ត្រីជារដ្ឋមន្ត្រីកិច្ចការនារីនិងវប្បធម៌ នឹងនៅបន្តការងារនាអាណត្តិក្រោយ	១៤៣
១៧	ការស្នង់មតិបង្ហាញថា "អ្នកចូលចិត្ត ហ៊ុន សែន" ជាស្ត្រី មានអត្រាខ្ពស់ជាងបុរស	១៤៣
១៨	បញ្ចប់សង្គ្រាម មានសន្តិភាពនិងអភិវឌ្ឍ ផ្តល់ផលប្រយោជន៍ច្រើនដល់ស្ត្រី	១៤៤
១៩	បំពេញថវិកាបន្ថែមឱ្យបាន ៥០០លានរៀល ជូនក្រុមប្រឹក្សាជាតិដើម្បីស្ត្រី	១៤៤
២០	ស្ត្រីក៏ត្រូវតែខំប្រឹងខ្លួនឯងផង និងគាំទ្រនូវតួនាទីរបស់ស្ត្រីគ្នាឯងផង	១៤៥

១. សូមបុរសជាស្វាមីផ្តល់ឱកាសអោយភរិយាបានទៅបន្តការសិក្សា

ពិធីចែកសញ្ញាបត្រនិស្សិត នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ១១ មីនា ២០១៩

... ដោយឡែក ក្នុងស្ថានភាពនៅក្នុងសាកលវិទ្យាល័យនេះ ... ទិន្នន័យនិស្សិតកំពុងសិក្សាមាន ១៤៧០០នាក់ក្នុងនោះមានស្ត្រី ៧១៩០នាក់ស្មើនឹង ៤៨,៩១% ដែលចំនួននេះ ប្រៀបធៀបទៅនឹងរយៈពេលមុនមានការកើនឡើង ... នៅថ្នាក់បរិញ្ញាបត្រ ... ស្ត្រីមានចំនួនច្រើនជាងបុរស។ ពេលឡើងទៅបរិញ្ញាជាន់ខ្ពស់ ក្នុងចំនួន ១៣០៧នាក់ នារីមានតែ ៣៩១នាក់ ... **បានសេចក្តីថាចំនួនធ្លាក់ចុះគំហុកតែម្តង។ យើងអាចយល់ស្ថានភាពនេះបាន គឺស្ត្រីដល់វ័យដែលខ្លួនត្រូវយកគូស្រករ ឬហូតដល់មានកូន ដូច្នេះការបន្តរៀនមានការធ្លាក់ចុះ។ យ៉ាងណាក្តី សូមបុរសជាស្វាមីផ្តល់ឱកាសអោយភរិយាបានបន្តការសិក្សាបន្ថែម** ...។

២. អតុល្យភាពការសិក្សានៅមហាវិទ្យាល័យ នាំដល់អតុល្យភាពមុខតំណែងក្នុងស្ថាប័ន មិនថាផ្នែករដ្ឋ មិនថាផ្នែកឯកជន

ពិធីចែកសញ្ញាបត្រនិស្សិត នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ១១ មីនា ២០១៩

... ជាការអំពាវនាវចំពោះស្ត្រីទាំងឡាយដែលចប់បរិញ្ញាហើយ គប្បីបន្តឈានឆ្ពោះទៅរកបរិញ្ញាបត្រជាន់ខ្ពស់។ ក្នុងនោះ ក៏សូមអំពាវនាវចំពោះមាតាបិតា និងអំពាវនាវចំពោះស្វាមីនៃស្ត្រីដែលចង់ទទួលបានការបណ្តុះបណ្តាលបន្ថែម (លើកទឹកចិត្ត)អោយបន្តការខិតខំ ដើម្បីលើកកម្ពស់ការស្មើភាព ទទួលបានការបណ្តុះបណ្តាល **បើមិនដូច្នេះទេ(មិនអាចទទួលបានមុខតំណែងខ្ពស់)។ ក្នុងការតែងតាំងមុខតំណែងកន្លែងខ្លះ មានការតម្រូវតែម្តងថា ទាល់តែអ្នកឯងមានបរិញ្ញាជាន់ខ្ពស់ទើបទទួល ឬក៏ទទួលអោយប្រឡង។ គេមានកម្រិតយ៉ាងដូច្នេះ។ អញ្ចឹង បើមានអតុល្យភាពតាំងពីមហាវិទ្យាល័យទៅហើយ វាក៏នឹងមានអតុល្យភាពនៅក្នុងស្ថាប័ន មិនថាផ្នែករដ្ឋ មិនថាផ្នែកឯកជននោះទេ** ...។

៣. លក្ខខណ្ឌជ្រើសរើស អាចឱ្យស្ត្រីបាត់បង់ឱកាស

ចែកសញ្ញាបត្រដល់និស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២៦ ធ្នូ ២០១៩

... (អត្រាបន្តការសិក្សានៅ)ថ្នាក់ក្រោយឧត្តមសិក្សាមានស្ត្រីចំនួនតិចជាង។ ទោះបីបែបនេះ គប្បីយើងប្រឹងរុញអត្រាស្ត្រី(បន្តការសិក្សានៅថ្នាក់ក្រោយឧត្តម) ឱ្យមានតួលេខ(ខ្ពស់ឡើង) កុំឱ្យធ្លាក់ច្រើនហួស ... **ការទាមទាររបស់ស្ត្រីគឺសមភាពយេនឌ័រ ហើយក៏ចង់បានការវិនិយោគចំពោះស្ត្រី ប៉ុន្តែបើស្ថាប័ននានាមិនបន្ធូរបន្ថយលក្ខខណ្ឌសំរាប់ស្ត្រីឱ្យទាបជាងទេ (គាត់ពិបាកនឹងមានឱកាស) ... ឧ. ការប្រឡងចូលស្ថាប័នមួយ តម្រូវឱ្យមានបរិញ្ញាបត្រជាន់ខ្ពស់។ (បើ)ស្ត្រីមានត្រឹមតែបរិញ្ញាបត្រ មិនមានឱកាសចូលប្រឡងជាមួយគេទេ។** តាមវិស័យឯកជនក៏ដូចគ្នា ជួនកាលគេតម្រូវ ... អញ្ចឹងស្ត្រីនឹងបាត់ឱកាស ...។

៤. ស្ត្រីប្រឹងប្រែងផ្ទាល់ខ្លួន និងការជ្រោមជ្រែងពីគ្រួសារទៅថ្នាក់ក្រោយឧត្តមសិក្សា

ចែកសញ្ញាបត្រដល់និស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២៦ ធ្នូ ២០១៩

... យើងមិនអាចទៅកំណត់ថា ជ្រើសរើសបុគ្គលិកប៉ុណ្ណោះ បុរសលក្ខខណ្ឌត្រូវតែមានបរិញ្ញាជាន់ខ្ពស់ឡើង ស្ត្រីត្រូវតែមានបរិញ្ញាបត្រនេះឬនោះទេ។ យើងអត់ទាន់ដាក់អញ្ចឹងបានទេ។ បើដាក់អញ្ចឹងថ្ងៃក្រោយស្ត្រីលែងរៀនហើយ។ រៀនត្រឹមតែបរិញ្ញាបត្រ។ នេះជាកត្តាសត្យានុម័ត។ **វាតម្រូវឱ្យមានការខិតខំផ្ទាល់ខ្លួនរបស់ស្ត្រីផង និងមានការជួយជ្រោមជ្រែងពីគ្រួសារផង នៅពេលដែលចប់បរិញ្ញាបត្រហើយ ត្បិតថាបើមានប្តីហើយ ទាល់តែប្តីអនុញ្ញាតឱ្យមករៀនដែរ** ...។

៥. ផ្តល់ទិដ្ឋាការឱ្យរដ្ឋមន្ត្រីតែងតាំងស្ត្រី ក្នុងថ្នាក់អនុប្រធាននាយកដ្ឋានចុះក្រោម

ក្នុងមិទ្ធិញអបអរសាទរខួបទី១០៨ ទិវាអន្តរជាតិនារី ៨មីនា, ៥ មីនា ២០១៩

... ខ្ញុំនៅតែលើកទឹកចិត្ត និងគាំទ្រឲ្យគ្រប់ស្ថាប័ន(អោយអនុវត្ត) ឧទាហរណ៍ កន្លងទៅ ដោយសារតែថ្នាក់អនុប្រធាននាយកដ្ឋានត្រូវបានតែងតាំងដោយរដ្ឋមន្ត្រី ការតែងតាំងអនុប្រធាននាយកដ្ឋានមានប៉ុន្មាននាក់។ វាច្រើនពេក។ ដូចនេះ កាល

ពីប៉ុន្មានឆ្នាំមុន មានការតែងតាំងអនុប្រធាននាយកដ្ឋានពេញក្រសួង។ (តែ ទោះបីជាច្រើនដូចនេះក្តី) នៅក្នុងចំនួននោះ មិនមានស្ត្រីទេ។ ឥឡូវនេះ **ប្រសិនបើត្រូវការពង្រីកមុខតំណែង (ក្រសួង)មុខងារសាធារណៈគួរផ្តល់ទិដ្ឋាការឱ្យរដ្ឋមន្ត្រីចុះហត្ថលេខាតែងតាំងស្ត្រីឱ្យកាន់មុខតំណែង ចាប់ពីអនុប្រធាននាយកដ្ឋានចុះក្រោម។ រឿងហ្នឹង ទាល់តែមានទិដ្ឋាការទើបអាចទទួលបានការតែងតាំង។ ឯចាប់ពីប្រធាននាយកដ្ឋានឡើងលើ ហ្នឹងជាសិទ្ធិអំណាចរបស់(នាយករដ្ឋមន្ត្រី)** ...។

៦. គួរឲ្យមានអភិបាលខេត្ត ឬអភិបាលរាជធានីជាស្ត្រី

ខួបអនុស្សាវរីយ៍លើកទី ១០៦ ទិវាអន្តរជាតិនារី ៨ មីនា, ៨ មីនា ២០១៧

សូមនិយាយទៅកាន់អ្នកចូលរួម ក៏ដូចបណ្តាស្ថាប័ននានាផងដែរ។ យើងបានកំណត់រួចហើយថានៅ**ថ្នាក់រដ្ឋបាលក្រោមជាតិ គឺថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ឱ្យមានអភិបាលរងរាជធានី-ខេត្តមួយ ឬស្រុក-ខណ្ឌមួយ(ជាស្ត្រី)ក៏ប៉ុន្តែក្នុង ២៥ រាជធានី-ខេត្ត មិនទាន់មានអភិបាលខេត្ត ឬអភិបាលរាជធានីជាស្ត្រីនោះទេ។ ខ្ញុំបានពិភាក្សាជាមួយសម្តេចក្រឡាហោមថា យើងគួរតែកំណត់ថាត្រូវតែមានមួយកន្លែងសំរាប់ចៅហ្វាយខេត្តជាស្ត្រី** ... ខ្ញុំគិតថាយើងរៀបចំបាន។ ពេលកន្លែងណាមួយមានអភិបាលខេត្តចូលនិវត្តន៍ ឬក៏មានការផ្លាស់ប្តូរណាមួយ អាចដាក់ស្ត្រីម្នាក់ក្នុងចំណោម២៥ (រាជធានី-ខេត្ត) ទុកតែ២៤ បានហើយសម្រាប់បុរស ...។

៧. គួរមានស្ត្រីមួយនាក់យ៉ាងតិច ក្នុងជួរដឹកនាំខេត្ត/ស្រុក និងតាមស្ថាប័ននានា

ខួបអនុស្សាវរីយ៍លើកទី ១០៦ ទិវាអន្តរជាតិនារី ៨ មីនា, ៨ មីនា ២០១៧

សម្រាប់**ថ្នាក់ខេត្ត ថ្នាក់ស្រុក យើងថាអោយមានមួយយ៉ាងតិច ហើយបើមាន ២ឡើងលើ ហ្នឹងកាន់តែល្អ។ ចំពោះក្រសួង ស្ថាប័នក៏ដូចគ្នាដែរ។** កម្រិតនយោបាយមានជារដ្ឋមន្ត្រីហើយ មានជាឧបនាយរដ្ឋមន្ត្រីហើយៗ ក៏មានរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ។ ខ្ញុំប្រើពាក្យថាមានមួយយ៉ាងតិច មានន័យថាអនុញ្ញាតអោយមាន ២, ៣, ៤, ៥ ក៏បានដែរ អត់មានទាស់អីទេ។ បញ្ហានេះទាក់ទងនឹងតួនាទីខ្ញុំផ្ទាល់ ដែលត្រូវពិនិត្យមើលតែក៏សំអាងលើថ្នាក់ក្រោមផ្តល់មតិ។ សម្រាប់មុខងារសាធារណៈ **សូមអោយក្រសួងស្ថាប័នពិនិត្យដាក់ស្ត្រីអោយបានកាន់តែច្រើនជា**

អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ដើម្បីស្ត្រីកាន់តែមានលទ្ធភាពចូលរួមក្នុងដំណើរការទាំងអស់ ...។

៨. គួរមានស្ត្រីយ៉ាងហោចម្នាក់ ក្នុងតំណែងដឹកនាំនៃកងកម្លាំងប្រដាប់អាវុធ

ខួបអនុស្សាវរីយ៍លើកទី ១០៦ ទិវាអន្តរជាតិនារី ៨ មីនា, ៨ មីនា ២០១៧

... និយាយពី**កងកម្លាំងប្រដាប់អាវុធវិញ យើងមានស្ត្រីក្នុងឋានៈជាលេខាធិការអនុរដ្ឋលេខាធិការ ក៏ប៉ុន្តែចង់បន្ថែមអោយជ្រៅលើសពីនេះ។ ក្នុងចំណោមអគ្គបញ្ជាការរងកងទ័ព កងយោធពលខេមរភូមិន្ទ គួរតែមានស្ត្រីម្នាក់(យ៉ាងតិច)ជាអគ្គបញ្ជាការរងកងទ័ព។ នាយសេនាធិការចម្រុះ នាយរងសេនាធិការចម្រុះ ក៏គួរមានស្ត្រីដែរ ... គួរបណ្តុះបណ្តាលស្ត្រីសំរាប់មុខតំណែងអនុភូមិភាគ**។ (សម្រាប់)កងពល យើងអាចឱ្យមានស្ត្រីដឹកនាំក្នុងកម្រិតអនុកងពលធំ។ យោធាខេត្តគួរតែមានស្ត្រីម្នាក់ដែរ ក្នុងចំណោមមេបញ្ជាការរងនៃប្រតិបត្តិការសឹក។ បើគាត់មានលទ្ធភាពធ្វើជាមេបញ្ជាការប្រតិបត្តិការសឹក ក៏កាន់តែល្អ ... អាវុធហត្ថលើផ្ទៃប្រទេសគួរមានម្នាក់ជាស្ត្រី ព្រោះខាងអគ្គស្នងការនគរបាលជាតិមានហើយ ...។

៩. តែងតាំងស្ត្រីក្នុងមុខតំណែង ហើយផ្តល់ការងារដែលចូលរួមធ្វើការសម្រេចចិត្ត

មិទ្ធិញអបអរសាទរខួបទី១០៨ ទិវាអន្តរជាតិនារី ៨មីនា, ៥ មីនា ២០១៩

... បច្ចុប្បន្នស្ត្រីបានកសាងសមត្ថភាពគ្រាន់បើហើយ។ ដូច្នេះ ការចាត់ឱ្យគាត់ទទួលបន្ទុក(ការងារកម្រិត)អគ្គនាយកដូចជាបុរសដែរគឺជាការល្អ។ មុខតំណែងអគ្គនាយករង(មួយកន្លែងៗ) ហោចណាស់មាន ៤ឬ ៥នាក់ ដែលគប្បីមានស្ត្រី១នាក់ ឬ ២នាក់ នៅក្នុងនោះ។ នៅថ្នាក់នាយកដ្ឋាន បើមិនបានធ្វើប្រធាននាយកដ្ឋានទេ ក៏គប្បីមានអនុប្រធាននាយកដ្ឋានម្នាក់(ជាស្ត្រី)ផងដែរ។ បើរៀបចំបែបនេះបាន វាជាការល្អ។ ខ្ញុំនៅតែបញ្ជាក់បន្ថែមថា **តែងតាំងហើយ ត្រូវផ្តល់ការងារឱ្យធ្វើផង មិនមែនតែងតាំងគ្រាន់តែបង្ក្រប់កិច្ច ដើម្បីនិយាយថាអង្គភាពឬស្ថាប័នមានសមភាពយេនឌ័រ ព្រោះស្ត្រីមានប៉ុណ្ណោះភាគរយប៉ុណ្ណោះភាគរយ ដែលទីចុងបំផុត ស្ត្រីមិនបានចូលរួមធ្វើការសម្រេចចិត្ត បំពេញមុខងារជាអ្នកទទួលខុសត្រូវក្នុងស្ថាប័នជំនាញនោះទេ** ...។

១០. សូមបណ្តារដ្ឋមន្ត្រីនានា ជួបនិងស្តាប់មតិដើម្បីកែលំអស្ថានភាពស្ត្រីក្នុងស្ថាប័ន

ការអត្ថាធិប្បាយក្នុងមីទ្ធិងអបអរសាទរខួបទី១០៨ ទិវាអន្តរជាតិនារី ៨មីនា, ៥ មីនា ២០១៩

... យើងមិននិយាយឱ្យតែពិរោះស្តាប់នោះទេ។ ត្រូវធ្វើសកម្មភាពជាក់ស្តែង។ បណ្តារដ្ឋមន្ត្រីតាមស្ថាប័ន គប្បីធ្វើការឱ្យបានញឹកញាប់បន្តិចជាមួយក្របខណ្ឌ(មន្ត្រី)ជាស្ត្រី។ ក្នុងមួយឆ្នាំ ប្រើប្រាស់ ២ទៅ ៣ពេលដើម្បី**ជួបស្ត្រី និងស្តាប់មតិរបស់ពួកគាត់ ... គេមានសំណួរអី ... គួរតែស្តាប់ដើម្បីបង្កើនការយកចិត្តទុកដាក់និងកែលម្អស្ថានភាពស្ត្រីតាមស្ថាប័ន ... បើសិនជាស្ថាប័ន ឬទីកន្លែងមួយៗនៅតាមខេត្ត/ស្រុក ធ្វើកិច្ចការនេះបានប្រសើរ ស្ថានភាពស្ត្រីរបស់យើង នឹងបានរួមចំណែកកាន់តែធំ ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ** ...។

១១. កម្មវិធីជួបជុំ ៨មីនា ត្រូវធ្វើមុនថ្ងៃ ៨មីនា ដើម្បីឱ្យស្ត្រីមានពេលសម្រាក

មិទ្ធិញអបអរសាទរខួបទី១០៨ ទិវាអន្តរជាតិនារី ៨មីនា, ៥ មីនា ២០១៩

... រៀងរាល់ឆ្នាំ យើងយកថ្ងៃ ៨មីនាដើម្បីធ្វើការជួបជុំគ្នា ដូច្នេះ ថ្នាក់ដឹកនាំជាស្ត្រីនិងស្ត្រីរបស់យើង មិនមានឱកាសនឹងបានធ្វើដំណើរកម្សាន្តសប្បាយ។ ចាប់ពីពេលនេះតទៅ **យើងត្រូវធ្វើពិធីនៅមុនថ្ងៃ ៨(មីនា)មកដល់ ដើម្បីទុកថ្ងៃ ៨មីនានោះ សំរាប់ទទួលបានការឈប់សម្រាកនិងកម្សាន្តតាមការចង់បានរបស់ស្ត្រីគ្រប់រូប។** ឆ្នាំនេះ ខ្ញុំស្នើឱ្យលោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារី ក៏ដូចជាស្ត្រីទាំងឡាយមេត្តាជួយអញ្ជើញប្រពន្ធខ្ញុំ ឱ្យបានទៅកម្សាន្តជាមួយគេផង ក្រែងគាត់ថាខ្ញុំទុកគាត់នៅផ្ទះ ...។

១២. ក្រុមមេធាវីសម្តេច គេជោ ការពារក្តីស្ត្រីក្រីក្រ ពិសេសស្ត្រីក្នុងមន្ទីរឃុំឃាំង

បើកការដ្ឋានសាងសង់សំណង់ផ្សេងៗ ក្នុងគម្រោងការពារទឹកជំនន់និងកែលម្អប្រព័ន្ធប្រឡាយ-លូ ក្នុងរាជធានីភ្នំពេញ ជំហានទី៤, ៤មីនា ២០១៩

... **មេធាវីរបស់ ហ៊ុន សែន បានចាប់ផ្តើមដំណើរការហើយ ... ដើម្បីការពារស្ត្រីក្រីក្រ។ ខ្ញុំឱ្យចាប់ផ្តើមពីស្ត្រីមុន ព្រោះស្ត្រីខ្លះនៅក្នុងមន្ទីរឃុំឃាំង មិនទាន់បានកាត់ទោសដោយសារតែខ្វះមេធាវី ដែល(ធ្វើឱ្យមាន)ភាពកកកុញនៅពន្ធនាគារ។**

សូមបញ្ជាក់ជាថ្មីជាសាធារណៈ សូមបណ្តាពន្ធនាគារបញ្ឈប់ការ(អនុញ្ញាត)ប្រើប្រាស់ទូរស័ព្ទ ... ខ្ញុំបានឲ្យ ឯកឧត្តម អង្គ វង្សវឌ្ឍនា ឆែ ស៊ីណារិទ្ធ និង(លោក ជំទាវ) អឹង កន្ថាផាវី បានដឹងហើយ។ រឿងប្រើប្រាស់ទូរស័ព្ទចេញពីពន្ធនាគារនៅតែមានបន្ត។ រត់ការដើម្បីយកឈ្នះខ្លួន។ តើសូកប៉ាន់អ្នកណា? ...។

១៣. ពង្រឹងអំណាចសេដ្ឋកិច្ច គឺពង្រឹងអំណាចនយោបាយរបស់ស្ត្រី

អបអរសាទរខួបទី១០៧ ទិវាអន្តរជាតិនារី ៨មីនា, ៨មីនា ២០១៨

... ដោយប្រាក់ចំណូលកើនឡើង ខ្ញុំកត់សម្គាល់ឃើញថាស្ត្រីបានពង្រឹងខ្លួនក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ស្ត្រីកាន់តែមានលទ្ធភាព ឬហៅថាអំណាចនៃសេដ្ឋកិច្ច ឬអំណាចនយោបាយនៅក្នុងគ្រួសារ ... កូនក្មួយ(ជាស្ត្រី)បច្ចុប្បន្នមានឥទ្ធិពលកាន់តែខ្ពស់ ព្រោះមិនបានពឹងពាក់ទៅលើប្រាក់ចំណូលរបស់បុរសនោះទេ។ គេមានប្រាក់ចំណូលខ្លួនគេ។ ដូច្នេះ **ការយកចិត្តទុកដាក់ពង្រឹងស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច គឺជាការពង្រឹងសិទ្ធិអំណាចនយោបាយរបស់ស្ត្រីនៅក្នុងគ្រួសារ ក៏ដូចជាការធ្វើការសម្រេចនានា ក្នុងក្របខណ្ឌនយោបាយផងដែរ** ...។

១៤. ម្ចាស់អាជីវកម្មខ្នាតតូច និងមធ្យម៦៥% ជាស្ត្រី

ការអធិប្បាយក្នុងមីទ្ទិងអបអរសាទរខួបទី១០៨ ទិវាអន្តរជាតិនារី ៨មីនា, ៥ មីនា ២០១៩

... ខ្ញុំមានការសប្បាយចិត្តដែលបានឃើញ**តួលេខចំនួនស្ត្រីជាសហគ្រិនកើនឡើង។ ម្ចាស់អាជីវកម្មខ្នាតតូច ឬមធ្យមនៅក្នុងប្រទេសរបស់យើង ជាស្ត្រីមានដល់៦៥% ដែលនេះជាតួលេខគួរអបអរសាទរចំពោះស្ត្រីកម្ពុជា**។ ខ្ញុំតែងតែតាមដានដោយយកចិត្តទុកដាក់ការសន្ទនាតាមកញ្ចក់ទូរទស្សន៍ អំពីសហគ្រិនជាស្ត្រី និងឃើញថាស្មានភាពរបស់ពួកគេប្រសើរ។ ខ្ញុំលើកទឹកចិត្តអំពីបញ្ហានេះ។ កុំឱ្យថាឱ្យតែថៅកែសុទ្ធតែប្រុស ...។

១៥. ចលនាជាតិកសាងអន្តេវាសិកដ្ឋានសម្រាប់សិស្សនិងនិស្សិតជាស្ត្រី

អបអរសាទរទិវាអន្តរជាតិនារី ៨មីនា លើកទី១១២, ៧ មីនា ២០២៣

... ក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ពីថ្ងៃ ២១កុម្ភៈ ២០២៣ ខ្ញុំបាន**ប្រគល់ភារកិច្ចឲ្យក្រសួងអប់រំ យុវជននិងកីឡា កសាងអន្តេវាសិកដ្ឋានសម្រាប់សិស្សនិងនិស្សិតជានារី ដើម្បីជួយសម្រួលដល់ការរៀនសូត្រនៅរាជធានីភ្នំពេញនិងនៅតាមខេត្តនានា ... (យើង)ធ្វើ(កិច្ចការនេះ)ឲ្យក្លាយទៅជាចលនាជាតិមួយ** ... យើងដាក់ចេញទិសដៅកសាងអន្តេវាសិកសម្រាប់សិស្សជាស្ត្រី ដែលមិនមែនរៀបចំតែនៅទីក្រុងភ្នំពេញនោះទេ ប៉ុន្តែក៏ត្រូវផ្តោតការយកចិត្តទុកផងដែរតាមបណ្តាខេត្ត។ សូមអំពាវនាវចំពោះសប្បុរសជន ចូលរួមកសាងអន្តេវាសិកសម្រាប់សិស្សជាស្ត្រីនៅតាមវិទ្យាល័យនានា ដែលយើងបានពង្រាយទូទាំងប្រទេសហើយនៅកៀកតាមភូមិ តាមខេត្ត តាមស្រុក ...។

១៦. ស្ត្រីជារដ្ឋមន្ត្រីកិច្ចការនារីនិងក្រសួងវប្បធម៌ នឹងនៅបន្តការងារនានាអាណត្តិក្រោយ

អបអរសាទរទិវាអន្តរជាតិនារី ៨មីនា លើកទី១១២, ៧ មីនា ២០២៣

... យើងត្រៀម(រៀបចំការ)បោះឆ្នោត ហើយរាជរដ្ឋាភិបាលថ្មី(ក៏នឹង)ត្រូវបង្កើត(ឡើង) ប្រហែលជានៅក្នុងអាទិត្យទី២ ឬអាទិត្យទី៣ នៃខែកញ្ញា។ មនុស្សមួយចំនួនអាចនឹងចង់ដឹង(អំពីសមាសភាពគណៈរដ្ឋមន្ត្រីថ្មី)។ **ខ្ញុំអាចនិយាយបានថា ស្ត្រីជារដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈមិនត្រូវបានផ្លាស់ប្តូរទេ។ សូមបន្តការងារតទៅទៀត។ ខ្ញុំបានដឹកនាំរាជរដ្ឋាភិបាល ៣៨ឆ្នាំ ហើយបើរាប់ទាំងក្របខណ្ឌរដ្ឋាភិបាល មានរយៈពេលជាង ៤៤ឆ្នាំ។ ខ្ញុំមានមោទនភាពចំពោះរដ្ឋមន្ត្រីក្រសួងកិច្ចការនារីដែលបានធ្វើកិច្ចការដ៏ល្អ។** ខ្ញុំសូមអរគុណដល់ស្ត្រីទាំងឡាយនៅទូទាំងកម្ពុជា ...។

១៧. ការស្ទង់មតិបង្ហាញថា "អ្នកចូលចិត្ត ហ៊ុន សែន" ជាស្ត្រី មានអត្រាខ្ពស់ជាងបុរស

អបអរសាទរទិវាអន្តរជាតិនារី ៨មីនា លើកទី១១២, ៧ មីនា ២០២៣

... សូមទម្លាយអាថ៌កំបាំងមួយអំពីការធ្វើការស្ទង់មតិ។ **មានការស្ទង់មតិ ៣ដងចុងក្រោយ គឺខែមករា២០២២, តុលា២០២២ និងខែមករា២០២៣ (បង្ហាញថាក្នុងចំណោម)អ្នកចូលចិត្ត ហ៊ុន សែន ស្ត្រីមានអត្រាខ្ពស់ជាងបុរសឆ្ងាយ**។ សូមអរគុណស្ត្រីទាំងឡាយដែលបានគាំទ្រ(ខ្ញុំ)។ ការគាំទ្រនេះជាសម្លេង/សន្លឹកឆ្នោត។

(ការស្នងមតិនេះ)តែង(ត្រូវបាន)ធ្វើ និងធ្វើដោយក្រុមអ្នកឯកទេសមកពីក្រៅប្រទេស។ **ការគាំទ្រអាចមានខ្ពស់មានទាប(តាម)តំបន់ ប៉ុន្តែទោះបីខ្ពស់ទោះបីទាបយ៉ាងណា ទីកន្លែងណាក៏ដោយ អត្រាពេញចិត្ត ហ៊ុន សែន គឺស្ត្រីមានច្រើនជាងបុរស។ ខ្ញុំកំពុងស្រាវជ្រាវថាហេតុអ្វីបានជាស្រីគាំទ្រ ហ៊ុន សែន?** ...៕

១៨. បញ្ចប់សង្គ្រាម មានសន្តិភាពនិងអភិវឌ្ឍ ផ្តល់ផលប្រយោជន៍ច្រើនដល់ស្ត្រី

អបអរសោទរទិវាអន្តរជាតិនារី ៨មីនា លើកទី១១២, ៧ មីនា ២០២៣

... **(ការគាំទ្រអត្រាខ្ពស់ក្នុងចំណោមស្ត្រីនេះ) ប្រហែលជាដោយសារស្ត្រីបានទទួលផលប្រយោជន៍ច្រើនពីសុខសន្តិភាពនិងការអភិវឌ្ឍ ដែលខ្ញុំបានដឹកនាំក្នុងរយៈពេលកន្លងទៅ។ ក្នុងពេលសង្គ្រាម ទោះបីមិនបានចូលរួមប្រយុទ្ធក្នុងសមរភូមិក៏ដោយ ស្ត្រីរងការឈឺចាប់ជាងគេ។** មិនត្រូវភ្លេចថា ស្ត្រីបានលះបង់ប្តីសី កូន បងប្រុស ប្អូន ឲ្យធ្វើកងទ័ព ... **បន្ទាប់ពី(ការបញ្ចប់)សង្គ្រាម នៅគ្រប់ទីកន្លែងទាំងអស់ តាំងពីតំបន់ឆ្នេរ តំបន់ទីក្រុង តំបន់ទន្លេសាប និងតំបន់ផ្សេង ដែលខ្ញុំបាន(ឱ្យ)ពិនិត្យសិក្សា ស្ត្រីទទួលផលប្រយោជន៍ធំ**។ មានឯកសារស្តីពីវឌ្ឍនភាពនេះនៅសម្តេច ពិជ័យសេនា និងលោកជំទាវ ម៉ែន សំអន ជាភាសាអង់គ្លេស តែយើងបានបកប្រែ។ ប៉ុន្តែខ្ញុំមិនផ្សព្វផ្សាយទេ ...៕

១៩. បំពេញថវិកាបន្ថែមឱ្យបាន ៥០០លានរៀល ជូនក្រុមប្រឹក្សាជាតិដើម្បីស្ត្រី

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្ត សម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

...**ខ្ញុំបានផ្តល់ឱ្យមេធាវីរាជរដ្ឋាភិបាល ...ដោយដំឡើងបន្តិចម្តងៗបន្ទាប់ទៅឱ្យក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ប៉ុន្មានឆ្នាំចុងក្រោយនេះ ៥០០លានរៀល ប៉ុន្តែលឺថាឆ្នាំក្រោយកាត់ឱ្យនៅសល់តែ ៣០០លាន(រៀល) ...ទោះបីច្បាប់ថវិកាចេញមែនក៏ដោយ ខ្ញុំស្នើឱ្យបំពេញបន្ថែមគ្រប់ ៥០០លានរៀល ដោយយកថវិកាដែលមិនទាន់បែងចែក ឬយកពីទីស្តីការគណៈរដ្ឋមន្ត្រីមកបន្ថែមអោយគ្រប់ ៥០០លានរៀល។** ដោយឃើញថាមិនគ្រប់ ទើបឆ្នាំកន្លងទៅ ពេលប្រជុំក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ខ្ញុំក៏ផ្តួចផ្តើមគំនិតបង្កើតឡើងនូវមេធាវីស្ម័គ្រចិត្តសម្តេចតេជោ ...៕

២០. ស្ត្រីក៏ត្រូវតែខំប្រឹងខ្លួនឯងផង និងគាំទ្រនូវតួនាទីរបស់ស្ត្រីគ្នាឯងផង

ជួបអនុស្សាវរីយ៍លើកទី ១០៦ ទិវាអន្តរជាតិនារី ៨ មីនា, ៨ មីនា ២០១៧

... **សូមអំពាវនាវស្ត្រីទាំងឡាយបង្កើនសមត្ថភាពខ្លួនឯង ហើយគាំទ្រតួនាទីរបស់ស្ត្រី(គ្នាឯង)ក្នុងការរៀបចំ(ខ្លួន)ចូលទៅក្នុងស្ថាប័នទាំងនោះ។ ធ្វើបានយ៉ាងនេះ ខ្ញុំគិតថាយើងនឹងពង្រីកបានចំនួនស្ត្រីក្នុងវិស័យសាធារណៈ វិស័យឯកជន ព្រមទាំងការបញ្ចូលក្នុងកងកម្លាំងប្រដាប់អាវុធ** ... សូមសម្តេចក្រឡាហោមពិភាក្សានិងពិនិត្យមើលតើអ្នកណា នៅកន្លែងណា សក្តិសមធ្វើជាអភិបាលខេត្តណានៅពេលខាងមុខ។ ខ្ញុំត្រៀមតែចុះហត្ថលេខាឲ្យទេ។ យើងមើល ២៥ខេត្ត និងរាជធានីអត់ទាន់មានស្ត្រីម្នាក់ទេ។ កាលពីជំនាន់អតីតរដ្ឋកម្ពុជា អភិបាលខេត្តរតនគិរី លោកជំទាវ ឡាក់ អូន ពេលនោះ សង្គ្រាមនៅហ៊ុំព័ទ្ធ ...សង្ឃឹមថាស្ត្រីរបស់យើងនឹងដើរតួកាន់តែធំទៅៗ ...៕

៧. គ្រោះមហន្តរាយ

១	មិនចោលមុខងារប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ	១៤៩
២	ហ៊ុន សែន គ្មានទម្លាប់រត់ចោលប្រជាជនពេលមានទុក្ខលំបាក	១៤៩
៣	ការសង្គ្រោះ/គ្រប់គ្រងគ្រោះមហន្តរាយឆ្លងព្រំដែនជាគំនិតផ្តួចផ្តើម ហ៊ុន សែន	១៤៩
៤	សមយុទ្ធប្រឆាំងភេរវកម្ម សង្គ្រោះគ្រោះមហន្តរាយ ជាសមយុទ្ធដែលចង់ធ្វើ	១៥០
៥	បំពាក់រថយន្តកងទ័ព ដើម្បីប្រើជាមធ្យោបាយសង្គ្រោះប្រជាពលរដ្ឋ	១៥០
៦	មិនអាចត្រួតត្រាគ្រោះធម្មជាតិបាន តែអាចសង្គ្រោះជីវិតពីស្លាប់បាន	១៥១
៧	គ្រោះធម្មជាតិមាននៅគ្រប់ប្រទេសលើពិភពលោក	១៥១
៨	វីរភាពប្រជាជន អាជ្ញាធរ មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ	១៥២
៩	ទទួលខុសត្រូវពីលើដល់ក្រោម សកម្មភាពព្រមៗគ្នា ទប់ស្កាត់បានមហន្តរាយ	១៥២
១០	ការចុះមកផ្ទាល់ធ្វើឱ្យប្រជាពលរដ្ឋទទួលជំនួយឧបត្ថម្ភក្នុងគ្រាលំបាកបានឆាប់	១៥៣
១១	ស្រឡាញ់គ្នាក្នុងគ្រាក្រ ស្គាល់មិត្តល្អក្នុងគ្រាលំបាក	១៥៣
១២	ប្រតិបត្តិការជួយសង្គ្រោះផ្អែកតាមគោលការណ៍ធំពីរ	១៥៤
១៣	ជម្លៀសប្រជាជនចេញពីតំបន់រងគ្រោះដោយទឹកជំនន់ជាបទបញ្ជាអាទិភាព	១៥៤
១៤	អាទិភាពដំបូង គឺសិទ្ធិរស់រានមានជីវិតរបស់ប្រជាជន	១៥៤
១៥	កុំឱ្យខ្វះស្បៀងសម្រាប់ប្រជាពលរដ្ឋរងគ្រោះ	១៥៥
១៦	មិនឱ្យប្រជាជនស្លាប់ដោយការលង់ទឹក និង/ឬដាច់បាយដោយមិនបានដឹង	១៥៥
១៧	តែងបានត្រៀមបម្រុងថវិកាសំរាប់សង្គ្រោះសភាពការណ៍គ្រោះមហន្តរាយ	១៥៦
១៨	មានស្តុកបម្រុង អាចប្រើបានទាន់ពេលរបស់រដ្ឋាភិបាល ជាការគិតគូរត្រូវ	១៥៦
១៩	សង្គ្រោះពីគ្រោះទឹកជនន់ ជាបញ្ហាជាតិ មិនមែនជាបញ្ហាបក្សនយោបាយ	១៥៧

១. មិនចោលមុខងារប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ

សួរសុខទុក្ខប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារទឹកជំនន់
នៅខេត្តបន្ទាយមានជ័យ (ទីតាំងទី ១), ២១ តុលា ២០២០

... គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គឺនាយករដ្ឋមន្ត្រីធ្វើជាប្រធាន ... ប្រទេសយើងមានយន្តការប្រតិកម្មរហ័ស ព្រោះនាយករដ្ឋមន្ត្រីមានសិទ្ធិបញ្ជាលើកម្លាំងទាំងអស់។ **ខ្ញុំសុខចិត្តចោលគណៈកម្មាធិការនេះគណកម្មាធិការនោះ ប៉ុន្តែគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ខ្ញុំមិនចោលទេ។ ត្រូវគ្រប់គ្រង។ ដូចជាក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងជនបទ កាលមុននេះខ្ញុំធ្វើជាប្រធាន ឥឡូវប្រគល់ឱ្យឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី។ ប៉ុន្តែ ខ្ញុំមិនចោលគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយទេ។ គ្រប់គ្រងក្នុងដៃ ហើយរកអនុប្រធានទី១ មួយនាក់ ជាអ្នកប្រតិបត្តិ ហើយ(ខ្ញុំ)ចង្អុលទិស ...។**

២. ហ៊ុន សែន គ្មានទម្លាប់រត់ចោលប្រជាជនពេលមានទុក្ខលំបាក

សួរសុខទុក្ខប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារទឹកជំនន់
នៅខេត្តបន្ទាយមានជ័យ (ទីតាំងទី ១), ២១ តុលា ២០២០

... ខ្ញុំមិនមានអ្វីសង(គុណដែលបានបោះឆ្នោតឱ្យ)ទេ ខ្ញុំមានតែខិតខំការពារនូវសន្តិភាពឱ្យខាងតែបាន ដើម្បីជានានូវការរស់រានរបស់ប្រជាជន កុំឱ្យស្ថិតក្នុងភ្នក់ភ្លើងសង្គ្រាមដូចប្រទេសខ្លះ ហើយនៅពេលដែលប្រជាជនជួបការលំបាក ក៏មិនមែនជាទម្លាប់ ហ៊ុន សែន ដែលរត់ចោលប្រជាជននោះទេ។ ប្រជាជនក៏មិនបានរត់មករក ហ៊ុន សែន ដែរ គឺ ហ៊ុន សែន រត់មករកវិញ។ ថ្ងៃនេះ អាវនេះ ខ្ញុំពាក់ ២៥ ឆ្នាំហើយ ... បើឃើញ ហ៊ុន សែន ពាក់អាវហ្នឹង បានសេចក្តីថា ហ៊ុន សែន ទៅជួបជាមួយប្រជាពលរដ្ឋ ជាមួយប្រជាកសិករនៅតាមទីជនបទហើយ ...

៣. ការសង្គ្រោះ/គ្រប់គ្រងគ្រោះមហន្តរាយឆ្លងព្រំដែនជាគំនិតផ្តួចផ្តើមរបស់ ហ៊ុន សែន

ប្រគល់សញ្ញាបត្រដល់និស្សិតនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល,
១៦ ធ្នូ ២០១៩

... សមយុទ្ធរវាងកម្ពុជានិងវៀតណាមកងទ័ពសង្គ្រោះមហន្តរាយ នឹងត្រូវធ្វើនៅប៉ុន្មានថ្ងៃខាងមុខនេះ ... **ហេតុអីបានជាត្រូវមានសមយុទ្ធកងទ័ពដើម្បីសង្គ្រោះមហន្តរាយឆ្លងកាត់ព្រំដែន? នេះជាគំនិតផ្តួចផ្តើមរបស់ខ្ញុំ ក្នុងហានៈជានាយករដ្ឋមន្ត្រីរបស់ព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំបានស្នើធ្វើរឿងនេះជាមួយវៀតណាម/ថៃ និងឡាវ ... ត្បិតខ្ញុំបានជួបបញ្ហាច្រើនដងណាស់ហើយ**។ ករណីឆ្នាំ២០១១ នៅឯរតនៈគិរី។ ពេលនោះ ទឹកជំនន់វាយលុកនៅតំបន់ព្រំដែន (គឺនៅ)ទន្លេសេសាន។ ខ្ញុំត្រូវទូរស័ព្ទទៅដល់ហាណូយ ដើម្បីសុំអន្តរាគមន៍របស់កងទ័ពវៀតណាម ... បើនៅតាមព្រំដែនកម្ពុជា-ថៃ ឧស្សាហ៍មានភ្លើងឆេះព្រៃឆ្លងគ្នាទៅវិញទៅមក ...។

៤. សមយុទ្ធប្រឆាំងភេរវកម្ម សមយុទ្ធសង្គ្រោះគ្រោះមហន្តរាយ ជាសមយុទ្ធដែលកម្ពុជាចង់ធ្វើ

សំណួរ/ចម្លើយសន្និសីទសារព័ត៌មានអំពីបច្ចុប្បន្នភាពនៃជំងឺ Covid-19,
០៧ មេសា ២០២០

... ខ្ញុំស្វាគមន៍ និងត្រៀមធ្វើសមយុទ្ធជាមួយគ្រប់ប្រទេស ... ប៉ុន្តែចេញលុយខ្លួនឯង។ សមយុទ្ធត្រូវកំណត់ប្រធានបទអី? ... សមយុទ្ធប្រឆាំងភេរវកម្ម សមយុទ្ធសង្គ្រោះគ្រោះមហន្តរាយ ជាសមយុទ្ធដែលកម្ពុជាចង់ធ្វើ មិនមែនសមយុទ្ធសំរាប់ការវាយលុក វាយទម្លាយកន្លែងនេះឬទម្លាយកន្លែងនោះទេ។ ការប្រយុទ្ធប្រឆាំងភេរវកម្មនិងគ្រប់គ្រងគ្រោះមហន្តរាយ មានដូចជាសមយុទ្ធរុករកការបាត់យន្តហោះ ឬក៏លិចនាវា ឬក៏សមយុទ្ធដែលគ្រប់គ្រងលើគ្រោះមហន្តរាយ។ ឥឡូវបើមកធ្វើសមយុទ្ធសង្គ្រោះ COVID-19 ... ធ្វើតេស្តឱ្យច្បាស់មក។ រួចដាក់នៅដាច់ដោយឡែក។ អញ្ចើញមកតែកុំយកលេសថាកម្ពុជាទាត់ចោលជំនួយយោធារបស់អាមេរិក ឬក៏ឈប់សហប្រតិបត្តិការសមយុទ្ធ ... បើមិនមកធ្វើ សូមតែកុំបន្ទោសកម្ពុជាតែប៉ុណ្ណឹងទេ ...។

៥. បំពាក់រថយន្តកងទ័ព ដើម្បីប្រើជាមធ្យោបាយសង្គ្រោះប្រជាពលរដ្ឋ

សួរសុខទុក្ខប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារទឹកជំនន់
នៅខេត្តបន្ទាយមានជ័យ (ទីតាំងទី ១), ២១ តុលា ២០២០

... រថយន្ត ២៩០គ្រឿង បានក្លាយទៅជាប្រធានបទនៃការវាយប្រហារក្នុងរយៈពេលកន្លងទៅ តែឡើយរថយន្តទាំងនោះកំពុងតែពន្យល់ទៅអ្នកដែលមិនយល់។ មុននេះថា ទិញរថយន្តយកមកធ្វើអី? ដើម្បីដឹកទ័ពសម្លាប់ប្រជាជនឬម៉េច? ប៉ុន្តែ ទីចុងបំផុត អ្វីៗ ដែលជាមធ្យោបាយបំពាក់ឱ្យកងទ័ពក្លាយជាមធ្យោបាយសង្គ្រោះប្រជាពលរដ្ឋនោះឯង។ នេះបញ្ជាក់ថា យើងយកទង្វើជាក់ស្តែងឆ្លើយតបទៅនឹងការចោទប្រកាន់ថាទិញរថយន្តដើម្បីដឹកកងទ័ពទៅបង្ក្រាបប្រជាពលរដ្ឋ។ ផ្ទុយទៅវិញ ប្រជាពលរដ្ឋទទួលបានការសង្គ្រោះពីកងកម្លាំងប្រដាប់អាវុធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ...។

៦. មិនអាចត្រួតត្រាគ្រោះធម្មជាតិបាន តែអាចសង្គ្រោះជីវិតពីស្លាប់បាន

សួរសុខទុក្ខប្រជាពលរដ្ឋរងផលប៉ះពាល់ពីទឹកជំនន់
ទីតាំងទី២ ក្រុងប៉ោយប៉ែត, ២២ តុលា ២០២០

... យើងពិបាកត្រួតត្រាលើអ្វីដែលគេហៅថាគ្រោះធម្មជាតិ ជាការញ្ជួយដី ជាខ្យល់ព្យុះ ជាភ្លៀងឬអត់ភ្លៀង សុទ្ធតែមិនអាចត្រួតត្រាបាន។ មិនថាតែប្រទេសយើងទេដែលមិនអាចត្រួតត្រាបានទេ សូម្បីមហាអំណាចធំៗ ប្រទេសដែលមានវិទ្យាស្ថានជឿនលឿន ក៏មិនអាចត្រួតត្រាគ្រោះមហន្តរាយធម្មជាតិនោះបានដែរ។ ប៉ុន្តែ អ្វីដែលយើងត្រួតត្រាបានគឺការចេញសង្គ្រោះប្រជាពលរដ្ឋឱ្យចេញផុតពីសេចក្តីស្លាប់។ បើគ្មានអន្តរាគមន៍ទាន់ពេលដោយរាជរដ្ឋាភិបាលដោយរដ្ឋបាលមូលដ្ឋាននិងកម្លាំងប្រដាប់អាវុធទេនោះ ច្បាស់ណាស់ថាប្រជាពលរដ្ឋនឹងរងគ្រោះធ្ងន់ធ្ងរជាងនេះ ...។

៧. គ្រោះធម្មជាតិមាននៅគ្រប់ប្រទេសលើពិភពលោក

សួរសុខទុក្ខប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារទឹកជំនន់
នៅខេត្តបន្ទាយមានជ័យ (ទីតាំងទី ២), ២១ តុលា ២០២០

... គ្រោះធម្មជាតិមិនមែនមានតែនៅកម្ពុជាទេ។ វាមាននៅគ្រប់ប្រទេសលើពិភពលោក។ ការយកបញ្ហាជាក់លើកម្ពុជា ដោយអ្នកនេះឬដោយអ្នកនោះ គ្រាន់តែការិះគន់បន្តុះបង្អាប់តែប៉ុណ្ណោះ។ ខ្ញុំសូមក្រុមប្រតិកម្មរហ័ស រៀបចំឯកសារ

ទាក់ទងនឹងជំនន់នៅតាមទីក្រុងប្រទេសនានា ចាក់ផ្សាយធ្វើការប្រៀបធៀបព្រោះពីកាលពីជំនាន់បាក់អាគារនៅក្រុងព្រះសីហនុ បន្ទាប់ទៅបាក់អាគារនៅខេត្តកែប មានការវាយប្រហារធ្ងន់ធ្ងរ។ ដល់តែទូរទស្សន៍ចាក់ផ្សាយករណីបាក់អាគារនៅអាមេរិក បង់ក្លាដែស ឥណ្ឌា ប្រទេសនេះ/នោះ (ការវាយប្រហារក៏)អន់ដែរ ...។

៨. វីរភាពប្រជាជន អាជ្ញាធរ មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ

ស្រុកអូរជ្រៅ(ទីតាំងទី១) បន្ទាយមានជ័យ សួរសុខទុក្ខប្រជាពលរដ្ឋ
រងផលប៉ះពាល់ដោយសារទឹកជំនន់, ២៤ តុលា ២០២០

...យើងបានឃើញវីរភាពរបស់អាជ្ញាធរមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលបានធ្វើសកម្មភាពព្រមៗគ្នាសង្គ្រោះប្រជាជនចេញពីតំបន់រងគ្រោះ និងចូលរួមឧបត្ថម្ភដល់ប្រជាជនដែលជួបការលំបាក។ បន្ទាយមានជ័យគឺជាខេត្តដែលរងគ្រោះធ្ងន់ធ្ងរជាងគេ តម្រូវឱ្យមានការអន្តរាគមន៍ពីថ្នាក់ជាតិ ក្នុងនោះនាយករដ្ឋមន្ត្រីចុះផ្ទាល់ ហើយបន្ទាប់ពីចាកចេញទៅ ក៏តំណាងរបស់ខ្ញុំបន្តធ្វើការងារនេះតទៅទៀត ... ខ្ញុំសូមថ្លែងកោតសរសើរចំពោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងផ្នែកពាក់ព័ន្ធដែលបានធ្វើសកម្មភាពព្រមគ្នាជាមួយប្រជាពលរដ្ឋ ហើយអរគុណចំពោះប្រជាពលរដ្ឋដែលបានរួមសហការ ផ្តល់លទ្ធភាពឱ្យអាជ្ញាធរធ្វើការសង្គ្រោះ ...។

៩. ការទទួលខុសត្រូវពីលើដល់ក្រោម ធ្វើសកម្មភាពព្រមៗគ្នា ទប់ស្កាត់បានមហន្តរាយ

ចុះសួរសុខទុក្ខប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារទឹកជំនន់
ទីតាំងទី១ ស្រុកថ្មពួក, ២២ តុលា ២០២០

បើគ្មានការសហការចូលរួមពីប្រជាពលរដ្ឋ ពីសំណាក់មេភូមិ មេឃុំ ស្រុក ខេត្ត ប្រហែលជា Covid-19 អាចឆ្លងចូលក្នុងសហគមន៍បាត់ទៅហើយ ព្រោះនៅតំបន់ព្រំដែនរវាងយើងនិងថៃ ក្នុងខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ ប៉ៃលិន បាត់ដំបង មានពលករយើងមកពីថៃប្រមាណជាង ១២ម៉ឺននាក់។ ប៉ុន្តែ (ពួកគាត់) ត្រូវបានទទួល**ពិនិត្យដោយអាជ្ញាធរមូលដ្ឋាន នៅតាមបណ្តោយខ្សែព្រំដែនកម្ពុជាថៃ កន្លែងខ្លះក៏ធ្វើការដោះស្រាយស្បៀង ស្នាក់នៅ និងធ្វើចត្តាឡីស័ក ដើម្បីចៀសវាងការយកជំងឺចូលមក ... ទាំងនេះ បង្ហាញឱ្យឃើញសមត្ថភាពនិងការទទួលខុសត្រូវតាំងពីថ្នាក់លើដល់ថ្នាក់ក្រោម ធ្វើសកម្មភាពព្រមគ្នា ទប់ស្កាត់មហន្តរាយ ...។**

១០. ការចុះមកផ្ទាល់ធ្វើឱ្យប្រជាពលរដ្ឋទទួលជំនួយឧបត្ថម្ភក្នុងគ្រាលំបាកបានឆាប់

សួរសុខទុក្ខប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារទឹកជំនន់
នៅខេត្តបន្ទាយមានជ័យ (ទីតាំងទី ១), ២១ តុលា ២០២០

... វិធីមួយដែលធ្វើ(ឱ្យប្រជាពលរដ្ឋដែលជួបគ្រោះមហន្តរាយទទួលជំនួយ)បានឆាប់រហ័ស គឺខ្លួនខ្ញុំចុះមកផ្ទាល់តែម្តង។ ការចុះផ្ទាល់នេះធ្វើឱ្យប្រជាពលរដ្ឋឆាប់បានទទួលជំនួយឧបត្ថម្ភក្នុងគ្រាដ៏លំបាក។ បើមិនដូច្នេះ យើងនៅតែបន្ត(ក្នុងល្បឿន)មួយថ្ងៃធ្វើបាន ១៣ន់ទៅ ២៣ន់(គ្រួសារ)។ ដែលខ្ញុំមកបានពីរថ្ងៃនេះ យើងធ្វើបាន ២ម៉ឺនគ្រួសារតែម្តង ... ខ្ញុំចង់នៅទីនេះបន្តែមក៏ប៉ុន្តែនៅថ្ងៃ ២៣(តុលា)នេះ មានប្រជុំគណៈរដ្ឋមន្ត្រីដើម្បីឆ្លងច្បាប់សំរាប់ការគ្រប់គ្រងថវិកាជាតិឆ្នាំ២០២១ និងគម្រោងមួយចំនួនផ្សេងទៀត ទាក់ទងនឹងការអភិវឌ្ឍប្រទេស ... ទោះបីថាខ្ញុំមកយឺត ក៏ប៉ុន្តែប្រសើរជាងមិនមក ... អ្វីដែលយើងត្រូវធ្វើជាបឋមនិងជាអាទិភាពនោះគឺការជម្លៀសប្រជាជនចេញពីតំបន់រងគ្រោះ ...។

១១. ស្រឡាញ់គ្នាក្នុងគ្រាក្រ ស្គាល់មិត្តល្អក្នុងគ្រាលំបាក

សួរសុខទុក្ខប្រជាពលរដ្ឋរងផលប៉ះពាល់ពីទឹកជំនន់នៅ
នៅទីតាំងទី២ ស្រុកម៉ាឡៃ, បន្ទាយមានជ័យ, ២៤ តុលា ២០២០

... សូមចូលរួមចែករំលែកការលំបាកទាំងឡាយដែលបងប្អូនបានជួបប្រទះក្នុងរយៈពេលកន្លងទៅ តាមរយៈសកម្មភាពរបស់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ជួយបងប្អូនឱ្យរួចផុតពីគ្រោះទឹកជំនន់នេះ។ ថ្ងៃនេះយើងមានឱកាសជួបជុំគ្នាបង្ហាញពីសាមគ្គីភាពក្នុងក្របខណ្ឌទូទាំងប្រទេស តាមរយៈការផ្តល់ជំនួយនានារបស់សប្បុរសជន។ **សប្បុរសជនខ្លះ យកជំនួយមកចែក(ផ្ទាល់)នៅទីនេះ ខ្លះចែកនៅកន្លែងផ្សេងៗ និងសប្បុរសជនខ្លះទៀត ក៏បានផ្តល់វិភាគទានតាមរយៈរាជរដ្ឋាភិបាល។ នៅក្នុងគ្រាក្រ ការជួយគ្នាសំខាន់ណាស់ ដែលពាក្យចាស់លោកបាននិយាយថា «ស្រឡាញ់គ្នាក្នុងគ្រាក្រ ស្គាល់មិត្តល្អក្នុង**

គ្រាលំបាក»។ នេះជាពាក្យស្លោកដែលយើងបានធ្វើជាប្រចាំស្របទៅតាមទំនៀមទម្លាប់ និងពាក្យស្លោករបស់ជូនតាយើងបន្សល់ទុក ...៕

១២. ប្រតិបត្តិការជួយសង្គ្រោះផ្អែកតាមគោលការណ៍ធំពីរ

លទ្ធផលនៃប្រតិបត្តិការរុករកនិងសង្គ្រោះជនរងគ្រោះ
ពីគំនរអគារ ៧ជាន់នៅខេត្តកែប, ០៥ មករា ២០២០

... សូមជម្រាបពីគោលការណ៍ ឬបទបញ្ជាសម្រាប់ការសង្គ្រោះនៅទីនេះ។ **ទី១ ត្រូវឱ្យអាទិភាពខ្ពស់លើការសង្គ្រោះជីវិតមនុស្ស គឺមិនអាចធ្វើដោយទទឹងទិស ឬដោយខ្វះការប្រុងប្រយ័ត្នទេ ...** នៅពេលដែលយើងរុករក បើឃើញមានសញ្ញាណាមួយមិនប្រក្រតី ហើយដែលសង្ស័យថាអាចមានមនុស្សយើងត្រូវតែបញ្ឈប់គ្រឿងចក្រ ហើយមធ្យោបាយផ្សេងៗ តាមលទ្ធភាពដែលអាចធ្វើទៅបាន ... **ទី២ គឺគោរពដល់សាកសព។ បើទោះបីជាពួកគាត់បានស្លាប់ទៅហើយ ក៏យើងត្រូវតែជានាថាសាកសពទាំងនោះមិនត្រូវបានពុះជ្រៀក**ដោយសារគ្រឿងចក្រទេ ...៕

១៣. ជម្លៀសប្រជាជនចេញពីតំបន់រងគ្រោះដោយទឹកជំនន់ជាបទបញ្ជាអាទិភាព

អញ្ជើញពិនិត្យស្ថានការណ៍ជំនន់ទឹកភ្លៀង, ព្រែកជ្រៃ, ១៥ តុលា ២០២០

... នេះហើយដែលហៅថាគ្រោះមហន្តរាយធម្មជាតិទឹកជំនន់។ ដោយសារតែទឹកជំនន់នេះហើយបានជាមានតម្រូវការជម្លៀសប្រជាជនចេញ។ នេះជាអាទិភាពខ្ពស់បំផុតនៃបទបញ្ជារបស់ខ្ញុំព្រះករុណាខ្ញុំ ក្នុងឋានៈជាប្រមុខរាជរដ្ឋាភិបាល ... ដំណើរការជម្លៀសមិនទាន់ចប់ទេសម្រាប់រាជធានីភ្នំពេញ និងខេត្តកណ្តាល ដោយសារតែស្ថានភាពទឹកធ្លាក់ពីខាងលើនៅមិនទាន់ធូរស្រាលនៅឡើយ។ ពិតមែនរបាយការណ៍ពីខេត្តកំពង់ស្ពឺប្រាប់មកថា ក្នុងករណីពុំមានភ្លៀងធ្លាក់បន្ត ទឹកអាចនឹងត្រឡប់មកកំរិតធម្មតាក៏ដោយ ក៏វាមិនធម្មតាសម្រាប់អ្នករាជធានីភ្នំពេញ និងអ្នកខេត្តកណ្តាលដែលនៅភាគខាងក្រោមទេ ...៕

១៤. អាទិភាពដំបូង គឺសិទ្ធិរស់នានមានជីវិតរបស់ប្រជាជន

អញ្ជើញពិនិត្យស្ថានការណ៍ជំនន់ទឹកភ្លៀង, ព្រែកជ្រៃ, ១៥ តុលា ២០២០

... យើងបានត្រៀមសំភារៈការពារកូវីដ-១៩ នៅក្រសួងសុខាភិបាលចំនួន ៥០០០ឃីត (ដៃល)នៅក្នុងឃីតនោះ មានទាំងមុង មានទាំងភួយ មានទាំងក្រមា មានទាំងកន្ទេល ខ្នើយ។ យើងយកឃីតនោះ(មកជា)បណ្តោះអាសន្នសិន។ (ប្រជាជនរងគ្រោះ)ចេញមកអត់បានយកមុងភួយមកតាមខ្លួនទេ យកបានតែខ្លួន ... នៅពេលនេះ **ធ្វើម៉េចឱ្យបានរស់សិន។ បើគ្មានជីវិតទេមិនអាចនិយាយពីអ្វីទាំងអស់រាប់ទាំងមិនអាចទៅសរសេរកាសែត មិនអាចទៅរកលទ្ធិប្រជាធិបតេយ្យ ឬសិទ្ធិមនុស្សទេ ... តាំងពីដើមដល់ចប់ នយោបាយរបស់ ហ៊ុន សែន គឺធ្វើយ៉ាងម៉េចឱ្យប្រជាជនរស់សិន ...** អ្នកណានិយាយពីសិទ្ធិមនុស្ស និយាយពីប្រជាធិបតេយ្យ ក៏សូមអញ្ជើញ ក៏ប៉ុន្តែសម្រាប់ខ្ញុំ អាទិភាពដំបូងគឺឱ្យប្រជាជនរស់សិន ...៕

១៥. កុំឱ្យខ្វះស្បៀងសម្រាប់ប្រជាពលរដ្ឋរងគ្រោះ

សួរសុខទុក្ខប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារទឹកជំនន់
នៅខេត្តបន្ទាយមានជ័យ(ទីតាំងទី១), ២១ តុលា ២០២០

... រឿងស្បៀងមួយ កុំឱ្យប្រជាពលរដ្ឋខ្វះ ... ពិសេសចៅហ្វាយខេត្ត ដែលកាន់កាប់គ្រប់គ្រង ត្បិតមានលុយក្នុងដៃហើយ។ បើសិនជាខ្វះ សូមប្រាប់ ធ្វើម៉េចរឿងស្បៀងមួយកុំឱ្យខ្វះ ... ថ្ងៃមុន ស៊ុន ចាន់ថុល ជាមួយនឹង អ៊ី ឈាន ថាបានចែកជំនួយហ្នឹងហើយ។ អញ្ចឹងលុយហ្នឹងថាទុកជួសជុលផ្លូវ។ នៅឯប៉ៃលិននោះភ្លៀងតែរហូត លិចតែរហូត។ អញ្ចឹងគាត់អត់រកអីបាន។ បើគាត់ខ្វះស្បៀងចែកស្បៀងថែមទៀត។ យក ១០ម៉ឺនដុល្លារហ្នឹងទៅចែកស្បៀងទៅ ... បើប្រជាជនត្រូវការ។ ជាកពិសោធន៍រឿងមួយបាន ងួន រតនៈ ទទួលស្គាល់។ ថ្ងៃនោះ យើងជួបគ្នាតាមទូរស័ព្ទ បាត់ដំបង(ទទួលទូកសង្គ្រោះ) ២០គ្រឿង ពោធិ៍សាត់ ២០គ្រឿងទៅដើម្បីពេលមានការគឺទូកហ្នឹងអាចចល័តបាន ...៕

១៦. មិនឱ្យប្រជាជនស្លាប់ដោយការលង់ទឹក និង/ឬដាច់បាយដោយមិនបានដឹង

ពិនិត្យស្ថានការណ៍ និងសួរសុខទុក្ខពលរដ្ឋរងគ្រោះដោយជំនន់ទឹកភ្លៀង,
ខណ្ឌដង្កោ, រាជធានីភ្នំពេញ, ១៥ តុលា ២០២០

.. ដែលខ្ញុំមកទីនេះគឺដើម្បីបានឃើញជាក់ស្តែង។ ខ្ញុំនឹងទៅកាន់កន្លែងមួយទៀតនៅស្ពានព្រែកជ្រៃជួបប្រជាពលរដ្ឋនៅទីកន្លែងនោះ ... នេះជាពេលវេលាដ៏លំបាកសម្រាប់យើង។ ក្រៅពីប្រជាពលរដ្ឋ នាយករដ្ឋមន្ត្រីលំបាកក្នុងការគិត **ព្រោះក្នុងគ្រួសារមួយក៏វាលំបាកទៅហើយ ទំរាំបើខ្ញុំទទួលខុសត្រូវចំពោះប្រជាជន ១៦លាននាក់ ហើយកំពុងតែខិតខំធ្វើយ៉ាងម៉េចកុំឱ្យប្រជាជនស្លាប់ដោយការលង់ទឹក កុំឱ្យប្រជាជនណាម្នាក់ជាច់បាយដោយមិនបានដឹង ហើយមិនបានដោះស្រាយ។** ត្រូវប្រើកម្លាំងទាំងអស់ជម្លៀសប្រជាជនចេញពីតំបន់រងគ្រោះ មកកាន់ទីទួលសុវត្ថិភាព ហើយត្រូវផ្តល់នូវការថែទាំ បាយទឹក ថ្នាំពេទ្យ ...។

១៧. តែងបានត្រៀមបម្រុងថវិកាសំរាប់សង្គ្រោះសភាពការណ៍គ្រោះមហន្តរាយ

សំណេះសំណាលជាមួយកម្មករ និយោជិត ស្រុកកៀនស្វាយ ខេត្តកណ្តាល,
២៣ សីហា ២០១៨

... យើងកំពុងជួបគ្រោះជំនន់ទឹកភ្លៀងនៅខេត្តពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ កំពង់ស្ពឺ ... និងមួយភាគរបស់ខេត្តកណ្តាល។ ឯខេត្តប៉ៃលិនដោយជំនន់មេគង្គរួមមានស្ទឹងត្រែង ក្រចេះ កំពង់ចាម និងខេត្តកណ្តាល ... ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រៀមបញ្ចេញគ្រាប់ពូជដែលប្រជាជនត្រូវការ ... ក្រសួងអភិវឌ្ឍន៍ជនបទ សាធារណការ ពិនិត្យមើលផ្លូវ/ថ្នល់ ដែលមានការខូចខាតក្នុងឆ្នាំនេះ។ **យើងបានត្រៀមបម្រុងថវិកាសំរាប់សង្គ្រោះសភាពការណ៍។ ដោយហេតុនេះហើយបានជា ជានិច្ចកាល យើងមិនដែលហ៊ានចាយថវិកាដែលបម្រុងទុកសម្រាប់គ្រោះមហន្តរាយទេ ... ។**

១៨. មានស្តុកបម្រុង អាចប្រើបានទាន់ពេលរបស់រដ្ឋាភិបាល ជាការគិតគូរត្រូវ

ស្រុកអូរជ្រៅ(ទីតាំងទី១) បន្ទាយមានជ័យ សួរសុខទុក្ខប្រជាពលរដ្ឋ
រងផលប៉ះពាល់ដោយសារទឹកជំនន់, ២៤ តុលា ២០២០

... គ្រាន់តែបន្ទាយមានជ័យ មានអ្នករងគ្រោះច្រើនរហូតទៅដល់ជាង ៤ម៉ឺនគ្រួសារ។ នៅខេត្តដទៃទៀត ក៏មាន(គ្រួសាររងគ្រោះ)ដូចគ្នាដែរ។ ជំនួយដែលបានពីសប្បុរសជន មកដល់ពេលនេះកើនដល់ជាង ៨លានដុល្លារ ជាមួយស្តុកបម្រុងរបស់រាជរដ្ឋាភិបាលត្រូវបានបញ្ជូនចេញ និងទិញបញ្ចូលស្តុកវិញជាបន្តបន្ទាប់។ **រាជរដ្ឋាភិបាលត្រូវមានស្តុកបម្រុង ដែលជាធម្មតាយើងតែងមាន។ ពីដើមឆ្នាំរហូតមកដល់ពេលនេះ មានស្តុកបម្រុងជាអង្ករ មី ទឹកសុទ្ធ ទឹកត្រី ទឹកស៊ីអ៊ីវ អំបិល ជាដើម។ នេះបានបង្ហាញថា ការគិតគូររបស់យើងគឺត្រូវ។ ពេលមានការគឺបញ្ចេញបានភ្លាម ដើម្បីធានាថាប្រជាពលរដ្ឋបានទទួល និងទប់ទល់កុំឱ្យមានប្រជាជនបាត់បង់ជីវិត ឬខូចខាត។ (ការដឹកនាំត្រូវតែកុំឱ្យ)រឿងដែលយើងអាចធ្វើបាន បែរជាមិនអាចធ្វើទៅរួច។ រាជរដ្ឋាភិបាលត្រូវគិតឱ្យល្អិតល្អន់ ...។**

១៩. សង្គ្រោះពីគ្រោះធម្មជាតិទឹកជនន់ ជាបញ្ហាជាតិ មិនមែនជាបញ្ហាបក្សនយោបាយ

សួរសុខទុក្ខប្រជាពលរដ្ឋរងផលប៉ះពាល់ពីទឹកជំនន់ ទីតាំងទី២
ក្រុងប៉ោយប៉ែត, ២២ តុលា ២០២០

... យើងអត់មានការរើសអើងទេ។ (អ្នកណាមកពី)បក្សនយោបាយណា ខ្ញុំអត់ដឹងទេ។ រឿងបោះឆ្នោតឱ្យអ្នកណារឿងអីផ្សេង តែរឿងប្រជាជនត្រូវការរស់ គឺរឿងផ្សឹង ដែលខ្ញុំត្រូវធ្វើក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ អញ្ចឹងទេ អាជ្ញាធរត្រូវពិនិត្យមើលថា កន្លែងដែលអ្នកមិនទាន់បានទទួល ត្រូវបានទទួល ដើម្បីកុំឱ្យមានការរើសអើងខាងនយោបាយណាមួយកើតឡើង ព្រោះនេះជាបញ្ហាជាតិ មិនមែនជាបញ្ហាបក្សនយោបាយទេ។ យើងបន្តការខិតខំរួមគ្នា ដើម្បីឈានឆ្ពោះទៅមុខ ម្ខាងប្រយុទ្ធជាមួយ Covid-19 ម្ខាងទៀតខិតខំប្រយុទ្ធជាមួយនឹងគ្រោះទឹកជំនន់ ស្តារឡើងវិញជីវភាព ...។

៨. ទេសចរណ៍

១	ទេសចរណ៍ជាវិស័យអាទិភាពមួយ គឺជាមាសបៃតង	១៦១
២	ឆ្នេរសមុទ្រស្អាត ប្រាង្គប្រាសាទ ទាក់ទាញភ្ញៀវទេសចរពី ០មកដល់ ៥លាននាក់	១៦១
៣	តភ្ជាប់ផ្លូវគោក ផ្លូវដែក និងផ្លូវអាកាសត្រង់ទៅមាត់សមុទ្របម្រើវិស័យទេសចរណ៍	១៦១
៤	កសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់បម្រើឲ្យវិស័យទេសចរណ៍	១៦២
៥	រក្សាសន្តិភាព ថែទាំបរិស្ថាន និងរមណីយដ្ឋាន ដើម្បីទទួលទេសចរ	១៦២
៦	ធ្វើឲ្យភ្ញៀវទេសចរម្នាក់ទាក់ទាញភ្ញៀវទេសចរមួយនាក់ឬច្រើននាក់ទៀត	១៦៣
៧	គ្មានគ្រឿងញៀនសៅល្អ ស្មាមញ្ញឹមបេតិកភណ្ឌនិងធម្មជាតិទាក់ទាញទេសចរ	១៦៣
៨	ទេសចរណ៍រីកចម្រើន ដោយមានវប្បធម៌និងធម្មជាតិជាគោលដៅ	១៦៤
៩	រក្សាហានៈឆ្នេរស្អាតបំផុត ជាតារាះទិសនិរតី សម្រាប់ខេត្ត៤ ជាប់មាត់សមុទ្រ	១៦៤
១០	ផលិតវត្ថុអនុស្សាវរីយ៍បញ្ជាក់ពីអត្តសញ្ញាណកម្ពុជាលក់ជូនភ្ញៀវទេសចរ	១៦៤
១១	តំបន់អតីតសមរភូមិ៩០% បានក្លាយជាតំបន់ទេសចរមានការទាក់ទាញ	១៦៥
១២	អេក្ទូទេសចរ បន្ថែមលើទេសភាពឆ្នេរ និងប្រាសាទ	១៦៥
១៣	សន្តិភាពមានតម្លៃសំរាប់ជីវិតនិងការអភិវឌ្ឍ ព្រមទាំងទាក់ទាញទេសចរ	១៦៦
១៤	របៀងសមុទ្រ បំរើអោយយុទ្ធសាស្ត្រដឹកជញ្ជូន និងវិស័យទេសចរណ៍	១៦៦
១៥	យកវិស័យទេសចរណ៍ជាទីផ្សារបស់កសិការនិងអ្នកប្រកបរបរចិញ្ចឹមសត្វ	១៦៦
១៦	អេក្ទូទេសចរណ៍ អោយដលច្រើនជាងកាប់ព្រៃធ្វើដំណាំកសិកម្ម	១៦៧
១៧	យកទេសចរណ៍ទាញកសិកម្ម សិប្បកម្មទាញវិស័យពាក់ព័ន្ធទេសចរណ៍ឯទៀត	១៦៧
១៨	ការពារសុវត្ថិភាពអ្នកទេសចរផ្លូវទឹកនិងតាមកោះនានា	១៦៧
១៩	វិនិយោគលើកោះជាតំបន់ទាក់ទាញទេសចរណ៍ តែមិនមែនទីចាក់សំរាម	១៦៨
២០	ការពារនិងរក្សាតំបន់ឆ្នេរឱ្យនៅស្អាត កុំឱ្យត្រូវដកចេញចេញពីក្លិប ឬសមាគម	១៦៨
២១	ការពារផ្ទៃបាតសមុទ្រ ៧ពាន់ហិកតាគ្របដណ្តប់ដោយស្មៅសមុទ្រ ដើម្បីទេសចរ	១៦៨
២២	ចលនាជាតិទីក្រុងស្អាត សុវត្ថិភាព សុខុមាលភាព ភ្ញៀវទេសចរមិនបារម្ភពីជំងឺឆ្លង	១៦៩
២៣	វិថីក្នុងក្រុងស្អាត អាហារឆ្ងាញ់និងមានអនាម័យ នឹងទាក់ទាញទេសចរ	១៦៩
២៤	ប្រើអស់សក្តានុពលកសិកម្មក្នុងស្រុក/ខ្សែក្រវ៉ាត់បៃតង មិនខ្ជះខ្ជាយរូបិយបណ្ណ	១៧០
២៥	គ្មានមីនមានហេដ្ឋារចនាសម្ព័ន្ធ អេក្ទូទេសចរណ៍ គឺសេដ្ឋកិច្ចហុិវិស័យមិនអស្តង្គត	១៧០

២៦	កុំឲ្យកម្ពុជាមានអំពើអោយកម្មតាមតំបន់ទេសចរ និងមានសហគមន៍សុខសាន្ត	១៧១
២៧	ប្រើសក្តានុពលតាមទីក្រុង/ខេត្តនានាអភិវឌ្ឍវិស័យទេសចរណ៍	១៧១
២៨	ពីទេសចរបរទេស ៦,៦លាន នៅឆ្នាំ២០២០ មកជាង ១លាន ដោយសារកូវីដ-១៩	១៧១
២៩	ឆ្នាំ២០២២ អាស៊ានប្រឈមនឹងធ្វើឲ្យទេសចរណ៍រស់ឡើងវិញក្នុងបរិបទកូវីដ-១៩	១៧២
៣០	សូមប្រជាពលរដ្ឋបង្វែរពីទេសចរណ៍ក្រៅប្រទេស មកធ្វើដំណើរកម្សាន្តក្នុងស្រុក	១៧២
៣១	គោលដៅទទួលទេសចរអោយបានពី ១៥ដល់ ២០លាននាក់/ឆ្នាំ	១៧៣
៣២	វ៉ាក់សាំង ២ដូស ធ្វើតេស្តរហ័សអវិជ្ជមានពេលមកដល់ មិនបាច់ចត្តាឡីស័ក	១៧៣
៣៣	កម្ពុជាមិនទាន់មានចំណូលជំនួសការយកថ្លៃទិដ្ឋាការទេសចរនៅឡើយ	១៧៤
៣៤	វិស័យទេសចរណ៍បន្តរងការប៉ះពាល់ពីសង្គ្រាមនិងទណ្ឌកម្មពិភពលោក	១៧៤
៣៥	កត្តា៤ ក្នុងសន្តិភាព ធ្វើឲ្យពលរដ្ឋកម្ពុជាធ្វើទស្សនាចរបាន	១៧៤
៣៦	កម្ពុជាអត់ត្រូវការយោធាបរទេសទេ ត្រូវការទេសចរបរទេសច្រើន	១៧៥
៣៧	ពង្រាយការលូតលាស់វិស័យទេសចរណ៍ទៅប្រជាជននៅជនបទឱ្យកាន់តែច្រើន	១៧៥
៣៨	អនុវត្តយុទ្ធនាការ «ភូមិស្អាត ស្រែល្អ» ជួយទាក់ទាញទេសចរទៅតាមភូមិឃុំ	១៧៦
៣៩	នយោបាយបើកចំហជើងមេឃ ការហោះហើរត្រង់មកខេត្តសៀមរាប	១៧៦

១. ទេសចរណ៍ជាវិស័យអាទិភាពមួយ គឺជាមាសបៃតង

ពិធីបុណ្យសមុទ្រ លើកទី៦ ឆ្នាំ២០១៧, ២៣ ធ្នូ ២០១៧

... ការនេះបង្ហាញឲ្យឃើញពី**វឌ្ឍនភាព និងការរីកលូតលាស់នៃសេដ្ឋកិច្ចជាតិដោយឡែកតែវិស័យទេសចរណ៍ មានចំណែករហូតទៅដល់ជាង១៣% នៃផលិតផលសរុបក្នុងស្រុក។ យើងចាត់ទុកវិស័យទេសចរណ៍ជាអាទិភាពមួយ គឺជាមាសបៃតងសម្រាប់យើង ដើម្បីរួមចំណែកទទួលខុសត្រូវ និងលើកកម្ពស់វិស័យទេសចរណ៍សម្រាប់ប្រទេស**។ ឆ្នាំនេះ តាមការប៉ាន់ស្មានមិនទាន់ចប់ឆ្នាំ ចំនួនទេសចរបរទេសដែលមកកាន់ព្រះរាជាណាចក្រកម្ពុជាមានជាង ៥លាន ៦សែននាក់ ដែលជាចំនួនមួយច្រើន។ ប៉ុន្តែ យើងមិនស្កប់ស្កល់(នឹងចំនួននេះ)ទេ។ យើងមានគោលដៅសម្រេចវិស័យទេសចរណ៍នៅឆ្នាំ២០២០ ខាងមុខឲ្យបានចំនួន ៧លាននាក់ ដែលជាផ្នែកដ៏សំខាន់មួយដើម្បីផ្តល់នូវប្រាក់ចំណូល ផ្តល់នូវមុខរបរ ផ្តល់នូវការងារធ្វើ ព្រមទាំងការនាំចេញនៅហ្នឹងកន្លែង ...។

២. ឆ្នេរសមុទ្រដ៏ស្អាត ប្រាង្គប្រាសាទ ទាក់ទាញភ្ញៀវទេសចរពីសូន្យមកដល់ ៥ លាននាក់

ពិធីបុណ្យសមុទ្រ លើកទី៦ ឆ្នាំ ២០១៧, ២៣ ធ្នូ ២០១៧

... ទោះបីកម្ពុជា ស្ថិតក្នុងស្ថានភាពជាប្រទេសក្រីក្រ ក៏ប៉ុន្តែកម្ពុជាស្ថិតក្នុងស្ថានភាពជាអ្នកធ្វើម្ចាស់លើជោគវាសនាខ្លួនឯង ... **កម្ពុជាត្រូវបានទទួលស្គាល់ថា ស្ថិតក្នុងចំណោមប្រទេសដែលមានឆ្នេរសមុទ្រស្អាតបំផុត។ យើងក៏បានដាក់ចេញនូវពាក្យស្លោកថា តារាះទិសនិរតីដែលរួមមានកំពត កែប ព្រះសីហនុ និងកោះកុង ... ឆ្នេរសមុទ្រដ៏ស្អាតបានបំពេញបន្ថែមទៅឲ្យប្រាង្គប្រាសាទរបស់យើងដែលដូនតា អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយ៉ានី បានបន្សល់ទុក ... ធ្វើឲ្យកម្ពុជា ចាប់ផ្តើមពីសូន្យទេសចរ មកដល់ដំណាក់កាលមានទេសចរជាង ៥ លាននាក់ ពីសណ្ឋាគារតូចតាច ... មកមានរាប់រយរាប់ពាន់សណ្ឋាគារ ...**។

៣. ឥស្សាប់ផ្លូវគោក ផ្លូវដែក និងផ្លូវអាកាសត្រង់ទៅមាត់សមុទ្របម្រើវិស័យទេសចរណ៍

ពិធីបុណ្យសមុទ្រ លើកទី ៦ ឆ្នាំ ២០១៧, ២៣ ធ្នូ ២០១៧

... បន្តកសាងហេដ្ឋារចនាសម្ព័ន្ធបម្រើឲ្យវិស័យទេសចរណ៍ ក្នុងហ្នឹងមាន

អាកាសយានដ្ឋាន មានផ្លូវ មានទឹកស្អាត មានភ្លើង មានសណ្ឋាគារ មានរមណីយដ្ឋាននានា ... ដូចជានៅក្នុងទីក្រុងកែប យើងបានផ្គត់ផ្គង់អគ្គិសនីរួចហើយ ក៏ប៉ុន្តែបញ្ហាទឹកស្អាតនៅជួបការលំបាក។ យើងត្រូវតែខិតខំការបង្កើតឲ្យមានការផលិតទឹកស្អាតដើម្បីចែកទៅខេត្តកំពតនិងកែប ... **ការតភ្ជាប់ក៏ត្រូវបានធ្វើពីតំបន់មួយទៅតំបន់មួយ ទាំងការតភ្ជាប់ខាងផ្លូវគោក តាមផ្លូវជែក និងតាមផ្លូវអាកាស ដូចជាការតភ្ជាប់ផ្លូវហោះហើរត្រង់មកកាន់មាត់សមុទ្រ** គឺខេត្តព្រះសីហនុ និងខេត្តកោះកុងនៅថ្ងៃអនាគត ...។

៤. កសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់បម្រើឲ្យវិស័យទេសចរណ៍

ពិធីបុណ្យសមុទ្រលើកទី៧ ជុំទី២, ១៥ ធ្នូ ២០១៨

... បន្តកសាងហេដ្ឋារចនាសម្ព័ន្ធ ក្នុងនោះ មានអាកាសយានដ្ឋាន ផ្លូវ ទឹក ភ្លើង សណ្ឋាគារ រមណីយដ្ឋានទេសចរណ៍ផ្សេងទៀត ដែលជាតម្រូវការ ... **ទេសចរបច្ចុប្បន្ន មិនមែនទេសចរសម័យបក់ផ្លិតទេ តែជាទេសចរសម័យម៉ាស៊ីនត្រជាក់ ... គេបើក internet ឡើងដឹងថា ប្រទេសយើងមានសណ្ឋាគារផ្កាយ៥ មានមន្ទីរពេទ្យដ៏ល្អបើសិនជាគេមានបញ្ហាសុខភាព។ (ព័ត៌មានទាំងនេះជួយដល់ការ)សម្រេចចិត្ត(របស់គេក្នុងការជ្រើសរើស)មក(ទស្សនា)ប្រទេសយើង។ ដូច្នេះ យើងត្រូវខំកសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដើម្បីបម្រើឲ្យវិស័យទេសចរណ៍** ...។

៥. រក្សាសន្តិភាព ថែទាំបរិស្ថាន និងរមណីយដ្ឋាន ដើម្បីទទួលទេសចរ

ទិវាជាតិទីក្រុងស្អាតលើកទី៥ និងជ័យលាភីរង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍លើកទី២ ... ចលនាប្រឡងប្រណាំងទីក្រុងស្អាតនិងច្រកទ្វារអន្តរជាតិលើកទី១, ២៧ កុម្ភៈ ២០១៧

... ខ្ញុំគួរតែរំឭកថាទេសចរច្បាស់ជាមិនប្រថុយប្រថានមកតំបន់គ្រោះថ្នាក់ តំបន់ដែលមានសង្គ្រាម ដូចដែលយើងធ្លាប់ជួបប្រទះនៅក្នុងអតីតកាល ហើយក៏ធ្លាប់បាននិងកំពុងកើតឡើងនៅតំបន់នានាដូចជាមជ្ឈិមបូព៌ា និងប្រទេសមួយចំនួន។ ដូច្នេះ **ការរក្សាសន្តិភាព ស្ថិរភាពនយោបាយប្រយុទ្ធប្រឆាំងមិនឲ្យមានភេរវកម្មនៅលើទឹកដីប្រទេសកម្ពុជាមានសារៈសំខាន់ខ្លាំង។ ខ្ញុំសង្ឃឹមថា ទាំងអស់គ្នានឹងធ្វើការខិតខំ(កែលំអបរិយាកាសទេសចរណ៍) ដើម្បីការកើនឡើងភ្ញៀវទេសចរ ដែលនឹងមិនមកស្រូបយកធាតុអាកាស ភ្លៀងស្អុយតាមទីក្រុងទីប្រជុំជន ក៏ដូចជារមណីយដ្ឋាននានានោះទេ**។ គេត្រូវការសប្បាយរីករាយ និងម្ហូបអាហារល្អៗ ...។

៦. ធ្វើឲ្យភ្ញៀវទេសចរម្នាក់ទាក់ទាញភ្ញៀវទេសចរមួយនាក់ឬច្រើននាក់ទៀត

ពិធីសម្ពោធសណ្ឋាគារ សុខាសៀមរាប, ២ តុលា ២០១៧

... បើទាញទេសចរបានម្នាក់ ហើយត្រឡប់ទៅវិញទេសចរនេះជួយឃោសនាទាក់ទាញឲ្យអ្នកដទៃ ឲ្យសាច់ញាតិ ឲ្យមិត្តភក្តិមកសាជាថ្មីម្តងទៀត គឺជាវិធីដែលល្អជាងគេ ... ពិតមែនហើយយើង**ត្រូវឃោសនាតាមប្រព័ន្ធនេះប្រព័ន្ធនោះដែរ តែវិធីដែលល្អជាងគេក្នុងការឃោសនា គឺទេសចរមកម្នាក់ត្រឡប់មកវិញ ហើយមកជាមួយនូវក្រុមគ្រួសារ/មិត្តភក្តិ** ... ក្នុងពេលជប់លៀងនៅកិច្ចប្រជុំវេទិកាសេដ្ឋកិច្ចពិភពលោកនៅឯ Davos រដ្ឋមន្ត្រីអាហ្សង់ទីនម្នាក់បានប្រាប់ខ្ញុំថា មុនពេលធ្វើជារដ្ឋមន្ត្រី គាត់បានមកទស្សនកិច្ចជាទេសចរនៅកម្ពុជា ... និងបន្ទាប់ទៅ កូនរបស់និងប្រពន្ធរបស់គាត់ ច្រណែននឹងគាត់ ...។

៧. គ្មានគ្រឿងញៀន សៅល្អ ប្រើស្មាមញញឹម បន្ថែមលើបេតិកភណ្ឌនិងធម្មជាតិទាក់ទាញទេសចរ

ទិវាជាតិទីក្រុងស្អាតលើកទី៥ ចលនាប្រឡងប្រណាំងទីក្រុងស្អាត
និងច្រកទ្វារអន្តរជាតិលើកទី១, ២៧ កុម្ភៈ ២០១៧

... ទើបនឹងធ្វើសន្និបាតក្រសួងមហាផ្ទៃហើយ (មានប្រធានបទ)ទាក់ទិននឹងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ... **ហើយកុំឲ្យទេសចរនិង/ឬប្រទេសនានា យល់ថាគួរកុំមកទស្សនកិច្ចនៅកម្ពុជា ដោយសារសំបូរអ្នកប្រើប្រាស់គ្រឿងញៀន ... បើមក(ហើយ) ត្រឡប់ទៅវិញថា កម្ពុជាមានភាពញើរញ័រនៅនឹងមាត់ច្រកទាំងព្រលានយន្តហោះទាំងផ្លូវគោក ... ថ្ងៃក្រោយទេសចរនឹងមិនមកទេ។ កុំភ្លេចថាយើងប្រកួតប្រជែងជាមួយប្រទេសដទៃទៀត។ មិនមែនមានតែកម្ពុជាមួយទេដែលមានបេតិកភណ្ឌនិងធម្មជាតិល្អនោះ។ ត្រូវចេះប្រើស្មាមញញឹម ភាពទាក់ទាញនៃបដិសណ្ឋារកិច្ច និងសៅបម្រើឲ្យទេសចរ ... មិនមែនជាទេសចរផ្លូវកែទនោះទេ** ...។

៨. ទេសចរណ៍រីកចម្រើន ដោយមានប្បធម៌និងធម្មជាតិជាគោលដៅ

ជ្រើសតាំងសម្តេចតេជោ ជា ឯកអគ្គរដ្ឋទូតសុច្ឆន្ទៈពិភពលោកសំរាប់វិស័យទេសចរណ៍ និងគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាពនិងជ័យលាភី «រាជធានីភ្នំពេញ ជារាជធានីនៃប្បធម៌ និងទេសចរណ៍ពិភពលោក», ៩ ធ្នូ ២០១៧

... ជានាកុំឲ្យទេសចរណ៍បំពានលើវប្បធម៌ជាតិ ... មានបេតិកភណ្ឌពិភពលោកជាប្រាសាទអង្គរ ប្រាសាទព្រះវិហារ និងសម្បូរព្រៃគុក ជាដើម។ យើងត្រូវគោរពលក្ខខណ្ឌដែលអង្គការ UNESCO បានកំណត់ឲ្យ។ ពេលធ្វើពិធីអបអរសាទរដាក់បញ្ចូលសំបូរព្រៃគុក ជាបេតិកភណ្ឌពិភពលោកខ្ញុំបានលើកឡើងថា "កុំគ្រាន់តែធ្វាញ់មួយពេល សម្លាប់មេមាន់។ ត្រូវចិញ្ចឹមមេមាន់យកកូន យកស៊ុតរបស់វា"។ **យើងត្រូវធ្វើកិច្ចការទាំងឡាយ ដើម្បីអភិរក្សនូវកេរ្តិ៍ដំណែលប្រវត្តិសាស្ត្រនេះ ... កុំឲ្យវិស័យទេសចរណ៍ បំពានលើវិស័យវប្បធម៌ ... តែវិស័យទេសចរណ៍រីកចម្រើនដោយយកវិស័យវប្បធម៌និងធម្មជាតិធ្វើជាគោលដៅ** នោះទើបមាននិរន្តរភាព និងចីរភាព មិនត្រឹមតែឆ្នាំ២០៣០ ទេ តែអាចឈានដល់ឆ្នាំ៣០០០ ក៏អាចថាបាន។ យើងត្រូវប្រឹងប្រែងរួមគ្នាដើរបណ្តើរឡើងដំណើរការទៅអនាគតទាំងអស់គ្នា ...។

៩. រក្សាឲ្យបានហានៈឆ្នេរស្អាតបំផុត ជាតារាៈទិសនិរតី សម្រាប់ខេត្ត៨ ជាប់មាត់សមុទ្រ

ពិធីបើកបុណ្យសមុទ្រ លើកទី៦, ២៣ ធ្នូ ២០១៧

... **រក្សាឲ្យបានសមុទ្របៃតង រក្សាឲ្យបានឆ្នេរសមុទ្រដែលស្អាតបំផុតលើពិភពលោក រក្សាឲ្យបានហានៈជាតារាៈនៅទិសនិរតីសម្រាប់ខេត្ត៨ ដែលនៅជាប់មាត់សមុទ្រ**។ ទាំងអស់គ្នាត្រូវខិតខំការពារផលប្រយោជន៍សម្រាប់យើងទាំងអស់គ្នា ដូចដែលខ្ញុំបានថ្លែងនៅថ្ងៃទី១៧ កក្កដា ២០១៧ កន្លងទៅ ពេលអបអរសាទរការដាក់សំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោកថា "សូមកុំសម្លាប់មេមាន់ដើម្បីធ្វាញ់មួយពេល ត្រូវរក្សាមេមាន់ដើម្បីទទួលបានអត្ថប្រយោជន៍តកូនតចៅ"...។

១០. ផលិតវត្ថុអនុស្សាវរីយ៍បញ្ជាក់ពីអត្តសញ្ញាណកម្ពុជាលក់ជូនភ្ញៀវទេសចរ

ពិធីបុណ្យសមុទ្រ លើកទី៦ ឆ្នាំ២០១៧, ២៣ ធ្នូ ២០១៧

... បណ្តាសណ្ឋាគារនានាទូទាំងព្រះរាជាណាចក្រកម្ពុជា សូមយកចិត្តទុកដាក់

ទិញពីប្រជាពលរដ្ឋមកផ្គត់ផ្គង់សម្រាប់សណ្ឋាគារ និងបម្រើឲ្យទេសចរ ដើម្បីរួមចំណែកក្នុងគោលដៅអភិវឌ្ឍទេសចរណ៍ និងកាត់បន្ថយនូវភាពក្រីក្រ។ ជាមួយគ្នានេះយើងក៏ត្រូវបង្ហាត់បង្រៀនប្រជាពលរដ្ឋអំពីប្រភេទនៃសិប្បកម្ម មានលទ្ធភាពផលិតវត្ថុអនុស្សាវរីយ៍ ដើម្បីលក់ឲ្យទេសចរ ... ខ្ញុំបានទទួលការដូច្រើនពីស្តង់នានាដែលមានតម្លៃសម្រាប់ការយល់ដឹងអំពីផលិតផលនៅតាមបណ្តាខេត្តនានា។ សំរាប់ទេសចរបរទេសក៏ដូចគ្នាដែរ។ គេអាចទិញចេញពីកម្ពុជា នូវវត្ថុអនុស្សាវរីយ៍ជាស្នាដៃផលិតរបស់ជនជាតិកម្ពុជា ...។

១១. តំបន់អតីតសមរភូមិ៩០% បានក្លាយជាតំបន់ទេសចរណ៍មានការទាក់ទាញ

សម្ពោធវិមានអនុស្សាវរីយ៍ «នយោបាយឈ្នះឈ្នះ» ..., ២៩ ធ្នូ ២០១៨

... សូមអ្នកទាំងឡាយកុំរំខានប្រជាជន កុំបង្កសង្គ្រាមរាំងជល់តាមរបៀបដែលហៅថារបបប្រជាធិបតេយ្យ ឬសិទ្ធិមនុស្ស ដែលទីចុងបំផុតសូម្បីតែប្រទេសប្រជាធិបតេយ្យក៏ធ្លាប់សាងកំហុសគាំទ្ររដ្ឋប្រហារយោធារបស់ លន់ នល់ ... និងសូមបញ្ជាក់ឡើងវិញថា (បច្ចុប្បន្ននេះ)**ជាង៩០%នៃតំបន់អតីតសមរភូមិកំពុងក្លាយទៅជាតំបន់ទេសចរណ៍ដែលមានការទាក់ទាញ។ សូមអញ្ជើញទៅលេង។ យើងបានប្រែក្លាយតំបន់ព្រំដែនជាតំបន់សន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍហើយ** ...។

១២. អេកូទេសចរ បន្ថែមលើទេសភាពឆ្នេរ និងប្រាសាទ

ពិធីបុណ្យសមុទ្រលើកទី៧ ជុំទី២, ១៥ ធ្នូ ២០១៨

... **ប្រទេសយើងមានតំបន់ឆ្នេរដ៏ស្អាត បំពេញបន្ថែមដោយប្រាង្គប្រាសាទនានាក្នុងផ្ទៃប្រទេស ធ្វើឲ្យក្លាយជាប្រទេសដែលមានទេសចរដ៏សម្បូរបែប ដែលយើងនិយមហៅថា ទេសចរវប្បធម៌និងធម្មជាតិ។ នៅក្នុងនោះ ... អេកូទេសចរណ៍ជានយោបាយមួយដែលយើងទើបនឹងបានឆ្លងនៅកាលពីក្នុងខែវិច្ឆិកាកន្លងទៅ**...ហើយកោះកុង គឺជាខេត្តដែលសម្បូរបែបទៅដោយ(បរិស្ថាន)អេកូទេសចរណ៍។ យើងត្រូវខិតខំធ្វើឲ្យប្រទេសមានចំណុចទាក់ទាញខាងវិស័យទេសចរណ៍ ...។

១៣. សន្តិភាពមានតម្លៃសំរាប់ជីវិតនិងការអភិវឌ្ឍ ព្រមទាំងទាក់ទាញទេសចរ

បិទសន្និបាទបូកសរុបការងារទេសចរឆ្នាំ២០១៧ និងលើកទិសដៅអនុវត្តបន្តឆ្នាំ ២០១៨, ២៨ កុម្ភៈ ២០១៨

... គ្មានប្រទេសណាទទួលបានទេសចរក្នុងខណៈដែលកំពុងជួបប្រទះការវាយប្រយុទ្ធគ្នានោះទេ ហើយក៏គ្មានគោលដៅដែលកើតមានការវាយប្រហារភេរវកម្ម បង្កើតនូវសោកនាដកម្មណាមួយ អាចទាក់ទាញទេសចរណ៍នោះដែរ ... **មិនមែនគ្រាន់តែជាបញ្ហាភេរវកម្មវាយប្រហារប៉ុណ្ណោះទេ សូម្បីតែចោរលួចតូចតាចក៏មិនត្រូវមានតាមតំបន់ទេសចរណ៍នានាដែរ ...** សន្តិភាពមានតម្លៃណាស់សំរាប់ជីវិតនិងការអភិវឌ្ឍរបស់យើង។ **អ្នកដែលគេមិនសប្បាយចិត្តចំពោះយើង គឺជារឿងរបស់គេ ប៉ុន្តែជាតិសាសន៍របស់គេ មិនបានមកស្លាប់ជាមួយយើងនោះទេ ...៕**

១៤. របៀងសមុទ្រ បំរើអោយយុទ្ធសាស្ត្រដឹកជញ្ជូន និងវិស័យទេសចរណ៍

ប្រសាសន៍ក្នុងពិធីបុណ្យសមុទ្រលើកទី៧ ដុំទី២, ១៥ ធ្នូ ២០១៨

... (យើងកំពុង)ពង្រីកនិងពង្រឹង**ការតភ្ជាប់តាមផ្លូវមាត់សមុទ្រ ហៅថារបៀងមាត់សមុទ្រពីកោះកុងទៅខេត្តព្រះសីហនុទៅកែបទៅកំពត។ នេះជារបៀងយុទ្ធសាស្ត្រដឹកជញ្ជូន ក៏ប៉ុន្តែវាក៏ជារបៀងទេសចរណ៍ដែរ**។ យើងត្រូវខិតខំពង្រីកផ្លូវលេខ៤៨ ... ការតភ្ជាប់រវាងទីរួមខេត្តកោះកុង នឹងតំបន់ទេសចរណ៍តារាសាគរ ជួយកាត់បន្ថយចម្ងាយក្នុងការធ្វើដំណើរ។ ត្រូវខិតខំតភ្ជាប់ពីតំបន់ខាងក្នុង (ប្រទេស)មកកាន់បណ្តាគោលដៅទេសចរណ៍នៅមាត់សមុទ្រ ហើយតំបន់មួយត្រូវមានការតភ្ជាប់ខ្លួនឯង ...៕

១៥. យកវិស័យទេសចរណ៍ជាទីផ្សាររបស់កសិករនិងអ្នកចិញ្ចឹម

បុណ្យសមុទ្រលើកទី៩ ដុំទី៣, ១០ ធ្នូ ២០២២

... ខ្ញុំទទូចថាត្រូវជំរុញការនាំចេញនៅនឹងកន្លែង។ **ការនាំចេញមិនសំដៅទៅលើការនាំចេញឆ្លងកាត់ព្រំដែនទេ។ ប្រជាកសិកររបស់យើងអាចដាំដុះ ចិញ្ចឹមសត្វ ហើយនាំចូលទៅកាន់សណ្ឋាគារ ឱ្យភ្ញៀវទេសចរបរទេសទទួលទានចាត់ទុកថាជាផ្នែកមួយនៃការនាំចេញនៅនឹងកន្លែង។ អំពាវនាវឱ្យវិស័យទេសចរណ៍ទាំងមូលក្លាយជាទីផ្សាររបស់កសិករនិងអ្នកផលិតអ្នកចិញ្ចឹម** ... យើងប៉ាន់ប្រមាណថាចំនួនទេសចរអាចវិលទៅរក ៦លានឬ ៧លាន(នាក់)វិញ ...៕

១៦. អោកូទេសចរណ៍ អោយផលច្រើនជាងកាប់ព្រៃធ្វើដំណាំកសិកម្ម

ពិធីបុណ្យសមុទ្រលើកទី៧ ដុំទី២, ១៥ ធ្នូ ២០១៨

... រក្សាឲ្យបានសមុទ្របៃតង រក្សាឲ្យបានតារាៈទិសនិរតីសម្រាប់ខេត្ត៤ ជាប់មាត់សមុទ្រ ដែលស្ថិតក្នុងចំណោមឆ្នេរស្អាតបំផុតលើពិភពលោក។ លើកទឹកចិត្តឲ្យមានការអភិវឌ្ឍអេកូទេសចរណ៍បែបតារាសាគរ (ដើម្បីយើង)ទទួលផលពីទេសចរណ៍ដោយមិនកាប់បំផ្លាញព្រៃឈើ។ ក្នុងខេត្តកោះកុងមានអេកូទេសចរច្រើន ... ការប្រគល់ដីធ្លីឲ្យកាប់ព្រៃឈើ ធ្វើការដាំដុះ ជាតម្រូវការនៃការអភិវឌ្ឍក្នុងវិស័យកសិកម្ម ...ដើម្បីបានកៅស៊ូស្វាយចន្ទីនិងធញ្ញជាតិដទៃ ...**តែអេកូទេសចរណ៍មិនតម្រូវឲ្យមានការកាប់ឈើច្រើនទេ។ តាមរយៈការរៀបចំមូលដ្ឋានអេកូទេសចរណ៍ យើងទទួលផលច្រើនជាងវិស័យកសិកម្ម ហើយការពារព្រៃបានល្អផង** ...៕

១៧. យកទេសចរណ៍ទាញកសិកម្ម សិប្បកម្មទាញវិស័យពាក់ព័ន្ធទេសចរណ៍ឯទៀត

ពិធីបុណ្យសមុទ្រលើកទី ៧ ដុំទី ២, ១៥ ធ្នូ ២០១៨

... ត្រូវខិតខំជំរុញការដាំដុះជំរុញការចិញ្ចឹមសត្វនៅក្នុងប្រទេស ដើម្បីកាត់បន្ថយប្រាក់ចំណូលដែលយើងបានមកពីទេសចរ ហើយនាំចេញទៅវិញ ដើម្បីនាំបន្ថែមបង្ការនាំសាច់ពីប្រទេសក្រៅមកផ្គត់ផ្គង់ទេសចរក្នុងស្រុក។ គ្រប់កន្លែងដែលមានតំបន់ទេសចរត្រូវខិតខំចលនា។ **ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទត្រូវកំណត់តំបន់នោះធ្វើជាខ្សែក្រវាត់បៃតង ជំរុញប្រជាជនដាំដុះបន្ថែមបង្កា ជំរុញប្រជាពលរដ្ឋចិញ្ចឹមសត្វចិញ្ចឹមត្រី ផ្គត់ផ្គង់បណ្តាសណ្ឋាគារដែលមានទេសចរ។ យើងយកវិស័យទេសចរណ៍មួយទាញវិស័យកសិកម្ម រីឯវិស័យសិប្បកម្ម ក៏ទាញវិស័យផ្សេងទៀតដែលមានតម្រូវការ សម្រាប់វិស័យទេសចរណ៍** ...៕

១៨. ការពារសុវត្ថិភាពអ្នកទេសចរផ្លូវទឹកនិងតាមកោះនានា

ពិធីបុណ្យសមុទ្រលើកទី៧ ដុំទី២, ១៥ ធ្នូ ២០១៨

... ត្រូវខំ**ការពារឱ្យខាងតែបានសុវត្ថិភាពអ្នកទេសចរណ៍ដែលធ្វើដំណើរតាមមធ្យោបាយផ្លូវទឹក ទៅសំរាកនៅតាមកោះ និងទស្សនាតាមផ្លូវទឹក។ ត្រួតពិនិត្យជាប្រចាំនូវមធ្យោបាយ និងពោងសុវត្ថិភាព** ... តាមបណ្តាកោះមានការវិនិយោគច្រើន ... អ្នកទៅលេងនៅកោះក៏ច្រើន តែត្រូវធានាមធ្យោបាយដឹកជញ្ជូន។ ប្រទេសមួយចំនួនមានការលិចកាណូតដឹក(អ្នកទេសចរ) ហើយបើមានករណីខ្វះពោង(សុវត្ថិភាព)ថែមទៀតនឹងធ្វើឱ្យអ្នកទេសចរគ្រោះថ្នាក់ ...៕

១៩. អោយវិនិយោគលើកោះជាតំបន់ទាក់ទាញទេសចរណ៍ តែមិនមែនទីចាក់សំរាម

ពិធីបុណ្យសមុទ្រលើកទី៧ ជុំទី២, ១៥ ធ្នូ ២០១៨

... កោះទាំងអស់នឹងត្រូវដាក់ឱ្យមានការវិនិយោគ ... ប្រទេសគេនានាបានធ្វើហើយ នៅតែកម្ពុជាហ្នឹងមិនទាន់ធ្វើ។ យើងបានធ្វើមួយចំនួនហើយៗ កំពុងតែបន្តធ្វើតទៅទៀត។ **យើងលើកទឹកចិត្ត(អោយមានការវិនិយោគ តែមិន)ឱ្យកោះរបស់យើង (ក្លាយជាទី)បោះបង់ចោលនូវកាកសំណល់ហួសសម័យ ដូចដែលគេចង់ធ្វើរោងចក្រជី និងរោងចក្រដុតអគ្គិសនីដើរដោយសំរាមដឹកពីប្រទេសគេនោះមកទេ។ យើង(ត្រូវតែ)ក្លាយទៅជាតំបន់ទេសចរណ៍ដ៏មានការទាក់ទាញ** ...៕

២០. ការពារនិងរក្សាតំបន់ឆ្នេរឱ្យនៅស្អាត កុំឱ្យត្រូវដកចេញចេញពីក្លិប ឬសមាគម

បុណ្យសមុទ្រលើកទី៨ ជុំទី២, ២១ ធ្នូ ២០១៩

... ដោយរក្សាបានឆ្នេរសមុទ្រស្អាត ដែលយើងជាសមាជិកក្លិបឆ្នេរសមុទ្រដែលស្អាតបំផុត ... កម្ពុជាបានជាប់ឆ្នោតឱ្យធ្វើជាអនុប្រធានសមាគមនេះ បូកនឹងធ្វើមហាសន្និបាតសម្រាប់ឆ្នាំ២០២២ និងការប្រណាំងកង់ជាអន្តរជាតិនៅតាមឆ្នេរសមុទ្រឆ្នាំ២០២០ ខាងមុខ ... ដូចនេះ ខេត្តជាប់មាត់សមុទ្រ **ត្រូវការពារតំបន់ឆ្នេរ រក្សាជាឆ្នេរដែលស្អាតបំផុតនៅក្នុងក្របខណ្ឌពិភពលោក កុំឱ្យឆ្នេររបស់យើងត្រូវបានដកហូតចេញពីសមាជិកក្លិប ឬសមាជិកសមាគម** ...៕

២១. ការពារផ្ទៃបាតសមុទ្រ ៧ពាន់ហិកតាគ្របដណ្តប់ដោយស្មៅសមុទ្រ ដើម្បីទេសចរ

បុណ្យសមុទ្រលើកទី៨ ជុំទី២, ២១ ធ្នូ ២០១៩

... យើងរក្សាបានធនធានធម្មជាតិក្នុងសមុទ្រនិងបាតសមុទ្រ បន្ថែមលើនោះការជំទាស់របស់ខ្ញុំមិនឲ្យបូមខ្សាច់ក្នុងសមុទ្រ ក៏បានថែទាំជីវៈចម្រុះក្នុងសមុទ្រ ... **មាន ៧ពាន់ហិកតាដែលគ្របដណ្តប់ដោយស្មៅសមុទ្រ និងមានអ្វីៗ នៅទីនោះដែលចាំបាច់ដាក់ជាតំបន់ការពារ ដើម្បីក្លាយជាកន្លែងទេសចរទាក់ទាញអាចនឹងមានអ្នកទេសចរមកមុជទឹកកម្សាន្ត**។ ខ្មែរយើងទៅមុជទឹកកំសាន្តនៅម៉ាល់ឌីវ ឬប្រទេសនានា ... ឥឡូវមានទេសចរដែល(ចាប់អារម្មណ៍ចង់)មុជទឹកទៅមើលអ្វីៗនៅក្រោមបាតសមុទ្រ(កម្ពុជា) ...៕

២២. ចលនាជាតិទីក្រុងស្អាត សុវត្ថិភាព សុខុមាលភាព ភ្ញៀវទេសចរមិនបារម្ភពីជំងឺឆ្លង

ទីក្រុងស្អាតលើកទី៧ ឆ្នាំ២០១៩ ក្រោមប្រធានបទ “ទីក្រុងស្អាត៖ ទីក្រុងផ្តល់ភាពកក់ក្តៅ”, ២៥ កុម្ភៈ ២០១៩

... ប្រជាពលរដ្ឋមួយចំនួនពេបជ្រាយថាទីក្រុងរបស់យើងមិនសូវស្អាត។ ប៉ុន្តែអ្នកដែលនិយាយថា ទីក្រុងមិនសូវស្អាត បែរជានាំគ្នាបោះចោលសំរាម បោះចោលចង់ផ្លាស្ទិកដែលជារឿងមិនគប្បីធ្វើ។ **ដើម្បីធ្វើអោយចលនាទីក្រុងស្អាត ទីក្រុងមានសុវត្ថិភាព ទីក្រុងផ្តល់សុខុមាលភាព យើងទាំងអស់គ្នាត្រូវបង្កើតជាចលនាជាតិមួយ ចាប់ផ្តើមពីក្មេងដឹងក្តីរហូតដល់មនុស្សចាស់ រួមចំណែក(ថែទាំនិងសំអាត)ទាំងអស់គ្នា ដើម្បីទាក់ទាញបានភ្ញៀវទេសចរមកប្រទេសយើង ដោយ(ពួកគាត់)គ្មានការភ័យខ្លាចពីជំងឺឆ្លងណាមួយកើតចេញពីកម្ពុជាត្រឡប់ទៅវិញ** ...៕

២៣. វិថីក្នុងក្រុងស្អាត អាហារឆ្ងាញ់និងមានអនាម័យ នឹងទាក់ទាញទេសចរ

ទីក្រុងស្អាតលើកទី៧ ឆ្នាំ២០១៩ ក្រោមប្រធានបទ “ទីក្រុងស្អាត៖ ទីក្រុងផ្តល់ភាពកក់ក្តៅ”, ២៥ កុម្ភៈ ២០១៩

... ត្រូវចាំថា អនាម័យចំណីអាហារគឺជាបញ្ហាធំ ... ភ្ញៀវទេសចរមកកាន់ប្រទេសយើង ក៏នឹងស្វែងរកចំណីអាហារដែលមានរសជាតិឆ្ងាញ់។ ឥឡូវនេះ ដាក់ចេញនូវគោលដៅស្តង់ដា**វិថីម្ហូបអាហារ ដោយបង្កើតឲ្យមានការប្រកួតប្រជែងលក់ម្ហូបអាហារ តាមវិថីនានា។ បើវិថីណា(មានអាហារ)ឆ្ងាញ់ពិសា ទេសចរច្បាស់ជាចូលចិត្តមកតាមវិថីហ្នឹងទាំងថ្ងៃទាំងយប់។ មួយទៀត បើចង់ឲ្យទេសចរទៅ(តាមវិថី)**

ហ្នឹងទាល់តែប្រឹងសំអាតផ្លូវ។ អញ្ចឹង ព្រួញមួយបាញ់បានសត្វពីរ។ នៅទីក្រុងភ្នំពេញ បើវិថីទាំងអស់ស្អាត មានម្ហូបឆ្ងាញ់ ... វានឹងចាប់ផ្តើមប្រកួតប្រជែង ទាញទេសចរទៅ មិនប្រមូលផ្តុំតែនៅមួយកន្លែងទេ ...៕

២៤. ប្រើអស់សក្តានុពលកសិកម្មក្នុងស្រុក/ខ្សែក្រវ៉ាត់បៃតង មិនខ្ជះខ្ជាយរូបិយបណ្ណ

ទីក្រុងស្អាតលើកទី៧ ឆ្នាំ២០១៩ ក្រោមប្រធានបទ "ទីក្រុងស្អាត៖ ទីក្រុងផ្តល់ភាពកក់ក្តៅ", ២៥ កុម្ភៈ ២០១៩

... **(ខ្សែក្រវ៉ាត់បៃតងនឹងជួយឱ្យ)យើងមិនខ្ជះខ្ជាយរូបិយបណ្ណដែលបានចូលមកដល់ក្នុងប្រទេស ហើយបែរជា(ត្រូវ)ហៀរចេញទៅប្រទេសក្រៅ។** មានរបស់ខ្លះយើងមិនទាន់ផលិតបានក្នុងស្រុក។ យើងត្រូវយកមកពីខាងក្រៅ(ប្រទេស) ដូចជាស្រា ... យើងបានធ្វើសាំប៉ាញពីទឹកត្នោត យើងបានធ្វើស្រាទំពាំងបាយជូរ តែមិនទាន់ពេញនិយមទេ។ គេត្រូវការស្រាបារាំង ស្រា Bordeaux ឯណោះ ... **អញ្ចឹងត្រូវខិតខំផលិត ដោយប្រើប្រាស់អោយអស់សក្តានុពលកសិកម្មក្នុងស្រុក បម្រើគោលដៅទេសចរណ៍ ...៕**

២៥. គ្មានមីន មានហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ អេកូទេសចរណ៍ គឺសេដ្ឋកិច្ចពហុវិស័យគ្មានទីអស្តង្គត

ទីក្រុងស្អាតលើកទី៧ ឆ្នាំ២០១៩ ក្រោមប្រធានបទ «ទីក្រុងស្អាត៖ ទីក្រុងផ្តល់ភាពកក់ក្តៅ, ២៥ កុម្ភៈ ២០១៩

... **ក្រោយពីនយោបាយឈ្នះឈ្នះឆ្នាំ១៩៩៨ ឯកភាពទឹកដីហើយ យើងបានបំផ្លាញចោលគ្រាប់មីន យើងធ្វើហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ ... ពេលខាងមុខនេះទៅទូទាំងប្រទេសនឹងកសាងផ្លូវបន្ថែមៗទៀត** រាប់ទាំងផ្លូវដែលតភ្ជាប់ពីខេត្តកោះកុងព្រំដែនកម្ពុជាថៃទៅឋ្មជា ... ប៉ៃលិន បាត់ដំបង ដែលទេសចរអាចធ្វើដំណើរបានទូទាំងព្រំដែន ... **យើងក៏មានចំណុចអេកូទេសចរណ៍ជំទាក់ទាញ។ នេះជាសេដ្ឋកិច្ចពហុវិស័យដែលគ្មានទីអស្តង្គត។ សូម្បីវិស័យកសិកម្ម ក៏មានអនុវិស័យជាច្រើនដែលក្នុងនោះមានអនុវិស័យបម្រើឲ្យទេសចរណ៍ក្នុងស្រុក ...៕**

២៦. កុំឲ្យកម្ពុជាមានអំពើភេរវកម្មតាមតំបន់ទេសចរ និងមានសហគមន៍សុខសាន្ត

ទីក្រុងស្អាតលើកទី៧ ឆ្នាំ២០១៩ ក្រោមប្រធានបទ «ទីក្រុងស្អាត៖ ទីក្រុងផ្តល់ភាពកក់ក្តៅ, ២៥ កុម្ភៈ ២០១៩

... ខ្ញុំសូមបន្តលើកទឹកចិត្ត និងដាក់ចេញបទបញ្ជាអំពីសន្តិភាពនិងស្ថិរភាពខាងនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សង្គម **ធ្វើយ៉ាងម៉េចជានាកុំឲ្យកម្ពុជាមានអំពើភេរវកម្មកើតឡើងតាមតំបន់ទេសចរណ៍នានា និងមិនថាតែតាមតំបន់ទេសចរណ៍ទេ តែត្រូវធ្វើឲ្យភូមិមួយ រោងចក្រមួយ សណ្ឋាគារមួយ សហគ្រាសមួយ ក្លាយទៅជាតំបន់សុខសាន្តមួយ** ... ទេសចរអាចទៅកាន់តែធ្ងាយនិងគ្រប់ទីកន្លែងដែលមានមណ្ឌលយ៍ដ្ឋាន(ដោយសារទីទាំងនោះ)ត្រូវបានរៀបចំអោយមានផ្លូវចូល ...៕

២៧. ប្រើសក្តានុពលតាមទីក្រុង/ខេត្តនានាអភិវឌ្ឍវិស័យទេសចរណ៍

ពិធីប្រកាសបើកបុណ្យទន្លេលើកទី៥, ១៦ មីនា ២០១៩

... ខិតខំ**អភិវឌ្ឍវិស័យទេសចរតាមទីក្រុងទីប្រជុំជនតាមដងទន្លេ ឬតំបន់ដែលមានការទាក់ទាញតាមមាត់ទន្លេ ដោយយកទេសចរទាញផ្នែកជាទៃ** ... កន្លែងផលិតវត្ថុអនុស្សាវរីយ៍សម្រាប់វិស័យទេសចរណ៍ ក៏បានឃើញរូបភាពភ្ញៀវទេសចរដើរទូកដើរកន្ទេះគោ។ល។ នេះជាការដែលយើងទទួលផលក្នុងរយៈពេលវែង។ ខ្ញុំធ្លាប់បាននិយាយហើយ "កុំសម្លាប់មេមាន់ដើម្បីគ្រាន់តែជាការឆ្ងាញ់មួយពេល។ ត្រូវរក្សាទុកមេមាន់ដើម្បីឲ្យតពូជតជំនាន់ ដើម្បីវាផ្តល់នូវស៊ុតកូន" ... **នោះជាផលដែលយើងអាចទទួលបាន។ ត្រូវប្រើប្រាស់ចំណុច(ល្អៗ)នៅក្នុងខេត្តនីមួយៗ ទាញយកវិស័យទេសចរណ៍ ...៕**

២៨. ពីទេសចរបរទេស ៦,៦លាន នៅឆ្នាំ២០២០ មកជាង ១លាន ដោយសារកូវីដ-១៩

សម្ពោធមជ្ឈមណ្ឌលកំសាន្ត Prince Manor, កៀនស្វាយ, កណ្តាល, ៧ តុលា ២០២០

... យើងក៏មានមជ្ឈមណ្ឌលមួយទៀតហើយ(Prince Manor)នៅទីនេះ ដែលបង្កើតបរិយាកាសការកម្សាន្តជូនប្រជាពលរដ្ឋ។ គេអាចចោទជាសំណួរថា ហេតុអ្វីបានជាសម័យកូវីដ ដែលទេសចរណ៍កំពុងតែធ្លាក់ចុះ បែរជានាំគ្នាសម្ពោធដាក់ឱ្យប្រើប្រាស់មជ្ឈមណ្ឌលកម្សាន្តទៅវិញ? ... ទោះបីបានបំផ្លិចបំផ្លាញ (សង្គម

សេដ្ឋកិច្ច) ក៏កូវីដមិនអាចសម្លាប់យើងបានទេ ... **កម្ពុជាធ្លាប់ទទួលបានទេសចរ(អន្តរជាតិ)រហូតទៅ ៦លាន ៦សែននាក់ កាលពីឆ្នាំ២០១៩ កន្លងទៅ។ ប៉ុន្តែនៅឆ្នាំនេះ យើងទទួលបានទេសចរបរទេសត្រឹមតែជាង ១លាននាក់ប៉ុណ្ណោះ។ មិនសង្ឃឹមថាទេសចរអន្តរជាតិមានការឆើបឡើងឆាប់រហ័សនោះទេ** ...៕

២៩. ឆ្នាំ២០២២ អាស៊ានប្រឈមនឹងធ្វើឲ្យទេសចរណ៍រស់ឡើងវិញក្នុងបរិបទកូវីដ-១៩

វេទិកាទេសចរណ៍អាស៊ាន ២០២២ លើកទី ៤០ ប្រធានបទ «អាស៊ាន៖ សហគមន៍សន្តិភាព និងវាសនាតែមួយ», ១៨ មករា ២០២២

... **របៀបវារៈកិច្ចការអាស៊ាន មិនមែនមានបញ្ហាតែមួយទេ គឺមានបញ្ហាច្រើនដែលត្រូវធ្វើ រាប់ទាំងតើត្រូវធ្វើដូចម្តេចឲ្យទេសចរណ៍រស់ឡើងវិញ ក្នុងបរិបទនៃកូវីដ-១៩** ... យើងបានឃើញថា នាយករដ្ឋមន្ត្រីអេស្ប៉ាញបានអំពាវនាវឲ្យទទួលស្គាល់ថាជំងឺកូវីដ១៩ គឺជាជំងឺផ្តាសាយធម្មតា។ ខ្ញុំហាក់ដូចជាមាននិន្នាការគាំទ្រដំណើរវិវឌ្ឍដើម្បីរស់នៅជាមួយនឹងកូវីដ១៩។ ប៉ុន្តែ ត្រូវមានការប្រុងប្រយ័ត្ន ត្រូវតែចាក់វ៉ាក់សាំងឲ្យបានគ្រប់គ្រាន់ការពារពីជំងឺនេះ។ បើទោះបីចាត់ទុកវាថាគ្រាន់តែជាប្រភេទជំងឺផ្តាសាយធម្មតាក៏ដោយចុះ ក៏ត្រូវតែបន្តមានការចាក់វ៉ាក់សាំង កិច្ចការពារខ្លួនដូចជាពាក់ម៉ាស លាងដៃ និងរក្សាគម្លាត ក្នុងបរិបទថ្មី ...៕

៣០. សូមប្រជាពលរដ្ឋបង្វែរពីទេសចរណ៍ក្រៅប្រទេស មកធ្វើដំណើរកម្សាន្តក្នុងស្រុក

សារនិងសេចក្តីអធិប្បាយជូនជនរួមជាតិស្តីពីវិធានការរាជរដ្ឋាភិបាលគ្រប់គ្រងផលប៉ះពាល់ពីជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ(កូវីដ-១៩)និងការព្យុះភាពអនុគ្រោះពន្ធលើទំនិញមួយចំនួនក្រោមកម្មវិធី "ទំនិញគ្រប់មុខលើកលែងអាវុធ"(EBA), ២៤ កុម្ភៈ ២០២០

... សម្រាប់អ្នកធ្លាប់ធ្វើទេសចរណ៍ក្រៅប្រទេស ដោយដើងហោះហើរមួយចំនួនត្រូវបានដ្ឋាក និងដោយសារភាពមិនច្បាស់លាស់នៃជំងឺទៅតាមប្រទេសនានាក៏ស្ថិតក្នុងស្ថានភាពដែលត្រូវប្រុងប្រយ័ត្ន **សូមបងប្អូនប្រជាពលរដ្ឋដែលក្នុងមួយឆ្នាំមានជាងមួយលាននាក់ធ្វើដំណើរទៅក្រៅប្រទេស ងាកមកធ្វើដំណើរក្នុងស្រុកទៅកាន់តំបន់ទេសចរណ៍នានា ក្នុងនោះឲ្យអាទិភាពខ្ពស់ទៅខេត្តសៀមរាប។ ធ្វើយ៉ាងនេះ យើងសន្សំរូបិយប័ណ្ណផង យើងឲ្យប្រជាពលរដ្ឋស្គាល់ប្រទេសរបស់ខ្លួនបានច្បាស់លាស់ផង។ នេះជាការអំពាវនាវរបស់ខ្ញុំ ដើម្បីជួយស្រោចស្រង់វិស័យទេសចរណ៍ ចំពោះមុខការធ្លាក់ចុះនៃទេសចរបរទេស** ...៕

៣១. គោលដៅទទួលទេសចរអោយបានពី ១៥ដល់ ២០លាននាក់/ឆ្នាំ

ពិនិត្យការដ្ឋាននិងប្រកាសឈ្មោះអាកាសយានដ្ឋានអន្តរជាតិតេជោក្រុងតាខ្មៅ, ០៩ ធ្នូ ២០២១

... (អំពី)សមត្ថភាពស្រូបយកផលប្រយោជន៍ពីការបើកចំហដើងមេឃ ដែលទេសចរនឹងមកកាន់តែច្រើននោះ ... ហើយដោយសារ(ព្រលានយន្តហោះ)នៅទីក្រុងភ្នំពេញអាចទទួលបានត្រឹមតែប៉ុន្មានគ្រឿងប៉ុណ្ណោះក្នុងមួយពេល ហើយនៅសៀមរាបទទួលបានកាន់តែតិច និងបានតែយន្តហោះធុនតូច ... **ផ្អែកទៅលើប្រការថាយើងការដែលយើងទទួលត្រឹមតែ ៦លាន ៦សែននាក់នៅឆ្នាំ២០១៦ វាលំបាកណាស់ទៅហើយៗ យើងយកគោលដៅ(ទទួល)ទេសចរ(អោយបានពី)១៥លានទៅ ២០លាននាក់ឯណោះ បានជាមានតម្រូវការកសាងព្រលានយន្តហោះថ្មីបន្ថែម(ទាំងនៅភ្នំពេញ ទាំងនៅសៀមរាប)** ...៕

៣២. ទទួលវ៉ាក់សាំង ២ដូស ធ្វើតេស្តរហ័សអវិជ្ជមានពេលមកដល់ មិនបាច់ចត្តាឡីស័ក

សម្ពោធដាក់ឲ្យប្រើប្រាស់នូវស្ពានមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រង់-ក្រូចឆ្មារ និងការប្រកាសបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ 71C, ២៣ វិច្ឆិកា ២០២១

...សៀវដៀលប៉ះពាល់ធំជាងគេគឺទេសចរណ៍ ... ខ្ញុំគិតថាសៀវទេសចរណ៍នឹងដើរឡើងវិញ។ ឥឡូវទេសចរក្នុងស្រុករាប់ទាំងបរទេសជាង ១ម៉ឺននាក់ កំពុងរស់នៅ និងដើរលេងក្នុងស្រុក។ នៅពេលខាងមុខ យើងនឹងមាន**ទេសចរមកកាន់ប្រទេសយើង ដោយអត់មានការចាំបាច់នឹងធ្វើចត្តាឡីស័កទេ ដោយលក្ខខណ្ឌទី១ អ្នកឯងត្រូវចាក់វ៉ាក់សាំង ២ដូសនៅប្រទេសរបស់អ្នកឯងឲ្យហើយ ... ជាមួយនឹងការបញ្ជាក់ថាបានធ្វើតេស្តមិនមាន COVID19, ទី២ មកដល់ព្រលានយន្តហោះ ត្រូវធ្វើតេស្តរហ័ស។ (បើឃើញ)អវិជ្ជមានហើយទៅកន្លែងណាក៏បាន**។ ពីមុននេះយើងគិតថា ឲ្យមកធ្វើចត្តាឡីស័ក ៥ថ្ងៃ ... ឥឡូវអត់ចាំបាច់(ធ្វើចត្តាឡីស័កទេ) សូម្បីតែ(ធ្វើតេស្តតាម)ម៉ាស៊ីន PCR ក៏មិនចាំបាច់ដែរ ...៕

៣៣. កម្ពុជាមិនទាន់មានចំណូលជំនួសការយកថ្លៃទិដ្ឋាការទេសចរនៅឡើយ

បើកការដ្ឋានសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង
និងសម្ពោធរោងចក្រប្រព្រឹត្តកម្មទឹកស្អាតចំការមន, ១ កុម្ភៈ ២០២១

... បើគិតអំពីចំណូលមិនមែនសារពើពន្ធ ថ្លៃទិដ្ឋាការដែលយើងធ្លាប់មានទេសចរ ៦លាន ៦សែននាក់ ... បើទេសចរ ១លាននាក់ វាបានបាត់បង់ទៅស្មើនឹងប្រាក់ ៣០លានដុល្លារទៅហើយ ព្រោះ VISA មួយ(ថ្លៃ) ៣០ដុល្លារ។ អញ្ចឹងទេ **ខ្ញុំមិនយល់ស្របនឹងសំណើណាមួយ ឲ្យកម្ពុជាបញ្ឈប់ការយកថ្លៃទិដ្ឋាការដើម្បីទាញទេសចរនៅឡើយ។ កម្ពុជាអត់ទាន់មានអីជំនួសទេ ... ប្រទេសគេយកថ្លៃជាងយើងផង។ ប្រទេសបារាំង(ថ្លៃទិដ្ឋាការ)ជាង ១០០ដុល្លារ គេទៅបាន**។ ចុះយើងតែ ៣០ដុល្លារ ម៉េចក៏គេមកមិនបាន? ក្រសួងទេសចរណ៍ចេះតែស្នើសុំ ប្រទេសមួយចំនួនក៏ស្នើសុំ ...៕

៣៤. វិស័យទេសចរណ៍បន្តរងការប៉ះពាល់ពីសង្គ្រាមនិងទណ្ឌកម្មពិភពលោក

បិទសន្និបាតបូកសរុបការងារទេសចរណ៍ (ក្រោយវិបត្តិជំងឺកូវីដ-១៩
ដំណាក់កាលទី១ រវាង ២០២០-២១), ១៤ កក្កដា ២០២២

...កូវីដ-១៩មានផលប៉ះពាល់ធ្ងន់លើវិស័យទេសចរណ៍។ឧស្សាហកម្ម កសិកម្ម និងសេវាមួយចំនួនបានដើរបន្តឡើងហើយ ប៉ុន្តែ**វិស័យទេសចរណ៍បន្តស្ថិតក្នុងស្ថានភាពរើបៗ។ ឥឡូវនេះ បញ្ហាថ្មីក៏បានមកដល់ដែលវាអាចបំផ្លាញវិស័យទេសចរណ៍នេះថែមទៀត នោះគឺសង្គ្រាមនិងទណ្ឌកម្ម ដែលបង្កើតជាស្ថានភាពមិនច្បាស់លាស់នៃពិភពលោកមួយដែលបែកបាក់និងគ្មានសណ្តាប់ធ្នាប់។ វាមិនមែនតែសង្គ្រាមនៅអ៊ុយក្រែនទេ ប៉ុន្តែវាក៏មានទណ្ឌកម្ម(ផងដែរ) ... កំណើនសេដ្ឋកិច្ចពិភពលោកអាចនឹងធ្លាក់ចុះ។ អតិផរណាតាមបណ្តាប្រទេសមានការកើនឡើង ... សំបុត្រយន្តហោះអាចឡើងថ្លៃ ជាការប៉ះពាល់វិនាសដល់វិស័យទេសចរណ៍** ...៕

៣៥. កត្តា៤ ក្នុងសន្តិភាព ធ្វើឲ្យពលរដ្ឋកម្ពុជាធ្វើទស្សនាចរបាន

សំណេះសំណាលជាមួយសហគមន៍ខ្មែរនៅទ្វីបអឺរ៉ុប, ២១ ឧសភា ២០២២

... ដែលប្រជាពលរដ្ឋអាចដើរលេងបានអាស្រ័យ **ទី១ កត្តាសន្តិភាព។ តើមានអ្នកណាហ៊ានទៅធ្វើទេសចរនៅប្រទេសអ៊ុយក្រែន ... ទី២ មានហេដ្ឋារចនាសម្ព័ន្ធល្អ អាចដើរលេងបាន។ ទី៣ មានមធ្យោបាយធ្វើដំណើរ ទាំងជាមធ្យោបាយផ្ទាល់ខ្លួន ទាំងជារថយន្តឈ្នួល និងទី៤ មានប្រាក់ចំណូលដែលអាចចែករំលែកទៅដើរលេងបាន** ... កត្តា៤ នេះធ្វើឲ្យទេសចរណ៍ក្នុងស្រុករស់រវើក។ ផលហ្នឹងបានទៅដល់អ្នកលក់ដូរនៅជនបទ ... សហគមន៍ព្រៃឈើនៅតាមមូលដ្ឋានដែលគេអភិរក្សតាមរយៈក្រសួងបរិស្ថាន ... ការកាប់អុស ការបាញ់សត្វ សកម្មភាពដុតព្រៃស្ទឹងហ្នឹងបានថយ ... ហើយប្រជាប្រភពទាក់ទាញទេសចរទៅកម្សាន្តកន្លែងគាត់ ...៕

៣៦. កម្ពុជាអត់ត្រូវការយោធាបរទេសទេ ត្រូវការទេសចរបរទេសច្រើន

ពិនិត្យការងារជាក់ស្តែងនៅការដ្ឋានអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ,
៣ មេសា ២០២២

... តិចអ្នកវិភាគទាំងឡាយនាំគ្នាវិភាគថា (អាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ)នេះ ជាមូលដ្ឋានសម្រាប់ចុះយន្តហោះចិន ... បើគេចង់ចុះ និយាយឲ្យត្រង់តែម្តងទៅ គេចុះពោធិ៍ចិនតុងក៏បានដែរ ... ឧបមាថាបើកប្រតិបត្តិការយោធាអញ្ចឹងចុះ គេចុះនៅទីណាក៏គេចុះបានដែរ ... ផ្ញើសារជូនទុកឲ្យហើយ។ កុំឲ្យវិភាគបែបឆ្គួត។ **កម្ពុជាអត់ត្រូវការយោធាបរទេសទេ។ ត្រូវការទេសចរបរទេសឲ្យច្រើន។ ដំណាក់កាលទីមួយ ៧លាននាក់។ បើថាសមត្ថភាពទទួលផុតពី ៧លាននាក់ហើយ ត្រូវពង្រីកឡើងទៅ ១០លាននាក់។ បើ ១០លាននាក់នៅតែមិនទាន់គ្រប់ពង្រីកឲ្យដល់ ២០លាននាក់ ដូចការគ្រោងទុក** ... (កុំអោយ)ឲ្យតែធ្វើអីជាមួយចិនដឹងតែពីថាឲ្យចិនដាក់កងទ័ពតែម្តង? ...៕

៣៧. ពង្រាយការលូតលាស់វិស័យទេសចរណ៍ទៅប្រជាជននៅជនបទឱ្យកាន់តែច្រើន

ពិធីអបអរសាទរទិវាជាតិទីក្រុងស្អាតលើកទី១១ ឆ្នាំ២០២៣, ២៧ កុម្ភៈ ២០២៣

... កាលពីពេលមុន វិស័យទេសចរណ៍មិនបាច់ទៅផ្សព្វផ្សាយតាម CNN, BBC អីទេ ផ្សព្វផ្សាយតែតាមរយៈទេសចរដែលមកក្នុងប្រទេសយើង ... ធ្វើម៉េចឲ្យបុគ្គលដែលមកទស្សនកិច្ចនេះចង់មកទៀត នាំទាំងក្រុមគ្រួសារ មិត្តភក្តិមកទៀត។ ហ្នឹងទើបជាចំណុចគន្លឹះ ... យើងទទួលទេសចរដោយបដិសណ្ឋារកិច្ចល្អ មានសន្តិសុខល្អ មានអនាម័យ មានកន្លែងទាក់ទាញដែលពួកគាត់ចង់ទៅមើល។ អញ្ចឹងទេសចរ

មកគឺចង់មកទៀតហើយ ... កុំធ្វើឲ្យទេសចរមកដល់កម្ពុជាហើយថាកុំទៅកម្ពុជាអី ... ហ្នឹងជាបញ្ហា។ **សូមប្រជាជនកម្ពុជាយើងគ្រប់រូបខិតខំ ព្រោះនេះជាផលប្រយោជន៍ជាតិ ហើយវាបានពង្រាយការលូតលាស់របស់ប្រទេសជាតិនៃវិស័យទេសចរណ៍ទៅកាន់ប្រជាជននៅតាមទីជនបទកាន់តែច្រើន ...៕**

៣៨. អនុវត្តយុទ្ធនាការ «ភូមិស្អាត ស្រែល្អ» ជួយទាក់ទាញទេសចរទៅតាមភូមិឃុំ

ពិធីអបអរសាទរទិវាជាតិទីក្រុងស្អាតលើកទី១១ ឆ្នាំ២០២៣, ២៧ កុម្ភៈ ២០២៣

... តើនៅចាំទេ? ប្រហែលជាប្រមាណ ២ទសវត្សរ៍មុន ឬក៏ ៣ទសវត្សរ៍មុន យើងប្រើពាក្យស្លោក **«ភូមិស្អាត ស្រែល្អ» ... ជាយុទ្ធនាការទាក់ទងនឹងអនាម័យជំងឺឈឺថ្កាត់មួយចំនួនដូចជាគ្រុនឈាមដែលកើតចេញពីការខ្វះអនាម័យនៅជនបទ ... ខ្ញុំសុំស្នើឲ្យពង្រីកយុទ្ធនាការនេះមិនតែនៅទីក្រុងទេ ក៏ប៉ុន្តែលាតសន្ធឹងទៅកាន់ទីជនបទ ដោយប្រើប្រាស់ស្ថានភាពល្អប្រសើរនៅជនបទ ... ទាក់ទាញបានទេសចរណ៍ថែមទៀតទៅលេងនៅភូមិឃុំរបស់ពួកគាត់ ...៕**

៣៩. នយោបាយបើកចំហជើងមេឃ ការហោះហើរត្រង់មកខេត្តសៀមរាប

ពិធីបើកព្រឹត្តិការណ៍អង្គសេង្ក្រាន្ត(លើកទី៦) ព.ស ២៥៦២, ១៣ មេសា ២០១៨

... ខ្ញុំមានមោទនភាពអំពីនយោបាយបើកចំហជើងមេឃ ដែលខ្ញុំសម្រេចចិត្តនិងធ្វើសកម្មភាពនាំយកការហោះហើរត្រង់ពីប្រទេសនានា មកចុះចតនៅក្នុងខេត្តសៀមរាប។ អ្នករកស៊ីក្នុងវិស័យសេវាទេសចរណ៍មួយចំនួននៅទីក្រុងភ្នំពេញបានត្រៀមរៀបចំធ្វើបាតុកម្មប្រឆាំងនឹងការបើកចំហជើងមេឃរបស់ខ្ញុំ។ ឥឡូវអ្នកទាំងនោះបានទទួលស្គាល់ថា **ការបើកចំហជើងមេឃសម្រាប់ខេត្តសៀមរាបក៏បានផ្តល់ផលប្រយោជន៍ដល់ពួកគេធ្វើទេសចរណ៍នៅឯទីក្រុងភ្នំពេញផងដែរ។ ប្រសិនបើយើងមិនបើកចំហជើងមេឃសម្រាប់ការហោះហើរត្រង់មកកាន់ទីនេះ តើមានអ្នកណានឹងវិនិយោគធ្វើសណ្ឋាគារនៅទីនេះ? បើគ្រាន់តែមកព្រឹកទៅវិញល្ងាច ហើយគ្រាន់តែធ្វើដំណើរក្នុងទីក្រុងភ្នំពេញមិនគ្រប់គ្រាន់ទេ។ ដូច្នេះយើងបើកចំហជើងមេឃ បើកចំហជើងទឹក និងបើកចំហជើងគោក ដោយទេសចរក្នុងប្រទេសជិតខាងអាចធ្វើដំណើរមកតាមផ្លូវគោក តាមផ្លូវទឹក ទាំងតាមសមុទ្រ ក៏ដូចជាតាមទន្លេ ...៕**

៩. ធនធានទឹក និងខ្សែទុនិយម

១	ការរំដោះទឹកមិនអាស្រ័យលើប្រឡាយធំឬតូច តែលើសមត្ថភាពទ្រទ្រង់ធារទឹក	១៧៩
២	បន្តយទំហំប្រឡាយ និងជីកអោយជ្រៅ	១៧៩
៣	បន្តយទំហំប្រឡាយតាមវាលស្រែ ធ្វើអោយចំណេញផ្ទៃដីបង្កបង្កើនផល	១៧៩
៤	ប្រឡាយបេតុង ពង្រីកថ្នល់សងខាង បង្កើនដីដាំដុះ នៅក្រោយឆ្នាំ២០៣០	១៨០
៥	ស្វះស្វែងរកកិច្ចសហប្រតិបត្តិការធារាសាស្ត្រជាមួយវៀតណាម ថៃ និងឡាវ	១៨០
៦	កាត់ផ្លូវជាតិលេខ២ បញ្ចៀសទឹកជំនន់ព្រែកត្នោតឲ្យហូរចូលបឹងជើងលោក	១៨១
៧	អន្តរាគមន៍លើការខ្វះទឹកស្រែប្រាំងនិងទឹកប្រើប្រាស់	១៨១
៨	ខិតខំជីកអណ្តូង ប្រសើរជាងដឹកទឹកយកទៅពីចម្ងាយ	១៨២
៩	អន្តរាគមន៍ការជីកអណ្តូងតាមភូមិសំរាប់ក្រុមគ្រួសារនិងសហគមន៍	១៨២
១០	អាចនឹងកាត់ផ្លូវដែលទឹកបុក កសាងស្ពានធំជំនួសវិញ	១៨៣
១១	រកវិធីដោះស្រាយទឹកធ្លាក់ពីថៃទាំង ៣ប្រភព	១៨៣
១២	កំណត់ទីតាំងក្នុងបឹងទន្លេសាប បូមស្តារបង្កើតជាជម្រកការក្សានិងអភិរក្សាពូជត្រី	១៨៣
១៣	ទំនប់ដំណាក់អំពិល ទំនប់ចារឹក ផ្តល់ទឹកសំរាប់រដូវប្រាំង នៅពោធិ៍សាត់	១៨៤
១៤	ដីស្រោចស្រពកើនពី៧% ដល់៦២%, ទំនប់ប្រឡាយជួយបង្កើនមច្ឆជាតិ	១៨៤
១៥	វិនិយោគលើទឹកស្រោចស្រពដើម្បីផ្ទៃដីដាំដុះ ១ហិកតាក្លាយជា ២ឬ៣ហិកតា	១៨៥

១. រំដោះទឹកមិនអាស្រ័យលើប្រឡាយធំឬតូច តែលើសមត្ថភាពទ្រទ្រង់ធារទឹក

ពិធីបើកការដ្ឋានស្ពានអាកាស និងផ្លូវក្រោមដីវង្វង់មូលចោមចៅ, ២៩ មិថុនា ២០១៨

... ការអនុញ្ញាតឱ្យប្រជាពលរដ្ឋដែលកំពុងខ្វះដីធ្លីនៅ ហើយទៅរស់នៅលើ (ប្រឡាយ) ដែលធម្មតា ដីហ្នឹងជាដីរបស់រដ្ឋ មិនអាចទន្ទ្រានកាន់កាប់បានទេ ជាការដោះស្រាយតាមរបៀបឈ្នះឈ្នះ ... **ការរំដោះទឹកមិនអាស្រ័យទៅលើប្រឡាយធំ ឬតូចទេ វាចំណុះទៅលើធារទឹកដែលអាចទ្រទ្រង់បាន។ ជួនកាលប្រឡាយហ្នឹង ១០ម៉ែត្រ ប៉ុន្តែរាក់ត្រឹមតែ ១ម៉ែត្រ។ អញ្ចឹង ទទួលបានធារទឹកត្រឹមថា ៥០០ម៉ែត្រគូបក្នុង ១វិនាទី ជាឧទាហរណ៍ ... បើយើងកាត់ទំហំប្រឡាយពី ១០ម៉ែត្រមកនៅត្រឹម ៥ម៉ែត្រ តែមានជម្រៅដល់ ៤ទៅ ៥ម៉ែត្រ អញ្ចឹងវាអាចទទួលធារទឹកបានច្រើនជាង** ... ដូច្នេះអាចសល់ផ្ទៃដីដើម្បីជូនប្រជាពលរដ្ឋ ...៕

២. បន្តយទំហំប្រឡាយ និងជីកអោយជ្រៅ

ពិធីបើកការដ្ឋានស្ពានអាកាសនិងផ្លូវក្រោមដីវង្វង់មូលចោមចៅ, ២៩ មិថុនា ២០១៨

... បន្ថែមលើនោះ ប្រជាពលរដ្ឋបានទៅតាំងទីលំនៅតាមតំបន់មួយចំនួនជាប់នឹងប្រឡាយ។ អាជ្ញាធរក្រុងកំពុងដោះស្រាយ ដើម្បីអោយប្រជាពលរដ្ឋទាំងនោះបានរស់នៅស្របច្បាប់ តាមវិធី**កាត់បន្តយទំហំ ហើយជីកប្រឡាយឱ្យយជ្រៅ ដូចជានៅម្តុំខាងស្ទឹងមានជ័យ និងតំបន់ដទៃទៀត ... រាជរដ្ឋាភិបាលបានអោយគោលនយោបាយនេះ ទៅសាលារាជធានីភ្នំពេញរួចហើយ ដោយអោយសាលារាជធានីភ្នំពេញ រកវិធីដើម្បីកាត់បន្តយទំហំនិងជីកប្រឡាយនេះអោយជ្រៅ** ហើយដីដែលបងប្អូនកំពុងរស់នៅ ក្លាយជាដីស្របច្បាប់ និងផ្តល់កម្មសិទ្ធិអោយបងប្អូន ...៕

៣. បន្តយទំហំប្រឡាយតាមវាលស្រែ ធ្វើអោយចំណេញផ្ទៃដីបង្កបង្កើនផល

ពិធីបើកការដ្ឋានស្ពានអាកាស និងផ្លូវក្រោមដីវង្វង់មូលចោមចៅ, ២៩ មិថុនា ២០១៨

... ផែនការដ៏មហិច្ឆតារបស់ខ្ញុំ គឺនៅពេលខាងមុខ **ចង់កាត់បន្តយទំហំប្រឡាយនៅតាមវាលស្រែទាំងឡាយដែលមិនចាំបាច់ ហើយដែលអាចអោយចំណេញផ្ទៃដីសម្រាប់បង្កបង្កើនផល ដោយ(បន្តយទំហំ)ប្រឡាយ ដែលមិនមែនជាប្រឡាយប្រើប្រាស់ជាចរាចរណ៍ដឹកជញ្ជូន។ ប្រឡាយខ្លះមិនអាចកាត់បន្តយបានទេ ដោយ**

យើងត្រូវទុកប្រឡាយហ្នឹង គួបផ្សំរវាងធារាសាស្ត្រនិងការដើកជញ្ជូន។ ចំណុចនេះត្រូវបានលើកនៅក្នុងមហាសន្និបាតគណបក្សប្រជាជន តាំងពីឆ្នាំ១៩៨៥ ដែលមានខ្ញុំជានាយករដ្ឋមន្ត្រីនៅពេលនោះ ...៕

៤. ធ្វើប្រឡាយពីបេតុង ដោះស្រាយទឹក ពង្រីកថ្នល់សងខាង បង្កើនដីដាំដុះនៅក្រោយឆ្នាំ ២០៣០

ពិធីបើកការដ្ឋានស្ពានអាកាសនិងផ្លូវក្រោមដីរង្វង់មូលចោមចៅ, ២៩ មិថុនា ២០១៨

... យើងនឹងឈានទៅធ្វើប្រឡាយពីបេតុង ដែលអាចដោះស្រាយទឹកជូនប្រជាពលរដ្ឋហើយកាត់បំព្រួញដី ដើម្បីពង្រីកជាថ្នល់នៅសងខាងហ្នឹងបានធំទូលាយជាង ឬអាចផ្តល់ដីនោះសម្រាប់ការបង្កបង្កើនផលនៅពេលក្រោយ។ នេះប្រហែលជានឹងកើតឡើងនៅក្រោយឆ្នាំ២០៣០។ នេះជាការ**និយាយប្រាប់ក្មេងៗ ទុកមុននៅពេលដែលគេនឹងបន្តវេនពេលក្រោយ។ បើធ្វើបែបនេះបាន យើងនឹងអាចបូមទឹកតែមួយដង ជាជាងប្រឡាយបែបបុរាណ ដែលត្រូវបូម ២ដង។ បូមមួយដងចូលប្រឡាយមុនេះ រួចហើយត្រូវបូមដាក់ស្រែ។ ថ្ងៃក្រោយ យើងធ្វើប្រឡាយពីបេតុង បណ្តែតបន្តិច អញ្ចឹងទំហំប្រឡាយក៏មិនធំ ទៅដល់កន្លែងណា វាទម្លាក់ទឹកចូលស្រែតែម្តង** វាជាផលចំណេញ ...៕

៥. សូរស្វែងរកកិច្ចសហប្រតិបត្តិការធារាសាស្ត្រជាមួយវៀតណាម ថៃ និងឡាវ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅក្រុងបាវិត ខេត្តស្វាយរៀង (ថ្ងៃទី២), ១០ ឧសភា ២០១៨

... ជាការងាយដោះស្រាយ បើយើងមានកិច្ចសហប្រតិបត្តិការនៅតាមព្រំដែន។ ឥឡូវ យើងកំពុងតែឈានទៅរកការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មតាមព្រំដែនរវាងកម្ពុជានិងវៀតណាមបន្ថែមទៀត។ យើងកំពុងស្វែងរកកិច្ចសហប្រតិបត្តិការលើការប្រើប្រាស់ទឹក រវាងប្រទេសដែលនៅជិតខាងខ្លួន។ **ធារាសាស្ត្រនៅខាងវៀតណាមល្អ ...យើងទាញទឹកពីវៀតណាម យកមកស្រោចស្រពកសិកម្មនៅខាងកម្ពុជា។ កន្លែងខ្លះ ខាងកម្ពុជាមានទឹក ខាងវៀតណាមអត់ទឹក។ យើងក៏ផ្គត់ផ្គង់ឲ្យទៅខាងនោះវិញ។ ជាមួយថៃក៏ដូចគ្នា។ ជាមួយឡាវក៏ដូចគ្នា។ យើង**

ធ្វើបែបនេះ។ នេះជាក្របខណ្ឌគោលនយោបាយប្រែក្លាយតំបន់ព្រំដែនជាមួយប្រទេសជិតខាងជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ ...៕

៦. កាត់ផ្លូវជាតិលេខ២ បញ្ចៀសទឹកជំនន់ព្រែកស្នោតឲ្យហូរចូលបឹងជើងលោក

បើកការដ្ឋានសាងសង់សំណង់ផ្សេងៗ ក្នុងគម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយ-លូ ក្នុងរាជធានីភ្នំពេញ ជំហានទី៤, ៤ មីនា ២០១៩

... ឆ្នាំ២០០០ ទន្ទឹមនឹងជំនន់មេគង្គដ៏ធំ ហួសពីអ្វីដែលយើងគិតថាវា(អាចកើត)មានហើយក្នុង ៥០ឆ្នាំមានតែម្តង យើងត្រូវជួបប្រទះទឹកជំនន់ព្រែកស្នោតពីទិសខាងលិចមក វាយលុកចូលរាជធានីភ្នំពេញ ក្នុងខណ្ឌដង្កោ ... ព្រែកស្នោតមិនមានលទ្ធភាពគ្រប់(គ្រាន់ក្នុងការទទួល)ទឹកដែលហូរចុះមកខាងក្រោម ព្រោះវានៅត្បៀត។ អញ្ចឹង **ទឹកអាចបុកចូលរាជធានីភ្នំពេញ ហើយអាចចូលចំតំបន់រោងចក្រមួយចំនួន រាប់ទាំងសាកលវិទ្យាល័យចំការដូងផងដែរ។ ប្រមាណជាម៉ោង ២ភ្លឺ ខ្ញុំបានសម្រេចចិត្តឲ្យរដ្ឋមន្ត្រីក្រសួងធនធានទឹក (កាត់ផ្តាច់)ផ្លូវជាតិលេខ២ ម្តុំព្រែកទាំង ដើម្បីទម្លាក់ទឹកចូលទៅបឹងជើងលោកនៅខាងក្រាំងយ៉ូវ ដែលតភ្ជាប់នឹងទន្លេបាទី និងព្រែកឫស្សីរបស់ខេត្តតាកែវ** ...៕

៧. អន្តរាគមន៍លើការខ្វះទឹកស្រែប្រាំងនិងទឹកប្រើប្រាស់

ពិធីចែកសញ្ញាបត្រសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ១១ មីនា ២០១៩

... ខ្ញុំព្រះករុណាខ្ញុំបានចេញសារាចរមុននេះ ស្នើអោយប្រជាពលរដ្ឋធ្វើស្រូវប្រាំងតែមួយដងបានហើយ។ ប៉ុន្តែ ប្រជាពលរដ្ឋមួយចំនួនឧស្សាហ៍ ប្រើប្រាស់ទឹកដែលនៅសល់ហ្នឹងដើម្បីធ្វើស្រែប្រាំងបន្ត។ បន្ទាប់ពីច្រូតកាត់ម្តងហើយ គាត់ធ្វើម្តងទៀត។ ធ្វើដូចនេះ ទឹកដែលតម្កល់ទុកសម្រាប់ការប្រើប្រាស់ វានឹងខ្វះ។ ឥឡូវ **ក្រសួងធនធានទឹកនិងឧតុនិយម កំពុងតែធ្វើអន្តរាគមន៍ស្រោចស្រពស្រូវប្រាំងមួយចំនួន ដែលកំពុងរងការគំរាមកំហែង និងដែលសុំអោយអាជ្ញាធរមូលដ្ឋាន ក្រសួងធនធានទឹក និងមន្ទីរធនធានទឹក បន្តការខិតខំដោះស្រាយ។ ចំណុចត្រូវយកចិត្តទុកដាក់ធំជាងគេ គឺទឹកសំរាប់ប្រជាពលរដ្ឋប្រើប្រាស់** ...៕

៨. ខិតខំជីកអណ្តូង ប្រសើរជាងដឹកទឹកយកទៅពីចម្ងាយ

ពិធីចែកសញ្ញាបត្រសាកល វិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ១១ មីនា ២០១៩

... ឆ្នាំ២០១៦ យើងបានដឹកទឹកទៅជូនប្រជាពលរដ្ឋ ប៉ុន្តែបញ្ហាចំណោទពេលនោះ គឺថា អណ្តូងទឹកត្រូវរីងស្ងួតដែរ ... ថាជីក ៨ម៉ែត្រដល់ដង្ហើមទឹក(ដែលត្រូវ)ទឹកចេញ ក៏ប៉ុន្តែទឹកបានធ្លាក់ដល់ ១០ម៉ែត្រទៅក្រោម ធ្វើអោយអណ្តូងស្ងួតទាំងអស់។ យើងត្រូវដឹកទឹក(ទៅអោយប្រជាពលរដ្ឋ)។ ឆ្នាំនេះ **គ្រប់ទីកន្លែងទាំងអស់សូមអាជ្ញាធរយកចិត្តទុកដាក់ជីកអណ្តូង បើទោះបីថាជ្រៅបន្តិច ប្រសើរជាងដឹកទឹកទៅពីចម្ងាយ។ ការជីកអណ្តូង គឺជាមធ្យោបាយដែលល្អ។ ទោះបីជាឆ្នាំហ្នឹងមានទឹក ឆ្នាំក្រោយខ្វះទឹកក៏នៅមានអណ្តូងប្រើប្រាស់។** ដូច្នេះ បន្តការជីកអណ្តូងនៅទីកន្លែងដែលខ្វះទឹក។ យើងទៅដឹកទឹកពីចម្ងាយប្រើប្រាស់អស់ប្រេងច្រើន ... ដឹកទឹកមួយដើង បានទឹកមួយធុង តម្លៃស្មើនឹងថ្លៃជីកអណ្តូងមួយហើយ ...៕

៩. អន្តរាគមន៍ការជីកអណ្តូងតាមភូមិសំរាប់ក្រុមគ្រួសារនិងសហគមន៍

ពិធីចែកសញ្ញាបត្រសាកល វិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ១១ មីនា ២០១៩

... ត្រូវខិតខំដោះស្រាយបញ្ហានេះ លើកលែងតែកន្លែងខ្លះអត់មានដង្ហើមទឹក ដើម្បីជីកអណ្តូងអោយចេញ(ទឹក)។ ហ្នឹងយើងត្រូវបង្ខំចិត្តដឹកទឹកហើយ ដើម្បីទៅផ្គត់ផ្គង់អោយប្រជាជនប្រើប្រាស់។ ប៉ុន្តែ កន្លែងដែលមានដង្ហើមទឹក ត្រូវខិតខំប្រើប្រាស់ការជីកអណ្តូង។ កាលពីឆ្នាំ២០១៦ យើងជីកអណ្តូងបានរាប់ម៉ឺនតែនៅមិនទាន់ឆ្លើយតបគ្រប់ទៅនឹងសេចក្តីត្រូវការរបស់ប្រជាជនទេ។ ឥឡូវ **ពេលអត់ទឹកនេះ គឺ(ត្រូវដៀ្លយគាំទ្រ)ការខិតខំរបស់ប្រជាពលរដ្ឋដែលមានធនធាន ក្នុងការជីកអណ្តូងតាមក្រុមគ្រួសារខ្លួនឯងនិងតាមសហគមន៍ ដោយរដ្ឋធ្វើអន្តរាគមន៍ចំពោះការជីកអណ្តូងក្នុងភូមិ ពេលដែលប្រជាជនមិនមានលទ្ធភាព**។ សប្បុរសជនក៏អាចចូលរួមបាននៅក្នុងការជីកអណ្តូងនៅតាមទីកន្លែងខុសៗ គ្នា ...៕

១០. អាចនឹងកាត់ផ្លូវដែលទឹកបុក កសាងស្ពានធំជំនួសវិញ

សួរសុខទុក្ខប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារទឹកជំនន់ នៅខេត្តបន្ទាយមានជ័យ (ទីតាំងទី ១), ២១ តុលា ២០២០

... ក្នុងស្មារតីនៃការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ក៏ដូចជាគ្រប់ស្ថាប័នថ្នាក់ជាតិ យើងអាចដោះស្រាយបញ្ហារាប់ទាំងសំណូមពររបស់អភិបាលខេត្ត ទាក់ទងជាមួយនឹងការបើកផ្លូវទឹក។ ខ្ញុំយល់ស្របៗ ត្រូវធ្វើការជាមួយក្រសួងធនធានទឹក ជាមួយក្រសួងសាធារណការ។ **តំបន់ខ្លះ គឺស្ពានវាតូច។ យើងអាចកាត់ផ្តាច់ផ្លូវ ហើយកសាងស្ពានបន្ថែមជំនួសវិញ។ រឿងនេះវាមិនមែនរឿងថ្មីទេ។ ខ្ញុំបានឱ្យកាត់ផ្លូវជាតិលេខ១ ឆ្នាំ២០០០ ... ក្រោយមកជប៉ុនបានធ្វើធ្វើស្ពានឱ្យ។ ផ្លូវជាតិលេខ ២ ដែលហៅថា ព្រៃកវាំងនោះ ពីដើមវាតូចណាស់កន្លែងហ្នឹង។ ឥឡូវកាត់ឱ្យវាធំ** ...៕

១១. រកវិធីដោះស្រាយទឹកធ្លាក់ពីថៃទាំង ៣ប្រភព

សួរសុខទុក្ខប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារទឹកជំនន់ នៅខេត្តបន្ទាយមានជ័យ (ទីតាំងទី១), ២១ តុលា ២០២០

... ពេលដែលមានជំនន់ម្តង យើងសិក្សាបានម្តង ... ខ្ញុំបានមើលផែនទីហើយដើម្បីដោះស្រាយទឹកដែលធ្លាក់មកពីថៃ មាន ៣ចំណុច ដែលមួយនៅខាងអូរល្អុង ... បន្ទាប់ទៅអូរ ៣ជាន់ ... និងបន្ទាប់ទៅមានអូរកំបុត។ យើងបានរកឃើញចំណុចអស់ទាំងនេះ។ យើងនឹងរកវិធីដោះស្រាយ។ ប៉ុន្តែ ដែលហៅថាគ្រោះមហន្តរាយធម្មជាតិ គឺវាមានរឿងដូច្នេះឯង។ ពេលណាទឹកភ្លៀងខ្លាំងពីខាងលើក្នុងតែមួយម៉ោង ១០០ ឬ ២០០មីល្លីម៉ែត្រ គឺទប់អត់ជាប់ទេ កុំថាកូនព្រែកតូចសូម្បីតែទន្លេក៏ទប់មិនជាប់ដែរ ...៕

១២. កំណត់ទីតាំងក្នុងបឹងទន្លេសាបបូមស្តារបង្កើតជាជម្រករក្សានិងអភិរក្សពូជត្រី

ថ្លែងសារស្តីអំពីការគ្រប់គ្រងផ្ទៃបឹងទន្លេសាប, ២៧ ឧសភា ២០២២

... សូមអាជ្ញាធរបឹងទន្លេសាបសហការជាមួយក្រសួងធនធានទឹក ក្រសួង

កសិកម្ម រុក្ខានិងប្រមាញ់ ក៏ដូចជាបណ្តាខេត្តទាំង៦ ពិនិត្យមើលថា តើកន្លែងណាខ្លះដែលចាំបាច់ត្រូវបូមស្តារ ។ រៀងរាល់ឆ្នាំ ដីល្បាប់ហូរចូលទៅ បូកជាមួយនឹងការឆ្លាក់ចុះនៃស្លឹកឈើ ធ្វើអោយបឹងទន្លេសាបពីមួយថ្ងៃទៅមួយថ្ងៃ គោករាក់បន្តិចម្តងៗ ... ដោយហេតុនេះ កំដៅទឹកក្នុងបឹងទន្លេសាបកើនឡើង។ ដោយហេតុនេះ ការអភិរក្សពូជត្រីជាការលំបាក។ ដូច្នេះ **ដើម្បីធានាថារក្សាពូជត្រីបែបណានៅក្នុងបឹងទន្លេសាប ចាំបាច់ត្រូវកំណត់ទីតាំង ដើម្បីយើង(គិតគូរ)ជួយបូមស្តារនៅក្នុងតំបន់នោះ អោយមានជម្រៅទឹកជ្រៅ ធានាថាក្នុងរដូវប្រាំង ត្រីអាចមានលទ្ធភាពចូលទៅរស់ និងជាជម្រករក្សាអភិរក្សពូជត្រី** ...។

១៣. ទំនប់ដំណាក់អំពិល ទំនប់ចារឹក ផ្តល់ទឹកសំរាប់រដូវប្រាំង នៅពោធិ៍សាត់

សំណេះសំណាលជាមួយប្រជាពលរដ្ឋ និងពិនិត្យការដ្ឋានសំណង់វារីអគ្គិសនីស្ទឹងពោធិ៍សាត់១ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់, ១៤ មីនា ២០២៣

... ខ្ញុំចង់អោយកើតទំនប់ដំណាក់អំពិលតាំងពីឆ្នាំ១៩៨៦ គឺតាំងពីអ្នកមួយចំនួននៅទីនេះមិនទាន់កើតផង ... ខ្ញុំបានទៅមើលទំនប់ដំណាក់អំពិលដែលពួកខ្មែរក្រហមកសាង ប៉ុន្តែអត់ត្រូវស្តែងដារ។ ពេលហ្នឹងទើបវាយគ្នាថ្មីៗ ក្នុងស្រុកបាកាន ... ខ្ញុំបានប៉ុនប៉ងថានឹងធ្វើទំនប់ដំណាក់អំពិល(ឱ្យបាន) ... **ចុះពីហ្នឹងទៅមុនទម្លាក់ទឹកទៅទន្លេសាប មានទំនប់ចារឹក។ ខ្ញុំប្រកាស(សាងសង់)ទំនប់ចារឹកពីកង់ប៉េរ៉ា រដ្ឋធានីនៃប្រទេសអូស្ត្រាលី ... យើងចុះហត្ថលេខាលើគម្រោងរ៉ែបុកស៊ីត។ ក្រុមហ៊ុនបានផ្តល់សួយសារ ៥លានដុល្លារ។ (ខ្ញុំ)ថាត្រូវយក ៥លានដុល្លារនោះ ចូលសង់ទំនប់ចារឹក ... យោងតាមការសិក្សា ពេលដែលសាងសង់ហើយ ទំនប់(វារីអគ្គិសនី)ស្ទឹងពោធិ៍សាត់មួយនេះនឹងកាត់បន្ថយការលិចលង់ទីរួមខេត្តនៅរដូវវស្សា ហើយទម្លាក់ទឹកនៅរដូវប្រាំង**បានយ៉ាងល្អ ...។

១៤. ដីស្រោចស្រពកើនពី៧% ដល់៦២%, ទំនប់ប្រឡាយជួយបង្កើនមច្ឆជាតិ

សំណេះសំណាលជាមួយ កម្មករនៅស្រុកបាទី ខេត្តតាកែវ, ១៩ កញ្ញា ២០២៣

... ឡូត៍នេសាទបានផ្តល់ឱកាសសម្រាប់ប្រជាពលរដ្ឋ ហើយអំណោយផលពីការដែលយើងបានធ្វើប្រព័ន្ធធារាសាស្ត្រច្រើន ដែលក្នុង**ទសវត្សរ៍៨០ ផ្ទៃដីដែលគ្របដណ្តប់ដោយប្រព័ន្ធស្រោចស្រពមានប្រហែលជា៧% តឡូវបានឡើងទៅ**

ជាង៦២%ទៅហើយ។ តាមរយៈប្រព័ន្ធធារាសាស្ត្រ ក៏ដូចជាទំនប់ ប្រឡាយដែលយើងបានធ្វើ ក៏បានជាផ្នែកមួយនៃការបង្កើនមច្ឆជាតិដែរ។ យើងធ្វើទិវាលែង(កូន)ត្រី ដែលមួយឆ្នាំៗយើងលែងរាប់លានកូន ដែលនោះជាត្រីសម្រាប់ប្រជាពលរដ្ឋទទួលផល តែកុំចាប់ក្នុងពេលវេលាហាមឃាត់ គឺពេលត្រីពង ...។

១៥. បន្តវិនិយោគលើទឹកស្រោចស្រព ដើម្បីផ្ទៃដីដាំដុះ ១ហិកតាក្លាយជា ២ឬ៣ហិកតា

ពិធីចែកសញ្ញាបត្រគ្រឹះស្ថានឧត្តមសិក្សាកសិកម្ម៣ គឺភូមិន្ទកសិកម្ម, កសិកម្មព្រៃកលាប, កសិកម្មកំពង់ចាម, ១៣ ឧសភា ២០២៣

... ក្នុងប្រធានបទស្តីពីការផ្ទេរពីការអភិវឌ្ឍតាមបែបបើកទូលាយ ទៅកាន់ការអភិវឌ្ឍបែបស៊ីជម្រៅ ការដោះស្រាយទឹកត្រូវតែបន្តធ្វើដើម្បីឲ្យកសិកររយើងគឺអាចធ្វើស្រូវបានច្រើនដង។ ពេលជិះឧទ្ធម្ភាចក្រជាមួយគ្នាពីភ្នំពេញទៅបន្ទាយមានជ័យ **ខ្ញុំបានចង្អុលចុះទៅក្រោមប្រាប់អតីតប្រធានធនាគារអភិវឌ្ឍអាស៊ីថា "នេះជាសក្តានុពលនៅសេសសល់របស់ខ្ញុំ" ... គាត់បង្ហាញអារម្មណ៍ងឿងឆ្ងល់ ហេតុអ្វីជញ្ជាំងស្រូវរាងនៅជាសក្តានុពល។ ខ្ញុំថា "កសិកររទើបនឹងធ្វើបានមួយដង។ ប្រសិនបើខ្ញុំដោះស្រាយទឹកបាន ប្រជាកសិករនឹងធ្វើបាន២ ដង ឬ៣ ដង។ អញ្ចឹងមួយហិកតារបស់ខ្ញុំ ក្លាយទៅជា២ ហិកតា ឬ៣ ហិកតា។ ហ្នឹងហើយជាសក្តានុពល" ... យើងត្រូវបន្តវិនិយោគលើទឹក(ស្រោចស្រព)នេះ។** មានទឹកហើយ បើមិនកែទម្លាប់ពីការប្រើប្រាស់ពូជល្អ ទិន្នផលខ្ពស់ វិធីដាំដុះឲ្យល្អ ក៏នៅតែទៅមិនរួច។ មានផលិតផលហើយ តែបើខ្វះទីផ្សារក៏នៅតែទៅមិនរួច។ អញ្ចឹងទេ មានសំណុំបញ្ហារបស់វាពីក្បាលដល់ចុងជើង ...។

១០. ធម្មការៈ និងសាសនា

១	អារាមនានាគួរស្រាវជ្រាវចងក្រងសៀវភៅប្រវត្តិវត្ត	១៨៩
២	សង្គ្រាមនិងរបប ប៉ុល ពត បានបំផ្លាញគ្រប់សាសនាដល់ឫសគល់	១៨៩
៣	ទន្ទឹមនឹងប្រជាជនរស់ឡើងវិញ សាសនាទាំងអស់ក៏បានកើតស្របពេលគ្នា	១៨៩
៤	ក្រោយថ្ងៃ ៧មករា១៩៧៩ សាសនាកើតឡើងវិញ មានសុខដុមភាវូបនីយ៍កម្ម	១៩០
៥	និក្ខេបបទវិទ្យាសាស្ត្រនយោបាយ "ផលប្រយោជន៍រវាងសាសនានិងសង្គមរដ្ឋ"	១៩០
៦	ការបង្កើតសាសនាឡើងវិញ ក្រោយរបប ប៉ុល ពត មិនមែនជាអំពើប្រជាភិថុតិ	១៩១
៧	ជីវសាអ៊ីងពូជសាសន៍ មិនមែនជាគោលនយោបាយ ... ការដឹកនាំរបស់ ហ៊ុន សែន ទេ	១៩១
៨	ការដឹកនាំត្រឹមត្រូវក្នុងផ្នែកអាណាចក្រ បង្កើតជាលទ្ធភាពអភិវឌ្ឍខាងសាសនា	១៩២
៩	ការប្រតិបត្តិសាសនា បញ្ជាក់ពីអត្ថិភាពសុខសន្តិភាព និងជីវភាពប្រជាជន	១៩២
១០	បើមិនអាចរក្សាសុខសន្តិភាពបាន កុំនិយាយពីការរីកចម្រើននៃវិស័យសាសនា	១៩៣
១១	ទីអារាមដើរតួសំខាន់ក្នុងការផ្តល់ប្រយោជន៍សម្រាប់សង្គមជាតិ	១៩៣
១២	ទទួលពរជ័យពីគ្រប់សាសនា តែសាសនាព្រះពុទ្ធនៅតែជាសាសនារបស់ជាតិ	១៩៤
១៣	"ជាតិ សាសនា ព្រះមហាក្សត្រ" ជាបាវចនារំលឹកគ្រប់គ្នានិងគ្រប់ពេលវេលា	១៩៤
១៤	សាសនាខុសគ្នា តែគោលដៅគឺការស្វែងរកសេរីភាព និងអ្វីដែលមនុស្សលោកត្រូវការ	១៩៥
១៥	ព្រះសង្ឃពុទ្ធសាសនាខិតខំរួមចំណែកក្នុងសកម្មភាពមនុស្សធម៌	១៩៥
១៦	ចំនួនព្រះសង្ឃព្រះពុទ្ធសាសនាច្រើនជាងពេទ្យនិងស្មើពាក់កណ្តាលចំនួនទ័ព	១៩៥
១៧	ចងក្រងនិងដំណើរការសហគមន៍អាចារ្យឲ្យបានទូលំទូលាយទូទាំងប្រទេស	១៩៦
១៨	អាចារ្យគោរពបាននាក្រម ជួយដល់ពុទ្ធបរិស័ទនិងគាំទ្រព្រះសង្ឃគ្រប់គ្រងទីអារាម	១៩៦
១៩	អាចារ្យអាចារិនី ត្រូវសម្របសម្រួលតម្រូវការ ចៀសវាងប្រកាន់បក្សពួកឬរីសអ៊ីង	១៩៧
២០	អាចារ្យត្រូវមានការប្តេជ្ញាចិត្តចំពោះពុទ្ធសាសនា ប្រពៃណីទំនៀមទម្លាប់ប្រកបដោយធម៌	១៩៧
២១	បណ្តុះបណ្តាលធនធានមនុស្សមិនតែក្នុងវិស័យសាសនាតែក៏មុខវិជ្ជាចំណេះទូទៅ	១៩៧
២២	ផ្តល់ក្របខណ្ឌគ្រូបង្រៀនក្នុងសហគមន៍អ៊ីស្លាម ព្រោះជាតម្រូវការអភិវឌ្ឍសង្គម	១៩៨
២៣	សិស្សស្រីឥស្លាមអាចស្លៀកពាក់ប្រពៃណីនិងថតរូបមិនបាច់ចេញស្លឹកត្រចៀក	១៩៨
២៤	ភាពជ្រុលនិយមមិនមែនជាបញ្ហាសំរាប់ជាតិសាសន៍ឬសាសនាណាតែមួយទេ	១៩៩
២៥	នឹងនៅតែមានពិធីស្រាយបួសដរាបណាគណបក្សប្រជាជនកាន់អំណាច	១៩៩

២៦	ឥស្លាមសាសនាបណ្តុះបណ្តាលបច្ចេកវិទ្យា/មុខជំនាញដើម្បីការងារ/មុខរបរ ...	២០០
២៧	ឥស្លាមកម្ពុជាមានចំនួនតិចតែសហគមន៍ធំទូលាយ មានទំនាក់ទំនងច្រើនប្រទេស	២០០
២៨	សូមប្រទេស OIC ជួយទិញទំនិញ និងផ្តល់ទីផ្សារការងារដល់ឥស្លាមកម្ពុជា	២០១
២៩	សង្ឃឹមថាគ្រីស្ទសាសនិក រួមចំណែកអប់រំកុំឲ្យប្រព្រឹត្តគ្រឿងញៀន	២០១
៣០	សូមអប់រំគោរពច្បាប់ចាចារ៉ៈដល់គ្រីស្តសាសនិកដើម្បីធានាសុវត្ថិភាពផ្ទាល់ខ្លួន	២០២
៣១	ធ្វើសុខដុមភាពបនីយកម្មផ្ទៃក្នុងគ្រីស្តសាសនា និងជាមួយសាសនាដទៃ	២០២
៣២	បណ្តុះបណ្តាលសមត្ថភាពធនធានមនុស្សក្នុងសាសនាកសាងសង្គមជាតិ និងគ្រួសារ	២០៣
៣៣	រៀបចំតំណាងគ្រីស្តបរិស័ទសំរាប់សន្ទនាជាមួយសាសនាដទៃនិង/ឬអាជ្ញាធររដ្ឋ	២០៣
៣៤	អ្នកប្រៀនប្រដៅសាសនាផ្តល់ការណែនាំអនុវត្តនយោបាយភូមិឃុំមានសុវត្ថិភាព	២០៤

១. អារាមនានាគួរស្រាវជ្រាវចងក្រងសៀវភៅប្រវត្តិវត្ត

ពិធីកាត់ឫសសីមាព្រះវិហារ និងសម្ពោធសមិទ្ធផលក្នុងវត្តព្រៃកប្រា, ៨ កុម្ភៈ ២០១៧

... មានមោទនភាពចំពោះការរីកចម្រើននៃទីអារាមវ័យចំណាស់នេះ ... មុនពេលកាត់ឫសសីមា និងការសម្ពោធដាក់អោយប្រើប្រាស់ មានការស្រាវជ្រាវចងក្រងសៀវភៅមួយនេះ ដែលខ្ញុំព្រះករុណាខ្ញុំមានការពេញចិត្ត។ រឿងនេះ ក៏បានធ្វើជាហូរហែមក។ សង្ឃឹមថា **តាមទីអារាមដទៃទៀតដែលមិនទាន់បានធ្វើ គួរតែធ្វើសៀវភៅមួយៗទៅតាមទីអារាមរបស់ខ្លួន។ បើមានការកត់ត្រាបែបនេះ យើងនឹងអាចដឹងបានពីប្រវត្តិ នៃការកកើតទីអារាមនេះ ពីដំណាក់កាលមួយទៅកាន់ដំណាក់កាលមួយ។ បើយោងទៅលើការកត់ត្រានៅក្នុងនេះ ទីអារាមនេះ មានអាយុរហូតទៅដល់ ២២៦ឆ្នាំ** ... ដែលយើងបានធ្វើបុណ្យរួមគ្នា ប្រហែលជាមាននិស្ស័យពីជាតិមុនមក ហើយសង្ឃឹមថាជាតិក្រោយជួបគ្នា ធ្វើបុណ្យជាមួយគ្នាទៀត បានរួមដំណើរជាមួយគ្នាអញ្ចឹងទៅ ...។

២. សង្គ្រាមនិងរបប ប៉ុល ពត បានបំផ្លាញគ្រប់សាសនាដល់ឫសគល់

ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារថ្មី វត្តសិរីសោភ័ (ហៅវត្តកំពង់ត្របែក)
ឃុំ-ស្រុកកំពង់ត្របែក, ១០ មីនា ២០១៧

... **ទីអារាមនៅទូទាំងប្រទេសរបស់យើង បើទោះបីជាមានវ័យចំណាស់ប៉ុណ្ណាក៏ដោយ ដែលកើតមុនឆ្នាំ ១៩៧០ ត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាម និងដោយរបប ប៉ុល ពត។ សាសនាទាំងអស់ មិនថាព្រះពុទ្ធសាសនា អ៊ីស្លាមសាសនា គ្រីស្តសាសនា និងសាសនាដទៃទៀត សុទ្ធតែត្រូវបានបំផ្លាញឫសគល់នៅក្នុងដំណាក់កាលនៃសម័យ ប៉ុល ពត** ។ ប៉ុន្តែ ពេលដែលយើងរំដោះ(ប្រទេស)នៅឆ្នាំ ១៩៧៩ គណបក្សប្រជាជនកម្ពុជា រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នៅពេលនោះ បានអនុញ្ញាត ផ្តល់ឱកាសអោយប្រជាជនមានជំនឿឡើងវិញ ទៅតាមអ្វីដែលជាចំណង់ចំណូលចិត្តរបស់ប្រជាជន ដែលពួក គេចង់ជឿ ...។

៣. ទន្ទឹមនឹងប្រជាជនបានរស់ឡើងវិញ សាសនាទាំងអស់ក៏បានកើតស្របពេលគ្នា

ពិធីសម្ពោធវិហារឥស្លាមជើមៀក, ០៤ កញ្ញា ២០១៧

...កុំភ្លេច តាសុស និយាយត្រូវណាស់ ។ តាសុស នៅឯពោធិសាត់ ។ គាត់ទៅតាមរកផ្ទះខ្ញុំដល់តាខ្មៅ ។ គាត់ថាមករកមេ។ តា រស់ ស្រែង បានសួរគាត់ មើលតាសុស តើឥស្លាមសានា និងព្រះពុទ្ធសាសនា មួយណាបងមួយណាប្អូន? តាសុស ឆ្លើយថា **"អត់មានមួយណាបងមួយណាប្អូនទេ ត្បិតកើតថ្ងៃតែមួយជាមួយគ្នា ខែតែមួយជាមួយគ្នា និងឆ្នាំតែមួយជាមួយគ្នា គឺ ៧ មករា ១៩៧៩"។ នេះជាចម្លើយជាក់ស្តែងបំផុត។ ក្នុងដំណាក់កាលគ្រប់គ្រងរបស់ពួកប៉ុល ពត សាសនាទាំងអស់ត្រូវបានបំផ្លាញហើយ។ ទន្ទឹមនឹងការរស់ឡើងវិញរបស់ប្រជាជន សាសនាទាំងអស់ក៏បានកើតឡើងស្របពេលតែមួយ គឺថ្ងៃ ៧ មករា ១៩៧៩** ...។

៤. ក្រោយថ្ងៃ ៧ មករា ១៩៧៩ សាសនាកើតឡើងវិញ និងមានសុខដុមភាវូបនីយ៍កម្ម

ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារថ្មី វត្តសិរីសោភ័ (ហៅវត្តកំពង់ត្របែក)
ឃុំ-ស្រុកកំពង់ត្របែក, ១០ មីនា ២០១៧

... ពីដំណាក់កាលមួយទៅកាន់ដំណាក់កាលមួយ ដែលធ្វើអោយមានការផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅក្នុងសង្គមជាតិ។ **ក្រោយថ្ងៃរំដោះ (៧ មករា ១៩៧៩) រហូតមកដល់ពេលនេះ យើងមានឱកាសធ្វើបុណ្យធ្វើទានទៅតាមប្រពៃណីជាតម្រូវការរបស់ប្រជាពលរដ្ឋ** ដែលមុននោះ មិនត្រឹមតែមិនបានធ្វើបុណ្យទេ ក៏ប៉ុន្តែទីអារាមទាំងឡាយត្រូវបានបំផ្លាញ ព្រះសង្ឃត្រូវបានធ្វើគត់ ឬចាប់ផ្សឹក។ យើងបានកសាងទីអារាមនៅទូទាំងព្រះរាជាណាចក្រកម្ពុជា រហូតទៅដល់ (ចំនួន) ជាង ៤.០០០វត្ត ហើយមានព្រះសង្ឃរហូតដល់ជាង ៥០.០០០អង្គ។ ជាមួយគ្នានេះ **ព្រះវិហារសាសនាអឺស្លាម គ្រីស្តសាសនា និងផ្នែកជំទៃទៀតក៏បានកើតឡើងជាបន្តបន្ទាប់ ដោយមានសុខដុមភាវូបនីយកម្មក្នុងនេះផង** ...។

៥. និក្ខេបបទវិទ្យាសាស្ត្រនយោបាយ៖ "ផលប្រយោជន៍ទៅវិញទៅមកវាងសាសនានិងសង្គមរដ្ឋ"

ជួបសំណេះសំណាលជាមួយនឹងអាចារ្យ អាចារិនី លើកទី៨, ០៨ មេសា ២០២៣

... បើយើងនិយាយក្នុងក្របខណ្ឌតូចចង្អៀតរវាងប្រទេសមួយ ដែលកាន់ព្រះពុទ្ធសាសនា យើងអាចនិយាយបានក្នុងកម្រិតថា ពុទ្ធចក្រនិងអាណាចក្រ ប៉ុន្តែបើយើងនិយាយទំយទូលាយជាងទៀត ដោយសារប្រទេសយើងមិនមែនមានត្រឹមតែព្រះពុទ្ធសាសនាទេ យើងមានឥស្លាមសាសនា គ្រិស្តសាសនា និងមានអ្នកដែលគោរពជំនឿដ៏ទៃទៀត គឺយើងអាចនិយាយពីតួនាទីសាសនាជាមួយរដ្ឋ ឬសាសនាជាមួយសង្គម។ នេះជាទំនាក់ទំនងចៀសមិនដាច់ ... **ខ្ញុំបានពិនិត្យនិក្ខេបបទបណ្ឌិតវិទ្យាសាស្ត្រនយោបាយ ដែលខ្ញុំបានសរសេរកាលពីជាង ៣០ឆ្នាំមុន ... អំពីទំនាក់ទំនងរវាងសាសនាជាមួយសង្គម, សាសនាជាមួយរដ្ឋ និងអំពីផលប្រយោជន៍ដែលទាំងសងខាងទទួលបាន** ...។

៦. ការបង្កើតសាសនាឡើងវិញ ក្រោយការបំបាត់ចោលដោយរបប ប៉ុល ពត មិនមែនជាអំពើប្រជាភិថុតិ

ជួបសំណេះសំណាលជាមួយនឹងអាចារ្យ អាចារិនី លើកទី៨, ០៨ មេសា ២០២៣

... យើងអាចនិយាយបានថា **(ចំណងទាក់ទង)រវាងសាសនានិងរដ្ឋ ឬនិយាយតាមច្រកចង្អៀតបន្តិចថា រវាងពុទ្ធចក្រនិងអាណាចក្រ មិនអាចផ្តាច់ចេញពីគ្នាបានទេ ... (ហេតុនេះ)ទើបយើងខិតខំរួមគ្នាបង្កើតឱ្យមានសាសនាឡើងវិញ បន្ទាប់ពីសាសនាទាំងអស់នៅកម្ពុជា ត្រូវបានរបប ប៉ុល ពត បំបាត់ចោល។ (ការប្រឹងប្រែងនោះ)មិនមែនជាការចែជន្យ ឬប្រជាភិថុតិទេ ប៉ុន្តែគឺ (ប្តូរផ្តាច់របស់) គណបក្សប្រជាជនកម្ពុជា** ដឹកនាំតាំងពីមុនពេលរំដោះ បង្កើតជារណសិរ្ស មានព្រះសង្ឃតំណាងក្នុងជួរថ្នាក់ដឹកនាំរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ...។

៧. ការរើសអើងពុជសាសន៍ មិនមែនជាគោលនយោបាយរបស់គណបក្សប្រជាជន ឬការដឹកនាំរបស់ ហ៊ុន សែន ទេ

ពិធីពិសារអាហារស្រាយបួសវ៉ាម៉ាឌុន, ១៥ មិថុនា ២០១៧

... បើអត់ពីខ្ញុំទៅ ទោះអ្នកណាក៏ដោយដែលជាសមាជិកគណបក្សប្រជាជនហើយឡើងមកបន្តតួនាទី (ដឹកនាំ) នេះ សូមកុំភ្លេចនយោបាយដែលយើងបានប្រកាន់ខ្ជាប់ជាង ៣៨ឆ្នាំរួចមកហើយ។ មិនមែនជានយោបាយកញ្ឆក់កណ្តៀត

នោះទេ តែជានយោបាយអមតៈរបស់គណបក្សប្រជាជន។ យើងមានគោលនយោបាយចំពោះជនជាតិ គោលនយោបាយចំពោះសាសនា គោលនយោបាយតាមវិស័យ និងតាមអនុវិស័យផងដែរ ... អ្នកជំនាន់ក្រោយគប្បីយកចិត្តទុកដាក់ពីសុខដុមភាវូបនីយ៍កម្មរវាងជាតិ សាសន៍ និងសាសនា ក៏ដូចជាផ្តល់នូវបទពិសោធន៍ និងការចងចាំថា ប្រទេសមួយនេះមិនត្រូវឯងការកើតកលយុគ្គ ឬក៏ជម្លោះសាសនា និងជាតិសាសន៍នោះទេ។ **ការប្រកាន់ពូជសាសន៍ និងការរើសអើង មិនមែនជាគោលនយោបាយរបស់គណបក្សប្រជាជនទេ ហើយវាកាន់តែជាមិនមែនជាការដឹកនាំរបស់ ហ៊ុន សែន ទៀតផង** ...។

៨. ការដឹកនាំត្រឹមត្រូវក្នុងផ្នែកអាណាចក្រ បង្កើតជាលទ្ធភាពអភិវឌ្ឍខាងសាសនា

ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារថ្មី វត្តសិរីសោគរ (ហៅវត្តកំពង់ត្របែក)
ឃុំ-ស្រុកកំពង់ត្របែក, ១០ មីនា ២០១៧

... គឺ**សន្តិភាពនោះហើយ ដែលផ្តល់ឱកាសឲ្យព្រះតេជព្រះគុណ ឲ្យខាងសាសនិកឥស្លាម ឲ្យគ្រីស្តសាសនិកនិងសាសនាជទៃទៀតមានលទ្ធភាពអភិវឌ្ឍ។ តាមរយៈភាពត្រឹមត្រូវនៃការដឹកនាំអាណាចក្រ គឺបក្សនយោបាយដឹកនាំត្រឹមត្រូវទើបបង្កើតឲ្យមានស្ថានភាពបែបនេះ។ កត្តាសំខាន់ស្ថិតត្រង់ថា តើពីដំបូងបំផុតបក្សនយោបាយដែលដឹកនាំរដ្ឋនោះ រាជរដ្ឋាភិបាលនោះ ផ្តល់លទ្ធភាពប៉ុណ្ណាឲ្យប្រជាពលរដ្ឋសម្រាប់ (ការប្រតិបត្ត)ជំនឿ**។ នៅប្រទេសខ្លះ បើក (សើរីភាពឱ្យសាសនា) ព្រះពុទ្ធ ប៉ុន្តែមិនបើកឲ្យឥស្លាម មិនបើកឲ្យគ្រីស្តទេ ឬបើកឲ្យគ្រីស្តសាសនា ប៉ុន្តែមិនបើកឲ្យព្រះពុទ្ធសាសនា ឬឥស្លាមសាសនាទេ ...។

៩. ការគោរពប្រតិបត្តិសាសនា បញ្ជាក់ពីអត្ថិភាពសុខសន្តិភាព និងជីវភាពប្រជាជន

ពិធីជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំគ្រឹស្តសាសនាដើម្បីពង្រឹង
សុខដុមភាវូបនីយ៍កម្មវិស័យគ្រីស្តសាសនានៅកម្ពុជា, ២៥ ឧសភា ២០១៧

... ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា សាសនាទាំងអស់នៅកម្ពុជាសុទ្ធតែបានរស់ឡើងវិញ បន្ទាប់ពីត្រូវបានសម្លាប់ និងបំផ្លិចបំផ្លាញដោយសង្គ្រាម និងដោយរបបប្រល័យពូជសាសន៍ ប៉ុល ពត។ សាសនាទាំងអស់បានរីកចម្រើនពីគំនរផេះផង់ ... **ដែលព្រះពុទ្ធសាសនា អ៊ីស្លាមសាសនា និងគ្រីស្តសានាបានគោរព (ប្រតិបត្តិ) បូជាតាមជំនឿរៀងៗខ្លួន) នោះជាអ្វីទៅ? គឺវាបញ្ជាក់ច្បាស់ថា សុខសន្តិភាពបានកើតមានពិតប្រាកដនៅលើទឹកដីនេះ ហើយជីវភាពប្រជាជនក៏ត្រូវបានកែលំអ**។ ទំនាក់ទំនងសាសនាជាមួយការគ្រប់គ្រងរដ្ឋ បេះមិនជាប់ពីគ្នាទេ។ ប្រសិនបើនយោបាយរបស់រាជរដ្ឋាភិបាលមិនបើកចំហសម្រាប់ការគោរពរបស់ប្រជាជនទេ ច្បាស់ជាមិនអាច (មានការប្រតិបត្តិ) បែបនេះបានទេ ...។

១០. បើមិនអាចរក្សាសុខសន្តិភាពបាន កុំនិយាយពីការរីកចម្រើននៃវិស័យសាសនា

សំណេះសំណាល និងពិសាបាយសាមគ្គីជាមួយគ្រីស្តបរិស័ទ, ១២ តុលា ២០១៩

... ចូរយើង **រួមគ្នាការពារសន្តិភាព សន្តិសុខសណ្តាប់ធ្នាប់សង្គម ... ប្រសិនបើមិនអាចរក្សាបានសុខសន្តិភាពទេ យើងកុំនិយាយទៅដល់ការរីកចម្រើននៃវិស័យសាសនា។ បទពិសោធន៍របស់កម្ពុជាខ្លួនឯង ល្មមគ្រប់គ្រាន់ណាស់ទៅហើយ**។ សង្គ្រាមបំផ្លិចបំផ្លាញចាប់ពីឆ្នាំ ១៩៧០ និងក្នុងកាលៈទេសៈនៃរបប ប៉ុល ពត សាសនាទាំងអស់នៅកម្ពុជាទាំងអស់ត្រូវបានស្លាប់។ នៅពេលប្រទេសដែលមានសង្គ្រាម សួរថាតំបន់អសន្តិសុខដោយសង្គ្រាមនោះ សាសនាអាចនឹងគោរពប្រតិបត្តិបានឬទេ? ... ដំបូងបំផុត បើចង់និយាយថាត្រូវការរស់រានមានជីវិត ត្រូវការការអភិវឌ្ឍ យើងមិនត្រូវភ្លេចនិយាយពីការពារសន្តិភាពឲ្យបានជាមុនទេ ...។

១១. ទីអារាមដើរតួសំខាន់ក្នុងការផ្តល់ប្រយោជន៍សម្រាប់សង្គមជាតិ

ពិធីសម្ពោធសមិទ្ធផលនានា ក្នុងវត្តឈូកវ៉ា, ៥ មីនា ២០១៨

... អាចចាត់ទុកថា **ទីអារាមជាផ្នែកមួយដ៏សំខាន់ក្នុងការបន្តអនុវត្តគោលនយោបាយសម្រាប់មនុស្សចាស់ ហើយក៏បន្តការអនុវត្តគោលនយោបាយសម្រាប់កុមារ និងយុវជនក្រីក្រ**។ ទីអារាមបានក្លាយទៅជាដម្រកសុវត្ថិភាពសម្រាប់លោកយាយ លោកតា ក្នុងពេលដែលចាស់ទៅ ហើយដែលត្រូវការសុំសីល់សុំទាន មួយចំនួនក៏ត្រូវបានមកស្នាក់នៅនឹងទីអារាម។ **កុមារ និងយុវជនមួយចំនួនដែលខ្វះលទ្ធភាពក៏បានប្រើប្រាស់ទីអារាម (ជាទីជ្រកកោន) ដោយចំនួនក៏បានបួស ហើយបន្តការសិក្សា។ ឯមួយចំនួនក៏បានមកស្នាក់នៅតាមទីអារាម ដើម្បីបានបន្តការសិក្សា**។

ទាំងអស់នោះជាផលប្រយោជន៍សម្រាប់សង្គមជាតិ ...។

១២. ទទួលពរជ័យពីគ្រប់សាសនា តែសាសនាព្រះពុទ្ធនៅតែជាសាសនារបស់ជាតិ

ពិធីស្រោចសុគន្ធវារីប្រគេនសម្តេចកិត្តិយស ៣ ព្រះអង្គ, ២៤ ឧសភា ២០១៨

... ដោយសារតែបានដឹងពីការលំបាកក្នុងដំណើរជីវិតនាពេលកន្លងទៅ ចាប់តាំងពីខ្ញុំព្រះករុណាខ្ញុំ នៅជាអតីតក្មេងវត្តម្នាក់ ... ពេលដែលទទួលតួនាទីជាអ្នកដឹកនាំ (ប្រទេស) ខ្ញុំព្រះករុណាខ្ញុំមិនដែលភ្លេចម្តងណាឡើយ ពីតួនាទីមិនអាចមើលរំលងបានរបស់វិស័យព្រះពុទ្ធសាសនានេះ។ ខ្ញុំព្រះករុណាខ្ញុំ ធ្លាប់បាននិយាយថា ខ្ញុំព្រះករុណាខ្ញុំ **ទទួលពរជ័យពីគ្រប់សាសនាទាំងអស់ ទាំងពីព្រះពុទ្ធសាសនា ទាំងពីអ៊ីស្លាមសាសនា និងទាំងពីគ្រីស្តសាសនា។ ប៉ុន្មានថ្ងៃមុន ខ្ញុំបានទៅជួបខាងគ្រីស្តសាសនា។ ប៉ុន្មានថ្ងៃខាងមុខនេះ ក៏ត្រូវទៅចូលរួមពិធីស្រាយបួស (នៃអ៊ីស្លាមសាសនា) ដែរ។ យ៉ាងណាក៏ដោយ ព្រះពុទ្ធសាសនានៅតែជាសាសនាសំខាន់របស់ជាតិ ...។**

១៣. បាវចនា "ជាតិ សាសនា ព្រះមហាក្សត្រ" ជាការរំលឹកគ្រប់គ្នានិងគ្រប់ពេលវេលា

ពិធីស្រោចសុគន្ធវារីប្រគេនសម្តេចកិត្តិយស ៣ ព្រះអង្គ, ២៤ ឧសភា ២០១៨

... ដើម្បី**អនុវត្តបាវចនា "ជាតិ សាសនា ព្រះមហាក្សត្រ" កន្លែងធ្វើការទាំងឡាយ និងកន្លែងដទៃ ត្រូវរៀបចំទង់ទាំងបីគឺទង់ជាតិ ទង់សាសនា និងទង់ព្រះមហាក្សត្រ ព្រមទាំងព្រះឆាយាលក្ខណ៍របស់ព្រះមហាក្សត្រ ដើម្បីអោយយើងគ្រប់គ្នារំលឹកគ្រប់ពេលវេលាថា យើងស្ថិតនៅក្រោមម្លប់បាវចនា ជាតិ សាសនា ព្រះមហាក្សត្រ** ... តាមទីកន្លែងធ្វើការនៃមន្ត្រីយើងសព្វថ្ងៃ និងនៅទីកន្លែងមួយចំនួនផ្សេងទៀត មាន (ការតាំង) ព្រះឆាយាលក្ខណ៍ព្រះមហាក្សត្រ មានទង់ជាតិផង ទង់សាសនាផង និងទង់ព្រះមហាក្សត្រផង ... ជាការរំលឹកដល់ជនគ្រប់រូប ... ថាមិនមែនមានតែព្រះសង្ឃគង់នៅទីនេះទេ ប៉ុន្តែមានទង់តំណាងឲ្យសាសនា ... មិនមែនមានតែព្រះឆាយលក្ខណ៍របស់ព្រះមហាក្សត្រទេ ប៉ុន្តែមានទង់ព្រះមហាក្សត្រ ហើយក៏មានទង់ជាតិ ...។

១៤. កាន់សាសនាខុសគ្នា តែមានគោលដៅដូចគ្នា គឺការរស់រានមានជីវិត មានសេរីភាពនិងមានអ្វីៗដែលមនុស្សលោកត្រូវការ

សំណេះសំណាល និងពិសាបាយសាមគ្គីជាមួយគ្រីស្តបរិស័ទ, ១២ តុលា ២០១៩

... យើងត្រូវផ្តល់ការគោរពចំពោះសិទ្ធិសេរីភាព និងជំនឿសាសនានានា ... តែអ្វីដែលយើងចង់បាន និងដែលយើងបានឃើញច្បាស់ហើយគឺ *"ការខុសគ្នាខាងសាសនា មិនមែនជាឧបសគ្គរារាំងការរក្សាសន្តិភាព និងការអភិវឌ្ឍប្រទេសទេ។ ប្រសិនបើគ្មានការបៀតបៀនរវាងគ្នានិងគ្នា ហើយធ្វើសុខដុមភាវូបនីយកម្មជាមួយគ្នា វានឹងមិននាំទៅដល់ការរំខានណាមួយក្នុងដំណើរឈានទៅមុខឡើយ"*។ យើងអាចនៅក្នុងបន្ទប់ធ្វើការជាមួយគ្នា នៅក្នុងការដ្ឋានសំណង់ជាមួយគ្នា នៅតាមវាលស្រែ និងរោងចក្រជាមួយគ្នា គ្រាន់តែមានជំនឿសាសនាខុសគ្នាប៉ុណ្ណោះ។ ទោះបីជា**កាន់សាសនាខុសគ្នា ក៏ប៉ុន្តែមានគោលដៅដូចគ្នា នៅត្រង់ថាមនុស្សទាំងអស់ត្រូវការការរស់រានមានជីវិត ត្រូវការនូវសេរីភាព ត្រូវការនូវអ្វីៗដែលមនុស្សលោកត្រូវការ** ...។

១៥. ព្រះសង្ឃពុទ្ធសាសនាខិតខំរួមចំណែកក្នុងសកម្មភាពមនុស្សធម៌

ខួបលើកទី១៥៤ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម, ០៨ ឧសភា ២០១៧

... រយៈពេលកន្លងទៅ **ព្រះសង្ឃបានបង្ហាញនូវការខិតខំយកចិត្តទុកដាក់ ចូលរួមក្នុងសកម្មភាពមនុស្សធម៌ តាមរយៈការផ្តល់ជំនួយដោយផ្ទាល់ចំពោះអ្នកខ្វះខាត ហើយក៏តាមរយៈការផ្តល់ជំនួយដល់កាកបាទក្រហម។ តាមទម្លាប់ ព្រះសង្ឃបានទទួលទេយ្យទាន និងវត្ថុនានា**។ ព្រះសង្ឃបានលៃទុកមួយចំណែក ដូចជាចាន ឆ្នាំង វែក ជាដើម ជួយមកកាកបាទក្រហមកម្ពុជា។ កាកបាទក្រហមកម្ពុជាក៏បានជូនរបស់ទាំងនោះទៅដល់ជនដែលមានសេចក្តីត្រូវការ។ ខ្ញុំមានការរីករាយដែលសង្កេតឃើញថា ជនរួមជាតិរបស់យើងចេះជួយគ្នា ...។

១៦. ចំនួនព្រះសង្ឃព្រះពុទ្ធសាសនាច្រើនជាងពេទ្យនិងស្មើពាក់កណ្តាលចំនួនទំព

ជួបសំណេះសំណាលជាមួយនឹងអាចារ្យ អាចារិនី លើកទី៨, ០៨ មេសា ២០២៣

... បន្ទាប់ពីប្រទេសត្រូវបានរំដោះ វត្តអារាម(ព្រះពុទ្ធសាសនាបាន)កើតឡើងបន្តិចម្តងៗ ដោយចំនួនព្រះសង្ឃក៏បានកើនពីតិចមកកាន់តែច្រើន។ ឥឡូវនេះ **ព្រះសង្ឃមានទៅដល់ជាង ៥ម៉ឺនអង្គឯណោះ។ ជាចំនួនមួយច្រើន។ បើប្រៀបធៀបទៅនឹងចំនួនគ្រូពេទ្យយើងមានគ្រូពេទ្យត្រឹមតែ ២ម៉ឺន ឬ ៣ម៉ឺននាក់ទេ ... ឬ(បើប្រៀបទៅកម្លាំងកងទ័ព)សឹងតែថាប្រហាក់ប្រហែលជិត ៥០% នៃចំនួនកងទ័ពនៅខ្ទមទាំងប្រទេសទៅហើយ** ...។

១៧. ចងក្រងនិងដំណើរការសហគមន៍អាចារ្យឲ្យបានខ្ទរំខ្ទរាយខ្ទទាំងប្រទេស

ជួបសំណេះសំណាលជាមួយនឹងអាចារ្យ អាចារិនី លើកទី៨, ០៨ មេសា ២០២៣

... ក្រសួងធម្មការ និងសាសនា ត្រូវបន្តរៀបចំវគ្គ**បណ្តុះបណ្តាលស្តីពីតួនាទី និងភារកិច្ច និងក្រមសីលធម៌ អាចារ្យ/អាចារិនី ដើម្បីបំពេញតម្រូវការរបស់ប្រជាពុទ្ធបរិស័ទ ... ដោយយកចិត្តទុកដាក់ រៀបចំចងក្រង និងដំណើរការ សហគមន៍អាចារ្យឲ្យបានខ្ទរំខ្ទរាយខ្ទទាំងប្រទេស** ... អាចារ្យដែលទើបតែមានអាយុ ៥០ឆ្នាំនៅពេលនេះ ឆ្មេចបើក។(ក៏នឹងមានអាយុ) ៦០ឆ្នាំ ... មិនមែនអាចារ្យមានជីវិតអមតៈឯណា។ ត្រូវបន្ត(ធ្វើកិច្ចការនេះ)បើយើងនៅមានព្រះសង្ឃ នៅមានវត្ត។ នេះមិនមែនមានតែក្នុងព្រះពុទ្ធសាសនាទេ។ វាមានក្នុងគ្រប់សាសនា ...។

១៨. សូមអាចារ្យ/អាចារិនីគោរពហានានុក្រម ក្នុងតួនាទីជួយដល់ពុទ្ធបរិស័ទ និងគាំទ្រព្រះសង្ឃគ្រប់គ្រងទីអារាម

ជួបសំណេះសំណាលជាមួយនឹងអាចារ្យ អាចារិនី លើកទី៨, ០៨ មេសា ២០២៣

... ក្នុងវិស័យពុទ្ធចក្រ ត្រូវបន្តការបណ្តុះបណ្តាលអាចារ្យ/អាចារិនី ហើយក៏សុំផ្តាំផ្ញើថា**អាចារ្យ/អាចារិនីកុំជ្រៀតជ្រែកកិច្ចការព្រះសង្ឃច្រើនពេក។ មានកន្លែងខ្លះ អាចារ្យទាស់ជាមួយចៅអធិការ ហើយការទាស់នោះ ធ្វើមចេញពីរឿងបញ្ហាកាន់កាប់ថវិកាហ្នឹងឯង។ សុំមេត្តាយោគយល់គ្នា។ ធ្វើបុណ្យធ្វើទាន អាចារ្យជើរតួនាទីសំខាន់។ ម្នាងជួយពុទ្ធបរិស័ទ ម្នាងជួយព្រះសង្ឃគ្រប់គ្រងទីអារាមក៏ប៉ុន្តែត្រូវគោរពតាមហានានុក្រម**។ អាចារ្យនៅជាមួយព្រះសង្ឃ ដែលនៅទីនោះ រចនាសម្ព័ន្ធគ្រប់គ្រងមានព្រះចៅអធិការ មានគ្រូសូត្រស្តាំមានគ្រូសូត្រឆ្វេង ...។

១៩. អាចារ្យ/អាចារិនី ត្រូវសម្របសម្រួលតម្រូវការ ចៀសវាងប្រកាន់បក្សពួក រើសអើង

ជួបសំណេះសំណាលជាមួយនឹងអាចារ្យ អាចារិនី លើកទី៨, ០៨ មេសា ២០២៣

... អាចារ្យ/អាចារិនីត្រូវពង្រឹងការថែ**រក្សាក្រមសីលធម៌អាចារ្យខ្មែរ ថែរក្សាឲ្យបាននូវកាពថ្លៃថ្នូរក្នុងតួនាទីរបស់ខ្លួន ត្រូវមានភាពឈ្លាសវៃក្នុងការរិះរកនីតិវិធីដោះស្រាយ សម្របសម្រួលគ្រប់តម្រូវការរបស់បរិស័ទ** គ្រប់មជ្ឈដ្ឋាន ព្រមទាំងទទួលខុសត្រូវ**សម្របសម្រួលគ្រប់តម្រូវការរបស់ពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋាន និងរក្សាគុណធម៌ ចៀសវាងការប្រព្រឹត្តខុសឆ្គង ប្រកាន់បក្សពួក ឬរើសអើងវណ្ណៈដែលធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ព្រះពុទ្ធសាសនា** ...។

២០. អាចារ្យ/អាចារិនីរក្សាមរតកវប្បធម៌ពុទ្ធសាសនា ប្រពៃណីទំនៀមទម្លាប់ខ្មែរប្រកបដោយអរិយធម៌

ជួបសំណេះសំណាលជាមួយនឹងអាចារ្យ អាចារិនី លើកទី៨, ០៨ មេសា ២០២៣

... **អាចារ្យ/អាចារិនីត្រូវបំពេញតួនាទី ភារកិច្ចឲ្យបានល្អ ស័ក្តិសមជាអ្នកដឹកនាំពិធីពុទ្ធសាសនា បង្ហាត់បង្រៀន ពន្យល់បង្ហាញ និងជាបុគ្គលដែលគួរឲ្យគោរព ព្រមទាំងចូលរួមរក្សាមរតកវប្បធម៌ព្រះពុទ្ធសាសនា និងប្រពៃណីទំនៀមទម្លាប់ខ្មែរឲ្យបានស្ថិតស្ថេរគង់វង្សប្រកបដោយអរិយធម៌ខ្ពស់** ... ផ្នែកអាណាចក្របច្ចុប្បន្នកំពុងជំរុញថៃទាំប្រពៃណី ដោយក្នុងពេលចូលឆ្នាំហ្នឹងមានការរៀបចំការវាំង រាំក្បាច់ សាវ៉ាវ៉ាន់ ឬក៏ទាញព្រ័ត្រ ឬលេងចោលឈូង លាក់កន្សែង ល្បែងរបាំនានា។ ដូច្នេះ សូមផ្តល់ឱកាសពិភាក្សាជាមួយព្រះសង្ឃ ឲ្យប្រជាពលរដ្ឋបានលេងក្នុងទីអារាម បង្កលក្ខណៈឲ្យទទួលបាន(ការសប្បាយរីករាយរក្សា)ទំនៀមទម្លាប់ វប្បធម៌ និងអរិយធម៌ ...។

២១. ព្រះសង្ឃពុទ្ធសាសនាទាំងធម្មយុត្តិកនិកាយទាំងមហានិកាយបណ្តុះបណ្តាលធនធានមនុស្សមិនតែក្នុងវិស័យសាសនា តែក៏គ្រប់មុខវិជ្ជាចំណេះទូទៅ

សម្ពោធអគារសិក្សាពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា, ៣០ ឧសភា ២០២៣

... ព្រះសង្ឃនៅខ្ទទាំងប្រទេស ទាំងធម្មយុត្តិកនិកាយទាំងមហានិកាយបានប្រឹងប្រែងកសាងសមិទ្ធផលនានា តាមរយៈការបណ្តុះបណ្តាលធនធានមនុស្ស

ដែលពុទ្ធិក(សាកលវិទ្យាល័យនេះ មិនមែន)បង្រៀនតែសាសនាសុទ្ធ ... តែចំណេះទូទៅគ្រប់មុខវិជ្ជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍប្រទេស។ យើងមិនអាចខ្វះធនធានមនុស្សបានទេ។ ប្រទេសជឿនលឿនទៅមុខបានទាល់តែយើងមានធនធានមនុស្សគ្រប់គ្រាន់។ យើងធ្លាប់មានពិសោធន៍ថា **(ខ្វះធនធានមនុស្សនាំដល់)ទី១ កើតសង្គ្រាម ទី២ បំផ្លាញធនធានមនុស្សដែលធ្វើឱ្យប្រទេសមានធនធានសម្បូរបែប ក្លាយទៅជាប្រទេសក្រីក្រ ក្នុងពេលដែលប្រទេសមួយចំនួនគ្មានធនធានធម្មជាតិទេ ប៉ុន្តែ ក្លាយទៅជាអ្នកមានបានដោយសារទី១ នយោបាយត្រូវ ទី២ មានធនធានមនុស្ស ...**។

២២. ផ្តល់ក្របខណ្ឌគ្រូបង្រៀនក្នុងសហគមន៍អ៊ីស្លាម ព្រោះជាតម្រូវការអភិវឌ្ឍសង្គម

ពិធីពិសាអាហារស្រាយបួសរ៉ាម៉ាឌន, ១៥ មិថុនា ២០១៧

...រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ដល់ការ**បណ្តុះបណ្តាលធនធានមនុស្សតាមរយៈសហគមន៍ឥស្លាម ដោយបានបញ្ចូលគ្រូបង្រៀនក្នុងក្របខណ្ឌរដ្ឋ ដែលជាការកាត់បន្ថយបន្ទុកចំណាយរបស់បងប្អូនមូស្លីមកម្ពុជា ដែលមុននេះត្រូវរែអង្គាសប្រាក់យកទៅផ្តត់ផ្តង់គ្រូ។ ខ្ញុំសូមជម្រាបជូនបងប្អូននៅទីនេះឲ្យបានជ្រាបថា មិនមែនត្រឹមតែ ១,៥០០ នាក់នោះទេ ប្រសិនបើមានតម្រូវការរហូតដល់ ៥,០០០ នាក់ក៏ខ្ញុំអាចជូនបានដែរ ព្រោះនេះជាតម្រូវការនៃការអភិវឌ្ឍន៍សង្គមជាដោយគ្មានការរើសអើង** ... សូមក្រសួងអប់រំ យុវជន និងកីឡា បន្តពិភាក្សាជាមួយគណៈចាងហ្វាង ក៏ដូចជាក្រសួងធម្មការ និងសាសនា អំពីតម្រូវការបំពេញបន្ថែមលើក្របខណ្ឌគ្រូបង្រៀន ដែលត្រូវទទួលបានប្រាក់បៀវត្សរ៍ ដូចជាគ្រូបង្រៀននៅផ្នែកដទៃទៀតដែរ ...។

២៣. សិស្សស្រីឥស្លាមអាចស្លៀកពាក់ប្រពៃណីនិងថតរូបមិនបាច់ចេញស្លឹកត្រចៀក

ពិធីពិសាអាហារស្រាយបួសរ៉ាម៉ាឌន, ១៥ មិថុនា ២០១៧

... ប្រទេសខ្លះ មិនទាន់បាន**អនុវត្តគោលនយោបាយស្តីពីសម្លៀកបំពាក់របស់ក្មួយៗ សិស្សានុសិស្ស និស្សិត នៅគ្រប់កម្រិតសិក្សា ទាំងបឋម មធ្យម និងឧត្តមសិក្សានៅឡើយទេ។ ប្រទេសមួយចំនួនមិនទាន់អនុញ្ញាតឲ្យស្ត្រីជាសាសនិកឥស្លាមមានស្លៀកនូវសំលៀកបំពាក់ប្រពៃណីរបស់ខ្លួន**ទៅរៀននោះទេ។ ប៉ុន្តែសម្រាប់កម្ពុជា **យើងអនុញ្ញាតឲ្យបងប្អូនជ្រើសរើសបានរវាងសម្លៀកបំពាក់ជាឯកសណ្ឋានសាលា និងឯកសណ្ឋានបងប្អូនស្ត្រីឥស្លាម។ រីឯការថតរូបធ្វើអត្តសញ្ញាណបណ្ណ ឬធ្វើលិខិតឆ្លងដែនទៀតសោតបន្ទាប់ពីបានពិភាក្សាជាមួយនឹងក្រសួងមហាផ្ទៃ ដែលថាការថតរូបដោយមិនបាច់ចេញស្លឹកត្រចៀកនោះ អាចធ្វើទៅរួចយើងក៏បានផ្តល់ឱកាសបែបនេះចំពោះស្ត្រីឥស្លាម** ... ចំណុចអស់ទាំងនេះមិនមែនគ្រាន់តែសន្យាទេ តែយើងបានអនុវត្តហើយលើការជាក់ស្តែង ...។

២៤. ភាពជ្រុលនិយមមិនមែនជាបញ្ហាសំរាប់ជាតិសាសន៍ឬសាសនាណាតែមួយទេ

ពិធីសម្ពោធវិហារឥស្លាមដើមៀក, ០៤ កញ្ញា ២០១៧

...អំពីសាសនានេះ ខ្ញុំគិតថាពិភពលោកត្រូវតែប្តូរបៀបនិយាយហើយ។ កន្លងទៅ ខ្ញុំក៏ធុញទ្រាន់ ហើយខ្ញុំក៏បាននិយាយអំពីបញ្ហានេះ នៅក្នុងក្របខណ្ឌនៃការប្រជុំនានានៅឯក្រៅប្រទេស។ មានបញ្ហាអ្វីឡើងគេ តែងតែនិយាយថាឥស្លាមនិយមជ្រុល។ ខ្ញុំចង់ឲ្យគេដកពាក្យឥស្លាមចេញ។ មិនចាំតែនៅក្នុងក្រុមឥស្លាមទេ ពួកជ្រុលនិយមក៏មាននៅក្នុងសាសនា និងនៅក្នុងជាតិសាសន៍ដទៃដែរ។ ដូច្នេះការប្រើពាក្យឥស្លាមនិយមជ្រុល គួរតែត្រូវបានបំបាត់ចោល ... **បើយើងនិយាយត្រឹមថារឿងនេះកើតឡើងដោយក្រុមឥស្លាមជ្រុលនិយមគឺវាមិនត្រឹមត្រូវទេ ... ខ្ញុំចង់ឲ្យដកពាក្យនោះចេញ ព្រោះភាពជ្រុលនិយមមិនមែនជាបញ្ហាដោយឡែករបស់ជាតិសាសន៍ ឬសាសនាណាមួយទេ** ...។

២៥. នឹងនៅតែមានពិធីស្រាយបួសដារបណាគណបក្សប្រជាជនកាន់អំណាច

ពិធីពិសាអាហារស្រាយបួសរ៉ាម៉ាឌន, ១៥ មិថុនា ២០១៧

... ខ្ញុំបាននិយាយកាលពីឆ្នាំទៅ **ពិធីស្រាយបួសដែលរៀបចំដោយរាជរដ្ឋាភិបាលមាន ហ៊ុន សែន ជានាយករដ្ឋមន្ត្រី តាងនាមអោយគណបក្សប្រជាជនកម្ពុជា (នឹងមានតរៀងទៅ)។ ខ្ញុំជានា(ថានឹងមានពិធីបែបនេះ)បានតែក្នុងដំណាក់កាលកាន់អំណាចនៃគណបក្សប្រជាជនកម្ពុជាប៉ុណ្ណោះ** ... ខ្ញុំជឿទុកចិត្តយ៉ាងមុតមាំលើភាពឥតងាករេ និងការស្មោះត្រង់របស់បងប្អូនសាសនិកឥស្លាម ដែលម្តងហើយ

ម្តងទៀត តាំងពីដំណាក់កាលរំដោះជាតិចេញពីរបបប្រល័យពូជសាសន៍ រហូតមកដល់ដំណាក់កាលបោះឆ្នោតជាបន្តបន្ទាប់ នៅតែមានសំឡេងគាំទ្រលើសលប់សម្រាប់គណបក្សប្រជាជនកម្ពុជា។ និយាយដូច្នេះ មិនមែនជាការឃោសនាសម្រាប់គណបក្សប្រជាជនកម្ពុជាទេ ក៏ប៉ុន្តែជាគោលនយោបាយដែលបង្ហាញជាក់ស្តែងជូនប្រជាជាតិកម្ពុជា សហគមន៍ឥស្លាម និងចំពោះប្រិយមិត្តនៃប្រទេសកាន់សាសនាឥស្លាម ឱ្យបានឃើញជាង ៣៨ឆ្នាំរួចហើយ ...។

២៦. ឥស្លាមសាសនាបណ្តុះបណ្តាលបច្ចេកវិទ្យា/មុខជំនាញផ្សេងៗ ដើម្បីការងារ/មុខរបរ ស្រាយជីវភាពនិងកំណើនសេដ្ឋកិច្ច

ពិធីពិសាអាហារស្រាយបួសវ៉ាម៉ាឌុនលើកទី៥, ២៩ ឧសភា ២០១៨

... ប៉ុន្មានឆ្នាំចុងក្រោយនេះ ក្នុងវិស័យអប់រំ ក្រោយពេលដែលរាជរដ្ឋាភិបាលផ្តល់ក្របខណ្ឌគ្រូបង្រៀនជូនទៅដល់សហគមន៍ឥស្លាមយើងបានឃើញថាវិស័យសិក្សាអប់រំនៅក្នុងសហគមន៍ឥស្លាម មានការរីកចម្រើន។ មុននោះ បន្ទុកថវិកាសម្រាប់ជួយគ្រូបង្រៀនផ្នែកឥស្លាម ត្រូវ៉ាប់រងដោយសហគមន៍ ។ ឥឡូវ បន្ទុកនេះត្រូវបានវ៉ាប់រងដោយរដ្ឋាភិបាល ដែលជាការកាត់បន្ថយនូវបន្ទុកចំណាយរបស់សហគមន៍ និងក្រុមគ្រួសារបងប្អូនឥស្លាម។ **(យើងសង្កេតឃើញថា)ចំនួនសិស្ស និស្សិតឥស្លាម ចំនួនបញ្ចរិន្តឥស្លាមមានកាន់តែច្រើន។ សូមអំពាវនាវបន្តយកចិត្តទុកដាក់បណ្តុះបណ្តាលធនធានមនុស្ស មិនតែក្នុងវិស័យសាសនាមួយមុខនោះទេ ក៏ប៉ុន្តែក្នុងវិស័យបច្ចេកវិទ្យា ឬមុខជំនាញផ្សេងៗទៀតផងដែរ ដើម្បីទទួលបានការងារធ្វើសមស្រប ឬការបង្កើតមុខរបរជំរុញដោះស្រាយជីវភាព និងកំណើនសេដ្ឋកិច្ចសម្រាប់ប្រទេស** ...។

២៧. ជនជាតិឥស្លាមមានចំនួនតិចតែសហគមន៍ធំទូលាយមានទំនាក់ទំនងជាមួយច្រើនទេស

ពិធីពិសាអាហារស្រាយបួសវ៉ាម៉ាឌុនលើកទី៥, ២៩ ឧសភា ២០១៨

... សូមអរគុណលោកជំទាវតំណាងអគ្គលេខាធិការ OIC ដែលបានលើកឡើងពីបំណងប្រាថ្នាចង់ឲ្យកម្ពុជាក្លាយទៅជាសមាជិកសង្កេតការណ៍នៃអង្គការ OIC។ កម្ពុជាពិតជាមានបំណងបែបនេះ។ សូមផ្តាំជូនទៅ ឯកឧត្តមអគ្គលេខាធិការ

OIC ក៏ដូចជាសមាជិក OIC ដទៃទៀតថា **កម្ពុជាពិតជាមានបំណងប្រែក្លាយខ្លួនជាសមាជិកសង្កេតការណ៍នៃអង្គការអន្តរជាតិដ៏ធំមួយនេះ។ ពិតមែនតែប្រទេសយើងមានជនជាតិឥស្លាមចំនួនតិចក៏ពិតមែន ក៏ប៉ុន្តែយើងមានសហគមន៍ដ៏ធំទូលាយមួយ មានទំនាក់ទំនងជាមួយបណ្តាប្រទេសជាច្រើន**។ យើងចង់បានតួអង្គសង្កេតការណ៍នៅក្នុងក្របខណ្ឌនៃអង្គការសហប្រតិបត្តិការឥស្លាម OIC នេះ ...។

២៨. សូមប្រទេស OIC ជួយទិញទំនិញ និងផ្តល់ទីផ្សារការងារដល់ឥស្លាមកម្ពុជា

ពិធីពិសារអាហារស្រាយបួសខែវ៉ាម៉ាឌុន, ០៧ ឧសភា ២០១៩

... យើងចង់ឱ្យប្រទេស(សមាជិក OIC)ទាំងនោះទទួលទិញទំនិញដែលផលិតនៅកម្ពុជា រាប់ទាំង Halal Food ដែលជាតម្រូវការនៃបងប្អូនសាសនិកម៉ូស្លីម ... សូមជួយទិញអង្ករពីយើង។ **ជួយទិញទំនិញពីយើង ដើម្បីឱ្យទីផ្សាររបស់កម្ពុជាកាន់តែរីកចម្រើន ហើយក៏ជាផ្នែកមួយ នៃការដោះស្រាយការងារធ្វើនៅក្នុងប្រទេសរបស់យើង។ យើងក៏ចង់រកទីផ្សារការងារ សម្រាប់បងប្អូនសាសនិកឥស្លាមនៅកម្ពុជាផងដែរ ... កម្ពុជាក៏មានសមត្ថភាពបញ្ជូនពលករទៅរកការងារធ្វើនៅ(បណ្តាប្រទេសអ៉ារ៉ាប់)ទាំងនោះដោយស្របច្បាប់ដែរ។ យើងចង់ស្វែងរកឱកាសការងារសម្រាប់បងប្អូនសាសនិកឥស្លាម ក៏ដូចជាបងប្អូនខ្មែរដទៃទៀតដោយមិនប្រកាន់ជាតិសាសន៍** ...។

២៩. សង្ឃឹមថាគ្រីស្តសាសនិក រួមចំណែកអប់រំកុំឲ្យប្រព្រឹត្តគ្រឿងញៀន

សំណេះសំណាល និងពិសាបាយសាមគ្គីជាមួយគ្រីស្តបរិស័ទ, ១២ តុលា ២០១៩

... សូមគ្រប់វិហារ និងបងប្អូនទាំងឡាយចូលរួមធ្វើយុទ្ធនាការ ដើម្បីបំបាត់ ឬកាត់បន្ថយគ្រឿងញៀន។ នៅលើពិភពលោកមានបញ្ហាច្រើនណាស់ ក្នុងហ្នឹងក៏មានកម្ពុជាដែរ ដែលគ្រឿងញៀនបានញាំញីក្នុងចំណោមយុវជន ក្នុងចំណោមប្រជាពលរដ្ឋរបស់យើង ដែលទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់។ **សង្ឃឹមថានៅក្នុងចំណោមអ្នកកាន់សាសនាគ្រីស្ត មិនមានអ្នកប្រព្រឹត្តគ្រឿងញៀន មិនមានអ្នកលក់ដូរគ្រឿងញៀន ផ្ទុយទៅវិញ ជាអ្នកដែលបានកាន់សាសនាគ្រីស្ត និងចូលរួមចំណែកអប់រំ កុំឲ្យប្រព្រឹត្តគ្រឿងញៀន** ...។

៣០. សូមអប់រំនិងគោរពច្បាប់ចរាចរណ៍ដល់អ្នកកាន់សាសនាគ្រីស្ទ ដើម្បីជានាសុវត្ថិភាពផ្ទាល់ខ្លួន

សំណេះសំណាល និងពិសាបាយសាមគ្គីជាមួយគ្រីស្តបរិស័ទ, ១២ តុលា ២០១៩

... សព្វថ្ងៃ កម្ពុជាបានក្លាយទៅជាកន្លែងដែលមានមនុស្សស្លាប់ (ដោយគ្រោះថ្នាក់ចរាចរណ៍)ច្រើនជាងសម័យសង្គ្រាម។ ខ្ញុំបានចូលរួមដឹកនាំប្រទេសនេះអស់រយៈពេល ៤០ឆ្នាំមកហើយៗ ក្នុងនោះ មានជាង ៣៤ឆ្នាំ កាន់មុខតំណែងជានាយករដ្ឋមន្ត្រី ។ ក្នុងសម័យមានសង្គ្រាម ថ្ងៃខ្លះមិនមានមនុស្សស្លាប់ទាល់តែសោះ ដោយសារតែគ្មានការប្រយុទ្ធ គ្មានស្លាប់ គ្មានរបួស។ ប៉ុន្តែមកដល់ពេលនេះ ថ្ងៃណាក៏មានមនុស្សស្លាប់ ... **ជាសោកនាដកម្មមួយដ៏ធំ ដែលសង្ឃឹមថាអ្នកដែលកាន់គ្រីស្ទសាសនាទាំងឡាយ មិនត្រឹមតែយកចិត្តទុកដាក់គោរពច្បាប់ចរាចរណ៍ខ្លួនឯងទេ ក៏ប៉ុន្តែនឹងផ្តល់នូវការអប់រំចំពោះអ្នកកាន់គ្រីស្ទសាសនាទាំងឡាយ ដើម្បីពួកគេគឺនឹងអាចនឹងជានាសុវត្ថិភាពផ្ទាល់ខ្លួន ក៏ដូចជាសុវត្ថិភាពសម្រាប់អ្នកដទៃទៀតដែលធ្វើចរាចរណ៍លើដងផ្លូវ** “ថ្ងៃនេះ ថ្ងៃស្អែក កុំឲ្យមានគ្រោះថ្នាក់ចរាចរណ៍” ...។

៣១. ធ្វើសុខដុមភាវូបនីយកម្មផ្ទៃក្នុងគ្រីស្តសាសនានិងជាមួយសាសនាដទៃ

សំណេះសំណាល និងពិសាបាយសាមគ្គីជាមួយគ្រីស្តបរិស័ទ, ១២ តុលា ២០១៩

... សូមអំពាវនាវ**ឲ្យបន្តការយកចិត្តទុកដាក់ធ្វើសុខដុមភាវូបនីយ៍កម្មផ្ទៃក្នុងគ្រីស្តសាសនាខ្លួនឯង និងជាមួយសាសនាដទៃទៀត** ... ក្នុងគ្រីស្ទសាសនាក៏មាននិកាយច្រើន ... នៅទីនេះ យើងនិយាយពីសុខដុមភាវូបនីយ៍កម្មជាតិសាសន៍និងសាសនា។ សាសនានីមួយៗ មាននិកាយខុសៗ គ្នា ... (ទោះជាកាន់)សាសនាណាក៏ដោយ ឬក៏និកាយណាក៏ដោយ សូមកុំអោយ(ការប្រកាន់យកនោះ)ក្លាយជាឧបសគ្គរារាំង រហូតទៅដល់បំផ្លាញគ្នា ... សូមអំពាវនាវឲ្យយកចិត្តទុកដាក់**ធ្វើសុខដុមភាវូបនីយ៍កម្មក្នុងក្របខណ្ឌគ្រីស្តសាសនាខ្លួនឯងដោយក្នុងជាមួយនោះក៏ត្រូវយកចិត្តទុកដាក់ធ្វើទំនាក់ទំនងជាមួយសាសនាដទៃ ដូចជាសាសនាព្រះពុទ្ធ សាសនាឥស្លាម ឬក៏អ្នកដែលមិនជឿសាសនា ឬក៏អ្នកដែលមានជំនឿ**

ខុសពីយើង ដូចដែលខ្ញុំបានលើកកន្លងមកថា “ជាតិសាសន៍ខុសគ្នា មិនមែនជាឧបសគ្គរារាំងសម្រាប់ការអភិវឌ្ឍប្រទេសយើងទេ” ...។

៣២. បណ្តុះបណ្តាលសមត្ថភាពធនធានមនុស្សក្នុងសាសនា ដើម្បីរួមចំណែកកសាងសង្គមជាតិ និងគ្រួសារ

សំណេះសំណាល និងពិសាបាយសាមគ្គីជាមួយគ្រីស្តបរិស័ទ, ១២ តុលា ២០១៩

... ការបណ្តុះបណ្តាលធនធានមនុស្សជាចំណុចមួយសំខាន់ បើចង់ឲ្យសាសនារឹងមាំ ។ ចង់ឲ្យសាសនាបន្តមានការរីកចម្រើន សូមកុំភ្លេចយកចិត្តទុកដាក់លើការបណ្តុះបណ្តាលធនធានមនុស្ស ដូចជាគ្រូអាចារ្យប្រដៅសាសនា ព្រឹទ្ធាចារ្យ បូជាចារ្យ ឬគ្រូជាដើម។ ត្រូវលើកកម្ពស់សមត្ថភាពដើម្បីផ្តល់ការអប់រំឲ្យបានត្រឹមត្រូវ ... **ទាមទារមានការបណ្តុះបណ្តាលធនធានមនុស្សដោយក្នុងនោះ មិនមែនសំដៅលើសាសនាតែមួយមុខទេ គឺលើកកម្ពស់សមត្ថភាពគ្រប់ផ្នែក ដើម្បីធ្វើឲ្យសមត្ថភាព ការចេះដឹង នៃអ្នកកាន់គ្រីស្ទសាសនា ក្លាយទៅជាផ្នែកមួយរួមចំណែកកសាងសង្គមជាតិ ក៏ដូចជាកសាងគ្រួសាររបស់ខ្លួនផងដែរ** ...។

៣៣. រៀបចំតំណាងគ្រីស្តបរិស័ទសំរាប់សន្ទនាជាមួយសាសនាដទៃនិង/ឬអាជ្ញាធររដ្ឋ

ពិធីអបអរសាទរខួប ១០០ ឆ្នាំនៃសាសនាគ្រីស្ទនៅកម្ពុជា ព្រឹត្តិការណ៍ មរតកដំណឹងល្អ (១៩២៣-២០២៣), ២៧ មករា ២០២៣

... នេះក៏ជាចំណុចមួយដើម្បីងាយស្រួលធ្វើការពិភាក្សា។ ឧទាហរណ៍ ការជួបជុំនៅថ្ងៃនេះ តើអ្នកណានឹងត្រូវធ្វើជាតំណាងឡើងថ្លែងសុន្ទរកថា ប្រសិនបើយើងមាននិកាយច្រើន ... បើយើងមានតំណាងច្រើននាក់មកថ្លែងសុន្ទរកថានោះវាពិតជាមិនគប្បីទេ ក្នុងពេលដែលយើងមានព្រះយេស៊ូគ្រីស្ទតែមួយប៉ុណ្ណោះ។ ដូច្នេះ **ខ្ញុំសង្ឃឹមថា អស់លោកលោកស្រី ដែលជាថ្នាក់ដឹកនាំនិងជាគ្រីស្តបរិស័ទនឹងយោគយល់ជ្រើសរើសភាពជាតំណាងសម្រាប់សន្ទនាជាមួយសាសនាដទៃទៀត ឬសម្រាប់សន្ទនាជាមួយអាជ្ញាធរពាក់ព័ន្ធខាងរាជរដ្ឋាភិបាល។ សង្ឃឹមថាអស់លោកនឹងអាចធ្វើបាននូវកិច្ចការដ៏ល្អមួយនេះ ក្នុងស្មារតីសាមគ្គីភាពនិងការយោគយល់** ...។

៣៤. អ្នកប្រៀនប្រដៅសាសនាផ្តល់ការណែនាំអនុវត្តនយោបាយភូមិឃុំមានសុវត្ថិភាព

សំណេះសំណាល និងពិសាបាយសាមគ្គីជាមួយគ្រីស្តបរិស័ទ, ១២ តុលា ២០១៩

... សូមចូលរួមអនុវត្តនយោបាយភូមិឃុំមានសុវត្ថិភាព ដែលជាចំណុចងាយស្រួលក្នុងការប្រៀនប្រដៅរបស់ព្រឹទ្ធាចារ្យ បូជាចារ្យ ក៏ដូចជាគ្រូគង្វាលទៅកាន់អ្នកដែលនៅតាមវិហារនានា។ **ដើម្បីឲ្យប្រទេសជាតិមួយមានសន្តិសុខសណ្តាប់ធ្នាប់សង្គម ត្រូវផ្តើមពីមូលដ្ឋានដែលរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដែលសង្ឃឹមថា គ្រូបង្រៀនក៏ដូចអ្នកប្រៀនប្រដៅទាំងឡាយនៅតាមព្រះវិហារផ្តល់នូវការណែនាំសម្រាប់គ្រីស្តបរិស័ទដែលត្រូវធ្វើការបន់ស្រន់ ឬទៅកាន់ពិធីនានានៅទីនោះ**។ នេះជាផលប្រយោជន៍យើងផ្ទាល់។ ប្រសិនបើភូមិដែលយើងរស់នៅមានការឆក់ប្លន់ គ្រឿងញៀន ឬអំពើឧបាយមុខផ្សេងៗ ភូមិឃុំនោះពិតជាមិនមានសុវត្ថិភាពទេ ...៕

១១. បរិស្ថាន

១	ការកាប់ឈើជាមុខរបរដើមផង មានសេចក្តីត្រូវការក្នុងការចម្អិនអាហារផង	២០៧
២	នឹងមានការប្រើប្រាស់ឧស/ធ្យូងចម្អិនអាហាររហូតដល់មានឧស្ម័នគ្រប់កន្លែង	២០៧
៣	គិតពីចម្លាស់ប្រភពកំដៅ/ចំហេះ ក្រៅពីឈើ/ឧស	២០៨
៤	បង្កើតមុខរបរថ្មីសំរាប់អ្នកអាស្រ័យផលដោយការកាប់ឧសនិងលុងឈើដុតយកជ័រ	២០៨
៥	ការពារឈើនិងអភិរក្សសត្វព្រៃ បង្កើតតំបន់ទេសចរណ៍ ផ្តល់ផលជូនប្រជាពលរដ្ឋ	២០៩
៦	ការពារព្រៃឈើ ការពារជម្រកសត្វ ការពារមរតកដូនតា	២០៩
៧	កាលបើដាំ ១លានដើម ត្រូវដឹងថាការកាប់អាចមានដល់ ២លានដើម	២១០
៨	ដោយសេចក្តីត្រូវការឈើដើម្បីប្រើប្រាស់ ធ្វើអោយឈើមានសត្រូវច្រើន	២១០
៩	គម្រប់ព្រៃឈើថ្មីជាកៅស៊ូ ស្វាយចន្ទី និងដំណាំផ្សេងៗ ជំនួសអោយព្រៃរិចរិល	២១០
១០	ទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ តាមរបៀបដាក់ជាតំបន់ការពារ	២១១
១១	វិមជ្ឈការអំណាចឱ្យប្រជាជនទាញយកផលដើម្បីជួយគ្រប់គ្រងតំបន់ព្រៃឈើ	២១១
១២	វិធីស្អាត ម្ហូបឆ្ងាញ់ នឹងប្រកួតប្រជែង ហើយមិនប្រមូលផ្តុំទេសចរតែមួយកន្លែង	២១២
១៣	ទំនប់ទឹកស្អាតកំពត តម្កល់ទឹកនិងទប់កុំឱ្យទឹកប្រែចូល	២១២
១៤	អនុវត្តយុទ្ធនាការអនាម័យតាំងពីប្រជាជនធម្មតារហូតដល់អ្នកមុខអ្នកការ	២១៣
១៥	សំអាតនិងការពារសមុទ្រ ទន្លេ ព្រៃកនានា ពីកាកសំណល់ផ្លាស្ទីក	២១៣
១៦	រួមគ្នាកាត់បន្ថយបញ្ហាប្រឈមពីផ្លាស្ទីកក្នុងសមុទ្រ ទន្លេ ព្រៃក និងបឹងបួរ	២១៤

១. ការកាប់ឈើជាមុខរបរដើមផង មានសេចក្តីត្រូវការក្នុងការចម្អិនអាហារផង

ពិធីវេទិកាថ្នាក់ជាតិលើកទី២ ស្តីពី «ការការពារនិងអភិរក្សធនធានធម្មជាតិ», ២២ សីហា ២០១៧

... (សុន្ទរកថា) ... *សកម្មភាពល្មើសច្បាប់ រួមមានការលួចកាប់ឈើ, ជីករ៉ែ, ការបរបាញ់សត្វ, ការកាប់រានទន្ទ្រានយកដីរដ្ឋធ្វើកម្មសិទ្ធិ, ការទន្ទ្រានតំបន់ការពារធម្មជាតិ, តំបន់អេកូទេសចរណ៍ជាដើម*... (សេចក្តីអធិប្បាយ) ... ពិតមែនតែ(ការកាប់ឈើខ្នាត)ធំអស់ (សល់តែការកាប់ឈើខ្នាត)តូច វានៅមាន។ អំពីការកាប់ឈើនេះ យើងយល់បញ្ហាមួយចំនួន។ (ដែលថាវាជា)**មុខរបរដើមរបស់ប្រជាពលរដ្ឋនោះ ក៏មួយផ្នែកហើយ ប៉ុន្តែមួយផ្នែកទៀត យើងក៏ត្រូវយល់អោយបានថាតើអ្នកទាំងអស់គ្នា រាប់ទាំងអង្គការក្រៅរដ្ឋាភិបាល ដែលជេរប្រទេច (ដាក់)បណ្តាសាលើរាជរដ្ឋាភិបាល បាននិងកំពុងចម្អិនអាហារដោយប្រើអ្វី(ជាគ្រឿងបង្គំចំហេះ)ទៅ? ច្បាស់ជាចម្អិនអាហារដោយឧសនិងធ្យូងនោះឯង**។ បើថាជាមនុស្សបរិស្ថានមិនចូលរួមដជែកពិភាក្សាក្នុងស្មារតីសហការ និងសន្ធនា(ដោយស្ថាបនា) ខ្លួនមិនគួរប្រើឧសនិងធ្យូងដើម្បីចម្អិនចំណីអាហារទេ ...។

២. ការប្រើប្រាស់ឧស/ធ្យូងចម្អិនអាហារនឹងមានរហូតដល់កម្ពុជាមានឧស្ម័នប្រើប្រាស់

ពិធីវេទិកាថ្នាក់ជាតិលើកទី២ ស្តីពី «ការការពារនិងអភិរក្សធនធានធម្មជាតិ», ២២ សីហា ២០១៧

... មានអ្នកចង់សហការ និងមានអ្នកចង់សហការដែលនៅក្រៅវង្វង់(នៃការប្រឹងប្រែងនេះ ហើយយ)ចាំតែសរសេរឯកសារវាយប្រហាររាជរដ្ឋាភិបាល ... **គ្រាន់តែចំណុច(ប្រើប្រាស់ឧស/ធ្យូងដើម្បីចម្អិនអាហារ)នេះមួយ មិនមែនត្រូវដោះស្រាយមួយឆ្នាំ ឬពីរឆ្នាំ ឬដប់ឆ្នាំទេ តែគឺត្រូវដោះស្រាយរហូតដល់ពេលដែលកម្ពុជាមានឧស្ម័ន gas សម្រាប់ប្រជាជនប្រើប្រាស់គ្រប់រូប**។ សូម្បីតែអ្នកប្រើប្រាស់មាន gas មានឧស្ម័ន ប្រើប្រាស់ចម្អិនអាហារក៏ដោយ ក៏នៅតែសេសសល់ប្រជាពលរដ្ឋមួយចំនួនដែលប្រើឧសសម្រាប់អាំងសាច់។ គាត់មិនអាំង(សាច់ដោយ gas)ហ្នឹងឯណាអាំង(ដោយ)ឧស និងធ្យូង ត្បិតវាមានរសជាតិឆ្ងាញ់ជាង ...។

៣. គិតពីចម្លាស់ប្រែភពកំដៅ/ចំហេះ ក្រៅពីឈើ/ឧស

ពិធីវេទិកាថ្នាក់ជាតិលើកទី២ ស្តីពី «ការការពារនិងអភិរក្សធនធានធម្មជាតិ», ២២ សីហា ២០១៧

... និយាយពីឈើមួយម៉ាត់ ត្រូវត្រៀមស្មារតីយូរអង្វែង។ យើងត្រូវជំរុញល្បឿនសាងសង់(ប្រព័ន្ធ)បង្ហូរឧស្ម័ន មកកាន់ទីកន្លែងដែលប្រជាជនត្រូវការប្រើប្រាស់។ ម្យ៉ាងទៀត **ការប្រើប្រាស់ធ្យូងថ្មជំនួសអោយការប្រើឧសដើម្បីរម្ងាស់ស្តរត្នោត ក៏ជាបញ្ហាដែរ។ យើងរកវិធីប្រើប្រាស់អ្វីផ្សេងដែលផ្តល់ចំហេះ/កំដៅ។ ឡថ្នាំ(ជក់)សុទ្ធតែប្រើប្រាស់ឧស**។ ឡត្រដ្ឋឡក្បឿងនេះ បើសិនជាបណ្តាលអោយផលិតកម្មជាគីអន្តរាយឈើតែម្តង។ ដើម្បីបានឥដ្ឋបានក្បឿងមួយឡ តើត្រូវអស់ឈើប៉ុន្មានម៉ែត្រគូប? សូមគិតអំពីបញ្ហានេះ ... ៕

៤. បង្កើតមុខរបរថ្មី សម្រាប់អ្នកអាស្រ័យផលដោយការកាប់ឧសនិងលុងឈើដុតយកជ័រ

ពិធីវេទិកាថ្នាក់ជាតិលើកទី២ ស្តីពី «ការការពារនិងអភិរក្សធនធានធម្មជាតិ», ២២ សីហា ២០១៧

... (សុន្ទរកថា) *ប្តូរឥរិយាបថរបស់ប្រជាជន ពីការប្រើប្រាស់ធនធានធម្មជាតិខ្លះខ្លាយហួស, មកជាការអភិរក្សជីវចម្រុះ និងអភិរក្សប្រភេទពុន្ធជាតិ, សត្វកម្រ ឬជិតផុតពូជ ...* (សេចក្តីអធិប្បាយ) **តម្រូវការដំបូងរបស់យើង គឺខិតខំកែប្រែមុខរបររបស់ពួកគាត់ ដោយបង្កើតមុខរបរថ្មី ដើម្បីគាត់បោះបង់ចោលមុខរបរចាស់ជាការកាប់ឈើ ការលុងជំរយកជ័រទឹក ជាដើមនេះ**។ បើដើររើសជ័រចុង វាមិនជាបញ្ហាទេ។ តំបន់អូរតាង៉ាវ និងតំបន់អូរអាល័យ ដែលកងកម្លាំងរបស់យើងឈរជើងនៅទីនោះបានអោយដឹងថា មានការកាប់ ដុតទាញយកជ័រទឹកច្រើនណាស់ ហើយវាអាចនាំទៅដល់ការមានភ្លើងឆេះព្រៃផងដែរ ... ពីសម័យដើម **តំបន់អង្គរវត្តនេះ ប្រជាពលរដ្ឋចោះឈើដុតគប់ ញាត់ទៅក្នុងហ្នឹងដើម្បីអោយក្តៅ(អោយ)ចេញជ័រ ... (ពេល)បក់ទៅ មាន(កំទេច)ភ្លើងក៏ឆាបឆេះព្រៃទៅ។ ប៉ុន្តែ បច្ចុប្បន្ននេះ ក្នុងតំបន់អង្គរវត្ត យើងបានកែឥរិយាបទនិងមុខរបររបស់គាត់ហើយ។ យើងត្រូវបន្តធ្វើនៅតំបន់ដទៃទៀត** ...៕

៥. ការពារឈើនិងអភិរក្សសត្វព្រៃ បង្កើតជាតំបន់ទេសចរណ៍ ផ្តល់ផលជូនប្រជាពលរដ្ឋ

ជាំកូនឈើនៅឧទ្យានរាជបណ្ឌិតសភាកម្ពុជា តេជោសែន ឫស្សីត្រឹប, ១៨ ឧសភា ២០១៨

... សូមអំពាវនាវចំពោះ**ប្រជាពលរដ្ឋ ក៏ដូចជាអាជ្ញាធរពាក់ព័ន្ធជួយការពារព្រៃឈើ។ ខ្ញុំបានប្រគល់ភារកិច្ចឲ្យកងពលធំទី៣ និងបណ្តាកងពលទាំងឡាយពេលចុះមកធ្វើការនៅតាមព្រំដែន។ ខ្ញុំបានឲ្យអស់លោកមកការពារទល់ដែន ការពារព្រៃឈើ មិនមែនមកឲ្យកាប់ឈើទេ។ សូមបន្តអំពាវនាវចំពោះប្រជាពលរដ្ឋចូលរួមការពារព្រៃឈើក្នុងតំបន់នេះ**។ បើ(សត្វព្រៃ)ចេញពីតំបន់ហ្នឹងទៅកន្លែងផ្សេង ជាប់អន្ទាក់អ្នកស្រុកក្រៅ ហ្នឹងជារឿងផ្សេង។ ប៉ុន្តែកុំឲ្យចូលមកជាក់អន្ទាក់ក្នុងតំបន់នេះ ព្រោះបន្តិចទៀត**នឹងមានការយកសត្វព្រៃមកលែងកាន់តែច្រើន ... កាលណាមានកូនមានចៅ យើងនឹងព្រលែងបន្តទៀត ... បើក្លាយទៅជាតំបន់ទេសចរណ៍ក្បែរខាងនេះ ច្បាស់ណាស់ថា ប្រជាជននឹងទទួលផល**។ ក្រុមទេសចរនេះគឺជាអតិថិជនរបស់កសិករជាំដុះ ឬចិញ្ចឹមសត្វនៅក្នុងតំបន់នេះ ...៕

៦. ការពារព្រៃឈើ ការពារជម្រកសត្វ ការពារមរតកដូនតា

ជាំកូនឈើនៅឧទ្យានរាជបណ្ឌិតសភាកម្ពុជា តេជោសែន ឫស្សីត្រឹប, ១៨ ឧសភា ២០១៨

... មិនត្រឹមតែការពារកុំឲ្យបាត់បង់(ព្រៃឈើនៅទីនេះ)ទេ ប៉ុន្តែត្រូវធ្វើឲ្យដើមឈើរីកលូតលាស់សម្រាប់ជំនាន់ក្រោយ ហើយសត្វព្រៃដែលបាត់បង់ទីជម្រកនៅកន្លែងផ្សេង ក៏បានមក(រស់នៅ)នៅទីនេះ ហើយក្លាយជាមរតក(ជាតិ)។ សត្វខ្លះជិតផុតពូជទៅហើយ បន្ថែមដោយការកាប់ព្រៃទន្ទ្រានដីដើម្បីបង្កបង្កើនផល គ្មានកន្លែងដែលសត្វជ្រកកោនទៀតបាន ... បច្ចុប្បន្នរដ្ឋមន្ត្រីក្រសួងបរិស្ថានកំពុងមមាញឹកធ្វើការជាមួយក្រសួងកសិកម្ម ជាក់តំបន់នេះជាព្រៃការពារ ដែលទោះបីថាវាតូច តែយ៉ាងហោចណាស់យើងបានការពារព្រៃទាំងនោះ ... **មានព្រៃដែលត្រូវការពារច្រើន (ដែលការ)ការពារលើក្រដាសមិនគ្រប់គ្រាន់ទេ។ ត្រូវការពារដោយសកម្មភាពជាក់ស្តែង ... ត្រូវ(ធ្វើ)រួមគ្នា ដោយមិនគ្រាន់តែមិនបំផ្លិចបំផ្លាញព្រៃឈើនិងសត្វព្រៃប៉ុណ្ណោះទេ ក៏ប៉ុន្តែរួមគ្នាការពារមរតកដូនតា** ...៕

៧. កាលបើដាំ ១លានដើម ត្រូវដឹងថាការកាប់អាចមានដល់ ២លានដើម

ដាំកូនឈើនៅឧទ្យានរាជបណ្ឌិតសភាកម្ពុជា តេជោសែន ឫស្សីត្រឹប,
១៨ ឧសភា ២០១៨

... ដែលហៅថាអភិរក្សនិងការអភិវឌ្ឍ គឺត្រូវដើរព្រមគ្នា ជាមួយផែនការជាក់លាក់ និងមានគោលដៅជាក់លាក់។ ខ្ញុំចង់និយាយទាក់ទងនឹងព្រៃឈើ។ ថ្ងៃនេះយើងនិយាយថានឹងដាំដើមឈើឲ្យបាន ១លានដើមនៅទីនេះ។ អ្វីដែលយើងត្រូវឃើញ គឺយើងមានទិវាដាំដើមឈើថ្ងៃទី ៩កក្កដា ជារៀងរាល់ឆ្នាំ ដែលព្រះមហាក្សត្រយាងជាព្រះរាជធិបតី ក៏ប៉ុន្តែ**យើងត្រូវទទួលស្គាល់ថា ឈើមានសត្រូវច្រើនណាស់។ កាលបើដាំ ១លានដើម មានការកាប់ដល់ទៅ ២លានដើម។ ហេតុអ្វីបានជាខ្ញុំនិយាយដូច្នេះ? ជួនកាលយើងមើលរំលងបញ្ហា ហើយដាក់កំហុសទៅអ្នកនេះ ឬអ្នកនោះ ដោយយើងមិនបានដោះស្រាយបញ្ហាជាកញ្ចប់** ...៕

៨. ដោយសេចក្តីត្រូវការឈើដើម្បីប្រើប្រាស់ ធ្វើអោយឈើមានសត្រូវច្រើន

ដាំកូនឈើនៅឧទ្យានរាជបណ្ឌិតសភាកម្ពុជា តេជោសែន ឫស្សីត្រឹប,
១៨ ឧសភា ២០១៨

យើងពិនិត្យមើល **ឈើមានសត្រូវច្រើន ព្រោះមានសេចក្តីត្រូវការ(ប្រើប្រាស់)ច្រើន ... ប្រជាជនធ្វើផ្ទះក៏ត្រូវកាប់ឈើ។ ប្រជាជនធ្វើស្រែចំការ ក៏ត្រូវកាប់ឈើ។ អ្នកលួចកាប់ឈើ ក៏លួចកាប់ឈើ។ កាប់ឈើយកទៅលក់ក៏កាប់ យកទៅធ្វើឧសដុតក៏កាប់។ ការអភិវឌ្ឍសម្រាប់ក្រុមគ្រួសារក្នុងវិស័យកសិកម្មក៏ត្រូវកាប់ឈើ ការអភិវឌ្ឍតាមរបៀបជីវសម្បទានសេដ្ឋកិច្ច** បង្កើតផលិតផលនិងការងារធ្វើក៏ត្រូវកាប់ឈើ។ សង្កេតមើលប្រទេសអឺរ៉ុបទៅ អឺរ៉ុបកាប់ឈើខ្ទេចអស់ហើយ រួចហើយគាត់មកប្រដៅពួកប្រទេសដូចយើង ដែលជាប្រទេសអន់ថយថាកុំឲ្យកាប់ឈើ។ យើងទទួលយក ប៉ុន្តែយើងត្រូវដឹងពី(បរិមាណនៃសេចក្តីត្រូវការធៀបទៅនឹង)ការកើនឡើងនៃចំនួនប្រជាពលរដ្ឋរបស់យើង ...៕

៩. គម្របព្រៃឈើថ្មី មានកៅស៊ូ ស្វាយចន្ទី និងដំណាំផ្សេងៗ ជំនួសអោយព្រៃចំរើល

ដាំកូនឈើនៅឧទ្យានរាជបណ្ឌិតសភាកម្ពុជា តេជោសែន ឫស្សីត្រឹប,
១៨ ឧសភា ២០១៨

... លើការដាក់ស្តែង បើប្រៀបធៀបជាមួយឆ្នាំ ១៩៧៩ ឬប្រៀបធៀបជាមួយឆ្នាំ ១៩៧០ តើប្រជាពលរដ្ឋបានពង្រីកផ្ទៃដីដាំដុះដល់ប៉ុន្មាន? យើងយកការប្រៀបធៀបចំណុចនេះឲ្យបានច្បាស់។ បើមិនដូច្នោះទេ (នឹងលុះដោយ)ទស្សនៈមួយដែលគិតតែពីការវាយប្រហារថាបាត់ឈើបាត់ព្រៃ។ **តើព្រៃហ្នឹងបាត់ទៅណា? ... ក្នុងនោះ មានព្រៃមួយចំនួនជាផ្ទៃដីរំចើល ត្រូវបានជំនួសមកវិញដោយគម្របព្រៃឈើថ្មី តាមរយៈការដាំកៅស៊ូ ការដាំស្វាយចន្ទី និងដំណាំផ្សេងទៀត** ... សូមបងប្អូនទាំងអស់គ្នាគិតមើលចុះ ក្រោយថ្ងៃ ៧មករា ១៩៧៩ ចំនួនប្រជាជន(មាន)ប្រមាណត្រឹមតែជុំវិញ ៥លាននាក់ប៉ុណ្ណោះ ...៕

១០. ទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ តាមរបៀបដាក់ជាតំបន់ការពារ

ដាំកូនឈើនៅឧទ្យានរាជបណ្ឌិតសភាកម្ពុជា តេជោសែន ឫស្សីត្រឹប, ១៨ ឧសភា ២០១៨

... ពេលខ្លះ ឃើញមុខដដែលៗ។ កាប់ឈើនៅក្រចេះក៏មានមុខហ្នឹង កាប់ឈើនៅកំពង់ស្ពឺ ក៏មានមុខហ្នឹង។ ហ្នឹងយើងអត់ទាន់មានបច្ចេកវិទ្យាសម្រាប់ដៅថាឈ្មោះនេះបានទទួលដីនៅនេះហើយផង។ ដោយហេតុនេះ ទើបបានជាវាសាំញ៉ាំក្នុងការដែលយើងត្រូវគ្រប់គ្រងដីធ្លីនិងប្រើប្រាស់ដីធ្លីឲ្យបានល្អ ដល់ប្រជាជនជាអ្នកទទួលផល។ នេះជារឿងមួយទាក់ទងនឹងការការពារព្រៃឈើ និងការដាំដើមឈើ។ បើយើងដាំ ១លានដើម តែកាប់ ២លានដើម ច្បាស់ណាស់ថាវាមិនគ្រប់គ្រាន់។ ការដាំវាមិនគ្រប់នឹងការកាប់បំផ្លាញទេ។ ឥឡូវនេះ **វិធានការទប់ស្កាត់កំពុងតែត្រូវបានពង្រឹងតាមរបៀបដូចនៅ តំបន់ឫស្សីត្រឹប ជាង ១ម៉ឺនហិកតា ជាតំបន់ការពារ និងមានតំបន់ការពារផ្សេងទៀត ... ដោយធ្វើសកម្មភាព មិនមែនការពារទុកបណ្តោយឲ្យមានការកាប់បំផ្លាញនោះទេ** ...៕

១១. វិមជ្ឈការអំណាចឱ្យប្រជាពលរដ្ឋទាញយកផលដើម្បីជួយគ្រប់គ្រងតំបន់ព្រៃឈើ

ដាំកូនឈើនៅឧទ្យានរាជបណ្ឌិតសភាកម្ពុជា តេជោសែន ឫស្សីត្រឹប,

១៨ ឧសភា ២០១៨

... ត្រូវបង្កើតមុខរបរអោយគាត់ រាប់ទាំងយកព្រៃចិញ្ចឹមព្រៃ។ ឧទាហរណ៍ តំបន់ព្រៃសហគមន៍ខ្លះមានផ្តៅ មានវល្លិ៍ ... នៅកន្លែងហ្នឹង។ គាត់ទទួលផលពីកន្លែង

ហ្នឹង គាត់ការពារព្រៃឈើហ្នឹង។ អនុញ្ញាតអោយទទួលផលហ្នឹងជាវល្លិ៍ ជាផ្តៅ ជាស្តីហ្នឹង ដោយ(អនុផលទាំងហ្នឹង)អាចលូតលាស់វិញបាន។ អញ្ចឹង យើងអោយឱ្យកមកកែច្នៃធ្វើជារបស់របរសម្រាប់ការប្រើប្រាស់ដូចជាកញ្ច្រែង ដូចជាល្អី ដូចជាស្តី ដែលអាចធ្វើបាន ... តាមរយៈនោះ ពួកគាត់នឹងការពារព្រៃហ្នឹង។ គាត់មិនបំផ្លាញព្រៃហ្នឹងទេ។ គាត់ចូលរួមការពារ ព្រោះគាត់ទទួលផលពី(របស់អស់ទាំង)ហ្នឹង។ គាត់មិនបំផ្លាញដើមទុន ឬឆ្នាំងបាយរបស់ពួកគាត់ទេ។ ត្រូវធ្វើរឹមជ្បាការកាន់តែច្រើន ប្រគល់អំណាចអោយប្រជាពលរដ្ឋជួយគ្រប់គ្រងតំបន់នេះ ...។

១២. វិថីស្អាត ម្ហូបឆ្ងាញ់ នឹងប្រកួតប្រជែង ហើយមិនប្រមូលផ្តុំទេសចរតែមួយកន្លែង

ទីក្រុងស្អាតលើកទី ៧ ឆ្នាំ ២០១៩ ក្រោមប្រធានបទ«ទីក្រុងស្អាត៖ ទីក្រុងផ្តល់ភាពកក់ក្តៅ», ២៥ កុម្ភៈ ២០១៩

... អនាម័យចំណីអាហារជាបញ្ហាធំ ដើម្បីធានាថាភ្ញៀវទេសចរមកកម្ពុជាដើម្បីស្វែងរកចំណីអាហារដែលមានរសជាតិឆ្ងាញ់។ ឥឡូវនេះ **ដាក់ចេញនូវគោលដៅស្តង់ដារវិថីម្ហូបអាហារ និងបង្កើតឲ្យមានការប្រកួតប្រជែងតាមវិថីនានា ដែលលក់ម្ហូបអាហារ**។ បើសិនជាវិថីនេះឆ្ងាញ់ពិសា ទេសចរច្បាស់ជាចូលចិត្តមកទាំងថ្ងៃទាំងយប់។ មកតាមវិថីហ្នឹង។ ប៉ុន្តែ មួយទៀត បើចង់បានឲ្យទេសចរទៅហ្នុងដែរ វាទាល់តែប្រឹងសំអាតផ្លូវ។ អញ្ចឹង ព្រួញមួយបាញ់បានសត្វពីរ។ **បើវិថីទាំងអស់នៅទីក្រុងភ្នំពេញ ជាវិថីដែលស្អាតទាំងអស់ ម្ហូបឆ្ងាញ់ទាំងអស់ អញ្ចឹងទេ វាចាប់ផ្តើមប្រកួតប្រជែងហើយទាញទេសចរទៅ ដែលមិនប្រមូលផ្តុំតែនៅមួយកន្លែងទេ**។ អញ្ចឹងទេ ត្រូវយកចិត្តទុកដាក់ទៅលើចំណុចនេះ ...។

១៣. ទំនប់ទឹកស្អាតកំពត តម្កល់ទឹកនិងទប់កុំឱ្យទឹកប្រៃចូល

សម្ពោធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខេត្តកំពតជំនួយជប៉ុន, ២ មេសា ២០១៩

... ត្រូវធ្វើទំនប់បង្ហៀរមួយតម្កល់ទុកនៅខាងលើ ... **ដើម្បីបូមមកផ្គត់ផ្គង់ខាងនេះ។ ប៉ុន្តែ ផលប្រយោជន៍ដែលសំខាន់មួយទៀត គឺទប់ស្កាត់កុំឱ្យទឹកប្រៃចូលទៅកន្លែងដែលយើងបូមទឹក**។ នេះជាចំណុចដែលត្រូវមើលឱ្យអស់។ រដ្ឋមន្ត្រីទាំងប៉ុន្មានត្រូវប្រជុំគ្នា ... រួចហើយរាយការណ៍ឱ្យខ្ញុំ។ ឥឡូវ ថាលុយហ្នឹងបានយកមកហើយ តែមួយឆ្លើយដាក់មួយ។ បើដូច្នេះ ឱ្យក្រសួងឧស្សាហកម្មនិងសិប្បកម្ម

(ដើរតួជា)ម្ចាស់គម្រោង ឯក្រសួងធនធានទឹក(ឧតុនិយម) ជាអ្នកអភិវឌ្ឍគម្រោងការនេះ ... គឺសមត្ថភាពរបស់ក្រសួងធនធានទឹក ...។

១៤. អនុវត្តយុទ្ធនាការអនាម័យតាំងពីប្រជាជនធម្មតារហូតដល់អ្នកមុខអ្នកការ

ទិវាជាតិទីក្រុងស្អាតលើកទី១១ ឆ្នាំ ២០២៣, ២៧ កុម្ភៈ ២០២៣

... យើងបានខិតខំច្រើនអំពីយុទ្ធនាការនានាសម្រាប់អនាម័យ ... យើងបានមើលឃើញរួចហើយពីទិដ្ឋភាពទាំងឡាយ ទាក់ទងនឹង(បរិស្ថាន)។ កាលពីពេលមុននោះ ស្បោងផ្លាស្ទិកហើរតាមខ្យល់។ ឥឡូវនេះ បណ្តាទីក្រុង ទីប្រជុំជន បានកាត់បន្ថយច្រើនហើយ។ នៅតែសេសសល់បញ្ហាមួយចំនួន ដែលយើងត្រូវយកចិត្តទុកដាក់អប់រំប្រជាជនឲ្យយល់ដឹងថា **(កិច្ចការ)នេះ(គឺដើម្បីអនាគតកម្ពុជា)ជាទឹកដីរបស់ពួកគាត់។ (ដោយហេតុថា)អ្វីៗជារបស់ពួកគាត់ៗ ត្រូវចូលរួម(ថែរក្សា)។ អ្នកណាក៏ដោយត្រូវតែចូលរួម ចាប់តាំងពីប្រជាជនធម្មតារហូតទៅដល់អ្នកមុខអ្នកការជាន់ខ្ពស់។ មិនមែនគ្រាន់តែអ្នកទីក្រុងទេ អ្នកនៅជនបទក៏ត្រូវតែជម្រុញស្ថានភាពអនាម័យនេះឲ្យបានល្អប្រសើរ ព្រោះមិនគ្រាន់តែជាការទាក់ទាញទេសចរទេ ក៏ប៉ុន្តែទាក់ទងនឹងសុខភាពនិងភាពស្អាតរបស់ប្រជាពលរដ្ឋ** ...។

១៥. សំអាតនិងការពារសមុទ្រ ទន្លេ ព្រៃកនានា ពីកាកសំណល់ផ្លាស្ទិក

ទិវាជាតិទីក្រុងស្អាតលើកទី១១ ឆ្នាំ ២០២៣, ២៧ កុម្ភៈ ២០២៣

... រឿងផ្លាស្ទិក ខ្ញុំសូមអបអរសាទរ និងអរគុណចំពោះមហាសន្និបាតឆ្នេរសមុទ្រស្អាតបំផុត ធ្វើឡើងនៅឯខេត្តព្រះសីហនុនាពេលកន្លងទៅ ដែលបានយកអនុសាសន៍របស់ខ្ញុំដាក់ក្នុងសេចក្តីសម្រេចចិត្តស្តីពីផ្លាស្ទិក។ **ផ្លាស្ទិកអាចជារឿងធ្ងន់ធ្ងរនៅក្នុងរង្វង់២០, ៣០ ឬ ៥០ឆ្នាំក្រោយ។ ផ្លាស្ទិកបានហូរចូលក្នុងសមុទ្រ ទន្លេ បឹងបួ។** ផ្លាស្ទិកនេះ មិនរលាយដូចក្រដាសទេ។ តើនៅក្នុងសមុទ្រ ទន្លេ បឹងបួ លើពិភពលោកមានផ្លាស្ទិកប៉ុន្មាន ហើយនឹងបង្កផលប៉ះពាល់បែបណា? **កម្ពុជាត្រូវចូលរួមចំណែកជាមួយប្រទេសនានា ដោយយើងមានសមុទ្រ ទន្លេ និងព្រៃក ច្រើន ... សូរថាមួយឆ្នាំៗ ផ្លាស្ទិកធ្លាក់ទៅក្នុងប្រព័ន្ធទាំងនោះប៉ុន្មាន ហើយនៅទីហ្នឹង មិនរលាយទេ ទោះជា ១០០ឆ្នាំ ក៏មិនរលាយទៅណាដែរ** ...។

១៦. រួមគ្នាកាត់បន្ថយបញ្ហាប្រឈមពីផ្លាស្ទិកក្នុងសមុទ្រ ទន្លេ ព្រែក និងបឹងបួ

ទិវាជាតិទីក្រុងស្អាតលើកទី១១ ឆ្នាំ ២០២៣, ២៧ កុម្ភៈ ២០២៣

... បញ្ហា(ផ្លាស្ទីក)នេះ ទាមទារឲ្យមានការគិតគូរផ្នែកបរិស្ថាន។ ត្រូវគិតពីការបន្ថយការប្រើប្រាស់ផ្លាស្ទិក មកប្រើប្រាស់អ្វីផ្សេងជំនួសវិញ។ ខ្ញុំគិតថា ឯកឧត្តម លោកជំទាវ អគ្គរដ្ឋទូត អគ្គរាជទូត ប្រិយ៍មិត្តបរទេស បានស្តាប់ពីកង្វល់ទាំងនេះតាមរយៈអង្គប្រជុំនានា ដែលលើកឡើងពីការព្រួយបារម្ភស្តីពីបញ្ហាផ្លាស្ទិក(ដែលធ្លាក់ចូលទៅ)ក្នុងសមុទ្រ។ **កម្ពុជាបានទៅហួសពីនេះ គឺមិនមែនព្រួយបារម្ភតែផ្លាស្ទិកក្នុងសមុទ្រទេ តែក៏ព្រួយបារម្ភពីផ្លាស្ទិកតាមដងទន្លេ ព្រែក បឹងបួរ ដែលខ្លួនមាន។ ក្នុងក្របខណ្ឌជាតិ យើងត្រូវរួមគ្នាជាមួយដៃគូកាត់បន្ថយបញ្ហាប្រឈម ឬលុបបំបាត់បញ្ហាប្រឈម។ ទោះបីថាការលុបទាំងស្រុងវាជាការលំបាកក៏ដោយ (ក៏យើងខំប្រឹងដើម្បីកុំឲ្យ)ផ្លាស្ទិកកើនច្រើនក្នុងបឹងបួ សមុទ្រ ទន្លេ ព្រែក** ... ៕

១២. រៃសណីយ៍ និងទូរគមនាគមន៍

១	សិក្ខាពីការប្តូរប្រព័ន្ធ Analog ទៅជាប្រព័ន្ធ Digital	២១៧
២	ដើរទាន់ជាមួយនឹងយុគបច្ចេកវិទ្យានៃសម័យកាលឌីជីថល	២១៧
៣	ដំឡើងអង់តែនអោយបានច្រើន បើកឱ្យក្រុមហ៊ុនផ្តល់សេវា Internet ចូលតាមឃុំ	២១៧
៤	ផ្តល់ឱកាសប្រកួតប្រជែង ដើម្បីបានសេវាអ៊ីនធើណេតប្រើល្អ	២១៨
៥	មន្ត្រីរាជការមិនចេះបច្ចេកវិទ្យាព័ត៌មាន នឹងមិនត្រូវបានតែងតាំងមុខតំណែង	២១៨
៦	ឌីជីថលូបនីយ៍កម្ម រីកចម្រើនក្នុងសម័យកូវីដ-១៩	២១៩
៧	ដៃគូបរទេសវិនិយោគក្នុងផ្នែកប្រព័ន្ធទូរស័ព្ទមានរៀតណាម ថៃ ម៉ាឡេស៊ី ...	២១៩
៨	អ្នកប្រើហ្វេកប៊ុក/បណ្តាញសង្គមហាមយកវឿងសន្តិសុខជាតិមកបង្ហោះ	២២០
៩	ទូរទស្សន៍៣ សហការកសាងថ្នាលការផ្សាយប្រើប្រព័ន្ធឌីជីថល	២២០
១០	គ្មានប្រទេសណាមួយមើលរំលងឧក្រិដ្ឋកម្មអ៊ីនធើណេតទេ	២២០

១. សិក្សាពីការប្តូរប្រព័ន្ធអាណាឡូក (Analog) **ទៅជាប្រព័ន្ធឌីជីថល**(Digital)
ជួបសំណេះសំណាល និងពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានជាតិ
និងមន្ត្រីចំណុះក្រសួងព័ត៌មាន, ១១ មករា ២០១៩

... **អំពី(ការប្តូរពីប្រព័ន្ធអាណាឡូក ទៅប្រព័ន្ធឌីជីថល)នេះ មានចំណោទ ២ យ៉ាង។ ចំណោទទី ១ គឺប្រទេសជិតខាងយើងនឹងទទួលរងនូវផែលប៉ះពាល់ពីការផ្សព្វផ្សាយប្រព័ន្ធអាណាឡូក របស់យើងលើបណ្តាខេត្តនៅជាប់តាមព្រំដែន** ជាមួយនឹងប្រទេសកម្ពុជា។ ឯ**ចំណោទទី២ ការបន្តប្រើប្រព័ន្ធអាណាឡូក ក្រុមហ៊ុនលែងផលិតសំភារៈបរិក្ខានេះយកមកប្រើប្រាស់** ... គួរពិភាក្សាបញ្ហានេះ ដើម្បីយើងសំរេចថាដកថយមកនៅកម្រិតត្រឹមប៉ុណ្ណា ឬក៏យើងធ្វើតាមលទ្ធភាពថាក្រុមហ៊ុនណាដែលមានលទ្ធភាពឈានមុនទៅ។ តើអាចទៅរួចទេ រវាងក្រុមហ៊ុនដែលអាចទៅមុនបាន និងក្រុមហ៊ុនដែលអាចទៅក្រោយ កុំរង់ចាំមួយពេល ...។

២. ដើរទាន់ជាមួយនឹងយុគបច្ចេកវិទ្យានៃសម័យកាលឌីជីថល
ជួបសំណេះសំណាល និងពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានជាតិ
និងមន្ត្រីចំណុះក្រសួងព័ត៌មាន, ១១ មករា ២០១៩

... គួរតែត្រូវលើក**មកពិចារណាមួយគ្នាជាការកដោះស្រាយ ដើម្បីអោយដើរទាន់ជាមួយយុគបច្ចេកវិទ្យានៃសម័យកាលឌីជីថល ...** សូមអោយក្រសួងដែលពាក់ព័ន្ធជាមួយនឹងប្រធានបទនេះ គឺក្រសួងព័ត៌មាន និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (រួមគ្នាពិចារណា) ព្រោះនេះជាប្រព័ន្ធដែលពាក់ព័ន្ធ។ **កាលណាយើងប្រើប្រាស់ប្រព័ន្ធឌីជីថលហើយ យើងនឹងយកប្រព័ន្ធដែលកំពុងប្រើនៅក្នុងទូរទស្សន៍សព្វថ្ងៃនេះ** ទៅប្រើទៅលើប្រព័ន្ធទូរស័ព្ទវិញ ដែលអាចប្រើប្រាស់បានល្អជាង ហើយវាចំណេញជាង ...។

៣. ដំឡើងអង់តែនអោយបានច្រើន បើកឲ្យមានក្រុមហ៊ុនផ្តល់សេវាInternetចូលតាមប៊ី
សម្ពោធនិងចែកសញ្ញាបត្រនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ,
២៤ ឧសភា ២០២៣

មន្ត្រីដែលធ្វើការជាមួយខ្ញុំ ច្រើនតែនៅតាមបុរី ... សូមរំលឹកទាំងម្ចាស់ក្រុមហ៊ុនដែលលក់អីនធើណេតទាំងម្ចាស់បុរីនានា **យកវិធានការដែលក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានដាក់ចេញកន្លងទៅ។ សូមឱ្យដំឡើងអង់តែនឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ... ក្រុមហ៊ុនមួយចូលកន្លែងហ្នឹងបាន ដល់ក្រុមហ៊ុនដទៃចូលមិនបាន។ ក្រុមហ៊ុនដែលចូលបានហ្នឹង មិនផ្តល់សេវាទេ ជាពិសេសហូមអីនធើណេត ធ្វើការមិនបាន ... គេដើរដល់ 5G ហើយ ឯងនៅត្រឹម២G ទៅម្តេចរួច ... រាជដ្ឋាភិបាលទទួលយកមិនបានទេ។ គ្រប់ទីតាំងត្រូវបើកឱកាសឱ្យគេចូល** ... ធ្វើយ៉ាងដូច្នេះលោកអ្នកនឹងលក់ផ្ទះដាច់។ កន្លែងមិនមានសេវាទូរស័ព្ទ លោកអ្នកលក់ផ្ទះក៏វាមិនដាច់ដែរ ...។

៤. ផ្តល់ឱកាសប្រកួតប្រជែង ដើម្បីបានសេវាអ៊ីនធើណេតប្រើល្អ

សម្ពោធនិងចែកសញ្ញាបត្រនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ,
២៤ ឧសភា ២០២៣

... (ឈានទៅប្រព័ន្ធ)ឌីជីថលយ៉ាងម៉េចបើម្ចាស់ឌីជីថលមិនព្រមធ្វើ។ ខ្ញុំសូមរំលឹកជាសាជាថ្មី ឱ្យត្រួតពិនិត្យនិងឱ្យទាញ(ខ្សែចូល)ទៅ។ នៅផ្ទះខ្ញុំ បានទាញ៣បណ្តាញចូល។ បណ្តាញ២ ប្រើ និងបណ្តាញមួយសង្គ្រោះ។ បើសិនជាបណ្តាញមួយអាក់រអួល ខ្ញុំចូលទៅបណ្តាញមួយទៀត ... ឥឡូវធ្វើការតាមរបៀបបច្ចេកវិជ្ជាព័ត៌មានតាមឌីជីថល ... បើសិនជាមកតែមកមួយបណ្តាញមិនអាចទៅរួចទេ ព្រោះអ្នកខ្លះប្រើ០១២ អ្នកខ្លះប្រើ០៩៧ អ្នកខ្លះស្មាត អ្នកខ្លះប្រើ Seatel ... ***ត្រូវ*****ឱ្យឱកាសប្រកួតប្រជែងដើម្បីឈ្នះទាំងអស់គ្នា** ... អត់អីនធើណេតស្មើនឹងអត់បាយ ឬអត់បាយគឺអត់បាន ប៉ុន្តែអត់អីនធើណេតអត់មិនបានទេ ...។

៥. មន្ត្រីរាជការមិនចេះបច្ចេកវិទ្យាព័ត៌មាន នឹងមិនត្រូវបានតែងតាំងមុខតំណែង

ពិធីចែកសញ្ញាបត្រដល់និស្សិតនៃសាកលវិទ្យាល័យពុទ្ធិសាស្ត្រ, ១៧ សីហា ២០២២

... ខ្ញុំបាននិយាយច្រើនដងហើយ យើងមិនតែងតាំងមន្ត្រីរាជការណា ដែលមិនចេះប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(អោយកាន់មុខតំណែងទេ) គឺធ្វើអក្ខរកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ហោចណាស់ប្រព័ន្ធទូរស័ព្ទគឺគ្រប់គ្រាន់ហើយ ព្រោះក្នុងស្មាតហ្នឹងនេះមានគ្រប់នៅក្នុងហ្នឹង។ ចេះប៉ុណ្ណឹងហ្នឹងទើបអាចធ្វើការជាមួយគេបាន។ ឧទាហរណ៍ សព្វថ្ងៃនាយករដ្ឋមន្ត្រីធ្វើការដោយមានគ្រុបរបស់(រាជ)រដ្ឋាភិបាល គ្រុបជាមួយអភិបាលខេត្ត គ្រុបជាមួយផ្នែកនេះ/នោះ អញ្ចឹង Add អ្នកឯងចូលម៉េចបាន បើអ្នកឯងអត់ទាំងចេះមើល អ្នកឯងអត់ទាំងមាន WhatsApp, Telegram ផងនោះ។ អញ្ចឹង មិនអាចទទួលបាននូវការចាត់តាំងទេ ...។

៦. ឌីជីថលលុបនីយ៍កម្ម វីកចម្រើនក្នុងសម័យកូវីដ-១៩

ប្រគល់សញ្ញាបត្រជូននិស្សិតវិទ្យាស្ថាន វ៉ាន់ដា, ២២ មីនា ២០២៣

... ខ្ញុំក៏បានមើលការផ្សាយបន្តផ្ទាល់ពី BTV ដែលធ្វើសម្ភាសន៍ទាក់ទិននឹងការរៀនតាមអនឡាញ ដែលគ្រូមានការលំបាកនឹងឆ្លើយតបទៅសំណួរបស់និស្សិតដោយចំនួនសិស្សច្រើនពេក ... **កូវីដ-១៩ វា(ជាស្ថានភាពសុកាពសាធារណៈមួយ)អាក្រក់ ក៏ប៉ុន្តែវាក៏បង្កប់នូវកាលានុវត្តភាពរបស់វាទាក់ទិនជាមួយនឹងការវីកចម្រើនឌីជីថលនេះ។ ឌីជីថលវីកចម្រើនខ្លាំងក្នុងវិស័យអប់រំ។ នេះគឺជាចំណុចល្អសម្រាប់ប្រទេសយើង។ ប៉ុន្តែ យើងមិនចង់ឱ្យមានកូវីដ-១៩ ដើម្បីរៀនតាមអនឡាញទៀតទេ ព្រោះមិនមែនជាការងាយស្រួលទេ ...។**

៧. ដៃគូបរទេសវិនិយោគក្នុងផ្នែកប្រព័ន្ធទូរស័ព្ទមានវៀតណាម ថៃ ម៉ាឡេស៊ី ...

បើកការដ្ឋានសាងសង់ផ្លូវល្បឿនលឿន ក្រុងភ្នំពេញ-ខេត្តព្រះសីហនុ, ២២ មីនា ២០១៩

... យើងកំពុងត្រូវការទុនបន្ថែមពីដៃគូអភិវឌ្ឍន៍ ក្នុងនោះគឺមិត្តចិនជាប្រភពទុនមួយដែរ។ និយាយយ៉ាងដូច្នេះ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនបដិសេធដៃគូបរទេសណាទាំងអស់។ សូមអញ្ជើញមកវិនិយោគ។ **សូមអញ្ជើញផ្តល់ប្រាក់កម្ចីឱ្យកម្ពុជាបន្តទៅទៀត ... វៀតណាមវិនិយោគមិនតិចទេនៅកម្ពុជា។ ទូរស័ព្ទប្រព័ន្ធ Metfone គ្របដណ្តប់ទូទាំងប្រទេសហ្នឹងជាប្រព័ន្ធមួយខ្លាំង ... ថៃក៏មានការវិនិយោគក្នុងប្រទេសកម្ពុជា ... ម៉ាឡេស៊ី វិនិយោគប្រព័ន្ធ Smart នេះ ... និងមានមកពីកូរ៉េខាងត្បូង មកពីជប៉ុន មកពីអាមេរិក មកពីអឺរ៉ុប មកពីប្រទេសនានា ...។**

៨. អ្នកប្រើហ្វេកប៊ុក/បណ្តាញសង្គមហាមយករឿងសន្តិសុខជាតិមកបង្ហោះ

សំណេះសំណាលកម្មករក្បែររោងចក្រស៊ីកឺ ស្រុកអង្គស្នួល ខេត្តកណ្តាល,
២៩ មិថុនា ២០២៣

ពួយប់មិញនេះ ម្ខាងតាមដានជ្រូនវាមកទៀតឬអត់ ? ថាអត់មានមកទេ ... មានហ្វេកប៊ុកពីរបង្ហោះថា ជ្រូនមកដល់ក្រុងបានលុង។ វាមានបានគិតពីជ្រូននិងយន្តហោះពាណិជ្ជកម្មឯណា។ ដល់ពេលស្រែកទៅវាលុបចេញ ... ស្រុកខ្មែរជាផ្លូវឆ្លងកាត់នៃយន្តហោះច្រើន ... **ខ្ញុំសូមផ្តាំផ្ញើអ្នកលេងហ្វេកប៊ុកទាំងអស់ហាមជាច់ខាតយករឿងសន្តិសុខជាតិមកបង្ហោះហ្វេកប៊ុក។ បើគ្មានបទបញ្ជា គ្មានការអនុញ្ញាតពីផ្នែកយោធា មិនអាច(បង្ហោះ)លេងសើចទេ** ...។

៩. ទូរទស្សន៍៣ សហការកសាងថ្នាលការផ្សាយប្រើប្រព័ន្ធឌីជីថល

សំណេះសំណាលនិងពិសាអាហារសាមគ្គីជាមួយអ្នកសារព័ត៌មានលើកទី៥,
១៤ មករា ២០២៣

... យើងឃើញថា ពេលដែលយន្តហោះចាប់ផ្តើមហោះហើរ គេស្នើឱ្យយើងបិទទូរស័ព្ទ ... ត្បិតវាធ្វើឱ្យដំណើរការនៃការហោះហើរ ឬប្រតិបត្តិការដែនអាកាសត្រូវជួបការរំខានដោយសារការផ្សាយនៅខាងក្រោមរបស់យើង។ នេះជាចំណុចទី១ ដែលសូមឱ្យឯកឧត្តមរដ្ឋមន្ត្រីបន្តការខិតខំ។ **បើនិយាយពីប្រព័ន្ធឌីជីថល វាមិនមែនគ្រាន់តែត្រូវការរដ្ឋមន្ត្រីទេ តែត្រូវការគ្រប់ផ្នែកនៃវិស័យឯកជនដែលមានទូរទស្សន៍ មានវិទ្យុមានស្តីៗ ហ្នឹង ត្រូវប្រើតាមប្រព័ន្ធឌីជីថល។ អ្នកដែលប្តូរបានមុនគឺប្តូរទៅ ... មានថ្នាលដែលត្រូវបានវិនិយោគរួមគ្នាដោយក្រសួងព័ត៌មានកាន់ភាគហ៊ុនមួយផ្នែកដើម្បីគ្រប់គ្រង។ គេថាក្តាប់ភាគហ៊ុនដោយមិនមែនទុន ប៉ុន្តែមានអាជ្ញាប័ណ្ណជាភាគហ៊ុន។ ក្រៅពីនោះមានទូរទស្សន៍បីចាប់ដៃគ្នាសហការកសាងថ្នាលឌីជីថលនេះ** ...។

១០. គ្មានប្រទេសណាមួយមើលរំលងឧក្រិដ្ឋកម្មអ៊ីនធើណែតទេ

ពិធីសំណេះសំណាលជាមួយយុវជន សិស្ស និស្សិតដែលកំពុងសិក្សានៅប្រទេសតួគី,
២១ តុលា ២០១៨

... បញ្ហាព័ត៌មានវិទ្យានេះ នៅពេលប្រជុំអាស៊ី-អឺរ៉ុបនេះ គឺធ្ងន់ធ្ងរណាស់។ គ្មានប្រទេសណាមួយមើលរំលងលើបញ្ហាឧក្រិដ្ឋកម្មអ៊ីនធើណែតទេ ហើយប្រទេសមួយចំនួនកំពុងធ្វើច្បាប់ ដើម្បីដាក់ទោសទៅលើព័ត៌មានក្លែងក្លាយ រាប់ទាំងប្រទេសបារាំង។ នៅអាល្លឺម៉ង់ ដូចមានរួចហើយ អំពីបញ្ហាព័ត៌មានក្លែងក្លាយព្រោះវាប្រឌិតរឿងអញ្ចេះ ប្រឌិតរឿងអញ្ចុះ គ្រប់សព្វហើយ។ នៅប្រទេសយើងក៏មានមួយក្រុមដែរ។ យើងនៅក្នុងអាស៊ាន គឺសាំងហ្គាពួរខ្លាំងជាងគេហើយរឿងផ្នែក IT ប៉ុន្តែនាយករដ្ឋមន្ត្រីសាំងហ្គាពួរគាត់ប្រកាសថា ហ្វេសប៊ុកគាត់ត្រូវគេhack។ គេហៅថា បណ្តាំព័ត៌មានរបស់គាត់ត្រូវគេ log ចូល។ វាធ្វើអីពូមិនបានវាមកលួចហ្វេសប៊ុកពូ ហើយយើងដឹងមុខសញ្ញាហ្នឹង ព្រោះវាបង្ហោះ វាបង្ហោះស្អី? វាបង្ហោះថាទី ១ យើងចែកកៅអីឲ្យបក្សជទៃ។ មួយទៀត វាសរសេរថា អរគុណចំពោះប្រជាជនហ្វីលីពីន ប្រជាជនមីយ៉ាន់ម៉ា ប្រជាជនឥណ្ឌា ដែលជួយ like ឲ្យខ្ញុំ។ អញ្ចឹងមានអ្នកណា? មានតែអ្នកលេងហ្វេសប៊ុកចាញ់ខ្ញុំ មករករឿងខ្ញុំ ប្តឹងទៅហ្វេសប៊ុកហ្នឹងហើយ។ ខូចមែន! មនុស្សនេះ អានេះរាប់អានគ្នាមិនបានទេ...។

១៣. ផែនការ

១	អត្រាកំណើតប្រជាជនថយពី ៣,៨ឆ្នាំមក ២,៤ឆ្នាំ តែចំណោលទៅតែ២០លាននាក់	២២៥
២	ធ្វើជំរឿនដើម្បីមានទិន្នន័យគ្រប់គ្រាន់ ដាក់ចេញជាចក្ខុវិស័យអភិវឌ្ឍប្រទេស	២២៥
៣	តួលេខពីមហាផ្ទៃ ផែនការនិងសុខាភិបាលបង្ហាញអត្រាកំណើតមិនខុសគ្នាច្រើនទេ	២២៥
៤	ផ្អែកតាមកំណត់ត្រាសុខាភិបាល ក្នុង៣ឆ្នាំនឹងមានកំណើនប្រជាជន ១,២លាននាក់	២២៦
៥	ការសង្ឃឹមរស់ ឡើងពី ៥៦ឆ្នាំ នៅឆ្នាំ១៩៩៨ ដល់ជាង ៧០ឆ្នាំ នាបច្ចុប្បន្ន	២២៦
៦	អត្រាវ័ណរស់របស់ប្រជាជនកម្ពុជាបច្ចុប្បន្នគឺ៧៦ ឆ្នាំ	២២៦
៧	បើរស់បាន ២០ឆ្នាំទៀត នឹងបានឃើញប្រជាជនកើនដល់ ២០លាន(នាក់)	២២៧

១. អត្រាកំណើតប្រជាជនពី ៣,៨/ឆ្នាំ មក ២,៤/ឆ្នាំ ... ចំណោលទៅរក ២០លាននាក់

សំណេះសំណាលជាមួយកម្មករ នៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង,
១០ មិថុនា ២០២៣

... **អត្រាកំណើតបច្ចុប្បន្ន ២,៤ ក៏មិនជា(ទាប)ពេកទេ ប៉ុន្តែនៅតែទាបជាងក្រោយរំដោះ(ដែលមានរហូតដល់) ៣,៨។ ក្នុងមួយឆ្នាំ យើងកើនចំនួនប្រជាជនប្រមាណជា ៣០ម៉ឺននាក់។ យើងបានធ្វើចំណោលទៅឃើញថា ពេលណាមួយប្រជាជនយើងនឹងឡើងដល់ ២០លាននាក់។ យើងបានចាប់ផ្តើមពីប្រជាជនត្រឹមតែជុំវិញ ៥លាននាក់(ក្រោយពីប្រទេសត្រូវបានរំដោះពីរបប ប៉ុល ពត)។** ឥឡូវយើងមានប្រជាជនជាង ១៧លាននាក់។ ក្មួយៗមួយចំនួនដែលកំពុងមានផ្ទៃពោះនេះតែមិនស្រួលកើតក្រោយឆ្នាំ ១៩៧៩ទេ ...។

២. ធ្វើជំរឿនដើម្បីមានទិន្នន័យគ្រប់គ្រាន់ ដាក់ចេញជាចក្ខុវិស័យអភិវឌ្ឍប្រទេស

ចែកសញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច,
១១ មីនា ២០១៩

... **ក្នុងនាមរាជរដ្ឋាភិបាល សូមអំពាវនាវចំពោះប្រជាជនដែលមិនទាន់បានធ្វើជំរឿន បន្តខំ(លៃពេល)ចូលធ្វើជំរឿន។ មកដល់ថ្ងៃនេះ នៅសល់តែ ៣ថ្ងៃទៀតទេ ... អ្នកដែលមិនទាន់ធ្វើជំរឿន សូមផ្តល់កិច្ចសហការ ព្រោះពេលវេលាជិតដល់ហើយ។ ជំរឿនជាការចាំបាច់ដើម្បីយើងមានទិន្នន័យគ្រប់គ្រាន់ដាក់ចេញជាចក្ខុវិស័យទៅអនាគតក្នុងការអភិវឌ្ឍប្រទេស។** សូមបងប្អូនបង្កលក្ខណៈសម្បត្តិឱ្យមន្ត្រីជំរឿនរបស់យើងបានចូលទៅកាន់លំនៅឋានរបស់ខ្លួនដើម្បីធ្វើជំរឿន ...។

៣. តួលេខពីមហាផ្ទៃ ផែនការនិងសុខាភិបាល បង្ហាញអត្រាកំណើតមិនខុសគ្នាច្រើនទេ

ចែកសញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច,
១១ មីនា ២០១៩

... តើប្រទេសរបស់យើងមានប្រជាជនប៉ុន្មានពិតប្រាកដ? **សព្វថ្ងៃយើងប្រើជើងលេខដែលមួយផ្នែកបានពីក្រសួងមហាផ្ទៃ តាមរយៈមន្ត្រីអត្រានុកូលដ្ឋានមួយផ្នែកបានពីវិទ្យាស្ថានស្ថិតិរបស់ក្រសួងផែនការ និងមួយផ្នែកទៀតបានមកពី**

ខាងមន្ទីរពេទ្យ(ដែលកត់ត្រា)អត្រាកំណើតដែលបានផ្តល់ក្នុងមួយឆ្នាំៗ ... តួលេខទាំងនោះក៏មិនខុសគ្នាឆ្ងាយគ្នាប៉ុន្មានទេ។ ពេលខាងមុខដែលយើងនឹងដាក់ឱ្យអនុវត្តនយោបាយគាំពារសង្គមសម្រាប់ស្ត្រីមានផ្ទៃពោះនិងឆ្លងទន្លេ យើងអាចដឹងបានអំពីអត្រាកំណើតក្នុងមួយឆ្នាំៗប៉ុន្មាន ...៕

៤. ផ្អែកតាមកំណត់ត្រាសុខាភិបាល ក្នុង៣ ឆ្នាំនឹងមានកំណើនប្រជាជន ១,២លាននាក់

សំណេះសំណាលជាមួយកម្មករ និយោជិតនៅស្រុកត្រាំកក់ ខេត្តតាកែវ, ៩ មករា ២០១៩

... ចំនួនប្រជាពលរដ្ឋយើងបានកើនឡើងជុំវិញ ១៦លាននាក់ គឺកើន ១០លាននាក់ ... **យើងអាចដឹងបានតាមរយៈស្ថិតិរបស់ក្រសួងសុខាភិបាលប្រចាំឆ្នាំ ដែលកត់ត្រាថាក្នុងមួយឆ្នាំមានកើតជាង ៤០ម៉ឺននាក់។ (បើផ្អែកតាមតួលេខនេះ) គិតទៅតែ ៣ឆ្នាំ យើងមានកំណើន ១លាន ២សែននាក់ ... គ្រាន់តែក្នុងកម្មករបាន ៦ម៉ឺននាក់ដែរ ស្មានថាតិចឬ ... ជឿថានៅឆ្នាំ២០១៩ ក្នុងចំណោមកម្មកនឹងមានកូនដល់ ៧ម៉ឺននាក់ ...៕**

៥. ការសង្ឃឹមរស់ ឡើងពី ៥៦ឆ្នាំ នៅឆ្នាំ១៩៩៨ ដល់ជាង ៧០ឆ្នាំ នាបច្ចុប្បន្ន

សម្ពោធដាក់ឲ្យប្រើប្រាស់ មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនត្បូងឃ្មុំ, ០៧ មីនា ២០២២

... ខ្ញុំសូមជម្រាបជូនប្រជាពលរដ្ឋរបស់យើងឲ្យបានជ្រាប នៅ**ឆ្នាំ១៩៩៨ ប្រជាជនដែលមានសង្ឃឹមរស់ពេលនោះជាមធ្យមត្រឹមតែ ៥៦ឆ្នាំតែប៉ុណ្ណោះ។ មកដល់បច្ចុប្បន្ន អាយុសង្ឃឹមរស់របស់ប្រជាជនមានរហូតដល់ជាង ៧០ឆ្នាំ**។ គេគិតថាអ្នកខ្លះអាចស្លាប់(នៅអាយុ) ៦០ឆ្នាំ អ្នកខ្លះអាចស្លាប់(នៅអាយុ) ៥៥ឆ្នាំ ប៉ុន្តែអ្នកខ្លះស្លាប់(នៅអាយុ) ៨០ឆ្នាំ ឬដល់អាយុ ៩០ឆ្នាំ។ សរុបមក ឥឡូវហ្នឹង(ការសង្ឃឹមរស់)នៅកម្ពុជាមានជាង ៧០ឆ្នាំ។ សុខុមាលភាពរបស់ប្រជាជនរបស់យើងត្រូវបានធានា ជាការទទួលផលពីសុខសន្តិភាព ទទួលផលពីការអភិវឌ្ឍក្នុងវិស័យសុខាភិបាលរបស់យើង ...៕

៦. អត្រារំពឹងរស់របស់ប្រជាជនកម្ពុជាបច្ចុប្បន្នគឺ៧៦ ឆ្នាំ

ជួបកម្មករ នៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង, ១០ មិថុនា ២០២៣

... ចំណុចដែលគួរកត់សម្គាល់នៅត្រង់ ចំនួនអ្នកមានផ្ទៃពោះដូចជាតិចជាងនេះ ... កើតច្រើនក៏អត់បញ្ហាទេ។ អ្វីដែលគួរអោយព្រួយ គឺការដែលមិនព្រមកើត(ផ្តល់កំណើត)ដែលធ្វើឲ្យមានវិបត្តិ(ប្រជាសាស្ត្រ)ទៅថ្ងៃក្រោយទៅវិញ។ ប្រទេសខ្លះមានកំណើនប្រជាពលរដ្ឋទាប ធ្វើឲ្យ៥០ឆ្នាំក្រោយជួបវិបត្តិ ដោយសារមនុស្សចាស់មានចំនួនច្រើន និងក្មេងមានចំនួនតិចជាង។**មុននេះអត្រារំពឹងរស់នៅកម្ពុជាជាមធ្យម មានត្រឹម៥០ឆ្នាំជាង ប៉ុន្តែឥឡូវ ជាមធ្យមយើងអាចរស់បាន ៧៦ឆ្នាំ។ មនុស្សមានអាយុកាន់តែវែង។ មនុស្សចាស់អាយុវែងនេះហើយដែលយើងត្រូវទទួលបន្ទុក** ... សង្ឃឹមថាយើងនឹងមិនមានវិបត្តិពីបញ្ហា(មនុស្សចាស់ច្រើនជាងក្មេង)នាពេលអនាគត ...៕

៧. បើរស់បាន ២០ឆ្នាំទៀត នឹងបានឃើញប្រជាជនកើនដល់ ២០លាន(នាក់)

ចែកសញ្ញាបត្រជូនដល់និស្សិតនៃសាកលវិទ្យាល័យ វ៉េស្លើន, ២៦ មករា ២០២៣

... អ្នកខ្លះថា ខ្ញុំនៅ ២ឬ ៣ឆ្នាំទៀតនឹងស្លាប់ហើយ ... ជីវិតមនុស្សមិនទៀងទេក៏ប៉ុន្តែ ខ្ញុំមានជំនឿច្បាស់ថា ខ្ញុំនឹងមាន(អាយុ)លើស ៩០(ឆ្នាំ)។ ខ្ញុំនៅចាំមើលរហូតដល់ប្រជាជនកើនឡើងដល់ ២០លាន(នាក់) ពីការចាប់ផ្តើមដែលមានប្រជាជនត្រឹមតែ ៥លាន(នាក់)។ ឥឡូវ ប្រជាជនយើងកើនឡើងដល់ ១៧លាន(នាក់)ហើយ។ **បើខ្ញុំរស់នៅបាន ២០ឆ្នាំទៀត ខ្ញុំនឹងបានឃើញប្រជាជនយើងកើនឡើងប្រមាណជា ២០លាន(នាក់) ជាមួយនឹងបណ្តាសមិទ្ធផលនានា ដែលយើងបានកសាង។** មិនមាននរណាអាចធ្វើនាយករដ្ឋមន្ត្រីរហូតដល់ថ្ងៃស្លាប់ទេ ដូច្នេះអ្នកជំនាន់ក្រោយរាប់ទាំងអ្នកនៅទីនេះត្រូវបន្តកិច្ចការ...៕

១៤. ពាណិជ្ជកម្ម

១	ប្រៃអតីតសមរភូមិទៅជាទីផ្សារ និងតំបន់អភិវឌ្ឍ	២៣១
២	ស្ថិរភាពផ្ទៃក្នុង និងទំនាក់ទំនងជិតខាងល្អ ដើម្បីពាណិជ្ជកម្ម	២៣១
៣	ទាក់ទាញវិនិយោគថ្មី តាមរូបមន្តមួយបួក	២៣១
៤	កែច្នៃផលិតផលកសិកម្មជាផលិតផលសម្រេចដើម្បីនាំចេញ	២៣២
៥	កម្ពុជានាំចូលទៅវៀតណាមច្រើនជាង ក្នុងពេលកូវីដ១៩	២៣២
៦	ខ្វះឃ្លាំង ម៉ាស៊ីនកិន និងទីផ្សារ កម្ពុជានាំស្រូវជាង៧0% ទៅវៀតណាម	២៣៣
៧	ផ្លូវជាតិលេខ២១ សម្រួលការផ្លាស់ប្តូរទំនិញរវាងគ្នាកម្ពុជានិងវៀតណាម	២៣៣
៨	ផ្លូវជាតិ៤៨ របៀងសមុទ្រដឹកទំនិញរហ័សរវាងថៃនិងវៀតណាមឆ្លងកាត់កម្ពុជា	២៣៣
៩	បង្កើតតំបន់សេដ្ឋកិច្ច ទីផ្សារ និងបើកច្រកតាមព្រំដែនកម្ពុជា-ថៃឲ្យកាន់តែច្រើន	២៣៤
១0	សេដ្ឋកិច្ចវៀតណាមនិងសេដ្ឋកិច្ចថៃកើន ជាការអនុគ្រោះដល់សេដ្ឋកិច្ចកម្ពុជា	២៣៤
១១	ច្រកអន្តរជាតិកម្ពុជា-វៀតណាមត្រូវមានកិច្ចព្រមព្រៀងច្រកពាណិជ្ជកម្មទ្វេទិស	២៣៥
១២	បង្កើតផ្សារ ៣កន្លែង តាមដែនការ ដោយក្រសួងពាណិជ្ជកម្មជាអាណាប៉ក	២៣៥
១៣	ត្រូវសង់ផ្សារធំអាយស្របជាមួយការបើកច្រកព្រំដែននៅខាងវៀតណាម	២៣៦
១៤	ស្វែងរកការពង្រីកទំហំពាណិជ្ជកម្មកម្ពុជា/វៀតណាម កម្ពុជា/ថៃ កម្ពុជា/ឡាវ	២៣៦
១៥	ទំហំពាណិជ្ជកម្មធំបំផុត ក្នុងប្រវត្តិទំនាក់ទំនងពាណិជ្ជកម្ម កម្ពុជា-អាមេរិក	២៣៧
១៦	រួមចំណែកក្នុងសង្វាក់ផ្គត់ផ្គង់ស្បៀងក្នុងតំបន់	២៣៧
១៧	FTA កម្ពុជា/ចិន និង RCEP នឹងជួយកម្ពុជានាំចេញផលិតផលកសិកម្មច្រើន	២៣៨
១៨	កម្ពុជានឹងបន្តធ្វើច្បាប់នានា តាមការសន្យាជាមួយអង្គការពាណិជ្ជកម្មពិភពលោក	២៣៨
១៩	ទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ពង្រីកទំនាក់ទំនងនយោបាយ	២៣៩
២0	គោលនយោបាយនាំចេញអង្ករ ១លានតោន នៅតែជាគោលដៅអាទិភាព	២៣៩
២១	ជោគជ័យក្នុងការបង្កើនទិន្នផលស្រូវ តែមិនទាន់ជោគជ័យក្នុងការនាំចេញអង្ករ	២៤0
២២	កំពត តាកែវ កណ្តាល ព្រៃវែង ស្វាយរៀង នាំស្រូវចេញទៅវៀតណាម	២៤0
២៣	ការជំរុញផលិតកម្មស្រូវដើរទៅផុតការវិនិយោគលើការកែច្នៃនិងការនាំចេញ	២៤១
២៤	គោលនយោបាយពន្ធដារទន់ភ្លន់សំរាប់ការនាំចេញកៅស៊ូ	២៤១
២៥	លក់អោយអ្នកទិញដែលឱ្យថ្លៃ មិនប្រកាន់ទីផ្សារណាទេ	២៤២

២៦ អតុល្យភាពជញ្ជីងពាណិជ្ជកម្ម តែវត្ថុធាតុដើមពីកូរ៉េត្រូវបានផលិតនាំចេញ ... ២៤២

២៧ ស្វាយខ្មែរក្នុងទីផ្សារកូរ៉េ បញ្ហាក់ពីការជឿនលឿនទៅមុខនៃសេដ្ឋកិច្ចកម្ពុជា ២៤៣

២៨ កម្ពុជា/កូរ៉េចាប់ដៃគ្នាបាន ព្រោះទាំងសងខាងមានសុច្ឆន្ទៈនិងការអភិវឌ្ឍ ២៤៣

២៩ សភាពាណិជ្ជកម្ម/ធុរកិច្ចកម្ពុជា គួរសម្លឹងឆ្ពោះទៅរកទីផ្សារថ្មីៗ ២៤៤

៣០ មិនមែន EBA ទេ គឺអង្គអឺតាលីនិងអេស្ប៉ាញលក់មិនដាច់ ដែលហាមអង្គរកម្ពុជា ២៤៤

៣១ កាត់បន្ថយចំណាយផ្លូវការ/មិនផ្លូវការ ឱ្យវិនិយោគិនមានឱកាសប្រកួតប្រជែង ២៤៥

៣២ កែច្នៃវត្ថុធាតុដើមជាផលិតផលសម្រេចនាំចេញនិងប្រើប្រាស់ជំនួសការនាំចូល ២៤៥

៣៣ ប្រើអស់សក្តានុពលទីផ្សារដែលកំពុងមានដើម្បីទាញតម្លៃស្រូវអោយឡើងបន្តិច ២៤៦

៣៤ នយោបាយគាំពារនិយម មិនមានជោគជ័យឡើយ ក្បិតប្រទេសមួយមិនអាចនៅឯកោបានទេ ២៤៦

១. ប្រែអតីតសមរភូមិទៅជាទីផ្សារ និងតំបន់អភិវឌ្ឍ

សម្ពោធនិងប្រគល់-ទទួលផ្សារគំរូព្រំដែនកម្ពុជា-វៀតណាម(ផ្សារដោរ), ២៤ ធ្នូ ២០១៩

... (អំពី)**ការប្រែក្លាយអតីតសមរភូមិទៅជាទីផ្សារ និងជាតំបន់មានការអភិវឌ្ឍមកដល់ពេលនេះ យើងអនុវត្តបានជាង ៩០% រួចស្រេចទៅហើយ។ ប្រែក្លាយពីតំបន់ដែលធ្លាប់ប្រយុទ្ធ ធ្លាប់វាយប្រហារគ្នា ឱ្យក្លាយជាតំបន់មានការអភិវឌ្ឍ ទៅជាទីផ្សារ ជាតំបន់ជាំដុះ។** នៅសល់ជាប្រមាណជាជិត១០%ទៀត គឺយើងកំពុងបំផ្លាញចោលគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ រំដោះយកដីនោះឱ្យប្រជាពលរដ្ឋអាស្រ័យផលលើដីធ្លីដែលធ្លាប់តែមានគ្រាប់បែក មីននិងគ្រាប់មិនទាន់ផ្ទុះ ...។

២. ស្ថិរភាពផ្ទៃក្នុង និងទំនាក់ទំនងជិតខាងល្អ ដើម្បីពាណិជ្ជកម្ម

ប្រគល់សញ្ញាបត្រដល់និស្សិតសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល, ១៦ ធ្នូ ២០១៩

... (យើង)**ប្រែក្លាយព្រំដែនជាមួយប្រទេសជិតខាងជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ។ ប្រទេសដែលមានការរីកលូតលាស់ (ចាំបាច់ត្រូវមាន)ទី១ ស្ថិរភាពផ្ទៃក្នុងល្អ និងទី(២)ទំនាក់ទំនងជិតខាងល្អ**។ បើមិនអញ្ចឹងទេ ទាហានរបស់យើងនៅតែត្រៀមតាមទល់ដែន (ដែលធ្វើឱ្យមាន)ការផ្គត់ផ្គង់ហិរញ្ញវត្ថុ និង/ឬអ្វីផ្សេងៗ ... ឥឡូវនេះ ទំហំពាណិជ្ជកម្មរវាងយើងនិងថៃ(មាន)ជិត ៧ពាន់លាន(ដុល្លារ) ... ជាមួយវៀតណាមមានប្រមាណជា ៥ពាន់លាន(ដុល្លារ) ...។

៣. ទាក់ទាញវិនិយោគថ្មី តាមរូបមន្តមួយបូក

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់សេដ្ឋកិច្ចពិសេសនាងកុក ខេត្តកោះកុង, ១៣ មីនា ២០១៩

... ជួបគណៈប្រតិភូរបស់ជប៉ុន។ ខ្ញុំស្នើគាត់នូវរូបមន្តមួយបូក។ អ្វីទៅរូបមន្តមួយបូក? **យើងមិនអាចស្នើជប៉ុន ឬប្រទេសជាទៃឱ្យរើរោងចក្រចេញពីប្រទេសថៃ ពីម៉ាឡេស៊ី ពីចិន ឬពីវៀតណាម មកកាន់ប្រទេសរបស់យើងទេ? ប៉ុន្តែ យើង**

អនុវត្តតាមរបៀប "រូបមន្តមួយបូក"។ គេមានទីតាំងរោងចក្រធំដែលគេធ្វើរាប់សិបឆ្នាំហើយនៅក្នុងប្រទេសថៃ តែគេបើកសាខារោងចក្រនៅក្នុងប្រទេសកម្ពុជា។ រូបមន្តនេះវាសមស្រប។ យើងមិនទាមទារឲ្យមានការផ្ទេររោងចក្រទាំងស្រុងទេ ... នេះហៅថា រូបមន្តមួយបូក។ រោងចក្រមួយចេញពីប្រទេសថៃចូលមកកម្ពុជា។ ឥឡូវរោងចក្រនៅកម្ពុជាសឹងតែធំជាងនៅក្នុងប្រទេសថៃទៅវិញ ...។

៤. កែច្នៃផលិតផលកសិកម្មជាផលិតផលសម្រេចដើម្បីនាំចេញ

សម្ពោធ និងប្រគល់-ទទួលផ្សារគំរូ ព្រំដែនកម្ពុជា-វៀតណាម(ផ្សារដោរ), ២៤ ធ្នូ ២០១៩

... ខ្ញុំចង់បានតំបន់សេដ្ឋកិច្ចច្រើនទៀត ដែលធ្វើនៅតាមតំបន់ព្រំដែនកម្ពុជា-វៀតណាម ហើយទាក់ទាញអ្នកវិនិយោគវៀតណាម ក៏ដូចជាអ្នកវិនិយោគដទៃទៀត មកវិនិយោគនៅកម្ពុជា ដើម្បីនាំចេញ ដែលវានឹងក្លាយទីផ្សារសម្រាប់ប្រជាពលរដ្ឋរបស់យើង។ **ប្រជាពលរដ្ឋរបស់យើងមានតម្រូវការក្នុងការកផ្សារ ហើយបើសិនជាយើងអាចខិតខំធ្វើទៅបាន គឺកែច្នៃផលិតផលកសិកម្មរបស់យើងឱ្យទៅជាផលិតផលសម្រេចរួចហើយទើបមានការនាំចេញ** ...។

៥. កម្ពុជានាំចូលទៅវៀតណាមច្រើនជាង ក្នុងពេលកូវីដ១៩

សំណេះសំណាលជាមួយសហគមន៍ខ្មែរនៅទ្វីបអឺរ៉ុប, ២១ ឧសភា ២០២២

... **ទំហំពាណិជ្ជកម្មកម្ពុជា-វៀតណាម ដែលនាយករដ្ឋមន្ត្រីទាំងពីរជាក់ចេញគោលដៅត្រឹមតែ ៥ពាន់លានដុល្លារត្រូវបានសម្រេចដល់ ៩ពាន់៥រយលាន ដោយកម្ពុជានាំចេញទៅវៀតណាមច្រើនជាងកម្ពុជានាំចូលមកកម្ពុជាវិញ ក្នុងពេលកូវីដ-១៩** ... យើងនាំគ្រាប់ស្វាយចន្ទី(ចូលទៅវៀតណាម)ព្រោះខាងវៀតណាមពូកែកែច្នៃ។ គាត់ដាំស្វាយចន្ទីក្នុងស្រុកបន្តិចបន្តួចទេ តែទិញពីអាហ្វ្រិកពីប្រទេសនានា។ អញ្ចឹង ខ្មែរយើងបុក(នាំចូល)គ្រាប់ស្វាយចន្ទី(ទៅ វៀតណាម)មិនតិចទេ។ នេះហើយជាសេដ្ឋកិច្ចបំពេញឱ្យគ្នា ...។

៦. ខ្វះឃ្លាំង ម៉ាស៊ីនកិន និងទីផ្សារ កម្ពុជានាំស្រូវជាង៧០% ទៅវៀតណាម

ពិនិត្យការបង្កបង្កើនផលស្រូវ និងសំណេះសំណាលជាមួយប្រជាកសិករ ស្រុកព្រៃកប្បាស ខេត្តតាកែវ, ២១ កក្កដា ២០២០

... យើងស្ថិតក្នុងស្ថានភាពមានមាសខ្វះក្រដាសខ្ចប់ ... យើងផលិតបានស្រូវ ប៉ុន្តែ**ទីផ្សារនៅឯណា? ងាកមកខ្លួនឯងខ្វះម៉ាស៊ីនកិនស្រូវ ខ្វះឃ្លាំងស្តុកស្រូវ ខ្វះអ្នកប្រមូលទិញ។ ដោយហេតុនេះ នាំចេញខ្លួនឯងបានប្រហែលកន្លះលានតោនកន្លងទៅ។ សល់ជាង ៣លានតោនទៀត តើនាំទៅណា? នាំទៅខាងវៀតណាមប្រហែលជាង ៧០% ទៅខាងថៃប្រហែលជាង ៣០%**។ នេះតាមទិន្នន័យដែលយើងរកឃើញ។ ឥឡូវនេះ យើងខិតខំជំរុញការវិនិយោគ ដោយធ្វើឃ្លាំងស្តុក ធ្វើម៉ាស៊ីនកិនស្រូវ ធ្វើឧស្សាហកម្ម ដើម្បី(រក្សាបាន)តម្លៃបន្ថែមនៅក្នុងប្រទេស ...។

៧. ផ្លូវជាតិលេខ២១ សម្រួលការផ្លាស់ប្តូរទំនិញរវាងគ្នាកម្ពុជានិងវៀតណាម

សម្ពោធបើកឱ្យប្រើប្រាស់ផ្លូវជាតិលេខ២១ ជាផ្លូវការ, ២៣ មីនា ២០២២

... បើយើងគិតពីផ្លូវដែលតភ្ជាប់ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម គឺ**ផ្លូវជាតិលេខ២១ នេះមានចម្ងាយជិតជាងគេ ... ក្នុងការផ្លាស់ប្តូរទំនិញទៅវិញទៅមក។ សម្រាប់ច្រកនេះ ការផ្លាស់ប្តូរគ្នាមិនមែនតែទំនិញទេ តែនៅមានការនាំអគ្គិសនីពីវៀតណាមមកកាន់កម្ពុជាផងដែរ។ កសិផលជាច្រើនរបស់កម្ពុជា ក៏ត្រូវបាននាំចេញតាមច្រកនេះ។** ផលិតផលខាងវៀតណាម ក៏នាំចូលតាមច្រកនេះ ... យើងក៏បានចេញលុយពាក់កណ្តាលម្នាក់ កសាងស្ពានជ្រៃធំ ដែលព្រំដែនរបស់វានៅពាក់កណ្តាលទន្លេ ...។

៨. ផ្លូវជាតិ៤៨ របៀងសមុទ្រដឹកទំនិញរហ័ស រវាងថៃនិងវៀតណាមឆ្លងកាត់កម្ពុជា

បើកការដ្ឋានគម្រោងលើកកម្រិតគុណភាពផ្លូវជាតិលេខ៤៨ (ឥណទានមូលនិធិ EDCFនៃសាធារណរដ្ឋកូរ៉េ), ៣ មករា ២០២២

... (យើងបានធ្វើការប្រឹងប្រែងច្រើន) ដើម្បីធ្វើឱ្យកោះកុងមានការរីកចម្រើនដោយតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធតាំងពីផ្លូវដី ឆ្លងទូកដ រហូតមកដល់ដំណាក់កាលធ្វើផ្លូវកៅស៊ូ និងមានស្ពានបេតុង ... **ផ្លូវនេះក្លាយជារបៀងមាត់សមុទ្រដែល ...**

ហម្រើមិនត្រឹមតែទំនាក់ទំនងផ្ទៃក្នុងរបស់កម្ពុជាទេក៏ប៉ុន្តែទំនាក់ទំនងរវាងថៃកម្ពុជា និងវៀតណាម ... បើវៀតណាមចង់យកទំនិញទៅប្រទេសថៃ ឆ្លងកាត់តាមផ្លូវនេះ ក៏វារហ័ស។ ថៃចង់នាំទំនិញឆ្លងកាត់ទៅវៀតណាម ក៏ឆ្លងកាត់បានរហ័សតាមផ្លូវនេះ ... ទន្ទឹមនឹងនេះរបៀងមាត់សមុទ្រនេះក៏ក្លាយទៅជាតំបន់ទេសចរណ៍ដ៏គួរឱ្យទាក់ទាញនិង(មាន)តំបន់ផលិតដែលហៅថាប៉ូលសេដ្ឋកិច្ចនៅទិសនិរតី ...៕

៩. បង្កើតតំបន់សេដ្ឋកិច្ច ទីផ្សារ និងបើកច្រកតាមព្រំដែនកម្ពុជា-ថៃឲ្យកាន់តែច្រើន

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់សេដ្ឋកិច្ចពិសេសនាងកុក ខេត្តកោះកុង, ១៣ មីនា ២០១៩

... សួរថា បើទំនាក់ទំនងកម្ពុជា-ថៃ ស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់ មានចម្បាំងរាំងជល់តាមព្រំដែន តើតំបន់នេះអាចមានការអភិវឌ្ឍបានឬទេ? វាពិតជាមិនបានទេ ទីនេះឃ្លាតពីព្រំដែនតែប៉ុន្មានគីឡូម៉ែត្រប៉ុណ្ណោះ ... អ្នកវិនិយោគក៏សិក្សាមើលដែរថាទំនាក់ទំនងរវាងកម្ពុជា និងព្រះរាជាណាចក្រថៃ អាចធ្វើទៅបានទេ។ **ប៉ុន្មានឆ្នាំចុងក្រោយនេះ ខ្ញុំនិងឯកឧត្តម ប្រាយុទ្ធ ចាន់អូចា នាយករដ្ឋមន្ត្រីថៃបច្ចុប្បន្ន ក៏បានឯកភាពគ្នាពន្លឿនការបង្កើតឲ្យមានតំបន់សេដ្ឋកិច្ចពិសេសថ្មីៗបន្ថែមទៀត ក្នុងហ្នឹងមានតំបន់សេដ្ឋកិច្ចពិសេសអូរនាង នៅខេត្តបន្ទាយមានជ័យ និងនៅតំបន់ជាទៃទៀត ... យើងបង្កើតទីផ្សារព្រំដែន និងបើកច្រកព្រំដែនកាន់តែច្រើន ដើម្បីបម្រើការរកស៊ីរបស់ប្រជាជន ...**៕

១០. សេដ្ឋកិច្ចវៀតណាមនិងសេដ្ឋកិច្ចថៃកើន ជាការអនុគ្រោះដល់សេដ្ឋកិច្ចកម្ពុជា

សម្ពោធ និងប្រគល់-ទទួលផ្សារគំរូព្រំដែនកម្ពុជា-វៀតណាម(ផ្សារដោរ), ២៤ ធ្នូ ២០១៩

... **រីករាយដោយមើលឃើញវឌ្ឍនភាពសេដ្ឋកិច្ចវៀតណាមក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ពិសេសឆ្នាំ ២០១៨ និង២០១៩ ដែលមានភាពនឹងនរ និងមានល្បឿនកើនឡើងខ្ពស់ ... ការព្រួយបារម្ភរបស់កម្ពុជាគឺសេដ្ឋកិច្ចរបស់វៀតណាម និងសេដ្ឋកិច្ចរបស់ថៃ។ ព្រោះអ្វី? ព្រោះថា (សេដ្ឋកិច្ចកម្ពុជា)ពាក់ព័ន្ធជាមួយ(គ្នា)។ បើសិនជាសេដ្ឋកិច្ចវៀតណាមនិងសេដ្ឋកិច្ចថៃថមថយ (រហូតមាន)អតិផរណាក្នុង**

ប្រទេសខ្ពស់ (វាក៏)នឹងទាញសេដ្ឋកិច្ចរបស់កម្ពុជាខាតបង់ដែរ។ ខ្ញុំសូមអបអរសាទរចំពោះវឌ្ឍនភាពសេដ្ឋកិច្ចវៀតណាម ដែលបានរួមចំណែកទៅលើការអភិវឌ្ឍរួមទាំងអស់គ្នា នៅក្នុងក្របខ័ណ្ឌតំបន់អាស៊ាន ...៕

១១. នៅច្រកអន្តរជាតិកម្ពុជា-វៀតណាម ត្រូវមានកិច្ចព្រមព្រៀងច្រកពាណិជ្ជកម្មទ្វេទិស

សម្ពោធ និងប្រគល់-ទទួលផ្សារគំរូព្រំដែនកម្ពុជា-វៀតណាម(ផ្សារដោរ), ២៤ ធ្នូ ២០១៩

... **(យើង)សម្បូរកិច្ចព្រមព្រៀង។ សូមទទួលយក។ ប៉ុន្តែ អ្វីដែលសំខាន់ ត្រូវតែទទួលយកឱ្យបានសងខាង។ ហ្នឹងគេហៅថា ការតភ្ជាប់ខាងសេដ្ឋកិច្ច (ឬ)ការតភ្ជាប់ខាងពាណិជ្ជកម្ម។ យើងធ្វើនៅកន្លែងហ្នឹង មានការព្រមព្រៀងជាមួយវៀតណាមអំពីតំបន់ច្រកពាណិជ្ជកម្ម។ បើធ្វើខ្លួនឯង ក៏ត្រូវមានការព្រមព្រៀងពីវៀតណាម ដោយកំណត់ថា វៀតណាមបើកច្រកនោះ ជាច្រកពាណិជ្ជកម្មទ្វេទិសរវាងកម្ពុជា និងវៀតណាម។ នេះជាច្រកអន្តរជាតិ។ យើងធ្វើនៅកន្លែងហ្នឹង បង្កើតផ្សារ ដើម្បីបង្កើតកម្លាំងនាំទំនិញរបស់យើងទៅវៀតណាម។** នេះជាចំណុចដែលខ្ញុំសុំចង្អុលបង្ហាញ។ ស្តាប់ក្នុងរបាយការណ៍កម្ពុជា គឺការិយាល័យនិយម។ អ្នកណាធ្វើផ្សារប៉ុណ្ណឹងប្រើពេល ១០ឆ្នាំ ...៕

១២. បង្កើតផ្សារ ៣កន្លែង តាមផែនការ ដោយក្រសួងពាណិជ្ជកម្មជាអាណាប៉ក

សម្ពោធ និងប្រគល់-ទទួលផ្សារគំរូព្រំដែនកម្ពុជា-វៀតណាម(ផ្សារដោរ), ២៤ ធ្នូ ២០១៩

... **យើងបង្កើតផ្សារបើកន្លែងជាដំហានដំបូង។ ទី១ ផ្សារគំរូនៅទីនេះ។ ទី២ និងទី៣ ផ្សារនៅស្ងាយរៀង និងនៅកំពត។ ជាក់ចូលទៅក្នុងផែនការរៀបចំសម្រាប់បង្កើតផ្សារ ហើយក្រសួងពាណិជ្ជកម្មធ្វើជាអាណាប៉កតែម្តង ...** មួយត្រឹមតែ ២(ឬ) ៣លានដុល្លារ(អាមេរិក)។ អត់ច្រើនទេ។ យើងធ្វើសាលារៀនមួយកន្លែងៗ កន្លែងខ្លះ(ត្រូវចំណាយ) ៤(ឬ) ៥លានដុល្លារអាមេរិក ព្រោះលេងសុទ្ធតែ ១ខ្នង ៤ជាន់ ៤០ឬ ៥០បន្ទប់ អីឯណោះ។ ដូច្នេះ វាអត់មានអីត្រូវច្រើនពេកទេ។ ខ្ញុំគិតថា សំណូមពរទៅមិត្តវៀតណាមនេះ អាចនឹងជាក់កន្លែងផ្សេង។

បើសិនជាឆ្លើយតប (សូមឱ្យ)ដាក់កន្លែងផ្សេង។ ឯពីរកន្លែងនេះ ខ្ញុំចង្អុលឱ្យធ្វើដោយប្រើថវិកាជាតិ ហើយក្នុងល្បឿនមួយលឿន ...។

១៣. ត្រូវសង់ផ្សារអោយស្របជាមួយការបើកច្រកព្រំដែននៅខាងវៀតណាម

សម្ពោធ និងប្រគល់-ទទួលផ្សារគំរូព្រំដែនកម្ពុជា-វៀតណាម(ផ្សារដោរ),
២៤ ធ្នូ ២០១៩

... ត្រូវស្របជាមួយថា តើតំបន់នោះវៀតណាមបើកច្រកឬអត់? យើងបើកច្រក(ដែល) ... ក្នុងផែនទីបង្ហាញថាមានចម្ងាយពីទីផ្សារតែ ៣៨០ម៉ែត្រទេ ... សំខាន់នៅត្រង់ថា **តើខាងវៀតណាមបើកច្រក(ព្រំដែន)ទេ។ នៅខេត្តកំពត/ស្វាយរៀងក៏ត្រូវតែខាងវៀតណាមបើកច្រកហ្នឹងដែរ។ បើ(មិន)អញ្ចឹង មានតែផ្សារខាងកម្ពុជា (តែ)ឆ្លង(ព្រំដែន)ទៅវៀតណាមអត់រួច។ គោលដៅផ្សារនេះគឺនាំចេញទំនិញទៅវៀតណាម** ... ដោយពិនិត្យឃើញថាការសាងសង់នេះប្រើពេលយូរនិងបែបបទច្រើន ខ្ញុំចង់កាត់បន្ថយបែបបទឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន ដោយប្រើថវិកាជាតិរបស់កម្ពុជា សម្រាប់ធ្វើផ្សារពីរបន្ថែមទៀត ...។

១៤. ស្វែងរកការពង្រីកទំហំពាណិជ្ជកម្មកម្ពុជា/វៀតណាម កម្ពុជា/ថៃ កម្ពុជា/ឡាវ

សំណេះសំណាលជាមួយសហគមន៍ខ្មែរនៅសហរដ្ឋអាមេរិក/កាណាដា ប្រមាណ
២ ពាន់នាក់ នៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី សហរដ្ឋអាមេរិក, ១២ ឧសភា ២០២២

... ត្រូវសន្ទនាគ្នាពីការពង្រឹងពាណិជ្ជកម្ម ... ដែលឆ្នាំ២០២០-២០២១ យើងសម្រេច(បានទំហំពាណិជ្ជកម្ម)ដល់ទៅ ៩៥០០លាន(ដុល្លារ)។ ក្នុងខែមេសានេះ (យើង)សម្រេច(ទំហំពាណិជ្ជកម្ម)បានរហូតដល់ ៤២០០ លាន(ដុល្លារ)។ ឆ្នាំនេះទៀត អាចឡើងដល់ ១០ពាន់លាន(ដុល្លារ) ... **យើងត្រូវសន្ទនាគ្នាក្នុងហាន:(ជា)ប្រទេសជិតខាង មិនមែនគ្រាន់តែជាមួយវៀតណាមទេ ត្រូវក៏ជាមួយ(ប្រទេស)ឡាវ ប្រទេសថៃដើម្បីពង្រីកទំហំពាណិជ្ជកម្ម។** ទំហំពាណិជ្ជកម្មរវាងយើងជាមួយថៃឡើងដល់ទៅ ១១ពាន់លាន(ដុល្លារ) ... ក្នុងចំណោម ១១ពាន់លានដុល្លារនេះ នាំចូលពីថៃមានរហូតដល់ ៩ពាន់លាន(ដុល្លារ) ហើយយើងនាំទៅថៃបានត្រឹមតែ ២ពាន់លាន(ដុល្លារ)ទេ។ តម្រូវការក្នុងស្រុកមានសម្ភារៈ

សំណង់ ក៏ដូចជាប្រេងឥន្ធនៈ គឺនាំចូលមកកាន់កម្ពុជា ...។

១៥. ពាណិជ្ជកម្មមានទំហំធំបំផុត ក្នុងប្រវត្តិទំនាក់ទំនងពាណិជ្ជកម្ម កម្ពុជា-អាមេរិក

សំណេះសំណាលជាមួយសហគមន៍ខ្មែរនៅសហរដ្ឋអាមេរិក/កាណាដា
នៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី សហរដ្ឋអាមេរិក, ១២ ឧសភា ២០២២

... អំពីបញ្ហាទំនាក់ទំនងរវាងកម្ពុជា-អាមេរិក។ តើទំនាក់ទំនងនេះដល់ណាហើយ? មានស្អីខ្លះ ដែលជាឧបសគ្គ? ដំបូងគួរតែនិយាយថា ទំនាក់ទំនងរវាងកម្ពុជានិងអាមេរិក បានដើរដល់ចំណុចកំពូលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រ។ ពិតមែនតែវាលិចអណ្តែតៗ ក៏ប៉ុន្តែសូមសង្កេតលើបញ្ហា២។ ទី១ នៅមុនឆ្នាំ ២០០០ តើសហរដ្ឋអាមេរិកមានស្ថានទូតផ្ទាល់ខ្លួននៅកម្ពុជាឬទេ? ចម្លើយគឺមិនមានទេ ... ក្រោយឆ្នាំ២០០០ ជាពិសេសក្រោយកម្ពុជារកឃើញសន្តិភាពពេញលេញ អាមេរិកបានកសាងស្ថានទូតនៅកម្ពុជា ... **ទី២ ក្នុងប្រវត្តិទំនាក់ទំនងពាណិជ្ជកម្ម ពេលនេះពាណិជ្ជកម្មរវាងប្រទេសទាំងពីរមានទំហំធំបំផុត។ ទំហំពាណិជ្ជកម្មដែលនាំចូលមកអាមេរិក មានជាង ៩ពាន់លានដុល្លារ(អាមេរិក)។ មានក្រុមហ៊ុនអាមេរិក កាន់តែច្រើនទៅស្រុកខ្មែរ ...។**

១៦. រួមចំណែកក្នុងសង្វាក់ផ្គត់ផ្គង់ស្បៀងក្នុងតំបន់

ទស្សនកិច្ចមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ពូជត្រី បាទី
និងជួបសំណេះសំណាលជាមួយនឹងកសិករនៅខេត្តព្រៃវែង, ១៤ កក្កដា ២០២០

... អត្ថបទសារព័ត៌មានរបស់ប្រទេសខ្លះបានចង្អុលចំមកកម្ពុជា ថៃ មីយ៉ាន់ម៉ា ឥណ្ឌា និងទៅរុស្សី។ ហេតុអី ... មកពីខ្ញុំបានប្រកាសថា សូមឱ្យផ្អាកការនាំចេញ។ អញ្ចឹងគេលើកជាកង្វល់ថា សង្វាក់ផ្គត់ផ្គង់ស្បៀងនៅក្នុងតំបន់អាស៊ីនេះនឹងមានការពិបាកដោយសារភាពតឹងរ៉ឹងរបស់ថៃ កម្ពុជា ភូមា ឥណ្ឌា និងអំពីស្រូវសាលីរបស់រុស្សីទៅទៀត។ **សូមបញ្ជាក់ឡើងវិញថា កម្ពុជានឹងចូលរួមក្នុងសង្វាក់ផ្គត់ផ្គង់ក្នុងតំបន់ ព្រោះកម្ពុជាមានសល់ជាស្រូវជិត ៦លានតោន ដែលបើគិតជាអង្ករក៏មានប្រមាណ ៤លានតោនក្នុងមួយឆ្នាំ។ កម្ពុជាមានសមត្ថភាពចូលរួមផ្គត់ផ្គង់ស្បៀង ដែលមិនត្រឹមតែដោះស្រាយបញ្ហាខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែយើង**

អាចនឹងនាំចេញបាន ... កម្ពុជាប្រកាសរួមចំណែកតាមលទ្ធភាពរបស់ខ្លួនក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ក្នុងតំបន់រាប់តាំងពីស្រូវរហូតដល់ផ្នែកដទៃ ដោយឈានទៅដល់ត្រី ...៕

១៧. FTA កម្ពុជា/ចិន និង RCEP នឹងជួយកម្ពុជានាំចេញផលិតផលកសិកម្មបានច្រើន

ជាក់ឱ្យប្រើប្រាស់ស្ពានមិត្តភាពកម្ពុជា-ចិនស្ទឹងត្រង់-ក្រូចឆ្មារ (ស្ពានភ្ជាប់និស្ស័យ) និងការប្រកាសបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ 71C, ២៣ វិច្ឆិកា ២០២១

... ជាមួយការមកដល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា-ចិនផង និងរវាងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ នឹងចូលនៅ**ថ្ងៃទី១ មករា ឆ្នាំ២០២២ កម្ពុជាមានលទ្ធភាពកាន់តែច្រើនក្នុងការពង្រឹងវិស័យកសិកម្ម និងការនាំចេញផលិតផលកសិកម្មទៅក្រៅប្រទេស ដែលក្នុងហ្នឹងការនាំចេញទៅប្រទេសចិនជាចំណែកដ៏ធំ។ (សំរាប់ខាង)អឺរ៉ុប យើងនាំចេញអង្ករល្អ ... ជាផ្នែកកសិកម្មរបស់កម្ពុជា មានតាំងពីកៅស៊ូ ស្វាយចន្ទី ម្រេច ស្រូវ ស្វាយ។ល។ ស្វាយនាំចេញបានច្រើន។ ឥឡូវ មានទាំងមៀនប៉ៃលិន ឬតាង៉ែនហ្នឹងទៀត ... យើងមាន (ដំណាំ)**រាប់មឺនហិកតា ដែលថ្ងៃក្រោយនៅមានចេកទៀត ...៕

១៨. កម្ពុជានឹងបន្តធ្វើច្បាប់នានា តាមការសន្យាជាមួយអង្គការពាណិជ្ជកម្មពិភពលោក

ពិធីសម្ពោធរោងចក្រស៊ីម៉ងត៍ ជីប ម៉ុង, ៨ កុម្ភៈ ២០១៨

...ខ្ញុំនិយាយអំពីបញ្ហាទាក់ទងនឹងរឿងសេដ្ឋកិច្ចនេះ មានរឿងច្រើនណាស់។ ទម្រាំកម្ពុជាមានសព្វថ្ងៃនេះ មិនមែនដំណើរការធម្មតាទេ។ យើងបានធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ចរបស់យើងនៅចុងទសវត្សរ៍ ៨០ ចាប់ពីពាក់កណ្តាលទសវត្សរ៍ ៨០ រហូតមក។ ឥឡូវនេះ យើងកំពុងធ្វើសុក្រឹត្យកម្មចាប់ពីឆ្នាំ ១៩៩១-១៩៩២ មក យើងកំពុងបន្តធ្វើសុក្រឹត្យកម្មសេដ្ឋកិច្ចផ្សាររបស់យើង។ រាប់ទាំងអាទិត្យមុននេះ យើងធ្វើច្បាប់មួយតម្រូវទៅតាមការសន្យារបស់យើងនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក អំពីគេហៅថា អាជ្ញាបណ្ណបញ្ជាផ្នែករវៃសាស្ត្រខាងផ្នែកវិស័យសុខាភិបាល ដែលពេលនោះ យើងបានធ្វើការសន្យានៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក។ **យើងនឹងបន្តធ្វើច្បាប់ ស្តីពីបញ្ហាទាក់ទងនឹងបញ្ហាមេធាវីតទៅទៀត។ អ្វីដែលយើងបានសន្យាជាមួយ អង្គការពាណិជ្ជកម្មពិភពលោកយើងត្រូវធ្វើអោយបានព្រោះនេះជាលក្ខខណ្ឌតម្រូវសម្រាប់សេដ្ឋកិច្ចសេរី សេដ្ឋកិច្ចបើកចំហរ ...៕**

១៩. ទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ពង្រីកទំនាក់ទំនងនយោបាយ

ជាក់ឱ្យប្រើប្រាស់នូវស្ពានមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រង់-ក្រូចឆ្មារ (ស្ពានភ្ជាប់និស្ស័យ) និងការប្រកាសបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ 71C, ២៣ វិច្ឆិកា ២០២១

... **ជាបទពិសោធន៍ដែលខ្ញុំមានក្នុងហានៈជារដ្ឋមន្ត្រីការបរទេស តាំងពីអាយុ ២៧ឆ្នាំ ទំនាក់ទំនងនយោបាយកើនឡើង ដោយសារមានការគាំទ្រនៃទំនាក់ទំនងខាងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ។ ពិនិត្យមើលចុះ ប្រទេសដែលមានតែទំនាក់ទំនងខាងនយោបាយ ពុំមានទំនាក់ទំនងច្រើនជាមួយគ្នាលើផ្នែកសេដ្ឋកិច្ចពាណិជ្ជកម្ម វិនិយោគទេ ទំនាក់ទំនងនោះមិនរឹងមាំទេ។ ប៉ុន្តែ បើមានទំនាក់ទំនងច្រើនលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ នោះទំនាក់ទំនងនយោបាយធ្វើឱ្យមានសកម្មភាពជាមួយគ្នាច្រើន។** យើងនៅសល់ច្រើនគម្រោងទៀត។ (ក្នុង)ខែ ១២ហ្នឹងយើងទៅសម្ពោធផ្លូវជាតិលេខ១១ ព្រៃវែង ហើយទៅសម្ពោធដល់ក្រចេះឯណោះ ដូចជាមានគម្រោងចិន៣ ...៕

២០. គោលនយោបាយនាំចេញអង្ករ ១លានតោន នៅតែជាគោលដៅអាទិភាព

អញ្ជើញចុះពិនិត្យការបង្កបង្កើនផលស្រូវ និងសំណេះសំណាលជាមួយប្រជាកសិករស្រុកព្រៃកប្បាស ខេត្តតាកែវ, ២១ កក្កដា ២០២០

... **គោលនយោបាយផលិតស្រូវ និងនាំចេញអង្ករឱ្យបានជាងមួយលានតោន នៅតែជាគោលដៅអាទិភាព ដែលត្រូវបន្តជាមួយគោលនយោបាយឧស្សាហកម្ម ២០១៥-២០២៥។** ខ្ញុំគួរតែនិយាយថា មុនពេលដែលយើងដាក់ចេញនូវគោលនយោបាយកសិកម្ម គោលនយោបាយផលិតស្រូវ និងការនាំចេញអង្ករបស់យើង ពេលនោះយើងនៅមានអតិរេកស្រូវតិចតួច ... បើគិតត្រឹមឆ្នាំ២០០២ យើងនៅខ្វះអង្ករទេ។ ពេលកម្ពុជាធ្វើជាប្រធានអាស៊ាន ឥណ្ឌាបានផ្តល់អង្ករមកឱ្យយើងចំនួន ២ម៉ឺនតោន។ យើងជួបគ្រោះរាំងស្ងួត បន្ទាប់ពីជំនន់ឆ្នាំ ២០០០-២០០១

និងគ្រោះរាំងស្ងួតឆ្នាំ២០០២។ យើងនៅខ្វះខាត។ នៅពេលយើងដាក់ចេញគោលនយោបាយផលិតស្រូវនិងការនាំចេញអង្ករ យើងក៏ចាប់ផ្តើមសល់ស្រូវ។ ចុងក្រោយនៅក្នុងឆ្នាំនេះ យើងសល់ស្រូវជិត ៦លានតោន ដែលបើគិតជាអង្ករគឺមានប្រមាណជិត ៤លានតោន ...។

២១. បានជោគជ័យក្នុងការបង្កើនទិន្នផលស្រូវ តែមិនទាន់ជោគជ័យក្នុងការនាំចេញអង្ករ

អញ្ជើញចុះពិនិត្យការបង្កបង្កើនផលស្រូវ និងសំណេះសំណាលជាមួយ
ប្រជាកសិករស្រុកព្រៃកប្បាស ខេត្តតាកែវ, ២១ កក្កដា ២០២០

... ប្រទេសតូចមួយដែលមានកសិកម្មមិនទាន់លូតលាស់ ក៏ប៉ុន្តែសល់ស្រូវរហូតទៅដល់ជាងជិត ៦លានតោន ជាទំហំមួយដ៏ធំ។ និយាយបានថា **យើងសម្រេចជោគជ័យបានតែមួយទេ ក្នុងកញ្ចប់នយោបាយស្តីពីការធ្វើផលិតកម្មស្រូវ និងការនាំចេញអង្ករ គឺការបង្កើនផលិតផលស្រូវពីដែលយើងខ្វះខាត ទៅជាសល់ស្រូវជិត ៦លានតោន។ យើងប្រើពាក្យថាលើស ៥លានតោន។ ប៉ុន្តែ គោលដៅនៃការនាំចេញឱ្យបាន ១លានតោន(អង្ករ) នៅមិនទាន់សម្រេចបានទេ**។ យើងនាំចេញបានតិចណាស់។ មានតែឆ្នាំនេះទេ ដែលក្នុងរយៈពេល ៦ខែ យើងនាំចេញបានជាង ៤០ម៉ឺនតោន។ តាមការព្យាករណ៍ទុក យើងអាចឈានទៅដល់ការនាំចេញអង្ករបាន ១លានតោនក្នុងរង្វង់ឆ្នាំ២០២១ ឬ២០២២ ...។

២២. កំពត តាកែវ កណ្តាល ព្រៃវែង ស្វាយរៀង នាំស្រូវចេញទៅវៀតណាម

អញ្ជើញចុះពិនិត្យការបង្កបង្កើនផលស្រូវ និងសំណេះសំណាលជាមួយនឹង
ប្រជាកសិករស្រុកព្រៃកប្បាស ខេត្តតាកែវ, ២១ កក្កដា ២០២០

... **តាមឯកឧត្តមរដ្ឋមន្ត្រីកសិកម្មខ្សឹបប្រាប់ ក្នុង ៦ខែកន្លងទៅនេះ យើងបាននាំចេញ(ស្រូវ)ជាង ១លានតោនរួចហើយ ពីខេត្តកំពត តាកែវ កណ្តាល ព្រៃវែង ស្វាយរៀងដែលនៅជាប់នឹងព្រំដែនវៀតណាម។ នោះហើយបានជាពាណិជ្ជកម្មរវាងកម្ពុជានិងវៀតណាមដែលមានទំហំ(ពាណិជ្ជកម្ម)ប្រមាណជាង ៥ពាន់លានដុល្លារ ដោយមិនទាន់គិតពីរឿងចរាចរណ៍ស្រូវដែលគយអត់បានកត់ត្រាទេ** ... ដំណាំស្រូវនៅវៀតណាមមានបញ្ហាមមាចត្នោតបំផ្លាញ។ វៀតណាមទិញក៏ស្រូវ

ពីកម្ពុជាដើម្បីផ្គត់ផ្គង់ឱ្យហ្វីលីពីន ... ឯកឧត្តមង្វៀន តាន់យុង អតីតនាយករដ្ឋមន្ត្រីវៀតណាមថា អរគុណឯកឧត្តម ហ៊ុន សែន ដែលបានលក់ស្រូវឱ្យវៀតណាមជាង ១លានតោន។ ខ្ញុំនិយាយតបទៅគាត់វិញថា ខ្ញុំក៏អរគុណឯកឧត្តមដែលបានជួយទិញស្រូវខ្ញុំជាង ១លានតោនដោយមិនបាច់បង់ពន្ធ ...។

២៣. ការជំរុញផលិតកម្មស្រូវដើរទៅផុតការវិនិយោគលើការកែច្នៃនិងការនាំចេញ

អញ្ជើញចុះពិនិត្យការបង្កបង្កើនផលស្រូវ និងសំណេះសំណាលជាមួយនឹង
ប្រជាកសិករស្រុកព្រៃកប្បាស ខេត្តតាកែវ, ២១ កក្កដា ២០២០

... យើងហៅក្រុមហ៊ុនមកពីក្រៅប្រទេស ផ្តល់ឱកាសឱ្យគេវិនិយោគ ហើយយើងក៏បានទៅរកទុនពីចិនប្រមាណជា ៤០០លានដុល្លារ ពង្រាយធ្វើឃ្លាំងនិងតំបន់សម្រាប់ការប្រមូលទិញ។ បើយើងធ្វើដូចនេះបាន ... យើងអាចធានាបានល្អជាង។ យើងម្ចាស់ការច្រើនជាង ព្រោះយើងទិញខ្លួនឯង។ ដូចនេះ **យើងមានតម្រូវការវិនិយោគបន្ថែម ... ត្បិតការជំរុញល្បឿនផលិតកម្មស្រូវដើរលឿនហួសទៅផុតពីការវិនិយោគសម្រាប់ការកែច្នៃនិងការនាំចេញ។ ការនាំចេញ មិនមែនចេះតែនាំទៅទេ។ ត្រូវធ្វើឱ្យវាស្អិត ត្រូវធ្វើម៉េចកុំឱ្យដឹកទៅបានពាក់កណ្តាលផ្លូវ(ក្នុងលំហ)សមុទ្រ ស្រាប់តែចេញកើតខ្នុត។ របៀបហ្នឹងគឺលក់ក្តៅឈ្មោះកម្ពុជាហើយ ...។**

២៤. គោលនយោបាយពន្ធជារទន់ភ្លន់សំរាប់ការនាំចេញកៅស៊ូ

ពិធីបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ឆ្នាំ២០១៨-២០១៩ និងទិសដៅការងារឆ្នាំ ២០១៩-២០២០, ១៤ មីនា ២០១៩

... **រាជរដ្ឋាភិបាលក៏បានយកគោលនយោបាយពន្ធជារមួយ បើកៅស៊ូធ្លាក់ថ្លៃប៉ុន្មាន យើងយក(វិធានការណ៍ពន្ធដូចជា) មានពេលខ្លះយើងអត់យកពន្ធតែម្តង។ ពន្ធសូន្យ។ នៅពេលវាឡើងដល់ប៉ុន្មាន យកពន្ធប៉ុន្មាន។ យើងមានគោលនយោបាយទន់ភ្លន់ លើបញ្ហាពន្ធជារសម្រាប់ការនាំចេញកៅស៊ូរបស់កសិករថែមទៀតផង**។ ហ្នឹងជារំដោះសេដ្ឋកិច្ចមួយដែលរាជរដ្ឋាភិបាលបានផ្តល់ ...។

២៥. លក់អោយអ្នកទិញដែលឱ្យថ្លៃ មិនប្រកាន់ទីផ្សារណាទេ

អញ្ជើញចុះពិនិត្យការបង្កបង្កើនផលស្រូវ និងសំណេះសំណាលជាមួយនឹង
ប្រជាកសិករស្រុកព្រៃកប្បាស ខេត្តតាកែវ, ២១ កក្កដា ២០២០

... ដែលហៅថាទីផ្សារ គឺតែងតែមានការប្រកួតប្រជែង។ បើកាលណាអ្នក(ទិញមក)ឱ្យដល់ថ្លៃ (អ្នកលក់)ត្រូវលក់ឱ្យអ្នកទិញនោះ ... យើងកំពុងតែ(នៅ)ក្នុងក្របខណ្ឌ AFTA ឬតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ... ពីរឆ្នាំមានសន្តិភាព ខ្ញុំបានប្រកាសថាឱ្យផ្អាកនាំចេញអង្ករសនិងនាំចេញស្រូវក្នុងមួយរយៈកាលខ្លី។បន្ទាប់ពីការពិនិត្យមើលតុល្យភាពស្បៀងរួចហើយ **និងច្បាស់ថាកម្ពុជាមិនមានការខ្វះខាតស្បៀងទេ ខ្ញុំបានអនុញ្ញាតឱ្យមានការនាំចេញ ... កុំចាំទីផ្សារមកពីអឺរ៉ុប ទើបលក់។ ថាមកពីវៀតណាមមិនលក់ មកពីថៃមិនលក់ មកពីចិនមិនលក់ ចាំតែអាមេរិកាំង ចាំតែបារាំង បានលក់។ មិនអញ្ចឹងទេ។ អ្នកណាឱ្យថ្លៃគឺយើងយកពីអ្នកហ្នឹង។** យើងត្រូវខិតខំអោយដំណើរការអភិវឌ្ឍវិស័យកសិកម្មនិយាយជារួមនិងវិស័យស្រូវអង្ករនិយាយដោយឡែកដើរទន្ទឹមគ្នានឹងដំណើរការគោលនយោបាយឧស្សាហកម្ម២០១៥-២០២៥ ទាញឧស្សាហកម្មពីក្រៅ តម្រង់ឆ្ពោះមកកែច្នៃវត្ថុធាតុដើមដែលមានក្នុងស្រុក ...។

២៦. អតុល្យភាពជញ្ជីងពាណិជ្ជកម្ម តែវត្ថុធាតុដើមនាំពីកូរ៉េត្រូវបានផលិតនាំចេញបន្តទៅទីផ្សារខាងក្រៅទៀត

ពិធីជួបជុំសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពលករ និងនិស្សិតខ្មែរ
កំពុងស្នាក់នៅ/ធ្វើការ/សិក្សានៅសាធារណរដ្ឋកូរ៉េ, ០៣ កុម្ភៈ ២០២០

... មកដល់ពេលនេះ ចាត់ទុកថាទំនាក់ទំនងរវាងយើងនិងកូរ៉េកើនលឿន។ យោងទៅលើទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ជើងលេខមាន២ ប៉ុន្តែយើងយកជើងលេខរបស់កូរ៉េច្បាស់ជាង។ ជើងលេខរបស់កម្ពុជា បង្ហាញថាទំហំពាណិជ្ជកម្មរវាងកម្ពុជានិងកូរ៉េ ឆ្នាំ២០១៩ កន្លងទៅមានត្រឹមតែ ៧៧៨លានដុល្លារ ដែលក្នុងនោះកម្ពុជានាំចេញមកកូរ៉េ ២១០លានដុល្លារ ឯកូរ៉េនាំចេញទៅកម្ពុជាវិញ ៦៦៧លានដុល្លារ។ ប៉ុន្តែ ជើងលេខរបស់កូរ៉េបញ្ជាក់ថា ទំហំពាណិជ្ជកម្មទ្វេទិសរវាងប្រទេសទាំងពីរមាន ១.០៣២ លានដុល្លារ ក្នុងនោះកម្ពុជានាំចេញ

មកកូរ៉េចំនួន ៣៣៥លានដុល្លារ ឯការនាំចូលពីកូរ៉េទៅចំនួន ៦៩៦លានដុល្លារ។ **មានអតុល្យភាពជញ្ជីងពាណិជ្ជកម្មពិតប្រាកដមែន ប៉ុន្តែវាគ្មានជម្រើសទេ ព្រោះយើងមានតម្រូវការនាំចូលទំនិញពីកូរ៉េ ក្នុងនោះវត្ថុធាតុដើមដែលនាំពីកូរ៉េនេះ ក៏ត្រូវបានផលិតកែច្នៃនៅកម្ពុជា ហើយនាំចេញបន្តទៅទីផ្សារខាងក្រៅទៀត មិនមែនប្រើសុទ្ធតែនៅកម្ពុជាទេ ...** បើគ្មានទំនាក់ទំនងការទូតទេ ទំហំពាណិជ្ជកម្មមិនអាចកើតមានបានក្នុងទំហំបែបនេះទេ ...។

២៧. ស្វាយខ្មែរក្នុងទីផ្សារកូរ៉េ បញ្ជាក់ពីការជឿនលឿនទៅមុខនៃសេដ្ឋកិច្ចកម្ពុជា

ពិធីជួបជុំសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពលករ និងនិស្សិតខ្មែរ
កំពុងស្នាក់នៅ/ធ្វើការ/សិក្សានៅសាធារណរដ្ឋកូរ៉េ, ០៣ កុម្ភៈ ២០២០

... ក្នុងខែមករាកន្លងទៅ មិនដឹងថាក្មួយៗបានទិញស្វាយទទួលទានហើយឬនៅទេ? ក្មួយៗដែលនឹកស្រុក សូមទៅរកទិញស្វាយខ្មែរទទួលទានទៅ(ស្នូរទេះដៃ)។ **វត្តមានស្វាយខ្មែរនៅក្នុងទីផ្សារកូរ៉េបានបង្ហាញពីការជឿនលឿនទៅមុខនៃសេដ្ឋកិច្ចរបស់កម្ពុជា ដែលតម្រូវបានតាមស្តង់ដារក្នុងទីផ្សារនៃប្រទេសជឿនលឿនមួយ ហើយធ្វើឱ្យអ្នកដាំស្វាយនៅប្រទេសកម្ពុជាមានលទ្ធភាពកាន់តែខ្ពស់ពង្រីកអាជីវកម្មស្វាយកាន់តែធំ ព្រោះនេះមិនមែនផ្តត់ផ្តង់តែកូរ៉េចំនួន ៥០លាននាក់នោះទេ។ កូរ៉េក៏មានទេសចរច្រើនដែរ ...** ផ្លែស្វាយកម្ពុជាមិនអន់ជាងស្វាយក្នុងបណ្តាប្រទេសអាស៊ានទេ។ អញ្ចឹង កូរ៉េជាទីផ្សារ ដែលយើងអាចនាំចេញមកដែលវាក៏ជាផ្នែកមួយជម្រុញការដាំដុះនៅប្រទេសកម្ពុជា។ យើងកំពុងស្វែងរកឱកាសដើម្បីនាំចេញមុខទំនិញផ្សេងៗបន្ថែមទៀត ...។

២៨. កម្ពុជានិងកូរ៉េចាប់ដៃគ្នាបាន ព្រោះទាំងសងខាងមានទាំងសុច្ឆន្ទៈមានទាំងការអភិវឌ្ឍ

ពិធីជួបជុំសំណេះសំណាលជាមួយប្រជាពលរដ្ឋ ពលករ និងនិស្សិតខ្មែរ កំពុងស្នាក់នៅ/ធ្វើការ/សិក្សានៅសាធារណរដ្ឋកូរ៉េ, ០៣ កុម្ភៈ ២០២០

... នៅថ្ងៃក្រោយ រកវិធីពង្រីកទីផ្សារនៅកូរ៉េ។ កម្ពុជានិងកូរ៉េ បានរៀបចំការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលយើងនឹងពង្រីកទីផ្សារនៅកូរ៉េកាន់តែធំ ... ត្រូវសម្លឹងអញ្ចេះ **ហេតុអ្វីកូរ៉េចាប់ដៃជាមួយយើង ហើយយើងអាចចាប់ដៃ**

កូរ៉េបាន? វាទាល់តែសងខាងមានសុចន្ទៈ។ ប៉ុន្តែ បើមានតែសុចន្ទៈមួយ ក៏វាមិនគ្រប់គ្រាន់ទេ។ វាទាល់តែកម្ពុជាខ្លួនឯងមានការអភិវឌ្ឍដែរ។ ដូចជាពាណិជ្ជកម្ម មិនមែននាំចេញតែពីកូរ៉េទៅកម្ពុជា តែគ្មានទំនិញពីកម្ពុជាត្រឡប់មកវិញ ហើយធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េកើតនោះទេ ... យើងមានលទ្ធភាពដើម្បីនឹងពង្រីកទំនិញពីកម្ពុជានាំចេញមកកូរ៉េ។ ប្រទេសដែលមានសមត្ថភាពនាំចេញ ប្រទេសនោះមានការអភិវឌ្ឍដែរ។ បើអត់មានការអភិវឌ្ឍធ្វើម៉េចមានទំនិញនាំចេញ? ...៕

២៩. សភាពាណិជ្ជកម្ម/ធុរកិច្ចកម្ពុជា គួរសម្លឹងឆ្ពោះទៅរកទីផ្សារថ្មីៗ

សម្ពោធអគារតំន្រ្តទៅ នៃរាជបណ្ឌិតសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... យើងនៅសេសសល់ប្រទេស(ខ្លះ) ... គួរណែនាំសភាពាណិជ្ជកម្មរបស់យើង (ឬ)ផ្នែកធុរកិច្ច ឱ្យសម្លឹងមើលឆ្ពោះទៅរកទីផ្សារនានារាប់ទាំងថ្ងៃមុន (មានកោះ) Palau ដែលថា ទិញអង្ករពីអាមេរិកថ្លៃណាស់ ... ខ្ញុំសួរគាត់ថា តើសព្វថ្ងៃទិញអង្ករពីណា? គាត់(ថា)ទិញពីអាមេរិក និងទិញពីអូស្ត្រាលី ហើយថ្លៃណាស់(រីង)ដឹកក៏ធ្ងាយ។ ខ្ញុំថា អញ្ចឹង ឯកឧត្តម រៀបចំទិញពីកម្ពុជាទៅ។ ធ្វើតាមអញ្ចេះឯកឧត្តម ឱ្យក្រុមវិនិយោគមួយក្រុមមកកសាងឃ្លាំង កសាងម៉ាស៊ីនកិនស្រូវប្រមូលទិញពីប្រជាពលរដ្ឋ កិនហើយនាំចេញទៅ Palau ដែលនៅមិនធ្ងាយពីហ្វីលីពីនប៉ុន្មានទេ។ អញ្ចឹងផ្តត់ផ្តង់មានស្ថិរភាព ...៕

៣០. មិនមែន EBA ទេ គឺរឿងអង្ករអ៊ីតាលីនិងអេស្ប៉ាញលក់មិនដាច់ រារាំងអង្ករកម្ពុជា

សម្ពោធ អគារតំន្រ្តទៅ នៃរាជបណ្ឌិតសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... ខ្ញុំមើលស្ថិតិនាំចេញអង្ករ។ **នេះក៏ជារឿងមួយគួរជកពិសោធន៍ដែរ។ (ដែលមានការារាំង)អង្ករយើងទៅអឺរ៉ុប មិនមែនរឿង EBA ទេ។ គឺរឿងប្រទេសអ៊ីតាលីនិងប្រទេសអេស្ប៉ាញ ដែលលក់អង្ករបស់គាត់មិនដាច់ ... ដូចនេះគាត់ប្រឆាំងនឹងអង្ករយើង និងអង្ករមីយ៉ាន់ម៉ា។ គាត់វាយពន្ធលើអង្ករយើង។ ខ្ញុំគិតស្មានថាការវាយពន្ធលើអង្ករយើង នឹងធ្វើឱ្យមានការផ្អាកនាំចេញអង្ករពីកម្ពុជាទៅកាន់អឺរ៉ុប។ ផ្ទុយទៅវិញក្នុងចំណោម ២៨ប្រទេស អង្ករកម្ពុជាចូលទៅកាន់បាន ២៣**

ប្រទេសនៅអឺរ៉ុបដដែល។ អញ្ចឹង ពេលមិនទាន់បង់ពន្ធក៏នាំទៅបានដល់គេឱ្យបង់ពន្ធនៅតែនាំទៅបាន។ ខាងមុខនេះក៏ដូចគ្នាដែរ បើគេដក EBA គេឱ្យបង់ពន្ធ បង់ពន្ធឱ្យគេទៅ ព្រោះអាហ្នឹងវាគង់តែបាត់ដដែល ...៕

៣១. កាត់បន្ថយចំណាយផ្លូវការនិងមិនផ្លូវការ ឱ្យអ្នកវិនិយោគមានឱកាសប្រកួតប្រជែង

បើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុង ខ្សែទី៣ (ផ្លូវជាតិលេខ៤ ដល់១), ១៤ មករា ២០១៩

... សូមផ្តាំទៅវិនិយោគិនទាំងឡាយ អ្នកធ្វើធុរកិច្ចទាំងឡាយ នៅពេលខាងមុខនឹងមានការដាក់ចេញវិធានការកាត់បន្ថយការចំណាយផ្លូវការ និងមិនផ្លូវការ ដើម្បីឱ្យអ្នកវិនិយោគមានឱកាសប្រកួតប្រជែងកាន់តែខ្លាំង លើវិស័យសេដ្ឋកិច្ចបម្រើឱ្យការប្រើប្រាស់ក្នុងស្រុក បន្ថយការនាំចូល និងជំរុញការនាំចេញ ... គ្រាន់តែវិស័យសំណង់មួយទេ ពីមុនយើងនាំចូលស្ទើរតែទាំងអស់ ស៊ីម៉ង់ត៍ ៥លានតោនរហូតដល់ ៧ទៅ ៨លានតោនដើម្បីប្រើប្រាស់ ... ឥឡូវនេះ យើងផលិតបានខ្លួនឯងរហូតទៅ ៧លាន ៥សែនតោន ដែលអាចផ្តល់អោយប្រមាណ៩០% នៃសេចក្តីត្រូវការក្នុងប្រទេស ...៕

៣២. កែច្នៃវត្ថុធាតុដើមជាផលិតផលសម្រេចនាំចេញ និងប្រើប្រាស់ជំនួសការនាំចូល

សំណេះសំណាលជាមួយកម្មករ និយោជិត ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ, ៨ សីហា ២០១៨

... យើងកំពុងជាក់រោងចក្រកែច្នៃដំឡូង។ **ក្នុងមួយឆ្នាំៗ យើងមាន(ដំឡូង)១៤លានតោន។ យើងត្រូវជាក់ម៉ាស៊ីនកែច្នៃជាម្សៅមី ឈានទៅដល់ការច្នៃធ្វើទៅជាអ្វីដែលជាផលិតផលសម្រេច ដើម្បីលក់នៅក្នុងទីផ្សាររបស់យើងនិងនាំចេញ។** ដូចជាការធ្វើមីកញ្ចប់ មីរបស់យើងដែលហៅថា «មីយើង» បច្ចុប្បន្នមិនមែនលក់តែក្នុងស្រុកទេ គឺបាននាំទៅដល់ប្រទេសជប៉ុន បានទៅដល់ប្រទេសជាទៃហើយ ... យើងជម្រុញការកែច្នៃម្រេចតាមភូមិសាស្ត្រ ដែលមានម្រេចកំពត ម្រេចកំពង់ចាម ម្រេចមេមត់ កន្លែងនេះកន្លែងនោះ។ យើងមានការកែច្នៃទៅលើបញ្ហាដទៃទៀត

ដូចជាទុរេន សាវម៉ាវ ទាំងអស់ហ្នឹងសុទ្ធតែជំនួសឲ្យការនាំចូល ហើយក៏អាចនាំចេញបន្ថែមបានទៀតផង ...៕

៣៣. ប្រើអស់សក្តានុពលទីផ្សារដែលកំពុងមានដើម្បីទាញតម្លៃស្រូវអោយឡើងវិញ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកអង្គស្នួល
ខេត្តកណ្តាល, ២០ កុម្ភៈ ២០១៩

... តម្លៃស្រូវមានការធ្លាក់ចុះ។ រដ្ឋមន្ត្រីក្រសួងកសិកម្មនិងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវខិតខំប្រើប្រាស់ទីផ្សារដែលកំពុងមាន។ ទៅប្រទេសវៀតណាម ៣០ម៉ឺនតោន ទៅប្រទេសចិន ៤០ម៉ឺនតោន តែពីរហ្នឹងគឺជាអង្ករ ៧០ម៉ឺនតោន ស្មើនឹងស្រូវជាង ១លានតោន។ **ត្រូវប្រឹងប្រែងប្រើឲ្យអស់នូវសក្តានុពលទីផ្សារដែលយើងមានខាងក្រៅជាមួយទីផ្សារទាំងឡាយដែលយើងកំពុងមានដើម្បីទាញតម្លៃស្រូវរបស់កសិករឲ្យឡើងមកវិញ។** សូមជម្រាបជូនបងប្អូនប្រជាកសិករ នៅពេលដែលតម្លៃស្រូវចុះ គួរកុំអាលប្រញាប់ប្រញាល់ជាមួយនឹងការលក់ចេញ។ ពេលខ្លះកសិកររបស់យើងលក់ស្រូវទាំងសើម ដោយសារខ្ជិលហាល ខ្ជិលដឹកចូលជង្រុក ... ដូច្នេះគេបង្អាប់ថ្លៃទៅតាមហ្នឹង ...៕

៣៤. នយោបាយគាំពារនិយម មិនមានជោគជ័យឡើយ ក្បិតប្រទេសមួយមិនអាចនៅឯកោបានទេ

ពិធីសម្ពោធរោងចក្រស៊ីម៉ងត៍ ជីប ម៉ុង, ៨ កុម្ភៈ ២០១៨

... ខ្ញុំនៅតែជឿជាក់ថា**នយោបាយគាំពារនិយមនឹងមិនមានជោគជ័យទេ។ ប្រទេសនីមួយៗ មិនអាចឯកោទៅតែឯងបានទេ គឺត្រូវមានសហប្រតិបត្តិការជាមួយប្រទេសផ្សេង។ អ្នកត្រូវនាំចេញទំនិញទៅខាងក្រៅ។ ខាងក្រៅត្រូវនាំចូលទំនិញចូលទៅក្នុងប្រទេសរបស់អ្នក។ នេះគឺជាដំណើរធម្មតានៃការរកស៊ីនៅក្នុងវិស័យសេដ្ឋកិច្ចរបស់គ្រប់ប្រទេសលើពិភពលោកនេះ**។ បើទោះបីជាអ្នកហាមឃាត់ ក៏អ្នកមិនអាចហាមឃាត់ក្រុមហ៊ុនឯកជនបានដែរ។ បើអ្នកហាមឃាត់ក្រុមហ៊ុនឯកជនបាន អ្នកមិនខុសពីប្រទេសដែលមានរបបផ្តាច់ការមួយ ដែលឈានរហូតដល់ហាមឃាត់ក្រុមហ៊ុនឯកជន មិនអោយធ្វើសកម្មភាពដោយសេរីនោះ

ទេ។ ប្រទេសដែលប្រកាន់លទ្ធិប្រជាធិបតេយ្យសេរី ជាប្រទេសដែលមិនដាក់កំណត់ណាមួយ(ឡើយ) លើកលែងតែវិធានពន្ធដារ និងបទដ្ឋានដែលមានការពាក់ព័ន្ធ ...៕

១៥. ព័ត៌មាន

១	អ្នកសារព័ត៌មានបានធ្វើអោយពិភពលោកស្គាល់ ហ៊ុន សែន តាំងពីឆ្នាំ១៩៨២	២៥១
២	នាំកម្មវិធីនយោបាយរដ្ឋាភិបាលទៅប្រជាជន នាំកង្វល់ពីប្រជាជនមករដ្ឋាភិបាល	២៥១
៣	មេដឹកនាំមានការប្រាស្រ័យទាក់ទងមិនអាចខ្វះបានជាមួយអ្នកសារព័ត៌មាន	២៥១
៤	សារព័ត៌មាននិងស្ថាប័នជាតិ ធ្វើទំនាក់ទំនងតាមរយៈទីប្រឹក្សាឬជំនួយការ	២៥២
៥	សារព័ត៌មាន/ស្ថាប័នជាតិ ធ្វើទំនាក់ទំនងតាមបណ្តាញសង្គម វិទ្យុ/ទូរទស្សន៍	២៥២
៦	ត្រូវតែមានអ្នកនាំពាក្យគ្រប់ស្ថាប័ន ក្រសួង និងប្រកបដោយវិជ្ជាជីវៈខ្ពស់	២៥៣
៧	បើធ្វើជាអ្នកនាំពាក្យបាន ធ្វើជានាយករដ្ឋមន្ត្រីបាន ត្បិតមានចរិតសរុប	២៥៣
៨	មិនស្វះស្វែងរកព័ត៌មានខ្លួនឯង អ្នកសារព័ត៌មាននឹងក្ស័យអាជីព	២៥៤
៩	សារព័ត៌មាន ៣ប្រភេទ ដែលមិនជួយសង្គម	២៥៤
១០	និយមកណ្តាល មិនឆ្វេងពេក មិនស្តាំពេក និងហ៊ាននិយាយការពិត	២៥៥
១១	អ្នកសារព័ត៌មានមិនត្រូវតាំងខ្លួនជាចៅក្រមកាត់សេចក្តី	២៥៥
១២	ថ្នាក់ដឹកនាំស្ថាប័ន/អាជ្ញាធរក្រោមជាតិ មិនត្រូវយកអ្នកសារព័ត៌មានជាសត្រូវ	២៥៦
១៣	អ្នកសារព័ត៌មានក្លាហាន សុចរិត ចៀសវាងភាពទុច្ចរិត ក្នុងការតាំងសំណួរ	២៥៦
១៤	រដ្ឋនិងសារព័ត៌មាន បំពេញតួនាទីជាកញ្ចក់ឆ្លុះភាពពិតនៃសង្គម	២៥៧
១៥	ចូលរួមវិភាគហេតុការណ៍ជាតិនិងអន្តរជាតិ ក្នុងកម្រិតយុទ្ធសាស្ត្រ	២៥៧
១៦	អត្ថប្រយោជន៍នៃការតភ្ជាប់ជាមួយប្រព័ន្ធព័ត៌មានអនឡាញ/ឌីជីថល	២៥៨
១៧	បញ្ហានព័ត៌មានពីប្រភពអនឡាញទៅស្ថាប័ន/ខត្តពាក់ព័ន្ធ ស្រាវជ្រាវ/ដោះស្រាយ	២៥៨
១៨	រំពឹងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន នឹងចេញនៅអាណត្តិទី៧ នៃរាជរដ្ឋាភិបាល	២៥៨
១៩	ព្រៀងច្បាប់ពីរ ប្រើរួមនឹងក្រមព្រហ្មទណ្ឌ ផ្តន្ទាទោសបទល្មើសបច្ចេកវិទ្យាព័ត៌មាន	២៥៩
២០	កំពុងពិចារណារៀបចំច្បាប់ប្រឆាំងព័ត៌មានក្លែងក្លាយ	២៥៩
២១	ព័ត៌មានក្លែងក្លាយធ្វើឱ្យសង្គមមានអស្ថិរភាពនយោបាយ អសន្តិសុខ និងអរិភាព	២៦០
២២	យកការពិតបកស្រាយឲ្យលឿន រហ័ស និងច្បាស់ ប្រឆាំងព័ត៌មានក្លែងក្លាយ	២៦០
២៣	ផ្តល់មេធាវីការពារក្តីអ្នកសារព័ត៌មានហ៊ានបញ្ចេញការពិត មានភស្តុតាងគ្រប់គ្រាន់	២៦១
២៤	"កុំបំពានអ្នកដទៃ កុំបំភ្លៃការពិត" និង "ផ្សព្វផ្សាយព័ត៌មានពិត កុំប្រឌិតកំហុស ..."	២៦១
២៥	ការបំពុលព័ត៌មានមានកម្រិតបំផ្លាញធំជាងគ្រាប់បែក និងអាចបំផ្លាញប្រទេសជាតិ	២៦២

២៦	**អ្នកសារព័ត៌មាន "កុំដើរតួជាតុលាការ"**	**២៦២**
២៧	**ស្លាកព័ត៌មាន មិនមែនអភ័យឯកសិទ្ធិការពារការប្រព្រឹត្តិអំពើផ្តេសផ្តាស**	**២៦២**
២៨	**ប្រណាំងប្រជែងដើម្បី"សារព័ត៌មានពិតនិងលឿន" និងបើច្រើនភាសាកាន់តែល្អ**	**២៦៣**
២៩	**ប្រទេសបិតាប្រជាធិបតេយ្យក៏បារម្ភពីឧក្រិដ្ឋកម្មព័ត៌មានវិទ្យានិងព័ត៌មានក្លែងក្លាយ**	**២៦៣**
៣០	**សូមជួយផ្សាយពាណិជ្ជកម្មក្នុងកម្មវិធីព័ត៌មាន**	**២៦៤**

១. អ្នកសារព័ត៌មានបានធ្វើអោយពិភពលោកស្គាល់ ហ៊ុន សែន តាំងពីឆ្នាំ១៩៨២

ពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី២, ២១ មករា ២០១៨

បើមិនមានអ្នកសារព័ត៌មានជួយទេ ប្រហែលជានៅលើពិភពលោកនេះគ្មាននរណាអាចស្គាល់ខ្ញុំទេ។ **សារព័ត៌មានមួយចំនួនបានជួយឲ្យខ្ញុំល្បីឈ្មោះតាំងពីទសវត្សរ៍៧០ ឯណោះ ជាពិសេស ចាប់តាំងពីឆ្នាំ១៩៨២។ អ្នកកាសែត ហ្សាក់ បេតែរ, ប៉ូល ម៉ុងតេ និងមនុស្សមួយចំនួនទៀត បានចូលចិត្តសរសេរពីខ្ញុំ។ គេបានសរសេរពីខ្ញុំថា "តារាកំពុងរះ" តាំងពីឆ្នាំ១៩៨២**។ សូមមើលឡើងវិញនូវកាសែត Bangkok Post និង Le Monde។ អ្នកទាំងពីរចូលចិត្តសរសេរដូចនេះនៅពេលនោះ។ គេសរសេរច្រើន។ តាមរយៈនោះហើយ ដែល**ធ្វើឲ្យពិភពលោកបានស្គាល់ពី ហ៊ុន សែន ហើយការស្គាល់នេះ ក៏មិនមែនស្គាល់ត្រឹមមួយឆ្នាំពីរឆ្នាំទេ គឺស្គាល់រាប់សិបឆ្នាំរួចមកហើយ ...**។

២. នាំកម្មវិធីនយោបាយរាជរដ្ឋាភិបាលទៅប្រជាជន នាំកង្វល់ពីប្រជាជនមករដ្ឋាភិបាលវិញ

សំណេះសំណាលនិងពិសាអាហារសាមគ្គីជាមួយអ្នកសារព័ត៌មានលើកទី៥, ១៤ មករា ២០២៣

... ស្ថាប័នព័ត៌មានត្រូវបង្កើតភាពជាដៃគូជាមួយរាជរដ្ឋាភិបាល ... បំពេញតួនាទីជាស្ពានចម្លង ផ្សាភ្ជាប់ទំនាក់ទំនងពីស្ថាប័នរដ្ឋទៅប្រជាជន និងពីប្រជាជនមកស្ថាប័នរដ្ឋវិញ ទាំងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលទាំងការអនុវត្តជាក់ស្តែងដែលតម្រូវឱ្យអ្នកសារព័ត៌មានចូលរួមកាន់តែសកម្មថែមទៀតថែរក្សាសុខសន្តិភាពនិងការអភិវឌ្ឍប្រទេសជាតិ ... **ត្រូវធ្វើយ៉ាងណាឲ្យយើងអាចយកកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលទៅកាន់ប្រជាជន ហើយពាំនាំមក(រដ្ឋាភិបាល)វិញនូវកង្វល់របស់ប្រជាជន ព្រោះមិនមែនអ្វីដែលដាក់ទៅប្រជាជនពេញចិត្តទាំងអស់ទេ ...**។

៣. មេដឹកនាំមានការប្រាស្រ័យទាក់ទងមិនអាចខ្វះបានជាមួយអ្នកសារព័ត៌មាន

ពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី២, ២១ មករា ២០១៨

... តើគួរធ្វើយ៉ាងម៉េចអំពីកិច្ចការអ្នកសារព័ត៌មានជាមួយស្ថាប័នជាតិ ? ដោយសារតែមានការពាក់ព័ន្ធរវាងស្ថាប័នរដ្ឋជាមួយអ្នកសារព័ត៌មាន បានជាកន្លងទៅ

មានវេទិការវាងអ្នកនាំពាក្យនិងអ្នកសារព័ត៌មាន។ តើគួរមានទំនាក់ទំនងដូចម្តេច ដើម្បីយើងរួមគ្នាលើនាវាមួយដែលមិនឃ្លេងឃ្លោង ... **ប្រទេសជាច្រើន មេដឹកនាំតែងមានការប្រាស្រ័យទាក់ទងជាប្រចាំ មិនអាចខ្វះអ្នកសារព័ត៌មានបានទេ។ មិនថាសារព័ត៌មាននោះបែបណា ប៉ុន្តែការប្រាស្រ័យទាក់ទងរវាងមេដឹកនាំជាមួយអ្នកសារព័ត៌មានអាចធ្វើទៅរួច ... ក្នុងរយៈពេល ៣៩ឆ្នាំ ខ្ញុំប្រើពេលវេលាច្រើនណាស់ជាមួយសារព័ត៌មាន**។

៤. សារព័ត៌មាននិងស្ថាប័នជាតិ ធ្វើទំនាក់ទំនងតាមរយៈទីប្រឹក្សាឬជំនួយការ

ពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី២, ២១ មករា ២០១៨

... **(សារព័ត៌មានមានទំនាក់ទំនងជាមួយស្ថាប័នជាតិ)តាមរយៈទីប្រឹក្សា ឬជំនួយការ ដែលត្រូវផ្តល់ព័ត៌មានឲ្យប្រព័ន្ធផ្សព្វផ្សាយ។**ជាទម្លាប់ធម្មតា ... ក្រៅពីជំនួបផ្ទាល់រវាងខ្ញុំជាមួយអ្នកសារព័ត៌មាន តាមរយៈបទសម្ភាសន៍ ការធ្វើសន្និសីទកាសែត ឬក៏ទំនាក់ទំនងដទៃទៀត នៅមាន(ការផ្តល់ព័ត៌មាន)តាមរយៈទីប្រឹក្សាឬជំនួយការ ដែលខ្ញុំប្រគល់ឲ្យពួកគេធ្វើជាអ្នកទទួលខុសត្រូវដល់ប្រព័ន្ធផ្សព្វផ្សាយ។ ក្រោយពីជួបភ្ញៀវរួចហើយ ឬការប្រជុំ ឬចរចារួចហើយ ខ្ញុំមិនមានពេលគ្រប់គ្រាន់ដើម្បីនឹងផ្តល់ព័ត៌មាន ឬប្រជុំកាសែតទេ។ យើងបានរៀបចំចាត់តាំងក្រុមអ្នកឯកទេសខាងផ្នែកព័ត៌មាន សម្រាប់ផ្តល់សារជូនអ្នកយកព័ត៌មាន។ បើមិនដូច្នេះទេ តើអ្នកសារព័ត៌មានបានអ្វីផ្សាយ? ដូចនេះ មន្ត្រីដែលបានទទួលភារកិច្ចក្នុងឋានៈជាទីប្រឹក្សា ឬជាជំនួយការ ត្រូវផ្តល់ព័ត៌មានឲ្យប្រព័ន្ធផ្សព្វផ្សាយ ...។

៥. សារព័ត៌មាននិងស្ថាប័នជាតិ ធ្វើទំនាក់ទំនងតាមបណ្តាញសង្គម វិទ្យុនិងទូរទស្សន៍

ពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី២, ២១ មករា ២០១៨

... **(អ្នកសារព័ត៌មានធ្វើទំនាក់ទំនងជាមួយស្ថាប័នជាតិ)តាមសេចក្តីប្រកាសឬសេចក្តីជូនដំណឹង ជាលាយលក្ខណ៍អក្សរ។ ស្ថាប័នភាគច្រើនមានគេហទំព័រ មានហ្វេសប៊ុក (បណ្តាញសង្គម) និងហូតដល់ស្ថាប័នខ្លះ ដូចជាក្រសួងការពារជាតិ មហាផ្ទៃ រាជធានីភ្នំពេញនិងខេត្តមួយចំនួន មានវិទ្យុនិងទូរទស្សន៍ផ្ទាល់ថែមទៀតផង**។ ដូច្នេះ បើមិនខ្ជិលទេ អ្នកសារព័ត៌មានអាចស្វែងរកគេហទំព័រ ឬហ្វេសប៊ុកឬក៏បណ្តាញផ្សព្វផ្សាយរបស់ស្ថាប័ននោះ ... សូមរំលឹកថា សព្វថ្ងៃមិនមែនខ្វះព័ត៌មានទេ។ ជួនកាលអាចនឹងលើសទៀតផង។ លើសត្រង់ថា អ្នកដែលចូលចិត្តនិយាយៗ ច្រើនពេក និយាយជ្រុល និយាយហួស។ ឯដែលខ្វះ គឺអ្នកដែលខ្ជិលស្វែងរកព័ត៌មាន។ នៅពេលគេបង្ហាញព័ត៌មាននៅគេហទំព័រផ្លូវការហើយ ទៅតាមសួរអីទៀត បើផ្សាយនៅហ្នឹងហើយ ...។

៦. ត្រូវតែមានអ្នកនាំពាក្យគ្រប់ស្ថាប័ន ក្រសួង និងប្រកបដោយវិជ្ជាជីវៈខ្ពស់

ពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី២, ២១ មករា ២០១៨

... **(អ្នកសារព័ត៌មានធ្វើទំនាក់ទំនងជាមួយស្ថាប័នជាតិ) តាមរយៈអ្នកនាំពាក្យដែលគ្រប់ស្ថាប័នរាជធានី ខេត្ត រៀបចំឡើង**។ កន្លងទៅ ខ្ញុំតែងតែមានការជំរុញឲ្យគ្រប់ស្ថាប័ន ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ រៀបចំអ្នកនាំពាក្យ។ យោងទៅលើការសិក្សានិងស្តាប់មតិពីអ្នកសារព័ត៌មាន អ្នកនាំពាក្យនៅតាមស្ថាប័នខ្លះមិនទាន់បំពេញតួនាទីគ្រប់គ្រាន់នៅឡើយទេ ពិសេសអ្នកនាំពាក្យនៅតាមខេត្តនីមួយៗ ... ត្រូវចង្អុលឲ្យចំតើអ្នកណាដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ក្នុងការផ្សព្វផ្សាយព័ត៌មាន ... អ្នកនាំពាក្យតាមស្ថាប័នរបស់រាជរដ្ឋាភិបាល អ្នកនាំពាក្យតាមសាលាខេត្ត រាជធានី ត្រូវតែបានពង្រឹងដើម្បីឆ្លើយតបទៅនឹងសិទ្ធិទទួលបានព័ត៌មានដល់អ្នកព័ត៌មាន ...។

៧. បើធ្វើជាអ្នកនាំពាក្យបាន ធ្វើជានាយករដ្ឋមន្ត្រីបាន ត្បិតមានចរិតសរុប

ពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី២, ២១ មករា ២០១៨

... (ការពង្រឹងអ្នកនាំពាក្យថ្នាក់ជាតិនិងក្រោមជាតិ)ជារឿងដែលអ្នកសារព័ត៌មាននិងស្ថាប័នព័ត៌មានទន្ទឹងរង់ចាំ ចង់ដឹងថាតើខ្ញុំមានប្រតិកម្ម និងការជំរុញគ្រឿនយ៉ាងណា ... **សម្រាប់អ្នកនាំពាក្យក៏ត្រូវតែច្បាស់លាស់ ហើយក៏ត្រូវតែមានចំណេះដឹងគ្រប់គ្រាន់ដើម្បីឆ្លើយតប(នឹងការចង់បានព័ត៌មាន) មិនមែនរៀបចំរួចពីដៃទេ។ បើធ្វើជាអ្នកនាំពាក្យបាន អាចធ្វើជានាយករដ្ឋមន្ត្រីបាន ... អ្នកនាំពាក្យត្រូវមានចរិតសរុប ហើយមានសមត្ថភាពពេញលេញឆ្លើយតបជាមួយគ្រប់**

ហេតុការណ៍។ ពិតមែនហើយ មិនមែនអ្នកណាចេះគ្រប់រឿងទេ ហើយក៏មិនតម្រូវឲ្យអ្នកនាំពាក្យឆ្លើយគ្រប់តែសំណួរនោះដែរ។ ក្នុងករណីដែលមិនច្បាស់ អ្នកនាំពាក្យគ្រាន់តែបង្ហាញថា រឿងនេះខ្ញុំមិនទាន់បានទទួលព័ត៌មានជាក់លាក់ ខ្ញុំនឹងឆ្លើយប្រាប់អស់លោកអ្នកនៅពេលក្រោយ ...។

៨. មិនស្វះស្វែងរកព័ត៌មានខ្លួនឯង អ្នកសារព័ត៌មាននឹងក្ស័យអាជីព

ពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី២, ២១ មករា ២០១៨

... **អ្នកសារព័ត៌មានត្រូវស្វះស្វែងរកព័ត៌មានដោយខ្លួនឯង។ នេះទើបជាកិច្ចការប្រកបដោយវិជ្ជាជីវៈ ... សម័យនេះ អ្នកចង់ផ្សព្វផ្សាយព័ត៌មាន ច្បាស់ជាទៅរកព័ត៌មានណាដែលពិត ដែលសរសេរល្អ រួចហើយផ្សាយបានឆាប់រហ័សទៀត ... ដូចនេះ បើអ្នកសារព័ត៌មានមិនស្វះស្វែងរកព័ត៌មានដោយខ្លួនឯង អ្នកសារព័ត៌មាននោះនឹងក្ស័យធន ហើយក្ស័យអាជីពទៀតផង ដោយសារបច្ចេកវិទ្យាបច្ចុប្បន្ន** ត្បិតមិនទាន់បានទាំងផ្សាយផង គេផ្សាយមុនតាមហ្វេសប៊ុក/បណ្តាញសង្គមបាត់ទៅហើយ ... សម័យបច្ចេកវិទ្យាព័ត៌មាន មេដឹកនាំម្នាក់ជាសារព័ត៌មានមួយដែរ ... ឧទាហរណ៍ ពេលដែលខ្ញុំផូស្តក្នុងហ្វេសប៊ុក Page ព័ត៌មានបានទៅដល់មនុស្ស ១៨លាននាក់ឯណោះ ... ដូច្នេះ ខ្ញុំគ្មានការចាំបាច់ដើម្បីរង់ចាំទេ ...។

៩. សារព័ត៌មាន ៣ប្រភេទ ដែលមិនជួយសង្គម

ពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី២, ២១ មករា ២០១៨

... នៅប្រទេសរបស់យើងមានសារព័ត៌មានបីប្រភេទផ្សេងទៀត ដែលក្រសួងព័ត៌មានក៏បានចាត់វិធានការណ៍រួចទៅហើយ។ **ទី១ ប្រភេទសារព័ត៌មានដែលមិនត្រូវអោយមានតទៅទៀតទេ។ គឺប្រភេទសារព័ត៌មានជើរតួម៉ាហ្វ៊ា (mafia) ...** ជើរតួនាទីជាអ្នកជម្រិតទារប្រាក់។ បើអោយលុយមិនចុះផ្សាយ មិនឱ្យលុយចុះផ្សាយព័ត៌មានអាក្រក់ៗ។ រឿងនេះទាក់ទងច្រើនទៅលើបញ្ហាបទល្មើសព្រៃឈើ។ សូមផ្តាំផ្ញើទៅអ្នកសារព័ត៌មានដែលធ្វើសកម្មភាពបែបនេះ សូមបញ្ឈប់ជាបន្ទាន់។ ខ្ញុំមានឯកសារនិងមានទាំងសម្លេងឆ្លើយឆ្លងរបស់អ្នកទៀតផង ...។

ទី២ ប្រភេទព័ត៌មានមិនគោរពច្បាប់ មិនចុះបញ្ជីតាមច្បាប់ និងរត់គេចវេះលួចបន្លំប្រាក់ពន្ធ។ ក្រោយបែករឿង ក៏ជើរសំដែងតួជាអ្នករងគ្រោះខាងនយោបាយតាមរបៀបថ្មី ដើម្បីទទួលបានការកោតសរសើរពីសាម៉ីប្រទេស និងពីអ្នកដែលគេបោកបាន។ កន្លងទៅជាការពិត សារព័ត៌មានមួយចំនួនមកធ្វើសកម្មភាពនៅក្នុងប្រទេសរបស់យើង ដោយរំលោភច្បាប់ នៃប្រទេសរបស់យើង ជាពិសេសមិនបានបង់ពន្ធត្រឹមត្រូវទៅតាមការកំណត់នៃច្បាប់របស់កម្ពុជា ... មិនត្រូវអោយរឿងនេះកើតមានតទៅទៀតទេ។ ក្រសួងព័ត៌មានជាអាណាប័កត្រូវទទួលខុសត្រូវ ...។

ទី៣ ប្រភេទសារព័ត៌មានដែលមានតែឈ្មោះតែគ្មានសកម្មភាព ... អ្នកខ្លះជើរតួជាចាងហ្វាងសារព័ត៌មាន។ ពេលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ក៏បង្ហាញកាតជាអ្នកសារព័ត៌មានដើម្បីរួចពីទោសទណ្ឌ ... ដែលជានោះការបំផ្លាញកិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់អ្នកសារព័ត៌មាន ...។

១០. គួរនិយមកណ្តាល មិនឆ្វេងពេក មិនស្តាំពេក និងហ៊ាននិយាយការពិត

ពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី២, ២១ មករា ២០១៨

... គួរស្តាប់នព័ត៌មាននិងអ្នកយកព័ត៌មានត្រូវធ្វើដូចម្តេច ទើបល្អ? ... ចម្លើយរបស់ខ្ញុំគឺទាំង**ស្តាប់នទាំងបុគ្គល(ធ្វើកិច្ចការព័ត៌មាន) កុំឆ្វេងពេក ហើយក៏កុំស្តាំពេក។ រឿងវាតែប៉ុណ្ណឹងទេ។ ចលនានិយមកណ្តាល គឺជាចលនាដែលគេទទួលបានគ្រប់ៗគ្នា**។ ចលនាឆ្វេងនិយម ឬស្តាំនិយម សុទ្ធតែជាចលនា(ជ្រុលនិយម)ទាំងអស់។ សូម្បីតែក្នុងដំណាក់កាលចុងក្រោយនេះ ក្នុងបរិបទតំបន់និងសកលលោក បន្ទាប់ពីមានហិង្សាជ្រុលនិយម មានការបង្កើតចលនានិយមកណ្តាល។ ដូច្នេះ **សម្រាប់អ្នកសារព័ត៌មាន ឬស្តាប័នព័ត៌មាន គឺមិនត្រូវស្តាំពេក ហើយក៏មិនត្រូវឆ្វេងពេក ហើយសំខាន់បំផុត គឺហ៊ាននិយាយការពិតចេញមក** ...។

១១. អ្នកសារព័ត៌មានមិនត្រូវតាំងខ្លួនជាចៅក្រមកាត់សេចក្តី

ពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី២, ២១ មករា ២០១៨

... ការធ្វើអត្ថាធិប្បាយរបស់ស្ថានីយទូរទស្សន៍និង/ឬវិទ្យុខ្លះ ហាក់ដូចជាបាននិងកំពុងធ្វើតួនាទីខុសពីទម្រង់ជាអ្នកព័ត៌មាន។ **អ្នកខ្លះធ្វើអត្ថាធិប្បាយហួត**

ដល់មានការសន្និដ្ឋានតាមបែបចៅក្រមកាត់សេចក្តី។ ខ្ញុំមិនលើកទឹកចិត្តអោយធ្វើបែបនេះទេ។ គប្បីរៀនសូត្រពីវិជ្ជាជីវៈសារព័ត៌មាន ... បើរឿងនោះទាក់ទងនឹងតុលាការ សូមទុកឲ្យតុលាការជាអ្នកធ្វើកិច្ចការនោះ ... អ្នកសារព័ត៌មាន អ្នកធ្វើអត្ថាធិប្បាយ អ្នកសរសេរព័ត៌មាន ត្រូវតែមានការប្តឹងប្តែង។ មិនត្រូវតាំងខ្លួនជាចៅក្រមកាត់សេចក្តី ហើយកំណត់អង្គហេតុនិងអង្គច្បាប់នោះទេ ...។

១២.ថ្នាក់ដឹកនាំស្ថាប័ន/អាជ្ញាធរក្រោមជាតិ មិនត្រូវយកអ្នកសារព័ត៌មានជាសត្រូវ

សំណេះសំណាលនិងពិសាអាហារសាមគ្គីនឹងអ្នកសារព័ត៌មានលើកទី៥, ១៤ មករា ២០២៣

...ថ្នាក់ដឹកនាំនៃស្ថាប័នជាតិ ក៏ដូចជាអាជ្ញាធរថ្នាក់ក្រោមជាតិ មិនត្រូវយកអ្នកសារព័ត៌មានធ្វើជាសត្រូវរបស់ខ្លួននោះទេ។ វានឹងជាកំហុសដ៏ធ្ងន់ធ្ងរនៃការដឹកនាំ ប្រសិនបើអ្នកទាំងអស់គ្នាចាត់ទុកថា អ្នកសារព័ត៌មានគឺជាសត្រូវរបស់ខ្លួន។ ខ្ញុំមិនជំទាស់ទេថាសារព័ត៌មានខ្លះដែលអត់បានការ។ ខ្ញុំមិននិយាយកផង។ ប៉ុន្តែអ្នកសារព័ត៌មានដែលមានចេតនាល្អក្នុងការផ្តល់ព័ត៌មានជូនសាធារណជន អំពីរឿងពិត គឺត្រូវគប្បីរាប់រកនិងធ្វើទំនាក់ទំនងអោយបានល្អ ដើម្បីផ្សារភ្ជាប់ព័ត៌មានដែលយើងធ្វើអោយសាធារណជនបានដឹង ...។

១៣. អ្នកសារព័ត៌មានក្លាហាន រក្សាសុចរិតភាព ចៀសវាងភាពទុច្ចរិតក្នុងការតាំងសំណួរ

ពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី២, ២១ មករា ២០១៨

... **អ្នកសារព័ត៌មានយើងត្រូវតែក្លាហាន ប៉ុន្តែត្រូវមានសុចរិតភាព។ សូម្បីតែក្នុងតាំងសំណួរ ខ្លះតាំងសំណួរប្រកបដោយភាពសុចរិត។ ការតាំងសំណួរខ្លះគឺជាការតាំងសំណួរបែបទុច្ចរិត**។ ឧទាហរណ៍ ដាក់ជាសំណួរមួយកំប្លែ។ និយាយពីសំណួរវែងនោះវែង និងចោទជាសំណួរ តែជាប្រភេទនៃចម្លើយ។ បើយើងបែរជាមិនចាប់អារម្មណ៍នឹងអ្នកទាំងនេះ ហើយ(ភ្លាត់មាត់)ឆ្លើយថា "បាន" ពួកគាត់នឹងយកទៅសរសេរ(បកស្រាយ)តែម្តង។ នេះជារបៀបដែលហៅថា ទុច្ចរិតភាពក្នុងការតាំងសំណួរ។ ការតាំងសំណួរនេះ ក៏ត្រូវតែមានរបៀបតាំងសំណួរឲ្យបានត្រឹមត្រូវ សមហេតុសមផល ងាយស្រួលដល់អ្នកដែលផ្តល់ជាចម្លើយផងដែរ ...។

១៤. រដ្ឋនិងសារព័ត៌មាន បំពេញតួនាទីជាកញ្ចក់ឆ្លុះភាពពិតនៃសង្គម

ពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី២, ២១ មករា ២០១៨

... តើខ្ញុំចង់បានអ្វីនៅពេលខាងមុខសម្រាប់ប្រទេសរបស់យើង។ **ទី១ ចង់បានស្ថាប័នព័ត៌មានទាំងរដ្ឋ ទាំងឯកជន ឲ្យបំពេញបាននូវតួនាទីជាកញ្ចក់ឆ្លុះបញ្ចាំងនូវស្ថានភាពពិតប្រាកដរបស់សង្គម។ នេះជាបំណងប្រាថ្នារបស់ខ្ញុំ ក្នុងពេលដែលគណបក្សប្រជាជន ជាពិសេសក្នុងពេលដែលខ្ញុំកាន់កាប់ដំណែងនាយករដ្ឋមន្ត្រី ខ្ញុំត្រូវការព័ត៌មានពិត ប្រៀបដូចជាការឆ្លុះបញ្ចាំងដោយកញ្ចក់** ... ខ្ញុំមានសំណូមពរថា សូមកុំឲ្យសារព័ត៌មានក្លាយទៅជាកញ្ចក់បែក ... អ្នកដែលមានវ័យលើសពី ៦០ ឆ្នាំចាំបានពីកញ្ចក់នៅវត្តភ្នំពីសម័យដើម។ កញ្ចក់នោះមានឆ្លុះទៅត្រឹមត្រូវ មានឆ្លុះទៅឃើញជាមនុស្សតឿ មានឆ្លុះទៅឃើញរបៀបជាមនុស្សស្គម ... **ខ្ញុំមិនចង់ឲ្យមានរឿងដូច្នឹងកើតទេ។ ដោយហេតុនេះ ទាំងរដ្ឋ ទាំងសារព័ត៌មានគ្រប់វិស័យត្រូវមានតម្លាភាព ធ្វើជាកញ្ចក់ឆ្លុះជាមួយគ្នា** ...។

១៥. ស្ថាប័នព័ត៌មានចូលរួមវិភាគហេតុការណ៍ជាតិនិងអន្តរជាតិ ក្នុងកម្រិតយុទ្ធសាស្ត្រ

ពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី២, ២១ មករា ២០១៨

... (ខ្ញុំ)**ចង់បានស្ថាប័នព័ត៌មានដែលចូលរួមវិភាគនយោបាយក្របខណ្ឌជាតិនិងអន្តរជាតិ ក្នុងកម្រិតយុទ្ធសាស្ត្រ ... ខ្ញុំចង់ឲ្យអ្នកសារព័ត៌មានរបស់យើងមានសមត្ថភាពដែលអាចវិភាគ មិនគ្រាន់តែហេតុការណ៍តូចតាចក្នុងស្រុក ប៉ុន្តែមានចក្ខុវិស័យនិងពិភពលោក**។ ខ្ញុំមានមោទនភាពថា អ្នកសារព័ត៌មានរបស់យើងទោះបីជាមិនទាន់កើនចំនួនច្រើន ក៏ប៉ុន្តែក្នុងរយៈពេលកន្លងទៅ បានរួមវិភាគទានជាការវិភាគ(ពីហេតុការណ៍)ក្នុងក្របខណ្ឌតំបន់និងអន្តរជាតិ ... ឧទាហរណ៍ យើងអាចព្យាករមើលថា តើកូរ៉េទាំងពីរអាចត្រូវរ៉ូវគ្នាពេលណា ក្នុងពេលដែលមានអ្នកមិនចង់ឲ្យកូរ៉េនិយាយគ្នានោះ ... ព្រោះថា ប្រសិនបើអស់ឧបសគ្គ(នៅឧបទ្វីប)កូរ៉េ ប្រហែលជាការតាំងកងទ័ពរបស់បរទេសក្នុងតំបន់ ក៏នឹងត្រូវអស់ន័យ ឬក៏មូលហេតុនេះមូលហេតុនោះ ...។

១៦. អត្ថប្រយោជន៍នៃការតភ្ជាប់ជាមួយប្រព័ន្ធព័ត៌មានអនឡាញ/ឌីជីថល

សំណេះសំណាលនិងពិសាអាហារសាមគ្គីនឹងអ្នកសារព័ត៌មានលើកទី៥,
១៤ មករា ២០២៣

... ក្នុងទូរស័ព្ទដៃរបស់ខ្ញុំៗបានភ្ជាប់ជាមួយសារព័ត៌មានអនឡាញដែលធ្វើឱ្យខ្ញុំបានដឹងព័ត៌មានទាំងឡាយ ... **ខ្ញុំមិនដឹងថារដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អភិបាលខេត្ត ឬអភិបាលស្រុក មន្ត្រីរាជការមានភ្ជាប់ប្រព័ន្ធនៃបណ្តាញព័ត៌មានឬអត់នោះទេ។ នេះជាសម័យឌីជីថល ជាសម័យដែលមិនចាំបាច់អានកាសែតទេព្រោះវាមាននៅក្នុងប្រព័ន្ធអនឡាញ** ... ផ្នែកទូរទស្សន៍ទៀតសោតក៏យើងអាចនឹង Download ចូលទៅក្នុងទូរស័ព្ទ ដែលយើងអាចមើលបានទាំងការផ្សាយបន្តផ្ទាល់ និងការផ្សាយដទៃទៀត ...។

១៧. បញ្ជូនព័ត៌មានពីប្រភពអនឡាញទៅស្តាប័នរដ្ឋពាក់ព័ន្ធ ស្រាវជ្រាវនិងដោះស្រាយ

សំណេះសំណាលនិងពិសាអាហារសាមគ្គីនឹងអ្នកសារព័ត៌មានលើកទី៥,
១៤ មករា ២០២៣

... សូមអរគុណចំពោះសារព័ត៌មានទាំងឡាយដែលបានចូលរួមប្រយុទ្ធប្រឆាំងនឹងអំពើអសកម្មនានា។ (សារព័ត៌មានទាំងនោះ)សព្វថ្ងៃបានបង្កើតនូវការងាយស្រួលដល់ខ្ញុំ។ សូមសំដែងការសោទរដោយស្មោះ ក្នុងនោះវិទ្យុនិងទូរទស្សន៍ជារឿងមួយហើយ ក៏ប៉ុន្តែបណ្តាញសង្គម/អនឡាញក៏បានជួយច្រើនដែរ។ ខ្ញុំតែងតែ Forward/បញ្ជូនចេញពីសារព័ត៌មានអនឡាញទៅខេត្តណាដែលមានបញ្ហា (ដូចមានក្នុងការផ្សាយ)អោយពិនិត្យ។ ប្រហែលជារដ្ឋមន្ត្រីមួយចំនួន អភិបាលខេត្តមួយចំនួនធ្លាប់បានទទួលរួចហើយ តាមរយៈប្រព័ន្ធតេឡេក្រាម ...។

១៨. រំពឹងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននឹងចេញនៅអាណត្តិទី៧ នៃរាជរដ្ឋាភិបាល

សំណេះសំណាលនិងពិសាអាហារសាមគ្គីនឹងអ្នកសារព័ត៌មានលើកទី៥,
១៤ មករា ២០២៣

... ប្រាកដណាស់ថា មកពេលនេះនៅសល់តែប៉ុន្មានខែទៀតតែប៉ុណ្ណោះ ការបោះឆ្នោតនឹងមកដល់។ **រំពឹងថា ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននឹងចេញនៅអាណត្តិទី៧ គឺអាចថានៅចន្លោះឆ្នាំ២០២៤ ឬ២០២៥។** ការយឺតយ៉ាវនេះ វាមិនមែនជារឿងដាច់ដោយឡែក(ពីរដ្ឋទេ)។ បើយើងគ្រាន់តែប្រើសិទ្ធិរបស់រដ្ឋធ្វើការសម្រេចវាជារឿងងាយ។ រដ្ឋមន្ត្រីធ្វើរួចហើយបញ្ជូនមកគណៈរដ្ឋមន្ត្រីអនុម័ត និងបញ្ជូនទៅសភាអនុម័ត(ជាការស្រេច)។ ប៉ុន្តែ យើងចង់ប្រមូលផ្តុំមតិយោបល់ពីគ្រប់ទិសទីដើម្បីឱ្យច្បាប់មួយនេះ ចេញទៅទទួលបានផលប្រយោជន៍ទាំងអស់គ្នា។ យើងបានសង្កេតឃើញថា **អង្គការក្រៅរដ្ឋាភិបាលខ្លះទាមទារជ្រុលនិងទាមទារច្រើនហួសហេតុនោះហើយ ដែលត្រូវឱ្យរដ្ឋមន្ត្រីធ្វើការសម្របសម្រួល** ...។

១៩. ព្រៀងច្បាប់ពីរប្រើរួមនឹងក្រមព្រហ្មទណ្ឌ ដើម្បីផ្តន្ទាទោសបទល្មើសបច្ចេកវិទ្យាព័ត៌មាន

ពិសាបាយសាមគ្គីនឹងអ្នកសារព័ត៌មានជាតិ/ក្រសួងព័ត៌មានលើកទី៣,
១១ មករា ២០១៩

... (អ្វីដែលខ្ញុំបានទទួលពី)រដ្ឋមន្ត្រីការបរទេសកម្ពុជា ដែលអគ្គរាជទូតកម្ពុជានៅវ៉ាស៊ីនតោន បានផ្ញើមកទាំងស្រុងអំពីសេចក្តីថ្លែងរបស់អគ្គរដ្ឋទូតថ្មីអាមេរិកចំពោះមុខព្រឹទ្ធសភាសហរដ្ឋអាមេរិក មិនដូចគ្នានឹងអ្វីដែលបានផ្សាយក្នុងវិទ្យុបរទេសមួយ ... បើធ្វើអញ្ចឹងបាន ពេលដែលនិយាយពីច្បាប់គ្រប់គ្រងសារព័ត៌មានមុខតែគេនឹងទាមទារឱ្យលុបច្បាប់នេះ ដោយចាត់ទុកថាជាការបំបិទមាត់អញ្ចេះឬអញ្ចុះ។ ប្រទេសទាំងអស់នៅលើពិភពលោក គឺសុទ្ធតែមានច្បាប់គ្រប់គ្រង។ **យើងមានច្បាប់មួយរួចហើយៗ កំពុងព្រៀងសេចក្តីព្រៀងច្បាប់ពីរផ្សេងទៀត។ ខ្ញុំសូមទាក់ទាញការចាប់អារម្មណ៍ថា ច្បាប់ទាំងអស់ត្រូវមានសង្គតិភាពនឹងគ្នាបំពេញឱ្យគ្នាទៅវិញទៅមក រាប់ទាំងក្រមព្រហ្មទណ្ឌដែលយើងកំពុងតែប្រើប្រាស់ផងដែរ ដើម្បីផ្តន្ទាទោសលើបទល្មើសបច្ចេកវិទ្យាព័ត៌មាន** ...។

២០. កំពុងពិចារណារៀបចំច្បាប់ប្រឆាំងព័ត៌មានក្លែងក្លាយ

ជួបជុំលើកទី៤ ជាមួយអ្នកសារព័ត៌មាន, ១៤ មករា ២០២០

... យើងត្រូវចូលរួមប្រយុទ្ធនឹងព័ត៌មានក្លែងក្លាយ ដោយការបញ្ជូនចេញនូវព័ត៌មានពិត។ ឥឡូវនេះ ពិភពលោកកំពុងខ្វាយខ្វល់ពីព័ត៌មានក្លែងក្លាយ។ នៅក្នុងតំបន់យើង សិង្ហបុរីជាអ្នកបង្កើតច្បាប់ប្រឆាំងនឹងព័ត៌មានក្លែងក្លាយមុនគេ។

ឯយើងមិនទាន់មានទេ។**យើងកំពុងពិនិត្យពិចារណាថាគប្បីធ្វើឬមិនធ្វើ? ប្រហែលជាលទ្ធភាពធ្វើ(ច្បាប់នេះ)ច្រើនជាង។ យ៉ាងណាក៏ដោយ វាកំពុងស្ថិតក្នុងដំណាក់កាលនៃការរៀបចំនិងការពិចារណា។** អ្វីដែលអ្នកសារព័ត៌មានធ្វើបានគឺនៅពេលដែលព័ត៌មានក្លែងក្លាយចេញមក ព័ត៌មានពិតបញ្ចេញទៅវិញភ្លាម ...។

២១. ព័ត៌មានក្លែងក្លាយធ្វើឲ្យសង្គមអស្ថិរភាពនយោបាយ អសន្តិសុខ និងមានអរិភាព

សំណេះសំណាលនិងពិសាអាហារសាមគ្គីនឹងអ្នកសារព័ត៌មានលើកទី៥,
១៤ មករា ២០២៣

... សូមចូលរួមប្រយុទ្ធប្រឆាំងព័ត៌មានមិនពិតនិងព័ត៌មានក្លែងក្លាយ ទាំងក្នុងក្របខណ្ឌជាតិនិងអន្តរជាតិ។ បច្ចុប្បន្ន យើងក៏មានតំណាងសារព័ត៌មាននៅក្នុងក្របខណ្ឌជាតិ/អាស៊ាន ដែលតម្រូវឲ្យស្ថាប័នយើងធ្វើការប្រយុទ្ធប្រឆាំងព័ត៌មានមិនពិតនិងព័ត៌មានក្លែងក្លាយឲ្យកាន់តែសកម្មថែមទៀត។**ព័ត៌មានក្លែងក្លាយនិងមិនពិតជាផ្នែកចិត្តសាស្ត្រ ធ្វើឲ្យសង្គមមានភាពចលាចល មានអស្ថិរភាពនយោបាយ អសន្តិសុខសង្គម និងកើតមានអរិភាពជាមួយបរទេស។** នេះមិនមែនគ្រាន់តែជាបញ្ហាកម្ពុជា (តែក៏ជាបញ្ហា)នៅលើពិភពលោក នៅគ្រប់ទីកន្លែង រាប់ទាំងនៅ(ក្នុង)ការអានសុន្ទរកថានៅក្នុងអង្គការសហប្រជាជាតិ ...។

២២. យកការពិតមកបកស្រាយឲ្យលឿន រហ័សនិងច្បាស់ ប្រឆាំងព័ត៌មានក្លែងក្លាយ

សំណេះសំណាលនិងពិសាអាហារសាមគ្គីនឹងអ្នកសារព័ត៌មានលើកទី៥,
១៤ មករា ២០២៣

ព័ត៌មានក្លែងក្លាយ (មានចរិត)ចិត្តសាស្ត្រអាក្រក់ ... យើងត្រូវប្រយុទ្ធ។ ឥឡូវយើងត្រូវយកអីទៅប្រយុទ្ធ? យកការពិតមកបកស្រាយភ្លាម។ ត្រូវធ្វើឲ្យលឿនធ្វើឲ្យរហ័ស និងធ្វើឲ្យច្បាស់។ មិនអាចទុកឲ្យព័ត៌មានក្លែងក្លាយនេះវាស្ថិតនៅយូរនោះទេ ... ទាក់ទងនឹងផ្នែកណាផ្នែកហ្នឹងត្រូវចេញមកបកស្រាយដើម្បីធ្វើឲ្យសាបព័ត៌មានក្លែងក្លាយនេះ។ មានតែព័ត៌មានពិតទេដែលយកទៅបំបាត់វាបាន។ អ្នកទទួលខុសត្រូវគាមស្ថាប័ននានាត្រូវតែរហ័សរហួន ឧស្សាហ៍មើលព័ត៌មានបើមិនមើលព័ត៌មានធ្វើម៉េចដឹងថាមួយណាពិតមួយណាមិនពិត។ ក្នុងពេលកាន់ការជា

រដ្ឋមន្ត្រី និយាយរួមជាអ្នកដឹកនាំ ត្រូវតែខិតខំមើលសារព័ត៌មាន ... (ករណីមានហេតុការណ៍) យើងសួរបញ្ជាក់ភ្លាម។ តើមានរឿងហ្នឹងមែនឬអត់? ...។

២៣. ផ្តល់មេធាវីការពារក្តីអ្នកសារព័ត៌មានហ៊ានបញ្ចេញការពិត មានភស្តុតាងគ្រប់គ្រាន់

សំណេះសំណាលនិងពិសាអាហារសាមគ្គីនឹងអ្នកសារព័ត៌មានលើកទី៥,
១៤ មករា ២០២៣

*... ខណៈរាជរដ្ឋាភិបាលកំពុងកែទម្រង់រដ្ឋដើម្បីឲ្យមានតម្លាភាព ទាមទារឲ្យអ្នកសារព័ត៌មានបំពេញតួនាទីតាមវិជ្ជាជីវៈ មានសមត្ថភាព និងសិក្សាបញ្ហាដល់ទីជម្រៅហ៊ានបញ្ចេញការពិតមិនភ្លែងបន្លំបំភ្លៃការពិត...***យើងរួមគ្នាប្រយុទ្ធប្រឆាំងនឹងភាពអសកម្ម អំពើពុករលួយ និងភាពអយុត្តិធម៌ក្នុងសង្គម ... ខ្ញុំនឹងផ្តល់មេធាវីការពារជូនអ្នកសារព័ត៌មានដែលហ៊ានបញ្ចេញការពិត ... ខ្ញុំទទួលយកឱ្យមានការការពារក្តីក្នុងអង្គហេតុនិងអង្គច្បាប់សមស្រប** ... តែខ្ញុំមិនទទួលរឿងក្តីណាដែលអ្នកសារព័ត៌មានបំផ្លាញគេ ហើយមកស្នើឲ្យខ្ញុំបញ្ជូន(មេធាវី)ទៅចូលរួមទេ ... **ឯអ្នកសារព័ត៌មានហ៊ានបញ្ចេញការពិតដែលមានភស្តុតាងគ្រប់គ្រាន់ ប្រសិនបើមានរឿងក្តី ខ្ញុំទទួលខុសត្រូវបញ្ជូនមេធាវីការពារក្តីទៅតុលាការ**...។

២៤. "កុំបំពានអ្នកដទៃ កុំបំភ្លៃការពិត" និង "ផ្សព្វផ្សាយព័ត៌មានពិត កុំប្រឌិតកំហុស ..."

សំណេះសំណាលនិងពិសាអាហារសាមគ្គីនឹងអ្នកសារព័ត៌មានលើកទី៥,
១៤ មករា ២០២៣

... ខ្ញុំនឹងមិនបញ្ជូនមេធាវីទៅការពារក្តីសារព័ត៌មានដែលមួលបង្កាច់គេទេ ... **ខ្ញុំបាននិយាយថា "អ្នកសារព័ត៌មាន កុំបំពានអ្នកដទៃ កុំបំភ្លៃការពិត"។ ឥឡូវនេះខ្ញុំក៏គួរតែនិយាយបន្ថែមថា "អ្នកសារព័ត៌មាន គួរផ្សព្វផ្សាយព័ត៌មានដែលពិត កុំប្រឌិតកំហុសជាក់អ្នកដទៃ"**។ នេះជាពាក្យស្លោកពីរ (ដែលជួយក្រើនរំលឹកក្នុងពេលធ្វើសកម្មភាពរបស់ស្ថាប័ននិងអ្នកសារព័ត៌មាន) ... ជួនកាល អាងមាន Facebook ទូរស័ព្ទមួយគ្រឿង ផ្សាយដេរគេដេរឯង តាំងខ្លួនជាចៅក្រមកាត់សេចក្តី ... សូមអ្នកសារព័ត៌មានកុំតាមរកភាពល្បីល្បាញតាមរបៀបដេរ បោកចាន បោកផ្នាំងនោះ ...។

២៥. ការបំពុលព័ត៌មាន មានកម្រិតបំផ្លាញធំជាងគ្រាប់បែក និងអាចបំផ្លាញប្រទេសជាតិ

ជួបជុំលើកទី ៤ ជាមួយអ្នកសារព័ត៌មាន, ១៤ មករា ២០២០

... សូមកោតសរសើរ (សារព័ត៌មាន)ទាំងផ្នែករដ្ឋទាំងឯកជន ដែលបានចូលរួមក្នុងមួយឆ្នាំកន្លងទៅនេះដល់ការរក្សាសន្តិភាព រក្សាស្ថិរភាពនយោបាយ និងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ **ហេតុអ្វីបានជានិយាយពីការផ្សាយព័ត៌មាន ហើយបែរជាមានចំណែកទាក់ទងទៅដល់ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ... (ថាដែល)ទាក់ទងនឹងសារព័ត៌មាន (ពីព្រោះការបំពុលព័ត៌មានមាន)កម្រិតបំផ្លាញធំធេងណាស់ ធំជាងគ្រាប់បែកផ្លោងទៅទៀត ... ព័ត៌មានបំភ្លៃការពិត អាចបំផ្លាញទៅដល់ប្រទេសជាតិមួយ** ...។

២៦. អ្នកសារព័ត៌មាន "កុំដើរតួជាតុលាការ"

ពិសាបាយសាមគ្គីនឹងអ្នកសារព័ត៌មានជាតិ/ក្រសួងព័ត៌មានលើកទី៣,
១១ មករា ២០១៩

... **សូមអ្នកសារព័ត៌មាន មិនថាប្រព័ន្ធណាទេ កុំធ្វើតាំងខ្លួនជាអ្នក "សរុបសន្និដ្ឋាន ហើយបិទផ្លូវគេ" ដែលខ្ញុំថា "កុំដើរតួជាតុលាការ" ... ធ្វើត្រឹមតែប្រាប់ថាព័ត៌មានហ្នឹងកើតអញ្ចេះៗ រួចហើយថាមិនអាចរកការបញ្ជាក់ពីកាគីនោះបានទេ** ... កុំធ្វើជាចៅក្រមកាត់សេចក្តីពេលធ្វើ(សេចក្តីរាយការណ៍)ព័ត៌មាន។ អ្វីដែលវាកើតឡើងពិត យើងត្រូវបញ្ជាក់ ... ក្នុងសម័យនេះ មិនដល់ ៥នាទីទេ រឿងដែលបានកើតឡើង គឺ(នឹងមានមនុស្សជាច្រើនបានដឹងនិង)ផ្តើល មិនមែនដូចសម័យមុនដេកពីរអាទិត្យហើយនៅតែមិនដឹងថាព័ត៌មានទៅដល់ណាទេ ...។

២៧. ស្លាកព័ត៌មាន មិនមែនអភ័យឯកសិទ្ធិការពារ ការប្រព្រឹត្តិអំពើផ្តេសផ្តាសទេ

ពិសាបាយសាមគ្គីជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី១, ១៤ មករា ២០១៧

... ថ្ងៃប្រជុំគណបក្សប្រជាជន អភិបាលស្រុកស្អួលបានលើកសំណូមពរសូមឱ្យឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន (មើល)ពួកអ្នកសារព័ត៌មានដែលជាក់កុងត្រូលយកលុយ ... ខ្ញុំថាគ្មានរឿងអភ័យឯកសិទ្ធិអីទេ។ កុំថាលោកឯងត្រឹមសារព័ត៌មានជាតំណាងរាស្ត្រក៏ដោយ ព្រឹទ្ធសភាក៏ដោយ ទៅធ្វើបទល្មើសជាក់ស្តែង (ត្រូវ)

ចាប់ខ្លួននៅនឹងកន្លែង។ **បណ្តាខេត្តទាំងអស់ បើឃើញអ្នកសារព័ត៌មានជាក់កុងត្រូលជជុះយកលុយ (ត្រូវ)ចាប់ទាំងអស់ ... កុំអាងស្លាកសារព័ត៌មាន។ មិនមែនអភ័យឯកសិទ្ធិការពារខ្លួនប្រព្រឹត្តអំពើផ្តេសផ្តាសទេ** ...។

២៨. ប្រណាំងប្រជែង ដើម្បី"សារព័ត៌មានពិតនិងលឿន" និងបើច្រើនភាសាក៏កាន់តែល្អ

ពិសាបាយសាមគ្គីនឹងអ្នកសារព័ត៌មានជាតិ/ក្រសួងព័ត៌មានលើកទី៣,
១១ មករា ២០១៩

... យល់ស្របនឹងការចង់បានរបស់លោកចាងហ្វាង Thmey Thmey ដែលថា ធ្វើម៉េចឲ្យសារព័ត៌មានយើងចេញជាភាសាបរទេស ... ធ្វើជាវិទ្យុ ធ្វើជាទូរទស្សន៍ ធ្វើមិនទាន់គេទេ។ ត្រូវមានអនឡាញ។ អនឡាញខ្លាំងៗ មានប៉ុន្មាននៅកម្ពុជា? ប្រណាំងប្រជែងគ្នាទៅ។ មាន Fresh News, Swift News, Thmey Thmey និងដើមអំពិល ... ប្រទេសមួយៗ តែងមានសារព័ត៌មានលឿនមួយ។ បារាំងមាន AFP អាមេរិកមាន AP វៀតណាមមាន VNA ចិនមាន Xinhua ជប៉ុនមាន Kyodo ... **សូមប្រកាសបើកយុទ្ធនាការប្រណាំងប្រជែង(ក្នុងវិស័យសារព័ត៌មាន ដើម្បី)ឲ្យក្លាយទៅជា "សារព័ត៌មានដែលមាន(ភាពពិត) និងល្បឿនលឿន។ ព័ត៌មានត្រូវពិតហើយត្រូវលឿន។ បើចេញបានច្រើនភាសាគឺកាន់តែល្អ"** ...។

២៩. ប្រទេសបិតាប្រជាធិបតេយ្យក៏បារម្ភពីឧក្រិដ្ឋកម្មព័ត៌មានវិទ្យានិងព័ត៌មានក្លែងក្លាយ

ពិសាបាយសាមគ្គីនឹងអ្នកសារព័ត៌មានជាតិ/ក្រសួងព័ត៌មានលើកទី៣,
១១ មករា ២០១៩

... ក្នុងសម័យប្រជុំអាស៊ីអឺរ៉ុបនៅប្រ៊ុចសែល ទាំងសម័យប្រជុំពេញអង្គ និងទាំងពេលប្រជុំពេលទទួលទានអាហារថ្ងៃត្រង់ (ឃើញថា)ប្រទេសអឺរ៉ុបភាគច្រើនដែលបានឡើងថ្លែងយោបល់ **មិនមានប្រទេសណាមួយឡើចនិយាយពីឧក្រិដ្ឋកម្មប្រព័ន្ធបច្ចេកវិទ្យានិងព័ត៌មានក្លែងក្លាយទេ ... ក្នុងនោះប្រទេសអឺរ៉ុបខ្លះដែលចាត់ទុកថាជាបិតាប្រជាធិបតេយ្យក៏(ប្រកាសថា)ត្រូវតែមានច្បាប់រារាំង ដាក់ទណ្ឌកម្មលើព័ត៌មានក្លែងក្លាយ និងដាក់ទណ្ឌកម្មលើការរំលោភបំពាននៃបច្ចេកវិទ្យាព័ត៌មាននេះផងដែរ** ...។

៣០. សូមជួយផ្សាយពាណិជ្ជកម្មក្នុងកម្មវិធីព័ត៌មាន

ពីធីជួបជុំលើកទី ៤ ជាមួយអ្នកសារព័ត៌មាន, ១៤ មករា ២០២០

... សូមអំពាវនាវវិស័យឯកជន ដែលត្រូវការផ្សព្វផ្សាយពាណិជ្ជកម្មផ្តល់អាទិភាពមួយចំណែកទៅបណ្តាញទូរទស្សន៍ឬវិទ្យុ ដែលធ្វើកម្មវិធីផ្សាយព័ត៌មានផងត្បិតកន្លងមកយើញថា ច្រើនតែផ្សាយពាណិជ្ជកម្មក្នុងកម្មវិធីកម្សាន្ត និងខ្សែភាពយន្ត ... សង្ឃឹមថា យើងនឹងមានតុល្យភាពការផ្សាយពាណិជ្ជកម្មរវាងកម្មវិធីព័ត៌មាននិងកម្មវិធីកម្សាន្តសប្បាយ ... ការផ្សាយព័ត៌មាននេះ មានសារសំខាន់ពិសេសរបស់វា ព្រោះផ្តល់ព័ត៌មានដល់សាធារណជន ក៏ដូចជាការអប់រំចំពោះប្រជាជនរបស់យើង ...។

១៦. មហាផ្ទៃ

១	ប្រធានក្រុមប្រឹក្សា/អភិបាលក្រុង/ខេត្ត នៅជាមួយគ្នាលើការតែងតាំងមន្ត្រី	២៦៩
២	អភិបាលរាជធានីខេត្តកុំអវត្តមានក្នុងសម័យប្រជុំក្រុមប្រឹក្សាអភិបាលរាជធានីខេត្ត	២៦៩
៣	សូមអ្នកបន្តជនកុំរៀបចំឱ្យក្រសួងមហាផ្ទៃ និងនគរបាលនៅដាច់ឡែកគ្នា	២៦៩
៤	ដំណើរការប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សមិនចាប់ផ្តើក្នុងសង្គ្រាមទេ	២៧០
៥	បាត់ដំបង និងប៉ៃលិន ស្រាយក្រៅព្រំប្រទល់រដ្ឋបាលខេត្តឱ្យស្រេច	២៧០
៦	សូមមន្ត្រីថ្នាក់ជាតិកុំទៅដណ្តើមកន្លែងមន្ត្រីថ្នាក់មូលដ្ឋាន	២៧១
៧	ស្ថាប័នពាក់ព័ន្ធពិចារណានីតិវិធីឱ្យបងប្អូននៅក្រៅប្រទេសមានអត្តសញ្ញាណប័ណ្ណ	២៧១
៨	រៀបចំឲ្យមានមន្ត្រីជនជាតិភាគតិចនៅតំបន់ឦសាន និងនៅខេត្តកោះកុង	២៧២
៩	រៀបចំតំណាងឥស្លាមក្នុងថ្នាក់ដឹកនាំនៃសហគមន៍ដែលមានខ្មែរឥស្លាមច្រើន	២៧២
១០	ក្នុងការរៀបចំមន្ត្រីបន្តជន កុំសួរពីអាយុ សំខាន់មានសមត្ថភាពបំពេញមុខនាទី	២៧៣
១១	ចាស់មានពិសោធន៍ ក្មេងមានចំណេះដឹង	២៧៣
១២	បំបែកខេត្តកំពង់ចាមនិងត្បូងឃ្មុំ ដូចពីអតីតកាល និងងាយគ្រប់គ្រងរដ្ឋបាល	២៧៤
១៣	អ្នកឈរឈ្មោះធ្វើជាមេឃុំ/ចៅសង្កាត់ ត្រូវមានសញ្ញាបត្រឧត្តមសិក្សា	២៧៤
១៤	ប្រឈមកូវីដ១៩ ឆ្នាំ២០២០ រដ្ឋាភិបាលកាត់បន្ថយចំណាយ ៩១៨លានដុល្លារ	២៧៥
១៥	ជោគជ័យលើកូវីដ១៩ គឺជោគជ័យនៃការបែងចែកមុខងារផ្នែកអំណាចទៅមូលដ្ឋាន	២៧៥
១៦	ថ្នាក់ជាតិផ្តល់មធ្យោបាយ និងសិទ្ធិអំណាច ឯថ្នាក់មូលដ្ឋានចាត់ចែង	២៧៦
១៧	បើធ្វើតាមរដ្ឋបាលឆ្នាំកម្ពុជា ការកែទំរង់ប្រជាធិបតេយ្យថ្នាក់ក្រោមជាតិដើរលឿន	២៧៦
១៨	មន្ត្រីថ្នាក់កណ្តាលចុះមូលដ្ឋាន មិនបានធ្វើឱ្យមូលដ្ឋានបាត់ការទទួលខុសត្រូវ	២៧៧
១៩	កិច្ចព្រមព្រៀងទីក្រុងប៉ារីស តម្រូវឱ្យមានក្រសួងសន្តិសុខ	២៧៧
២០	ឆ្នាំ១៩៩២ បំបែកជាសន្តិសុខនិងមហាផ្ទៃ តបតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស	២៧៨
២១	ក្រោយបោះឆ្នោត១៩៩៣ ក្រសួងសន្តិសុខនិងមហាផ្ទៃត្រូវបានបញ្ចូលគ្នាជាថ្មី	២៧៨
២២	មិនបំបែកនគរបាលជាតិចេញពីការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃជាការត្រឹមត្រូវ	២៧៩
២៣	មហាផ្ទៃជាភ្នែកឆ្អឹងឯកភាពដឹកនាំប្រតិបត្តិការការពារសន្តិសុខផ្ទៃក្នុងកំណែទម្រង់រដ្ឋបាល	២៧៩
២៤	ព្រំសីមា/ព្រំដែនអាចជាទីតាំងលាក់ខ្លួន រត់ពន្ធគ្រឿងញៀនឬទំនិញខុសច្បាប់	២៨០
២៥	អនុវត្តនយោបាយភូមិឃុំមានសុវត្ថិភាពមិនចាំនាយការដ្ឋមន្ត្រី/រដ្ឋមន្ត្រីមហាផ្ទៃស្រែក	២៨១

២៦	ព្រមគ្នារាំងស្កាត់ល្បែងស៊ីសង អំពើទុច្ចរិត ដែលនឹងនាំដល់ការជួញដូរមនុស្ស	២៨១
២៧	ចូលរួមនិងរាយការណ៍ឱ្យសមត្ថកិច្ច កុំឱ្យកម្ពុជាក្លាយជាឋានសួគ៌នៃឧក្រិដ្ឋកម្ម	២៨២
២៨	កុំឲ្យកម្ពុជាក្លាយជាជម្រកការពារការ ប្រើប្រាស់ទឹកដីវាយគោលដៅប្រទេសដទៃ	២៨២
២៩	មិនមានអាវុធហ្វូរចូលដោយគ្មានច្បាប់ទម្លាប់ និងក្លាយជាអាវុធនៃឧក្រិដ្ឋជន	២៨៣
៣០	បោះឆ្នោតសកល២០២៣ ជាការប្រកួតរវាងគាំទ្រនិងបំផ្លាញប្រជាធិបតេយ្យ	២៨៣
៣១	តើ៦៥ប្រទេស/សញ្ជាតិប្រកាសពីភាពត្រឹមត្រូវនៃការបោះឆ្នោតនៅកម្ពុជាជាអ្វី?	២៨៤
៣២	«ប្រជាធិបតេយ្យនៅកម្ពុជាបានឈ្នះហើយ»	២៨៤
៣៣	ប្រជាធិបតេយ្យឬមិនប្រជាធិតេយ្យ អាស្រ័យលើអ្នកទៅ ឬមិនទៅបោះឆ្នោត	២៨៥
៣៤	លែងជានាយករដ្ឋមន្ត្រី ក៏បន្តគ្រប់គ្រងនយោបាយក្នុងឋានៈជាប្រធានគណបក្ស	២៨៥
៣៥	មិនមានរដ្ឋធម្មនុញ្ញឬច្បាប់កំណត់ឲ្យរដ្ឋាភិបាលទៅពិគ្រោះនឹងសង្គមស៊ីវិលទេ	២៨៦
៣៦	ជនក្បត់ជាតិ ៣ជំនាន់ ចុះហត្ថលេខាសន្យាផ្តល់ដីដល់រដ្ឋ Degar	២៨៦
៣៧	កុកស ងាប់ តែកិច្ចព្រមព្រៀងរវាងជនក្បត់ជាតិ ៣ជំនាន់ និងDegar ងាប់ឬទេ	២៨៧
៣៨	មនុស្សចិត្តធ្ងន់ក្នុងការសម្រេចចិត្តខាងនយោបាយទាក់ទងនឹងជីវិតជាតិ	២៨៧
៣៩	គណបក្សប្រជាជនមានយុវជនរាប់រយរាប់ពាន់នាក់បន្តវេនតាមថ្នាក់	២៨៨
៤០	ការបញ្ជូនមន្ត្រីចុះមូលដ្ឋានត្រូវបានអនុវត្តតាំងពីឆ្នាំ១៩៨២	២៨៨
៤១	គណបក្សប្រជាជនមានផែនទីចង្អុលផ្លូវ មិនដែលបាត់ម្ចាស់ការម្តងណាទេ	២៨៩
៤២	មានផែនទីចង្អុលផ្លូវហដ្ឋារចនាសម្ព័ន្ធ អ្វីដែលត្រូវធ្វើគឺកែតម្រូវតាមសភាពការណ៍	២៨៩
៤៣	ទៅខ្សែក្រៀម ទៅតុចរចាគ្រប់កន្លែង និងនៅវាលស្រែជាមួយកសិករ	២៩០
៤៤	ស្រុកស្ទឹងត្រង់ផលិតនាយករដ្ឋមន្ត្រី៣ ដែលនាយករដ្ឋមន្ត្រីពីរប្រឆាំងរាជានិយម	២៩០
៤៥	នាយករដ្ឋមន្ត្រី ហ៊ុន សែន ដឹកនាំបានយូរ ព្រោះមិនក្បត់ព្រះមហាក្សត្រ	២៩១
៤៦	ពី ៨មករា ១៩៧៩ ដល់ថ្ងៃ ១៣កុម្ភៈ ២០១៨ នៅក្នុងរដ្ឋាភិបាលមិនដាច់រយៈ	២៩១
៤៧	សមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវប្រជាធិបតេយ្យប្រមូលផ្តុំ ភាគតិចគោរព...	២៩២
៤៨	ប្រជាធិបតេយ្យប្រមូលផ្តុំ គឺប្រមូលផ្តុំធ្វើតាមការសម្រេចរបស់សម្លេងភាគច្រើន	២៩២
៤៩	សមូហភាពដឹកនាំតាមកម្មវិធីនយោបាយ បុគ្គលទទួលខុសត្រូវចំពោះសកម្មភាព	២៩៣
៥០	កុំរង់ចាំដល់សង្គ្រាមកើតឡើង ទើបស្វែងរកនិងស្រែកថាសន្តិភាពមានតម្លៃ	២៩៣
៥១	ការផ្លាស់ប្តូរក្រៅរបៀបប្រជាធិបតេយ្យ មិនជាការចាំកចម្រើន តែនាំមកនូវសង្គ្រាម	២៩៤
៥២	រូបមន្តប្រព័ន្ធសមាមាត្រតាមខេត្ត ស្នើឡើងដោយរដ្ឋកម្ពុជា	២៩៤
៥៣	មនោគមវិជ្ជាគ្រប់គ្រងប្រទេសមួយ មិនប្រាកដថាអនុវត្តបានក្នុងប្រទេសមួយទៀត	២៩៥
៥៤	ជនរងគ្រោះនៃប្រល័យពូជសាសន៍ ឃ្លែជាទទួលទណ្ឌកម្មពីប្រទេសប្រជាធិបតេយ្យ	២៩៥
៥៥	គណបក្សប្រជាជនរួមសុខរួមទុក្ខ និងតែងមានវត្តមានពេលប្រជាជនជួបការលំបាក	២៩៦
៥៦	ផែនទីព្រំដែនមិនកែប្រែបន្សល់ទុកពីអាណានិគមបារាំងនិងមានថែងក្នុងរដ្ឋធម្មនុញ្ញ	២៩៦
៥៧	ជម្រើសដោះដូរទឹកដី ដោយរៀបចំខ្សែព្រំដែនថ្មី	២៩៧
៥៨	កុំញុះញង់ឱ្យមានចម្បាំងជាមួយប្រទេសជិតខាងរឿងព្រំដែន	២៩៧
៥៩	ប្រគល់ផែនទី១/២៥000 ដល់ខេត្តនិងកងទ័ព តាមព្រំដែនជាមួយវៀតណាម	២៩៨
៦០	ព្រំដែនមិននៅលើមាត់ តែនៅលើការចាចរាងប្រទេស ធានាដោយច្បាប់អន្តរជាតិ	២៩៨
៦១	ពង្រឹងការអនុវត្តច្បាប់ចាចណ៉ ដាក់ចេញវិធានការនានារួមទាំងវិសោធនកម្មច្បាប់	២៩៩
៦២	ពិចារណាវិធានការផាកពិន័យជាលំដាប់ រហូតដល់ដកសិទ្ធិបើកបរ	២៩៩
៦៣	ការកាត់សិទ្ធិបើកបរមិនមែនជាទណ្ឌកម្ម តែការពារជីវិតអ្នកបើកបរទៅវិញទេ	៣00
៦៤	មិនត្រូវសាទរកំណើនតួលេខអ្នកទទួលបានការពិនិត្យព្យាបាលគ្រឿងញៀន	៣00
៦៥	ធ្វើរឿងគ្រឿងញៀនឱ្យហ្មត់ចត់ ... មិនមែនជាសារព្រមានទៅកាន់តុលាការទេ	៣01
៦៦	មិនផលិតតែក្លាយជាកន្លែងចែកចាយនិងប្រើប្រាស់គ្រឿងញៀន	៣01
៦៧	កម្ពុជាអាចក្លាយជាកន្លែងសុវត្ថិភាពសម្រាប់ឧក្រិដ្ឋជនធ្វើសកម្មភាព	៣01
៦៨	ជនរងគ្រោះខ្លះលុះតាមការលួងលោមថាជាថ្នាំព្យាបាលជំងឺ ឬលើកកម្លាំង	៣02
៦៩	គ្រឿងញៀនជះឥទ្ធិពលអាក្រក់លើសន្តិសុខសណ្តាប់ធ្នាប់ ការអភិវឌ្ឍសង្គម	៣02
៧0	អ្នកប្រើប្រាស់គ្រឿងញៀន គឺជាជនរងគ្រោះ	៣03
៧1	គ្រឿងញៀន ល្បែងស៊ីសង ជួញដូរមនុស្ស ហិង្សា កើតនៅនឹងមូលដ្ឋាន	៣03
៧2	ត្រងត្រាប់មតិប្រជាពលរដ្ឋ ធានាសុវត្ថិភាព និងអនុវត្តកិច្ចការបានជោគជ័យ	៣03
៧3	ធ្វើកិច្ចការភូមិឃុំមានសុវត្ថិភាព ដើម្បីធានាសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម	៣04
៧4	សូមទូរទស្សន៍រត់អក្សរថា ប្រើប្រាស់គ្រឿងញៀនគឺបំផ្លាញអាយុជីវិតខ្លួនឯង	៣04
៧5	សំណូមពរដាក់ឃ្លាអប់រំពីបញ្ហាគ្រឿងញៀននៅលើផលិតផលប្រើប្រាស់នានា	៣05
៧6	ព្រះសង្ឃក៏អាចជួយអប់រំពីបញ្ហាគ្រឿងញៀនបានដែរ	៣05
៧7	ពិធីករ/ការនី សិល្បករ/ការនី ជួយផ្សព្វផ្សាយ ប្រឆាំងគ្រឿងញៀន	៣05
៧8	"គ្រប់គ្នាថាទេ ចំពោះគ្រឿងញៀន"	៣06
៧9	កម្ពុជាត្រូវបានយកជាចំណុចចេញដំណើរនៃការរត់ពន្ធមនុស្សទៅអូស្ត្រាលី	៣06

៨០	ការជួញដូរមនុស្ស/កេងប្រវ័ញ្ច កើតពេលប្រជាពលរដ្ឋទទួលបានទីផ្សារការងារ	៣០៦
៨១	ការរៀសខ្លួនពីប្រទេសមួយទៅប្រទេសមួយ ជាប្រយោជន៍សម្រាប់ពួកទុច្ចរិត	៣០៧
៨២	សង្គ្រាមនិងការបោកប្រាស់ ... ធ្វើឱ្យពលរដ្ឋកម្ពុជារៀសខ្លួនទៅក្រៅប្រទេស	៣០៧
៨៣	ប្រជាពលរដ្ឋខ្លះចាញ់បោកមេក្លោងជួញដូរមនុស្ស ... ទៅធ្វើការក្រៅប្រទេស	៣០៨
៨៤	ប្រជាពលរដ្ឋខ្លះក្លាយជាអ្នកបន្តស្នាក់នៅខុសច្បាប់នៅប្រទេសក្រៅ	៣០៨
៨៥	ពីប្រភពនៃការជួញដូរ កម្ពុជាក្លាយជាគោលដៅនៃការជួញដូរ	៣០៩
៨៦	គណៈប្រតិភូទៅបរទេស គប្បីបង្ការករណីមនុស្សទៅមិនវិលចូលប្រទេសវិញ	៣០៩
៨៧	កុំឲ្យកម្ពុជាក្លាយជាឋានសួគ៌នៃឧក្រិដ្ឋកម្ម កន្លែងលាងលុយ ជួញដូរមនុស្ស	៣១០
៨៨	ថ្ងៃ២០ សីហា រៀងរាល់ឆ្នាំ ជាទិវាអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស	៣១០
៨៩	គ្រប់តួអង្គពាក់ព័ន្ធ ... ពិនិត្យករណីជនបរទេសរស់នៅស្រុប ឬមិនស្របច្បាប់	៣១០
៩០	សូមគ្រប់សាសនានៅកម្ពុជាចូលរួមប្រឆាំងនឹងការជួញដូរមនុស្ស	៣១១
៩១	បំបាត់ល្បែងស៊ីសងនិងជួញដូរគ្រឿងញៀនជាធាតុផ្សំទប់ស្កាត់ការជួញដូរមនុស្ស	៣១១
៩២	ពង្រឹងសមត្ថភាពកម្លាំង/ច្បាប់ ប្រឆាំងការជួញដូរគ្រឿងញៀន/មនុស្ស/ការរកម្ម	៣១២
៩៣	ទាមទារតាក់តែងច្បាប់បទដ្ឋាន ស្របតាមច្បាប់បទដ្ឋានអន្តរជាតិ	៣១២

១. ប្រធានក្រុមប្រឹក្សា(ក្រុង/ខេត្ត)និងអភិបាល(ក្រុង/ខេត្ត)នៅជាមួយគ្នាលើការតែងតាំងមន្ត្រី

បិទសន្និបាតត្រួតពិនិត្យលទ្ធផលការងារ២០១៩ និងលើកទិសដៅការងារ២០២០
ក្រសួងមហាផ្ទៃ, ២០ កុម្ភៈ ២០២០

... ពង្រឹងប្រសិទ្ធភាពនៃការធ្វើការងារ ជាពិសេសការតែងតាំងមន្ត្រី។ ការតែងតាំងមន្ត្រីចាំបាច់ត្រូវតែពិភាក្សាគ្នា។ ខេត្តកណ្តាល ម៉ៅ ការុណ ចូលនិវត្តន៍។ ឯណាអភិបាលខេត្តថ្មី។ មិនមានអ្នកណាគិតថាលោកឯងឡើងជាចៅហ្វាយខេត្ត ទេ ... មន្ត្រីឡេមឡឺមតែងតែរត់ទៅកៀកកន្លែងមានសិទ្ធិតែងតាំង ... **វិធីតែមួយគត់គឺប្រធានក្រុមប្រឹក្សានិងអភិបាលនៅជាមួយគ្នាលើការតែងតាំងមន្ត្រី។ របៀបហ្នឹងទើបមិនមានការបែងចែក។ កម្លាំងទៅប្រមូលផ្តុំ។ មិនមានមន្ត្រីឡេមឡឺម ... ដោយចៅហ្វាយខេត្តមានសិទ្ធិស៊ីញ្ញែតែងតាំង ឯប្រធានក្រុមប្រឹក្សាមិនមានសិទ្ធិ ... មន្ត្រីឡេមឡឺមក៏ទៅ(អែបអប)តែនឹងអភិបាល។ ស៊ីញ្ញែជាក់ពេញទឹកពេញដី** ...។

២. សូមអភិបាលរាជធានីខេត្ត កុំអវត្តមានក្នុងសម័យប្រជុំក្រុមប្រឹក្សាភិបាលរាជធានីខេត្ត

បិទសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារ២០២០
ក្រសួងមហាផ្ទៃ, ២០ កុម្ភៈ ២០២០

... ពេលនេះ កំពុងតែផ្ទេរការងារពីថ្នាក់ជាតិទៅឱ្យថ្នាក់ក្រោមជាតិ។ ទំហំកាន់តែធំហើយ។ ការទទួលខុសត្រូវរបស់មូលដ្ឋានកាន់តែធំជាងមុន ... (ក្រសួងគ្រប់គ្រងដែនដី នគរូបនីយ៍កម្ម និងសំណង់បានផ្ទេរ)មុខងារ៨ ឱ្យមូលដ្ឋានទទួលខុសត្រូវ ដូចជាថ្នាក់ស្រុក(ទទួលផ្តល់ការសម្រេច)សាងសង់ប៉ុន្មានម៉ែត្រការ៉ែ ថ្នាក់ខេត្តប៉ុន្មានម៉ែត្រការ៉ែ និងមុខងារដទៃទៀត ... **(ដូចនេះ)សូមអភិបាលខេត្តរាជធានីកុំអវត្តមានក្នុងសម័យប្រជុំក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត/រាជធានី ... បើបើអភិបាលខេត្ត ឬអភិបាលរាជធានី មិនចូលរួមប្រជុំក្រុមប្រឹក្សា ៣ដងជាប់គ្នាដោយគ្មានមូលហេតុ សូមរាយការណ៍មកខ្ញុំៗ នឹងដកចេញពីតំណែង** ...។

៣. សូមអ្នកបន្តវេនកុំរៀបចំឱ្យក្រសួងមហាផ្ទៃនិងនគរបាលនៅដាច់ឡែកគ្នា

ប្រគល់សញ្ញាបត្រនិងវិញ្ញាបនបត្រដល់និស្សិត និងសិក្ខាកាម
នៃបណ្ឌិត្យសភានគរបាលកម្ពុជា, ៥ សីហា ២០១៩

... រឿងមួយដែលខ្ញុំគួរតែផ្តាំ មិនថាថ្ងៃនេះឬថ្ងៃស្អែក ឆ្នាំនេះឬឆ្នាំក្រោយ **អ្នកបន្តវេនគួរការក្សាទុកក្បាលម៉ាស៊ីនក្រសួងមហាផ្ទៃ(ដូចបច្ចុប្បន្ន គឺទុក)នគរបាលឱ្យនៅក្នុងមហាផ្ទៃ។ យោងតាមបទពិសោធន៍ជោគជ័យរបស់យើង បើសិនជា(ផ្តាច់ចេញពីគ្នា) ខ្ញុំគិតថា(វានឹងកើតភាព)រញ៉ើរញ៉ៃ។ សូមកុំរៀបចំឱ្យមានមហាផ្ទៃមួយនិងនគរបាលមួយដោយឡែក។ សូមទុកបែបនេះ។ ហ្នឹងជាវិធីដ៏ល្អបំផុតយោងទៅលើបទពិសោធន៍ដែលយើងធ្លាប់មានក្នុងការគ្រប់គ្រងរដ្ឋ នារយៈពេលកន្លងទៅ** ... យើងមិនទាន់បានអនុវត្តពេញលេញនៅឡើយទេ មិនថាតែក្រសួងមហាផ្ទៃទេ ក្រសួងយុត្តិធម៌ ឬក្រសួងការពារជាតិ ...។

៤. ដំណើរការប្រជាធិបតេយ្យ និងការពារពសិទ្ធិមនុស្ស មិនចាប់ផ្តៃក្នុងសង្គ្រាមទេ

ចែកសញ្ញាបត្រជូននិស្សិត នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២២ ឧសភា ២០១៨

... **ប្រជាធិបតេយ្យនិងសិទ្ធិមនុស្សមិនដែលចាប់ផ្តៃនៅក្នុងប្រទេសដែលមានសង្គ្រាមទេ? សូមមើលទៅ(ករណីរបប) លន់ នល់ ដែលមានការគាំទ្រពីបរទេស សួរថាតើ លន់ នល់ អាចអនុវត្តការគោរពសិទ្ធិមនុស្សដែលមានពីបរទេសបានឬមិនបានទេ? អាចអនុវត្តដំណើរការប្រជាធិបតេយ្យបានឬមិនបានទេ? ថាមិនបានទេ។** នោះគឺជាប្រទេសបិតាប្រជាធិបតេយ្យដែលមកគាំទ្ររបប លន់ នល់ នៅទីក្រុងភ្នំពេញ ... មើលក្នុងតំបន់ តើដំណើរការប្រជាធិបតេយ្យនិងសិទ្ធិមនុស្សនៅនៅអ៊ីរ៉ាក់, លីប៊ី, ស៊ីរី, យេមែន និងប្រទេសមានសង្គ្រាមដទៃទៀត ដូចជាស៊ូដង់ ... ម៉ាលី, អាហ្វ្រិកកណ្តាល ជាដើម ... របៀបម៉េច? ...។

៥. បាត់ដំបងនិងប៉ៃលិនស្រាយត្រូវព្រំប្រទល់រដ្ឋបាលខេត្តឱ្យស្រេច

ប្រគល់សញ្ញាបត្រជូននិស្សិតជ័យលាភី នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង,
១៧ តុលា ២០២២

... ខ្ញុំនិយាយតាមទូរស័ព្ទជាមួយ**អភិបាលខេត្តបាត់ដំបងនិង(អភិបាលខេត្ត)ប៉ៃលិនថា សូមដោះស្រាយឱ្យចប់។ គ្រាន់តែកែសម្រួលព្រំប្រទល់រដ្ឋបាល ធ្វើប៉ុន្មានជំនាន់ហើយធ្វើអត់ចេញ? ខ្ញុំបានផ្ញើសារទៅ សុខ លូ ថាបើសិនជា**

២អាទិត្យទៀតធ្វើមិនចេញ ខ្ញុំចុះទៅ(ធ្វើ)តែម្តង។ វាមិនមែនកាត់ដីឱ្យបរទេសឯណា? ភូមិហ្នឹងជាភូមិបងប្អូនធ្វើសមាហរណកម្ម។ ដល់ចេញ(ពីសង្គ្រាមស៊ីវិល)មកអ្នកមួយចំនួនបានទៅបោះ(ឆ្នោត)នៅប៉ៃលិន ឯមួយចំនួន (ទៀតបានបោះឆ្នោត)នៅបាត់ដំបង។ បាត់ដំបងដីវាធំ ... ខ្ញុំ voiced សំឡេងទៅឱ្យ ... ខាង(បាត់ដំបងឯ)នេះក៏មិនចេញកម្មសិទ្ធិឱ្យ។ ខាង(ប៉ៃលិនឯ)នោះក៏មិនចេញកម្មសិទ្ធិឱ្យ ... **សូមចៅហ្វាយខេត្ត/ស្រុកដែលពាក់ព័ន្ធស្តាប់ឱ្យបាន ខ្ញុំនិយាយខាងផ្នែករដ្ឋបាល។ ឯចំពោះឃុំគឺការបោះឆ្នោត។ អញ្ចឹងកែសម្រួលព្រំប្រទល់រដ្ឋបាលឱ្យគាត់បានកម្មសិទ្ធិទៅ** ...។

៦. សូមមន្ត្រីថ្នាក់ជាតិកុំទៅដណ្តើមកន្លែងមន្ត្រីថ្នាក់មូលដ្ឋាន

បិទសន្និបាតត្រួតពិនិត្យលទ្ធផលការងារ២០១៩ និងលើកទិសដៅការងារ២០២០
ក្រសួងមហាផ្ទៃ, ២០ កុម្ភៈ ២០២០

... ខ្ញុំនៅតែទទូចថា **មិនឱ្យបោះមន្ត្រីថ្នាក់ជាតិទៅដណ្តើមកន្លែងមន្ត្រីថ្នាក់មូលដ្ឋាន។ កុំឱ្យបោះពីលើ។ ទុកឱកាសឱ្យខាងមូលដ្ឋានរៀបចំមន្ត្រីរបស់គេ**។ បើមិនអញ្ចឹងទេ ណា(មួយ)យកផ្តាយពាក់ពេញស្មា រួចបន្ទាប់ទៅចង់ទៅធ្វើអភិបាលស្រុក ចង់ទៅធ្វើអភិបាលខេត្ត ចង់ទៅធ្វើអភិបាលរងខេត្ត ... ខ្ញុំនៅតែរំលឹក។ ដាក់ព្រឹបយកមន្ត្រីយោធាពីខាងលើមកធ្វើអភិបាលរង ... ថ្ងៃមុនខ្ញុំឱ្យសួរថាម្នាក់ហ្នឹងនៅឯណា? ព្រោះគ្រាន់តែដាក់ពាក្យថាមន្ត្រីជាន់ខ្ពស់នៅក្រសួងមហាផ្ទៃ។ ខ្ញុំស្នើដាក់ឱ្យចំមកថាបច្ចុប្បន្នជាអភិបាលរងស្រុកនេះ សុំដំឡើង(ទៅថ្នាក់នោះ) ... បើមិនអញ្ចឹងខ្ញុំអត់ស៊ីញ្ជេទេ ...។

៧. ស្តាប់ពាក់ព័ន្ធពិចារណានីតិវិធីឱ្យបងប្អូននៅក្រៅប្រទេសមានអត្តសញ្ញាណប័ណ្ណ

សំណេះសំណាលជាមួយសហគមន៍ខ្មែរនៅសហរដ្ឋអាមេរិក/កាណាដា ប្រមាណ២
ពាន់នាក់ នៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី សហរដ្ឋអាមេរិក, ១២ ឧសភា ២០២២

...ខ្ញុំក្តាប់បាននូវរឿងមួយដែលឯកឧត្តមប្រាក់ សុខុន ត្រូវនាំយកបញ្ហានេះទៅពិភាក្សាជាមួយក្រសួងមហាផ្ទៃ។ នោះគឺការសម្រួលទិដ្ឋាការ។ យើងបានដោះស្រាយហើយ។ បងប្អូនយើងអត់ត្រូវបង់ថ្លៃ Visa ទេ។ យើងបោះត្រាជូនបងប្អូន។

ស្រុកគេ ១០ឆ្នាំ ដូរ Passport ម្តង។ អញ្ចឹង ពេលដូរ(លិខិតឆ្លងដែន) សូមមកស្ថានទូតដើម្បីបោះត្រា។ មានរឿងមួយគួរឱ្យចាប់អារម្មណ៍ ត្រូវដោះស្រាយរវាងក្រសួងការបរទេសនិងក្រសួងមហាផ្ទៃ។ **ក្រសួងការបរទេសមានផ្នែកកុងស៊ុល ក្រសួងមហាផ្ទៃមានផ្នែកអន្តោប្រវេសន៍និងអត្តសញ្ញាណកម្ម ... បងប្អូនដែលមកទីនេះ ខ្លះមិនមានសញ្ជាតិខ្មែរទេ ព្រោះមក(នៅក្រៅប្រទេស)តាំងពីតូច ឬក៏មិនមានឈ្មោះក្នុងបញ្ជីក្នុងស្រុក។ ត្រូវធ្វើឱ្យបងប្អូនអាចមានអត្តសញ្ញាណប័ណ្ណ** ...។

៨. រៀបចំឲ្យមានមន្ត្រីជនជាតិភាគតិចនៅតំបន់ឦសាននិងនៅខេត្តកោះកុង

បិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារ២០២២ ក្រសួងមហាផ្ទៃ, ២៣ កុម្ភៈ២០២២

... ទាក់ទិនជាមួយ**កម្មវិធីជាតិកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ សូមយកឱកាសនេះនិយាយទៅកាន់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ក៏ដូចជាអភិបាលខេត្តរាជធានីអំពីការតែងតាំងមន្ត្រី។ កន្លងទៅ យើងបានខិតខំរៀបចំឲ្យមានមន្ត្រីជនជាតិភាគតិចនៅតំបន់ឦសាននិងនៅខេត្តកោះកុង**។ពីមុននោះ យើងបានបញ្ជូនមន្ត្រីជាច្រើនជាជនជាតិខ្មែរឡើងទៅកាន់កិច្ចការសំខាន់ៗ នៅភូមិភាគឦសាន។ ប៉ុន្តែ ក្រោយមក **យើងក៏បានរៀបចំបណ្តុះបណ្តាលឲ្យមន្ត្រី(ក្នុងមូលដ្ឋាន) ឱ្យទទួលខុសត្រូវការងារទីនោះ ហើយយើងធ្វើការងារនេះប្រកបដោយជោគជ័យ**...។

៩. រៀបចំឱ្យមានតំណាងឥស្លាមក្នុងថ្នាក់ដឹកនាំនៃសហគមន៍ដែលមានខ្មែរឥស្លាមច្រើន

បិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារ២០២២ ក្រសួងមហាផ្ទៃ, ២៣ កុម្ភៈ២០២២

... ខ្ញុំ**ស្នើឲ្យបណ្តាខេត្តដែលមានបងប្អូនឥស្លាមរស់នៅ យកចិត្តទុកដាក់រៀបចំដើម្បីហោចណាស់មានអភិបាលរងម្នាក់ និងឬបើអាចធ្វើទៅបាន កាន់តំណែងអភិបាលស្រុកឬខណ្ឌ ក្នុងខេត្តដែលមានប្រជាជន(ឥស្លាម)ច្រើន** ... ពេលដែលយើងផ្ទេរការងារពីថ្នាក់ជាតិទៅឲ្យថ្នាក់ក្រោមជាតិ កិច្ចការថ្នាក់ក្រោមជាតិកាន់តែច្រើន។ ដូច្នេះហើយ គណៈអចិន្ត្រៃយ៍បានសម្រេចប្រគល់ភារកិច្ចជូន សម្តេចក្រឡាហោម ធ្វើវិសោធនកម្មច្បាប់បង្កើនចំនួនអាសនៈសម្រាប់គណៈអភិបាល

ខេត្តរាជធានី គណៈអភិបាលស្រុក/ខណ្ឌ/ក្រុង ... ដូចនេះ សូមស្នើថាស្រុកដែលមានបងប្អូនឥស្លាមរស់នៅច្រើន **គប្បីមានអភិបាលរងម្នាក់ក្នុងស្រុក/ខណ្ឌនោះ ដើម្បីសម្រួលទំនាក់ទំនងក្នុងសហគមន៍ ដែលវាជាផ្នែកមួយនៃសុខដុមភាវូបនីយកម្មក្នុងចំណោមជាតិសាសន៍ ... នេះមិនមែនជាកូតាដែលថាត្រូវតែជាក់ឥស្លាមទេ** ក៏ប៉ុន្តែនេះជាគោលនយោបាយដែលយើងត្រូវយកចិត្តទុកដាក់ ...។

១០. ក្នុងការរៀបចំមន្ត្រីបន្តវេន កុំសូរពីអាយុ សំខាន់មានសមត្ថភាពបំពេញមុខនាទី

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៥១ ចាប់ពីឧដុង្គ/ផ្លូវជាតិលេខ៥ ដល់ថ្នល់ទទឹង/ផ្លូវជាតិលេខ៤, ២៥ មីនា ២០២២

... កាល(ពីពេល)ដែលខ្ញុំធ្វើរដ្ឋមន្ត្រីដំបូងនៅអាយុ ២៧ឆ្នាំ ក៏មានរដ្ឋមន្ត្រីដែលមានវ័យចាស់ជាង(ខ្ញុំ) ... ហៅខ្ញុំថាជារដ្ឋមន្ត្រីដែលមិនទាន់បាត់ធុំក្លិនទឹកដោះគោ ... ក្រោយមក រដ្ឋមន្ត្រីទាំងនោះបានក្លាយជាអ្នកបោះឆ្នោតគាំទ្រខ្ញុំឱ្យធ្វើនាយករដ្ឋមន្ត្រី ក្រោយពីបានឃើញសមត្ថភាពតាមរយៈសកម្មភាពក្នុងក្របខណ្ឌជាយុវជន។ ចាប់ពីពេលនោះ ខ្ញុំថា **ពេលដែលចាត់តាំងមនុស្ស(ឲ្យកាន់មុខតំណែងឬការទទួលខុសត្រូវ) មិនចាំបាច់សួរថាឈ្មោះអី អាយុប៉ុន្មានទេ ហើយកុំនិយាយថានៅក្មេងពេក** ព្រោះបទពិសោធន៍កម្ពុជាធ្លាប់មានរដ្ឋមន្ត្រីការបរទេសអាយុ ២៧ឆ្នាំ ហើយក៏ធ្លាប់មាននាយករដ្ឋមន្ត្រីអាយុ ៣២ឆ្នាំដែរ គឺខ្លួនខ្ញុំនេះឯង ... ដូច្នេះ **ក្នុងការរៀបចំមន្ត្រីបន្តវេនទៅមុខទៀត កុំចាំបាច់សួរថាអាយុប៉ុន្មាន។ សំខាន់បំផុតគឺគេធ្វើបានឬអត់។ រឿងវាស្ថិតនៅកន្លែងហ្នឹងទេ** ...។

១១. ចាស់មានពិសោធន៍ ក្មេងមានចំណេះដឹង

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៥១ ចាប់ពីឧដុង្គ/ផ្លូវជាតិលេខ៥ ដល់ថ្នល់ទទឹង/ផ្លូវជាតិលេខ៤, ២៥ មីនា ២០២២

... ក្មេងត្រូវយល់ពីមនុស្សចាស់។ **ក្មេងមានចំណេះដឹងក៏ប៉ុន្តែខ្វះពិសោធន៍។ ឯចាស់ អាចថាមិនមានចំណេះដឹងគ្រប់គ្រាន់ប៉ុន្តែសម្បូរពិសោធន៍។ ជារឿងដែលត្រូវផ្គុំគ្នា។ គេហៅថា ស្ថានភាពបោះចម្រុះរវាងគ្រប់ជំនាន់** ... គេឃើញហើយថាក្នុងគណបក្សប្រជាជន មានមន្ត្រីដែលមានអាយុ ៨០ឆ្នាំ ... មានអាយុ ៤០ឆ្នាំ និង

នៅមានបន្តតាមលំដាប់អញ្ចឹងមក ... **អ្នកចាស់មិនត្រូវមើលស្រាលក្មេងដែលមិនទាន់មានពិសោធន៍ ។ ឯក្មេងដែលមានចំណេះដឹង ក៏មិនត្រូវមើលស្រាលមនុស្សចាស់(អ្នកមុន)ដែលជាធនធានមរតកនៃបទពិសោធន៍ក្នុងគ្រប់ការងារ ជាពិសេសទាក់ទងនឹងការគ្រប់គ្រងប្រទេសជាតិ ។ មនុស្សចាស់ជាធនធានមានតម្លៃ** ។ និយាយអញ្ចឹង មិនមែនចង់ថាថ្ងៃក្រោយត្រូវតែសួរយោបល់ខ្ញុំនោះទេ ...។

១២. បំបែកខេត្តកំពង់ចាមនិងត្បូងឃ្មុំដើម្បីឱ្យដូចពីអតីតកាលនិងងាយគ្រប់គ្រងរដ្ឋបាល

បើកការដ្ឋានសង់ស្ពានឆ្លងកាត់ទន្លេមេគង្គ ពីស្ទឹងត្រង់ ទៅក្រូចឆ្មារ, ៩ កុម្ភៈ ២០១៨

... ការបែងចែកខេត្តកំពង់ចាមនិងខេត្តត្បូងឃ្មុំនេះ កើតនៅក្នុងដំណាក់កាលហ៊ុនសែន ... **(ក្នុងបំណង)ធ្វើឲ្យស្ថានភាពបានវិលត្រឡប់ទៅអតីតកាលផងប៉ុន្តែបញ្ហាសំខាន់ជាងគេនៅត្រង់ថា ងាយគ្រប់គ្រងរដ្ឋបាល** ។ ខេត្តកំពង់ចាមនេះ មានប្រជាជនរហូតទៅដល់ជិត ២លាននាក់ គឺស្មើតែស្មើនឹង១០% (នៃប្រជាជនទូទាំងប្រទេស)។ បើពីមុន ដែលមានប្រជាជនតែប្រមាណ ១០លាននាក់ គឺ(ប្រជាជនខេត្តកំពង់ចាមគឺ)ស្មើនឹងប្រមាណ១៥% នៃប្រជាជនទូទាំងប្រទេស។ ដោយហេតុនេះ យើងបានបំបែកត្រើយម្ខាងខាងនោះទៅជាខេត្តត្បូងឃ្មុំ ឯត្រើយម្ខាងខាងនេះគឺខេត្តកំពង់ចាមដដែល។ សម័យដើម **ខេត្តត្បូងឃ្មុំនោះ មិនមែនជាស្រុកត្បូងឃ្មុំទេ គឺខេត្តត្បូងឃ្មុំដែរ ដែលមាន អារជូន ធ្វើជាចៅហ្វាយខេត្ត ។ ឯនៅត្រើយខាងយើងនេះ បើតាមការស្រាវជ្រាវ គឺខេត្តជើងព្រៃទៅវិញទេ** ។ ពីដើមមានពីរខេត្ត ។ ឥឡូវយើងក៏រៀបចំឲ្យមានពីរខេត្តឡើងវិញ ...។

១៣. អ្នកឈរឈ្មោះធ្វើជាមេឃុំ/ចៅសង្កាត់ ត្រូវមានសញ្ញាបត្រឧត្តមសិក្សា

ពិធីចែកសញ្ញាបត្រជូនដល់និស្សិតនៃសាកលវិទ្យាល័យ វេស្ទើន, ១៨ ធ្នូ ២០១៩

... ខ្ញុំបានសូមឱ្យសម្តេចក្រឡាហោមធ្វើស្ថិតិឱ្យខ្ញុំថា ប៉ុន្មានភាគរយនៃថ្នាក់ដឹកនាំខេត្ត/ស្រុក ដែលមានសញ្ញាបត្រឧត្តមសិក្សា? ការពិត លើសពី៩០% ទៅហើយដែលមានសញ្ញាបត្រឧត្តមសិក្សា។ បើនិយាយពីថ្នាក់ខេត្តមានរហូតដល់ទៅ១០០% ... ឯថ្នាក់ស្រុកក៏ស្ទើរតែ១០០% ទៅហើយដែរ ... នៅពេលខាងមុខអាចនឹង(រៀបចំថាអ្នកដែលបានរៀនចប់)ថ្នាក់ឧត្តមសិក្សា អាចទៅឈរឈ្មោះធ្វើ

ជាមេឃុំ/ចៅសង្កាត់ ព្រោះមេឃុំ/ចៅសង្កាត់រាល់ថ្ងៃប្រាក់ខែច្រើន បន្ថែមដោយថវិកាដែលផ្តល់ឱ្យថ្នាក់ឃុំ/សង្កាត់កាន់តែច្រើនទៀត។ ហេតុហ្នឹង ត្រូវការសមត្ថភាពចាត់ចែង។ ការធ្វើដូច្នេះនឹងជួយឱ្យប្រទេសគ្រប់គ្រងបានកាន់តែប្រសើរ ...។

១៤. ប្រឈមនឹងកូវីដ១៩ ឆ្នាំ២០២០ រដ្ឋាភិបាលកាត់បន្ថយចំណាយ ៩១៨លានដុល្លារ

សេចក្តីដកស្រង់ប្រសាសន៍ក្នុងសន្និសីទសារព័ត៌មាន
អំពីបច្ចុប្បន្នភាពនៃជំងឺ Covid-19, ៧ មេសា ២០២០

... យើងត្រូវដាក់សង្គ្រាមប្រឆាំងនឹង Covid-19 ក្នុងក្របខណ្ឌយុទ្ធសាស្ត្រយៈពេលវែង ព្រោះជំងឺឆ្លងនេះមិនទាន់ឃើញសញ្ញាថយចុះនៅឡើយ ហើយក៏មិនទាន់មានថ្នាំព្យាបាលដែរ ... **សូមស្ថាប័នគ្រប់ថ្នាក់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានការយោគយល់អំពីប្រការដែលរាជរដ្ឋាភិបាលត្រូវបង្ខំចិត្តកាត់បន្ថយការចំណាយ(ដល់ទៅ) ២ដង។** លើកទី១ បានកាត់បន្ថយការចំណាយចំនួន ៤៤៣ លានដុល្លារ សហរដ្ឋអាមេរិក និងម្សិលមិញ ខ្ញុំចេញបទបញ្ជា តាមសំណើរបស់ឯកឧត្តម អូន ព័ន្ធមុន្នីរ័ត្ន កាត់បន្ថយចំណាយ ៤៧៥លានទៀត។ **សរុបមក ការកាត់បន្ថយចំណាយទាំង ២លើកនេះ មានចំនួន ៩១៨លានដុល្លារអាមេរិក។ រដ្ឋត្រូវតែខ្ជាប់(ឋិតានេះ)មកវិញ ... រាប់ទាំងថវិកាមូលនិធិភូមិឃុំ ក៏ត្រូវបន្ថយក្នុងពេលហ្នឹង។ ប៉ុន្តែមិនប៉ះពាល់ការដ្ឋានផ្លូវថ្នល់ប្រឡាយទឹកទេ** ...។

១៥. ជោគជ័យលើកូវីដ១៩ គឺជោគជ័យនៃការបែងចែកមុខងារ/ផ្ទេរអំណាចទៅមូលដ្ឋាន

ផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្តជាផ្លូវការកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២(២០២១-២០៣០), ២១ មីនា ២០២២

... សម្តេចក្រឡាហោម ស ខេង បានដាក់ឲ្យខ្ញុំនូវពង្រៀងធ្វើវិសោធនកម្មច្បាប់ការគ្រប់គ្រងនេះ។ យើងមិនបានឆ្លងគណៈកម្មាធិការជាតិទេ ប៉ុន្តែខ្ញុំបានដាក់នៅ(ក្នុងរបៀបវារៈ)ប្រជុំគណៈរដ្ឋមន្ត្រីនៅថ្ងៃ ១មេសា ខាងមុខនេះ។ ថ្នាក់មូលដ្ឋានកំពុងមានការងារយ៉ាងច្រើន។ **បទពិសោធន៍ជោគជ័យរយៈពេល ២ឆ្នាំនៃការប្រយុទ្ធប្រឆាំងជំងឺកូវីដ–១៩ គឺជាជោគជ័យនៃការបែងចែកមុខងារ និងការផ្ទេរអំណាចកាន់តែច្រើនទៅកាន់មូលដ្ឋាន។ ប្រសិនបើអ្វីៗ រង់ចាំថ្នាក់ជាតិ ហើយ**

ថ្នាក់ក្រោមជាតិ មិនអាចធ្វើសកម្មភាពបានតាមទំហំការងារ និងឆ្លើយតបបន្ទាន់ទេនោះ យើងមិនអាចមានជោគជ័យតាមរបៀបសព្វថ្ងៃនេះទេ ...។

១៦. ថ្នាក់ជាតិផ្តល់មធ្យោបាយ និងសិទ្ធិអំណាច ឯថ្នាក់មូលដ្ឋានចាត់ចែង

ផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្តជាផ្លូវការកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២(២០២១-២០៣០), ២១ មីនា ២០២២

... ជំងឺរាតត្បាតនេះធ្ងន់ធ្ងរ។ វាហួសពីលទ្ធភាពត្រួតត្រាបាន។ ប៉ុន្តែ ដោយសារយើងបានផ្ទេរអំណាចនិងបែងចែកមុខងារទៅមូលដ្ឋានមួយជំហានមុន មូលដ្ឋានបានប្រឹងប្រែងខ្លាំងដើម្បីឆ្លើយតប ... ឥឡូវនេះ ការឆ្លងនៅខេត្តខ្លះអត់មានទេក្នុងមួយថ្ងៃៗ។ **សញ្ញាវិជ្ជមាននេះ មិនមែនបានមកពីថ្នាក់ជាតិទាំងអស់ទេ។ ថ្នាក់ជាតិផ្តល់មធ្យោបាយ និងសិទ្ធិអំណាច ឯថ្នាក់មូលដ្ឋានចាត់ចែង ... ក្នុងពេលដែលថ្នាក់មូលដ្ឋានទទួលខុសត្រូវ យើងបានឃើញថាថ្នាក់មូលដ្ឋានកំពុងខ្វះកំលាំង។** ដូច្នេះ ត្រូវរៀបចំវិសោធនកម្មច្បាប់ដើម្បីកំណត់ចំនួនអ្នកទទួលខុសត្រូវក្នុងក្របខណ្ឌគណៈអភិបាលខេត្ត និងស្រុកផងដែរ។ នេះជាបទពិសោធន៍ល្អ ដែលចាំបាច់ត្រូវជម្រុញនៅពេលខាងមុខ។ មិនអាចថាអ្វីៗ (ប្រមូលផ្តុំតែ)នៅថ្នាក់ជាតិហើយអ្វីៗនៅថ្នាក់មូលដ្ឋានដែលនៅកៀក(នឹងប្រជាពលរដ្ឋ) បែជាមិនធ្វើសកម្មភាពនោះទេ ...។

១៧. បើធ្វើតាមរដ្ឋបាលអតីតរដ្ឋកម្ពុជា ល្បឿនកែទម្រង់ប្រជាធិបតេយ្យថ្នាក់ក្រោមជាតិអាចដើរលឿនជាងច្រើនដង

បិទកិច្ចប្រជុំបូកសរុបសកម្មភាពនិងលទ្ធផលការងារ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាននារាជធានីខេត្ត នីតិកាលទី៦ នៃរដ្ឋសភានិងទិសដៅបន្ត, ១៩ មិថុនា ២០២៣

... ពួកគេចង់សម្លាប់មូលដ្ឋាន (ព្រោះតែគេ)ដឹងច្បាស់ថាមូលដ្ឋានគឺជាគ្រឹះរបស់គណបក្សប្រជាជន។ ក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ពួកគេមានចេតនាធ្វើឲ្យមូលដ្ឋាន(ទន់ខ្សោយ)។ ខេត្តមួយ(ត្រូវបានកំណត់ក្នុង)មួយខែឲ្យមានប្រាក់ត្រឹមតែ ១លានរៀលទេ។ **ខ្ញុំបានទៅដឹកនាំរៀបចំផែនការវាយប៉ែលិន ... នៅខេត្តបាត់ដំបង មួយខែឲ្យគ្នាចាយ ១លានរៀល។ យកទៅចាយអី? អញ្ចឹងទេ**

និយាយតាមមួយបែប ពួកគេមានចេតនាជាក់លាក់។ បើពេលនោះធ្វើតាមអ្វីដែលអតីតរដ្ឋកម្ពុជាបានធ្វើ ល្បឿននៃកំណែទម្រង់ប្រជាធិបតេយ្យថ្នាក់ក្រោមជាតិដើរលឿនជាងនេះច្រើនដង ... បើមានដាច់ស្ពានត្រឹម១០ ឬ២០ ម៉ែត្រ មិនចាំបាច់ក្រសួងសាធារណការទៅធ្វើទេ គឺមូលដ្ឋានធ្វើតែម្តង ...។

១៨. មន្ត្រីថ្នាក់កណ្តាលចុះមូលដ្ឋាន មិនបានធ្វើឱ្យមូលដ្ឋានបាត់ការទទួលខុសត្រូវ

បិទកិច្ចប្រជុំបូកសរុបសកម្មភាពនិងលទ្ធផលការងារ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាននារាជធានីខេត្ត នីតិកាលទី៦ នៃរដ្ឋសភានិងទិសដៅបន្ត, ១៩ មិថុនា ២០២៣

... យើងបានប្រគល់អំណាចឲ្យច្រើន។ ប្រគល់អំណាចទាំងកងទ័ព ទាំងនគរបាល ... ឯការបញ្ជូនមន្ត្រីចុះមូលដ្ឋាន មិនមែនជារឿងថ្មីថ្មោងទេ។ គណបក្សបានធ្វើរហូត(មក) ... ខ្ញុំបានសង្កេតឃើញថា **ពេលមន្ត្រីពីខាងលើដែលចុះទៅ មិនបានធ្វើឲ្យបាត់ការទទួលខុសត្រូវរបស់មូលដ្ឋានទេ។ ផ្ទុយទៅវិញ បានរួមគ្នាដោះស្រាយបញ្ហា។ [សុន្ទរកថា] ... ត្រូវខិតខំរួមគ្នាជានាប្រក្រតីភាព និរន្តភាព និងប្រសិទ្ធភាពការងារនៅតាមក្រសួង-ស្ថាប័ន និងរដ្ឋបាលគ្រប់ថ្នាក់ នៅថ្នាក់ក្រោមជាតិ ដើម្បីជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព ដោយបង្កើនការយកចិត្តទុកដាក់ក្នុងការផ្តល់សេវាសាធារណៈ រួមនឹងដោះស្រាយសំណូមពរនានារបស់ប្រជាពលរដ្ឋ ក៏ដូចជាបញ្ហាប្រឈមនៅតាមមូលដ្ឋានប្រកបដោយតម្លាភាព និងប្រសិទ្ធភាពរហូតរាជរដ្ឋាភិបាលថ្មីដែលកើតចេញពីការបោះឆ្នោតចូលកាន់តំណែង ...។**

១៩. កិច្ចព្រមព្រៀងទីក្រុងប៉ារីស តម្រូវឱ្យមានក្រសួងសន្តិសុខ

ប្រគល់សញ្ញាបត្រនិងវិញ្ញាបនបត្រដល់និស្សិតនិងសិក្ខាកាម នៃបណ្ឌិត្យសភានគរបាលកម្ពុជា, ៥ សីហា ២០១៩

... **ក្នុងសារបានទាក់ទិននឹងការរៀបចំនៃក្រសួងមហាផ្ទៃ។ បើពីអតីតកាល ខ្ញុំមិនរំលឹកទេ ដែលមានហៅថា មានសាលាតម្រួតមានស្តីៗនោះ។ ប៉ុន្តែ ពីដំណាក់កាលមួយទៅដំណាក់កាលមួយ ប្រទេសយើងក៏ដូចជាប្រទេសជិតខែមានការរៀបចំខុសៗគ្នាដែរ។ នៅក្នុងដំណាក់កាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋ**

កម្ពុជា យើងរៀបចំឱ្យមានក្រសួងមហាផ្ទៃដែរ តែពេលនោះក្រសួងធ្វើការងារនគរបាល មិនបានធ្វើការងារគ្រប់គ្រងរដ្ឋបាលដែនដីនោះឡើយ។ ត្រូវមើលឃើញពីការរៀបចំរបស់យើងកាលពីគ្រានោះ ... ទាក់ទងនឹងគ្រប់គ្រងរដ្ឋបាលដែនដី បើនិយាយពីចៅហ្វាយខេត្ត អនុខេត្តអីៗ មិនមែនក្រសួងមហាផ្ទៃជាអ្នកលើកសំណើតែងតាំងទេ គឺគណៈចាត់តាំងមជ្ឈិមឯនោះទេ ដែលដើរតួនាទីធ្វើកិច្ចការនេះ ...។

២០. ឆ្នាំ១៩៩២ បំបែកជាក្រសួងសន្តិសុខនិងមហាផ្ទៃ តបតាមការតម្រូវនៃកិច្ចព្រមព្រៀងប៉ារីស

ប្រគល់សញ្ញាបត្រនិងវិញ្ញាបនបត្រដល់និស្សិតនិងសិក្ខាកាម
នៃបណ្ឌិត្យសភានគរបាលកម្ពុជា, ៥ សីហា ២០១៩

... នៅ**ឆ្នាំ ១៩៩២ យើងបានបំបែកឱ្យមានក្រសួងសន្តិសុខនិងក្រសួងមហាផ្ទៃ ត្បិតកិច្ចព្រមព្រៀងទីក្រុងប៉ារីសបានតម្រូវឱ្យអ៊ុនតាក់ត្រួតពិនិត្យលើស្ថាប័ន៥ គឺ មហាផ្ទៃ ការពារជាតិ ព័ត៌មាន យុត្តិធម៌ និងហិរញ្ញវត្ថុ។ តបនឹងតម្រូវការនេះ ពេលនោះ យើងត្រូវរៀបចំឱ្យមានក្រសួងសន្តិសុខមួយទៀត ដែលបែងចែកឲ្យ ឯកឧត្តម សុិន សុង ដឹកនាំក្រសួងសន្តិសុខវិញ ហើយសម្តេចក្រឡាហោម ត្រូវយកពីប្រធានឧទ្ធរណ៍យ័តគណៈកម្មាធិការកណ្តាល ទៅធ្វើជារដ្ឋមន្ត្រីមហាផ្ទៃ** ... ពេលបោះឆ្នោតរួច ថ្ងៃទី១៨ មិថុនា ឆ្នាំ១៩៩៣ ខ្ញុំបានជួបពិភាក្សាជាមួយសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ រៀបចំរដ្ឋាភិបាលបណ្តោះអាសន្ន។ យើងបានរំលាយរដ្ឋបាលនៅហ្នឹងកន្លែង គឺរដ្ឋកម្ពុជាមុនការកំណត់នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ...។

២១. ក្រោយការបោះឆ្នោត១៩៩៣ ក្រសួងសន្តិសុខនិងមហាផ្ទៃត្រូវបានបញ្ចូលគ្នាជាថ្មី

ប្រគល់សញ្ញាបត្រ និងវិញ្ញាបនបត្រដល់និស្សិត និងសិក្ខាកាម
នៃបណ្ឌិត្យសភានគរបាលកម្ពុជា, ៥ សីហា ២០១៩

... (ការរំលាយរដ្ឋបាលនៅហ្នឹងកន្លែងគឺរដ្ឋកម្ពុជា)នេះហើយ ជាការបើកផ្លូវដើម្បីឈានឆ្ពោះទៅបង្រួបបង្រួមនិងការតាក់តែងរដ្ឋធម្មនុញ្ញ ... អ៊ុនតាក់ (បានរៀបចំការ)បោះឆ្នោតតែនៅក្នុងតំបន់ដែលភាគីនីមួយៗកាន់កាប់ (ដោយមានវត្តមានអ៊ុនតាក់) លើកលែងតំបន់ខ្មែរក្រហម។ កិច្ចព្រមព្រៀងទីក្រុងប៉ារីសតម្រូវ

ឱ្យមានការបោះឆ្នោតរើសសភាធម្មនុញ្ញ បន្ទាប់ទៅសភាធម្មនុញ្ញអនុម័តរដ្ឋធម្មនុញ្ញ រួចហើយសភាធម្មនុញ្ញក្លាយជាសភាជាតិ ដែលដំណើរការបង្កើតរដ្ឋាភិបាលថ្មី។ ប៉ុន្តែ ដើម្បីបង្កើតការជឿទុកចិត្តគ្នា **យើងបានពិភាក្សាគ្នានាំដល់ការបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នដែលមាននាយករដ្ឋមន្ត្រីពីរ។ ពេលនោះក្រសួងសន្តិសុខនិងក្រសួងមហាផ្ទៃត្រូវបញ្ចូលគ្នាឡើងវិញ ... ដោយសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និងខ្ញុំបានក្លាយជាសហនាយករដ្ឋមន្ត្រីផង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃផង និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិផង** ...។

២២. មិនបំបែកនគរបាលជាតិចេញពីការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃជាការត្រឹមត្រូវ

ប្រគល់សញ្ញាបត្រនិងវិញ្ញាបនបត្រ ដល់និស្សិតនិងសិក្ខាកាម
នៃបណ្ឌិត្យសភានគរបាលកម្ពុជា, ៥ សីហា ២០១៩

... ក្នុងអាណត្តិទី១ (នៃរាជរដ្ឋាភិបាល) ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងទីស្តីការគណៈរដ្ឋមន្ត្រី មានសហរដ្ឋមន្ត្រី។ ក្រោយការបោះឆ្នោតឆ្នាំ១៩៩៨បន្ទាប់ពីគណបក្សប្រជាជនបានជ័យជំនះ **មនុស្សមួយចំនួនបានស្នើឱ្យខ្ញុំរៀបចំក្រសួងសន្តិសុខជាតិ ឬក្រសួងនគរបាលជាតិ ដោយបំបែកចេញពីក្រសួងមហាផ្ទៃ ដោយមើលឃើញថាការបន្តនៅមានសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្រសួងមហាផ្ទៃ ក្រសួងការពារជាតិជាការលំបាក។ ខ្ញុំមិនព្រម។ ការលើកគំនិតទាក់ទងនឹងការបំបែកក្រសួងមហាផ្ទៃទៅផ្សេង និងយកនគរបាលទៅជាក្រសួងមួយផ្សេង ត្រូវបានលើកឡើងក្នុងចន្លោះឆ្នាំ១៩៩៨ រហូតដល់ឆ្នាំ២០០៦ រហូតដល់ក្រោយកែរដ្ឋធម្មនុញ្ញហើយ ទើបផុតរលត់។ ខ្ញុំយល់ថាបានគិតត្រូវដែលរៀបចំស្ថាប័ននេះដោយមិនព្រមបំបែកនគរបាលជាតិឱ្យចេញពីការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ** ...។

២៣. មហាផ្ទៃជាតួអង្គឯកភាពដឹកនាំប្រតិបត្តិការការពារសន្តិសុខផ្ទៃក្នុង និងកំណែទម្រង់រដ្ឋបាល

ប្រគល់សញ្ញាបត្រនិងវិញ្ញាបនបត្រ ដល់និស្សិតនិងសិក្ខាកាម
នៃបណ្ឌិត្យសភានគរបាលកម្ពុជា, ៥ សីហា ២០១៩

... **បើជាក្រសួងមហាផ្ទៃ បានត្រឹមតែនិយាយជាមួយខេត្ត គ្មានឧបករណ៍នៅក្នុងដៃ តើការពារសន្តិសុខផ្ទៃក្នុងបែបណាទៅ។ បើប្រគល់(ការងារនេះ)**

ឱ្យក្រសួងសន្តិសុខជាតិមួយទៀត វានឹងកាន់តែច្របូកច្របល់។ នៅប្រទេសវៀតណាម អត់មានក្រសួងមហាផ្ទៃទេ គឺមានក្រសួងនគរបាល។ នៅថៃក្រសួងមហាផ្ទៃអត់មានគ្រប់គ្រងនគរបាលទេ គឺដាក់នគរបាលនៅក្រោមការគ្រប់គ្រងរបស់នាយករដ្ឋមន្ត្រី។ នៅចិន មានក្រសួងសន្តិសុខផ្ទៃក្នុង។ នៅឡាវមានតែក្រសួងនគរបាល។ នៅប្រទេសខ្លះ ដូចជាតួកគីជាដើម ក្រសួងមហាផ្ទៃគ្រប់គ្រងនគរបាល។ ខ្ញុំមិនដឹងថាប្រទេសណាខ្លះដែលក្រសួងមហាផ្ទៃនៅដាច់ដោយឡែក ហើយនគរបាលរៀបចំដោយឡែក ឬដាក់ក្រោមការបញ្ជារបស់នាយករដ្ឋមន្ត្រី។ នេះជាចំណុចដែលខ្ញុំបានប្រកាន់ជំហរម៉ឺងម៉ាត់ **រៀបចំឱ្យមាន (កម្លាំងនគរបាលនៅក្រោមក្រសួងមហាផ្ទៃជា)តួអង្គឯកភាព ដឹកនាំប្រតិបត្តិការរក្សាសន្តិសុខផ្ទៃក្នុងប្រទេស រាប់ទាំងកំណែទម្រង់រដ្ឋបាល ពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិ** ...៕

២៤. ព្រំសីមា និងព្រំដែនអាចជាទីតាំងលាក់ខ្លួន រត់ពន្ធគ្រឿងញៀនឬទំនិញខុសច្បាប់

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៥១ ចាប់ពីឧដុង្គ/ផ្លូវជាតិលេខ៥ ដល់ថ្នល់ទទឹង/ផ្លូវជាតិលេខ៤, ២៥ មីនា ២០២២

... តំបន់នេះ មានព្រំប្រទល់រវាងខេត្តកណ្តាល ជាមួយខេត្តកំពង់ស្ពឺ។ ប៉ុន្តែដីនៅនេះនៅក្នុងខេត្តកំពង់ស្ពឺ។ ខាងណោះដីក្នុងខេត្តកណ្តាលហើយយកផ្លូវជាតិហ្នឹងធ្វើព្រំដែន។ ប៉ុន្តែប្រយ័ត្នខាងណោះទៅមិនដល់ខាងណោះទៅមិនដល់ ពួកហ្នឹងដក់គ្រឿងញៀនពេញហ្នឹង ... តាមបទពិសោធកាលពីសម័យសង្គ្រាម ឬបទពិសោធនៃការរក្សាសន្តិសុខតាមព្រំដែនច្រើនតែអញ្ចេះ ... ឧទាហរណ៍ថា ព្រំប្រទល់ខេត្តកណ្តាលនិងព្រំប្រទល់ខេត្តកំពង់ស្ពឺ ខាងកណ្តាលក៏មកមិនដល់ខាងកំពង់ស្ពឺក៏ទៅមិនដល់។ អញ្ចឹង**តំបន់ហ្នឹងជាតំបន់ដែលមានការលាក់ខ្លួន។ កាលជំនាន់សង្គ្រាម កម្លាំងប្រដាប់អាវុធលាក់ខ្លួន។ តែជំនាន់នេះក្រុមរត់គ្រឿងញៀនជាអ្នកលាក់ខ្លួន។ តាមព្រំដែនកម្ពុជា-ថៃ ព្រំដែនកម្ពុជា-វៀតណាម និងព្រំដែនកម្ពុជា-ឡាវ ក៏ដូចគ្នាដែរ។ ខាងយើងក៏ទៅមិនដល់ ខាងនោះក៏មកមិនដល់ វាឆ្លៀតប្រើកន្លែងហ្នឹងធ្វើសកម្មភាពបង្កការអុកឡុក ឬក៏រត់ពន្ធមនុស្សរត់ពន្ធគ្រឿងញៀនឬរត់ពន្ធទំនិញខុសច្បាប់ជាដើម** ...៕

២៥. អនុវត្តនយោបាយភូមិឃុំមានសុវត្ថិភាព មិនបាច់នាយករដ្ឋមន្ត្រី/រដ្ឋមន្ត្រីមហាផ្ទៃស្រែក

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
លើកទី៦ ឆ្នាំ ២០២២, ២៩ កញ្ញា ២០២២

...រកឃើញក្រឡាល្អមួយត្រង់ថា បង្កើត channel ហ្វេសប៊ុក ឬក៏ Telegram ឬក៏ channel ដទៃទៀត ដែលធ្វើឱ្យមិត្តភក្តិបរទេសមានពលរដ្ឋខ្លួនត្រូវគេជួញដូរ ឬក៏ពលរដ្ឋកម្ពុជាត្រូវគេជួញដូរ ត្រូវគេបង្ខាំង អាចចូលមក(ផ្តល់ព័ត៌មាន) ដែលយើងងាយធ្វើសហប្រតិបត្តិការក្នុងការលុបបំបាត់ចំណុចអសកម្មទាំងនោះ។ ប៉ុន្មានខែចុងក្រោយនេះ ពេលដែលយើងបើកប្រទេសឡើងវិញ ក៏ឃើញមានស្ថានភាពនៃការជួញដូរមនុស្ស/គ្រឿងញៀននិងអំពើខុសច្បាប់ដទៃផ្សេងទៀតកើនឡើងគួរឱ្យចាប់អារម្មណ៍។ ល្បែងស៊ីសងបានកើតឡើងច្រើន ... **ខ្ញុំបានចុះហត្ថលេខាបង្កើតគណៈកម្មការអន្តរក្រសួង និងចេញសារសំឡេងណែនាំ ... រឿងហ្នឹងទាក់ទងជាមួយបញ្ហាភូមិឃុំមានសុវត្ថិភាព ដែលយើងបានដាក់ឱ្យអនុវត្តច្រើនឆ្នាំទៅហើយ ...សូមកុំចាំរដ្ឋមន្ត្រីមហាផ្ទៃស្រែកឬកុំចាំបាច់នាយករដ្ឋមន្ត្រីស្រែកទើបធ្វើ។ សូមនាំគ្នាធ្វើឱ្យដូចភ្លៀងរលឹមទៅ** ...៕

២៦. ព្រមៗគ្នារាំងស្កាត់ល្បែងស៊ីសង អំពើទុច្ចរិត ដែលនឹងនាំដល់ការជួញដូរមនុស្ស

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
លើកទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

...គ្រប់តួអង្គពាក់ព័ន្ធត្រូវធ្វើសកម្មភាពព្រមៗ គ្នា មិនមែនតែចំពោះការជួញដូរមនុស្សតែមួយមុខទេ តែក៏ទាំងមែកធាងរបស់វា ដូចជាល្បែងស៊ីសង និងអំពើទុច្ចរិតនានា ដែលវានាំឆ្ពោះទៅដំណាក់កាលធ្ងន់ធ្ងរគឺការជួញដូរមនុស្ស និងឬការជួញដូរផ្លូវភេទ ដែលយើងត្រូវតែដោះស្រាយដោយជៀសវាងមិនបាន។ យើងត្រូវតែកំណត់គោលដៅ ... ស៊ើបអង្កេតជនប្រព្រឹត្តបទល្មើស និងបក្សពួក ស្រាវជ្រាវរកមេខ្លោង ដើម្បីផ្តន្ទាទោសតាមច្បាប់ដោយគ្មានការលើកលែង។ ត្រួតពិនិត្យប្រមូលកស្តុតាង បិទអាជីវកម្មខុសច្បាប់ ពិសេសល្បែងស៊ីសង និងល្បែងតាមប្រព័ន្ធអេឡិចត្រូនិចដែលខុសច្បាប់ និងបើរកឃើញថាមានករណីជួញដូរមនុស្ស គឺត្រូវធ្វើការស៊ើបអង្កេត ចាប់បញ្ជូន និងអនុវត្តតាមច្បាប់ ...៕

២៧. ចូលរួមនិងរាយការណ៍ឱ្យសមត្ថកិច្ច ដើម្បីកុំឱ្យកម្ពុជាក្លាយជាឋានសួគ៌នៃឧក្រិដ្ឋកម្ម

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
លើកទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

... គួរកវិធីបង្ការកុំឲ្យរឿងកើតរួចហើយ ទើបយើងរកវិធីដោះស្រាយ។ បង្ការកុំឲ្យវាកើត រារាំងកុំឲ្យវាកើត ដូចជាតាមរយៈនិកាយសាសនានីមួយៗ រួមចំណែកដើម្បីអប់រំមនុស្ស។ វិធីល្អជាងគេគឺអញ្ចឹង ... ព្រះពុទ្ធសាសនាអប់រំមនុស្ស អ្នកកាន់ព្រះពុទ្ធសាសនាទៅ។ គ្រីស្តសាសនាក៏អប់រំគ្រីស្តសាសនាទៅ។ ឥស្លាមសាសនាក៏អប់រំឥស្លាមទៅ។ នៅមាននិកាយដទៃទៀត ក្នុងទីនេះអាចមានទាំងអ្នកកាន់សាសនាហ៊ីនឌូផងដែរ។ ចំណុចដែលយើងគួរធ្វើ គឺ**រារាំងការប្រព្រឹត្តល្មើស ហើយត្រូវប្រើប្រាស់កិច្ចសហប្រតិបត្តិការគ្រប់តួអង្គ ពិសេសការចូលរួមរបស់ប្រជាពលរដ្ឋទាក់ទងនឹងសកម្មភាពដែលខ្លួនបានឃើញ ហើយហ៊ានរាយការណ៍ឲ្យសមត្ថកិច្ច ដើម្បីទប់ស្កាត់កុំឲ្យកើតឡើងនូវរឿងអកុសលចំពោះកូនចៅ ក្រុមគ្រួសារ សាច់ញាតិរបស់យើង ហើយធ្វើឲ្យកម្ពុជាក្លាយទៅជាឋានសួគ៌នៃឧក្រិដ្ឋកម្ម** ...៕

២៨. កុំឲ្យកម្ពុជាក្លាយជាជម្រកភេរវកម្ម ប្រើប្រាស់ទឹកដីវាយគោលដៅប្រទេសដទៃ

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
លើកទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

...យើងធ្លាប់ធ្វើដោយជោគជ័យក្រោយព្រឹត្តិការណ៍ការវាយប្រហារភេរវកម្មនៅទីក្រុងញូវយ៉កថ្ងៃ ១១កញ្ញា ។ពេលនោះយើងបានសហការជាមួយសហរដ្ឋអាមេរិក និងដៃគូដទៃទៀតទប់ស្កាត់ភេរវកម្ម។ យើងសហការជាមួយសហរដ្ឋអាមេរិក ជាមួយដៃគូដទៃទៀតចាប់មេភេរវកម្មឈ្មោះ Hambali ...។ យើងទប់ស្កាត់បានភេរវកម្មមិនឲ្យកើតមាននៅលើទឹកដីយើង។ យើងតែងតែរំលឹកខ្លួនយើងថា **កុំឲ្យកម្ពុជាក្លាយជាជម្រកនៃភេរវកម្ម។ បើទោះបីជាកម្ពុជាមិនមែនជាគោលដៅនៃការវាយប្រហារភេរវកម្មក៏ដោយ ក៏កុំឲ្យកម្ពុជាក្លាយជាជម្រករបស់ពួកភេរវកម្មដែលប្រើប្រាស់ទឹកដីកម្ពុជា វាយទៅលើប្រទេសដទៃគោលដៅ**។ យើងបានធ្វើការងារនេះបានល្អ ជាមួយនឹងដៃគូ ...៕

២៩. ធានាមិនមានអាវុធហូរចូលដោយគ្មានច្បាប់ទម្លាប់ និងក្លាយជាអាវុធនៃឧក្រិដ្ឋជន

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
លើកទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

... យើងក៏នឹងធ្វើកិច្ចការនេះបានល្អដូចគ្នា តាមរយៈនៃការខិតខំប្រើប្រាស់វិធីបង្ការ ការអប់រំ វិធានការរដ្ឋបាលនិងវិធានការច្បាប់។ ឥឡូវនេះ **ឧក្រិដ្ឋកម្មខ្លះមានដល់អាវុធប្រើប្រាស់នៅលើទឹកដីរបស់យើង ដែលចាំបាច់ត្រូវបំផ្លាញបង្ក្រាប (ករណី)ជំគ្រោះថ្នាក់នេះ។ អាវុធចេញមកពីណា? គេយកចូលប្រទេសតាមរបៀបណា? ត្រូវប្រើប្រាស់(វិធីសាស្ត្រស្រាវជ្រាវរក)ឲ្យអស់លទ្ធភាព តាមគ្រប់ច្រក ដែនអាកាស ផ្លូវគោក និងផ្លូវទឹក ដើម្បីធានាថាអាវុធត្រូវបានគ្រប់គ្រងបានយ៉ាងរឹងមាំ ហើយមិនត្រូវឲ្យមានអាវុធហូរចូលមកក្នុងប្រទេសដោយគ្មានច្បាប់ទម្លាប់ ឬអាវុធនៅក្នុងឃ្លាំងក្លាយទៅជាអាវុធនៃឧក្រិដ្ឋជន** ដែលធ្វើការបាញ់ប្រហារនិងសម្លាប់មនុស្សនៅលើទឹកដីរបស់យើងនោះទេ ...ព្រះសង្ឃគ្រប់និកាយសាសនាមានលទ្ធភាពផ្តល់ការអប់រំ។ ជម្រើសដែលល្អជាងគេគឺអប់រំឲ្យប្រព្រឹត្តអំពើល្អនេះឯង ...៕

៣០. ការបោះឆ្នោតសកល២០២៣ ជាការប្រកួតប្រជែងរវាងអ្នកគាំទ្រនិងអ្នកបំផ្លាញប្រជាធិបតេយ្យ

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវក្រវាត់ក្រុងទី៣ ប្រវែង៥២ គីឡូម៉ែត្រ,
៣ សីហា ២០២៣

... ការបោះឆ្នោតនៅកម្ពុជាមានចរិក ២យ៉ាង។ ទី១ គឺជាការប្រកួតប្រជែងដណ្តើមកៅអីក្នុងសភា (ដែលការប្រកួតប្រជែង)នេះប្រព្រឹត្តទៅក្នុងសភាពការណ៍ស្ងប់ស្ងាត់ល្អប្រសើរ។ ប៉ុន្តែ **អ្វីដែលជាការប្រកួតប្រជែងពិតប្រាកដ (ទី២) គឺរវាងអ្នកគាំទ្រការបោះឆ្នោតនិងប្រជាធិបតេយ្យតាមរយៈការបោះឆ្នោត និងម្ខាងទៀតអ្នកបំផ្លាញប្រជាធិបតេយ្យ ដោយការរារាំងមិនឲ្យទៅបោះឆ្នោត គូសបំផ្លាញសន្លឹកឆ្នោត។ សរុបមកគឺបំផ្លាញចោលការបោះឆ្នោត។** នេះទើបជាការតស៊ូពិតប្រាកដក្នុងការបោះឆ្នោតកន្លងទៅនេះ។ រយៈពេលកន្លងទៅ ... (ទោះបីមាន) យុទ្ធនាការឲ្យប្រជាជនកុំទៅបោះឆ្នោតយ៉ាងណាក្តី ប្រជាជនរហូតដល់ ៨៤ភាគរយ

បានទៅបោះឆ្នោត។ មានន័យថាម៉េច? អ្នកឯងឲ្យធ្វើយុទ្ធនាការ(បំផុសអ្នកបោះឆ្នោត)គួសបំផ្លាញសន្លឹកឆ្នោតចោល (តែ)សន្លឹកឆ្នោតដែលខូចមានត្រឹមតែជាង ៥ភាគរយ ប្រៀបធៀបជាមួយនឹងឆ្នាំ ២០១៨ (ដែលមាន)ខូចជាង ៨ភាគរយ ...៕

៣១. តើ៦៥ប្រទេស/សញ្ជាតិប្រកាសពីភាពត្រឹមត្រូវនៃការបោះឆ្នោតនៅកម្ពុជាជាអ្វី?

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវក្រវ៉ាត់ក្រុងទី៣ ប្រវែង ៥២គីឡូម៉ែត្រ, ៣ សីហា ២០២៣

... ឥឡូវលទ្ធផលបានបង្ហាញច្បាស់ហើយ។ ប្រជាជនបានចូលរួមបោះឆ្នោតបានបោះឆ្នោតជ្រើសរើសគាំទ្រដំណើរការប្រជាធិបតេយ្យនៅកម្ពុជាជាទៀងទាត់ដែលយើងត្រូវការបោះឆ្នោត ៥ឆ្នាំម្តង។ "នៅកម្ពុជាគ្មានការបោះឆ្នោតមុនការកំណត់ទេ" **ខ្ញុំបានប្រាប់ទៅកាន់អ្នកសង្កេតការទាំងឡាយដែលមកពីជាង ៦៥ ប្រទេស ឬសញ្ជាតិ។ តើ ៦៥សញ្ជាតិនេះ មកកាន់កម្ពុជាតំណាងឲ្យអ្វី? តើនេះហៅថាជាសហគមន៍អន្តរជាតិទេ? ... ប្រទេស១ ឬប្រទេស២ កុំតាំងខ្លួនជាសហគមន៍អន្តរជាតិ។ មិនត្រឹមត្រូវទេ។ ចំនួនភាគច្រើនជាង ៦០សញ្ជាតិបានមកកាន់ទឹកដីកម្ពុជាប្រកាសអំពីភាពត្រឹមត្រូវនៃការបោះឆ្នោតនៅកម្ពុជា។** អញ្ចឹង មនុស្សមួយចំនួនមិនយកប្រទេសមួយឬពីរធ្វើជាសហគមន៍អន្តរជាតិអ្វីឡើយ ...៕

៣២. "ប្រជាធិបតេយ្យនៅកម្ពុជាបានឈ្នះហើយ"

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវក្រវ៉ាត់ក្រុងទី៣ ប្រវែង៥២ គីឡូម៉ែត្រ, ៣ សីហា ២០២៣

...អ្នកមិនពេញចិត្តគឺជារឿងរបស់អ្នក។តែសម្រាប់អ្នកដែលពេញចិត្ត សូមទុកសិទ្ធិឲ្យគេពេញចិត្ត ហើយកុំយកប្រទេសមួយឬប្រទេសពីរ ឬបីបួនមកធ្វើជាសហគមន៍អន្តរជាតិ។ សហគមន៍អន្តរជាតិទាល់តែសម្លេងភាគច្រើននៅមហាសន្និបាតអង្គការសហប្រជាជាតិបានគេហៅថាសហគមន៍អន្តរជាតិ។ បើនិយាយពីកិច្ចការផ្ទៃក្នុងរបស់ប្រទេសមួយគឺមិនអាចជ្រៀតជ្រែកទេ។ ទីបំផុត **ខ្ញុំអាចប្រកាសបានថា ប្រជាធិបតេយ្យនៅកម្ពុជាបានឈ្នះហើយ។ យើងអនុវត្តការបោះឆ្នោតទៀងទាត់ ក្នុងនោះនាយករដ្ឋមន្ត្រីគ្មានសិទ្ធិរំលាយសភាទេ។** រដ្ឋធម្មនុញ្ញបានចងយ៉ាង

ច្បាស់ថា សភាមានអាណត្តិ ៥ឆ្នាំ។ សភាមិនអាចរំលាយមុនអាណត្តិបានទេ លើកលែងរាជរដ្ឋាភិបាលត្រូវរំលាយ ២ដងក្នុងរយៈពេល ១២ខែ ...៕

៣៣. ប្រជាធិបតេយ្យឬមិនប្រជាធិតេយ្យ អាស្រ័យលើអ្នកទៅ ឬមិនទៅបោះឆ្នោត

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវក្រវ៉ាត់ក្រុងទី៣ ប្រវែង ៥២គីឡូម៉ែត្រ, ៣ សីហា ២០២៣

... ច្បាប់បោះឆ្នោតបានបញ្ជាក់យ៉ាងច្បាស់ថា រៀងរាល់ ៥ឆ្នាំម្តង នាថ្ងៃអាទិត្យសប្តាហ៍ទី៤ ខែកក្កដា ត្រូវធ្វើការបោះឆ្នោត។ នាយករដ្ឋមន្ត្រីគ្រាន់តែចេញសេចក្តីសម្រេចពីកាលបរិច្ឆេទផ្អែកទៅតាមរដ្ឋធម្មនុញ្ញ និងផ្អែកទៅលើច្បាប់បោះឆ្នោត ... **រឿងគេថាគណបក្សនយោបាយ១ ឬ២ មិនបានចូលរួម (ធ្វើឲ្យការបោះឆ្នោត) មិនប្រជាធិបតេយ្យ។ អ្នកឯងគិតខុសហើយ។ ប្រជាធិបតេយ្យ ឬមិនប្រជាធិតេយ្យគឺអាស្រ័យលើប្រជាជនទៅ ឬមិនទៅបោះឆ្នោត ដែលខ្ញុំនិយាយថាដំណើរការពិតប្រាកដនៃប្រជាធិបតេយ្យនៅកម្ពុជា គឺលើកនេះការបោះឆ្នោតស្តែងឡើងវាងម្ខាងអ្នកចង់បានលទ្ធិប្រជាធិបតេយ្យតាមរយៈការបោះឆ្នោត និងម្ខាងទៀតបំផ្លាញប្រជាធិបតេយ្យតាមរយៈបំផ្លាញចោលការបោះឆ្នោត** ...៕

៣៤. ទោះមិនជានាយករដ្ឋមន្ត្រី ក៏បន្តគ្រប់គ្រងនយោបាយក្នុងឋានៈជាប្រធានគណបក្ស

សំណេះសំណាលជាមួយកម្មកររោងចក្រនៅស្រុកក្រគរ ខេត្តពោធិ៍សាត់, ៣០ មិថុនា ២០២៣

... គ្មាននរណាមួយអាចរាំងដំណើរឈានទៅមុខរបស់ ហ៊ុន សែន ឬដំណើរឈានទៅមុខរបស់ ហ៊ុន ម៉ាណែត បានទេ។ **បើទោះបីជា ហ៊ុន សែន មិនធ្វើនាយករដ្ឋមន្ត្រី ក៏ប៉ុន្តែការគ្រប់គ្រងខាងនយោបាយគឺនៅលើដៃ ហ៊ុន សែន ក្នុងឋានៈជាប្រធានគណបក្សកាន់អំណាច ... សូមកុំមានការបារម្ភ** ...អស់ពី ហ៊ុនសែន នៅមាន ហ៊ុន ម៉ាណែត។ កុំចង់កម្ចាត់ត្រកូល ហ៊ុន ឲ្យសោះ។ អ្នកគាំទ្រត្រកូល ហ៊ុន មានមួយប្រទេស ... តែគាំទ្រ/ស្រឡាញ់ឪពុក គេគាំទ្រ/ស្រឡាញ់កូន វៀរលែងតែកូនធ្វើផ្តេសផ្តាស ...នៅថៃ គេស្រឡាញ់ ថាក់ស៊ីន បន្ទាប់ទៅគេស្រឡាញ់យីងឡាក់ ជាប្អូនរួចទៅគេស្រឡាញ់កូន ថាក់ស៊ីនទៀត ...៕

៣៥. មិនមានរដ្ឋធម្មនុញ្ញឬច្បាប់កំណត់ឲ្យរាជរដ្ឋាភិបាលទៅពិគ្រោះនឹងសង្គមស៊ីវិលទេ

សំណេះសំណាលជាមួយកម្មកររោងចក្រនៅស្រុកក្រគរ ខេត្តពោធិ៍សាត់, ៣០ មិថុនា ២០២៣

... មើលច្បាប់ដែលសភាបានបោះឆ្នោត(អនុម័ត) ... ក្រៅពីពង្រឹងការទទួលខុសត្រូវនៃអ្នកឈរឈ្មោះ សូមពិនិត្យមើលផ្នែកទោសទណ្ឌ (ដែល)នៅមានការកាត់សិទ្ធិនយោបាយមិនឲ្យចូលរួមបោះឆ្នោត អាចថាមួយជីវិតថែមទៀត ... នេះមិនមែនជាការកាត់សិទ្ធិពលរដ្ឋ តែដើម្បីការពារភាពសុខសាន្តរបស់ប្រជាពលរដ្ឋ និងដំណើរការអនុវត្តសិទ្ធិរបស់ប្រជាពលរដ្ឋទៅវិញទេ ... ពួកលោកឯងចង់ធ្វើជាអង្គការក្រៅរដ្ឋាភិបាល ចាត់តាំងគ្នាខ្លួនឯង ៣ទៅ ៤នាក់ មកធ្វើជាអ្នកការាំងមន្ត្រីជាប់ឆ្នោតចេញពីសភានិងព្រឹទ្ធសភា ដែលសុទ្ធតែជាមន្ត្រីជាប់ឆ្នោតតំណាងឲ្យពលរដ្ឋ ... **អ្នកខ្លះថាធ្វើហ្នឹងខុសនីតិវិធីដោយមិនបានពិគ្រោះនឹងសង្គមស៊ីវិល។ ខ្ញុំគ្រាន់តែសូមប្រាប់អ្នកឯងថា រដ្ឋធម្មនុញ្ញឬច្បាប់ណាក៏ដោយមិនបានកំណត់ថា ឲ្យរាជរដ្ឋាភិបាលទៅពិគ្រោះជាមួយសង្គមស៊ីវិលទេ** ...៕

៣៦. ជនក្បត់ជាតិ ៣ជំនាន់ ចុះហត្ថលេខាសន្យាផ្តល់ដីដល់រដ្ឋ Degar

សំណេះសំណាលជាមួយកម្មកររោងចក្រនៅក្បែរវត្តព្រៃស្តី ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ, ២៨ មិថុនា ២០២៣

... (ជ្រូន)វាមក(ហោះចូលទឹកដីកម្ពុជា)។ ខ្ញុំជឿថា(ជ្រូន)នេះមកធ្វើទំនាក់ទំនងជាមួយកម្លាំងបាក់ទ័ពដែលរត់ពីវៀតណាមមកនៅក្នុងដីខ្មែរ។ វាគ្មានហេតុផលបញ្ជូនជ្រូនហ្នឹងមកទេ។ ពួកនេះវាឱ្យសញ្ញា។ ថ្ងៃមុន មានករណីដែលយើងដេញតាម។ មានម្នាក់រត់ធ្លាក់ទូរស័ព្ទ ... យើងក៏លើកស្តាប់។ និយាយចេញពីវៀតណាម។ ជាសម្លេងជនជាតិភាគតិច។ **សូមបញ្ជាក់ជូនបងប្អូនជនរួមជាតិ នេះ(ជាក្រុមកុកស)ដែលមកក្បត់ជាតិ ៣ជំនាន់ចុះហត្ថលេខាជាមួយ។ នេះគឺពួក Degar ហ្នឹងឯង។ ត្រូវតែកាត់ទោសជនក្បត់ជាតិ ៣ជំនាន់ដែលចុះហត្ថលេខាជាមួយរដ្ឋ Degar។ ហ្នឹងគឺកម្លាំង FULRO រួចហើយខំមកនិយាយថាប្រគល់សិទ្ធិឲ្យជនជាតិដើមភាគតិច**។ ឥឡូវជនជាតិដើមភាគតិចនៅកន្លែងណា? មើលពីក្រោយខ្នងកុកសនិងជនក្បត់ជាតិ ៣ជំនាន់ មានទង់ជាតិអាមេរិកមួយ ទង់ជាតិ

ខ្មែរមួយ និងមានទង់ជាតិ Degar មួយ ...៕

៣៧. កុកស ងាប់ តែកិច្ចព្រមព្រៀងរវាងជនក្បត់ជាតិ ៣ជំនាន់ និង Degar ងាប់ឬទេ

សំណេះសំណាលជាមួយកម្មកររោងចក្រនៅក្បែរវត្តព្រៃស្តី ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ, ២៨ មិថុនា ២០២៣

... កុំថាជារឿងនយោបាយឱ្យសោះ។ រឿងក្បត់ជាតិពេញទី។ ខ្ញុំសូមព្រមានម្តងហើយម្តងទៀត អ្នកដែលពាក់ព័ន្ធនឹងជនក្បត់ជាតិនេះ (យើងចាំបាច់)ត្រូវមានវិធានការ។ **លើការជាក់ស្តែង កុក ស ងាប់បាត់ហើយ ប៉ុន្តែ តើកិច្ចព្រមព្រៀងរវាង(ជនក្បត់ ៣ជំនាន់និងរដ្ឋDegar)ងាប់ឬអត់។ យ៉ាងណាក៏ដោយ សក៏ដោយខ្មៅក៏ដោយវាយទាំងអស់។ ដីនេះជាដីរបស់ខ្មែរអត់មានត្រូវកាត់ឱ្យអ្នកណាទេ។ ជនជាតិដើមភាគតិចរបស់កម្ពុជាមានគ្រប់គ្រាន់ហើយ**។ បងប្អូនជនជាតិភាគតិចរស់នៅតាមភូមិ តាមឃុំ នៅខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ។ ព្រះវិហារក៏មានបងប្អូនជនជាតិភាគតិច ... Degar បង្កើតជារដ្ឋមួយ។ មានទង់ជាតិរបស់វា។ រឿងអី(ដែលត្រូវ)ទៅចុះហត្ថលេខា? ដល់តែគេកាត់ទោស តាំងថាហ្នឹងជារឿងនយោបាយ។ មិនទាន់បានកាន់អំណាចផង ចុះហត្ថលេខាឱ្យដីគេ ៤ខេត្ត។ នេះជាអំពើក្បត់ជាតិ មិនអាចអត់ឱនឱ្យបាន ...៕

៣៨. មនុស្សចិត្តធ្ងន់ក្នុងការសម្រេចចិត្តខាងនយោបាយទាក់ទងនឹងជីវិតជាតិ

ក្នុងឱកាសខួបទី៤៦ ទិវានៃការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ២០ មិថុនា ១៩៧៧-២០២៣, ២០ មិថុនា ២០២៣

... ថ្ងៃនេះខ្ញុំបានទម្លាយបន្ថែមនូវអ្វីដែលបានកើតក្នុងព្រឹត្តិការណ៍ រាប់ទាំងការបញ្ចេញឈ្មោះនិងតួអង្គ ដែលមានការពាក់ព័ន្ធទៅនឹងសោកនាដកម្មក្នុងជីវិតរបស់ខ្ញុំ។ ពេលខ្លះ ប្រសិនបើខ្ញុំគ្មានការអត់ធ្មត់គ្រប់គ្រាន់ (ស្ថានការណ៍អាចនឹងមានភាពស្មុគស្មាញ)។ តើមនុស្សមួយចំនួនអាចនឹងធ្វើ(ការអត់ធ្មត់ដូចខ្ញុំ)បានទេ ... **ខ្ញុំទទួលស្គាល់ខ្លួនឯងថាជាមនុស្សឆេវឆាវ ប៉ុន្តែការសម្រេចចិត្តខាងនយោបាយ គឺខ្ញុំជាមនុស្សចិត្តធ្ងន់បំផុត។ អ្នកទាំងអស់គ្នាអាចមើលឃើញហើយ តើខ្ញុំដែលបានសម្រេចចិត្តខាងនយោបាយ តាមរបៀបឆេវឆាវពាក់ព័ន្ធនឹងដំណើរផែល**

ប្រយោជន៍ជាតិទេ? (ពិតជា)អត់ទេ។ ខ្ញុំទទួលស្គាល់ខ្លួនឯងថាជាមនុស្សឆេវឆាវ ប៉ុន្តែការសម្រេចចិត្តខាងនយោបាយទាក់ទងនឹងជីវិតជាតិគឺមិនឆេវឆាវទេ។ អ្នកដទៃមិនអាចចិត្តធ្ងន់ដូច ហ៊ុន សែន ទេ ...។

៣៩. គណបក្សប្រជាជនមានយុវជនរាប់រយរាប់ពាន់នាក់បន្តវេនតាមថ្នាក់

បិទកិច្ចប្រជុំបូកសរុបសកម្មភាពនិងលទ្ធផលការងារ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានីខេត្ត នីតិកាលទី៦ នៃរដ្ឋសភានិងទិសដៅបន្ត, ១៩ មិថុនា ២០២៣

... ឥឡូវ (ជំនាន់នេះមាន)អាយុសុទ្ធតែជាង ៧០ហើយ។ សល់ ៥ឆ្នាំប៉ុន្មានដងទៀត? **មុខពួកអ្នកឯង មិនមានអ្នកបន្តវេនទេ។ ប្រៀបធៀបនឹងគណបក្សប្រជាជនមានយុវជនរាប់រយរាប់ពាន់នាក់បន្តវេនតាមថ្នាក់។ តើពួកឯងមានប៉ុន្មាននាក់ទៅដើម្បីបន្តវេន?** ... បន្ទាប់ពីការប៉ុនប៉ងបំផ្លាញការដំណើរការរបបរំលាត់ កុំទុកពេលឱ្យក្រុមនេះបន្តបំផ្លាញតទៅទៀត។ តែច្បាប់ហ្នឹងចេញហើយ គឺគណបក្សដែលនៅទីក្រុងភ្នំពេញ សុំឱ្យប្រយ័ត្ន។ ការនិយាយស្តីគឺឱ្យត្រឹមត្រូវ។ កុំនិយាយញើវញែតទៅទៀត។ ទៅនិយាយអួតអាងអញ្ចេះ/អញ្ចុះ និយាយយូរៗវាត្រូវតែខ្លួនឯង ...។

៤០. ការបញ្ជូនមន្ត្រីចុះមូលដ្ឋានត្រូវបានអនុវត្តតាំងពីឆ្នាំ១៩៨២

បិទកិច្ចប្រជុំបូកសរុបសកម្មភាពនិងលទ្ធផលការងារ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានីខេត្ត នីតិកាលទី៦ នៃរដ្ឋសភានិងទិសដៅបន្ត, ១៩ មិថុនា ២០២៣

... ហាក់ដូចជាការគាប់ជួន ឬដើរត្រូវទិសតាំងពីដំណាក់កាលដំបូង។ ប្រហែលជាលោកលោកស្រីមួយចំនួននៅចាំបាន។ **យើងបានពង្រាយមន្ត្រីចុះមូលដ្ឋានតាំងពីឆ្នាំ១៩៨២** ... ពេលនោះ ខ្ញុំនៅកាន់ក្រសួងការបរទេស។ បន្តមក យើងបានបញ្ជូនមន្ត្រីមន្ត្រីទៅកាន់មុតំណែងជាអភិបាលរងស្រុក ឬប្រធានស្រុក។ សូម្បីមន្ត្រីការទូត មុននឹងបញ្ជូនទៅធ្វើទូតត្រូវចុះមូលដ្ឋាន។ ឧទាហរណ៍មន្ត្រីនៅក្រសួងការបរទេសដូចជា ឯកឧត្តម សៀង គឹមហ៊ន់ លោក ភី ថាច ជាដើម យើងបានបញ្ជូនចុះមូលដ្ឋាន។ ម្ខាងទៀត **ការផ្តល់អំណាចទៅមូលដ្ឋានមានតាំងពីដំណាក់កាលមុន ប៉ុន្តែត្រូវបានបំផ្លាញដោយអ្នកដែលមានចេតនាបំផ្លាញ។**

(ដោយហេតុនេះ)បានជាយើងត្រូវធ្វើការប្រគល់អំណាចទៅឲ្យមូលដ្ឋានឡើងវិញ ...។

៤១. គណបក្សប្រជាជនមានផែនទីចង្អុលផ្លូវ ដែលមិនធ្វើឱ្យបាត់ម្ចាស់ការម្តងណាទេ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ផ្លូវជាតិលេខ៣, ២៧ ធ្នូ ២០១៧

... អ្នកនៅខាងលើ(វេទិកានេះ)មួយចំនួន មិនអាចរស់បានដល់ឆ្នាំ២០៥០ ឬមិនអាចរស់បានរហូតទៅដល់ឆ្នាំ២០៣០ ក៏ដោយចុះ ក៏ប៉ុន្តែវា**ត្រូវតែមានផែនទីចង្អុលផ្លូវសម្រាប់ប្រទេស មិនមែនជានយោបាយកញ្ជក់កណ្តៀតតាមដងវិថីយោសនាបោះឆ្នោតនោះទេ។ គណបក្សប្រជាជនកម្ពុជាបានដាក់ចេញនូវក្របខណ្ឌគោលនយោបាយរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ដូច្នេះហើយ បានជាគេឃើញថា ទោះបីស្ថានការណ៍យ៉ាងណាក៏ដោយ មិនថាការរាប់រងហានិភ័យប្រភេទណា បណ្តាលពីអ្វី រាប់ទាំងពីគ្រោះធម្មជាតិ គណបក្សប្រជាជនមិនដែលបាត់ម្ចាស់ការនោះទេ**។ ដូចជាក្នុងគ្រោះធម្មជាតិឆ្នាំ២០០០ ហៅថាគ្រោះទឹកជំនន់សហស័ត្ស៍ ដែលជាងពាក់កណ្តាលផ្ទៃប្រទេសរងគ្រោះ យើងនៅតែម្ចាស់ការចិញ្ចឹមប្រជាពលរដ្ឋបាន មិនទុកឲ្យប្រជាពលរដ្ឋរបស់យើងណាម្នាក់ស្លាប់ដោយអត់បាយដែលយើងមិនបានដឹងនិងមិនបានដោះស្រាយនោះទេ ...។

៤២. មានផែនទីចង្អុលផ្លូវ/ហដ្ឋារចនាសម្ព័ន្ធ អ្វីដែលត្រូវធ្វើគឺកែតម្រូវតាមសភាពការណ៍

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ផ្លូវជាតិលេខ៣, ២៧ ធ្នូ ២០១៧

... នោះហើយជាកិច្ចការនិងការរៀបចំក្របខណ្ឌគោលនយោបាយជាយុទ្ធសាស្ត្រ ទាំងខាងនយោបាយ ទាំងខាងសេដ្ឋកិច្ចក្តី និងខាងសង្គម ... **បើទោះបីថាខ្លួនខ្ញុំស្លាប់ ឬមេដឹកនាំគណបក្សប្រជាជន(ជំនាន់មុន)ស្លាប់ ក៏នឹងបន្សល់ទុកផែនទីចង្អុលផ្លូវ ... ដែលគ្រាន់តែធ្វើការកែតម្រូវឲ្យស្របនឹងសភាពការណ៍(រាប់ថាជាការស្រេច) ... គោលដៅដែលបានដាក់ចេញនោះ មានហេដ្ឋារចនាសម្ព័ន្ធនានាទ្រទ្រង់រួចហើយ**។ ឧទាហរណ៍ យើងបានធ្វើផ្លូវ យើងបានធ្វើស្ពាន យើងបានធ្វើស្ពានមិនត្រឹមតែស្ពានឆ្លងព្រែក ឆ្លងកូនព្រែកនោះទេ ក៏ប៉ុន្តែយើងបានធ្វើស្ពានឆ្លងដៃសមុទ្រ ឆ្លងទន្លេមេគង្គ ទន្លេសេកុង ទន្លេសាប ទន្លេបាសាក់រួចរាល់។ អ្នក

បន្តវេនបន្តទៅក្រោយនឹងមិនវាយបំបាក់ស្ពានទាំងនោះទេ ...។

៤៣. ទៅខ្សែត្រៀម ទៅតុចរចាគ្រប់កន្លែង និងនៅវាលស្រែជាមួយកសិករ

សំណេះសំណាលជាមួយកម្មករ និយោជិត តំបន់ទួលពង្រ, ២០ ធ្នូ ២០១៧

... ការចាប់ផ្តើមរបស់យើងលំបាក។ ពេលមុន ក្មួយៗប្រហែលជាមើលរូបថត **សកម្មភាពរបស់ពូនៅខ្សែត្រៀមជួរមុខ ដើម្បីដោះស្រាយការលំបាកក្នុងពេលមានសង្គ្រាមរបស់កងទ័ព និងប្រជាជននៅតំបន់សមរភូមិ ដើម្បីទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ក្នុងពេលជាមួយគ្នា គេក៏បានឃើញវត្តមានរបស់ពូនៅតាមតុចរចាឯនៅក្រៅប្រទេសគ្រប់ទីកន្លែង ដើម្បីស្វែងរកដំណោះស្រាយ(នយោបាយ)បញ្ចប់ការបែកបាក់ បញ្ចប់ការធ្វើសង្គ្រាមបង្ហូរឈាមគ្នា។ បន្ទាប់ទៅ គេបានឃើញវត្តមានរបស់ពូនៅតាមវាលស្រែជាមួយកសិករ ក្នុងការធ្វើប្រព័ន្ធប្រឡាយទឹក ការធ្វើទំនប់ទឹក និងការជាំជុះដទៃទៀត** ... យើងបានឆ្លងកាត់ដោយជោគជ័យពីស្ថានភាពប្រទេសមួយ ដែលមានប្រជាជនត្រឹមតែជាង ៥លាននាក់ ហើយខ្វះស្បៀង មកមានប្រជាជនជាង ១៥លាននាក់ និងសល់ស្រូវជាង ៥លានតោនសម្រាប់ការនាំចេញ ...។

៤៤. ស្រុកស្ទឹងត្រង់ផលិតនាយករដ្ឋមន្ត្រី៣ ដែលនាយករដ្ឋមន្ត្រីពីរប្រឆាំងរាជានិយម

បើកការដ្ឋានសង់ស្ពានឆ្លងកាត់ទន្លេមេគង្គ ពីស្ទឹងត្រង់ទៅក្រូចឆ្មារ, ៩ កុម្ភៈ ២០១៨

... **ស្រុកស្ទឹងត្រង់បង្កើតនាយករដ្ឋមន្ត្រីបានច្រើនជាងគេ។ មាននាយករដ្ឋមន្ត្រី ៣ ដែលបានកើតនៅស្រុកស្ទឹងត្រង់។ ទីមួយ អិន តាំ, ទីពីរ ហង្ស ធុនហាក់ ដោយអ្នកទាំងពីរនាក់ហ្នឹងជាអ្នកសាធារណរដ្ឋ ដែលផ្តួលរំលំសម្តេច ព្រះនរោត្តម សីហនុ** ... ឯនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺខុសពីអ្នកទាំងពីរហ្នឹង។ ស្រុកស្ទឹងត្រង់ផលិតនាយករដ្ឋមន្ត្រីបានច្រើនជាងគេ បើប្រៀបធៀបទៅនឹងស្រុកនានានៅទូទាំងប្រទេស។ នាយករដ្ឋមន្ត្រី អិន តាំ ដូចជាកាន់តំណែងបាន ២ឆ្នាំ បន្ទាប់ទៅ ហង្ស ធុនហាក់ (ដែលត្រូវ) ប៉ុល ពត សម្លាប់ ... ធ្វើការជាមួយព្រះករុណាសុខៗ ទៅរួមដៃគ្នាស្តាប់បរទេសធ្វើរដ្ឋប្រហារទម្លាក់ព្រះករុណា។ កម្មពៀរដល់។ ឯរឿងរបស់ខ្ញុំវាផ្សេង។ មានរដ្ឋប្រហារភ្លាម ព្រះករុណាអំពាវនាវឲ្យចូលព្រៃម៉ាគី (ខ្ញុំ)ទៅ

នឹងគេ ហើយបានរស់រានមានជីវិតដល់ឥឡូវ។ គ្រាន់តែអស់ភ្នែកម្ខាងដែរ របួសប្រាំលើក ប៉ុន្តែសុខភាពនៅល្អទេ ...។

៤៥. នាយករដ្ឋមន្ត្រី ហ៊ុន សែន ដឹកនាំបានយូរ ព្រោះមិនក្បត់ព្រះមហាក្សត្រ

សម្ពោធដាក់ឱ្យប្រើប្រាស់នូវស្ពានមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រង់-ក្រូចឆ្មារ និង ការប្រកាសបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ 71C, ២៣ វិច្ឆិកា ២០២១

... តំបន់(ស្ទឹងត្រង់)នេះ ផលិតនាយករដ្ឋមន្ត្រី ៣នាក់ ... នាយករដ្ឋមន្ត្រី អិន តាំ នាយករដ្ឋមន្ត្រី ហង្ស ធុនហាក់ និងនាយករដ្ឋមន្ត្រី ហ៊ុន សែន ... ប៉ុន្តែ នាយករដ្ឋមន្ត្រី ២នោះ ក្បត់ម្ចាស់។ អិន តាំ ព្រះករុណាគាំទ្រឲ្យធ្វើចៅហ្វាយខេត្តតាំងពីកំពង់ចាមឡាក់ទៅដល់បាត់ដំបង។ ក្រោយមកធ្វើរដ្ឋមន្ត្រី ... និងរួមចំណែកទម្លាក់ព្រះករុណាបិតា។ ហង្ស ធុនហាក់ ក៏អញ្ចឹង។ **ហ៊ុន សែន អត់អញ្ចឹងទេ។ ហេតុនេះហើយបានជា ហ៊ុន សែន នៅបានយូរ។ ខ្ញុំមិនបានក្បត់។ ព្រះករុណាបិតា អំពាវនាវឲ្យកូនចៅចូលព្រៃម៉ាគី។ ហ៊ុន សែន ទៅតាមការអំពាវនាវ។** ខ្ញុំអត់មានត្រូវបណ្តាសាព្រះទេ។ ឥឡូវ ជីតាអាយុ ៩៣ ជីដូនអាយុ ៩២ ទើបមរណភាពពីឆ្នាំ ១៩៩១ ...។

៤៦. ពី ៨មករា ១៩៧៩ មកដល់ថ្ងៃ ១៣កុម្ភៈ ២០១៨ នៅក្នុងរដ្ឋាភិបាលមិនដាច់រយៈ

ចែកសញ្ញាប័ត្រសាកលវិទ្យាល័យវេស្ទឹន, ១៣ កុម្ភៈ ២០១៨

... **ខ្លួនខ្ញុំផ្ទាល់នៅក្នុងរដ្ឋាភិបាលយូរជាងគេ ហើយក៏មានតែមនុស្សម្នាក់គត់ដែលនៅក្នុងរដ្ឋាភិបាលរយៈពេល ៣៩ឆ្នាំជាង យូរជាងគេទាំងអស់។ មនុស្សដែលមិនចង់ធ្វើបែរជាធ្វើកន្លែងហ្នឹង**។ ថ្ងៃ ៧ ខែមករា ឆ្នាំ ១៩៧៩ យើងរំដោះប្រទេស។ ថ្ងៃ ៨ ខែមករា មានការចាត់តាំងរដ្ឋាភិបាល ដែលហៅថាក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា។ ក្នុងកិច្ចពិភាក្សារៀបចំរដ្ឋាភិបាល ខ្ញុំត្រូវបានប្រគល់ភារកិច្ចឱ្យធ្វើជារដ្ឋមន្ត្រីការបរទេស។ ខ្ញុំបានប្រាប់ថ្នាក់ដឹកនាំ ក្នុងនោះមាន សម្តេច ជា ស៊ីម, សម្តេច ហេង សំរិន ថា “ខ្ញុំមិនដែលស្គាល់កិច្ចការបរទេសទេ ... ខ្ញុំមិនធ្វើទេ” ខ្ញុំប្រកែក។ ពេលនោះ បើមិនបង ហេង សំរិន គឺបង ជា ស៊ីម និយាយថា “បើ សែន ឯងមិនធ្វើទេ មានតែឲ្យ អៀង សារី ធ្វើវិញ?” ... **ខ្ញុំសុខចិត្តធ្វើ ៣ខែ ... ប៉ុន្តែ ចាប់ពី**

ថ្ងៃ ៨ មករា (១៩៧៩) រហូតមកដល់ថ្ងៃ ១៣ កុម្ភៈ ២០១៨ គឺ ៣៩ ឆ្នាំជាង ខ្ញុំជាមនុស្សតែម្នាក់គត់ដែលនៅក្នុងរដ្ឋាភិបាលមិនជាច់រយៈ ...។

៤៧. សមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវប្រជាធិបតេយ្យប្រមូលផ្តុំ ភាគតិចគោរពភាគច្រើន

តំណាងទូទាំងប្រទេសលើកទី៤ របស់សហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក), ២៧ វិច្ឆិកា ២០១៨

... យើងប្រើពាក្យថា "សមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវ ប្រជាធិបតេយ្យប្រមូលផ្តុំ ភាគតិចគោរពភាគច្រើន"។ ខ្លះថា ភាសានេះ គឺជាភាសាកុម្មុយនីស្ត។ ក៏ប៉ុន្តែខ្ញុំចង់និយាយទៅអស់លោកអ្នកនិយាយនោះថា ... បើមិនផ្អែកលើសម្លេងភាគតិចគោរពភាគច្រើនទេ តើវាជាប្រជាធិបតេយ្យឬទេ? តើប្រទេសទាំងអស់មានការចាំបាច់ធ្វើការបោះឆ្នោតឬទេ បើសម្លេងភាគច្រើនបែជាត្រូវគោរពភាគតិចនោះ។ **គេបើកឱ្យមានការបោះឆ្នោត ដើម្បីអ្នកបានសម្លេងភាគច្រើនជាអ្នកដែលឈ្នះឆ្នោត។ ដូច្នេះហើយទើបបានជាប្រើពាក្យថាប្រជាធិបតេយ្យត្រូវតែមានការប្រមូលផ្តុំ ឬប្រមូលផ្តុំប្រជាធិបតេយ្យ។** ឧទាហរណ៍ ការអនុម័តណាមួយត្រូវលើកមកដាក់លើតុជជែកគ្នា ...។

៤៨. ប្រជាធិបតេយ្យប្រមូលផ្តុំ គឺប្រមូលផ្តុំធ្វើតាមការសម្រេចរបស់សម្លេងភាគច្រើន

តំណាងទូទាំងប្រទេសលើកទី៤ របស់សហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក), ២៧ វិច្ឆិកា ២០១៨

... (ការអនុម័តណាមួយត្រូវលើកមកដាក់លើតុជជែកគ្នា) ដូចជាថាតើគួរដាំពោត គួរដាំផ្តា ឬគួរដាំបន្លែណាផ្សេង។ តើភាគច្រើនយកការសម្រេចចិត្តណាមួយ? បើសម្រេចចិត្តថាត្រូវដាំផ្តា ច្បាស់ណាស់អ្នកដែលថាដាំពោតអ្នកដែលថាដាំដំណាំដទៃទៀត **ត្រូវតែ(គោរពនិង)ប្រមូលផ្តុំគ្នាមកដាំផ្តាដែល(ជាការសម្រេចរបស់)សម្លេងភាគច្រើន គឺជាការប្រមូលផ្តុំសម្លេងមកដាំផ្តា។ នោះហើយដែលហៅថា "ប្រមូលផ្តុំប្រជាធិបតេយ្យ" មិនអាចទុកឱ្យមតិ៣ នៅតែជាមតិដែលវាខ្វែងគ្នាក្នុងពេលអនុវត្ត ដោយមួយទៅឆ្វេងមួយទៅស្តាំនោះទេ** ... បើទោះបីជាអ្នកនៅបក្សដទៃមិនប្រើប្រាស់ហើយចំអកឡកឡើយយ៉ាងណាក្តី ក៏សូម

សមាជិក/ជិកានៃគណបក្សប្រជាជនកម្ពុជាក្តាប់បទពិសោធន៍ពីប្រមូលផ្តុំប្រជាធិបតេយ្យ ឬប្រជាធិបតេយ្យប្រមូលផ្តុំនេះឲ្យបាន ដោយមិនត្រូវទុកឱ្យមានការបែកខ្ញែកក្រៅអង្គប្រជុំទេ ...។

៤៩. សមូហភាពដឹកនាំតាមកម្មវិធីនយោបាយ បុគ្គលទទួលខុសត្រូវចំពោះសកម្មភាព

តំណាងទូទាំងប្រទេសលើកទី៤ របស់សហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក), ២៧ វិច្ឆិកា ២០១៨

... ក្នុងផ្នែករដ្ឋ ខ្ញុំមិនអាចទៅសុំមតិរបស់គណបក្សលើរឿងដែលគណបក្សបានផ្តល់ការឯកភាពរួចហើយ តាមរយៈក្របខ័ណ្ឌគោលនយោបាយ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញនៅមុនការបោះឆ្នោត និងដែលបានដាក់ឆ្លងកាត់សភាទេ។ **នាយករដ្ឋមន្ត្រីត្រូវយកការសម្រេចចិត្តទទួលខុសត្រូវចំពោះមុខគណបក្ស។ ហ្នឹងជាទិដ្ឋភាពផ្ទៃក្នុង។ ក៏ប៉ុន្តែ(ស្របពេលគ្នានោះ ក៏)ត្រូវទទួលខុសត្រូវចំពោះមុខសភាពីសកម្មភាពរបស់ខ្លួនខាងផ្នែករដ្ឋ។ រដ្ឋមន្ត្រីមួយៗត្រូវទទួលខុសត្រូវតាមមុខនាទីរបស់ខ្លួនដែលច្បាប់បានកំណត់ឱ្យ។ នោះហើយដែលចង្អុលបង្ហាញពីរបៀបសមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវ ...។**

៥០. កុំរង់ចាំដល់សង្គ្រាមកើតឡើង ទើបស្វែងរកនិងស្រែកថាសន្តិភាពមានតម្លៃ

អភិសេករូបសំណាកព្រះថោងនាងនាគ ក្រុងព្រះសីហនុ, ១៦ មេសា ២០២២

... កាលពី ៤៧ឆ្នាំមុន គឺថ្ងៃ ១៦មេសា ១៩៧៥ គឺជាថ្ងៃចុងក្រោយ ដែលខ្ញុំព្រះករុណាខ្ញុំ ប្រែខ្លួនពីជនដែលមិនពិការទៅជាជនពិការភ្នែក ... នោះជា(ផលវិបាកនៃ)សង្គ្រាម។ សង្គ្រាមបានឆាបឆេះតាំងពីក្រោយរដ្ឋប្រហារ ១៨មីនា ដែលទម្លាក់សម្តេចព្រះនរោត្តម សីហនុ ... ក្នុងន័យនេះ ឱកាសដែលខ្ញុំព្រះករុណាខ្ញុំមានលទ្ធភាពជាអ្នកដឹកនាំ ខ្ញុំព្រះករុណាខ្ញុំប្តូរផ្តាច់ដឹកនាំប្រទេសស្វែងរកសន្តិភាពឲ្យខាងតែបានជូនប្រជាជន។ ខ្ញុំមិនចង់ឲ្យយុវជននិងកុមារអភ័ព្វដូចខ្ញុំព្រះករុណាខ្ញុំ ដែលក្លាយខ្លួនទៅជាជនរងគ្រោះនៃសង្គ្រាមទេ ... យើងមិនចង់ឲ្យអ្នកណាមួយបំផ្លាញសន្តិភាពនៃប្រទេសនេះទេ។ **ដោយសារ(មាន)សន្តិភាព(នេះហើយ)ទើបបានជាយើងអាចមានឱកាសធ្វើពិធីចូលឆ្នាំ ឬធ្វើពិធីគ្រប់យ៉ាង ជាតម្រូវការ**

នៃគ្រប់ជាតិសាសន៍ដែលរស់នៅក្នុងប្រទេសកម្ពុជា ... ដែលចង្អុលបង្ហាញថា សន្តិភាពមានតម្លៃខ្លាំងណាស់។ កុំរង់ចាំសង្គ្រាមកើតឡើង ទើបស្រែករក សន្តិភាព។ កុំចាំដល់សង្គ្រាមកើតឡើង ទើបគិតថាសន្តិភាពមានតម្លៃ ...។

៥១. ការផ្លាស់ប្តូរក្រៅបរិបទប្រជាធិបតេយ្យ មិនជាការរីកចម្រើន តែនាំមកនូវសង្គ្រាម

ពិធីបុណ្យសមុទ្រលើកទី៨ ជុំទី២, ២១ ធ្នូ២០១៩

... ប្រសិនបើទុកឱ្យ សម្តេច ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ នៅបន្ត ដឹកនាំ កុំធ្វើរដ្ឋប្រហារ បើទោះបីមិនដល់ដំណាក់កាលនេះក៏ដោយ ក៏ប្រហែលជា ប្រទេសយើងមិនចាញ់គេឯងក្នុងតំបន់ទេ។ គេត្រូវទទួលយកការពិតមួយនេះ ... **នេះជាមេរៀនប្រវត្តិសាស្ត្រដែលយើងត្រូវចងចាំ កុំឱ្យមានព្រឹត្តិការណ៍ការផ្លាស់ប្តូរ ណាក្រៅពីបរិបទប្រជាធិបតេយ្យ។ ការផ្លាស់ប្តូរដែលមិនចេញពីបរិបទប្រជាធិប តេយ្យ មិនមែនជាការផ្លាស់ប្តូរ ដែលធ្វើឱ្យប្រទេសមានការរីកចម្រើនទេ។ ផ្ទុយទៅ វិញ វានឹងនាំមកដល់សង្គ្រាម។** សង្ឃឹមថា អ្នកការទូតដែលបានមកដល់ទីនេះ និង អ្នកការទូតដែលបានស្តាប់និងតែងតែបកប្រែជាទៀងទាត់នូវអ្វីដែល ហ៊ុន សែន និយាយ គួរតែក្រឡេកមើលក្រោយបន្តិចដើម្បីយល់ពីអតីតកាលរបស់កម្ពុជា (និងអាចសន្និដ្ឋានបានថា)ហេតុអ្វីកម្ពុជាឱ្យតម្លៃសន្តិភាពយ៉ាងដូច្នេះ? ...។

៥២. រូបមន្តប្រព័ន្ធសមាមាត្រតាមខេត្ត ស្នើឡើងដោយរដ្ឋកម្ពុជា

ចែកសញ្ញាបត្រដល់និស្សិត នៃសាកលវិទ្យាល័យ ប៉ៃលប្រាយ, ២២ តុលា ២០១៩

... មួយទៀតគឺប្រព័ន្ធបោះឆ្នោត។ ពង្រៀងកិច្ចព្រមព្រៀងប៉ារីស គឺការបោះ ឆ្នោតតាមប្រព័ន្ធសមាមាត្រទូទាំងប្រទេស។ រដ្ឋកម្ពុជាបានស្នើសុំបោះឆ្នោតតាម ប្រព័ន្ធឯកត្តនាម ... មកដល់ស្រុក យើងបានពិភាក្សាគ្នាយ៉ាងហ្មត់ចត់ ព្រោះទិស ដៅរបស់រដ្ឋកម្ពុជាគឺកម្ចាត់ចោលអង្គការចាត់តាំងនយោបាយ និងយោធាខ្មែរ ក្រហម ... ដើម្បីកុំឱ្យគ្រោះគំរាមកំហែងរបបប្រល័យពូជសាសន៍ត្រឡប់មកវិញ។ បើបោះឆ្នោតតាមប្រព័ន្ធសមាមាត្រ ខ្មែរក្រហមចូលពេញសភា ព្រោះខ្មែរក្រហម បោះត្រង់នេះបន្តិចបោះត្រង់នោះបន្តិច។ អញ្ចឹងធ្វើឱ្យខ្មែរក្រហមមានសម្លេង ឆ្នោតនៅក្នុងសភា ... **យើងក៏បានពិភាក្សាគ្នាសម្រេចយកប្រព័ន្ធសមាមាត្រតាម**

ខេត្ត ដើម្បីកាត់ផ្តាច់សម្លេងខ្មែរក្រហមជាកង់ៗ កុំឱ្យបូកបញ្ចូលគ្នាបាន។ អញ្ចឹង រូបមន្តប្រព័ន្ធសមាមាត្រតាមខេត្តគឺជារូបមន្តដែលរដ្ឋកម្ពុជាស្នើឡើង ហើយ SNC និងប្រទេសធំទាំងប្រាំ បានយល់ព្រម និងប្រើដល់រាល់ថ្ងៃនេះ ...។

៥៣. មនោគមវិជ្ជាគ្រប់គ្រងប្រទេសមួយ មិនប្រាកដថាអនុវត្តបានក្នុងប្រទេសមួយទៀត

កម្មវិធីសំណួរ/ចម្លើយ បន្ទាប់ពីសន្និសីទអន្តរជាតិលើកទី២៥ ស្តីពី«អនាគតអាស៊ី» នៅទីក្រុងតូក្យូ ប្រទេសជប៉ុន, ៣០ ឧសភា ២០១៩

... ប្រទេសមួយឯករាជ្យ តើយើងអនុវត្តច្បាប់របស់យើងបានឬអត់? ប្រទេស ជប៉ុនត្រូវអនុវត្តច្បាប់របស់ប្រទេសជប៉ុន។ ប្រទេសកម្ពុជាត្រូវអនុវត្តច្បាប់ប្រទេស កម្ពុជា។ វាជារឿងធម្មតាខ្លាំងណាស់។ ខ្ញុំគិតថា យើងគួរគោរពវិធានច្បាប់តាម ប្រទេសនីមួយៗ។ ពិតហើយ យើងយល់អំពីការកង្វល់នានា ក៏ប៉ុន្តែ គេត្រូវតែ សិក្សាអំពីអង្គហេតុ និងអង្គច្បាប់ឲ្យបានច្បាស់។ កុំដាក់បញ្ហាផ្លូវច្បាប់ទៅជា សកម្មភាពនយោបាយ ដែលវាមិនយុត្តិធម៌សម្រាប់កម្ពុជានោះទេ ... **ការគ្រប់គ្រង នៃមនោគមវិជ្ជាដែលសមស្របនៅក្នុងប្រទេសមួយ មិនប្រាកដថាយកទៅអនុវត្ត ក្នុងប្រទេសមួយទៀតបានទេ។ នេះវាជារឿងធម្មតាខ្លាំងណាស់។ ប្រជាធិបតេយ្យ នៅប្រទេសជប៉ុនមានបែបផែនមួយទៅ។ ប្រជាធិបតេយ្យនៅកូរ៉េខាងត្បូងមាន បែបផែនមួយទៅ។ ប្រជាធិបតេយ្យនៅក្នុងប្រទេសនេះប្រទេសនោះមានបែបផែន ផ្សេងទៅ** ...។

៥៤. ជាជនរងគ្រោះនៃប្រល័យពូជសាសន៍ ហែជាទទួលទណ្ឌកម្មពីប្រទេសប្រជាធិបតេយ្យ

បើកការដ្ឋានសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង និងសម្ពោធរោងចក្រប្រព្រឹត្តកម្មទឹកស្អាតចំការមន, ១ កុម្ភៈ ២០២១

... ភ្នំពេញកំសត់ណាស់ក្នុងកាលៈទេសៈនោះ។ ឱ្យផ្ទះម្នាក់មួយមិនមានអ្នក ណាហ៊ានយកទេ។ ផ្ទះមួយនៅ២ឬ៣គ្រួសារ។ ក្រោយមកចាប់ផ្តើមទាស់ទែងគ្នា ... ប្រទេសមួយចំនួនបានគាំទ្រខ្មែរក្រហមនៅអង្គការសហប្រជាជាតិ។ យើងបាន ទទួលទណ្ឌកម្ម (ដូចអ្វី)ដែលលោកស្រី អ៉ាំង (មីស្លីវីច)និងអូណេស្តា (កាប៉ែន) បានសរសេរក្នុងសៀវភៅ(ក្រោមចំណងជើង)ថា **"ទណ្ឌកម្មលើអ្នកក្រ"។ យើង**

ជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ក៏ប៉ុន្តែបែរជាត្រូវទទួលទណ្ឌកម្មពីប្រទេសប្រជាធិបតេយ្យទៅវិញ។ តាំងខ្លួនប្រជាធិបតេយ្យ ប្រទេសទាំងនោះគាំទ្ររដ្ឋប្រហារយោធារបស់ លន់ នល់ ទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ក្រោយមកគាំទ្រពួកខ្មែរក្រហមនៅអង្គការសហប្រជាជាតិ ធ្វើបាបយើងទៀត។ ប៉ុន្តែ ជាភ័ព្វសំណាង ដែលក្រោយមកមានការផ្តល់ជំនួយឱ្យតុលាការកាត់ទោសខ្មែរក្រហមដែលទើបជិតឈានដល់ទីបញ្ចប់ ...។

៥៥. គណបក្សប្រជាជនរួមសុខរួមទុក្ខ និងតែងមានវត្តមានពេលប្រជាជនជួបការលំបាក

សួរសុខទុក្ខប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារទឹកជំនន់ ទីតាំងទី១
ស្រុកថ្មពួក, ២២ តុលា ២០២០

... នេះហើយដែលហៅថា រួមសុខ រួមទុក្ខ។ និយាយតាមមួយបែប គណបក្សប្រជាជនរួមទាំងសុខរួមទាំងទុក្ខ។ ពាក្យខ្មែរបានភ្ជាប់គ្នាថារួមសុខរួមទុក្ខ ក៏ប៉ុន្តែអ្នកខ្លះរួមតែមានសុខទេ ពេលមានទុក្ខ ក៏រត់បាត់ចោលអស់។ សូម្បីតែពាក្យមួយម៉ាត់សម្តែងមរណទុក្ខ សម្តែងនូវការសោកស្តាយចំពោះការលិចលង់ក៏គេមិនបាននិយាយផង។ **គណបក្សប្រជាជនបានរួមសុខរួមទុក្ខជាមួយប្រជាពលរដ្ឋតាំងពីក្រោយរបប ប៉ុល ពត ជាង ៣១ឆ្នាំ ហើយនៅតែបន្តប្រពៃណីនេះ ដែលបង្ហាញឱ្យឃើញកាន់តែច្បាស់ថារាល់ពេលដែលមានមហន្តរាយកើតឡើង។ គ្រាដែលប្រជាជនមានការលំបាក តែងមានវត្តមានមន្ត្រីគណបក្សប្រជាជនជានិច្ច។ ខ្ញុំគ្មានទម្លាប់ដើរចាលប្រជាជន នៅពេលដែលប្រជាជនកំពុងជួបការលំបាកទេ** ...។

៥៦. ផែនទីព្រំដែនមិនកែប្រែ បន្សល់ទុកពីអាណានិគមបារាំងនិងមានចែងក្នុងរដ្ឋធម្មនុញ្ញ

បើកដំណើរការសោកល្បងសួនទឹកកំសាន្ត Garden City Water Park,
១៦ សីហា ២០២០

... **(លើការងារព្រំដែននេះ)បានធ្វើច្បាស់លាស់ក្នុងផ្លូវច្បាប់ មានកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនិងរដ្ឋាភិបាល សច្ចាប័នពីសភា និងព្រះមហាក្សត្រឡាយព្រះហត្ថលេខាដ៏ជាក់លាក់។** រឿង(ដែលអ្នកឯងនិយាយថា) "ការដោះដូរដីធ្លីជាអំពើក្បត់ជាតិ"នោះ ខ្ញុំបាននិយាយនៅសភាអស់ពេលជាង ៥ម៉ោង។ យើងបាន

ចុះហត្ថលេខាត្រឹមត្រូវ។ តើឱ្យខ្ញុំដោះស្រាយយ៉ាងម៉េច? (សូម)ឱ្យខ្ញុំនិយាយកន្លែងហ្នឹងបន្តិច។ **ផែនទីព្រំដែនមានបន្សល់ទុកពីអាណានិគមនិយមបារាំង ហៅថាព្រំដែនមិនកែប្រែនោះមានចែងក្នុងរដ្ឋធម្មនុញ្ញតែម្តង**។ សួរថាតើយើងមានបង្គោលព្រំដែនហើយឬនៅ? ថាមិនទាន់មាន ... យើងមានបង្គោលព្រំដែនមួយចំនួនដែលបន្សល់ទុកពីអាណានិគមនិយមបារាំង ទាំងជាមួយខាងវៀតណាម ជាមួយខាងថៃ ជាមួយខាងឡាវ។ យើងចង់ឱ្យមានបង្គោលព្រំដែនជាក់លាក់ ...។

៥៧. ជម្រើសដោះដូរទឹកដី ដោយរៀបចំខ្សែព្រំដែនថ្មី

បើកដំណើរការសោកល្បងសួនទឹកកំសាន្ត Garden City Water Park,
១៦ សីហា ២០២០

... នៅពេលទៅបោះបង្គោលព្រំដែន យើងបានឃើញភូមិវៀតណាមមួយចំនួននៅក្នុងទឹកដីរបស់កម្ពុជា ហើយភូមិរបស់កម្ពុជាមួយចំនួនក៏ទៅនៅក្នុងទឹកដីរបស់វៀតណាម ដូចជាភូមិរបស់សម្តេច ហេង សំរិន ជាដើម ... តើយើងត្រូវយកជម្រើសណាដើម្បីដោះស្រាយបញ្ហានេះ ... ផែនទីផ្លូវការដែលព្រះករុណាព្រះបិតាយកទៅតម្កល់នៅអង្គការសហប្រជាជាតិគឺផែនទីហ្នឹង។ ឥឡូវ យើងប្រើផែនទីហ្នឹងដដែលបែរជាភូមិសម្តេច ហេង សំរិន នៅក្នុងទឹកដីវៀតណាម ... ជម្រើសទី១ កាត់ភូមិបង ហេង សំរិន ទៅឱ្យនៅក្រោមការគ្រប់គ្រងរបស់វៀតណាម ដោយរក្សាទុកខ្សែព្រំដែនដដែល ... ជម្រើសទី២ រក្សាខ្សែព្រំដែនដដែល ប៉ុន្តែរើភូមិបង ហេង សំរិន ចេញរកដីឱ្យគាត់ធ្វើភូមិថ្មី នៅដីខ្មែរ ... **ឯជម្រើសទី៣ ដោះដូរដីគ្នាដោយរៀបចំខ្សែព្រំដែនជាថ្មី ... ដោយត្រូវដូរខ្សែព្រំដែនព័ទ្ធយកភូមិបង ហេង សំរិន ហ្នឹងឱ្យមកនៅក្នុងដីខ្មែរ** ...។

៥៨. កុំញុះញង់ឱ្យមានចម្បាំងជាមួយប្រទេសជិតខាងរឿងព្រំដែន

បើកដំណើរការសោកល្បងសួនទឹកកំសាន្ត Garden City Water Park,
១៦ សីហា ២០២០

... ម៉េចបានអ្នកឯងហ៊ានថា នេះជាទោសក្បត់ជាតិ? ... ថ្ងៃប្រជុំគណៈរដ្ឋមន្ត្រី ខ្ញុំបានប្រាប់ថា រង់ចាំមើលប្រធានគណបក្សនយោបាយមួយដែលនឹងចេញសេចក្តី

ថ្លែងការណ៍។ បើចេញសេចក្តីថ្លែងការណ៍បែបអ្នកមុនក៏ត្រូវចាប់ដូចអ្នកមុន។ ប៉ុន្តែពេលចេញពីគណៈរដ្ឋមន្ត្រី ខ្ញុំបានទទួលនូវ(ការផ្សាយរបស់) Cambodia Daily បន្តផ្ទាល់ជាមួយម្នាក់ហ្នឹង **ដោយវាចាត់ទុកថាការដោះដូរដីគឺជាទោសក្បត់ជាតិ។ អញ្ចឹង បើទោសក្បត់ជាតិ វាក្បត់ជាតិទាំងព្រះមហាក្សត្រ វាក្បត់ជាតិទាំងសភា វាក្បត់ជាតិទាំងព្រឹទ្ធសភា វាក្បត់ជាតិទាំងរាជរដ្ឋាភិបាល។ អញ្ចឹង អ្នកឯងស្នេហាជាតិអីតែឯង ... កុំញុះញង់ឱ្យមានចម្បាំងជាមួយប្រទេសជិតខាង តាមរយៈសាររបស់អ្នកឯង ចង្អុលកន្លែងនេះកន្លែងនោះ ... បញ្ហាព្រំដែនមិនមែនជារឿងលេងសើច ហើយវាអាចមានសង្គ្រាមព្រំដែនរវាងកម្ពុជានិងប្រទេសជិតខាងដោយសារតែមាត់អ្នកឯងញុះញង់បង្កើតចលាចលនៅទល់ដែន ...**។

៥៩. ប្រគល់ផែនទី១/២៥000 ដល់ខេត្តនិងកងទ័ព តាមព្រំដែនជាមួយវៀតណាម

បើកដំណើរការសាកល្បងសួនទឹកកំសាន្ត Garden City Water Park, ១៦ សីហា ២០២០

... រឿងផែនទីនេះទៀតសោត មានការមួលបង្កាច់(អីចេះអីចុះ)។ ប៉ុន្តែនេះក៏ប្រហែលមកពីគណៈកម្មាធិការព្រំដែនមិនបានពន្យល់ឱ្យបានច្បាស់លាស់។ ផែនទីដែលយើងប្រើជាមូលដ្ឋានដើមគឺផែនទីខ្នាត ១/១000000 ដែលបោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន គួបផ្សំជាមួយនឹងផែនទី UTM របស់អាមេរិកខ្នាត ១/៥0000។ ប៉ុន្តែ **ដើម្បីធានាដល់ការបោះបង្គោលជាក់លាក់ យើងត្រូវមានផែនទីខ្នាត ១/២៥000 ដែលបោះពុម្ពដោយប្រទេសជាណីម៉ាកឯនោះ មិនមែនបោះពុម្ពដោយវៀតណាមទេ។ យើងបានផ្ទៀងផ្ទាត់ជាមួយគ្នា ... អញ្ចឹងខាងវៀតណាមត្រូវទទួលប៉ុន្មានច្បាប់ ខាងយើងទទួលប៉ុន្មានច្បាប់។ យើងទទួលបានស្មើគ្នា។ ថ្ងៃទី ២៧សីហា សម្តេចពិជ័យ(សេនា ទៀ បាញ់) ជាអ្នកតំណាងឱ្យខ្ញុំនឹងប្រគល់ផែនទីនេះទៅឱ្យបណ្តាខេត្តតាមព្រំដែនកម្ពុជាវៀតណាម ប្រើប្រាស់ជាព្រំដែនផ្លូវការ ដោយកងទ័ពក៏ត្រូវប្រើប្រាស់ផែនទីហ្នឹងដែរ** ...។

៦0. ព្រំដែនមិននៅលើមាត់ទេ នៅលើការចរចារវាងប្រទេស ធានាដោយច្បាប់អន្តរជាតិ

បើកដំណើរការសាកល្បងសួនទឹកកំសាន្ត Garden City Water Park, ១៦ សីហា ២០២0

... ខ្ញុំបានទៅឆ្លើយ ៥ម៉ោង(នៅក្នុងសភា)។ តើវាជាការតស៊ូមតិឬទេ? ... សូមឱ្យទូរទស្សន៍ជាតិកម្ពុជា និងគ្រប់ទូរទស្សន៍ចាក់ផ្សាយចម្លើយរបស់ខ្ញុំនៅក្នុងសភា ... លោកឯងទើបធ្វើបក្សថ្មីៗ មកចាត់ទុករឿងព្រំដែនជាការតស៊ូមតិ។ ការតស៊ូមតិនេះបានឆ្លងកាត់សភាហើយ មិនមែនត្រឹមតែរឿងលោកឯងជិះម៉ូតូ(ទៅមើលត្រង់នេះត្រង់នោះទេ) ... កាលដែលចាប់ ហុង សុងហួរ និង អ៊ុំ សំអាត ក្នុងហាន:សមាជិកព្រឹទ្ធសភានិងសមាជិករដ្ឋសភា គឺចាប់ក្នុងបទល្មើសជាក់ស្តែង។ ឥឡូវ**អ្នកណានិយាយក្នុងករណីហ្នឹងគឺចាប់ក្នុងបទល្មើសជាក់ស្តែងទាំងអស់ ... អ្នកឯងចង្អុលថាព្រំដែនកម្ពុជានៅឯកម្ពុជាក្រោម ហ្នឹងក៏នៅលើមាត់របស់អ្នកឯង អ្នកឯងចង្អុលថានៅអយុធ្យា នៅបាងកក ក៏នៅលើមាត់អ្នកឯង អ្នកឯងថានៅហ្គួងប្រាបាងប្រទេសឡាវក៏នៅលើមាត់អ្នកឯង។ ព្រំដែនអត់នៅលើមាត់ទេ ព្រំដែននៅលើការចរចារវាងប្រទេស និងប្រទេស ហើយត្រូវបានធានាដោយច្បាប់អន្តរជាតិ មិនមែនធានាដោយមាត់ពួកអ្នកឯងទេ** ...។

៦១. ពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ ដាក់ចេញវិធានការនានា រួមទាំងវិសោធនកម្មច្បាប់

បិទសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារ២០២0 ក្រសួងមហាផ្ទៃ, ២0 កុម្ភៈ ២0២0

... សម្តេចក្រឡាហោម បានលើកឡើងពីការកើនឡើងនៃគ្រោះថ្នាក់ចរាចរណ៍ក្នុងខែមករានិងការធ្លាក់ចុះគ្រោះថ្នាក់ចរាចរណ៍នៅក្នុងខែកុម្ភៈ។ តើមកពីអ្វី? សម្រាប់ខ្ញុំៗ គិតថា វាមានកត្តា២។ កត្តាទី១ ក្នុងខែមករាគឺស្រឹងច្រើន។ ចូលឆ្នាំចិន ស្រឹងខ្មែរ។ ហ្នឹងជារឿងមួយ។ ប៉ុន្តែរឿង(ទី២) ការពង្រឹងការអនុវត្តច្បាប់ទើបជាហេតុផលពិតប្រាកដ។ **ខ្ញុំស្នើឱ្យយកចិត្តទុកដាក់(អនុវត្ត) វិធានការទាំងឡាយ ដោយយើងត្រូវប្រកាន់យកពេលខាងមុខ ពង្រឹងការអនុវត្តច្បាប់ រាប់ទាំងដាក់ចេញវិធានការនានាសម្រាប់ដំណើរការទៅមុខ។ បើថាធ្វើវិសោធនកម្មច្បាប់ ក៏ធ្វើទៅ។ ធ្វើអ្វីបាន គឺធ្វើ** ...។

៦២. ពិចារណាវិធានការដាកពិន័យជាលំដាប់ រហូតដល់ដកសិទ្ធិបើកបរ

បិទសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ ២០១៩ និងលើកទិសដៅការងារឆ្នាំ ២០២0 ក្រសួងមហាផ្ទៃ,២0 កុម្ភៈ ២0២0

... ខ្ញុំលើកឧទាហរណ៍ថ្ងៃមុនក្នុងការប្រជុំគណបក្ស ... ឥឡូវអ្នកបើកបរៗតែងមានប័ណ្ណបើកបរ។ **អ្នកឯងឧសម្ដង ខ្ញុំកិបមួយ។ កិប(ប័ណ្ណបើកបរ)ហ្នឹង ជាកប៉ុន្មានអញ្ចឹងទៅ ជាកហើយកិបទៀត កិបឱ្យដឹង។ អញ្ចឹងនគរបាលគ្រប់ទីកន្លែងដឹងថា កន្លែងកិបហ្នឹងគឺអ្នកហ្នឹងបានបំពានម្ដងហើយ។ ដល់ឧសលើកទី២ ត្រូវជាកប៉ុន្មាន? បើគេឃើញថា មានកិបមួយហើយ ជាកលើកទី២ គឺជាកឧប្ដិ ... ដល់ទៅបំពានលើកទី៣ ... ដល់ឱកាសជាកសិទ្ធិ។** ជាកសិទ្ធិមិនឱ្យបើកបរថា ១ឆ្នាំ ឬ ២ឆ្នាំតែម្ដង។ មិនឱ្យអ្នកឯងបើកបរតទៅទៀតទេ។ ដល់ទៅគ្រប់ ២ឆ្នាំ ឬ ១ឆ្នាំចាំយើងឱ្យសិទ្ធិបើកបរឡើងវិញ។ ក្នុងរយៈពេលហ្នឹង គាត់ឱ្យកូនគាត់ ឬមិត្តភក្តិ ឬនរណាជួយបើកសិនទៅ ព្រោះបើគាត់បើកបរអោងតែមានលុយទៅបុកគេ ...។

៦៣. ការកាត់សិទ្ធិបើកបរមិនមែនជាទណ្ឌកម្ម តែការពារជីវិតអ្នកបើកបរទៅវិញទេ

បិទសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារ២០២០ ក្រសួងមហាផ្ទៃ, ២០ កុម្ភៈ ២០២០

... ខ្ញុំគាំទ្រឱ្យធ្វើវិធីនេះ។ ពិភាក្សាគ្នាមើលទៅ ពេលដែលយើងកាត់សិទ្ធិ តើប៉ុន្មានដងទើបយើងកាត់សិទ្ធិ? ត្រឹម ៣ដង ឬ ៤ដង ឬ ៥ដង? ពិភាក្សាគ្នាទៅ។ ការកាត់សិទ្ធិនេះទៀតកាត់សិទ្ធិ ១ឆ្នាំ ឬ២ឆ្នាំ ឬកាត់រយៈពេលប៉ុន្មាន? ប៉ុន្តែ ត្រូវតែមានតែម្ដង។ បើមិនអញ្ចឹងនៅតែបំពានរហូត។ អាងទឹកលុយ នៅបំពានរហូត អត់រាង(ចាល)ទេ។ ទាល់តែយកអ្នកឧសច្បាប់ហ្នឹងចេញពីផ្លូវ ... គាត់អាចធ្វើដំណើរបាន តែគាត់អត់មានសិទ្ធិបើកបរ។ អញ្ចឹងទៅណាធ្លាប់តែបើកឡានខ្លួនឯង ឱ្យជិះតាក់ស៊ីទៅ ជិះកង់បីអីទៅ ឬគាត់ឱ្យកូនបើក ឬអ្នកណាបើកទៅ ... **វិធីនេះមិនមែនទណ្ឌកម្មចំពោះគាត់ទេ វិធីនេះការពារជីវិតគាត់ទៅវិញទេ ...។**

៦៤. មិនត្រូវសាទរកំណើនតួលេខអ្នកទទួលបានការពិនិត្យព្យាបាលគ្រឿងញៀន

បិទសន្និបាតសុខាភិបាលលើកទី៤០, ១២ មីនា ២០១៩

... **តួលេខទទួលបានការពិនិត្យព្យាបាលពីបញ្ហាគ្រឿងញៀន(កើនឡើង) មិនមែនជាតួលេខដែលត្រូវអរទេ ... នៅឆ្នាំ២០១៧ ដូចជាមានតែជាង ៤០០០នាក់ទេ។ ឆ្នាំ២០១៨ ឡើងដល់ ៨០០០ មែនទេ? ... អញ្ចឹង កើនមួយជាពីរ។** អាជ្ញាធរ

គ្រឿងញៀនបានរាយការណ៍ពីការចាប់បានក្នុងមួយឆ្នាំៗ នូវចំនួនដែលមានការកើនឡើង។ យើងត្រូវរកគ្រប់វិធីដើម្បីបំផ្លាញចោលក្រុមគ្រឿងញៀន ហើយក្រុមនេះវាជ្រកកោននៅទីណា? ... (ដោយសារ)ការគ្រប់គ្រងធូរលុង ... សណ្ឋាគារខ្លះក្លាយជាកន្លែងជួញដូរនិងជក់គ្រឿងញៀន ...។

៦៥. ធ្វើរឿងគ្រឿងញៀនឱ្យហ្មត់ចត់ ... មិនមែនជាសារព្រមានទៅកាន់តុលាការទេ

បិទសន្និបាតសុខាភិបាលលើកទី៤០, ១២ មីនា ២០១៩

... មិនមែនជាសារជះឥទ្ធិពលលើតុលាការទេ ក៏ប៉ុន្តែត្រូវតែធ្វើ(កិច្ចការពាក់ព័ន្ធនឹងគ្រឿងញៀន)ឲ្យហ្មត់ចត់។ បើមិនហ្មត់ចត់ទេ តុលាការក៏មិនរួចខ្លួនដែរ ... ផ្នែកតុលាការ ការគ្រប់គ្រងនយោបាយព្រហ្មទណ្ឌ គឺមានផ្នែកអយ្យកា គឺព្រះរាជអាជ្ញាស្ថិតក្រោមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌... បើព្រះរាជអាជ្ញាមិនធ្វើការចោទប្រកាន់ ... អ្វីទៅដែលហៅថាព្រះរាជអាជ្ញាតំណាងឲ្យរដ្ឋ? បើព្រះរាជអាជ្ញាមិនធ្វើការចោទប្រកាន់ ... រដ្ឋមន្ត្រីយុត្តិធម៌ត្រូវប្រើសិទ្ធិស្នើព្រះមហាក្សត្រដកពីតំណែង ...។

៦៦. មិនផលិតតែក្លាយជាកន្លែងចែកចាយនិងប្រើប្រាស់គ្រឿងញៀន

ពិសាអាហារសាមគ្គីជាមួយកីឡាករ/ការិនី, ៤ មេសា ២០១៩

... ខ្ញុំតែងតែហាមប្រើប្រាស់ថ្នាំលើកកម្លាំង ប៉ូវកម្លាំង ដោយសារធាតុដែលគេហាមឃាត់ក្នុងការប្រកួត ... ប៉ុន្តែ ក្នុងប្រទេសមានបញ្ហាគ្រឿងញៀនកើតឡើងច្រើន។ **កម្ពុជាមិនមែនជាប្រទេសផលិតគ្រឿងញៀនទេ តែប៉ុន្មានថ្ងៃនេះ (បានកេរយើញ)រាប់រយគីឡូក្រាមមកពីប្រទេសដទៃចូលមកប្រទេសយើង ហើយយើងក៏បានក្លាយទៅជាកន្លែងចែកចាយ និងប្រើប្រាស់គ្រឿងញៀន។** សូមកីឡាករ/ការិនីជួយផ្សព្វផ្សាយនិងទប់ស្កាត់ ការប្រើប្រាស់គ្រឿងញៀន ហោចបំផុតកុំឱ្យមិត្តភក្តិនិងក្រុមគ្រួសារប្រើប្រាស់គ្រឿងញៀន ...។

៦៧. កម្ពុជាអាចក្លាយជាកន្លែងសុវត្ថិភាពសម្រាប់ឧក្រិដ្ឋជនធ្វើសកម្មភាព

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

... ជាបញ្ហាសាំញ៉ាំ មិនមែនគ្រាន់តែកម្ពុជាដាច់ដោយឡែកទេ តែពាក់ព័ន្ធគ្រប់កន្លែងទាំងអស់លើពិភពលោក គ្រាន់តែតិចឬច្រើនតែប៉ុនណោះ។ **ឯកម្ពុជា ប្រសិនបើមិនប្រយ័ត្ន អាចនឹងក្លាយទៅជាទីកន្លែងសុវត្ថិភាពសម្រាប់ឧក្រិដ្ឋជន ដែលមកធ្វើសកម្មភាពក្នុងប្រទេស យកប្រទេសយើងធ្វើជាឈ្នាន់សម្រាប់ផលិតគ្រឿងញៀន ដែលគេយក(វត្ថុធាតុដើម)មកពីក្រៅ តែយកមកផលិតនៅកម្ពុជា រួចហើយចែកចាយចេញទៅវៀតណាម ទៅថៃ ទៅប្រទេសផ្សេង ទៀតក៏ថាបាន** ...។

៦៨. ជនរងគ្រោះខ្លះលុះតាមការលួងលោមថាជាថ្នាំព្យាបាលជំងឺ ឬលើកកម្លាំង

ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, ២៦ មិថុនា ២០០៩

... សូមយុវជន/នារី និងពលរដ្ឋទាំងអស់ កុំទទួលយកប្រភេទថ្នាំណាដែលមិនមែនគ្រូពេទ្យផ្តល់ឲ្យ ឬទិញដោយផ្ទាល់ពីឱសថស្ថាន ឬក៏មិនមែនដោយអាណាព្យាបាល មាតាបិតា ដែលជាអ្នកផ្តល់ឲ្យនោះ ... **អ្នកញៀនគ្រឿងញៀនមួយចំនួនមិនបានដឹងថានេះជាសារធាតុញៀននោះទេ។ ដោយហេតុនេះ គេបានក្លាយទៅជាជនរងគ្រោះ ជាចំណាប់ខ្មាំង និងទៅជាអតិថិជនទិញគ្រឿងញៀនពីអ្នកផ្គត់ផ្គង់គ្រឿងញៀន ដែលជាអ្នកលួងលោមពួកគេឲ្យប្រើប្រាស់ថា ជាថ្នាំព្យាបាលជំងឺ ឬជាថ្នាំលើកកម្លាំងនោះឯង** ...។

៦៩. គ្រឿងញៀនជះឥទ្ធិពលអាក្រក់លើសន្តិសុខសណ្តាប់ធ្នាប់ ការអភិវឌ្ឍសង្គម

អបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, ២៦ មិថុនា ២០១៤

... **គ្រឿងញៀនជាបញ្ហាសកលដែលបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរទៅលើសុខភាពនិងអាយុជីវិតរបស់ប្រជាជននៅលើសកលលោក។ ជាមួយគ្នា គ្រឿងញៀនក៏បង្កើតឱ្យមានជាអំពើហឹង្សា ឧក្រិដ្ឋកម្ម និងអំពើអសកម្មផ្សេងទៀត ដែលជះឥទ្ធិពលអាក្រក់និងធ្ងន់ធ្ងរដល់សន្តិសុខសណ្តាប់ធ្នាប់ ពិសេសកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋនីមួយៗ ក្នុងការងារអភិវឌ្ឍសង្គមជាតិផងដែរ** ... ក្រុមឧក្រិដ្ឋជននៅតែបន្តមហិច្ឆតាក្នុងការលួចលាក់ផលិត កែច្នៃនិងចរាចរគ្រឿងញៀនពី ប្រទេស/តំបន់មួយទៅប្រទេស/តំបន់មួយ ... ដើម្បីផ្គត់ផ្គង់និងពង្រីកទីផ្សារប្រើប្រាស់ ...។

៧០. អ្នកប្រើប្រាស់គ្រឿងញៀន គឺជាជនរងគ្រោះ

អបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, ២៦ មិថុនា ២០១៤

... ត្រូវបន្តសហការគ្នាឱ្យបានជិតស្និទ្ធតាមគ្រប់រូបភាព គ្រប់ទីកន្លែង និងគ្រប់ពេលវេលា ទាំងក្នុងកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីបង្ការទប់ស្កាត់បញ្ហាគ្រឿងញៀន និងការពារកុំឱ្យបងប្អូនសាច់ញាតិ និងមិត្តភក្តិរបស់យើង ចាញ់ការបោកបញ្ឆោតក្រុមឧក្រិដ្ឋជន ធ្លាក់ខ្លួនជាអ្នកពាក់ព័ន្ធនិងប្រើប្រាស់គ្រឿងញៀនដោយខុសច្បាប់។ ក្នុងនោះ **យើងក៏ត្រូវចាត់ទុកអ្នកប្រើប្រាស់គ្រឿងញៀន គឺជាជនរងគ្រោះ ដែលត្រូវឱ្យពួកគាត់បញ្ឈប់ការប្រើប្រាស់ ងាកមកគិតគូរពីអនាគតរបស់ខ្លួន និងក្រុមគ្រួសារ** ...។

៧១. អនុវត្តនយោបាយ "ភូមិឃុំមានសុវត្ថិភាព" ព្រោះគ្រឿងញៀន ល្បែងស៊ីសង ជួញដូរមនុស្ស ហិង្សាកើតនៅនឹងមូលដ្ឋាន

បិទសន្និបាតត្រួតពិនិត្យការងារមហាផ្ទៃ ឆ្នាំ២០១៩ លើកទិសដៅការងារ២០២០, ២០ កុម្ភៈ ២០២០

... សម្តេចក្រឡាហោមបានសង្កត់ធ្ងន់ទៅលើការអនុវត្តគោលនយោបាយ «ភូមិឃុំមានសុវត្ថិភាព»។ ខ្ញុំចង់ឱ្យចលនានេះក្លាយជាចលនារួមរបស់យើងទាំងអស់គ្នា ហើយកិច្ចការស្នូលក្នុងដំណើរទៅមុខ ប្រមូលផ្តុំអនុវត្តឱ្យបានល្អបំផុតនូវគោលនយោបាយភូមិឃុំមានសុវត្ថិភាព ... គ្មានឧក្រិដ្ឋកម្មណាមួយដែលវាមិនបានកើតឡើងនៅទឹកដីភូមិនោះទេ។ **ទីតាំងមជ្ឈិមក៏ដោយ ទីតាំងខេត្តក៏ដោយ ទីតាំងស្រុកក៏ដោយ ទីតាំងឃុំក៏ដោយ វានៅនឹងភូមិនោះឯង ... ជាចំណុចស្នូលនៃការដោះស្រាយ ព្រោះរឿងគ្រឿងញៀន ល្បែងស៊ីសង ជួញដូរមនុស្ស ហិង្សា វាកើតឡើងនៅនឹងមូលដ្ឋាន** ...។

៧២. ត្រងត្រាប់មតិប្រជាពលរដ្ឋ ដើម្បីធានាសុវត្ថិភាព និងអនុវត្តកិច្ចការបានជោគជ័យ

បិទសន្និបាតត្រួតពិនិត្យការងារមហាផ្ទៃ ឆ្នាំ២០១៩ លើកទិសដៅការងារ២០២០, ២០ កុម្ភៈ ២០២០

... ចាប់យកគោលនយោបាយភូមិឃុំមានសុវត្ថិភាពជាស្នូល ... ជាប្រធានបទ

ស្នូលសម្រាប់ដោះស្រាយបញ្ហាទៅមុខ ... ឥឡូវអ្វីដែលជាការនៅខ្វះ គឺនៅត្រង់ថា យើងមិនបានក្តាប់ជាប់កូនសោរនេះ ...**ពេលពិភាក្សារកវិធីដោះស្រាយវានឹងលេចឡើងនូវមតិរបស់ប្រជាពលរដ្ឋថាតើគួរធ្វើបែបណា។ ពួកគាត់នឹងចូលរួមជាមួយយើង។ បើពួកគាត់មិនសហការជាមួយយើងទេ សុវត្ថិភាពពួកគាត់ក៏មិនត្រូវបានធានា ឯយើងក៏ពិបាកអនុវត្តកិច្ចការដែរ**។ ដូច្នេះ ទាល់តែមានទំនាក់ទំនងរវាង និងជាមួយនឹងពួកគាត់ ទើបយើងអាចដោះស្រាយបានបញ្ហា ...។

៧៣. ធ្វើកិច្ចការភូមិឃុំមានសុវត្ថិភាព ដើម្បីធានាសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម

បិទសន្និបាតត្រួតពិនិត្យការងារមហាផ្ទៃ ឆ្នាំ២០១៩ លើកទិសដៅការងារ២០២០, ២០ កុម្ភៈ ២០២០

... **យកកិច្ចការភូមិឃុំមានសុវត្ថិភាពជាស្នូល ដើម្បីធ្វើឱ្យស្ថានភាពសន្តិសុខសណ្តាប់ធ្នាប់សង្គមប្រសើរឡើង។** តើវាលក់គ្រឿងញៀននៅឯណា? វាមិនដែលលក់ក្នុងការិយាល័យរដ្ឋមន្ត្រីមហាផ្ទៃទេ ...វាលក់តាមផ្ទះក្នុងភូមិហ្នឹងណា។ ប្រជាជនគាត់ដឹងរឿងរាវ។ នៅពេលដែលយើងធ្វើវេទិកាសាធារណៈជាមួយពួកគាត់ ដោយផ្តោតលើ «ភូមិឃុំមានសុវត្ថិភាព» ... ក្នុងនោះទាក់ទងគោលដៅជាសកម្មភាពចលនា «ភូមិឃុំមានសុវត្ថិភាព» នេះ ... សូមកុំឱ្យមានឧក្រិដ្ឋកម្មគ្របដណ្តប់ទៅលើសេចក្តីសុខសុវត្ថិភាពរបស់ប្រជាជន ...។

៧៤. សូមទូរទស្សន៍រត់អក្សរថា ប្រើប្រាស់គ្រឿងញៀនគឺបំផ្លាញអាយុជីវិតខ្លួនឯង

ផ្ទេរតំណែងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, ១៩ ឧសភា ២០០៩

... សូមក្រសួងវប្បធម៌ធ្វើកិច្ចការងារនេះ។ យើងមានកុនច្រើន។ អញ្ចឹង យើងអំពាវនាវឲ្យគ្រប់ផលិតកម្មជួយដាក់(ការណែនាំ)ហ្នឹងបន្តិចទៅ។ មុនការបញ្ចាំងខ្សែភាពយន្ត ត្រូវដាក់(ការណែណាំ)ហ្នឹងសិន ឬអាចដាក់អក្សររត់ខាងក្រោម។ គេអាចច្នៃបាន ... ហើយទូរទស្សន៍មួយៗ សុទ្ធតែមានបញ្ចាំងភាពយន្ត ជួនកាលផលិតខ្លួនឯង ជួនកាលបញ្ចាំងរឿងមកពីបរទេស។ ក្នុងពេលហ្នឹង**ទូរទស្សន៍អាចរត់អក្សរបានតើថា ប្រើប្រាស់គ្រឿងញៀនគឺបំផ្លាញអាយុជីវិតខ្លួនឯង** ...។

៧៥. សំណូមពរដាក់ឃ្លាអប់រំពីបញ្ហាគ្រឿងញៀននៅលើផលិតផលប្រើប្រាស់នានា

ផ្ទេរតំណែងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, ១៩ឧសភា ២០០៩

... **មានផលិតផលមួយចំនួន ឧទាហរណ៍ មីយើង។ បើគាត់អាចធ្វើបាន ដាក់នៅតែមកភ្ជាប់នឹងបន្តិចទៅថា ប្រើប្រាស់គ្រឿងញៀនគឺបំផ្លាញអនាគតនិងជីវិត ឬក៏ដាក់យ៉ាងម៉េចអីយ៉ាងម៉េចឲ្យវាសមរម្យ។ ឬថាទទួលទានមីប្រសើរជាងប្រើគ្រឿងញៀន។ នោះក៏កាន់តែលក់ដាច់ទៅទៀត** ... ខ្ញុំអនុញ្ញាតឲ្យប្រើប្រាស់អាវ "ហសៈ" ពាក់ឲ្យចំណុះទូក ដាក់ខ្លះទៅក្រោមផ្ទាក "ហសៈ" ថាហាមប្រើប្រាស់គ្រឿងញៀន ខាងមុខផងខាងក្រោយផង។ ខ្ញុំទៅមុនគេ ហើយសៀវភៅដែលបោះរូបខ្ញុំ ពីថ្ងៃនេះទៅ ខុទ្ទកាល័យសូមដាក់ថែមទៅ ...។

៧៦. ព្រះសង្ឃក៏អាចជួយអប់រំពីបញ្ហាគ្រឿងញៀនបានដែរ

ផ្ទេរតំណែងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, ១៩ឧសភា ២០០៩

... អាជ្ញាធរជាតិត្រូវបានពង្រីកសមាសភាព។ មុននេះមានតែ ១០ ស្ថាប័នទេ។ ឥឡូវយើងមាន១៥ តាមសារាចរណែនាំក្រោយនេះ។ សារាចខ្លះណែនាំតាមរយៈសម្តេចព្រះសង្ឃរាជ ឬសម្តេចព្រះសង្ឃនាយក អមដោយរដ្ឋមន្ត្រីក្រសួងធម្មការជួយ ... **ព្រះសង្ឃក៏អាចជួយបានមួយចំណែក តាមរយៈការផ្តល់ធម្មទេសនា អប់រំពុទ្ធបរិស័ទ កុំឲ្យប្រើប្រាស់គ្រឿងញៀន ហើយជួយដល់អ្នកដែលញៀន អាចឲ្យមកស្នាក់នៅតាមទីអារាមខ្លះ**។ តែខ្លាចទៅវាយលោកទៀត ... ត្រូវធ្វើគ្រប់សកម្មភាព។

៧៧. ពិធីករ/ការនី សិល្បៈករ/ការនី ជួយផ្សព្វផ្សាយ ប្រឆាំងគ្រឿងញៀន

ផ្ទេរតំណែងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, ១៩ ឧសភា ២០០៩

... ស៊ីឌីអត់មានរូបទេ ឮតែសម្លេង។ ឲ្យគេដាក់មុនដល់ចម្រៀងសូមកុំប្រើប្រាស់គ្រឿងញៀន។ គ្រឿងញៀនបណ្តាលឲ្យគ្រោះថ្នាក់ ឬពេលខ្លះ មុនឆ្លងពីចម្រៀងទី១ ទៅទី២ អាចដាក់ចូលចន្លោះហ្នឹង។ នេះសុទ្ធតែវិធីជួយគ្នា។ គ្រប់ផលិតកម្មទាំងអស់។ **ពិធីករតាមស្ថានីយ៍នីមួយៗ សូមជួយនិយាយផងថា កុំប្រើប្រាស់គ្រឿងញៀន ឬក៏សិល្បករ សិល្បការិនីមួយចំនួន ក៏អាចធ្វើបាន។ ក្នុងនោះ**

អ្នកចម្រៀងដែលស្ថិតក្នុងស្រទាប់យុវវ័យ ... ប្អូនៗ ក្មួយៗ សិល្បករ សិល្បការិនី សូមនិយាយមួយម៉ាត់ ពីរម៉ាត់ សូមកុំប្រើប្រាស់គ្រឿងញៀន អញ្ចឹងទៅ ...។

៧៨. "គ្រប់គ្នាថាទេ ចំពោះគ្រឿងញៀន"

សារហ្វេសប៊ុក សម្តេចតេជោ ហ៊ុន សែន ស្តីពីគ្រឿងញៀន, ២៩ មករា ២០១៦

... ដើម្បីបំបាត់ចោលនូវគ្រឿងញៀន និងដើម្បីជានាប្រសិទ្ធិភាពបំបាត់ចោលគ្រឿងញៀន ដើម្បីកម្ពុជាគ្មានគ្រឿងញៀន មនុស្សទាំងអស់កុំសេពគ្រឿងញៀន ហើយគ្រប់គ្នាត្រូវឆ្លើយថា "ទេ"។ បុគ្គលម្នាក់ៗ មិនថាចាស់ ក្មេង ប្រុស ស្រី ត្រូវខិតខំដោយខ្លួនឯង។ រីឯគ្រួសារនីមួយៗ ត្រូវគ្រប់គ្រងអប់រំកូនចៅនៅក្រោមអាណាព្យាបាលឲ្យបានល្អ។ សាលារៀន គ្រូ សាស្ត្រាចារ្យត្រូវផ្តល់ការអប់រំចំពោះសិស្សនិស្សិត តាមរយៈសកម្មភាពមិត្តអប់រំមិត្តឲ្យចាកឆ្ងាយពីគ្រឿងញៀនដើម្បីរួមចំណែកទប់ស្កាត់គ្រឿងញៀន ...។

៧៩. កម្ពុជាត្រូវបានយកជាចំណុចចេញដំណើរនៃការរត់ពន្ធមនុស្សទៅអូស្ត្រាលី

បើកសិក្ខាសាលាស្តីពីសន្តិសុខលំហសមុទ្រ, ២៦ ឧសភា ២០០៩

... ការកសាងសមត្ថភាពកងទ័ពជើងទឹក មិនមែនសម្រាប់តែការវាយដណ្តើមកោះ ដណ្តើមដែនទឹកនោះទេ គឺជាការពង្រឹងសមត្ថភាពកម្ចាត់ពួកចោរសមុទ្រ ... ពួកចោរ ពួករត់ពន្ធគ្រឿងញៀន មិនខុសអីពីពួកភេរវកម្មទេ។ យូរៗទៅ វាទៅជាក្រុមតែមួយ មានប្រដាប់អាវុធទំនើបៗ ... សូម(អាមេរិក/អូស្ត្រាលី)ជួយផ្តល់កប៉ាល់ដេញចាប់ល្បឿនលឿនៗ ខ្លះមក។ និយាយឱ្យពិត **ប្រទេសអូស្ត្រាលីគឺជាអ្នករងគ្រោះ។ កម្ពុជាត្រូវគេយកជាចំណុចចេញដំណើរ រត់ពន្ធមនុស្សចូលទៅប្រទេសអូស្ត្រាលី គ្រឿងញៀនមួយចំនួនចេញពីកម្ពុជា ហើយចេញពីកម្ពុជា** ...។

៨០. ការជួញដូរមនុស្សរកងប្រាក់ បានកើតពេលដែលប្រជាពលរដ្ឋទទួលបានទីផ្សារការងារ

សន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិនទី១២ "តួនាទីព្រះរាជអាជ្ញាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងតំបន់", ៦ វិច្ឆិកា ២០១៩

... ទាក់ទងលំហូរមនុស្សពលកម្ម ដែលបានអនុម័តនៅទីក្រុងម៉ានីឡា **កាលពីប៉ុន្មានឆ្នាំមុននេះ បានក្លាយជាបញ្ហាសំខាន់មួយសម្រាប់យើង។ ឥឡូវ ទីផ្សារការងារគឺធ្វើឱ្យប្រជាពលរដ្ឋទទួលបានការងារធ្វើ ប៉ុន្តែក្នុងពេលជាមួយគ្នានោះ ការជួញដូរមនុស្សរកងប្រាក់ បានកើតឡើងក្នុងពេលហ្នឹងតែម្តង**។ ជាឧទាហរណ៍ កម្ពុជា ឡាវ មីយ៉ាន់ម៉ា មានពលករចូលមកធ្វើការក្នុងប្រទេសថៃ។ មានអ្នកទៅដោយចាញ់បោកគេ ... មានពលករកម្ពុជានៅកូរ៉េប្រមាណ ៥ម៉ឺននាក់ ... នៅមានអ្នកចាញ់បោកគេទោះបីបញ្ជូនតាមផ្លូវការមានការប្រឡងច្បាស់លាស់ក្តី ...។

៨១. ការភៀសខ្លួនពីប្រទេសមួយទៅប្រទេសមួយ ជាឱកាសប្រយោជន៍សម្រាប់ពួកទុច្ចរិត

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

... ការរត់ភៀសខ្លួនរបស់ប្រជាជនមួយចំនួនដែលឆ្លងកាត់ពីប្រទេសមួយទៅប្រទេសមួយ វាក្លាយទៅជារឿងដ៏អកុសលសម្រាប់ប្រជាជនក្រីក្រ ក៏ប៉ុន្តែវាជាឱកាសនៃពួកទុច្ចរិតដែលបានធ្វើកិច្ចការនេះបម្រើផលប្រយោជន៍របស់ខ្លួន។ រឿងរបស់យើងនេះ បើប្រៀបធៀបជាមួយនឹងបណ្តាប្រទេសនៅលើសកលលោកវាមិនទាន់ធំហួសទេ។ ប៉ុន្តែ បើសិនជាយើងមិនទប់ស្កាត់ពីពេលនេះ និងរួមគ្នាទប់ស្កាត់ វាក៏នឹងក្លាយជាគោលដៅសុវត្ថិភាពសម្រាប់ឧក្រិដ្ឋជនរត់ពន្ធមនុស្សចូលមកកម្ពុជាវិញម្តង ឬរត់ពន្ធពីកម្ពុជាចេញទៅក្រៅប្រទេស ... យើងត្រូវរួសរាន់រួមគ្នាធ្វើសកម្មភាពប្រឆាំងនឹងការជួញដូរមនុស្ស ...។

៨២. សង្គ្រាមនិងការបោកប្រាស់ថាទៅធ្វើការនៅក្រៅប្រទេស ធ្វើឱ្យពលរដ្ឋកម្ពុជាភៀសខ្លួនទៅក្រៅប្រទេស

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

... មុននេះ កម្ពុជាគឺជាទីកន្លែងដែលប្រជាជនរបស់ខ្លួនរត់ភៀសខ្លួនចេញទៅប្រទេសក្រៅ។ ដោយសារអ្វី? **សង្គ្រាមផ្ទុះឡើងនៅឆ្នាំ ១៩៧០ បានធ្វើឱ្យប្រជាពលរដ្ឋរបស់យើងមួយចំនួនភៀសខ្លួនទៅក្រៅប្រទេស។ ក្នុងពេលនៃរបប ប៉ុល ពត**

ប្រជាជនក៏បានភៀសខ្លួនមួយចំនួនទៅក្រៅប្រទេស។ ក្រោយរបបប៉ុល ពត នៅក្នុងដំណាក់កាលដែលប្រទេសកម្ពុជាមានសន្តិភាពផង និងមានសង្គ្រាមផង ប្រជាជនកម្ពុជាមួយចំនួនក៏បានរត់ចេញទៅក្រៅប្រទេស រហូតមានការធ្វើដំណើរតាមទូកទៅអូស្ត្រាលី តាមរយៈដែលគេហៅថា រត់ពន្ធមនុស្ស ... រយៈពេលក្រោយមកទៀត **ប្រជាជនកម្ពុជាត្រូវគេបោកប្រាស់យកទៅធ្វើការនៅក្រៅប្រទេស** ...៕

៨៣. ប្រជាពលរដ្ឋខ្លះចាញ់បោកមេខ្លោងជួញដូរមនុស្សខ្វីបុលសូកប៉ាន់ទៅធ្វើការក្រៅប្រទេស

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

... **កាគច្រើនបានទៅធ្វើការនៅក្រៅប្រទេសក្រោមរូបភាពស្របច្បាប់ តាមភ្នាក់ងារដោះស្រាយការងារ ដោយរាជរដ្ឋាភិបាលបានប្រឹងប្រែងធ្វើការជាមួយដៃគូ ដូចជាកូរ៉េខាងត្បូង ជប៉ុន ថៃ ម៉ាឡេស៊ីជាដើម ... ប៉ុន្តែមានមួយចំនួនក៏ទៅដោយសារតែការជួញដូរមនុស្ស។ បងប្អូនមួយចំនួនចាញ់បោកមេខ្លោងជួញដូរមនុស្ស(ធ្វើការបោកប្រាស់)ដោយគេជឿថានឹងបានប្រាក់ខែប៉ុណ្ណោះប៉ុណ្ណោះ។ អញ្ចឹងក៏ត្រូវទៅខ្វីបុលគេ ដើម្បីយកទៅសូកគេធ្វើដំណើរទៅ(ក្រៅប្រទេសធ្វើការ)** ... ខ្លះបាត់ដំណឹងឈឹង មិនដឹងថាទៅកន្លែងណា។ ជួនកាលយើងបានរកឃើញពលរដ្ឋរបស់យើងត្រូវគេប្រើប្រាស់ជាកម្លាំងពលកម្មនេសាទនៅតាមប្រទេសនានា ដែលពួកគេមិនដែលបានឡើងគោក ផ្តាច់ដំណឹងទាំងស្រុងពីក្រុមគ្រួសារ ...៕

៨៤. ប្រជាពលរដ្ឋខ្លះក្លាយជាអ្នកបន្តស្នាក់នៅខុសច្បាប់នៅប្រទេសក្រៅ

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

... **បងប្អូនយើងមួយចំនួនទៀត ទៅធ្វើការនៅក្រៅប្រទេស ដូចជាកូរ៉េខាងត្បូងជាដើម រហូតផុតការកំណត់នៃកិច្ចសន្យាការងារ តែបន្តស្នាក់នៅដោយខុសច្បាប់នៅទីនោះ បង្កើតជាបញ្ហាសម្រាប់ប្រទេសគេថែមទៀត ... មានការរត់ពន្ធមនុស្សរហូតទៅដល់មជ្ឈិមបូព៌ា។** ខ្ញុំគួរតែនិយាយថា អះម៉ាត់យ៉ាស់យ៉ា ដែលជាមូស្លីមដែរ ជាសមាជិកសភានិងជាថ្នាក់ដឹកនាំរដ្ឋលេខាធិការក្រសួងសាធារណការ ចុងក្រោយនេះជារដ្ឋលេខាធិការក្រសួងសង្គមកិច្ច ក៏ត្រូវបានចាប់ខ្លួនផ្តន្ទាទោស ដោយសារគាត់នាំក្មួយៗស្ត្រីជនជាតិឥស្លាមទៅដល់មជ្ឈិមបូព៌ាឯណោះ ...៕

៨៥. ពីប្រភពនៃការជួញដូរ កម្ពុជាក្លាយជាគោលដៅនៃការជួញដូរ

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

... សភាពការណ៍បានដើរខុសពីនេះ **គឺចាប់ផ្តើមពីកម្ពុជាទៅកការងារធ្វើនៅក្រៅប្រទេសមកជាត្រូវគេជួញដូរ។ ឥឡូវបែរជាមានជនបរទេសត្រូវគេជួញដូរយកមកស្រុកខ្មែរវិញម្តង ... មុននេះ មានតែខ្មែរទេ ត្រូវគេជួញដូរទៅក្រៅ។ ឥឡូវមានជនបរទេសត្រូវគេជួញដូរចូលស្រុកខ្មែរទៅវិញ។** តើផ្តើមចេញពីអ្វី ? ... វាទាក់ទិនជាមួយនឹងការដែលកម្ពុជាមានសន្តិភាព។ បើមិនមានសន្តិភាពទេ នរណាមកកម្ពុជា។ ប៉ុន្តែមួយទៀត ក៏ផ្តើមចេញពីចំណុចខ្សោយណាមួយដែលបង្កើតឱ្យមានច្រកដែលគេជ្រៀតចូលមកធ្វើអាជីវកម្មក្នុងប្រទេសរបស់យើង ...៕

៨៦. គណៈប្រតិភូទៅបរទេស គប្បីបង្ការករណីមនុស្សទៅមិនវិលចូលប្រទេសវិញ

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

... ការជួញដូរនេះទៀត ខ្លះធ្វើឱ្យខូចកេរ្តិ៍ឈ្មោះ ឧទាហរណ៍ ចេញទៅសហរដ្ឋអាមេរិក ដោយមានទិដ្ឋាការត្រឹមត្រូវ។ **គណៈប្រតិភូខ្លះ ជាក់មនុស្សទៅជាមួយដែលមនុស្សទាំងនោះទៅដល់អាមេរិកហើយ មិនព្រមត្រឡប់មកវិញ ... ខ្លះថា សុំទៅជាមួយ តែពេលទៅដល់ក៏ស្រាប់តែមិនមកវិញ**។ ដល់អញ្ចឹង អាមេរិកមិនមែនជាក់ទណ្ឌកម្មត្រឹមតែអ្នកដែលទៅស្នាក់នៅខុសច្បាប់នៅអាមេរិកទេ ជាក់ទាំងប្រធានគណៈប្រតិភូហ្នឹងតែម្តង ដែលថ្ងៃក្រោយលែងចូលអាមេរិកបាន។ **នេះជាការផ្តាំផ្ញើដើម្បីរក្សានូវភាពថ្លៃថ្នូររបស់គណៈប្រតិភូកម្ពុជាទៅប្រទេសនានា មិនមែនតែអាមេរិកទេ ជួនកាលទៅបារាំង ជួនកាលទៅអឺរ៉ុបក៏មានជាក់មនុស្សទៅដែរ** ...៕

៨៧. កុំឲ្យកម្ពុជាក្លាយជាឋានសួគ៌នៃឧក្រិដ្ឋកម្ម កន្លែងលាងលុយ កន្លែងជួញដូរមនុស្ស

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

... មានតែប្រើប្រាស់វិធីអប់រំក្នុងវិស័យសាសនា និងការអប់រំតាមផ្លូវរដ្ឋទេ ទើបអាចបញ្ចៀសអំពើទុច្ចរិតទាំងឡាយ។ បើយើងធ្វើបាន ប្រជាជននឹងសល់លុយព្រោះអត់យកលុយទៅចាញ់ល្បែងអីផង។ កម្លាំងពាក់ព័ន្ធទាំងអស់ធ្វើសកម្មភាពព្រមៗគ្នា ទើបអាចជោគជ័យទៅបាន។ ចំណុចចុងក្រោយ**ក្នុងប៉ុន្មានខែនេះ យើងប្រឹងប្រែងកុំឲ្យកម្ពុជាក្លាយទៅជាឋានសួគ៌នៃឧក្រិដ្ឋកម្ម ជាកន្លែងលាងលុយ និងជាកន្លែងជួញដូរមនុស្ស**។ សម្តេចក្រឡាហោម បានរាយការណ៍ឲ្យខ្ញុំបន្តបន្ទាប់។ យើងអត់នឹកដល់ថាមានជនជាតិបរទេសមកចាញ់បោកគេអស់មិនចេះតិច ក្នុងហ្នឹងចូលដល់រាប់ពាន់នាក់ ... **ជនបរទេសរាប់ម៉ឺននាក់ តាំងពីឥណ្ឌូនេស៊ី ម៉ាឡេស៊ី ដែលត្រូវគេទាញយកមកធ្វើការនៅស្រុកខ្មែរ** ...។

៨៨. ថ្ងៃ២០ សីហា រៀងរាល់ឆ្នាំ ជាទិវាអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

... ចាប់ពីឆ្នាំនេះតទៅ **រាជរដ្ឋាភិបាលកំណត់យកថ្ងៃ២០ ខែសីហា ជារៀងរាល់ឆ្នាំធ្វើជា «ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស» ... អាចមានការជួបជុំតាមខេត្តដែលមានសាសនា មានការជួបជុំតាមស្រុក និងបើសិនជាអាចធ្វើកាន់តែល្អ គឺសាសនាទាំងឡាយនៅភូមិនិងឃុំស្រាប់**។ ប្រសិនបើមានទាំងឥស្លាមក៏នៅហ្នឹង ព្រះពុទ្ធក៏នៅហ្នឹង គ្រីស្តក៏នៅហ្នឹង គឺយើងធ្វើនៅក្របខ័ណ្ឌមូលដ្ឋាន ដើម្បីឲ្យយើងរកឃើញចំណុចខ្លាំង ចំណុចខ្សោយនៃភូមិ/ឃុំមានសុវត្ថិភាព ... មិនមែនធ្វើសកម្មភាពប្រឆាំងការជួញដូរមនុស្សត្រឹមតែមួយថ្ងៃទី២០ សីហាទេ គឺធ្វើ ៣៦៥ថ្ងៃ ...។

៨៩. គ្រប់តួអង្គពាក់ព័ន្ធទាំងប្រដាប់អាវុធទាំងច្បាប់ ត្រួតពិនិត្យការណើជនបរទេសនៅស្របច្បាប់ឬមិនស្របច្បាប់

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

... ដោយកិច្ចសហប្រតិបត្តិការ និងការយោគយល់នៃអន្តរសាសនា ដែលទទួលបានការជឿទុកចិត្តគ្នា សុខដុមនីយកម្មជាតិសាសន៍ និងសាសនា នៅក្នុងប្រទេសនឹងបើកឱកាសឲ្យយើងធ្វើកិច្ចសហការនេះបានយ៉ាងល្អ។ **តួអង្គពាក់ព័ន្ធរបស់រដ្ឋក៏ត្រូវធ្វើសកម្មភាពដោយព្រមៗគ្នា មិនមែនគ្រាន់តែក្រសួងមហាផ្ទៃម្នាក់ឯងធ្វើគ្រប់ទេ មិនមែនតែនគរបាលមួយធ្វើគ្រប់ទេ គ្រប់កម្លាំងទាំងអស់ត្រូវធ្វើ ដោយក្នុងនោះស្ថាប័នសំខាន់ៗ មានមហាផ្ទៃ ការពារជាតិ ដែលទាក់ទងនឹងអាវុធហត្ថ ផ្នែកច្បាប់គឺទាក់ទងជាមួយក្រសួងយុត្តិធម៌ ក្រសួងការងារ ស្តីពីអ្នកដែលមកនៅស្រុកយើងស្របឬមិនស្របច្បាប់ មានបណ្ណការងារឬអត់** ...។

៩០. សូមគ្រប់សាសនានៅកម្ពុជាចូលរួមប្រឆាំងនឹងការជួញដូរមនុស្ស

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

... **រាជរដ្ឋាភិបាលក៏ត្រូវការ ការចូលរួមពីគ្រប់សាសនានៅកម្ពុជាប្រឆាំងនឹងការជួញដូរមនុស្ស** ... សូមឆ្លៀតធ្វើការវាយតម្លៃលើស្ថានការណ៍ខ្លះជាក្របខ័ណ្ឌរួមនិងជាក្របខ័ណ្ឌដោយឡែកសម្រាប់ប្រទេសកម្ពុជា។ ប្រសិនបើគ្មានការបកស្រាយច្បាស់លាស់ទេ ប្រទេសយើងក៏គេអាច(ត្រូវបាន)ចាត់ទុកថាជាប្រទេសដ៏អាក្រក់បំផុតនៅលើលោក ... កម្ពុជាមិនជាប្រទេសល្អឯកទេ តែសូមឱ្យអ្នកដទៃទៀតកុំឆ្លៀតឱកាសបង្អាប់ថា ជាប្រទេសអាក្រក់នៅលើលោក ... មិនមានតែប្រទេសកម្ពុជាមួយទេ ... យើងក្រឡេកមើលទៅសហរដ្ឋអាមេរិក និងតំបន់អាមេរិក (មានករណី)រហូតដល់អតីតប្រធានាធិបតី ដូណាល់ ត្រាំម៍ ចង់ធ្វើរបងរវាងសហរដ្ឋអាមេរិក និងម៉ិចស៊ីក។ (បំណងធ្វើដូចនោះ) សំដៅដោះស្រាយអី? ...។

៩១. បំបាត់ល្បែងស៊ីសង ការជួញដូរគ្រឿងញៀន ជាធាតុផ្សំទប់ស្កាត់ការជួញដូរមនុស្ស

វេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទី៦ ឆ្នាំ២០២២, ២៩ កញ្ញា ២០២២

... ជាមួយយុទ្ធនាការមានគោលដៅជាក់លាក់ ដែលយើងបាននិងកំពុងធ្វើរួចមកហើយនេះ ... ជឿជាក់ថា យុទ្ធនាការបង្ក្រាបល្បែងស៊ីសងនឹងរួមចំណែកកាត់បន្ថយការជួញដូរមនុស្សនិងបង្កើនសុវត្ថិភាពភូមិឃុំមានសុវត្ថិភាព ព្រោះកាលណាចាញ់ល្បែងហើយ ចាប់ផ្តើមមានបញ្ហាហើយ។ ដំបូងបញ្ហាខ្លួនឯងអស់លុយ ដើម្បីនឹងធ្វើកិច្ចការនេះ ក៏កើតមានជម្លោះក្នុងគ្រួសារ ... **ដើម្បីភូមិឃុំមានសុវត្ថិភាពវិធីដែលល្អ គឺជំរុញអនុវត្តបំបាត់ល្បែងស៊ីសង បំបាត់ការជួញដូរគ្រឿងញៀននៅឯមូលដ្ឋានដែលនោះ វាជាធាតុផ្សំសម្រាប់ការទប់ស្កាត់ការជួញដូរមនុស្ស។ ប្រជាពលរដ្ឋរបស់យើងនឹងសន្សំបានប្រាក់កាក់ និងមានសុខដុមរមនា** ...។

៩២. ពង្រឹងសមត្ថភាពកម្លាំងនិងច្បាប់ ប្រឆាំងការជួញដូរគ្រឿងញៀន/មនុស្ស/ភេរវកម្ម

បើកសិក្ខាសាលាស្តីពីសន្តិសុខលំហសមុទ្រ, ២៦ ឧសភា ២០០៩

... យើងមិនត្រូវភ្លេចថា តំបន់សមុទ្រដ៏តូចរបស់យើងនេះ អាចក្លាយទៅជាតំបន់ជ្រកកោនតាមរយៈធ្វើជារបៀបនាវាទេសចរណ៍ ឬនាវានេសាទស្តីៗរបស់ពួកមេដឹកនាំភេរវកម្ម រួចបញ្ជាចេញពីដែនទឹក កម្ពុជា ឬក៏សមុទ្រអន្តរជាតិ ដែលនៅជាប់កៀកនឹងកម្ពុជា។ ដូច្នេះហើយ **យើងត្រូវពង្រឹងសមត្ថភាពនៃកម្លាំង និងច្បាប់អនុវត្តមិនត្រូវបណ្តែតបណ្តោយឱ្យសកម្មភាពណាមួយ ចេញពីទឹកដីរបស់យើងនោះទេ ទោះបីថាវាបំផ្លាញទឹកដីរបស់យើង តាមរយៈការជួញដូរគ្រឿងញៀន ការត់ពន្ធមនុស្ស ឬរកស៊ីគេចពន្ធ ឬអំពើភេរវកម្ម** ...។

៩៣. ទាមទារតាក់តែងច្បាប់បទដ្ឋាន ស្របតាមច្បាប់បទដ្ឋានអន្តរជាតិ

បើកសិក្ខាសាលាស្តីពីសន្តិសុខលំហសមុទ្រ, ២៦ ឧសភា ២០០៩

... ពេលនេះ យើងកំពុងរុករកប្រេងនិងឧស្ម័ន ទាមទារឱ្យយើងត្រូវតែមានការលើកកម្ពស់កម្រិតសមត្ថភាពអំពីប្រតិបត្តិការការពាររបស់យើង ចំពោះបណ្តាក្រុមហ៊ុននានាដែលដាក់ទុនធំៗ ក្នុងដែនសមុទ្ររបស់យើង ... **បើយើងការពារមិនបាន បែរជាភេរវកម្ម ឬក្រុមចោរសមុទ្រវាយប្រហារ ឬចាប់ជំរិតទៅលើនាវាទាំងនោះគឺជាប្រការគ្រោះថ្នាក់ធំ ... កងកម្លាំងតែមួយមុខមិនគ្រប់ទេ។ យើងត្រូវមានច្បាប់បទដ្ឋានត្រឹមត្រូវរាប់ទាំងការកសាងច្បាប់ឱ្យស្របតាមបទដ្ឋានអន្តរជាតិ** ...។

១៧. កថ្នការមីន និងគ្រាប់មិនទាន់ផ្ទុះ

១	SNC និង UNTAC ប្រជុំនៅប្រាសាទខេមរិន្ទសំរេចរួមគ្នាពីការបំផ្លាញគ្រាប់មីន	៣១៥
២	កម្ពុជាមានជនរងគ្រោះពីគ្រាប់មីន/សំណល់ជាតិផ្ទុះច្រើនជាងគេលើពិភពលោក	៣១៥
៣	បំផ្លាញគ្រាប់មីនអស់ឆ្នាំ២០២៥ ជាយុទ្ធសាស្ត្រដឹកនាំប្រទេសឆ្នាំ២០២៣-២៨	៣១៦
៤	កងវរសេនាតូចនារី កសាងពេលវាយ ប៉ុល ពត ដោះមីននៅខេត្តស្វាយរៀង	៣១៦
៥	មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នៅជាឧបសគ្គ១០% ក្នុងតំបន់ព្រំដែនអភិវឌ្ឍ/ទីផ្សារ	៣១៧
៦	រៀបចំបន្ទាន់ «មូលនិធិគ្មានមីន ឆ្នាំ២០២៥»	៣១៧
៧	ប្រកាសដាក់ខេត្ត ស្រុក ឃុំ ជាបណ្តើរៗ ពីការអស់មីន	៣១៨
៨	នឹងប្រកាសឃុំប៉ោយចារនិងអាងត្រពាំងថ្មជាតំបន់គ្មានមីននៅចុងឆ្នាំ២០២២	៣១៨
៩	ផ្តួបថវិកាជាតិនិងថវិកាសប្បុរសជន ធ្វើឱ្យកម្ពុជាគ្មានមីន/មានតែស្នាមញញឹម	៣១៩
១០	រាល់ការសាងសង់នៅកម្ពុជា ត្រូវចំណាយលើការរកមីននិងគ្រាប់មិនទាន់ផ្ទុះ	៣១៩
១១	បន្ថយចំណាយទ្រទ្រង់អ្នកប៉ះពាល់ពីកូវីដ១៩ ធ្វើលំហូរថវិកាទៅសកម្មភាពមីន	៣១៩
១២	សុំពីមិត្តភក្តិខាងក្រៅ ពីសប្បុរសជនក្នុងស្រុក ប្រើថវិកាជាតិ ដោះមីនពីទឹកដី	៣២០
១៣	កម្ពុជាក្លាយជាប្រទេសនាំមុខផ្នែកបោសសំអាត/កំចាត់មីន	៣២០
១៤	រុករកនិងបំផ្លាញគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ ជាគោលដៅមួយនៃការអភិវឌ្ឍ	៣២១
១៥	កម្ពុជាដាក់ការកំចាត់មីនជាគោលដៅទី៩ នៃគោលដៅអភិវឌ្ឍន៍សហវត្សរ៍	៣២១
១៦	កម្ពុជាគ្មានការចាំបាច់នឹងដាក់មីននៅលើទឹកដីខ្លួនបន្ថែមទេ	៣២២
១៧	ឆ្នាំ២០២៥បំផ្លាញមីនឱ្យអស់ដើម្បីប្រជាពលរដ្ឋទទួលបានដីដោយគ្មានគ្រោះថ្នាក់	៣២២
១៨	ពីរងគ្រោះដោយសារមីន កម្ពុជាចែករំលែកចំណេះដឹងនិងបទពិសោធន៍ពីមីន	៣២៣
១៩	ប្រទេសរងគ្រោះដោយគ្រាប់មីន មករៀនសូត្រនិងរំលែកបទពិសោធន៍ពីកម្ពុជា	៣២៣
២០	ប្រកាសទទួលហ្វឹកហ្វឺនអ្នកដោះមីន ដល់ប្រទេសដែលត្រូវការ	៣២៤
២១	ករណីកម្ពុជាជួយបណ្តុះបណ្តាលអ្នកដោះមីនឱ្យអ៊ុយក្រែនជាកិច្ចការមនុស្សធម៌	៣២៤
២២	កម្ពុជាមិនបានបញ្ជូនកងទ័ព និង/ឬគ្រូបង្វឹកដោះមីន ទៅអ៊ុយក្រែនទេ	៣២៥
២៣	ស្នើឱ្យកងទ័ពចិនជួយកម្ពុជាបំផ្លាញចោលគ្រាប់មីនឱ្យអស់ក្នុងឆ្នាំ២០២៥	៣២៥

១. SNC និងអ៊ុនតាក់ប្រជុំនៅប្រាសាទខេមរិន្ទសំរេចរួមគ្នាពីការបំផ្លាញចោលគ្រាប់មីន

បិទសន្និបាតជាតិ ប្រារព្ធខួប ៣០ឆ្នាំនៃសកម្មភាពមីននៅកម្ពុជា ក្រោមប្រធានបទ «ផ្តល់ដីសុវត្ថិភាព បង្កើតស្នាមញញឹម», ២២ វិច្ឆិកា ២០២២

... ឆ្នាំនេះជាខួបទី៣០ (នៃសកម្មភាពដោះមីន)។ ដើម្បីនឹងយល់ច្បាស់ថា តើសកម្មភាពមីនចាប់ផ្តើមពីណា នៅពេលណា និងរបៀបដូចម្តេច ... ខ្ញុំសូមជំរាបថា **(គំនិតផ្តើមស្តីពី)ការបំផ្លាញចោលគ្រាប់មីននេះ ទទួលបានការសម្រេចរួមគ្នារវាង (ក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា) SNC និងអ៊ុនតាក់ (អាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា)។ ការប្រជុំស្តីពីកិច្ចការនេះ ត្រូវបានធ្វើនៅប្រាសាទខេមរិន្ទ** ក្រោមព្រះរាជធិបតីភាពរបស់ព្រះករុណាព្រះបិតា ព្រះបរមរតនកោដ្ឋ ជាមួយប្រធាន អ៊ុនតាក់ លោក យ៉ាស៊ូស៊ី អាកាស៊ី។ **នៅគ្រាចាប់ផ្តើម ការប្រជុំរវាង SNC និងអ៊ុនតាក់ ធ្វើនៅព្រះបរមរាជវាំង មិនទាន់មកប្រជុំនៅដំណាក់ច័ន្ទនៅឡើយទេ ... នោះជាព្រះរាជតម្រិះគាំទ្ររបស់អតីតព្រះមហាក្សត្រ សម្តេចឪដែលព្រះអង្គបានយកព្រះទ័យទុកដាក់លើកិច្ចការងារនេះ រួមដោយការគាំទ្រពីសមាជិកក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទាំងអស់** ... ៣០ឆ្នាំហើយតែនៅដោះមិនទាន់អស់ ...។

២. កម្ពុជាមានជនរងគ្រោះពីគ្រាប់មីននិងសំណល់ជាតិផ្ទុះច្រើនជាងគេលើពិភពលោក

បិទសន្និបាតជាតិវិស័យសកម្មភាពមីនក្រោមប្រធានបទ «ឆ្ពោះទៅរកកម្ពុជាមួយដែលគ្មានមីន ឆ្នាំ២០២៥», ១៧ ឧសភា ២០១៨

... កេរដំណែលគ្រាប់មីននិងសំណល់ជាតិផ្ទុះនៅកម្ពុជា ត្រូវបានបន្សល់ទុកពីសម័យសង្គ្រាមនិងជម្លោះផ្ទៃក្នុងរាប់ទសវត្សរ៍ ធ្វើឱ្យក្លាយជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសដែលរងផលប៉ះពាល់ និងមានជនរងគ្រោះដោយសារគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមច្រើនជាងគេបំផុតក្នុងពិភពលោក។ តាមប្រព័ន្ធព័ត៌មាន (CMMIS) ជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅកម្ពុជា គិតចាប់តាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ២០១៧ មានចំនួន ៦៤៦៨៨នាក់។ ដោយមានការខិតខំរកមធ្យោបាយដោះស្រាយបញ្ហា រហូតឈានដល់ការគ្រប់គ្រងបានល្អប្រសើរនូវការងារកំចាត់សម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ព្រមទាំងការអប់រំដើម្បីកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន កម្ពុជាបាន

ទាញចំនួនគ្រោះថ្នាក់ពី ៤៣២០នាក់ក្នុងឆ្នាំ១៩៩៦ មកនៅចំនួនប្រហែល ១០០ នាក់ ក្នុងមួយឆ្នាំជាមធ្យម ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ...។

៣. បំផ្លាញគ្រាប់មីនអស់ក្នុងឆ្នាំ២០២៥ ជាយុទ្ធសាស្ត្រដឹកនាំប្រទេសឆ្នាំ២០២៣-២៨

បើកការដ្ឋានពង្រីក ស្តារ និងលើកកម្រិតគុណភាពផ្លូវជាតិលេខ ៤១ ពីថ្នល់ទទឹង ត ភ្ជាប់ទៅកាន់ខេត្តកំពត, ២៦ ធ្នូ ២០២២

... គោលដៅដែលខ្ញុំបានដាក់ចេញ បន្ទាប់ពីអនុវត្តន៍នយោបាយឈ្នះឈ្នះ មាន ២ចំណុចធំគឺ ទី១ ប្រែក្លាយតំបន់អតីតសមរភូមិឱ្យក្លាយទៅជាតំបន់អភិវឌ្ឍន៍ និងទី២ ប្រែក្លាយព្រំដែនជាមួយប្រទេសជិតខាងជាខ្សែព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍន៍ ... មកដល់ពេលនេះ យើងសម្រេចបានគោលដៅទី១ ភាគច្រើនហើយ តែនៅសេសសល់តំបន់មួយចំនួនដែលមិនទាន់បានដោះមីន ... ថ្ងៃមុន(**គណៈ)អចិន្ត្រៃយ៍គណបក្សប្រជាជន(កម្ពុជាបានប្រជុំ) បានដាក់ចេញយុទ្ធសាស្ត្រមួយគឺបំផ្លាញចោលគ្រាប់មីនឱ្យអស់ក្នុងឆ្នាំ២០២៥ ដែលជាយុទ្ធសាស្ត្រ សម្រាប់ការដឹកនាំប្រទេសសម្រាប់ឆ្នាំ២០២៣ ដល់២០២៨** ដែលក្នុងខែ មករា២០២៣ គណបក្សប្រជាជននឹងបើកមហាសន្និបាត ដើម្បីអនុម័តលើមាគាគោលនយោបាយរបស់ខ្លួនសម្រាប់អាណត្តិបន្ត ...។

៤. កងវរសេនាតូចនារី កសាងពេលវាយ ប៉ុល ពត ដោះមីននៅខេត្តស្វាយរៀង

សំណេះសំណាលជាមួយកម្មករវាងចក្រនៅតំបន់សេដ្ឋកិច្ចពិសេស Manhattan ក្រុងបាវិត ខេត្តស្វាយរៀង, ២៥ មិថុនា ២០២៣

... (គោលនយោបាយដែល)ខ្ញុំបានដាក់ចេញថាត្រូវប្រែក្លាយអតីតសមរភូមិឱ្យទៅជាទីផ្សារ និងប្រែក្លាយខ្សែព្រំដែនជាមួយប្រទេសជិតខាង ឱ្យទៅជាព្រំដែនសន្តិភាព មិត្តភាព និងសហប្រតិបត្តិការ កំពុងទទួលបានជោគជ័យ។ លើការដាក់ស្តែង តើអ្វីទៅដែលហៅថាប្រែក្លាយតំបន់អតីតសមរភូមិឱ្យទៅជាតំបន់អភិវឌ្ឍ? នោះគឺជាការដាក់ទិសដៅដោះនិងបំផ្លាញចោលគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ជានាសុវត្ថិភាពជីវិតឱ្យប្រជាពលរដ្ឋ។ **ស្វាយរៀង ជាសំបុក/ចំការមីនតាំងពីពេលវរដោះប្រទេសមក។ កាលនោះ កងវរសេនាតូចនារី ជាកងទ័ពដែលខ្ញុំបានកសាង**

ពេលវាយ ប៉ុល ពត ត្រូវ(បានប្រគល់ភារកិច្ចឱ្យ)មកដោះមីននៅខេត្តស្វាយរៀង។ ហេតុនេះហើយ បានជាមានវរនារី គង់ សារឿន (ដែលល្បីល្បាញខាងដោះមីន)។ យើងក៏បានប្រើកងអនុសេនាធំនារីដើម្បីដោះបំផ្លាញចោលគ្រាប់មីនដែរ ...។

៥. មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នៅជាឧបសគ្គ១០% ក្នុងតំបន់ព្រំដែនអភិវឌ្ឍនិងទីផ្សារ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់សេដ្ឋកិច្ចពិសេសនាងកុក ខេត្តកោះកុង, ១៣ មីនា ២០១៩

... បន្ទាប់ពីនយោបាយឈ្នះឈ្នះ (បំណងជា)យុទ្ធសាស្ត្រ២ ដែល ហ៊ុន សែន បានដាក់ចេញ និងដឹកនាំរួមមាន ទី១ ប្រែក្លាយតំបន់អតីតសមរភូមិទាំងអស់ឱ្យទៅជាតំបន់អភិវឌ្ឍន៍ និងទៅជាទីផ្សារ។ គោលបំណងនេះបាន និងកំពុងទទួលជោគជ័យ**អាចថា៩០%រួចហើយ។នៅសល់១០%(ដែលមិនទាន់សំរេចបាន)។ មិនមែនរារាំងដោយនយោបាយទេ។ តែរារាំងដោយឃាតករលាក់មុខ គឺគ្រាប់មីនគ្រាប់មិនទាន់ផ្ទុះ។ យើងចាំបាច់ត្រូវដោះនិងបំផ្លាញចោលគ្រាប់ទាំងនោះ ដើម្បីឱ្យទីនោះក្លាយទៅជាតំបន់ដាំដុះរបស់កសិករ។ ឯទី២ នយោបាយកសាងខ្សែព្រំដែនជាមួយប្រទេសជិតខាង ឱ្យទៅជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ បាន និងកំពុងទទួលជោគជ័យ** ...។

៦. រៀបចំបន្ទាន់ «មូលនិធិគ្មានមីន ឆ្នាំ២០២៥»

ចែកសញ្ញាបត្រជូនដល់និស្សិតនៃសាកលវិទ្យាល័យ វេស្ទើន, ២៦ មករា ២០២៣

...យើងបានប្រើពេល ៣០ឆ្នាំហើយ ក្នុងការដោះមីន(ក្នុងប្រទេសតែ)អត់ទាន់អស់ទេ។ ឥឡូវ យើងត្រូវវិនិយោគដោយគំហ៊ុក។ ថ្ងៃមុនសប្បុរសជនបានចូលរួមរាប់ទាំងព្រះករុណា ព្រះមហាក្សត្រ និងហ្លួងម៉ែ ជិត ១៩លានដុល្លារ ... **ខ្ញុំបានរៀបចំបន្ទាន់នូវ «មូលនិធិគ្មានមីនឆ្នាំ២០២៥»។ ដាក់ទុន ៣០លានដុល្លារភ្លាមចូលក្នុង មូលនិធិកម្ពុជាគ្មានមីនឆ្នាំ២០២៥ ដើម្បីឱ្យប្រតិបត្តិការដោះមីនទាំង CMAC កងកម្លាំងរក្សាសន្តិភាពហ្វឹកហាត់កម្លាំងដោះមីន និងបណ្តាអង្គភាពកងទ័ព ប្រើប្រាស់សម្រាប់ការដោះមីន រួមជាមួយធនធានប្រមូលបានពីក្រៅប្រទេស** ...។

៧. ប្រកាសដាក់ខេត្ត ស្រុក ឃុំ ជាបណ្តើរៗ ពីការអស់មីន

ទិវាមច្ឆជាតិ អាងទឹកត្រពាំងថ្ម ភូមិត្រពាំងថ្ម ឃុំប៉ោយចារ ខេត្តបន្ទាយមានជ័យ, ០១ កក្កដា ២០២២

... ពេលនេះ យើងចាប់ផ្តើមប្រកាសដាក់ខេត្ត/ស្រុក/ឃុំជាបណ្តើរៗ ជា(ខេត្ត/ស្រុក/ឃុំ)អស់មីន។ ខ្ញុំសុំឱ្យឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **ពិចារណាដាក់ចូលក្នុងថវិកាជាតិសម្រាប់ឆ្នាំ២០២៣-២០២៤ ខាងមុខ ជាដំណាក់ៗ ដើម្បីបង្កើយការដោះមីន ...** យើងប្រកាសថា ខេត្តកែបជាខេត្តដែលគ្មានមីនហើយ។ **កន្លែងខ្លះទៀតត្រូវការលុយត្រឹមតែ ៥ម៉ឺនដុល្លារទេ។ យើងទៅរកសុំបរទេស ... ឥឡូវដាក់ចូលក្នុងថវិកាជាតិដើម្បីបញ្ចប់នៅទីកន្លែងមួយចំនួនដែលជិតអស់ហើយប៉ុន្តែខ្វះលុយដោះ។** កម្លាំងដោះមីនជាកម្លាំង CMAC និង/ឬ កម្លាំងប្រតិបត្តិការជទៃទៀត ដូចវិស្វកម្មកងទ័ព ទាំងកងទ័ព អគ្គបញ្ជាការកងទ័ពទាំងជើងគោក ទាំងកម្លាំងប្រតិបត្តិការក្សាសន្តិភាពទៅក្រៅប្រទេស ប្រើប្រាស់ថវិកានោះបាសសម្អាតមីនហើយដាក់តំបន់ទាំងនោះជាតំបន់គ្មានមីន...។

៨. នឹងប្រកាសឃុំប៉ោយចារនិងអាងត្រពាំងថ្មជាតំបន់គ្មានមីននៅចុងឆ្នាំ២០២២

ទិវាមច្ឆជាតិ អាងទឹកត្រពាំងថ្ម ភូមិត្រពាំងថ្ម ឃុំប៉ោយចារ ខេត្តបន្ទាយមានជ័យ, ០១ កក្កដា ២០២២

... ខ្ញុំទទួលនូវរបាយការណ៍ថា ឃុំប៉ោយចារ ស្រុកភ្នំស្រុក អាងត្រពាំងថ្ម មានផ្ទៃដីដែលបានបោសសម្អាតមីនរួចចំនួន ១,២៣ គីឡូម៉ែត្រក្រឡា (តួលេខជាក់ស្តែង ១២៣៨០២៧ ម៉ែត្រក្រឡា) ... ផ្ទៃដីនៅសល់មានចំនួន ០,២៤ គីឡូម៉ែត្រក្រឡា(តួលេខជាក់ស្តែង ២៤៥៦៧៣ម៉ែត្រក្រឡា) ស្មើនឹងចំការមីន៦ ប្រមាណ ៩៨% នៃផ្ទៃដីមានមីននៅទូទាំងស្រុកភ្នំស្រុក ... **ខ្ញុំស្នើឱ្យផ្តោចព្រ័ត្រទៅលើការដោះមីននៅលើផ្ទៃដីដែលនៅសេសសល់។ សូមឯកឧត្តម អ៊ំ រាត្រី ធ្វើការភ្លាមជាមួយអាជ្ញាធរមីនបញ្ជូនកម្លាំងចុះដោះឱ្យអស់ ហើយប្រកាសឃុំប៉ោយចារក៏ដូចជាអាងត្រពាំងថ្មជាតំបន់គ្មានមីន។ ទោះបីដោយតម្លៃណាក៏ដោយ ត្រូវតែដោះមីននៅតំបន់នេះ ហើយធ្វើម៉េចនៅចុងឆ្នាំ(២០២២)នេះយ៉ាងយូរ ត្រូវតែប្រកាសតំបន់នេះជាតំបន់គ្មានមីនដើម្បីធានាសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋ ...**។

៩. ផ្តួបរវាងថវិកាជាតិនិងថវិកាសប្បុរសជន ធ្វើឱ្យកម្ពុជាគ្មានមីននិងមានតែស្នាមញញឹម

ទិវាមច្ឆជាតិ អាងទឹកត្រពាំងថ្ម ភូមិត្រពាំងថ្ម ឃុំប៉ោយចារ ខេត្តបន្ទាយមានជ័យ, ០១ កក្កដា ២០២២

... សូមអំពាវនាវចំពោះវិស័យឯកជន។ ប្រសិនបើមានបំណង ខ្ញុំសូមអរគុណទុកជាមុនទទួលយកការរួមចំណែកដោះមីននៅកន្លែងណាមួយ ឧទាហរណ៍ថាកន្លែងខ្លះត្រូវការត្រឹមតែ ១០ម៉ឺនដុល្លារប៉ុណ្ណឹងទេ។ ដូចមានភូមិមួយ ឥណ្ឌាជួយ ៥ម៉ឺនដុល្លារដើម្បីបញ្ចប់(ការដោះមីន)។ អញ្ចឹងទេ **យើងអាចប្រើការគួបផ្សំពីរៗ មួយថវិកាជាតិ និងមួយទៀតថវិកាសប្បុរសជនចូលរួមដើម្បីបង្កើតសុវត្ថិភាព ... ធ្វើឱ្យប្រទេសកម្ពុជាជាប្រទេសដែលអត់មានមីន(សម្លាប់មនុស្ស) តាមការគ្រោងទុក ...ជាពិសេស ជានាថាកន្លែងហ្នឹងមិនមាន(ការ)ភ័យខ្លាចតែមានស្នាមញញឹមជំនួសឱ្យទឹកភ្នែករបស់ប្រជាជនពីអតីតកាល ...**។

១០. រាល់ការសាងសង់នៅកម្ពុជា ត្រូវចំណាយលើការរកមីននិងគ្រាប់មិនទាន់ផ្ទុះ

បើកការដ្ឋានធ្វើឱ្យប្រសើរឡើងវិញផ្លូវជាតិលេខ២ និងផ្លូវជាតិលេខ២២, ១១ កុម្ភៈ ២០២០

... **នៅកម្ពុជា រាល់ការសាងគ្រប់ទីកន្លែងត្រូវចំណាយខ្ពស់ជាងនៅប្រទេសជទៃត្រង់ថា គំរោង/កន្លែងណាក៏ត្រូវតែរាវ(រក)មីនដែរ។** មីននិងគ្រាប់មិនទាន់ផ្ទុះតម្រូវឱ្យធ្វើការចំណាយ។ បើមិនដូច្នោះទេ នឹងមានការសង្ស័យពីគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ និង/ឬដែលអាចនាំដល់ការបាត់បង់អាយុជីវិត អ្នកដែលកំពុងធ្វើការសាងសង់ ឬក៏គ្រោះថ្នាក់សម្រាប់ប្រជាពលរដ្ឋទៀតផង ... ដូច្នេះហើយ **យើងតែងយកចិត្តទុកដាក់លើការដោះស្រាយផលប៉ះពាល់នេះម្ខាង និងម្ខាងទៀតត្រូវតែស្វែងរកគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ដោយសារតែប្រទេសយើងធ្លាប់មានសង្គ្រាម** ដែលតែងតែមានគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះនៅកន្លែងនេះ/នោះ ...។

១១. បន្តយចំណាយទ្រទ្រង់អ្នកងផលប៉ះពាល់ពីកូវីដ១៩ ធ្វើលំហូរថវិកាទៅសកម្មភាពមីន

បិទសន្និបាតជាតិប្រារព្ធខួប ៣០ឆ្នាំ នៃសកម្មភាពមីននៅកម្ពុជា ក្រោមប្រធានបទ «ផ្តល់ជីសុវត្ថិភាព បង្កើតស្នាមញញឹម», ២២ វិច្ឆិកា ២០២២

... ខ្ញុំគិតថាមានវិធីបង្កើនទំហំថវិកាជាតិសម្រាប់ការវិនិយោគទៅលើការដោះមីននេះ។ ដូចដែលយើងបាននឹងកំពុងបញ្ចេញថវិកាប្រមាណ ៤០លានដុល្លារអាមេរិក/ខែ ចិញ្ចឹមប្រជាជនរងផលប៉ះពាល់ពីជំងឺកូវីដ-១៩នេះ។ ខ្ញុំមានអារម្មណ៍ថានៅពេលដែលកូវីដ-១៩ធូរស្រាល យើង**អាចការកាត់បន្ថយចំណាយសម្រាប់ទ្រទ្រង់ជីវភាពប្រជាពលរដ្ឋដែលរងផលប៉ះពាល់ និងធ្វើលំហូរថវិកានោះសម្រាប់សកម្មភាពមីនដែលមិនត្រូវឱ្យខ្វះឡើយ។ ខ្ញុំនឹងធ្វើការងារនេះ ... ដើម្បីធានាថាថវិកាត្រូវរុញទៅគ្រប់គម្រោង និងគ្រប់គោលដៅដែលបានដាក់ចេញ។ យើងត្រូវធ្វើការនេះដើម្បីធានាថាឆ្នាំ២០២៥ នឹងគ្មានគ្រាប់មីនទៀតទេ ...**។

១២. សុំពីមិត្តភក្តិខាងក្រៅ ពីសប្បុរសជនក្នុងស្រុក និងប្រើថវិកាជាតិ ដោះមីនពីទឹកដីកម្ពុជា

បិទសន្និបាតជាតិប្រារព្ធខួប ៣០ឆ្នាំនៃសកម្មភាពមីននៅកម្ពុជា ក្រោមប្រធានបទ «ផ្តល់ដីសុវត្ថិភាព បង្កើតស្នាមញញឹម», ២២ វិច្ឆិកា ២០២២

... បើគ្មានការប្តេជ្ញាចិត្ត គ្មានការតាំងចិត្ត យើងមិនអាចដោះមីនចេញពីទឹកដីកម្ពុជាបានទេ។ អញ្ចឹង មានតែអនុវត្តវិធី ម្ខាងអំពាវនាវមិត្តភក្តិពីខាងក្រៅ និងម្ខាងអំពាវនាវសប្បុរសជននៅក្នុងប្រទេស ដែលមានចិត្តចង់ចូលរួមជួយដោះមីននៅកម្ពុជា និងម្ខាងទៀតដែរ ប្រើថវិកាជាតិដើម្បីដោះស្រាយបញ្ហានេះ។ បើយើងបញ្ចប់បានបញ្ហាមីននៅកម្ពុជា វាជាកុសលផលបុណ្យដ៏វិសេស ត្បិតថាប្រទេសមួយនេះរងគ្រោះច្រើនពេកហើយ ... ខ្ញុំជាមួយឯកឧត្តមប្រាយុទ្ធ ចាន់អូចា នាយករដ្ឋមន្ត្រីថៃ បានឯកភាពគ្នាដោះមីននៅកន្លែងណាដែលមានមីន ដោយមិនគិតអំពីបញ្ហាព្រំដែនទេ។ រឿងនេះឯកឧត្តម ប៉ា គឹមហុង ត្រូវបន្តធ្វើការ ត្បិតបន្តិចទៀតត្រូវរួមដំណើរនឹង សម្តេចពិជ័យសេនា ទៀ បាញ់ ប្រជុំគណៈកម្មាធិការព្រំដែន ...។

១៣. កម្ពុជាក្លាយជាប្រទេសនាំមុខគេផ្នែកបោសសំអាតមីន

បិទសន្និបាតបូកសរុបលទ្ធផលការងារបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពអង្គការសហប្រជាជាតិ រយៈពេល ១០ឆ្នាំ (២០០៦-២០១៦), ០១ មីនា ២០១៦

... កម្ពុជាបានក្លាយទៅជាប្រទេសនាំមុខផ្នែកបោសសម្អាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដោយត្រូវបានអន្តរជាតិទទួលស្គាល់និងកោតសរសើរទាំងចំពោះសកម្ម

ភាពក្នុងស្រុកទាំងចំពោះសកម្មភាពក្នុងក្រខណ្ឌអង្គការសហប្រជាជាតិ។ អង្គការសហប្រជាជាតិបានស្នើខ្លឹកម្លាំងកងវិស្វកម្មកម្ពុជានៅ លីបង់ មកប្រតិបត្តិការបោសសំអាតមីននៅលើ កោះស៊ីព្រ ហើយសមាជិកនានានៃសហគមអាស៊ាន បានគាំទ្រកម្ពុជាធ្វើម្ចាស់ផ្ទះ មជ្ឈមណ្ឌលសកម្មភាពមីនតំបន់អាស៊ាន(ARMAC)។ ទាំងនេះជាសក្ខីភាពនៃការទទួលស្គាល់ស្នាដៃរបស់កម្ពុជា។ នេះគឺជាមោទនភាពបំផុតដែលទង់ជាតិកម្ពុជាបានបក់រីចៗ ជាមួយទង់ជាតិនៃបណ្តាប្រទេសដែលបរិច្ចាគកងទ័ពចូលរួមបំពេញបេសកកម្មក្រោមឆត្រអង្គការសហប្រជាជាតិ ...។

១៤. រុករកនិងបំផ្លាញគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ ជាគោលដៅមួយនៃការអភិវឌ្ឍ

បិទសន្និបាតជាតិវិស័យសកម្មភាពមីន ក្រោមប្រធានបទ «ឆ្ពោះទៅកេកម្ពុជាមួយដែលគ្មានមីន ឆ្នាំ២០២៥», ១៧ ឧសភា ២០១៨

... ក្នុងគោលដៅអភិវឌ្ឍសហស្សវត្សរ៍ គេមិនឃើញនៅក្នុងគោលដៅទាំងនោះមានការរុករក ឬក៏បំផ្លាញចោលគ្រាប់មីននោះទេ។ រហូតមកដល់ដំណាក់កាលនៃការអភិវឌ្ឍប្រកបដោយចីរភាពនេះទៀតសោត ក៏មិននិយាយផងដែរ។ យ៉ាងណាក្តី **កម្ពុជានៅតែជម្នះដាក់ជាគោលដៅអាទិភាពមួយ ក្នុងចំណោមគោលដៅអាទិភាពរបស់កម្ពុជា ... កម្ពុជាខ្លួនឯងត្រូវមានការទទួលខុសត្រូវ**។ (វ)មិនមែនដាឯកសារ(ក្នុង)ក្របខណ្ឌរបស់អង្គសហប្រជាជាតិ ដែលយកទៅអនុវត្តនៅគ្រប់ប្រទេសនោះទេ ព្រោះប្រទេសខ្លះគ្មានគ្រាប់មីន(ដែលកប់ក្នុងដី) ប៉ុន្តែ**ប្រទេសដែលមានគ្រាប់មីន(លាក់ក្នុងដី) ដូចជាកម្ពុជា បើមិនដាក់បញ្ចូលទៅក្នុងផែនការនិងទិសដៅជាក់លាក់ទេ យើងច្បាស់ជាមើលរំលងអ្វីដែលបាននិងកំពុងកើតនៅក្នុងប្រទេសជាមិនខាន ...**។

១៥. កម្ពុជាដាក់ការកំចាត់មីនជាគោលដៅទី៩ នៃគោលដៅអភិវឌ្ឍន៍សហវត្សរ៍

បិទសន្និបាតជាតិប្រារព្ធខួប ៣០ ឆ្នាំ នៃសកម្មភាពមីននៅកម្ពុជា ក្រោមប្រធានបទ "ផ្តល់ដីសុវត្ថិភាព បង្កើតស្នាមញញឹម", ២២ វិច្ឆិកា ២០២២

... គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍(សហប្រជាជាតិ) មានគោលដៅត្រឹមតែ៨ ប៉ុណ្ណោះ។ កម្ពុជាបានដាក់ចេញនូវគោលដៅទី៩ គឺបញ្ហាមីន។ ឯគោលដៅការ

អភិវឌ្ឍដោយចីរភាព ក៏អង្គការសហប្រជាជាតិដាក់ចេញតែ ១៧គោលដៅ ប៉ុន្តែយើងបានដាក់ចេញនូវគោលដៅរហូតដល់ ១៨ គឺបន្ថែមបញ្ហាមីនមួយទៀត។ ជាក័ព្វសំណាង UNDP ដៃគូ និងអគ្គលេខាធិការអង្គការសហប្រជាជាតិបានទទួលស្គាល់នូវគោលដៅដែលយើងបានដាក់ចេញ ... ប្រទេសជាច្រើនជាអ្នកមាន គ្មានបញ្ហាមីន ដូច្នេះគេលើកគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ រហូតមកដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនេះ ដោយមិនដាក់ចេញគោលការណ៍ពីការបំផ្លាញគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះទេ។ ប៉ុន្តែ លើការដាក់ស្តែង សកម្មនៅទូទាំងទូទាំងពិភពលោកបច្ចុប្បន្ន មីនបានក្លាយទៅជាបញ្ហាប្រឈមមួយ ...។

១៦. កម្ពុជាគ្មានការចាំបាច់នឹងដាក់មីននៅលើទឹកដីខ្លួនបន្ថែមទេ

សន្និសីទកាសែតក្រោយប្រជុំគណៈរដ្ឋមន្ត្រី, ១៧ តុលា ២០០៨

... តាំងពីដើមមក យើងទទួលស្គាល់ថាជាមីនផលិតនៅសហភាពសូវៀតមែន តែមីននេះត្រូវបានដាក់តាំងពីទសវត្សឆ្នាំ ៨០។ មិនដឹងខាងណាអ្នកដាក់។ ខាងកងទ័ពអតីតរដ្ឋកម្ពុជាក៏មិនដឹង ខាងអតីតភាគីបដិបក្ខនៅជាយដែនក៏មិនដឹង? ប៉ុន្តែ ពេលនេះ ជាពេលដែលកម្ពុជាកំពុងបំផ្លាញចោលមីននេះ ទី១។ ទី២ យើងជាហត្ថលេខីនៃអនុសញ្ញា OTAWA ស្តីពីការហាមប្រើប្រាស់មីន។ យើងបានកម្ទេចមីនក្នុងឃ្លាំងចោលអស់ហើយ។ តើមានមីនឯណាយកទៅដាក់ទៀត? **កម្ពុជាគ្មានការចាំបាច់នឹងដាក់មីននៅលើដីរបស់ខ្លួនបន្ថែមទេ ត្បិតវាផ្ទុយពីគោលនយោបាយរបស់រាជរដ្ឋាភិបាល ផ្ទុយពីការខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការមីន ក្នុងនោះមានយន្តការកងវិស្វកម្ម CMAC, HELLO TRUST អង្គការ MAG ស្ថីៗច្រើនទៀតដែលកំពុងតែដោះមីន** ...។

១៧. ឆ្នាំ២០២៥ បំផ្លាញមីនឱ្យអស់ ដើម្បីប្រជាពលរដ្ឋទទួលបានដីដោយគ្មានគ្រោះថ្នាក់

ចែកសញ្ញាបត្រជូនដល់និស្សិតនៃសាកលវិទ្យាល័យ វ៉េស្លើន, ២៦ មករា ២០២៣

... ខ្ញុំបាននិយាយពីប្រវត្តិទំនាក់ទំនងរវាងសន្តិភាពនិងសង្គ្រាមបែកបាក់ ... ពេលនេះ **យើងមានឱកាសនៅគ្រប់ទីកន្លែងរុករកនិងបំផ្លាញចោលគ្រាប់មីនឱ្យអស់នៅត្រឹមឆ្នាំ២០២៥ ដើម្បីធានាថា ប្រជាជនទទួលបានដីធ្លីទៅ(ធ្វើផលិតកម្ម)គ្មានគ្រោះថ្នាក់ ឬអ្នកចូលចិត្តធ្វើដំណើរកំសាន្ត ឬក៏អត់ស្គាល់ភូមិសាស្ត្រ (អាចធ្វើសកម្មភាពបានដោយមិនមានគ្រោះថ្នាក់)។ យើងនឹងខិតខំបំផ្លាញមីនចោលឱ្យអស់ត្រឹមឆ្នាំ២០២៥។** យើងប្រើពេល ៣០ឆ្នាំហើយ ដើម្បីដោះ(មីន) ក៏ប៉ុន្តែវាមិនទាន់អស់ ដោយសារថាប្រទេសយើងមានសង្គ្រាមហ្នឹងវាធំពេក ...។

១៨. ពីរងគ្រោះដោយសារមីន កម្ពុជាចែករំលែកចំណេះដឹងនិងបទពិសោធន៍ពីមីន

បិទសន្និបាតជាតិវិស័យសកម្មភាពមីនក្រោមប្រធានបទ
«ឆ្ពោះទៅកេកម្ពុជាមួយដែលគ្មានមីន ឆ្នាំ២០២៥», ១៧ ឧសភា ២០១៨

... ក្នុងរយៈពេលនេះ កម្ពុជាទទួលបានចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់អំពីមីន ហើយបានប្រែពីប្រទេសដែលរងគ្រោះដោយសារគ្រាប់មីន ទៅជាប្រទេសដែលដែករំលែកចំណេះដឹងនិងបទពិសោធន៍ ប្រកបដោយជំនាញបោសសម្អាត (កំចាត់)គ្រាប់មីននៅលើឆាកអន្តរជាតិ ពិសេសបណ្តាប្រទេសដែលកំពុងជួបប្រទះបញ្ហាមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។ កម្ពុជាតែងបានទទួលគណៈប្រតិភូមកពីបណ្តាប្រទេសជាច្រើនមកទស្សនា រៀនសូត្រ និងទទួលបទពិសោធន៍ផងដែរ។ ចាប់ពីឆ្នាំ២០០៦ មកទោះបីកំពុងប្រឈមនឹងគ្រោះថ្នាក់ដោយសារមីន ក៏កម្ពុជាបានខិតខំចែករំលែកកងកម្លាំងបោសសម្អាតមីនរបស់ខ្លួន ទៅរួមចំណែកសំរាលទុក្ខលំបាកនៃប្រជាពលរដ្ឋ នៃប្រទេសដែលកំពុងប្រឈមនឹងរងគ្រោះថ្នាក់ដោយសារមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ...។

១៩. គណៈប្រតិភូប្រទេសរងគ្រោះដោយគ្រាប់មីនមករៀនសូត្រនិងរំលែកបទពិសោធន៍

បិទសន្និបាតជាតិវិស័យសកម្មភាពមីន, ២ មេសា ២០១៣

... ទិន្នន័យនេះបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីជោគជ័យដែលអាជ្ញាធរមីនកម្ពុជាខិតខំសម្រេចបាន សំដៅចូលរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ឆ្ពោះទៅវឌ្ឍនភាពវិបុលភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនយើង។ ជាមួយគ្នានេះ ចំណេះដឹងនិងបទពិសោធន៍របស់កម្ពុជាក្នុងវិស័យសកម្មភាពមីន ក៏ត្រូវបានចែករំលែកនៅលើឆាកអន្តរជាតិផងដែរ។ ជាក់ស្តែង ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ **គណៈប្រតិភូជាច្រើន ពីប្រទេសរងគ្រោះដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិន**

ទាន់ផ្ទុះ ដូចជាវៀតណាម ឡាវ មីយ៉ាន់ម៉ា បង់ក្លាដេស នេប៉ាល់ អាហ្គានីស្ថាន លីប៊ី អង់ហ្គោឡា កូឡុំប៊ី និងស៊ូដង់ ជាដើម បានមកកម្ពុជាដើម្បីរៀនសូត្រ និងចែករំលែកបទពិសោធន៍ពីយើង ...៕

២០. ប្រកាសទទួលហ្វឹកហ្វឺនអ្នកដោះមីន ដល់ប្រទេសដែលត្រូវការ

ចែកសញ្ញាបត្រជូនដល់និស្សិតនៃសាកលវិទ្យាល័យ វេស្ទើន, ២៦ មករា ២០២៣

... **ជាអ្នកសម្រេចចិត្តខាងនយោបាយ ទទួលការខុសត្រូវលើនយោបាយក្នុងប្រទេសនិងក្រៅប្រទេស ខ្ញុំសូមប្រកាសថាកម្ពុជានឹងទទួលយកប្រទេសណាក៏ដោយដែលចង់ហ្វឹកហ្វឺនពីការដោះមីនឱ្យមករៀននៅកម្ពុជា។ តែសូមកុំឱ្យកម្ពុជាចូលទៅពាក់ព័ន្ធជាមួយសកម្មភាពយោធានៅអ៊ុយក្រែន**។ កម្ពុជាគ្មានសមត្ថភាពធ្វើបែបនោះទេ។ប៉ុន្តែ ទាក់ទងនឹងការកំចាត់ចោលគ្រាប់មីន ជាកិច្ចការមនុស្សធម៌ ហើយដែលកម្ពុជាមានបទពិសោធន៍ច្រើន។ ពលរដ្ឋកម្ពុជាមានស្លាប់និងពិការច្រើនណាស់។ ដោយហេតុនេះ កម្ពុជាមិនអាចបើកភ្នែកមើលសោកនាដកម្មនៅតាមបណ្តាប្រទេសនានាទេ។ កូឡុំប៊ីមករៀនច្រើនជាងគេនៅស្រុកខ្មែរ។ គាត់នៅទ្វីបអាមេរិក ...៕

២១. ករណីកម្ពុជាជួយបណ្តុះបណ្តាលអ្នកដោះមីនឱ្យអ៊ុយក្រែនជាកិច្ចការមនុស្សធម៌

ចែកសញ្ញាបត្រជូនដល់និស្សិតនៃសាកលវិទ្យាល័យ វេស្ទើន, ២៦ មករា ២០២៣

... **កម្ពុជាមិនបានផ្តល់ជំនួយយោធាឱ្យអ៊ុយក្រែនទេ។ កម្ពុជាគ្មានសមត្ថភាពផ្តល់ជំនួយយោធាឱ្យអ៊ុយក្រែនទេ។ ឯរឿងកម្ពុជាជួយបណ្តុះបណ្តាលអ្នកដោះមីនឱ្យអ៊ុយក្រែន គឺជាកិច្ចការមនុស្សធម៌សុទ្ធសាធ។កម្ពុជាបានបញ្ជូនកងទ័ពទៅដោះមីននៅក្រៅប្រទេសរួមចំណែកការពារសន្តិភាពក្រោមច័ត្រអង្គការសហប្រជាជាតិ។** ឥឡូវយើងមានកងទ័ពឈរជើង នៅ៤ ប្រទេសគឺនៅម៉ាលី សូដង់ខាងត្បូង លីបង់ និងអាហ្រិកកណ្តាល។ កាលមុន យើងមាននៅស៊ីរី, ឆាដ, ស៊ីព្រ៍ (ដែលនៅខាង)អឺរ៉ុប។ ម៉េចបានយើងទៅដល់ហ្នឹង? វាមានតំបន់មួយមានជម្លោះរវាងទួគីជាមួយស៊ីព្រ៍។ តំបន់ហ្នឹងមានមីន។ អង្គការសហប្រជាជាតិយកកងទ័ពយើងទៅជួយដោះមីននៅកន្លែងហ្នឹង។ យើងបានបញ្ជូនកម្លាំងទៅជួយដោះមីន ដែលជាឃាតករលាក់មុកនៅតាមប្រទេសនានា ...៕

២២. កម្ពុជាមិនបានបញ្ជូនកងទ័ព និង/ឬគ្រូបង្វឹកដោះមីន ទៅអ៊ុយក្រែនទេ

ចែកសញ្ញាបត្រជូនដល់និស្សិតនៃសាកលវិទ្យាល័យ វេស្ទើន, ២៦ មករា ២០២៣

... នៅក្នុងប្រទេស យើងបានជួយបណ្តុះបណ្តាលអ្នកដែលមកពីកូឡុំប៊ី និងប្រទេសមួយចំនួនផ្សេងទៀត អំពីការដោះមីន។ មជ្ឈមណ្ឌលមីនអាស៊ានមានទីតាំងនៅកម្ពុជា។ ខ្ញុំសូមជម្រាបថា ប្រទេសណាក៏ដោយដែលចង់មករៀនដោះមីននៅកម្ពុជា សូមអញ្ជើញ រាប់ទាំងរុស្សីផង យើងនឹងជួយបណ្តុះបណ្តាលអោយទាំងអស់។ សូមបញ្ជាក់ថា **កម្ពុជាមិនបានបញ្ជូនកងទ័ពទៅប្រទេសអ៊ុយក្រែនទេ ហើយក៏មិនបានបញ្ជូនគ្រូដោះមីនទៅប្រទេសអ៊ុយក្រែនដែរ។ ដូច្នេះ កិច្ចការដែលយើងបានធ្វើនេះ ជាកិច្ចការមនុស្សធម៌សុទ្ធសាធ**។ ការបំផ្លាញចោលគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ គឺជាកិច្ចការដែលត្រូវធ្វើនៅគ្រប់ទីកន្លែងនៅលើពិភពលោកនេះ។ សូមបញ្ជាក់ឱ្យបានច្បាស់ថា មិនមានពាក់ព័ន្ធសកម្មភាពយោធាអ្វីទាំងអស់ ...៕

២៣. ស្នើឱ្យកងទ័ពចិនជួយកម្ពុជាបំផ្លាញចោលគ្រាប់មីនឱ្យអស់ក្នុងឆ្នាំ២០២៥

បើកការដ្ឋានពង្រីក ស្តារ និងលើកកម្រិតគុណភាពផ្លូវជាតិលេខ៤១
ពីថ្នល់ទទឹងតភ្ជាប់ទៅកាន់ខេត្តកំពត, ២៦ ធ្នូ ២០២២

... សូមយកឱកាសនេះ អរគុណទាំងអ្នកខេត្តកណ្តាលទាំងអ្នកខេត្តកំពង់ស្ពឺ ដែលបានបោះឆ្នោតជូនគណបក្សប្រជាជន(កម្ពុជា) ... ប្រជាពលរដ្ឋបានឃើញរួចហើយថា ពេលគណបក្សប្រជាជន(កម្ពុជា)កាន់អំណាច សន្តិភាពកំពុងកើតមាននៅទូទាំងប្រទេស គ្រប់ទីកន្លែង។ ពេលនេះ កន្លែងដែលធ្លាប់ច្បាំងរាំងដល់ទាំងប៉ុន្មាន ក្លាយទៅជាតំបន់ទេសចរណ៍អស់ហើយ។ យើងកំពុងតែពន្លឿនការដោះមីនដែលនៅសេសសល់។ **ជួបជាមួយរដ្ឋមន្ត្រីការពារជាតិចិន ក្រៅពីការផ្តល់ជំនួយដោយរដ្ឋាភិបាលចិនដល់ការដោះមីន ខ្ញុំបានស្នើឱ្យកងទ័ពចិនមកជួយដល់កងទ័ពកម្ពុជាដើម្បីបំផ្លាញចោលគ្រាប់មីនឱ្យអស់ក្នុងឆ្នាំ២០២៥ ខាងមុខនេះ** ដើម្បី

បញ្ចៀសគ្រោះថ្នាក់ដល់ប្រជាជនយើងផង និងដើម្បីផ្តល់ជីដោយសុវត្ថិភាពជូនប្រជាជនបង្កបង្កើនផលផង ... ។

១៨. មុខងារសារធារណៈ:

១	ជាសាស្ត្រាចារ្យកិត្តិយសតាំងពីឆ្នាំ១៩៩៧ ...បង្រៀនមន្ត្រីមុនចាកចេញពីសាលា	៣២៩
២	ការធ្វើទំនើបកម្មក្តី ការកែទម្រង់ក្តី ត្រូវចាប់ផ្តើមពីមនុស្ស	៣២៩
៣	សំណូមពរបង្កើតវគ្គសិក្សាពិសេសសម្រាប់តែស្ត្រី	៣៣០
៤	វិធីសាស្ត្រដឹកនាំនិងធ្វើការងារ មាន ៣ដំណាក់កាល	៣៣០
៥	បើមិនកែទម្រង់ ៩៩% នឹងស្លាប់ ... បើកែទម្រង់ ៩៩% នឹងរស់	៣៣១
៦	ពង្រឹងសមត្ថភាពមន្ត្រីដើម្បីកំណើន ការងារ សមធម៌ និងត្រូវមានប្រសិទ្ធភាព	៣៣១
៧	កែទម្រង់ដើម្បីដើរស្របជាមួយដៃគូអាស៊ាន ឆ្លើយតបកិច្ចការតំបន់/អន្តរជាតិ	៣៣២
៨	បម្រើនិងការពារប្រជាជនតាមពាក្យ "នៅប្រជាជនស្រឡាញ់ ទៅប្រជាជននឹក"	៣៣២
៩	បញ្ចប់ការសុំតែងតាំងមន្ត្រីពីគណបក្សនយោបាយ យកសមត្ថភាពជាគោល	៣៣២
១០	ត្រូវមានព័ត៌មានត្រឹមត្រូវ ដើម្បីវិភាគនិងវាយតម្លៃសភាពការណ៍ត្រូវ	៣៣៣
១១	អ្នកដឹកនាំ មិនត្រូវឱ្យរបាយការណ៍ និង/ឬព័ត៌មានបំភ្លៃបោកប្រាស់បាន	៣៣៣
១២	ពីចុងឆ្នាំ២០១៧ បន្ថែម "វះកាត់" លើអភិក្រម "ឆ្លុះកញ្ចក់ ងូតទឹក ជុសកែលព្យាបាល"	៣៣៤
១៣	វិភាគ វាយតម្លៃ និងព្យាករសភាពការណ៍ដោយប្រើវិធីសាស្ត្រ៣ គួបផ្សំគ្នា	៣៣៤
១៤	ត្រូវមានយុត្តិធម៌ ស្តាប់ឱ្យគ្រប់ជ្រុងជ្រោយ មុនធ្វើការសម្រេចចិត្ត	៣៣៥
១៥	ពេលធ្វើការតែងតាំង សូមកុំសួរអាយុ តែត្រូវមើលពីសមត្ថភាព	៣៣៦
១៦	ធ្វើការងារល្អ បម្រើប្រជាជន តាមពាក្យចាស់ថា "ឱនដាក់គ្រាប់! ងើយស្តុក"	៣៣៦
១៧	បក្សនយោបាយប្រើមនុស្សខ្លួនចាត់តាំង បំផ្លាញកេរ្តិ៍ឈ្មោះរដ្ឋបាលសាធារណៈ	៣៣៦
១៨	កុំរង់ចាំស៊ីផលពីការបែកបាក់របស់បក្សដទៃ តែរួមគ្នាបម្រើប្រយោជន៍ប្រជាជន	៣៣៧
១៩	រំលាយយន្តការកែទម្រង់៣ ប្រគល់ឱ្យក្រសួងពាក់ព័ន្ធ	៣៣៧
២០	មុខងារសាធារណៈជាជើងមុខ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាជើងក្រោយ ...	៣៣៨
២១	គ្រប់គ្រងមន្ត្រីដោយប្រព័ន្ធព័ត៌មានវិទ្យា រកឃើញនិងកាត់ចោលមន្ត្រី/ទាហានខ្មោច	៣៣៩
២២	ឡើងកាំយឺត ដល់ពេលត្រូវឡើងស័ក្តិ មិនដំឡើងឱ្យទៀត	៣៣៩
២៣	"សំណាបយោងដី ស្រីយោងប្រុស" តែភរិយា/កូន កុំលូកលាន់កិច្ចការប្តី/ឪពុក	៣៤០
២៤	បញ្ចៀសការតែងតាំងរបៀបបក្ខពួក/ក្រួសារនិយម ដោយការប្រឡងប្រជែង	៣៤០
២៥	២០២៣ ដំឡើងបៀវត្សមន្ត្រីរាជការ រំកិលពិដានពន្ធបៀវត្សទាំងរដ្ឋទាំងឯកជន	៣៤០

២៦	ចាយដល់ជាង៥0% នៃចំណាយចរន្ត ជំរុញបៀវត្សមិនទាបជាង ១លានរៀល	៣៨១
២៧	ចំណាយលើបុគ្គលិកច្រើនជាង៥% បន្តិច នៃផលិតផលក្នុងស្រុកសរុប	៣៨១
២៨	បើមិនចេះបច្ចេកវិទ្យាព័ត៌មាន មិនត្រូវតែងតាំងទេ	៣៨២
២៩	ការបណ្តុះបណ្តាលមន្ត្រី អាចធ្វើតាមក្រសួងស្ថាប័នថ្នាក់ជាតិនិងក្រោមជាតិ	៣៨២
៣0	សាលាភូមិន្ទរដ្ឋបាលរៀបកម្មវិធីបណ្តុះបណ្តាលភាគជាអ្នកដឹកនាំវិស័យសាធារណៈ	៣៨៣
៣១	តែងតាំងមុន បណ្តុះបណ្តាលតាមក្រោយ សាមីខ្លួនស្វែងយល់អំពីកិច្ចការត្រូវធ្វើ	៣៨៣
៣២	បញ្ហាអ្វីក៏ដោយ បើដោះស្រាយដោយផ្អែកលើផលប្រយោជន៍ប្រជាជន មិនខុសទេ	៣៨៤
៣៣	តែងមានសេណារីយូប្រុងប្រៀបឆ្លើយតបទៅនឹងលទ្ធភាពកើតឡើងច្រើនបែប	៣៨៤
៣៤	មន្ត្រីគេចវេះពីការទទួលវ៉ាក់សាំងកូវីដ១៩ មិនអាចចូលធ្វើការបានទេ	៣៨៤
៣៥	មុខងារសាធារណៈបូកសរុបចំនួនមន្ត្រីបានចាក់វ៉ាក់សាំង គ្រប់គ្រងជាព័ត៌មាន ...	៣៨៥
៣៦	រក្សាតួនាទីមន្ត្រីនយោបាយទទួលបានការតែងតាំងរួចមកហើយឲ្យនៅដដែល	៣៨៦
៣៧	តំណែងរដ្ឋមន្ត្រីប្រកាសអនុញ្ញាតរដ្ឋមន្ត្រី សំរាប់អគ្គនាយការង និងអគ្គនាយកគយ	៣៨៦
៣៨	នាយករដ្ឋមន្ត្រី/រដ្ឋមន្ត្រី គួបផ្សំការទទួលខុសត្រូវក្នុងការជ្រើសនិងតែងតាំងមន្ត្រី	៣៨៧
៣៩	ការគ្រប់គ្រងរដ្ឋបាលថ្នាក់ជាតិនិងក្រោមជាតិ ត្រូវមានចំណេះដឹង/ធ្វើ ជាមូលដ្ឋាន	៣៨៧
៤0	បង្កើតច្បាប់បាន កែច្បាប់បាន តែឱ្យត្រូវតាមកម្រិត	៣៨៨
៤១	កែសេចក្តីសម្រេចដែលមិនបម្រើប្រយោជន៍ប្រជាជន មិនមានអ្វីខុស ជាការកែទំរង់	៣៨៨
៤២	ក្រោយចាកចេញពីមុខតំណែងអាចរកពេលមកឆ្លើយសំណួរនៅសាលាភូមិន្ទរដ្ឋបាល	៣៨៩

១. ជាសាស្ត្រាចារ្យកិត្តិយសតាំងពីឆ្នាំ១៩៩៧ ...បង្រៀនមន្ត្រីមុនចាកចេញពីសាលា

បិទវគ្គបណ្តុះបណ្តាលឆ្នាំ ២០២0-២0២១ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២0២២ សាលាភូមិន្ទរដ្ឋបាល, ១៣ មិថុនា ២0២២

... ជាការល្អដែលបានអញ្ជើញសាស្ត្រាចារ្យ ក្នុងហ្នឹងមានសាស្ត្រាចារ្យជារដ្ឋមន្ត្រី សាស្ត្រាចារ្យជាឧបនាយករដ្ឋមន្ត្រី ជារដ្ឋលេខាធិការ ឬជាអ្នកជំនាញតាមស្ថាប័ននានា មកធ្វើបទឧទ្ទេសនាម ... **ខ្ញុំក៏ជាសាស្ត្រាចារ្យកិត្តិយសនៅសាលានេះ តាំងពីឆ្នាំ១៩៩៧ មក ប៉ុន្តែសាស្ត្រាចារ្យកិត្តិយសនេះ ទទួលបានប្រាក់កំរៃតម្លៃគត់ ... ជាធម្មតា សាស្ត្រាចារ្យកិត្តិយសនេះ មកផ្តាំផ្ញើចុងក្រោយ។ បង្រៀនចុងក្រោយនៅមុនពេលដែលមន្ត្រីចាកចេញពីសាលា។** ជាទូទៅ មន្ត្រីទទួលបានការផ្តាំផ្ញើពីខ្ញុំ ចំនួន ២លើក។ លើកទី១ នៅពេលបើក ... រួចហើយនឹងជួបខ្ញុំនៅឆ្នាំក្រោយទៀត នៅពេលត្រូវបិទវគ្គ ... បើទោះបីជាមិនបានចូលបង្រៀនក៏ដោយចុះ ក៏សាស្ត្រាចារ្យកិត្តិយសនេះ មានបណ្តាំចុងក្រោយ ដែលក៏មានតម្លៃគួរសមដែរ ...៕

២. ការធ្វើទំនើបកម្មក្តី ការកែទម្រង់ក្តី ត្រូវចាប់ផ្តើមពីមនុស្ស

បិទវគ្គ ប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ជូនសិស្សមន្ត្រីជាន់ខ្ពស់សាលាភូមិន្ទរដ្ឋបាល, ២៥ កុម្ភៈ ២0២0

... **សាលាភូមិន្ទរដ្ឋបាល មានតួនាទីសំខាន់ក្នុងការបណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងរដ្ឋបាលថ្នាក់ជាតិផង និងរដ្ឋបាលថ្នាក់ក្រោមជាតិផង ... ពាក់ព័ន្ធនឹងដំណើរទៅមុខ តើយើងគួរតែធ្វើអ្វីបន្ថែមទៀត ... យើងមានការកែទម្រង់។ ប៉ុន្តែ តើការកែទម្រង់ត្រូវចាប់ផ្តើមពីអ្វី ... បើទោះបីជាមានសម្ភារទំនើបបែបណាក៏ដោយចុះ បើមនុស្សមិនទំនើបទេ គឺវានៅតែប៉ុណ្ណឹង។** ខ្ញុំលើកឧទាហរណ៍ ស្តាប័នព័ត៌មានមួយទៅចុះ។ អ្វីៗសុទ្ធតែឌីជីថលទាំងអស់ ប៉ុន្តែ ព័ត៌មាននោះអាចផ្សាយបានទេ ទូរទស្សន៍មួយអាចផ្សាយបានទេ បើមនុស្សដេកមិនក្រោក។ តើបានអ្នកណាឡើងរត់អក្សរ អ្នកណាតាមដានព័ត៌មាន បានព័ត៌មានពីណាយកទៅផ្សាយ។ **ខ្ញុំចង់រំលេចថា ការចាប់ផ្តើមធ្វើទំនើបកម្ម ការកែទម្រង់ ត្រូវចាប់ផ្តើមពីមនុស្ស។ ចង់ធ្វើឱ្យស្ថាប័នមួយរឹងមាំទៅបាន ទាមទារឱ្យមនុស្សរឹងមាំសិន ទើបស្ថាប័ននោះដំណើរការបាន មិនថាស្ថាប័នរដ្ឋឬផ្នែកឯកជននោះទេ** ...៕

៣. សំណូមពរបង្កើតវគ្គសិក្សាពិសេសសម្រាប់តែស្ត្រី

ចែកវិញ្ញាបនបត្រដល់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់និងមធ្យម និងបើកវគ្គ
បណ្តុះបណ្តាលសាលាភូមិន្នរដ្ឋបាល, ១០ មីនា ២០១៥

... **(អ្វី)ខ្ញុំចង់បានយូរហើយ ប៉ុន្តែមិនទាន់សម្រេចបាន គឺគណៈរដ្ឋមន្ត្រីនឹងសុំយកសាលានេះឲ្យទទួលបណ្តុះបណ្តាលមន្ត្រីជាស្ត្រី ដែលត្រូវបានតែងតាំងឲ្យធ្វើរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អភិបាលរងខេត្ត អភិបាលរងស្រុក និងមានមួយចំនួនថ្នាក់អគ្គនាយកអគ្គនាយករង ជាមួយវគ្គ**។ ខ្ញុំសូមប្រគល់ជូនឯកឧត្តមសខេងទទួលទាំងខាងរដ្ឋបាលសាធារណៈ និងមន្ត្រីក្នុងរដ្ឋាភិបាល ... (ជាញឹកញយយើញថា) ឱ្យតែចាប់ផ្តើមបានធ្វើធំហ្នឹង មិនព្រមរៀនទៀត។ យកអ្នកហ្នឹងទៅរៀនមុនគេ។ អាងតែជំទាវ មិនខ្វីរៀន ហើយយើងចេះតែលើកឡើងពី(វិសមភាព) gender ... អ្នកប្រឹង ចេះតែប្រឹង អ្នកមិនប្រឹង ក៏ក្លាយជាអភិរក្ស ... បើតែយើងដកចេញពីតំណែង នឹងមានការរិះគន់ថា "កាត់ស្ត្រី" ចេញ(ពីការទទួលខុសត្រូវ) ...។

៤. វិធីសាស្ត្រដឹកនាំនិងធ្វើការងារ មាន ៣ដំណាក់កាល

ចែកសញ្ញាបត្រមន្ត្រីជាន់ខ្ពស់ មន្ត្រីក្រមការនៃសាលាភូមិន្នរដ្ឋបាល, ២០ មិថុនា ២០១៦

... ខ្ញុំធ្លាប់បាននិយាយអំពី**វិធីសាស្ត្រដឹកនាំនិងធ្វើការងារថា មានបីដំណាក់កាល។ ដើម្បីធ្វើការងារបាននៅស្ថាប័នមួយ ឬអង្គការចាត់តាំងមួយ ជាសង្គមស៊ីវិលក្តី ជាបក្សនយោបាយក្តី ឬស្ថឹក៏ដោយ ដំណាក់កាលទី១ គឺត្រូវតែមានផែនការច្បាស់លាស់ ... រៀបចំបានផែនការ ទើបនឹងសម្រេចបាន ៣០% នៃអ្វីដែលយើងត្រូវធ្វើ ... ដំណាក់កាលទី២ គឺការចាត់តាំងអនុវត្ត ... បើមានផែនការយកទៅដាក់ក្នុងថតតុ មិនចាត់តាំងអនុវត្ត ក៏មិនមានន័យអីទាំងអស់ ... ហើយការចាត់តាំងអនុវត្តក៏ទើបនឹងបាន ៣០%ទៀតដែរ ... (ដូច្នេះ ទាំងពីរនេះ)ទើបតែសម្រេចបាន ៦០% ទេ ... តើ ៤០% ទៀតស្ទឹ? កត្តាចៃដន្យវានឹងលេចឡើងក្នុងពេលអនុវត្ត**។ នេះហើយជាចំណុចសំខាន់ ... មិនថាប្រទេសទាំងមូលទេ អង្គភាពតូចមួយ ក៏សុទ្ធតែមានកត្តាចៃដន្យអាចកើតឡើង។ ខ្លួនយើងម្នាក់ៗ គ្រួសារនីមួយៗសុទ្ធតែមានកត្តាចៃដន្យដែលនឹងលេចឡើង ... ដែលវានឹងក្លាយជាការដាក់បន្ទុកឲ្យដោះ

ស្រាយ ... (ការប្រឈមដោះស្រាយនឹង)ចំណុចនេះ វានឹងរំលេចអោយយើញនូវសមត្ថភាពរបស់មន្ត្រី ...។

៥. បើមិនកែទម្រង់ ៩៩% នឹងស្លាប់ ... បើកែទម្រង់ ៩៩% នឹងរស់

ចែកវិញ្ញាបនបត្រដល់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់និងមធ្យមនិងបើកវគ្គបណ្តុះបណ្តាល
សម្រាប់ឆ្នាំ២០០៩ សាលាភូមិន្នរដ្ឋបាល, ១៧ មិថុនា ២០០៩

... សូមនិយាយដោយត្រង់ **បើមិនកែទម្រង់ទេនោះ ៩៩% (យើងនឹង)ស្លាប់, (និងមានតែ) ១% ទេ ដែលរស់។ តែបើ(យើងធ្វើការ)កែទម្រង់ នោះ៩៩% (យើង)រស់ (និងមានតែ)១% ទេ (ដែល)ស្លាប់។ ដោយហេតុនេះ យើងបានចាប់ផ្តើមកែទម្រង់រហូតមក**។ អ្វីដែលយើងចង់បាន គឺសេវាសាធារណៈដ៏ល្អមួយសម្រាប់ប្រជាពលរដ្ឋ។ អ្នកទាំងអស់គ្នាជាមន្ត្រីរាជការ ជាកងកម្លាំងប្រដាប់អាវុធ មិនមែនជាចៅហ្វាយរបស់ប្រជាជនទេ តែជាខ្ញុំបម្រើដោយស្មោះត្រង់របស់ប្រជាជន មិនអាចយកហាន: យកបុណ្យស័ក្តិទៅគាបសង្កត់ ធ្វើជាចៅហ្វាយរបស់ប្រជាជនទេ យើងគ្រាន់តែជាខ្ញុំបម្រើរបស់ប្រជាជនតែប៉ុណ្ណោះ ...។

៦. ពង្រឹងសមត្ថភាពមន្ត្រីដើម្បីកំណើន ការងារ សមធម៌ និងត្រូវមានប្រសិទ្ធភាព

ចែកវិញ្ញាបនបត្របញ្ចាក់ការសិក្សាសិស្សមន្ត្រីសាលាភូមិន្នរដ្ឋបាល, ៧ មីនា ២០១៣

... ពីដំណាក់កាលមួយទៅកាន់ដំណាក់កាលមួយ ការពង្រឹងសមត្ថភាពមន្ត្រីរាជការជាការចាំបាច់ដើម្បីឆ្លើយតបទៅកំណែទម្រង់ទាំងឡាយ ដែលកំពុងមានការវិវឌ្ឍ។ យើងមិនអាចនៅទ្រឹង ហើយខ្វះការយល់ដឹងបានទេ។ ក្នុងន័យនេះ **ក្រៅពីការបណ្តុះបណ្តាលមន្ត្រីថ្មីជាអ្នកបន្តវេន ជាអ្នកដែលកំពុងធ្វើការ យើងក៏បានផ្តល់ឱកាសធ្វើការបណ្តុះបណ្តាលតាមរយៈសុក្រឹត្យការឬក្រឹត្យការដើម្បីឱ្យពួកគេមានចំណេះដឹង។ បើយើងមិនអាចមើលយល់រដ្ឋធម្មនុញ្ញ ឬក៏ច្បាប់ផង តើយើងអាចនឹងទៅនិយាយជាមួយប្រជាពលរដ្ឋយ៉ាងម៉េច? ... ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណ មានពាក្យបួនម៉ាត់ដែលត្រូវខិតខំសម្រេច គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។ ពាក្យបួនម៉ាត់នេះ(មានន័យថា) ចង់ឱ្យមានកំណើន ចង់បង្កើតការងារធ្វើ ចង់ឱ្យមានសមធម៌ អ្វីៗ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ...។**

៧. កំណែទម្រង់ដើម្បីដើរស្របជាមួយដៃគូអាស៊ាន ឆ្លើយតបកិច្ចការតំបន់/អន្តរជាតិ

បិទវគ្គ ប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ជូនសិស្សមន្ត្រីជាន់ខ្ពស់សាលាភូមិន្នរដ្ឋបាល, ២៥ កុម្ភៈ ២០២០

... ទាក់ទងជាមួយកំណែទម្រង់នេះ អស់លោកប្រាកដជាបានរៀនហើយ។ **យើងបន្តខិតខំធ្វើការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ និងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ មានការកែទម្រង់ច្រើន។ មិនអាចនៅទ្រឹងប៉ុណ្ណឹងបានទេ។ យើងត្រូវដើរស្របជាមួយដៃគូក្នុងអាស៊ាន។** យើងមិនអាចនៅក្រោយគេបានទេ។ មន្ត្រីរបស់យើងត្រូវឆ្លើយតប មិនត្រឹមតែកិច្ចការក្នុងប្រទេសរបស់ខ្លួនទេ ប៉ុន្តែក៏ត្រូវឆ្លើយតបចំពោះកិច្ចការតំបន់និងអន្តរជាតិថែមទៀត ...៕

៨. បម្រើ និងការពារប្រជាជន តាមពាក្យថា "នៅប្រជាជនស្រឡាញ់ ទៅប្រជាជននឹក"

ចែកវិញ្ញាបនបត្រដល់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់និងមធ្យមនិងបើកវគ្គបណ្តុះបណ្តាលសម្រាប់ឆ្នាំ២០០៩ សាលាភូមិន្នរដ្ឋបាល, ១៧ មិថុនា ២០០៩

...យើងមានការកិច្ចបម្រើប្រជាជន ការពារប្រជាជន។ ការផ្លាស់ប្តូរឥរិយាបថនៅទីនេះ ជាការចាំបាច់ ចៀសវាងមិនបាន ... សុំផ្តាំផ្ញើគ្រប់ទីកន្លែង មិនថាអ្នកអង្គុយនៅទីនេះទេ គឺនៅទូទាំងប្រទេសត្រូវ ធ្វើឲ្យដូចពាក្យថា "នៅឲ្យគេ (ប្រជាជន) ស្រឡាញ់ ទៅឲ្យគេ(ប្រជាជន)អាណិតនិងនឹក"។ កុំឲ្យនៅ ត្រូវគេទន្ទឹងថា កាលណាទើបដកអាមួយហ្នឹង ... សេវាសាធារណៈមានច្រើន ... នៅមូលដ្ឋាន ត្រឹមថ្នាក់ឃុំ-សង្កាត់ ចាប់ពីមន្ត្រីអត្រានុកូលដ្ឋានចុះសំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណភាព សំបុត្រកំណើតស្អីៗនេះ (សូមធ្វើ)ឲ្យលឿន ឲ្យទាន់ពេល ឲ្យរហ័ស កុំកិកកុក។ ជួនកាល បើមិនបានដាក់ស្រោមសំបុត្រទេ កើតរឿងមិនធ្វើឲ្យ ... បញ្ហានេះត្រូវបានកាត់បន្ថយច្រើន ព្រោះគាត់ដឹងដៃរថាថ្ងៃក្រោយ គេមិនបោះឆ្នោតឲ្យ ...៕

៩. បញ្ចប់ការស្នើសុំតែងតាំងមន្ត្រីពីគណបក្សនយោបាយ និងយកសមត្ថភាពជាគោល

ចែកវិញ្ញាបនបត្រដល់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់និងមធ្យមនិងបើកវគ្គបណ្តុះបណ្តាលសម្រាប់ឆ្នាំ២០០៩ សាលាភូមិន្នរដ្ឋបាល, ១៧ មិថុនា ២០០៩

... ចាប់ពីពេលនេះតទៅ **មិនឲ្យមានការស្នើណាមួយពីគណបក្សនយោបាយរាប់ទាំង CPP បើមិនអញ្ចឹង តើយើងនឹងដំណើរការធ្វើអព្យាក្រឹតភាវូបនីយកម្ម កម្លាំងប្រដាប់អាវុធ និងរដ្ឋបាលស៊ីវិលបែបណាបាន ... មន្ត្រីក្នុងមុខងារសាធារណៈមិនប្រកាន់ថា អ្នកជាសមាជិកបក្សនេះបក្សនោះទេ គឺយកសមត្ថភាពជាគោល**។ ត្រង់អ្នកឯងបោះឆ្នោតឲ្យគណបក្សណា ជារឿងរបស់អ្នកឯង។ ខ្ញុំសូមប្រកាសជាសាធារណៈថា (ការសុំតែងតាំងមន្ត្រីមុខងារសាធារណៈ ទាំងផ្នែកស៊ីវិល ផ្នែកកងទ័ពឬនគរបាល ពីគណបក្សនយោបាយនានា) ត្រូវបានបញ្ចប់ ... គ្មានសំណើណាមួយពីគណបក្សនយោបាយណាមួយបញ្ជូនមកនាយករដ្ឋមន្ត្រី ស្តីពីការសុំតែងតាំងមន្ត្រីមុខងារសាធារណៈ ទាំងផ្នែកស៊ីវិល ផ្នែកកងទ័ពឬនគរបាលទេ ...៕

១០. ត្រូវមានព័ត៌មានត្រឹមត្រូវ ដើម្បីវិភាគនិងវាយតម្លៃសភាពការណ៍ត្រូវ

ចែកវិញ្ញាបនបត្របញ្ចាក់ការសិក្សាសិស្សមន្ត្រីសាលាភូមិន្នរដ្ឋបាល, ៧ មីនា ២០១៣

... ពេលធ្វើការវាយតម្លៃ សូមមន្ត្រីយើងកុំវាយតម្លៃតាមសង្គ្រាមចិត្តសាស្ត្រឱ្យសោះ។ ត្រូវវាយតម្លៃតាមរឿងពិត។ ចំណុចខ្សោយយើងនៅកន្លែងណា? ចំណុចខ្លាំងយើងនៅកន្លែងណា? បើការបោះឆ្នោតវិញ គូប្រកួតរបស់យើងខ្លាំងរឿងអី? ខ្សោយរឿងអី? សម្រាប់ប្រជាពលរដ្ឋ តើយើងត្រូវជួយអីគាត់? **ដូចជាយើងដាក់ចេញនយោបាយអាទិភាព ទឹក ផ្លូវ ភ្លើង មនុស្ស ... បើមនុស្ស គឺត្រូវនិយាយពីសេវាអប់រំ សេវាសុខភាពស្តីៗ ... ហើយដើម្បីដាក់ចេញកម្មវិធីនយោបាយបានត្រូវតែមានព័ត៌មានត្រឹមត្រូវវិភាគឱ្យត្រូវវាយតម្លៃសភាពការណ៍ឱ្យត្រូវ** ...៕

១១. អ្នកដឹកនាំ មិនត្រូវឱ្យរបាយការណ៍ និង/ឬព័ត៌មានបំភ្លៃបោកប្រាស់បាន

បិទវគ្គ ប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ជូនសិស្សមន្ត្រីជាន់ខ្ពស់សាលាភូមិន្នរដ្ឋបាល, ២៥ កុម្ភៈ ២០២០

...ភាពមិនស្មោះត្រង់ អាចធ្វើឱ្យអ្នកដឹកនាំធ្វើការវិនិច្ឆ័យខុសបាន។ អ្នកដឹកនាំនោះក៏ត្រូវតែច្បាស់ មិនត្រូវឱ្យរបាយការណ៍ (និង/ឬ)ព័ត៌មានបំភ្លៃបោកប្រាស់បានឡើយ។ ក្នុងករណីមានការបោកប្រាស់បាន ក៏យើងត្រូវតែកត្រូវភ្លាម។ ខ្ញុំគិតថា នេះជាការដាស់តឿនមួយ សម្រាប់មន្ត្រីក្នុងពេលបំពេញការងារ (គឺត្រូវ)យកចិត្តទុកដាក់លើបញ្ហាទាំងអស់ ហើយត្រូវបង្កើនសមត្ថភាពជាប្រចាំ។ មិនមែន

រៀនចប់ប៉ុណ្ណឹងហើយ ចាត់ទុកថាគ្រប់គ្រាន់នោះទេ។ គ្មានចំណេះដឹងណាគ្រប់គ្រាន់នោះទេ។ ជាងនេះទៅទៀត ពិភពលោកមានការវិវឌ្ឍលឿនណាស់ ក្នុងដំណាក់កាលបដិវត្តឧស្សាហកម្ម៤.០ ឬសេដ្ឋកិច្ចឌីជីថលនេះ ...៕

១២. ចាប់ពីចុងឆ្នាំ២០១៧ បន្ថែមការ "វះកាត់" លើអភិក្រម "ឆ្លុះកញ្ចក់ ងូតទឹក ជុសក្អែល ព្យាបាល"

កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧ និងសមិទ្ធផល ៥ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២០ មេសា ២០១៨

... [សុន្ទរកថា] កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងឈានដល់ជំហាន និងដំណាក់កាលចុងក្រោយគឺ « គណនេយ្យភាពសមិទ្ធកម្ម » ដែលតម្រូវឱ្យមានការចូលរួមរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ក្នុងការអនុវត្តផែនការសកម្មភាពរៀងៗខ្លួន ដោយបុរេសកម្ម និងគណនេយ្យភាព។ ក្នុងការបន្តអនុវត្តកម្មវិធីនេះ ខ្ញុំសូមឱ្យគណៈកម្មាធិការដឹកនាំការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បន្តប្រកាន់ខ្ជាប់នូវស្មារតីនៃភាពប្រាកដនិយម និងភាពជាម្ចាស់ខ្ពស់ ព្រមទាំងអភិក្រមទន់ភ្លន់តែម៉ឺងម៉ាត់អនុវត្តស្របតាមគោលការណ៍ «ឆ្លុះកញ្ចក់ ងូតទឹក ជុសក្អែល ព្យាបាល និងវះកាត់»។

[សេចក្តីអធិប្បាយ] **មុននេះ យើងមានអភិក្រមត្រឹមតែបួនទេ គឺឆ្លុះកញ្ចក់ ងូតទឹក ជុសក្អែល និងព្យាបាល។ ប៉ុន្តែ ចាប់ពីឆ្នាំចុងឆ្នាំ២០១៧ មក យើងបានដាក់ចេញនូវចំណុចសំខាន់មួយទៀតគឺការវះកាត់។ យើងមិនអាចត្រឹមតែព្យាបាលហើយបន្តទុកជំងឺឱ្យនៅរ៉ាំរ៉ៃទៀតនោះទេ។ សូមរំលឹកជាស់ឡើងចំណុចនេះសាជាថ្មីម្តងទៀត។ ការវះកាត់ក្នុងចំណោមមន្ត្រីរបស់យើងជាការចាំបាច់ណាស់។ មិនអាចទុកឲ្យជំងឺរ៉ាំរ៉ៃនេះ បន្តទៅជាជំងឺមហារីករហូតងាប់ខ្លួននោះទេ** ...៕

១៣. វិភាគ វាយតម្លៃ និងព្យាការសភាពការណ៍ដោយប្រើវិធីសាស្ត្រ៣ គួបផ្សំគ្នា

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារទីស្តីការក្រសួងសាធារណការ និងដឹកជញ្ជូន និងវិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន, ២២ មករា ២០២១

... អ្នកណាក៏ដោយ បើមិនផ្អែកលើទស្សនៈប្រវត្តិសាស្ត្រ ខ្ញុំនៅតែឲ្យពិន្ទុថាជា

"លង់ទូ" ដដែល។ បើអ្នកឯងមិនទទួលស្គាល់ថាសង្គ្រាមឆ្នាំ១៩៧០ ដល់ ១៩៧៥ បានបង្កវិនាសកម្ម(ចំពោះប្រទេស)ប៉ុណ្ណាផង មិនទទួលស្គាល់ថា ប៉ុល ពត (បាន)កាប់សម្លាប់មនុស្សប៉ុណ្ណាផង ហើយផលវិបាកនៃរបប ប៉ុល ពត (បាន)បន្សល់ទុកកុមារកំព្រា ស្ត្រីមេម៉ាយ ការព្រាត់ប្រាសនានា និងសង្គ្រាមបន្តរហូតមកបញ្ចប់នៅឆ្នាំ១៩៩៨ តាមរយៈនយោបាយឈ្នះឈ្នះ(យ៉ាងណាផង) ... ទោះបីអ្នកឯងមានបណ្ឌិតដឹកទាំងឡាន ក៏ខ្ញុំនៅតែហៅអ្នកឯង "លង់ទូ" ដែរ ... **ជានិច្চকাল ហ៊ុន សែន ប្រើ ៣វិធីសាស្ត្រគួបផ្សំគ្នា គឺ ទី១ វិធីសាស្ត្រប្រវត្តិសាស្ត្រ។ ទី២ វិចារវិទ្យា និងទី៣ គឺ logic ឬតក្កវិជ្ជា ... ដើម្បីវិភាគសភាពការណ៍ វាយតម្លៃសភាពការណ៍ និងព្យាការសភាពការណ៍នៅពេលខាងមុខ** ...៕

១៤. ត្រូវមានយុត្តិធម៌ ស្តាប់ឱ្យគ្រប់ជ្រុងជ្រោយ មុនធ្វើការសម្រេចចិត្ត

បិទវគ្គបណ្តុះបណ្តាលឆ្នាំ២០២២ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០២៣ សាលាភូមិន្ទរដ្ឋបាល, ២៧ មេសា ២០២៣

... មានរឿងមួយ ដែលមកដល់ម៉ោងនេះ ខ្ញុំអាចនិយាយបាន។ សម្តេចក្រឡាហោមនៅចាំទេ? បើកុំអី ស ចំរុង ដែលជាប្រធានគណៈកម្មការសភារាល់ថ្ងៃ ជាសមាជិកសភារាល់ថ្ងៃ ត្រូវចាប់ខ្លួនដោយតុលាការពេធ៌សាត់ទៅហើយ។ ពេលហ្នឹង សម្តេចក្រឡាហោមជឿតាមអនុខេត្តម្នាក់។ បើខ្ញុំស្តាប់សម្តេចក្រឡាហោម ស ចំរុង ត្រូវចាប់ខ្លួន ... នេះជាបទពិសោធ។ បើសិនជាពេលហ្នឹង ខ្ញុំចុះហត្ថលេខាយល់ព្រមហើយចាប់ខ្លួន ស ចំរុង ដោយផ្ទេរសមត្ថកិច្ចពីបន្ទាយមានជ័យ មកតុលាការខេត្តពោធ៌សាត់ ស ចំរុង ... មិនអាចកំពុងធ្វើសមាជិកអចិន្ត្រៃយ៍សភានិងជាប្រធានគណៈកម្មការរបស់សភាទេ។ វានឹងខូចមន្ត្រីមួយទៅទេ ដោយសារតែការញុះញង់របស់អនុខេត្តម្នាក់។ ខ្ញុំនិយាយមុខអ្នកទាំងអស់គ្នា រាប់ទាំងសម្តេចក្រឡាហោម ដែលធ្វើសំណើមកខ្ញុំនៅពេលនោះ។ **ធ្វើការអ្វីក៏ដោយ យើងត្រូវមានយុត្តិធម៌ ស្តាប់ឱ្យគ្រប់ជ្រុងជ្រោយ រឿងចាក់រុក ញុះញង់នេះ សូមកុំ(ស្តាប់)ឱ្យសោះ កុំយកក្បែរខ្លួនឱ្យសោះ។ គ្រោះថ្នាក់ណាស់។** មិនគួរទេ មិនគួរចង់បានកន្លែងគេ ហើយទៅចាក់រុកថាអ្នកហ្នឹងមិនល្អ ...៕

១៥. ពេលធ្វើការតែងតាំង សូមកុំសួរអាយុ តែត្រូវមើលពីសមត្ថភាព

ចែកវិញ្ញាបនបត្របញ្ចាក់ការសិក្សាសិស្សមន្ត្រីសាលាភូមិន្នរដ្ឋបាល, ២៦ មិថុនា ២០១៧

... ក្នុងការគូសវាសនយោបាយ យោធា និងសេដ្ឋកិច្ចនៅកម្ពុជា ខ្ញុំព្រះករុណាខ្ញុំបានផ្សារភ្ជាប់ខ្លួនជាមួយសុខទុក្ខរបស់ប្រជាជននៅក្នុងប្រទេស ដោយមិនដែល(គិតថា)ទៅរស់(យកសុខ)ម្នាក់ឯងទេ។ គេ(វៀតណាម)បានរៀបចំឱ្យខ្ញុំព្រះករុណាខ្ញុំទៅអូស្ត្រាលី ទៅជប៉ុន ទៅបារាំង ទៅកាណាដា តែខ្ញុំថាអត់ទេ។ បើអស់លោកជួយខ្ញុំមិនបានទេ សូមប្រគល់អាវុធមកឱ្យខ្ញុំ។ ខ្ញុំទៅស្លាប់ជាមួយប្រជាជនរបស់ខ្ញុំ។ ដោយហេតុនេះ **ខ្ញុំបានបំពេញតួនាទីយុវជនហើយៗ ក៏បានកាត់ផ្តាច់នូវពាក្យដែលថាក្មេងពេក។ កម្ពុជាលែងមានពាក្យក្មេងពេកហើយ។ ក្នុងពេលដែលធ្វើការតែងតាំង សូមកុំសួរអាយុ តែត្រូវមើលពីលទ្ធភាពរបស់មនុស្សវិញ។ យុវជនបច្ចុប្បន្ន មានឱកាសច្រើន** ...។

១៦. ធ្វើការងារល្អ បម្រើប្រជាជន តាមពាក្យចាស់ថា "ឱនដាក់គ្រាប់! ងើយស្តុក"

ចែកវិញ្ញាបនបត្របញ្ចាក់ការសិក្សាសិស្សមន្ត្រីសាលាភូមិន្នរដ្ឋបាល, ២៦ មិថុនា ២០១៧

... ខ្ញុំនៅចាំបានវគ្គសិក្សាមួយ។ កាលពីក្នុងរង្វង់ឆ្នាំ ១៩៩៦/៩៧ ខ្ញុំធ្លល់នឹងប្រការដែលមានការរៀននិយាយពាក្យ "សហជីវិន" "បាទ! តេជគុណ"។ ខាងម្ខាងនិយាយថា "សហជីវិន" ខាងនោះត្រូវតបមកវិញថា "បាទ! តេជគុណ"។ **របៀបឆ្លងឆ្លើយជាមួយគ្នា ជាប្រការមួយ ក៏ប៉ុន្តែ វាមិនមែនជាតម្រូវការចាំបាច់ទេ។ តម្រូវការចាំបាច់ គឺធ្វើការងារឱ្យល្អ បម្រើប្រជាពលរដ្ឋ ហើយត្រូវធ្វើខ្លួនតាមពាក្យចាស់ដែលលោកថា "ឱនដាក់គ្រាប់! ងើយស្តុក"។** (ក្នុងការដាក់ស្តែង) អ្នកខ្លះបានទទួលទាំងការមិនពេញចិត្តពីសំណាក់ប្រជាពលរដ្ឋ តាមរយៈអាកប្បកិរិយាផ្ទាល់របស់ខ្លួនផង ...។

១៧. បក្សនយោបាយ ប្រើមនុស្សខ្លួនចាត់តាំង បំផ្លាញកេរ្តិ៍ឈ្មោះរដ្ឋបាលសាធារណៈ

សម្ពោធអគារ រដ្ឋបាលថ្មី នៃសាលារាជធានីភ្នំពេញ, ៥ មេសា ២០១៦

... ថ្ងៃនេះ មានមន្ត្រីថ្នាក់មូលដ្ឋានមក(ចូលរួម)។ រឿងសេវាសាធារណៈនេះ ជាចំណុច(ដែលទទួលបានការ)គួញត្អែរ(ពីសំណាក់ប្រជាពលរដ្ឋ) ... (ត្រូវ)ខិតខំ

ដោះស្រាយសេវាសាធារណៈ ពិសេសត្រូវធ្វើឱ្យ "សេវាតម្រូវការ" បានបម្រើប្រជាជនឲ្យបានស្មោះត្រង់បំផុត។ កន្លែងខ្លះ ក្នុងចំណោមមន្ត្រី ១ពាន់នាក់មាន ៤ឬ ៥ នាក់ទេ ដែលខិលខូច តែវាធ្វើឲ្យខូច(ឈ្មោះ)មន្ត្រីទាំង ១ពាន់នាក់ ... មួយចំនួនតូចមានចេតនារុញឲ្យខ្លោចរោចឲ្យធៅ។ **តាមការស្រាវជ្រាវ ខ្លះជាមនុស្សរបស់បក្សផ្សេង។ គេធ្វើរឿងហ្នឹងដើម្បីឲ្យរដ្ឋបាល(នៃបក្សដឹកនាំ)ខូចឈ្មោះ។ រដ្ឋបាលសាធារណៈមិនមែនជារបស់បក្សនយោបាយណាមួយទេ ប៉ុន្តែបក្សនយោបាយខ្លះ បានប្រើប្រាស់មនុស្សដែលខ្លួនចាត់តាំងបានក្នុងរដ្ឋបាលសាធារណៈ ឱ្យបំផ្លាញកេរ្តិ៍ឈ្មោះមន្ត្រីរដ្ឋបាលសាធារណៈ**។ ខ្ញុំសូមស្នើឲ្យមន្ត្រីដែលល្អ ចាប់ខ្លួនមនុស្សនោះ ដើម្បីផ្តន្ទាទោស លាងសងភាពស្អាតស្អំរបស់យើងវិញ ...។

១៨. កុំរង់ចាំស៊ីផលពីការបែកបាក់របស់បក្សដទៃ តែរួមគ្នាបម្រើប្រយោជន៍ប្រជាជន

ចែកវិញ្ញាបនបត្របញ្ចាក់ការសិក្សាសិស្សមន្ត្រីសាលាភូមិន្នរដ្ឋបាល, ២៦ មិថុនា ២០១៧

... ទាក់ទងនឹងការបោះឆ្នោត ... មនុស្សខ្ញុំនេះខុសគេ។ បើកាន់តែទាវឱ្យចុះអញកាន់តែនៅ ... អ្នកវិភាគទាំងឡាយថា ដូចជាមានការបែក(បាក់ផ្ទៃក្នុងគណបក្សប្រជាជន)។ ដោយសារអស់លោកវាយតម្លៃមិនត្រូវហ្នឹងហើយ ទើបបានជាអស់លោកចាញ់រហូត ... **គួរតែកុំរង់ចាំស៊ីផលពីការបែកបាក់របស់គេ។ អ្នកខ្លះរង់ចាំគ្រួសារនោះបែកបាក់ អញនឹងអាលទៅទិញដី ព្រោះគេលក់ដីចែករកេរ។ កុំអញ្ចឹង។ យកល្អជួយកុំឱ្យគេលែងលះគ្នា ... ខ្ញុំសង្ឃឹមថា បណ្តាបក្សនយោបាយនៅកម្ពុជានឹងចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម កាត់បន្ថយភាពក្រីក្រ ព្រោះបក្សទាំងអស់សុទ្ធតែបានសន្យាគ្រាន់តែខ្លះក៏ជាប់ឆ្នោតខ្លះក៏មិនជាប់ឆ្នោត ... ប្រឹងធ្វើទាំងអស់គ្នាទៅ ដើម្បីផលប្រយោជន៍ជារបស់ប្រជាជន** ...។

១៩. រំលាយយន្តការកែទម្រង់៣ ប្រគល់ឱ្យក្រសួងពាក់ព័ន្ធ

បិទវគ្គប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ជូនសិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់/មធ្យមឆ្នាំ២០១៧ បើកវគ្គបណ្តុះបណ្តាលឆ្នាំ២០១៨, ៥ មិថុនា ២០១៨

... ចុងអាណត្តិនៃរាជរដ្ឋាភិបាលនីតិកាលទី ៥ ... ខ្ញុំព្រះករុណាខ្ញុំ គប្បីលាតត្រដាងពីការជាប់គាំងក្នុងរយៈកាលប្រមាណជា ១០ឆ្នាំមុន ... **(រាជរដ្ឋាភិបាលបាន)រំលាយ**

ចោលគណៈកម្មការកែទម្រង់រដ្ឋ ដែលក្នុងនោះមានយន្តការ ៣ ដែលមិនដើរ គឺ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ប្រព័ន្ធតុលាការ និងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ...។ (ចំពោះការ)រំលាយចោលគណៈកម្មការកំណែទម្រង់រដ្ឋ (យើងបាន)លើកកម្រិតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ឱ្យទៅជាក្រសួង ... ប្រគល់កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ ឱ្យក្រសួងយុត្តិធម៌ រីឯការងារកម្លាំងប្រដាប់អាវុធ ត្រូវផ្តល់ទៅឱ្យស្ថាប័នពាក់ព័ន្ធ គឺក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ...។

២០. មុខងារសាធារណៈជាជើងមុខ សេដ្ឋកិច្ច និងហិរញ្ញវត្ថុជាជើងក្រោយ ដើរជាមួយគ្នាលើកំណែទម្រង់មុខងារសាធារណៈ និងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

បិទវគ្គប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ជូនសិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់/មធ្យមឆ្នាំ២០១៧ បើកវគ្គបណ្តុះបណ្តាលឆ្នាំ២០១៨, ៥ មិថុនា ២០១៨

... អ្នកមានសញ្ញាបត្រធំ ដែលមិនព្រមធ្វើសកម្មភាព ហើយមិនយល់ដឹងច្បាស់ មិនប្រាកដថាអាចធ្វើកើតនោះទេ។ ឧទាហរណ៍ ពីពេលមុននេះ ក្របខ័ណ្ឌមន្ត្រីមាន ៤ ថ្នាក់ ក្របខ័ណ្ឌ (ក) ... (ខ) ... (គ)និង(ឃ)។ លើកចំណុច ១ ធ្វើជាការគិតគូរ តើវាសមហេតុសមផលឬអត់? ... ក្របខ័ណ្ឌ(ឃ) មាន ៣០ថ្នាក់ ហើយក្នុង ២ឆ្នាំត្រូវបានឡើងមួយថ្នាក់។ បើដូច្នេះ តម្រូវឱ្យមន្ត្រីរាជការរបស់យើងក្នុងក្របខ័ណ្ឌនីមួយៗ ធ្វើការ ៦០ ឆ្នាំ? ... បើអាយុ ២៥ ចូលធ្វើការ ចាប់ពីថ្នាក់ទី ៣០ ទម្រាំតែឡើងដល់ថ្នាក់ទី១ វាមិនត្រូវឡើងទៅដល់អាយុ ៨៥ឆ្នាំ។ អញ្ចឹង ខ្ញុំត្រូវកាន់ (កិច្ចការហ្នឹងដោយខ្លួនឯង)តែម្តង។ **រំលាយចោលគណៈកម្មការកែទម្រង់រដ្ឋ បង្កើតក្រសួងមុខងារសាធារណៈ ហើយអោយក្រសួងមុខងារសាធារណៈជាជើងមុខ និងក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ជាជើងក្រោយ ដើរទៅជាមួយគ្នាលើកំណែទម្រង់មុខងារសាធារណៈ និងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ...។**

២១. គ្រប់គ្រងមន្ត្រីដោយប្រព័ន្ធព័ត៌មានវិទ្យា រកឃើញនិងកាត់ចោលមន្ត្រី/ទាហានខ្មោច

បិទវគ្គប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ជូនសិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់/មធ្យមឆ្នាំ២០១៧ បើកវគ្គបណ្តុះបណ្តាលឆ្នាំ២០១៨, ៥ មិថុនា ២០១៨

... ឥឡូវ **យើងប្រើប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគ្រប់គ្រងមន្ត្រីរាជការ។ មុននេះ កុំថានៅប្រទេសយើង ប្រទេសផ្សេងក៏មាន ករណីមន្ត្រីខ្មោច និងឬទាហានខ្មោច។** ថាជំនាន់ លន់ នល់ ទៅចុះ មានទាហានខ្មោច។ ដល់ជំនាន់យើងនេះ ក៏មានទាហានខ្មោចផង មានមន្ត្រីខ្មោចផង។ យើងបានរកឃើញដោយធ្វើការកែទម្រង់រដ្ឋបាលសាធារណៈ បូកជាមួយការគ្រប់គ្រងហិរញ្ញវត្ថុ ដូចជាយើងតម្រូវឱ្យមន្ត្រីរាជ**ការបើកបៀវត្សរ៍តាមប្រព័ន្ធធនាគារ។ គ្រាន់តែចំណុចនេះមួយ យើងកាត់ខ្មោចចោលបានរាប់ពាន់រាប់ម៉ឺនឯណោះ ... ចំណេញថវិកាជាតិមិនតិចទេ។ មន្ត្រីខ្លះធ្វើការ ៣កន្លែង បើកបៀវត្សរ៍ ៣កន្លែង ...។**

២២. ឡើងកាំយឺត ដល់ពេលត្រូវឡើងស័ក្តិ មិនដំឡើងឱ្យទៀត

បិទវគ្គប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ជូនសិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់/មធ្យមឆ្នាំ២០១៧ បើកវគ្គបណ្តុះបណ្តាលឆ្នាំ២០១៨, ៥ មិថុនា ២០១៨

... ថាកំណែទម្រង់នោះវាយឺតនោះក៏យឺតទៅហើយ ប៉ុន្តែនៅពេលដែលមន្ត្រីត្រូវឡើងស័ក្តិ តាមស្ថាប័ននីមួយៗ មិនព្រមដំឡើងឱ្យថែមទៀត។ នេះហើយគឺជាចំណុចដែលខ្ញុំតែងតែធ្វើការដាស់តឿនចំពោះបណ្តារដ្ឋមន្ត្រី សូមឱ្យយកចិត្តទុកដាក់។ នៅដើមអាណត្តិ ខ្ញុំបានប្រកាសថាឲ្យធ្វើរំលឹក ... **ស័ក្តិដែលមិនទាន់បានឡើងតាមកម្រិត ត្រូវឱ្យឡើង ... អ្វីដែលបានដោះស្រាយក្នុងពេលកន្លងទៅ ធ្វើឲ្យមុខងារសាធារណៈ ត្រូវបានបែងចែកចេញជាថ្នាក់ទាក់ទងជាមួយការគ្រប់គ្រងនៅថ្នាក់កណ្តាល និងនៅថ្នាក់ក្រោមជាតិ នឹងមានលក្ខន្តិកៈដោយឡែកសំរាប់មន្ត្រីមុខងារសាធារណៈនៅថ្នាក់ក្រោមជាតិថែមទៀត ... ភាពសាំញ៉ាំខ្លះមិនបណ្តាលពីស្ថាប័ន ឬមន្ត្រីថ្នាក់ក្រោមទេ តែចេញពីការដឹកនាំរបស់រដ្ឋាភិបាល ក្នុងនោះនាយករដ្ឋមន្ត្រីត្រូវរែកពន់ការលំបាក ...។**

២៣. សំណាងយោងដី ស្រីយោងប្រុស តែការិយា/កូន កុំលូកលាន់កិច្ចការប្តី/ឪពុក

ចែករំលែកបនបត្របញ្ជាក់ការសិក្សាសិស្សមន្ត្រីសាលាភូមិន្ទរដ្ឋបាល, ២៦ មិថុនា ២០១៧

... ខ្ញុំសូមស្នើឱ្យយកចិត្តទុកដាក់អំពីភរិយានិងកូន។ រឿងនេះ ហាក់ដូចជារឿងកំប៉ិកកំប៉ុក ក៏ប៉ុន្តែ រឿងប្តីស័ក្តិបី ប្រពន្ធស័ក្តិបួន កូនស័ក្តិប្រាំ ខ្មែរស្អប់ណាស់ ... **នៅពេលដែលខ្ញុំមានលទ្ធភាពគ្រប់គ្រងប្រទេស កូនរបស់ខ្ញុំ ចៅរបស់ខ្ញុំ ត្រូវតែជាកូនល្អ មិនអាចប្រើប្រាស់ឥទ្ធិពលរបស់ឪពុកម្តាយ គំរាមកំហែងអ្នកដទៃបានទេ។** ពាក្យខ្មែរបាននិយាយថា "**សំណាងយោងដី ស្រីយោងប្រុស**"។ ការរីកធំធាត់របស់យើង ក៏ចាប់ផ្តើមពីការដែលយើងមានភរិយាជួយកិច្ចការប្តី ដូចជាទាក់ទងទៅនឹងកម្មវិធីមនុស្សធម៌ ប៉ុន្តែមិនមែនលូកលាន់កិច្ចការប្តីនោះទេ ...៕

២៤. បញ្ជៀសការតែងតាំងរបៀបបក្ខពួក/គ្រួសារនិយម ដោយការប្រឡងប្រជែង

បិទវគ្គប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ជូនសិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់/មធ្យមឆ្នាំ២០១៧ បើកវគ្គបណ្តុះបណ្តាលឆ្នាំ២០១៨, ៥ មិថុនា ២០១៨

...មិនត្រូវយល់ថា ខ្លួនជាអ្នកមានបុណ្យស័ក្តិ មើលស្រាលចំពោះអ្នកដទៃដែលធ្វើការជាមួយខ្លួន ឬរហូតទៅដល់មើលស្រាលចំពោះប្រជាពលរដ្ឋដែលយើងជាខ្ញុំបម្រើរបស់ពួកគាត់ទេ ... បើសិនជាបោះបង់ចោលចំណុចនេះ អ្នកមិនអាចទទួលជោគជ័យក្នុងជីវិតទេ ... យើងត្រូវឃើញឱ្យច្បាស់អំពីការរៀបចំមន្ត្រីដើម្បីទទួលការងារ។ **ការតែងតាំងរបៀបបក្ខពួកនិយម គ្រួសារនិយមណាមួយ វាមិនទទួលបាននូវការស្វាគមន៍ពីសំណាក់មន្ត្រីនៅក្រោមឱវាទនោះទេ។ ចំណុចនេះ ក៏រំលឹកជាស់តឿន ចំពោះថ្នាក់ដឹកនាំតាមស្ថាប័ន និងការរំលឹកជាស់តឿន ចំពោះថ្នាក់ខេត្ត/រាជធានី ដែលត្រូវតែងតាំងយ៉ាងណាឱ្យស្រប ដោយការបើកឱ្យមានការប្រឡងប្រជែងដោយស្មើភាព ជាការល្អបំផុត** ...៕

២៥. (មកវា)២០២៣ ដំឡើងបៀវត្សមន្ត្រីរាជការ រកិលពិដានពន្ធបៀវត្សទាំងរដ្ឋនិងឯកជន

បិទវគ្គបណ្តុះបណ្តាលឆ្នាំ ២០២០-២០២១ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ ២០២២ សាលាភូមិន្ទរដ្ឋបាល, ១៣ មិថុនា ២០២២

...បានប្រាប់ទៅឯកឧត្តមអូន ព័ន្ធមុនីរ័ត្ន ថា **ពេលដែលយើងដំឡើងបៀវត្សក៏យើងត្រូវដំឡើងពិដាននៃប្រាក់បៀវត្សជាប់ពន្ធ។ ឧបមាថា ដំឡើងបៀវត្សទាបបំផុត ១លាន ៥សែនរៀល។ អញ្ចឹង យើងដាក់បៀវត្សជាប់ពន្ធហ្នឹង អ្នកដែលមានប្រាក់បៀវត្ស ក្រោម ១លាន ៥សែន ១រៀល អត់ជាប់ពន្ធ។ បើឡើងលើស ១រៀល នឹងជាប់ពន្ធ។ ដើម្បីអី ? ដើម្បីចៀសវាងការដែលអ្នកមានប្រាក់ខែទាបជាងគេត្រូវជាប់ពន្ធ។ អ្នកដែលមានប្រាក់ខែខ្ពស់ហ្នឹង ឱ្យជាប់ពន្ធចុះ។ យើងគិតដូចនេះ ទាំងក្នុងវិស័យរដ្ឋ និងវិស័យឯកជន។ យើងអាចធ្វើទៅបាន**។ ឥឡូវបន្ទុបន្តយការចំណាយបានយ៉ាងច្រើន បើយើងប្រៀបធៀបពេលដែលកូវីដ១៩ (កំពុងរីករាលដាល) ...៕

២៦. ចាយដល់ជាង៥០% នៃចំណាយចរន្ត ជំរុញបៀវត្សមិនទាបជាង ១លានរៀល

បិទវគ្គប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ជូនសិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់/មធ្យមឆ្នាំ២០១៧ បើកវគ្គបណ្តុះបណ្តាលឆ្នាំ២០១៨, ៥ មិថុនា ២០១៨

...អនុវត្តក្រឹត្យក្រមសេដ្ឋកិច្ចទាក់ទងនឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច (ដោយ) យើងហ៊ានចាយតែ ៤០% នៃចំណាយចរន្តប៉ុណ្ណោះលើបន្ទុកបុគ្គលិក ឬស្មើនឹង ៤%នៃផលិតផលសរុបក្នុងស្រុក។ ឥឡូវនេះ **យើងហ៊ានចាយដល់ជាង៥០% នៃចំណាយចរន្តសម្រាប់បន្ទុកបុគ្គលិក។ ទោះបីជាចាយមកដល់ទំហំនេះក៏ដោយពិតមែនតែយើងបានកាត់បន្ថយចំណែកខ្លះលើការវិនិយោគ ក៏ប៉ុន្តែ យើងបានបំពេញតម្រូវការចំពោះមន្ត្រីរាជការ ដែលក្នុងពេល ១ អាណត្តិនេះ យើងបានសម្រេចគោលដៅជំរុញបៀវត្សទាបបំផុតរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធមិនឲ្យទាបជាង ១លានរៀល** ...៕

២៧. ចំណាយលើបុគ្គលិករាច្រើនជាង ៥% បន្តិច នៃផលិតផលក្នុងស្រុកសរុប

ប្រគល់សញ្ញាបត្រជូននិស្សិតនៃសាកលវិទ្យាល័យអាស៊ី-អឺរ៉ុប, ២៣ សីហា ២០២២

... ប្រទេសស្រីលង្កា គ្រាន់តែបុគ្គលិករដ្ឋ ទាំងកងទ័ព/ស៊ីវិល មាន ១លាន ៨ សែននាក់។ ចំណូលជាតិ បានត្រឹមតែចិញ្ចឹមមន្ត្រីរដ្ឋការ។ ខាងស៊ីវិលជាង ១លាន ៥សែន(នាក់) និងកងទ័ពជិត ៣២ម៉ឺន(នាក់)។ (ការចាំបាច់ធ្វើ)កំណែទម្រង់

ស្ថិតនៅកន្លែងហ្នឹង។ កុំឱ្យចំណាយលើបន្ទុកបុគ្គលិកធំហួសពេក។ **ស្រីលង្កា មានប្រជាជនសរុបជិត ២២លាន(នាក់) តែចំនួនបុគ្គលិកធ្វើលើសយើងដល់ទៅប្រាំដងឯណោះ។ សព្វថ្ងៃនេះ សរុបមនុស្សដែលយើងត្រូវទទួលបន្ទុកចិញ្ចឹមត្រឹមតែជាង ៤០ម៉ឺននាក់ទេ។ (ក្នុងស្ថានភាពហ្នឹងស្រីលង្កា) មិនអាចទប់ទល់ដល់ទៅ ១លាន ៨សែននាក់ ដែលត្រូវទទួលបៀវត្ស រួចទេ។ ជាការផ្តល់មតិ វិធីមានតែមួយទេ គឺកាត់បុគ្គលិកសម្រាលបន្ទុក ព្រោះធម្មតាចំណាយលើបន្ទុកបុគ្គលិកត្រូវមានត្រឹមតែ ៤% នៃផលិតផលសរុបក្នុងស្រុកទេ។ (ក្នុងកំរិត)ហ្នឹង (ទើបមាន) ស្ថិរភាព។ សព្វថ្ងៃ យើងចំណាយច្រើនជាង ៥% បន្តិចតែប៉ុណ្ណោះ** ...៕

២៨. បើមិនចេះបច្ចេកវិទ្យាព័ត៌មាន មិនត្រូវតែងតាំងទេ

បិទវគ្គប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ជូនសិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់/មធ្យមឆ្នាំ២០១៧ បើកវគ្គបណ្តុះបណ្តាលឆ្នាំ២០១៨, ៥ មិថុនា ២០១៨

... **បច្ចេកវិទ្យាព័ត៌មានបានជួយយើងក្នុងការជំរុញកំណែទម្រង់។ យើងក៏ត្រូវដើរឱ្យទាន់សភាពការណ៍។ ដោយហេតុនេះ យើងក៏ត្រូវតែមានលក្ខខណ្ឌដែរ។ បើមិនចេះបច្ចេកវិទ្យាព័ត៌មានទេ មិនត្រូវបានទទួលការតែងតាំងទេ។** ហោចបំផុតឱ្យមន្ត្រីរបស់យើង ចេះប្រើតែប្រព័ន្ធស្មាតហ្វូនហ្នឹង ដើម្បីធ្វើការជាមួយគេបាន ... ឥឡូវ ប្រព័ន្ធស្មាតហ្វូនចង់ខ្លាំងជាងកុំព្យូទ័រលើតុផង ... ទោះបីខ្ញុំទៅអង្គការសហប្រជាជាតិ ខ្ញុំអាចមើលព័ត៌មានពីក្នុងប្រទេស ហើយឆ្លងឆ្លើយពីសភាពការណ៍នៅពេលដែលមានការសុំយោបល់ណាមួយកើតឡើង ...៕

២៩. ការបណ្តុះបណ្តាលមន្ត្រី អាចធ្វើតាមក្រសួងស្ថាប័នថ្នាក់ជាតិនិងក្រោមជាតិ

បិទវគ្គ ប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ជូនសិស្សមន្ត្រីជាន់ខ្ពស់សាលាភូមិន្ទរដ្ឋបាល, ២៥ កុម្ភៈ ២០២០

... **ការបណ្តុះបណ្តាលមន្ត្រី យើងនៅតែត្រូវធ្វើបន្ត តាមរយៈសាលា(ភូមិន្ទរដ្ឋបាល)នេះ ប៉ុន្តែ ក៏ត្រូវធ្វើតាមរយៈនៃការបណ្តុះបណ្តាលតាមក្រសួង-ស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិផងដែរ។ កិច្ចការខ្លះ វាមិនទាមទារដល់ការចូលរៀននៅសាលាដោយមានការប្រមូលផ្តុំនោះទេ។** ពេលដែលអ្វីបានកើតឡើងនោះ

ទាមទារឱ្យមានការប្រជុំ ការស្រាវជ្រាវ និងការបណ្តុះបណ្តាលរយៈខ្លីនៅតាមទីកន្លែងរៀងៗខ្លួន ដើម្បីពង្រឹងគុណភាពឆ្លើយតប នៃមន្ត្រីដែលត្រូវធ្វើការងារ ... សាលា(ភូមិន្ទរដ្ឋបាល)នេះ ដូចដែលបានបញ្ជាក់ក្នុងរបាយការណ៍របស់ឯកឧត្តម ពេជ្រ ប៊ុនធិន មានមុខនាទីកសាងសមត្ថភាពមន្ត្រី ...៕

៣០. សាលាភូមិន្ទរដ្ឋបាលរៀបចំកម្មវិធីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំវិស័យសាធារណៈ

បិទវគ្គបណ្តុះបណ្តាលឆ្នាំ២០២២ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០២៣ សាលាភូមិន្ទរដ្ឋបាល, ២៧ មេសា ២០២៣

... **សាលាភូមិន្ទរដ្ឋបាលត្រូវតែរៀបចំកម្មវិធីបណ្តុះបណ្តាលភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ ដោយបង្កើតឲ្យមានវេទិកាភាពជាអ្នកដឹកនាំនិងនាវានុវត្តន៍នៅក្នុងវិស័យរដ្ឋបាលសាធារណៈ។** ចំណុចនេះ សាលាខ្លួនឯងក៏ត្រូវកែទម្រង់ដែរ កុំមករៀនដដែលៗ ទ្រឹស្តីតាំងពីណាពីណា វានៅតែដដែល។ ត្រូវមានការកែទម្រង់នៅក្នុងសាលា។ ឥឡូវនេះ តាមស្ថាប័ននានាមានមន្ត្រីដែលមានបទពិសោធច្រើនណាស់ ដែលយើងអាចអញ្ជើញមន្ត្រីទាំងនោះ មកធ្វើបទឧទ្ទេសនាម ...៕

៣១. តែងតាំងមុន បណ្តុះបណ្តាលតាមក្រោយ សាមីខ្លួនស្វែងយល់អំពីកិច្ចការត្រូវធ្វើ

បិទវគ្គ ប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ជូនសិស្សមន្ត្រីជាន់ខ្ពស់សាលាភូមិន្ទរដ្ឋបាល, ២៥ កុម្ភៈ ២០២០

... ជំនាន់ខ្ញុំនៅជាកូនទាហាន ឬនៅថ្នាក់ក្រោម មុនពេលឡើងថ្នាក់(បង្រៀន) ត្រូវទៅរៀនសិនរួចហើយបានឡើងថ្នាក់។ ឧទាហរណ៍ យើងកាន់កងអនុសេនាធំ ប៉ុន្តែ សមត្ថភាពរបស់យើងអាចកាន់វរសេនាតូច ឬវរសេនាធំ។ អញ្ចឹងត្រូវទៅរៀនគ្រប់គ្រងថ្នាក់កងវរសេនាតូច និងថ្នាក់កងវរសេនាធំ ឬហូតទៅដល់កងពលសិនទើបអាចឡើងថ្នាក់ទៅរួច។ វិធីបញ្ជានៃថ្នាក់នីមួយៗ មិនដូចគ្នាទេ ... ដូច្នេះត្រូវតែមានការប្រុងប្រយ័ត្ន។ សម្រាប់យើងៗ **មានការតែងតាំងមុនរួចបណ្តុះបណ្តាលតាមក្រោយ។ វាមិនជាបញ្ហានោះទេ។ យ៉ាងណាក៏ដោយ អ្នកដែលមិនទទួលបានការបណ្តុះបណ្តាលតាមសាលា ក៏ត្រូវតែស្វែងយល់អំពីកិច្ចការដែលត្រូវធ្វើ** ...៕

៣២. បញ្ហាអ្វីក៏ដោយ ឱ្យតែដោះស្រាយដោយផ្អែកលើផលប្រយោជន៍ប្រជាជន មិនខុសទេ

បិទវគ្គ ប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ជូនសិស្សមន្ត្រីជាន់ខ្ពស់សាលាភូមិន្ទរដ្ឋបាល, ២៥ កុម្ភៈ ២០២០

... សង្ឃឹមថា មន្ត្រីទាំងអស់នឹងយកចំណេះវិជ្ជាដែលខ្លួនទទួលបាន ទៅបម្រើការងារ។ ឯមន្ត្រីដែលនឹងចូលធ្វើកម្មសិក្សា និងធ្វើការរៀនសូត្របន្ត ក៏នឹងខិតខំរៀនសូត្រ។ ឆ្នាំក្រោយយើងនឹងជួបគ្នានៅកន្លែងនេះទៀត។ ខ្ញុំនៅតែនិយាយ(រឿង)ដដែលហ្នឹង ព្រោះវាប្រៀបដូចជាការស្រោចទឹករំដោះគ្រោះ មុនចេញទៅធ្វើការ។ **ហ្នឹងដូចបាលីការពារខ្លួនអញ្ចឹងថា "ខ្ញុំគឺជាអ្នកបម្រើប្រជាជន"។ មិនថាជាបញ្ហាអ្វីក៏ដោយ បើយើងដោះស្រាយដោយផ្អែកលើមូលដ្ឋាននៃផលប្រយោជន៍ប្រជាជន វាមិនខុសទេ។ លើកលែងតែយើងមានភាពលម្អៀងណាមួយ និងផលប្រយោជន៍ណាមួយនៅក្នុងហ្នឹង ទើបដោះអត់ចេញ ...**។

៣៣. តែងមានសេណារីយូប្រុងប្រៀបឆ្លើយតបទៅនឹងលទ្ធភាពកើតឡើងច្រើនបែប

សំណេះសំណាលក្រុមគ្រូពេទ្យសម្តេចតេជោប្រឆាំងកូវីដ១៩, ១៧ ឧសភា ២០២២

... ពេលដែលខ្ញុំអំពាវនាវនោះ កម្ពុជាមិនទាន់មានកូវីដ១៩ប៉ុន្មានទេ។ មកដល់ពេលនេះ អ្នកទាំងអស់គ្នាអាចដឹងបានហើយថា មិនមែនជាការចៃដន្យទេ ក្នុងការដែលយើងយកជោគជ័យលើកូវីដ១៩។ **គ្រាន់តែប៉ុណ្ណោះ អាចផ្តល់នូវសញ្ញាបានថា ហ៊ុន សែន មិនដែលខ្វះសេណារីយូ (ប្រុងប្រៀបឆ្លើយតបទៅនឹង) លទ្ធភាពកើតឡើងច្រើនបែប**។ ពេលនោះ យើងមានក្រុមឆ្លើយតបបន្ទាន់ស្អីៗ គ្រប់គ្រាន់ក៏ប៉ុន្តែ ប្រសិនបើខ្ញុំមិនបានបង្កើតសកម្មភាពយុវជនគ្រៀមបម្រុងទុក ដើម្បីរួមចំណែកនៅពេលសភាពការណ៍ធំកើតឡើង នៅពេល(ផ្ទុះ)ព្រឹត្តិការណ៍(ជំងឺឆ្លងកូវីដ១៩ ថ្ងៃទី)២០ ខែកុម្ភៈ ឆ្នាំ២០២១ តើយើងមានលទ្ធភាពឯណា ដើម្បីដោះស្រាយ? ... **គេអាចយល់បានអំពីការគិតគូររបស់នាយករដ្ឋមន្ត្រីរូបនេះ (ដែល)តាំងពីមុនមក(តែង)មានការគ្រៀមរៀបចំមុន មិនមែនតែចំពោះកូវីដ១៩ទេ ...**។

៣៤. មន្ត្រីគេចវេះពីការទទួលវ៉ាក់សាំងកូវីដ១៩ មិនអាចចូលធ្វើការបានទេ

សារសំឡេងរំលឹកដល់មន្ត្រីរាជការដែលពុំទាន់បានចាក់វ៉ាក់សាំងការពារកូវីដ១៩, ៦ មេសា ២០២១

... ក្នុងយុទ្ធនាការចាក់វ៉ាក់សាំងនេះ បានឃើញកើតមានមន្ត្រី២ប្រភេទ។ ប្រភេទទី១ គឺមន្ត្រីចង់ចាក់វ៉ាក់សាំងបានឆាប់តាមដែលអាចធ្វើបាន ... ប្រភេទមន្ត្រីទី២ គេចវេះពីការចាក់វ៉ាក់សាំង ... សូមជម្រាបជូនថា ខ្ញុំមិនចង់ឲ្យដល់ដំណាក់កាលដែលមានការលំបាកហើយ ទើបស្រោចស្រង់ទេ។ **សូមបញ្ជាក់ជូនមន្ត្រីរាជការដែលមិនចង់ចាក់វ៉ាក់សាំងឲ្យបានជ្រាបថា ពេលណាដែលគ្រប់ស្តាប់ចាក់បានពី៧០% ឡើងលើ មន្ត្រីមិនចាក់វ៉ាក់សាំងប្រហែលជាមិនអាចចូលធ្វើការបានទេ។** សុំដេកផ្ទះចុះ។ **បើសិនជាថ្នាក់ដែលត្រូវចូលប្រជុំ ក៏មិនចាំបាច់ឲ្យប្រធានស្តាប់ន អញ្ជើញចូលរួមប្រជុំដែរ ព្រោះ(ថា បើ)គ្រាន់តែវ៉ាក់សាំងការពារជីវិតខ្លួនឯង និងចូលរួមប្រយុទ្ធនឹង Covid-19 ធ្វើមិនបានផង តើចាំបាច់បន្តធ្វើជាទាហានជាប៉ូលីសឬក៏ជាមន្ត្រីរាជការធ្វើអ្វីតទៅទៀត ...**។

៣៥. ក្រសួងមុខងារសាធារណៈបូកសរុបចំនួនមន្ត្រីបានចាក់វ៉ាក់សាំងរួចជូននាយករដ្ឋមន្ត្រីដើម្បីគ្រប់គ្រងជាព័ត៌មាន និងស្វះស្វែងរកវ៉ាក់សាំងបន្ត

សារសំឡេងរំលឹកដល់មន្ត្រីរាជការដែលពុំទាន់បានចាក់វ៉ាក់សាំងការពារកូវីដ១៩, ៦ មេសា ២០២១

... យើងសុខចិត្តឲ្យគាត់(មន្ត្រីប្រភេទទី២ ដែលគេចវេះពីការចាក់វ៉ាក់សាំង)ចាកចេញពីការងារ ហើយជ្រើសរើសមន្ត្រីថ្មីចូលធ្វើការជំនួសវិញ។ នេះជាបញ្ហាសុខភាពសាធារណៈ ... យើងត្រូវគិតអំពីប្រយោជន៍រួមរបស់ជាតិ លើកលែងតែករណីមួយគត់ គឺគ្រូពេទ្យបញ្ជាក់ថាបុគ្គលនេះមិនអាចចាក់វ៉ាក់សាំងបាន ... នេះ **មិនមែនជាការជំរុញឱ្យមានការរើសអើងទេ ក៏ប៉ុន្តែជាការជាស់តឿនដើម្បីការពារខ្លួនពីជំងឺកូវីដ១៩ សម្រាប់សាមីខ្លួនផង និងសម្រាប់អង្គភាពដែលត្រូវធ្វើការផង ... សូមរដ្ឋមន្ត្រីនីមួយៗ ទទួលចំពោះមុខនាយករដ្ឋមន្ត្រី ហើយរាយការណ៍ទៅក្រសួងមុខងារសាធារណៈ។ ក្រសួងមុខងារសាធារណៈត្រូវតែធ្វើការបូកសរុបចំនួនមន្ត្រីដែលបានចាក់វ៉ាក់សាំងរួចហើយ ជូនមកនាយករដ្ឋមន្ត្រីដើម្បីគ្រប់គ្រងជាព័ត៌មាន អំពីការធ្វើជំរឿន ធ្វើបច្ចុប្បន្នភាព និងស្វះស្វែងរកវ៉ាក់សាំងចាក់បន្ត** ទៀតនៅពេលក្រោយ ...។

៣៦. រក្សាតួនាទីមន្ត្រីនយោបាយទទួលបានការតែងតាំងរួចមកហើយឲ្យនៅដដែល

សារសម្លេង សម្តេចតេជោ ហ៊ុន សែន ស្តីពីការតែងតាំងឥស្សរជនក្នុងក្របខ័ណ្ឌនយោបាយ, ២៩ កក្កដា ២០២៣

...ខ្ញុំព្រះករុណាខ្ញុំ ក៏ដូចជាសម្តេច សាយ ឈុំ, សម្តេច សខេង, សម្តេច ទៀ បាញ់, សម្តេច ម៉ែន សំអន, បណ្ឌិត ហ៊ុន ម៉ាណែត, បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន, ឯកឧត្តម កើត រិទ្ធ ដែលបានពិភាក្សាគ្នានៅផ្ទះខ្ញុំព្រះករុណាខ្ញុំ បានសម្រេចចិត្តថា នឹងរក្សាទុកមន្ត្រីទាំងអស់ដែលបានតែងតាំងរួចមកហើយជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬទីប្រឹក្សារាជរដ្ឋាភិបាលឲ្យបន្តតទៅទៀត ... **អ្នកដែលកាន់មុខងារសាធារណៈពុំមានអ្វីជាចំណោទនោះទេ លើកលែងតែអ្នកដល់អាយុចូលនិវត្តន៍ទើបអាចចូលនិវត្តន៍។ ក្រសួងមុខងារសាធារណៈមិនត្រូវបានប៉ះពាល់ឡើយ ដូចជាអគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អភិបាលខេត្ត អភិបាលរង អភិបាលស្រុក អភិបាលរងស្រុក/ខណ្ឌ គឺមិនត្រូវបានប៉ះពាល់ទេ។ មេទាហានគ្រប់ជាន់ថ្នាក់ មេប៉ូលីស អាវុធហត្ថគ្រប់ជាន់ថ្នាក់ មិនត្រូវបានប៉ះពាល់ទេ លើកលែងតែអ្នកនោះដល់អាយុចូលនិវត្តន៍គឺត្រូវចូលនិវត្តន៍តាមច្បាប់** ...។

៣៧. តំណែងរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី សំរាប់អគ្គនាយកពន្ធដារនិងអគ្គនាយកគយ

សារសម្លេង សម្តេចតេជោ ហ៊ុន សែន ស្តីពីការតែងតាំងឥស្សរជនក្នុងក្របខ័ណ្ឌនយោបាយ, ២៩ កក្កដា ២០២៣

... កិច្ចការតែមួយទេ ដែលត្រូវធ្វើការកែទម្រង់នោះគឺរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី។ កន្លងទៅនេះ មានការតែងតាំងរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីមួយចំនួន (ដែលមានតំណែង)ជារដ្ឋលេខាធិការ គឺជាអ្នកដែលធ្វើការផ្ទាល់ជាមួយនាយករដ្ឋមន្ត្រី។ ដូច្នេះយើងទុកឱ្យម្នាក់ៗធ្វើការជ្រើសរើសថាតើនៅជារដ្ឋលេខាធិការ ឬទៅជារដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី។ ឱ្យកតែមួយទេ ... **ករណីលើកលែងគឺមានតែអង្គភាព ២ ធំៗដែលខ្ញុំព្រះករុណាខ្ញុំបានប្រាប់ទៅអនាគតថ្នាក់ដឹកនាំជំនាន់ក្រោយ គឺមុខតំណែងរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនេះ នឹងរក្សាទុកសម្រាប់អគ្គនាយកពន្ធដារ និងអគ្គនាយកគយ ដែលទាំង ២ នេះត្រូវធ្វើការម្នាង**

ជាមួយរដ្ឋមន្ត្រី ឯម្នាងទៀតជាមួយនាយករដ្ឋមន្ត្រី ដែលត្រូវភ្ជាប់ផ្ទាល់ទៅលើថវិកាប្រចាំថ្ងៃប្រចាំខែ ...។

៣៨. នាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រី គួបផ្សំការទទួលខុសត្រូវក្នុងការជ្រើសនិងតែងតាំងមន្ត្រី

បិទវគ្គបណ្តុះបណ្តាលឆ្នាំ២០២២ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០២៣ សាលាភូមិន្នរដ្ឋបាល, ២៧ មេសា ២០២៣

... សិទ្ធិអំណាចជ្រើសរើសមន្ត្រីនយោបាយជាថ្នាក់រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬហៅថាមន្ត្រីនយោបាយ ជាសិទ្ធិអំណាចរបស់នាយករដ្ឋមន្ត្រី។ ក្នុងមួយរយៈនេះ ខ្ញុំបានផ្តល់ឱកាសឱ្យរដ្ឋមន្ត្រីនានាមានលទ្ធភាពជ្រើសរើសមន្ត្រីដែលមានសមត្ថភាព ហើយស្នើមកខ្ញុំ ... ជាទូទៅ ខ្ញុំគោរពនូវការសម្រេចរបស់រដ្ឋមន្ត្រីដែលស្នើឡើង ... **ក្រសួងមុខងារសាធារណៈក៏បានផ្តល់យោបល់ ... ពេលលើកសំណើត្រង់មកនាយករដ្ឋមន្ត្រី ក៏នាយករដ្ឋមន្ត្រីមិនដែលជំទាស់ដែរ។ ធ្វើបែបនេះ វាក៏អាចបង្ហាញនូវចំណែកនៃការទទួលខុសត្រូវ ... យើងបានគួបផ្សំ(ការពិនិត្យនិងទទួលខុសត្រូវជាមួយ)គ្នា ក្នុងការជ្រើសរើសនិងតែងតាំងមន្ត្រី។ យើងត្រូវបន្តការខិតខំ ដើម្បីជំរុញកំណែទម្រង់នេះ ឱ្យទៅមុខជាបន្តទៀត** ...។

៣៩. ការគ្រប់គ្រងរដ្ឋបាលថ្នាក់ជាតិនិងក្រោមជាតិ ត្រូវមានចំណេះដឹង ចំណេះធ្វើ ជាមូលដ្ឋាន

បិទវគ្គបណ្តុះបណ្តាលឆ្នាំ២០២២ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០២៣ សាលាភូមិន្នរដ្ឋបាល, ២៧ មេសា ២០២៣

... សូមថ្លែងនូវការកោតសរសើរចំពោះក្រសួងមុខងារសាធារណៈ ក៏ដូចជា សាលាភូមិន្នរដ្ឋបាល ដែលបានខិតខំបើកវគ្គបណ្តុះបណ្តាលមន្ត្រីរាជការរបស់យើង ... តាមរយៈការកែទម្រង់រដ្ឋបាល **យើងបានខិតខំបណ្តុះបណ្តាលមន្ត្រីរាជការ ដើម្បីពួកគេទទួលបានចំណេះដឹង ចំណេះធ្វើសម្រាប់ដំណើរការ ទាំងនៅថ្នាក់ជាតិ ជាពិសេសនៅថ្នាក់ក្រោមជាតិ**។ ខ្ញុំបានឃើញការធ្វើសម្ភាសន៍ខាង BTV របស់កញ្ញា ពៅ រក្សា ជាមួយអភិបាលរងស្រុកជាស្ត្រីនិងមន្ត្រីមួយចំនួន ... **បើសិនជាមិនបានការបណ្តុះបណ្តាលទេ វាលំបាកនឹងសម្រេចបានកិច្ចការដែលយើងត្រូវធ្វើ។ យើងត្រូវមានមូលដ្ឋានគ្រឹះ នៃចំណេះដឹង ចំណេះធ្វើ ក្នុងដំណើរការគ្រប់គ្រងរដ្ឋបាលទាំងថ្នាក់ក្រោមជាតិ ទាំងថ្នាក់ជាតិ ក៏ដូចជាតាមស្ថាប័ននានា** ...។

៤០. បង្កើតច្បាប់បាន កែច្បាប់បាន តែឱ្យត្រូវតាមកម្រិត

បិទវគ្គបណ្តុះបណ្តាលឆ្នាំ២០២២ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០២៣
សាលាភូមិន្ទរដ្ឋបាល, ២៧ មេសា ២០២៣

... ទាក់ទងនឹងការរង់ចាំរបស់ប្រជាពលរដ្ឋ ... ទាក់ទងនឹងការកែទម្រង់។ បើសិនជាអ្វីដែលយើងដាក់ចុះទៅ ឃើញថាវាមិនត្រូវ យើងអាចកែវាបាន។ **អនុក្រឹត្យយើងបង្កើតបាន យើងក៏លុបវាបាន។ ច្បាប់ក៏ដូចគ្នា។ យើងបង្កើតច្បាប់ យើងក៏មានលទ្ធភាពកែច្បាប់នោះឡើងវិញបានដែរ ប៉ុន្តែកែឱ្យត្រូវនឹងកម្រិត** ... ទាក់ទងជាមួយអន្លង់ផ្សោតរបស់ខេត្តក្រចេះ និងមួយផ្នែករបស់ខេត្តស្ទឹងត្រែង។ សត្វផ្សោតនេះបានស្លាប់ជាបន្តបន្ទាប់ដោយការជាប់មង។ **ពេលបើកការដ្ឋានសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គនៅខេត្តក្រចេះ ខ្ញុំបានផ្តល់អនុសាសន៍ឱ្យរៀបចំតំបន់ស្នូល ហាមឃាត់ការធ្វើនេសាទដោយមង។ បន្ទាប់ពីការអនុវត្តនៅខែកុម្ភៈរហូតមកដល់ខែមេសានេះ ក៏នៅតែមានសត្វផ្សោតងាប់ជាដែល ជាមួយគ្នានឹងផលប៉ះពាល់ចំពោះអ្នកនេសាទរាប់ពាន់គ្រួសារ ... (ដោយហេតុនេះ) ខ្ញុំបានសម្រេចលុបចោលអនុក្រឹត្យថ្មីលេខ១៥៥ ចុះថ្ងៃទី២៧ ខែកុម្ភៈ ត្បិតថា(បើក្បាទុក)អនុវត្តទៅក៏ស្ថានការណ៍នៅដដែល ហើយងាកទៅបន្តអនុវត្តអនុក្រឹត្យថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ វិញ** ...។

៤១. កែសេចក្តីសម្រេចដែលមិនបម្រើប្រយោជន៍ប្រជាជន មិនមានអ្វីខុសនិងជាការកែទម្រង់

បិទវគ្គបណ្តុះបណ្តាលឆ្នាំ២០២២ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០២៣
សាលាភូមិន្ទរដ្ឋបាល, ២៧ មេសា ២០២៣

... ខ្ញុំបានធ្វើការសម្រេចចិត្តមួយក្នុងចរិតមានលក្ខណៈជាការកែទម្រង់។ សូមកុំស្លាប់ក្រឡា។ សេចក្តីសម្រេច វាមិនមែនត្រូវទាំងអស់ទេ។ វាមានសេចក្តីសម្រេចដែលចេញទៅវាត្រូវ វាក៏មានសេចក្តីសម្រេចចេញទៅវាខុស។ បើឃើញថាវាខុសហើយ យើងកែវាទៅ។ ហ្នឹងហៅថា កែទម្រង់ហើយ។ ធ្វើម៉េចឱ្យតែធ្វើការសម្រេចចិត្តដោយផ្អែកលើផលប្រយោជន៍របស់ប្រជាជន។ នេះក៏ជាផ្នែកមួយដែលត្រូវអប់រំចំពោះសិស្សដែលបញ្ចប់ការសិក្សា និងសិស្សចូលថ្មី ក៏ដូចជាប្រាប់ទៅមន្ត្រីដែលកំពុងកាន់មុខងារទាំងឡាយ។ **“អ្វីដែលជាការសម្រេចរបស់យើង មិនមែនត្រូវទាំងអស់នោះទេ”។ បើឃើញថាសេចក្តីសម្រេចនោះមិនចំគោលដៅបម្រើផលប្រយោជន៍ប្រជាជន ក៏យើងកែវាទៅ។ អត់មានអីដែលត្រូវខុស អត់មានអីដែលត្រូវលំបាកទេ** ...។

៤២. ក្រោយចាកចេញពីមុខតំណែង អាចរកពេលមកឆ្លើយសំណួរនៅសាលាភូមិន្ទរដ្ឋបាល

បិទវគ្គបណ្តុះបណ្តាលឆ្នាំ២០២២ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០២៣
សាលាភូមិន្ទរដ្ឋបាល, ២៧ មេសា ២០២៣

... ថ្ងៃក្រោយ បើសិនជាមានពេល ខ្ញុំនឹងទៅឧទ្ទេសនាមទៀត។ មិនទៅនិយាយឲ្យគេស្តាប់ទេ ចង់ទៅឲ្យគេសួរ។ ប៉ុន្តែ យ៉ាងច្រើន ១០សំណួរ។ ស្វាគមន៍អីបន្តិចបន្តួចហើយ ដាក់ជាសំណួរតែម្តង នៅក្នុងក្របខ័ណ្ឌនៃកិច្ចការដែលត្រូវតែធ្វើ។ ជាលទ្ធភាពមួយដែលខ្ញុំអាចធ្វើទៅរួច។ ប៉ុន្តែរង់ចាំមើលសិន តើពេលណានាយករដ្ឋមន្ត្រីរូបនេះចាកចេញពីមុខតំណែង ដើម្បីផ្ទេរទៅឲ្យអ្នកក្រោយ ... ប្រកួតកីឡាប្រកួតបាល់ទាត់ បាល់ទះ ឬក៏ប្រកួតវាយកូនគោល ឬក៏ប្រកួតស្ពឺៗ បាន តែប្រកួតជាមួយព្រហ្មលិខិតប្រកួតមិនបានទេ។ ខ្ញុំមិនដែលប៉ុនប៉ងណាមួយ ធ្វើចៅហ្វាយស្រុក ធ្វើចៅហ្វាយខេត្ត ធ្វើរដ្ឋមន្ត្រី ធ្វើនាយករដ្ឋមន្ត្រីទេ ... ការប៉ុនប៉ងរបស់ខ្ញុំពីដើម គឺត្រឹមធ្វើគ្រូបង្រៀន។ ប៉ុន្តែ មិននឹកស្មានថាមកធ្វើនាយករដ្ឋមន្ត្រីជិត ៤ ទសវត្សរ៍ ... ហ្នឹងជាព្រហ្មលិខិត ប៉ុន្តែបើមិនប្រឹងទេ ក៏អត់បានដែរ ...។

១៩. យុត្តធម៌

១	អតីតកាលផ្តល់មេរៀននិងរំលឹកថាចាប់ផ្តើមពីកន្លែងណា	៣៥៣
២	បង្កើតសាលាឧទ្ធរណ៍ក្នុងសម័យអន្តរកាលអ៊ុនតាក់	៣៥៣
៣	ប្រធានតុលាការតែងតាំងដោយក្រុមប្រឹក្សារដ្ឋមន្ត្រី និងជាសមាជិកក្រុមអធិការកិច្ច	៣៥៣
៤	ប្រធានតុលាការនិងអយ្យការអមតុលាការ តែងតាំងដោយក្រុមប្រឹក្សារដ្ឋ ...	៣៥៤
៥	ក្នុងតំណែងប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ដកហូតអំណាចតែងតាំងប្រធានតុលាការ...	៣៥៤
៦	ដកសមាសភាពប្រធានតុលាការពីក្រុមអធិការកិច្ច	៣៥៥
៧	កាត់ក្តីដោយគុណធម៌ មានឬក្រទទួលបានយុត្តិធម៌ដូចគ្នា	៣៥៥
៨	ការផ្តល់ជំនួយផ្នែកច្បាប់ជូនប្រជាពលរដ្ឋក្រីក្រ ផ្តើមចេញពីកត្តា៣ យ៉ាង	៣៥៦
៩	ការប្រឹក្សាខាងផ្នែកច្បាប់ ជាផ្នែកមួយនៃកំណែទម្រង់ប្រព័ន្ធយុត្តិធម៌និងតុលាការ	៣៥៦
១០	ក្នុងនីតិកាលខាងមុខគប្បីជំរុញឱ្យចេញបានតុលាការឯកទេស	៣៥៧
១១	ខិតខំបណ្តុះបណ្តាលមន្ត្រីយុត្តិធម៌ជាស្ត្រីគ្រប់ផ្នែកទាក់ទងនឹងសេវាយុត្តិធម៌	៣៥៧
១២	ករណីខ្លះមេធាវីជាបុរសមិនអាចយកចម្លើយពីកូនក្តីជាស្ត្រីអស់ដូចមេធាវីជាស្ត្រី	៣៥៨
១៣	ពង្រីកចំណុចត្រូវគ្នា បង្រួមចំណុចមិនត្រូវគ្នា ក្នុងការស្រាយមំនាស់រដ្ឋប្បវេណី	៣៥៨
១៤	ផុតពីរដ្ឋបាលដែនដីមកដល់តុលាការក៏សូមចៅក្រមប្រកាន់តួនាទីសម្របសម្រួល	៣៥៩
១៥	ដំណើរការកាត់ក្តីធ្លាប់យឺតយ៉ាវ ដោយសារខ្វះសាលសវនាការ ចៅក្រម មេធាវី	៣៥៩
១៦	អរគុណមិត្តភក្តិ ពិសេសជប៉ុនដែលរួមចំណែកក្នុងការកែទំរង់ប្រព័ន្ធតុលាការ	៣៦០
១៧	ជប៉ុនជួយពង្រឹងនីតិរដ្ឋ ការអនុវត្តច្បាប់នៅកម្ពុជា	៣៦០
១៨	កំណើនសាលាឧទ្ធរណ៍តាមភូមិភាគ ធ្វើអោយមានតម្រូវការធនធានមនុស្ស	៣៦១
១៩	ដំណើរការប្រជាធិបតេយ្យនិងនីតិរដ្ឋទៅជាមួយគ្នា	៣៦១
២០	ក្តាប់បានអង្គហេតុពីកូនក្តី ទើបមេធាវីអាចកំណត់បានពីអង្គច្បាប់	៣៦២
២១	សូមចៅក្រមផ្សះផ្សារបញ្ចប់វិវាទរវាងគូភាគី ក្បិតក្តីរដ្ឋប្បវេណីគ្មានអ្នកចំណេញ	៣៦២
២២	ដោះស្រាយមំនាស់ក្រៅប្រព័ន្ធតុលាការដោយយោគយល់ក្នុងស្ថានភាពឈ្នះឈ្នះ	៣៦៣
២៣	អ្នកឈ្នះថាតុលាការយុត្តិធម៌ អ្នកចាញ់ថាអយុត្តិធម៌	៣៦៤
២៤	កំណែទំរង់ប្រព័ន្ធយុត្តិធម៌និងតុលាការ ជាក់ចេញដោយរដ្ឋាភិបាលអាណត្តិទី៣	៣៦៤
២៥	ផ្តល់ការការពារក្តីចំពោះតែអ្នកសារព័ត៌មានគោរពតាមក្រមសីលធម៌វិជ្ជាជីវៈ	៣៦៥

២៦	ស្វែងរកសង្គតិភាពរវាងច្បាប់ស្តីពីលក្ខខន្តិកៈមេធាវី និងក្រមនីតិវិធីព្រហ្មទណ្ឌ	៣៦៥
២៧	យុត្តិធម៌ មេធាវីមិនអាចកំរៃ អាជ្ញាធរដែនដី ស្តាប់នពាក់ព័ន្ធសំរុះសំរួលក្រៅប្រព័ន្ធ	៣៦៦
២៨	បើចង់ដំណើរការសវនាការក្តីបានឆាប់ មេធាវីមិនត្រូវធ្វើពហិកា	៣៦៦
២៩	នៅពេលខ្លះមេធាវីកាតព្វកិច្ច តើមេធាវីស្មើគ្រិចត្តៃជៃសែនអាចដើរភ្លេជំនួសឬទេ?	៣៦៧
៣០	ពិនិត្យមើលការប្រឈមក្នុងក្របខណ្ឌច្បាប់ស្តីពីលក្ខខន្តិកៈមេធាវី	៣៦៧
៣១	យន្តការមេធាវីស្មើគ្រិចត្តការពារក្តីនិងផ្តល់ប្រឹក្សាផ្នែកច្បាប់ជាជំរើសល្អជាងគេ	៣៦៨
៣២	ការផ្តល់មេធាវីកាតព្វកិច្ច ក្នុងការណើបទឧក្រិដ្ឋ ឬសំណុំរឿងពាក់ព័ន្ធនឹងអនីតិជន	៣៦៨
៣៣	សមាគម/អង្គការក្រៅរដ្ឋាភិបាល ផ្តល់មេធាវី/ពិគ្រោះផ្លូវច្បាប់ដល់ពលរដ្ឋក្រីក្រ	៣៦៩
៣៤	អង្គការក្រៅរដ្ឋាភិបាលនិងមេធាវីខ្លះ ឆ្លៀតឱកាសរុញឱ្យមានបាតុកម្ម	៣៧០
៣៥	វិជ្ជាជីវៈមេធាវី នៅក្រៅក្របខណ្ឌនីតិប្រតិបត្តិ/បញ្ញត្តិ តុលាការ តែមានលក្ខខន្តិកៈ	៣៧០
៣៦	ថវិការដ្ឋផ្តល់ឱ្យគណៈមេធាវី មានគោលដៅបម្រើជនក្រីក្រពិតប្រាកដ	៣៧១
៣៧	រាជរដ្ឋាភិបាលត្រូវតែមានចំណែកគ្រប់គ្រងនិងរៀបចំលើនយោបាយព្រហ្មទណ្ឌ	៣៧១
៣៨	ច្បាប់កំណត់សញ្ជាតិខ្មែរតែមួយសម្រាប់មេដឹកនាំស្តាប់នកំពូលចូលជាធរមាន	៣៧២
៣៩	ព្រះរាជអាជ្ញាចេញដីកា ទើបនគរបាលយុត្តិធម៌ចាប់ វាលែងតែបទល្មើសជាក់ស្តែង	៣៧២
៤០	ពេលនាយករដ្ឋមន្ត្រីត្រូវទម្លាក់ចេញពីតំណែង តើអ្នកណាបន្តគ្រប់គ្រងប្រទេស	៣៧៣
៤១	បើតំណែងនាយករដ្ឋមន្ត្រីទំនេរស្តាពរ អ្នកណាទទួលរៀបចំគណៈរដ្ឋមន្ត្រីឡើងវិញ	៣៧៤
៤២	ប្រមុខរដ្ឋតែងតាំងនាយករដ្ឋមន្ត្រី ដូច្នេះសំណើលាលែងត្រូវថ្វាយទៅព្រះមហាក្សត្រ	៣៧៤
៤៣	សុំការអនុញ្ញាតអនុវត្តច្បាប់អស្សាមិករណ៍ឱ្យត្រឹមត្រូវដើម្បីប្រយោជន៍សាធារណៈ	៣៧៥
៤៤	មិនមានអ្នកទោសនយោបាយទេ មានតែអ្នកនយោបាយជាប់ទោសព្រហ្មទណ្ឌ	៣៧៥
៤៥	ក្តីបរិហារកេរ្តិ៍ នៅបារាំង ប្រើពេលដល់ទៅ ៣ឆ្នាំ ទើបបើកសវនាការ	៣៧៦
៤៦	ដល់ពេលវេលារៀបចំច្បាប់ដាក់ក្រុមបង្កើងនេះជាក្រុមការងារហើយឬនៅ	៣៧៧

១. អតីតកាលផ្តល់មេរៀននិងរំលើកថាចាប់ផ្តើមពីកន្លែងណា

សម្ភោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា
និងប្រគល់សញ្ញាបត្រ ដល់សិស្សវិជ្ជាជីវៈតុលាការ, ៦ មិថុនា ២០២៣

... ការចងចាំរបស់ខ្ញុំគ្រាន់តែជាអតីតកាលទេ។ ដូចដែលខ្ញុំបាននិយាយច្រំដែលៗ **អតីតកាលមិនអាចប្តូរយកអ្វីបានមកវិញទេ មិនអាចទៅកែអតីតកាលកើតទេ ប៉ុន្តែអតីតកាលនោះផ្តល់មេរៀននិងពិសោធន៍ឱ្យយើង (និងរំលឹក)ថាយើងចាប់ផ្តើមពីទីកន្លែងណា។ និយាយពីហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិស័យតុលាការទៀតសោត យើងមានតិចតួចណាស់។ ខ្ញុំទើបនឹងឱ្យដីសម្រាប់ការសាងសង់តុលាការរាជធានីភ្នំពេញទេ។ បង្កើតបានប៉ុណ្ណឹង។ ដោយយើងបានកសាងរដ្ឋសភា (នៅទីតាំង)ថ្មី យើងក៏យកទីតាំង/អគាររដ្ឋសភាចាស់ដាក់ជាតុលាការកំពូល។** មុននោះ នៅទីកន្លែងមិនសមរម្យទេ។ ឥឡូវ សាលាឧទ្ធរណ៍កំពុងនៅជាប់នឹងក្រសួងយុត្តិធម៌។ បន្តិចទៀតក៏នឹងចេញទៅកន្លែងថ្មី ទីក្រុងថ្មី ...។

២. បង្កើតសាលាឧទ្ធរណ៍ក្នុងសម័យអន្តរកាលអ៊ុនតាក់

សម្ភោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារសាលាយុត្តិធម៌, ២៦ មិថុនា ២០២៣

... *នៅឆ្នាំ ១៩៨២ តុលាការនេះ ត្រូវបានប្តូរឈ្មោះទៅជា "តុលាការប្រជាជនខេត្ត-ក្រុង និងអយ្យការអមតុលាការប្រជាជនខេត្ត-ក្រុង"។ នៅឆ្នាំ ១៩៨៥ "តុលាការប្រជាជនកំពូល" និង "មហាអយ្យការអមតុលាការប្រជាជនកំពូល" ត្រូវបានបង្កើតឡើង ដោយក្រឹត្យឆ្នាំ ១៩៨៥។ នៅឆ្នាំ ១៩៩២ "សាលាឧទ្ធរណ៍" ទើបត្រូវបានបង្កើតឡើង*... [សេចក្តីអធិប្បាយ] ខ្ញុំគួរបញ្ជាក់ថា **សាលាឧទ្ធរណ៍ដែលបានបង្កើតឡើងពាក់ព័ន្ធនឹងវត្តមានអ៊ុនតាក់។ មុននេះ យើងមានតែសាលាដំបូងនិងតុលាការកំពូល។ ថ្ងៃមុន ខ្ញុំក៏បានបញ្ជាក់នៅពេលដែលសម្ភោធសាលាបណ្តុះបណ្តាលវិជ្ជាជីវៈតុលាការការផងដែរថា ពេលអ៊ុនតាក់ចូលមក អ៊ុនតាក់ក៏បានសំណូមពរឱ្យយើងរៀបចំសាលាឧទ្ធរណ៍នេះ។ ដូច្នេះ បានជាមានសាលា(ក្តី) ៣ថ្នាក់** ...។

៣. ប្រធានតុលាការតែងតាំងដោយក្រុមប្រឹក្សារដ្ឋមន្ត្រី និងជាសមាជិកក្រុមអធិការកិច្ច

សម្ភោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា
និងប្រគល់សញ្ញាបត្រ ដល់សិស្សវិជ្ជាជីវៈតុលាការ, ៦ មិថុនា ២០២៣

... គួរតែរំលឹកបន្តិច ដោយហេតុថាពេលដែលចាប់ផ្តើមធ្វើកំណែទម្រង់យុត្តិធម៌ និស្សិតខ្លះមិនទាន់កើតផងទេ។ អញ្ចឹងទេ បានជាត្រូវការចាស់ទុំរៀបរាប់ពីដំណើររឿងខ្លះ ... ក្រោយពេលផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពតវិស័យយុត្តិធម៌ត្រូវបានរៀបចំឡើងវិញជាដំណាក់ៗ។ ខ្ញុំរំលឹករឿង២ សំខាន់ទាក់ទងនឹងការចាប់ផ្តើមក្នុងការធ្វើកំណែទម្រង់តុលាការ ... **ទី១ ប្រធានតុលាការភ្នំពេញ និងបណ្តាខេត្ត ក៏ដូចជាអយ្យការអមតុលាការសាលាដំបូង ត្រូវតែងតាំងដោយក្រុមប្រឹក្សារដ្ឋមន្ត្រី។ គឺនាយករដ្ឋមន្ត្រី ឬប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រីជាអ្នកតែងតាំង។ ចំណុចទី២ ការចុះទៅត្រួតពិនិត្យកន្លែងណា តែងតែជាក់ប្រធានតុលាការជាសមាជិក** ...។

៤. ប្រធានតុលាការនិងអយ្យការអមតុលាការ តែងតាំងដោយក្រុមប្រឹក្សារដ្ឋ តាមសំណើរដ្ឋមន្ត្រីយុត្តិធម៌

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា
និងប្រគល់សញ្ញាបត្រ ដល់សិស្សវិជ្ជាជីវៈតុលាការ, ៦ មិថុនា ២០២៣

... មានការកើតឡើង(រឿងរ៉ាវ)នៅកន្លែងណាមួយ ដែលតម្រូវអោយមានការត្រួតពិនិត្យឬហៅថាធ្វើអធិការកិច្ច គឺផ្នែកធ្វើអធិការកិច្ចហ្នឹងមានទាំងប្រធានតុលាការ... ដល់មកដំណាក់កាលខ្ញុំធ្វើនាយករដ្ឋមន្ត្រី ខ្ញុំបានរៀបចំឱ្យ**ប្រធានតុលាការនិងអយ្យការអមតុលាការ ត្រូវបានតែងតាំងដោយក្រុមប្រឹក្សារដ្ឋ តាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌វិញ**។ (ដែលធ្វើដូចនេះ ព្រោះ)ខ្ញុំយល់ថាមិនសមស្របទេ។ យើងជានីតិប្រតិបត្តិ ប៉ុន្តែបែរជាមានសិទ្ធិតែងតាំងប្រធានតុលាការ សាលាដំបូង និងអយ្យការអមសាលាដំបូង។ ពេលនោះ យើងមិនហៅព្រះរាជអាជ្ញាដូចឥឡូវទេ។ យើងហៅអយ្យការអមតុលាការ និងហៅក្រៅថារដ្ឋអាជ្ញា ដោយសារមិនមែនជារបបរាជានិយម ...។

៥. ក្នុងតំណែងប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ដកហូតអំណាចតែងតាំងប្រធានតុលាការនិងអយ្យការអមសាលាដំបូង

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារសាលាយុត្តិធម៌, ២៦ មិថុនា ២០២៣

... ខ្ញុំនៅចាំបានច្បាស់ពីភាពចាំបាច់ពេលនោះ។ ខ្ញុំដកសិទ្ធិខ្លួនឯងតែម្តង។ ក្នុងហាន:ជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ដែល(មានមនុស្ស) ២នាក់ បានធ្វើមុនខ្ញុំ។ ដល់មកខ្ញុំ**ជាមនុស្សទី៣ នៃតំណែងប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រីគឺខ្ញុំបានដកហូតសិទ្ធិអំណាចរបស់ខ្ញុំក្នុងការចុះហត្ថលេខាតែងតាំងប្រធានតុលាការ និងអយ្យការអមសាលាដំបូង ហើយតាមរយៈនោះបានរៀបចំឱ្យមាននីតិវិធីស្នើតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងមានការតែងតាំងដោយ(ប្រធាន)ក្រុមប្រឹក្សារដ្ឋវិញ**។ ពេលនោះ ខាងនីតិប្រតិបត្តិ គឺរដ្ឋាភិបាល យើងហៅថាក្រុមប្រឹក្សារដ្ឋមន្ត្រី។ ប្រធានរដ្ឋគឺហៅក្រុមប្រឹក្សារដ្ឋ ក្នុងហ្នឹងសម្តេច ហេង សំរិន ជាប្រធានរដ្ឋ ...។

៦. ដកសមាសភាពប្រធានតុលាការពីក្រុមអធិការកិច្ច

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា
និងប្រគល់សញ្ញាបត្រ ដល់សិស្សវិជ្ជាជីវៈតុលាការ, ៦ មិថុនា ២០២៣

... ពេលដែលមានតម្រូវការធ្វើអធិការកិច្ចនៅកន្លែងណាមួយ តែងមានប្រធានតុលាការ(ចូលរួម) រួចហើយក៏យក(ការសំរេច)មកឱ្យខ្ញុំចុះហត្ថលេខា។ **ខ្ញុំថាសុំដកប្រធានតុលាការចេញ។ ខ្ញុំផ្តល់នូវហេតុផលថា បើត្រួតពិនិត្យរួចហើយ រឿងហ្នឹងត្រូវឡើងទៅតុលាការ។ ចុះបើប្រធានតុលាការនៅក្នុងហ្នឹង ឯកភាពរួចហើយតើទៅកាត់ក្តីធ្វើអីទៀត។ អញ្ចឹងបានជាត្រូវដកប្រធានតុលាការឱ្យនៅក្រៅ(ក្រុមអធិការកិច្ច)។** លោតែទៅត្រួតពិនិត្យនោះ វាមានរឿងមិនសមស្របក៏ត្រូវឡើងតុលាការ។ ទុកតុលាការឱ្យនៅសល់សិទ្ធិរបស់គេ ...។

៧. កាត់ក្តីដោយគុណធម៌ មានឬក្រទទួលបានយុត្តិធម៌ដូចគ្នា

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា
និងប្រគល់សញ្ញាបត្រ ដល់សិស្សវិជ្ជាជីវៈតុលាការ, ៦ មិថុនា ២០២៣

... និយាយ(ពីការលើកទឹកចិត្តឲ្យមានការសម្រុះសម្រួលគ្នាក្រៅប្រព័ន្ធតុលាការ) អញ្ចឹង មេធាវីមិនសប្បាយចិត្តទេ។ មេធាវីត្រូវការឲ្យមានបណ្តឹងច្រើន។ ធ្វើជាមេធាវី ត្រូវការពារក្តី ហើយការពារក្តីគឺបានលុយ។ អញ្ចឹងមេធាវីមិនសប្បាយចិត្តនឹងខ្ញុំដែលនិយាយអញ្ចឹងទេព្រោះបាត់មុខរបរគាត់។ ប៉ុន្តែកន្លែងខ្លះ ការដោះស្រាយនោះក៏មានមេធាវីចូលរួមដែរ។ យើងលើកទឹកចិត្តឲ្យមានការដោះស្រាយតាមបែប

នេះ។ **ក្នុងករណីក្តីក្តាំណាមួយកើតឡើង អ្វីដែលសំខាន់គឺគុណធម៌។ សូមកាត់ក្តីដោយមិនលំអៀង ហើយស្រាវជ្រាវឲ្យបានហ្មត់ចត់។ កុំឲ្យមានពាក្យថា ឲ្យតែអ្នកមានគឺឈ្នះក្តីទាំងអស់។ អ្នកណាក៏ដោយ មានក៏ដោយ ក្រក៏ដោយ ត្រូវទទួលបានយុត្តិធម៌ដូចគ្នា**។ អ្នកខ្លះឲ្យតែឃើញថាអ្នកមាន ដឹងតែអ្នកមានខុសតែម្តង។ អ្នកខ្លះក៏គិតថា ឲ្យតែអ្នកក្រ ក៏ដឹងតែត្រូវទាំងអស់។ មិនដូចនោះទេ ...៕

៨. ការផ្តល់ជំនួយផ្នែកច្បាប់ជូនប្រជាពលរដ្ឋក្រីក្រ ផ្តើមចេញពីកត្តា៣ យ៉ាង

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... ត្រូវឃើញពីការចាំបាច់នៃការផ្តល់ជំនួយផ្នែកច្បាប់ជូនប្រជាជនក្រីក្រ។ តើចាប់ផ្តើមពីអ្វី? **ទី១ ការយល់ដឹងឱ្យបានច្បាស់អំពីច្បាប់ ជារឿងចាំបាច់សំរាប់ប្រជាពលរដ្ឋប្រើប្រាស់សិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវនៅក្នុងសង្គមនីតិរដ្ឋ** ... ក្នុងសង្គមនីតិរដ្ឋ វិជ្ជាជីវៈមេធាវីត្រូវបានបង្កើតដើម្បីបំពេញតួនាទីផ្តល់ជំនួយផ្នែកច្បាប់ តាមរយៈការផ្តល់សេវាប្រឹក្សាយោបល់ និងផ្តល់សេវាការពារក្តីនៅចំពោះមុខតុលាការជូនប្រជាពលរដ្ឋដើម្បីការពារសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់ ... **ទី២ មេធាវីជាវិជ្ជាជីវៈសើរើបំពេញការងាររបស់ខ្លួនដោយឯករាជ្យពីស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័នតុលាការ** ... ដោយការប្រើប្រាស់សេវាមេធាវី ត្រូវបង់ថ្លៃ ហើយកម្រៃសេវានេះ ត្រូវកំណត់ដោយសើរើពីមេធាវី ធ្វើឱ្យប្រជាពលរដ្ឋក្រីក្រមិនអាចមានលទ្ធភាពស្វែងរកជំនួយផ្នែកច្បាប់ពីមេធាវីបាន ... **ទី៣ ការផ្តល់ជំនួយសេវាផ្នែកច្បាប់ដល់ជនក្រីក្រ បានក្លាយជាការទទួលខុសត្រូវ និងជាផ្នែកមួយនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីធានាសិទ្ធិទទួលបានយុត្តិធម៌របស់ប្រជាពលរដ្ឋក្រីក្រនៅក្នុងសង្គមនីតិរដ្ឋ** ...៕

៩. ការប្រឹក្សាខាងផ្នែកច្បាប់ ជាផ្នែកមួយនៃកំណែទម្រង់ប្រព័ន្ធយុត្តិធម៌និងតុលាការ

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... មិនត្រឹមតែអ្នកពាក់ព័ន្ធនឹងបទល្មើសដែលខ្លួនបានប្រព្រឹត្តនោះទេ សូម្បីតែអ្នករកស៊ីក៏អាចត្រូវការជំនួយផ្លូវច្បាប់ផងដែរ។ មិនថាអ្នកក្រទេ អ្នកមានក៏ត្រូវការជំនួយផ្នែកច្បាប់។ គោលដៅរបស់យើង គឺតម្រង់ទៅរកអ្នកក្រីក្រដែលត្រូវការប្រឹក្សាខាងផ្លូវច្បាប់ជាមួយយើង។ ចំណុចនេះ ទាមទារឱ្យមេធាវីរបស់យើងជួយបំពេញការយល់ដឹងរបស់ប្រជាពលរដ្ឋ។ យើងត្រូវចាត់ទុកថា**ការប្រឹក្សាផ្នែកច្បាប់និងកិច្ចការដែលយើងកំពុងធ្វើនេះ ក៏ជាផ្នែកមួយនៃកំណែទម្រង់ប្រព័ន្ធយុត្តិធម៌និងតុលាការរបស់យើងផងដែរ**។ យើងមិនត្រឹមតែធ្វើកិច្ចការទាក់ទងជាមួយការការពារចំពោះមុខតុលាការទេ។ កិច្ចការមានច្រើនជាងនេះទៀត ព្រោះយើងជាមេធាវី ជាអ្នកយល់ច្បាប់ ចេះច្បាប់ ឯប្រជាពលរដ្ឋអត់ដឹងទេ។ ជួនកាលប្រជាពលរដ្ឋត្រូវការយើងឱ្យជួយសរសេរពាក្យបណ្តឹង ឬសរសេរពាក្យស្នើសុំកាន់កាប់ដីធ្លី ... ទាក់ទងទាំងអស់។ គឺជាការប្រឹក្សាផ្លូវច្បាប់ ត្រូវឱ្យប្រជាពលរដ្ឋយល់អំពីច្បាប់ ...៕

១០. ក្នុងនីតិកាលខាងមុខគប្បីជំរុញឱ្យចេញបានតុលាការឯកទេស

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារសាលាយុត្តិធម៌, ២៦ មិថុនា ២០២៣

... ក្នុងសេចក្តីព្រៀងច្បាប់ឬហៅថាកម្មវិធីនៃការកសាងសក្តីភាពច្បាប់ គប្បីពន្លឿនច្បាប់ទាក់ទិននឹងតុលាការពាណិជ្ជកម្ម ព្រោះឥឡូវនេះមានបញ្ហាកាន់តែធំកាន់តែច្រើន។ យើងកំពុងតែជាប្រទេស(កំពុងមានការ)អភិវឌ្ឍ ត្រូវពង្រឹងការជឿជាក់សម្រាប់ការធ្វើធុរកិច្ចនៅកម្ពុជា។ **ខ្ញុំស្នើថាគួរតែខិតខំជម្រុញឱ្យចេញនៅក្នុងនីតិកាលខាងមុខនេះ នូវច្បាប់ស្តីអំពីតុលាការពាណិជ្ជកម្ម។ រៀបចំតុលាការពាណិជ្ជកម្មនេះឡើង ដើម្បីកាត់ក្តីរឿង(ទាក់ទងនឹងពាណិជ្ជកម្ម)។ ពេលនេះតុលាការយើងកាត់គ្រប់រឿង។ យើងត្រូវមានតុលាការឯកទេស** ...៕

១១. ខិតខំបណ្តុះបណ្តាលមន្ត្រីយុត្តិធម៌ជាស្ត្រីគ្រប់ផ្នែកទាក់ទងនឹងសោយយុត្តិធម៌

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជានិងប្រគល់សញ្ញាបត្រ ដល់សិស្សវិជ្ជាជីវៈតុលាការ, ៦ មិថុនា ២០២៣

... ខ្ញុំរីករាយដែល**ស្ត្រីបានចូលរួមក្នុងកិច្ចការតុលាការ និងកិច្ចការយុត្តិធម៌នេះ។ ខ្ញុំលើកទឹកចិត្តឱ្យខិតខំដើម្បីបណ្តុះបណ្តាលមន្ត្រីយុត្តិធម៌ជាស្ត្រី ជាចៅក្រម ជាអ្នកអាជ្ញា ជាក្រឡាបញ្ជី គ្រប់ផ្នែកទាក់ទងនឹងសោយយុត្តិធម៌**។ ខ្ញុំបានមើលតួលេខកំរិតបរិញ្ញានៅគ្រប់សាលា ឃើញថាស្ត្រីមានចំនួនច្រើនជាងបុរស។ តែ

ចាប់ពីបរិញ្ញាជាន់ខ្ពស់ឡើងដល់បណ្ឌិតបុរសច្រើនជាង ... នេះជាកត្តាសត្យានុម័ត។ ដំណាក់កាលហ្នឹងជាដំណាក់កាលត្រូវយកប្តី។ ដល់យកប្តីក៏ជាប់កូនជាប់ចៅ។ ដូចនេះការរៀនបន្តជាការលំបាក។ បើនៅប្រឹងរៀនមិនព្រមយកប្តីវាទៅជាក្រមុំចាស់។ សម័យដើមជំនាន់ទសវត្សរ៍៦០ ឬ៧០ ត្រឹមតែអាយុ២៤ ឬ២៥ គេហៅក្រមុំចាស់ហើយ។ បើបុរសត្រឹមតែ២៧ ឬ២៨ គេហៅកម្លោះចាស់ ...៕

១២. ការណីខ្លះមេធាវីជាបុរសមិនអាចយកចម្លើយពីកូនក្តីជាស្ត្រីអស់ដូចមេធាវីជាស្ត្រី

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... មានការផ្តល់ជំនួយផ្នែកច្បាប់ដោយក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ និងខាងផ្នែកមេធាវីរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ... ចំពោះមេធាវីតេជោសែន ... ខ្ញុំសូមអរគុណចំពោះការរៀបចំបានយ៉ាងឆាប់ ហើយស្ម័គ្រចិត្តទទួលយកកាតព្វកិច្ចជួយការពារស្ត្រីក្រីក្រ ... ប្រជាពលរដ្ឋអាចនឹងត្រូវការ(ជំនួយនេះ) ... តាមខេត្តនីមួយៗក៏ត្រូវខិតខំ ដើម្បីចុះទៅដល់ទីកន្លែងដែលគាត់ត្រូវការពិគ្រោះ ... **មេធាវីតេជោសែនក៏សម្បុរទៅដោយស្ត្រីដែរ។ បញ្ហាខ្លះ មេធាវីជាបុរសមិនអាចទទួលបានចម្លើយអស់នៅពេលការពារកូនក្តីជាស្ត្រី ដូចមេធាវីជាស្ត្រីទេ។ ខ្លះគេរំលោភផ្លូវភេទអីអញ្ចេះអញ្ចុះ ឱ្យបុរសទៅសួរ គឺចប់(សេចក្តីហើយ)។ មានតែស្ត្រីគ្នាឯងទេ ដែលអាចសួរពិនិត្យរឿងហ្នឹងបាន(ដោយស្រួលជាងបុរស)** ...៕

១៣. ពង្រីកចំណុចត្រូវគ្នា បង្រួមចំណុចមិនត្រូវគ្នា ក្នុងការស្រាយទំនាស់រដ្ឋប្បវេណី

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារសាលាយុត្តិធម៌, ២៦ មិថុនា ២០២៣

... ចៅក្រមត្រូវចេះវិធីប្រើប្រាស់រូបមន្តដោះស្រាយ។ យើង**ត្រូវពិនិត្យឲ្យបានដឹងថាតើចំណុចណាខ្លះដែលវាត្រូវគ្នា ហើយមានចំណុចណាខ្លះដែលវាមិនត្រូវគ្នា? ត្រូវរកឲ្យឃើញចំណុចទាំងហ្នឹងមុន**។ សូម្បីការចរចានយោបាយដែលខ្ញុំធ្លាប់ធ្វើជាហូរហែមក ដូចជាការចរចានៅ ហ្ស៊ឺអង់តាឌើន័រ រវាងខ្ញុំនិងព្រះករុណាបិតា យើងតែងបានពិនិត្យរួចស្រេចថា អ្វីទៅជាចំណុចត្រូវគ្នា ហើយអ្វីខ្លះទៅជាចំណុចមិនត្រូវគ្នា? **យើងរកវិធីដោះស្រាយចំណុចដែលមិនត្រូវគ្នា ហើយពង្រីកទំហំនៃចំណុចដែលត្រូវគ្នា កាត់បន្ថយទំហំការដែលមិនត្រូវគ្នា។ ទីបុងបំផុត**

យើងឈានទៅរកចំណុចត្រូវគ្នាទាំងស្រុង។ សូមលើកទឹកចិត្ត(ឱ្យសិក្សាចំណុចនេះ ដើម្បីអាចឈ្នះទាំងអស់គ្នា ...៕

១៤. ផុតពីរដ្ឋបាលដែនដីមកដល់តុលាការ ក៏សូមចៅក្រមប្រកាន់តួនាទីសម្របសម្រួល

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារសាលាយុត្តិធម៌, ២៦ មិថុនា ២០២៣

... បើកាលណា(នាំទំនាស់ទៅដល់ការ)កាត់ក្តីហើយ "អ្នកឈ្នះតែងនិយាយថាតុលាការយុត្តិធម៌ រីឯអ្នកចាញ់ថាតុលាការអយុត្តិធម៌"។ អញ្ចឹង តុលាការស្ថិតនៅក្នុងមាត់ដង្កាប់ រវាងម្ខាងថាឲ្យយើងត្រូវ ម្ខាងទៀតថាឲ្យយើងខុស ... ទោះបីយើងកាត់យុត្តិធម៌យ៉ាងម៉េចក៏ដោយ ក៏នៅតែមានពាក្យហ្នឹង។ ក្រុមប្រឆាំងក៏តែងតែប្រើ(ពាក្យសម្តី)ហ្នឹងដែរ។ **សំរាប់អ្នកឈ្នះ (ពួកប្រឆាំង)ថា(មានការ)ឃុបឃិតជាមួយតុលាការ មានលុយបង់។ រីឯអ្នកចាញ់ក៏ត្រូវបានអូសទាញដើម្បីប្រឆាំង។ ដូច្នឹង ខ្ញុំស្នើរូបមន្តដោះស្រាយតាមរបៀបឈ្នះៗ ដែលជាវិធីល្អ។ បើទំនាស់មិនទាន់មកដល់តុលាការ សូមអាជ្ញាធរដែនដីចេញមុខអន្តរាគមន៍ ដោះស្រាយ កុំឲ្យរឿងហ្នឹងមកដល់តុលាការ។ ប៉ុន្តែ បើផុតរបូតពីរដ្ឋបាលមកដល់តុលាការហើយ ក៏ចៅក្រមយើងនៅមានតួនាទីធ្វើការសម្របសម្រួលដែរ** ...៕

១៥. ដំណើរការកាត់ក្តីធ្លាប់យឺតយ៉ាវ ដោយសារខ្វះសាលសវនាការ ចៅក្រម មេធាវី

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារសាលាយុត្តិធម៌, ២៦ មិថុនា ២០២៣

... គួររំលឹកអតីតកាលបន្តិច។ **ច្រើនលើកហើយដែលសំណុំរឿងជាច្រើនត្រូវកកស្ទះ។ ស្ថានភាពនេះតំរូវឲ្យរាជរដ្ឋាភិបាលជួយ។ មិនមែនជួយជាការកាត់ក្តីទេ ប៉ុន្តែជួយពន្លឿន(បន្ថយ)ការកកស្ទះសំណុំរឿង។ ពេលនោះ តុលាការបានប្រាប់ថា សាលសវនាការមានតែមួយ ឬមានតិច។ ខ្ញុំថាបើដូច្នោះ ជួលបន្ទប់សណ្ឋាគារធ្វើសវនាការជំរះសំណុំរឿង**។ នេះជំនាន់ អង្គ វង្សវឌ្ឍនា (ជារដ្ឋមន្ត្រីយុត្តិធម៌)។ មានរឿងខ្លះ ខ្ញុំទទួលបានដូចជានៅខេត្តស្ទឹងត្រែង។ បើយោងតាមច្បាប់ ត្រូវជាប់គុកត្រឹមតែប៉ុន្មានដូចថា ២ឆ្នាំប៉ុណ្ណឹងទេ។ ប៉ុន្តែ មនុស្សនៅក្នុងឃុំដល់ទៅ ៤ឆ្នាំមិនទាន់កាត់ក្តី។ **មានរឿងច្រើន។ ម្ខាងខ្វះសវនាការ តែរឿងខ្វះមេធាវីក៏ម្ខាងទៀតដែរ។ ឥលូវស្ថានភាពប្រសើរជាងមុន** ដោយហោចណាស់យើងបានដោះស្រាយទីកន្លែងសវនាការដែលអស់លោកមិនស្រែករកអន្តរាគមន៍បន្ថែមទៀតទេ ...៕

១៦. អរគុណមិត្តភ័ក្រ ពិសេសជប៉ុនដែលរួមចំណែកក្នុងការកែទំរង់ប្រព័ន្ធតុលាការ

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជានិងប្រគល់សញ្ញាបត្រ ដល់សិស្សវិជ្ជាជីវៈតុលាការ, ៦ មិថុនា ២០២៣

... ឥឡូវក្រសួងនីមួយៗប្រឹងប្រែងបណ្តុះបណ្តាលធនធានមនុស្សបម្រើឱ្យវិស័យរបស់ខ្លួន។ ដូចជាក្រសួងសាធារណការ មានបណ្តុះបណ្តាលខាងផ្នែកសាធារណការរបស់គេ។ (ក្រសួង)ប្រៃសណីយ៍(និងទូរគមនាគមន៍) ក៏មានសាលាសិក្សាពីប្រៃសណីយ៍(និងទូរគមនាគមន៍)ខាងផ្នែកឌីជីថល។ ផ្នែកការទូត មានវិទ្យាស្ថានការទូតរបស់គេ។ ខាងកសិកម្មមានសាលាកសិកម្ម ៣កន្លែងឯណោះ។ ឥឡូវខាងផ្នែកហិរញ្ញវត្ថុ ខាងផ្នែកយុត្តិធម៌ សុទ្ធតែមានសាលាបណ្តុះបណ្តាល។ បើយើងមិនបណ្តុះបណ្តាលធនធានមនុស្ស តើយើងអាចធ្វើអ្វីកើត។ អរគុណមិត្តភក្តិបរទេស ពិសេស**ប្រទេសជប៉ុនបានរួមចំណែកក្នុងការកែទម្រង់ប្រព័ន្ធតុលាការនៅកម្ពុជា។ ខ្ញុំសូមអរគុណមិត្តភក្តិបរទេសដែលបានជួយរួមចំណែកនៅក្នុងការកែទម្រង់(ប្រព័ន្ធ)តុលាការនៅកម្ពុជា** ...។

១៧. ជប៉ុនជួយពង្រឹងនីតិរដ្ឋ ការអនុវត្តច្បាប់នៅកម្ពុជា

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា និងប្រគល់សញ្ញាបត្រ ដល់សិស្សវិជ្ជាជីវៈតុលាការ, ៦ មិថុនា ២០២៣

... សូមអរគុណ អគ្គរដ្ឋទូតជប៉ុន ឯកឧត្តម Ueno Atsushi ... ដែល**ជប៉ុនបានជួយកសាងក្រមរដ្ឋប្បវេណីឲ្យកម្ពុជា ហើយឥឡូវក៏តាមមកជួយបណ្តុះបណ្តាលសិស្សផ្នែករដ្ឋប្បវេណី។ ការជួយទាំងអស់នេះ បានចូលរួមចំណែកនៅក្នុងការពង្រឹងនីតិរដ្ឋ ពង្រឹងការអនុវត្តច្បាប់នៅកម្ពុជា**។ នោះហើយ គឺជាការឆ្លើយតបទៅនឹងការរីកចម្រើនរបស់សង្គម។ ពីមុនយើងមានប្រជាជនត្រឹមប្រមាណ ៥លាននាក់។ ពេលនេះ (ដែលយើងនិយាយ)តាំងពីឆ្នាំ២០១៨ ធ្លាក់ដល់ឆ្នាំ២០២៣ នៅតែថា ១៦លាននាក់ ... ប៉ុន្តែ ដែលអត្រាកើតមួយឆ្នាំមានជាង ៣០ម៉ឺននាក់ ម៉េចក៏មិនបូកចូលផង។ មើល Worldometer (ដែលនិយាយពីចំនួនប្រជាសាស្ត្រ)ទាក់ទងនឹងកូវីដ-១៩ (ហាក់ដូចជា)គិតត្រូវដាង។ យើងគិតអត់ព្រមឡើង(តួលេខ)សោះ។ កាលពីឆ្នាំ២០១៨ នៅ ១៦លាននាក់។ ឥឡូវក៏នៅតែ ១៦លាននាក់

ដដែល ... ឥឡូវប៉ុន្មានហើយ? ១៧លាននាក់។ បើ១៧ លាននាក់ត្រូវគ្នា ... ជាចំណោលដែល យើងកាត់កងគ្នា រវាងអ្នកកើតនិងអ្នកដែលស្លាប់។ អ្នកស្លាប់តិចជាងទេ ...។

១៨. កំណើនសាលាឧទ្ធរណ៍តាមភូមិភាគ ធ្វើអោយមានតម្រូវការធនធានមនុស្ស

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា និងប្រគល់សញ្ញាបត្រ ដល់សិស្សវិជ្ជាជីវៈតុលាការ, ៦ មិថុនា ២០២៣

... ជាការល្អហើយដែលក្នុងរយៈពេលកន្លងទៅនេះ យើងបានផ្តួចផ្តើមរួមគ្នាបង្កើតឱ្យមានសាលាឧទ្ធរណ៍តាមភូមិភាគ។ បើសិនជាមិនបង្កើតឱ្យមានសាលាឧទ្ធរណ៍នៅតាមភូមិភាគទេ ប្រហែលសំណុំរឿងកកស្ទះនៅសាលាឧទ្ធរណ៍ភ្នំពេញច្រើន។ យើងសុខចិត្ត**បង្កើតឱ្យមានសាលាឧទ្ធរណ៍តាមភូមិភាគ ដើម្បីងាយស្រួលផ្តល់សេវាយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋ ... ការកើនឡើងសាលាឧទ្ធរណ៍តាមភូមិភាគ (ធ្វើអោយមាន)តម្រូវការធនធានមនុស្សកាន់តែច្រើន**។ ខ្ញុំយល់ថា មានការចាំបាច់ដើម្បីផ្តល់ក្របខ័ណ្ឌបន្ថែមជូនដល់ផ្នែកតុលាការ សំរាប់ដំណើរការសាលាក្តី ទាំងសាលាដំបូង ទាំងសាលាឧទ្ធរណ៍តាមភូមិភាគ និងរាប់ទាំងតុលាការកំពូល។ ឥឡូវ ចៅក្រមរបស់យើងចាស់ៗ ណាស់ទៅហើយ ... ចៅក្រមសាលាកំពូលខ្លះចូលដល់ ៨០ឆ្នាំហើយ ដូចបង ឃឹម ប៉ុណ្ណ ជាដើមដែលពីដើមជាប្រធានស្នងការនគរបាលរាជធានីភ្នំពេញ។ ពេលនោះ មួយអាទិត្យគាត់ត្រូវចូលជួបខ្ញុំម្តងស្តីពីកិច្ចការសន្តិសុខនៅទីក្រុងភ្នំពេញ។ ឥឡូវគាត់នៅជាអនុប្រធានតុលាការកំពូល ...។

១៩. ដំណើរការប្រជាធិបតេយ្យនិងនីតិរដ្ឋទៅជាមួយគ្នា

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា និងប្រគល់សញ្ញាបត្រ ដល់សិស្សវិជ្ជាជីវៈតុលាការ, ៦ មិថុនា ២០២៣

... សុទ្ធរកថាខ្ញុំរាល់ថ្ងៃពេកហើយ។ ប៉ុន្តែ អ្វីដែលគួរឲ្យកត់សម្គាល់គឺពីមួយថ្ងៃទៅមួយថ្ងៃ យើងឈានឡើងតាមដំណាក់ៗ។**យើងកំពុងដំណើរការប្រជាធិបតេយ្យនិងនីតិរដ្ឋ។ ត្រូវចាំឲ្យច្បាស់ពាក្យហ្នឹង។ ប្រជាធិបតេយ្យដែលគ្មានការគោរពច្បាប់គឺអនាធិបតេយ្យ។ បើគិតតែពីអនុវត្តច្បាប់ដោយមិនបើកសើរភាព គឺផ្តាច់ការ។ វា**

ត្រូវអមដំណើរជាមួយគ្នារវាងប្រជាធិបតេយ្យនិងនីតិរដ្ឋ។ នៅលើពិភពលោកក៏គេកំពុងតែធ្វើរឿងហ្នឹងដែរ។ ត្រូវឲ្យមានការគោរពច្បាប់។ ពិភពលោកគោរពច្បាប់ផ្អែកលើច្បាប់។ បើមិនផ្អែកលើច្បាប់ ផ្អែកលើកំលាំង នឹងវាយគ្នាពេញពិភពលោកហ្នឹងហើយ។ នៅក្នុងប្រទេសនីមួយៗ បើមិនមានច្បាប់គ្រប់គ្រងទេ វានឹងកើតមានអ្នកខ្លាំងទៅបំពានអ្នកខ្សោយ។ អញ្ចឹង ត្រូវដំណើរទៅជាមួយគ្នា ចូលរួមជាមួយគ្នា រក្សាសន្តិភាពឲ្យខានតែបាន ...៕

២០. ក្តាប់បានអង្គហេតុពីកូនក្តី ទើបមេធាវីអាចកំណត់បានពីអង្គច្បាប់

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... ខ្ញុំសូមផ្តាំផ្ញើមួយទៀត ចំពោះមេធាវីរបស់យើង។ ឮថាមានការលើកឡើងអំពីអង្គហេតុនិងអង្គច្បាប់។ **ដើម្បីការពារក្តី ឬការធ្វើអ្វីក៏ដោយ មុនការកាត់សេចក្តី ចៅក្រមត្រូវក្តាប់អង្គហេតុឲ្យជាប់។ បន្ទាប់ទៅទើបបានគេពិនិត្យទៅលើអង្គច្បាប់ តើត្រូវចោទប្រកាន់តាមច្បាប់មួយណា។ យើងជាមេធាវីក៏ត្រូវធ្វើដូចគ្នាដែរ។ ក្តាប់ឲ្យជាប់អង្គហេតុពីកូនក្តីរបស់យើង ទើបយើងពិនិត្យដល់អង្គច្បាប់។ អញ្ចឹងបានជាយើងត្រូវចេះច្បាប់**។ ហេតុអ្វីបានជាខ្ញុំត្រូវនិយាយរឿងនេះ ... ទៅបើកការដ្ឋាន(សាងសង់ស្ពានភ្ជាប់កោះពេជ្រ)ទៅកោះនរា ខ្ញុំបានចាក់សំឡេងហូ វ៉ាន់ ដែលបញ្ជាពីសហរដ្ឋអាមេរិកមកក្រុមបាតុកម្មនៅទីនេះ ... មានការចោទឡើងថា តើការលួចថតសំឡេងនេះវាខុសនឹងរដ្ឋធម្មនុញ្ញឬអត់? បើសិនជាអ្នកនយោបាយឆ្លើយថាខុស ក៏វាមិនអីដែរ ក៏ប៉ុន្តែក្នុងនោះ មេធាវីម្នាក់បាននិយាយថា "ខុសនឹងរដ្ឋធម្មនុញ្ញ" ក្នុងពេលដែលមេធាវីរូបនេះមិនទាន់ដឹងថា តើសំឡេងហូ វ៉ាន់ នេះ ... បានមកពីការលួចថត ឬបានមកពីនរណា? នេះជាអំពើឆោតល្ងង់នៃមេធាវីម្នាក់ ... ប្រសិនបើមិនច្បាស់ទេ គប្បីប្រើភាសាថា «ប្រសិនបើលួចថតមែន គឺគាត់ធ្វើខុសទៅនឹងរដ្ឋធម្មនុញ្ញ ...»។ គាត់ត្រូវមានការគិតទុក ...៕

២១. សូមចៅក្រមផ្សះផ្សារបញ្ចប់វិវាទរវាងគូភាគី ក្បិតក្តីរដ្ឋប្បវេណីគ្មានអ្នកចំណេញទេ

សម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ អគារសាលាយុត្តិធម៌, ២៦ មិថុនា ២០២៣

... រឿងប្តីប្រពន្ធ។ កុំលើកទឹកចិត្តឲ្យលែងលះពេក។ ហៅមកសម្របសម្រួលគ្នាសិនទៅ។ បន្តិចទៅត្រូវគ្នាវិញហើយ។ ជួនកាលអញ្ចឹង។ ឡើងទៅដល់តុលាការហើយ។ តុលាការចង់ចេញសាលក្រមលុបអេតាស៊ីវិល។ ប៉ុន្តែ អ្នកដែលគេពូកែសម្របសម្រួលចុះឡើង មានផ្ទៃពោះមួយទៀតបាត់ ... មើលស្លោកអមតាមជណ្តើរឡើង។ អ្នកឈ្នះក្តីនៅសល់តែខោមួយចង្កេះទេ។ អ្នកចាញ់ក្តីបោសគូទខោតែម្តង។ ជីដូនខ្ញុំធ្លាប់ជាស្មាក្តី ... ការពារក្តីដោយមិនយកប្រាក់ទេ។ គាត់ចង្អុលបង្ហាញពីគូភាគីដំលោះព្រំដីជាបងប្អូនបង្កើត។ ក្រទាំងសងខាង ព្រោះក្តីខ្លះមានអាយុកាលដល់ទៅ ៧ឬ ៨ឆ្នាំ។ មកកំពង់ចាមម្តងត្រូវអស់លុយប៉ុន្មាន។ **អ្នកខ្លះឡើងមកដល់សាលាជំរះក្តី មកដល់សាលាវិនិច្ឆ័យទៀត។ គ្មានអ្នកណាមានផលចំណេញទេ។ សូមលើកទឹកចិត្តចៅក្រមផ្សះផ្សារបញ្ចប់វិវាទរវាងគូភាគី** ...៕

២២. ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ ដោយយោគយល់ក្នុងស្ថានភាពឈ្នះឈ្នះ

សម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ អគារបណ្ណិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា និងប្រគល់សញ្ញាបត្រ ដល់សិស្សវិជ្ជាជីវៈតុលាការ, ៦ មិថុនា ២០២៣

... វិលមកបញ្ហាយុត្តិធម៌ ... ការអនុវត្តច្បាប់គឺអនុវត្តហើយ ប៉ុន្តែសុំកុំភ្លេចពី**ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ ... ព្រោះជាផ្នែកមួយនៃការដោះស្រាយដោយការយោគយល់គ្នា ហើយស្ថិតក្នុងស្ថានភាពឈ្នះឈ្នះ។ បើចូលតាមផ្លូវតុលាការ ការកាត់ក្តីមិនដែលកាត់ឲ្យស្មើទេ។ តែងតែមានអ្នកឈ្នះនិងអ្នកចាញ់**។ យើងបន្ទោសតុលាការអត់បានទេ។ អ្នកឈ្នះថាតុលាការយុត្តិធម៌ អ្នកចាញ់ថាតុលាការអយុត្តិធម៌ ... បើសិនជាឈ្នះនៅសាលាដំបូង ដល់ទៅសាលាឧទ្ធរណ៍អាចមានការកាត់ឲ្យអ្នកដែលឈ្នះនៅសាលាដំបូងទៅជាចាញ់វិញ។ អញ្ចឹង អ្នកហ្នឹងក៏ស្រែកថាអយុត្តិធម៌។ ដល់ទៅតុលាការកំពូល អ្នកហ្នឹងបែរជាឈ្នះ អញ្ចឹងគាត់ថា សាលាដំបូងនិងសាលាកំពូលគឺយុត្តិធម៌ តែអយុត្តិធម៌នៅឧទ្ធរណ៍។ ដូចនេះ វិធីល្អដោះស្រាយបញ្ហា គឺប្រើប្រាស់រូបមន្ត/វិធីសាស្ត្រធ្វើការសម្របសម្រួលការវិវាទ ដែលភាគច្រើនកើតឡើងពីជម្លោះដីធ្លី ... និងជួនកាល រឿងដែលឈឺក្បាល គឺក្រុមគ្រួសារខ្លួនឯងទាស់គ្នា ...៕

២៣. អ្នកឈ្នះថាតុលាការយុត្តិធម៌ អ្នកចាញ់ថាអយុត្តិធម៌

បើកការដ្ឋានស្តារ និងលើកកម្ពស់កម្រិតគុណភាពផ្លូវជាតិលេខ ៣១ និងផ្លូវជាតិលេខ ៣៣ ប្រវែងសរុប ១០៦ គីឡូម៉ែត្រ, ៣០ ធ្នូ ២០២២

... ប្រជាពលរដ្ឋខេត្តកំពតបានស្ងប់ចិត្តច្រើនហើយ។ អភិបាលខេត្តត្រូវខិតខំធ្វើឱ្យខេត្តកំពតក្លាយជាខេត្តដែលសុវត្ថិភាពបំផុត គ្មានជម្លោះដីធ្លី ចៅហ្វាយខេត្តឈរដោះស្រាយជម្លោះដីធ្លីក្រៅប្រព័ន្ធតុលាការ។ កូនឯងបន្តធ្វើទៅ។ បើសិនជាអភិបាលខេត្តគ្រប់ខេត្តធ្វើបានដូច ម៉ៅ ធនិន បានធ្វើនៅខេត្តពោធិ៍សាត់ ហើយបន្តមកធ្វើនៅខេត្តកំពត ខ្ញុំគិតថាជម្លោះដីធ្លីនេះវានឹងស្ងប់ ... កន្លែងខ្លះ(ជម្លោះ)រវាងម៉ែនិងកូន កន្លែងខ្លះ(ជម្លោះ)បងប្អូនឯង ទាស់គ្នាហើយឡើងតុលាការ។ **តែឡើងតុលាការហើយ តុលាការត្រូវតែកាត់សេចក្តី។ មិនអាចកាត់ឱ្យស្មើទេ។ គឺដឹងតែម្នាក់ចាញ់ម្នាក់ឈ្នះ។ អ្នកឈ្នះថាតុលាការយុត្តិធម៌ អ្នកចាញ់ថាអយុត្តិធម៌។ អញ្ចឹងបានជាខ្ញុំស្នើលើទឹកចិត្តឱ្យដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ** ...៕

២៤. កំណែទំរង់ប្រព័ន្ធយុត្តិធម៌និងតុលាការ ដាក់ចេញដោយរដ្ឋាភិបាលអាណត្តិទី៣

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា និងប្រគល់សញ្ញាបត្រដល់សិស្សវិជ្ជាជីវៈតុលាការ, ៦ មិថុនា ២០២៣

...ពេលខ្លះ សំណុំរឿងវាកកស្ទះច្រើនរកកន្លែងសវនាការវាមិនបាន។ ពេលណាមួយនោះ ខ្ញុំស្រែកថាឱ្យជួលសណ្ឋាគារខ្លះទៅដើម្បីកាត់ក្តី។ ប៉ុន្តែ (បើទោះជា)មានសាលកាត់ក្តី តែបើអត់មានចៅក្រម អត់មានធនធានមនុស្សគ្រប់គ្រាន់ តើធ្វើអីកើត? ដូច្នឹង **មានការចាំបាច់នឹងធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌និងតុលាការនេះ ដែលយើងបានដាក់ចេញក្នុងអាណត្តិទី៣។ កាលនោះ យើងបានដាក់ចេញនូវកំណែទម្រង់ជាច្រើនវិស័យរួមមាន កំណែទម្រង់យុត្តិធម៌និងតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ និងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ និយាយតាមមួយបែបតាំងពីដើមមកថា "បើ(ធ្វើ)កំណែទម្រង់ នោះ៩៩%យើងនឹងរស់។ បើមិនកែទម្រង់ទេ ៩៩%យើងនឹងងាប់"**។ ដូចនេះ អ្វីៗកុំនៅទ្រឹងមួយកន្លែង ត្រូវដើរឱ្យទាន់សភាពការណ៍។ យើងត្រូវធ្វើការកែទម្រង់កិច្ចការតុលាការជាបន្តទៀត ...៕

២៥. ផ្តល់ការការពារក្តីចំពោះតែអ្នកសារព័ត៌មានគោរពតាមក្រមសីលធម៌វិជ្ជាជីវៈ

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... កាលពីដើមឆ្នាំ នៅពេលដែលជួបអ្នកសារព័ត៌មាន រដ្ឋមន្ត្រី(ព័ត៌មាន)ខៀវ កាញារីទ្ធ បានសំណូមពរឱ្យមេធាវីតែជោសែន ជួយការពារ(ក្តី) អ្នកសារព័ត៌មាន។ ខ្ញុំក៏ព្រមទទួល ក៏ប៉ុន្តែ **ទទួលឱ្យការពារតែអ្នកសារព័ត៌មានដែលបានបំពេញការងារដោយគោរពតាមក្រមសីលធម៌វិជ្ជាជីវៈ ហើយដែលត្រូវបានគេប្តឹងតែប៉ុណ្ណោះ** ... បើអ្នកខ្លះ ភ្លាមឡើងក៏តាំងជេរគេ។ ហើយបើជេរគេ មិនឱ្យគេប្តឹងឬ? ថ្ងៃមុន(មានអ្នកសារព័ត៌មានម្នាក់)ជាប់ ២បណ្តឹងឯណោះ។ **ដើម្បីរួចពីបណ្តឹងអ្នកកាសែតនេះបានសុំចូលគណបក្សប្រជាជន។ ខ្ញុំបានតបត្រឡប់ទៅវិញថា "មិនមានការដោះដូរគ្នាថា ពេលទទួលការប្តឹងហើយ មកសុំចូលគណបក្សប្រជាជន (ដើម្បីនឹង)បានរួចពីបណ្តឹងទេ"**។ រឿងសុំចូលគណបក្សប្រជាជនជារឿងដោយឡែក ឯរឿងជាប់ក្តីក្តាំ ជារឿងដោយឡែកពីគ្នា ... មន្ត្រីគណបក្សប្រជាជនមិនតិចទេ ដែលបានជាប់គុក។ តែធ្វើខុសច្បាប់ ជាប់គុកហើយ ...៕

២៦. ស្វែងរកសង្គតិភាពរវាងច្បាប់ស្តីពីលក្ខខន្តិកៈមេធាវី និងក្រមនីតិវិធីព្រហ្មទណ្ឌ

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្ត សម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... ដើម្បីដោះស្រាយបញ្ហាថ្ងៃមុខ ក្រសួងយុត្តិធម៌ត្រូវពិនិត្យឡើងវិញអំពីការធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខខន្តិកៈមេធាវី ព្រមទាំងក្រមនីតិវិធីព្រហ្មទណ្ឌ សំរាប់ដោះស្រាយបញ្ហាប្រឈមបច្ចុប្បន្ន ពិសេស**ជានាអោយការអនុវត្តមានភាពងាយស្រួលជាងមុន ទាំងក្នុងការចាត់តាំងមេធាវី ក៏ដូចជាការជានាឱ្យនីតិវិធីតុលាការមានដំណើរការដោយគ្មានឧបសគ្គទាក់ទងនឹងកង្វះមេធាវី។ ត្រូវធ្វើឱ្យច្បាប់ទាំងពីរម្ខាងគឺច្បាប់ស្តីពីលក្ខខន្តិកៈមេធាវី និងម្ខាងទៀតក្រមនីតិវិធីព្រហ្មទណ្ឌ មានសង្គតិភាពជាមួយគ្នា** ... ចូលអាណត្តិថ្មី គឺដល់(លើ ច័ន្ទ)តុលា ត្រូវចាប់ផ្តើមរៀបចំ(វិធាន)ហ្នឹង។ ពីមុននេះ គណៈមេធាវីជាអ្នកចង្អុលមេធាវី។ ឥឡូវ តើយើងគួរយកចេញពីដៃ(គណៈ)មេធាវី មកដាក់ឱ្យប្រធានតុលាការចង្អុលមេធាវីឬទេ?

នេះគ្រាន់តែជាការផ្តល់មតិទេ ... តើគួរឱ្យសិទ្ធិទៅប្រធានតុលាការ ឬឱ្យសិទ្ធិទៅគណៈមេធាវី? រឿងហ្នឹងទុក(ពិភាក្សា)គ្នាទៅ។ ទៅតាមផ្លូវណា។ ឱ្យតែស្រុះស្រួលគ្នា គឺខ្ញុំគាំទ្រទៅលើបញ្ហាហ្នឹង ...។

២៧. ផ្នែកយុត្តិធម៌ មេធាវីមិនរកកំរៃ អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធគប្បីជួយសំរុះសំរួលក្រៅប្រព័ន្ធ

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារបណ្ណិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជានិងប្រគល់សញ្ញាបត្រ ដល់សិស្សវិជ្ជាជីវៈតុលាការ, ០៦ មិថុនា ២០២៣

... ពេលខ្លះបង្ហោះហ្វេសប៊ុក ... មានរឿងច្រើន។ ដល់មើលទៅ រឿងជម្លោះកូនទៅប្តឹងទារយកដីពីម្តាយ ឬម្តាយឪពុកទៅប្តឹងយកដីពីកូន។ សូម្បីតែនៅក្នុងក្រុមគ្រួសារក៏មិនត្រូវគ្នាផង ហើយមកអំពាវនាវឱ្យនាយករដ្ឋមន្ត្រីកាត់ក្តីឱ្យ។ (គាត់រៀបរាប់)ថាគាត់បានចាញ់ក្តីនៅឯនេះឯនោះ ជាការអយុត្តិធម៌ណាស់ សុំឱ្យសើរើក្តី ... ពេលខ្លះ ខ្ញុំក៏រុញទៅឱ្យខេត្ត ឱ្យមើលរឿងហ្នឹងយ៉ាងម៉េច។ មិនមែនបានសេចក្តីថា មិនចង់បង្ហោះហ្វេសប៊ុកទេ ... តែ កាលណាខ្ញុំបង្ហោះចេញសារព័ត៌មាននានាចាប់យកទៅផ្សាយ។ សូមរំលឹកឡើងវិញថា **លើកទឹកចិត្តឱ្យមានការសម្រុះសម្រួលគ្នាក្រៅប្រព័ន្ធតុលាការ ដោយមានការចូលរួមពីផ្នែកយុត្តិធម៌ ពីមេធាវីមិនរកប្រាក់កំរៃ ពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងស្ថាប័នដែលមានការពាក់ព័ន្ធ ... ហ្នឹងគឺជាវិធីសាស្ត្រដោះស្រាយបញ្ហាក្នុងសង្គម ជៀសវាងបានការប្រឈមនានាដែលនឹងកើតមាន**...។

២៨. បើចង់ដំណើរសវនាការក្តីបានឆាប់ មេធាវីមិនត្រូវធ្វើពហិកា

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្ត សម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... សូមបញ្ជាក់ជូនបន្ថែម(ត្រង់នេះ) ព្រោះ(ថា)**បើគ្មានមេធាវី នោះដំណើរការក្តីទៅមិនបាន។ កន្លងទៅ ការដំណើរការក្តីខ្លះមានការឆោតល្ងង់របស់មេធាវី។ ខ្លួនចង់បានដំណើរការក្តីឱ្យបានឆាប់ ប៉ុន្តែខ្លួនបែរជាធ្វើពហិកា(សវនាការ)ដោយមេធាវីដើរចេញ។ ដូច្នេះ នេះជាកំហុសយុទ្ធសាស្ត្រផ្លូវច្បាប់តែម្តង**។ ខ្ញុំនិយាយបែបនេះ ប្រហែលជាអ្នកដែលមានការពាក់ព័ន្ធក្នុងចំណោមរឿងក្តីនេះ និងដែលធ្លាប់បានពហិកា អាចនឹងដឹងខ្លួនថាបានធ្វើកំហុសផ្លូវច្បាប់(នោះហើយ)។ ជា(កំហុស)យុទ្ធសាស្ត្រផ្លូវច្បាប់តែម្តង។ ខ្ញុំមិនមែនជាអ្នកច្បាប់ទេ តែខ្ញុំជាមេធាវីម្នាក់ ហើយក៏ធ្លាប់ដឹកនាំកសាងច្បាប់រាប់សិបឆ្នាំហើយ។ **(ខណៈ)កំពុងជម្រុញ(ឱ្យដំណើរការ)រឿង(ក្តី)នេះឱ្យបានឆាប់ ប៉ុន្តែ បន្តិចៗ ខ្លួនឯងបែរជាធ្វើពហិកាហើយដើរចេញ។ ដល់ទៅធ្វើពហិកា តុលាការគេធុញ គេបិទសវនាការ។ អញ្ចឹងរង់ចាំតទៅទៀតទៅ**...។

២៩. នៅពេលខ្វះមេធាវីកាតព្វកិច្ច តើមេធាវីស្ម័គ្រចិត្តតេជោសែន អាចដើរតួជំនួសឬទេ?

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្ត សម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... ក្រសួងយុត្តិធម៌មាន(មេធាវីកាតព្វកិច្ច) ៦៨រូបហើយ។ សម្តេចក្រឡាហោមស ខេង បានស្នើសុំចាត់តាំងមេធាវី ប៉ុន្តែ(ការស្នើសុំ)នោះ(ជា)មេធាវីការពារខាងរដ្ឋវិញទេ។ **មេធាវីដែលត្រូវធ្វើជាមេធាវីកាតព្វកិច្ច ឥឡូវទើបនឹងមាន ៦៨នាក់ បូកមេធាវីរបស់តេជោសែន ១៥៣នាក់ ដែលដូចជាផ្នែកមួយនៃមេធាវីកាតព្វកិច្ចដែរ។ ខ្ញុំសុំឱ្យឯកឧត្តម គី គិច ធ្វើការជាមួយមេធាវី ... នៅពេលដែលមានការខ្វះ(មេធាវី) តើយើងអាចដើរតួជាមេធាវីកាតព្វកិច្ច(ឬទេ)។** បញ្ហាស្ថិតនៅត្រង់រឿងនេះទៀត គឺបើជាឃាតករ ហើយយកមេធាវីតេជោសែនទៅការពារគឺវាចប់(សេចក្តីហើយ)។ ពាក់ព័ន្ធនឹងគ្រឿងញៀន បើយកមេធាវីតេជោសែនទៅការពារទៀត គឺជារឿងមួយពិបាក។ ចំណុចនេះ ត្រូវថ្លឹងថ្លែងឱ្យបានច្បាស់។ អ្វីដែលជាក់លាក់គឺមេធាវីកាតព្វកិច្ច ៦៨រូបត្រូវបានតែងតាំងរួចហើយ។ ពួកគាត់មិនយកប្រាក់បៀវត្សទេ។ ឥឡូវបានបែងចែកទៅតាមសាលាដំបូងរាជធានី/ខេត្តនៅទូទាំងប្រទេសហើយ...។

៣០. ពិនិត្យមើលការប្រឈមក្នុងក្របខណ្ឌច្បាប់ស្តីពីលក្ខខន្តិកៈមេធាវី

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្ត សម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... ដែលកំណត់ថា ប្រធានគណៈមេធាវីអាចចាត់តាំងមេធាវីការពារក្តីដោយឥតគិតថ្លៃសម្រាប់តែជនក្រីក្រ ជាបញ្ហាប្រឈមក្នុងក្របខណ្ឌច្បាប់ស្តីពីលក្ខខន្តិកៈមេធាវី។ នេះជាចំណុច ដែលសូមឱ្យរដ្ឋមន្ត្រីយុត្តិធម៌ (និងឬ)គណៈមេធាវី(ពិនិត្យ

មើលថាតើ)អាចនឹងត្រូវធ្វើវិសោធនកម្មលើចំណុចនេះ(ទេ)។ បើមនុស្សខ្លះមិនមែនជាជនក្រីក្រ បើគ្មានមេធាវី (រឿងក្តី)នេះទៅ(មុខ)អត់រួច។ (ដូចនេះ)ធ្វើអត់បាន។ កកស្ទះសំណុំរឿង ដោយសារតែច្បាប់របស់យើងតម្រូវឱ្យការពារតែអ្នកក្រីក្រ។ ចុះបើអ្នកមិនមែនក្រីក្រ តែមិនព្រមយកមេធាវី។ បើគេមិនព្រម យកមេធាវី ហើយគេសុខចិត្តធ្វើមេធាវីខ្លួនឯង ហ្នឹងវាអត់បញ្ហា។ ប៉ុន្តែ បើគាត់មិនព្រមយកមេធាវី បានសេចក្តីថា ដំណើរការក្តីនេះទៅ(មុខ)អត់បាន ...។

៣១. បច្ចុប្បន្ន យន្តការមេធាវីស្ម័គ្រចិត្តការពារក្តីនិងផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ដោយឥតគិតថ្លៃ ជាជម្រើសល្អជាងគេ

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្ត សម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... ក្នុងបណ្តាប្រទេសមួយចំនួន មេធាវីការពារជនក្រីក្រ និងមេធាវីកាតព្វកិច្ច ត្រូវបានចាត់តាំងដោយប្រធានតុលាការ ពីក្នុងបញ្ជីមេធាវីប្រចាំឆ្នាំមួយ ដើម្បីការពារក្តីនៅចំពោះមុខតុលាការ ហើយមេធាវីនោះត្រូវទទួលបានកម្រៃសេវាក្នុងអត្រាមួយ ដែលត្រូវបានកំណត់ជាមុនដោយរដ្ឋ។ **សម្រាប់កម្ពុជា រដ្ឋពុំទាន់មានលទ្ធភាពផ្នែកថវិកា ដើម្បីរ៉ាប់រងការអនុវត្តគោលនយោបាយផ្តល់ជំនួយផ្នែកច្បាប់ពេញលេញ រួមទាំងការផ្តល់សេវាប្រឹក្សាយោបល់សម្រាប់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននៅឡើយ។ ដូច្នេះ ចំពោះមុខ យន្តការមេធាវីស្ម័គ្រចិត្តជួយការពារក្តីនិងផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ដោយឥតគិតថ្លៃ ដល់ប្រជាពលរដ្ឋដែលត្រូវការសេវាផ្នែកច្បាប់នេះ គឺជាជម្រើសដែលល្អជាងគេ ដើម្បីដោះស្រាយបញ្ហាប្រឈម ដែលកំពុងកើតមានបច្ចុប្បន្ន** ...។

៣២. ការផ្តល់មេធាវីកាតព្វកិច្ច ក្នុងករណីបទឧក្រិដ្ឋ ឬសំណុំរឿងពាក់ព័ន្ធនឹងអនីតិជន

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្ត សម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... ឯក្របខណ្ឌទី២ **ស្តីពីការផ្តល់មេធាវីកាតព្វកិច្ច ក្នុងករណីបទឧក្រិដ្ឋ ឬសំណុំរឿងពាក់ព័ន្ធនឹងអនីតិជន។ យោងតាមមាត្រា៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវតែជំនួយពីមេធាវីមានជាជាច់ខាត ក្នុងករណីបទឧក្រិដ្ឋដែលជនជាប់**

ចោទជាអនីតិជន។ ទន្ទឹមនេះ មាត្រា៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ក៏បានចែងផងដែរថា អនីតិជនគ្រប់រូប ដែលជាប់សង្ស័យ ឬត្រូវបានចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើស ត្រូវតែទទួលបានសិទ្ធិជាមូលដ្ឋាន គឺការទទួលបានជំនួយពីមេធាវី ដោយការជ្រើសរើស ឬដោយការចាត់តាំង ដោយមិនយកកម្រៃស្របតាមលក្ខខណ្ឌដែលមានចែងដោយច្បាប់ស្តីពីលក្ខន្តិក:មេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី។ **ការចាត់តាំងមេធាវីក្នុងករណីទាំងពីរនេះ គឺជាលក្ខខណ្ឌចាំបាច់តម្រូវដោយច្បាប់ ដែលហៅថាមេធាវីកាតព្វកិច្ច ដើម្បីឱ្យនីតិវិធីតុលាការអាចដំណើរការទៅបាន។ តាមផ្លូវច្បាប់ ជនជាប់ចោទអាចជ្រើសរើសមេធាវីដោយខ្លួនឯងបាន។ ប្រសិនបើជនជាប់ចោទពុំព្រមជ្រើសរើសមេធាវីដោយខ្លួនឯងទេ តុលាការត្រូវតែជានាឱ្យមានមេធាវីជួយការពារក្តីឱ្យជនជាប់ចោទទាំងនេះដោយឥតគិតថ្លៃ បើទោះបីជនជាប់ចោទនោះមិនមែនជាអ្នកក្រីក្រក៏ដោយ**...។

៣៣. សមាគម/អង្គការក្រៅរដ្ឋាភិបាលខ្លះ ផ្តល់មេធាវី/ការពិគ្រោះផ្លូវច្បាប់ដល់ពលរដ្ឋក្រីក្រតាមមូលដ្ឋាន

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្ត សម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... លើការជាក់ស្តែង ការផ្តល់មេធាវីការពារជនក្រីក្រអនុវត្តតែក្នុងពេលដែលសំណុំរឿងមកដល់តុលាការ ហើយតុលាការតម្រូវឱ្យមានមេធាវីការពារក្តីតែប៉ុណ្ណោះ។ ប៉ុន្តែ ការផ្តល់សេវានេះមិនគ្របដណ្តប់ដល់ការផ្តល់ជំនួយផ្នែកប្រឹក្សាយោបល់ផ្លូវច្បាប់នៅថ្នាក់មូលដ្ឋានឡើយ។ កន្លងមក **សមាគមឬអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានធ្វើសកម្មភាពនៅថ្នាក់មូលដ្ឋាន ដោយជួបផ្ទាល់ជាមួយប្រជាពលរដ្ឋដែលត្រូវការសេវាផ្នែកច្បាប់ ទាំងការផ្តល់ជំនួយប្រឹក្សាយោបល់ក៏ដូចជាជួយរៀបចំដាក់ពាក្យបណ្តឹងទៅតុលាការ និងការពារក្តីជូនប្រជាពលរដ្ឋក្រីក្រ**។ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលទាំងនោះ ទទួលបានថវិកាពីបរទេសដើម្បីបើកស្នាក់ការធ្វើប្រតិបត្តិការ ក៏ដូចជាជួលមេធាវីប្រចាំការ ដើម្បីផ្តល់សេវាជំនួយផ្នែកច្បាប់ដល់ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋដែលត្រូវការសេវាផ្នែកច្បាប់។ នេះ ជាផ្នែកមួយនៃការជួយឧបត្ថម្ភ ដែលសូមថ្លែងការអរគុណ

និងកោតសរសើរចំពោះ**អង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដែលបានធ្វើសកម្មភាពក្នុងការផ្តល់នូវមេធាវី ក៏ដូចជាការពិគ្រោះខាងផ្លូវច្បាប់សម្រាប់ប្រជាជននៅតាមមូលដ្ឋាន** ...។

៣៤. អង្គការក្រៅរដ្ឋាភិបាលមួយចំនួននិងមេធាវីខ្លះឆ្លៀតឱកាសរុញឱ្យមានបាតុកម្ម

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្ត សម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... ខ្ញុំក៏សូមបញ្ជូនសញ្ញាប្រាប់ថា **មានអង្គការមួយចំនួននិងមេធាវីខ្លះ ក៏បានឆ្លៀតឱកាសរុញឱ្យមានបាតុកម្មផ្ទុះឡើង។ មិនមែនយើងជា(រាជ)រដ្ឋាភិបាលមិនដឹងរឿងនោះទេ។ យើងលើកទឹកចិត្តឱ្យផ្តល់ជំនួយផ្លូវច្បាប់ ឬការពារក្តីជូនជនក្រីក្រ តែយើងមិនលើកទឹកចិត្ត អោយអ្នកធ្វើសកម្មភាពញុះញង់រុញឱ្យធ្វើបាតុកម្មទេ។ ទន្ទឹមនឹងថ្លែងអំណរគុណ ខ្ញុំក៏សូមបង្ហាញពីការខកចិត្តខ្លះផង។ ខ្ញុំលើកទឹកចិត្តឱ្យអង្គការក្រៅរដ្ឋាភិបាល ដែលបានទទួលជំនួយពីបរទេសជួយសង្គ្រោះផ្លូវច្បាប់ និងការពារ(ក្តី)ចំពោះជនក្រីក្រ តែខ្ញុំមិនលើកទឹកចិត្តឱ្យឆ្លៀតធ្វើសកម្មភាពញុះញង់បង្កើតឱ្យមានបាតុកម្មទេ**។ (មាន)រឿងខ្លះ ក្រុមមេធាវីនៃអង្គការក្រៅរដ្ឋាភិបាលមួយចំនួនរុញពីកំពង់សោម/កោះកុង/ក្រចេះមក ... មិនមែនយើងមិនដឹងទេ តែចំណុចអវិជ្ជមានទាំងនេះ យើងមិនដែលបាននិយាយ ... បើយើងតម្រូវឱ្យធ្វើតាមផ្លូវច្បាប់ គឺដំណើរតាមផ្លូវច្បាប់ កុំរុញពលរដ្ឋឱ្យមកធ្វើសកម្មភាពបែបនេះ ...។

៣៥. វិជ្ជាជីវៈមេធាវី នៅក្រៅក្របខណ្ឌនីតិប្រតិបត្តិ នីតិបញ្ញត្តិ តុលាការ តែមានលក្ខខន្តិកៈមេធាវី

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្ត សម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... **វិជ្ជាជីវៈមេធាវី គឺជាវិជ្ជាជីវៈនៅក្រៅក្របខណ្ឌនីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការ ប៉ុន្តែមានលក្ខខន្តិកៈដូចដែលយើងកំពុងមានសព្វថ្ងៃនេះ។ ខ្ញុំមានសិទ្ធិបោះឆ្នោត(ជ្រើសរើសប្រធានគណៈមេធាវី ដែល)កន្លងទៅលោក លី ច័ន្ទតុលា ក៏ទទួលបានឆ្នោតរបស់ខ្ញុំមួយសន្លឹកដែរ។ ខ្ញុំដូចជាបានស្បថ (ចូលជាសមាជិក**

មេធាវី)នៅឆ្នាំ១៩៩៦ ឬ១៩៩៧។ បានសេចក្តីថា ខ្ញុំជាមេធាវីដែលព្យួរ។ ដល់ពេលខ្ញុំចូលនិវត្តន៍ ក្លឹបមេធាវីសម្តេចតេជោនៅបន្ត។ គោលដៅរបស់ខ្ញុំ គឺដូច្នេះ។ ពេលខ្ញុំឈប់ធ្វើជានាយករដ្ឋមន្ត្រី បើអ្នកទាំងអស់ស្ម័គ្រចិត្តនៅជាមួយខ្ញុំបន្តទៀត យើងអាចរកកន្លែងមួយផ្សេងធ្វើជាទីស្នាក់ការ។ វាមិនលំបាកទេ។ ខ្ញុំធ្លាប់បាននិយាយហើយថា ជីដូនរបស់ខ្ញុំជាស្មាក្តី ដែលក្រោយមកគេហៅមេធាវីនេះឯង ...។

៣៦. ថវិការដ្ឋផ្តល់ឱ្យគណៈមេធាវី មានគោលដៅបម្រើជនក្រីក្រពិតប្រាកដ

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្ត សម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... សូមឯកឧត្តម លី ច័ន្ទតុលា **ពិនិត្យមើលផងដែរ អំពីការចំណាយថវិកាដែលរដ្ឋផ្តល់ឱ្យគណៈមេធាវី។ ការចាយវាយត្រូវឱ្យចំទិសដៅ និងបម្រើទៅជនក្រីក្រពិតប្រាកដ។ ប្រសិនបើអាចធ្វើទៅបាន គួរតែធ្វើរបាយការណ៍មួយ។ ក្នុងប៉ុន្មានឆ្នាំដែលចាប់ផ្តើមទទួលថវិកាពីរដ្ឋាភិបាល ការពារក្តីបានប៉ុន្មាន? ផ្តល់ការពិគ្រោះផ្លូវច្បាប់បានប៉ុន្មាន? ក្រសួងយុត្តិធម៌ ត្រូវទទួលខុសត្រូវទៅលើកិច្ចការហ្នឹង ព្រោះក្រសួងយុត្តិធម៌ជាអាណាប៉ក**។ ឆ្នាំនេះ(ថវិកាដែលរដ្ឋបានផ្តល់ឱ្យមានចំនួន) ១៦០០ លាន(រៀល) ហើយឆ្នាំក្រោយនឹងឡើងទៅដល់ ២០០០ លាន(រៀល)។ អាណាប៉កត្រូវតែធ្វើការត្រួតពិនិត្យថវិកានោះផង ... ខ្ញុំមិនគិតថាមានបញ្ហារឿងថវិកាសម្រាប់មេធាវីស្ម័គ្រចិត្តរបស់សម្តេចតេជោទេ ...។

៣៧. រាជរដ្ឋាភិបាលត្រូវតែមានចំណែកគ្រប់គ្រងនិងរៀបចំលើនយោបាយព្រហ្មទណ្ឌ

បើកសន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន លើកទី ១២ "តួនាទីព្រះរាជអាជ្ញាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងតំបន់", ៦ វិច្ឆិកា ២០១៩

... យើងត្រូវការពារអ្នកដែលងាយរងគ្រោះ តាមរយៈតួនាទីរបស់ព្រះរាជអាជ្ញា។ នៅមុនពេលដែលយើងចូលប្រជុំនេះ អំពីការគ្រប់គ្រងនយោបាយព្រហ្មទណ្ឌ ខ្ញុំបានជម្រាបថា**រាជរដ្ឋាភិបាលត្រូវតែមានចំណែកគ្រប់គ្រង និងរៀបចំព្រះរាជអាជ្ញា។ បើមិនដូច្នោះ រាជរដ្ឋាភិបាលនឹងបាត់បង់ការគ្រប់គ្រងនយោបាយព្រហ្មទណ្ឌរបស់ប្រទេស។ ពិតមែនហើយថា ដំណើរការតុលាការត្រូវតែឯករាជ្យ ក៏ប៉ុន្តែបើរាជរដ្ឋាភិបាលមិនអាចគ្រប់គ្រងបាននយោបាយព្រហ្មទណ្ឌទេ នោះគឺជាគ្រោះថ្នាក់**។

ខ. ករណីត្រូវចោទ ... ព្រះរាជអាជ្ញាគឺជាអ្នកចោទ។ ព្រះរាជអាជ្ញាតំណាងឱ្យរដ្ឋត្រូវធ្វើការចោទប្រកាន់។ បើព្រះរាជអាជ្ញាតាំងខ្លួនជាអ្នកឯករាជ្យមិនព្រមធ្វើការចោទ (ប្រកាន់) តើត្រង់ណាជានយោបាយព្រហ្មទណ្ឌរបស់រាជរដ្ឋាភិបាល? មិនអាចទៅរួចទេ។ ក្តីនៅសាលាដំបូង ចៅក្រមកាត់ឱ្យរួចខ្លួន ឬក៏កាត់ស្រាលពេក បែរជាព្រះរាជអាជ្ញាមិនព្រមធ្វើការប្តឹងឧទ្ធរណ៍។ ដូចនេះតើខាងផ្នែករដ្ឋអាចគ្រប់គ្រងបាននយោបាយព្រហ្មទណ្ឌឬទេ? នោះហើយ(ដែលជាកត្តាដែល)ស្ថិតនៅក្នុងកំណែទម្រង់ប្រព័ន្ធតុលាការរបស់យើង ...៕

៣៨. ច្បាប់កំណត់សញ្ជាតិខ្មែរតែមួយសម្រាប់មេដឹកនាំស្តាប័នកំពូលចូលជាធរមាន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីសម្ពោធអគារក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ៨ វិច្ឆិកា ២០២១

... ឯកឧត្តម អ៊ឹម ឈុនលឹម កាលហ្នឹងជារដ្ឋលេខាធិការមហាផ្ទៃ បានយកចេញពីមហាផ្ទៃឲ្យទៅកាន់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម។ តមកឯកឧត្តម ជា សុផារ៉ា ប៉ុន្តែ**តំឡូវតំណែងរបស់ឯកឧត្តម អ៊ឹម ឈុនលឹម និងខ្ញុំ ត្រូវមានសញ្ជាតិតែមួយអត់មានសញ្ជាតិពីរទេ** ... ហ៊ុន សែន កំពុងឈរនៅទីនេះ ដោយមានសញ្ជាតិតែមួយគត់ពីកំណើត មិនដែលប៉ុងប៉ងសូម្បីតែនឹកយល់សប្តិឲ្យបានសញ្ជាតិនេះឬនោះទេ ... ខ្ញុំមិនបានបិទផ្លូវអ្នកដទៃដែលមិនប្រជែងយកតំណែងទាំង៤ គឺ**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នាយករដ្ឋមន្ត្រី ប្រធានសភា ប្រធានព្រឹទ្ធសភា(ទេ) ... អ្នកអាចធ្វើអនុប្រធានសភា អាចធ្វើសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ អាចធ្វើឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីបានតើ អនុប្រធានសភា អនុប្រធានព្រឹទ្ធសភា អាចធ្វើបានតើ** ... ប្រទេសសិង្ហបុរីបានធ្វើហើយ ច្បាប់ប្រឆាំងការជ្រៀតជ្រែក ... ច្បាប់អូស្ត្រាលីក៏មានផ្នែកមួយអំពីនៃការប្រឆាំងការជ្រៀតជ្រែក។ រឿងអីដែលខ្មែរធ្វើមិនបាន។ ដោយសារតែការជ្រៀតជ្រែកហ្នឹងហើយ បានខ្មែរវេទនា ...៕

៣៩. ព្រះរាជអាជ្ញាចេញដីកា ទើបនគរបាលយុត្តិធម៌ឃាត់/ចាប់ខ្លួន លើកលែងតែបទល្មើសជាក់ស្តែង

បើកសន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន លើកទី ១២ "តួនាទីព្រះរាជអាជ្ញាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងតំបន់", ៦ វិច្ឆិកា ២០១៩

... **ដីកាចាប់ខ្លួនឬឃាត់ខ្លួន ត្រូវតែចេញដោយព្រះរាជអាជ្ញា ទើបនគរបាលយុត្តិធម៌អនុវត្ត លើកលែងតែបទល្មើសជាក់ស្តែង ដែលមិនរង់ចាំដីការបស់ព្រះរាជអាជ្ញានោះទេ**។ ជាទូទៅអាចថាក្នុង១០០០រឿង មាន ៩៩៩ករណីហើយដែលត្រូវព្រះរាជអាជ្ញាចេញដីកាដើម្បីឱ្យនគរបាលយុត្តិធម៌ធ្វើការឃាត់/ចាប់ខ្លួន។ អញ្ចឹង ប្រសិនបើព្រះរាជអាជ្ញាមិនព្រមចេញដីកា តើយើងធ្វើយ៉ាងម៉េចទៅក្នុងការគ្រប់គ្រងសន្តិសុខរបស់ប្រទេស? ដោយប្រការនេះ យើងខ្ញុំបានជ្រើសរើសយកប្រព័ន្ធមួយ ដែលផ្តល់ការសហការជាប់លាប់រវាងប្រព័ន្ធតុលាការ ជាមួយនិងអង្គនីតិប្រតិបត្តិ ដើម្បីអង្គនីតិប្រតិបត្តិគឺរាជរដ្ឋាភិបាលគ្រប់គ្រងបាននយោបាយព្រហ្មទណ្ឌ ...៕

៤០. ពេលនាយករដ្ឋមន្ត្រីត្រូវទម្លាក់ចេញពីតំណែង តើអ្នកណាទទួលខុសត្រូវបន្តគ្រប់គ្រងប្រទេស

សម្តេចតេជោ ហ៊ុន សែន ទទួលសញ្ញាបត្របណ្ឌិតកិត្តិយសផ្នែកអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ៥ សីហា ២០២២

... ឯកឧត្តម កើត រិទ្ធ ពន្យល់ច្បាស់និងពន្យល់ល្អបំផុតហើយ ប៉ុន្តែជួនកាលការប្រើសម្តែងឡើងចុះ ក៏អាចជាការទាក់ទាញមួយនៃការយល់ដឹងដែរ ... ពាក្យថា "នៅពេលដែលតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ គណៈរដ្ឋមន្ត្រីមួយត្រូវរៀបចំឡើងវិញ"។ ចំណុចត្រង់នេះ បូកជាមួយរដ្ឋាភិបាលត្រូវបានទម្លាក់ គ្មានការចែងនៅកន្លែងណាមួយទាល់តែសោះ។ នាយករដ្ឋមន្ត្រីស្លាប់ភ្លាម រាជរដ្ឋាភិបាលរលាយតែម្តង។ តើយើងគួរបម្រុងទុកនៅកន្លែងនេះទេ? មានកថាខណ្ឌមួយនិយាយដាច់ដោយឡែក ទាក់ទិននឹង(ប្រការដែល)រដ្ឋាភិបាលត្រូវបានទម្លាក់។ ក្នុង**កថាខណ្ឌនៃមាត្រានោះ មិនបាននិយាយថា(ពេលនាយករដ្ឋមន្ត្រីត្រូវបាន)ទម្លាក់ចេញពីតំណែង តើអ្នកណាទទួលខុសត្រូវ(បន្តគ្រប់គ្រងប្រទេស)? បើដូចនោះ នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទាំងអស់ដែលគណៈរដ្ឋមន្ត្រីត្រូវបានទម្លាក់ នាំគ្នាដើរទៅផ្ទះ**។ អញ្ចឹង អ្នកណាគ្រប់គ្រងប្រទេស? ដោយហេតុនេះហើយ បានជាយើងដាក់ក្នុងរដ្ឋធម្មនុញ្ញថា គណៈរដ្ឋមន្ត្រីដែលត្រូវចេញពីតំណែងនេះ ត្រូវដឹកនាំធ្វើការងារប្រចាំថ្ងៃរហូតដល់គណៈរដ្ឋមន្ត្រីមួយត្រូវបានបង្កើត ...៕

៤១. បើតំណែងនាយករដ្ឋមន្ត្រីទំនេរជាស្ថាពរ អ្នកណាទទួលបន្ទុករៀបចំគណៈរដ្ឋមន្ត្រីមួយឡើងវិញ

សម្តេចតេជោ ហ៊ុន សែន ទទួលសញ្ញាបត្របណ្ឌិតកិត្តិយសផ្នែកអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ៥ សីហា ២០២២

... និយាយពីតំណែងនាយករដ្ឋមន្ត្រីដែលនៅទំនេរជាស្ថាពរ មានស្ថានភាពពីរបែប។ ស្ថានភាពមួយគឺ នាយករដ្ឋមន្ត្រីស្លាប់។ អញ្ចឹង **ការចែង(ថាតំណែង)នាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ ក្នុងរដ្ឋធម្មនុញ្ញគឺគ្រោះថ្នាក់ខ្លាំងណាស់ ... ដោយសារតែវាបង្កើតឡើងនូវស្ថានភាពច្របូកច្របល់ (ពេល) គ្មានរដ្ឋាភិបាល។ គ្រាន់តែនិយាយថាបើតំណែងនាយករដ្ឋមន្ត្រីទំនេរជាស្ថាពរ គណៈរដ្ឋមន្ត្រីមួយនឹងត្រូវរៀបចំឡើងវិញ (សួរថា)អ្នកណាទទួលបន្ទុករៀបចំ?** អញ្ចឹង បានជានៅកន្លែងនេះ ប្រសិនបើនាយករដ្ឋមន្ត្រីស្លាប់ ឧបនាយករដ្ឋមន្ត្រី ដែលបានទទួលបានការតែងតាំងឱ្យធ្វើជានាយករដ្ឋមន្ត្រីស្តីទី ត្រូវទទួលខុសត្រូវដឹកនាំការងារប្រចាំថ្ងៃ មុនពេលដែលរដ្ឋាភិបាលថ្មីចូលកាន់តំណែងជំនួស ... ហ្នឹងចំណុចទំនេរជាស្ថាពរ (នៃតំណែងនាយករដ្ឋមន្ត្រីដោយសារ)ការស្លាប់។ សាកល្បងមើល។ ឧទាហរណ៍ថាខ្ញុំចេញពីនេះទៅស្លាប់ បើមិនរត់ជាន់ជើងគ្នា ... ពេលហ្នឹងអ្នកណាខ្លាំង អ្នកនោះឈ្នះ។ ឥឡូវរដ្ឋធម្មនុញ្ញមានទាន់ចូលជាធរមានពីអង្កាល់? ...។

៤២. ប្រមុខរដ្ឋជាអ្នកតែងតាំងនាយករដ្ឋមន្ត្រី ដូចនេះសំណើលាលែងត្រូវតែថ្វាយទៅព្រះមហាក្សត្រ/ប្រមុខរដ្ឋ ហើយចម្លងជូនទៅសភា

សម្តេចតេជោ ហ៊ុន សែន ទទួលសញ្ញាបត្របណ្ឌិតកិត្តិយសផ្នែកអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ,៥ សីហា ២០២២

... ឯតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរមួយទៀត គឺនាយករដ្ឋមន្ត្រីលាលែងពីតំណែង (ក៏)អត់បានចែងក្នុងរដ្ឋធម្មនុញ្ញទេ។ និយាយរួម តំណែងក្នុងរដ្ឋធម្មនុញ្ញ នាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ ទាំងស្លាប់និងលាលែងអត់ទាន់មានចែងទាល់តែសោះ។ អ្នកខ្លះលើកឡើងថា នាយករដ្ឋមន្ត្រីលាលែងដាក់ទៅប្រធានសភា។ គេចង់ថា(ដាក់ត្រឹម)សភាទេដើម្បីអនុវត្តរបបសភានិយម។ ប៉ុន្តែ អ្នកកុំភ្លេចថា ព្រះមហាក្សត្រជាព្រះប្រមុខរដ្ឋ។ **បើប្រមុខរដ្ឋជាអ្នកតែងតាំង អ្នកត្រូវដាក់សំណើលាលែងទៅអ្នកតែងតាំង គឺព្រះមហាក្សត្រ គឺប្រមុខរដ្ឋ ហើយចម្លងជូនទៅសភា**។ គេថា បើ(ដាក់សំណើ)ត្រង់ទៅស្តេចអញ្ចឹង វានឹងបាត់តួនាទីសភា។ មិនដូចនោះទេ។ សភាអត់មានបាត់តួនាទីអ្វីទាំងអស់។ ពីដើមគ្រាន់តែធ្វើស្រោមសំបុត្រ តែងតាំងនាយករដ្ឋមន្ត្រី ដោយមានការឯកភាពពីប្រធាននិងអនុប្រធានទាំងពីរបស់សភា ...។

៤៣. ការអនុវត្តច្បាប់អស្សាមិករណ៍ តម្រូវដោយផលប្រយោជន៍សាធារណៈ ត្រូវសុំការអនុញ្ញាតអោយបានត្រឹមត្រូវ

សម្ពោធដាក់ឱ្យប្រើប្រាស់នូវផ្លូវជាតិលេខ ៣ ពីរង្វង់មូលចោមចៅ រាជធានីភ្នំពេញ ទៅកាន់ខេត្តកំពត, ២ មីនា ២០២២

... បើយោងទៅលើច្បាប់ទាក់ទងនឹងផ្លូវថ្នល់ ដីនេះគឺជាដីរបស់រដ្ឋទេ ... អ្វីដែលបានកើតឡើងកន្លងទៅ គឺដោយសារតែចិត្តធម៌របស់អាជ្ញាធរដែលឃើញថាប្រជាពលរដ្ឋនៅកន្លែងហ្នឹងហើយ ក៏ចេះតែអោយគាត់នៅទៅ។ ដូចនេះ ដល់ពេលត្រូវធ្វើផ្លូវ យើងត្រូវតែផ្តល់លុយអោយគាត់។ កន្លែងខ្លះ ដូចជាផ្លូវកែងផ្លូវជាតិលេខ៦ តភ្ជាប់ទៅផ្អាវ ស្គន់ តភ្ជាប់ទៅខេត្តសៀមរាប ជាង ៤០០០គ្រួសារបានទទួលយកការដោះស្រាយផលប៉ះពាល់ និងចាកចេញហើយ។ នៅសល់ប៉ុន្មានគ្រួសារមិនព្រម។ បើមិនព្រមទេ ជម្រើសដែលនៅសល់ គឺច្បាប់អស្សាមិករណ៍ ... ស្គានអ្នកលឿងក៏អញ្ចឹងដែរ។ ដោះស្រាយផលប៉ះពាល់អស់ហើយ នៅសល់ ២ គ្រួសារអត់ព្រម។ តើយើងសុខចិត្តបោះបង់ស្គានមួយដែលជប៉ុនជួយ ជាមួយនឹងការដែល ២ គ្រួសារមិនព្រម ឬយ៉ាងម៉េច? **តាមច្បាប់អស្សាមិករណ៍ ពេលណាផលប្រយោជន៍រដ្ឋតម្រូវ គឺត្រូវតែយកហើយ ... ប៉ុន្តែមិនមែនស្តីក៏សុទ្ធតែអស្សាមិករណ៍ទាំងអស់នោះទេ ... ដើម្បីអនុវត្តច្បាប់អស្សាមិករណ៍ត្រូវមកសុំការអនុញ្ញាតអោយបានត្រឹមត្រូវ ព្រោះវាពាក់ព័ន្ធផលប្រយោជន៍របស់ប្រជាជន ផលប្រយោជន៍សាធារណៈនិងប្រទេសជាតិ ...**។

៤៤. មិនមានអ្នកទោសនយោបាយទេ មានតែអ្នកនយោបាយជាប់ទោសព្រហ្មទណ្ឌ

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្ត សម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... ថាលោក ហ៊ុន សែន អប់រំគេឱ្យចេះសំរបសំរួល តែខ្លួនឯងមិនចេះសំរបសំរួល។ ខ្ញុំសំរបសំរួលអស់ប៉ុណ្ណឹងហើយ។ **ខ្ញុំគ្មានពេលសំរបសំរួលជាមួយអ្នកណាទៀតទេ។ ដំណើរការផ្លូវច្បាប់ត្រូវតែធ្វើតាមច្បាប់។ ផុតពីរឿងច្បាប់ហើយ ចាំសំរបសំរួលគ្នាខាងនយោបាយ។ អត់មានសំរួលគ្នាខាងនយោបាយមុនសំរួលគ្នាខាងផ្លូវច្បាប់ទេ**។ សូមជូនសារទុកឱ្យហើយ។ ដំណើរការផ្លូវច្បាប់នៅតែបន្ត។ បើត្រូវជាប់គុក អ្នកឯងត្រូវតែជាប់គុកឱ្យហើយ ចាំមកនិយាយគ្នាខាងនយោបាយ។ បើមិនទាន់កាត់ក្តី ត្រូវតែកាត់ក្តីឱ្យហើយ ចាំមកនិយាយគ្នាខាងនយោបាយ។ ថ្ងៃនេះ ក៏ដូចជាការជូនសារមួយសម្រាប់អ្នកដទៃទៀតថា អត់មានដំណោះស្រាយនយោបាយទេ។ ខ្មែរអត់មានត្រូវការមានជម្លោះទេ មានតែអ្នកដែលមានជម្លោះជាមួយផ្លូវច្បាប់តែប៉ុណ្ណោះ។ អត់មានជម្លោះនយោបាយទេ។ កម្ពុជាអត់មានអ្នកទោសនយោបាយទេ មានតែអ្នកនយោបាយជាប់ទោសព្រហ្មទណ្ឌតែប៉ុណ្ណោះ។ ខ្ញុំមិនមានជម្លោះជាមួយអ្នកណាទេ។ អ្នកបានបង្កជម្លោះជាមួយច្បាប់ទេតើ ...។

៤៥. ក្តីបរិហារកេរ្តិ៍ នៅបារាំង ប្រើពេលដល់ទៅ ៣ឆ្នាំ ទើបបើកសវនាការ

ជួបសមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល/ក្រុមមេធាវីស្ម័គ្រចិត្ត សម្តេចតេជោ, ២៧ វិច្ឆិកា ២០២០

... ខ្ញុំបាន**ប្តឹងពីបទបរិហារកេរ្តិ៍(មួយ)នៅតុលាការបារាំង។ តុលាការហ្នឹងកំណត់សវនាការនៅវេលាម៉ោង ១៖៣០ នាទីរសៀលថ្ងៃទី ០១កញ្ញា ២០២២។ សវនាការនេះ អាចប្រើរយៈពេល ២ម៉ោងកន្លះ។ នេះគ្រាន់តែជាបណ្តឹងបរិហារកេរ្តិ៍ (ដែលបាន)ប្តឹងតាំងពីឆ្នាំ២០១៩។ រឿងអីដែលពួកបរទេសនានាមកនិយាយថា ឱ្យកាត់ក្តីសំណុំរឿងមួយចំនួននៅភ្នំពេញឱ្យបានឆាប់។ មើលខ្លួនឯងទៅ។ ឱ្យយើងទៅបង្ខំតុលាការម៉េចហ្នឹងកើត? យើងគ្មានលទ្ធភាពទៅបង្ខំតុលាការ(ទេ)។ ស្រុកបារាំងក៏គេគ្មានលទ្ធភាពបង្ខំតុលាការដែរ?** ... បទល្មើសល្អិតល្អន់ច។ គេថាសំណុំរឿងកកស្ទះដោយសារ(ការផ្ទុះជំងឺ)កូវីដ-១៩។ នៅទីនេះ ក៏មានការកកស្ទះដោយសារ កូវីដ-១៩ ... គ្រាន់តែរឿងក្តីបរិហារកេរ្តិ៍ ប្រើពេលដល់ទៅ ៣ឆ្នាំ។ រឿងអីមកគាបសង្កត់ឱ្យតុលាការភ្នំពេញកាត់ក្តីរឿងធំៗ មួយចំនួនឱ្យបានឆាប់រហ័ស? (បារាំង)នេះ(ជា)ប្រទេសដែលគេចាត់ទុកថាឯករាជ្យ តុលាការឆាប់រហ័ស ...។

៤៦. ដល់ពេលវេលារៀបចំច្បាប់ដាក់ក្រុមបង្ករឿងនេះជាក្រុមភេរវកម្មហើយឬនៅ

បើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣២ ឆ្នាំ២០២៤, ២១ វិច្ឆិកា ២០២៤

... ពេលនេះគេកំពុងធ្វើថាឱ្យប្រជាជនកម្ពុជាធ្វើបាតុកម្ម ដើម្បីរុញរដ្ឋាភិបាលឱ្យប្តឹងទៅតុលាការអន្តរជាតិ។ ដំបៅមិនឈឺយកឈើចាក់។ រឿងគេកំពុងតែជជែកគ្នាឯក្រុម(នេះបែរជា)មករុញ។ តើនេះជាអំពើអ្វី? ម្តងហើយម្តងទៀត ពួកគេមិនទុកឱ្យប្រជាពលរដ្ឋបានទទួលសេចក្តីសុខ ដោយបង្កើតជាចលនាប្រឆាំងនេះ/នោះ។ **តើដល់ពេលវេលាដែលរាជរដ្ឋាភិបាល ឬអ្នកតាក់តែងច្បាប់រៀបចំច្បាប់ដាក់ក្រុមនេះជាក្រុមភេរវកម្មហើយឬនៅ? ខ្ញុំព្រះករុណាខ្ញុំ ក៏ដូចជាអ្នកនយោបាយដទៃទៀត កំពុងពិនិត្យមើលថា តើដល់ពេលហើយឬនៅ? (អ្វីដែលក្រុមអ្នកនយោបាយប្រឆាំងធ្វើ)នេះ ជាការញុះញង់ អុចអាល ដែលអាចនាំដល់ការផ្ទុះអាវុធរវាងកម្ពុជានិងថៃ ដែលមិនគ្រាន់តែជាបញ្ហាផ្ទៃក្នុងកម្ពុជានោះទេ** ... ដែលយន្តការនៃកំពុងតែដំណើរការ ទាំងខាងថៃទាំងខាងយើង មិនទាន់ឈានដល់ការសម្រេចចិត្តណាមួយផង ហេតុអ្វីបានជាធ្វើរឿងនេះ ជំរុញឱ្យមានបាតុកម្មនៅទូទាំងប្រទេស? សូមបងប្អូនប្រជាពលរដ្ឋពិចារណា ...។

២០. រាជបណ្ឌិត្យសភា

១	សង់អគារសមរម្យសំរាប់ក្រុមបញ្ញវន្តធ្វើការនៅរាជបណ្ឌិតសភា	៣៨១
២	មិនអាចធ្វើប្រធានកិត្តិយសជងប្រធានប្រតិបត្តិជង នៃរាជបណ្ឌិត្យសភាបានទេ	៣៨១
៣	កំពុងទទួលផលពីធនធានមនុស្សដែលបានដាំមក ៣៨ឆ្នាំ	៣៨១
៤	រៀបចំរចនាសម្ព័ន្ធត្រូវនឹងក្របខណ្ឌតួនាទីភារកិច្ចនៃរាជបណ្ឌិតសភាកម្ពុជា	៣៨២
៥	ការតែងតាំងនិងដំឡើងជាបណ្ឌិតសភាចារ្យមិនមានការរើសអើងទេ	៣៨២
៦	ជារដ្ឋមន្ត្រីការបរទេស សំណូមពរធំគឺអាហារូបករណ៍និងការបណ្តុះបណ្តាល	៣៨៣
៧	បណ្តុះបណ្តាលធនធានមនុស្ស ដោយមិនរារាំងទុកនៅទ្រឹងមួយកន្លែង	៣៨៣
៨	រាជបណ្ឌិត្យសភាធ្វើការកែទម្រង់ ដើម្បីជាគំរូដល់ស្ថាប័នដទៃ	៣៨៤
៩	អ្នកមានជំនាញអាចប្រមូលបញ្ញវន្តអោយអង្គុយធ្វើការជាមួយគ្នាបាន	៣៨៤
១០	«ក្រអឺតក្រទម មិនអាចក្លាយជាអ្នកដឹកនាំ» និង «ឡើងកាន់តែខ្ពស់ កាន់តែជាក់ខ្លួន»	៣៨៥
១១	ប្រើខួរក្បាលនិងធានធានមានកំរិត ធ្វើកិច្ចការណាមុននិងធ្វើកិច្ចការណាក្រោយ	៣៨៦
១២	សាមគ្គីភាពជាកត្តាសំរាប់ប្រែក្លាយរាជបណ្ឌិត្យសភាជាឃ្លាំងនៃធនធានបញ្ញា	៣៨៦
១៣	សូមបញ្ញវន្តជាតិ ចូលរួមសិក្សាស្រាវជ្រាវសភាពការណ៍ប្រឈមបច្ចុប្បន្ន	៣៨៧
១៤	រួមគ្នាធ្វើឱ្យការស្រាវជ្រាវមានលក្ខណៈវិទ្យាសាស្ត្រ ផ្តល់ធាតុចូលដល់គ្រប់ផ្នែក	៣៨៧
១៥	រាជបណ្ឌិត្យសភាមានតួនាទីស្រាវជ្រាវប្រធានបទទាក់ទងនឹងការអភិរក្សនិងអភិវឌ្ឍ	៣៨៨
១៦	រៀបបទបញ្ជាផ្ទៃក្នុងឧទ្យានរាជបណ្ឌិតសភា សង្គតិភាពនឹងច្បាប់ ការស្រាវជ្រាវ ...	៣៨៨
១៧	CAP បង្កើតពីឆ្នាំ ១៩៩៧ មានមុខងារវិភាគយុទ្ធសាស្ត្រនិងប្រឆាំងចារកម្ម	៣៨៩
១៨	ស្រាវជ្រាវប្រធានបទមានភាពបន្ទាន់ក្របខណ្ឌតំបន់និងពិភពលោកឱ្យចូលំទូលាយ	៣៨៩
១៩	ហ៊ុន សែន ជាអ្នកវាយតម្លៃសភាពការណ៍ច្រើនជាងគេក្នុងបក្ស	៣៩០
២០	ស្រាវជ្រាវប្រធានបទទាក់ទងស្ថានភាពជាក់ស្តែង ជាធាតុចូលដល់ស្ថាប័នអនុវត្ត	៣៩០
២១	ឧទ្យានរាជបណ្ឌិត្យសភា តោជោសែនឫស្សីត្រឹប នឹងក្លាយជាតំបន់ទេសចរណ៍	៣៩១
២២	បណ្តុះបណ្តាលភាសាចិនតបទៅកំណើនវិនិយោគនិងទេសចរចិន	៣៩១
២៣	គម្រោង "អគារឥន្ទ្រទេវី" មានតម្លៃខ្ពស់លើសការគ្រោងទុក	៣៩១
២៤	រាជបណ្ឌិត្យសភា ធ្វើការស្រាវជ្រាវផងបណ្តុះបណ្តាលផង	៣៩២
២៥	ប្រទេសធំទាំង៥ ចង់បានទីតាំងរាជបណ្ឌិត្យសភាពេលនោះ ជាទីបញ្ជាការអ៊ុនតាក់	៣៩២

២៦	ស្នើសុំក្រសួងអប់រំកាត់មួយផ្នែកធ្វើរាជបណ្ឌិត្យសភា	៣៩៣
២៧	ត្រូវមានសង្គតិភាពនៃការស្រាវជ្រាវ	៣៩៤
២៨	ត្រូវលើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវ	៣៩៤
២៩	ត្រូវមានក្រុមជំនាញបកប្រែឯកសារជាខេមរភាសា សំរាប់អ្នកមិនចេះភាសាបរទេស	៣៩៥
៣០	រៀបចំបន្ទប់ពិសោធន៍ និងបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍	៣៩៥

១. សង់អគារសមរម្យសំរាប់ក្រុមបញ្ញវន្តធ្វើការនៅរាជបណ្ឌិតសភា

ពិធីប្រកាសចូលកាន់តំណែងជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា
និងប្រកាសសមាសភាពក្រុមបណ្ឌិត្យសភាចារ្យ, ១១ សីហា ២០១៧

... គេអាចសម្លឹងមើលទៅក្រោយវិញថា រាជបណ្ឌិត្យសភានេះបានកើតឡើងនៅក្នុងដំណាក់កាលដែលខ្ញុំគ្រប់គ្រង។ វាស្ទើរតែជាកូនបង្កើតរបស់ខ្ញុំ។ ប៉ុន្តែ ឪពុកមួយនេះ មិនបានយកចិត្តទុកដាក់គ្រប់គ្រាន់ចំពោះអ្វីដែលខ្លួនបានបង្កើតនោះទេ រាប់ទាំងអគារធ្វើការ។ ប៉ុន្តែ **(ពេលនេះ)ខ្ញុំបាន(សំរេចឱ្យ)ធ្វើការជួសជុល ដោយពីម្សិលមិញនេះ គ្រឿងចក្របានចូលទៅដល់ការដ្ឋានរួចស្រេចទៅហើយ។ ខ្ញុំក៏បញ្ជាក់ជាមួយបណ្ឌិតសភាចារ្យ សុខ ទូច អោយរក(វេលា)ល្អដើម្បីធ្វើពិធីក្រុងពាលីចាប់ផ្តើមសាងសង់ជាអគារមួយសមរម្យ សម្រាប់ការធ្វើការរបស់ក្រុមបញ្ញវន្តនៅទីនោះ** ...។

២. មិនអាចធ្វើប្រធានកិត្តិយសផង ប្រធានប្រតិបត្តិផង នៃរាជបណ្ឌិត្យសភាបានទេ

ពិធីប្រកាសចូលកាន់តំណែងជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា
និងប្រកាសសមាសភាពក្រុមបណ្ឌិត្យសភាចារ្យ, ១១ សីហា ២០១៧

... បន្ទាប់ពីមរណភាពរបស់សម្តេចវិបុលបញ្ញាសុខអាន ... ដែលជាប្រធានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ **លោកជំទាវ(ខ្លូតធីតា)បានស្នើអោយខ្ញុំទទួលភារកិច្ចជាប្រធានបណ្ឌិតសភាចារ្យ។ ខ្ញុំគិតថា ទាំងខ្ញុំទាំងលោកជំទាវសុទ្ធតែជាមនុស្សរងកម្ម ... លោកជំទាវក៏ដល់អាយុចូលនិវត្តន៍ តាំងពីប៉ុន្មានឆ្នាំមុនឯនោះ ... ការដែលខ្ញុំទទួលធ្វើទាំងជាប្រធានកិត្តិយសផង ធ្វើទាំងជាប្រធានផង បន្ថែមដោយអនុប្រធានម្នាក់ ដែលមានសុខភាពមិនពេញលេញទៀត ពិតជាមិនអាចរែកអម្រែកនេះរួចទេ** ... ខ្ញុំមានតែវិធីមួយគត់គឺស្នើសុំទៅព្រះមហាក្សត្របំពេញឋានៈបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន និងបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន ... ឱ្យកាន់កាប់តំណែងជាប្រធានបណ្ឌិតសភាចារ្យជំនួស សម្តេចវិបុលបញ្ញា សុខ អាន ...។

៣. កំពុងទទួលផលពីធនធានមនុស្សដែលបានដាំមក ៣៨ឆ្នាំ

ពិធីប្រកាសចូលកាន់តំណែងជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា
និងប្រកាសសមាសភាពក្រុមបណ្ឌិត្យសភាចារ្យ, ១១ សីហា ២០១៧

... អ្វីដែលយើងគួរកត់សម្គាល់ គឺ**យើងកំពុងបាននិងទទួលផលពី(ធនធានមនុស្ស)ដែលបានខំប្រឹងដាំរយៈពេល ៣៨ឆ្នាំកន្លងមក។ ខ្ញុំនៅចាំអនុស្សាវរីយ៍បន្ទាប់ពីរំដោះទីក្រុងភ្នំពេញ។ តើពេលនោះយើងនៅសល់បណ្ឌិតប៉ុន្មាននាក់? យើងនៅសល់បញ្ញវន្តដែលចប់បរិញ្ញា(បត្រ)ឬបរិញ្ញាជាន់ខ្ពស់ប៉ុន្មានទៅ?** តិចណាស់។ ចំនួនមិនគ្រប់គ្រាន់(តាមតម្រូវការ)ទេ។ យើងប្រឹងប្រែងប្រមូលធនធានទាំងនោះបន្តធ្វើការងារ។ ក្នុងហាន:ជារដ្ឋមន្ត្រីការបរទេសនៅដំណាក់កាលនោះ ខ្ញុំមានមនុស្សតែ ៣នាក់ប៉ុណ្ណោះដែលត្រូវកសាងស្ថាប័នក្រសួងការបរទេសមួយ។ មិនមែនគ្រាន់តែខ្លួនខ្ញុំទេ ក្រសួងដទៃ ស្ថាប័នដទៃ ក៏សុទ្ធតែកសាងពីបាតដៃទទេដូចគ្នា ...។

៤. រៀបចំរចនាសម្ព័ន្ធត្រូវនឹងក្របខណ្ឌតួនាទីភារកិច្ចនៃរាជបណ្ឌិត្យសភាកម្ពុជា

ពិធីប្រកាសចូលកាន់តំណែងជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា
និងប្រកាសសមាសភាពក្រុមបណ្ឌិត្យសភាចារ្យ, ១១ សីហា ២០១៧

...លើកនេះជាការ**រៀបចំអោយត្រូវនឹងក្របខណ្ឌនៃលក្ខន្តិក:បទបញ្ញត្តិ នៅក្នុងក្របខណ្ឌនៃរាជបណ្ឌិត្យសភាទាក់ទិននឹងតួនាទីភារកិច្ចដែលខ្លួនត្រូវបំពេញ** ... មុនទៅទស្សនកិច្ចនៅប្រទេសជប៉ុន ក៏បានតែងតាំងបណ្ឌិត ហ៊ីង ចូរ៉ាក់ស៊ី ជាបណ្ឌិតសភាចារ្យ។ ត្រឡប់ពីជប៉ុនមកវិញ ... តែងតាំងបណ្ឌិត ចាន់ សំណព្វ ជាបណ្ឌិតសភាចារ្យ និងជាអនុប្រធានរាជបណ្ឌិត្យសភា។ ពេលនេះ យើងចាប់ផ្តើមមានរចនាសម្ព័ន្ធក្បាលកន្ទុយត្រឹមត្រូវ។ ម្ខាងបណ្ឌិតសភាចារ្យ មានឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន ជាប្រធាន មានឯកឧត្តម ហង់ ជួនណារ៉ុន ជាអនុប្រធាន និងមានឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច ដែលជាប្រធានរាជបណ្ឌិត្យសភាជាអនុប្រធានប្រចាំការ។ ទំរង់បែបនេះល្អ ... ឱ្យប្រធានរាជបណ្ឌិត្យសភា ជាអនុប្រធានប្រចាំការធ្វើកិច្ចការបណ្ឌិតសភាចារ្យ ...។

៥. ការតែងតាំងនិងដំឡើងជាបណ្ឌិតសភាចារ្យមិនមានការរើសអើងទេ

ពិធីប្រកាសចូលកាន់តំណែងជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា
និងប្រកាសសមាសភាពក្រុមបណ្ឌិតសភាចារ្យ, ១១ សីហា ២០១៧

... បើធ្វើការសង្កេត **ក្នុងចំណោមបណ្ឌិតសភាចារ្យ ៨រូប ដែល ៣រូប ត្រូវដំឡើងជាបណ្ឌិតសភាចារ្យថ្មី និងមួយរូបត្រូវតែងតាំងជាប្រធានរាជបណ្ឌិត្យសភា យើញថាអ្នករៀននៅអតីតសហភាពសូវៀតមានទៅដល់ ៨នាក់ អ្នករៀននៅបារាំងមានតែមួយនាក់ទេ ...វាមិនមែនជាការរើសអើងថា(ទាល់តែ)អ្នកមកពីអតីតសហភាពសូវៀតទើបបានទទួលការតែងតាំងនោះទេ**។ ខ្ញុំសង្ឃឹមថាក្រុមសមាជិកបណ្ឌិតសភាចារ្យនឹងបន្តកិច្ចការជ្រើសរើសតាមលក្ខណៈសម្បត្តិ ដែលតម្រូវដោយលក្ខន្តិក: និងបែបបទរបស់ខ្លួន។ បើយោងទៅតាមការកំណត់ ចំនួនសមាជិកបណ្ឌិតសភាចារ្យមានដល់ ៧៩នាក់។ ចំនួនដែលត្រូវជ្រើសរើសនៅពេលខាងមុខ មានច្រើនបង្គួរ (ដែល)ខ្ញុំទុកតួនាទីនេះជូនទៅប្រធាន និងអនុប្រធាន ... បណ្ឌិតសភាចារ្យពិនិត្យជ្រើសរើស ...។

៦. ជារដ្ឋមន្ត្រីការបរទេស អាហារូបករណ៍និងការបណ្តុះបណ្តាលជាសំណូមពរធំជាងគេ

ពិធីប្រកាសចូលកាន់តំណែងជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា
និងប្រកាសសមាសភាពក្រុមបណ្ឌិត្យសភាចារ្យ, ១១ សីហា ២០១៧

... ទៅប្រទេសណាក៏ដោយ ខ្ញុំមិនភ្លេចនឹងស្នើសុំអាហារូបករណ៍ទេ ... ក្នុងហាន:ជារដ្ឋមន្ត្រីការបរទេសនៅដំណាក់កាលនោះ **(ខ្ញុំបាន)ជួបអង់ជ្រេ ហ្គ្រូមីកូ (រដ្ឋមន្ត្រីការបរទេសសហភាពសូវៀត) ដែលពេលនោះមានអាយុ ៧២ឆ្នាំ។ ខ្ញុំមានអាយុ ២៧ឆ្នាំ ... (ជា)រដ្ឋមន្ត្រីការបរទេសមួយក្មេងបំផុតលើលោក។ គឺជួបជាមួយនឹងរដ្ឋមន្ត្រីការបរទេស ដែលតាំងពីខ្ញុំកើតមកឮតែឈ្មោះ អង់ជ្រេ ហ្គ្រូមីកូ តាមវិទ្យុ។ ក្នុងជំនួប(នោះ អ្វីដែលជា)សំណូមពរធំជាងគេ(របស់ខ្ញុំ) គឺអាហារូបករណ៍ និងការបណ្តុះបណ្តាល**។ ដោយហេតុនេះហើយ យើង(មានឱកាស)បញ្ជូន(និស្សិត/សិក្ខាកាម)ទៅអតីតសហភាពសូវៀតបានច្រើន រួចហើយក៏បានបញ្ជូនទៅអាល្លឺម៉ង់ខាងកើត ហុងគ្រី ប៊ុលការី ប៉ូឡូញ ជាបន្តបន្ទាប់។ រួមជាមួយគ្នានោះ ក៏ចេះតែធ្វើការបណ្តុះបណ្តាលក្នុងស្រុកជាហូរហែ ...។

៧. បណ្តុះបណ្តាលធនធានមនុស្ស ដោយមិនរារាំងទុកនៅទ្រឹងមួយកន្លែង

ពិធីប្រកាសចូលកាន់តំណែងជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា
និងប្រកាសសមាសភាពក្រុមបណ្ឌិត្យសភាចារ្យ, ១១ សីហា ២០១៧

... ដូចដែល ឯកឧត្តមបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន បានលើកឡើង **វិធី(សាស្ត្រ)នៃការបណ្តុះបណ្តាលរបស់ខ្ញុំមានច្រើនផ្សេងៗគ្នា។ ក្នុងអតីតកាលពេលដែលធ្វើទាហាន ខ្ញុំបានបណ្តុះបណ្តាលនារសាររបស់ខ្ញុំ ដែលជាកងការពាររបស់ខ្ញុំ រហូតគេក្លាយខ្លួនទៅជាអ្នកដែលមានហានៈស្មើខ្ញុំ។ ខ្ញុំមិនរារាំងគេទុកនៅទ្រឹងមួយកន្លែងទេ។ សម្តេចវិបុលបញ្ញា សុខ អាន, ឯកឧត្តមទេសរដ្ឋមន្ត្រី ចមប្រសិទ្ធ, ឯកឧត្តម ឡុង វិសាលោ សុទ្ធតែជាអតីតលេខាផ្ទាល់របស់ខ្ញុំ** ... ខ្ញុំបានបញ្ជូន ឯកឧត្តម អូន ព័ន្ធមុន្នីរ័ត្ន អោយទៅតភ្ជាប់ជើងនឹង ឯកឧត្តម គាត ឈន់ ហើយបន្តទៅតភ្ជាប់ជាមួយខ្លួនខ្ញុំ។ ហង់ ជួនណារ៉ុន ក៏ដូចគ្នាដែរ។ ដល់ដំណាក់កាល ក៏ទាញយកមកធ្វើរដ្ឋមន្ត្រី ...។

៨. រាជបណ្ឌិត្យសភាធ្វើការកែទម្រង់ ដើម្បីជាគំរូដល់ស្ថាប័នដទៃ

ពិធីប្រកាសចូលកាន់តំណែងជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា
និងប្រកាសសមាសភាពក្រុមបណ្ឌិត្យសភាចារ្យ, ១១ សីហា ២០១៧

... ខ្ញុំស្នើបណ្ឌិតសភាចារ្យ សុខ ទូច **ធ្វើកំណែទម្រង់ឱ្យបានលើចំណុចចាំបាច់មួយចំនួន។ បើមិនធ្វើកំណែទម្រង់ទេ ស្ថាប័នមួយនេះ អាចរយីការយោក ... ជាគំរូមិនល្អចំពោះស្ថាប័នដទៃ។ ទីនេះជាកន្លែងប្រមូលផ្តុំបញ្ញវន្ត ប្រមូលផ្តុំខួរក្បាល ... ដល់តែធ្វើការមិនត្រូវគ្នា ខ្វះប្រសិទ្ធភាព ... មិនដឹងថា(ធ្វើជា)គំរូអោយនរណាទេ។ ហេតុនេះ រាជបណ្ឌិត្យសភាត្រូវធ្វើជាជំនួយដល់ស្ថាប័នដទៃ ឬស្ថាប័នដទៃក៏ជួយដល់រាជបណ្ឌិត្យសភាវិញ។** ត្រូវមានការបំពេញអោយគ្នារវាងស្ថាប័ននានា និងរាជបណ្ឌិត្យសភា។ ស្ថាប័នដែលនៅជាប់ជាមួយខ្ញុំ ធ្វើការស្រាវជ្រាវផ្នែកយុទ្ធសាស្ត្រ មានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ច ដែលប្រធានបណ្ឌិតសភាចារ្យ អូន ព័ន្ធមុន្នីរ័ត្ន ជាប្រធានស្រាប់ និងមួយទៀតជាក្រុមដែលមានឈ្មោះជាអក្សរកាត់ CAP ...។

៩. អ្នកមានជំនាញអាចប្រមូលបញ្ញវន្តអោយអង្គុយធ្វើការជាមួយគ្នាបាន

ពិធីប្រកាសចូលកាន់តំណែងជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា
និងប្រកាសសមាសភាពក្រុមបណ្ឌិត្យសភាចារ្យ, ១១ សីហា ២០១៧

... ពាក្យថាបញ្ញវន្ត មិនដូចគោដូចក្របី (ដែល)ប្រើទៅលិចក៏ទៅលិច ប្រើទៅកើតក៏ទៅកើតនោះទេ។ ចំណុចហ្នឹងត្រូវយល់អោយច្បាស់។ មានពាក្យថា **ជាការពិបាកណាស់ក្នុងការគ្រប់គ្រងបញ្ញវន្ត ព្រោះ(ជាញឹកញយ)បញ្ញវន្តមិនសូវត្រូវគ្នាទេ។ ក៏ប៉ុន្តែ វាលំបាកតែអ្នកមិនចេះ អ្នកដែលមិនមានជំនាញ ... អ្នកដែលមានជំនាញអាចប្រមូលបញ្ញវន្តទាំងអស់អោយអង្គុយជាមួយគ្នា**។ ខ្ញុំនៅចាំបាន។ បង ជា សុទ្ធ ជាឧបនាយករដ្ឋមន្ត្រីប្រចាំការ។ ពេលនោះ ខ្ញុំឧស្សាហ៍ទៅបរទេស(ដើម្បីធ្វើការ)ចរចា។ មានអ្នកច្បាប់ ៥នាក់ចូលប្រជុំ។ គាត់(បង ជា សុទ្ធ)អត់ចូលតែម្តងព្រោះអ្នកច្បាប់និយាយមិនត្រូវគ្នា ... គាត់មិនខ្លាចទេបញ្ញវន្តខាងសេដ្ឋកិច្ចខាងស្តីៗតែគាត់ខ្លាចអ្នកច្បាប់ ព្រោះអ្នកច្បាប់និងអ្នកច្បាប់ និយាយមិនត្រូវគ្នា។ បង ជា សុទ្ធ សរុប(ការប្រជុំ)មិនកើត ...។

១០. «ក្រអឺតក្រទម មិនអាចក្លាយជាអ្នកដឹកនាំ» និង «ឡើងកាន់តែខ្ពស់ កាន់តែជាក់ខ្លួន»

ពិធីប្រកាសចូលកាន់តំណែងជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា
និងប្រកាសសមាសភាពក្រុមបណ្ឌិត្យសភាចារ្យ, ១១ សីហា ២០១៧

... ចាស់ពីដើមប្រើភាសាថា "សង្ឃឹតង់ខ្វះអំបែង"។ ត្រូវយល់(ភាសានេះ)ឱ្យបានច្បាស់។ **ភាពពើងទ្រេងក្រអឺតក្រទម មិនអាចក្លាយទៅជាមេដឹកនាំបានទេ។ "ឡើងកាន់តែខ្ពស់ កាន់តែជាក់ខ្លួន"។ ត្រូវចាំថា "ភាពពើងទ្រេង ក្រអឺតក្រទម នឹងនាំទៅដល់ភាពឯកោខ្លួន" តែប៉ុណ្ណោះ។ ទីចុងបំផុត ពេលចុះនរក ក៏ចុះតែឯង។ គ្មាននរណាចុះជាមួយទេ ព្រោះយើងអត់បានរួមសុខរួមទុក្ខជាមួយគេ។ អញ្ចឹង ពាក្យថា "រួមសុខ រួមទុក្ខ" ក៏ត្រូវមួយទៅ។ ពាក្យមួយទៀតថា "ទទួលខុសត្រូវ" (ក៏មួយទៀត)**។ ធ្វើជាមេដឹកនាំ មិនថាកន្លែងណាជាកន្លែងណា សូម្បីកន្លែងនេះគឺរាជបណ្ឌិតសភា ត្រូវចាំថា "ភាពក្រអឺតក្រទម ឬតាំងខ្លួនថាជាអ្នកចេះដឹងលើសគេលើសឯង វានឹងបង្កើតបាននូវស្ថានភាពស្ងួយឯកោ" ... គ្រូដែលធ្លាប់បង្រៀនយើងនៅបឋមសិក្សា ទោះដល់ពេលនេះយើងក្លាយទៅជាបណ្ឌិត ក៏យើងនៅតែត្រូវគោរពគាត់។ មិនត្រូវមើលស្រាល ... ត្រូវធ្វើបុណ្យជូនគាត់ ដោយសារអ្នកដឹកដៃមុនហ្នឹងហើយដែលនាំយើងឱ្យមកដល់ថ្ងៃនេះ ...។

១១. ប្រើខួរក្បាលនិងធានធានមានកំរិត ធ្វើកិច្ចការណាមុននិងធ្វើកិច្ចការណាក្រោយ

ប្រកាសគោរមងារវិទ្យាសាស្ត្រ និងគោរមងារកិត្តិយស នៃរាជបណ្ឌិតសភា,
១៩ មិថុនា ២០១៨

... ខ្ញុំចង់រំលឹកពីតួនាទីរបស់រាជបណ្ឌិតសភាក៏ដូចជាតួនាទីបញ្ញវន្តរបស់យើង ... ការស្រាវជ្រាវនានាត្រូវតែមាន ហើយវាក៏មិនមែនមានតែបញ្ហាប៉ុណ្ណឹងទេ។ នៅមានបញ្ហាច្រើនជាងនេះ។ **ខ្ញុំស្នើសុំឱ្យផ្តល់អាទិភាពចំពោះកិច្ចការបន្ទាន់ៗ ចំពោះមុខ។ បើសិនយើងប្រើប្រាស់ខួរក្បាល និងធានធានដ៏មានកម្រិតរបស់យើងទៅ (សិក្សាបញ្ហាច្រើន)ក្នុងតែមួយពេល ពិតជាមិនអាចឆ្លើយតបបានទេ។ ដូច្នេះ ត្រូវប្រមូលផ្តុំកិច្ចការណាត្រូវធ្វើមុន កិច្ចការណាត្រូវធ្វើក្រោយ។** និយាយដូច្នេះមិនមែនបានសេចក្តីថាបោះបង់ចោលនូវកិច្ចការផ្សេងទេ។ កិច្ចការ(ទាំងឡាយ)វាពិតជាមានអាទិភាព និងមានលំដាប់លំដោយរបស់វា ...។

១២. សាមគ្គីភាពជាកត្តាសំរាប់ប្រែក្លាយរាជបណ្ឌិត្យសភាជាឃ្លាំងនៃធនធានបញ្ញា

ពិធីប្រកាសចូលកាន់តំណែងជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា
និងប្រកាសសមាសភាពក្រុមបណ្ឌិតសភាចារ្យ, ១១ សីហា ២០១៧

... ខ្ញុំគួរនិយាយបន្តិចទាក់ទិននឹងស្ថាប័នរាជបណ្ឌិត្យសភា។ ដូចដែល ឯកឧត្តម បណ្ឌិតសភាចារ្យ សុខ ទូច ប្រធានរាជបណ្ឌិត្យសភា បានលើកឡើង **ដើម្បីអោយទៅជាធនធានបញ្ញាបាន ដើម្បីអោយអង្គភាពនេះខ្លាំង ... បញ្ហាធំជាងគេគឺសាមគ្គីភាព។ ចំណុចនេះធំណាស់។ តាមបទពិសោធន៍ដែលខ្ញុំឆ្លងកាត់ជោគជ័យពីដំណាក់កាលមួយទៅដំណាក់កាលមួយ គឺពីដំណាក់កាលដែលគេហៅខ្ញុំថាជារដ្ឋមន្ត្រីមិនទាន់បាត់ក្លិនទឹកដោះគោ ... (ព្រោះ)ខ្ញុំចូលកាន់ដំណែងជារដ្ឋមន្ត្រីការបរទេស ក្នុងវ័យមិនទាន់ទាំងដល់ ២៧ឆ្នាំផង ... គឺនៅមានអាយុ ២៦ឆ្នាំកន្លះនៅឡើយ ហេតុអីបានជាខ្ញុំឈរជើងជាប់នៅទីនេះ? សំខាន់ជាងគេ គឺការដាក់ខ្លួនរៀនសូត្រមិនតាំងខ្លួន(ចេះជាងអ្នកដទៃ) មិនពើងទ្រេងថាជាអ្នកចេះតែឯង**។ នៅលើលោកនេះ ... គ្មាននរណាមួយអាចចេះទាំងអស់ទេ។ ខ្ញុំនេះកំពុងតែពឹងពាក់(គេដួយចង)ក្រាំត់ក ត្បិតរៀនមួយជីវិតទៀតក៏មិនចេះចង់ដែរ ...។

១៣. សូមបញ្ញវន្តជាតិ ចូលរួមសិក្សាស្រាវជ្រាវសភាពការណ៍ប្រឈមបច្ចុប្បន្ន

ប្រកាសគោរមងារវិទ្យាសាស្ត្រ និងគោរមងារកិត្តិយសនៃរាជបណ្ឌិតសភា,
១៩ មិថុនា ២០១៨

... ខ្ញុំសង្ឃឹមថា **បញ្ញវន្តយើង ទាំងអ្នកទទួលគោរមងារថ្ងៃនេះ ក៏ដូចជាអ្នកទាំងអស់ដែលជាបញ្ញវន្តរបស់ជាតិ រាប់ទាំងបណ្តាសាកលវិទ្យាល័យនានាក្នុងព្រះរាជាណាចក្រកម្ពុជា អាចនឹងចូលរួមផ្តល់ធាតុចូល សម្រាប់ការសិក្សាស្រាវជ្រាវពាក់ព័ន្ធទៅនឹងស្ថានភាពបច្ចុប្បន្ននេះ** ត្បិតវាមិនគ្រាន់តែជាសង្គ្រាមពាណិជ្ជកម្មដែលទើបនឹងកើតទេ ក៏ប៉ុន្តែក៏មានសង្គ្រាមដែលបានឆាបឆេះនៅក្នុងតំបន់ខ្លះនៅទូទាំងពិភពលោក បញ្ហាភេរវកម្ម ការប្រែប្រួលអាកាសធាតុ និងបញ្ហាផ្សេងៗទៀតដែលសុទ្ធសឹងតែក្លាយជាប្រធានបទដែលត្រូវរកវិធីដោះស្រាយ ក្នុងក្របខណ្ឌប្រទេសខ្លួនឯងផង ក្នុងក្របខណ្ឌអនុតំបន់និងតំបន់ ក៏ដូចជាពិភពលោកផង ...។

១៤. រួមគ្នាធ្វើឱ្យការស្រាវជ្រាវមានលក្ខណៈវិទ្យាសាស្ត្រ ផ្តល់ធាតុចូលដល់គ្រប់ផ្នែក

សម្ពោធអគារឥន្ទ្រទេវី នៃរាជបណ្ឌិត្យសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... និយាយពីរាជបណ្ឌិត្យសភា ខ្ញុំរីករាយដោយបានឃើញថាបានធ្វើកិច្ចការច្រើនហើយ។ សូមអរគុណចំពោះឯកឧត្តម ស៊ិន សំណាង ដែលជាប្រធានបណ្ឌិត្យសភាលើកទី១ និងជំទាវ ខ្លូត ធីតា ដែលជាប្រធានដំណាក់កាលទី២។ ឥឡូវនេះ គឺឯកឧត្តម សុខ ទូច ដែលបន្ត ដើម្បីគ្រប់គ្រងស្ថាប័នស្រាវជ្រាវមួយនេះ។ **យើងបន្តខិតខំរួមគ្នាធ្វើឱ្យដំណើរការស្រាវជ្រាវរបស់យើង ក្លាយទៅជាការស្រាវជ្រាវដែលមានលក្ខណៈវិទ្យាសាស្ត្រ ហើយដែលផ្តល់ធាតុចូលសម្រាប់ឱ្យគ្រប់ផ្នែក**។ ខ្ញុំគួរតែនិយាយបន្តិចថា តើយើងគួរស្រាវជ្រាវរបៀបម៉េច ហើយគួរផ្សារភ្ជាប់គ្នាយ៉ាងម៉េច? បើមិនដូច្នោះ ការស្រាវជ្រាវក៏គិតតែស្រាវជ្រាវទៅ ប៉ុន្តែមិនមានអ្នកណាទទួលយកទៅសិក្សានិង/ឬទៅអនុវត្ត។ សម័យកាលមុនមិនមែនគ្រាន់តែកម្ពុជាទេ នៅលើពិភពលោក រវាងក្រុមអ្នកស្រាវជ្រាវ និងក្រុមអនុវត្ត ស្ថិតនៅឃ្លាតឆ្ងាយពីគ្នាខ្លាំងណាស់។ ឥឡូវក្រុមអនុវត្ត និងក្រុមស្រាវជ្រាវនៅក្បែរគ្នា ឬនៅជាប់គ្នាតែម្តង ... ដែលជាហេតុបានជំរុញបច្ចេកវិទ្យាមានការជឿនលឿនយ៉ាងខ្លាំង ...។

១៥. រាជបណ្ឌិត្យសភាមានតួនាទីស្រាវជ្រាវប្រធានបទទាក់ទងនឹងការអភិរក្សនិងអភិវឌ្ឍ

ពិធីដាំកូនឈើនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែនឫស្សីត្រឹប,
១៨ ឧសភា ២០១៨

... **រាជបណ្ឌិត្យសភាមានតួនាទីធំលើការស្រាវជ្រាវទៅលើប្រធានបទនីមួយៗ ដែលមិនគ្រាន់តែទាក់ទងនឹងការអភិរក្សទេ ក៏ប៉ុន្តែក៏ទាក់ទងនឹងការអភិវឌ្ឍ។ ការចាំបាច់កែទំរង់ក្បាលម៉ាស៊ីនរាជបណ្ឌិត្យសភា គឺសំដៅដល់គោលដៅហ្នឹង។ មិនមែនសំដៅឱ្យអោយខ្ញុំជួយរកថវិកាដើម្បីបោះពុម្ពសៀវភៅ(នោះទេ)** ... រឿងនោះក៏យើងធ្វើ ប៉ុន្តែទុកអោយក្រសួងធម្មការអើធ្វើទៅ។ យើងចូលទៅក្នុងការស្រាវជ្រាវទាក់ទងនឹងការអភិវឌ្ឍ។ ពិតហើយ យើងបន្តស្រាវជ្រាវកន្លែងស្លដែកនេះ(ដើម្បីឱ្យបានដឹងថាមានមក)ពីជំនាន់ណាពិតប្រាកដ ... អាចធ្វើកោសលវិច័យដឹងថាប៉ុន្មានរយឆ្នាំហើយ មានប្រវត្តិយ៉ាងម៉េច ... តំបន់ព្រៃម្ល អាចចាត់ទុកថាជាកន្លែងផលិតយុទ្ធោបករណ៍ ឬកន្លែងយោធា។ (កន្លែងនេះក៏)ទាក់ទងជាមួយហ្នឹងប្រវត្តិ តេជោមាស តេជោយ៉ែត ដែលឡើងពីកំពង់ស្ពឺមកទប់ទល់នឹងព្រះបាទថៃណាមួយដែលចូលមកតំបន់នេះ។ ពីមុន តំបន់នេះជាខេត្តកំពង់ធំទេក្នុងសតវត្សរ៍ទី១៦ ...។

១៦. រៀបចំបទបញ្ជាផ្ទៃក្នុងឧទ្យានរាជបណ្ឌិត្យសភា មានសង្គតិភាពនឹងច្បាប់ ការស្រាវជ្រាវ និងអភិវឌ្ឍន៍

ពិធីដាំកូនឈើនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែនឫស្សីត្រឹប,
១៨ ឧសភា ២០១៨

...ខ្ញុំសូមគាំទ្រទស្សនាទានជាទស្សនវិស័យទាំង៦របស់រាជបណ្ឌិត្យសភា...ត្រូវធ្វើឱ្យទស្សនាទានទាំង៦ នេះ ជោគជ័យ។ ខ្ញុំឯកភាពថា សូមរៀបចំឱ្យកន្លែងនេះដោយកុំចាំដល់ទៅច្បាប់។ យើងមានច្បាប់រួចហើយ ប៉ុន្តែយើងរៀបចំបទបញ្ជាផ្ទៃក្នុងដោយសហការជាមួយក្រសួងបរិស្ថានធ្វើការងារនេះ។ត្រូវមានបទបញ្ជាផ្ទៃក្នុងដោយឡែកមួយសម្រាប់តំបន់ហ្នឹងតែម្តង ព្រោះស្ថានភាពវាមិនដូចតំបន់ដទៃទេ។ នៅតំបន់នេះ **យើងដំណើរការទៅព្រមគ្នានឹងការស្រាវជ្រាវផង រហូតដល់ការចិញ្ចឹមសត្វស្ពឺៗ ផង ... អាចរៀបចំជាបទបញ្ជាផ្ទៃក្នុង អាចចេញជាព្រះរាជក្រឹត្យ ឬ**

ចេញដោយអនុក្រឹត្យស្តីពីការគ្រប់គ្រង ... ដោយមានសង្គតិភាពជាមួយច្បាប់ផង ... ការស្រាវជ្រាវផង និងការអភិវឌ្ឍផង ...។

១៧. CAP បង្កើតពីឆ្នាំ ១៩៩៧ មានមុខងារវិភាគយុទ្ធសាស្ត្រនិងប្រឆាំងចារកម្ម

សម្ពោធអគារតេន្ត្រទៅ នៃរាជបណ្ឌិត្យសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... **(ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចបង្កើតនៅឆ្នាំ២០០២) ជាអ្នកស្រាវជ្រាវក្របខណ្ឌគោលនយោបាយលើវិស័យសេដ្ឋកិច្ច ក៏ដូចជាវិស័យនយោបាយ។ ស្ថាប័នស្រាវជ្រាវមួយទៀតដែលនៅអមជាមួយខ្ញុំ ហៅកាត់ថា CAP ... បង្កើតតាំងពីឆ្នាំ ១៩៩៧ ស្ថាប័ននេះ មិនមានអ្នកណាដឹងទេ ហើយ(មានមុនាទី)ធ្វើការវិភាគបញ្ហាយុទ្ធសាស្ត្រ និងចារកម្ម។** ឯកឧត្តម ប្រាក់ សុខុន ក៏បានដឹកនាំបង្កើតនូវក្រុមស្រាវជ្រាវមួយ។ក្រុមស្រាវជ្រាវនោះអាចទទួលយកបាន...ខ្ញុំឱ្យឯកឧត្តម សុខ ទូច ស្រាវជ្រាវឱ្យខ្ញុំ។ ខ្ញុំចង់សាកល្បងសមត្ថភាព ឯកឧត្តម សុខ ទូច នៅពេលដែលកាន់ផ្នែក គេហៅថាទំនាក់ទំនងអន្តរជាតិ។ ផ្នែកហ្នឹងយល់ដឹងប៉ុណ្ណា? ពេលនោះខ្ញុំឱ្យស្រាវជ្រាវឱ្យខ្ញុំអំពីបញ្ហាស្ថានភាពមួយចំនួនដូចជានៅមជ្ឈឹមបូព៌ា បញ្ហានៅអ៊ុយក្រែន ដោយសារ សុខ ទូច ធ្លាប់រៀននៅហ្នឹងនិងបញ្ហាផ្សេងទៀត...។

១៨. ស្រាវជ្រាវប្រធានបទមានភាពបន្ទាន់ក្របខណ្ឌតំបន់និងពិភពលោកឱ្យទូលំទូលាយ

សម្ពោធអគារតេន្ត្រទៅ នៃរាជបណ្ឌិត្យសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... យើងស្រាវជ្រាវលើ(ប្រធានបទ)ដែលជាភាពបន្ទាន់។ ខ្ញុំសូមផ្តល់ជាគំនិត។ (ដែលថាយើងធ្វើ)**ការស្រាវជ្រាវប្រវត្តិសាស្ត្រ ក៏យើងត្រូវតែស្រាវជ្រាវហើយ ប៉ុន្តែភាពបន្ទាន់នៅពីមុខក៏មាន(ប្រធានបទ)ស្រាវជ្រាវច្រើនណាស់** ... យើងដាក់ជាសំណួរថាបន្ទាប់ពីអង់គ្លេសចាកចេញ(ពីសហភាពអឺរ៉ុប) ទោះបីមានឬគ្មានកិច្ចព្រមព្រៀង តើសេដ្ឋកិច្ចអង់គ្លេសនឹងមានស្ថានភាពដូចម្តេច? មានផលប៉ះពាល់ដល់ប្រទេសអឺរ៉ុបណាទៀត?... ឬរគីដែលជាសមាជិកអង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង/ណាតូឬអូតង់ មិនមែនជាសមាជិកសហភាពអឺរ៉ុប/EU ... តែជាកម្លាំងធំទីពីរបន្ទាប់ពីអាមេរិក ទៅជាធ្វើសម្ព័ន្ធមិត្តនឹងរុស្ស៊ី ហើយទិញអាវុធរបស់រុស្ស៊ី។ តើកម្លាំងណាតូពិតប្រាកដជាអ្វី? ... **យើងត្រូវដឹង មិនមែននៅកម្ពុជាយើងគិតតែពី**

រឿងកម្ពុជា មិនមើលគេឯងទេ។ ត្រូវមើលឱ្យទូលាយ ទាំងក្នុងក្របខណ្ឌតំបន់ និងក្របខណ្ឌពិភពលោក ...។

១៩. ហ៊ុន សែន ជាអ្នកវាយតម្លៃសភាពការណ៍ច្រើនជាងគេក្នុងបក្ស

សម្ពោធអគារឥន្ទ្រទេវី នៃរាជបណ្ឌិត្យសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... មិនមែនបានសេចក្តីថា ខ្ញុំធ្វើការគ្មានអ្នកស្រាវជ្រាវផ្នែកយុទ្ធសាស្ត្រនោះទេ។ ខ្លួនខ្ញុំផ្ទាល់ហ្នឹងក៏ជាអ្នកស្រាវជ្រាវម្នាក់ ក្នុងចំណោមអ្នកដែលចូលរួមស្រាវជ្រាវជាមួយគ្នា។ មិនមែនប្រគល់ឱ្យគេស្រាវជ្រាវទាំងអស់ទេ។ ស្រាវជ្រាវ វិភាគ វាយតម្លៃសភាពការណ៍ ហើយភាគច្រើនក្នុងតួអង្គគណបក្សប្រជាជនក៏បានដឹងថា (ក្នុងចំណោម)អ្នកស្រាវជ្រាវពិតប្រាកដនៅក្នុងបក្ស គឺ ហ៊ុន សែន (ជាអ្នក)វាយតម្លៃសភាពការណ៍ច្រើនជាងគេទាំងអស់ និងមានស្ថាប័នមួយទៀត ដែលជាស្ថាប័នរបស់ជាតិ គឺគណៈកម្មាការគោលនយោបាយសេដ្ឋកិច្ច ដែលដឹកនាំដោយឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន ... ស្ថាប័នជាតិស្រាវជ្រាវ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ CAP ក្រុមស្រាវជ្រាវដែលឥឡូវទៅនៅនឹងក្រសួងការបរទេស ...។

២០. ស្រាវជ្រាវប្រធានបទទាក់ទងស្ថានភាពជាក់ស្តែងដើម្បីជាធាតុចូលដល់ស្ថាប័នអនុវត្ត

សម្ពោធអគារឥន្ទ្រទេវី នៃរាជបណ្ឌិត្យសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... ក្នុងកិច្ចប្រជុំអាស៊ាននិងដៃគូពាក់ព័ន្ធនៅសិង្ហបុរី ខ្ញុំបានចោទសួរទៅអគ្គនាយក IMF ប្រធានធនាគារពិភពលោក នាយករដ្ឋមន្ត្រីកាណាដា Justin Trudeau និងប្រធានាធិបតី Chile ... អំពីតួនាទីរបស់អង្គការពាណិជ្ជកម្មពិភពលោកនៅក្នុងដំណាក់កាលគាំពារនិយមនេះ ... វាមានការពាក់ព័ន្ធជាមួយអាណត្តិរបស់មេដឹកនាំតាមប្រទេសដែលមេដឹកនាំមួយអាចធ្វើតាមរបៀបមួយ ដល់មេដឹកនាំថ្មីមកក៏កែសម្រួលគោលនយោបាយ ... **ជាស្ថាប័នសិក្សាស្រាវជ្រាវ យើងត្រូវបន្តសិក្សាឱ្យច្បាស់។ តើគួរចំណាយធនធានធ្វើការសិក្សា(លើប្រធានបទអ្វីដើម្បី)បម្រើស្ថានភាពជាក់ស្តែង។ (លទ្ធផលនៃ)ការសិក្សាគួរត្រូវបានទទួលយកជាធាតុចូលដោយស្ថាប័នអនុវត្ត ហើយនៅកៀកជាមួយគ្នា។ មិនមែនសិក្សាហើយបញ្ជូនឱ្យនាយករដ្ឋមន្ត្រី ហើយនាយករដ្ឋមន្ត្រីជម្រុញឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តទេ។**

ត្រូវដឹងថា នៅពេលដែលយើងកំពុងសិក្សានេះ គោលនយោបាយជាក់លាក់មួយត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល ...។

២១. ឧទ្យានរាជបណ្ឌិត្យសភា តេជោសែនឫស្សីត្រឹប នឹងក្លាយជាតំបន់ទេសចរណ៍

ពិធីដាំកូនឈើនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែនឫស្សីត្រឹប, ១៨ ឧសភា ២០១៨

... ខ្ញុំពិតជាមានមោទនភាពដែលយើងបានរួមគ្នាបង្កើតឡើងនូវស្ថានភាពនេះ។ ទោះបីថាពេលនេះ **តំបន់នេះមិនទាន់ជាទីចាប់អារម្មណ៍របស់មនុស្សមួយចំនួនក៏ដោយ ខ្ញុំគិតថាក្នុង ៥ឆ្នាំឬ ១០ឆ្នាំក្រោយទៀត តំបន់នេះអាចក្លាយទៅជាតំបន់ទេសចរណ៍ប្រកបដោយភាពទាក់ទាញ**។ ប្រហែលជាពេលនោះ នៅខេត្តព្រះវិហារនេះ យើងនឹងមានសណ្ឋាគារមួយចំនួនទៀត ដែលនៅមិនឆ្ងាយពីទីនេះរាប់ទាំងនៅស្រុក ព្រោះទេសចរត្រូវការខ្លាំងការដើរក្នុងព្រៃ ដែលគេអាចមើលសត្វព្រៃនៅក្នុងពេលវេលាយប់។ យើងអាចនឹងធ្វើជាតំបន់ដែលមានការទាក់ទាញក្នុងវិស័យទេសចរណ៍ ...។

២២. បណ្តុះបណ្តាលភាសាចិនតបទៅកំណើននិងយោគនិងទេសចរចិន

ពិធីពិសារអាហារសាមគ្គីជាមួយសមាគមខ្មែរ-ចិន, ១០ មេសា ២០១៨

... រាជបណ្ឌិត្យសភាកម្ពុជា បានធ្វើទំនាក់ទំនងជាមួយបណ្តាសាកលវិទ្យាល័យនៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីបណ្តុះបណ្តាលគ្រូកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ហើយយកអ្នកទាំងនោះធ្វើជាជើមទុន ក្នុងការបណ្តុះបណ្តាលភាសាចិននៅរាជបណ្ឌិតសភាកម្ពុជា។ សង្ឃឹមថាលោកឧកញ៉ា ពង្ស ខៀវសែ និងជាប្រធានសមាគម នឹងធ្វើការសហការជិតស្និទ្ធជាមួយបណ្ឌិតសភាចារ្យ សុខ ទូច ដើម្បី**រកមធ្យោបាយរួមគ្នាជម្រុញបណ្តុះបណ្តាលភាសាចិនឲ្យបានលឿន តាមដែលអាចធ្វើទៅបានដើម្បីឆ្លើយតបនឹងកំណើននិយោគពីសាធារណរដ្ឋប្រជាមានិតចិន ក៏ដូចជាកំណើនដ៏ឆាប់រហ័សនៃទេសចរចិនមកកាន់ព្រះរាជាណាចក្រកម្ពុជា ...។**

២៣. គម្រោង "អគារឥន្ទ្រទេវី" មានតម្លៃខ្ពស់លើសការគ្រោងទុក

សម្ពោធអគារឥន្ទ្រទេវី នៃរាជបណ្ឌិត្យសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... សុំការអធ្យាស្រ័យពីសំណាក់រាជបណ្ឌិត្យសភា ដែលរយៈពេលកន្លងទៅនេះ ឆ្លងកាត់មក ២០ឆ្នាំ ទោះបីជាមានការយកចិត្តទុកដាក់ ក៏រាជបណ្ឌិត្យសភារបស់យើង គ្មានកន្លែងធ្វើការឱ្យសក្តិសមទៅនឹងស្ថាប័នជាស្ថាប័នឧក្រិដ្ឋរបស់ជាតិទេ។ ដូច្នេះហើយបានជា**នៅឆ្នាំ២០១៧ ខ្ញុំឃើញថាមានការចាំបាច់នឹងកសាងនូវអគារមួយសម្រាប់រាជបណ្ឌិត្យសភា។ កាលពីពេលនោះ យើងគូសប្លង់ក្នុងកម្រិតតម្លៃប្រហាក់ប្រហែល ៤ទៅ ៥លានដុល្លារទេ ក៏ប៉ុន្តែការថែមថយចុះឡើងៗ ឥឡូវអគារនេះឡើងតម្លៃទៅដល់ប្រមាណ ១០លានដុល្លារ ហើយដែលនឹងត្រូវសម្រេចឱ្យចប់នៅឆ្នាំ២០២០ ខាងមុខ**។ ពេលនោះ យើងនឹងមានកន្លែងធ្វើការគ្រប់គ្រាន់។ សម្រាប់អគារនេះ ខ្ញុំបានធ្វើការជាមួយលោកឧកញ៉ា ពង្ស ខៀវសែ សុំការគាំទ្រខាងហិរញ្ញវត្ថុ និងបានប្រសិទ្ធនាមថា "អគារឥន្ទ្រទេវី" ...៕

២៤. រាជបណ្ឌិត្យសភា ធ្វើការស្រាវជ្រាវផងបណ្តុះបណ្តាលផង

សម្ពោធអគារឥន្ទ្រទេវី នៃរាជបណ្ឌិត្យសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... ស្ថាប័នស្រាវជ្រាវមួយនេះ មានអាយុកាល ២០ឆ្នាំ។ បើនិយាយពីមនុស្សគឺពេញកំលោះឬក៏ក្រមុំហើយ។ កាលពីរយៈពេលកន្លងទៅនេះ **យើងបានចូលរួមចំណែកច្រើនក្នុងការស្រាវជ្រាវ ក៏ដូចជាការចូលរួមចំណែកក្នុងការបណ្តុះបណ្តាលធនធានមនុស្ស។ មុខងារ២ ដែល(រាជបណ្ឌិត្យសភា)បានធ្វើនៅទីនេះ គឺមុខងារស្រាវជ្រាវនិងមុខងារនៃការបណ្តុះបណ្តាល ... ទីនេះជាការដោះដូរដើម្បីគ្នារវាងសាលានយោបាយរបស់គណបក្សប្រជាជន និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ** ... កាលដើមឡើយ ទាំងផ្នែកម្ខាងដែលជាចំណែកមួយនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ គឺជាសាលាគណបក្សប្រជាជនកម្ពុជា ... ជាជំនួយរបស់បក្សកុម្មុយនីស្តវៀតណាម ... យើងមិនអាចប្រើប្រាស់អស់។ ខ្ញុំក៏បានផ្តល់អគារនេះជាផ្នែកមួយនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ... មិនមែនគណបក្សប្រជាជនយក(ដី)វិទ្យាល័យបឹងត្របែកដោយគ្មានការដោះដូរទេ ...៕

២៥. ប្រទេសធំទាំង៥ ចង់បានទីតាំងរាជបណ្ឌិត្យសភាពេលនោះ ជាទីបញ្ជាការអ៊ុនតាក់

សម្ពោធអគារឥន្ទ្រទេវី នៃរាជបណ្ឌិត្យសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... សម័យថ្ងៃមួយ អ៊ុនតាក់ ចង់ជួល(ទីតាំងនេះ)។ ខ្ញុំនិយាយប្រវត្តិកន្លែងហ្នឹងបន្តិច។ ប្រកែកគ្នាពេញហ្នឹង។ ពាក្យ(របស់ខ្ញុំ)តែមួយម៉ាត់ទេ ធ្វើឱ្យ អ៊ុនតាក់ និងប្រទេសធំទាំង៥ ដកថយភ្លាម ... ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ប្រជុំនៅមហាប្រាសាទខេមរិន្ទ ដឹកនាំអង្គប្រជុំដោយ ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ដែលពេលនោះ ព្រះអង្គជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់/SNC និង យ៉ាស៊ូស៊ី អាកាស៊ី ដែលជាប្រធានអ៊ុនតាក់។ **ដោយសារគ្មានទីតាំងធ្វើទីបញ្ជាការ ប្រទេសធំទាំង៥ ទាមទារឱ្យខ្ញុំផ្តល់កន្លែងនេះសំរាប់ជា Headquarters របស់ អ៊ុន តាក់ ដោយគិតប្រាក់ឈ្នួលក្នុងមួយខែ ៥០ម៉ឺនដុល្លារសហរដ្ឋអាមេរិក ... ខ្ញុំមិនយល់ព្រមចំពោះសំណើនេះទេ ... ខ្ញុំបានតបថា "ប្រសិនបើឯកឧត្តមត្រូវការក៏សូមអញ្ជើញយកទៅចុះ។ ប៉ុន្តែ ខ្ញុំសូមលាលែងចេញពីតំណែង មុនពេលដែលនិស្សិតធ្វើបាតុកម្មប្រឆាំងជាមួយខ្ញុំ"។ ភ្លាមនោះ ទាំងអស់គ្នាលើកដៃថា "អត់ទេ យើងខ្ញុំត្រូវការឯកឧត្តមជាងអគារ"** ...៕

២៦. ស្នើសុំក្រសួងអប់រំកាត់មួយផ្នែកធ្វើរាជបណ្ឌិត្យសភា

សម្ពោធអគារឥន្ទ្រទេវី នៃរាជបណ្ឌិត្យសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... បើអត់ ហ៊ុន សែន អ្នកណាដឹកនាំអនុវត្តកិច្ចព្រមព្រៀងប៉ារីស? និយាយឱ្យវាពិត។ ហ៊ុន សែន ជាអ្នកទៅចរចាចុះហត្ថលេខាជាមួយនឹងតួអង្គផ្សេងៗ ទៀតដែលខាងរដ្ឋកម្ពុជាមាន ៦នាក់ និងខាងត្រីភាគីមាន ៦នាក់ រួមទាំងមានប្រទេសដទៃទៀត ... និស្សិតកំពុងតែរៀននៅ(សាលា)ហ្នឹង។ ពួកគាត់មកទារឱ្យយើងដេញនិស្សិតចេញ ដើម្បីធ្វើជាមូលដ្ឋានរបស់ អ៊ុន តាក់។ **(ដោយសារតែប្រតិកម្មរបស់ខ្ញុំនោះហើយ)បានវាគង់វង់អញ្ចឹង។ ក្រោយមក ដោយមានតម្រូវការនៃការបង្កើតរាជបណ្ឌិត្យសភា ខ្ញុំក៏បានពិភាក្សាជាមួយនឹងក្រសួងអប់រំ ស្នើសុំកាត់មួយផ្នែកយកមកធ្វើរាជបណ្ឌិត្យសភា។** ពេលមុននោះ ចង់ពង្រីកដីដែរ ប៉ុន្តែដីនោះរបស់ក្រសួងការពារជាតិ ... ដីរបស់យើងក៏វាធំណាស់ដែរ តែអគាររបស់យើងគឺវាត្រង់នេះបន្តិចត្រង់នោះបន្តិច។ អញ្ចឹងទេ ឥឡូវយកដកអគារខ្លះចេញ ហើយយើងដាក់អគារធំៗមកជំនួស ...៕

២៧. ត្រូវមានសង្គតិភាពនៃការស្រាវជ្រាវ

សម្ពោធអគារឥន្ទ្រទេវី នៃរាជបណ្ឌិត្យសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... តើរាជបណ្ឌិត្យសភាត្រូវស្រាវជ្រាវនិងផ្សារភ្ជាប់(បកគំហើញ)របៀបម៉េច? **សង្ឃឹមថា ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ធ្វើការសម្រុះសម្រួលជាមួយរាជបណ្ឌិត្យសភា ... តើអ្វីដែលស្រាវជ្រាវបានត្រូវយកទៅណា ផ្គុំគ្នានៅកន្លែងណា ព្រោះមិនអាចឱ្យអង្គភាពនោះមកចំណុះស្ថាប័ននេះ ហើយស្ថាប័ននេះទៅចំណុះអង្គភាពនោះបានទេ។ ត្រូវតែមានសង្គតិភាពនៃការស្រាវជ្រាវ ... បើមិនដូច្នេះទេ ស្ថាប័ននេះស្រាវជ្រាវ(រឿងនេះ)ថាត្រូវ ស្ថាប័ននោះក៏ថាត្រូវ ហើយដល់ទៅ(ត្រូវ)គ្រប់ទិដ្ឋភាពទាំងអស់ ក៏បង្កើតទៅជាជំងឺឡប់** ។ ខ្ញុំជាមនុស្សម្នាក់ដែលចូលចិត្តស្រាវជ្រាវ ហើយចូលចិត្តវាយតម្លៃសភាពការណ៍ ... អ្នកដែលតែងធ្វើដំណើរជាមួយខ្ញុំទៅចរចា (រកដំណោះស្រាយនយោបាយសំរាប់បញ្ហាកម្ពុជា) កាលពីទសវត្សរ៍ ៨០ ហោចណាស់មាន សម្តេចទៀបាញ់ ឯកឧត្តម ឱឥតមន្ទី ... មុនចេញដំណើរទៅ (យើង)បានតែវាយតម្លៃពីលទ្ធភាពថាភាគីម្ខាងទៀតនឹងលើកពីបញ្ហាអ្វីខ្លះ ចំណុចអីខ្លះ និងតើការឆ្លើយតបរបស់យើងយ៉ាងណា។ ហ៊ុន សែន បានសរសេរដាក់ក្នុងហៅប៉ៅម្នាក់មួយដើម្បីកុំឱ្យអ្នកនេះឆ្លើយអញ្ចេះ ហើយអ្នកនោះឆ្លើយអញ្ចុះ ... ។

២៨. ត្រូវលើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវ

សម្ពោធអគារឥន្ទ្រទេវី នៃរាជបណ្ឌិត្យសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... **ត្រូវតែបន្តឹង(ការប្រឡង)។ មិនមែនបានសេចក្តីថាយើងមិនចង់ឱ្យជាប់នោះទេ។ អ្នកណាមានលទ្ធភាព(ពិតប្រាកដ)គឺជាប់** ។ កាលពីមុន នៅសាកលវិទ្យាល័យមួយនោះ ឃើញតែ(ទទួលបានសញ្ញាបត្រ)ថ្នាក់នេះថ្នាក់នោះពេញ។ ទីចុងបំផុត អ្នកទាំងនោះមិនទាំងបានទៅរៀនផង។ ចម្លងតគ្នា។ អញ្ចឹងទៅវាទៅជាជាប់ទាំងអស់ទៅ ... សារណាចម្លងតាមគ្នាទាំងអស់។ ជាក់ទៅ។ គ្រូមានពេលឯណាមើល។ ចេះតែឱ្យជាប់។ ចេះតែទៅប្រគល់សញ្ញាបត្រឱ្យទៅ ... ដល់អញ្ចឹងវាអត់មានគុណភាព។ **ឯអ្នកខ្លះទៀតអត់មានយកបណ្ឌិតអីទេ តែមានការស្រាវជ្រាវ**

ផ្ទាល់របស់គេ។ យើងត្រូវមានការលើកទឹកចិត្តឱ្យមានការ(សិក្សា)ស្រាវជ្រាវ។ យើងខិតខំរៀបចំឱ្យមានបណ្ណាល័យ ... ។

២៩. ត្រូវមានក្រុមជំនាញបកប្រែឯកសារជាខេមរភាសា សំរាប់អ្នកមិនចេះភាសាបរទេស

សម្ពោធអគារឥន្ទ្រទេវី នៃរាជបណ្ឌិត្យសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... រាជបណ្ឌិត្យសភា ថ្ងៃក្រោយរៀបចំឱ្យមានបណ្ណាល័យពេលដែលយើងមានអគារធំ ... ដែលអាចទាក់ទាញអ្នកសិក្សាឱ្យចូលស្រាវជ្រាវនៅកន្លែងហ្នឹង។ ខ្ញុំគាំទ្រ ហើយនឹងផ្តល់ថវិកា។ សូមឯកឧត្តមអូន ព័ន្ធមុនីរ័ត្ន **ធ្វើការកត់សម្គាល់(អំពីការ)បកប្រែឯកសារនានាជាខេមរភាសា បោះពុម្ពនិងយកទៅដាក់នៅរាជបណ្ឌិត្យសភា ព្រមទាំងចែកចាយទៅតាមបណ្ណាល័យនានា ព្រោះមិនមែនគ្រប់រូបចេះភាសា(បរទេសនោះ)ទេ។ ជួនកាលយកសៀវភៅរបស់គេមកបានត្រឹមតែ ១០០ច្បាប់។ បើសិនជាយើងបោះចេញជាភាសាខ្មែរបានច្រើនពាន់/ម៉ឺនច្បាប់ ចែកចាយទូលំទូលាយឱ្យប្រជាជនអាន ដោយអ្នកមិនចេះភាសាបរទេសក៏អាចជាភាសាខ្មែរបាន។ ត្រូវមានក្រុមជំនាញធ្វើការបកប្រែចេញជាភាសាខ្មែរ** ។ ខ្ញុំគាំទ្រកិច្ចការហ្នឹង ... ។

៣០. រាជបណ្ឌិត្យសភា រៀបចំបន្ទប់ពិសោធន៍ និងបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍

សម្ពោធអគារឥន្ទ្រទេវី នៃរាជបណ្ឌិត្យសភាកម្ពុជា, ២១ វិច្ឆិកា ២០១៩

... សូមអបអរសាទរជាមួយជ័យលាភីដែលទទួលបានគោរមងារក៏ដូចជាសញ្ញាបត្រនៅថ្ងៃនេះ។ **ចំពោះសំណូមពរទាំងពីរស្តីពី ទី១ ការរៀបចំបន្ទប់ពិសោធន៍មានបំពាក់គ្រឿងបរិក្ខាបម្រើឱ្យរាល់ការងារស្រាវជ្រាវបង្កាត់ពូជរុក្ខជាតិជាដើម មានតម្លៃប្រមាណ ២០ម៉ឺនដុល្លារអាមេរិក ខ្ញុំយល់ព្រម(តាមសំណើ) ហើយសុំឱ្យឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន ដាក់ចូលក្នុងផែនការថវិកាសម្រាប់ឆ្នាំ២០២០ និង ទី២ ការស្នើសុំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៅរាជបណ្ឌិត្យសភា។** សូមគាំទ្រនិងសូម(ផ្តល់អនុសាសន៍អោយ) ធ្វើការងារជាមួយក្រសួងទេសចរណ៍។ ម្យ៉ាងមិញឃើញ ឯកឧត្តម សុខ ទូច បញ្ជូន(សារ)ទៅឱ្យខ្ញុំថា បានធ្វើការជាមួយនឹងក្រសួងទេសចរណ៍សម្រាប់បម្រើឱ្យការសិក្សាជំនាញលើវិស័យទេសចរណ៍ ដែលនេះជាផ្នែកមួយនៃការចូលរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្ស ... ។

២១. រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

១	កំណែទម្រង់សេដ្ឋកិច្ច ចាប់ផ្តើមពីកំណែទម្រង់ដីធ្លី	៣៩៩
២	ជំលោះដីធ្លីលេចធ្លោនៅពេលប្រទេសមានសន្តិភាពឆ្នាំ ១៩៥៩/១៩៦០	៣៩៩
៣	មានសន្តិភាព មានការអភិវឌ្ឍន៍, មានការអភិវឌ្ឍន៍ ក៏កើតជំលោះដីធ្លី	៤០០
៤	សង្គ្រាមផ្ទុះ លែងចង់បានដី និងប្រើពេល១០ឆ្នាំ ធ្វើកំណែទំរង់ដីធ្លី	៤០០
៥	ដល់ដំណាក់កាលកសាងអគារស្ថាប័នបម្រើសេវាប្រជាជន	៤០១
៦	ចេញប័ណ្ណកម្មសិទ្ធ ស្រាយជាម្លោះដីធ្លីក្រៅប្រព័ន្ធតុលាការផ្តល់ដីសម្បទានសង្គមកិច្ច	៤០១
៧	ចុះបញ្ជីដី ធ្វើបណ្ណកម្មសិទ្ធ ដើម្បីការកាន់កាប់ដីធ្លីដោយសុវត្ថិភាព	៤០២
៨	ត្រូវចាត់ទុកដីប្រជាជនមិនទាន់ចុះបញ្ជីជា “សោរចាំបាច់ ឬជាសោរតម្រូវការ”	៤០២
៩	ការផ្ទេរកម្មសិទ្ធកម្ម ជាសោរតម្រូវការ ដែលត្រូវធ្វើអោយបានរហ័សរហួន	៤០៣
១០	សង់លំនៅហានតម្លៃសមរម្យ និងលើកលែងពន្ធផ្ទះតម្លៃក្រោម ៧ម៉ឺនដុល្លារ	៤០៣
១១	ផ្តល់ដីសម្បទានសង្គមកិច្ច ... កសាងផ្ទះជូនក្រុមគ្រួសារកម្លាំងប្រដាប់អាវុធ	៤០៤
១២	គ្រប់គ្រងដីរុនតាឯក ... ដោះស្រាយការរើចេញពីតំបន់អង្គរ និងការបែកគ្រួសារ	៤០៤
១៣	ប្រគល់ដីរុនតាឯកឱ្យអប្សរាគ្រប់គ្រង ត្រៀមសំរាប់ការបំបែកគ្រួសារ/តាំងទីលំនៅថ្មី	៤០៥
១៤	ការតាំងលំនៅថ្មីនៅរុនតាឯក ជាគោលនយោបាយត្រូវការពេលអនុវត្ត១០ឆ្នាំ	៤០៥
១៥	គោលនយោបាយ៩ទាក់ទងការផ្លាស់ទីលំនៅពីតំបន់អង្គរមករុនតាឯកនិងពាក់ស្នែង	៤០៦
១៦	អភិបាលខេត្តតំបន់ទន្លេសាបត្រូវពិនិត្យនិងទប់ស្កាត់ការកាប់រានដីព្រៃលិចទឹក	៤០៦
១៧	ដកដីដែលត្រូវបានកាប់ទន្ទ្រាន ដាំកូនឈើជាគំរបព្រៃ ជាជម្រកត្រីពងតំបន់ទន្លេសាប	៤០៧
១៨	រៀបក្រុមការងារស្ថាប័នចុះពិនិត្យនិងដកហូតដីដែលការពារលោភបំពានក្នុងតំបន់ទន្លេសាប	៤០៧
១៩	ហាមបង្កបង្កើនផលលើដីដែលបានដកហូត ចាប់ខ្លួនអ្នកបំពានបទប្បញ្ញត្តិរបស់រដ្ឋ	៤០៨
២០	ចាប់និងបញ្ជូនជនល្មើសក្នុងក្របខណ្ឌកាប់ព្រៃលិចទឹកតំបន់ទន្លេសាបទៅតុលាការ	៤០៩
២១	បើធ្វើសកម្មភាពគ្មានព្រែងរំអិលច្បាប់របស់ប្រទេសជាតិ មិនសមធ្វើជាមន្ត្រីទៀតទេ	៤០៩
២២	ការដោះស្រាយដីធ្លីក្នុងតំបន់ទន្លេសាបនៅសេសសល់តិច	៤១០
២៣	កែសំរួលព្រំប្រទល់តំបន់ ធ្វើលទីតាំងដីរស់នៅពីយូរលង់ឲ្យចប់ចុងខែឧសភា២០២៣	៤១០
២៤	មិនគប្បីសង់សំណង់ខ្ពស់ជាងដើមឈើទេ នៅលើបណ្តាកោះ	៤១១
២៥	បណ្តាកោះទាំងអស់ជាសម្បត្តិរបស់រដ្ឋ មិនត្រឹមតែកោះរុងមួយទេ	៤១១

២៦	ក្បាលដីលើកោះរុងមិនទាន់ចេញប័ណ្ណកម្មសិទ្ធ ដោយមានវិវាទឬពិនិត្យអត្តសញ្ញាណ	៤១២
២៧	ការកាប់ព្រៃយកដី កើតមានលើកោះមួយចំនួន តែលើកោះរុងច្រើនជាងគេ	៤១២
២៨	គម្រោងផ្លាស់ប្តូរទីតាំងឲ្យប្រជាពលរដ្ឋ ករណីបានរស់នៅមុនចុះហត្ថលេខា២០០៨	៤១៣
២៩	លើកោះរុង មានសណ្ឋាគារផ្កាយ៥ និងបញ្ចប់ភាពអនាធិបតេយ្យទន្ទ្រានដីធ្លី	៤១៣
៣០	ត្រួតពិនិត្យនិងដកហូតត្រឡប់មកវិញកោះទាំងឡាយដែលមិនមានការវិនិយោគ	៤១៤

១. កំណែទម្រង់សេដ្ឋកិច្ច ចាប់ផ្តើមពីកំណែទម្រង់ដីធ្លី

ពិធីប្រកាសដាក់ឱ្យអនុវត្តជំណាក់កាលទី៤៖ គណនេយ្យភាពសមិទ្ធកម្ម
នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២០ មីនា ២០២៣

... **“កំណែទម្រង់សេដ្ឋកិច្ចចាប់ផ្តើមពីកំណែទម្រង់ដីធ្លី”។ វាមិនមែនជាបញ្ហាងាយស្រួលទេ។ ក្នុងរបប ប៉ុល ពត ដីធ្លីទាំងអស់ត្រូវបានរឹបអូសជាសម្បត្តិរដ្ឋ។ ក្រោយរបបប្រល័យពូជសាសន៍ដួលរលំ យើងខ្ញុំគ្មានជម្រើសអ្វីក្រៅតែពីអនុវត្តនូវកិច្ចការទាំងឡាយដើម្បីសង្គ្រោះជីវិតប្រជាជនសិន**។ ពេលនោះ ២០គ្រួសារមានគោមួយនឹម។ តើត្រូវធ្វើរបៀបម៉េចដើម្បីរស់? អ្នកទាំងអស់គ្នាបានឃើញភ្នំពេញសព្វថ្ងៃនេះ កកស្ទះដោយឡាន។ ក៏ប៉ុន្តែ ទីក្រុងភ្នំពេញកាលពី ៤៤ឆ្នាំមុន គ្មានមនុស្សនៅទេ។ (ពីដំណាក់កាលមួយទៅដំណាក់កាលមួយ) យើងឈានដល់ការជម្រុញធ្វើឯកជនភាវូបនីយ៍កម្ម។ តើមនុស្សប៉ុន្មាននាក់ទៅ ដែលបានយល់ពីបញ្ហាសេដ្ឋកិច្ច? បើពេលនោះ មនុស្សមួយចំនួនដែលធ្លាប់រៀននៅភាគខាងជើងវៀតណាម ក្រោយសន្និសីទហ្សឺណែវឆ្នាំ១៩៥៤ ត្រឡប់មកវិញ ដោយនាំមកនូវគំនិតស្តីពីការធ្វើសហករណ៍ ការធ្វើរួម និងចែកផល ...។

២. ជំលោះដីធ្លីលេចធ្លោនៅពេលប្រទេសមានសន្តិភាពឆ្នាំ ១៩៥៩/១៩៦០

បិទសន្និបាតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងសម្ពោធ
ដាក់ឱ្យប្រើប្រាស់ “អគារមន្ទីរពិសោធន៍ជាតិសំណង់”, ២៧ ធ្នូ ២០២២

... ខ្ញុំតែងតែមានសំណូមពរជាបន្តបន្ទាប់ឱ្យយកចិត្តទុកដាក់ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ការដោះស្រាយវិវាទដីធ្លី មិនមែនជាបញ្ហាថ្មីថ្មោងទេ។ បើពិនិត្យពីសារបាន **ជំលោះដីធ្លីបានលេចធ្លោឡើងនៅពេលដែលប្រទេសមានសន្តិភាព**។ នោះអាចនិយាយបានថាក្នុងឆ្នាំ១៩៥៩ ... ក្រោយឯករាជ្យឆ្នាំ១៩៥៣ បញ្ហាជំលោះដីធ្លីវាមិនទាន់កើតទេ។ ប៉ុន្តែបើយោងទៅលើប្រវត្តិសាស្ត្រប្រទេសរបស់យើង ជំលោះដីធ្លីបានកើតមាននៅពេលដែលប្រទេសមានសន្តិភាពនោះឯង។ (ជំលោះ)ដែលគានតឹង និងដែលគេតែងតែលើកមកនិយាយគឺ**ជំលោះនៅតំបន់សំឡូតនាឆ្នាំ១៩៥៩/១៩៦០** ដែលបង្កើតបានជាចលនាប្រឆាំងរដ្ឋាភិបាលដ៏ខ្លាំងនៅពេលដែលអ៊ិន តាំ ធ្វើជាអភិបាលខេត្តបាត់ដំបង ...។

៣. មានសន្តិភាព មានការអភិវឌ្ឍន៍, មានការអភិវឌ្ឍន៍ ក៏កើតជំលោះដីធ្លី

បិទសន្និបាតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងសម្ពោធ
ដាក់ឱ្យប្រើប្រាស់ "អគារមន្ទីរពិសោធន៍ជាតិសំណង់", ២៧ ធ្នូ ២០២២

... ជំលោះដីធ្លីនេះដែរ បានលាតសន្ធឹង(សឹងតែទូទាំងប្រទេស)។ សូម្បីតែខ្លួនខ្ញុំក៏ធ្លាប់ដឹកនាំបាតុកម្មប្រឆាំង លោកជំទាវ តុប ជាប្អូនរបស់សម្តេចចក្រី ដូឡុង នៅចំការថ្មី មេមុត ដែលបំពានលើដីធ្លីរបស់ខ្ញុំ។ ខ្ញុំត្រូវបានប៉ូលីសដេញតាមចាប់ ហើយបានរត់ធ្លាក់ដល់ខេត្តក្រចេះ។ បានសេចក្តីថា **ខណៈដែលប្រទេសយើង** មានសន្តិភាព ប្រជាពលរដ្ឋបានស្វះស្វែងរកដីនៅកន្លែងនេះ/នោះ ទន្ទឹមនឹងនោះ អ្នកមានគេក៏ពង្រីកសកម្មភាពដីធ្លីរបស់គេ ហើយមន្ត្រីរាជការធំៗ ក៏ដើររកដីដែរ។ ការនោះបង្កើតជាជំលោះដីធ្លីនៅច្រើនកន្លែង។ **នេះគឺជារឿងពិតដែលបានកើតឡើង។ ដោយសារតែមានសន្តិភាព ក៏មានការអភិវឌ្ឍន៍ឡើង។ ដល់ទៅមានការអភិវឌ្ឍន៍ឡើង គឺជំលោះដីធ្លីចាប់ផ្តើម**។ មិនមែនជារឿងថ្មីថ្មោងទេ ...។

៤. សង្គ្រាមផ្ទុះ លែងចង់បានដី និងប្រើពេល១០ឆ្នាំ ធ្វើកំណែទំរង់ដីធ្លី

បិទសន្និបាតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងសម្ពោធ
ដាក់ឱ្យប្រើប្រាស់ "អគារមន្ទីរពិសោធន៍ជាតិសំណង់", ២៧ ធ្នូ ២០២២

... ដីទាំងនេះក៏ត្រូវបានបោះបង់ចោល ពេលដែលប្រទេសបាត់បង់សន្តិភាព ... **នៅឆ្នាំ១៩៧០ ពេលដែលសង្គ្រាមផ្ទុះភ្លាម គ្មានអ្នកណាចង់បានដីទៀតទេ មានតែរត់ចោលដី។ ឆ្នាំ១៩៧៩ យើងជូនលុយប្រជាជនដើម្បីឱ្យទៅធ្វើស្រែ**។ ប្រហែលជានៅលើពិភពលោកនេះ មិនមានប្រទេសច្រើនទេ ... ដែលបានជូនលុយប៉ុន្មានដើម្បីឱ្យប្រជាពលរដ្ឋទៅពង្រីកដីក្នុងមួយហិកតា។ បន្ថែមលើនោះ **ប៉ុល ពត បានធ្វើបដិរូបដីស្រែ/ចំការ ដោយដីទាំងអស់ប្រែទៅជីរបស់រដ្ឋ។ រឿងនេះយើងត្រូវធ្វើការ ១០ឆ្នាំដើម្បីកែទម្រង់** ... មិនអាចអ្នកណាបដិសេធតួនាទីរបស់ ហ៊ុន សែន លើការកែទម្រង់ដីធ្លីនេះបានទេ។ ក្នុងរវាងឆ្នាំ១៩៧៩–១៩៨៩ ទើបយើងដកហូតចេញពីរដ្ឋធម្មនុញ្ញនូវការកំណត់ថាដីជារបស់រដ្ឋ និងចាប់ផ្តើមពីឆ្នាំ១៩៨៩ ទើបយើងបានផ្តល់កម្មសិទ្ធឱ្យប្រជាជន។ ពីពេលនោះមក ជំលោះដីធ្លីចេះតែកើតបន្តិចម្តង ហើយជំលោះដីធ្លីកើតឡើងធំ ពេលដែលប្រទេសកម្ពុជាបញ្ចប់សង្គ្រាម ...។

៥. ដល់ដំណាក់កាលកសាងអគារស្ថាប័នបម្រើសេវាប្រជាជន

សម្ពោធអគារក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់, ០៨ វិច្ឆិកា ២០២១

... ពេលមុននេះ សូម្បីតែទីស្តីការគណៈរដ្ឋមន្ត្រី ក៏ខ្ញុំមិនធ្វើដែរ។ ខ្ញុំបាននិយាយថា តម្រូវការពេលនេះមិនមែនកន្លែងធ្វើការល្អទេគឺវិនិយោគជួយប្រជាជន។ អំពីការរៀបចំស៊ីហ្គេម ក៏ខ្ញុំបានប្រកាសដែរ។ ខ្ញុំបានស្នើទៅមេដឹកនាំអាស៊ាន ឱ្យមានការយោគយល់ ព្រោះខ្ញុំត្រូវការលុយដើម្បីធ្វើផ្លូវ លុយធ្វើស្ពាន លុយធ្វើប្រឡាយទឹក លុយធ្វើសាលារៀន ធ្វើមន្ទីរពេទ្យ មិនទាន់មានលុយធ្វើស៊ីហ្គេមទេ។ ដោយហេតុនេះហើយ បានជាយើងលើកទៅធ្វើនៅឆ្នាំ២០២៣។ ពេលហ្នឹង ប្រធានាធិបតីឥណ្ឌូនេស៊ីប្រើពាក្យថា "ត្រឹមត្រូវ"។ ប៉ុន្តែឥឡូវនេះ **មិនអាចដូចមុនបានទេ។ ផ្ទះប្រជាជនឡើងដល់ណាដល់ណីហើយ។ យើងទុកស្ថាប័ន(វង្វេ)ឱ្យនៅតូចតាច ... វាមិនសមស្របនឹងជាទីកន្លែងបម្រើសេវាប្រជាជន។ ដូច្នេះ យើងក៏មានការតម្រូវអោយសាងសង់** ...។

៦. បន្តចេញបណ្ណកម្មសិទ្ធ ស្រាយជម្លោះដីធ្លីក្រៅប្រព័ន្ធតុលាការ និងផ្តល់ដីសម្បទានសង្គមកិច្ច

សម្ពោធអគារក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់, ០៨ វិច្ឆិកា ២០២១

... សូមផ្តាំការងារ៣។ **ទី១ បន្តខិតខំចេញប័ណ្ណកម្មសិទ្ធិ(ដីធ្លី) ... ទី២ ខិតខំដោះស្រាយជម្លោះដីធ្លីដែលនៅសេសសល់ឬកើតមាន ដោយខំសម្រុះសម្រួលក្រៅប្រព័ន្ធតុលាការ**។ បើតែចូលដល់តុលាការ វាមានឈ្នះវាមានចាញ់។ បើដោះក្រៅប្រព័ន្ធតុលាការមិនអីទេ ... ខិតខំដោះស្រាយជម្លោះដីធ្លីក្រៅប្រព័ន្ធតុលាការ ហើយត្រូវមានសុច្ចរិតភាពក្នុងការដោះស្រាយ។ បើមានសុច្ចរិតភាពយើងនឹងដោះស្រាយបានបញ្ហា ... **ការងារទី៣ ខិតខំដោះស្រាយបញ្ហាដីសម្បទានសង្គមកិច្ចឲ្យអ្នកខ្វះដីធ្លី** ដែលជាកិច្ចការអាទិភាពមួយក្នុងចំណោមកិច្ចការអាទិភាពដែលត្រូវធ្វើ។ យើងបានធ្វើផ្ទះសំបែងឲ្យ និងត្រូវរៀបចំដីធ្លីជូនអ្នកខ្វះដី ...។

៧. ចុះបញ្ជីដី ធ្វើបណ្ណកម្មសិទ្ធ ដើម្បីការកាន់កាប់ដីធ្លីដោយសុវត្ថិភាព

បិទសន្និបាតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងសម្ពោធដាក់ឱ្យប្រើប្រាស់ "អគារមន្ទីរពិសោធន៍ជាតិសំណង់", ២៧ ធ្នូ ២០២២

... ខ្ញុំបានទទូចឲ្យធ្វើកិច្ចការ(ចុះបញ្ជីដី ធ្វើបណ្ណកម្មសិទ្ធជាលក្ខណៈប្រព័ន្ធក្តី ជាលក្ខណៈដាច់ដោយដុំក្តី)នេះ ឲ្យបានសម្រេចដូចដែលបានគ្រោងទុកក្នុងនេះ នៅឆ្នាំ២០២៣។ ចំណុចសេសសល់របស់យើង នៅមិនច្រើនទេ។ វានៅតិច ប៉ុន្តែកន្លែងខ្លះ**យើងហាក់ដូចជាពន្យាការធ្វើកិច្ចការនេះ។ ទោះបីការចុះបញ្ជី ឬធ្វើបណ្ណកម្មសិទ្ធជាលក្ខណៈប្រព័ន្ធក្តី ជាលក្ខណៈដាច់ដោយដុំក្តី គឺហាក់ដូចជានៅទ្រឹង ឬធ្វើដែរ ក៏ប៉ុន្តែធ្វើដោយមិនមានការជំរុញ មិនមានសន្ទុះ ដែលធ្វើឲ្យប្រជាជនរង់ចាំ**។ មានការស្នើសុំត្រង់មកខ្ញុំមួយចំនួន តាមហ្វេសប៊ុកក្តី ជួនកាលតាមmessenger ក្តី ... សូមស្នើឲ្យឯកឧត្តមរដ្ឋមន្ត្រី ជា សុផារ៉ា បញ្ជាទៅមន្ទីរៀបចំដែនដីនគរូបនីយ៍កម្មតាមបណ្តាខេត្ត និងឯកឧត្តម លោកជំទាវ អស់លោក**អភិបាលខេត្តយកចិត្តទុកដាក់ធ្វើកិច្ចការនេះ។ នេះជាសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ចៀសវាងការកើតឡើងបញ្ហានានាជាបន្តទៀត** ...៕

៨. ត្រូវចាត់ទុកដីប្រជាជនមិនទាន់បានចុះបញ្ជីជា "សោរចាំបាច់ ឬជាសោរតម្រូវការ"

បិទសន្និបាតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងសម្ពោធដាក់ឱ្យប្រើប្រាស់ "អគារមន្ទីរពិសោធន៍ជាតិសំណង់", ២៧ ធ្នូ ២០២២

... (**ការទទួលបានបណ្ណកម្មសិទ្ធដីធ្លីជា**) រឿងចាំបាច់សម្រាប់ប្រជាពលរដ្ឋរបស់យើង ... **ខ្ញុំមិនប្រើយុទ្ធនាការបែប "គោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី" ដូចពីឆ្នាំ២០១២ នោះទេ។ ប៉ុន្តែខ្ញុំសូមឲ្យអស់លោក ជាពិសេសអភិបាលខេត្ត ប្រធានសុរិយោដី ប្រធានគណៈកម្មាធិការដីថ្នាក់ខេត្ត មើលកិច្ចការងារនេះ ឲ្យបានខ្ជាប់ខ្ជួន។ សូមដោះស្រាយបញ្ហាទាក់ទងដីធ្លីនេះ ដោយដីរដ្ឋក៏ត្រូវមើល ដីសហគមន៍ក៏ត្រូវមើល ហើយដីប្រជាជនដែលមិនទាន់បានចុះបញ្ជីហ្នឹង ក៏ត្រូវធ្វើឲ្យពួកគាត់ ដោយចាត់ទុកថា "នេះជាសោរចាំបាច់ ឬជាសោរតម្រូវការ"**។ (មិនអាច)នៅអង្អែលៗ របៀបទំពាអៀងហ្នឹងបានទេ។ រឿងហ្នឹងក៏សូមឱ្យដាស់តឿនទៅមន្ត្រីខាងក្រោមយកទៅអនុវត្ត ...៕

៩. ការផ្ទេរកម្មសិទ្ធកម្ម ជាសោរតម្រូវការ ដែលត្រូវធ្វើអោយបានរហ័សរហួន

បិទសន្និបាតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងសម្ពោធដាក់ឱ្យប្រើប្រាស់ "អគារមន្ទីរពិសោធន៍ជាតិសំណង់", ២៧ ធ្នូ ២០២២

... រឿងដីធ្លីនេះ ត្រូវចាត់ទុកថាជាការផ្តល់សេវាសាធារណៈ ហើយការផ្តល់សេវាសាធារណៈនៅទីនេះ គឺជា**ការផ្តល់សេវាសាធារណៈប្រភេទ "សេវាចាំបាច់ ឬជាសេវាតម្រូវការ"។ ប្រជាពលរដ្ឋត្រូវការប័ណ្ណកម្មសិទ្ធដីធ្លី។ ហ្នឹងជាសេវាតម្រូវការព្រោះបើគាត់មិនទាន់ច្បាស់ពីកម្មសិទ្ធ គាត់មិនហ៊ានវិនិយោគទេ ហើយមិនមានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីទេ។** ដូច្នេះ អស់លោកត្រូវមើលឃើញផលហ្នឹង ... ការផ្ទេរកម្មសិទ្ធដីធ្លីហ្នឹង ដូចជាផ្ទេរពីឪពុកទៅកូន ផ្ទេរពីជីដូនទៅចៅអី យើងមានគោលនយោបាយសម្រាប់ដោះស្រាយបញ្ហាហ្នឹងហើយ។ **ការផ្ទេរកម្មសិទ្ធ(កម្ម)ក្នុងការលក់ ការដូរនេះ ... យើងក៏ត្រូវធ្វើឲ្យរហ័សរហួន** ជាមួយគ្នាយើងក៏បានពន្ធបង់ប្រថាប់ត្រាដែរ។ បើនៅស្រុកគេ គេបន់ឲ្យតែអ្នកឯងលក់តឲ្យបានលឿន លក់ម្តងពន្ធម្តង។ ...៕

១០. សង់លំនៅឋានតម្លៃសមរម្យ និងលើកលែងពន្ធផ្ទះតម្លៃក្រោម ៧ម៉ឺនដុល្លារ

បិទសន្និបាតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងសម្ពោធដាក់ឱ្យប្រើប្រាស់ "អគារមន្ទីរពិសោធន៍ជាតិសំណង់", ២៧ ធ្នូ ២០២២

... ចំណុច(ស្តីពីគម្រោងសាងសង់លំនៅឋានតម្លៃសមរម្យ សំដៅលើកកម្ពស់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានលំនៅឋានសមរម្យ)នេះ ចែកជា **ទី១ ការលើកទឹកចិត្តអោយមានការសាងសង់លំនៅឋានតម្លៃទាប សំរាប់មន្ត្រីរាជការ ឬក៏ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប អាចមានតម្រូវការលំនៅឋាន ដោយតម្លៃសមរម្យ**។ រកគ្រប់វិធីដោះស្រាយលំនៅឋានក្នុងប្រទេសសំរាប់អ្នកដែលមានប្រាក់ចំណូលមធ្យមឬក៏តូចតាច ដែលពុំមានលទ្ធភាពទិញផ្ទះបានតម្លៃខ្ពស់។ មួយទៀត**យើងក៏បានលើកទឹកចិត្តហើយដែរ អោយមានការលើកលែងពន្ធនៃផ្ទះដែលមានតម្លៃក្រោម ៧ម៉ឺនដុល្លារ** ...៕

១១. ផ្តល់ដីសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋខ្វះដីពិត និងកសាងផ្ទះជូនក្រុមគ្រួសារកម្លាំងប្រដាប់អាវុធ

បិទសន្និបាតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងសម្ពោធដាក់ឱ្យប្រើប្រាស់ "អគារមន្ទីរពិសោធន៍ជាតិសំណង់", ២៧ ធ្នូ ២០២២

... បន្ត**អនុវត្តនូវនយោបាយផ្តល់ដីសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋដែលខ្វះដីពិតប្រាកដ ហើយធ្វើអត្តសញ្ញាណកម្ម ឬកំណត់មុខសញ្ញានៃការផ្តល់ដីឲ្យដើម្បីឲ្យពួកគាត់មានដីពិតប្រាកដក្នុងការកសាងជីវភាព។ មួយទៀត យើងបន្តកសាងផ្ទះជូនក្រុមគ្រួសារកម្លាំងប្រដាប់អាវុធឈរជើងនៅតាមព្រំដែន**។ ជាមួយគ្នានោះ យើងក៏នឹងបន្តកសាងផ្ទះសម្រាប់អតីតយុទ្ធជនដែលឯកឧត្តម គន់ គីម ដឹកនាំការងារនេះ។ ខ្ញុំបានផ្តល់ថវិកាតាមក្រោយជូនកន្លែងនេះបានបន្តិច ជូនកន្លែងនោះបានបន្តិច ក្នុងទស្សនៈថា "ធ្វើបានច្រើនល្អជាងធ្វើបានតិច និងធ្វើបានតិចគ្រាន់បើជាងអត់បានធ្វើ"។ មួយផ្នែកជូនចំពោះអ្នកដែលជាកងទ័ព ឬនគរបាល ឬក៏អាវុធហត្ថឈរជើងតាមព្រំដែន ... តំបន់ព្រះវិហារតំបន់អីហ្នឹង យើងមានផ្ទះសំបែងរាប់ពាន់រាប់ម៉ឺនខ្នងចែកជូនហើយ ...៕

១២. គ្រប់គ្រងដីរុនតាឯកសំរាប់ដោះស្រាយការរើចេញពីតំបន់អង្គរ និងការបំបែកគ្រួសារ

សំណេះសំណាលជាមួយប្រជាពលរដ្ឋស្ម័គ្រចិត្តរើសំណង់ចេញពីតំបន់រមណីយដ្ឋានអង្គរ ទៅតាំងទីលំនៅដ្ឋានថ្មី នៅភូមិរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប, ១៣ កញ្ញា ២០២២

... ខ្ញុំដាក់ចេញគោលនយោបាយជាក់លាក់សម្រាប់ការដោះស្រាយ ... ប្រជាពលរដ្ឋក្នុងតំបន់ហាមឃាត់ដោយលក្ខខណ្ឌរបស់អង្គការ UNESCO ក៏មិនអាចធ្វើអីបានដែរ។ សូម្បីតែផ្ទះមួយដែលឆ្លាប់នៅតែមួយគ្រួសារ ដល់រៀបការហើយក៏មិនអាចឱ្យកសាងផ្ទះថ្មីនៅក្បែរហ្នឹងដែរ ... គួរតែនឹកទៅដល់សម្តេច វិបុលបញ្ញា សុខ អាន ដែលគាត់បានស្នើមកខ្ញុំ**ទិញដីនៅរុនតាឯកនេះ សម្រាប់ដោះស្រាយការចាកចេញរបស់ប្រជាពលរដ្ឋដែលត្រូវរើចេញពីតំបន់អង្គរ និងការដែលត្រូវបែកគ្រួសារ។ ប៉ុន្តែយើងដោះស្រាយបានត្រឹមតែរុនតាឯកទេ។ ឥឡូវនេះ ប្រគល់ឱ្យអប្សារគ្រប់គ្រងដើម្បីត្រៀមទុកឱ្យក្រុមគ្រួសារដែលត្រូវបែក ឱ្យបានទទួលគោលនយោបាយដីធ្លីនៅកន្លែងនោះ និងគោលនយោបាយផ្សេងទៀតសម្រាប់ការដោះស្រាយការតាំងទីលំនៅថ្មី ... ទោះក្រោយពីខ្ញុំ អ្នកបន្តវេនក៏ត្រូវដោះស្រាយរបៀបនេះ ...**៕

១៣. ប្រគល់ដីរុនតាឯកឱ្យអប្សារគ្រប់គ្រង ត្រៀមសំរាប់ការបំបែកគ្រួសារតាំងទីលំនៅថ្មី

សំណេះសំណាលជាមួយប្រជាពលរដ្ឋស្ម័គ្រចិត្តរើសំណង់ចេញពីតំបន់រមណីយដ្ឋានអង្គរ ទៅតាំងទីលំនៅដ្ឋានថ្មី នៅភូមិរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប, ១៣ កញ្ញា ២០២២

... ការ(មានជីរុនតាឯក សម្រាប់ដោះស្រាយការចាកចេញរបស់ប្រជាពលរដ្ឋដែលត្រូវរើចេញពីតំបន់អង្គរនិងដែលត្រូវបែកគ្រួសារ)នេះ មានផលប្រយោជន៍ទាំង ២ទិស។ ទី១ **ប្រទេសជាតិទាំងមូលនឹងទទួលបានផលប្រយោជន៍ពីការការពារបេតិកភ័ណ្ឌ ដែលដូនតាយើងបានកសាងទុកឱ្យយើងរាប់ពាន់ឆ្នាំហើយនៅទីនេះ និងដែលយើងបានដាក់ចូលជាសម្បត្តិបេតិកភ័ណ្ឌពិភពលោក ... ឯចំពោះប្រជាពលរដ្ឋដែលរស់នៅដោយមិនស្របច្បាប់ ក៏នឹងទទួលបានជីជាកម្មសិទ្ធិស្របច្បាប់របស់ខ្លួន ... ជាការជ្រើសរើសរៀងការរស់នៅដោយមិនមានភាពច្បាស់លាស់ ហើយពង្រីកគ្រួសារ ពង្រីកផ្ទះមិនកើត និងការចាកចេញមកតាំងទីលំនៅកន្លែងស្របច្បាប់ និងទទួលបានកម្មសិទ្ធិ** ... នេះជាការទទួលផលប្រយោជន៍របស់ប្រជាពលរដ្ឋ ...៕

១៤. ការតាំងលំនៅថ្មីនៅរុនតាឯក ជាគោលនយោបាយត្រូវការពេលអនុវត្ត ១០ឆ្នាំ

សំណេះសំណាលជាមួយប្រជាពលរដ្ឋស្ម័គ្រចិត្តរើសំណង់ចេញពីតំបន់រមណីយដ្ឋានអង្គរ ទៅតាំងទីលំនៅដ្ឋានថ្មី នៅភូមិរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប, ១៣ កញ្ញា ២០២២

... នេះជាការដាក់ចេញគោលនយោបាយដែលកុំឱ្យមាន ការអនុវត្តដោយកញ្ជក់កណ្តៀតម្តងធ្វើម្តងមិនធ្វើ។ នេះជាដំណើរការគោលនយោបាយរយៈពេលវែង។ **ខ្ញុំសុំប្រើរយៈពេល ១០ឆ្នាំ ក្នុងការអនុវត្តគោលនយោបាយនេះ។ សង្ឃឹមថាក្នុងករណីដែលខ្ញុំចាកចេញពីតំណែង(ជាប្រមុខរាជរដ្ឋាភិបាល) នាយករដ្ឋមន្ត្រី**

ក្រោយដែលចេញពីគណបក្សប្រជាជន ក៏នឹងបន្តអនុវត្តនូវគោលនយោបាយនេះ ... នេះជាគោលនយោបាយរបស់គណបក្សប្រជាជន (ដែលនឹងប្រើ)រយៈពេលមិនតិចជាង ១០ឆ្នាំ។ បើទោះបីចាកចេញពីតួនាទីជានាយករដ្ឋមន្ត្រី ក៏ខ្ញុំនៅតែធ្វើជាប្រធានគណបក្សប្រជាជនដដែល។ ខ្ញុំមានសិទ្ធិត្រួតពិនិត្យសកម្មភាពនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីនានា។ បើធ្វើមិនត្រូវ (បក្សនឹង)ដកចេញ ... និយាយអញ្ចឹងថា (ខ្ញុំ)ត្រៀមបញ្ជាលើនាយករដ្ឋមន្ត្រីក្រោយ។ ការបោះឆ្នោតនៅកម្ពុជា ជាការបោះឱ្យបក្ស។ តទៅ បក្សតែងតាំងនាយករដ្ឋមន្ត្រី ...៕

១៥. គោលនយោបាយ៩ទាក់ទងការផ្លាស់ទីលំនៅពីតំបន់អង្គរមកនៅតាឯកនិងពាក់ស្នែង

សំណេះសំណាលជាមួយប្រជាពលរដ្ឋតាំងទីលំនៅថ្មីនៅតំបន់ រុនតាឯក(លើកទី ៣) ស្រុកបន្ទាយស្រី ខេត្តសៀមរាប, ២១ តុលា ២០២២

... សូមបញ្ជាក់វិធានការដែលត្រូវដោះស្រាយអោយបងប្អូនបានដឹង **ទី១ ការដឹកជញ្ជូនបងប្អូនមកកាន់ទីនេះ ជាបន្ទុករបស់យោធភូមិភាគ៤ និងកងពលធំលេខ២ ... ទី២ ជំនួយឧបត្ថម្ភស្មើៗគ្នាទាំងមុននិងក្រោយ ... (៣) ត្រូវចេញប័ណ្ណកម្មសិទ្ធិឱ្យតែម្តង ព្រោះបងប្អូនត្រូវការយកទៅដាក់នៅធនាគារដើម្បីខ្ចីប្រាក់គេ ... ទី៤ ត្រៀមលក្ខណៈសម្រាប់អ្នកដែលបែកគ្រួសារថ្មី ... ទី៥ ដោះស្រាយតម្រូវការហេដ្ឋារចនាសម្ព័ន្ធនៅកន្លែងនេះ ... ទី៦ សូមមីក្រូហិរញ្ញវត្ថុក៏ដូចជាធនាគារផ្តល់ការយោគយល់សម្រាប់ការឱ្យខ្ចីប្រាក់របស់បងប្អូន ... (៧)** មិនឱ្យមានការរុះរើចេញទេនូវត្តអារាមនៅក្នុងតំបន់(អង្គរ) ... **ទី៨ រាជរដ្ឋាភិបាលមិនឱ្យបងប្អូនទៅឃុំព្រះដាក់រុះរើចេញទេ** ... តែការសង់សំណង់ថ្មី ត្រូវតែគោរពតាមបែបបទរបស់អាជ្ញាធរអប្សរា ... និងចំណុចទាក់ទិនជាមួយបាតបារាយណ៍ ដើម្បីទំលាក់ទឹកខ្លះមក ... និង **ទី ៩ សាលាស្រុកបន្ទាយស្រី ត្រូវរើមកនៅរុនតាឯកដែរ** ...៕

១៦. អភិបាលខេត្តតំបន់ទន្លេសាបត្រូវពិនិត្យមើលនិងទប់ស្កាត់ការកាប់រានដីព្រៃលិចទឹក

សារសម្លេងពាក់ព័ន្ធនឹងបញ្ហាទន្ទ្រានយកដីនៃបឹងទន្លេសាប, ២៨ វិច្ឆិកា ២០២១

... សូមប្រគល់ឱ្យ**អភិបាលខេត្តតាមតំបន់ទន្លេសាប ទទួលខុសត្រូវពិនិត្យមើល និងទប់ស្កាត់ជាបន្ទាន់ការកាប់រានដីព្រៃលិចទឹក ដែលនឹងឈានទៅដល់**

ការកើតឡើងវិញ បន្ទាប់ពីរដូវទឹកសម្រកនេះ ហើយត្រូវគ្រប់គ្រងដីដែលបានកាប់ទន្ទ្រានរួចហើយផង។ អាជ្ញាធរខេត្តត្រូវប្រើប្រាស់ឱ្យអស់លទ្ធភាពទៅតាមដែនសមត្ថកិច្ចរបស់ខ្លួន។ អភិបាលខេត្តក៏ជាប្រធានគណៈកម្មការសូរិយោដីថ្នាក់ខេត្ត ជាមួយនោះក៏មានមន្ទីរជំនាញដែលមានការពាក់ព័ន្ធដូចជាបរិស្ថាន ធនធានទឹក កសិកម្ម និងមន្ទីររៀបចំដែនដី នគរូបនីយកម្មនៅតាមខេត្ត ដែលត្រូវប្រើប្រាស់កម្លាំងក្រោមឱវាទរបស់ខ្លួន មានការគាំទ្រពីកម្លាំងកងទ័ព នគរបាល និងអាវុធហត្ថ ដើម្បីធ្វើការបង្ក្រាប។ ខ្ញុំប្រើពាក្យថា "នេះជាការបង្ក្រាប" មិនមែនជាការអប់រំទេ។ យើងគ្មានពេលវេលាដើម្បីធ្វើការអប់រំបន្ថែមទេ ...៕

១៧. ដកយកដីដែលត្រូវបានកាប់ទន្ទ្រាន ដាំកូនឈើជាគំរបព្រៃ សំរាប់ជាជម្រកត្រីពងក្នុងតំបន់ទន្លេសាប

សារសម្លេងពាក់ព័ន្ធនឹងបញ្ហាទន្ទ្រានយកដីនៃបឹងទន្លេសាប, ២៨ វិច្ឆិកា ២០២១

... ខ្ញុំបានចេញបទបញ្ជាដកយកត្រឡប់មកវិញទាំងអស់នូវដីទាំងឡាយ ដែលបានកាប់(ទន្ទ្រាន)រួចមកហើយ ដូចជា(ករណីដី)នៅខេត្តកំពង់ឆ្នាំង។ ប្រសិនបើរបាយការណ៍នេះខុស ក៏ខ្ញុំសូមអធ្យាស្រ័យ។ ឮថា អតីតអភិបាលខេត្ត(កំពង់ឆ្នាំង)ដែលទើបនឹងចាកចេញពីតំណែងក្នុងប៉ុន្មានខែមុន បានកាប់បំផ្លាញយកដីប្រមាណជាជាង ២.០០០ ហិកតាឯណោះ ... ទោះបីថ្នាក់ណាក៏ដោយ ត្រូវតែប្រមូលដីនេះយកមកវិញទាំងអស់។ ដីនោះត្រូវតែជាកម្មវត្ថុនៃការដាំដើមឈើឡើងវិញនៅពេលក្រោយ ... សង្ឃឹមថា ឯកឧត្តម លោកជំទាវ ទាំងនៅថ្នាក់ខេត្ត ថ្នាក់ជាតិ ស្ថាប័នមានការពាក់ព័ន្ធ នឹងចាត់វិធានការយ៉ាងឆាប់ ... **ត្រូវដកមកវិញនូវដីទាំងឡាយដែលត្រូវបានកាប់បំផ្លាញ ... ទោះបីជាត្រូវលះបង់អ្វី ដោយតម្លៃណា ក៏ត្រូវតែយកដីមកវិញឱ្យបាន។ ដីទាំងនេះ ត្រូវតែបានដាំកូនឈើ ជាគំរបព្រៃឈើ ដែលត្រូវការពារឱ្យក្លាយជាព្រៃ រក្សាជាជម្រកត្រីពងក្នុងតំបន់ទន្លេសាប** ដូចដែលយើងបានធ្វើរួចមកហើយ ...៕

១៨. រៀបចំក្រុមការងារនិងស្ថាប័នពាក់ព័ន្ធ ចុះពិនិត្យនិងដកហូតដី រងការរំលោភបំពានក្នុងតំបន់កំណត់និងត្រូវការពារនៃតំបន់ទន្លេសាប

សារសម្លេងពាក់ព័ន្ធនឹងបញ្ហាទន្ទ្រានយកដីនៃបឹងទន្លេសាប, ២៨ វិច្ឆិកា ២០២១

... ដូច្នេះ (ឧបនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់)ត្រូវធ្វើការងារនេះជាបន្ទាន់ ... ព្រោះថា ក្រសួងធនធានទឹក និងឧតុនិយមក៏ដូចជាអាជ្ញាធរទន្លេសាប បានបោះបង្គោលកំណត់តំបន់ដែលត្រូវការពារ និងដែលមិនអាចនរណាប៉ះពាល់បានហើយ។ ឥឡូវ មានអ្នកដែលបានប៉ះពាល់ក្នុងតំបន់ស្នូលនេះរួចហើយ។ ខ្ញុំសូមស្នើឱ្យមានការចាត់វិធានការ ដោយរៀបចំក្រុមការងារសម្រាប់គ្រប់ខេត្ត ព្រោះតាមក្រសួងនីមួយៗ មានរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការច្រើន។ ត្រូវរៀបចំជាច្រើនក្រុមចុះទៅកាន់បណ្តាខេត្តក្នុងតំបន់ទន្លេសាប ...រួមទាំងក្រុមដែលអាចនឹងមានផ្នែករាយរងពាក់ព័ន្ធជាមួយនឹងទន្លេសាប ដូចជាខេត្តកំពង់ចាម និងខេត្តកណ្តាលផងដែរ។ **សំខាន់ត្រូវចុះទៅតំបន់មាន(ការបំពាន)ធ្ងន់ធ្ងរ គឺខេត្តកំពង់ឆ្នាំង និងអាចផ្នែកខ្លះទាក់ទងនឹងខេត្តដទៃទៀត ... ត្រូវតែដកហូត(ដីទាំងនោះ)ត្រឡប់មកវិញទាំងអស់ ទាំងរបស់មន្ត្រីទាំងរបស់ប្រជាជន ... មិនត្រូវឱ្យមានការរំលោភបំពានលើតំបន់បានកំណត់ និងដែលត្រូវការពារទេ** ...។

១៩. ហាមបង្កបង្កើនផលលើដីដែលបានដកហូត ចាប់ខ្លួនអ្នកបំពានបទឃុបឃិតរបស់រដ្ឋ

សារសម្លេងពាក់ព័ន្ធនឹងបញ្ហាទន្ទ្រានយកដីនៃបឹងទន្លេសាប, ២៨ វិច្ឆិកា ២០២១

... ឯកឧត្តម នាយកឧត្តមសេនីយ៍ សៅ សុខា ត្រូវធ្វើសកម្មភាពជាបន្ទាន់ដឹកនាំកម្លាំងដោះស្រាយបញ្ហានេះ ដោយប្រើទាំងកម្លាំងថ្មើរជើង ទាំងជើងទឹក ទាំងឧទ្ធម្ភាគចក្រ ដើម្បីត្រួតពិនិត្យជាបន្ទាន់លើប្រតិបត្តិការរក្សាតំបន់ព្រៃលិចទឹកនេះ ព្រោះនៅមិនយូរប៉ុន្មានទេ ទឹកនឹងស្រកផុត ហើយពួកគេនឹងចាប់ផ្តើមធ្វើការបង្កបង្កើនផល ឬកាប់បន្ថែមនៅទីនោះ។ យើង**មិនអនុញ្ញាតឱ្យមានបង្កបង្កើនផលទៅលើដីដែលត្រូវដកហូតនេះត្រឡប់មកវិញទេ។ ដោយសារតែសមត្ថកិច្ចទាំងអស់សុទ្ធតែជានគរបាលយុត្តិធម៌ ដូច្នេះត្រូវតែចាប់ខ្លួនអ្នកណាដែលបានបំពានលើបទឃុបឃិតទាំងឡាយ ដែលយើងធ្លាប់បានដាក់ចេញជាការពារាំងចំពោះការលើសទៅនឹងការកំណត់របស់រដ្ឋ** ...។

២០. ចាប់និងបញ្ជូនជនល្មើសច្បាប់ក្នុងក្របខណ្ឌកាប់ព្រៃលិចទឹកក្នុងតំបន់ទន្លេសាប ទៅតុលាការ

សារសម្លេងពាក់ព័ន្ធនឹងបញ្ហាទន្ទ្រានយកដីនៃបឹងទន្លេសាប, ២៨ វិច្ឆិកា ២០២១

... សូមឯកឧត្តម ឱម យិនទៀង ដឹកនាំអង្គភាពប្រឆាំងអំពើពុករលួយចុះស្រាវជ្រាវ តើមន្ត្រីណាខ្លះដែលមានការពាក់ព័ន្ធដើម្បីរៀបចំនូវសំណុំរឿងបញ្ជូនទៅតុលាការកាត់ទោស។ រាជរដ្ឋាភិបាលមានការនឿយហត់។ យើងគ្មានឱកាសនឹងអប់រំច្រំដែលៗ លើការរំលោភបំពានដែលអ្នកទាំងនេះបានធ្វើទៀតទេ។ សូមចងចាំថា **"ពុំមានពេលអប់រំទៀតទេ។ (មានតែ)ច្បាប់ទើបអាចដោះស្រាយបានបញ្ហា"។ ត្រូវចាប់និងបញ្ជូនទៅតុលាការនូវជនទាំងឡាយ ហើយបើសិនជាមន្ត្រីក៏ត្រូវដកហូតត្រឡប់មកវិញ រហូតដល់រឹបអូសទ្រព្យសម្បត្តិដែលពួកគេបាន ពីការល្មើសច្បាប់ក្នុងក្របខណ្ឌនៃការកាប់ព្រៃលិចទឹកក្នុងតំបន់ទន្លេសាបនេះ** ... អ្នកប្រព្រឹត្តិ ត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់ដោយខានមិនបាន ... យើងបានអប់រំរាប់សិបឆ្នាំរួចមកហើយពីផលវិបាកលើបញ្ហានេះ ...។

២១. ធ្វើសកម្មភាពគ្មានក្រែងរអែងច្បាប់របស់ប្រទេសជាតិ មិនសមធ្វើជាមន្ត្រីទៀតទេ

សារសម្លេងពាក់ព័ន្ធនឹងបញ្ហាទន្ទ្រានយកដីនៃបឹងទន្លេសាប, ២៨ វិច្ឆិកា ២០២១

... ហេតុអ្វីក៏នៅតែមានមន្ត្រីបែបនេះទៀត។ ខ្ញុំក៏សូមប្រាប់ទៅមន្ត្រីទាំងឡាយដែលបានអនុវត្តខុស បើសិនជាចង់បានការបន្ធូរបន្ថយទោសត្រូវតែចេញសារភាពជាបន្ទាន់។ បើមិនចេញសារភាពជាបន្ទាន់ **ខ្ញុំសូមឱ្យចាត់វិធានការដោយម៉ឺងម៉ាត់បំផុត គឺចាប់ខ្លួនផ្តន្ទាទោសតាមច្បាប់ ហើយឈានទៅរឹបអូស មិនត្រឹមតែដីធ្លីនៅហ្នឹងកន្លែងទេ តែក៏ទាំងទ្រព្យសម្បត្តិដែលពួកគេមាន បានមកពីដីធ្លីដែលពួកគេបំផ្លាញនេះ។** ដូច្នេះ **អង្គភាពប្រឆាំងអំពើពុករលួយ ត្រូវចេញធ្វើសកម្មភាពស្រាវជ្រាវការពាក់ព័ន្ធជាមួយបុគ្គលណាផ្សេងទៀត។ យើងមិនអត់ឱនបានទេ។ ពេលកំពុងប្រយុទ្ធប្រឆាំងនឹង COVID-19 បែរជាមានមន្ត្រីធ្វើសកម្មភាពដោយគ្មានការទទួលខុសត្រូវ គ្មានការក្រែងរអែងចំពោះច្បាប់របស់ប្រទេសជាតិ។ អ្នកទាំងនេះមិនសក្តិសមធ្វើជាមន្ត្រីតទៅទៀតទេ** ...។

២២. ការដោះស្រាយដីធ្លីក្នុងតំបន់ទន្លេសាបនៅសេសសល់តិច

ពិធីបុណ្យទន្លេលើកទី ៧ នៅខេត្តកំពង់ធំ, ៩ មីនា ២០២៣

... សូមអរគុណចំពោះឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ជា សុផារ៉ា ព្រមទាំងថ្នាក់ដឹកនាំនៃ**ស្ថាប័នដែលមានការពាក់ព័ន្ធ និងអាជ្ញាធរខេត្ត ដែលបានខិតខំធ្វើកិច្ចការងារនេះដ៏ល្អ។ មកដល់ពេលនេះ នៅសេសសល់មិនច្រើនប៉ុន្មានទេ។ ខ្ញុំសូមរំលឹកឱ្យធ្វើឱ្យបានចប់សព្វគ្រប់។ ទន្លេសាបចែកជា ៣តំបន់។ តំបន់ទី១ តំបន់ទី២ និងតំបន់ទី៣។ តំបន់ទី១ អនុញ្ញាតផ្តល់កម្មសិទ្ធិជូនប្រជាជន។ តំបន់ទី២ គឺជាតំបន់ប្រជាជនអាស្រ័យផល។ ឯតំបន់ទី៣ គឺជាតំបន់ហាមប៉ះពាល់។** ប៉ុន្តែយើងក៏ត្រូវគិតថា តំបន់ទី៣ ក៏មានភូមិឃុំខ្លះប្រជាជនរស់នៅ ២០០ ឬ ៣០០ ឆ្នាំ រួចមកហើយ។ ដូច្នេះ យើងមិនអាចទៅយកពួកគាត់ចេញទេ។ យើងត្រូវធ្វើល (ទីតាំងនោះ)ឲ្យពួកគាត់រស់នៅនិងអាស្រ័យផលជាលក្ខណៈពិសេស ...៕

២៣. កែសម្រួលព្រំប្រទល់តំបន់និងកាត់ធ្វើលទីតាំងដីដែលប្រជាជនរស់នៅពីយូរលង់ឲ្យចប់នៅចុងខែឧសភាឆ្នាំ២០២៣

បិទសន្និបាតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងសម្ពោធដាក់ឱ្យប្រើប្រាស់ "អគារមន្ទីរពិសោធន៍ជាតិសំណង់", ២៧ ធ្នូ ២០២២

... ខ្ញុំសូមដាក់ការកំណត់ថា**ដោះស្រាយ(បញ្ហាជូនប្រជាជនដែលរស់នៅជាភូមិការនៅជុំវិញបឹងទន្លេសាប ដោយធ្វើបច្ចុប្បន្នភាពផែនទីតាមខេត្តនីមួយៗ កែសម្រួលព្រំប្រទល់តំបន់៣ ព្រំប្រទល់តំបន់២ និងកាត់ធ្វើលទីតាំងដីដែលប្រជាជនរស់នៅពីយូរលង់មកហើយក្នុងតំបន់៣ និងតំបន់២)ឲ្យចប់ នៅចុងខែឧសភាឆ្នាំ២០២៣** ... យើងឡើងផែនទីរួមមកហើយ ប៉ុន្តែខេត្តត្រូវបញ្ចេញផែនទីតាមខេត្តមួយៗ។ កន្លែងណាកាត់ឲ្យប្រជាជន ធ្វើលឲ្យប្រជាជនរបៀបម៉ែច កាត់តំបន់៣ ផ្ទេរមកតំបន់២ ឬកាត់តំបន់២ ផ្ទេរមកតំបន់១។ ប៉ុន្តែអ្នកដែលរស់នៅក្នុងតំបន់៣ ដែលមិនអាចផ្ទេរអោយគាត់បាន គឺយើងត្រូវធ្វើលឲ្យគាត់យ៉ាងម៉ែច។ ត្រូវធ្វើកិច្ចការហ្នឹងឲ្យស្រួត។ រៀបចំកម្លាំង ដើម្បីធ្វើកិច្ចការងារនេះ ... ខ្ញុំសូមដាក់កំណត់ ថាកុំអូសបន្លាយយូរពេក ... សូមដាក់កំណត់ថា នៅចុងខែឧសភាឆ្នាំ

២០២៣ ត្រូវធ្វើឲ្យរួចរាល់គ្រប់ខេត្តនិងទូទាំងប្រទេស ដោយឡែកក្នុងតំបន់ទន្លេសាបនេះ ...៕

២៤. មិនគប្បីសង់សំណង់ខ្ពស់ជាងដើមឈើទេ នៅលើបណ្តាកោះ

សម្ពោធសណ្ឋាគារ រ៉ូយ៉ាល់សាន់កោះរុង, ២៣ មេសា ២០១៨

... ខ្ញុំគិតថាជាអនុសាសន៍ដែលសមស្របបំផុតដែលថា នៅលើបណ្តាកោះមិនគប្បីសង់(សំណង់)ខ្ពស់ជាងដើមឈើទេ។ ឯកឧត្តម ជា សុផារ៉ា ក្នុងឋានៈជាអ្នកដែលប្រគល់ប្លង់សម្រាប់ការសាងសង់ **មិនត្រូវឲ្យសាងសង់ ២០ឬ ៣០ជាន់នៅលើកោះទេ។ ត្រូវកសាងតាមរបៀបអញ្ចឹង។ បើមិនដូច្នោះ វាមិនមែនជាកោះធម្មជាតិទៀតទេ។ យើងចង់ក្សាការអភិវឌ្ឍដែលគ្របដណ្តប់ដោយធម្មជាតិ អែបជាមួយការអភិវឌ្ឍតាមបែបសំណង់ទេសចរណ៍ ប៉ុន្តែមិនមែនជាសំណង់ ៣០, ៤០ ឬ ៥០ជាន់ទេ។ ធ្វើ(អាគារកំពស់)ហ្នឹងនៅលើគោកឯណោះ។ ឯនៅលើកោះ មួយជាន់ប៉ុណ្ណឹងវាល្មម ហើយឬថាខ្ពស់បំផុត ៣ជាន់ប៉ុណ្ណឹងបានហើយ ដើម្បីក្សាធ្នេរទុកឱ្យយើងទាំងអស់គ្នា។ ខ្ញុំក៏សូមយកឱកាសនេះបញ្ជាក់ថា គ្រប់បណ្តាកោះត្រូវគោរពបែបបទនិងផែនការមេ** ... យើងដោះស្រាយបញ្ហាជាមួយគ្នានិងឈានទៅធ្វើសុខដុមភាវូបនីយ៍កម្មលើកោះរុងនេះ ...៕

២៥. បណ្តាកោះទាំងអស់ជាសម្បត្តិរបស់រដ្ឋ មិនត្រឹមតែកោះរុងមួយទេ

សម្ពោធសណ្ឋាគារ រ៉ូយ៉ាល់សាន់កោះរុង, ២៣ មេសា ២០១៨

... ជាមួយការលើកទឹកចិត្តដើម្បីអភិវឌ្ឍបន្ត ដោយគោរពបែបបទនិងការរក្សាបរិស្ថាន ក៏ដូចជាធ្នេរធម្មជាតិ ខ្ញុំសូមបញ្ជាក់ជូនប្រជាពលរដ្ឋដែលរស់នៅទីនេះឱ្យបានយល់ថា គឺមិនត្រឹមតែកោះរុងមួយទេ **បណ្តាកោះទាំងអស់សុទ្ធតែជាសម្បត្តិរបស់រដ្ឋ។ ការប្រគល់ណាមួយ ក៏ត្រឹមតែជាសិទ្ធស្នាក់នៅ ជាសិទ្ធទទួលផល ប៉ុន្តែមិនមានសិទ្ធចាត់ចែងនោះទេ។ កោះរុងគឺជាសម្បត្តិរបស់រដ្ឋ គ្រាន់តែរដ្ឋសម្បទានទៅឲ្យក្រុមហ៊ុនដើម្បីធ្វើការវិនិយោគ ដើម្បីទាក់ទាញភ្ញៀវទេសចរ ដោះស្រាយការងារធ្វើរបស់ប្រជាពលរដ្ឋតែប៉ុណ្ណោះ។ ដល់រយៈពេលណាមួយ ដីធ្លី(នៃកោះ)នេះនឹងក្លាយជាដីរបស់រដ្ឋវិញ។ សូមបញ្ជាក់ថា មិនមែនជាដីរបស់**

ឯកជនទេ តែជីរបស់រដ្ឋដែលត្រូវបានជួលទៅឲ្យឯកជនសម្រាប់ការវិនិយោគ ...។

២៦. ក្បាលដីលើកោះរុងដែលមិនទាន់ចេញបណ្ណកម្មសិទ្ធ ដោយសារមានវិវាទ ឬកំពុងពិនិត្យអត្តសញ្ញាណ

សម្ពោធសណ្ឋាគារ រ៉ូយ៉ាល់សាន់កោះរុង, ២៣ មេសា ២០១៨

... នៅលើពិភពលោកនេះ ពិសេសនៅក្នុងតំបន់ មានកោះច្រើនណាស់ដែលត្រូវបានអភិវឌ្ឍទៅមុនយើង។ ប្រជាពលរដ្ឋមិនត្រូវយល់ថាជីនៅកោះរុងជាជីរបស់ឧកញ៉ា គិត ម៉េង ទេ។ គឺជាជីរបស់រដ្ឋ តែរដ្ឋបានផ្តល់ទៅឲ្យក្រុមហ៊ុនដើម្បីធ្វើការអភិវឌ្ឍ។ កន្លងទៅតែងតែយល់ថា នេះជាជម្លោះរវាងប្រជាពលរដ្ឋជាមួយក្រុមហ៊ុននេះ/ក្រុមហ៊ុននោះ ក៏ប៉ុន្តែអ្នកដែលទទួលខុសត្រូវពិតប្រាកដគឺរដ្ឋឯនេះវិញទេ ... កន្លងទៅ ឯកឧត្តម ជា សុផារ៉ា បានដោះស្រាយបញ្ហានេះមួយចំនួន។ **ខ្ញុំបានចេញអនុក្រឹត្យមួយដោះស្រាយបញ្ហាដីធ្លីនៅទីនេះ។ មានដីធ្លីដែលយើងបានប្រគល់ប្លង់កាន់កាប់ឲ្យប្រជាពលរដ្ឋ និងដីធ្លីដែលមិនទាន់ប្រគល់កម្មសិទ្ធិឲ្យប្រជាពលរដ្ឋ។ នៅទីនេះ យើងមាន ១.២២១ក្បាលដី ... យើងបានប្រគល់កម្មសិទ្ធិឱ្យ ៦៣៧ក្បាលដី ដែលមានទំហំ ៥២៥,៣៧ ហិកតា សំរាប់ប្រជាជន ២៩៤ គ្រួសារដែលរស់នៅអចិន្ត្រៃយ៍លើកោះនេះ ... នៅ ៥៨៤ក្បាលដីទៀតចេញបណ្ណកម្មសិទ្ធិជូនមិនទាន់បាន ដោយកម្មសិទ្ធិខ្លះមានវិវាទ និងក្បាលដីខ្លះ កំពុងបន្តពិនិត្យអត្តសញ្ញាណ ...។**

២៧. ការកាប់ព្រៃយកដី កើតមានលើកោះមួយចំនួន តែលើកោះរុងច្រើនជាងគេ

សម្ពោធសណ្ឋាគារ រ៉ូយ៉ាល់សាន់កោះរុង, ២៣ មេសា ២០១៨

... និយាយដោយត្រង់ទៅ មុនឆ្នាំ២០០៨ តើមានប្រជាជនប៉ុន្មាន? តើអ្នកកាន់កាប់ដីធ្លីលើកោះនេះ មានប៉ុន្មានពិតប្រាកដ? នេះជារឿងទន្ទ្រានកាន់កាប់ដោយប្រជាពលរដ្ឋ ហើយអ្នកខ្លះក៏មកពីចម្ងាយឯណោះទេ។ យកនាមប្រជាជននៅលើកោះ ប៉ុន្តែខ្លួននៅទីក្រុងភ្នំពេញ និងនៅកន្លែងផ្សេងៗ ហើយបានបោះទុនតាមរបៀបនេះរបៀបនោះ ហើយ(បង្ក)ជាបញ្ហា។ ខ្ញុំមិនជឿថាប្រជាពលរដ្ឋនៅកោះរុងនេះមានដីធ្លីច្រើនដល់កម្រិតប៉ុណ្ណឹងទេ។ **អ្នកកោះរុងធ្វើផ្ទះ ឬធ្វើអាជីវកម្ម**

ប៉ុន្មានទៅ ទើបមានដីធ្លីហ្នឹងច្រើន។ ការកាប់(ព្រៃ)យកដី បំផ្លាញធ្នេរ ជាស្ថានភាពដែលកើតមិនគ្រាន់តែលើកោះរុងទេ តែក៏លើកោះមួយចំនួនទៀតដែរ។ យ៉ាងណាក្តី លើកោះរុងនេះ បានកើតច្រើនជាងគេ។ មិនមែនមែនតែជាមួយក្រុមហ៊ុនកន្លែងនេះទេ តែជាមួយកងទ័ពក៏ទើបតែមានបញ្ហាថ្មីៗ កើតឡើងដែរ។ បើតាមខ្ញុំទទួលបានព័ត៌មាន។ ខ្ញុំដឹងថា មូលដ្ឋានដែលត្រូវបានកំណត់ឲ្យកងទ័ពជើងទឹកគ្រប់គ្រងនោះ ត្រូវប្រជាពលរដ្ឋចូលទៅអះអាងថាជាជីរបស់គាត់ពីឆ្នាំនេះឆ្នាំនោះ ...។

២៨. គប្បីផ្លាស់ប្តូរទីតាំងឲ្យប្រជាពលរដ្ឋ ករណីបានរស់នៅមុនចុះហត្ថលេខា២០០៨

សម្ពោធសណ្ឋាគារ រ៉ូយ៉ាល់សាន់កោះរុង, ២៣ មេសា ២០១៨

... ខ្ញុំបានប្រាប់ទៅ ឯកឧត្តម ជា សុផារ៉ា ថា ដីខ្លះដែលវាពាក់ព័ន្ធជាមួយ(ទីតាំង)ដែលយើងសាងសង់រួចហើយ យើងអាចសម្របសម្រួលរកដីផ្សេងឲ្យគាត់។ ឧទាហរណ៍ថាទីតាំងយោធា។ ត្រូវរក្សាទីតាំងយោធា។ **ក្នុងករណីប្រជាពលរដ្ឋកាន់កាប់មុនពេលដែលយើងកំណត់ឲ្យទីតាំងយោធា យើងក៏ត្រូវរកដីធ្លីឲ្យពួកគាត់បានសមរម្យ។ ក្នុងករណីដូចនៅកន្លែងនេះ ពេលដែលយើងដាក់ប្លង់មេចេញមក យើងអត់បានឃើញថាមានប្រជាពលរដ្ឋទេ។ ដូច្នេះ ពេលពិនិត្យជាក់ស្តែង តើ អ្នកដែលរស់នៅមុនពេលយើងចុះហត្ថលេខាឆ្នាំ២០០៨ មានប៉ុន្មាន? អ្នកទាំងនេះគប្បីទទួលបាននូវការផ្លាស់ប្តូរ ដោយផ្តល់សម្បទានដីធ្លីនៅកន្លែងផ្សេងណាមួយ។** មានអ្នកខ្លះបានស្គាល់ទាំងលេខទូរស័ព្ទខ្ញុំទៅទៀត ... សូម្បីតែយប់មិញ អ្នកនៅលើកោះរុងវាយចូលមក ...។

២៩. លើកោះរុង មានសណ្ឋាគារផ្កាយ៥ និងបានបញ្ឈប់ភាពអនាធិបតេយ្យទន្ទ្រានដីធ្លី

សម្ពោធសណ្ឋាគារ រ៉ូយ៉ាល់សាន់កោះរុង, ២៣ មេសា ២០១៨

... តាមពិតសណ្ឋាគារនេះ ខ្ញុំអាចឲ្យឧបនាយករដ្ឋមន្ត្រីណាមួយមកសម្ពោធក៏បាន ប៉ុន្តែខ្ញុំមានគោលដៅ២។ ទី១ **ធ្វើសារទៅអ្នកទេសចរទាំងឡាយដែលចង់មកកម្សាន្តនៅលើកោះរុងថា មានសណ្ឋាគារលំដាប់ផ្កាយ៥ ហើយ**។ ឯទី២ **ដាក់ចេញបទបញ្ជា បិទបញ្ចប់ស្ថានភាពរ៉ាំរ៉ៃនៃជម្លោះដីធ្លីនៅលើកោះរុង។ មកបិទ**

បញ្ចប់ភាពអនាធិបតេយ្យកាប់ឈើ និងកាប់ទន្ទ្រានយកដីនៅលើកោះរុង។ ម៉្យាងទៀត ក៏ជាសារបញ្ជាក់ថា កោះមួយចំនួននៅក្នុងសមុទ្រដែលចុះហត្ថលេខារាប់ឆ្នាំហើយនោះ ហើយដែលមិនបានអនុវត្ត ហើយគិតតែពីដើរលក់គម្រោងនោះ គឺទោះបីលោកឯងលក់ក៏ខ្ញុំមិនឲ្យដែរ។ បើចាប់ដៃគូបាន ប៉ុន្តែមិនអនុញ្ញាតឲ្យលក់ទេ។ យើងត្រូវសើរើពិនិត្យមើល ...។

៣០. ត្រួតពិនិត្យនិងដកហូតត្រឡប់មកវិញ កោះទាំងឡាយដែលមិនមានការវិនិយោគ

សម្ពោធសណ្ឋាគារ រ៉ូយ៉ាល់សាន់កោះរុង, ២៣ មេសា ២០១៨

... **(គំរោងអភិវឌ្ឍលើ)បណ្តាកោះតាមសមុទ្ររបស់យើង ប្រហែលជា(ភ្លាយជា)ដីរើមទាំងអស់ហើយ បើគិតតាមរយៈពេលនៃដែលបានផ្តល់(ការសំរេច)ឱ្យក្រុមហ៊ុននានាវិនិយោគ លើប្រហែលជា ៣០កោះ ដែលយើងត្រូវដកហូតត្រឡប់មកវិញ ដោយសារតែពួកគេមិនបានធ្វើអ្វីទាំងអស់**។ ខ្ញុំបានផ្តល់អោយឯកឧត្តម សុខ ចិន្តា **ធ្វើការពិនិត្យនិងដកហូតកោះទាំងនោះត្រឡប់មកវិញ ហើយរៀបចំការវិនិយោគសាជាថ្មី ដោយមិនអាចទុកកោះរបស់យើងឱ្យនៅរបៀបដូចសព្វថ្ងៃនេះ គ្មានការគ្រប់គ្រង ហើយអ្នកដែលបានទទួលសិទ្ធិធ្វើការវិនិយោគចេះតែដើរលក់បន្តបានទេ។ បើចាប់ដៃគូគឺអនុញ្ញាតបាន**។ ក៏ប៉ុន្តែ ដៃគូលែងហ៊ានចូលមកជាមួយអ្នកទាំងនោះ។ ដូច្នេះ តើរង់ចាំអ្វីទៀត? ...។

២២. តែ និងថាមពល

១	ការវិនិយោគក្នុងវិស័យអគ្គិសនី ត្រូវនឹងអាទិភាពរបស់កម្ពុជា	៤១៧
២	អ្នកខ្លះទប់ស្កាត់ការផលិតវាមពលវារីអគ្គិសនី តែទាវឱ្យស្រាយតម្រូវការអគ្គិសនី	៤១៧
៣	ការវិនិយោគវិស័យអគ្គិសនី តម្រូវឱ្យមានការធានាពីអង្គការនីតិបញ្ញត្តិ	៤១៨
៤	អគ្គិសនីផ្តល់ឱកាសជំរុញឧស្សាហកម្មនិងទេសចរណ៍ដែលបង្កើតជាការងារ	៤១៨
៥	តម្រូវការអគ្គិសនីកើនខ្ពស់មានអន្តរសកម្មទៅនឹងឧស្សាហកម្ម សៅ កសិកម្ម	៤១៩
៦	ពី ១៥០មេហ្គាវ៉ាត់ឆ្នាំ១៩៩៨ មក ២៦៨៨មេហ្គាវ៉ាត់ ... នៅ២០ឆ្នាំបន្ទាប់	៤១៩
៧	វារីអគ្គិសនី "សេសាន២" នឹងផ្គត់ផ្គង់ជាចម្បងដល់ខេត្ត៤ នៃភាគឦសាន	៤២០
៨	យកអគ្គិសនីពីឡាវ ឬពីវារីអគ្គិសនីសេសាន ផ្គត់ផ្គង់ខេត្តកំពង់ធំ និងខេត្តព្រះវិហារ	៤២០
៩	វារីអគ្គិសនី សេសាន២ នឹងពង្រឹងឯករាជ្យភាពកម្ពុជាផ្នែកវាមពលអគ្គិសនី	៤២១
១០	បើថា"វារីអគ្គិសនីសេសានក្រោម២ ធ្វើឱ្យបាត់ផលត្រី៧០%" មានតែត្រីឡើងភ្នំ	៤២១
១១	វារីអគ្គិសនី ណាំង៉ម ផ្តល់ពិសោធន៍ពីការគ្រប់គ្រងព្រៃឈើក្នុងអាងដល់កម្ពុជា	៤២២
១២	គ្រោះរាំងស្ងួត និងកំណើនសំណង់ ធ្វើឱ្យជួបកង្វះអគ្គិសនីមិនធ្លាប់មាន	៤២២
១៣	ភ្លៀងច្រើនធ្វើឲ្យវារីអគ្គិសនីមិនខ្វះទឹក កាត់បន្ថយការប្រើឥន្ធនៈនិងធ្យូងថ្ម	៤២៣
១៤	មិនអនុញ្ញាតអោយធ្វើវារីអគ្គិសនីនៅតំបន់អារ៉ាង	៤២៣
១៥	វារីអគ្គិសនីនៅតែជាជម្រើសដ៏ល្អ ក្នុងការជៀសពីបំពុលបរិស្ថាន	៤២៤
១៦	អគ្គិសនីពីបាមពលកកើតឡើងវិញ៦២% ចាត់ថាកម្ពុជាមិនបំពុលបរិស្ថានច្រើនទេ	៤២៤
១៧	បោះបង់គំរោងវារីអគ្គិសនីស្ទឹងត្រែងនិងក្រចេះ ដើម្បីបន្តយក្តីបារម្ភរបស់ប្រជាជន	៤២៥
១៨	ធ្វើឲ្យជនបទ/គ្រប់ភូមិ មានអគ្គិសនីប្រើប្រាស់និងទឹកស្អាត	៤២៥
១៩	ភូមិ៩៩% និងផ្ទះ៩០% ទូទាំងប្រទេសបានភ្ជាប់បណ្តាញអគ្គិសនីរួចរាល់	៤២៦
២០	ផ្គត់ផ្គង់អគ្គិសនីទៅសិង្ហបុរីតាមបាតសមុទ្រនិងផ្លូវគោក	៤២៦
២១	ឧស្សាហកម្មបច្ចេកវិទ្យាប្រើថាមពលបៃតង និងគាំទ្រឱ្យលំនៅដ្ឋានតម្លៃសមរម្យ	៤២៦
២២	សូមអភិបាលខេត្ត/រាជធានីបញ្ឈប់ទិញអំពូលភ្លើងឆ្លាតផលិតដោយទឹកដែកម្ពុជា	៤២៧
២៣	អឺរ៉ុបវិលទៅផលិតអគ្គិសនីពីធ្យូងថ្ម បន្ទាប់ពីប្រកាសបោះបង់កាលពីឆ្នាំ២០០១	៤២៧
២៤	ក្រចេះ ស្ទឹងត្រែង រតនគីរី មណ្ឌលគីរី ជាប៉ូលសេដ្ឋកិច្ចកសិ-ឧស្សាហកម្ម/ធនធានជី	៤២៨
២៥	កម្ពុជាមានមាស ក្បាង ធ្យូងថ្ម ប៉ែដែក គ្រាន់តែមិនទាន់បានធ្វើអាជីវកម្ម	៤២៨

២៦	ផលិតមាសបានជាង ២តោន សម្រាប់តែរណ្តៅមួយនៅខេត្តមណ្ឌលគិរី	៤២៩
២៧	បញ្ហានដុំមាសខ្វីទៅចម្រាញ់ជាមាសទឹកដប់នៅអ្រស្តាលី	៤២៩
២៨	ក្រុមហ៊ុនអ្រស្តាលីធំមួយកំពុងសិក្សាទីតាំងរុករកនិងផលិតមាសផ្សេងទៀត	៤៣០
២៩	ចំណូលពីប្រេង តិចជាងចំណូលពីពន្ធដារ និងគយ	៤៣០
៣០	អាជីវកម្មប្រេងមិនកាក់កប តែបានផលពីធីមាសវិញ	៤៣១

១. ការវិនិយោគក្នុងវិស័យអគ្គិសនី ត្រូវនឹងអាទិភាពរបស់កម្ពុជា

បើកការដ្ឋានសាងសង់ផ្លូវល្បឿនលឿន ក្រុងភ្នំពេញ-ខេត្តព្រះសីហនុ, ២២ មីនា ២០១៩

... ទាក់ទាញ**វិនិយោគិនចិនមកអភិវឌ្ឍវិស័យអគ្គិសនី ដែលស្ថិតក្នុងលំដាប់អាទិភាពដែលយើងត្រូវការវិនិយោគ។ ចំណុចនេះ អាចនិយាយបានថា អាទិភាព ៤ ដែលខ្ញុំបានប្រកាសតាំងពីឆ្នាំ ១៩៨៧ ដែលមកដល់ពេលនេះ(បង្ហាញថាត្រឹមត្រូវអស់)រយៈពេល ៣២ឆ្នាំរួចមកហើយ គឺនៅតែបន្តត្រឹមត្រូវ**។ ខ្ញុំបានលើកឡើងពីអាទិភាពវិនិយោគពេលនោះ ដោយប្រើពាក្យ៤ គឺទឹក ផ្លូវ ភ្លើង និងមនុស្ស ... ឥឡូវហ្នឹង យើងគ្រាន់តែបានដូរមនុស្សមកដាក់ជាអាទិភាពទី១តែប៉ុណ្ណឹងទេ។រីងអាទិភាពទាំង៤ នៅតែដដែលហ្នឹង។ អញ្ចឹងរកលុយធ្វើផ្លូវ រកលុយធ្វើប្រឡាយទឹក រកលុយតភ្ជាប់អគ្គិសនី ឬធ្វើ(អោយមានហាមពល)អគ្គិសនីដើម្បីឲ្យមានហាមពលប្រើប្រាស់ ...។

២. អ្នកខ្លះទប់ស្កាត់ការផលិតហាមពលវារីអគ្គិសនី តែទារឱ្យស្រាយតម្រូវការអគ្គិសនី

សំណេះសំណាលជាមួយប្រជាពលរដ្ឋ និងពិនិត្យការដ្ឋានសំណង់វារីអគ្គិសនីស្ទឹងពេធ៏សាត់១ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពេធ៏សាត់, ១៤ មីនា ២០២៣

... ត្រូវរកវិធីដើម្បីដោះស្រាយ(កំណើនសេចក្តីត្រូវការហាមពល)អគ្គិសនី ... ចូលមកដល់ទសវត្សរ៍៩០ ហើយ កម្ពុជានៅប្រើប្រាស់ត្រឹម ៣០MW នៅទីក្រុងភ្នំពេញ ហើយតាមខេត្តនានាគឺតិចតួចទេ។ ឥឡូវ ទំហំនៃការប្រើប្រាស់(ទូទាំងប្រទេស) គឺជាង ២២០០ MW ទៅហើយ ... ជា**ការព្យាករទៅមុខ តម្រូវការអគ្គិសនីកាន់តែច្រើន ដែលយើងត្រូវរកប្រភពដើម្បីបង្កើតឱ្យមានអគ្គិសនីឱ្យប្រជាជនប្រើប្រាស់។ មនុស្សមួយចំនួនបាននិយាយទប់ស្កាត់ការផលិតហាមពលពីវារីអគ្គិសនីក្នុងពេលជាមួយគ្នាដែលពួកគេក៏ទាមទារឱ្យយើងដោះស្រាយ (សេចក្តីត្រូវការ)អគ្គិសនី។តើដោះស្រាយវាបៀបម៉េច? (ផលិតអគ្គិសនីដោយប្រើ)ប្រេងវាថ្លៃ ដោយធ្យូងថ្មបំពុលបរិស្ថាន។ធ្វើវារីអគ្គិសនីថាបំផ្លាញព្រៃបង្កើតឱ្យមានការលិចលង់ផ្ទៃដីមួយចំនួន។តើត្រូវរើលត្រឡប់ទៅដុតចន្ទុះចង្កៀងប្រេងកាតទៀនឬយ៉ាងម៉េច ...។

៣. ការវិនិយោគវិស័យអគ្គិសនី តម្រូវឱ្យមានការធានាពីអង្គការនីតិបញ្ញត្តិ

ទស្សនកិច្ចវារីអគ្គិសនីសេសានក្រោម ២ និងចុចប៊ូតុងបិទទ្វារទឹក
ដើម្បីក្សាទឹកទុកក្នុងអាងស្តុកទឹក, ២៥ កញ្ញា ២០១៧

... យើងមិនអាចផលិត(អគ្គិសនី)ផ្គួនៗ ដោយមិនរង់ចាំដំណាក់កាលរបស់វានោះទេ។ ដោយហេតុនេះហើយបានជា(យើងត្រូវរៀបចំ)ផែនការក្នុងការផលិតអគ្គិសនី (ដោយកំណត់ថា)ផលិតមួយណាមុននិងមួយណាក្រោយ ... **ការផលិតអគ្គិសនីខុសពីការវិនិយោគផ្នែកដទៃទៀត នៅត្រង់ថា ដើម្បីធានាឱ្យមានការដាក់ទុនវិនិយោគ(វារីអគ្គិសនី)សេសាន២ នេះ ដល់ទៅជាង ៧០០លានដុល្លារសហរដ្ឋអាមេរិក ... តម្រូវអោយមានការធានាដល់រដ្ឋសភា គឺដោយអង្គការនីតិបញ្ញត្តិ។ (ការវិនិយោគក្នុងផ្នែក)ឧស្សាហកម្ម និងសេវាមួយចំនួន មិនតម្រូវឱ្យរដ្ឋាភិបាលធ្វើការធានាដល់ថ្នាក់រដ្ឋសភា/ថ្នាក់នីតិបញ្ញត្តិនោះទេ។ ក៏ប៉ុន្តែ (សម្រាប់ការវិនិយោគក្នុងវិស័យ)អគ្គិសនី មានតម្រូវការធ្វើបែបនេះ ព្រោះបង្ការថាក្រែងលោរដ្ឋាភិបាលក្រោយៗ មិនគោរពការសន្យា** ... ការយកទុនដ៏ធំមកបណ្តាក់នៅទីកន្លែងមួយរយៈពេល ៣៥ឬ ៤៥ឆ្នាំ ហើយក្រោយរយៈពេលដំណើរការ តំបន់នេះនឹងក្លាយជារបស់រដ្ឋ ដែលរដ្ឋគ្រប់គ្រង ១០០ភាគរយ និងដែលបើរដ្ឋចង់ជួលឱ្យក្រុមហ៊ុនតទៅទៀត ហ្នឹងជារឿងរបស់រដ្ឋ អាស្រ័យលើការគិតតម្លៃផ្សេង ...។

៤. អគ្គិសនីផ្តល់ឱកាសជំរុញឧស្សាហកម្មនិងទេសចរណ៍ដែលបង្កើតជាការងារ

សំណេះសំណាលជាមួយប្រជាពលរដ្ឋ និងពិនិត្យការដ្ឋានសំណង់វារីអគ្គិសនីស្ទឹងពេធ៏សាត់១ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពេធ៏សាត់, ១៤ មីនា ២០២៣

... បើគ្មានប្រភពអគ្គិសនីប្រើទេ ប្រជាពលរដ្ឋនៅតែជុតអុស/ចន្ទុះ/ជ័រ និងប្រេងកាតនោះឯង ... បើយើងមានអគ្គិសនី យើងមិនមែនគ្រាន់តែ(ប្រើក្នុង)ការបំភ្លឺក្នុងផ្ទះទេ។ **ប្រភពអគ្គិសនីនេះវានឹងផ្តល់ឱកាសឱ្យយើងជំរុញវិស័យឧស្សាហកម្មនិងវិស័យដទៃទៀត ... ឧស្សាហកម្ម (ក៏ដូចជា) រោងចក្រមួយៗ គឺប្រើប្រាស់ឋាមពលអគ្គិសនី។ អ្វីដែលធ្ងន់ជាងនេះ សេវាកម្មទាក់ទងនឹងវិស័យទេសចរណ៍ប្រើប្រាស់អគ្គិសនីធំណាស់។** សណ្ឋាគារមួយដែលមាន ៤០០ទៅ ៥០០បន្ទប់ តើត្រូវការអគ្គិសនីប៉ុន្មាន? មិនមែនជាសម័យទេសចរណ៍បក់ផ្លិតទេ គឺជាសម័យទេសចរ

ប្រើម៉ាស៊ីនត្រជាក់។ គ្រួសារនីមួយៗសុទ្ធតែប្រើម៉ាស៊ីនត្រជាក់ (និង/ឬ)ហោចណាស់ក៏(មាន)កង្ហារដែរ ... នេះជាដំណាក់កាលសតវត្សរ៍ទី២១។ នៅពេលដែលយើងមានអគ្គិសនី ការងារធ្វើវាបានចេញមក។ រោងចក្រត្រូវការអគ្គិសនីផលិតចេញជាផលិតផល មិនថារោងចក្រណាៗនោះទេ ...។

៥. តម្រូវការអគ្គិសនីកើនខ្ពស់ដោយមានអន្តរសកម្មទៅនឹងឧស្សាហកម្ម សេវា កសិកម្ម

ទស្សនកិច្ចវារីអគ្គិសនីសេសានក្រោម២ និងចុចប៊ូតុងបិទទ្វារទឹក
ដើម្បីក្សាទឹកទុកក្នុងអាងស្តុកទឹក, ២៥ កញ្ញា ២០១៧

... ដំណាក់កាលជុតទៀន ជុតចង្កៀងប្រេងកាត ជុតចន្ទុះ ជុតជ័រ ជុតខ្លាញ់ត្រីបានរសាត់ឆ្ងាយពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជាហើយ។ ឥឡូវនេះ មិនដូចជាសម័យកាលដើម ឬក៏ ៣០ឆ្នាំមុន ដែលយើងលក់ប្រេងកាតជូនប្រជាជនទេ។ ឥឡូវនេះ (ការផលិត)អគ្គិសនីរបស់កម្ពុជាបានកើនឡើងជាបន្តបន្ទាប់។ ខ្ញុំអាចធ្វើការប្រៀបធៀបថា ក្នុងទសវត្សរ៍៨០ ការប្រើប្រាស់អគ្គិសនីមានត្រឹមប្រមាណតែ ៣០ទៅ ៤០មេហ្គាវ៉ាត់តែប៉ុណ្ណោះ។ បច្ចុប្បន្ន **ព្រះរាជាណាចក្រកម្ពុជាបានឈានដល់ដំណាក់កាលប្រើប្រាស់ជាង ២៣ន់មេហ្គាវ៉ាត់ហើយ ដោយទីក្រុងភ្នំពេញដែលពីមុនប្រើត្រឹមតែ ៣០មេហ្គាវ៉ាត់ ឥឡូវត្រូវប្រើប្រាស់ប្រមាណខ្នង់ ៥០០ មេហ្គាវ៉ាត់។ បច្ចុប្បន្ននេះ យើងមានតម្រូវការអគ្គិសនីកាន់តែខ្ពស់ ហើយមានអន្តរសកម្មលើវិស័យឧស្សាហកម្ម វិស័យសេវា វិស័យកសិកម្ម និងវិស័យដទៃទៀតដែលទាក់ទងនឹងជីវភាពរបស់ប្រជាពលរដ្ឋ** ...។

៦. ពីមានអគ្គិសនី ១៥០មេហ្គាវ៉ាត់ឆ្នាំ១៩៩៨ មកមាន ២៦៤៨មេហ្គាវ៉ាត់នៅ២០ឆ្នាំបន្ទាប់

សម្ពោធវារីអគ្គិសនីសេសានក្រោម ២ អនុភាព ៤០០ មេហ្គាវ៉ាត់, ១៧ ធ្នូ ២០១៨

... បន្ទាប់ពីការសម្ពោធ**ដាក់ឱ្យប្រើប្រាស់វារីអគ្គិសនីនេះរួចហើយ បរិមាណ(ផលិតផល)អគ្គិសនីរបស់កម្ពុជានឹងឡើងដល់ ២៦៤៨មេហ្គាវ៉ាត់ បានមកពីប្រភពផ្គត់ផ្គង់ ១៦គម្រោង ...របាយការណ៍របស់ឯកឧត្តមរដ្ឋមន្ត្រី ស៊ុយ សែម ...បានបញ្ជាក់ពីវឌ្ឍនភាព(ក្នុងវិស័យឋាមពលអគ្គិសនី)រយៈពេល ២០ឆ្នាំ ក្រោយ (ការអនុវត្ត)នយោបាយឈ្នះ-ឈ្នះ ដែលបានរំលត់ភ្លើងសង្គ្រាម នាំមកនូវសន្តិភាពថា កាលពីឆ្នាំ១៩៩៨ កម្ពុជាមានអគ្គិសនីប្រើប្រាស់ត្រឹមតែ ១៥០មេហ្គាវ៉ាត់ប៉ុណ្ណោះ។**

ប៉ុន្តែ ២០ឆ្នាំក្រោយ យើងមានរហូតដល់ ២៦៤៨មេហ្គាវ៉ាត់ ... បកក្រោយរំលឹកអតីតកាលរបស់ប្រជាជនកម្ពុជា ... យើងបានឆ្លងកាត់ដំណាក់កាលដុតចន្ទុះ ដុតជ័រ ដុតខ្លាញ់ត្រី ដុតប្រេងកាត។ តើនៅចាំបានទេ? ...៕

៧. វារីអគ្គិសនី "សេសាន២" នឹងផ្គត់ផ្គង់ជាចម្បងដល់ខេត្ត៤ នៃភាគឦសាន

ទស្សនកិច្ចវារីអគ្គិសនីសេសានក្រោម ២ និងចុចប៊ូតុងបិទទ្វារទឹក
ដើម្បីក្សាទឹកទុកក្នុងអាងស្តុកទឹក, ២៥ កញ្ញា ២០១៧

... សម្រាប់ភូមិភាគឦសាន ដែលរួមមានខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តរតនគិរី និងមណ្ឌលគិរី ពីមុននេះការផ្គត់ផ្គង់អគ្គិសនីមានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ដោយយើងទាញការផ្គត់ផ្គង់ភ្លើងពីឡាវមកខ្លះ និងទាញភ្លើងពីការផលិតរបស់ក្រុមហ៊ុនតូចៗ មួយចំនួន។ ប៉ុន្តែ ចាប់ពីពេលនេះទៅ ជាពិសេស **នៅពេលដែលតួប៊ីនទី១ (នៃវារីអគ្គិសនីសេសានមានកម្លាំងរហូតដល់ ៤០០មេហ្គាវ៉ាត់) ដំណើរការ អ្នកនៅក្នុងខេត្តស្ទឹងត្រែងផ្ទាល់ ក៏ដូចជាអ្នកដែលរស់នៅតាមតំបន់នេះ តាមរយៈអនុស្ថានីយ៍នៅខេត្តក្រចេះ វានឹងអាចផ្តល់អោយខេត្តទាំង២ នេះនូវស្ថេរភាពនៃការផ្គត់ផ្គង់ រួមដោយការរៀបចំបណ្តាញផ្គត់ផ្គង់ទៅខេត្តរតនគិរី និងខេត្តមណ្ឌលគិរី ដែលធ្វើអោយការផ្គត់ផ្គង់(អគ្គិសនីដល់)ខេត្តទាំង៤ នេះ មានស្ថេរភាពរយៈពេលវែង ហើយមានតម្លៃថោក** ...៕

៨. តើយកអគ្គិសនីពីឡាវ ឬពីវារីអគ្គិសនីសេសាន ផ្គត់ផ្គង់ខេត្តកំពង់ធំ និងខេត្តព្រះវិហារ

ទស្សនកិច្ចវារីអគ្គិសនីសេសានក្រោម ២ និងចុចប៊ូតុងបិទទ្វារទឹក
ដើម្បីក្សាទឹកទុកក្នុងអាងស្តុកទឹក, ២៥ កញ្ញា ២០១៧

... យើងបានប្រមើលមើលពី**ការផ្គត់ផ្គង់សម្រាប់ខេត្តព្រះវិហារថាត្រូវទាញភ្លើងពីឡាវមកកាន់ខេត្តព្រះវិហារ ឬក៏ត្រូវទាញភ្លើងពីវារីអគ្គិសនីសេសាន?** បើយើងគិតជាចម្ងាយពីខេត្តស្ទឹងត្រែងទៅកាន់ខេត្តព្រះវិហារ អាចនិយាយបានថា ចម្ងាយមិនជាឆ្ងាយជាងពីកំពង់ចាមមកកាន់ខេត្តស្ទឹងត្រែងនោះទេ។ ក៏ប៉ុន្តែ **ដោយសារមានតម្រូវការទាប ការវិនិយោគទៅលើបណ្តាញដែលតភ្ជាប់ជាមួយវារីអគ្គិសនីសេសាននៅខេត្តស្ទឹងត្រែងនេះមានការលំបាក។ (នេះយើង)ប្តឹងថ្លែងពីការចំណេញ**

ខាតនៅទីនោះផងដែរ។ ប៉ុន្តែ គេក៏ត្រូវគិតពីលទ្ធភាពផ្សេងទៀតនៃការផ្គត់ផ្គង់អគ្គិសនីសម្រាប់ខេត្តកំពង់ធំ ខេត្តព្រះវិហារ ដែលជាតំបន់ខ្វះខាតដែរ ...៕

៩. វារីអគ្គិសនី សេសាន២ នឹងពង្រឹងឯករាជ្យភាពកម្ពុជាផ្នែកឋាមពលអគ្គិសនី

ទស្សនកិច្ចវារីអគ្គិសនីសេសានក្រោម២ និងចុចប៊ូតុងបិទទ្វារទឹក
ដើម្បីក្សាទឹកទុកក្នុងអាងស្តុកទឹក, ២៥ កញ្ញា ២០១៧

... តាមរយៈ**ការបញ្ចេញនូវ(ចរន្តពីវារី)អគ្គិសនី(សេសាន២)នេះ ខណៈដែលបច្ចុប្បន្ន កម្ពុជាកំពុងនាំចូលពីក្រៅប្រទេសដូចជាពីវៀតណាម ពីថៃ និងពីឡាវ បរិមាណអគ្គិសនីដែលត្រូវផ្គត់ផ្គង់នឹងមានការកាត់បន្ថយ ព្រោះថាប្រទេសទាំងនោះសុទ្ធតែមានការកើនឡើងនៃបរិមាណអគ្គិសនីជាតម្រូវការផ្ទាល់ខ្លួន ...ឯកម្ពុជាយើងក៏ត្រូវការនូវឯករាជ្យភាពរបស់ខ្លួនលើការផ្គត់ផ្គង់អគ្គិសនីផងដែរ**។ នៅទីណាក៏ដោយ ពេលប្រជុំអន្តរជាតិសំខាន់ៗ បញ្ហាពីរដែលបានលើកមកពិភាក្សាគឺសន្តិសុខស្បៀង និងសន្តិសុខថាមពល។ សម្រាប់ព្រះរាជាណាចក្រកម្ពុជាក៏ដូចគ្នា ដើម្បីការពារកសាងនៃវិស័យកសិកម្ម សៅកម្ម ក៏ដូចជាវិស័យផ្សេងទៀត រាប់ទាំងកសិកម្មផងដែរ ទាមទារឱ្យអគ្គិសនីត្រូវដើរមុខមួយជំហាន ...៕

១០. ដែលថា "វារីអគ្គិសនីសេសានក្រោម២ នឹងធ្វើបាត់ផលត្រី៧០%" មានតែត្រីឡើងភ្នំ

សម្ពោធវារីអគ្គិសនីសេសានក្រោម ២ អនុភាព ៤០០ មេហ្គាវ៉ាត់, ១៧ ធ្នូ ២០១៨

... ខ្ញុំសូមនិយាយដោយចំហរនៅថ្ងៃនេះ។ មាន**ជនបរទេសមួយនាក់បានទៅជួបខ្ញុំដល់ផ្ទះ និងបាននិយាយថា ប្រសិនបើសាងសង់វារីអគ្គិសនីសេសាន កម្ពុជានឹងបាត់បង់ត្រីរហូតដល់៧០%។ ខ្ញុំបានប្រាប់គាត់វិញថា "ខ្ញុំមានការភ្ញាក់ផ្អើលខ្លាំងណាស់ ដោយសារត្រីនៅប្រទេសយើងខ្ញុំចេះឡើងភ្នំ" ... តាមពិតត្រីនៅក្នុងប្រទេសរបស់យើងប្រមូលផ្តុំនៅក្នុងទន្លេសាប និងទន្លេមេគង្គ។ វាមិនគួរឡើងភ្នំមកនៅកន្លែងហ្នឹងទេ**។ ប៉ុន្តែ គេបានលើក(ទឡ្ហីករណ៍នេះដើម្បី)ជាការដំទាស់ហាក់បីដូចជា ហ៊ុន សែន មិនស្គាល់បញ្ហា ហើយគេស្គាល់បញ្ហាជាង ហ៊ុន សែន រហូតថា បើសិនជាវារីអគ្គិសនីសេសានត្រូវបានសាងសង់ វានឹងធ្វើឱ្យប៉ះពាល់ផលត្រីរហូតដល់៧០%។ ខ្ញុំបានបង្ហាញការភ្ញាក់ផ្អើល និងផ្តល់ការប្រដៅទៅជាមួយ

ថា "ត្រីនៅក្នុងទន្លេសាប ក្នុងទន្លេមេគង្គទេ ហេតុអីបានជាត្រីយើងវាចេះឡើងភ្នំ? ត្រីខ្មែរវាឆ្លាតណាស់។ ប៉ុន្តែវាឆ្លាតនៅពេលដែលគេប្រឆាំងយើងតែប៉ុណ្ណោះ" ...។

១១. វារីអគ្គិសនី ណាំងឹម ផ្តល់បទពិសោធន៍ពីការគ្រប់គ្រងព្រៃឈើក្នុងអាងដល់កម្ពុជា

សម្ពោធវារីអគ្គិសនីសេសានក្រោម ២ អនុភាព ៤០០ មេហ្គាវ៉ាត់, ១៧ ធ្នូ ២០១៨

... ខ្ញុំបានហោះមើលពីលើបន្តិច ... មុនពេលខ្ញុំព្រះករុណាខ្ញុំស្គាល់វារីអគ្គសនីនៅកម្ពុជា ខ្ញុំព្រះករុណាខ្ញុំស្គាល់វារីអគ្គិសនី២ ជាមុន។ ទី១ វារីអគ្គិសនីនៅក្នុងអតីតសហភាពសូវៀត ... មានវារីអគ្គិសនីមួយកាត់(លើដង)ទន្លេ Volgograd ... ភាគខាងលើនៃវារីអគ្គិសនីនោះ បានក្លាយជាតំបន់ទេសចរណ៍ប្រកបដោយការទាក់ទាញ ហើយមានការស្ងួចត្រីនៅក្នុងតំបន់នោះ។ (ខ្ញុំបាន)ស្គាល់(វារីអគ្គិសនីនេះ)ក្នុងអំឡុងឆ្នាំ១៩៨២ ឬ១៩៨៣។ ឯ**វារីអគ្គិសនីទី២ ... គឺវារីអគ្គិសនី ណាំងឹម ក្នុងប្រទេសឡាវ ដែលយើងបានបើកកាណូតឆ្លងកាត់។ វារីអគ្គិសនី ណាំងឹម នោះ ហើយដែលផ្តល់បទពិសោធន៍មកកម្ពុជា។ វារីអគ្គិសនីនោះបានបិទទំនប់មុនពេលកាប់ឈើចេញ។ បន្ទាប់ពីបិទវារីអគ្គិសនី (ទឹក)លិចព្រៃឈើ។ ក្រោយមកក៏ចាប់ផ្តើមកាប់ឈើនោះលក់។ ក្រុមហ៊ុនប្រទេសមួយចំនួនបានមុជទឹកទៅកាប់ឈើ។ បើអញ្ចឹង យើងត្រូវសិក្សាពីតំបន់ដែលត្រូវលិច រួចហើយត្រូវកាប់ឈើ និងសម្អាតវាកុំឱ្យមានផលប៉ះពាល់ដែលអាចនាំដល់ការបំផ្លាញតួបឹង** ...។

១២. គ្រោះរាំងស្ងួត និងកំណើនសំណង់ ធ្វើឱ្យជួបកង្វះអគ្គិសនីមិនធ្លាប់មាន

បិទសន្និបាតបូកសរុបការងារអប់រំ យុវជន និង កីឡា ឆ្នាំសិក្សា ២០១៧-២០១៨ និងលើកទិសដៅការងារឆ្នាំសិក្សា ២០១៨-២០១៩, ២៧ មីនា ២០១៩

... យើងកំពុងតែធ្វើការជាមួយទួគី។ ថ្ងៃស្អែកនេះ គណៈប្រតិភូទួគីនឹងមកចរចានៅទីក្រុងភ្នំពេញ។ ប្រហែលជាចៀសមិនផុតពីត្រូវអូសនាវាផ្ទុកដោយម៉ាស៊ីនភ្លើងដើរដោយប្រេងខ្មៅ ចូលមកកាន់រាជធានីភ្នំពេញដែលអាចផលិតបាន(បរិមាណអគ្គិសនី)ប្រមាណជា ២០០មេហ្គាវ៉ាត់បន្ថែមទេ។ នេះជារឿងអកុសលសម្រាប់យើង។ **ឆ្នាំនេះមានការហួតហែង ដែលធ្វើឱ្យអគ្គិសនីរបស់យើងជួបកង្វះ(អគ្គិសនី)ប្រមាណ ៤០០មេហ្គាវ៉ាត់។ នេះជារឿងមិនធ្លាប់(ជួបប្រទះ)។ ឯរឿងមួយទៀត ការកើនឡើងខ្លាំងនៃសំណង់ធ្វើឱ្យការវាយតម្លៃពីពេលមុនមកមិនត្រូវទេ។ យើងត្រូវការអគ្គិសនីបន្ថែម**។ តែមុនទៅដល់ការបន្ថែមនោះ គឺមានតម្រូវការយកនាវារបស់ទួគីយកមកជាក់ប្រមាណជា ៣ឆ្នាំសិន។ យើងនឹងស្នើវៀតណាម ថៃ ឡាវ ឱ្យជួយផ្គត់ផ្គង់បន្ថែម ...។

១៣. ភ្លៀងច្រើនធ្វើឲ្យវារីអគ្គិសនីមិនខ្វះទឹក កាត់បន្ថយការប្រើឥន្ធនៈនិងធ្យូងថ្ម

បើកការដ្ឋានពង្រីក និងលើកកម្ពស់កំណាត់ផ្លូវជាតិលេខ៧ ជា ៤គន្លង, ៩ មករា ២០២៣

... កន្លងទៅមានភ្លៀងធ្លាក់។ ដោយសារភ្លៀងធ្លាក់ហ្នឹង ទឹកនៅតាមវារីអគ្គិសនីនៅពេញទាំងអស់ ផ្តល់ឱកាសឲ្យកាត់បន្ថយការខាតបង់ អាស្រ័យដោយ**ប្រទេសយើងប្រើប្រាស់(ឋាមពលអគ្គិសនី)ពីប្រភពកកើតឡើងវិញ ក្នុងនោះពីវារីអគ្គិសនីនិងពន្លឺព្រះអាទិត្យ ហួតប្រមាណ៦២% នៃបរិមាណអគ្គិសនីសរុប។ វារីអគ្គិសនីជាប្រភពដ៏ធំ។ ដោយសារកន្លងទៅភ្លៀងវាច្រើន អាងទឹកក្នុងវារីអគ្គិសនីនៅច្រើន ដែលអាចកាត់បន្ថយការប្រើប្រាស់(ឋាមពលផលិតចេញពី)ធ្យូងថ្មជាដើម ស្របគ្នានឹងការដែលតម្លៃប្រេងក៏កើនធ្យូងថ្មក៏កើន។ យ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលមិនបានតម្លើងថ្លៃអគ្គិសនីទេ ដែល(បើសិនជាតម្លើងថ្លៃអាច)ធ្វើឲ្យប្រជាជនជួបការលំបាក**។ យើងរកែពន់ការលំបាកនេះ មិនថាខាតតិចឬខាតច្រើន។ ប្រសិនបើមិនមានភ្លើងគ្រប់គ្រាន់ទេ វានឹងអាចខាតច្រើនដោយសារវារីអគ្គិសនីមិនបញ្ចេញ(ថាមពល) នាំដល់ការផលិតឋាមពលប្រើប្រេងឥន្ធនៈឬធ្យូងថ្ម ...។

១៤. មិនអនុញ្ញាតអោយធ្វើវារីអគ្គិសនីនៅតំបន់អារ៉ែង

សម្ពោធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខេត្តកំពតជំនួយជប៉ុន, ២ មេសា ២០១៩

... សង្ឃឹមថាអ្វីដែលខ្ញុំបាននិយាយនេះប្រជាពលរដ្ឋនឹងយល់។ ប៉ុន្តែសំរាប់ពួកអ្នកមិនយល់ ក៏សូមមិនយល់ទៀតចុះ ... **ពួកនេះថាយើងផ្តាច់ភ្លើងនេះដើម្បីបានលេសសង់វារីអគ្គិសនីថែម។ សួរថាទៅធ្វើនៅកន្លែងណាឥឡូវនេះ? នៅអារ៉ែងជាច់ខាតមិនឱ្យសង់ទេ។ ប្រាប់ឱ្យហើយ។ ការសិក្សាដោយជប៉ុន(អំពីសមិទ្ធលទ្ធភាពសង់វារីអគ្គិសនី)តាមគម្រោងដើម ក៏ប៉ុន្តែយើងអត់ធ្វើអារ៉ែងទេ។ ខ្ញុំមិនព្រមទេ រឿង(សង់វារីអគ្គិសនីនៅ)អារ៉ែង ដោយសារជាតំបន់អេកូទេសចរណ៍ ហើយដែលយើងត្រូវការពារធនធានធម្មជាតិនៅតំបន់នោះ។ ខ្ញុំជាអ្នកបានប្រកាសថា**

សិក្សាអីក៏សិក្សាទៅ ក៏ប៉ុន្តែអត់ឱ្យធ្វើទេ។ ឥឡូវ យើងកំពុងធ្វើហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបម្រើឱ្យការអភិវឌ្ឍក្នុងតំបន់នោះទៅជាអេកូទេសចរណ៍ ...។

១៥. វារីអគ្គិសនីនៅតែជាជម្រើសដ៏ល្អ ក្នុងការជៀសពីបំពុលបរិស្ថាន

សំណេះសំណាលជាមួយប្រជាពលរដ្ឋ និងពិនិត្យការដ្ឋានសំណង់វារីអគ្គិសនីស្ទឹង ពេធ៏សាត់១ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពេធ៏សាត់, ១៤ មីនា ២០២៣

... ការផលិតឋាមពលអគ្គិសនីបច្ចុប្បន្ន ទាមទារឱ្យធ្វើតាមរបៀបដែលមិនបំពុលបរិស្ថាន។ ដូច្នេះ វារីអគ្គិសនីត្រូវបានចាត់ទុកជាប្រភេទ(ឋាមពលបានពី) ប្រភពកកើតឡើងវិញ ដែលមិនប៉ះពាល់ដល់ការប្រែប្រួលអាកាសធាតុ។ ពិតមែនថា **នៅពេលទប់អាង វាមានផលប៉ះពាល់ដល់ផ្ទៃដីនៅហ្នឹងកន្លែង ដែលត្រូវយកប្រជាពលរដ្ឋចេញ តែបើនិយាយពីការបំពុលបរិស្ថាន ដែលធ្វើឱ្យមានការប្រែប្រួលអាកាសធាតុ រហូតប្រទេសនានាប្រកាសពីការប្តេជ្ញាចិត្តមិនប្រើអគ្គិសនីដើរដោយធ្យូងថ្មថែមទៀតនោះ ក៏ឃើញថាវារីអគ្គិសនីនៅតែជាជម្រើសដ៏ល្អ។ មកដល់ពេលនេះ ឋាមពលអគ្គិសនីក្នុងប្រទេសកម្ពុជាដែលបានពីប្រភពកកើតឡើងវិញ មានរហូតជាង ៦២%។ នៅសល់ជាង៤0% ទៀតដែលយើងកំពុងតែខិតខំ** ... យើងត្រូវតែបង្សំរវាងវារីអគ្គិសនីជាមួយប្រភពដែលបានមកពីពន្លឺព្រះអាទិត្យ ...។

១៦. អគ្គិសនីពីឋាមពលកកើតឡើងវិញ៦២% ចាត់ថាកម្ពុជាមិនបំពុលបរិស្ថានច្រើនទេ

សំណេះសំណាលជាមួយប្រជាពលរដ្ឋ និងពិនិត្យការដ្ឋានសំណង់វារីអគ្គិសនីស្ទឹង ពេធ៏សាត់១ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពេធ៏សាត់, ១៤ មីនា ២០២៣

... បច្ចុប្បន្ន **(ឋាមពលអគ្គិសនីនៅកម្ពុជា)មានជាង ៦២% (ជាឋាមពល) កកើតឡើងវិញ។ អាចថាជាប្រទេសមួយក្នុងចំណោមប្រទេសដែលមិនបំពុលបរិស្ថានច្រើន។ យើងត្រូវការបំពេញ(ឋាមពលអគ្គិសនី)បន្ថែមឱ្យបានច្រើនសំរាប់ការប្រើប្រាស់នាពេលខាងមុខនេះពីប្រភពកកើតឡើងវិញ**។ បើបច្ចេកវិទ្យាអាចស្រាវជ្រាវឃើញថា (ឋាមពលពី)ប្រភពកកើតឡើងវិញ ទោះបីមិនមានពន្លឺព្រះអាទិត្យ(គ្រប់គ្រាន់ ក៏)វានៅតែអាចឱ្យភ្លើងដដែលនោះ ប្រហែលជាល្អ។ ប៉ុន្តែវាមិនអាចទៅរួច។ ឧទាហរណ៍ ពីពន្លឺព្រះច័ន្ទក៏អាចទទួលបានឋាមពល ខ្យល់បក់មកក៏ទទួលបានឋាមពល ឋាមពលកកើតដោយខ្យល់ ...។

១៧. បោះបង់គំរោងវារីអគ្គិសនីស្ទឹងត្រែងនិងក្រចេះ ដើម្បីកាត់បន្ថយបារម្ភរបស់ប្រជាជន

សំណេះសំណាល និងពិសាបាយជាមួយសមាគមអ្នកឧកញ៉ា/ឧកញ៉ា, ២៦ មេសា ២០២៤

... គួររំលឹកថា មុននេះវារីអគ្គិសនី សាយ៉ាបូរី របស់ឡាវ ក៏ត្រូវបានជំទាស់ដែរ។ សាយ៉ាបូរី នៅឃ្លាតពីវៀងច័ន្ទ ១២០០គីឡូម៉ែត្រ ត្រូវគេជំទាស់នៅឯណោះ។ ខ្ញុំបានប្រាប់ ថងលូន (ស៊ីសូលីត) ដែលបច្ចុប្បន្នជាប្រធានរដ្ឋថា មូលហេតុដែលគេជំទាស់ គឺដោយសារតែទំនប់វារីអគ្គិសនីនេះត្រូវបានចិនវិនិយោគ ... ក្រោយមកវារីអគ្គិសនី ដនសាហុង នៅឃ្លាតពីព្រំដែនកម្ពុជា-ឡាវ ២គីឡូម៉ែត្រ។ ឡាវធ្វើវារីអគ្គិសនីនៅតាមដៃមួយនៃទន្លេមេគង្គ។ មានដៃ៥ តែគេធ្វើតែ១ ទេ ... ខ្ញុំប្រាប់ថា ផលិតបានអគ្គិសនីនៅ ដនសាហុង លក់មកឱ្យកម្ពុជាមក ... ខ្ញុំលើកទឹកចិត្តឱ្យធ្វើ។ **ឯយើងបែរជាបោះបង់ចោល គំរោងកសាងវារីអគ្គិសនីនៅស្ទឹងត្រែងនៅសំបូរ/ក្រចេះ ដែលសិក្សាតាំងពីជំនាន់មុនមក ... ដើម្បីកាត់បន្ថយការព្រួយបារម្ភរបស់ប្រជាជនផង ការព្រួយបារម្ភរបស់វៀតណាមផង** ...។

១៨. ធ្វើឱ្យជនបទ/គ្រប់ភូមិ មានអគ្គិសនីប្រើប្រាស់និងទឹកស្អាត

សម្ពោធកំណាត់ផ្លូវជាតិលេខ ៧ ប្រវែង ៩៣,៦៤ គីឡូម៉ែត្រ ពីរង្វង់មូលខ្លាស្ទុះ ទៅឃុំរមៀត ខេត្តក្រចេះ, ៧ កុម្ភៈ ២០២២

សូមសួរថា តើក្រចេះមានអគ្គិសនីប្រើប្រាស់បានគ្រប់ភូមិហើយឬនៅ? បាន ៨៧ ភាគរយហើយឬ? (នៅខ្វះអគ្គិសនីខាងធ្ងាយៗ) ... សម្រាប់ខេត្តដែលអភិវឌ្ឍថ្មីដូចជាខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ព្រះវិហារ (ការមានអគ្គិសនីប្រើប្រាស់តាមភូមិ)អាចយឺតបន្តិច ប្រៀបជាមួយបណ្តាខេត្តនៅភាគខាងក្រោមដែលមានអគ្គិសនីប្រើប្រាស់គ្រប់ភូមិរួចហើយ។ ដោយសារអ្វី? ប្រជាពលរដ្ឋទើបតែទៅចាក់ដីថ្មី ឬក៏ទទួលដីសម្បទានសង្គមកិច្ចថ្មី។ អញ្ចឹងការភ្ជាប់បណ្តាញអគ្គិសនីទៅទីនោះមានការលំបាក ... **យើងនឹងប្តូរផ្តាច់ធ្វើឱ្យគ្រប់ភូមិជនបទមានអគ្គិសនីប្រើប្រាស់។ ឥឡូវ ៩៨ ភាគរយនៃភូមិមានអគ្គិសនីប្រើប្រាស់រួចហើយ។ នៅសល់២ភាគរយទៀតសំដៅទៅលើខេត្តណា? គឺសំដៅលើក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ព្រះវិហារ ដែលជាខេត្តមានការអភិវឌ្ឍថ្មី** ...។

១៩. ភូមិ៩៩% និងផ្ទះ៩០% ទូទាំងប្រទេសបានភ្ជាប់បណ្តាញអគ្គិសនីរួចរាល់

សំណេះសំណាលជាមួយប្រជាពលរដ្ឋ និងពិនិត្យការដ្ឋានសំណង់វារីអគ្គិសនីស្ទឹងពេជ៏សាត់១ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពេជ៏សាត់, ១៤ មីនា ២០២៣

... សូមបងប្អូនទាំង ៣៤២គ្រួសារនៅទីនេះ ដែលមានផលប៉ះពាល់ដោយវារីអគ្គិសនីមានការយោគយល់។ អគ្គិសនីជាតម្រូវការនៃការអភិវឌ្ឍប្រទេសជាតិ។ ពេលដែលយើងធ្វើវារីអគ្គិសនី តិចឬច្រើនគឺមានផលប៉ះពាល់ហើយ។ ប៉ុន្តែ យើងត្រូវដោះស្រាយផលប៉ះពាល់នោះរបៀបម៉េច។ ការជួបជុំថ្ងៃនេះបញ្ជាក់ពីរបៀបដែលយើងដោះស្រាយ(ផលប៉ះពាល់) ... (គឺ)តាមជម្រើសរបស់ប្រជាជនយើង។ ឥឡូវ **នៅទូទាំងប្រទេស ភូមិដែលភ្ជាប់ជាមួយនឹងបណ្តាញជាតិរួចហើយមានដល់ទៅ៩៩% ... ឯផ្ទះប្រជាពលរដ្ឋដែលភ្ជាប់ជាមួយបណ្តាញជាតិរួចហើយមានដល់ទៅ៩០% ... វាជាសម័យប្រើអគ្គិសនី មិនមែនសម័យប្រើចន្លុះដុត ប្រើភ្លើងទៀន/ចង្កៀងមកដុតទៀតទេ** ...៕

២០. ផ្គត់ផ្គង់អគ្គិសនីទៅសិង្ហបុរីតាមបាតសមុទ្រនិងផ្លូវគោក

សំណេះសំណាលជាមួយកម្មកររោងចក្រនៅស្រុកក្រគរ ខេត្តពេជ៏សាត់, ៣០ មិថុនា ២០២៣

... យើងបាន**ចុះហត្ថលេខារួចហើយជាមួយសិង្ហបុរីស្តីពីការផ្គត់ផ្គង់អគ្គិសនីតាមបាតសមុទ្រ។ យើងតភ្ជាប់នាំឋាមពលអគ្គិសនីពីឡាវមក ហើយកម្ពុជាក៏មានអគ្គិសនី ទម្លាក់ទៅបាតសមុទ្រ ឆ្លងកាត់វៀតណាមបន្តិច និងឆ្លងកាត់ម៉ាឡេស៊ី។ ខ្ញុំបានលើក(គំរោងនេះ)ជាមួយនាយករដ្ឋមន្ត្រីម៉ាឡេស៊ី និងជាមួយនាយករដ្ឋមន្ត្រីវៀតណាមរួចហើយ។ សិង្ហបុរីកំពុងមានតម្រូវការឋាមពលអគ្គិសនី ១០០មេហ្គាវ៉ាត់ ដែលទៅតាមផ្លូវគោក ផ្គត់ផ្គង់តភ្ជាប់ពីកម្ពុជាចូលថៃ ចេញពីថៃចូលម៉ាឡេស៊ី ចេញពីម៉ាឡេស៊ី ទៅសិង្ហបុរី**។ បើយើងមានការតភ្ជាប់គ្នាបែបនេះ ទំនាក់ទំនងរវាងយើងជាមួយសិង្ហបុរីក៏មានការល្អប្រសើរ ...៕

២១. ឧស្សាហកម្មបច្ចេកវិទ្យាប្រើថាមពលបៃតង និងគម្រោងលំនៅដ្ឋានតម្លៃសមរម្យ

សំណេះសំណាលជាមួយកម្មកររោងចក្រនៅតំបន់សេដ្ឋកិច្ចពិសេស Manhattan ក្រុងបាវិត ខេត្តស្វាយរៀង, ២៥ មិថុនា ២០២៣

... សូមលោក Clement Yang បន្តទាក់ទាញវិនិយោគចូលតំបន់សេដ្ឋកិច្ចពិសេស Manhattan ... លោក Clement Yang មានគម្រោង ... **ទី១ ទស្សនៈវិស័យ «មួយទសវត្សរ៍ក្នុងការប្រែក្លាយតំបន់សេដ្ឋកិច្ចពិសេសទៅជាតំបន់ឧស្សាហកម្មបច្ចេកវិទ្យាជាន់ខ្ពស់ប្រើប្រាស់ថាមពលបៃតង» ... ទី២ គម្រោងលំនៅដ្ឋានតម្លៃសមរម្យ** ដែលចាប់បើកដំណើរការហើយ ដោយផ្តើមពី ៤០០ខ្នងផ្ទះ ហើយនឹងបន្តទៅ ១០០០ខ្នងផ្ទះក្នុងមួយឆ្នាំ ... យើងកំពុងស្វែងរកអ្នកវិនិយោគផ្ទះតម្លៃទាបតាមប្រាក់ចំណូល ...៕

២២. សូមអភិបាលខេត្តរាជធានី បញ្ជាទិញអំពូលភ្លើងឆ្លាតផលិតដោយទឹកដែកម្ពុជា

អបអរសាទរខួប ១០+១ ឆ្នាំ នៃប្រតិបត្តិការរបស់ក្រុមហ៊ុន មីនេបៀ(Minebea) Cambodia នៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ, ១ ធ្នូ ២០២២

... សូមយកឱកាសថ្លែងការកោតសរសើរចំពោះលោក កៃនុម៉ា ដែលយើងតែងបានជួបគ្នានៅភ្នំពេញ និងនៅតូក្យូ ... ខ្ញុំមានការសប្បាយរីករាយចំពោះផលិតផលនៅក្នុងទឹកន្លែងនេះ។ ទឹកដែកម្ពុជានេះត្រូវបានចែកចាយទៅទីផ្សារពិភពលោក ក្នុងនោះដូចជាអំពូលវៃឆ្លាត ក៏ត្រូវបានបំពាក់ក្នុងប្រទេសជប៉ុន ហើយក៏ត្រូវបានបំពាក់នៅក្នុងប្រទេសកម្ពុជា។ ខ្ញុំ**សូមជម្រាបទៅអភិបាលខេត្តរាជធានី បន្តការប្រើប្រាស់អំពូលវៃឆ្លាតបំភ្លឺតាមដងផ្លូវនានា ដោយធ្វើការបញ្ជាទិញផលិតផលដែលមានស្រាប់ពីរោងចក្រក្នុងប្រទេស។ វាជាផលចំណេញមួយសម្រាប់យើង។ ឧទាហរណ៍ លើដងផ្លូវមួយដំរែង ប្រសិនបើពុំមានរថយន្តឆ្លងកាត់ទេ អំពូលនេះនឹងកាត់បន្ថយពន្លឺ ពេលដែលកាត់បន្ថយពន្លឺក៏ធ្វើឱ្យចំណេញអគ្គិសនីផងដែរ** ...៕

២៣. អ៊ឺរ៉ុបវិលទៅផលិតអគ្គិសនីពីធ្យូងថ្ម បន្ទាប់ពីប្រកាសបោះបង់ពីឆ្នាំ២០០១

សំណេះសំណាលជាមួយប្រជាពលរដ្ឋ និងពិនិត្យការដ្ឋានសំណង់វារីអគ្គិសនីស្ទឹងពេជ៏សាត់ ១ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពេជ៏សាត់, ១៤ មីនា ២០២៣

... ជារួម យើងខំដោះស្រាយតម្រូវការអគ្គិសនី ... គួរនិយាយបន្តិចពីតម្លៃអគ្គិសនី។ នៅអឺរ៉ុប(អគ្គិសនី)ឡើងថ្លៃ។ បច្ចុប្បន្ននេះ ទីផ្សារឈើអឺរ៉ុបមានតម្លៃ។ ហេតុអី? គឺដោយសារប្រទេសអឺរ៉ុបមួយចំនួន (ក្នុងយុទ្ធនាការ)ដាក់ទណ្ឌកម្មលើរុស្សី បានមិនទិញឧស្ម័នពីរុស្សី ... (គោលនយោបាយនេះ បានធ្វើឱ្យ)ប្រជា

ជនដែលធ្លាប់តែប្រើឧស្ម័នកំដៅក្នុងផ្ទះ ឬក៏ចំអិនអាហារ មិនមាន(ឋាមពលដុតកំដៅ) ... (អញ្ចឹង)ហើយទៅកាប់ឧសយកមកដុត ... **ចាប់បង្ខំប្រទេសអឺរ៉ុបមួយចំនួនប្រើប្រាស់ធ្យូងថ្មឡើងវិញ បន្ទាប់ពីបានប្រកាសនៅទូទាំងពិភពលោកកាលពីឆ្នាំ២០២១ ថា មិនកសាងអគ្គិសនីដើរដោយធ្យូងថ្ម។ ទីបំផុត ប្រទេសអឺរ៉ុបមួយចំនួនបានប្រើប្រាស់ធ្យូងថ្មឡើងវិញ។ ដោយហេតុនេះ កិច្ចព្រមព្រៀងប្រែប្រួលអាកាសធាតុលែងមានន័យហើយ ព្រោះប្រទេសដែលនាំគ្នាសន្យាស្តីអំពីការមិនបង្កើតរោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម បានត្រលប់ទៅប្រើធ្យូងថ្មវិញ ...**៕

២៤. ក្រចេះ ស្នឹងត្រែង រតនគីរី មណ្ឌលគីរី អាចជាប៉ូលសេដ្ឋកិច្ចកសិ-ឧស្សាហកម្ម និងធនធានរ៉ែ

សារពិសេសទាក់ទិនទៅនឹងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍
តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA), ២៣ កក្កដា ២០២៤

... ទទួលបានកិច្ចសហប្រតិបត្តិការពីប្រទេសនានា ទើបយើង(មាន)ឱកាសអភិវឌ្ឍ ... **ខ្ញុំចង់(អោយរាជដ្ឋាភិបាលពិចារណា)ថា ចាប់ពីក្រចេះ ស្នឹងត្រែង រតនគីរី មណ្ឌលគីរី ថ្ងៃក្រោយឱ្យទៅជាប៉ូលសេដ្ឋកិច្ចមួយទៀត ជាប៉ូលកសិ-ឧស្សាហកម្ម និងធនធានរ៉ែ ព្រោះនៅតំបន់នោះ សេដ្ឋកិច្ចផ្តើមចេញពីកសិកម្ម ដែលអាចកែច្នៃ ដូចជាកៅស៊ូ ស្វាយចន្ទី និងផ្នែកផ្សេងទៀតសម្រាប់ការនាំចេញ។ មានធនធានរ៉ែដែលកំពុងក្រុមហ៊ុនអូស្ត្រាលីកំពុងតែ(រុករកនិង)ផលិត។ ឯរ៉ែបុកស៊ីតក៏មាន**។ ប្រសិនបើយើងដឹកជញ្ជូនទៅកាន់កំពង់ផែក្រុងព្រះសីហនុ ប្រហែលជាគ្មានផលចំណេញខាងសេដ្ឋកិច្ចទេ។ បើយើងសហការល្អជាមួយវៀតណាម អាចប្រើប្រាស់ការដឹកជញ្ជូនចុះទៅកំពង់ផែ Qui Nhon ព្រោះវាជិតចំណាយតិចជាង។ ឡាវក៏មានការដឹកជញ្ជូនមកចុះមកតាមហ្នឹងដែរ ...៕

២៥. កម្ពុជាមានមាស ក្បាង ធ្យូងថ្ម រ៉ែដែក គ្រាន់តែមិនទាន់បានធ្វើអាជីវកម្ម

ចែកសញ្ញាបត្រជូនដល់និស្សិតនៃសាកលវិទ្យាល័យ វេស្ទើន, ២៦ មករា ២០២៣

... យើងរីករាយទទួលសមិទ្ធផលទាំងអស់នេះ ដែលជាផ្នែកដ៏សំខាន់សម្រាប់ការដោះស្រាយបញ្ហាក្នុងប្រទេសជាតិ។ លើកឧទាហរណ៍ក្នុងតំបន់ថា ប្រទេសដែលមានធនធានធម្មជាតិសម្បូរបែប មិនប្រាកដថាក្លាយទៅជាប្រទេសមានទេ។ ឯប្រទេសដែលគ្មានធនធានធម្មជាតិ ក៏មិនប្រាកដថានឹងមិនក្លាយទៅជាអ្នកមានបានដែរ។ យើងលើកឧទាហរណ៍ក្នុងក្របខណ្ឌអាស៊ាន **ប្រទេសកម្ពុជាយើងគឺជាប្រទេសដែលមានធនធានធម្មជាតិ អាចនិយាយបានថាសម្បូរបែប យើងមានតាំងពីមាសនិងក្បាង។ ធ្យូងថ្មក៏មាន គ្រាន់តែយើងមិនទាន់បានប្រើប៉ុណ្ណឹង។ យើងកំពុងតែជាក់ឱ្យវិនិយោគសម្រាប់អគ្គិសនីដើរដោយធ្យូងថ្ម។ រ៉ែដែកក៏មានតែយើងមិនទាន់បានធ្វើអាជីវកម្ម ...**៕

២៦. ផលិតមាសបានជាង ២តោន សម្រាប់តែរណ្តៅមួយនៅខេត្តមណ្ឌលគីរី

សំណេះសំណាលជាមួយសហគមន៍ខ្មែរនៅសហរដ្ឋអាមេរិក/កាណាដា ប្រមាណ ២ពាន់នាក់ នៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី សហរដ្ឋអាមេរិក, ១២ ឧសភា ២០២២

... អ្នកមួយចំនួនឃោសនាថា តម្លៃប្រេងនៅស្រុកខ្មែរថ្លៃជាងគេទាំងអស់។ (គួរមើលថា)តម្លៃប្រេងនៅអាមេរិកខ្លួនឯងនេះវាយ៉ាងម៉េច? ... តម្លៃប្រេងនៅអាមេរិកដែលជាអ្នកផលិតប្រេង ឬស្តុកប្រេងបម្រុងច្រើនជាងគេនៅលើពិភពលោកម៉េចក៏វាឡើងថ្លៃដែរ។ យើងអត់មានស្តុកបម្រុងផង អត់ទាំងមានផលិតប្រេងផងហ្នឹង។ (ការប្រឹងប្រែង)ផលិត(ប្រេង) មិនទាន់បានប៉ុន្មានផង (ក្រុមហ៊ុន)មួយនោះវាក្រឡាយធនបាត់។ ប៉ុន្តែ (ស្ថានភាព)បែរ(ផ្លាស់ប្តូរ)ទៅអញ្ចេះវិញ។ **ប្រេងផលិតមិនបាន ប៉ុន្តែផលិតមាសបាន។ មកដល់ពេលនេះ រយៈពេល ៨ខែ(ដើមឆ្នាំ) យើងផលិតមាសបានជាង ២តោន។ អញ្ចឹង ចេះតែដំណើរទៅមុខ។ ហ្នឹងតែរណ្តៅមួយកន្លែងនៅមណ្ឌលគិរី។ មិនទាន់គិតកន្លែងផ្សេងទេ ...**៕

២៧. បញ្ជូនដុំមាសខ្វៃទៅចម្រាញ់ជាមាសទឹកដប់នៅអូស្ត្រាលី

សម្ពោធកំណាត់ផ្លូវជាតិលេខ ៧ ប្រវែង ៩៣,៦៤ គីឡូម៉ែត្រ
ពីរង្វង់មូលខ្លាស្នុះ ទៅឃុំរមៀត ខេត្តក្រចេះ, ៧ កុម្ភៈ ២០២២

... យើងទើបនឹងចាប់ផ្តើមផលិតមាសក្នុងរយៈកាល ០៧ខែកន្លងទៅនេះ។ មកដល់ពេលនេះ **មាសមិនទាន់ទៅជាទឹកដប់ទេ ... ខ្ញុំបើកមើលក្នុង WhatsApp ដែលរដ្ឋមន្ត្រី រ៉ែនិងថាមពល ស៊ុយ សែម បានផ្តល់មក ... ជាធម្មតា ថ្ងៃច័ន្ទនិងថ្ងៃសុក្រមានការរាយការណ៍ពីចំនួនមាសដែលផលិតបាន។ ពេលយើងផលិតទៅជាមាសដុំៗ ដុំខ្លះមាន ២០គីឡូ, ដុំខ្លះ ៣០គីឡូ, ដុំខ្លះជាង ១០គីឡូ រួចហើយបានយើង**

ដឹកពីហ្នឹងទៅចម្រាញ់ទៅជាមាស គេហៅថាមាសទឹកដប់ នៅឯប្រទេសអូស្ត្រាលីឯណោះ។ ឥឡូវដំណាំដាំដុះ នៅក្នុងខេត្តទាំងប៉ុន្មាននេះ យើងបាននាំចេញ បើទោះបីយើងមិនទាន់មានការកែច្នៃគ្រប់គ្រាន់ក៏ដោយ ...។

២៨. ក្រុមហ៊ុនអូស្ត្រាលីធំមួយកំពុងសិក្សាទីតាំងផ្សេងទៀតដើម្បីការកនិងផលិតមាស

សម្ពោធអគារក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ៨ វិច្ឆិកា ២០២១

... ខ្ញុំនឹងចេញទៅជួបរដ្ឋមន្ត្រីការបរទេសអូស្ត្រាលី ... ប្រហែលជា(ត្រូវស្តាប់)ការពន្យល់របស់គាត់ឱ្យយើងយល់ពីអ្វីដែលហៅថា AUKUS ឬសម្ព័ន្ធភាពរវាងអូស្ត្រាលី អាមេរិក និងអង់គ្លេស។ ប្រហែលរឿងហ្នឹង សំខាន់ជាងរឿងដទៃ។ នេះបើតាមការស្មានរបស់ខ្ញុំ ... ប៉ុន្តែ កិច្ចសហប្រតិបត្តិការទ្វេភាគីក៏នៅមានរឿងច្រើន។ **ក្នុងរយៈពេលតែប៉ុន្មានខែ យើងដឹកមាសបានជិត ៨០០គីឡូក្រាម គិតពីខែមិថុនា ... ឥឡូវកំពុងសិក្សានៅកន្លែងផ្សេង ដោយក្រុមហ៊ុន(អូស្ត្រាលី)មួយដ៏ធំ ក្នុងកិច្ចសហប្រតិបត្តិការជាមួយគ្នា**។ ទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរក៏មានការកើនឡើង។ ជាមួយនោះ ពេលដែល RCEP(Regional Comprehensive Economic Partnership)ចូលជាធរមាន ... យើងនឹងធ្វើពាណិជ្ជកម្មជាមួយអូស្ត្រាលីកាន់តែច្រើន។ នៅមានអូស្ត្រាលីមេគង្គ អូស្ត្រាលីអាស៊ាន និងអូស្ត្រាលីអាស៊ីបូព៌ា ...។

២៩. ចំណូលពីប្រេង តិចជាងចំណូលពីពន្ធដារ និងគយ

បើកការដ្ឋានសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង និង សម្ពោធរោងចក្រប្រព្រឹត្តកម្មទឹកស្អាតចំការមន, ១ កុម្ភៈ ២០២១

... សូមប្រកាសជូនប្រជាពលរដ្ឋរបស់យើងឱ្យបានជ្រាបថា អណ្តូងប្រេងទី១ បានដំណើរការ ៣៣ថ្ងៃ អណ្តូងទី២ កំពុងតែដំណើរការ ហើយនឹងឈានទៅអណ្តូងទី៣ ទី៤ និងទី៥ **ដែលតាមការប៉ាន់ស្មាន យើងនឹងមានប្រេង ៣០០០ទៅ ៣៥០០បារ៉ែល/ថ្ងៃ ហើយការទទួលប្រាក់ចំណូលនឹងបានប្រមាណជា ៣០លានដុល្លារអាមេរិកតែប៉ុណ្ណោះ ក្នុងពេលដែលចំណូលរបស់យើងពីថ្ងៃម្សិល (ពីពន្ធដារ និងពន្ធគយ) គឺជាថ្ងៃបូកលេខចុងខែ មានជាង ៤០០លានដុល្លារអាមេរិក ក្នុងនោះពន្ធដារបាន ២១៨លាន ពន្ធគយបានប្រមាណ ២០១លាន។ អញ្ចឹង បានជាង**

៤០០លានដែរ។ ចំណូលវាធ្លាក់ចុះតែវាស្ថិតនៅក្នុងរង្វង់លើ ៤០០លានប៉ុណ្ណឹង។ អញ្ចឹង បានជាយើងនៅបន្តដំណើរការជាធម្មតានៃសេដ្ឋកិច្ចរបស់យើង ...។

៣០. អាជីវកម្មប្រេងមិនកាក់កប តែបានផលពីធ្វើមាសវិញ

សម្ពោធដាក់ឱ្យប្រើប្រាស់នូវស្ពានអាកាស និងផ្លូវក្រោមដីចោមចៅ, ៣១ មីនា ២០២២

... ខ្ញុំគួរចែករំលែកព័ត៌មានជូនប្រជាពលរដ្ឋយើងផងដែរថា ការជីកប្រេងនៅឯសមុទ្រនោះវាបង្កើតបានជាបញ្ហា។ ការជីកនោះក៏វាអត់ផល ថែមទាំងត្រូវគេលួចកប៉ាល់រត់ទៅទៀត។ ប៉ុន្តែ **យើងបែរជាមកកាក់កបជាមួយរ៉ែមាសទៅវិញ។ យើងធ្វើរ៉ែមាសចាប់ពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១។ មកដល់ពេលនេះ ៩ខែហើយ យើងផលិតមាសបាន ២២៧៥គីឡូក្រាម។ ពេលដែលយើងយកទៅចម្រាញ់ឱ្យចេញជាមាសទឹកដប់ នឹងបានបរិមាណស្មើនឹងជក១០% ... អញ្ចឹងវាបានជាង២តោន។** ឯសល់ពីនោះវាចេញទៅជាប្រាក់ លង្ហិន ស្ពឺៗថែមទៀត។ វាទៅជាកាត់កងអញ្ចេះទៅវិញ។ ហ្នឹងគិតតែមួយកន្លែងទេ នៅមិនទាន់គិតកន្លែងផ្សេងផង។ យើងចាប់ផ្តើមប្រើប្រាស់ធនធានធម្មជាតិរបស់យើងមួយចំណែក ដែលបាននិងកំពុងរុករក ធ្វើអាជីវកម្ម ដើម្បីបម្រើឱ្យសេចក្តីត្រូវការរបស់ប្រទេសជាតិ ...។

២៣. ទប្បធម៌ និងទេចិត្រសិល្បៈ

១	តា ឆេង ផុន ដឹកនាំសិល្បៈទៅសំដែងនៅកំពង់ធំមុនមកធ្វើរដ្ឋមន្ត្រីប្បធម៌	៤៣៧
២	យកចិត្តទុកដាក់ដល់ធនធានមនុស្សវប្បធម៌ និងសិល្បៈ	៤៣៧
៣	រាល់ការចេញទៅសំដែងនៅកន្លែងដទៃ ត្រូវបំពាក់អត្តសញ្ញាណជាតិ	៤៣៨
៤	បោះប្រក្រតិទិន និងក្របសៀវភៅ ដោយដាក់ព្រឹត្តិការណ៍ជាតិ	៤៣៨
៥	អ្នកសិល្បៈទាំងអស់ត្រូវចេះគ្រប់ទម្រង់	៤៣៩
៦	ជិត៣ទសវត្សនៃជម្លោះប្រដាប់អាវុធ បានបញ្ចៀសប្រាង្គប្រាសាទពីផលប៉ះពាល់	៤៣៩
៧	ក្រោយឆ្នាំ១៩៨៥ មិនឲ្យប្រជាជនតាំងលំនៅនិងស្តារសណ្ឋាគារនៅបរិវេណអង្គរវត្ត	៤៤០
៨	មិនគួរទុកបេតិកភណ្ឌប្រវត្តិសាស្ត្រមនុស្សជាតិ ត្រូវបានលួកលាន់ដោយនយោបាយ	៤៤០
៩	ប៉ុល ពត កាន់កាន់អាសនៈកម្ពុជានៅ អ.ស.ប ធ្វើឱ្យកម្ពុជានិងអង្គរវត្តជាប់ទណ្ឌកម្ម	៤៤១
១០	កម្ពុជាមានប្រាង្គប្រាសាទច្រើនត្រៀមបម្រុងស្នើចុះបញ្ជីបេតិកភណ្ឌពិភពលោក	៤៤១
១១	ពលរដ្ឋបន្តកាន់កាប់ដីតំបន់អង្គរ ប្រាសាទបាត់លក្ខណៈជាបេតិកភណ្ឌពិភពលោក	៤៤២
១២	ពេលចូលជាបេតិកភណ្ឌពិភពលោក ប្រាសាទលែងជារបស់កម្ពុជាតែឯងទៀតហើយ	៤៤២
១៣	អង្គរសង្គ្រោន្តផ្តុំវប្បធម៌អារូបី លើទឹកដីនៃវប្បធម៌រូបី រៀបចំដោយមនុស្ស	៤៤៣
១៤	ជូនតានិងអតីតព្រះមហាក្សត្រ/យានី បានកសាងប្រាង្គប្រាសាទដ៏អស្ចារ្យលើទឹកដី	៤៤៣
១៥	ការពារបេតិកភណ្ឌវប្បធម៌ មានអន្តរសកម្មចំពោះសេដ្ឋកិច្ចនិងសង្គម	៤៤៤
១៦	ធ្វើការអភិរក្សនិងអភិវឌ្ឍវប្បធម៌ ផ្តល់ការងារធ្វើនិងរួមចំណែកបន្ថយភាពក្រីក្រ	៤៤៥
១៧	១០កក្កដា ជាទិវាបញ្ចូលប្រាសាទសំបូរព្រៃគុកជាសម្បត្តិបេតិកភណ្ឌពិភពលោក	៤៤៥
១៨	ដាក់តំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោកបាន ព្រោះមានសន្តិភាព	៤៤៦
១៩	ព្រះមហាក្សត្រ ... គាំទ្រដំណើរការសុំបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុក ...	៤៤៦
២០	បញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកបាន ... មាននយោបាយច្បាស់ពីវប្បធម៌និងសិល្បៈ	៤៤៧
២១	បញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកបាន ព្រោះយន្តការក្នុងនិងក្រៅប្រទេសស៊ីសង្វាក់គ្នា	៤៤៧
២២	បញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកបាន ត្បិតប្រជាជនគាំទ្រការដឹកនាំបក្សកាន់អំណាច	៤៤៨
២៣	បញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកបាន ត្បិតនយោបាយការបរទេសបានការគាំទ្រពីមិត្ត	៤៤៩
២៤	អភិវឌ្ឍនិងអភិរក្ស(តំបន់ប្រាសាទ)តាមផែនការមេ ជាអនុសាសន៍ពីយូណេស្កូ	៤៤៩
២៥	ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ពិសេសប្រព័ន្ធផ្លូវនិងសៅ ក្នុងតំបន់ប្រាសាទសំបូរព្រៃគុក	៤៥០

២៦	ទាំងអស់គ្នាជាកូនកតញ្ញូ ចូលរួមការពារវប្បធម៌ជាតិពីដូនតា ទាំងរូបីនិងអរូបី	៤៥០
២៧	អង្គរសង្ក្រាន្ត ផ្តល់ភាពស្រស់ថ្លាយនិងស្មាមញ្ញឹមចេញពីចិត្តបងប្អូនខ្មែរនិងភ្ញៀវអន្តរជាតិ	៤៥១
២៨	អង្គរសង្ក្រាន្ត ឆ្លុះបញ្ចាំងពីសាមគ្គីភាព ឯកភាព មិត្តភាព គ្រួសារខ្មែរ	៤៥១
២៩	អង្គរសង្ក្រាន្តបង្ហាញវប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ ប្រពៃណី ... ពីសម័យមហានគរ	៤៥១
៣០	គំនិតច្នៃប្រឌិតអង្គរសង្ក្រាន្ត នាំអោយកើតមានសង្ក្រាន្តនៅច្រើនកន្លែង	៤៥២
៣១	កត្តា៤ ធ្វើឱ្យប្រជាពលរដ្ឋអាចចូលរួមពិធីបុណ្យប្រពៃណីជាមួយគ្រួសារ	៤៥២
៣២	កត្តា៦ ដែលនាំទៅដល់ការរៀបចំអង្គរសង្ក្រាន្តបានដោយរីករាយនិងជោគជ័យ	៤៥៣
៣៣	បេះដូងក្រដាសនៃព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ជាការគិតគូរដ៏ស៊ីជម្រៅរបស់យុវជន	៤៥៤
៣៤	លើកកម្ពស់សមត្ថភាពអ្នកនិពន្ធ អ្នកដឹកនាំរឿង និងតួសំដែង	៤៥៤
៣៥	ធ្វើឱ្យភាពយន្តខ្មែរទទួលបានការពេញនិយមពីសំណាក់ប្រជាជនកម្ពុជាឡើងវិញ	៤៥៥
៣៦	ហ៊ុន សែន នៅធ្វើជានាយករដ្ឋមន្ត្រី ពន្ធមិនត្រូវបានមិនដាក់បន្ទុកលើសិល្បៈ	៤៥៥
៣៧	រុញវប្បធម៌ទៅក្នុងវិស័យអប់រំ ដើម្បីការពារ/លើកកំពស់ការស្រលាញ់វប្បធម៌ជាតិ	៤៥៦
៣៨	ការកសាងរូបសំណាក ឬបដិមា ត្រូវតែធ្វើឲ្យបានត្រឹមត្រូវតាមវចនាបថ	៤៥៦
៣៩	ទោះបីមានសម្ភារៈទំនើប សូមរក្សាទំនៀមទំលាប់ របស់របរពីអតីតកាល	៤៥៧
៤០	សូមពុទ្ធបរិស័ទជួយព្រះសង្ឃ រក្សាភ្លេងពិណពាទ្យ និងឆៃយ៉ាំ	៤៥៧
៤១	តើអាចសន្ទនាជាមួយប្រទេសពាក់ព័ន្ធ ចុះបញ្ជីរួមគ្នានូវសម្បត្តិវប្បធម៌អរូបីបានទេ	៤៥៨
៤២	មរតកវប្បធម៌ខ្លះ ក៏មិនអាចចុះបញ្ជីរួមគ្នាបាន	៤៥៨
៤៣	ទោះចុះបញ្ជីរួមគ្នាតាមអនុសាសន៍ UNESCO ក៏របស់យើងនៅតែជារបស់យើង	៤៥៩
៤៤	ប្រើវិធីសាស្ត្រទូតជំរុញវប្បធម៌ និងទំនាក់ទំនងវប្បធម៌ជំរុញទំនាក់ទំនងនយោបាយ	៤៥៩
៤៥	"កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូណ៌មី" ព្រោះកើតថ្ងៃ ១៥កើត ខែស្រាពណ៌	៤៦០
៤៦	"កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូណ៌មី" ជារឿងពិត មិនអាចថតសំដែងខុសបានទេ	៤៦០
៤៧	ដល់ពេលត្រូវថតរឿង «កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូណ៌មី» ជាខ្សែភាពយន្ត	៤៦១
៤៨	តួអង្គ ហ៊ុន សែន ផ្សារភ្ជាប់ការរស់រានមានជីវិតរបស់ប្រជាជននិងសន្តិភាព ...	៤៦១
៤៩	អរគុណសហរដ្ឋអាមេរិកនិងចក្រភពអង់គ្លេស នាំមកវិញនូវសម្បត្តិវប្បធម៌ខ្មែរ	៤៦២
៥០	ប្រទេសដទៃគប្បីចូលរួមជួយនាំសម្បត្តិវប្បធម៌កម្ពុជាត្រឡប់មកជួបជុំវិញ	៤៦៣
៥១	សង្ក្រាមពង្រាត់ពូជពង្សព្រះអាទិទេព សន្តិភាពធ្វើអោយគ្រួសារព្រះអាទិទេពជួបជុំគ្នា	៤៦៣
៥២	សិល្បៈទម្រង់ធំស៊ីហ្គេមបង្ហាញពីភាពស៊ីសង្វាក់គ្នារវាងចលនាមនុស្សនិងឌីជីថល	៤៦៣
៥៣	សូមកុំឱ្យប្រវត្តិសាស្ត្រមានបញ្ហូលគំនិតអ្នកនិពន្ធ ធ្វើអោយរឿងខុសពីការពិត	៤៦៤
៥៤	ប្រទេសរីកចម្រើន ការធ្វើបុណ្យទានកាន់តែច្រើន តម្រូវការអាចារ្យនិងសិល្បៈកើន	៤៦៤
៥៥	មិនមានការឈ្លានពានវប្បធម៌ទេ មានតែការទទួលយកដោយស្ម័គ្រចិត្ត	៤៦៥
៥៦	ខ្មែរក្បាអក្សរនិងវប្បធម៌តាមទីវត្តអារាម បារាំងឲ្យកត់ត្រានិងរក្សាទុកល្បើកក្រម ង៉ុយ	៤៦៦
៥៧	នាយករដ្ឋមន្ត្រីបង្ហាញទស្សនីយ៍ភាពសិល្បៈច្រើនឈុតឆាកក្នុងពិធីជប់លៀង	៤៦៦

១. តា ឆេង ផុន ដឹកនាំសិល្បៈទៅសំដែងនៅកំពង់ធំមុនមកធ្វើរដ្ឋមន្ត្រីវប្បធម៌

ទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ១៩ និងពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេស, ៣ មីនា ២០១៧

... តាណៃ ដើរជាមួយខ្ញុំមិនដាបានច្រើនប៉ុន្មានទេ។ អ្នកដែលដើរជាមួយខ្ញុំច្រើនគឺ តាឈួន។ តាឈួន ធ្លាប់ទៅសម្រាកដល់ផ្ទះដីដូនជីតារបស់ខ្ញុំ ... តាំងពីឆ្នាំ ១៩៨១ ... យើងកម្សត់កម្រជាមួយគ្នា។ **យើងធ្វើតាំងពីជំនាន់តា(ឆេង)ផុនដឹកនាំសិល្បៈ(ទៅសំដែង)នៅកំពង់ធំ មុនមកធ្វើរដ្ឋមន្ត្រីវប្បធម៌(និងវិចិត្រសិល្បៈ)។ តាផុន បានធ្វើមរណកាលទៅហើយ**។ គួរអោយសោកស្តាយ។ ពីដើម **សិល្បៈរបស់យើងត្រូវពាក់អាវុធ ហើយអត់ហ៊ានលេងពេលយប់ទេ ហ៊ានលេងតែពេលថ្ងៃ ព្រោះខ្មែរក្រហមធ្វើសកម្មភាពពេលយប់។ ដល់ខ្មែរក្រហមចូលមកទៀតពេលថ្ងៃ យក្សក៏កាន់កាំភ្លើងរត់ចូលលេណដ្ឋានការពារខ្លួនពីខ្មែរក្រហម។ ឥឡូវនេះ ក្មួយៗទៅសឹងគ្រប់កន្លែង ហើយពូមើលទៅឃើញមនុស្សច្រើន។ សម័យដើម អត់មានអញ្ចឹងទេក្មួយអើយ។ពេលលេងហ្នឹងភ្នែកនៅហ្នឹងកញ្ចឹងកមិនមានអគ្គិសនីអញ្ចឹងទេ មានតែចង្កៀង** ... ៕

២. យកចិត្តទុកដាក់ដល់ធនធានមនុស្សវប្បធម៌ និងសិល្បៈ

ទិវាវប្បធម៌ជាតិ ៣មីនា លើកទី១៩ និងពិធីបិទមហោស្រពសិល្បៈយុវជន ទូទាំងប្រទេស, ៣ មីនា ២០១៧

... ថ្ងៃក្រោយ គឺ**យើងពង្រីកលទ្ធភាពកាន់តែធំ ព្រោះថា បើគ្មានធនធានមនុស្សយើងក៏មិនអាចធ្វើអីកើតដែរ។ ក្នុងហ្នឹង ខ្ញុំក៏បាននិយាយជាមួយរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈពីធនធានក្នុងវិស័យសិល្បៈ ថាឲ្យយកចិត្តទុកដាក់មើលផង ប្រយ័ត្នដាច់ពូជ។** ដាច់ពូជយ៉ាងម៉េច? បានសេចក្តីថា អ្នកចាស់ស្លាប់ ឬចូលនិវត្តន៍ទៅរើសថ្មីវាអត់បាន។ អញ្ចឹងត្រូវតែឲ្យក្របខណ្ឌខ្លះមកក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដែលវិស័យវប្បធម៌ និងសិល្បៈនេះមានច្រើនទម្រង់ណាស់ តាំងពីរបាំ ចម្រៀង សូនរូប តាំងពីអក្សរអង្គរស្មើៗច្រើនណាស់ ... ៕

៣. រាល់ការចេញទៅសំដែងនៅកន្លែងដទៃ ត្រូវបំពាក់អត្តសញ្ញាណជាតិ

ទិវាប្បធម៌ជាតិ ៣មីនា លើកទី១៩ និងពិធីបិទមហោស្រពសិល្បៈយុវជន ទូទាំងប្រទេស, ៣ មីនា ២០១៧

... បើយើងនៅតែប្រុំដែល វានឹងនៅតែដដែលហ្នឹង។ វាតែងមានការវិវឌ្ឍរបស់វា។ **ការវិវឌ្ឍណាក៏ដោយ ត្រូវតែបំពាក់អត្តសញ្ញាណជាតិឲ្យបាន រាប់ទាំងក្មួយៗ ដែលជាសិល្បករ សិល្បការិនី ដែលចេញទៅសម្តែងតាមការប្រគំតន្ត្រីនានា តែងមានក្រមរំរបស់ខ្លួន។ ក្រមរាំនោះ ប្រសិនបើមិនមានបំពាក់អត្តសញ្ញាណជាតិរបស់ខ្លួនខ្លះ អាចនឹងត្រូវគេប្តឹងពីប្រទេសក្រៅមកថាលួចកម្មសិទ្ធិបញ្ញាគេ។ ដូច្នេះ គប្បីម្ខាងបំពាក់អត្តសញ្ញាណជាតិ និងម្ខាងទៀតកម្មសិទ្ធិបញ្ញា** ដើម្បីចៀសវាងការដែលគេប្តឹងពីក្រៅប្រទេសមកថាលួចក្បាច់រំរបស់គេមក ... ត្រូវបំពាក់នូវអត្តសញ្ញាណមួយនៅក្នុងចំណោមក្រុមក្មួយៗសិល្បករ/ការិនី ដែលទៅសម្តែងតាមស្ថានីយទូរទស្សន៍នានា នៅតាមបណ្តាខេត្ត ឬក៏តាមកន្លែងសម្តែងនានា ...៕

៤. បោះប្រក្រតិទិន និងក្របសៀវភៅ ដោយដាក់ព្រឹត្តិការណ៍ជាតិ

ទិវាប្បធម៌ជាតិ ៣មីនា លើកទី១៩ និងពិធីបិទមហោស្រពសិល្បៈយុវជន ទូទាំងប្រទេស, ៣ មីនា ២០១៧

... យើងត្រូវសហការគ្នាជាចង្កោម ... **មានផ្នែកជាច្រើនដែលបោះប្រក្រតីទិន ដូចជាក្រសួងវប្បធម៌ ឬក៏ក្រសួងទេសចរណ៍ ឬក៏ក្រុមហ៊ុនខ្លះ ជាក្រុមហ៊ុនទេសចរណ៍ជាក្រុមហ៊ុនស្តី។ ហ្នឹង គប្បីសហការគ្នាដើម្បីឲ្យពលរដ្ឋបានចាំ។ អ្នកខ្លះចាំហើយ ប៉ុន្តែវាភ្លេច។ សព្វថ្ងៃ យើងបោះ(ប្រក្រតីទិន) ថ្ងៃនេះថ្ងៃសីល ថ្ងៃនេះថ្ងៃមាឃបូជា ថ្ងៃនេះថ្ងៃពិសាខបូជា។ យើងគ្រាន់តែថែមថាថ្ងៃទី ៧កក្កដា ២០០៨ ជាថ្ងៃដាក់បញ្ចូលប្រាសាទព្រះវិហារជាបេតិកភណ្ឌពិភពលោក ... ហ្នឹងក៏ជារបៀបសហការមួយឲ្យមានការចងចាំ**។ ចំណុចអស់ទាំងនេះ សូម្បីតែការបោះសៀវភៅក្មេងរៀនក៏យើងអាចធ្វើបានដែរ។ ខ្ញុំទៅណា ខ្ញុំតែងចែកសៀវភៅ។ **អញ្ចឹងទេតែខុទ្ទកាល័យរបស់ខ្ញុំដែលទទួលបន្ទុកចែកសៀវភៅនេះ គួរដាក់ប៉ុន្មានចំណុចលើក្របសៀវភៅ** ... ពេលឃើញក្របសៀវភៅ ក្មេងចាំតែម្តង។ មានរឿងច្រើនដែលយើងអាចធ្វើជាមួយ

គ្នា។ កុំធ្វើដាច់ដោយឡែក។ យើងត្រូវចងក្រងការងារជាក្រុម។ បណ្តាញសារព័ត៌មាននានាក៏អាចជួយរួមចំណែកដែរ ...៕

៥. អ្នកសិល្បៈទាំងអស់ត្រូវចេះគ្រប់ទម្រង់

ទិវាប្បធម៌ជាតិ ៣មីនា លើកទី១៩ និងពិធីបិទមហោស្រពសិល្បៈយុវជន ទូទាំងប្រទេស, ៣ មីនា ២០១៧

... អ្វីដែលខ្ញុំចង់និយាយនៅពេលនេះចង់សំដៅទៅដល់ក្មួយៗ ជាយុវសិល្បករ សិល្បការិនី។ ក្មួយ ឱក សុគន្ធកញ្ញា ក៏ដូចជា ធន សុវណ្ណរាជ មកច្រៀងនៅទីនេះ។ បើយើងនិយាយអំពីសម្លេងរបស់ក្មួយៗ ពិតជាខ្លាំង ប៉ុន្តែពូចង់មានយោបល់អញ្ចេះ បើយើងចេះតែមួយទម្រង់គឺប្រហែលជាមានការលំបាកពេលក្រោយ ... **ទាំងអ្នកមានសម្លេង(ល្អ)ច្រៀងតាមបែបបុរាណ បែបប្រពៃណី ទាំងអ្នកតាមបែបសម័យ គួរតែហ្វឹកហាត់ទាំងសងខាង ទើបអាចក្លាយជាមនុស្សអ្នកដែលអាចទ្រទ្រង់បានច្រើនទម្រង់** ... អ្នកចម្រៀងពីដើមដែលល្បីៗ ដូចជា ស៊ិន ស៊ីសាមុត មិនមែនចេះច្រៀងតែមួយទម្រង់ទេ ... គ្រាន់តែឃើញក្មួយៗ លោត ពូហត់ជួសហើយ។ ហ្នឹងក្មួយនៅលោតបាន។ តែដល់ពេលក្មួយលោតលែងបាន អ្នកណាជួលក្មួយទៅទៀត។ **អញ្ចឹងត្រូវចាប់ផ្តើមមានទម្រង់មួយផ្សេងដែលមិនមែនទម្រង់លោត។ បើយោងទៅលើសម្លេងក្មួយៗ អាចច្រៀងបានគ្រប់ទម្រង់ ... គួរតែចេះច្រើនទម្រង់ ល្អជាងចេះតែមួយទម្រង់។ ឯអ្នកដែលចេះភ្លេងការក៏គួរតែត្រូវចេះច្រៀងបទសម័យ** ...៕

៦. ជិត៣ទសវត្សនៃជម្លោះប្រដាប់អាវុធ បានបញ្ចៀសប្រាង្គប្រាសាទពីផលប៉ះពាល់

ពិធីបើកការប្រារព្ធខួប ២៥ឆ្នាំនៃការបង្កើតគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្চគាំពារនិងអភិវឌ្ឍតំបន់អង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ, ៤ ធ្នូ ២០១៨

... ខ្ញុំនៅចាំបានថា ថ្ងៃទី២ធ្នូ ១៩៨៧ នៅហ្វ្រីអង់តាជីណារ ប្រទេសបារាំង ពេលចរចាលើកដំបូង រវាងសម្តេចព្រះនរោត្តម សីហនុ និងខ្លួនខ្ញុំ យើងក៏បានពិភាក្សាពាក់ព័ន្ធនឹងការបញ្ចៀសការប្រយុទ្ធគ្នានៅតំបន់ដែលមានប្រាង្គប្រាសាទនានា ជាបេតិកភណ្ឌ។ **ទោះបីជាយើងមានជម្លោះប្រដាប់អាវុធ ក៏ប៉ុន្តែយើងខិតខំបញ្ចៀសគ្រោះថ្នាក់ដែលអាចប៉ះពាល់ដល់ប្រាង្គប្រាសាទដែលជាមរតកជូនតាយើង**។ នេះ

គឺជាចំណុចរួមរវាងខ្ញុំនិងសម្តេចព្រះបិតាជាតិ ព្រះនរោត្តម សីហនុ ពេលចាប់ផ្តើមចរចារកដំណោះស្រាយនយោបាយដើម្បីបង្រួមបង្រួមជាតិ។ នេះក៏នាំទៅដល់ចំណុចរួមនៃបណ្តាភាគីពាក់ព័ន្ធ ដែលក្នុងរយៈពេលសង្គ្រាមក្នុងប្រទេសកម្ពុជា រយៈកាលជិត ៣ទសវត្សរ៍ យើងបានបញ្ឈៀសការប្រយុទ្ធនៅក្បែរកន្លែងដែលមានប្រាង្គប្រាសាទ។ លើកលែងតែក្នុងរបប ប៉ុល ពត ទេ ដែលមានប្រាសាទខ្លះ ដូចជានៅខេត្តកំពង់ចាម ត្រូវគេរុះរើយកទៅធ្វើជាទំនប់ទឹក។ ជាក់ឮសំណាងមួយ ដែលប្រាង្គប្រាសាទមិនបានរងការវាយប្រហារដោយគ្រាប់ផ្លោង គ្រាប់បែកនិងការបំផ្លាញដោយការប្រយុទ្ធគ្នានោះទេ ...។

៧. ក្រោយឆ្នាំ១៩៨៥ មិនឲ្យប្រជាជនតាំងលំនៅនិងស្ពារសណ្ឋាគារនៅបរិវេណអង្គរវត្ត

ពិធីបើកការប្រារព្ធខួប ២៥ ឆ្នាំនៃការបង្កើតគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍតំបន់អង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ, ៤ ធ្នូ ២០១៨

... ប្រសិនបើគ្មានដំណោះស្រាយក្រោយឆ្នាំ ១៩៨៥ ពេលដែលខ្ញុំបានក្លាយខ្លួនជានាយករដ្ឋមន្ត្រីហើយធ្វើការសម្រេចចិត្តដ៏លំបាកមួយទេ អង្គរវត្តមិនគ្រប់លក្ខណសម្បត្តិក្លាយជាបេតិកភណ្ឌពិភពលោកនោះឡើយ។ អ្នកទាំងអស់គ្នាអាចនៅចាំបានថា កាលពីទសវត្សរ៍៦០ មានសណ្ឋាគារហូតទៅដល់២ នៅទល់មុខភ្លោងទ្វារចូលអង្គរវត្ត។ បន្ទាប់ពីរំដោះប្រទេសនៅខេត្តសៀមរាបយើងអនុញ្ញាតឲ្យប្រជាពលរដ្ឋតាំងទីលំនៅមុខអង្គរវត្ត។ **(គ្រានោះ)ក៏មានការប៉ុនប៉ងស្ពារឡើងវិញនូវសណ្ឋាគារចាស់ៗ ដែលនៅសល់គ្រឹះមួយចំនួននៅទល់មុខប្រាង្គប្រាសាទ។ ពេលនោះ ខ្ញុំមិនត្រឹមតែមិនយល់ស្របជាមួយនឹងការស្តារបែបនេះទេ តែនៅបានស្នើសុំឲ្យមានការផ្លាស់ប្តូរទីលំនៅប្រជាពលរដ្ឋចេញពីតំបន់នោះ ហើយយកដីទាំងនោះដាំដើមឈើ។ ឥឡូវ ដើមឈើ(ដែលបានដាំ)តាំងពីឆ្នាំ ១៩៨៥-៨៦ រហូតមកដល់ពេលនេះ (មានអាយុ)ជាង ៣០ឆ្នាំទៅហើយ** ...។

៨. មិនគួរទុកបេតិកភណ្ឌប្រវត្តិសាស្ត្រមនុស្សជាតិ ត្រូវបានលួកលាន់ដោយនយោបាយ

ពិធីបើកការប្រារព្ធខួប ២៥ឆ្នាំនៃការបង្កើតគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍតំបន់អង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ, ៤ ធ្នូ ២០១៨

... សៀមរាបគ្មានមនុស្សនៅទេ។ យើងខ្ញុំចាប់ផ្តើមពីសណ្ឋាគារចាស់ៗតែ២ទេ។ ឥឡូវនេះ យើងមានសណ្ឋាគារជាង១០០ ... (រហូត)អ្នកខ្លះ ដោយឃើញសកម្មភាពជីវភាពប្រជាជនធម្មតា ទេសចរមកពាសពេញ ហាក់ដូចជាភ្លេចគិតថា "តើកម្ពុជាបានជួបរឿងអ្វីខ្លះពីអតីតកាល" ... គ្រប់ទីក្រុងក្នុងប្រទេសកម្ពុជា គ្មានមនុស្សនៅទេ រាប់ទាំងទីក្រុងភ្នំពេញនិងទីក្រុងសៀមរាប ... សូម្បីតែអង្គរវត្តក៏ត្រូវជាប់ទណ្ឌកម្មអន្តរជាតិផងដែរ ... **អង្គរវត្ត ព្រះវិហារឬប្រាង្គប្រាសាទនៅក្នុងប្រទេសកម្ពុជា ជាប់ទៅក្នុងទណ្ឌកម្មនយោបាយ និងការហ៊ឹមព័ទ្ធពីខាងក្រៅ។ នេះជាចំណុចដែលត្រូវតែដកពិសោធន៍។ វាមិនមែនគ្រាន់តែជាបញ្ហាកម្ពុជាមួយទេ ក៏ប៉ុន្តែគួរដកពិសោធន៍សម្រាប់ពិភពលោកផងដែរ។ មិនគួរទុកឲ្យបេតិកភណ្ឌប្រវត្តិសាស្ត្ររបស់មនុស្សជាតិតាមបណ្តាប្រទេសនានា (ត្រូវបាន)លួកលាន់ដោយនយោបាយទេ** ...។

៩. ប៉ុល ពត កាន់កាន់អាសនៈកម្ពុជានៅ អ.ស.ប ធ្វើឱ្យកម្ពុជានិងអង្គរវត្តជាប់ទណ្ឌកម្ម

ពិធីបើកការប្រារព្ធខួប ២៥ឆ្នាំនៃការបង្កើតគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍតំបន់អង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ, ៤ ធ្នូ ២០១៨

... ដោយសារតែអង្គការសហប្រជាជាតិនៅមានការទទួលស្គាល់ និងឲ្យពួកប៉ុល ពត កាន់កាប់អាសនៈកម្ពុជា យើងខ្ញុំមិនបានទទួលជំនួយបរទេសណាមកជួយ(ប្រាង្គប្រាសាទ ដែលសូម្បី)អង្គរវត្តក៏ត្រូវទទួលទណ្ឌកម្ម ... ជាក់ឮសំណាងរបស់យើងខ្ញុំដែលមានសាស្ត្រាចារ្យជប៉ុនមកសិក្សា ហើយបានពិភាក្សាជាមួយយើងខ្ញុំជាទៀងទាត់។ ក្រោយមក រដ្ឋាភិបាលឥណ្ឌាក៏បានបញ្ជូនអ្នកបច្ចេកទេសមកជួយសង្គ្រោះក្នុងដំណាក់កាលទសវត្សរ៍៨០។ អញ្ចឹង នេះក៏ជាបទពិសោធន៍សំរាប់អង្គការសហប្រជាជាតិ ឬក៏(ដូច)ជា(ស្ថាប័នពាក់ព័ន្ធ)នានាថា មិនត្រូវប្រើប្រាស់(ការដាក់)ទណ្ឌកម្មណាមួយ ដែលសូម្បីតែបេតិកភណ្ឌឬសម្បត្តិវប្បធម៌ ក៏ត្រូវទទួលរងគ្រោះដែរនោះទេ ...។

១០. កម្ពុជាមានប្រាង្គប្រាសាទច្រើនត្រៀមបម្រុងស្នើចុះបញ្ជីបេតិកភណ្ឌពិភពលោក

ពិធីបើកការប្រារព្ធខួប ២៥ឆ្នាំនៃការបង្កើតគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍតំបន់អង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ, ៤ ធ្នូ ២០១៨

... ការគ្រប់គ្រងបេតិកភណ្ឌមិនមែនជាការងាយស្រួលទេ។ ពេលខ្លះយើងត្រូវមានជម្រើស។ ខ្ញុំលើកឡើងចំណុចនេះដើម្បីជាបទពិសោធន៍ហើយក៏ជា**សារនេះយោបាយជូនបណ្តាបក្សនយោបាយទាំងអស់នៅកម្ពុជា សូមកុំញុះញង់ប្រជាពលរដ្ឋទៅកាន់កាប់(ដីក្នុង)តំបន់បេតិកភណ្ឌ និងមិនមែនតែ(ដីក្នុង)តំបន់បេតិកភណ្ឌដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌនោះទេ។ យើងមានប្រាង្គប្រាសាទច្រើននៅក្នុងប្រទេសកម្ពុជា ដែលត្រៀមបម្រុង(សំរាប់ស្នើ)ជាក់បញ្ចូលបណ្តីរៗ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ... មិនមានជំរើសទេ ដែលពេលខ្លះ យើងខ្ញុំក្លាយទៅជារដ្ឋាភិបាលរំលោភសិទ្ធិមនុស្សក្នុងការតាំងលំនៅស្ថាន ...**។

១១. ពលរដ្ឋបន្តកាន់កាប់ដីតំបន់អង្គរ ប្រាសាទបាត់លក្ខណៈជាបេតិកភណ្ឌពិភពលោក

ពិធីបើកការប្រារព្ធខួប ២៥ឆ្នាំនៃការបង្កើតគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍតំបន់អង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ, ៤ ធ្នូ ២០១៨

... លោកជំទាវអគ្គនាយិកាក៏ដូចជាគណៈប្រតិភូទាំងអស់អាចចោទជាសំណួរថា មុននឹងអនុញ្ញាតឲ្យចូលជាសម្បត្តិបេតិកភណ្ឌពិភពលោក ច្បាស់ណាស់ត្រូវមានលក្ខខណ្ឌតម្រូវឱ្យធ្វើយ៉ាងម៉េចៗ ...ឧ. តំបន់អង្គរ មានការហាមប្រាមសាងសង់សំណង់ខ្ពស់ឬចំណុចនេះចំណុចនោះ។នៅកម្ពុជា**យើងខ្ញុំមានចំណុចអភ័ព្វត្រង់ថា ក្នុងពេលយុទ្ធនាការបោះឆ្នោតម្តងៗ តែងតែមានអ្នកប្រើមនុស្សឱ្យទៅរំលោភដីនៅជុំវិញប្រាង្គប្រាសាទ។អញ្ចឹងតើយើងខ្ញុំត្រូវធ្វើយ៉ាងម៉េចវាងជំរើសពីរ? បើសិនជាគោរពសិទ្ធិតាំងទីលំនៅរបស់ប្រជាពលរដ្ឋ ដោយឱ្យបន្តកាន់កាប់ដីធ្លីនៅកន្លែងនោះ ប្រាសាទនឹងបាត់បង់លក្ខណៈលែងក្លាយជាបេតិកភណ្ឌពិភពលោកហើយ។ ប៉ុន្តែ ដើម្បីក្សាលក្ខណៈជាបេតិកភណ្ឌពិភពលោក យើងខ្ញុំគ្មានជំរើសណាផ្សេងក្រៅពីរុះរើផ្ទះសំបែងនោះ ឲ្យប្រជាពលរដ្ឋនោះចាកចេញទៅ (តាំងលំនៅ)កន្លែងផ្សេងទេ ...**។

១២. ពេលចូលជាបេតិកភណ្ឌពិភពលោក ប្រាសាទលែងជារបស់កម្ពុជាតែឯងទៀតហើយ

ពិធីបើកការប្រារព្ធខួប ២៥ឆ្នាំនៃការបង្កើតគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍតំបន់អង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ, ៤ ធ្នូ ២០១៨

... ត្រង់នេះហើយដែលគេចោទរដ្ឋាភិបាលខ្ញុំ ជារដ្ឋាភិបាលផ្តាច់ការរំលោភសិទ្ធិមនុស្ស រំលោភសិទ្ធិលំនៅស្ថាន ដោយគេមិនបានស្វែងយល់ថាតើអ្វីទៅជាមូលហេតុពិតប្រាកដ ... **ខ្ញុំចង់បានការវិនិច្ឆ័យពិតប្រាកដជាក់លាក់ថា តើការ(ធ្វើដូច)នេះជាការរំលោភសិទ្ធិមនុស្ស ដោយជម្លៀសមនុស្សដោយបង្ខំ ឬក៏យើងត្រូវការពារបេតិកភណ្ឌរបស់មនុស្សជាតិ? ពេលដែលយើងជាក់(ប្រាសាទ)ចូលជាបេតិកភណ្ឌពិភពលោក វាមិនមែនជារបស់កម្ពុជា(តែឯង)ទៀតទេ។ នៅឯព្រះវិហារ ប្រជាជនបានតាំងទីលំនៅលើកសិណ។យើងខ្ញុំត្រូវតែដោះដូរដោយប្រគល់ដីថ្មីជូនពួកគាត់ដើម្បីយើងយកទីកន្លែងនេះស្តារនិងជួសជុលកសិណឡើងវិញ**។ បើមិនដូច្នេះ ព្រះវិហារក៏នឹងបាត់បង់លក្ខណៈសម្បត្តិជាបេតិកភណ្ឌពិភពលោកផងដែរ។ បញ្ហានេះមិនងាយស្រួលទេ។វាប្រៀបដូចជាកាន់ដុំថ្មក្តៅអញ្ចឹង ...**។**

១៣. អង្គរសង្ក្រាន្តផ្តុំប្បធម៌អរូបី លើទឹកដីនៃប្បធម៌រូបី រៀបចំដោយមនុស្ស

ពិធីបើកអង្គរសង្ក្រាន្តឆ្នាំ២០១៧, ១៤ មេសា ២០១៧

... ឆ្នាំទៅ ខ្ញុំព្រះករុណាខ្ញុំបាននិយាយអំពីជំនួបត្រីភាគីរវាងវប្បធម៌អរូបី និងវប្បធម៌រូបី ដោយមានការរៀបចំរបស់មនុស្ស គឺសហភាពសហព័ន្ធយុវជន។ ថ្ងៃនេះ ក៏ដូចជាឆ្នាំមុនៗ យើងមានបន្ថែមជាបន្តបន្ទាប់គ្រប់ទម្រង់សិល្បៈវប្បធម៌ជាតិ។ (ក្បាច់គុន)ល្បុក្តតោក៏បានអញ្ជើញមកទីនេះសាជាថ្មីម្តងទៀត។ បន្ទាប់ពីការីកដុះដាលឡើងវិញ ល្បុក្តតោត្រូវបានដាក់ជាក្បាច់គុណមួយរបស់កងយុទ្ធពលខេមរភូមិន្ទ។ នេះបង្ហាញអោយឃើញថា **កម្ពុជាមានប្រវត្តិចំណាស់រាប់ពាន់ឆ្នាំ (ហើយ)អ្វីដែលសំខាន់ត្រូវរំលេចអោយឃើញវប្បធម៌ជាតិ ដោយបង្ហាញទីតាំងប្រវត្តិសាស្ត្រនៃទឹកដីបុរាណ ដែលជាវប្បធម៌រូបី ហើយក៏ក្លាយជាបេតិកភណ្ឌពិភពលោក។ យើងជួបជុំគ្នាក្នុងឱកាសនៃអង្គរសង្ក្រាន្ត ដើម្បីផ្តុំគ្នានូវវប្បធម៌អរូបីដទៃទៀតលើទឹកដីនៃវប្បធម៌រូបី ...**។

១៤. ជូនតានិងអតីតព្រះមហាក្សត្រ/យានី បានកសាងប្រាង្គប្រាសាទដ៏អស្ចារ្យលើទឹកដី

ពិធីបើកអង្គរសង្ក្រាន្តឆ្នាំ២០១៧, ១៤ មេសា ២០១៧

... មកដល់ទីតាំងនេះ **យើងមិនភ្លេចនឹងជូន/ថ្វាយការដឹងគុណដល់ដូនតា អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រយានីគ្រប់ព្រះអង្គ ដែលបានកសាងប្រាង្គប្រាសាទដ៏អស្ចារ្យនៅលើទឹកដីនេះ។ ប្រសិនបើដូនតា អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រយានី មិនបានយកព្រះទ័យ/ចិត្តទុកដាក់ខិតខំកសាងទេ យើងគ្មានទីតាំងឈរជើងធ្វើអង្គរសង្ក្រាន្តទេ**។ យើងក៏បាននឹកទៅដល់ព្រះបរមរតនកោដ្ឋ សម្តេចព្រះនរោត្តម សីហនុ ដែលខ្ញុំព្រះករុណាខ្ញុំបានចូលរួមផ្ទាល់ជាមួយព្រះអង្គចរចារកសន្តិភាព។ គ្រប់ពេលវេលានៃការចរចា (ព្រះអង្គ)តែងតែគិតដល់សុវត្ថិភាពនៃទីតាំងអង្គរ។ តាំងពីមិនទាន់បោះឆ្នោតនៅឡើយ គឺក្នុងក្របខណ្ឌនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ **ព្រះករុណាសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ បានសុំការឯកភាពពីក្រុមប្រឹក្សាជាតិជាន់ខ្ពស់បញ្ចូលប្រាសាទអង្គរវត្តជាបេតិកភណ្ឌពិភពលោក។ នោះជាការចាប់ផ្តើមដែលកម្ពុជាមានលក្ខន្តិកៈត្រូវគោរព។ បន្ទាប់ទៅ យើងអរព្រះគុណចំពោះព្រះមហាក្សត្របច្ចុប្បន្ន សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ដែលជានិច្ចកាលព្រះអង្គបានយកចិត្តទុកដាក់ខ្ពស់បំផុតទៅនឹងវប្បធម៌ជាតិរបស់យើង** ...។

១៥. ការពារបេតិកភណ្ឌវប្បធម៌ មានអន្តរសកម្មចំពោះសេដ្ឋកិច្ចនិងសង្គម

ពិធីអបអរសាទរការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោក, ១៧ កក្កដា ២០១៧

... យើងត្រូវមើលឃើញថា វប្បធម៌បេតិកភណ្ឌឬសិល្បៈ មិនមែនជាបញ្ហាដាច់ដោយឡែកនោះទេ។ វាជាប់ពាក់ព័ន្ធជាមួយបញ្ហាសេដ្ឋកិច្ចសង្គមផងដែរ។ យើងបានខិតខំបង្កើតឲ្យមានការប្រែប្រួលពីសូន្យទេសចរមកដល់ជាង ៥លានទេសចរតាមរយៈការប្រើប្រាស់សម្បត្តិ(វប្បធម៌)ដែលដូនតាបានបន្សល់ទុក។ **រឿងដែលយើងបានធ្វើគឺជាចុងខ្សែច្រើននៃចំណងមួយ។ យើងធ្វើការការពារបេតិកភណ្ឌវប្បធម៌ ក៏ប៉ុន្តែវាមានអន្តរសកម្មចំពោះបញ្ហាសេដ្ឋកិច្ចនិងសង្គមផងដែរ។ កំណើនសេដ្ឋកិច្ចដ៏ធំធេង ក៏បានមួយភាគធំចេញមកពីទេសចរណ៍ ដែលចាក់បញ្ចូលទៅក្នុងសេដ្ឋកិច្ចជាតិ និងបង្កើតការងារ និងមុខរបរសម្រាប់ប្រជាពលរដ្ឋរបស់យើង** ...។

១៦. ធ្វើការអភិរក្សនិងអភិវឌ្ឍវប្បធម៌ ផ្តល់ការងារធ្វើនិងរួមចំណែកបន្ថយភាពក្រីក្រ

ពិធីអបអរសាទរការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោក, ១៧ កក្កដា ២០១៧

... មិនត្រូវមើលស្រាលអន្តរសកម្មនៅទីនេះទេ។ ប្រទេសជាច្រើនបានយកវិស័យទេសចរណ៍ជាគោលដៅនៃការធ្វើឲ្យមានកំណើនសេដ្ឋកិច្ច និងការងារជូនប្រជាជន ...**យើងធ្វើកិច្ចការទាក់ទិននឹងវប្បធម៌ ក៏ប៉ុន្តែវាបានផ្តល់ផលមកវិញ មិនគ្រាន់តែការពារ អភិរក្ស និងអភិវឌ្ឍវប្បធម៌ប៉ុណ្ណោះទេ ក៏ប៉ុន្តែវាបានផ្តល់ឲ្យយើងនូវកំណើនសេដ្ឋកិច្ច ក៏ដូចជាការងារធ្វើសម្រាប់ពលរដ្ឋ ដែលផលនេះបានជាការរួមចំណែកកាត់បន្ថយភាពក្រីក្រសម្រាប់ប្រជាពលរដ្ឋ។ នេះហើយជាកិច្ចការដែលយើងត្រូវធ្វើ ហើយត្រូវចងចាំថាកូនចៅជំនាន់ក្រោយ ត្រូវតែខិតខំការពារ អភិរក្សនិងអភិវឌ្ឍ ក្នុងវិស័យវប្បធម៌របស់យើង** ...។

១៧. ថ្ងៃ ១០កក្កដា ជាទិវាបញ្ចូលប្រាសាទសំបូរព្រៃគុកជាសម្បត្តិបេតិកភណ្ឌពិភពលោក

ពិធីអបអរសាទរការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោក, ១៧ កក្កដា ២០១៧

... ករណីមុនៗ ដូចជា ប្រាសាទព្រះវិហារ ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅថ្ងៃទី ៧កក្កដា ឆ្នាំ២០០៨ បន្ទាប់ពីប្រាសាទអង្គរ ដែលបានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅឆ្នាំ១៩៩២ ... ថ្ងៃទី ៧កក្កដា ២០០៨ ប្រាសាទព្រះវិហារត្រូវបានដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោក ហើយត្រូវបានចេញសារអបអរសាទរនៅថ្ងៃទី៨ កក្កដា និងការអបអរសាទរនៅទីក្រុងភ្នំពេញគោះជួងនៅទូទាំងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី៩ កក្កដា ... ឯចំពោះ**តំបន់ប្រាសាទសំបូរព្រៃគុក ត្រូវបានដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោកនៅថ្ងៃទី ៨កក្កដា ហើយសាររបស់ខ្ញុំត្រូវបានចេញនៅថ្ងៃទី ៩កក្កដា ហើយកំណត់យកម៉ោង ១០ ថ្ងៃទី១០កក្កដា ធ្វើការអបអរសាទរតាមរយៈសកម្មភាពរួមរបស់ប្រជាជាតិទាំងមូល**។ ដូច្នេះ សំរាប់តំបន់ទាំងពីរ គឺប្រាសាទព្រះវិហារនិងប្រាសាទសំបូរព្រៃគុក

យើងធ្វើពិធីតែមួយបំផុសចិត្តគំនិតប្រជាពលរដ្ឋកម្ពុជាអំពីការស្រឡាញ់វប្បធម៌ជាតិ ...។

១៨. ដាក់តំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោកបាន ព្រោះមានសន្តិភាព

ពិធីអបអរសាទរការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោក, ១៧ កក្កដា ២០១៧

...ហេតុអ្វីយើងទទួលបាននូវជោគជ័យ លើការងារ(បញ្ចូលប្រាសាទជាបេតិកភណ្ឌពិភពលោក) ... ប្រទេសមួយចំនួនបានដាក់បញ្ជីស្នើសុំទៅអង្គការយូណេស្កូ ២០ឆ្នាំ ឬជិត ៣០ឆ្នាំរួចមកហើយ តែមិនទាន់ត្រូវបានអនុម័តទទួលយកដោយអង្គការយូណេស្កូនោះទេ។ ក៏ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជា ដាក់មួយបានមួយ ដាក់ពីរបានពីរ ដាក់បីបានបី។ ខ្ញុំសុំលើកនៅទីនេះ ដោយសង្កត់ធ្ងន់លើចង្កោមបញ្ហានៃទិដ្ឋភាពនយោបាយ សេដ្ឋកិច្ចសង្គមផងដែរ ... **ដំបូងបំផុត គឺវត្តមាននៃសន្តិភាព និងការឯកភាពទឹកដី ជំនួសឲ្យសង្គ្រាម និងការបែកបាក់ពីអតីតកាល (នេះហើយជាកត្តាសារវន្តដែលនាំអោយយើងអាចធ្វើការងារនេះបានដោយជោគជ័យ)**។ ចំណុចនេះមានសារសំខាន់ ដែលជនរួមជាតិត្រូវចងចាំ។ **វត្តមានសន្តិភាពបាននាំឲ្យយើងនូវការឯកភាពជាតិជាលើកដំបូងក្នុងប្រវត្តិសាស្ត្ររាប់សិបឆ្នាំ ឬរាប់រយឆ្នាំ ... ដូច្នេះ ត្រូវចងចាំថា វត្តមាននៃសន្តិភាព ជំនួសឲ្យសង្គ្រាម និងការបែកបាក់គឺជាកត្តាទីមួយនិងដំបូងបំផុត ដែល(នាំឲ្យ)សម្រេចបាននូវជោគជ័យកន្លងមក និងនៅថ្ងៃនេះ** ...។

១៩. ព្រះមហាក្សត្រនិងព្រះវររាជមាតាជាតិ គាំទ្រដំណើរការសុំបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោក

ពិធីអបអរសាទរការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោក, ១៧ កក្កដា ២០១៧

... **តាំងពីអតីតព្រះមហាក្សត្រ សម្តេចព្រះវររាជបិតាជាតិ ព្រះបរមរតនកោដ្ឋ មកដល់ព្រះមហាក្សត្របច្ចុប្បន្ន តែងផ្តល់ការគាំទ្រនិងលើកទឹកចិត្តជាប្រចាំ**។ ព្រះអង្គបានផ្តល់ការគាំទ្រពេញលេញក្នុងដំណើរការ ... ខ្ញុំសូមបញ្ជាក់ថា មុនពេលព្រះមហាក្សត្របច្ចុប្បន្នគ្រងរាជ្យ ព្រះអង្គគឺជាអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅយូណេស្កូ។ ចំណុចនេះមានអត្ថន័យសំខាន់មួយទៀត ដែលជួយជំរុញឲ្យយើងអាចដំណើរការដាក់បញ្ចូលប្រាសាទព្រះវិហារ និងតំបន់សំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោក។ និយាយដូច្នេះ មិនមែនជាការទិញដូរទឹកចិត្តនោះទេ ក៏ប៉ុន្តែជាការស្គាល់នូវកម្ពុជាពិតប្រាកដ ដែលជាការចាំបាច់ណាស់ ...។

២០. ដាក់តំបន់សំបូរព្រៃគុកជាសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោកបាន ដោយសារបក្សកាន់អំណាចមាននយោបាយច្បាស់លាស់លើវិស័យវប្បធម៌និងសិល្បៈ

ពិធីអបអរសាទរការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោក, ១៧ កក្កដា ២០១៧

... **បក្សដឹកនាំរាជរដ្ឋាភិបាល បាននយោបាយច្បាស់លាស់លើវិស័យវប្បធម៌ និងសិល្បៈ** ... ខ្ញុំគ្រាន់តែលើកជ្រុងមួយនៃវប្បធម៌និងសិល្បៈទេ។ បក្សនយោបាយដែលដឹកនាំរដ្ឋ ត្រូវតែមាននយោបាយគ្របដណ្តប់ទាំងក្នុងនិងក្រៅប្រទេស ដោយក្នុងនោះ នយោបាយវប្បធម៌ក៏ជាផ្នែកមួយ។ តាំងពីគំនរផេះផង់ យើងបានធ្វើឲ្យប្រជាជាតិនេះរស់ឡើងវិញ ងើបឡើងស្មើមុខស្មើមាត់ជាមួយគេឯង។ នេះជាភាពចាំបាច់មួយទៀត ដែលកូនខ្មែរត្រូវមើលឲ្យឃើញពីកត្តាដឹកនាំ។ តើបក្សនយោបាយណាទៅដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើកិច្ចការទាំងអស់នេះ? ពេលសន្តិភាពត្រូវបាត់បង់ អ្វីៗក៏ត្រូវបំផ្លាញ (ពួកអគតិប្រើ)នយោបាយមើលស្រាលចំពោះវប្បធម៌ ដែលសូម្បីតែពាក្យមួយម៉ាត់ស្វាគមន៍ការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោក ក៏មិនព្រមធ្វើផង។ តើវាស័ក្តសមទៅនឹង(ក្លាយជា)បក្សកាន់អំណាច ឬដឹកនាំប្រជារាស្ត្រខ្មែរនោះទេ? ...។

២១. ដាក់តំបន់សំបូរព្រៃគុកជាសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោកបាន ដោយសារយន្តការអនុវត្តមានភាពស៊ីសង្វាក់គ្នា ទាំងក្នុងប្រទេសនិងក្រៅប្រទេស

ពិធីអបអរសាទរការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោក, ១៧ កក្កដា ២០១៧

... **យើងមានយន្តការអនុវត្តដែលស៊ីសង្វាក់គ្នា ទាំងការអនុវត្តក្នុងប្រទេសទាំងការអនុវត្តក្រៅប្រទេស។** លទ្ធផលនេះ មិនធ្លាក់មកពីលើមេឃនោះទេ តែវាបានមកពីការខិតខំរបស់រាជរដ្ឋាភិបាល ...យើងមិនអាចទៅបោកប្រាស UNESCO ជាពិសេសអង្គការ ICOMOS នោះបានទេ។ ភាពស៊ីសង្វាក់រវាងខាងក្នុង និងខាងក្រៅ គឺជាបញ្ហាសំខាន់ខ្លាំងណាស់ ដែលផ្តល់ឱកាសដល់យើងសម្រាប់ការចូលជាបេតិកណ្ឌពិភពលោក។ មិនមែនដោយសារយើងពូកែ lobby ទើបគេបញ្ចូលនោះទេ។ នេះគឺបានមក ដោយសារការខិតខំបំពេញលក្ខខណ្ឌរបស់ផ្នែកមួយ នៃអង្គការបេតិកណ្ឌពិភពលោករបស់ UNESCO។ បើយើងធ្វើមិនបានតាមលក្ខខណ្ឌតម្រូវទេ យើងគ្មានលទ្ធភាពដើម្បីចូលទេ ... ខាងក្នុងជាកត្តាកំណត់និងខាងក្រៅជាផ្នែកដែលទ្រទ្រង់ ... មិនមែនអ្វីៗ សុទ្ធតែអាចពឹងពាក់បរទេសបានទេ បើសិនជាខាងក្នុងមិនបានបំពេញតាមលក្ខខណ្ឌ ...។

២២. ដាក់តំបន់សំបូរព្រៃគុកជាសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោកបាន ដោយសារប្រជាជនគាំទ្រការដឹកនាំរបស់បក្សកាន់អំណាច

ពិធីអបអរសាទរការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោក, ១៧ កក្កដា ២០១៧

... **យើងមានការគាំទ្ររបស់ប្រជាជនតាមរយៈការបោះឆ្នោត ជូនគណបក្សប្រជាជនឲ្យធ្វើការដឹកនាំប្រទេសរៀងរហូតមក** ... បន្ទាប់ពីអាណត្តិទី៤ ដែលបានបញ្ចូលប្រាសាទព្រះវិហារជាសម្បត្តិវប្បធម៌ពិភពលោក ក្នុងដំណាក់កាលនៃការឃោសនាបោះឆ្នោតឆ្នាំ២០០៨ **ក្នុងអាណត្តិទី៥ យើងទទួលជោគជ័យសារជាថ្មីម្តងទៀតក្នុងការដាក់តំបន់សំបូរព្រៃគុកទៅជាសម្បត្តិបេតិកណ្ឌវប្បធម៌ពិភពលោក។ នេះគឺជាការគាំទ្ររបស់ប្រជាជនចំពោះបក្សកាន់អំណាច ចំពោះគណបក្សប្រជាជនដែលកំពុងដឹកនាំរាជរដ្ឋាភិបាល ហើយសូមអរគុណចំពោះប្រជាពលរដ្ឋគ្រប់ទិសទីដែលបានបោះឆ្នោតគាំទ្រគណបក្សប្រជាជនជារៀងរហូតមក** ... មិនមែនតែក្រសួងវប្បធម៌និងវិចិត្រសិល្បៈមួយគ្រប់គ្រាន់ទេ។ ផ្នែកពាក់ព័ន្ធទាំងអស់ មានចំណែកដែលសមហេតុសមផលនិងទទួលយកនូវមោទនភាពជាប្រជាជន និងជាស្ថាប័ន ដែលនៅក្នុងក្របខណ្ឌជាតិសក្តិសមជាស្ថាប័ននិងជាពលរដ្ឋនៃព្រះរាជាណាចក្រវប្បធម៌ ...។

២៣. ដាក់តំបន់សំបូរព្រៃគុកជាសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោកបាន ព្រោះមាននយោបាយការបរទេសត្រឹមត្រូវ ទាក់ទាញការគាំទ្រប្រទេសជាមិត្ត

ពិធីអបអរសាទរការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោក, ១៧ កក្កដា ២០១៧

... **យើងមាននយោបាយការបរទេសត្រឹមត្រូវ ដែលទាក់ទាញការគាំទ្រពីប្រទេសជាមិត្ត និងអង្គការអន្តរជាតិ ពិសេសគឺ UNESCO ទាំងការដាក់បញ្ចូលសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោក ទាំងការជួយជំនួយហិរញ្ញវត្ថុបច្ចេកទេស ដើម្បីជួសជុលនិងអភិរក្ស ក៏ដូចជាការបណ្តុះបណ្តាលធនធានមនុស្ស ... នយោបាយការបរទេសត្រឹមត្រូវនេះនាំមកនូវការចូលរួមចំណែកពីសំណាក់តួអង្គទាំងអស់** មិនគ្រាន់តែជាការដាក់បញ្ចូលទេ ក៏ប៉ុន្តែរយៈពេលកន្លងទៅ ប្រទេសមួយចំនួនបានជួយជួសជុលប្រាសាទនិងជួយអភិរក្សគំនូរឬផ្នែកសិល្បៈណាមួយរបស់យើង។ ក្នុងហ្នឹងគ្រាន់តែក្រឡេកមើលនៅ ICC អង្គរ គេអាចឃើញជប៉ុននិងបារាំង ជាសហប្រធាននៅទីនេះ ហើយបើយើងពិនិត្យទៅលើ ICC ព្រះវិហារ គេនឹងឃើញប្រទេសធំ២ គឺចិន និងឥណ្ឌា ជាសហប្រធាន។ យើងអាចទាក់ទាញនឹងប្រទេសធំ ២ ដែលមានប្រជាជន ៣ ពាន់លាននាក់ធ្វើជាសហប្រធានគាំទ្រការអភិរក្សខាងប្រាសាទព្រះវិហារ ...។

២៤. អភិវឌ្ឍនិងអភិរក្ស(តំបន់ប្រាសាទ)តាមផែនការមេ ជាអនុសាសន៍ពីយូណេស្កូ

ពិធីអបអរសាទរការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោក, ១៧ កក្កដា ២០១៧

... **(ប្រឹងប្រែង)ជំរុញការអភិវឌ្ឍនិងអភិរក្ស តាមផែនការមេ ដែលជាអនុសាសន៍ឬជាក្របខណ្ឌដែលយើងបានព្រមព្រៀងជាមួយដៃគូ**។ នោះគឺអនុសាសន៍ដែលយូណេស្កូបានផ្តល់ឲ្យយើង។ ត្រូវខិតខំដើម្បីធានាថា អ្វីដែលយើងបានស្នើសុំទៅមិនត្រូវបានទាត់ចេញពីសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោកវិញទេ។ ប្រទេសមួយចំនួនបានបាត់បង់រួចហើយ។ គេបញ្ចេញ ... សង្ឃឹមថា យើងទាំងអស់គ្នាត្រូវការបំពេញលក្ខខណ្ឌដែលតម្រូវ។ វាមិនមែនជាផលប្រយោជន៍ដល់បរទេសទេ។ វាជាផលប្រយោជន៍ផ្ទាល់របស់ប្រជាជនកម្ពុជា ដែលតម្រូវឲ្យយើងត្រូវធ្វើបែបនេះ...។

២៥. ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ពិសេសប្រព័ន្ធផ្លូវនិងសៅ ក្នុងតំបន់ប្រាសាទសំបូរព្រៃគុក

ពិធីអបអរសាទរការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោក, ១៧ កក្កដា ២០១៧

... **ត្រូវពង្រឹងហេដ្ឋារចនាសម្ព័ន្ធដើម្បីអភិវឌ្ឍទេសចរណ៍ក្នុងតំបន់ សំខាន់លើប្រព័ន្ធផ្លូវ និងសៅផ្សេងទៀត ដែលមានពាក់ព័ន្ធនៅទីនេះ**។ ថ្ងៃនេះ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អូន ព័ន្ធមុនីរ័ត្ន រួមជាមួយក្រសួងវប្បធម៌ វិចិត្រសិល្បៈ អាជ្ញាធរសំបូរព្រៃគុក ពិនិត្យមើលអំពីតំបន់មួយចំនួនដែលយើងត្រូវធ្វើផ្លូវវាង ចៀសវាងការបើករថយន្តបំពាន ធ្វើឲ្យខ្ទេចខ្ទាំនៅទីនោះ។ តំបន់មួយចំនួននៅទីនោះ ក៏មានផ្លូវមិនទាន់សមស្រប **ឆ្លើយតបទៅនឹងតម្រូវការនៃវិស័យទេសចរណ៍ដែលនៅពេលខាងមុខ នឹងកើនឡើងគំហុកនៅក្នុងតំបន់សំបូរព្រៃគុក**។ ទាំងអស់នេះ សុទ្ធតែជាចំណុចដែលយើងត្រូវធ្វើទាំងអស់គ្នា ...។

២៦. ទាំងអស់គ្នាជាកូនកតញ្ញូ ចូលរួមការពារវប្បធម៌ជាតិពីដូនតា ទាំងរូបីនិងអរូបី

ពិធីអបអរសាទរការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកជាបេតិកភណ្ឌពិភពលោក, ១៧ កក្កដា ២០១៧

... សូមចូលរួមក្នុងចលនាការពារវប្បធម៌ជាតិ ទាំងរូបីនិងអរូបី។ សូមកុំសម្លាប់មេមាន់ដើម្បីធ្វាញ់មួយពេល។ សូមរក្សាមេមាន់ ចិញ្ចឹមយកស៊ុត/យកកូន ទើបមានប្រយោជន៍ ... ទាំងអស់គ្នាត្រូវចូលរួមការពារនូវសម្បត្តិវប្បធម៌របស់យើង ដូចជាប្រាង្គប្រាសាទនិងតំបន់ប្រាសាទ ដែលចាត់ទុកដូចជាតំបន់ការពារ ប្រៀបបីដូចជាមេមាន់ ដែលយើងមិនគប្បីសម្លាប់ដើម្បីការធ្វាញ់មួយពេលទេ។ **យើងគួរតែត្រូវថែទាំមេមាន់ឲ្យបានល្អដើម្បីចិញ្ចឹមយកកូន និងបន្តឲ្យបែកមែកសាខាតទៅទៀត ... ត្រូវចងចាំថា យើងចូលរួមទាំងអស់គ្នាការពារបេតិកភណ្ឌវប្បធម៌ ...យើងត្រូវការពារបេតិកភណ្ឌដូនតា។ គ្រាន់តែអ្នកធ្វើគឺលំបាកណាស់ទៅហើយ តែយើងទាំងអស់គ្នាគឺជាកូនកតញ្ញូដែលចាំបាច់ត្រូវ(ថែរក្សា) ...**។

២៧. អង្គរសង្ក្រាន្ត ផ្តល់ភាពរីករាយឆ្នាំថ្មីប្រពៃណីជាតិ និងស្នាមញញឹមចេញពីទឹកចិត្តបងប្អូនខ្មែរនិងភ្ញៀវអន្តរជាតិ

ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត(លើកទី៦) ព.ស ២៥៦២, ១៣ មេសា ២០១៨

... **អង្គរសង្ក្រាន្តបានផ្តល់ភាពសប្បាយរីករាយ អបអរសាទរឆ្នាំថ្មីប្រពៃណីជាតិ និងស្នាមញញឹមចេញពីទឹកចិត្តបងប្អូនខ្មែរយើង និងភ្ញៀវអន្តរជាតិដែលបានមកចូលរួម** ... ខ្ញុំក៏បានឃើញនូវការផ្សព្វផ្សាយមួយថា ក្រៅពីបញ្ចប់ការជួបជុំរាំលេងនៅតំបន់អង្គរនេះ នៅតំបន់អង្គរឃ្យុងឃ្យូ ក៏មានការប្រគុំតន្ត្រីដ៏ធំរបស់ទូរទស្សន៍ហង្សមាសផងដែរ។ ដូច្នេះ ឆ្នាំនេះមានប្រជាជនចូលរួមច្រើន។ សង្ឃឹមថាប្រជាពលរដ្ឋ(នៅសៀមរាប)ទទួលបានផលប្រយោជន៍ពីការស្នាក់នៅ ការលក់ដាំរនិងរបស់របរហូបចុក។ ក៏ប៉ុន្តែ ខ្ញុំក៏សូមអំពាវនាវថា ដើម្បីរក្សាតម្លៃនិងទាក់ទាញឲ្យកាន់តែច្រើន គឺមិនត្រូវបង្កើនថ្លៃហួសហេតុពេកទេ ...។

២៨. អង្គរសង្ក្រាន្ត ឆ្លុះបញ្ចាំងពីសាមគ្គីភាព ឯកភាព មិត្តភាព គ្រួសារខ្មែរ

ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត (លើកទី៦) ព.ស ២៥៦២, ១៣ មេសា ២០១៨

... **អង្គរសង្ក្រាន្តគឺជាព្រឹត្តិការណ៍ឆ្លុះបញ្ចាំងអំពីឯកភាពសាមគ្គីភាពមិត្តភាពស្មារតីគ្រួសារខ្មែរសេចក្តីអំណរសាទរភាពសុខដុម សុភមង្គល និងមោទនភាពក្នុងចំណោមយុវជន ក៏ដូចជាប្រជាជនទូទាំងប្រទេសជាគ្រួសារតែមួយ**។ យើងគ្មានការបែងចែករើសអើងណាមួយ សម្រាប់ក្រុមនេះឬក្រុមនោះឡើយ។ វាជារបស់យើងទាំងអស់គ្នា។ ដូច្នេះយើងមានសិទ្ធិនឹងសប្បាយរីករាយជាមួយគ្នា ...។

២៩. អង្គរសង្ក្រាន្តបង្ហាញភាពរុងរឿងនៃវប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ ប្រពៃណីសាសនាពីសម័យមហានគរ

ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត(លើកទី៦) ព.ស ២៥៦២, ១៣ មេសា ២០១៨

... **អង្គរសង្ក្រាន្តជាឱកាសបង្ហាញជល់អន្តរជាតិនិងមិត្តកក្តិបរទេស អំពីភាពរុងរឿង ភាពសម្បូរបែបនៃវប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ ប្រពៃណីសាសនា (របស់ជាតិសាសន៍ខ្មែរ) តាំងពីសម័យមហានគរ រហូតដល់ពេលបច្ចុប្បន្ន** ... គ្រាសង្គ្រាមនិងការបែកបាក់របស់កម្ពុជា ព្រមទាំងរបបប្រល័យពូជសាសន៍ គេស្ទើរតែភ្លេចពី

កម្ពុជាទៅហើយ។ ប៉ុន្តែ តាមរយៈសកម្មភាពនានាដែលយើងបានប្រឹងប្រែង កម្ពុជាបានក្លាយជាគោលដៅទេសចរណ៍ដ៏ទាក់ទាញ ដែលឆ្នាំកន្លងទៅ ទេសចរ ៥លាន ៧សែននាក់បានមកកាន់ព្រះរាជាណាចក្រកម្ពុជា។ ជារៀងរាល់ឆ្នាំខ្ញុំតែងតែឃើញថាភ្ញៀវទេសចរបរទេសបានមកពាំកម្សាន្តសប្បាយជាមួយប្រជាពលរដ្ឋរបស់យើង ហើយប្រជាពលរដ្ឋយើងក៏បានផ្តល់ស្នាមញញឹមនិងរាំជាមួយមិត្តភក្តិបរទេសជាភ្ញៀវ ...៕

៣០. គំនិតច្នៃប្រឌិតអង្គរសង្ក្រាន្ត នាំអោយកើតមានសង្ក្រាន្តនៅច្រើនកន្លែង

ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត (លើកទី៦) ព.ស.២៥៦២, ១៣ មេសា ២០១៨

... តាមរយៈ**គំនិតច្នៃប្រឌិតអង្គរសង្ក្រាន្តនេះ សង្ក្រាន្តក៏បានកើតនៅកន្លែងដទៃទៀត ដូចដែលខ្ញុំបញ្ជាក់រួចហើយ។ ឆ្នាំនេះ នៅទីក្រុងភ្នំពេញមានសង្ក្រាន្តពីរកន្លែង គឺសង្ក្រាន្តវត្តភ្នំនិង(សង្ក្រាន្ត)ពោធិ៍សែនជ័យ។ ខេត្តកណ្តាលមានសង្ក្រាន្តនៅ ភ្នំព្រះរាជទ្រព្យ មានសង្ក្រាន្តស្វាយរៀង សង្ក្រាន្តព្រៃវែង សង្ក្រាន្តថ្មីសម្បូរព្រៃគុកខេត្តកំពង់ធំ សង្ក្រាន្តបន្ទាយមានជ័យ សង្ក្រាន្តកំពង់ស្ពឺ សង្ក្រាន្តបាត់ដំបង សង្ក្រាន្តកោះកុង សង្ក្រាន្តកំពត។ល។ សរុបទៅ យើងមានរហូតទៅដល់សង្ក្រាន្តនៅឯសាធារណរដ្ឋកូរ៉េឯណោះ**។ យើងមានពលរដ្ឋនិងនិស្សិតដែលធ្វើការ/រៀនសូត្រនៅកូរ៉េ ប្រមាណជា ៥ម៉ឺននាក់។ ដូច្នេះក៏មានពិធីរៀបចំនៅទីនោះផងដែរ។ ខ្ញុំអបអរសាទរជាមួយយុវជន ក៏ដូចជាសិល្បករ/សិល្បការិនី កីឡាករ/កីឡាការិនី ដែលបានចូលរួមសង្ក្រាន្តនៅទីនេះ ក៏ដូចជាសង្ក្រាន្តនៅកន្លែងនានា ...៕

៣១. កត្តា៤ ធ្វើឱ្យប្រជាពលរដ្ឋអាចធ្វើដំណើរទៅភូមិកំណើតចូលរួមពិធីបុណ្យប្រពៃណីជាមួយគ្រួសារ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ចាក់អង្រែលើ, ២៧ កញ្ញា ២០១៧

... មានកត្តា៤ ដែលធ្វើឱ្យពិធីភ្ជុំបិណ្ឌក៏ដូចជាពិធីបុណ្យនានាអាចប្រព្រឹត្តទៅបានស្រួល និងប្រជាជនមានលទ្ធភាពធ្វើដំណើរ ... **ទី១ កត្តាសន្តិភាព**។ នេះជាកត្តាធំជាងគេ ដែលធ្វើអោយប្រទេសកម្ពុជារបស់យើងមានលទ្ធភាពធ្វើដំណើរដោយគ្មានការភ័យខ្លាច។ មិនមែនគ្រាន់តែភ័យខ្លាចសម្រាប់ការវាយកេរវកម្ម ឬការពួនស្នាក់ដោយក្រុមឧទ្ទាមណាមួយដូចកាលពីពេលមុនទេ ក៏ប៉ុន្តែឥឡូវនេះ ប្រជា

ពលរដ្ឋមិនត្រឹមតែធ្វើដំណើរពេលថ្ងៃទេ គេធ្វើដំណើរក្នុងពេលយប់ ដោយមានសុវត្ថិភាព ... កត្តា**ទី២ គឺហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ពីតំបន់មួយទៅកាន់តំបន់មួយ។** បើទោះបីវាមិនទាន់ស្រួលឥតខ្ចោះ ក៏ប៉ុន្តែបានអនុញ្ញាតអោយប្រជាពលរដ្ឋរបស់យើងអាចធ្វើដំណើរបានទៅគ្រប់ទីកន្លែង នៅក្នុងក្របខណ្ឌទូទាំងប្រទេស ... កត្តា**ទី៣ យើងមានមធ្យោបាយធ្វើដំណើរ** ជាមធ្យោបាយផ្ទាល់ខ្លួនក្តី ... មធ្យោបាយដោយបង់ប្រាក់ក្តី ... និងកត្តា**ទី៤ គឺប្រាក់ចំណូល** ... ដោយសារប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ រាប់ទាំងប្រាក់ចំណូលរបស់កម្មករ/ការិនីមានការកើនឡើង ព្រមដោយការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល សម្រាប់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធប្រមាណជាងកន្លះលាននាក់បានទទួលនូវប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភពេលភ្ជុំបិណ្ឌ ...៕

៣២. កត្តាទាំង៦ ដែលនាំទៅដល់ការរៀបចំអង្គរសង្ក្រាន្តបានដោយរីករាយនិងជោគជ័យ

ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០២៣ និងអបអរសាទរខួប ១០ឆ្នាំ នៃការបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត, ១៤ មេសា ២០២៣

... អ្វីដែលធ្វើឱ្យអាចរៀបចំពិធីនានាទូទាំងប្រទេស មិនគ្រាន់តែអង្គរសង្ក្រាន្តនោះទេ នៅគ្រប់ទីកន្លែង ជាខេត្ត ជាស្រុក ជាឃុំ រហូតដល់ភូមិ និងរហូតទៅតាមគ្រឹះស្ថានសិក្សានានា ជាសាកលវិទ្យាល័យវិទ្យាល័យ និងកន្លែងដទៃទៀត ... ដំបូងបំផុត**ខ្ញុំសូមចាប់ផ្តើមពីកត្តាថា (យើងមាន)សុខសន្តិភាព ស្ថិរភាពខាងនយោបាយ។** នេះជាកត្តាសំខាន់ ... ត្បិតមិនមានការសប្បាយណាមួយអាចកើតឡើងក្រោមគ្រាប់បែក គ្រាប់ផ្លោង និងក្នុងសង្គ្រាមនោះទេ ... **ទី២ ... យើងគ្រប់គ្រងបានជំងឺកូវីដ-១៩ ដែលលែងជាការឆ្លងធ្ងន់ធ្ងរ**។ ទោះបីយ៉ាងនេះក្តី ... សង្ឃឹមថា បងប្អូនយើងនឹងយកចិត្តទុកដាក់លើបញ្ហាអនាម័យនានា ហើយក្រុមគ្រូពេទ្យនៅតែធ្វើសកម្មភាពដោះស្រាយបញ្ហាដែលអាចកើតឡើងជាយថាហេតុ ... **ទី៣ (យើងមាន)ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់** ដែលធ្វើឲ្យប្រជាជនអាចធ្វើដំណើរពីទីកន្លែងមួយទៅកាន់កន្លែងមួយ ...**ទី៤ ប្រជាពលរដ្ឋមានមធ្យោបាយធ្វើដំណើរ** ទោះជាផ្ទាល់ខ្លួនក្តីជារថយន្តឈ្នួលក្តី ... បន្ថែមដោយការបញ្ចេញរថយន្តក្រុង ៣៤៥គ្រឿងដោយសាលារាជធានីភ្នំពេញ ជួយដឹកប្រជាពលរដ្ឋពីទីក្រុងឆ្ពោះទៅកាន់ជនបទ ... **ទី៥ បើទោះបីមានការលំបាក**

បន្តិច ក៏ប៉ុន្តែប្រជាពលរដ្ឋនៅមានប្រាក់ចំណូលដែលអាច(រំលែកមកចាយវាយ)ដើរលេងបាន ... និងទី៦ តាមគំនិតផ្តួចផ្តើមនិងសកម្មភាពរបស់ខ្លួន សហភាពសហព័ន្ធយុវជនកម្ពុជា បានធ្វើកិច្ចការរៀបចំព្រឹត្តិការណ៍នេះបានយ៉ាងល្អ ...៕

៣៣. បេះដូងក្រដាសជិត ៨លាននៃព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ជាការគិតគូរដ៏ស៊ីជម្រៅរបស់បងប្អូនយុវជន

ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០២៣ និងអបអរសាទរខួប ១០ឆ្នាំនៃការបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត, ១៤ មេសា ២០២៣

... ខ្ញុំមានការរីករាយចំពោះសមិទ្ធផលនៃការ(បង្កើតឯកទគ្គកម្ម)បេះដូង(ក្រដាស)ច្រើនជាងគេនៅលើពិភពលោក។ ខ្ញុំបានទទួលនូវតួលេខ(ចំនួនបេះដូងក្រដាស)នេះថាមាន ៣ ៩១៧ ៨០៥ គឺជាចំនួនមួយដ៏ច្រើន ... ប្រជាជនកម្ពុជាចាប់អារម្មណ៍និងចូលរួមគាំទ្រដំណើរការនេះ។ យើងបានបំបែកឯកទគ្គកម្មបេះដូងច្រើនជាងគេ (ដែលមុននេះ)ចក្រភពអង់គ្លេសមានតែជាង ៥ម៉ឺនទេ។ យើង(បានគិតថានឹង)ប្រឹងសម្រេចឱ្យបានត្រឹមតែមួយលានបេះដូងប៉ុននោះ។ **មិននឹកស្មានថាយើងឈានរហូតទៅដល់ជិត ៤លានបេះដូង ... តាមរបាយការណ៍ អ្នកដែលចូលរួមបត់បេះដូងក្រដាសនេះ មានអាយុចាប់ពី ៤ឆ្នាំរហូតដល់អាយុ ៨០ឆ្នាំ ... (ដូចនេះ)គេអាចយល់បានអំពីអត្ថន័យនៃ(ការបត់)បេះដូង(ក្រដាសនេះ)។ វាមិនមែនជាការចៃដន្យនោះទេ។ខ្ញុំគិតថាវាជាការគិតគូរដ៏ស៊ីជម្រៅមួយរបស់បងប្អូនយុវជន...**៕

៣៤. លើកកម្ពស់សមត្ថភាពអ្នកនិពន្ធ អ្នកដឹកនាំរឿង និងតួសំដែង

ទិវាវប្បធម៌ជាតិ ៣មីនា ទី២១ ពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេសឆ្នាំទី៥ និងពិធីសំណេះសំណាលជាមួយសិល្បករ/ការិនីទូទាំងប្រទេស, ៦ មីនា ២០១៩

... ខ្ញុំសូមអំពាវនាវឲ្យបន្តការយកចិត្តទុកដាក់**លើកកម្ពស់សមត្ថភាពអ្នកនិពន្ធ អ្នកដឹកនាំរឿង និងតួសំដែងនានាឲ្យបានសមរម្យ**។ បញ្ហាដែលត្រូវគិតមុនគេគឺអ្នកនិពន្ធនិងអ្នកដឹកនាំរឿង។រីឯតួសំដែងងាយស្រួលទេ ដោយសារថា បើសិនមានការនិពន្ធនិងការដឹកនាំរឿងបានត្រឹមត្រូវ បច្ចុប្បន្ននេះ តួសម្តែងមានសមត្ថភាពគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅការតម្រូវរបស់អ្នកនិពន្ធនិងអ្នកដឹកនាំរឿង។ រឿងដែលគួរ

ឲ្យចាប់ចិត្តនៅត្រង់ថា ខ្សែភាពយន្តដែលបញ្ចាំងតាមគ្រប់ស្តានីយ៍ទូរទស្សន៍នានា ក្នុងម៉ោងមាស ទទួលបានសាទរពីសំណាក់ប្រជាពលរដ្ឋកាន់តែច្រើនទៅៗ។ ក៏ប៉ុន្តែ ខ្ញុំសុំធ្វើការកត់សម្គាល់ឲ្យយកចិត្តទុកដាក់លើកត្តាអ្នកនិពន្ធនិងអ្នកដឹកនាំរឿង ...៕

៣៥. ធ្វើឱ្យភាពយន្តខ្មែរទទួលបានការពេញនិយមពីសំណាក់ប្រជាជនកម្ពុជាឡើងវិញ

ទិវាវប្បធម៌ជាតិ ៣មីនា ទី២១ ពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេសឆ្នាំទី៥ និងពិធីសំណេះសំណាលជាមួយសិល្បករ/ការិនីទូទាំងប្រទេស, ៦ មីនា ២០១៩

... ខ្ញុំចង់ឲ្យសិល្បៈភាពយន្តខ្មែរដែលបានស្លាប់ទៅក្នុងជំនាន់ ប៉ុល ពត និងដែលបានរស់ឡើងវិញក្នុងដំណាក់កាលដែលខ្ញុំដឹកនាំ ទទួលបាននូវការពេញនិយមពីសំណាក់ប្រជាជនកម្ពុជាឡើងវិញ។ វាបានចាប់កំណើតឡើងវិញក្នុងពេលដែលខ្ញុំធ្វើនាយករដ្ឋមន្ត្រីនៃប្រទេសនេះ។ខ្ញុំចង់ឃើញថា**ភាពយន្តកម្ពុជាមិនគ្រាន់តែពេញនិយមនៅក្នុងប្រទេសរបស់ខ្លួនទេ ប៉ុន្តែអាចនឹងនាំយកទៅបញ្ចាំងនៅក្រៅប្រទេសបាន ដូចកាលពីជំនាន់ទសវត្សរ៍ទី៦០ និង៣ក់កណ្តាលទសវត្សរ៍៧០ដែលខ្សែភាពយន្តរបស់យើងក៏មានការពេញនិយម** ... យើងមានមោទនភាពដែលពីអតីតកាល(ការផលិតភាពយន្តរបស់)យើងមិនអន់ទេ។ សង្ឃឹមថា វិស័យខ្សែភាពយន្តខ្មែរនឹងបន្តមានជីវិតតទៅទៀត ...៕

៣៦. ហ៊ុន សែន នៅធ្វើជានាយករដ្ឋមន្ត្រី ពន្ធមិនត្រូវបានមិនដាក់បន្ទុកលើសិល្បៈ

ទិវាវប្បធម៌ជាតិ ៣មីនា ទី២១ ពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេសឆ្នាំទី៥ និងពិធីសំណេះសំណាលជាមួយសិល្បករ/ការិនីទូទាំងប្រទេស, ៦ មីនា ២០១៩

... ខ្ញុំសូមបញ្ជាក់ជូនទាំងអស់គ្នានៅទីនេះ ហេតុអ្វីបានជាខ្ញុំមិនបន្តឲ្យមានការរួចពន្ធរហូតដល់ ១០ឆ្នាំ? ... ខ្ញុំមិនចង់អោយមានការយកពន្ធអាករធ្ងន់ហួសកម្រិតលើវិស័យសិល្បៈទេ។ ប៉ុន្តែ ដោយសារអាណត្តិរបស់រាជរដ្ឋាភិបាលត្រូវបញ្ចប់នៅឆ្នាំ២០២៣ហើយក៏មានការបោះឆ្នោតនៅឆ្នាំ២០២៣ដែរនោះ**បើសិនជាប្រជាពលរដ្ឋកម្ពុជានិយាយជារួម និងនិយាយដោយឡែកសិល្បករ/ការិនីបន្តការគាំទ្រគណបក្សប្រជាជន (ឬនិយាយម្យ៉ាងទៀតថា) ពេលណា ហ៊ុន សែន នៅជានាយករដ្ឋមន្ត្រីពេលនោះពន្ធមិនត្រូវបានដាក់បន្ទុកទៅសិល្បៈទេ**។អញ្ចឹង ក្រោយឆ្នាំ២០២៣ បើសិនជា

ជាប់ឆ្នោត ច្បាស់ណាស់ថា ខ្ញុំនឹងបន្តរយៈពេល(មិនជាប់បន្ទុកពន្ធ)នោះទៅដល់ឆ្នាំ២០២៨ គឺទៅនីតិកាលក្រោយ ... សង្ឃឹមថា អ្នកទាំងអស់គ្នានឹងបន្តការគាំទ្រខ្ញុំ និងគណបក្សប្រជាជនបន្តទៀត ...។

៣៧. វប្បធម៌វិចិត្រសិល្បៈ និងអប់រំ យុវជន និងកីឡា រុញការបណ្តុះបណ្តាលវប្បធម៌ទៅក្នុងវិស័យអប់រំ ដើម្បីការពារនិងលើកកំពស់ការស្រលាញ់វប្បធម៌ជាតិ

ទិវាវប្បធម៌ជាតិ ៣មីនា ទី២១ ពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេសឆ្នាំទី៥ និងពិធីសំណេះសំណាលជាមួយសិល្បករ/ការិនីទូទាំងប្រទេស, ៦ មីនា ២០១៩

... ខ្ញុំមានការលើកទឹកចិត្តណាស់ (ដោយឃើញថាមាន)យុវជនបានមកចូលរួមសម្តែង (ហើយក៏បានធ្វើមក)តាំងពីប៉ុន្មានឆ្នាំរួចហើយ។ **យើងត្រូវបន្តប្រធានបទ «យុវជនដើម្បីវប្បធម៌ជាតិ»នេះតទៅទៀត ព្រោះពួកគេជាអ្នកស្នងដំណែង** ...យើងមិនចាំបាច់ដោះដូរប្រធានបទនេះទេ ... ខ្ញុំបានឃើញអំពីសមត្ថភាពសម្តែងរបស់ក្រុមយុវជនយើងនៅកន្លែងនេះនៅកន្លែងនោះ ហើយជារៀងរាល់ពេលដែលមានការផ្សាយបន្តផ្ទាល់ ឬមានសិល្បៈដែលជាការសម្តែងរបស់សិល្បៈខ្មែរយើង ខ្ញុំតែងព្យាយាមតាមសង្កេតពីសមត្ថភាពសម្តែងរបស់ពួកគេ។ ដូច្នេះ **ការសហការរវាងក្រសួងវប្បធម៌វិចិត្រសិល្បៈនិងក្រសួងអប់រំ យុវជន និងកីឡា ជំរុញ(ការបណ្តុះបណ្តាល)វប្បធម៌របស់យើងទៅក្នុងវិស័យអប់រំ គឺជាអាទិភាពមួយក្នុងចំណោមបណ្តាអាទិភាពនានា ដើម្បីការពារនិងលើកកំពស់ការស្រលាញ់វប្បធម៌ជាតិ** ...។

៣៨. ការកសាងរូបសំណាក ឬបដិមា ត្រូវតែធ្វើឲ្យបានត្រឹមត្រូវតាមរចនាបថ

ទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៥ ឆ្នាំ២០២៣ និងពិធីសំណេះសំណាលជាមួយសិល្បករ/ការិនីទូទាំងប្រទេសលើកទី៤, ២ មីនា ២០២៣

... ចំណុចដែល**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក៏ដូចជាស្ថាប័នពាក់ព័ន្ធនានា ត្រូវយកចិត្តទុកដាក់ គឺការកសាងរូបសំណាក ឬបដិមា ត្រូវតែធ្វើឲ្យបានត្រឹមត្រូវតាមរចនាបថ** និងមានក្បួនខ្នាត ត្បិតពេលដែលបានអភិសេកនិងដាក់ឲ្យប្រើប្រាស់រួចហើយ។ បើការកសាងបែរជាមិនត្រូវក្បួនខ្នាត គ្មានអ្នកណាហ៊ាន(យកចេញឬ)វាយចោលនោះទេ ព្រោះបារម្ភពីគ្រោះថ្នាក់តាមអបិយជំនឿ។ បើអញ្ចឹង របស់នោះ

នឹងត្រូវបានបន្សល់ទុករាប់រយឆ្នាំទៅខាងមុខទៀត។ ប្រការនេះក៏នឹងនាំឲ្យក្មេងជំនាន់ក្រោយអាចយល់ខុសអំពីទម្រង់ខ្មែរពិតប្រាកដ។ ទាក់ទិននឹងរូបបដិមា ឬក៏រូបសំណាកនេះ ពេលដែលអភិសេករួចហើយ អត់មានអ្នកណាទៅប៉ះពាល់បានទេ ... អញ្ចឹងស្នើឲ្យក្រសួងយកចិត្តទុកដាក់ ...។

៣៩. ទោះបីមានសម្ភារៈទំនើប សូមរក្សាទំនៀមទំលាប់ របស់បុរាណអតីតកាល

ទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៥ ឆ្នាំ២០២៣ និងពិធីសំណេះសំណាលជាមួយសិល្បករ/ការិនីទូទាំងប្រទេសលើកទី៤, ២ មីនា ២០២៣

... ខ្ញុំបានសម្រេចរួចហើយ។ ក្នុងចំណោម ១លាន ៥សែននាក់នៃសិស្សដែលត្រូវទទួលបានការបណ្តុះបណ្តាល **គឺសូមទុក២% ទៅ៤% ឱ្យក្រសួងវប្បធម៌និងវិចិត្រសិល្បៈបណ្តុះបណ្តាល "មាតកជូនតា"។ នេះជាចំណុចត្រូវយកចិត្តទុកដាក់មិនអាចធ្វេសប្រហែស និងមើលស្រាលបានទេ។ ខ្ញុំខ្លាចមានការបាត់បង់ ដោយសារតែមានសំភារៈកាន់តែទំនើប។ អ្វីក៏ទំនើបៗ ក៏តាំងបោះបង់ចោលទំនៀមទំលាប់និងរបស់របរដែលយើងធ្លាប់មានពីអតីតកាល** ... ខ្ញុំស្នើដោយទទូចឲ្យយកចិត្តទុកដាក់ជាពិសេស ការកសាងរូបសំណាកនិងបដិមា ...។

៤០. សូមពុទ្ធបរិស័ទជួយព្រះសង្ឃ រក្សាភ្លេងពិណពាទ្យ និងឆៃយ៉ាំ

ទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៥ ឆ្នាំ២០២៣ និងពិធីសំណេះសំណាលជាមួយសិល្បករ/ការិនីទូទាំងប្រទេសលើកទី៤, ២ មីនា ២០២៣

... **ទីអារាមនានាបានជួយយើង(ក្នុងវិស័យថែទាំវប្បធម៌មួយចំនួន) យ៉ាងហោចក្នុងនោះមាន២ សំខាន់គឺភ្លេងពិណពាទ្យនិងឆៃយ៉ាំ។ សូមពិនិត្យមើល ភ្លេងពិណពាទ្យ មិនមានអ្នកនៅខាងក្រៅ(ទីអារាម)រក្សាបានទេ។ ភាគច្រើន ភ្លេងពិណពាទ្យនេះត្រូវបានទុកនៅទីអារាម។ យើងគួរតែលើកទឹកចិត្តដល់ពុទ្ធបរិស័ទ ជួយដល់ព្រះសង្ឃ ដើម្បីទីអារាមមានភ្លេងពិណពាទ្យ**។ យើងមានប្រមាណ ៤០០០ទីអារាម ប្រសិនបើត្រឹមតែ៥០%នៃចំនួននេះ ក៏យើងមាន ២០០០វង់ភ្លេងពិណពាទ្យ ...នេះគឺជាការថែរតែកជូនតារបស់យើង។ នៅខាងក្រៅមានវង់ភ្លេង ឧបករណ៍ខាងសម័យ

អីហ្នឹង ជារឿងមួយ ប៉ុន្តែរឿងភ្លេងពិណពាទ្យ ... អាចជាក់តាមសាលវិចិត្រសិល្បៈប៉ុន្តែប្រហែលជានៅតាមវត្តអារាមច្រើនជាង ...។

៤១. តើអាចសន្ទនាជាមួយប្រទេសពាក់ព័ន្ធ ចុះបញ្ជីរួមគ្នានូវសម្បត្តិវប្បធម៌អ្ហរបី បានទេ?

ទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៥ ឆ្នាំ២០២៣ និងពិធីសំណេះសំណាលជាមួយសិល្បករ/ការិនីទូទាំងប្រទេសលើកទី៤, ២ មីនា ២០២៣

... ពាក់ព័ន្ធនឹងការដណ្តើមកម្មសិទ្ធភាព(សម្បត្តិវប្បធម៌)។ នេះជារឿងដែលមិនគួរចិញ្ចឹមទំនាស់ ឱ្យអូសបន្លាយមិនចេះចប់មិនចេះហើយ ដូចជាសព្វថ្ងៃមានរឿងរ៉ាវកើតឡើងស្តីពីក្បាច់ប្រដាល់ ដែលខ្មែរហៅថា "ក្បាច់គុនខ្មែរ" ឯថៃក៏ហៅ "មួយថៃ" ឡាវក៏មានមួយផ្សេង មីយ៉ាន់ម៉ាក៏មានផ្សេង។ យើងដឹងថា នៅតាមប្រាង្គប្រាសាទរបស់យើង មាន(ចម្លាក់បង្ហាញ)ក្បាច់គុននោះពិតហើយ ក៏ប៉ុន្តែចំណុចនេះ **តើយើងអាចធ្វើការសន្ទនាជាមួយបណ្តាប្រទេសដែលជាប់ពាក់ព័ន្ធ ... សំរបសំរួលគ្នាបានទេ? ឧទាហរណ៍ យើងអាចចុះបញ្ជីរួមគ្នាក្នុងក្របខណ្ឌបេតិកភណ្ឌអូបីរបស់អង្គការយូនេស្កូ ដូចដែលកន្លងទៅ យើងបានចុះបញ្ជី(ល្បែង)ទាញព្រ័ត្ររួមគ្នា** ...។

៤២. មរតកវប្បធម៌ខ្លះក៏មិនអាចចុះបញ្ជីរួមគ្នាបាន

ទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៥ ឆ្នាំ២០២៣ និងពិធីសំណេះសំណាលជាមួយសិល្បករ/ការិនីទូទាំងប្រទេសលើកទី៤, ២ មីនា ២០២៣

... ពិតហើយ (**មរតក់វប្បធម៌)ខ្លះយើងមិនអាចនឹងបោះបង់ចោលទេ។ ឧ. អប្សារឬក៏ចាប៉ីដងវែង ដែលយើងបានដាក់ចូលទៅក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌវប្បធម៌អូបី (របស់អង្គការយូនេស្កូ) ឬក៏ល្បក្តោ។ ហ្នឹងយើងមិនអាចទៅចុះបញ្ជីរួមទេ។** ប៉ុន្តែស្តីពីក្បាច់គុននេះ យើងពិនិត្យមើលថាពីអតីតកាលប្រទេសកម្ពុជាយើងពិតជាធំធេងមែន។ ក៏ប៉ុន្តែបន្ទាប់ទៅ ប្រទេសនេះមួយភាគបានស្ថិតក្នុងទឹកដីវៀតណាមមួយភាគបានស្ថិតក្នុងទឹកដីថៃ។ រឿងនេះជារឿងពិត។ ប្រទេសឡាវក៏ដូចគ្នាដែរ។ មុននេះមួយភាគឦសានរបស់ប្រទេសថៃគឺជាទឹកដីរបស់ឡាវ។ **អញ្ចឹងក្រោយពីទឹកដីវាឡូកឡំអញ្ចឹងទៅ (ជាការលំបាកនឹងកំណត់ពី)ប្រភពដើមថានៅទីណា? ថ្វីបើ**

យើងមានសាក្សី ក៏ប៉ុន្តែសភាពការណ៍បានវិឆ្ឍប្រែប្រួល។ ដូចនេះ យើងរកវិធីសម្របសម្រួលដើម្បីចៀសវាងនូវជម្លោះទាក់ទងនឹងវប្បធម៌នេះ ...។

៤៣. បើទោះចុះបញ្ជីរួមគ្នាតាមអនុសាសន៍ UNESCO ក៏របស់យើងនៅតែជារបស់យើង

ទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៥ ឆ្នាំ២០២៣ និងពិធីសំណេះសំណាលជាមួយសិល្បករ/ការិនីទូទាំងប្រទេសលើកទី៤, ២ មីនា ២០២៣

... សង្ឃឹមថាសមភាគីរបស់យើងនៅឡាវ និងនៅថៃ ក៏នឹងពិចារណាអំពីបញ្ហានេះ។ ខ្ញុំធ្លាប់បានពិភាក្សាជាមួយនាយករដ្ឋមន្ត្រី (ប្រាយុទ្ធ) ចាន់អូចា ពេលដែលគាត់មកប្រជុំអាស៊ាននៅកម្ពុជា។ ពេលទស្សនកិច្ចនៅឯប្រទេសឡាវកន្លងទៅ ខ្ញុំក៏បានលើកបញ្ហាហ្នឹង។(រដ្ឋមន្ត្រីវប្បធម៌និងវិចិត្រសិល្បៈ) លោកជំទាវ ភឿង សកុណា (ក៏បានផ្តល់របាយការណ៍មក)ថា **UNESCO លើកទឹកចិត្តឲ្យធ្វើរួមគ្នា ដើម្បីកុំឲ្យមានជម្លោះ។ (ថ្វីបើ)ចុះរួម(គ្នា) តែមិនមានអ្នកណាយកទៅណាទេ។ របស់យើងនៅតែជារបស់យើង។ មកប្រទេសកម្ពុជា គឺតាមរបៀបកម្ពុជាទៅ។ ឈ្មោះក្បាច់គុនកម្ពុជា។ កន្លងទៅ ថៃបដិសេធមិនបញ្ជូនកីឡាករមកប្រកួតក្បាច់គុនខ្មែរ** ... ច្បាស់ណាស់ មានអ្នកជេរខ្ញុំ។ ក៏ប៉ុន្តែអ្នកដែលជេរខ្ញុំក៏ប្រហែលរកច្រកចេញមិនឃើញ។ អាចថាយើងទទួលធ្វើសម្បទាន ក៏ប៉ុន្តែអ្នកត្រូវគិតថា តើប្រជាជាតិជិតខាងយើងសុខចិត្តទេ? គេព្រមទេ? គេក៏ជាប្រទេសមួយ ជាជាតិសាសន៍មួយ។ បើយើងមិនព្រមគេក៏មិនព្រម។ បើអញ្ចឹងវានៅតែទំនាស់រហូតហ្នឹង ...។

៤៤. ប្រើវិធីសាស្ត្រទូតជំរុញវប្បធម៌ និងទំនាក់ទំនងវប្បធម៌ជំរុញទំនាក់ទំនងនយោបាយ

ទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៥ ឆ្នាំ២០២៣ និងពិធីសំណេះសំណាលជាមួយសិល្បករ/ការិនីទូទាំងប្រទេសលើកទី៤, ២ មីនា ២០២៣

... **ខ្ញុំចង់ប្រើវិធីសាស្ត្រទូតដើម្បីរួមចំណែកជំរុញវប្បធម៌។ ហើយក៏តាមរយៈនៃការទំនាក់ទំនងវប្បធម៌នោះ នឹងជំរុញទំនាក់ទំនងនយោបាយឡើងវិញ**។ ខ្ញុំសូមលើកជាមតិសម្រាប់ការពិនិត្យស្រាវជ្រាវ ដោយលោកជំទាវរដ្ឋមន្ត្រីក្រសួងវប្បធម៌(និងវិចិត្រសិល្បៈ)អាចចាប់ផ្តើមពិគ្រោះយោបល់ជាមួយនឹងចាស់ទុំ និងផ្នែកពាក់ព័ន្ធក្នុងស្រុកថា តើមានអ្វីខ្លះដែលយើងអាចលើកជាគំនិតផ្តួចផ្តើម? ... យើងអាច

មានវិធីសាស្ត្រដួយដោះស្រាយ កុំឲ្យមើលមុខគ្នាមិនត្រង់ដោយសារតែការដណ្តើមជាកម្មសិទ្ធិ។ បងប្អូនយើងមានសិទ្ធិនឹងឈឺឆ្អាលរឿងនេះ។ ខ្ញុំនិយាយទៅកាន់បងប្អូនជនរួមជាតិគ្រាន់តែឲ្យឮឮងថ្លែងអំពីបញ្ហានេះ។យើងអត់មានបាត់បង់អ្វីទាំងអស់។ បើទៅយកពីថៃត្រឡប់មកវិញ តើថៃគេសុខចិត្តឲ្យទេ? គេមិនសុខចិត្តឲ្យទេ។ បើថៃចង់យកពីយើងៗក៏មិនសុខចិត្តឲ្យដែរ។ រឿងហ្នឹងវាទាល់ច្រកត្រឹមហ្នឹង ...។

៤៥. ភាពយន្ត "កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូណ៌មី" ព្រោះកើតថ្ងៃ ១៥កើត ខែស្រាពណ៌

សម្ពោធភាពយន្ត កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូរណ៌មី និងពិសាបាយ,
១៣ មីនា ២០២៣

... ទាក់ទងទៅនឹងចំណងជើង ច្បាស់ជាមានការវាយប្រហារ។ ខ្ញុំចង់ផ្ញើសារទុកមុនឲ្យហើយ ត្បិតអីគ្រាន់តែចាប់ផ្តើមថត មានការប្រមាថ(ទៅហើយ)។ **ខ្ញុំចង់ប្រាប់អស់លោកអ្នកថា បើខ្ញុំកើតថ្ងៃត្រង់ ប្រហែលជាគេដាក់ចំណងជើងរឿងនេះថាកូនប្រុសកើតក្រោមពន្លឺព្រះសុរិយាហើយ គេមិនដាក់កូនប្រុសក្រោមពន្លឺព្រះចន្ទទេ។ សូមអ្នកទាំងឡាយកុំឆ្ងល់នឹងពាក្យក្រោមពន្លឺព្រះចន្ទ។ ខ្ញុំបានកើតនៅថ្ងៃ ១៥កើត ខែស្រាពណ៌ គឺខែពេញបូរណ៌មីនោះឯង។** យើងគប្បីបកស្រាយបង្ការទុកជាមុន ព្រោះពួកអគតិតែងតែរករឿង ដែលសូម្បីតែរឿងនេះជារបស់គេសោះ។ ខ្លួនឯងចង់បង្កើតរឿងអីក៏បង្កើតទៅធ្វើទៅ។ រឿងរបស់គេទុកឲ្យគេ។ នេះជាការបង្ការទុក។ បើសិនជាខ្ញុំកើត(ពេល)ថ្ងៃ មុខតែមិនដាក់ចំណងជើងកើតពេលយប់ទេ ... ឥឡូវអ្នកណាចង់ដាក់ក្រោមភ្លើងចន្ទះ ឬក្រោមអំពូលម៉ែត្រអីក៏ដាក់ទៅ។ ជារឿងរបស់អ្នកឯង។ ប៉ុន្តែរឿងរបស់ខ្ញុំគឺផ្សេង ...។

៤៦. "កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូណ៌មី" ជារឿងពិត មិនអាចថត/សំដែងខុសបានទេ

សម្ពោធភាពយន្ត កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូរណ៌មី និងពិសាបាយ,
១៣ មីនា ២០២៣

... ក្រោយពីរឿង កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូរណ៌មី បានចាក់ផ្សាយតាមវិទ្យុ មានក្រុមហ៊ុនបរទេស៣ បានមកជួបខ្ញុំ។ ក្រុមហ៊ុនមួយដែលខ្ញុំមិនបញ្ចេញឈ្មោះទេ បានមកហួតដល់២ ដង។ ខ្ញុំមិនព្រមឲ្យថតទេ។ បើសិនជាអ្នកឯងថត គឺ

ខ្ញុំសុំឲ្យយកសេណារីយ៉ូដែលមាននៅក្នុងរឿងភាគនិទានរឿង "កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូរណ៌មី"។ ខ្ញុំបានឲ្យឯកឧត្តម ហ៊ុយ វាសនា បញ្ជូនឲ្យខ្ញុំប៉ុន្មានកេសឯណោះ ... **រឿងរបស់ខ្ញុំមិនអាចយកទៅកាឡៃបានទេ ... បើមិនអញ្ចឹងធ្វើឲ្យអ្វីដែលជាសាច់រឿងពិតក្លាយទៅជារឿងភូតកុហក។ ក្នុងរឿងនេះ ការសំដែងជាតួអង្គខ្ញុំ សូម្បីតែពាក្យមួយម៉ាត់ក៏មិនអាចឲ្យខុសបានទេ។ (បើសំដែងឬនិយាយខុស) ថ្ងៃក្រោយ រឿងហ្នឹងអាចក្លាយទៅជារឿងមួយផ្សេង។ ខ្ញុំស្នើឲ្យយកចិត្តទុកដាក់ ក្នុងហ្នឹងរឿងទាំងឡាយដែលពាក់ព័ន្ធនឹងរឿង "កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូរណ៌មី" ដែលប្រហែលជា ២០ភាគចុងក្រោយនៃភាគនិទាន ខ្ញុំបានជួយសារសេរ ...។**

៤៧. ដល់ពេលដែលត្រូវថតរឿង «កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូណ៌មី» ជាខ្សែភាពយន្ត

សម្ពោធភាពយន្ត កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូរណ៌មី និងពិសាបាយ,
១៣ មីនា ២០២៣

... នៅពេលដែលរឿង(កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូណ៌មី)នេះត្រូវបានចាក់ផ្សាយតាមវិទ្យុ ក្នុងហ្នឹងក៏មានតាមហ្វេសប៊ុករបស់ទូរទស្សន៍បាយ័ន, ហ្វេសប៊ុករបស់ BTV, ហ្វេសប៊ុករបស់ Fresh News ... **មានសំណូមពរច្រើនពីសំណាក់អ្នកស្តាប់ ចង់ឲ្យមានការថតជាខ្សែភាពយន្តនេះ។ វាល្មមដល់ពេលដែលត្រូវថតរឿងនេះហើយដែរ**។ សូម្បីតែរឿងដែលខ្ញុំនិយាយទុកនេះ ក៏ខ្ញុំគ្មានពេលសារសេរទេ។ ខ្ញុំនិយាយរួចហើយឲ្យចម្លង ព្រោះក្រែងលោពេលដែលខ្ញុំស្លាប់ទៅ យករឿងវារអាចំកំបាំងទាំងឡាយទៅតាមខ្លួន។ ខ្ញុំចង់អោយមានរឿងមួយ។ រឿងនេះមិនមែនជាហេតុការណ៍ដាច់ដោយឡែករបស់ខ្ញុំទេ។ វាពាក់ព័ន្ធទៅនឹងដំណើរជាតិទាំងមូល។ តើការឈឺចាប់របស់ជាតិរបស់យើងវាយ៉ាងម៉េច? ដូច្នេះបានជារឿងនេះ គ្របដណ្តប់អំពីព្រឹត្តការណ៍ទាំងឡាយដែលបានកើត។

៤៨. តួអង្គ ហ៊ុន សែន ផ្សារភ្ជាប់ការរស់រានមានជីវិតរបស់ប្រជាជននិងសន្តិភាព ជាមូលហេតុនាំដល់ការថតខ្សែភាពយន្ត «កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូណ៌មី»

សម្ពោធភាពយន្ត កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូរណ៌មី និងពិសាបាយ,
១៣ មីនា ២០២៣

... តើវាមានផលប្រយោជន៍ទេសម្រាប់អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រ? ថាវាមានប្រយោជន៍ (ព្រោះវានឹងជួយ)ឱ្យអ្នកស្រាវជ្រាវទាំងឡាយ បានដឹងអំពីដំណើរវិវត្តនៃសភាពការណ៍ពីដំណាក់កាលមួយទៅកាន់ដំណាក់កាលមួយ ... វាជារឿងចាំបាច់ដែលត្រូវធ្វើ ... **ពលរដ្ឋកម្ពុជាអាចនឹងយល់បានហើយថា ចាប់ផ្តើមពីការយកជីវិតធ្វើដើមទុននោះហើយ ដែលសភាពការណ៍បានវិវត្ត ហើយខ្ញុំបាននាំប្រទេសជាតិរហូតមកដល់ពេលនេះ។ គេមិនអាចផ្តាច់ចេញពីបញ្ហាទាំងហ្នឹងបានទេ។ តួអង្គ ហ៊ុន សែន មិនមែនគ្រាន់តែ ហ៊ុន សែន (ខ្លួនឯង)នោះទេ ក៏ប៉ុន្តែបានផ្សារភ្ជាប់ទៅនឹងជីវិតរបស់ប្រជាជន ពីពេលនោះរហូតមកដល់ពេលនេះ។ ក្បាលរបស់ខ្ញុំត្រូវយកទៅដូរជាមួយហ្នឹងការរស់រានមានជីវិតរបស់ប្រជាជន។ ក្បាលរបស់ខ្ញុំក៏ត្រូវបានយកទៅប្តូរជាមួយនឹងសន្តិភាព។ ជាភ័ព្វសំណាងល្អ ដែលខ្ញុំមានជីវិតដល់សព្វថ្ងៃ។ នោះហើយជាមូលហេតុដែលនាំដល់ការថតចេញនូវឧស្សភាពយន្តនេះ** ...។

៤៩. អរគុណសហរដ្ឋអាមេរិកនិងចក្រភពអង់គ្លេស នាំមកវិញនូវសម្បត្តិវប្បធម៌ខ្មែរ

ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០២៣ និងអបអរសាទរខួប ១០ឆ្នាំនៃការបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត, ១៤ មេសា ២០២៣

... រមណីយដ្ឋានអង្គរគឺជាបេតិកភណ្ឌពិភពលោក។ យើងមិនត្រូវធ្វើឲ្យខុសនឹងគោលការណ៍ដែលដាក់ចេញដោយអង្គការយូនេស្កូទេ។ បើមិនដូច្នោះ ... គេនឹងបញ្ចេញចេញពីបញ្ជីនៃបេតិកភណ្ឌពិភពលោក។ មិនមែនជាការយោគយល់ឬមិនយោគយល់ទេ ក៏ប៉ុន្តែនេះជាលក្ខខណ្ឌ។ ខ្ញុំក៏សូមយកឱកាសនេះ អរគុណចំពោះប្រិយមិត្តបរទេសទាំងអស់មានវត្តមាននៅទីនេះ ដែលបានចូលរួមជួយដល់ការអភិរក្សប្រាង្គប្រាសាទអង្គរវត្ត ក៏ដូចជាប្រាង្គប្រាសាទដទៃទៀតដែលមានក្នុងប្រទេសកម្ពុជា។ ខ្ញុំ**សូមអរគុណឯកឧត្តមអគ្គរដ្ឋទូតសហរដ្ឋអាមេរិក (Patrick) Murphy និងលោកជំទាវនៅទីនេះ ក៏ដូចជាអគ្គរដ្ឋទូតអង់គ្លេសដែលក្នុងរយៈពេលកន្លងទៅ បានធ្វើសកម្មភាពនាំមកវិញនូវមរតកវប្បធម៌ ដែលត្រូវបានលួច ដែលត្រូវបានជួញដូរទៅដល់សហរដ្ឋអាមេរិក ទៅដល់ចក្រភពអង់គ្លេស** ...។

៥០. ប្រទេសដទៃគប្បីចូលរួមជួយនាំសម្បត្តិវប្បធម៌កម្ពុជាត្រឡប់មកជួបជុំវិញ

ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០២៣ និងអបអរសាទរខួប ១០ឆ្នាំនៃការបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត, ១៤ មេសា ២០២៣

... **សង្ឃឹមថា ប្រទេសនានានឹងចូលរួមក្នុងកិច្ចការនាំសម្បត្តិវប្បធម៌ដែលបានបាត់បង់ វិលត្រឡប់មកប្រទេសកម្ពុជា តបតាមការខិតខំរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈដែលបានធ្វើកិច្ចការងារនេះយ៉ាងសកម្ម ជាមួយនឹងដៃគូខាងក្រៅ ក្នុងនោះសហរដ្ឋអាមេរិកគឺជាប្រទេសនាំមុខមួយ ក្នុងចំណោមប្រទេសនាំមុខទាំងឡាយនៃការបញ្ជូនត្រឡប់វិញនូវសម្បត្តិវប្បធម៌ ដែលត្រូវបានយកចេញពីកម្ពុជា ...តាមរយៈការលួច តាមរយៈការជួញដូរវត្ថុនេះ។ សង្ឃឹមថា ប្រទេសដ៏ទៃទៀតនឹងចូលរួមជួយយើងដើម្បីនាំត្រឡប់មកជួបជុំ**។ ខ្ញុំសូមជម្រាបថា នៅពេលសម័យសង្គ្រាមនិងរបបប្រល័យពូជសាសន៍ សូម្បីតែគ្រួសារអាទិទេពក៏ត្រូវបែកបាក់គ្នាដែរ ...។

៥១. សង្គ្រាមពង្រាត់ពូជពង្សព្រះអាទិទេព សន្តិភាពធ្វើអោយគ្រួសារព្រះអាទិទេពជួបជុំគ្នា

ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០២៣ និងអបអរសាទរខួប ១០ឆ្នាំនៃការបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត, ១៤ មេសា ២០២៣

...ថ្ងៃមុនខ្ញុំបានទៅទទួលដោយ**ចិត្ត(ញាប់ញ័រ)ហើយព្រឺក្បាលព្រឺខ្លួន ពិសេសត្រង់ថា ព្រះឥសូរនិងព្រះរាជបុត្រទាំង ២អង្គ ដែលបានបែកខ្ញែកគ្នា ព្រាត់គ្នាក្នុងសម័យសង្គ្រាម ត្រូវបានវិលត្រឡប់(មកជួបជុំគ្នាវិញ)។ នោះគឺព្រះស្កន្ទ ។ព្រះឥសូរមានព្រះរាជបុត្រ ២ព្រះអង្គ ។សង្គ្រាមគឺយ៉ាងដូច្នេះ។ សូម្បីពូជពង្សព្រះអាទិទេពក៏បែកខ្ញែកគ្នាដែរ។ សន្តិភាពបាននាំព្រះអាទិទេពជួបជុំគ្នានៅក្នុងសុខសន្តិភាព។ នេះជាតម្លៃពិតនៃសន្តិភាព**។ បើបាត់បង់សន្តិភាព សូម្បីតែពូជពង្សព្រះអាទិទេពក៏ព្រាត់ប្រាសគ្នាដែរ។ នេះនិយាយតាមភាសាមួយបែប ... ពេលដែលមានសន្តិភាព ក្រុមគ្រួសារព្រះអាទិទេពបានមកជួបជុំគ្នាក្រោមម្លប់សន្តិភាពនៃសម័យយើងនេះ ...។

៥២. សិល្បៈទម្រង់ធំស៊ីហ្គេមបង្ហាញពីភាពស៊ីសង្វាក់គ្នារវាងចលនាមនុស្សនិងឌីជីថល

សម្ពោធនិងចែកសញ្ញាបត្រនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ២៤ ឧសភា ២០២៣

... សូមអរគុណលោកជំទាវរដ្ឋមន្ត្រី ក៏ដូចជាថ្នាក់ដឹកនាំក្រសួងដែលបានចូលរួម **រៀបចំសិល្បៈក្នុងទម្រង់ដ៏ធំមួយសម្រាប់ស៊ីហ្គេមក្នុងរយៈពេលកន្លងទៅ។ អរគុណសិល្បករ/ការិនីទាំងអស់ដែលបានហ្វឹកហាត់រាប់ខែ។ ខ្ញុំរកអត់ឃើញកន្លែងទាស់ទេ ព្រោះស៊ីសង្វាក់គ្នាខ្លាំងណាស់រវាងចលនារបស់មនុស្ស និងចលនានៃព័ត៌មានវិទ្យា ដែលហៅថា ឌីជីថល**។ វាផ្សារភ្ជាប់គ្នាអត់ដាច់រយៈ។ ការហ្វឹកហាត់របស់សិល្បៈករ/ការិនីរួមជាមួយកម្លាំងប្រដាប់អាវុធ គឺអង្គរក្ស ២០០០នាក់ ... ពួកគេបម្រើការងារសិល្បៈ ហើយបើមានការចលាចលណាមួយកើតឡើង គឺពួកអង្គរក្សនោះទទួលគ្រប់គ្រងសភាពការណ៍ ...។

៥៣. សូមកុំឱ្យប្រវត្តិសាស្ត្រមានបញ្ហូលគំនិតអ្នកនិពន្ធ ធ្វើអោយរឿងខុសពីការពិត

ពិធីបិទកញ្ចក់កាមេរ៉ាថតខ្សែភាពយន្តរឿង កូនប្រុសក្រោមពន្លឺព្រះច័ន្ទពេញបូណ៌មី, ៩ តុលា ២០២៣

... ខ្ញុំមានការរីករាយជាមួយនឹងការសម្រេចបាន(ជាខ្សែភាពយន្តនេះ)។ ទោះបីថាឆ្នុះបញ្ចាំងមិនអស់នូវអ្វីដែលវាបានកើតឡើងក្តី **ក៏ខ្ញុំមានសំណូមពរថាសូមកុំឱ្យមានរឿងស្តីពីប្រវត្តិ ហ៊ុន សែន ដល់ទៅពីរ ... សូមប្រើប្រាស់អ្វីដែលមានក្នុងខ្សែភាពយន្តនេះជាមូលដ្ឋានសម្រាប់ការឆ្លុះបញ្ចាំងអំពីដំណើរជីវិតរបស់ខ្ញុំ។ អ្វីដែលខ្ញុំខ្លាចបំផុតគឺរឿងប្រវត្តិសាស្ត្របានបញ្ចូលនូវគំនិតរបស់អ្នកនិពន្ធ ធ្វើឱ្យរឿងនោះក្លាយទៅជាខុសការពិត**។ ឧទាហរណ៍ ខ្ញុំបានសំណូមពរឱ្យផ្អាកការបញ្ចាំងតាមទូរទស្សន៍នានា ហើយរៀបចំការចាក់ផ្សាយឡើងវិញនោះ គឺបទចម្រៀង «អនិច្ចាកូនកម្សត់ប្រវត្តិម្តាយកម្ម» ដែលក្នុងរូបភាពនៃការចាក់ផ្សាយនោះ បានឃើញថាពេទ្យឆ្មបបោះកូនទៅក្រៅផ្ទះ។ នេះវាខុសពីការពិត។ ឥឡូវ មានរូបភាពនៅក្នុងខ្សែភាពយន្តនេះហើយ។ ប្រសិនបើយើងចង់ដាក់ចូល គឺយើងត្រូវដាក់សាច់រឿងពិតដែលវាបានកើតឡើង ដូចដែលខ្សែភាពយន្តនេះបានបង្ហាញ ...។

៥៤. ប្រទេសរីកចម្រើន ការធ្វើបុណ្យទានកាន់តែច្រើន តម្រូវការអាចារ្យនិងសិល្បៈកើន

ទិវាវប្បធម៌ជាតិ ៣មីនា លើកទី១៩ និងពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេស, ៣ មីនា ២០១៧

... អ្វីដែលខ្ញុំបាននិយាយ(ពីវិបត្តិអាចារ្យ)តាំងពីមុននោះ ឥឡូវបានល្អហើយ។ សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ បានជួយ ... បញ្ហាខ្លះអាចារ្យត្រូវបានដោះស្រាយ។ អាចារ្យដែលមានទីផ្សារគឺអាចារ្យចេះគ្រប់មុខ។ បើអាចារ្យចេះតែមួយមុខ គឺអាចារ្យអត់ទីផ្សារ។ ឧ. អាចារ្យចេះកាន់តែពេលាការ ... ដូចនេះ គាត់ត្រូវប៉ាន់តែខែមានពិធីការ(អាពាហ៍ពិពាហ៍)។ ខែមិនមានពិធីការ គាត់ដាច់អាជីព។ **រីឯអាចារ្យចេះគ្រប់មុខ (អាចជួយរៀបចំ/ជំណើរការ)ទាំងបុណ្យសព បុណ្យបច្ច័យបួន សង្ឃទាន ... យ៉ាងណាក្តី ក៏មានអ្នកប្រកាន់ថាអាចារ្យជុតខ្មោច មិនឱ្យមកកាន់ពេលាការទេ។ ហ្នឹងជាទំនៀមទម្លាប់ខ្មែរ**។ ថ្ងៃមុនខ្ញុំមកសំណេះសំណាលនៅទីហ្នឹងពីវិបត្តិអាចារ្យ។ អាចារ្យខ្លះត្រូវកាត់សក់(នៅពិធីមួយ)ឲ្យបានលឿន នឹងបានគាត់ទៅកាត់សក់ឲ្យមួយកន្លែងទៀត។ (នេះមកពី)ខ្វះអាចារ្យ។ **ប្រទេសកាន់តែមានការីកចម្រើនទៅ ការធ្វើបុណ្យទានក៏កាន់តែច្រើន។ តម្រូវការអាចារ្យនិងសិល្បៈគឺកាន់តែច្រើន** ...។

៥៥. មិនមានការឈ្លានពានវប្បធម៌ទេ មានតែការទទួលយកដោយស្ម័គ្រចិត្ត

សម្ពោធនិងចែកសញ្ញាបត្រនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ២៤ ឧសភា ២០២៣

... ខ្ញុំធ្លាប់ប្រតិកម្មនឹងខ្សែភាពយន្តមួយ ដែលស្លៀកពាក់មិនដឹងជាសម័យណារួចហើយថាមានសម័យកាលរបស់វា។ ខ្ញុំថា ឲ្យឆ្លើយឲ្យខ្ញុំរបៀបហ្នឹងសម័យណា ... តាំងពីហ្នុងមកជាង ១០ឆ្នាំហើយ មិនហ៊ានឆ្លើយទេ។ប្រយ័ត្នមែនទែនកន្លែងហ្នឹងដែលភាពក្លាយ(វាទៅជាគំរូមត៌ក)។ **ខ្ញុំមិនជឿអំពីការឈ្លានពានខាងវប្បធម៌ទេ។ ខ្ញុំនៅតែអះអាងថា ខ្ញុំមិនជឿថាមានការឈ្លានពានវប្បធម៌ឡើយ ព្រោះមិនអាចនឹងឈ្លានពានកើតទេ។ អ្វីដែលត្រូវកែយខ្លាចបំផុត គឺការទទួលយកដោយស្ម័គ្រចិត្ត។ នេះទើបជារឿងដែលត្រូវប្រុងប្រយ័ត្ន**។ បារាំងបានមកត្រួតកម្ពុជា ៩០ឆ្នាំ។ សួរថាបារាំងអាចកែយើងបានទេ? យើងអត់ទទួលយកវប្បធម៌បារាំងទេ។ វត្តអារាមរបស់យើងក៏មានទីកន្លែងរក្សាទុកអក្សរសាស្ត្រ ក្នុងពេលប្រទេសជាទៃដែលបារាំងត្រួត គេនិយាយនិងយកភាសាបារាំងទៅប្រើ ...។

៥៦. ខ្មែរក្សាអក្សរនិងវប្បធម៌តាមទីវត្តអារាម បារាំងឲ្យកត់ត្រាក្សាទុក ល្បើកក្រម ង៉ុយ

សម្ភោធនិងចែកសញ្ញាបត្រនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ,
២៤ ឧសភា ២០២៣

... ប្រទេសជិតខាងយើង ដូចជាប្រទេសវៀតណាម ពីដើមប្រើអក្សរដូចជាអក្សរចិនអញ្ចឹង ហើយមានសំនៀងអានដូចគ្នា ... វៀតណាមហៅ នគរបាល ថា កុងអាន។ ចិនក៏ហៅ កុងអាន ដូចគ្នា។ អញ្ចឹង ភាសាអ្នកទាំងពីរប្រហាក់ប្រហែលគ្នា។ អក្សរដើមក៏ប្រហាក់ប្រហែលគ្នាដែរ។ ពេលដែលបារាំងចូលមកធ្វើ romanisé ទៅជាភាសាមួយផ្សេង។ **ឯកម្ពុជា បារាំងមិនមានលទ្ធភាពនឹងកែវប្បធម៌ខ្មែរទេ នៅពេលដែលខ្មែរនៅតែបន្តរក្សាទុកនៅតាមវត្តអារាម។ ប៉ុន្តែ ក៏មានចំណុចដែលយើងគួរតែដឹងគុណបារាំងដែរ។ បើយើងពិនិត្យមើលល្បើកក្រមង៉ុយស្តីៗ នេះ គឺបារាំងហើយជាអ្នកហៅមកច្រៀង ហើយឲ្យគេកត់ត្រារក្សាទុក**។ បានបារាំងជួយ កុំអីបាត់ក្រមង៉ុយ (ល្បើក)បាត់(ហើយ)។ អត់មានក្រមង៉ុយដល់រាល់ថ្ងៃទេ។ ហ្នឹងវាមានចំណុចខ្លាំងចំណុចខ្សោយរបស់វា ...៕

៥៧. នាយករដ្ឋមន្ត្រីបង្ហាញទស្សនីយ៍ភាពសិល្បៈច្រើនឈុតឆាកក្នុងពិធីជប់លៀង

សម្ភោធនិងចែកសញ្ញាបត្រនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ,
២៤ ឧសភា ២០២៣

... សម្លៀកបំពាក់ក៏ដូចគ្នា។ ត្រូវកំណត់ដំណាក់កាលណា។ ដំណាក់កាលអង្គរលង្វែក ចតុមុខ។ នៅតែស្រមៃ បើទោះបីថាពេលនោះមិនទាន់ដឹងក្តី ព្រោះដូចជានៅរៀនថ្នាក់កុមារដ្ឋាន ឬថ្នាក់បរិវច្ឆដ្ឋាន។ ម្តាយខ្ញុំនៅពាក់អាវបំពង់នៅឡើយ ... មកដល់ទសវត្សរ៍៦០ ប្តាយទៅហើយហ្នឹង ក៏នៅមានអាវបំពង់នៅឡើយទេ។ ឥឡូវនេះ វាបាត់បង់អាវបំពង់នោះហើយ ប៉ុន្តែនៅពេលដែលយើងសម្តែងសិល្បៈ ដូចជានៅក្នុងពេលដែលព្រះមហាក្សត្រទទួលភ្ញៀវ គឺមានភ្លេងកំដរអញ្ចឹង (តែងតែមាន) ... **ចំពោះខ្ញុំ (ក្នុងការលាងសាយភោជន៍ទទួលភ្ញៀវ គឺឱ្យ)សម្តែងរហូតតាំងពីចាប់ផ្តើមទទួលទាន ព្រោះខ្ញុំមិនមានសុន្នរកថាទេ។ ចរចាអស់ ២ម៉ោងអីហើយ តើមានសុន្នរកថាអីទៀត។ ចូលដល់សំដែងសិល្បៈតែម្តង។ អញ្ចឹង សម្តែងបានច្រើនឆាកច្រើនឈុត ក្នុងហ្នឹងទម្រង់ដើមដែលជារបាំព្រះរាជទ្រព្យផងនិងរបាំតាមតំបន់ ដូចជារបាំគោះក្រឡោកក្ងោកប៉ែលិនរបាំសួយបេះក្រវ៉ាញ ...៕**

២៤. សន្តិសុខសង្គម និងយុវនីតិសម្បទា

១	កាយសម្បទាមិនមែនជាឧបសគ្គនៃការអភិវឌ្ឍខ្លួន	៤៧១
២	រដ្ឋាភិបាលយកចិត្តទុកដាក់បង្រួមគម្លាតរវាងអ្នកពិការនិងអ្នកមិនពិការ	៤៧១
៣	សូមស្តានីយទូរទស្សន៍មានបកប្រែព័ត៌មានជាភាសាសញ្ញា	៤៧១
៤	ជនពិការបានចូលធ្វើការនៅតាមស្ថាប័នរដ្ឋមួយចំនួន	៤៧២
៥	កុំរើសអើងនឹងជនពិការ ជនពិការក៏អាចក្លាយជាអ្នកដឹកនាំប្រទេស	៤៧២
៦	ស្អប់ខ្ពើមនិងប្តោលទោសអ្នកមើលងាយជនពិការ	៤៧៣
៧	សេចក្តីសុខរបស់ប្រជាជាតិ មិនអាចកាត់ផ្តាច់ពីពលិកម្មនៃយុទ្ធជនពិការ	៤៧៣
៨	យុទ្ធជនពិការទទួលបានការយកចិត្តទុកដាក់ពីរដ្ឋាភិបាលនិងគណបក្សប្រជាជន	៤៧៣
៩	យកចិត្តទុកដាក់ចំពោះយុទ្ធជនពិការក្រៅមណ្ឌល តាមរយៈសមាគមអតីតយុទ្ធជន	៤៧៤
១០	បោះមេដាយបំពាក់ជូនយុទ្ធជន ជាការទទួលស្គាល់គុណបំណាច់ពីរដ្ឋាភិបាល	៤៧៤
១១	បន្តដោះស្រាយដីសម្បទានសង្គមកិច្ចជូនអតីតយុទ្ធជន	៤៧៤
១២	ដោះស្រាយលំនៅដ្ឋាន ជាគោលដៅអាទិភាពនៃសមាគមអតីតយុទ្ធជន	៤៧៥
១៣	ជនពិការខិតខំដើម្បីសេចក្តីថ្លៃថ្នូររបស់ខ្លួន គ្រួសារនិងមោទនភាពសំរាប់កូនចៅ	៤៧៥
១៤	ការបើកផ្តល់ប្រាក់បៀវត្សបានទាន់ពេលវេលាដល់ទាហាននិងយុទ្ធជនពិការ	៤៧៦
១៥	មិនទុកអោយមជ្ឈមណ្ឌល/AFESIP ត្រូវបិទឡើយ	៤៧៦
១៦	នៅមានអ្នកបន្តវេនទ្រទ្រង់មជ្ឈមណ្ឌល/AFESIP	៤៧៦
១៧	អ្នកនៅក្នុងមណ្ឌល/AFESIP ជាប់បាក់ឌុប្លី ទទួលបានអាហារូបករណ៍រៀនបន្ត	៤៧៧
១៨	១៩៧៩ កន្លែងចិញ្ចឹមកុមារកំព្រាមានអាទិភាពជាងអគារធ្វើការនៃចៅហ្វាយខេត្ត	៤៧៧
១៩	មិនឱ្យកុមារណាគ្មានការថែទាំ និងត្រូវទទួលបានការអប់រំនិងបណ្តុះបណ្តាល	៤៧៨
២០	ប្រៃពីជនរងគ្រោះទៅជាកម្លាំងគស៊ូ ជាធនធានមនុស្សបម្រើសង្គម	៤៧៨
២១	ចេញពីមណ្ឌលកុមារកំព្រាក្លាយជាធនធានមនុស្សសម្រាប់សង្គមជាតិ	៤៧៩
២២	ពិនិត្យ/ព្យាបាលជំងឺឥតគិតថ្លៃសំរាប់កុមារីរងគ្រោះ បុគ្គលិកមជ្ឈមណ្ឌល/AFESIP	៤៧៩
២៣	ក្រោយបញ្ចូលក្របខ័ណ្ឌរដ្ឋ ផ្តល់ថវិកាឧបត្ថម្ភបន្ថែមដល់គ្រូក្នុងអង្គការគ្រួសារថ្មី	៤៨០
២៤	អប់រំសីលធម៌សង្គមនិងឲ្យជាប់ទោសមួយជីវិត សំរាប់ជនដែលរំលោភកូន/ចៅខ្លួន	៤៨០
២៥	ក្រសួងសង្គមកិច្ចនិងក្រសួងអប់រំ ត្រៀមទទួលរ៉ាប់រងមជ្ឈមណ្ឌលនានា	៤៨១

២៦	ផ្តល់បណ្ណក្រីក្រដល់គ្រួសារងងលប៉ះពាល់ពីកូវីដ-១៩ និងពីអតិផរណាបន្ថែម	៤៨១
២៧	ជំនួយសង្គមក្នុងពេលមានវិបត្តិ មិនមែនជាការចិញ្ចឹមរបស់រដ្ឋជាអចិន្ត្រៃយ៍	៤៨២
២៨	គោលនយោបាយគាំពារសង្គម រាប់បញ្ចូលអ្នកក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ	៤៨២
២៩	មន្ត្រីរាជការចូលនិវត្តន៍នៅអាយុ ៦០ឆ្នាំ ដដែល	៤៨២
៣០	ពន្យារអាយុចូលនិវត្តន៍ចំណេញថវិកា តែត្រូវគិតពីលំហាការងារសម្រាប់យុវជន	៤៨៣
៣១	ផ្តល់បណ្ណក្រីក្រ១ ជូនពលរដ្ឋស្ម័គ្រចិត្តពីរមណើយដ្ឋានអង្គរទៅតំបន់រុនតាឯក	៤៨៣
៣២	សម្រេចបង្កើតមូលនិធិស៊ីក្ខ ជាការជួយដល់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ	៤៨៤
៣៣	អាទិភាពនៃនយោបាយ ហ៊ុន សែន ក្នុងគោលនយោបាយថ្មីលើវិស័យសង្គម	៤៨៤
៣៤	សមាជិកមូលនិធិអ្នកធាក់ស៊ីក្ខ ទទួលបានការពិនិត្យនិងព្យាបាលឥតគិតថ្លៃ ...	៤៨៥
៣៥	សមាជិកមូលនិធិអ្នកធាក់ស៊ីក្ខ ទទួលប្រាក់ឧបត្ថម្ភមរណភាព ១លាន ៥ម៉ឺនរៀល	៤៨៥
៣៦	សមាជិកមូលនិធិអ្នកធាក់ស៊ីក្ខ ទទួលបានអារក្សៀងនៅខែក្សៀង អាងងានៅខែងា	៤៨៦
៣៧	ចង់ឲ្យមូលនិធិស៊ីក្ខមាននិរន្តរភាព	៤៨៦

១. កាយសម្បទាមិនមែនជាឧបសគ្គនៃការអភិវឌ្ឍខ្លួន

សួរសុខទុក្ខកុមារពិការភ្នែក/គ-ថ្លង់គ្រួសារថ្មី, ១៨ វិច្ឆិកា ២០១៨

... តាមកនេះ បន្តការដាស់តឿនចំពោះចៅៗទាំងអស់ត្រូវខិតខំរៀនសូត្រ។ **យើងបានជាកើតមកកាយសម្បទារបស់យើងមិនគ្រប់គ្រាន់ ក៏ប៉ុន្តែសម័យនេះបើយើងចេះជម្នះ កាយសម្បទាមិនមែនជាឧបសគ្គនៃការអភិវឌ្ឍខ្លួនចៅៗ ម្នាក់ៗនោះទេ។** ឥឡូវនេះ មានអក្សរស្ទាប មានទាំងរបៀបការបកប្រែ ធ្វើឱ្យកុមារគ-ថ្លង់និងពិការភ្នែកមួយចំនួន ទទួលបានការបណ្តុះបណ្តាលរហូតទៅដល់ឧត្តមសិក្សានិងក្រោយឧត្តមសិក្សាទៅទៀត។ មួយចំនួនកំពុងធ្វើការងារនៅតាមស្ថាប័នរបស់រដ្ឋ តាមវិស័យឯកជន និងធ្វើការនៅតាមក្រុមគ្រួសាររបស់ខ្លួនផងដែរ ...៕

២. រដ្ឋាភិបាលយកចិត្តទុកដាក់បង្រួមគម្លាតរវាងអ្នកពិការនិងអ្នកមិនពិការ

សំណេះសំណាលជាមួយកម្មករ/ការិនី នៅតំបន់កប់ស្រូវ, ១៣ ធ្នូ ២០១៧

... ជាលើកដំបូងដែលខ្ញុំបានជួបជាមួយកម្មករ/ការិនីជាជនពិការ ដែលនេះក៏ជាសូចនាករតាមដានមួយរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាក្រសួងសង្គមកិច្ច អតីតយុទ្ធជន ទាក់ទងនឹងការទទួលយកជនពិការចូលទៅក្នុងក្របខ័ណ្ឌការងាររដ្ឋ ដែលត្រូវទទួល២% និងវិស័យឯកជនត្រូវទទួល១%។ ប៉ុន្តែយើងមិនទាន់បានអនុវត្តទាំងស្រុងទេ។ ថ្ងៃនេះ ហោចណាស់ក៏បង្ហាញពីវឌ្ឍនភាពមួយ ដែលយើងបានឃើញថា កម្មករ/ការិនី (ពិការ)មកកាន់ទីនេះ។ ខ្ញុំក៏បានសួរអំពីប្រាក់ចំណូល គឺបានជាង ២០០ ដុល្លារសហរដ្ឋអាមេរិក។ អាចចាត់ទុកថានេះជាផ្នែកមួយដ៏សំខាន់ ក្នុងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលចំពោះជនពិការ កុំឱ្យមានគម្លាតរវាងអ្នកដែលមិនពិការ និងអ្នកដែលពិការ ...៕

៣. សូមស្តាប់ទូរទស្សន៍មានបកប្រែព័ត៌មានជាភាសាសញ្ញា

ផ្ទេរសាលាកុមារពិការភ្នែក និងគ/ថ្លង់ ពីអង្គការគ្រួសារថ្មី ទៅក្រសួងអប់រំ យុវជន និងកីឡា, ១ កក្កដា ២០១៩

... នៅប្រទេសយើង ណែនាំម្តងបានម្តង ណែនាំ ២ដង បាន ២ដង ... កន្លងទៅពេលអានព័ត៌មាន តែងតែមានអ្នកបកប្រែភាសាគ-ថ្លង់។ សូមទូរទស្សន៍ទាំងនោះផ្តល់សិទ្ធិឱ្យអ្នកគ-ថ្លង់បានយល់ផង។ អ្នកធ្វើការនៅគ្រួសារថ្មីនេះ ជាអ្នកដែលត្រូវ

ឡើងប៉ុស្តិ៍ទៅធ្វើជាសញ្ញា ដើម្បី(អោយអ្នកទស្សនាដែលគថ្លង់មាន)ការយល់ដឹង។ មុននេះទូរទស្សន៍បាយ័នបានធ្វើច្រើនជាងគេ ... **សង្ឃឹមថា ទូរទស្សន៍មួយៗ រៀបចំឱ្យមានអ្នកបកប្រែ សម្រាប់ការផ្តល់ព័ត៌មានដល់ក្មួយៗ ចៅៗ ដែលជាអ្នក គ-ថ្លង់**...៕

៤. ជនពិការបានចូលធ្វើការនៅតាមស្ថាប័នរដ្ឋមួយចំនួន

ផ្ទេរសោលកុមារពិការភ្នែក និងគ/ថ្លង់ ពីអង្គការគ្រួសារថ្មី ទៅក្រសួងអប់រំ យុវជន និងកីឡា, ១ កក្កដា ២០១៩

... នៅទីនេះ ចៅៗ ចេះទាំងស្រាវជ្រាវ កុំព្យូទ័រ ស្អីៗ ដែលឥឡូវហ្នឹង **មួយចំនួន បានចូលធ្វើការនៅទីស្តីការគណៈរដ្ឋមន្ត្រី ចូលធ្វើការនៅក្រសួងអប់រំ យុវជន និង កីឡា នៅក្រសួងការបរទេស ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងធ្វើកិច្ចការងារ មួយចំនួនផ្សេងទៀត។** អ្នកទាំងនោះពិការភ្នែកទេ ប៉ុន្តែមានលទ្ធភាពនឹងសរសេរចេញជាអត្ថបទ ហើយយកមកឱ្យយើងអ្នកភ្លឺភ្នែកអានថែមទៀតផង។ នោះហើយជាក្របខ័ណ្ឌនៃការពង្រឹងសមត្ថភាព ដែលមិនមែនគ្រាន់តែអ្នកមានកាយសម្បទាគ្រប់គ្រាន់ទេ សូម្បីតែអ្នកដែលគ្មានកាយសម្បទាគ្រប់គ្រាន់ ក៏យើងបានធ្វើរឿងនេះដែរ ...៕

៥. កុំរើសអើងនឹងជនពិការ ជនពិការក៏អាចក្លាយជាអ្នកដឹកនាំប្រទេស

សំណេះសំណាលជាមួយកម្មករ/ការិនី នៅតំបន់កប់ស្រូវ, ១៣ ធ្នូ ២០១៧

... **កុំរើសអើងជាមួយយុវជនពិការ។ បុរសយើងក៏មិនត្រូវរើសអើងជាមួយនារីពិការដែរ។ ឯនារី/ស្ត្រីយើង ក៏មិនត្រូវរើសអើងជាមួយនឹងជនពិការដែរ ... យុទ្ធជនពិការម្នាក់នេះ បានក្លាយទៅជាមេដឹកនាំប្រទេស ក្នុងមុខតំណែងផ្សេងៗ គ្នា ក្នុងរយៈពេលជិត ៤០ឆ្នាំរួចហើយៗ** ក៏មិនមែនមានតែពូម្នាក់ដែលជាអ្នកជនពិការហើយដឹកនាំប្រទេសដែរ។ ព្រះមហាក្សត្រថៃដែលទើបបានសោយទិវង្គត ... ក៏ព្រះអង្គខូចព្រះនេត្រឆ្វេងម្ខាងដូចពូដែរ។ អតីតប្រធានាធិបតីឥណ្ឌូនេស៊ី ដែលជាប្រទេសមានប្រជាជនច្រើនបំផុតនៅក្នុងអាស៊ាន គឺលោក (អាប់ឌុ៉ារ៉ាហ្មាន) វ៉ាហ៊ីត ខូចភ្នែកទាំងពីរឯណោះ តែអាចធ្វើប្រធានាធិបតីបាន ... ពាក្យសម្តីនៃជនដែលមិនគោរពសិទ្ធិចំពោះជនពិការ ជាភាពតិរិច្ឆានរបស់ពួកគេតែប៉ុណ្ណោះ ...៕

៦. ស្អប់ខ្ពើមនិងថ្កោលទោសអ្នកមើលងាយជនពិការ

ប្រគល់សញ្ញាបត្រសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ, ១១ តុលា ២០២២

... ខ្ញុំឆ្លៀតនិយាយបន្តិចថា យើងពិការរូបកាយតែកុំពិការផ្លូវចិត្ត និងខួរក្បាលៗ ចំណុចនេះសំខាន់ណាស់។ ខ្ញុំ**ស្អប់ខ្ពើមនិងតែងតែថ្កោលទោសអ្នកណាក៏ដោយ ដែលជេរជនពិការថាអាខ្វាក់/អាខ្វិន/អាកំបុត/អាកំបាក់។ ហ្នឹងគឺពួកអសីលធម៌។** ខ្ញុំក៏បានបញ្ជាក់ថា ដោយសារតែកាយសម្បទារបស់យើងអញ្ចឹងបានជាយើងត្រូវតែប្រឹង។ **ចំណេះដឹងរបស់យើងវាជាគ្រឿងអលង្ការដែលល្អជាងរូបកាយពិត។ អ្នកខ្លះរូបកាយល្អ ក៏ប៉ុន្តែចរិតមិនល្អ មិនមានតម្រិះរិះគិត** ...៕

៧. សេចក្តីសុខរបស់ប្រជាជាតិ មិនអាចកាត់ផ្តាច់ពីពលិកម្មនៃយុទ្ធជនពិការ

សំណេះសំណាលជាមួយយុទ្ធជនពិការ ៣១៧, ១៣ មេសា ២០១៧

... ក្មួយៗ ចៅៗ ត្រូវមានមោទនភាពចំពោះឪពុករបស់ខ្លួន ដែលបានលះបង់សាច់ស្រស់ឈាមស្រស់ដើម្បីជាតិមាតុភូមិ។ **សេចក្តីសុខរបស់ប្រជាជាតិនៅពេលនេះ មិនអាចកាត់ផ្តាច់ចេញបានពីពលិកម្ម ពីតំណក់ឈាមដែលឪពុករបស់យើងបានខិតខំនោះទេ**។ មានយុទ្ធជនពិការរបស់យើងមួយចំនួន មិនទាន់មានការិយាទេ។ សង្ឃឹមថាក្មួយៗ ប្អូនៗ នឹងរកបានការិយាដ៏ល្អ ដោយមាននារីស្រឡាញ់ក៏ប៉ុន្តែ ទាល់តែយើងកុំពិការផ្លូវចិត្ត ...៕

៨. យុទ្ធជនពិការទទួលបានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលនិងគណបក្សប្រជាជន

សំណេះសំណាលជាមួយយុទ្ធជនពិការ ៣១៧, ១៣ មេសា ២០១៧

... **យុទ្ធជនពិការរបស់យើងមានរាជរដ្ឋាភិបាល ជាពិសេសមានគណបក្សប្រជាជនយកចិត្តទុកដាក់។ ខ្ញុំបានធ្លាក់ខ្លួនពិការ ក្នុងកាលៈទេសៈដ៏លំបាក**។ អរគុណការិយាខ្ញុំដែលបានទទួលខ្ញុំជាប្តី។ នេះជាឧទាហរណ៍មួយ ដែលគ្រប់ក្រុមគ្រួសារជនពិការមើលឱ្យឃើញតម្លៃ។ កាយសម្បទាជារឿងមួយហើយ ... ប៉ុន្តែ**ការលះបង់របស់យើងមានតម្លៃរបស់វា។ ក្នុងហានៈជាយុទ្ធជនពិការក្នុងសម័យសង្គ្រាម និងក្នុងរបប ប៉ុល ពត ការឆើបឈរឡើងរបស់ខ្ញុំបង្ហាញថា (វា)មិនចាំបាច់ថា ទាល់តែមិនពិការ ទើបអាចធ្វើការបានទេ** ...៕

៩. យកចិត្តទុកដាក់ចំពោះយុទ្ធជនពិការក្រៅមណ្ឌល តាមរយៈសមាគមអតីតយុទ្ធជន

សំណេះសំណាលជាមួយយុទ្ធជនពិការ ៣១៧, ១៣ មេសា ២០១៧

... ឆ្នាំនេះ ខ្ញុំមកទីនេះ(គូលេន)តែខ្ញុំនៅជំពាក់បងប្អូននៅតាកែនកោះស្លា និងនៅភ្នំឆត្រ។ មិនទាន់បានទៅសម្ពោធនៅភ្នំឆត្រទេ តែការរៀបចំកសាងផ្ទះសម្បែងស្អីៗនេះ គឺកំពុងដំណើរការល្អហើយ។ ខ្ញុំនៅជំពាក់កុមារកំព្រា កុមារ ពិការគ/ថ្លង់ ដោយសារតែកម្មវិធីច្រើនពេក។ ក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ **យើងបានបង្កើនការយកចិត្តទុកដាក់ មិនគ្រាន់តែចំពោះយុទ្ធជនពិការនៅក្នុងមណ្ឌលនោះទេ តែតាមរយៈនៃសមាគមអតីតយុទ្ធជន ជួយដល់អតីតយុទ្ធជន ក្នុងនោះមានទាំងយុទ្ធជនពិការផង ដោយផ្តល់ជូនសំណង់មួយចំនួន ដូចជា ផ្ទះសម្បែង នៅទីណាដែលមានដី ហើយអាចមានប្រាក់ដើម្បីសាងសង់ផ្ទះ** ...។

១០. បោះមេដាយបំពាក់ជូនយុទ្ធជន ជាការទទួលស្គាល់គុណបំណាច់ពីរដ្ឋាភិបាល

ពិធីប្រារព្ធខួបទី១០ ទិវាអតីតយុទ្ធជនកម្ពុជា, ១០ ឧសភា ២០១៧

... សូមអរគុណនិងកោតសរសើរ ចំពោះថ្នាក់ដឹកនាំនៃអតីតយុទ្ធជន ពិសេសឯកឧត្តម នាយឧត្តមសេនីយ៍ គន់ គីម ដែលបានប្រឹងប្រែងពាំនាំនូវការសួរសុខទុក្ខរបស់ខ្ញុំ និងអំណោយរបស់ខ្ញុំ ទៅកាន់បងប្អូនអតីតយុទ្ធជន នៅតាមមូលដ្ឋាននានា។ អម្បាញ់មិញ មាននិយាយពីការខ្វះមេដាយ។ ឯកឧត្តម បិន ឈិន **ត្រូវខិតខំបោះមេដាយដែលជាតម្រូវការ។ រឿងមេដាយមិនលំបាកទេ ហើយរឿងស៊ីញ៉ែឲ្យមេដាយ ក៏វាមិនពិបាកដែរទេ ក៏ប៉ុន្តែការផលិតមេដាយនោះត្រូវឲ្យគ្រប់ដើម្បីបំពាក់ជូនបងប្អូនគ្រប់ៗគ្នា។ យ៉ាងណាក៏ក្នុងមួយជីវិតរបស់យើងក៏បានការទទួលស្គាល់ពីសំណាក់រាជរដ្ឋាភិបាល ជាការបំពាក់ផ្តល់មេដាយទាំងអស់នេះ** ...។

១១. បន្តដោះស្រាយដីសម្បទានសង្គមកិច្ចជូនអតីតយុទ្ធជន

ពិធីប្រារព្ធខួបទី១០ ទិវាអតីតយុទ្ធជនកម្ពុជា, ១០ ឧសភា ២០១៧

... **សូមឯកឧត្តម ជា សុផារ៉ា និងឯកឧត្តម គន់ គីម ធ្វើការជាមួយគ្នាឲ្យបានជិតស្និទ្ធដោះស្រាយដីសម្បទានសង្គមកិច្ច ជូនចំពោះអតីតយុទ្ធជនរបស់យើង។ ឯកឧត្តម ជា សុផារ៉ា បានប្រាប់ខ្ញុំអំពីការប្រគល់ដីធ្លីនោះទៅឲ្យខេត្ត។ ដូច្នេះទន្ទឹមនឹងធ្វើការងារជាមួយថ្នាក់ជាតិ យើងក៏ត្រូវធ្វើការងារជាមួយថ្នាក់ក្រោមជាតិ**

គឺនៅថ្នាក់ខេត្តដើម្បីផ្តល់ដីធ្លីជូនចំពោះអតីតយុទ្ធជន។ ខ្ញុំស្នើសុំថា នៅពេលដែលបងប្អូនបានដីហើយ សូមកុំលក់។ សូមទុកជាកេរអាករ ប្រើប្រាស់វាដើម្បីបង្កបង្កើនផល ប្រើប្រាស់វាជាកេរមត៌ក ដែលរាជរដ្ឋាភិបាលផ្តល់ឲ្យ សម្រាប់ខ្លួនផងនិងសំរាប់តកូនតចៅផង។ ខ្ញុំមានមោទនភាព ដោយកន្លងទៅសង្កេតឃើញថាអតីតយុទ្ធជននិងយុទ្ធជនរបស់យើង ក្រៅពីការខិតខំបម្រើជាតិតាំងពីវ័យក្មេង ទោះបីជានៅក្នុងក្របខ័ណ្ឌទាហានបច្ចុប្បន្ន កងទ័ពបច្ចុប្បន្ន ឬក៏ធ្លាក់ខ្លួនពិការក៏ដោយ ក៏ប៉ុន្តែបានប្រឹងប្រែងដើម្បីបណ្តុះបណ្តាលកូនរបស់ខ្លួនឲ្យក្លាយជាបញ្ញវន្តដែលជាសេចក្តីត្រូវការរបស់ប្រទេសជាតិ ...។

១២. ដោះស្រាយលំនៅដ្ឋាន ជាគោលដៅអាទិភាពនៃសមាគមអតីតយុទ្ធជន

ពិធីប្រារព្ធខួបទី១១ ទិវាអតីតយុទ្ធជនកម្ពុជា, ៤ មិថុនា ២០១៨

... **ទាក់ទងជាមួយនឹងការកសាងលំនៅដ្ឋានជូនចំពោះអតីតយុទ្ធជន សម្រាប់ពីពេលនេះទៅមុខ ត្រូវតែក្លាយជាគោលដៅអាទិភាពនៃសកម្មភាពរបស់សមាគមរបស់យើង។ ខ្ញុំបានយល់ព្រម បង្វែរថវិកា ដែលបណ្តាខេត្តបានចូលរួម ដើម្បីកសាងគេហដ្ឋានសម្រាប់អតីតយុទ្ធជន**។ លោកឧកញ៉ា វ៉ែង ហួ បានទៅជួបខ្ញុំ ហើយបានប្រាប់ថា នឹងសាកល្បងជំហានដំបូងជួយកសាងលំនៅដ្ឋានចំនួន ១០០ខ្នង ដោយក្រុមហ៊ុនរបស់គាត់ជាអ្នកសាងសង់ដោយផ្ទាល់។ យើងប្រាប់តែទីតាំងពួកគាត់ចុះទៅសាកល្បងសាងសង់។ ដូច្នេះមានវិធីច្រើនណាស់។ ក្រុមហ៊ុនសប្បុរសជននានា អាចចូលរួមជាប្រាក់កាស អាចចូលរួមតាមរយៈការសាងសង់ដោយផ្ទាល់ដោយក្រុមហ៊ុនរបស់ខ្លួន ...។

១៣. ជនពិការបន្តខិតខំដើម្បីសេចក្តីថ្លៃថ្នូររបស់ខ្លួន គ្រួសារនិងមោទនភាពសំរាប់កូនចៅ

សំណេះសំណាលជាមួយយុទ្ធជនពិការ ៣១៧, ១៣ មេសា ២០១៧

... កែវភ្នែកដែលយើងស្រឡាញ់ មិនអាចវិលត្រឡប់មកវិញទេ ប៉ុន្តែយើងអាចនឹងប្រឹងប្រែងងើបឈរឡើងវិញ កុំឱ្យធ្លាក់ទៅក្នុងស្ថានភាពជាអ្នកដែលពិការរូបកាយហើយ ពិការផ្លូវចិត្តថែមទៀត។ មានឧទាហរណ៍ច្រើនណាស់ ដែលយុទ្ធជនពិការរបស់យើងបានប្រឹងប្រែងងើបឈរ ជម្នះបានការលំបាក ហើយផ្តល់ឱកាសសម្រាប់កូនៗ បន្តការសិក្សា រហូតដល់កូនៗទាំងនោះ បានក្លាយទៅជាបញ្ញវន្ត

បញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា ហើយក៏មានការងារធ្វើ។ **នេះហើយដែលខ្ញុំបន្ត អំពាវនាវចំពោះជនពិការគ្រប់រូប រាប់ទាំងយុទ្ធជនពិការ បន្តខិតខំងើបឈរឡើង ដើម្បីសេចក្តីថ្លៃថ្នូររបស់យើង គ្រួសាររបស់យើង និងបន្សល់ទុកឱ្យកូនចៅយើងនូវ មោទនភាពបន្តទៀត** ...៕

១៤. ការបើកផ្តល់ប្រាក់បៀវត្សបានទាន់ពេលវេលាដល់ទាហាននិងយុទ្ធជនពិការ

សំណេះសំណាលជាមួយយុទ្ធជនពិការ ៣១៧, ១៣ មេសា ២០១៧

... ខ្ញុំបានឆ្លៀតសួរទាហាន និងយុទ្ធជនពិការរបស់យើងនៅខាងមុខនេះ អំពីការបើកផ្តល់បៀវត្សរ៍ និងប្រាក់ឧបត្ថម្ភនានា។ ខ្ញុំមានមោទនភាពចំពោះការចាត់ចែងទាំងឡាយរបស់ស្ថាប័នជាតិ ក្នុងហ្នឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាតាមរយៈនៃផ្នែកកស្តការរបស់ក្រសួងការពារជាតិ ដែល**បានផ្តល់ទាន់ពេលវេលានូវ ប្រាក់ទាំងឡាយ រាប់ទាំងប្រាក់ដែលទើបនឹងបានដំឡើងថ្មី ព្រមទាំងប្រាក់ឧបត្ថម្ភ សម្រាប់ការចូលឆ្នាំផងដែរ។** ប្រាក់បៀវត្សរបស់យុទ្ធជនពិការ មានលើសពី ១ លានរៀល ...៕

១៥. មិនទុកអោយមជ្ឈមណ្ឌល/AFESIP ត្រូវបិទឡើយ

សំណេះសំណាល សួរសុខទុក្ខកុមារីរងគ្រោះនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តារនីតិសម្បទាយុវនារី AFESIP, ១០ មីនា ២០១៩

... ចៅៗ បាននិយាយថាមានបង្អែកហើយ។ **តាជាបង្អែកដ៏រឹងមាំមួយសម្រាប់ចៅៗ។ បើទោះបីថា ថ្ងៃក្រោយទៅសប្បុរសជនបានជាកខ្លួន ក៏តាមិនទុកឲ្យមជ្ឈមណ្ឌលមួយនេះត្រូវបិទនោះទេ។** ខ្ញុំអំពាវនាវចំពោះសប្បុរសជនទាំងឡាយដែលបានជួយរួចមកហើយនោះ បន្តជួយតទៅទៀត។ នៅពេលណាដែលគេមិនអាចជួយបាន យើងក៏នឹងដោះស្រាយធ្វើយ៉ាងម៉េច ឲ្យអង្គការក្រៅរដ្ឋាភិបាលមួយនេះបន្ត។ (មជ្ឈមណ្ឌល)រួមចំណែកដ៏ធំក្នុងការដោះស្រាយបញ្ហា ...៕

១៦. នៅមានអ្នកបន្តវេនទ្រទ្រង់មជ្ឈមណ្ឌល/AFESIP

សំណេះសំណាល សួរសុខទុក្ខកុមារី យុវតី និងបុគ្គលិកនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តារនីតិសម្បទាយុវនារី AFESIP, ២៩ កញ្ញា ២០២៤

... សូមកុំបារម្ភអំពីការដួលរលំនៃមជ្ឈមណ្ឌលនេះ។ (ថ្វីត្បិតតែ)មានអ្នកចង់ផ្តួលរំលំត្រកូល ហ៊ុន តែគេមិនអាចមានលទ្ធភាពផ្តួលរំលំត្រកូល ហ៊ុន ទេ។ **ទោះបី តាមិនធ្វើជានាយករដ្ឋមន្ត្រីទៀតក៏ដោយ ប៉ុន្តែការទ្រទ្រង់មជ្ឈមណ្ឌលនេះ គឺតា មានអ្នកបន្តវេន កុំសូម្បី(ថាទៅថ្ងៃមុខ)អត់ពីតាយាយក៏ដោយ**។ ថ្ងៃនេះ ប្រពន្ធនាយករដ្ឋមន្ត្រីមកដែរ។ "កូនត្រូវចាំ អត់ពីពុកម៉ែទៅ កូនត្រូវរក្សាអ្វីដែលជាកេរដំណែលដែលពុកម៉ែបានធ្វើនៅទីនេះ ហើយអាចចែកទៅប្អូនៗ បន្តទៀត"។ **បើទោះបីជាអត់ពីតាយាយទៅ ក៏នៅសល់កូន។ បន្ទាប់ពីកូនទៅ នៅសល់ចៅ។ មជ្ឈមណ្ឌលនេះមិនដួលរលំទេ។ ទោះបីថារំលំបាកពីខាងក្រៅ ក៏ប៉ុន្តែយើងអាចបំពេញ(សេចក្តីត្រូវការ)នៅទីនេះបាន** ...៕

១៧. អ្នកនៅក្នុងមណ្ឌល/AFESIP ជាប់បាក់ឌុប្លី ទទួលបានអាហារូបករណ៍រៀនបន្ត

សំណេះសំណាល សួរសុខទុក្ខកុមារីរងគ្រោះនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តារនីតិសម្បទាយុវនារី AFESIP, ១០ មីនា ២០១៩

... តើចៅហ៊ានសន្យាជាមួយតាឬអត់? ... តាសុំដាក់លក្ខខណ្ឌ។ តើចៅអាចធ្វើបានទេ។ ធ្វើម៉េចរៀនឱ្យបានដល់ថ្នាក់ទី១២ ហើយប្រឡងឲ្យជាប់បាក់ឌុប្លី។ តើអាចធ្វើបានឬអត់? ... មិនមែនត្រឹមតែថ្នាក់ទី១២ ទេគឺចៅៗចង់រៀនធ្វើពេទ្យ ចៅៗចង់រៀនគួរប្លង់ក៏ដោយ។ **តាយកការសន្យាមួយជាមួយចៅៗ។ អ្នកដែលប្រឡងជាប់បាក់ឌុប្លីទាំងអស់ នឹងទទួលអាហារូបករណ៍ពីតាចូលរៀន(សាកលវិទ្យាល័យ) ... រីឯសម្រាប់ផ្នែកពេទ្យ តម្រូវឲ្យចៅប្រឡងឲ្យជាប់**។ ជាប់បាក់ឌុប្លីហើយ ទៅប្រឡងចូលពេទ្យឲ្យជាប់ទៀត ... **បើជាមានការតម្រូវពីសាលាណាឱ្យបង់ប្រាក់ តាយាយបង់ឲ្យ ដើម្បីឲ្យចៅៗ រៀនបានសញ្ញាបត្រខ្ពស់** ...៕

១៨. ១៩៧៩ កន្លែងចិញ្ចឹមកុមារកំព្រា មានអាទិភាពជាងអគារធ្វើការរបស់ចៅហ្វាយខេត្ត

ពិធីសម្ពោធភូមិកុមារ SOS ខេត្តព្រៃវែង, ១៧ មីនា ២០២២

... កិច្ចការដែលកម្ពុជាបានធ្វើដើម្បីកុមារមានច្រើន។ នៅលើពិភពលោកនេះគ្មានប្រទេសណាមួយ ដែលមានកុមាររងគ្រោះច្រើនដូចជាកម្ពុជានោះទេ។ កម្ពុជាមានកុមាររងគ្រោះច្រើនជាងគេ ដោយសារតែរបបប្រល័យពូជសាសន៍ ប៉ុល ពត បានសម្លាប់ឪពុកម្តាយ បន្សល់ទុកឱ្យយើងចិញ្ចឹមនូវកុមារទាំងអស់នោះ។ **ដោយ**

មានការចូលរួមតាំងពីឆ្នាំ ១៩៧៩ ក្នុងការគ្រប់គ្រងប្រទេសជាមួយថ្នាក់ដឹកនាំជំទែ ទៀត ខ្ញុំនៅចាំបានថាអ្វីដែលជាអាទិភាពរបស់យើងគ្រានោះ គឺគ្រប់ខេត្តទាំងអស់ មិនមែនអគារធ្វើការរបស់ចៅហ្វាយខេត្ត ឬមន្ទីរជុំវិញខេត្តនោះទេ ក៏ប៉ុន្តែទីកន្លែង ចិញ្ចឹមកុមារកំព្រា។ នេះជារឿងដែលបានកើតឡើងលើទឹកដីកម្ពុជាដ៏កម្សត់ ...៕

១៩. មិនឱ្យកុមារណាម្នាក់គ្មានការថែទាំ និងត្រូវទទួលបានការអប់រំនិងបណ្តុះបណ្តាល

ពិធីសម្ពោធភូមិកុមារ SOS ខេត្តព្រៃវែង, ១៧ មីនា ២០២២

... យើងមានមោទនភាព ដោយ**មិនបានទុកឱ្យកុមារណាម្នាក់ស្លាប់ដោយគ្មាន ការយកចិត្តទុកដាក់ថែទាំ។ បន្ថែមលើនោះ យើងក៏មានមោទនភាព ដោយសារ កុមាររបស់យើងបានទទួលការអប់រំនិងបណ្តុះបណ្តាល**។ បើប្រៀបធៀបកុមារនៅ តាមមជ្ឈមណ្ឌលកុមារកំព្រា រាប់ទាំងកុមារដែលមាននៅទីនេះ (គឺ)ទទួលបាននូវ ការមើលថែទាំ/បណ្តុះបណ្តាល ជួនកាលច្រើនជាងកុមារដែលរស់នៅតាមក្រុម គ្រួសារទៅទៀត ដោយសារយើងបានដាក់កំណត់កាលពីពេលនោះថា ដរាបណា មិនទាន់ចប់មធ្យមសិក្សាបឋមភូមិ យើងមិនអនុញ្ញាតឱ្យឈប់រៀនទេ។ អ្នកដែល មានលទ្ធភាព គឺយើងបន្តឱ្យមានការសិក្សារហូតទៅដល់គេរកការងារធ្វើបាន ...៕

២០. ប្រែពីជនរងគ្រោះទៅជាកម្លាំងតស៊ូ ជាធនធានមនុស្សបម្រើសង្គម

សំណេះសំណាល សួរសុខទុក្ខកុមាររងគ្រោះនៅមជ្ឈមណ្ឌលបណ្តុះបណ្តាល
វិជ្ជាជីវៈ និងស្តារនីតិសម្បទាយុវនារី AFESIP, ១០ មីនា ២០១៩

... **សង្ឃឹមថា ចៅៗខិតខំប្រែក្លាយការឈឺចាប់ឲ្យទៅជាកម្លាំងតស៊ូ ក្លាយទៅជា ធនធានមនុស្សដែលបម្រើឲ្យសង្គម ដែលមានការលូតលាស់ ដោយចាប់ផ្តើមពី ចៅៗរងគ្រោះទាំងអស់ មិនទទួលបានការប្រមាថមើលងាយពីនរណាឡើយ។ វិធី ដែលចៅៗត្រូវធ្វើគឺរៀនសូត្រឲ្យមានចំណេះដឹងខ្ពស់**។ បើចៅធ្វើរឿងហ្នឹងបាន គឺ ជាការប្រពៃ ... ពេលមុនចៅទទួលរងការរំលោភបំពាន ជាជនរងគ្រោះ តែនៅពេល ដែលចៅពេញវ័យ ចៅកុំធ្វើអ្វីដែលសង្គមស្អប់ខ្ពើម ដូចជាការប្រព្រឹត្តគ្រឿងញៀន ជើរលេងពាលអាវ៉ាសែ ឬរហូតដល់ប្រាសចាកសីលធម៌ខ្លួនឯង។ (បើដូចនោះ) យើងប្រែក្លាយខ្លួនពីជនរងគ្រោះ ទៅជាអ្នកបង្កើតកំហុសដោយខ្លួនឯង ដែលនោះ មិនមែនជាបំណងរបស់ចៅ ហើយក៏មិនមែនជាបំណងរបស់អ្នកឧបត្ថម្ភដែរ ...៕

២១. ចេញពីមណ្ឌលកុមារកំព្រាក្លាយជាធនធានមនុស្សសម្រាប់សង្គមជាតិ

ពិធីសម្ពោធភូមិកុមារ SOS ខេត្តព្រៃវែង, ១៧ មីនា ២០២២

... **អ្នកដែលចេញពីកន្លែងថែទាំ ៤នាក់ បានក្លាយទៅរៀបជ្ឈបណ្ឌិត, ៥នាក់ក្លាយ ទៅជាវិស្វករ, ៧នាក់ (ក្លាយទៅ)ជាធនាគារិក, ៣នាក់(ក្លាយ)ជាស្ថាបត្យករ, ២ នាក់(ក្លាយ)ជាអ្នកចនានិងច្រើនអ្នកទៀតក្នុងវិស័យអាជីវកម្ម សេវាបម្រើអតិថិជន និងបម្រើការងារក្នុងជួររដ្ឋាភិបាល ... នេះ (បញ្ជាក់ថា) កម្ពុជាមានកុមារកំព្រា (ដែលត្រូវយកចិត្តទុកដាក់)សូម្បីតែក្នុងក្របខណ្ឌនៃការអប់រំក្នុងរយៈកាល ២០ ឆ្នាំ ដោយឆ្នាំនេះ ជាខួបទី២០នៃការសម្ពោធដាក់ឱ្យប្រើប្រាស់ភូមិកុមាររលើកទី១ នៅក្រុងភ្នំពេញ។** ថ្វីបើជាផ្នែកតូចមួយក្តី (មណ្ឌលទាំងនោះ)បានផលិតធនធាន មនុស្សសម្រាប់សង្គមជាតិយើង។ ឯកុមាររងគ្រោះនិងបានក្លាយទៅជាកុមារកំព្រា នាឆ្នាំ១៩៧៩ ក៏ដូចជាក្រោយឆ្នាំ ១៩៧៩ យើងក៏បណ្តុះបណ្តាលពួកគេ ដែល ពេលនេះបានក្លាយជាឪពុកម្តាយ ឬខ្លះទៀតជាជីដូនជីតាថែមទៀតផង។ នេះ បង្ហាញឱ្យឃើញអំពីការយកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់កុមារ ដែលនៅរស់ រានមានជីវិតបន្ទាប់ពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ...៕

២២. ពិនិត្យ/ព្យាបាលជំងឺឥតគិតថ្លៃសំរាប់កុមាររងគ្រោះ បុគ្គលិកមជ្ឈមណ្ឌល/AFESIP

សំណេះសំណាល និងសួរសុខទុក្ខកុមាររងគ្រោះនៅមជ្ឈមណ្ឌលបណ្តុះបណ្តាល
វិជ្ជាជីវៈ និងស្តារនីតិសម្បទាយុវនារី AFESIP, ១០ មីនា ២០១៩

... កំពុងតែពិនិត្យថា យើងនឹងបង្កើនប្រាក់បន្តទៀត នៅពេលដែលសេដ្ឋកិច្ច អនុញ្ញាត។ កម្រិតនៃការឧបត្ថម្ភរបស់យើងមានចំនួនមិនច្រើនទេ ប៉ុន្តែនៅពេល ដែលសេដ្ឋកិច្ចរបស់យើងរីកលូតលាស់ យើងអាចពិនិត្យបន្ថែមអំពីករណីនេះ ... ការដោះស្រាយមួយទៀតគឺ **ចៅៗនឹងមានបណ្ណនេះម្នាក់មួយ(បណ្ណសមធម៌)។ ខ្ញុំស្មើថា បណ្ណបេឡាជាតិសន្តិសុខសង្គមសំរាប់ការពិនិត្យព្យាបាលនៅពេទ្យរដ្ឋ ត្រូវបន្ថែមឲ្យបុគ្គលិកនៅទីនេះផងដែរ(បុគ្គលិកមានរួចហើយ)។ បណ្ណ ប.ស.ស របស់បុគ្គលិក អាចប្រើបានទាំងមន្ទីរពេទ្យរដ្ឋ និងឯកជនដែលបានចុះហត្ថលេខា ជាមួយ ប.ស.ស** ...៕

២៣. ក្រោយបញ្ចូលក្របខ័ណ្ឌរដ្ឋ ផ្តល់ថវិកាឧបត្ថម្ភបន្ថែមសំរាប់គ្រូក្នុងអង្គការគ្រួសារថ្មី

ពិធីផ្ទេរសោលាកុមារពិការភ្នែក និងគ-ថ្លង់ ពីអង្គការគ្រួសារថ្មី
ទៅក្រសួងអប់រំ យុវជន និងកីឡា, ១ កក្កដា ២០១៩

... ចំពោះគ្រូ យើងបានបញ្ចូលក្របខ័ណ្ឌរួចហើយ។ នេះជាសេចក្តីសម្រេច ដែលមានចុះហត្ថលេខា ដោយមនុស្ស ៣នាក់នោះ គឺ(ឧបនាយករដ្ឋមន្ត្រី) ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង ឯកឧត្តម ពេជ្រ ប៊ុនធិន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ដែលបាន**ស្នើទៅខ្ញុំសុំបន្ថែមថវិកាសម្រាប់គ្រូ គឺម្នាក់បានទទួលបន្ថែម ៨០ម៉ឺន(រៀល) ពីលើប្រាក់បៀវត្ស ៨០ម៉ឺនរៀល ... សង្ឃឹមថាលោក/អ្នកគ្រូបង្រៀននៅសាលាចំណេះទូទៅ នឹងមិនមានការប្រៀបធៀប ឬការច្រណែនណាមួយជាមួយគ្រូនៅទីនោះនោះទេ។ សង្ឃឹមថា លោក Arminjon អាចប្រាប់ទៅម្ចាស់ជំនួយហើយមានការកង្វល់ថា កុំឱ្យមានការព្រួយបារម្ភពីសមត្ថភាពទទួលខុសត្រូវរបស់កម្ពុជា ...**។

២៤. អប់រំសីលធម៌សង្គមនិងឲ្យជាប់ទោសមួយជីវិត សំរាប់ជនដែលរំលោភកូន/ចៅខ្លួន

ពិធីចែកសញ្ញាបត្រនិស្សិតនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ១១ មីនា ២០១៩

... មតិនេះគឺត្រូវ។ ប្រសិនបើមានការប្រហារជីវិតដោយកាន់ច្រឡំណាមួយកើតឡើង វានឹងជាគ្រោះថ្នាក់ធំទៅវិញទេ ... ខ្ញុំព្រះករុណាខ្ញុំយល់ថា ប្រសិនបើមានការថ្លោះធ្លោយណាមួយកើតឡើងក្នុងការកាត់ទោសប្រហារជីវិត ... ស្រាប់តែមានការសើរើរឿងក្តីមកវិញ បង្ហាញថាអ្នកដែលស្លាប់ទៅ មិនមានទោសអីសោះ វាគឺជារឿងមួយអាណោចអាធ័មលើសពីអ្វីដែលយើងគិតដល់។ **ខ្ញុំព្រះករុណាខ្ញុំ គិតថា មិនមានការចាំបាច់ដើម្បីធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីនឹងឱ្យមានទោសប្រហារជីវិតទេ ... ត្រូវយកវិធានការព្រមៗគ្នា គឺវិធានការអប់រំសីលធម៌ក្នុងសង្គម ... ប្រើប្រាស់វិធីសាស្ត្រដែលមានព្រះសង្ឃចូលរួមចំណែក លើកកម្ពស់គុណធម៌នេះផងដែរសម្រាប់សង្គម ... ឯទី២ ការអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់បំផុតលើអ្នកប្រព្រឹត្តរឿងនេះ(ជនដែលរំលោភកូន/ចៅខ្លួនឯង)។ បើសិនវាកើត ការប្រព្រឹត្តទោសមួយជីវិតវាគ្រប់គ្រាន់ហើយ ...**។

២៥. ក្រសួងសង្គមកិច្ចនិងក្រសួងអប់រំ ត្រៀមទទួលរ៉ាប់រងមជ្ឈមណ្ឌលនានា

សួរសុខទុក្ខកុមារពិការភ្នែក/គ-ថ្លង់គ្រួសារថ្មី, ១៨ វិច្ឆិកា ២០១៨

... ជាលទ្ធផលរំលោភមួយ ដែលក្រសួងអប់រំ យុវជន និងកីឡា (ត្រូវ)រែកពន់ការទទួលខុសត្រូវហើយ។ មិនមែនគ្រាន់តែទទួលយកនៅកន្លែងនេះមួយទេ។ ថ្ងៃក្រោយទៅ ត្រូវទទួលយកនៅកន្លែងផ្សេងៗទៀត ដោយសារសេដ្ឋកិច្ចរបស់កម្ពុជាកំពុងតែផ្ទេរជំណាក់កាលពីការដែលគេផ្តល់ជំនួយ ទៅកាន់ការដែលគេជកថយ។ ដូច្នេះ យើងចាប់ផ្តើមទទួលខុសត្រូវហើយ ... លក្ខខណ្ឌសេដ្ឋកិច្ចរបស់កម្ពុជាកើនឡើង តម្រូវឲ្យគេជកថយ ដើម្បីយក(ការជួយឧបត្ថម្ភ)ទៅឲ្យប្រទេសដទៃដែលមិនមានលក្ខខណ្ឌអនុគ្រោះដូចយើង ... ដូច្នេះ **ទាំងផ្នែកសង្គមកិច្ច ទាំងផ្នែកអប់រំ ត្រូវត្រៀមទទួលយកបណ្តាមជ្ឈមណ្ឌល ដែលជាបណ្តើរៗ នឹងប្រគល់មកឱ្យដើម្បីយើងទទួលរ៉ាប់រងខ្លួនឯង**។ ដូច្នេះហើយ ទំហំថវិកាផ្តល់ទៅវិស័យអប់រំ វិស័យសុខាភិបាល និងវិស័យសង្គមកិច្ច កាន់តែធំទៅៗ ...**។**

២៦. ផ្តល់បណ្ណក្រីក្រដល់គ្រួសារងងឹតលប៉ះពាល់ពីកូវីដ-១៩ និងពីអតិផរណាបន្ថែម

ចែកសញ្ញាបត្រនិស្សិតនៃសកលវិទ្យាល័យវ៉ាន់ដា, ៣ តុលា ២០២២

... គេថា លោក ហ៊ុន សែន យកសៀវភៅក្រីក្រធ្វើជាមធ្យោបាយឃោសនា។ ខ្ញុំ**កំពុងតែរៀបចំប្រាប់ទៅ (ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី) អូន ព័ន្ធមុនីរ័ត្ន ឱ្យការិយាល័យបង្កើនចំនួនគ្រួសារមួយចំនួនដែលមានផលប៉ះពាល់ពីកូវីដ-១៩ផង (និង)ផលប៉ះពាល់ចេញពីអតិផរណាផង។ បន្ថែម(ចំនួន)គ្រួសារថែមទៀត។ (ថែម)ពីរបីម៉ឺន(គ្រួសារ) ឬបួនប្រាំម៉ឺនគ្រួសារទៀត។ យើងកំពុងចិញ្ចឹមមួយខែជិតនឹង ៤០លាន។ អត់អីទេ។ បន្តទៀត។ អ្នកណាថារដ្ឋាភិបាល ហ៊ុន សែន អត់លុយ(ក៏ថាទៅ) អ្នកឯង(ជា)អ្នកថាទេតើ តែប្រជាពលរដ្ឋទទួលលុយពិតប្រាកដ** ... អ្នកក្រីក្រឥឡូវដិត ៧០ម៉ឺនគ្រួសារ ឥឡូវ ខ្ញុំបន្ថែម ១០ម៉ឺនគ្រួសារទៀត ក៏វាអត់ទាស់ខុសអីដែរ។ ក្នុងចំណោមហ្នឹង អ្នកក្រីក្រមិនមែនបានតែមនុស្សចាស់ទេ កូនក្មេងក៏វាបានឪពុកម្តាយក៏នៅបាន ...**។**

២៧. ជំនួយសង្គមក្នុងពេលមានវិបត្តិ មិនមែនជាការចិញ្ចឹមរបស់រដ្ឋជាអចិន្ត្រៃយ៍

ប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ «កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺកូវីដ-១៩», ២៤ មិថុនា ២០២០

... ខ្ញុំគួរតែបញ្ជាក់ថា **នេះគឺជាជំនួយសង្គមក្នុងពេលមានវិបត្តិ មិនមែនជាការចិញ្ចឹមរបស់រដ្ឋជាអចិន្ត្រៃយ៍នោះទេ**។ មនុស្សមួយចំនួន (ដែលធ្វើ)ការអុជអាលនិងមិនយល់ ក៏ល្មមនឹងចូលសាលារៀនឡើងវិញដើម្បីយល់ដឹងថាអ្វីទៅដែលជាការចិញ្ចឹម និងអ្វីដែលហៅថាជាកិច្ចការជំនួយសង្គម ... **នេះមិនមែនការចិញ្ចឹមរបស់រដ្ឋទេ តែគឺជាជំនួយសង្គមមួយដ៏ធំ ដែលខ្ញុំគិតថាប្រសិនបើវាអូសបន្លាយពេលវែង យើងក៏ត្រូវប្រើពេលវែងដែរ ... ជាមួយនេះ អំពាវនាវចំពោះប្រជាពលរដ្ឋអោយរកការងារធ្វើនៅកន្លែងដែលអាចធ្វើការខ្លួនឯងបាន លើកលែងតែមនុស្សចាស់និងកុមារអាយុក្រោម ៥ឆ្នាំទេ។ ក្រៅពីនោះ នៅអាចដាំដុះ នៅអាចធ្វើការងារបាន ជាកសិករដែលធ្វើស្រូវ ឬក៏ធ្វើចម្ការ ការចិញ្ចឹមសត្វ ឬគាត់អាចរកការងារដទៃទៀត**ដែលអាចធ្វើបាន ...៕

២៨. គោលនយោបាយគាំពារសង្គម រាប់បញ្ចូលអ្នកក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវឯកសារក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥, ២៤ កក្កដា ២០១៧

... ខ្ញុំមិនដឹងថាតើ ឯកឧត្តមលោកជំទាវ ដែលចូលរួមនៅទីនេះ មានការចាប់អារម្មណ៍យ៉ាងណានោះទេ។ ចំណុចនេះ **យើងបានគិតដល់ការលើកឡើងនៅក្នុងបណ្តាញសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលកន្លងទៅបានស្នើសុំឲ្យមានការយកចិត្តទុកដាក់ ដូចជាសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ ដូច្នេះ គោលនយោបាយគាំពារសង្គមរបស់យើងនៅថ្ងៃនេះ ក៏បានរាប់បញ្ចូលអ្នកនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធមកដែរ។ នេះជាការយកចិត្តទុកដាក់ស្តាប់សម្លេងសង្គមទាំងមូល ដែលបានលើកឡើងទាក់ទងនឹងបញ្ហានានា**ក្នុងនោះរាប់បញ្ចូលទាំងសេដ្ឋកិច្ចក្រៅប្រព័ន្ធមកក្នុងការរៀបចំតាក់តែងគោលនយោបាយរបស់យើងផង ...៕

២៩. មន្ត្រីរាជការចូលនិវត្តន៍នៅអាយុ ៦០ឆ្នាំ ដដែល

ពិធីសម្ពោធអគារសិក្សានៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ចរិយាវង្ស, ២៣ ធ្នូ ២០១៧

... មានការសួរក្នុងហ្វេសប៊ុក ហើយក៏មានកើតនូវចរន្តខ្លះអំពីការស្នើសុំពន្យារអាយុចូលនិវត្តន៍។ ខ្ញុំបានលើកគំនិតឱ្យមានការពិចារណា ទៅលើការពន្យារអាយុចូលនិវត្តន៍របស់គ្រូបង្រៀន ហើយអាចនឹងមានដល់មន្ត្រីរាជការឯទៀត។ ឥឡូវនេះ យើងអត់ទាន់បានកែច្បាប់ទេ។ អញ្ចឹង **សូមប្រកាសជូនប្រជាជន មន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌទូទាំងប្រទេសថា យើងនៅតែបន្តការចូលនិវត្តន៍ក្នុងវ័យ ៦០ឆ្នាំ ដដែល មិនមានការប្រែប្រួលទេ។ រឿងនេះ ត្រូវលើកទៅពិចារណានៅឆ្នាំ២០១៩ឯណោះ។ មិនទាន់ពិចារណានៅពេលនេះទេ ព្រោះវាមានចំណុចដែលត្រូវគិតគូរឱ្យគ្រប់ជ្រុងជ្រោយ ...៕**

៣០. ពន្យារអាយុចូលនិវត្តន៍ចំណេញថវិកា តែត្រូវគិតពីលំហាការងារសម្រាប់យុវជន

ពិធីសម្ពោធអគារសិក្សានៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ចរិយាវង្ស, ២៣ ធ្នូ ២០១៧

... **ពេលយើងពន្យារអាយុចូលនិវត្តន៍នៃមន្ត្រីរាជការដល់ ៦៥ឆ្នាំ បើនិយាយពីទិដ្ឋភាពថវិកា គឺច្បាស់ជាមានផលចំណេញហើយ**។ ឧទាហរណ៍ថា មន្ត្រី ១ម៉ឺននាក់ ត្រូវចូលនិវត្តន៍ ប្រាក់សោធននិវត្តន៍របស់គាត់មាន៨០%។ អញ្ចឹង បើប្រាក់ខែ ១លាន(រៀល) គឺប្រាក់ចូលនិវត្តន៍នៅសល់ ៨០ម៉ឺន(រៀល)។ អញ្ចឹងយើងត្រូវចិញ្ចឹម ១ម៉ឺននាក់ដែលចូលនិវត្តន៍នោះដោយប្រាក់បៀវត្សរ៍៨០% ... ដល់ទៅយើងរើស ១ម៉ឺននាក់ថ្មីមកទៀត ពួកគាត់ស៊ីប្រាក់ខែពេញ។ អញ្ចឹង ជា**ទិដ្ឋភាពថវិកាវាចំណេញ ប៉ុន្តែទិដ្ឋភាពខាងបច្ចេកទេសទាក់ទងនឹងការរក្សាទុកធនធានដែលមានពិសោធន៍ក្នុងវ័យ ៦០ឆ្នាំ និងរហូត ៦៥ឆ្នាំវិញ្ញ ប៉ុន្តែបញ្ហាមួយយើងត្រូវគិត គឺលំហាសម្រាប់យុវជនដែលត្រូវការធ្វើការងារវិញតូច**។ ចំណុចនេះត្រូវគិតឱ្យបានជិតដល់។ គិតតែមួយជ្រុងមិនបានទេ ...៕

៣១. ផ្តល់បណ្ណក្រីក្រ១ ជូនពលរដ្ឋស្ម័គ្រចិត្តរើពីរមណីយដ្ឋានអង្គរទៅតំបន់រុនតាឯក

សំណេះសំណាលជាមួយអ្នកបានចាប់ឆ្នោតរើសទីតាំងលំនៅដ្ឋានថ្មីនៅភូមិធម្មជាតិរុនតាឯក, ១ តុលា ២០២២

... ត្រូវតែដោះស្រាយជាកញ្ចប់គោលនយោបាយ (សម្រាប់)បងប្អូនទាំងអស់ដែលស្ម័គ្រចិត្តរើចេញពីតំបន់រស់នៅចាស់(រមណីដ្ឋានអង្គរ)មកនៅតំបន់រុនតាឯកពាក់ស្នែង និងអាចជាកន្លែងដទៃ ឱ្យទទួលបានបានបណ្ណក្រីក្រប្រភេទ១ ទាំងអស់

គ្នា ... (រវាង)បណ្ណក្រីក្រ១ និងបណ្ណក្រីក្រ២ (គឺ)បណ្ណក្រីក្រ១ បានលុយច្រើនជាង។ **ដើម្បីកុំឱ្យក្រសួងផែនការពិបាកចុះទៅវាយតម្លៃថាអ្នកនេះប្រភេទ២ អ្នកនេះត្រូវប្រភេទ១ ... ខ្ញុំសម្រេចថ្ងៃនេះ ប្រគល់ជូនបងប្អូនទាំងអស់ទាំងមុននិងក្រោយ នូវប្រភេទបណ្ណក្រីក្រ១ ទាំងអស់គ្នា។ អ្នកកំពុងកាន់(បណ្ណក្រីក្រ)ប្រភេទ ២ ត្រូវដូរមកប្រភេទ១វិញ ... ខ្ញុំត្រូវមានការទទួលខុសត្រូវចំពោះពលរដ្ឋរបស់ខ្លួនដែលបានស្មគ្រគិតគ្ត(រុះរើមករស់នៅតំបន់រុនតាឯក/ពាក់ស្នែងនេះ)** ...។

៣២. សម្រេចបង្កើតមូលនិធិស៊ីភ្លូ ជាការជួយដល់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ផ្សារសោន់ហាន់, ៣ មករា ២០១៨

... ភរិយាខ្ញុំប្រាប់ខ្ញុំថា **ខាងស៊ីភ្លូចង់ឲ្យសម្តេចនាយកបង្កើតមូលនិធិ។ អញ្ចឹងខ្ញុំប្រកាស។ ខ្ញុំបង្កើត។ សូមអញ្ជើញប្រធានសមាគមស៊ីភ្លូនិងលោក វ៉ែន ពៅ ... (ឯកឧត្តម ឃួង) ស្រែង ស្គាល់ វ៉ែន ពៅ ស្រាប់ហើយ។ ទូរស័ព្ទហៅ វ៉ែន ពៅ មកជួយធ្វើលក្ខន្តិកៈគ្នា។ (នេះជាក្រុម)សេដ្ឋកិច្ចក្រៅប្រព័ន្ធ**។ អ្នកទៀតណាចង់ចូលរួម? យើងដោះស្រាយតាំងពីឯកសណ្ឋាន ... មួយឆ្នាំយើងដោះស្រាយឲ្យគាត់ប៉ុន្មានកំប្លេសម្រាប់កម្មករស៊ីភ្លូ? នៅពេលដែលគាត់មិនអាចទៅធាក់បាន តើយើងគួរដោះស្រាយឲ្យយ៉ាងម៉េច? មន្ទីរពេទ្យរដ្ឋទទួលព្យាបាលគាត់ហើយ តែប្រាក់ចំណូលគាត់ត្រូវដាច់។ តើគួរប៉ះប៉ូវឲ្យគាត់យ៉ាងម៉េច? ...។

៣៣. អាទិភាពនៃនយោបាយ ហ៊ុន សែន ក្នុងគោលនយោបាយថ្មីលើវិស័យសង្គម

សំណេះសំណាល និងពិសាអាហារជាមួយកម្មករធាក់ស៊ីភ្លូ នៃមូលនិធិស៊ីភ្លូ,
៨ មីនា ២០១៩

... ខ្ញុំចាត់ទុកថា គ្មានអ្នកណាមានស្មានភាពងាយរងគ្រោះ និងផុយស្រួយជាងកម្មករស៊ីភ្លូនោះទេ។ **ក្នុងរយៈពេល ១ឆ្នាំកន្លងផុតទៅ កម្មករស៊ីភ្លូនៅក្នុងទីក្រុងភ្នំពេញយើង បានទទួលការជានារ៉ាប់រងមួយផ្នែក ដែលខ្ញុំចាត់ទុកថាជាកិច្ចគាំពារសង្គម ដែលជាអាទិភាពនយោបាយរបស់រាជរដ្ឋាភិបាល ឬអាចនិយាយបានថា ជាអាទិភាពនៃនយោបាយរបស់ ហ៊ុន សែន ក្នុងគោលនយោបាយថ្មីលើវិស័យសង្គម**។ សូម្បីតែបញ្ហាស៊ីភ្លូ ក៏យើងបានកែលម្អតាំងពីចាប់ហ្វ្រាំងនៅខាងក្រោយ កែលំអឲ្យវាមកខាងមុខ។ ស្ថានភាពស៊ីភ្លូបច្ចុប្បន្ននេះ ល្អជាងពេលមុន ហើយធានាជាងពេលមុនដែលមិននាំទៅដល់ការគ្រោះថ្នាក់ដល់អ្នកជិះ ...។

៣៤. សមាជិកមូលនិធិអ្នកធាក់ស៊ីភ្លូ ទទួលបានការពិនិត្យនិងព្យាបាលឥតគិតថ្លៃពីមន្ទីរពេទ្យរដ្ឋ និងប្រាក់ប្រចាំថ្ងៃ ៧០០០រៀល

សំណេះសំណាល និងទទួលទានអាហារថ្ងៃត្រង់ជាមួយកម្មករធាក់ស៊ីភ្លូ,
១៣ មករា ២០១៨

... ដើម្បីធានាផលប្រយោជន៍របស់អ្នកធាក់ស៊ីភ្លូពិតប្រាកដ អ្នកធាក់ស៊ីភ្លូទាំងឡាយត្រូវចូលជាសមាជិកនៃមូលនិធិ។ តាមរយៈនៃការចូលជាសមាជិកមូលនិធិនេះ **អ្នកធាក់ស៊ីភ្លូត្រូវបានទទួលនូវផលប្រយោជន៍ ទីមួយ ការពិនិត្យព្យាបាលជំងឺដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យរដ្ឋទាំងអស់**។ បណ្ណសមាជិកនេះ ត្រូវបានយកទៅចុះបញ្ជីជាមួយនឹងបេឡាជាតិ(របប)សន្តិសុខសង្គមរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្តល់ទៅឱ្យការពិនិត្យព្យាបាលដោយមិនគិតថ្លៃនៅតាមមន្ទីរពេទ្យរដ្ឋ ក្រោមមូលនិធិសមធម៌ ... **ទីពីរ ទទួលបានបណ្ណមូលនិធិនេះ គឺទទួលបានប្រាក់ប្រចាំថ្ងៃ ៧០០០ រៀលក្នុងមួយថ្ងៃ** ...។

៣៥. ពេលមរណភាព សមាជិកមូលនិធិអ្នកធាក់ស៊ីភ្លូ ទទួលប្រាក់ឧបត្ថម្ភ ១លាន ៥ម៉ឺនរៀល

សំណេះសំណាល និងពិសាអាហារជាមួយកម្មករធាក់ស៊ីភ្លូ នៃមូលនិធិស៊ីភ្លូ,
៨ មីនា ២០១៩

... នៅពេលដែល**កម្មករស៊ីភ្លូទទួលមរណភាព គាត់នៅទទួលប្រាក់ជាង ១លានរៀលថែមទៀតពីមូលនិធិ ដែលនេះអាចចាត់ទុកថាជាលក្ខណៈពិសេសរបស់មូលនិធិ។ មានមូលនិធិខ្លះបន្ទាប់ពីស្លាប់ទៅ ក៏ចប់ត្រឹមប៉ុណ្ណឹងតែម្តង។ ប៉ុន្តែ មូលនិធិនេះ ត្រូវតាមថែទាំដល់ក្រុមគ្រួសារ រហូតទៅដល់ប៉ុន្មានខែក្រោយ គឺដែលមានទឹកប្រាក់រហូតទៅដល់ ១លាន ៥ម៉ឺនរៀលថែមទៀត។** ប៉ុន្តែ សុំអ្នកទាំងអស់គ្នាកុំទាន់ទៅណាអី នៅរស់ជាមួយខ្ញុំហ្នឹងសិនហើយ ... ពិតមែនតែសក់ស្កូវ ក៏ប៉ុន្តែខ្ញុំសួរទៅ អាយុតិចជាងខ្ញុំទេ ...។

៣៦. សមាជិកមូលនិធិអ្នកធាក់ស៊ីក្លូ ទទួលបានអាវភ្លៀងនៅខែភ្លៀង អាវរងានៅខែរងា

សំណេះសំណាល និងទទួលទានអាហារថ្ងៃត្រង់ជាមួយកម្មករធាក់ស៊ីក្លូ,
១៣ មករា ២០១៨

... នៅខែរងា យើងក៏ត្រូវរកវិធីដោះស្រាយអាវរងា នៅខែភ្លៀងធ្លាក់ យើងក៏ត្រូវរកវិធីដោះស្រាយផ្តល់អាវភ្លៀង ... ថ្ងៃនេះ ខ្ញុំយកអាវរងាសម្រាប់កងទ័ព និងអាវភ្លៀងសម្រាប់កងទ័ព មកឲ្យអ្នកធាក់ស៊ីក្លូ។ ពិតមែនតែវាមិនត្រូវ ប៉ុន្តែប៉ុន្មានថ្ងៃនេះ កំពុងតែរងា ... សង្ឃឹមថា អ្នកធាក់ស៊ីក្លូទាំងអស់នឹងគោរពលក្ខន្តិកៈ។ យើងត្រូវបោះ(ពុម្ព)លក្ខន្តិកៈនេះ ចែកជូនសមាជិក។ បោះជាកូនសៀវភៅតែម្តង។ មិនមែនតែសមាជិកសកម្មដែលជាអ្នកធាក់ស៊ីក្លូទេ ក៏ប៉ុន្តែវត្តមានអ្នកចូលរួមទាំងឡាយនៅថ្ងៃនេះ ក៏ជាសមាជិកដែរ។ ខ្ញុំស្នើឲ្យមានបណ្ណថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមឋិកា ចុះហត្ថលេខាដោយខ្លួនខ្ញុំជាប្រធានកិត្តិយសនៃមូលនិធិ ដើម្បីជាការចងចាំរំលឹកនូវគុណបំណាច់អ្នកដែលបានចូលរួម ...។

៣៧. ចង់ឲ្យមូលនិធិស៊ីក្លូមាននិរន្តរភាព

សំណេះសំណាល និងទទួលទានអាហារថ្ងៃត្រង់ជាមួយកម្មករធាក់ស៊ីក្លូ,
១៣ មករា ២០១៨

... អរគុណសប្បុរសជនទាំងឡាយ ដែលរួមជាមួយខ្ញុំបង្កើតនូវស្ថានភាពថ្មីមួយមិនធ្លាប់មានកាលពីពេលមុន។ មុននេះ តើអ្នកណាខ្លះធ្លាប់ផ្តល់លុយឱ្យអ្នកធាក់ស៊ីក្លូ? អាចនឹងមានខ្លះតែវាមិនច្រើនដូចជាពេលនេះទេ ... ខ្ញុំមិនចង់ឱ្យធ្វើត្រឹមតែ ១ ឬ ២ខែ ហើយក្ស័យធនទេ។ ថវិកាដែលយើងមានក្នុងដៃ ហោចបំផុតយើងអាចប្រើក្នុងរយៈពេល ២ឆ្នាំ ... **តែយើងមិនត្រឹមធ្វើត្រឹម ២ឆ្នាំទេ។ ខ្ញុំចង់ឱ្យមូលនិធិនេះស្ថិតស្ថេរ ... អ្នកចាស់បានចាកចេញទៅ អ្នកថ្មីបានចូលមក។ អ្នកថ្មីនឹងទទួលបានផលប្រយោជន៍ដូចគ្នាជាបន្តទៀត** ...។

២៥. សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១	ជាក់ចេញកញ្ចប់កែទំរង់នយោបាយ និងសេដ្ឋកិច្ច ដើរទន្ទឹមគ្នា	៤៩១
២	កំណែទម្រង់សេដ្ឋកិច្ច ច្បាប់ផ្តើមពីកំណែទម្រង់ដីធ្លី	៤៩១
៣	កំលាំងសង្កត់៣ លើការប្រឹងប្រែងកែទំរង់	៤៩២
៤	កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ បានផ្តល់ផលឲ្យមានអតិរេកថវិកាចរន្ត	៤៩២
៥	អត្រានៃភាពក្រីក្របន្តធ្លាក់ចុះ ក្នុងរង្វង់ជុំវិញ១០%	៤៩៣
៦	ឈានទៅប្រាក់ចំណូលមធ្យមកំរិតខ្ពស់ឆ្នាំ២០៣០ ប្រាក់ចំណូលខ្ពស់ឆ្នាំ២០៥០	៤៩៣
៧	រដ្ឋជាសេដ្ឋវិទូដឹកនាំក្របខណ្ឌគោលនយោបាយ ទុកឱ្យទីផ្សារប្រកួតប្រជែង	៤៩៣
៨	បើកចំហសេដ្ឋកិច្ច តាំងពីមុនមានកិច្ចព្រមព្រៀងប៉ារីស	៤៩៤
៩	ពីសេដ្ឋកិច្ចផែនការ មកឯកជនូបនីយ៍កម្ម និងកំពុងសុក្រឹតកម្មសេដ្ឋកិច្ចទីផ្សារ	៤៩៤
១០	ទំនាក់ទំនងនយោបាយរឹតធំ ដោយសារទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្មវិនិយោគ	៤៩៥
១១	ចាប់ផ្តើមអភិវឌ្ឍសេដ្ឋកិច្ច ដោយជំរុញខ្លាំងវិស័យកសិកម្ម	៤៩៦
១២	វិស័យឯកជនជាចក្លឹងនៃកំណើនសេដ្ឋកិច្ច	៤៩៦
១៣	គ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច អតិផរណា ការពារ១៧លាននាក់ពីគ្រាប់បែកសេដ្ឋកិច្ច	៤៩៧
១៤	កំណើនសេដ្ឋកិច្ចកម្ពុជា(ឆ្នាំ២០២០) អាវិជ្ជមាន ១,៩ភាគរយ	៤៩៧
១៥	កំណើនសេដ្ឋកិច្ចឆ្នាំ២០២១ អាចនៅជុំវិញ ៣ភាគរយ	៤៩៨
១៦	ក្បាស្តិភាពនយោបាយម៉ាក្រូសេដ្ឋកិច្ច ស្តាត់អតិផរណាក្បាកម្លាំងទិញប្រាក់រៀល	៤៩៨
១៧	រចនាសម្ព័ន្ធសេដ្ឋកិច្ចបានផ្លាស់ប្តូរ ពីកសិកម្មមានចំណែក៨០% មកត្រឹម២៥%	៤៩៩
១៨	សេដ្ឋកិច្ចពហិវិស័យដែលគ្មានទីអស្តង្គត	៤៩៩
១៩	សេដ្ឋកិច្ចឆ្នាំ២០២០ អវិជ្ជមាន តែបន្តជំរុញសេដ្ឋកិច្ច និងជំនួយសង្គម	៥០០
២០	កម្ពុជាបោះពុម្ពប្រាក់ប្រើឡើងវិញ នៅខែមីនា ឆ្នាំ១៩៨០	៥០០
២១	រឿងដែលនាយករដ្ឋមន្ត្រីបារម្ភជាងគេ គឺគ្មានប្រាក់បើកប្រាក់ខែឲ្យមន្ត្រីរាជការ	៥០១
២២	មានអតិរេកសាច់ប្រាក់ ដោយមិនគិតប្រាក់បម្រុងអន្តរជាតិ និងមាស ៣០តោន	៥០១
២៣	គ្រប់គ្រងឱ្យចំណូលលើសផែនការ និងចំណាយមិនឱ្យលើសផែនការ	៥០២
២៤	ដោយសេដ្ឋកិច្ចមិនច្បាស់លាស់ ផ្អាកដំឡើងប្រាក់ខែដល់មន្ត្រីរាជការឆ្នាំ២០២១	៥០២
២៥	ថវិកានិងជំនួយពី ៥ប្រភព ប្រើប្រាស់ក្នុងគ្រាប្រយុទ្ធនឹងកូវីដ-១៩	៥០២

២៦	គ្រោះកូវីដ-១៩ ចំណូលធ្លាក់ តែអាចទ្រទ្រង់ចំណាយវិនិយោគហេដ្ឋារចនាសម្ព័ន្ធ	៥០៣
២៧	កម្ពុជាមិនស្នើសុំផ្អាកសងម្ចាស់កម្ចីទេ ហើយក៏មិនចុះហត្ថលេខាខ្ចីលុយថែម	៥០៤
២៨	គ្រោះកូវីដ-១៩ ចាយប្រាក់សន្សំ១/៣ តែមិនរំខានប្រាក់បំរុងអន្តរជាតិនិងមាសទេ	៥០៤
២៩	មិនយល់ស្របនឹងការបង្កើនការខ្ចីដល់ពិដាន៤០%	៥០៤
៣០	រាជរដ្ឋាភិបាលសន្សំប្រាក់បម្រើតម្រូវការចំណាយចរន្ត និងហេដ្ឋារចនាសម្ព័ន្ធ	៥០៥
៣១	បន្តមិនយកភាគលាភពីប្រាក់ចំណេញអគ្គិសនីកម្ពុជា ៥ឆ្នាំ ២០២០-២០២៥	៥០៦
៣២	ផ្អាកចំណាយតាមក្រសួង/ស្ថាប័ន៥% លើកលែង ៣ស្ថាប័ន បន្តយកតែ២៥%	៥០៦
៣៣	តែងតែបានត្រៀមថវិកាបដិភាគកសាងអភិវឌ្ឍផ្លូវស្ពាន	៥០៧
៣៤	ចំណាយច្រើននិងត្រៀមចំណាយ មិនប្រកាសធ្វើផ្លូវពីល្វាឯមទៅផ្លូវជាតិ១១	៥០៧
៣៥	ស្តាយមិនបានចាយប្រាក់សន្សំដើម្បីពន្លឿនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ	៥០៨
៣៦	ខួបទី៧០ ថ្ងៃបង្កើតគយនៅកម្ពុជា ដោយបំបែកចេញពីសហភាពគយឥណ្ឌូចិន	៥០៨
៣៧	ព្រះមហាក្សត្រទាមទារគយពីបារាំង ២ឆ្នាំ(១៩៥១) មុនឯករាជ្យ ៩វិច្ឆិកា ១៩៥៣	៥០៩
៣៨	សារមន្ទីរគយ ជាទីតាំងប្រវត្តិសាស្ត្រនៃព្រះរាជបូជនីយ៍កិច្ច	៥១០
៣៩	រដ្ឋាភិបាលបណ្តោះអាសន្ន ថ្ងៃ ០៨មករា ១៩៧៩ មិនទាន់មានក្រសួង	៥១០
៤០	ផ្ទេរគយពីក្រសួងពាណិជ្ជកម្មទៅក្រសួងហិរញ្ញវត្ថុ	៥១១
៤១	ក្រសួងហិរញ្ញវត្ថុទទួលគយ ក្រសួងពាណិជ្ជកម្មប្រគល់គយ	៥១១
៤២	បញ្ចប់កាំកុងត្រូល រដ្ឋបាត់ ៣០លាន វិស័យឯកជនចំណេញ ៤០លាន	៥១២
៤៣	លុបកាំសាប លុបពន្ធកាត់ទុក មិនលក់/ជួរអធិបតេយ្យនឹងអ្នកណាដាច់ខាត	៥១២
៤៤	សូមរួសារាន់បង់ពន្ធរថយន្តដើម្បីទទួលបាននូវភាពអនុគ្រោះ ១០ភាគរយ	៥១៣
៤៥	អ្នកជាប់ពន្ធត្រូវតែបង់ពន្ធ ដើម្បីរដ្ឋយកពន្ធទៅអភិវឌ្ឍ	៥១៣
៤៦	សូមធនាគារមីក្រូហិរញ្ញវត្ថុ បន្ថយការប្រាក់ឬការសងនៃអ្នកងរគ្រោះដោយទឹកជំនន់	៥១៣
៤៧	ប្រទេសជាច្រើននិងស្ថាប័នហិរញ្ញវត្ថុជាច្រើន វាយតម្លៃខុសពីការអភិវឌ្ឍរបស់កម្ពុជា	៥១៤
៤៨	បាត់ EBA មិនមែនបាត់ចំនាក់ចំនងរវាងរដ្ឋនិងរដ្ឋនោះទេ	៥១៥
៤៩	មាន EBA ក៏មិនក្លាយជាអ្នកមាន បាត់ EBA ក៏វាមិនស្លាប់	៥១៥
៥០	មេរៀនវិបត្តិសេដ្ឋកិច្ច ៣លើក៖ "លោតមិនទាន់ខ្ពស់ ធ្លាក់មកវិញមិនឈឺខ្លាំង"	៥១៦
៥១	ADB សន្យាផ្តល់ ៦០ម៉ឺនដុល្លារសំរាប់ការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ	៥១៦
៥២	អាចសម្រេចគោលដៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់និងចំណូលខ្ពស់	៥១៧
៥៣	អត្រាភាពក្រីក្រ៥៣% នៅឆ្នាំ២០០៤ ធ្លាក់មកនៅត្រឹម១៣.៥% នៅឆ្នាំ២០១៤	៥១៨
៥៤	កម្ពុជារក្សាបានអធិបតេយ្យក្នុងការខ្ចីបុល	៥១៨
៥៥	កម្ពុជាទើបនឹងជំពាក់បំណុលបរទេស២១,៥% នៃអនុបាត៤០%	៥១៩
៥៦	ទាក់ទាញវិនិយោគថ្មី តាមរូបមន្តមួយបួក	៥១៩
៥៧	វិនិយោគិនក្រៅប្រទេសមានសិទ្ធិវិនិយោគ១០០% មិនបាច់ដៃគូ/ភាគហ៊ុនក្នុងស្រុក	៥២០
៥៨	គោលនយោបាយសេដ្ឋកិច្ចផ្តាយព្រឹកឬហ៊ុនសែនណូមិកបើកចំហសំរាប់វិនិយោគិន	៥២០
៥៩	ពិចារណាអោយក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុរៀបចំស្តុកប្រេងឥន្ធនៈជាយុទ្ធសាស្ត្រ	៥២០
៦០	ចលនាពីក្រៅប្រទេសឱ្យអ្នកខាងក្នុងដកលុយនិងឬកុំសងធនាគារមីក្រូហិរញ្ញវត្ថុ	៥២១
៦១	វិទ្ធង្សនាសេដ្ឋកិច្ច ស្មើនឹងការធ្វើការកម្ម	៥២២

១. ដាក់ចេញកញ្ចប់កែទំរង់នយោបាយ និងសេដ្ឋកិច្ច ដើរទន្ទឹមគ្នា

ពិធីប្រកាសដាក់ឱ្យអនុវត្តដំណាក់កាលទី៤៖ «គណនេយ្យភាពសមិទ្ធកម្ម»
នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២០ មីនា ២០២៣

... ពិតមែនថាសុន្ទរកថានៅវែងឆ្ងាយ ក៏ប៉ុន្តែខ្ញុំមិនគួររំលងការរំលឹកឡើងវិញនូវចំណុចខ្លះដែលគួរតែត្រូវបានចែករំលែកនៅក្នុងឱកាសនេះ ... សូមអរគុណលោកជំទាវអគ្គរដ្ឋទូតនៃសហភាពអឺរ៉ុបដែលតំណាងឲ្យដៃគូ ដែលបានធ្វើការវាយតម្លៃខ្ពស់ចំពោះ(កិច្ចការរបស់)យើង។ ដូចខ្ញុំបានបញ្ជាក់ហើយថា យើងមិនបានរង់ចាំថាទាល់តែមានសន្តិភាពពេញលេញ ទើបធ្វើការកែទម្រង់នោះទេ។ ខ្ញុំអាចនិយាយបានថា ការរស់រានរបស់យើងមកដល់ពេលនេះបានកើតចេញពីការកែទំរង់នោះឯង ... ជីវិតរបស់ខ្ញុំមានភាពផុយស្រួយប្រឈមនឹងគ្រោះថ្នាក់ត្រង់ថា ពេលចូលគ្រប់គ្រងតំណែងជានាយករដ្ឋមន្ត្រី **ខ្ញុំបានដាក់ចេញនូវកញ្ចប់កែទំរង់ពីរដែលដើរទន្ទឹមជាមួយគ្នា។ ទី១ កំណែទម្រង់ខាងនយោបាយ គឺត្រូវដោះស្រាយជម្លោះកម្ពុជាតាមរយៈនៃការចរចា ដែលពោរពេញដោយគ្រោះថ្នាក់សំរាប់ជីវិតរបស់ខ្ញុំ។ ទី២ គឺកំណែទម្រង់ខាងសេដ្ឋកិច្ចនោះឯង ...**៕

២. កំណែទម្រង់សេដ្ឋកិច្ច ចាប់ផ្តើមពីកំណែទម្រង់ដីធ្លី

ពិធីប្រកាសដាក់ឱ្យអនុវត្តដំណាក់កាលទី៤៖ «គណនេយ្យភាពសមិទ្ធកម្ម»
នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២០ មីនា ២០២៣

... **កំណែទម្រង់សេដ្ឋកិច្ច បានចាប់ផ្តើមពីកំណែទម្រង់ដីធ្លី។ មិនមែនជាបញ្ហាងាយស្រួលទេ។** នៅក្នុងរបប ប៉ុល ពត ដីធ្លីទាំងអស់ត្រូវបានរឹបអូសទៅជាសម្បត្តិរដ្ឋ។ ក្រោយរបបប្រល័យពូជសាសន៍ដួលរលំ យើងខ្ញុំគ្មានជម្រើសអ្វីក្រៅតែពីធ្វើកិច្ចការទាំងឡាយ(ដែលអាចធ្វើបាន)ដើម្បីសង្គ្រោះជីវិតប្រជាជន។ គ្រានោះក្នុង២០គ្រួសារមានគោមួយនឹម។ តើយើងខ្ញុំត្រូវធ្វើរបៀបម៉េច? ... កាលពី ៤៤ឆ្នាំមុន ទីក្រុងភ្នំពេញគ្មានមនុស្សនៅទេ ... តើមនុស្សប៉ុន្មាននាក់ដែលយល់ពីបញ្ហាសេដ្ឋកិច្ច? បើពេលនោះ មនុស្សមួយចំនួនធ្លាប់ទៅរៀននៅភាគខាងជើងវៀតណាមក្រោយសន្និសីទហ្សឺណែវឆ្នាំ ១៩៥៤ បានត្រឡប់មកប្រទេសវិញ ដោយនាំមកនូវគំនិតធ្វើសហករណ៍ ធ្វើរួម និងចែកផល ...៕

៣. កំលាំងសង្កត់៣ លើការប្រឹងប្រែងកែទំរង់

ពិធីប្រកាសដាក់ឱ្យអនុវត្តដំណាក់កាលទី៤៖ «គណនេយ្យភាពសមិទ្ធកម្ម» នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២០ មីនា ២០២៣

...អាចនិយាយបានថាមានកំលាំងសង្កត់បីមកលើជីវិតរបស់ខ្ញុំ (ក្នុងដំណើរការកែទំរង់)នៅពេលនោះ។ **ទី១ ផ្ទៃក្នុងខ្លួនឯងមិនយល់ថាអ្វីជាកំណែទម្រង់នយោបាយ? អ្វីទៅជាការចរចា? អ្វីទៅជាសេដ្ឋកិច្ចឯកជន?** ខណៈមនុស្សរបស់យើងនិយាយតែពីរឿងច្បាំង ហ្នឹងខាងផ្នែកនយោបាយ។ ឯខាងសេដ្ឋកិច្ច ពួកគេស្អប់សេដ្ឋកិច្ចឯកជន។ ដូច្នេះ ខ្ញុំត្រូវប្រឹងធ្វើពីមូលដ្ឋានដើម្បីដោះស្រាយបញ្ហា ... **ទី២ មានកងទ័ពវៀតណាមមិនតិចជាង ១០ម៉ឺននាក់នៅកម្ពុជា** ពេលដែលខ្ញុំធ្វើកំណែទំរង់ខណៈដែលវៀតណាមអត់ទាន់ធ្វើកំណែទម្រង់អ្វីទាំងអស់ ... និង**ទី៣ យើងខ្ញុំទទួលទណ្ឌកម្មពីប្រទេសនានា មានតែសូវៀត និងក្រុមប្រទេសសង្គមនិយមនៅអឺរ៉ុបខាងកើតដែលហៅថា Comecon និងសាធារណរដ្ឋតំណាង** ព្រមទាំងចំណែកណាមួយដែលបានផ្តល់ជំនួយដល់កម្ពុជា ...។

៤. កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ បានផ្តល់ផលឱ្យមានអតិរេកថវិកាចរន្ត

បិទសន្និសីទជាតិស្តីពីការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ៖ «មេរៀនបទពិសោធន៍ បញ្ហាប្រឈមនិងចក្ខុវិស័យទៅអនាគត», ២២ កុម្ភៈ ២០១៨

...យើងបានប្រឹងប្រែងធ្វើ**កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដែលបានឱ្យយើងមានអតិរេកថវិកាចរន្ត មានលទ្ធភាពមានប្រាក់កាសដំឡើងបៀវត្សឱ្យមន្ត្រីរាជការ និងមានលទ្ធភាពបញ្ជូនប្រាក់ទៅឱ្យមូលដ្ឋានដំណើរការ។ យើងមានប្រាក់ដើម្បីធ្វើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់តាមស្ថាប័នមួយៗ ហើយស្ថាប័នហ្នឹងក៏បញ្ជូនតាមខ្សែបណ្តាយរបស់ខ្លួនទៅឱ្យថ្នាក់ក្រោមជាតិផងដែរ** ... ត្រូវមើលឃើញថា ដើម្បីមានប្រាក់សម្រាប់ចំណាយនេះ អស់លោកត្រូវតែចូលរួមប្រមែប្រមូលកុំឱ្យបាត់បង់ប្រាក់ចំណូលជាតិ។ បើគ្មានប្រាក់ចំណូល ក៏គ្មានប្រាក់ចំណាយដែរ។ ខ្ញុំសូមអបអរសាទរ និងបង្ហាញនូវក្តីមោទនៈចំពោះកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដែលជានិច្চកាលប្រចាំឆ្នាំ យើងមានអតិរេកថវិកាចរន្តសំរាប់ប្រើប្រាស់ឆ្នាំបន្តទៅមុខ ជាការដំឡើងបៀវត្សរ៍ ការវិនិយោគទៅឯមូលដ្ឋាន ...។

៥. អត្រានៃភាពក្រីក្របន្តធ្លាក់ចុះ ក្នុងរង្វង់ជុំវិញ១០%

សំណេះសំណាលជាមួយកម្មករ និយោជិត តំបន់ផ្លូវជាតិលេខ៣, ២៧ ធ្នូ ២០១៧

... អត្រានៃភាពក្រីក្របានធ្លាក់ចុះ។ ទោះបីជាយើងមិនទាន់ធ្វើដំរើនឡើងវិញក៏ដោយចុះ ក៏**អត្រានៃភាពក្រីក្របច្ចុប្បន្នក្នុងប្រទេសនៅសល់មិនដល់១០% ទេ (ឬអាចថា)នៅក្នុងរង្វង់៩% និងបើយើងគិតក្នុងឆ្នាំ២០១៤ សល់ត្រឹម១៣%។ យើងមិនទាន់បានធ្វើដំរើនទេ ក៏ប៉ុន្តែ(យើងអាចដឹងបានថា)អត្រានៃភាពក្រីក្របានធ្លាក់ចុះមិនតិចជាង១% នោះទេក្នុងមួយឆ្នាំ។** យើងបានចាប់ផ្តើមពីអត្រានៃភាពក្រីក្រ១០០% ក្រោយចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ... (ការដែលបានមកដល់)អត្រានៃភាពក្រីក្រ (ដែលអាច)ថាជុំវិញ១០% ជាដំណើរលឿនមួយប្រៀបធៀបទៅនឹងប្រទេសមួយចំនួនដែលមានការអភិវឌ្ឍយូរជាងយើង វែងឆ្ងាយជាងយើង ហើយដែលអត្រាភាពក្រីក្រនៅសល់ក្នុងចន្លោះពី២០% ទៅ៣០% ...។

៦. ឈានទៅប្រាក់ចំណូលមធ្យមកំរិតខ្ពស់ឆ្នាំ២០៣០ និងប្រាក់ចំណូលខ្ពស់ឆ្នាំ២០៥០

សំណេះសំណាលជាមួយកម្មករ និយោជិត តំបន់ផ្លូវជាតិលេខ៣, ២៧ ធ្នូ ២០១៧

... តាមការវាស់ស្ទង់ភាពក្រីក្រដែលដាក់ចេញដោយអង្គការសហប្រជាជាតិ ក្នុងការអភិវឌ្ឍសហស្សវត្សរ៍ ក៏ដូចជាការអភិវឌ្ឍដោយចីរភាពនៅដំណាក់កាលក្រោយនេះ គឺដែលពីមុនការរកបានប្រាក់ចំណូលត្រឹមតែ ១ដុល្លារសហរដ្ឋអាមេរិក (ក្នុងមួយថ្ងៃ រាប់ថាបានឆ្លងផុតបន្ទាត់នៃភាពក្រីក្រហើយនោះ) ឥឡូវនេះគឺ(ទាល់តែ)រកបាន ១ដុល្លារ ២៥សេន(ក្នុងមួយថ្ងៃ)។ យ៉ាងណាក្តី សម្រាប់ក្លួយៗជាកម្មករ/ការិនី **រកបានមិនតិចជាង ៥ដុល្លារសហរដ្ឋអាមេរិកនោះទេ(ក្នុងមួយថ្ងៃ)។ នេះក៏មិនមែនជាការស្កប់ស្កល់របស់យើងនោះទេ។ ប្រទេសយើងបានចេញផុតពីហានៈជាប្រទេសដែលមានប្រាក់ចំណូលទាប ទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកំរិតទាប ប៉ុន្តែមហិច្ឆតារបស់យើងគឺខិតខំឈានទៅសម្រេចឱ្យបានស្ថានភាពជាប្រទេសមានប្រាក់ប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ ហើយនឹងក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០** ...។

៧. រដ្ឋជាសេដ្ឋវិទូដឹកនាំក្របខណ្ឌគោលនយោបាយ ទុកឱ្យទីផ្សារមានការប្រកួតប្រជែង

សម្ពោធរោងចក្រស៊ីម៉ងត៍ ជីប ម៉ុង, ៨ កុម្ភៈ ២០១៨

... យើងបានរុញដំណើរការឯកជនូបនីយកម្មរោងចក្ររដ្ឋទាំងអស់។ មិនទុកទេ ក្នុងពេលដែលប្រទេសមួយចំនួនបន្តធ្វើរោងចក្ររដ្ឋ សហគ្រាសរដ្ឋ ក្រុមហ៊ុនរដ្ឋ។ ខ្ញុំតែងតែបង្ហាប់ថាក្រុមហ៊ុនរដ្ឋរកស៊ីមិនឈ្នះក្រុមហ៊ុនឯកជនទេ។ ខ្ញុំឧស្សាហ៍និយាយពីរឿងអ្នកលក់គុយទាវ។ មួយជាហាងគុយទាវរដ្ឋ និងមួយជាហាងគុយទាវឯកជន។ យើងចូលទៅហាងគុយទាវឯកជន ទោះបីជាមិនទាន់មានស្អីក៏ដោយចុះ អ្នករត់តុបានមកអញ្ជើញឱ្យអង្គុយ និងពិសាទឹកតែសិន ... មកដល់ចាប់ផ្តើមបម្រើតែម្តង ទោះបីតុហ្នឹងមិនមានធូលីក៏ដោយ ក៏វាជូតដែរ។ ឃ្លាតតែពីហ្នឹង ៥០ម៉ែត្រ រោងគុយទាវរដ្ឋ ទៅដល់ហ្នឹង គឺអង្គុយមួយសន្ទុះធំ គ្មាននរណាមកអើតទេ ... ព្រោះថាលក់ដាច់ក៏បានប្រាក់ខែប៉ុណ្ណឹង លក់មិនដាច់ក៏បានប្រាក់ខែប៉ុណ្ណឹង។ ដូច្នេះ វាមិនមានអីជាការជម្រុញឱ្យប្រឹង។ **ដូច្នេះ រុញអោយឯកជនធ្វើ ហើយរដ្ឋថាំឱ្យទីផ្សារកាត់សេចក្តី។ រដ្ឋជាសេដ្ឋវិទូ ដឹកនាំក្របខណ្ឌគោលនយោបាយ ក្រៅពីនោះ ទុកអោយទីផ្សារមានការប្រកួតប្រជែង** ...៕

៨. បើកចំហសេដ្ឋកិច្ច តាំងពីមុនមានកិច្ចព្រមព្រៀងប៉ារីស

សម្ពោធរោងចក្រស៊ីម៉ងត៍ ជីប ម៉ុង, ៨ កុម្ភៈ ២០១៨

... យើងចាប់ផ្តើមដំណើរការ**ឯកជនូបនីយកម្មបណ្តារោងចក្ររដ្ឋតាំងពីឆ្នាំ ១៩៩០ ព្រោះពេលវេលាបានមកដល់។ យើងបានបើកចំហទីផ្សារ**។ បើទោះបីជាមិនទាន់មានអ្នកវិនិយោគពីខាងក្រៅធំៗក៏ដោយចុះ ប៉ុន្តែវាក៏ចាប់ផ្តើមមានចលនាចូលមកធ្វើការវិនិយោគនៅកម្ពុជាបណ្តើរៗហើយ។ តាំងពីពេលនោះមក សេដ្ឋកិច្ចរបស់កម្ពុជាបន្តមានការលូតលាស់។ **សូមកុំភាន់ច្រឡំថា កិច្ចព្រមព្រៀងប៉ារីសអ្នកនាំសេដ្ឋកិច្ចផ្សារមកអោយកម្ពុជាឲ្យសោះ? សូមកុំនិយាយធុនហ្នឹង។ អ្នកខ្លះថា កិច្ចព្រមព្រៀងប៉ារីស នាំសេដ្ឋកិច្ចទីផ្សារមកអោយកម្ពុជា។ សូមប្រាប់ទៅអ្នកទាំងឡាយអោយបានជ្រាបថា កម្ពុជាបានធ្វើសេដ្ឋកិច្ចទីផ្សារ(តាំងពីមុនមានកិច្ចព្រមព្រៀងប៉ារីសរួចទៅហើយ)** ...៕

៩. ផ្តើមពីសេដ្ឋកិច្ចផែនការ មកដំណើរការឯកជនូបនីយ៍កម្ម និងកំពុងធ្វើសុក្រឹតកម្មសេដ្ឋកិច្ចទីផ្សារ

សម្ពោធរោងចក្រស៊ីម៉ងត៍ ជីប ម៉ុង, ៨ កុម្ភៈ ២០១៨

... បើនិយាយពីសេដ្ឋកិច្ច អាចនិយាយបានថា ខ្ញុំបានដឹកនាំសេដ្ឋកិច្ចតាម ៣ ផ្នែកសំខាន់។ **ទី១ ចូលរួមដឹកនាំសេដ្ឋកិច្ចផែនការ** ... បណ្តើរៗយើងបានរុញឱ្យមានការរីកចំរើន ដោយវិស័យឯកជនបានងើបឈរឡើង ក្នុងហ្នឹងរាប់ទាំងការបែងចែកនិងផ្តល់កម្មសិទ្ធិដីធ្លីឱ្យប្រជាពលរដ្ឋ ... បន្ទាប់ទៅ យើងបាន**រុញដំណើរការឯកជនូបនីយកម្មរោងចក្ររដ្ឋ** ... និងចាប់ពីឆ្នាំ ១៩៩១-១៩៩២ មកយើង**កំពុងបន្តធ្វើសុក្រឹតកម្មសេដ្ឋកិច្ចទីផ្សារ** ... យើងបានធ្វើច្បាប់មួយតម្រូវតាមការសន្យាចំពោះអង្គការពាណិជ្ជកម្មពិភពលោក អំពីអាជ្ញាបណ្ណវិជ្ជសាស្ត្រខាងវិស័យសុខាភិបាល ហើយយើងនឹងបន្តធ្វើច្បាប់ស្តីពីមេធាវីតទៅទៀត។ អ្វីដែលយើងបានសន្យាជាមួយអង្គការពាណិជ្ជកម្មពិភពលោក យើងត្រូវធ្វើអោយបាន ព្រោះនេះជាលក្ខខណ្ឌតម្រូវចំពោះសេដ្ឋកិច្ចសើរ សេដ្ឋកិច្ចបើកចំហ ...៕

១០. ទំនាក់ទំនងនយោបាយរឹតធំ ដោយការគាំទ្រពីទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ

ដាក់ឱ្យប្រើប្រាស់នូវស្ពានមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រង់-ក្រូចឆ្មារ (ស្ពានភ្ជាប់និស្សិ័យ) និងការប្រកាសបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ 71C, ២៣ វិច្ឆិកា ២០២១

... ជា**បទពិសោធន៍ដែលខ្ញុំមាន តាំងពីអាយុ ២៧ឆ្នាំ ក្នុងឋានៈជារដ្ឋមន្ត្រីការបរទេស "ទំនាក់ទំនងនយោបាយមានការកើនឡើង ដោយសារការគាំទ្រនៃទំនាក់ទំនងខាងសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ"។ ពិនិត្យមើលចុះ ប្រទេសដែលពុំមានទំនាក់ទំនងច្រើនជាមួយគ្នាលើផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ដោយគ្រាន់តែមានទំនាក់ទំនងខាងនយោបាយ ទំនាក់ទំនងនោះមិនរឹងមាំទេ**។ បើមានទំនាក់ទំនងច្រើនលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ទំនាក់ទំនងនោះពិតជាធ្វើសកម្មភាពជាមួយគ្នាច្រើន។ យើង(កម្ពុជានិងចិន)នៅសល់ច្រើនគម្រោងទៀត។ (ក្នុង)ខែ១២ ហ្នឹង យើងទៅសម្ពោធផ្លូវជាតិលេខ ១១ នៅព្រៃវែង យើងត្រូវទៅសម្ពោធគម្រោងចិន៣ ដល់ក្រចេះឯណោះ។ ដូច្នេះសល់ ៤កម្មវិធី មិនទាន់គិតទៅដល់មន្ទីរពេទ្យនៅត្បូងឃ្មុំដែលសង់បាន៩៧% ហើយ។ កាលបើសង់រួចរាល់នោះ ច្បាស់ជាខ្ញុំទៅសម្ពោធហើយ យ៉ាងច្រើនឆ្នាំ២០២២ ដាក់ឱ្យប្រើប្រាស់ ...៕

១១. ចាប់ផ្តើមអភិវឌ្ឍសេដ្ឋកិច្ច ដោយជំរុញខ្លាំងវិស័យកសិកម្ម

សំណេះសំណាលជាមួយកម្មករ និយោជិត នៅឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ, ៧ វិច្ឆិកា ២០១៨

... គ្រាន់តែរំលឹក ដើម្បីឲ្យក្មួយអាចបានដឹង ... **យើងចាប់ផ្តើមអភិវឌ្ឍសេដ្ឋកិច្ចដោយជម្រុញខ្លាំងលើវិស័យកសិកម្ម។ ពេលនោះ យើងត្រូវធ្វើក្នុងក្របខណ្ឌនៃសេដ្ឋកិច្ចផែនការទៅទៀត។ មិនមែនជាសេដ្ឋកិច្ចទីផ្សារទេ ព្រោះគ្មានអ្នកមកវិនិយោគនៅស្រុកយើងទេ**។ អ្នកតាកែវនេះ ជាអ្នកដែលមានសំណាងជាងគេ ដោយសារអភិបាលខេត្ត ប៉ុល សារឿន មិនព្រមធ្វើក្រុមសាមគ្គី ... គាត់ចែកដីឲ្យប្រជាជនធ្វើ(ស្រែ)។ (ពេលនោះ)អ្នកតាកែវជាអ្នកផ្តត់ផ្តង់ស្រូវទៅជួយខេត្តដទៃទៀត។ មានជង្រុកស្រូវច្រើនណាស់។ (ប៉ុល) សារឿន លាក់ស្រូវមិនតិចទេ។ ពេលខ្ញុំកាន់តំណែងជានាយករដ្ឋមន្ត្រី ខ្ញុំបានមកតាកែវ មើលឃើញតែឃ្លាំងស្រូវ។ សារឿន ថា "ខ្ញុំអត់ត្រូវការមេដាយទេ ខ្ញុំត្រូវការតែកុំឲ្យប្រជាជនអត់បាយតែប៉ុណ្ណឹង" ...។

១២. វិស័យឯកជនជារថភ្លើងនៃកំណើនសេដ្ឋកិច្ច

ក្នុងពិធីសម្ពោធសណ្ឋាគារ Hyatt Regency ភ្នំពេញ, ១៥ ធ្នូ ២០២១

... ខ្ញុំមានមោទនភាព និងវាយតម្លៃខ្ពស់ ចំពោះការរួមចំណែករបស់ក្រុមហ៊ុនជីបម៉ុង និយាយដោយឡែក ក៏ដូចជាក្រុមហ៊ុនដទៃទៀត និយាយជារួម ក្នុងការធ្វើឱ្យមានការរីកចម្រើនឡើងនូវការអភិវឌ្ឍសម្រាប់ប្រទេស។ **ការរីកចម្រើនរបស់ក្រុមហ៊ុននីមួយៗ ការរីកចម្រើនរបស់គ្រួសារនីមួយៗ វាជាផ្នែកសំខាន់នាំទៅដល់ប្រទេសរីកចម្រើន។ មិនអាចអោយត្រឹមតែរដ្ឋធ្វើជាអ្នកមាន ប៉ុន្តែប្រជាជននៅក្រីក្រនោះទេ។ យើងចាត់ទុក វិស័យឯកជនជាក្បាលរថភ្លើងនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេស។ រដ្ឋត្រឹមតែជាសេដ្ឋវិទូ ដើម្បីតម្រង់ទិសប៉ុណ្ណោះ**។ ប្រតិបត្តិការជាក់ស្តែងនៃការធ្វើឱ្យមានការរីកចម្រើនគឺវិស័យឯកជននេះឯង។ យើងសង្កេតឃើញថា វិនិយោគិនក៏មានច្រើននៅទីនេះ ដូចជា ឧកញ៉ា ពុង ឃាវសែ ដែលវិនិយោគដល់ទៅព្រលានយន្តហោះឯណោះ ...។

១៣. គ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច អតិផរណា ការពារ ១៧លាននាក់ពីគ្រាប់បែកសេដ្ឋកិច្ច

សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២១ និងលើកទិសដៅការងារ ឆ្នាំ ២០២២ ក្រសួងមហាផ្ទៃ, ២៣ កុម្ភៈ ២០២២

... យើងធ្លាប់ជួបប្រទះហើយការជំពាក់ប្រាក់ខែបុគ្គលិកមន្ត្រីរាជការ ... ក្នុងមួយខែមាន ៦០ឬ ៧០ថ្ងៃ។ ឥឡូវ ក្នុងមួយខែបើកប្រាក់បៀវត្ស ២ដង ដោយសារយើងបានសន្សំសាច់ប្រាក់ទុក។ ដំឡើងបៀវត្សរ៍ហើយ បើកមួយខែ ២ដង។ កម្មវិធីហ្នឹងអត់ដកថយទេ ... ចំណាយចាំបាច់ដែលខានមិនបានគឺបៀវត្សរ៍។ ចំណាយដែលចាំបាច់ខានមិនបានគឺការព្យាបាលជំងឺកូវីដ-១៩ រាល់ថ្ងៃនេះ ... ចូលមកដល់ឥឡូវដូចជា ៣០២៣(នាក់បានស្លាប់) ហើយកូវីដ-១៩ អាចបន្តសម្លាប់ ... ប៉ុន្តែខ្ញុំសុំបញ្ជាក់ **បើគ្រាប់បែកសេដ្ឋកិច្ចផ្ទុះ មនុស្សជិត ១៧លាននាក់ទៅទាំងអស់។ ធ្វើយ៉ាងម៉េចត្រូវគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច គ្រប់គ្រងអតិផរណាឱ្យបានដើម្បីធានាជីវភាពប្រជាពលរដ្ឋ** ...។

១៤. សេដ្ឋកិច្ចកម្ពុជា(ឆ្នាំ២០២០) អវិជ្ជមាន ១,៩ភាគរយ

ព្រីនស៍ ម៉ាណ័រ (Prince Manor), កៀនស្វាយ, កណ្តាល, ៧ តុលា ២០២០

... ពីមុននេះ គេព្យាករថាសេដ្ឋកិច្ចកម្ពុជាអាចធ្លាក់ពី ៧ភាគរយ ទៅ ៩ភាគរយ (ក្រោមសូន្យ) ក្នុងពេលដែលយើងព្យាករថា **សេដ្ឋកិច្ចយើង(នឹងនៅក្នុងវង់) អវិជ្ជមាន ១,៩ភាគរយ។ ឥឡូវនេះ ស្ថាប័នហិរញ្ញវត្ថុធំៗ រាប់ទាំងធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី បានធ្វើការព្យាករឡើងវិញ ប្រហាក់ប្រហែលនឹងការព្យាករណ៍របស់រាជរដ្ឋាភិបាល។ បើធនាគារពិភពលោក ចាត់ទុកថា អវិជ្ជមានត្រឹមតែ ២ភាគរយទេ។ បើ ២ភាគរយ យើង(ព្យាករ) ១,៩ភាគរយ មិនមានអីខុសគ្នា។ អញ្ចឹង មុននេះ គេមើលឃើញស្ថានភាពរបស់យើងផ្សេង**។ ក៏ប៉ុន្តែ យើងប្រឹងដោយខ្លួនឯង ងើបឈរដោយខ្លួនឯង គ្រប់គ្រង COVID-19 ផង ខិតខំរក្សាលំនឹងសេដ្ឋកិច្ចសង្គមផង ធ្វើឱ្យស្ថានភាព ជីវភាពរបស់ប្រជាពលរដ្ឋ មានភាពល្អប្រសើរឡើង បន្ថែមលើនោះ វិស័យកសិកម្មរបស់យើង ក៏បានផ្តល់ឱកាសដ៏ធំធេងសម្រាប់កសិកររបស់កម្ពុជា ...។

១៥. កំណើនសេដ្ឋកិច្ចឆ្នាំ២០២១ អាចនៅជុំវិញ ៣ភាគរយ

សម្ពោធសណ្ឋាគារ Hyatt Regency ភ្នំពេញ, ១៥ ធ្នូ ២០២១

... ពេលដែលចាប់ផ្តើមបើកប្រទេស ខ្ញុំសង្កេតឃើញប្រាក់ចំណូលកើន។ (មុននេះ)វាធ្លាក់ចុះក្នុងរយៈពេលប៉ុន្មានខែ។ ឥឡូវងើបឡើងវិញ។ ទោះបីថាវាមិនទាន់ងើបស្មើនឹងមុនសម័យ កូវីដ-១៩ក៏ដោយ។ ដែលយើង(ធ្លាប់)រកមួយខែបានរង្វង់ប្រមាណ ៥០០ទៅ ៧០០លានដុល្លារក្នុងមួយខែ វាបានធ្លាក់ចុះមកនៅលើ ៤០០លាន(ដុល្លារ) ហើយក៏បន្តធ្លាក់ចុះមកនៅក្រោម ៤០០លាន(ដុល្លារ)ប៉ុន្មានខែ។ ឥឡូវនេះវាក៏បានងើបឡើងវិញ ពេលដែលចាប់ផ្តើមមានតម្រូវការក្នុងស្រុក តម្រូវការនាំចូលច្រើន ពន្ធគយក៏មានកំណើន ... **ពិតមែនតែយើងជាក់ក្នុងច្បាប់ថវិកាថានឹងមានកំណើនត្រឹមតែ ២,៤ (ភាគរយទេ) ក៏ប៉ុន្តែអង្គការមួយបានវាយតម្លៃពីខែ១០ មកថាយើងនឹងមានកំណើន ២,៨ភាគរយ។ ខ្ញុំគិតថាកំណើនសេដ្ឋកិច្ចរបស់យើងអាចនឹងមានកំណើន ២,៩ភាគរយឬ ៣ភាគរយ ឬអាចលើស ៣ភាគរយតិចតួច។ ខ្ញុំប្រើពាក្យជុំវិញ ៣ភាគរយ** ...។

១៦. រក្សាស្ថិរភាពនយោបាយ ម៉ាក្រូសេដ្ឋកិច្ច ទប់ស្កាត់អតិផរណា រក្សាកម្លាំងទិញនៃប្រាក់រៀល

សម្ពោធសណ្ឋាគារ Hyatt Regency ភ្នំពេញ, ១៥ ធ្នូ ២០២១

... ជាភ័ព្វសំណាងរបស់យើង ក្នុងកាលៈទេសៈដ៏លំបាកនេះ **ម្ខាងយើងរក្សាបានស្ថិរភាពនយោបាយ ម្ខាងទៀតយើងរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ទប់ស្កាត់បានអតិផរណា រក្សាបានកម្លាំងទិញនៃប្រាក់រៀល។ នេះគឺជាចំណុចល្អ។ ឥឡូវកំពុងតែ(មានការ)ព្រួយបារម្ភអំពីអតិផរណា។** យើងក៏មានការព្រួយបារម្ភដែរ។ យើងបន់ស្រន់ឲ្យប្រទេសក្នុងតំបន់ ជាពិសេសប្រទេសជិតខាងកុំជួបនឹងអតិផរណា ព្រោះតែអតិផរណាកើតមាននៅប្រទេសជិតខាង ផ្នែកណាមួយក៏នឹងផ្តល់ផលប៉ះពាល់ដល់យើង។ ប្រសិនបើអាចធ្វើទៅបាន សំរាប់ការរៀបចំប្រជុំក្នុងនាមជាប្រធានអាស៊ានប្តូរវេនឆ្នាំ២០២២ សណ្ឋាគារ Hyatt អាចទទួលថ្នាក់ប្រមុខរដ្ឋ/រដ្ឋាភិបាលបានខ្លះ ...។

១៧. រចនាសម្ព័ន្ធសេដ្ឋកិច្ចបានផ្លាស់ប្តូរ ពីកសិកម្មមានចំណែក៨០% មកត្រឹម២៥%

សំណេះសំណាលជាមួយនិស្សិត និងប្រជាពលរដ្ឋខ្មែរ កំពុងសិក្សា និងរស់នៅប្រទេសជប៉ុន, ៧ តុលា ២០១៨

... **រចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់កម្ពុជាបានផ្លាស់ប្តូរហើយ។ ពីមុន ៨០% (នៃសេដ្ឋកិច្ចយើងបានការ)រួមចំណែកពីវិស័យកសិកម្ម និង២០% បានការរួមចំណែកពីវិស័យឧស្សាហកម្មនិងសេវា។ ឥឡូវនេះ សេដ្ឋកិច្ចរបស់កម្ពុជាបានផ្លាស់ប្តូររចនាសម្ព័ន្ធមក ២៥% ជាការរួមចំណែកពីកសិកម្ម ៣០% ពីឧស្សាហកម្ម និង៤៥% ពីសេវាកម្ម។** អ្នកទាំងអស់គ្នាប្រយ័ត្នច្រឡំថា ជាប្រទេសកសិកម្ម ហើយបែរជានៅសល់ការរួមចំណែកតែ ២៥%? សូមមើលប្រទេសជប៉ុន ... កសិកម្មជប៉ុនសល់ចំណែកតែ១% ទេ ប៉ុន្តែអាចចិញ្ចឹមខ្លួនឯងបាន និងនាំចេញផលិតផលកសិកម្មទៅក្រៅប្រទេស ... កាលពីកសិកម្មរួមចំណែក៨០% ប្រជាជនខ្វះអង្ករស៊ី។ ឥឡូវយើងនៅសល់តែ២៥% តែនៅសល់ស្រូវជិត ៦លានតោន ...។

១៨. សេដ្ឋកិច្ចពហុវិស័យដែលគ្មានទីអស្តង្គត

ទីក្រុងស្អាតលើកទី៧ ឆ្នាំ២០១៩ ក្រោមប្រធានបទ
«ទីក្រុងស្អាត៖ ទីក្រុងផ្តល់ភាពកក់ក្តៅ», ២៥ កុម្ភៈ ២០១៩

... ក្រោយពីនយោបាយឈ្នះឈ្នះឆ្នាំ ១៩៩៨ បានឯកភាពទឹកដីហើយ **យើងបំផ្លាញចោលគ្រាប់មីន ធ្វើហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងឥឡូវនេះ ទេសចររបស់យើង(អាចធ្វើដំណើរ)ជុំវិញ(ប្រទេសបាន)តែម្តង។ ខាងមុខនេះ យើងនឹងកសាងផ្លូវបន្ថែមៗទៀត រាប់ទាំងផ្លូវតភ្ជាប់ពីខេត្តកោះកុង តាមព្រំដែនកម្ពុជា-ថៃទៅ ឬជាហើយចេញពីឬជាភពធ៌សាត់ ទៅប៉ៃលិន ទៅបាត់ដំបង ដែលទេសចរអាចធ្វើដំណើរទូទាំងព្រំដែនកម្ពុជាដែលបានតភ្ជាប់គ្នាទាំងអស់។ យើងក៏មានចំណុចទាក់ទាញជាអេកូទេសចរណ៍។ ទាំងនេះជាសេដ្ឋកិច្ចពហុវិស័យ គ្មានទីអស្តង្គតទេ**។ សូម្បីតែក្នុងវិស័យកសិកម្ម ក៏មានអនុវិស័យច្រើនណាស់ ក្នុងនោះមានអនុវិស័យដែលបម្រើឲ្យវិស័យទេសចរណ៍ក្នុងស្រុកដែលត្រូវការច្រើន ... យើងធ្វើការសម្របសម្រួលដើម្បីឲ្យភោជនីយដ្ឋាននិងសណ្ឋាគារ ក្លាយជាទីផ្សារនៃផលិតផលរបស់កសិករ ...។

១៩. សេដ្ឋកិច្ចឆ្នាំ២០២០ អាចជួមាន តែបន្តជំរុញសេដ្ឋកិច្ច និងជំនួយសង្គម

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អាគារទីស្តីការក្រសួងសាធារណការ និងដឹកជញ្ជូន និងវិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន, ២២ មករា ២០២១

... **សេដ្ឋកិច្ចឆ្នាំ២០២០ បើទោះបីជាអាចជួមាន ក៏វាមិនអាក្រក់ហួសហេតុពេកទេ។ យើងធ្លាប់រងផលអាក្រក់នេះ សម្រាប់កាលពីវិបត្តិសេដ្ឋកិច្ចហិរញ្ញវត្ថុសកលឆ្នាំ២០០៨ និងក្រោយឆ្នាំ២០០៨** ... យើងធ្លាប់ធ្វើសេដ្ឋកិច្ចឆ្នាំ២០០៥ មាន ១៣,៣ ភាគរយ។ ឆ្នាំ ២០០៦ មាន ១២ ភាគរយ។ ឆ្នាំ ២០០៧ មានជាង ១១ ភាគរយ ប៉ុន្តែដល់វិបត្តិសេដ្ឋកិច្ចចាប់ផ្តើមឆ្នាំ២០០៨ យើងធ្លាក់មកនៅត្រឹម ៦,៨ភាគរយ ដល់ចូលឆ្នាំ២០០៩ នៅសល់ ០,៥ភាគរយតែប៉ុណ្ណោះ។ ឆ្នាំ២០១០ យើងងើបមកជាង ៦ភាគរយ។ ចាប់ពីឆ្នាំ២០១១ រហូតដល់ឆ្នាំ២០១៩ មានជាង ៧ភាគរយរហូត។ ឥឡូវនេះ មានការព្យាករថា យើងនឹងមានកំណើនជិត ៤ភាគរយ។ ត្រូវជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ... ដោយបន្តជួយ(ផ្តល់ប្រាក់ឧបត្ថម្ភ)ប្រជាពលរដ្ឋជិត ៣លាននាក់។ កម្មករបាត់បង់ការងារធ្វើក៏ត្រូវជួយ។ គោលនយោបាយសង្គម ជំនួយសង្គមទាំងឡាយ នៅបន្តធម្មតា ...។

២០. កម្ពុជាបោះពុម្ពប្រាក់ប្រើឡើងវិញ នៅខែមីនា ឆ្នាំ១៩៨០

សំណេះសំណាលជាមួយកម្មករ និយោជិត នៅឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ, ៧ វិច្ឆិកា ២០១៨

... នៅកម្ពុជាយើងមិនដូច្នេះទេ។ **(របប ប៉ុល ពតបាន)លុបចោលទាំងអស់។ ការចាប់ផ្តើមរបស់យើងវាលំបាកណាស់ គឺពីការដូររបស់នឹងរបស់។ អ្នកមានអង្ករទៅដូរជាមួយអ្នកមានត្រី អ្នកមានត្រីទៅដូរជាមួយអ្នកមានក្រមា ... បន្ទាប់ទៅ ជាបណ្តើរៗ នៅខែមីនា ឆ្នាំ១៩៨០ ទើបយើងបោះក្រដាសប្រាក់អោយចាយ(ឡើងវិញ)។ គឺជាប្រទេសដែលចម្លែកជាងគេនៅលោកនេះ។ អ្វីៗត្រូវចាប់ផ្តើមកសាងថ្មីទាំងអស់ សូម្បីតែគ្រួសារនីមួយៗ ក៏ត្រូវចាប់ផ្តើមថ្មីដែរ** ... ប៉ុល ពត បានរឹបអូសយកដីស្រែចំការ ផ្ទះសម្បែង និងយកគោក្របី ចានឆ្នាំង ទៅ(ដាក់ជាទ្រព្យ)សហករណ៍។ ដល់ពេលរំដោះហើយ ក៏ចែកគ្នាត្រឡប់មកវិញ។ កាលពីយកទៅវាយកចានទាំងរាវ យកឆ្នាំង ៤-៥ យកវែក យកស្លាបព្រា។ ដល់ចែកត្រឡប់មកវិញ

បានចានមួយ បាត់ស្លាបព្រា បានឆ្នាំងអត់គម្រប... មិនមែនតែស្តាប័នរដ្ឋទេ សូម្បីតែក្រុមគ្រួសារនីមួយៗ ក៏ត្រូវចាប់ផ្តើមថ្មីឡើងវិញទាំងអស់ ...។

២១. រឿងដែលនាយករដ្ឋមន្ត្រីបារម្ភជាងគេ គឺគ្មានប្រាក់បើកប្រាក់ខែឲ្យមន្ត្រីរាជការ

សម្ពោធដាក់ឱ្យប្រើប្រាស់នូវស្ពានអាកាស និងផ្លូវក្រោមដីចោមចៅ, ៣១ មីនា ២០២២

... ពេលទទួលជើងលេខពីខាងពន្ធដារនិងគយ បរិមាណសាច់ប្រាក់ក្នុងរតនាគារបានកើនឡើងប្រមាណជាង ៩០០ពាន់លាន ... បង្ហាញថាជើងលេខនៃអតិរេកសាច់ប្រាក់ដែលយើងសន្សំ(កើនឡើង) ... **នៅកម្ពុជានេះ ពេលនោះ មានតែខ្ញុំម្នាក់គត់ដែលមានបទពិសោធន៍ថាតើនាយករដ្ឋមន្ត្រីគិតពីអីខ្លាំងជាងគេ? ... ធ្វើ(ជានាយករដ្ឋមន្ត្រី)ជិត ៤ទសវត្សរ៍ហើយ ដែលនាយករដ្ឋមន្ត្រីភ័យជាងគេគឺអត់សាច់ប្រាក់បើកប្រាក់ខែ។ យើងខំសន្សំសាច់ប្រាក់យ៉ាងខ្លាំង បានជាយើងទប់ទល់ ២ឆ្នាំនេះបាន**។ ក្នុងមួយខែត្រូវចាយជិត ៤០លានដុល្លារចិញ្ចឹមប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ដោយកូវីដ-១៩។ អញ្ចឹងនាយករដ្ឋមន្ត្រីដែលពិបាកជាងគេ គឺនាយករដ្ឋមន្ត្រីដែលចំណូលអត់(ចូល) ហើយចំណាយចេះតែចេញ។ ទោះបីជាប្រាក់ចំណូលកើនឡើងក៏ដោយ យើងនៅតែមិនមានឲ្យធ្វេសប្រហែសរឿងហ្នឹងទេ ...។

២២. មានអតិរេកសាច់ប្រាក់ ដោយមិនគិតប្រាក់បម្រុងអន្តរជាតិ និងមាស ៣០តោន

ពិធីចែកសញ្ញាបត្រដល់និស្សិត នៃសាកលវិទ្យាល័យ ប៊ែលធីអន្តរជាតិ និងផ្សព្វផ្សាយសៀវភៅ "ហ៊ុន សែន កម្ពុជា", ២ តុលា ២០១៩

... **អតិរេកសាច់ប្រាក់មកដល់ពេលនេះ ដោយមិនគិតអំពីប្រាក់បម្រុងអន្តរជាតិដែលមកដល់ក្នុងខែ៨ កន្លងទៅ មានជាង ១៥ពាន់លាន(ដុល្លារអាមេរិក) ជាមួយនឹងមាស ៣០តោននោះទេ។** មាសមរតកដើម តម្កល់នៅស្ទឹស ដែលបានការប្រគល់ឱ្យមកវិញមានចំនួន ១២តោន។ មាសដែលធនាគារជាតិទិញ ហើយទុកនៅទីក្រុងឡុងដ៏ ប្រទេសអង់គ្លេសមាន ១៥តោន និងមាសដែលធនាគារជាតិតម្កល់ទុកនៅទីក្រុងភ្នំពេញ ៣តោន។ អញ្ចឹងយើងមាន ៣០តោន។ តែទំហំហ្នឹងតិចតួចទេ **បើគិតជាប្រាក់បម្រុងដែលយើងមានតាំងពី ០ ដុល្លារ(អាមេរិក) រហូតទៅដល់ ១៥ពាន់លាន(ដុល្លារអាមេរិក)។ យើងអត់ប៉ះពាល់ទេ។ សាច់ប្រាក់ដែលយើងមានសព្វថ្ងៃជិត ៤ពាន់លាន(ដុល្លារអាមេរិក) សម្រាប់ចាយរាល់ថ្ងៃ** ...។

២៣. គ្រប់គ្រងឱ្យចំណូលលើសផែនការ និងចំណាយមិនឱ្យលើសផែនការ

ពិធីចែកសញ្ញាបត្រជូននិស្សិតនៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា, ១១ ធ្នូ ២០១៩

... យើងមានថវិកាជាសាច់ប្រាក់ដែលអាចចាយបានភ្លាម ប្រមាណជា ៣៥០០ លានដុល្លារ។ នេះមិនបានគិតពីទុនបម្រុងអន្តរជាតិប្រមាណជា ១៥០០០ លាន (ដុល្លារ) និងមាស ៣០ តោននោះទេ ... យើងតែងតែមានការត្រៀមទុកជាយថាហេតុសំរាប់គ្រោះអាក្រក់ ដូចជាទឹកជំនន់ឬការាំងស្ងួត។ ដល់ទៅផុត(រដូវប្រឈមនឹង)គ្រោះទឹកជំនន់ ទើបយើងបែងចែកថវិកាសល់ឱ្យទៅក្រសួង/ស្ថាប័នមួយចំនួន ដែលមានតម្រូវការបន្ថែម ... នេះជា**យន្តការគ្រប់គ្រងថវិកា តាមបែបអគ្គបញ្ជាការតែមួយនិងអគ្គសេនាធិការតែមួយ។ អគ្គបញ្ជាការគឺនាយករដ្ឋមន្ត្រី និងអគ្គសេនាធិការគឺរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលគ្រប់គ្រងយ៉ាងហ្មត់ចត់ មិនគ្រាន់តែប្រាក់ចំណូលចំណាយទេ តែក៏ចំណូល(ត្រូវឱ្យ)លើសផែនការ ឯចំណាយប្រហែលឱ្យបានត្រឹមតែគ្រប់ផែនការ គឺមិនឱ្យលើសផែនការទេ** ...។

២៤. ដោយសេដ្ឋកិច្ចមិនច្បាស់លាស់ ផ្អាកដំឡើងប្រាក់ខែដល់មន្ត្រីរាជការឆ្នាំ២០២១

ព្រីនស៍ ម៉ាណ័រ (Prince Manor), កៀនស្វាយ, កណ្តាល, ៧ តុលា ២០២០

... បកមកឯណេះវិញ សូមកោតសរសើរចំពោះការខិតខំ ហើយសូមក្រើនរំលឹកបុគ្គលិកនៅទីនេះអោយមានការប្រយ័ត្នប្រយែង បង្ការការឆ្លង Covid-19។ នេះប្រហែលសុទ្ធតែមន្ត្រីភូមិ-ឃុំ របស់យើង។ ឥឡូវនិយាយត្រង់នេះទុកឱ្យហើយ។ សុំទោសទុកឱ្យហើយ។ ឯកឧត្តម (ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីសេដ្ឋកិច្ចហិរញ្ញវត្ថុ) អូន ព័ន្ធមុន្នីវ័ត្ន បានគ្រោងឡើងប្រាក់ខែ ប៉ុន្តែខ្ញុំបានប្រាប់ថា **"ដោយសារសេដ្ឋកិច្ចមិនច្បាស់លាស់ សុំផ្អាកការដំឡើងឆ្នាំ២០២១"។ អញ្ចឹង សុំទោសទុកឱ្យហើយ។ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ រក្សាទុកនូវប្រាក់បៀវត្សជាដែល តែប្រាក់ឧបត្ថម្ភសម្រាប់ចូលឆ្នាំ និងភ្ជុំ ហ្នឹងនៅបន្តឱ្យ** ...។

២៥. ថវិកានិងជំនួយពី ៥ប្រភព ប្រើប្រាស់ក្នុងគ្រាប្រយុទ្ធនឹងកូវីដ-១៩

ប្រសាសន៍ក្នុងសន្និសីទសារព័ត៌មាន បើកយុទ្ធនាការចាក់វ៉ាក់សាំងការពារ
កូវីដ-១៩ ជូនជនវ័យជំទង់ អាយុពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ, ១ សីហា ២០២១

... ក្នុងពេលកន្លងទៅ យើងមិនត្រឹមតែចំណាយលើ(ការប្រយុទ្ធនឹង)កូវីដ-១៩ ប៉ុណ្ណោះទេ តែក៏មានទាំងគ្រោះទឹកជំនន់ផងដែរ ... យើងមិនចាយក៏មិនបាន ... ហេតុអ្វី រដ្ឋាភិបាលកម្ពុជា ដែលគេនិយាយថានឹងរលំក្នុងប៉ុន្មានខែ តែនៅតែ(មានអត្ថិភាព)ជាដែល? ខ្ញុំគួរតែប្រាប់ថា យើងមានថវិកាពី ៥ប្រភពមកចំណាយ ដែលក្នុងនោះ ...**ប្រភពទី១ (យើងមាន)ចំណូលចរន្តជាមធ្យមក្នុងមួយខែ ប្រមាណ ៤០០លានដុល្លារ ... ប្រភពទី២ យើងបានសន្សំសាច់ប្រាក់ជាង ៣ពាន់លានដុល្លារ** មុនពេលកូវីដ-១៩ មកដល់ ... **ប្រភពទី៣ មានការចូលរួមពីព្រះមហាក្សត្រ សម្តេចម៉ែ សប្បុរជនស្ម័គ្រចិត្ត** ... សរុបជាង ១៤០លានដុល្លារ ... **ប្រភពទី ៤ ការគាំទ្រថវិកាពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ** ... មានធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី មានធនាគារពិភពលោកខ្លះ ធនាគារអឺរ៉ុប ... និង**ប្រភពទី៥ គឺជំនួយទ្វេភាគីពីប្រទេសមួយចំនួន** មានចិន ជប៉ុន សហរដ្ឋអាមេរិក អង់គ្លេស អូស្ត្រាលី វៀតណាម ថៃ ... ជាសម្ភារពេទ្យ វ៉ាក់សាំង រថយន្តដឹកអ្នកជំងឺ ថ្នាំពេទ្យ សម្ភារបរិក្ខារ ...។

២៦. គ្រាកូវីដ-១៩ ចំណូលធ្លាក់ តែអាចទ្រទ្រង់ចំណាយនិងវិនិយោគហេដ្ឋារចនាសម្ព័ន្ធ

ប្រសាសន៍ក្នុងសន្និសីទសារព័ត៌មាន បើកយុទ្ធនាការចាក់វ៉ាក់សាំងការពារ
កូវីដ-១៩ ជូនជនវ័យជំទង់ អាយុពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ, ១ សីហា ២០២១

... ចំណូលចរន្តរបស់យើងក្នុងមួយខែមានជាមធ្យមប្រមាណ ៤០០លានដុល្លារ ... **បើទោះបីជាចំណូលធ្លាក់ចុះ ក៏យើងក៏នៅតែអាចទ្រទ្រង់ការចំណាយបាន ... គិតមកដល់ម្សិលមិញនេះ ចំណូល ៧ខែរបស់យើង មិនទាន់គិតចំណូលសារពើពន្ធ គិតតែចំណូលពន្ធដារនិងគយបានចំនួន ៣០៦១លានដុល្លារអាមេរិក ... នៅសល់ ៥ខែទៀត ដែលយ៉ាងហោចណាស់ក៏បាន ២ពាន់លានទៀត**។ ដូចនេះក្នុងមួយឆ្នាំ ៥ពាន់លាន គឺជាមធ្យមប្រមាណ ៤០០លាន/ខែ។ មិនមែនយើងចាយតែលើការប្រយុទ្ធប្រឆាំងកូវីដ-១៩ទេ តែក៏បន្តចាយវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ... ទោះបីកូវីដ-១៩ ផ្ទុះឡើង ក៏យើងនៅតែធ្វើផ្លូវ។ ចំណាយអស់ប៉ុន្មានរយលានដុល្លារនៅក្រុងព្រះសីហនុ ... ឥឡូវដំណើរការសាងសង់ផ្លូវ ៣៨ ខ្សែ នៅសៀមរាប ... អត់មានថយទេ ទាំងវិនិយោគផ្ទាល់ទាំងថវិកាបដិភាគ ...។

២៧. កម្ពុជាមិនស្នើសុំផ្អាកសងម្ចាស់កម្ចីទេ ហើយក៏មិនចុះហត្ថលេខាខ្ចីលុយថែម

ប្រសាសន៍ក្នុងសន្និសីទសារព័ត៌មាន បើកយុទ្ធនាការចាក់វ៉ាក់សាំងការពារ
កូវីដ-១៩ ជូនជនវ័យជំទង់ អាយុពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ, ១ សីហា ២០២១

...យើងមិនទាន់មានស្នើសុំទៅប្រទេសម្ចាស់កម្ចីផ្អាកការសងទេ។ យើងនៅតែសងគេដដែល។ ពិតមែនហើយ ឆ្នាំនេះយើងមិនទាន់មានចុះហត្ថលេខាខ្ចីលុយអ្នកណាទេ គឺមានតែចុះហត្ថលេខាលើហិរញ្ញប្បទានជំនួយឥតសំណងៗ មែនហើយមានហិរញ្ញប្បទានទិញវ៉ាក់សាំងដែរ។ (ប្រាក់)ADB ចំនួន ៩៥លានហ្នឹង គេឱ្យមកទិញវ៉ាក់សាំង ... អញ្ចឹង រឿងអីដែលថារដ្ឋាភិបាល ហ៊ុន សែន ដួលៗ ខ្លះនិយាយសុទ្ធតែថា ហ៊ុន សែន ចេញលុយអស់ពីឃ្លាំងហើយ ... (បើថាមើលពី) ចំណូល ត្រឹមប្រាក់បៀវត្ស(បូកទាំង)ប្រាក់ខែនិវត្តជនស្មើៗ ថា(ចំណាយ)២៥០លាន(ដុល្លារ)ទៅចុះក្នុងមួយខែ។ អញ្ចឹងសល់ ១៥០លាន(ដុល្លារ)ទៀត សំរាប់ចាយលើមុខនេះ/មុខនោះ ...។

២៨. គ្រាកូវីដ-១៩ ចាយប្រាក់សន្សំអស់១/៣ តែមិនរំខានប្រាក់បំរុងអន្តរជាតិនិងមាសទេ

ប្រសាសន៍ក្នុងសន្និសីទសារព័ត៌មាន បើកយុទ្ធនាការចាក់វ៉ាក់សាំងការពារ
កូវីដ-១៩ ជូនជនវ័យជំទង់ អាយុពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ, ១ សីហា ២០២១

...យើងបានសន្សំសាច់ប្រាក់ជាង ៣ពាន់លានដុល្លារ កាលពីមុនកូវីដ-១៩ មកដល់។ យើងទទួលស្គាល់ថាមកដល់ពេលនេះ យើងបានចាយអស់ ១ភាគ៣ ទៅហើយ។ បានសេចក្តីថា **យើងចាយប្រាក់សន្សំអស់ជាង ១ពាន់លាន(ដុល្លារ)។ ឥឡូវយើងនៅសល់សាច់ប្រាក់ប្រមាណជាង ២ពាន់លាន(ដុល្លារ)។ ហ្នឹងហៅថាសាច់ប្រាក់។ យើងមិនរំខានដល់ប្រាក់បម្រុងអន្តរជាតិ ២០ពាន់លាន(ដុល្លារ) និងមាសប្រមាណប៉ុន្មានសិបតោននោះទេ**។ តែយើងទទួលស្គាល់ថា បានចាយប្រាក់សន្សំដែលមានជាង ៣ពាន់លាន(ដុល្លារ) ប្រមាណ ១ភាគ៣ ហើយ ...។

២៩. មិនយល់ស្របនឹងការបង្កើនការខ្ចីដល់ពិដាន៤០%

សំណេះសំណាលជាមួយនិស្សិត និងប្រជាពលរដ្ឋខ្មែរ កំពុងសិក្សា និងរស់នៅ
ប្រទេសជប៉ុន, ៧ តុលា ២០១៨

... ចុងខែនេះ យើងនឹងមានការប្រជុំឆ្លងចប្បាប់ថវិកា ... ដែលយើងគ្រោងថានឹងមានកំណើន៧% អត្រាអតិផរណា៣,៥% អត្រាប្តូរប្រាក់ ៤០៥០រៀល/ដុល្លារ ... បើយោងលើការវាយតម្លៃ ពីពេលនេះរហូតដល់ដាច់ឆ្នាំ គ្មានរញ្ជួយផែនដីគ្មានស្អី **កំណើនសេដ្ឋកិច្ចកម្ពុជានឹងលើសពី៧%។ អត្រាអតិផរណាដែលធនាគារជាតិវាយតម្លៃចុងក្រោយមានត្រឹម ២,៥% ជាមួយទុនបម្រុងអន្តរជាតិជិត ១០ពាន់លានបន្ថែមដោយមាសមួយចំនួន ... ខាងស្ថាប័នហិរញ្ញវត្ថុបានផ្តល់អនុសាសន៍ឲ្យកម្ពុជាបង្កើនការខ្ចីដល់៤០% គឺឲ្យដល់ពិដាន ព្រោះអនុបាតសម្រាប់ការខ្ចីពីបរទេសមានដល់៤០%នៃផលិតផលសរុប។ ឯយើងទើបនឹងជំពាក់គេ២៣% បូកទាំងបំណុលចាស់ដែលសល់តាំងពីសម័យមុន។ ទោះបីមានយោបល់បែបនេះក៏ដោយ ខ្ញុំមិនយល់ស្របទេ**។ ខ្ចីត្រូវគិតពីសមត្ថភាពសង ហើយខិតខំសន្សំទុនក្នុងស្រុកដើម្បីមួយផ្នែកតម្លើងប្រាក់ខែមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងមួយផ្នែកទៀតរុញទៅវិនិយោគខ្លួនឯង ...។

៣០. រាជរដ្ឋាភិបាលសន្សំប្រាក់បម្រើតម្រូវការចំណាយចរន្ត និងហេដ្ឋារចនាសម្ព័ន្ធ

បើកការដ្ឋានស្ថាបនាផ្លូវ ៣៤ខ្សែ តម្លៃ ២៩៤លានដុល្លារ ក្នុងខេត្តព្រះសីហនុ,
១៦ វិច្ឆិកា ២០១៩

... គម្រោងបរទេសទាំងអស់ តម្រូវឱ្យរាជរដ្ឋាភិបាលមានថវិកាបដិភាគ ទើបអាចអនុវត្តគម្រោងបាន។ **រាជរដ្ឋាភិបាលត្រូវតែមានការសន្សំប្រាក់។ ប្រាក់សន្សំនោះយកទៅបម្រើឱ្យសេចក្តីត្រូវការចំណាយជាប្រចាំ ឬហៅថាចំណាយចរន្ត** (ដែលមាន)រាប់ទាំងបៀវត្សរ៍មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ដែលនៅសល់តែមួយខែទៀតនឹងឡើងបៀវត្សរ៍មួយដំណាក់ និងដល់ចូលទៅដល់ចូលឆ្នាំខ្មែរ ត្រូវឡើងបៀវត្សរ៍មួយដំណាក់ទៀត។ ក្រៅពីនោះ ក៏ត្រូវចំណាយទៅលើសុខុមាលភាព និងផ្តត់ផ្តង់ មន្ទីរពេទ្យថ្នាំពេទ្យ កសាងអគារសិក្សាក្នុងវិស័យអប់រំ និងវិស័យច្រើនណាស់។ មិនមែនគ្រាន់តែចំណាយលើប្រាក់ខែមួយមុខទេ។ **ទុនដែលនៅសល់ពីការចំណាយនោះ គឺជាប្រាក់សន្សំសម្រាប់ការវិនិយោគ បម្រើឱ្យសេចក្តីត្រូវការរបស់ប្រជាជន មានជាផ្លូវថ្នល់ ប្រឡាយទឹក ទំនប់ទឹក** ... និងអ្វីៗ ដែលជាសេចក្តីត្រូវការរបស់ជាតិ ...។

៣១. បន្តមិនយកភាគលាភចេញពីប្រាក់ចំណេញអគ្គិសនីកម្ពុជា ៥ឆ្នាំ ២០២០-២០២៥

ក្នុងឱកាសអញ្ជើញដឹកនាំកិច្ចប្រជុំគណៈរដ្ឋមន្ត្រី, ២៥ តុលា ២០១៩

... ខ្ញុំបានសម្រេចហើយ គឺជម្រុញផែនការឱ្យគ្រប់ភូមិមានអគ្គិសនីពីបណ្តាញជាតិប្រើប្រាស់។ ការកែទម្រង់ស៊ីជម្រៅក្នុងវិស័យថាមពល ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ ធ្វើឱ្យ៩២%នៃចំនួនភូមិសរុបទូទាំងប្រទេស ១៤.១៦៨ភូមិ បានទទួលអគ្គិសនី ដែលមានថ្លៃសមរម្យ ពីបណ្តាញជាតិហើយ។ ដើម្បីជម្រុញឱ្យគ្រប់ភូមិក្នុងប្រទេសមានថ្លៃអគ្គិសនីដូចគ្នា **ខ្ញុំបានសម្រេចកាលពីថ្ងៃ២២ ខែតុលា ឆ្នាំ២០១៩ ឱ្យរាជរដ្ឋាភិបាលបន្តមិនយកភាគលាភចេញពីប្រាក់ចំណេញ ចេញពីការអាជីវកម្មរបស់អគ្គិសនីកម្ពុជាពីឆ្នាំ២០២០-២០២៥ ដោយរក្សាទុកថវិកានេះ ជាការវិនិយោគបន្ថែមរបស់រដ្ឋ ជួយពង្រីកបណ្តាញអគ្គិសនីទៅតំបន់ជនបទ ជាពិសេសតំបន់ដែលប្រជាពលរដ្ឋមិនទាន់អគ្គិសនីផ្ទាល់ពីបណ្តាញជាតិ** ... ការមិនកាត់យកភាគលាភពី ៥ឆ្នាំកន្លងទៅ បានជួយអគ្គិសនីកម្ពុជាបង្កើនទុនវិនិយោគមានលទ្ធភាពពង្រីកបណ្តាញអគ្គិសនីទៅប្រជាជនតំបន់ជនបទប្រកបដោយផ្លែផ្កា ...។

៣២. ផ្អាកចំណាយតាមក្រសួង/ស្ថាប័ន៥% លើកលែង ៣ស្ថាប័ន បន្តយ៉ាង២៥%

ពិធីចែកសញ្ញាបត្រដល់និស្សិត នៃវិទ្យាស្ថាន វ៉ាន់ដា, ១០ មីនា ២០២០

... ខ្ញុំបានបញ្ជាឱ្យផ្អាកការចំណាយមួយចំនួន។ **ក្រសួងមួយចំនួនត្រូវកាត់បន្ថយការចំណាយ៥០%។ (មាន)ក្រសួង ៣៖ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេស និងក្រសួងពាណិជ្ជកម្មដែលធ្វើការទាក់ទងបរទេសច្រើន ឱ្យកាត់បន្ថយ ២៥%។ ប្រសិនបើការកាត់បន្ថយរបស់យើង គ្មានរឿងអីកើតឡើង ហើយសល់លុយហ្នឹង ក៏វាអត់ផ្លូវទេ។ ការដ្ឋានខ្លះដែលមិនចាំបាច់ យើងផ្អាកការបើកការដ្ឋានសិន**។ ពន្យារពេលរហូតដល់ពេលដែល Covid-19 ទៅផុតចាំបើកការដ្ឋាន ... យើងសន្សំថវិកាទុកសង្គ្រោះសេដ្ឋកិច្ច ... ឥឡូវត្រៀមបម្រុងថវិកា ៣០លានដុល្លារ បំពេញបន្ថែមឱ្យការចំណាយលើសុខាភិបាល បន្ថែមលើច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ... ការបម្រុងទុកដែលយើងត្រូវប៉ះប៉ូវឱ្យសេដ្ឋកិច្ច ក្នុងរយៈពេល ៦ខែនៃការកើតឡើងនូវការប្រឈមជំងឺ ប្រមាណជា ៨០០លាន(ដុល្លារ) បើសិនវាមិនកើតទេ វាសល់ ៨០០លាន(ដុល្លារ) ...។

៣៣. តែងតែបានត្រៀមថវិកាបដិភាគកសាងអភិវឌ្ឍផ្លូវស្ពាន

បើកការដ្ឋានសាងសង់ផ្លូវល្បឿនលឿន ក្រុងភ្នំពេញ-ខេត្តព្រះសីហនុ, ២២ មីនា ២០១៩

... សូមនិយាយរឿងមួយ។ ផ្លូវច្បារអំពៅតែ ៤គីឡូម៉ែត្រទេ ជប៉ុនចេញថវិកាសាងសង់ ១២លានដុល្លារ ឯរាជរដ្ឋាភិបាលចេញថវិកាសំណងសម្រាប់ប្រជាជន ១៤លានដុល្លារ។ ប៉ុន្តែ កន្លែងហ្នឹងត្រូវដោះស្រាយអញ្ចឹង ... **គ្រាន់តែដើមឆ្នាំនេះ មិនទាន់គ្រប់ ៣ខែផង ខ្ញុំស៊ើញ្ចើរបញ្ចេញថវិកាប្រមាណជិត ១០០លានដុល្លារអាមេរិកជាថវិកាបដិភាគ ... កន្លែងខ្លះ ៣លានដុល្លារ កន្លែងខ្លះ ៥លានដុល្លារ កន្លែងខ្លះ ៦លានដុល្លារ។ ជីកប្រឡាយទឹកអោយគាត់ហើយ ត្រូវទិញដីគាត់ថែមទៀត។ ត្រូវចេញលុយជិត ១០០លានដុល្លារ។ អញ្ចឹងហើយបានជាខ្ញុំនិយាយ ដើម្បីអភិវឌ្ឍគម្រោងមួយបាន ចាំបាច់ត្រូវតែមានទុនក្នុងដៃធ្វើជាថវិកាបដិភាគ។** នៅក្របខណ្ឌខ្លះ យើងចេញដល់ទៅ៣០%។ បើគម្រោងហ្នឹងថ្លៃ ១០០លានដុល្លារ យើងត្រូវចេញ ៣០លានដុល្លារ។ ដូចនេះ យើងត្រូវសន្សំលុយ កុំគ្រប់គ្រងសេដ្ឋកិច្ចតាមរបៀបកញ្ជើឆ្កុះ។ បើធ្វើសេដ្ឋកិច្ចតាមរបៀបកញ្ជើឆ្កុះ គម្រោងអីក៏អត់អនុវត្តបានដែរ។ សូម្បីតែគេអោយលុយមកហើយ ក៏យើងយកមកធ្វើអីអត់កើត ព្រោះយើងអត់មានលុយធ្វើបដិភាគ។ កុំឃើញសល់សាច់លុយច្រើនក្នុងរតនាគារ សុំចាយថែមៗ។ អត់អោយចាយថែមទេ។ ទុកលុយធ្វើបដិភាគ។ បើមិនកសាងផ្លូវខ្លួនឯងទេ គឺយកថវិកាហ្នឹងទៅធ្វើបដិភាគកសាងផ្លូវដែលដៃគូបានផ្តល់មក ...។

៣៤. ចំណាយច្រើន និងនៅត្រៀមចំណាយ មិនប្រកាសធ្វើផ្លូវពីល្វាឯមទៅផ្លូវជាតិ១១

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផ្លូវជាតិលេខ ១១ តភ្ជាប់រវាងខេត្តព្រៃវែងទៅខេត្តត្បូងឃ្មុំ, ៦ ធ្នូ ២០២១

...ហេតុអ្វីបានជាខ្ញុំមិនប្រកាសធ្វើផ្លូវនេះ(ពីស្រុកល្វាឯមមកកាន់ផ្លូវជាតិលេខ ១១) ដែលបានសិក្សារួចហើយ(ថាមាន) តម្លៃ ៧០ លានដុល្លារសហរដ្ឋអាមេរិក? វាមានការប្រទាក់ក្រឡាគ្នាជាមួយនឹងបញ្ហាហិរញ្ញប្បទាន។ តើយើងរកលុយបានពីណាពិតប្រាកដដើម្បីយកមកធ្វើ។ យើងបានចំណាយច្រើនណាស់ ហើយនិងត្រៀមចំណាយក្នុងមួយខែៗ ... នេះគ្រាន់តែគិតចំណាយសង្គមទេ អត់ទាន់គិត

ចំណាយទៅលើការព្យាបាលជំងឺ ឧបត្ថម្ភសម្រាប់គ្រូពេទ្យ ... ការបើកប្រទេស(មក)ក្នុងមួយខែ ឃើញថាស្ថានការណ៍សេដ្ឋកិច្ចយើងចាប់ផ្តើមរើ។ តម្រូវការខាងក្នុង(ប្រទេស)មានច្រើន តម្រូវការនាំចូលក៏មានច្រើនដែរ។ អញ្ចឹងខាងក្នុងពន្ធក៏ច្រើនផ្នែកគយចាប់ផ្តើម ...៕

៣៥. ស្តាយមិនបានចាយប្រាក់សន្សំដើម្បីពន្លឿនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ

សម្តេចតេជោ ហ៊ុន សែន ផ្នែកសួរឆ្លើយក្នុងសន្និសីទសារព័ត៌មាននៅវិមានរដ្ឋសភា, ២២ សីហា ២០២៣

... ការដឹកនាំតែងតែមានការពេញចិត្ត និងការមិនពេញចិត្ត ឬហូតទៅដល់ការខកចិត្ត។ តើអ្វីខ្លះដែលជាការខកចិត្ត(របស់ខ្ញុំ)។ ខ្ញុំមិននិយាយពីការពេញចិត្តទេ ត្បិតការពេញចិត្តនោះ អង្គុយមួយថ្ងៃក៏និយាយមិនចង់អស់ផង។ ឯការខកចិត្តវាមានចំណុចរបស់វា ... ការខកចិត្តចុងក្រោយរបស់ខ្ញុំគឺ កម្ពុជាដែលធ្លាប់តែមានកំណើន(សេដ្ឋកិច្ច)ជិស្តិរភាពមួយ ដល់ជាង ៧% ក្នុងមួយឆ្នាំ ត្រូវបានកូវីដ១៩ បន្ថយបង្អាក់ ហើយអត្រាភាពក្រីក្រដែលបានបញ្ចុះមកនៅក្រោម ១០%ទៅហើយនោះ វាក៏បានកើនឡើងវិញ។ ប្រាក់សន្សំប្រមាណជិត ៤ពាន់លានដុល្លារ ដែលខ្ញុំប៉ុនប៉ងថាប្រើដើម្បីធ្វើហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា ដោយមិនពឹងផ្អែកបរទេសក៏ត្រូវបាត់បង់ ដោយ(យើងត្រូវ)យកមកទប់ទល់ជាមួយនឹងកូវីដ-១៩ ព្រមជាមួយការចិញ្ចឹមប្រជាជន ... **(ដូចនេះ)ការខកចិត្តនៅដំណាក់កាលចុងក្រោយ គឺខណៈប្រទេសកំពុងតែមានលឿនទៅមុខ យើងបែជាបាត់បង់ប្រាក់ដែលបានសន្សំសំរាប់ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីពន្លឿនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ...**៕

៣៦. ខួបទី៧០ ថ្ងៃបង្កើតគយនៅកម្ពុជា ដោយបំបែកចេញពីសហភាពគយឥណ្ឌូចិន

ពិធីសម្ពោធអគាររដ្ឋបាលគយនិងរដ្ឋាករ ព្រមទាំងសាលាជាតិគយ និងសារមន្ទីរគយ, ២៣ ធ្នូ ២០២១, ២៣ ធ្នូ ២០២១

... និយាយអំពីប្រវត្តិវិញ មកដល់ពេលនេះគឺខួបលើកទី៧០ នៃថ្ងៃបង្កើតគយនៅកម្ពុជា។ **បើយើងនិយាយអំពីខួបលើកទី៧០ ឆ្នាំនេះយើងទើបនឹងប្រារព្ធពិធីខួបលើកទី៦៨ នៃថ្ងៃឯករាជ្យជាតិរបស់យើង។ ដូច្នេះ មានន័យថាម៉េច ... យើងត្រូវសំដែងការគោរពនូវការដឹងគុណចំពោះព្រះករុណា ព្រះមហាក្សត្រ ដែលពេលនោះ ព្រះអង្គបានធ្វើព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យមួយដំហានម្តងៗ ពីផ្នែកមួយទៅកាន់ផ្នែកមួយ។ កុំភ្លេចថាគយនេះ ជាសេវាអធិបតេយ្យ ជាចំណែកមួយនៃឯករាជ្យភាពរបស់យើង។ ដូច្នេះ ព្រះអង្គបានទាមទារបង្កើតឡើងនូវរដ្ឋបាលគយកម្ពុជា ដោយបំបែកចេញពីសហភាពគយឥណ្ឌូចិន។** មានន័យថា ជាស្នាព្រះហស្តដ៏ធំរបស់ព្រះអង្គមួយទៀត ដែលយើងត្រូវមើលឃើញ ហើយដែលមានរូបភាពចាក់បញ្ចាំងផ្សាយតាមទូរទស្សន៍ជាតិ ... ក្រៅពីរូបភាពស្តីពីព្រះរាជដំណើររបស់ព្រះអង្គទៅកាន់តំបន់ស្វយ័តសៀមរាប ឬតំបន់ដទៃទៀត គឺពាក់ព័ន្ធនឹងការតស៊ូលើវិស័យនានាទាមទារនូវឯករាជ្យជាដំណាក់ៗ និងជាផ្នែកៗ ទម្រាំបានឯករាជ្យពេញលេញនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ គឺថេរៈវេលា ៩០ឆ្នាំគត់ ដែលបារាំងត្រួតត្រាលើកម្ពុជា ...៕

៣៧. ព្រះបរមរតនកោដ្ឋទាមទារគយពីបារាំង ២ឆ្នាំ(១៩៥១) មុនឯករាជ្យថ្ងៃ ៩វិច្ឆិកា ១៩៥៣

ពិធីសម្ពោធអគាររដ្ឋបាលគយនិងរដ្ឋាករ ព្រមទាំងសាលាជាតិគយ និងសារមន្ទីរគយ, ២៣ ធ្នូ ២០២១, ២៣ ធ្នូ ២០២១

... មុននឹងបានឯករាជ្យ អ្វីដែលពិសេស គឺពេលដែលវត្តមានបារាំងលើទឹកដីខ្មែរ ព្រះអង្គបានទាមទារជាផ្នែកៗ កាលពីដំណាក់កាលនោះ។ ផ្នែកមួយនៃឯករាជ្យរបស់យើង គឺការទាមទារបំបែក(គយ)ចេញពីសហភាពគយឥណ្ឌូចិន។ អ្នកខ្លះចោទយើងអំពីបក្សកុម្មុយនិស្តឥណ្ឌូចិន ឬសហព័ន្ធឥណ្ឌូចិន ដែលរៀបចំដោយប្រធានហូ ជីមិញរបស់វៀតណាម។ ក៏ប៉ុន្តែយើងមិនត្រូវភ្លេចហើយកុំមួលបង្កាច់ប្រវត្តិសាស្ត្រឱ្យសោះ។ ពាក្យ ឥណ្ឌូចិន ឬសហភាពឥណ្ឌូចិន គឺជាពាក្យរបស់បារាំងទេ។ បារាំងជាអ្នកបង្កើតពាក្យសហភាពឥណ្ឌូចិននេះ។ អគ្គទេសាភិបាលនៅឯវៀតណាម។ ឯយើង នៅឯវត្តភ្នំ គឺ CDC រាល់ថ្ងៃនេះមានត្រឹមតែទេសាភិបាលទេ។ នៅឡាវ ក៏មានត្រឹមតែទេសាភិបាលដែរ។ គេចាត់ទុកប្រទេស ៣ ដូចជាប្រទេសតែមួយ នៅក្រោមការត្រួតត្រារបស់បារាំងដូចគ្នា។ នៅកម្ពុជា ... **ព្រះករុណា ព្រះមហាក្សត្រ បានតស៊ូតាមរបៀបរបស់ព្រះអង្គគឺមិនប្រើអាវុធ ប៉ុន្តែ(ប្រើ)បញ្ញាដើម្បីដោះស្រាយបញ្ហា រហូតធ្វើឱ្យបារាំងដកចេញ ... មុននឹងមកដល់ថ្ងៃ ៩វិច្ឆិកា ព្រះអង្គបានធ្វើកិច្ចការនេះមុន ២ឆ្នាំ។ បានសេចក្តីថា កើតនៅឆ្នាំ ១៩៥១។ អញ្ចឹង ២ឆ្នាំមុនបានឯករាជ្យពេញលេញ ...**៕

៣៨. សារមន្ទីរគយ ជាទីតាំងប្រវត្តិសាស្ត្រនៃព្រះរាជបូជនីយ៍កិច្ច

ពិធីសម្ពោធអគាររដ្ឋបាលគយនិងរដ្ឋាករ ព្រមទាំងសាលាជាតិគយ និងសារមន្ទីរគយ, ២៣ ធ្នូ ២០២១, ២៣ ធ្នូ ២០២១

... សូម្បីតែទីតាំងមួយនេះ **យើងរក្សាទុកជាសារមន្ទីរ(គយ) គឺជាទីតាំងប្រវត្តិសាស្ត្រដែលកសាងនៅក្នុងឆ្នាំ១៩៦៥** (ដូចមាន)នៅក្នុងរបាយការណ៍ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន។ សមិទ្ធផលច្រើនទៀត ដែលបានកសាងនៅក្នុងដំណាក់កាលនោះ។ នេះគ្រាន់តែជាការរំលឹក ដើម្បីយើងអាចដឹងអំពីប្រវត្តិថាចាប់ផ្តើមពីទីណា។ **ប្រសិនបើជាគ្មានព្រះរាជបូជនីយ៍កិច្ចនេះ ប្រហែលកម្ពុជានៅតែជាដែនដីមួយរបស់បារាំងនៅឯនាយសមុទ្រ** ដូចជាអគ្គរដ្ឋទូតបារាំងធ្លាប់បានជួបនិងនិយាយជាមួយខ្ញុំថា នៅក្នុងប៉ាស៊ីហ្វិកនេះ គឺមានជនជាតិបារាំងប្រមាណជាង ២លាននាក់នៅតាមកោះនានា។ នេះជាចំណុចដែលថា យើងទទួលទានទឹក ត្រូវឃើញប្រភពទឹកចេញពីណា? យើងទទួលទានផ្លែឈើ តើនរណាជាអ្នកដាំដើមឈើនោះ?

៣៩. រដ្ឋាភិបាលបណ្តោះអាសន្ន ថ្ងៃ ០៨មករា ១៩៧៩ មិនទាន់មានក្រសួង

ពិធីសម្ពោធអគាររដ្ឋបាលគយនិងរដ្ឋាករ ព្រមទាំងសាលាជាតិគយ និងសារមន្ទីរគយ, ២៣ ធ្នូ ២០២១, ២៣ ធ្នូ ២០២១

... គួររំលឹកដល់ឯកឧត្តម តាំង សារឹម ដែលពេលនោះត្រូវបានចាត់តាំងជាប្រធានគណៈកម្មការពាណិជ្ជកម្ម ក្រោយមកហៅថាជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ ខ្ញុំសុំលើកត្រង់ចំណុចនេះបន្តិច ដើម្បីជាការចែករំលែកដល់អ្នកជំនាន់ក្រោយ ឱ្យបានដឹង។ **រដ្ឋាភិបាលបណ្តោះអាសន្ន ដែលបង្កើតនៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៩ ពុំមានក្រសួងពាណិជ្ជកម្ម ពុំមានក្រសួងឧស្សាហកម្ម ពុំមានក្រសួងកសិកម្ម និងក្រសួងហិរញ្ញវត្ថុ ឬធនាគារទេ។ មានតែក្រសួងសេដ្ឋកិច្ច និងជីវភាព មួយគត់។** ខ្ញុំនៅចាំបានរឿងនេះ ព្រោះខ្ញុំជាអ្នកចូលរួមពិភាក្សាពីការរៀបចំក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ... គឺប្រើពាក្យទទួលបន្ទុកយ៉ាងដូច្នេះ។ មិនមានក្រសួងឧស្សាហកម្ម ក្រសួងស្មីៗ ទេ មានតែក្រសួងសេដ្ឋកិច្ចនិងជីវភាព។ មកដល់ទីក្រុងភ្នំពេញនេះ យើងបង្កើតគណៈកម្មការទេ តែចង់ថាគណៈកម្មការទាំងនេះចំណុះឱ្យក្រសួង

សេដ្ឋកិច្ចនិងជីវភាពរួមមាន គណៈកម្មការពាណិជ្ជកម្ម គណៈកម្មការហិរញ្ញវត្ថុ គណៈកម្មការឧស្សាហកម្ម គណៈកម្មការកសិកម្ម ... បន្តពីគណៈកម្មការហិរញ្ញវត្ថុ ដែលដឹកនាំដោយ បង ចាន់ ភិន នៅពេលនោះ និងមានគណៈកម្មការសង្គមកិច្ច។ ក្រោយមកក៏បានអ្នកទាំងនោះក្លាយទៅជារដ្ឋមន្ត្រីទាំងអស់ ...។

៤០. ផ្ទេរគយពីក្រសួងពាណិជ្ជកម្មទៅក្រសួងហិរញ្ញវត្ថុ

ពិធីសម្ពោធអគាររដ្ឋបាលគយនិងរដ្ឋាករ ព្រមទាំងសាលាជាតិគយ និងសារមន្ទីរគយ, ២៣ ធ្នូ ២០២១, ២៣ ធ្នូ ២០២១

... ពីដំបូង គយមិនចំណុះក្រសួងហិរញ្ញវត្ថុទេ គឺចំណុះក្រសួងពាណិជ្ជកម្ម។ **នៅពេលដែលខ្ញុំមកកាន់តំណែងជានាយករដ្ឋមន្ត្រី ក៏គិតថា បើទាត់បាល់ផង ធ្វើអាប៊ីតផង មិនបានទេ។ ព្រោះអី? ក្រសួងពាណិជ្ជកម្មជាក្រសួងនាំចេញនាំចូលរួចហើយគយមកកាន់ខ្លួនឯងទៀត អញ្ចឹងវាមិនចប់រឿង? ដូច្នេះហើយបានជាត្រូវផ្ទេរគយពីក្រសួងពាណិជ្ជកម្ម មកកាន់ក្រសួងហិរញ្ញវត្ថុ ដែលពេលនោះបង តាំង សារឹម ជារដ្ឋមន្ត្រីពាណិជ្ជកម្ម និងបង ចាន់ ភិន ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ...** មុនពេលដែលឯកឧត្តម ឆាយ ឋន ចូលទៅជំនួសបង ចាន់ ភិន ... យើងក៏គួរតែគោរពដល់អ្នកដែលបានបង្កើតស្ថាប័នគយនេះឡើង។ ការពិតទៅបង តាំង សារឹម គាត់មានទស្សនវិស័យច្រើន គាត់មានការរៀបចំច្រើន ... ស ហូ ប្រធានគយមុនគេ។ បន្ទាប់ពី ស ហូ បានដល់ អ៊ិន សារឿន បន្ទាប់ទៅបានដល់ ប៉ែន ស៊ីម៉ន ហើយចប់ពី ប៉ែន ស៊ីម៉ន បានមកដល់ គុណ ញឹម សព្វថ្ងៃនេះ ...។

៤១. ក្រសួងហិរញ្ញវត្ថុទទួលគយ ក្រសួងពាណិជ្ជកម្មប្រគល់គយ

ខួបលើកទី៦៥ នៃការបង្កើតស្ថាប័នគយនិងរដ្ឋាករកម្ពុជា, ២៩ មិថុនា ១៩៥១ - ២៩ មិថុនា ២០១៦

... អំពីការផ្ទេរទទួលនៅពេលនោះ ឯកឧត្តម ចាន់ ភិន ដែលធ្លាប់ធ្វើជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏មិនធ្វើជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតទៅទៀតទេ គឺឯកឧត្តម ឆាយ ឋន (បានទទួលមុខតំណែងជំនួស) ... ខ្ញុំធ្វើជានាយករដ្ឋមន្ត្រីផង និងជារដ្ឋមន្ត្រីការបរទេសផង។ ប៉ុន្តែ ខ្ញុំក៏ផ្ទេរទៅឲ្យមនុស្សម្នាក់ដែលមិនបានការ និងបន្ទាប់ទៅខ្ញុំក៏ត្រូវកាន់ឡើងវិញ នូវ(តំណែង)រដ្ឋមន្ត្រីការ

បរទេស។ ខ្ញុំនៅចាំបានថា **ក្រសួងដែលទទួលយកគយ គឺឯកឧត្តម ឆាយ ថន ឯ ក្រសួងដែលប្រគល់គយ គឺលោកជំទាវ ហូ ណន**។ សូមធ្វើការស្វែងយល់ ... ខ្ញុំតែង ប្រគល់សិទ្ធិឲ្យឧបនាយករដ្ឋមន្ត្រីប្រចាំការ ចុះហត្ថលេខាលើអនុក្រឹត្យជាច្រើន ជំនួសឲ្យខ្ញុំ។ បើមិនឯកឧត្តម ជា សុទ្ធ ក៏សម្តេចចៅហ្វាវាំង គង់ សំអុល ...៕

៤២. បញ្ចប់កាំកុងត្រូល រដ្ឋបាត់ ៣០លាន វិស័យឯកជនចំណេញ ៤០លាន

ពិធីសំណេះសំណាលជាមួយកម្មករ និយោជិត នៅខេត្តកំពត, ២៥ មករា ២០១៩

... ខ្ញុំបានធ្វើការសម្រេច ទី១ ចុះហត្ថលេខាលើអនុក្រឹត្យបញ្ចប់វត្តមានកាំកុង ត្រូលតាមមាត់ច្រកទាំងអស់ ដើម្បីកាត់បន្ថយភាពសាំញ៉ាំលើការនាំចេញ/នាំចូល ក្នុងដំណើរការធ្វើធុរកិច្ច ...គោលដៅរបស់ខ្ញុំទុកតែ២ទេ គឺនគរបាលអន្តោប្រវេសន៍ និងគយ។ បើសិនជាមាននៅសល់ខាងផ្នែកកសិកម្ម ខាងផ្នែកអីទៀត ដកទៀតតែ ធ្វើនៅពេលក្រោយ ... **(ការបញ្ចប់វត្តមាន)កាំកុងត្រូល ដែលធ្លាប់មាននៅទីនោះ (រដ្ឋត្រូវបាត់បង់)ប្រាក់ចំណូលប្រមាណជា ៣០លានដុល្លារអាមេរិក ... តែវិស័យ ឯកជននឹងចំណេញ ៤០លានដុល្លារសហរដ្ឋអាមេរិក**។ ព្រោះអី? បង់ផ្លូវការ ប្រហែល ៣០លានដុល្លារ តែមិនផ្លូវការប្រហែល ១០លាន ...៕

៤៣. លុបកាំសាប លុបពន្ធកាត់ទុក មិនលក់/ដូរអធិបតេយ្យនឹងអ្នកណាជាច់ខាត

សំណេះសំណាលជាមួយប្រជាពលរដ្ឋ និងនិស្សិតខ្មែរ មកពីបណ្តាប្រទេស ក្នុងសហគមន៍អឺរុប, ៤ កក្កដា ២០១៩

... កំណែទម្រង់ដែលយើងបានធ្វើកន្លងទៅ គ្រាន់តែពាក់ព័ន្ធជាមួយសេវាដឹក ជញ្ជូននិងសេវានៅកំពង់ផែ បានកាត់បន្ថយថ្លៃដើមការផលិតយ៉ាងច្រើន ឧ. ដក កាំកុងត្រូល។ សេវានេះត្រូវចំណាយពេលវេលារបស់ធុរជន និងចំណាយប្រាក់ កាសរបស់ធុរជន។ យើងដកចេញ។ **លុបចោលអង្គភាពមួយដែលមានអាយុ ៤០ ឆ្នាំ គឺអង្គភាពកាំសាប។ យើងហ៊ានធ្វើ។ មុននេះ យើងស្ទេនគ្រប់កុងតែន័រ តែ ឥឡូវយើងស្ទេនកុងតែន័រណាដែលមានការសង្ស័យតែប៉ុណ្ណោះ។ រឿងបង់ថ្លៃវា ម្យ៉ាង តែរឿងយឺតយ៉ាវគឺជារឿងម្យ៉ាង។ ពន្ធកាត់ទុក ក៏យើងត្រូវលុបចោលទៀត។ អញ្ចឹង គ្រាន់តែទំហំការកាត់បន្ថយនេះ បើសិនជាគេតម្រូវឱ្យបង់ពន្ធ យើងក៏រកស៊ី**

បង់ពន្ធដែរ។ យើងមិនលក់អធិបតេយ្យ ឬយកអធិបតេយ្យទៅដូរជាមួយអ្នកណា ឡើយ។ យើងគ្រាន់តែសុំឱ្យប្រព្រឹត្តដោយយុត្តិធម៌ចំពោះយើងតែប៉ុណ្ណោះ ...៕

៤៤. សូមរួសាន់បង់ពន្ធរថយន្តដើម្បីទទួលបាននូវភាពអនុគ្រោះ ១០ភាគរយ

សម្ពោធសណ្ឋាគារ Hyatt Regency ភ្នំពេញ, ១៥ ធ្នូ ២០២១

... ថ្ងៃនេះ គឺថ្ងៃទី១៥(ធ្នូ) ហើយនៅតែ ១៥ថ្ងៃទៀតទេ(នឹងដល់កាលបរិច្ឆេទ ផាកពិន័យ)។ **សូមអំពាវនាវម្ចាស់រថយន្តមិនទាន់បានបង់ពន្ធ អញ្ជើញមកបង់ពន្ធ ឲ្យបានរួសាន់ដើម្បីទទួលបានភាពអនុគ្រោះ ១០ភាគរយ ... ដោយយើងមិនឲ្យ មានព្រឹត្តិការណ៍ច្រំដែលកើតឡើងតទៅទៀតទេ ទាក់ទងនឹងរថយន្តមិនបង់ពន្ធ ជ្រកក្រោមផ្ទាំកលេខនេះឬលេខនោះ ហើយក៏មិនឲ្យមានវត្តមាន(បើកបរ) មិនថា តែលើផ្លូវជាតិទេ ឲ្យតែបើកលើផ្លូវ**។ រថយន្តចង្កូតស្តាំ ត្រូវកែទៅឆ្វេង។ អញ្ចឹង អ្នក មិនបានបង់ពន្ធ រួសាន់មកបង់ពន្ធ។ ក្រោយថ្ងៃ ៣១ធ្នូ បង់ពន្ធពេញ អត់បាន(ការ អនុគ្រោះ) ១០ភាគរយទេ ...៕

៤៥. អ្នកជាប់ពន្ធត្រូវតែបង់ពន្ធ ដើម្បីដួយកពន្ធទៅអភិវឌ្ឍ

ពិធីចែកសញ្ញាបត្រជូននិស្សិតនៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា, ១១ ធ្នូ ២០១៩

... សមិទ្ធផលទាំងនេះ បានមកពីការខិតខំទាំងអស់គ្នា។ សូម្បីតែ(នៅទី)នេះ មួយឆ្នាំៗ បង់ពន្ធមិនតិចទេ។ សាស្ត្រាចារ្យមួយចំនួនត្រូវបង់ពន្ធ ... អ្នកជាប់ពន្ធ ទាំងឡាយត្រូវតែអនុវត្តនូវកម្មវិធីបង់ពន្ធ។ ពន្ធលើប្រាក់បៀវត្សរ៍ក៏ត្រូវតែបង់។ ពីមួយឆ្នាំទៅមួយឆ្នាំ ពន្ធលើប្រាក់បៀវត្សក៏ច្រើនដែរ ព្រោះមនុស្សចូលធ្វើការបាន ប្រាក់ខែច្រើន។ អញ្ចឹង ត្រូវកាត់ពន្ធបន្តិចមក។ **ពន្ធហ្នឹងយកទៅធ្វើអី? សន្សំ យកទៅធ្វើផ្លូវ ធ្វើប្រឡាយទឹក ទិញថ្នាំពេទ្យ កសាងមន្ទីរពេទ្យ នោះហើយជា តម្រូវការរបស់យើង។ យើងមានផ្ទះសម្បែង បង់ពន្ធអចលនទ្រព្យបន្តិចទៅ**។ (អ្នកប្រើប្រាស់)ឡាន កុំគេចពន្ធ។ ត្រូវបង់ពន្ធនាំចូល បង់ពន្ធផ្លូវ ...៕

៤៦. សូមធនាគារ/មីក្រូហិរញ្ញវត្ថុ បន្ធូរបន្ថយការប្រាក់ឬការសងដល់អ្នករងគ្រោះដោយទឹក ជំនន់

ប្រគល់សញ្ញាបត្រជូននិស្សិតជ័យលាភី នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង, ១៧ តុលា ២០២២

... **ខ្ញុំព្រះករុណាខ្ញុំសូមអំពាវនាវ ចំពោះផ្នែកធនាគារ និងមីក្រូហិរញ្ញវត្ថុ ផ្តល់ការអនុគ្រោះ សម្រាប់អ្នកដែលទទួលផលប៉ះពាល់ពីគ្រោះទឹកជំនន់នេះ តាមរយៈនៃការពន្យារពេល សម្រាប់ការសង (និង)បន្ធូរបន្ថយការប្រាក់ ឬតាមរយៈការរៀបចំឥណទានឡើងវិញ**។ សូមយោគយល់ ចំពោះការលំបាករបស់ប្រជាពលរដ្ឋ ដែល(មានការ)លិចលង់ ហើយយើងទៅរឹបអូសផ្ទះសម្បែង (និង/ឬ)ដីធ្លីរបស់គាត់ទៅតាមកិច្ចសន្យាដើមវាមិនត្រូវទេ។ ខ្ញុំសូមឱ្យធនាគារជាតិ នៃកម្ពុជា ធ្វើការប្រជុំមួយជាមួយម្ចាស់គ្រឹះស្ថានហិរញ្ញវត្ថុ ដើម្បីឱ្យគ្រឹះស្ថានហិរញ្ញវត្ថុផ្តល់ការ(យោគយល់)។ ខ្ញុំក៏អំពាវនាវត្រង់ទៅកាន់គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ ចូលរួមសម្រាលបន្ទុក ផ្តល់ការអនុគ្រោះដល់អ្នកខ្វីឥណទាន ដែលរងផលប៉ះពាល់ តាមរយៈការពន្យារពេលសង(និង/ឬ)បន្ធូរបន្ថយអត្រាការប្រាក់ និងរៀបចំឥណទានឡើងវិញ ... មនុស្ស ១០ម៉ឺនគ្រួសារ មានអ្នកដែលទទួលរងផលប៉ះពាល់ដែលលំបាក យើងគិតថា ១៨% អញ្ចឹង ប្រមាណជិត ២ម៉ឺនគ្រួសារដែលត្រូវទទួលបានអន្តរាគមន៍...។

៤៧. ប្រទេសជាច្រើននិងស្ថាប័នហិរញ្ញវត្ថុជាច្រើន វាយតម្លៃខុសពីការវិឌ្ឍរបស់កម្ពុជា

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៥១ ប្រវែង ៣៧គីឡូម៉ែត្រ
ចាប់ពីឧដុង្គ ផ្លូវជាតិលេខ៥ ដល់ថ្នល់ទទឹង ផ្លូវជាតិលេខ៤, ២៥ មីនា ២០២២

... **ក្នុងជំនាន់ទសវត្សរ៍៩០ ប្រទេសជាច្រើននិងស្ថាប័នហិរញ្ញវត្ថុជាច្រើន វាយតម្លៃខុសអំពីការវិឌ្ឍរបស់កម្ពុជា** បានជាពេលនោះ ប្រទេសខ្លះ និងស្ថាប័នហិរញ្ញវត្ថុខ្លះ បាន(សំរេច)ធ្វើផ្លូវឱ្យយើង(ទទឹង)ត្រឹមតែ ៧ ម៉ែត្រតែប៉ុណ្ណឹង ឬខ្ពស់បំផុត ១០ម៉ែត្រ។ វាអត់បានដល់ ១០ម៉ែត្រហ្នឹងទៀត។ សូម្បីតែផ្លូវជាតិលេខ៤ រាល់ថ្ងៃហ្នឹង កន្លែងខ្លះនៅ ៧ម៉ែត្រដដែលហ្នឹង។ ទើបនឹងពង្រីកបន្តហ្នឹង។ (ពួកគេ)វាយតម្លៃខុសអំពីការកែចម្រើនរបស់កម្ពុជា ដែលពេលនោះក៏ត្រូវធ្វើផ្លូវ(ទទឹង) ត្រឹមតែ៧ម៉ែត្រ។ កន្លែងធ្លាប់ធ្វើផ្លូវ(ទំហំ) ៧ម៉ែត្រ ឥឡូវទៅជា ២៤ម៉ែត្រ ២៥ម៉ែត្រ ទើបដោះស្រាយបានបញ្ហា(កកស្ទះ)។ **គេក៏មិននឹងស្មានថាមានការវិឌ្ឍលឿនបែបនេះ** ...។

៤៨. បាត់ EBA មិនមែនបាត់ទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋនោះទេ

បិទសន្និបាតត្រួតពិនិត្យការងារ ឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩
ក្រសួងមហាផ្ទៃ, ១៤ កុម្ភៈ ២០១៩

... សូមបញ្ជាក់ជូនអ្នកឯងអោយបានច្បាស់ថា ពេលនេះម៉ោងនេះ បើទោះគ្មានចំណូលបន្ថែមរដ្ឋាភិបាលហ៊ុនសែនមានសមត្ថភាពបើកប្រាក់ខែជូនមនុស្សទាំងអស់រយៈពេល ១២ ខែ ដោយមិនចាំបាច់មានចំណូលថ្មី ... យើងបាននិយាយហើយ ការដក EBA គឺមានតំលៃស្មើនឹងសម្លាប់បក្សប្រឆាំង ... ខ្ញុំបានណែនាំផ្ទៃក្នុងរួចហើយ។ អំពើខុសច្បាប់ណាមួយដែលកើតលើទឹកដីកម្ពុជា ត្រូវតែប្រើវិធានផ្លូវច្បាប់ដើម្បីចាត់ការ។ **យើងត្រូវខិតខំដើម្បីឈានឆ្ពោះទៅរកភាពឯករាជ្យទាំងនយោបាយ និងសេដ្ឋកិច្ច។ វាមិនបានធ្វើឲ្យមានការរង្គោះរង្គើនៅក្នុងទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋនោះទេ។ រកស៊ីបង់ពន្ធឲ្យគ្នា។ ទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋនៅតែបន្ត។ មិនមែនបានសេចក្តីថា ដកហូតភាពអនុគ្រោះ ហើយផ្តាច់ទំនាក់ទំនងខាងការទូតនោះទេ** ...។

៤៩. មាន EBA ក៏មិនក្លាយជាអ្នកមាន បាត់ EBA ក៏វាមិនស្លាប់

សំណេះសំណាលជាមួយប្រជាពលរដ្ឋ និងនិស្សិតខ្មែរ មកពីបណ្តាប្រទេស
ក្នុងសហគមន៍អឺរុប, ៤ កក្កដា ២០១៩

... តើបានមើលការសម្ភាសន៍របស់លោកជំទាវ (Cecilia) Malmström ទេ? និយាយអំពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាង EU ជាមួយវៀតណាមក្នុងពេលដែលព្រមានចំពោះកម្ពុជា មីយ៉ាន់ម៉ា និងបង់ក្លាដែស។ ខ្ញុំបានមើលដោយយកចិត្តទុកដាក់នូវបទសម្ភាសន៍នេះ។ **ខ្ញុំបានបញ្ជាក់ហើយ "មាន EBA ក៏មិនអាចក្លាយទៅជាអ្នកមាន បាត់ EBA ក៏វាមិនងាប់ទេ"។ តែយើងត្រូវប្រើងខ្លួនឯងមួយជាពីរ។ អ្វីដែលខ្ញុំបារម្ភមិនមែនបញ្ហាបាត់ EBA ឬមិនបាត់ EBA ទេ តែបារម្ភក្រែងលោមានភាពស្តឹកស្រពន់ក្នុងមន្ត្រីរាជការរបស់យើង**។ ត្រឡប់ទៅវិញនឹងមានការប្រជុំបក្សនៅថ្ងៃទី ១០ មានពេលមួយព្រឹកដើម្បីខ្ញុំនិយាយ ... EBA ជាស្អី? វាជាប្រព័ន្ធអនុគ្រោះ សម្រាប់ប្រទេសដែលមិនទាន់រីកចម្រើន។ វានឹងបាត់នៅពេលណាមួយ ... ឱ្យតែសេដ្ឋកិច្ចយើងឡើងបន្តិចវាបាត់ហើយ ... ប្រទេសមាន

ការលូតលាស់ជាងយើង ជាងឡាវ ជាងមីយ៉ាន់ម៉ា ដូចជាថៃ វៀតណាម ឥណ្ឌូនេស៊ី ម៉ាឡេស៊ី គេមិនបានទទួល EBA ហ្នឹងទេ។ ប្រទេសនៅអាហ្វ្រិកមួយចំនួន គេអត់លេងចូលទេ។ ព្រោះគេដឹង។ គេមិនយកផង ...។

៥0. មេរៀនវិបត្តិសេដ្ឋកិច្ច ៣លើក៖ "លោតមិនទាន់ខ្ពស់ ធ្លាក់មកវិញមិនឈឺខ្លាំង"

សំណេះសំណាលជាមួយកម្មកររោងចក្រនៅក្បែរវត្តព្រៃស្ពឺ ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ, ២៨ មិថុនា ២0២៣

... ការប៉ះទង្គិចខាងសេដ្ឋកិច្ច តាមការចំណាំមើល មាន ៣លើកហើយ ដូច **ជាវិបត្តិហិរញ្ញវត្ថុអាស៊ីឆ្នាំ ១៩៩៧-១៩៩៨ មានផលប៉ះពាល់តិចទេសំរាប់កម្ពុជា។ ដោយសារអ្វី? កម្ពុជាបានដាក់ឲ្យប្រើប្រាស់ទាំងប្រាក់រៀលនិងប្រាក់រូបិយបណ្ណបរទេសនៅលើទីផ្សាររបស់ខ្លួន។ អញ្ចឹង ផលប៉ះពាល់នៅកម្ពុជាមានមិនធំទេ។ ខ្ញុំបាននិយាយថា "លោតមិនទាន់ខ្ពស់ ធ្លាក់មកវិញក៏មិនឈឺខ្លាំងដែរ"**។ ពេលនោះ សេដ្ឋកិច្ចយើងនៅតូច។ ដល់**វិបត្តិសេដ្ឋកិច្ចហិរញ្ញវត្ថុឆ្នាំ ២00៨-២00៩ ផលប៉ះពាល់ទាក់ទងទៅនឹងអតិផរណា ក៏មានមិនជាធំទេ ដោយសារយើងប្រើការទូទាត់ (ជារូបិយប័ណ្ណ)ចម្រុះ។ ដល់ឥឡូវវិបត្តិដំណាក់កាលកូវីដ-១៩ និងនិងដំណាក់កាលសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន បូកជាមួយនឹងទណ្ឌកម្មជាឯកតោភាគី ធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចទូទាំងពិភពលោក**។ អតិផរណាតាមប្រទេសនានាឡើងកប់ពពក។ កម្ពុជាយើងនៅរក្សាកម្លាំងទិញរបស់កម្មករ ដោយយកវិធានការម្ខាងខិតខំដំឡើងបៀវត្ស៍ តែម្ខាងទៀតក៏ខិតខំកម្រិតតម្លៃទំនិញឱ្យនៅទាបតាមដែលអាចធ្វើទៅបាន ...។

៥១. ADB សន្យាផ្តល់ ៦0ម៉ឺនដុល្លារសំរាប់ការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

សម្ពោធ អគារឥន្ទ្រទេវី នៃរាជបណ្ឌិត្យសភាកម្ពុជា, ២១ វិច្ឆិកា ២0១៩

... **ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចបានបង្កើតនៅឆ្នាំ២00២។ ពេលនោះ ធនាគារអភិវឌ្ឍន៍អាស៊ីបានសន្យានឹងផ្តល់ជំនួយ ៦0ម៉ឺនដុល្លារសហរដ្ឋអាមេរិក ដើម្បីបង្កើត(ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ច) ក្នុងគោលបំណងធ្វើឱ្យមានសង្គតិភាពលើការរៀបចំសុន្ទរកថារបស់នាយករដ្ឋមន្ត្រី។** ជួនកាល ស្ថាប័នមួយមកព្រៀងសុន្ទរកថា ចង់បានលើចំណុចនេះ រវាងពីរសុន្ទរកថានៅទីកន្លែងមួយ ទៅសុន្ទរកថាមួយ

ទៀត នៅកាន់កន្លែងមួយទៀត មិនដូចគ្នា។ វាមិនមានសង្គតិភាពទេ។ ចង់ឱ្យវាមានដាលក្ខណៈស្រាវជ្រាវក្នុងក្របខណ្ឌជាយុទ្ធសាស្ត្រ ... ដល់បង្កើតបានហើយ វាអត់បានលុយ ៦0ម៉ឺនដុល្លារនោះ។ មូលហេតុអី? ... **គោលដៅរបស់ADB គឺ រុញគ្រូមកបង្រៀន។ ឯយើងដាក់មនុស្សដូចជា ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន, ហង្សជួន ណារ៉ុន និងបណ្ឌិតមួយចំនួនទៀត ក៏បាត់លុយ ៦0ម៉ឺនដុល្លារបណ្តាយ។ ទោះបីមកដល់ម៉ោងនេះក៏ដោយ ADB គួរបញ្ចេញការិការអីមួយ ទោះឱ្យ ៦៣ន់ដុល្លារក៏បានដែរ។** សន្យាឱ្យលុយគ្នា ៦0ម៉ឺនដុល្លារបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ។ ដល់ទៅឥឡូវ ទទេស្អាត។ មូលហេតុដែលទទេស្អាត ព្រោះយើងដាក់មនុស្សទៅវាខ្លាំង។ ដល់ខ្លាំង គាត់ថា មិនមានការចាំបាច់ដើម្បីហ្វឹកហ្វឺនផង ...។

៥២. អាចសម្រេចគោលដៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់និងចំណូលខ្ពស់

តំណាងទូទាំងប្រទេសលើកទី៤ សហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក), ២៧ វិច្ឆិកា ២0១៨

... ពេលនេះ កម្ពុជាកំពុងស្ថិតក្នុងក្របខ័ណ្ឌជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ តែយើងមានគោលដៅក្លាយជា**ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២0៣0 និងក្លាយទៅជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ ២0៥0** ... ដែលហៅថា ប្រទេសមានចំណូលកំរិតទាបគឺ ៩៩៥ដុល្លារ (អាមេរិក) ចុះ ... ចាប់ពី ៩៩៦-៣.៨៩៥ដុល្លារ(អាមេរិក) ចាត់ទុកជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ ចាប់ពី ៣.៨៩៦-១២.0៥៥ ដុល្លារ(អាមេរិក)ជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់។ ចាប់ពី ១២.0៥៥ ដុល្លារ (អាមេរិក)ឡើងទៅ ចាត់ទុកជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់។ ឥឡូវនេះ យើងកំពុងស្ថិតនៅប្រាក់ចំណូល ១.៥៦៣ ដុល្លារ (អាមេរិក) ឆ្នាំក្រោយយើងនឹងឡើងទៅដល់ ១.៧0៥ ដុល្លារ (អាមេរិក)។ តាមការព្យាករ នៅឆ្នាំ ២0២១ យើងអាចនឹងឡើងទៅដល់លើស ២.000 (ដុល្លារ អាមេរិក)។ **អញ្ចឹង (ឆ្នាំ) ២0៣0 ខ្ញុំគិតថា យើងនឹងសម្រេចគោលដៅក្លាយទៅជាប្រទេស ដែលមានប្រាក់ចំណូលលើសពី ៣.៨00(ដុល្លារអាមេរិក)។ អាចទៅរួច។ យើងត្រូវប្រឹងធ្វើទាំងអស់គ្នាដើម្បីសម្រេចកំណើនសេដ្ឋកិច្ច៧% ក្នុងមួយឆ្នាំ** ...។

៥៣. អត្រានៃភាពក្រីក្រ៥៣% នៅឆ្នាំ២០០៤ ធ្លាក់មកនៅត្រឹម១៣.៥% នៅឆ្នាំ២០១៤

ការជួបសំណេះសំណាលជាមួយបងប្អូនខ្មែរនៅប្រទេសស្ទីស, ២៣ តុលា ២០១៨

... យើងត្រូវខិតខំរួមគ្នារក្សាសន្តិភាព។ ដោយសារសន្តិភាព កំណើនសេដ្ឋកិច្ច របស់យើងលឿន។ ខ្ញុំសូមបញ្ជាក់ថា**ឆ្នាំ២០០៤ អត្រានៃភាពក្រីក្រនៅសល់ ៥៣% ឯណោះ តែឆ្នាំ២០១៤ ត្រូវជា ១០ឆ្នាំក្រោយ យើងទម្លាក់អត្រានៃភាពក្រីក្រមកនៅ ១៣.៥%។ ឥឡូវ ៤ឆ្នាំបន្ទាប់ទៀត យើងអត់ទាន់បានធ្វើអង្កេតឡើងវិញ ដូច្នេះ យើងនៅប្រើតួលេខចាស់។ ឆ្នាំ២០១៤ អត្រានៃភាពក្រីក្រនៅសល់ ១៣.៥% ប៉ុន្តែយោងទៅលើកំណើនសេដ្ឋកិច្ច៧% អត្រានៃភាពក្រីក្រធ្លាក់ជាង ១% ក្នុងមួយឆ្នាំ ដូច្នេះ ពេលនេះអត្រានៃភាពក្រីក្ររបស់យើងនៅម្តុំ៩%។** យើងនឹងធ្វើអង្កេតឡើងវិញ។ យើងបានប្តូរផ្តាស់ពីប្រទេសមួយមានប្រាក់ចំណូលរាប់សិបដុល្លារ(អាមេរិក) មកកើនដល់ ១.៥៥៦(ដុល្លារអាមេរិក)។ ខ្ញុំសង្ឃឹមថា ចប់អាណត្តិរាជរដ្ឋាភិបាលអាណត្តិទី៦ មនុស្សម្នាក់ៗ នឹងមានប្រាក់ចំណូលលើសពី ២.០០០ (ដុល្លារអាមេរិក) ...៕

៥៤. កម្ពុជារក្សាបានអធិបតេយ្យក្នុងការខ្ចីបុល

កម្មវិធីសំណួរ/ចម្លើយ បន្ទាប់ពីសន្និសីទអន្តរជាតិលើកទី ២៥ ស្តីពី«អនាគតអាស៊ី» នៅទីក្រុងតូក្យូ ប្រទេសជប៉ុន, ៣០ ឧសភា ២០១៩

... ខ្ញុំបានលឺគេនិយាយច្រើនថា "កម្ពុជាអាចនឹងធ្លាក់ក្នុងអន្ទាក់បំណុល (គឺអន្ទាក់)នៃបំណុលរបស់ចិន"។ និយាយមួយបែប មិនមែនគ្រាន់តែជាទំនាក់ទំនងរវាងផ្លូវមួយខ្សែក្រវាត់មួយទេ។ ក៏ប៉ុន្តែ ខ្ញុំអាចបញ្ជាក់បានថា **មិនដល់កម្រិតនោះទេ។ (មាន)ប្រទេសខ្លះជំពាក់បំណុលបរទេសរហូតទៅដល់២០០% ឬ៣០០% ឬ ៥០០% នៃ GDP ប៉ុន្តែមិនមែនបានជំពាក់ចិនឯណា។ អញ្ចឹងវាមិនមែនជាអន្ទាក់របស់ចិនទេ។ប្រទេសខ្លះមិនបានជំពាក់ចិនទេ តែជំពាក់(បរទេស)តាំងពីពេលមុន ចិនមាននយោបាយផ្លូវមួយខ្សែក្រវាត់មួយឯណោះ។រីឯកម្ពុជារក្សាបានអធិបតេយ្យក្នុងការខ្ចីបុល។ យើងខ្ចីខ្លីតាមគម្រោងដែលយើងខ្ចីត្រូវការ ហើយចិនគោរពនូវការសម្រេចរបស់យើង។ ខ្ញុំសូមគូសបញ្ជាក់ថា ចិនមិនបានបង្ខំឲ្យយើងធ្វើនេះ ឬធ្វើនោះទេ។ ចិនបានគោរពនូវការសម្រេចចិត្តរបស់កម្ពុជា** ...៕

៥៥. កម្ពុជាទើបនឹងជំពាក់បំណុលបរទេស២១,៥% នៃអនុបាត៤០%

កម្មវិធីសំណួរ/ចម្លើយ បន្ទាប់ពីសន្និសីទអន្តរជាតិលើកទី ២៥ ស្តីពី«អនាគតអាស៊ី» នៅទីក្រុងតូក្យូ ប្រទេសជប៉ុន, ៣០ ឧសភា ២០១៩

... យើងបានខ្ចីនូវអ្វីដែលហៅថា "ឥណទានសម្បទាន"(មាន)អត្រាការប្រាក់ទាបនិងរយៈពេលសងវែង។ យើងត្រូវធ្វើរឿងនេះជាបន្តទៀត មិនមែនតែជាមួយប្រទេសចិនទេ តែជាមួយជប៉ុន ជាមួយស្ថាប័នហិរញ្ញវត្ថុដទៃទៀត យើងក៏នៅតែបន្តនិងធ្វើការងារនេះ។ មួយទៀត យើងខ្ញុំមានការប្រុងប្រយ័ត្នខ្ពស់លើការខ្ចីបុលពីបរទេស។ មកដល់ពេលនេះ **និយាយពីបំណុលបរទេស(កម្ពុជា)ទើបនឹងមានបំណុលស្មើនឹង២១,៥% នៃអនុបាតអនុញ្ញាតឲ្យខ្ចី ៤០% ទេ។ យើងខ្ញុំទើបនឹងជំពាក់ត្រឹមតែ២១,៥% (នៃផសស)ប៉ុណ្ណោះ។ គ្រប់គ្នាត្រូវមើលឃើញនូវចំណុចនេះ** ...៕

៥៦. ទាក់ទាញវិនិយោគថ្មី តាមរូបមន្តមួយបូក

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់សេដ្ឋកិច្ចពិសេសនាងកុក ខេត្តកោះកុង, ១៣ មីនា ២០១៩

... ខ្ញុំបានជួបគណៈប្រតិភូរបស់ជប៉ុន។ ខ្ញុំស្នើគាត់។ នេះក៏ជាចំណុចជោគជ័យដែរ គេហៅថា រូបមន្តមួយបូក។ អ្វីទៅរូបមន្តមួយបូក? យើងមិនអាចស្នើជប៉ុន ឬប្រទេសដទៃឲ្យរើរោងចក្រចេញពីប្រទេសថៃ រើរោងចក្រចេញពីប្រទេសម៉ាឡេស៊ី រើរោងចក្រចេញពីប្រទេសចិន រើរោងចក្រចេញពីប្រទេសវៀតណាម មកកាន់ប្រទេសរបស់យើងទេ? **យើងអនុវត្តតាមរបៀបគេហៅថារូបមន្តមួយបូក។ គេមានទីតាំងធំរោងចក្រដែលធ្វើរាប់សិបឆ្នាំហើយនៅក្នុងប្រទេសថៃ គេមកបើកសាខារោងចក្រនៅក្នុងប្រទេសកម្ពុជា។ រូបមន្តនេះវាសមស្រប ដែលយើងមិនទាមទារឲ្យមានការផ្ទេររោងចក្រទាំងស្រុងទេ។ នេះហៅថា រូបមន្តមួយបូក**។ មានរោងចក្រមួយនៅទីក្រុងភ្នំពេញ គឺចេញពីថៃចូលមកក្នុងកម្ពុជា។ ឥឡូវដល់មកក្នុងកម្ពុជាសឹងតែធំជាងនៅក្នុងប្រទេសថៃទៅវិញ។ បន្តិចទៀតកម្ពុជាបូកថៃទៅវិញ។ ពីមុនថៃបូកកម្ពុជា។ នៅពេលមានការវិឌ្ឍកាន់តែខ្ពស់នៅកម្ពុជា វាទៅជា កម្ពុជាបូកថៃ ...៕

៥៧. វិនិយោគិនក្រៅប្រទេស មានសិទ្ធិវិនិយោគ១០០% មិនបាច់ដៃគូ/ភាគហ៊ុនក្នុងស្រុក

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល, ២០ កុម្ភៈ២០១៩

... យើងអត់ប្រកាន់ថាប្រទេសណា ហើយគ្មានការរើសអើងបែងចែករវាងអ្នកវិនិយោគក្នុងស្រុក និងអ្នកវិនិយោគមកពីក្រៅប្រទេសទេ។ **អ្នកវិនិយោគមកពីក្រៅប្រទេសមានសិទ្ធិវិនិយោគ ១០០ភាគរយ ដោយមិនចាំបាច់មានដៃគូក្នុងស្រុក ឬភាគហ៊ុនក្នុងស្រុក។ នេះជាចំណុចពិសេសនៃគោលនយោបាយបើកចំហរបស់រាជរដ្ឋាភិបាលកម្ពុជា**។ ប្រទេសខ្លះតម្រូវឲ្យមានភាគហ៊ុនក្នុងស្រុក។ កម្ពុជាមិនតម្រូវដូចនោះទេ។ អ្នកទាំងឡាយដាក់ភាគហ៊ុន ១០០ភាគរយ ខ្លួនឯងចុះ ហើយយើងក៏មិនកំណត់ការនាំចេញប្រាក់ចំណេញទៅក្រៅប្រទេសទេ។ យើងមិនមានកំណត់ទេ។ ប៉ុន្តែ យើងកាន់តែស្វាគមន៍ថែមទៀត ពេលដែលប្រាក់ចំណេញរបស់អ្នកត្រូវបានប្រើប្រាស់ពង្រីកអាជីវកម្មបន្ថែមទៀតក្នុងប្រទេស។ យើងលើកទឹកចិត្ត ...៕

៥៨. គោលនយោបាយសេដ្ឋកិច្ចផ្តាយព្រឹក ឬហ៊ុនសែនណូមិក បើកចំហសំរាប់វិនិយោគិន

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល, ២០ កុម្ភៈ២០១៩

... កម្ពុជាមិនប្រកាន់ថាប្រទេសណា អ្នកវិនិយោគក្នុងស្រុក និង/ឬអ្នកវិនិយោគមកពីក្រៅប្រទេសទេ ... **គោលនយោបាយសេដ្ឋកិច្ចរបស់យើង អាចចាត់ទុកថា ជាគោលនយោបាយសេដ្ឋកិច្ចផ្តាយព្រឹកដែលវាគ្មានពេលអស្តង្គតទេ។ នេះជាគោលនយោបាយ ហ៊ុនសែនណូមិក ឬប្រៀបដូចជានយោបាយសេដ្ឋកិច្ចផ្តាយព្រឹកដែលវាគ្មានពេលវេលាដែលនឹងអស្តង្គតទេ**។ ព្រឹកណាក៏វាមានផ្តាយព្រឹករះដែរ។ រយៈពេល ៤០ឆ្នាំកន្លងផុត ជាពិសេស រយៈពេល ៣៤ឆ្នាំនេះ ក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រីរូបនេះ តាំងពីក្មួយៗ ឱពុកម្តាយ ជីដូនជីតា របស់ក្មួយៗ តាំងពីរកស្បែកជើងពាក់មិនបាន ... ពួកគាត់បានរួមដំណើរជាមួយពូ ... ជាមួយគណបក្សប្រជាជនតាំងពីគ្រាដែលលំបាកបំផុត ...៕

៥៩. ពិចារណាឆៀរយក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុរៀបចំស្តុកប្រេងឥន្ធនៈជាយុទ្ធសាស្ត្រ

សម្ពោធដាក់ឱ្យប្រើប្រាស់ស្ពានអាកាស និងផ្លូវក្រោមដីចោមចៅ, ថ្ងៃ៣១ មីនា ២០២២

... ទាក់ទងនឹងប្រេង បើឡើង(ថ្លៃ)គ្រប់ប្រទេស ផលប៉ះពាល់បណ្តាលពីសង្គ្រាមរុស្ស៊ីនិងអ៊ុយក្រែនមកដល់ហើយ។ ការដោះស្រាយតម្រូវការនៅពេលខាងមុខយ៉ាងម៉េច។ ខ្ញុំកំពុងតែគិតថា **ឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំស្តុកប្រេងយុទ្ធសាស្ត្រ។ ពីមុន យើងផ្តែកលើវិស័យឯកជនរៀបចំស្តុកយុទ្ធសាស្ត្រ។ ឥឡូវយើងត្រូវបង្កើនការស្តុកទុកប្រេងឥន្ធនៈ។ ឧទាហរណ៍ថា រ៉ាអ៊ីអគ្គិសនីរបស់យើង ឬក៏ម៉ាស៊ីនភ្លើងដើរដោយធ្យូងថ្មរត់វាមិនគ្រប់ដូចនៅឆ្នាំ២០១៨ អញ្ចឹងយើងក៏ត្រូវតែជម្រុញការបញ្ឆេះម៉ាស៊ីនដែលដើរដោយប្រេងឥន្ធនៈ។** យើងបានទិញម៉ាស៊ីនផលិតអគ្គិសនី ៤០០មេហ្គាវ៉ាត់មកដាក់ក្បែររាជធានីភ្នំពេញ។ វាមានតម្រូវការ(ប្រើប្រាស់)ប្រេង ... ពីដំណាក់កាលមួយ ទៅកាន់ដំណាក់កាលមួយ តម្រូវការវាខុសគ្នា។ ដូចជាយុទ្ធសាស្ត្រចតុកោណអញ្ចឹង កាលពីមុនៈ ទឹក ផ្លូវភ្លើង មនុស្ស។ ឥឡូវយើងដាក់ជាៈ មនុស្ស (ទឹក ផ្លូវភ្លើង)។ ទៅជា មនុស្សមុន យកវិស័យបណ្តុះបណ្តាលធនធានមនុស្ស គឺជាអាទិភាពជាមុំទី១ នៃការដោះស្រាយការវិនិយោគសម្រាប់ការឈានឡើងរបស់ប្រទេសជាតិ ...៕

៦០. ចលនាក្រៅប្រទេសឱ្យអ្នកក្នុងប្រទេសដកលុយនិង/ឬកុំសងធនាគារ/មីក្រូហិរញ្ញវត្ថុ

បើកដំណើរការសោកល្បងសួនទឹកកំសាន្ត Garden City Water Park, ១៦ សីហា ២០២០

... មានអ្នកនៅបរទេសមួយចំនួននិយាយអំពីក្របខណ្ឌឥណទានមីក្រូហិរញ្ញវត្ថុ ថា លោក ហ៊ុន សែន លើកទឹកចិត្តឱ្យមានការរឹបអូស។ (ពិចារណាចុះ) គ្មានអ្នកណាដែលមានចិត្តជ្រះថ្លាលើស ហ៊ុន សែន ទេ។ អំពាវនាវឱ្យមីក្រូហិរញ្ញវត្ថុ ឱ្យធនាគារមានការយោគយល់ចំពោះអ្នកដែលបានដំពាក់ប្រាក់ ហើយសុំឱ្យរៀបចំឥណទានឡើងវិញរាប់សិបម៉ឺនគ្រួសារឯនោះ។ ប៉ុន្តែ **ក្នុងពេលដែលយើងកំពុងតែទន់ភ្លន់ កំពុងតែអំពាវនាវកុំឱ្យមានការរឹបអូសនៅក្នុងដំណាក់កាល កូវីដ១៩ ឱ្យធនាគារនិងស្ថាប័នមីក្រូហិរញ្ញវត្ថុមានការអធ្យាស្រ័យយោគយល់ បែរជាមានចលនាពីក្រៅប្រទេស រុញឱ្យអ្នកក្នុងប្រទេស ទី១ ដកលុយចេញពីធនាគារដើម្បីឱ្យធនាគារដួលរលំ និងទី២ ចលនាឱ្យប្រជាពលរដ្ឋខ្មែរដែលជំពាក់លុយធនាគារ និងមីក្រូហិរញ្ញវត្ថុ កុំសងលុយធនាគារនិងមីក្រូហិរញ្ញវត្ថុ។** ដើម្បីជាការឆ្លើយតប និងជាការព្រមាន ខ្ញុំបានប្រកាសថា បើអ្នកណាធ្វើតាមមេឧទ្ធាម មិនព្រមសងលុយ

ធនាគារ មិនព្រមសងលុយមីក្រូហិរញ្ញវត្ថុ (ខ្ញុំនឹង)លើកទឹកចិត្តឱ្យមានការរឹបអូស ... ឥឡូវស្ងាត់ឈឹង។ ខ្ញុំនៅតែនិយាយដដែល ខ្ញុំអង្វរការធនាគារ អង្វរការមីក្រូហិរញ្ញវត្ថុ យោគយល់ចំពោះការលំបាកក្នុងការសងប្រាក់ ហើយអំពាវនាវឱ្យមានការរៀបចំឥណទានឡើងវិញ ...៕

៦១. វិទ្វង្សនាសេដ្ឋកិច្ច ស្មើនឹងការធ្វើភេរវកម្ម

ជជកស្រង់ប្រសាសន៍សំណេះសំណាលជាមួយនឹងមន្ត្រីរាជការ និងក្រុមការងារបច្ចេកទេស ស្តាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុង ក្នុងខេត្តព្រះសីហនុ, ១ មិថុនា ២០២០

... ផែនការរបស់ពួកឯងគឺធ្វើឱ្យធនាគារនៅកម្ពុជារលំ។ ចរិតពួកឯងគឺជាចរិតបំផ្លាញជាតិពិតប្រាកដ ... **ការធ្វើវិទ្វង្សនាសេដ្ឋកិច្ច ស្មើនឹងការធ្វើភេរវកម្ម។ ឯងចង្អុលការមកខាងក្នុង យើងនឹងចាប់អ្នកខាងក្នុង ... ឱ្យបញ្ឈប់ពីបារាំង/អាមេរិក/កាណាដាមក ... ពួកឯងមិនត្រឹមតែមិនជួយជាតិទេ ឯងចង់បង្កើតចលាចលដោយបំផុសមនុស្សមិនឱ្យសងលុយធនាគារ ធ្វើឱ្យធនាគាររលំ ហើយទាញយកផលផ្តួលរលំ។ យើងមិនទុកឱកាសឱ្យឯងទេ ... ភេរវកម្ម មិនសំដៅតែទៅលើការវាយប្រហារដោយគ្រាប់បែក/មីននោះទេ។ អ្នកឯងធ្វើវិទ្វង្សនាសេដ្ឋកិច្ច បំផ្លាញជាតិយ៉ាងដូច្នេះ គ្មានរឿងត្រូវទុកអ្នកឯងទេ**។ រឿងសិទ្ធិមនុស្សទុកមួយឡែកសិន ព្រោះអ្នកឯងបំផ្លាញ។ រឿងអីនិយាយដល់សិទ្ធិមនុស្ស? សិទ្ធិមនុស្សមិនឱ្យបំផ្លាញទេ ...៕

២៦. សាធារណការនិងដឹកជញ្ជូន

១	នយោបាយហេដ្ឋារចនាសម្ព័ន្ធ បែងចែកកំណើនសេដ្ឋកិច្ចដោយសមភាព	៥២៧
២	រៀបចំហេដ្ឋារចនាសម្ព័ន្ធចង្អុលផ្លូវសម្រាប់មនុស្សជំនាន់ក្រោយ	៥២៧
៣	ជោគជ័យច្រើនក្នុងការតភ្ជាប់ភ្ជាប់ផ្ទៃក្នុង និងការតភ្ជាប់ជាមួយប្រទេសជិតខាង	៥២៨
៤	កូវីដ-១៩ មិនអាចបញ្ឈប់ការខិតខំប្រឹងប្រែងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវ	៥២៨
៥	កូវីដ-១៩ បង្ហាក់ការប្រើប្រាស់ប្រាក់សន្សំសាងសង់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់	៥២៨
៦	ផ្លូវ/ស្ពាន ជាការបែងចែកផ្លែផ្កានៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌	៥២៩
៧	"ខ្មែរធ្វើបាន" ជាដំណើរជាតិ តាំងពីចាប់ផ្តើមមកដល់ពេលនេះ និងទៅអនាគត	៥៣០
៨	ដំណើរ ៦ពាន់គីឡូម៉ែត្រវាយតម្លៃស្ថានភាពប្រទេសសង្គ្រាម សន្តិភាព និងអភិវឌ្ឍន៍	៥៣០
៩	យុទ្ធសាស្ត្រនៃការធ្វើផ្លូវត្រូវបានផ្លាស់ប្តូរ និងមានតម្លៃថ្លៃជាងមុន	៥៣១
១០	សម្ភារៈកើតមុនគំនិតជាហេតុនៃការរីកចម្រើនរបស់ប្រជាជនតម្រូវឱ្យធ្វើស្ពានផ្លូវ	៥៣១
១១	កម្ពុជាកសាងហេដ្ឋារចនាសម្ព័ន្ធគ្រប់ទីកន្លែង ឯប្រទេសខ្លះកំពុងរងការបំផ្លាញ	៥៣២
១២	ប្រើផលសហប្រតិបត្តិការនិងវិនិយោគអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ពង្រីកកំណើនសេដ្ឋកិច្ច	៥៣២
១៣	សង់ផ្លូវសាងសេដ្ឋកិច្ចជឿនលឿន កាត់បន្ថយភាពក្រីក្រ បន្តយការលំបាកចំណាយ	៥៣៣
១៤	ផ្លូវនិងស្ពាន លីយ៉ុងជាត់ព្រែកព្នៅ ប្រើប្រាស់ដោយមិនបង់ថ្លៃ	៥៣៣
១៥	កម្ពុជាត្រូវការស្ពានឆ្លងទន្លេមេគង្គ៣ បន្ថែម នៅពេលខាងមុខ	៥៣៤
១៦	កម្ពុជាកសាងសមត្ថភាពដើម្បីធ្វើស្ពានឆ្លងកាត់ទន្លេដោយខ្លួនឯង	៥៣៤
១៧	មានបំណងស្ពារទន្លេមេគង្គត្រង់កោះប៉ែនដែលមានការគោករាក់	៥៣៥
១៨	ស្ពានកោះប៉ែន/កំពង់ចាម សាងសង់ដោយអ្នកបច្ចេកទេសនិងថវិកាកម្ពុជា	៥៣៥
១៩	មានលទ្ធភាព រដ្ឋទិញស្ពាន/ផ្លូវឯកជនឱ្យប្រជាពលរដ្ឋប្រើប្រាស់មិនបង់លុយ	៥៣៦
២០	កូវីដ-១៩ ស៊ីថវិកា ២៣០០លានដុល្លារ ដែលអាចសង់ស្ពានឆ្លងទន្លេ ស្ទឹង ព្រែក	៥៣៦
២១	ស្ពាន/ផ្លូវ៣ ឆ្លងទន្លេមេគង្គក្រចេះ/កំពង់ធំ, កំពង់ឆ្នាំង/កំពង់ធំ បាត់ដំបង/សៀមរាប	៥៣៧
២២	គំរោងស្ពាន៣ តភ្ជាប់និងជម្លៀសចរាចរណ៍ពី និងការកកស្ទះនៅក្រុងភ្នំពេញ	៥៣៧
២៣	ចំណាយថវិកាដោះស្រាយផលប៉ះពាល់ ដោយសារចិត្តធម៌រាជរដ្ឋាភិបាល	៥៣៨
២៤	ការធ្វើផ្លូវជាតិលេខ៥ មាន ៣កញ្ចប់ឬដំណាក់កាល	៥៣៩
២៥	ផ្លូវជាតិលេខ៥ តភ្ជាប់ ASEAN Highway ទី១ ឬក៏របៀងខាងត្បូង	៥៣៩

២៦	តភ្ជាប់តំបន់មាត់សមុទ្រ ទាញទេសចរនិងជារបៀងសេដ្ឋកិច្ចក្នុង/ក្រៅប្រទេស	៥៤០
២៧	បង្វិលទិសពង្រីកផ្លូវជាតិ៥ ពីទំនប់កប់ស្រូវមកផ្លូវជាតិ៨ តម្រង់ទៅតាខ្មៅវិញ	៥៤០
២៨	អតុល្យភាពរវាងមធ្យោបាយច្រើន តែផ្លូវតិចនិងមានទំហំតូចៗ	៥៤១
២៩	អតុល្យភាពរៀបរាប់ក្នុងសៀវភៅ "១០ឆ្នាំនៃដំណើរកម្ពុជា" បានផ្លាស់ប្តូរ	៥៤១
៣០	អ្នកកោះអន្លង់ចិន ស្រុកស្អាង សំណាងបានស្ពានធំ និងលែងប្រើទូកដ	៥៤២
៣១	នឹងកសាងផ្លូវពីក្រោមទន្លេ មិនបាច់ធ្វើស្ពាន	៥៤២
៣២	ផ្លូវជាតិលេខ៧ ឆ្លងខ្នងមួយសំរាប់តភ្ជាប់ភូមិភាគកណ្តាលទៅឦសាននិងឧត្តរ	៥៤៣
៣៣	តភ្ជាប់ស្រុកព្រៃកប្រសព្វ/ក្រចេះ ទៅស្រុកសណ្តាន់និងស្រុកកំពង់ថ្ម/កំពង់ធំ	៥៤៣
៣៤	ពង្រីកសមត្ថភាពកំពង់ផែទឹកជ្រៅ ដែលគ្របដណ្តប់៧០% នៃសកម្មភាពទំនិញ	៥៤៤
៣៥	ប្រើប្រាស់គ្រប់វិធីបញ្ចៀសការធ្វើឯកជនភាវូបនីយកម្មកំពង់ផែក្រុងព្រះសីហនុ	៥៤៤
៣៦	ការពង្រីកសមត្ថភាពកំពង់ផែក្រុងព្រះសីហនុប្រើឥណទានជប៉ុន ៣៨១លានដុល្លារ	៥៤៥
៣៧	ក្រុងព្រះសីហនុ មជ្ឈមណ្ឌលតភ្ជាប់ដឹកជញ្ជូនរវាងផ្លូវទឹកនិងផ្លូវគោក និងផ្លូវអាកាស	៥៤៥
៣៨	ពីខ្វះទឹក ខ្វះភ្លើង ខ្វះមធ្យោបាយធ្វើដំណើរ មកស្នះផ្លូវ ស្នះលូ ស្នះសំរាម	៥៤៦
៣៩	លូក្នុងក្រុងភ្នំពេញ ធ្វើខ្លួនឯងផង ជប៉ុនជួយផង	៥៤៦
៤០	បរិមាណទឹកភ្លៀងឬពីប្រភពណាមួយលើសពីសមត្ថភាពរំដោះរបស់លូកើតជាជំនន់	៥៤៧
៤១	ជប៉ុនជួយគំរោងការពារទឹកជំនន់ តែលំអប្រព័ន្ធប្រឡាយលូ ៨ដំណាក់កាលហើយ	៥៤៧
៤២	សុំជំនួយពីក្រៅផងវិនិយោគខ្លួនឯងផង ធ្វើលូរំដោះនិងទាញទឹកចេញពីទីក្រុង	៥៤៨
៤៣	រំដោះទឹកចេញពីក្រុង ដោយលូនិងដោយការបូម ក្រោយឆ្លងកាត់ប្រព្រឹត្តកម្ម	៥៤៨
៤៤	កង្វះការថែទាំ/ការពិនិត្យហ្មត់ចត់ ការស្នះសំរាម បន្ថយសមត្ថភាពលូស្រូបទឹក	៥៤៩
៤៥	ក្រៅពីផ្លូវ មានរៀបចំប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ មុនបញ្ចេញទឹកទៅសមុទ្រ	៥៤៩
៤៦	ស្នើចិនដកជំនួយឥតសំណង ១៧០លានរៀបគម្រោងច្រោះទឹកមុនបង្ហូរចូលសមុទ្រ	៥៥០
៤៧	ធ្វើឯកជនូបនីយ៍កម្មដើម្បីយកលុយធ្វើផ្លូវរថភ្លើង តែមិនកើតជាប្រយោជន៍	៥៥០
៤៨	នាយការដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីដឹកជញ្ជូនថៃ ឆ្លើយតបជាវិជ្ជមានផ្តល់ផ្លូវដែក ១៤០គម	៥៥១
៤៩	ពិចារណាពីផ្លូវរថភ្លើងល្បឿនលឿន និងផ្លូវពីសៀមរាបទៅបាត់ដំបង	៥៥១
៥០	រថភ្លើងក្រោមដីអាចជាជម្រើសសម្រាប់កម្ពុជាទៅអនាគត	៥៥២
៥១	មិនចង់ប្រើធនធានច្រើនលើរថភ្លើងអាកាស ក្នុងពេលជនបទកំពុងមានតម្រូវការ	៥៥២
៥២	លើកទឹកចិត្តឱ្យចូលរួមអភិវឌ្ឍផ្លូវរថភ្លើងល្បឿនលឿន តាមរបៀប B.O.T	៥៥៣
៥៣	ចិនជួយផ្លូវលេខ៥ និង៥១ ហើយនឹងសុំចិនធ្វើផ្លូវពីសំឡូតទៅកោះកុង	៥៥៣
៥៤	ផ្លូវរវាងកំពង់ធំនិងក្រចេះ ជាបេក្ខភាពគំរោងជូនសាធារណរដ្ឋប្រជាមានិតចិន ...	៥៥៤
៥៥	បើសិក្សាផ្លូវ/ស្ពានកំពង់ធំ/កំពង់ឆ្នាំងឡើងវិញ ត្រូវយកបទបន្ត Shenzhen	៥៥៤
៥៦	សូមចិនគាំទ្រគម្រោងផ្លូវតភ្ជាប់ពីកោះកុង ទៅកាន់ថ្មដា និងទៅកាន់សំឡូត	៥៥៥
៥៧	គោលនយោបាយតភ្ជាប់ផ្ទៃក្នុងប្រទេសផង និងជាមួយប្រទេសជិតខាងផង	៥៥៥
៥៨	មិត្តភាពនិងការជឿទុកចិត្ត នាំអោយចាប់ផ្តើមគំរោងហេដ្ឋារចនាសម្ព័ន្ធ P3	៥៥៦
៥៩	ស្នើបើកច្រកព្រំដែន៤ ជាមួយថៃគឺ អានសេះ, ជប់គគី, ភ្នំដី និងថ្មដា	៥៥៦
៦០	ក្រោយចប់កុងត្រា ផ្លូវល្បឿនលឿន BOT ជាផ្លូវរបស់រដ្ឋ	៥៥៧
៦១	ត្រូវការផ្លូវល្បឿនលឿនតភ្ជាប់ជាមួយវៀតណាមនិងថៃ	៥៥៧
៦២	រកឥណទាន ជំនួយឥតសំណង វិនិយោគទុន កសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវស្ពាន	៥៥៨
៦៣	ស្នើកូរ៉េពិចារណាកសាងស្ពានមិត្តភាពកម្ពុជាកូរ៉េ ពីជ្រោយចង្វារទៅស្វាយជ្រុំ	៥៥៨
៦៤	ចិនរួមចំណែកសង់ផ្លូវ ៣០០០/១៥០០០ គីឡូម៉ែត្រ និង១០/២០ស្ពាន	៥៥៩
៦៥	សិក្សាផ្លូវពីស្រុកល្វាឯមទៅផ្លូវជាតិលេខ១១ និងទៅព្រំដែនកម្ពុជាវៀតណាម	៥៥៩
៦៦	ផ្លូវជាតិ៤៨ ជារបៀងសមុទ្រតភ្ជាប់ផ្ទៃក្នុងនិង រវាងថៃនិងវៀតណាម កាត់កម្ពុជា	៥៦០
៦៧	តភ្ជាប់ផ្លូវជាតិលេខ៧ ទៅព្រំដែនឡាវ សង់ស្ពានក្បែរក្រុងក្រចេះនិងផ្លូវទៅកំពង់ធំ	៥៦០
៦៨	អាស៊ាន Highway ហូជីមិញ/ភ្នំពេញ/បាងកក ក្លាយជាការពិត	៥៦១
៦៩	រាល់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ត្រូវស្វែងរកមីននិង/ឬយុទ្ធភណ្ឌមិនទាន់ផ្ទុះ	៥៦១
៧០	៩០%ជាតំបន់ព្រំដែនអភិវឌ្ឍនិងទីផ្សារ នៅ១០%រារាំងដោយមីននិងគ្រាប់មិនទាន់ផ្ទុះ	៥៦២
៧១	ការដឹកជញ្ជូនមានតម្លៃខ្ពស់ ក្នុងក្របខ័ណ្ឌបណ្តាប្រទេសក្នុងតំបន់	៥៦២
៧២	គិតគូរភូមិសាស្ត្រប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនដើម្បីផលចំណេញខាងសេដ្ឋកិច្ច	៥៦៣
៧៣	នឹងអាចសង់ព្រលានយន្តហោះមួយទៀតនៅភាគឦសាន	៥៦៤
៧៤	ព្រលានទទួលយន្តហោះធុនធំនៅសៀមរាបភ្នំពេញ ពង្រីក Piste នៅខេត្តព្រះសីហនុ	៥៦៤
៧៥	"តារាះទិសឧត្តរ" ... វឌ្ឍនភាពសាងសង់អាកាសយានដ្ឋានអន្តរជាតិសៀមរាប	៥៦៥
៧៦	ចាប់ឡានដឹកលើសទម្ងន់ មិនឱ្យឡានតម្រុងខុសបច្ចេកទេសមានវត្តមានលើផ្លូវ	៥៦៥
៧៧	៦ចំណុចឆ្លើយតបទៅការចុះផ្សាយមួលបង្កាច់ស្តីពីព្រែកជីកហ្វូណានតេជោ	៥៦៦
៧៨	ត្រូវការប្រជាជនគាំទ្រជាចលនាជាតិ ដើម្បីសំរេចបានព្រែកជីកហ្វូណានតេជោ	៥៦៧
៧៩	ផលប្រយោជន៍៤ យ៉ាង នៃព្រែកជីកហ្វូណានតេជោ	៥៦៧

៨០	ប្រព័ន្ធដឹកជញ្ជូនព្រែកជីកហ្វូណនតេជោ ប្រទាក់ក្រឡារវាងផ្លូវទឹកនិងផ្លូវគោក	៥៦៨
៨១	ព្រែកជីកហ្វូណនតេជោ នឹងបង្កើតបានជាប្រព័ន្ធ ecology	៥៦៩
៨២	បើមិនធ្វើព្រែកជីកហ្នឹងកម្ពុជានៅតែពឹងដង្ហើមគេដក មិនអាចប្រកួតប្រជែងបាន	៥៦៩
៨៣	ទ្វារទឹក៣ មិនឱ្យទឹកសាបចេញទៅសមុទ្រ ហើយទឹកប្រៃចូលមកក្នុងព្រែក	៥៧០
៨៤	ឆ្នាំ២០១៦ ទឹកសមុទ្រហូរចូលវៀតណាមជាគ្រោះធម្មជាតិ មិនមែនមកពីកម្ពុជាទេ	៥៧០
៨៥	ការប្រើប្រាស់ដៃទន្លេមេគង្គ មិនតំរូវឲ្យពិគ្រោះយោបល់ឬយល់ព្រមពីហត្ថលេខី	៥៧១
៨៦	មិនបាច់ពិគ្រោះយោបល់អ្នកណាទេ ក្បិតកម្ពុជាប្រើប្រាស់ដៃនៃដៃទន្លេមេគង្គ	៥៧១
៨៧	ព្រែកជីកហ្វូណន-តេជោ ... មិនមែនគំនិតផ្តើមក្របខ័ណ្ឌខ្សែក្រវាត់និងផ្លូវទេ	៥៧២
៨៨	ទទឹង១០០ម៉ែត្រ ជំរៅទឹក៥ម៉ែត្រ មិនឆ្លើយតបទៅការចល័តកងទ័ពជើងទឹកទេ	៥៧២
៨៩	៨០គម នៃព្រែកជាប្រឡាយលេខ១៥ កំពុងប្រើជាប្រព័ន្ធស្រោចស្រព និងដឹកជញ្ជូន	៥៧៣
៩០	ថា "ព្រែកជីកហ្វូណនតេជោ" ធ្វើឱ្យបាត់ទឹកពីទន្លេមេគង្គ៥% ជាការមិនត្រឹមត្រូវ	៥៧៣
៩១	កត្តា៦ ធ្វើអោយការដឹកទំនិញឆ្លងកាត់វៀតណាមបង្កការខាតបង់	៥៧៤
៩២	គួរធ្វើដំណើរដោយសុំច្បាប់/បបបទរាល់ពេល ឬមិនបាច់សុំច្បាប់ក្នុងទឹកដីឯង	៥៧៥
៩៣	ជាផលប្រយោជន៍សេដ្ឋកិច្ចនិងសង្គមផង ឯការជ្យកាពលើការដឹកជញ្ជូនផ្លូវទឹកផង	៥៧៥
៩៤	ព្រែកជីកហ្វូណនតេជោ បង្កាវិបាកដឹកជញ្ជូនពីកត្តាធម្មជាតិ នីតិវិធី ទំនាក់ទំនង	៥៧៦
៩៥	"ព្រែកជីកហ្វូណនតេជោ នឹងបន្តយឥទ្ធិពលវៀតណាមលើកម្ពុជា" ជាការពិត	៥៧៦
៩៦	សន្តិភាពគ្មានស្ថិរភាព ហើយសង្គ្រាមនិងប្រល័យពូជសាសន៍ ជីកព្រែកមិនបាន	៥៧៧

១. នយោបាយហេដ្ឋារចនាសម្ព័ន្ធ បែងចែកកំណើនសេដ្ឋកិច្ចដោយសមភាព

សម្តេចកំណាត់ផ្លូវជាតិលេខ៦ ពីជ្រោយចង្វាទៅថ្នល់កែង, ៦ មេសា ២០១៧

... គោលដៅធំបំផុតរបស់យើង គឺផ្តោតទៅលើ**ការកសាងហេដ្ឋារចនាសម្ព័ន្ធ។ ហេដ្ឋារចនាសម្ព័ន្ធនៅតែជាអាទិភាពនៃនយោបាយរបស់គណបក្សប្រជាជន ក្នុងការដឹកនាំប្រទេស។ គ្មានជម្រើសណាល្អ និងមានសមភាពជាងការប្រើប្រាស់កំណើនសេដ្ឋកិច្ច ឬការគាំទ្រពីមិត្តភក្តិកសាងហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវថ្នល់ ប្រឡាយទឹក អគ្គីសនី ឬក៏ហេដ្ឋារចនាសម្ព័ន្ធទាក់ទងជាមួយវិស័យអប់រំ និងសុខាភិបាល(នោះទេ)។ វាមានសមភាពខ្លាំងណាស់**។ ការធ្វើបានផ្លូវមួយខ្សែ អ្នកមានក៏ធ្វើដំណើរ អ្នកក្រក៏ធ្វើដំណើរ។ តាមរយៈការតភ្ជាប់ ការធ្វើផ្លូវថ្នល់នេះ ធ្វើឱ្យប្រជាជនរវាងទីក្រុងនិងជនបទ មិនមានការខុសប្លែកឆ្ងាយពេកទេ។ នៅទីក្រុងមានផ្លូវចាក់កៅស៊ូ នៅជនបទក៏មានផ្លូវចាក់កៅស៊ូ នៅទីក្រុងមានអគ្គិសនីប្រើប្រាស់ នៅជនបទក៏មានអគ្គិសនីប្រើប្រាស់ ...។

២. រៀបចំហេដ្ឋារចនាសម្ព័ន្ធចង្អុលផ្លូវសម្រាប់មនុស្សជំនាន់ក្រោយ

បើកការដ្ឋានសាងសង់ផ្លូវល្បឿនលឿន ក្រុងភ្នំពេញ-ខេត្តព្រះសីហនុ, ២២ មីនា ២០១៩

... ពិតមែនហើយ មិនប្រាកដថាខ្ញុំរស់ដល់ឆ្នាំ២០៥០ ទេ ក៏មិនដឹង។ ប៉ុន្តែដូចមិនមែនទេ។ ២០៥០ដូចនៅ(មានជីវិតទេ) ព្រោះខ្ញុំអាយុមិនច្រើនទេ យ៉ាងតិចណាស់ ៣០ ឬ៤០ឆ្នាំទៀតតែប៉ុណ្ណឹង។ មនុស្សមិនងាយងាប់ឯណា។ **បើទោះបីថា នៅឬមិននៅ យើងដាក់ផែនទីចង្អុលផ្លូវមួយសម្រាប់អ្នកជំនាន់ក្រោយ គេយកទៅធ្វើ និងរៀបចំជាហេដ្ឋារចនាសម្ព័ន្ធទាំងនេះ។ មិនមែនរៀបចំសម្រាប់យើងទេ។ មនុស្សឯណាចាស់សក។ ធ្វើសម្រាប់ក្មេងជំនាន់ក្រោយ។ ចាស់ៗជំនាន់មុនបានធ្វើសម្រាប់យើងជំនាន់នេះ។ ឥឡូវយើងជំនាន់នេះ ធ្វើសម្រាប់យើងជំនាន់នេះផង នឹងធ្វើសម្រាប់ក្មេងជំនាន់ក្រោយផង**។ នេះជារឿង(ពិត)។ មិនមែនប្រទេសនេះជារបស់យើងកាន់កាប់ម្នាក់ឯង រហូតទៅដល់មួយពាន់ឆ្នាំឯណា។ ហ្នឹងហើយជាតម្រូវការសម្រាប់ការលូតលាស់មួយ ...។

៣. ជោគជ័យច្រើនហើយក្នុងការតភ្ជាប់ផ្ទៃក្នុង និងជាមួយប្រទេសជិតខាង

បើកការដ្ឋានសាងសង់អាគារច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ និងផ្លូវតភ្ជាប់ទៅផ្លូវជាតិលេខ ៥, ២២ មេសា ២០១៩

... បន្ទាប់ពីជោគជ័យនៃនយោបាយឈ្នះឈ្នះ រយៈពេល ២០ឆ្នាំក្រោយ យើងសំរេចបានជោគជ័យយុទ្ធសាស្ត្រ ៣យ៉ាង ... ទី១ យើងបាននិងកំពុងប្រែក្លាយតំបន់អតីតសមរភូមិអោយក្លាយទៅជាតំបន់មានការអភិវឌ្ឍ ... ទី២ យើងបានប្រែក្លាយខ្សែព្រំដែនជាមួយប្រទេសជិតខាងឲ្យទៅជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ ... **ទី៣ យើងបានទទួលជោគជ័យច្រើនហើយក្នុងការតភ្ជាប់ភ្ជាប់ផ្ទៃក្នុង និងការតភ្ជាប់ជាមួយប្រទេសជិតខាង។ សូមជនរួមជាតិរបស់យើងពិនិត្យមើលចុះ តើពីមុនយើងមានផ្លូវគ្រប់គ្រាន់ទេ? ទោះបីថាឥឡូវនៅមិនទាន់គ្រប់ក៏ដោយ តែបើប្រៀបធៀបពីពេលមុន ខេត្តបន្ទាយមានជ័យអាចចាត់ទុកថាជាខេត្តដែលមានភ័ព្វសំណាងអំពីការតភ្ជាប់** ...។

៤. កូវីដ-១៩ មិនអាចបញ្ឈប់ការខិតខំប្រឹងប្រែងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវ

បើកការដ្ឋានសាងសង់ និងកែលម្អផ្លូវ ៣៨ខ្សែនៅក្នុងក្រុងសៀមរាប, ៣០ វិច្ឆិកា ២០២០

... **កូវីដ-១៩ អាចរារាំងដំណើរការរបស់យើងមួយចំនួន ប៉ុន្តែមិនអាចបញ្ឈប់កិច្ចខិតខំប្រឹងប្រែងក្នុងការស្ថាបនាផ្លូវទាំងនេះទេ ... កាលពីថ្ងៃទី៤ កញ្ញា ២០២០ ក្នុងពេលប្រជុំគណៈរដ្ឋមន្ត្រីពេញអង្គ ខ្ញុំបានប្រកាសទម្លាក់ថវិកាពីរង្វង់ ១០០ ទៅ ១៥០លានដុល្លារ ដើម្បីសាងសង់ផ្លូវចំនួន ៣៨ខ្សែសម្រាប់ទីក្រុងសៀមរាប** និងបន្ថែមលើនោះ ដោយមានការសិក្សាជាក់លាក់របស់ឯកឧត្តម ជា សុផារ៉ា ទៅលើការកែលម្អដងស្ទឹងសៀមរាបផង ថ្ងៃនេះក៏មានការបង្កើតការដ្ឋានមួយទៀតកែលម្អដងស្ទឹងសៀមរាប ដែលនៅសងខាងប្រវែង ៨៤៤០ម៉ែត្រ (ឬជិត ៩គីឡូម៉ែត្រ) ឱ្យក្លាយទៅជាកន្លែងដើរកំសាន្តរបស់ប្រជាពលរដ្ឋ ក៏ដូចជាទេសចរ ...។

៥. កូវីដ-១៩ បង្អាក់ការប្រើប្រាស់ប្រាក់សន្សំសាងសង់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា

ក្នុងពិធីសម្ពោធអគារដ្ឋបាលគយនិងរដ្ឋាករ ព្រមទាំងសាលាជាតិគយ និងសារមន្ទីរគយ, ២៣ ធ្នូ ២០២១

... ខ្ញុំតែងតែបាននិយាយថា **"បើកុំមាន(គ្រោះ)កូវីដ-១៩នេះ ខ្ញុំនឹងដាក់មួយព្រនង់អោយរង្គើកម្ពុជា។ មួយព្រនង់នោះជាអ្វី? គឺប្រើប្រាស់ប្រាក់ដែលសន្សំបាននិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ជាផ្លូវ ជាស្ពាន ដែលខ្ញុំថាដូចជាព្រែកត្នោតអញ្ចឹង ដាក់ ១គីឡូម៉ែត្រស្ពានមួយៗ។ ស្ពានខ្លះតែ ៥០ម៉ឺនដុល្លារ ស្ពានខ្លះ ១លានដុល្លារ។ ដាក់អោយព្រាតពេញប្រទេសតែម្តង។ ផ្លូវណាដែលយើងពិបាករកទុនពីក្រៅប្រទេស យើងសង់ខ្លួនឯង។** កន្លងទៅយើងប្រើអស់ប្រមាណជាជិត ១៣ន់លានដុល្លារ។ យោងលើបទពិសោធន៍ខ្វះអគ្គិសនី នៅឆ្នាំ២០១៩ តើចាំបានទេ? វ៉ារីអគ្គិសនីទាំងអស់ដើរបានតិច ដោយសារខ្វះទឹក។ អញ្ចឹង ទីក្រុងភ្នំពេញអត់ភ្លើងប្រើប្រាស់។ ខ្ញុំបានទាក់ទងទៅប្រធានាធិបតីវៀតណាម ... សូមឱ្យជួយផ្តល់ ៥០មេហ្គាវ៉ាត់ភ្លាមដើម្បីបញ្ជូនមកភ្នំពេញ ...បន្ទាប់ពីនោះ យើងប្រើប្រាស់ ៤០០លានដុល្លារទិញម៉ាស៊ីនពីហ្វាំងឡង់ ២០០មេហ្គាវ៉ាត់និងពីអាល្លឺម៉ង់ ២០០មេហ្គាវ៉ាត់ ដើរដោយប្រេង មកដាក់ក្បែរភ្នំពេញ ... ពេលខ្វះអគ្គិសនី ប្រើដោយប្រេងស្ទីក៏ដោយ អោយតែវាអាចផលិតបាន ...។

៦. ផ្លូវ/ស្ពាន ជាការបែងចែកផ្លែផ្កានៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌

ដាក់ឱ្យប្រើប្រាស់ស្ពានមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រង់-ក្រូចឆ្មារ (ស្ពានភ្ជាប់និស្សិ្យ) និងការប្រកាសបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ 71C, ២៣ វិច្ឆិកា ២០២១

... ចំណុច**អាទិភាពនៃនយោបាយរបស់ខ្ញុំគឺធ្វើឱ្យប្រជាជនមានផ្លូវដើរ មានស្ពានឆ្លង មានមន្ទីរពេទ្យ មានសាលារៀន ... ពាក្យថាបែងចែកផ្លែផ្កាកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ល្អជាងគេ គឺប្រើប្រាស់ធនធានដែលបានមកពីកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ឬក៏ជំនួយពីបរទេស និងកម្ចីពីបរទេស យកមកប្រើប្រាស់កសាងហេដ្ឋារចនាសម្ព័ន្ធ។ (ធ្វើដូច)ហ្នឹង(គឺ)សមធម៌ជាងគេ** ព្រោះផ្លូវដើរបានទាំងអស់គ្នា។ អ្នកមានក៏ដើរអ្នកក្រក៏ដើរ។ ស្ពានអ្នកមានក៏ឆ្លងអ្នកក្រក៏ឆ្លង។ អ្នកមានក៏ចូលពេទ្យអ្នកក្រក៏ចូលពេទ្យ។ សាលារៀនកូនអ្នកក្រក៏ចូលរៀន កូនអ្នកមានក៏ចូលរៀន។ **ហ្នឹងជាការបែងចែកដោយសមធម៌ហើយ**។ យើងប្រើប្រាស់វិធីនេះវាល្អជាង។ ការដែលចំណេញ(គឺរយៈពេលនៃការ)ត្រូវធ្វើដំណើរ ...។

៧. "ខ្មែរធ្វើបាន" ជាដំណើរទូទាំងជាតិ តាំងពីចាប់ផ្តើមមកដល់ពេលនេះ និងបន្តទៅអនាគត

សម្ពោធដាក់ឲ្យប្រើប្រាស់ ផ្លូវ ៣៧ខ្សែ ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ និងសមិទ្ធផលនានា ក្នុងក្រុង/ខេត្តព្រះសីហនុ, ២ ធ្នូ ២០២១

... អត្ថន័យពាក្យ "ខ្មែរធ្វើបាន" មិនសំដៅតែទៅលើការអភិវឌ្ឍនៅក្នុងក្រុងព្រះសីហនុនោះទេ។ ខ្មែរធ្វើបាន មានតាំងពីរាប់ពាន់ឆ្នាំរួចមកហើយ។ ខ្មែរធ្វើបានប្រាង្គប្រាសាទនានានៅទូទាំងប្រទេស ហើយលេចធ្លោជាងគេគឺប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ ប្រាសាទសំបូរព្រៃគុក ប្រាសាទកោះកេរ្តិ៍។ នៅកន្លែងណាក៏មានប្រាសាទ។ ខ្មែរធ្វើបាន។ ដំណាក់កាលមុនសង្គ្រាមឆ្នាំ ១៩៧០ ដំណាក់កាលក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះករុណា ព្រះបិតាជាតិ ខ្មែរធ្វើបានដូចជាស្តាតដូចជាស្តាន ទោះបីថាពេលនោះមិនទាន់មានច្រើនក៏ដោយ ក៏វាជាមោទនភាពកាលពីជំនាន់នោះ។ នៅពីក្មេង វាជាមោទនភាពដែលយើងមានស្តាតប្រើប្រាស់រហូតដល់សព្វថ្ងៃ។ យើងមានស្តានឆ្លងកាត់ទន្លេសាប យើងមានស្តានឆ្លងកាត់ទន្លេបាសាក់។ អញ្ចឹងពាក្យថា **"ខ្មែរធ្វើបាន" ចង់សំដៅទៅលើទូទាំងដំណើរជាតិរបស់យើង ពីការចាប់ផ្តើមរហូតមកដល់ពេលនេះ។ ហើយខ្ញុំសង្ឃឹមថាខ្មែរធ្វើបាននឹងបន្តនៅពេលអនាគត តាមរយៈស្នាដៃរបស់យើង** ...។

៨. ដំណើរ ៦៣ន់គីឡូម៉ែត្រ វាយតម្លៃស្ថានភាពប្រទេសបន្ទាប់ពីសង្គ្រាម មានសន្តិភាព និងអភិវឌ្ឍន៍

សម្ពោធកំណាត់ផ្លូវជាតិលេខ៧ ប្រវែង ៩៣, ៦៤គីឡូម៉ែត្រ ពីរង្វង់មូលខ្លាស្ទុះ ទៅឃុំរមាត ខេត្តក្រចេះ, ៧ កុម្ភៈ ២០២២

... ខ្ញុំបានធ្វើ**ដំណើរ ៦៣ន់គីឡូម៉ែត្រ តាមផ្លូវគោក។ ខ្ញុំចង់មើលអំពីទីកន្លែងដែលធ្លាប់ប្រយុទ្ធគ្នាពីមុនមកថា តើឥឡូវវាយ៉ាងម៉េចទៅហើយ។ ឆ្នាំ២០១៦ ខ្ញុំធ្វើដំណើរច្រើនខេត្ត ទៅកាន់តំបន់ដែលធ្លាប់ប្រយុទ្ធគ្នា ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពប្រទេសដែលមានសង្គ្រាម ស្ថានភាពបន្ទាប់ពីសង្គ្រាម និងស្ថានភាពប្រទេសដែលមានសន្តិភាពនិងការអភិវឌ្ឍរួចហើយ**។ ក្នុងដំណើរ ៦៣ន់ គីឡូម៉ែត្រនោះ ខ្ញុំបានពង្រាយសាលារៀនក្នុងក្របខណ្ឌខេត្ត ដែលខេត្តក្រចេះទទួលបាន(អគារសិក្សា)ប៉ុន្មានជាន់ៗនៅទីរួមខេត្ត។ ខ្ញុំគួរតែត្រូវបញ្ជាក់បន្តិចលើបញ្ហា

ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ពេលដែលធ្វើដំណើរមក ខ្ញុំបានសង្កេតពីឧទ្ធម្ភាគចក្រយើញថាក្នុងដែនដីខេត្តក្រចេះនេះ សម្បូរដោយកៅស៊ូ និងដំណាំឧស្សាហកម្មផ្សេងទៀត ដែលជាផ្នែកមួយនៃសេដ្ឋកិច្ចរបស់កម្ពុជា។ គ្រប់ខេត្តទាំងអស់ សុទ្ធតែមានការអភិវឌ្ឍ ...។

៩. យុទ្ធសាស្ត្រនៃការធ្វើផ្លូវត្រូវបានផ្លាស់ប្តូរ និងមានតម្លៃថ្លៃជាងមុន

សម្ពោធដាក់ឱ្យប្រើប្រាស់នូវផ្លូវជាតិលេខ ៣ ពីរង្វង់មូលចោមចៅ រាជធានីភ្នំពេញ ទៅកាន់ខេត្តកំពត, ២ មីនា ២០២២

... ឥឡូវនេះ **យុទ្ធសាស្ត្រនៃការធ្វើផ្លូវរបស់យើងត្រូវបានផ្លាស់ប្តូរ។ កាលពីទសវត្សរ៍ឆ្នាំ ៨០ យើងធ្វើផ្លូវឱ្យបានវែង។ រហូតមកដល់ឥឡូវ បងប្អូនយើងនិយាយថា ធ្វើផ្លូវធ្វើមិនចប់។ មិនមែនមានន័យថាធ្វើមិនជាប់ទេ។ មានសេចក្តីថាធ្វើមិនចប់។ ធ្វើទៅដល់មុខ វាខូចខាងក្រោយ។ នេះដោយសារផ្លូវយើងមានកម្រាស់ស្តើង**។ ឥឡូវនេះ ក្នុងការស្ថាបនាផ្លូវ **យើងបានកែលម្អវា ដែល(ការកសាងផ្លូវថ្មី) មានតម្លៃថ្លៃជាងពេលមុន**។ ពេលមុន យើងធ្វើផ្លូវថ្លៃថោកជាង ប៉ុន្តែបានផ្លូវវែង ហើយប្រើបាន(រយៈពេល)ឆាប់ ដោយសារម្ខាងអាស្រ័យលើគុណភាព និងបន្ថែមទៅដោយការដឹកលើសទម្ងន់ផង។ ដូច្នេះហើយ យើងត្រូវរៀបចំឱ្យមានការសាងសង់ផ្លូវនេះឡើងវិញ ...។

១០. សម្ភារៈកើតមុនគំនិត ជាហេតុដែលការរីកចម្រើនរបស់ប្រជាជនតម្រូវឱ្យធ្វើស្ពានផ្លូវ

សម្ពោធដាក់ឱ្យប្រើប្រាស់នូវស្ពានអាកាស និងផ្លូវក្រោមដីចោមចៅ, ៣១ មីនា ២០២២

... រវាងលទ្ធិសម្ភារៈនិយមនិងគំនិតនិយម មានការជជែកគ្នាយ៉ាងតឹងតែង ដោយម្ខាងថាគំនិតកើតមុនសម្ភារៈ ឯម្ខាងទៀតថាសម្ភារៈកើតមុនគំនិត។ (ការថ្លែងតទៅនេះ)**មិនមែនជាការបង្រៀន ហើយក៏មិនមែនជាការគាំទ្រទស្សនៈណាមួយទេ ក៏ប៉ុន្តែអ្វីដែលបានលេចឡើងនៅទីនេះ បញ្ជាក់ច្បាស់ណាស់ថាសម្ភារៈកើតមុនគំនិត ដោយសារតែមើលឃើញថា ស្ថានភាពនៅទីនេះមានការកកស្ទះចរាចរណ៍។ ដូច្នេះហើយក៏ចាប់ផ្តើមមានគំនិតធ្វើស្ពានអាកាស ផ្លូវក្រោមដី និងលើដី។ ដោយមូលហេតុនេះ មនុស្សភាគច្រើន ហើយក៏ logic ផងដែរ ដែលយល់ពីលទ្ធិសម្ភារៈនិយម វាត្រឹមត្រូវជាងលទ្ធិគំនិតនិយម។ ខ្ញុំមិនដឹងទាស់នឹងនរណា**

មួយ ដែលលើកអំពីគំនិតកើតមុនសម្ភារៈ ឬក៏សម្ភារៈកើតមុនគំនិតនោះទេ ប៉ុន្តែចង់និយាយថា គឺចាប់ផ្តើមពីការកែចម្រើនរបស់ប្រជាជននោះឯង ដែលតម្រូវឱ្យយើងធ្វើស្ពានធ្វើផ្លូវនេះ។ តំបន់នេះ ជាតំបន់កកស្ទះខ្លាំង។ ដូច្នេះវាមានតម្រូវការឱ្យយើងធ្វើ(ស្ពានអាកាស និងផ្លូវក្រោមដី)នៅទីនេះ ...។

១១. កម្ពុជាកសាងហេដ្ឋារចនាសម្ព័ន្ធគ្រប់ទីកន្លែង ខណៈប្រទេសខ្លះកំពុងរងការបំផ្លាញ

សម្ពោធដាក់ឱ្យប្រើប្រាស់នូវស្ពានអាកាស និងផ្លូវក្រោមដីចោមចៅ, ៣១ មីនា ២០២២

... មកពីហេតុអ្វីបានជាយើងធ្វើ(របស់អស់ទាំង)ហ្នឹង? ថាមកពីតម្រូវការ។ ហេតុអ្វីបានជានាំទៅដល់(មាន)តម្រូវការបែបនេះ។ ចេញមកពីអ្វី? ខ្ញុំគ្រាន់តែធ្វើការរំលឹកបន្តិច ពេលនេះម៉ោងនេះ **ប្រទេសកម្ពុជាកំពុងកសាងហេដ្ឋារចនាសម្ព័ន្ធគ្រប់ទីកន្លែងលើផ្ទៃប្រទេស ក្នុងពេលដែលប្រទេសអ៊ុយក្រែននិងប្រទេសខ្លះទៀតកំពុងរងការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ កុំនិយាយឡើយដល់ការសាងសង់**។ កាលពី ៥២ឆ្នាំមុន ពេលនេះម៉ោងនេះ បន្ទាប់ពីរដ្ឋប្រហារថ្ងៃ ១៨មីនា ១៩៧០ ការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធបានចាប់ផ្តើម។ ខ្ញុំនៅចាំបានស្ពានជ្រៃ តាមផ្លូវជាតិលេខ៧ ត្រូវបានដាក់មីនផ្តាច់នៅថ្ងៃ២៩ ខែមីនា។ នោះជាការចាប់ផ្តើមនៃការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធហើយ។ កម្ពុជា (មាន)ស្ពានច្រើនដែលត្រូវបានបំផ្លិចបំផ្លាញដោយគ្រាប់បែកដែល(ផ្តោង)ពីលើផងពីក្រោមផង ដើម្បីកាត់ផ្តាច់ការជឹកជញ្ជូន។ តើអ្វីទៅដែលអាចឱ្យយើងធ្វើបានសមិទ្ធផលទាំងនេះ។ គឺសន្តិភាពដែលយើងកបានដោយលំបាកកាលពី ២៤ឆ្នាំកន្លងផុតទៅនោះឯងហើយ។ យើងបានប្រឹងប្រែងដើម្បីរកសន្តិភាពសម្រាប់ប្រទេសជាតិ ...។

១២. ប្រើប្រាស់ផលពីការសហប្រតិបត្តិការវិនិយោគ សំរាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពង្រីកកំណើនសេដ្ឋកិច្ច

បើកការដ្ឋានសាងសង់ស្ពានអាកាសចំនួន២ ដោយប្រសិទ្ធនាមថា ស្ពានអាកាសព្រះមុន្នីវង្ស និងស្ពានអាកាសសម្តេចចៅហ្វាវាំង គង់ សំអុល, ៣១ សីហា ២០២២

... យើងបើកការដ្ឋានសាងសង់ស្ពានអាកាស ចំនួន ២កន្លែង ដែលខ្ញុំហៅថា "ស្ពានអាកាសព្រះមុន្នីវង្ស"និង "ស្ពានអាកាស គង់ សំអុល" ដែលការ(សាងសង់មាន)រយៈពេល ៣៦ខែ និងត្រូវចំណាយថវិកា ៣៦ ៧៧៥ ០០០ ដុល្លារសហរដ្ឋ

អាមេរិក។ ឯស្ពានអាកាសទី(២) ត្រូវសាងសង់រយៈពេល ១៦ខែ ត្រូវចំណាយថវិកា ១០លានដុល្លារសហរដ្ឋអាមេរិក ... តើយើងបានថវិកាមកពីណា? ប្រវត្តិនៃការកសាងស្ពានអាកាស និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួននៅទីក្រុងភ្នំពេញ ត្រូវប្រើប្រាស់វិធីសាស្ត្រ "យកស្លឹកត្នោតខ្ទប់ស្ករត្នោត" មានន័យថា "យកក្រុងចិញ្ចឹមក្រុង"។ តាមការសហប្រតិបត្តិការជាមួយក្រុមហ៊ុន OCIC យើងបានប្រើប្រាស់ថវិកាជាចំណូលបានមកពីកោះពេជ្រ(និង)ពីកោះនរា និងពីជ្រោយចង្វារ មកកសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នេះ។ **ខ្ញុំបានចេញបទបញ្ជាដាច់ណាត់មិនឱ្យប្រើប្រាស់ផលទទួលបានពីការសហប្រតិបត្តិការវិនិយោគ ទៅលើចំណាយចរន្តជាច់ខាត។ ត្រូវប្រើប្រាស់តែក្នុងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីពង្រីកកំណើនសេដ្ឋកិច្ចតែប៉ុណ្ណឹង។ គិតមកដល់ពេលនេះ យើងបានចំណាយលើស្ពានឆ្លងកាត់ទន្លេ ៥ទីតាំង និងស្ពានអាកាស ៨ទីតាំង ស្មើនឹងថវិកាជាង ២២៦លានដុល្លារសហរដ្ឋអាមេរិក ...។**

១៣. កសាងផ្លូវដើម្បីកសាងសេដ្ឋកិច្ចជឿនលឿន កាត់បន្ថយភាពក្រីក្រ បន្ថយការលំបាក/ចំណាយរបស់ប្រជាជន

បើកការដ្ឋានស្ពារ និងលើកកម្ពស់កម្រិតគុណភាពផ្លូវជាតិលេខ៣១ និងផ្លូវជាតិលេខ ៣៣ ប្រវែងសរុប ១០៦ គីឡូម៉ែត្រ, ៣០ ធ្នូ ២០២២

... យើងនៅតែផ្តល់អាទិភាពដល់ការតភ្ជាប់។ **បើគ្មានផ្លូវទេ យើងមិនអាចនឹងសម្រេចបានការកសាងសេដ្ឋកិច្ចមួយប្រកបដោយការជឿនលឿន និងបន្ថយការលំបាករបស់ប្រជាជន(បានទេ)។ បើមិននិយាយដល់ការកាត់បន្ថយភាពក្រីក្រទេ ក៏និយាយពីការលំបាករបស់ប្រជាជន ឬក៏បន្ថយការចំណាយរបស់ប្រជាជន** ដូចដែលខ្ញុំធ្លាប់បានធ្វើការប្រៀបធៀបមុននេះ។ ផ្លូវមិនល្អយើងធ្វើដំណើរអស់ប្រាក់ច្រើននិងពេលវេលាច្រើន។ នៅពេលដែលមានផ្លូវល្អ យើងនឹងចំណាយប្រាក់តិចនិងពេលវេលាតិចជាងក្នុងការធ្វើដំណើរ។ នោះហើយជាផលចំណេញសម្រាប់ប្រជាពលរដ្ឋ ដែលយើងត្រូវតែប្រឹងប្រែងធ្វើបន្តទៀត ...។

១៤. ចាប់ពីម៉ោង ០០:០០ ផ្លូវនិងស្ពាន លីយ៉ុងជាត់ព្រៃកព្មៅ ប្រើប្រាស់ដោយមិនបង់ថ្លៃ

សារលើហ្វេសប៊ុកផេចសម្តេចតេជោ ហ៊ុន សែន, ៥ តុលា ២០១៧

... ដើម្បីដោះស្រាយការលំបាក និងជួយលើកកំពស់ជីវភាពប្រជាជន ពិសេស សម្រួលដល់ការធ្វើដំណើរទៅមករបស់ប្រជាពលរដ្ឋ **ចាប់ពីម៉ោង០០:០០ នាទីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧ នេះតទៅ ស្ពាននិងផ្លូវតភ្ជាប់ពីផ្លូវជាតិលេខ៦A ទៅផ្លូវជាតិលេខ៥ (ស្ពាននិងផ្លូវ លើ យ៉ុងផាត់ព្រែកញ្ជៅ) នឹងត្រូវ(បើកឱ្យ)ធ្វើដំណើរដោយមិនបាច់បង់ថ្លៃឆ្លងកាត់ទៀតទេ**។ រាជរដ្ឋាភិបាលនឹងទិញកំណាត់ផ្លូវនោះមកគ្រប់គ្រងវិញ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសាធារណការនិងដឹកជញ្ជូន សាលារាជធានីភ្នំពេញនិងស្ថាប័នពាក់ព័ន្ធ ត្រូវពិភាក្សាជាមួយក្រុមហ៊ុនពិនិត្យដោះស្រាយបញ្ហាដែលនៅសេសសល់។ ប្រជាពលរដ្ឋយើងនឹងទទួលបានផលប្រយោជន៍ពីការសម្រេចនេះ ...៕

១៥. កម្ពុជាត្រូវការស្ពានឆ្លងទន្លេមេគង្គ៣ បន្ថែម នៅពេលខាងមុខ

បើកការដ្ឋានសង់ស្ពានឆ្លងកាត់ទន្លេមេគង្គ ពីស្ទឹងត្រង់ទៅក្រូចឆ្មារ, ៩ កុម្ភៈ ២០១៨

... **យើងខ្ញុំត្រូវការស្ពាន៣ យ៉ាងតិច** ... គ្រាន់តែមុននិងក្រោយតែប៉ុណ្ណោះ ដើម្បីនឹងដំណើរការក្នុងដំណាក់កាលដែលយើងកំពុងអភិវឌ្ឍនេះ។ ស្ពាន៣ នោះ មាន **ទី១ ស្ពានតាមជង់ទន្លេមេគង្គដៃរ ប៉ុន្តែយើងធ្វើនៅទីរួមខេត្តក្រចេះ តភ្ជាប់ទៅកាន់ខេត្តកំពង់ធំអោយមានភាពងាយស្រួល។** ឯស្ពាន**ទី២ នៅតាមជង់ទន្លេមេគង្គដៃរ ក៏ប៉ុន្តែភ្ជាប់រវាងជ្រោយចង្វារ និងស្វាយជ្រុំ អរិយក្សត្រ។ ឯស្ពានទី៣ នៅតាមជង់ទន្លេមេគង្គក្រោម ក្តីតាកុយ ជាមួយនឹងត្រើយម្ខាងទៀត**។ នេះមិនទាន់គិតដល់ស្ពានមួយចំនួនផ្សេងទៀតទេ និងគ្រាន់តែជាការរៀបលំដាប់អាទិភាពស្តីអំពីការកសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់របស់ព្រះរាជាណាចក្រកម្ពុជា ...៕

១៦. កម្ពុជាកសាងសមត្ថភាពដើម្បីធ្វើស្ពានឆ្លងកាត់ទន្លេដោយខ្លួនឯង

សម្ពោធស្ពានកោះកំពង់ត្រុំ/កោះប៉ែន, ១៤ មីនា ២០១៨

... ខ្ញុំព្រះករុណាខ្ញុំ មានការរីករាយដែលបានមកចូលរួមជាមួយព្រះតេជព្រះគុណ ព្រះសង្ឃគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ ក៏ដូចជាបងប្អូនប្រជាពលរដ្ឋ... សម្ពោធដាក់អោយប្រើប្រាស់ស្ពានឆ្លងកាត់ដៃទន្លេ ដែលខ្ញុំព្រះករុណាខ្ញុំប្រសិទ្ធនាមថា "ស្ពានកោះប៉ែន" ដែលតភ្ជាប់ម្ខាងរវាងភូមិកំពង់ត្រុំ ឃុំកោះមិត្ត ស្រុកកំពង់សៀម និងម្ខាងទៀតនៅស្រុកសំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

នេះជាសមិទ្ធផលថ្មីមួយ ក្នុងចំណោមសមិទ្ធផលទាំងឡាយដែលយើងបានរួមគ្នាកសាងឡើង។ **អ្វីដែលសំខាន់សម្រាប់ខ្ញុំព្រះករុណាខ្ញុំ នៅថ្ងៃនេះ មិនត្រឹមតែមានស្ពានដែលជំនួសអោយការឆ្លងដោយទូកជនិងស្ពានឫស្សីក្នុងរដូវប្រាំងទេ តែក៏សូមប្រកាសជាសាធារណៈថា ពេលដែលអាចផ្គុំកម្លាំងគ្រប់ប្រភេទបាន កម្ពុជាមានសមត្ថភាពនឹងធ្វើស្ពានដោយខ្លួនឯង ឆ្លងទន្លេក្នុងព្រះរាជាណាចក្រកម្ពុជា។ នោះជាសមិទ្ធផលពិតនៃការកសាងសមត្ថភាព និងភាពជាម្ចាស់របស់កម្ពុជា** ...៕

១៧. មានបំណងស្ពារទន្លេមេគង្គត្រង់កោះប៉ែនដែលមានការគោករាក់

សម្ពោធស្ពានកោះកំពង់ត្រុំ/កោះប៉ែន, ១៤ មីនា ២០១៨

... អភិបាលខេត្ត ហ៊ុន ណេង បានស្នើសុំធ្វើត្រឹមតែស្ពានដៃកបាឡេប៉ុណ្ណោះ ... ហេតុអ្វីបានជាពីមុនមិនព្រមធ្វើ ហើយក្រោយមកបានធ្វើ ... កាលពីសម័យដើមតំបន់នៅទិសខាងលិចនេះគឺជាទន្លេមួយ ដែលនៅសងខាងកោះនេះ។ ទន្លេនៅចរាចរណ៍បានក្នុងចន្លោះទសវត្សរ៍៧០។ មិនមានការគោករាក់ទេ។ ក្រោយមក **មានការគោករាក់បណ្តើរៗ ដែលខ្ញុំព្រះករុណាខ្ញុំមានបំណងស្ពារទន្លេនេះឡើងវិញ។ ពេលនោះ មានការសិក្សាមួយថាតើត្រូវការចំណាយប៉ុន្មាន ត្រូវយកខ្សាច់ទៅទីណាដើម្បីអោយកកើតឡើងវិញមួយទន្លេ? ... តំបន់នេះ យើងប្រើទន្លេដល់ទៅពីរ ហើយនៅឆ្នាំណាមួយនោះ ខ្ញុំព្រះករុណាខ្ញុំ ជិះអូបីរ នៅរដូវប្រាំងមកតាមទន្លេខាងនេះ ... ពីមួយឆ្នាំទៅមួយឆ្នាំកាន់តែមានការគោករាក់។ យើងក៏ឃើញថាស្ថានភាពនេះ គប្បីត្រូវស្តារទន្លេឡើងវិញដើម្បីប្រើប្រាស់ដឹកជញ្ជូនផ្លូវទឹក** ...៕

១៨. ស្ពានកោះប៉ែន/កំពង់ចាម សាងសង់ដោយអ្នកបច្ចេកទេសនិងថវិកាកម្ពុជា

សម្ពោធស្ពានកោះកំពង់ត្រុំ/កោះប៉ែន, ១៤ មីនា ២០១៨

... ខ្ញុំព្រះករុណាខ្ញុំ មានការរីករាយដែលបានមកចូលរួមជាមួយព្រះតេជព្រះគុណ ព្រះសង្ឃគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ ក៏ដូចជាបងប្អូនប្រជាពលរដ្ឋ... សម្ពោធដាក់អោយប្រើប្រាស់ស្ពានឆ្លងកាត់ដៃទន្លេ ដែលខ្ញុំព្រះករុណាខ្ញុំប្រសិទ្ធនាមថា "ស្ពានកោះប៉ែន" ដែលតភ្ជាប់ម្ខាងរវាងភូមិកំពង់ត្រុំ ឃុំកោះមិត្ត ស្រុកកំពង់សៀម និងម្ខាងទៀតនៅស្រុកសំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

ជាមិនចុះទៅក្នុងទឹកទេ តើយើងអាចចេះហែលទឹកវៀបម៉េចទៅ? អញ្ចឹងមានវិធីតែម្យ៉ាងគត់ គឺសម្រេចអោយធ្វើនិងប្រើប្រាស់អ្នកបច្ចេកទេស ព្រមទាំងថវិកាផ្ទាល់របស់កម្ពុជាខ្លួនឯង។ នេះបង្ហាញពីសមត្ថភាពរបស់យើង។ ទោះបីគេចាត់ទុកស្ពាននេះជាស្ពានតូចតាច ក៏ប៉ុន្តែ**សម្រាប់ប្រជាពលរដ្ឋដែលរស់នៅ និងធ្លាប់ឆ្លងទូកដែនៅទីនេះ ហើយដែលរដូវប្រាំងឆ្លងកាត់តែដោយស្ពានឫស្សី ច្បាស់ជាចាត់ទុកថា ជាស្ពានមហាសាលសម្រាប់ប្រជាពលរដ្ឋហើយ ...**៕

១៩. ពេលមានលទ្ធភាព រដ្ឋទិញស្ពាន/ផ្លូវវិនិយោគដោយឯកជនមកវិញ ដោយប្រជាពលរដ្ឋប្រើប្រាស់មិនបង់លុយទៀតទេ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់សេដ្ឋកិច្ចពិសេសនាងកុក ខេត្តកោះកុង, ១៣ មីនា ២០១៩

... ជាមួយគ្នាដែរ ពេលដែលខ្ញុះខុន យើងបើកឱកាសឲ្យឧកញ៉ា លី យ៉ុងផាត់ កសាងស្ពានឆ្លងកាត់ដៃសមុទ្រនេះ។ យើងមានផ្លូវហើយ តែអភិវឌ្ឍតំបន់ខាងនេះដូចម្តេច បើគ្មានស្ពាន ហើយនាំគ្នាជិះកាណូត ជិះអូប៉ះមកនោះ ... អញ្ចឹង យើងបានឲ្យឧកញ៉ា លី យ៉ុងផាត់ វិនិយោគាងសង់ស្ពាននេះ។ កាលពីមុន ការឆ្លងស្ពាននេះត្រូវបង់ប្រាក់។ ឥឡូវ កម្មករ/ការិនី និងប្រជាពលរដ្ឋទាំងអស់ មិនបង់ប្រាក់ទៀតទេ។ រាជរដ្ឋាភិបាលបានទិញស្ពាននេះ និងប្រគល់ឲ្យសាលាខេត្តកោះកុងគ្រប់គ្រង និងកំពុងប្រើប្រាស់ដោយមិនបង់ថ្លៃ ... ដំណាក់កាលដែលនៅក្រ យើងត្រូវរកវិធី។ យើងបានទិញយកស្ពាន(ដែលវិនិយោគដោយ ឧកញ៉ា) លី យ៉ុងផាត់ដល់ទៅពីរ។ មួយគឺស្ពានកោះកុងនេះ តែមួយទៀតគឺស្ពានព្រែកញៅដែលសុទ្ធតែជាស្ពានត្រូវយកប្រាក់ ព្រោះថាគេបានដាក់ទុនវិនិយោគ ... **យើងប្រើ(វិធីសាស្ត្រនេះ)ជាដំណាក់កាលអន្តរកាលទេ។ តែដល់មានលទ្ធភាព រដ្ឋទិញយកត្រឡប់មកវិញទាំងអស់។ ផ្លូវអ្នកណាធ្វើ អស់ប៉ុន្មានលានៗ នៅសល់ប៉ុន្មានទូទាត់ជាមួយគ្នា រួចហើយប្រជាជនប្រើប្រាស់ដោយលែងបង់ប្រាក់ហើយ ...**៕

២០. កូវីដ-១៩ ស៊ីថវិកា ២៣០០លានដុល្លារ ដែលអាចសង់ស្ពានឆ្លងទន្លេ ស្ទឹងនិងព្រែក

ដាក់ឱ្យប្រើប្រាស់ស្ពានមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រង់-ក្រូចឆ្មារ(ស្ពានភ្ជាប់និស្សយ) និងការប្រកាសបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ 71C, ២៣ វិច្ឆិកា ២០២១

... ខ្ញុំមានការសោកស្តាយដែល កូវីដ១៩ បានស៊ី(ថវិកាដែលយើងសន្សំបាននិងដែលអាចប្រើប្រាស់សង់បាន)ប្រហែលជា ២០ស្ពាន។ ហ្នឹងគិតតម្លៃសាងសង់ខ្ពស់ផង ... **គោលដៅរបស់ខ្ញុំគឺប្រើ២/៣ នៃថវិកាលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់។ នៅពេលដែលប្រាក់សន្សំកើនដល់កម្រិតមួយ ខ្ញុំនឹងចង្អុលឲ្យធ្វើស្ពាននេះធ្វើស្ពាននោះ ... ខ្ញុំចង់ឲ្យធ្វើស្ពានព្រែកស្នោត ២គីឡូ ស្ពានមួយ។ ទន្លេតូច ស្ទឹងពោធិសាត់ ស្ទឹងមង្គលបុរី ស្ទឹងសង្កែ ស្ទឹងសែន ២គីឡូ ឬ៣គីឡូ ជាក់ស្ពានមួយ។ គិតថាស្ពានមួយអស់ ១លានដុល្លារចុះ។ ប្រើតែ ១០០លានបាន ១០០ស្ពានឆ្លងព្រែក។ យើងជាក់ស្ពានឆ្លងទន្លេមេគង្គ ទន្លេបាសាក់ និងទន្លេសាបបន្ថែមទៀត។ មិននឹកស្មានថា កូវីដ១៩ វាទទួលទានអស់ ២៣០០ លាន(ដុល្លារ) ...**៕

២១. គម្រោងស្ពាន/ផ្លូវ៣ ឆ្លងកាត់ទន្លេមេគង្គពីក្រចេះទៅកំពង់ធំ, កំពង់ឆ្នាំងនិងកំពង់ធំ និងរវាងបាត់ដំបងនិងសៀមរាប

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផ្លូវជាតិលេខ១១ តភ្ជាប់រវាងខេត្តព្រៃវែងទៅខេត្តត្បូងឃ្មុំ, ៦ ធ្នូ ២០២១

... ដូចដែលឯកឧត្តម ស៊ុន ចាន់ថុល បានលើកឡើង យើងដាក់(បេក្ខភាព)គម្រោងស្ពានធំៗ៣ ក្រៅពីអ្វីដែលបានបើកការដ្ឋានហើយ។ **គម្រោងមួយគឺស្ពានឆ្លងកាត់ទន្លេមេគង្គនៅទីរួមខេត្តក្រចេះនិងផ្លូវតភ្ជាប់កាត់ស្រុកស្នោងទៅទីរួមខេត្តកំពង់ធំ**។ គម្រោងនេះបង្កើនភាពងាយស្រួល (ប្រៀបដូចជា)ថាបំព្រួញដីតែម្តងសម្រាប់ការដឹកជញ្ជូន។ ភាពចំណេញរបស់វាធំ។ **គម្រោងមួយទៀត គឺធ្វើស្ពានឆ្លងកាត់ទន្លេសាបនិងផ្លូវពីខេត្តកំពង់ឆ្នាំង តម្រង់ឆ្ពោះទៅខេត្តកំពង់ធំ**ដោយអ្នកកំពង់ឆ្នាំង ឬកំពង់ធំមិនចាំបាច់ចុះមកប្រើប្រាស់ស្ពានព្រែកក្តាម(នៅភាគខាងក្រោម)ទេ ... **ឯគម្រោងមួយទៀតដែលកំពុងសិក្សាយ៉ាងយកចិត្តទុកដាក់ គឺការតភ្ជាប់រវាងបាត់ដំបងនិងសៀមរាប ដែលអាច(មានស្ពាន)កាត់ទន្លេសាបទៀត ...**៕

២២. គំរោងស្ពាន៣ តភ្ជាប់និងជម្លៀសចរាចរណ៍ពី និងការកកស្ទះនៅក្រុងភ្នំពេញ

បើកការដ្ឋានសាងសង់ស្ពានអាកាសចំនួន២ ដោយប្រសិទ្ធនាមថាស្ពានអាកាសព្រះមុន្នីវង្ស និងស្ពានអាកាសសម្តេចចៅហ្វាវាំង គង់ សំអុល, ៣១ សីហា ២០២២

... ទីក្រុងភ្នំពេញមានតម្រូវការស្ពាន៣ ទៀតចាំបាច់។ **ស្ពានទី១ គឺកំពុងតែចរចា និងសុំការយល់ព្រម។ ការសិក្សាពីសាធារណរដ្ឋកូរ៉េ ដោយផ្សារភ្ជាប់រវាងទីក្រុងភ្នំពេញទៅស្វាយជ្រុំ។ ពេលជួបអតីតប្រធានាធិបតី Moon Jae-in ខ្ញុំបានស្នើសុំឱ្យកជម្រើសផ្សារភ្ជាប់ស្ពាននេះ ពីផ្សាររាត្រីនៅផ្សារចាស់ឆ្លងទៅចុះនៅជ្រោយចង្វារ ហើយឡើងពីជ្រោយចង្វារចុះទៅស្វាយជ្រុំ ... ស្ពានទី២ ប្រហែលជាពីក្តីតាកុយ ឆ្លងកាត់ទៅម្ខាងទៀត** ដើម្បីជានាក្នុងការជម្លៀសចរាចរណ៍។ ហ្នឹងផ្នែកខាងទន្លេមេគង្គ។ ខាងទន្លេបាសាក់ មានស្ពានព្រះមុន្នីវង្សពីរ និងស្ពានតាខ្មៅហើយ នៅតែកកស្ទះ។ ដូច្នេះហើយ ឯកឧត្តម ស៊ុន ចាន់ថុល ទទួលបានបទបញ្ជាចរចាជាមួយភាគីចិន ដោយ**យើងនឹងកសាងស្ពានមួយទៀតនៅម្តុំព្រែកប្រា ... តម្លៃប្រហាក់ប្រហែលប្រមាណ ៦០លានដុល្លារ** ... ប្រសិនបើមិត្តចិនយល់ស្របនឹងគម្រោងនេះ អាចនឹងបើកការដ្ឋាននៅឆ្នាំក្រោយ ...។

២៣. ចំណាយថវិកាដោះស្រាយផលប៉ះពាល់ ដោយសារចិត្តធម៌រាជរដ្ឋាភិបាល

បើកការដ្ឋានធ្វើអោយប្រសើរឡើងផ្លូវជាតិលេខ៥
ភាគខាងត្បូងព្រែកក្តាម-ឆ្លាម្ពម, ២១ ឧសភា ២០១៨

... **ផ្លូវមួយខ្សែៗ ត្រូវចាយច្រើនណាស់។ ប្រការនេះវាកើតចេញពីទឹកចិត្តធម៌របស់រាជរដ្ឋាភិបាលមុន ក៏ដូចជារាជរដ្ឋាភិបាលដំណាក់កាលក្រោយមក។ ចិត្តធម៌យ៉ាងម៉េច? តាមពិត យើងមានអនុក្រឹត្យស្តីអំពីការទុកចំណីផ្លូវតាំងពីណាពីណី**ឯណោះ ក៏ប៉ុន្តែ ដំបូងឡើយ ប្រជាពលរដ្ឋខ្វីទីតាំងហ្នឹងលក់ចេកអាំង ខ្លះលក់អន្សមអាំង ខ្លះលក់ចេកចៀន ខ្លះលក់នំបញ្ចុកអញ្ចឹងទៅ។ ដល់ទៅលក់យូរៗទៅក្លាយទៅជាតូបលក់(អចិន្ត្រៃយ៍) និងផុតពីតូបលក់ទៅជាផ្ទះតែម្តង។ ពេលរដ្ឋាភិបាលត្រូវយកដីមកធ្វើផ្លូវ ក៏ត្រូវតែយកលុយទៅឱ្យដើម្បីឱ្យគាត់ចាកចេញ ... មានកន្លែងខ្លះ មិនត្រឹមតែមិនចេញទេ ថែមទាំងធ្វើបាតុកម្មទៀតផង ... ទោះបីយ៉ាងម៉េចក៏ដោយ **រាជរដ្ឋាភិបាលក៏ត្រូវរកថវិកាដោះស្រាយផលប៉ះពាល់ ដោយមិនអាចឱ្យគាត់ចេញដោយដៃទទេបានទេ។ ប៉ុន្តែ យើងក៏ត្រូវគិតដែរថាផលប៉ះពាល់នោះប៉ុន្មានដែលវាសមល្មម**...។

២៤. ការធ្វើផ្លូវជាតិលេខ៥ មាន ៣កញ្ចប់ឬដំណាក់កាល

បើកការដ្ឋានគម្រោងធ្វើអោយប្រសើរឡើងកំណាត់ផ្លូវជាតិលេខ៥
ភាគខាងជើងបាត់ដំបង-សិរីសោភ័ណ, ២៦ មីនា ២០១៨

... ថ្ងៃ(២៦មីនា ២០១៨)នេះ យើងបើកការដ្ឋាន(ធ្វើឱ្យប្រសើរឡើងកំណាត់ផ្លូវជាតិលេខ៥ ភាគខាងជើងបាត់ដំបង-សិរីសោភ័ណ)នៅទីនេះ។ នៅថ្ងៃទី២១ ខែឧសភា យើងនឹងបើកការដ្ឋានផ្លូវ(លេខ៥)ដដែលហ្នឹងទៀត ... អញ្ចឹងបងប្អូនមួយចំនួនអាចចោទជាសំណួរថា តើផ្លូវជាតិលេខ៥ ធ្វើពីបាត់ដំបង ទៅស៊ីសុផុន ហើយធ្វើតែត្រឹមឆ្លាម្ពម មកពោធិ៍សាត់ ឬយ៉ាងណា? ... **ផ្នែកខាងជើង(ទី១)គឺកំណាត់ផ្លូវពីបាត់ដំបងទៅសិរីសោភ័ណ ... ជាដំណាក់កាលមួយ**ដែលនៅពេលសាងសង់ចប់ រវាងទីក្រុងបាត់ដំបងនិងទីក្រុងសិរីសោភ័ណ នឹងមិនមានការស្ទះចរាចរណ៍ដូចពីពេលមុននោះ ... **ទី២ គឺផ្នែកខាងត្បូង ជាកំណាត់ផ្លូវពីស្ពានព្រែកក្តាម ដល់ឆ្លាម្ពមក្រពោធិ៍សាត់ ...** ជាដំណាក់កាលទី២ ឬជាកញ្ចប់ទី២ នៃការអនុវត្តគម្រោង ... **ទី៣ គឺផ្នែកកណ្តាលនិងផ្នែកបញ្ចប់។ ផ្នែកកណ្តាលគឺកំណាត់ផ្លូវពីឆ្លាម្ពមក្រុងពោធិ៍សាត់ មកក្រុងបាត់ដំបង និងកំណាត់ផ្លូវពីក្រុងសិរីសោភ័ណទៅដល់ក្រុងប៉ោយប៉ែត ...** សរុបពីទីក្រុងភ្នំពេញមកទល់នឹងព្រំដែនមាន ៤០០ គីឡូម៉ែត្រ ... គឺជប៉ុនជាអ្នកប៉ាវក្នុងការកសាង ...។

២៥. ផ្លូវជាតិលេខ៥ តភ្ជាប់ ASEAN Highway ទី១ ឬក៏របៀងខាងត្បូង

បើកការដ្ឋានគម្រោងធ្វើអោយប្រសើរឡើងកំណាត់ផ្លូវជាតិលេខ៥
ភាគខាងជើងបាត់ដំបង-សិរីសោភ័ណ, ២៦ មីនា ២០១៨

... ឆ្នាំទៅ(ខ្ញុំបាន)មក(បាត់ដំបង)ជាមួយឯកឧត្តម Kumamaru Yuji ដើម្បីសម្ពោធដាក់អោយប្រើប្រាស់(ប្រព័ន្ធ)ទឹកស្អាត ... ថ្ងៃមុន(មានការសម្ពោធ)មន្ទីរពេទ្យជាមួយសម្តេចក្រឡាហោម ស ខេង។ អញ្ចឹង យើងធ្វើសមិទ្ធផលបានច្រើនដើម្បីជានាថាប្រទេសយើងមានការរីកចម្រើន តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធ។ **ផ្លូវមួយខ្សែនេះ ជប៉ុនបានដើរតួនាទីក្នុងការតភ្ជាប់ ASEAN Highway ទី១ ឬក៏របៀងខាងត្បូង ដែលតភ្ជាប់ពីទីក្រុងបាងកក ចូលមកកាន់ទីក្រុងភ្នំពេញ ហើយតភ្ជាប់ពីទីក្រុងភ្នំពេញទៅទីក្រុងហូជីមិញ តាមផ្លូវជាតិលេខ៥ ផងនិងតាម**

ផ្លូវជាតិលេខ១ និងស្ពានអ្នកលឿងផង។ នេះជាផ្លូវយុទ្ធសាស្ត្រមួយរបស់កម្ពុជា ហើយផ្លូវជាតិលេខ៥នៅចំកណ្តាលមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍប្រទេស ...៕

២៦. តភ្ជាប់តំបន់មាត់សមុទ្រ ទាក់ទាញទេសចរនិងជារបៀងសេដ្ឋកិច្ចក្នុង/ក្រៅប្រទេស

បើកការដ្ឋានសាងសង់ផ្លូវជាតិលេខ៣ ពីរង្វង់មូលចោមចៅទៅទីរួមខេត្តកំពត, ៧ ឧសភា ២០១៨

... យើងកំពុងតែពង្រីកហេដ្ឋារចនាសម្ព័ន្ធ ដើម្បីតភ្ជាប់ទៅតារាងនៃទិសនិរតី។ យើងបានធ្វើការខិតខំយ៉ាងច្រើន ដើម្បី**អភិវឌ្ឍបណ្តាខេត្តនានានៅមាត់សមុទ្រ ក្នុងនោះមានខេត្តជាប់មាត់សមុទ្រនៅភាគនិរតីផង និងភាគបស្ចិមផងដែរ។ យើងប្រើពាក្យនិរតី ដោយរួមបញ្ចូលខេត្តកំពត កែប ព្រះសីហនុ និងខេត្តកោះកុង ... ដោយមិនគ្រាន់តែជាការសំដៅទៅលើទេសចរទេ តែខេត្តទាំងប៉ុន្មាននៅហ្នឹងមាត់សមុទ្ររបស់យើង សុទ្ធតែជាច្រករបៀងសេដ្ឋកិច្ច ហើយសុទ្ធតែជាខេត្តដែលតភ្ជាប់ជាមួយសេដ្ឋកិច្ចក្នុងនិងក្រៅប្រទេស ...៕**

២៧. បង្វិលទិសពង្រីកផ្លូវជាតិលេខ៥ពីទំនប់កប់ស្រូវមកផ្លូវជាតិលេខ៤ និងតម្រង់ទៅតាខ្មៅជំនួសវិញ

សម្ពោធស្ពានអាកាសមិត្តភាព កម្ពុជា-ចិន សែនសុខ, ២ កក្កដា ២០១៨

... **បង្វិលទិស(ពង្រីកផ្លូវជាតិលេខ៥) មកតាមទំនប់កប់ស្រូវ ដើម្បីចេញមកកាត់ផ្លូវជាតិលេខ៤ វិញ**។ ហេតុអ្វីបានជាធ្វើផ្លូវបួនគន្លងពីទំនប់កប់ស្រូវទៅស្ពានព្រែកក្តាមនិងទៅដល់ប៉ោយប៉ែត ... ប៉ុន្តែពីទំនប់កប់ស្រូវចូលមកទីក្រុងភ្នំពេញនៅសល់តែពីរគន្លង? សូមញាតិញោមជួយគិតខ្ញុំព្រះករុណាខ្ញុំ។ បើសិន(ជាយើងពង្រីកផ្លូវពីទំនប់កប់ស្រូវចូលមកទីក្រុងភ្នំពេញជាបួនគន្លង) ប្រជាពលរដ្ឋនឹងបាត់បង់ផ្ទះសម្បែងក្នុងចម្ងាយរាប់គីឡូ(ម៉ែត្រតាមដងផ្លូវ)។ វាដោយទៅទាំងវត្ត ទាំងវិហារឥស្លាម ទាំងផ្ទះប្រជាពលរដ្ឋ ទាំងហាងលក់ដូរដែលកំពុងតែលក់ស៊ុបលក់អីរាល់ថ្ងៃ តាមមាត់ទន្លេហ្នឹង។ ដោយមូលហេតុនេះក៏សុំថាធ្វើតែត្រឹមប៉ុណ្ណឹងចុះ ហើយ**បង្វិលទិសមកតាមទំនប់កប់ស្រូវ តភ្ជាប់មកផ្លូវជាតិលេខ ៤ ហើយកាត់ផ្លូវជាតិលេខ៤ តម្រង់ទៅតាខ្មៅឯណោះវិញ ... ប៉ុន្តែនៅខ្សែក្រវាត់មួយជាន់ទៀត ទើបអាចដោះស្រាយបានបញ្ហាដែលមាននៅទីក្រុងភ្នំពេញ ...៕**

២៨. អតុល្យភាពរវាងមធ្យោបាយច្រើន ចំនួនផ្លូវតិចនិងទំហំតូច

បើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុងខ្សែទី៣ (ផ្លូវជាតិលេខ ៤ ដល់ ១), ១៤ មករា ២០១៩

... អ្នកដែលមានលទ្ធភាពទិញឡានក៏ទិញឡាន អ្នកដែលមានលទ្ធភាពទិញម៉ូតូក៏ទិញម៉ូតូ ឯអ្នកដែលមានលទ្ធភាពទិញកង់ក៏ទិញកង់។ ដោយហេតុនេះចំនួនមធ្យោបាយធ្វើដំណើររបស់ប្រជាពលរដ្ឋកាន់តែមានចំនួនច្រើនទៅ និងទំនើបទៅ... ប៉ុន្មានឆ្នាំមុននោះ **ខ្ញុំបានលើកអំពីអតុល្យភាពក្នុងវិស័យមួយចំនួន ក្នុងនោះមានអតុល្យភាពរវាងតម្រូវការរបស់ប្រជាជនក្នុងការធ្វើដំណើរ ជៀបទៅនឹងការខ្វះមធ្យោបាយធ្វើដំណើរ។ ឥឡូវនេះ អតុល្យភាពប្រភេទនោះ ត្រូវបានលុបបំបាត់ហើយៗ វាមកមានអតុល្យភាពរវាងមធ្យោបាយធ្វើដំណើរច្រើន ជៀបទៅផ្លូវថ្នល់មានទំហំតូចនិងចំនួនតិចជំនួសវិញ**។ ស្ថានភាពវាអត់ដូចគ្នា។ កាលពីប្រហែល ២០ឆ្នាំមុន មានអតុល្យភាពរវាងសេចក្តីត្រូវការធ្វើដំណើរ និងការដឹកជញ្ជូន ដែលច្រើនជាងមធ្យោបាយធ្វើដំណើរនិងដឹកជញ្ជូនមិនគ្រប់គ្រាន់។ ឥឡូវនេះ មធ្យោបាយធ្វើដំណើរច្រើនពេក ឯផ្លូវថ្នល់នៅតូច និងថែមទាំងខ្វះផង ...៕

២៩. អតុល្យភាពរៀបរាប់ក្នុងសៀវភៅ "១០ឆ្នាំនៃដំណើរកម្ពុជា" បានផ្លាស់ប្តូរ

បើកការដ្ឋានពង្រីកនិងលើកកម្ពស់គុណភាពកំណាត់ផ្លូវជាតិលេខ៧ ជា ៤គន្លង ប្រវែង ៤៥,៤៧៩ គីឡូម៉ែត្រ, កំពង់ចាម, ៩ មករា ២០២៣

... នៅក្នុងសៀវភៅ(មានចំណងជើងថា) "១០ឆ្នាំនៃដំណើរកម្ពុជា" ដែលខ្ញុំបានសរសេរ មាន(រៀបរាប់អំពី)អតុល្យភាពច្រើន ក្នុងនោះក៏មាន**អតុល្យភាពរវាងសេចក្តីត្រូវការនៃការធ្វើដំណើរ ជាមួយការខ្វះមធ្យោបាយនៃការដឹកជញ្ជូន។ ឥឡូវអតុល្យភាពនេះបានផ្លាស់ប្តូរហើយ គឺទៅជាអតុល្យភាពរវាងមធ្យោបាយធ្វើដំណើរច្រើនពេក ជាមួយនឹងផ្លូវតូច។ (ការកំណត់អតុល្យភាព)តាមដំណាក់កាលនីមួយៗគឺមិនដូចគ្នាទេ។** យើងត្រូវតែធ្វើបច្ចុប្បន្នភាពអំពីតម្រូវការជាក់ស្តែង ដើម្បីយើងដាក់គោលដៅវិនិយោគឱ្យបានត្រូវ។ បើពុំដូច្នេះទេ យើងច្បាស់ជានឹងធ្វើកំហុសក្នុងការកសាងប្រទេស ...៕

៣០. អ្នកកោះអន្លង់ចិន ស្រុកស្អាង សំណាងបានស្ពានធំ និងលែងប្រើទូកដ

បើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុងខ្សែទី៣ (ផ្លូវជាតិលេខ៤ ដល់១),
១៤ មករា ២០១៩

... អ្នកដែលសំណាងជាងគេនៅផ្លូវខ្សែក្រវាត់ក្រុងនេះគឺកោះអន្លង់ចិន ស្រុកស្អាង។ ផ្លូវខ្សែក្រវាត់ក្រុងលាតសន្ធឹងរហូតដល់ស្រុកស្អាង ហើយត្រូវធ្វើស្ពានមានទទឹងរហូតទៅដល់ ២៥ម៉ែត្រឯណោះ ... **ធ្វើស្ពានដើម្បីជាខ្សែក្រវាត់ក្រុង ឆ្លងកាត់កោះអន្លង់ចិន រាងម្ខាងត្រើយខាងកើត និងត្រើយខាងលិច ... ធ្វើឲ្យអ្នកអន្លង់ចិន ដែលធ្លាប់តែពឹងពាក់ជីវិតលើអ្នករត់ទូកដ(កាន់តែមានភាពងាយស្រួល)។** ជីវិតអ្នករត់ទូកដនៅកោះអន្លង់ចិន នឹងត្រូវបញ្ចប់នៅឆ្នាំ២០២១ ... ហេតុអីបានជាធ្វើស្ពានដល់ទៅ ២៥ម៉ែត្រ? គឺដើម្បីកុំឲ្យវាទៅជាកងបៗ។ ផ្លូវរបស់យើងមានទទឹង ២៥ម៉ែត្រ ... ដូចនេះចាត់ថាជាស្ពានដ៏ធំ បម្រើដល់ប្រព័ន្ធដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋ កាត់បន្ថយការកកស្ទះ និងបង្កើតភាពចំណេញសម្រាប់ប្រជាពលរដ្ឋរបស់យើង ...៕

៣១. នឹងកសាងផ្លូវពីក្រោមទន្លេ មិនបាច់ធ្វើស្ពាន

បើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុង ខ្សែទី៣ (ផ្លូវជាតិលេខ៤ ដល់១),
១៤ មករា ២០១៩

... ឥឡូវយើងមាន(ស្ពានអាកាស)៥ កំពុងដាក់ឲ្យប្រើប្រាស់ កំពុងសាងសង់មួយនៅចោមចៅ ហើយនឹងកសាងមួយទៀត។ បន្តិចទៀត ស្ពានអាកាសលែងជាអ្វីដែលយើងយកមកអួតហើយ ព្រោះវាមានលើសពី១០។ ដោយចាប់ផ្តើមពីមានតែមួយហ្នឹង ដែលត្រូវតែអួត។ **បន្តិចទៀត យើងនឹងគិតពីការធ្វើផ្លូវក្រោមបាតទន្លេ គឺមិនចាំបាច់ធ្វើស្ពានឆ្លងទន្លេទេ។ លែងផ្លូវពីក្រោមទន្លេទៀត។ បានទី១ ហ្នឹងអួតចេញភ្លើងហើយ។ មិនឲ្យអួតម៉េច វាត្រូវតែអួត។ ដល់ទៅមានច្រើនចូលដល់រាប់សិប លែងអួតហើយ។** ដូចចិនឥឡូវ គាត់ចាំបាច់អួតអី បើទៅសៀងហៃវិញសឹងតែថាធ្វើដំណើរលើផ្លូវអាកាសរហូត។ នៅទីក្រុងសៀងហៃ ធ្វើដំណើរទៅជួបមេដឹកនាំនៅកន្លែងធ្វើការស្ទើៗ ឃើញតែធ្វើដំណើរលើស្ពានអាកាស។ ស្ពានវែងជាងគេលើពិភពលោក កាត់ដៃសមុទ្រគឺមាននៅប្រទេសចិន។ ពីមុនពី Shenzhen ទៅហុងកុង។ ឥឡូវស្ពានមានណាមួយនោះដែលភ្ជាប់ពី ម៉ាកាវ ទៅ ហុងកុង ...៕

៣២. ផ្លូវជាតិលេខ៧ ឆ្ពឹងខ្នងមួយសំរាប់តភ្ជាប់ភូមិភាគកណ្តាលទៅឦសាននិងឧត្តរ

បើកការដ្ឋានពង្រីកនិងលើកកម្ពស់គុណភាពកំណាត់ផ្លូវជាតិលេខ៧
ខេត្តកំពង់ចាម, ៩ មករា ២០២៣

... សន្តិភាពបានផ្តល់ឱកាសឲ្យយើងអភិវឌ្ឍ ដូចដែលឯកឧត្តម វ៉ាង វិនធានបានលើកអម្បាញ់មិញ ... ខ្ញុំចង់និយាយអំពីផ្លូវជាតិលេខ៧ របស់យើងនេះ ដើម្បីយើងអាចមើលឃើញថា **(ផ្លូវជាតិលេខ៧)នេះគឺជាឆ្ពឹងខ្នងមួយសម្រាប់កំណើនតភ្ជាប់ភូមិភាគកណ្តាលទៅឦសានទិសរបស់យើង។ ក្នុងតំបន់ភូមិភាគកណ្តាលនេះ គឺយើងតភ្ជាប់នៅខេត្តកំពង់ចាមខ្លួនឯង និងក៏តភ្ជាប់ទៅកាន់កំពង់ធំ ហើយក៏តភ្ជាប់ទៅកាន់ផ្នែកផ្សេងៗ នៃទិសឧត្តររបស់យើង។ ក៏ប៉ុន្តែឆ្ពោះទៅកាន់ទិសឦសាន ផ្លូវនេះវាបានតភ្ជាប់ឱ្យយើងទៅខេត្តព្រៃវែង ដែលអាចតភ្ជាប់ទៅភ្នំពេញតាមរយៈផ្លូវជាតិលេខ ១១ តាមរយៈផ្លូវលេខ ៨ ផងដែរ** ...៕

៣៣. តភ្ជាប់ស្រុកព្រៃកប្រសព្វ/ក្រចេះ ទៅស្រុកសណ្តាន់និងស្រុកកំពង់ថ្ម/កំពង់ធំ

បើកការដ្ឋានសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គពីស្រុកចិត្របុរី
ទៅស្រុកព្រៃកប្រសព្វ ខេត្តក្រចេះ, ២ មករា ២០២៣

... នៅខាងត្រើយម្ខាង **យើងមិនមែន(ធ្វើ)ត្រឹមតែប៉ុណ្ណឹងទេ។ គោលដៅរបស់យើងគឺតភ្ជាប់ស្រុកព្រៃកប្រសព្វ ឆ្លងកាត់ទៅស្រុកសណ្តាន់ និងចេញទៅកំពង់ថ្មឯខេត្តកំពង់ធំឯណោះ** ... (ការតភ្ជាប់នេះ)ធ្វើឱ្យផែនដីកាន់តែតូចទៅៗ។ មិនមែនដីរួញទេ។ ដីយើងមិនបាត់ទៅណាទេ ក៏ប៉ុន្តែការ(តភ្ជាប់ជាបណ្តាញផ្លូវស្ពាននេះ)ដោះស្រាយ(ការធ្វើដំណើរអោយបានឆាប់)ឱ្យប្រជាពលរដ្ឋ ... មុននេះយើងឆ្លងទូកដ ដ៏លំបាកទាំងការភ័យខ្លាច ហើយក៏មានពេលកំណាត់ផងដែរ។ ទូកដឬក៏ហៅថាកាណូតដវាមិនធំទេ។ ប៉ុន្តែយើងអត់មានជម្រើសទេ។ យើងត្រូវតែឆ្លងវា។ លំបាកជាងគេ នៅពេលដែលមានអ្នកជំងឺ ដែលជួនកាលត្រូវបញ្ជូនមកកាន់មន្ទីរពេទ្យ ប៉ុន្តែមិនមានលទ្ធភាពចម្លងមកបាន។ ជំងឺមិនគួរស្លាប់ក៏អាចស្លាប់បាន ...៕

៣៤. ពង្រីកសមត្ថភាពកំពង់ផែទឹកជ្រៅ ដែលគ្របដណ្តប់៧០% នៃសកម្មភាពទំនិញ

សម្ពោធចំណតផែពហុបំណងកំពង់ផែស្វយ័តក្រុងព្រះសីហនុ, ២៥ មិថុនា ២០១៨

... យើងបានបង្កើន(ជំរៅទឹក)ថែម ១ម៉ែត្រ គឺពី ១៣,៥ម៉ែត្រ នៅពេលនេះ ដល់ ១៤,៥ម៉ែត្រ ដែលអាចឲ្យកប៉ាល់ធំជាងចូលមកដល់។ ខ្ញុំព្រះករុណាខ្ញុំនៅតែប្រមើលមើលឃើញថា វាមិនទាន់គ្រប់គ្រាន់ដើម្បីឆ្លើយតបទៅការដឹកជញ្ជូន ក្នុងកម្រិតដែលមិនចាំបាច់លើកដាក់តាមរយៈកំពង់ផែនៃប្រទេសដទៃ ដែលមានជំរៅទឹកជ្រៅជាងយើង។ ខ្ញុំព្រះករុណាខ្ញុំគិតថា ដំណាក់កាលទី៦ នេះ មិនមែនជាដំណាក់កាលចុងក្រោយទេ ... **JICA នឹងសិក្សាជាមួយយើងបន្តទៀតដើម្បីក្រោយពីដំណាក់កាលមួយទៅដំណាក់កាលមួយ គឺយើងនឹងពង្រីកសមត្ថភាពនៃការដឹកជញ្ជូនតាមច្រកកំពង់ផែទឹកជ្រៅ ដែលគ្របដណ្តប់ទំនិញរហូតដល់ជាង ៧០% នៃទំនិញតាមច្រកចេញចូល** ...។

៣៥. ប្រើប្រាស់គ្រប់វិធីបញ្ចៀសការធ្វើឯកជនភាវូបនីយកម្មកំពង់ផែក្រុងព្រះសីហនុ

សម្ពោធចំណតផែពហុបំណងកំពង់ផែស្វយ័តក្រុងព្រះសីហនុ, ២៥ មិថុនា ២០១៨

... ទាក់ទងជាមួយនឹងតួនាទីរបស់ជប៉ុន ខ្ញុំព្រះករុណាខ្ញុំគួរតែលើកមកបញ្ជាក់ជូនបន្តិច ដើម្បីបង្ហាញថាតើជប៉ុនបានចាប់ផ្តើមពីពេលណា។ **គួរតែរំលឹកអំពីការដែលខ្ញុំព្រះករុណាខ្ញុំបានខិតខំថែទាំកំពង់ផែមួយនេះ មិនឱ្យធ្លាក់ទៅជាអ្វីដែលហៅថា "ឯកជនភាវូបនីយកម្មកំពង់ផែក្រុងព្រះសីហនុ" បន្ទាប់ពីការបាត់បង់នូវព្រលានយន្តហោះ។ ពេលនោះ ក្រុមហ៊ុនច្រើន ពីស្ទើរតែគ្រប់កន្លែងចង់បានកំពង់ផែក្រុងព្រះសីហនុនេះ។ ខ្ញុំព្រះករុណាខ្ញុំ បានប្រើប្រាស់វិធីសាស្ត្រគ្រប់បែបយ៉ាងបញ្ចៀសការធ្វើឯកជនភាវូបនីយកម្មកំពង់ផែក្រុងព្រះសីហនុ។ ប្រសិនបើយើងធ្វើឯកជនភាវូបនីយកម្ម ជប៉ុននឹងមិនផ្តល់ប្រាក់កម្ចី សម្រាប់ការអភិវឌ្ឍកំពង់ផែមួយនេះទេ** ... ខ្ញុំបានមកទីនេះ ហូបបាយជាមួយបងប្អូន ហើយក៏មានវត្តមានរៀងរាល់ឆ្នាំថែទាំនិងរក្សាទុកកំពង់ផែនេះ។ បើមិនដូចនេះ កំពង់ផែមួយនេះធ្លាក់ទៅក្នុងដៃឯកជនបាត់ទៅហើយ។ វាមានចរន្តនៃការគិតគូរខុសគ្នាពីមនុស្សម្នាក់ទៅកាន់មនុស្សម្នាក់ផ្សេងទៀត។ ក៏ប៉ុន្តែកម្មករ/ការិនីនៅទីនេះអាចដឹងនិងយល់បានថា ខ្ញុំបានប្រឹងប្រែងការពារកំពង់ផែនេះ។ ហេតុនេះហើយ ខ្ញុំតែងយកថ្ងៃទី១ ឧសភារៀងរាល់ឆ្នាំចុះមក ឬក៏បញ្ជូនតំណាងមក ...។

៣៦. ការពង្រីកសមត្ថភាពកំពង់ផែក្រុងព្រះសីហនុ ប្រើឥណទានជប៉ុន ៣៨១លានដុល្លារ

សម្ពោធចំណតផែពហុបំណងកំពង់ផែស្វយ័តក្រុងព្រះសីហនុ, ២៥ មិថុនា ២០១៨

... រហូតមកដល់បច្ចុប្បន្ន សម្រាប់កំពង់ផែមួយនេះ យើងបានចុះហត្ថលេខានិងទទួលឥណទាន ទាំងឥណទានចុងក្រោយចំនួន ២៣៣ន់ ៥យលានយេន ត្រូវជាប្រមាណ ២០៣លានដុល្លារសហរដ្ឋអាមេរិក។ **សរុបមកដល់ពេលនេះ យើងបានប្រើប្រាស់ឥណទានរបស់ជប៉ុន ចំនួន ៤៣៣ន់ ១០២លានយេន ឬត្រូវជាប្រមាណ ៣៨១លានដុល្លារសហរដ្ឋអាមេរិក ដើម្បីពង្រីកសមត្ថភាពកំពង់ផែកំពង់សោមនេះ**។ ថ្ងៃនេះ យើងប្រកាសថា នាវាចំណុះ ២ ឬ៣ ឬ៤ ឬ៥ ម៉ឺនតោន ដែលមុននេះត្រូវផ្ទេរនៅសិង្ហបុរី នៅវៀតណាម នៅថៃ ឬនៅម៉ាឡេស៊ី នឹងមិនចាំបាច់ផ្ទេរនៅទីនោះទៀតទេ។ សូមអញ្ជើញចូលមក ...។

៣៧. ក្រុងព្រះសីហនុ មជ្ឈមណ្ឌលតភ្ជាប់ដឹកជញ្ជូនរវាងផ្លូវទឹកនិងផ្លូវគោក និងផ្លូវអាកាស

សំណេះសំណាលជាមួយនឹងមន្ត្រីរាជការ និងក្រុមការងារបច្ចេកទេសស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុង ក្នុងខេត្តព្រះសីហនុ, ១ មិថុនា ២០២០

... គោលដៅធំរបស់យើងគឺ **បង្កើតទីជាទីក្រុងពហុបំណង។ ម៉េចបានជាយើងត្រូវនិយាយពីទីក្រុងពហុបំណង? យើងត្រូវមើលឃើញថាក្រុង(ព្រះសីហនុ)បានដើរតួជាមជ្ឈមណ្ឌលនៃការដឹកជញ្ជូនតភ្ជាប់ពីផ្លូវទឹកទៅផ្លូវគោក ពីផ្លូវគោកទៅផ្លូវទឹក ការដឹកតភ្ជាប់ផ្លូវអាកាសពីតំបន់ក្នុងប្រទេសចូលមកទីនេះ និងពីក្រៅប្រទេសចូលមកព្រលានយន្តហោះកងកេង ជាតំបន់ទេសចរណ៍ និងអាចអនាគតប្រែក្លាយទៅជាមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិ**។ នេះគឺជាការស្រមៃ។ ប្រហែលជាត្រូវការមនុស្សជំនាន់ក្រោយ ធ្វើកិច្ចការនេះបន្តទៀត។ កន្លែងនេះ ក៏ជាតំបន់ឧស្សាហកម្ម។ គ្រាន់តែតំបន់សេដ្ឋកិច្ចពិសេសមានរហូតដល់ទៅ២ ដែលមួយជាតំបន់សេដ្ឋកិច្ចពិសេសវិនិយោគដោយចិន និងមួយទៀតជាតំបន់សេដ្ឋកិច្ចពិសេសវិនិយោគដោយជប៉ុន ...។

៣៨. ពីខ្វះទឹក ខ្វះភ្លើង ខ្វះមធ្យោបាយធ្វើដំណើរ មកស្នះផ្លូវ ស្នះលូ ស្នះសំរាម

បើកការដ្ឋានស្ពានអាកាស និងផ្លូវក្រោមដីរង្វង់មូលចោមចៅ, ២៩ មិថុនា ២០១៨

... ទឹកជីរបស់យើងដែលមុននេះ ជាទីក្រុងខ្មោច ជាទីក្រុងដែលគ្មានសកម្មភាព ឥឡូវបានក្លាយជាទីក្រុងដែលប្រឈមនឹងបញ្ហាថ្មីៗ។ **កាលពីឆ្នាំ១៩៧៩ និងទសវត្សរ៍៨០ យើងមានការលំបាក និងការងាយស្រួលមួយបែបរបស់វា។ វាមានការលំបាកហើយ ដូចជាខ្វះទឹក ខ្វះភ្លើង ខ្វះមធ្យោបាយធ្វើដំណើរក្នុងទីក្រុង ... ប៉ុន្តែមកដល់ពេលនេះ បញ្ហាប្រឈមថ្មីៗ បានកើតឡើងសម្រាប់យើង គឺ(ស្ថានភាពទាំងនោះបាន)បែរទៅជាកកស្នះចរាចរណ៍ កកស្នះលូ និងកកស្នះសំរាម**។ គ្រាន់តែមិនបានយកប៉ុន្មានថ្ងៃ ត្បិតមិនមានឡានសំរាម និងមិនមានកម្មករយកសំរាមដោយត្រូវចំបុណ្យតែប៉ុន្មានថ្ងៃ សំរាមកកកុញពេញទីក្រុង។ ដោយសារអី ? ដោយសារតែសំបូរស៊ីហ្នឹងហើយ បានមានសំរាមច្រើន ...។

៣៩. លូក្នុងក្រុងភ្នំពេញ ធ្វើខ្លួនឯងផង ជប៉ុនជួយផង

បើកការដ្ឋានស្ពានអាកាស និងផ្លូវក្រោមដីរង្វង់មូលចោមចៅ, ២៩ មិថុនា ២០១៨

... រឿង(លិច)នេះ វាបានកើតតាំងពីស្រុកចិន ធ្លាក់មកភូមា មកឡាវ ថៃ យើងរហូតដល់វៀតណាម។ ហ្នឹងដែលហៅថាទឹកជំនន់។ វាបណ្តាលមកពីផ្នែកទ្រទ្រង់ និងរំដោះទឹកខាងក្រោម។ ចោទជាសំណួរ ហេតុអីបានមានទឹកជំនន់ ... មិនមែនមានតែនៅកម្ពុជាទេ។ បើឆ្នាំទៅមួយ ជំនាន់ យីងឡាក់ ធ្វើនាយករដ្ឋមន្ត្រី ក្រុងបាងកក លិចចូលដល់រាប់ខែឯណោះ។ ប៉ារីសក៏ធ្លាប់លិច ក្រុងរ៉ូមក៏ធ្លាប់លិច ... មូលហេតុងាយយល់ទេ។ លូវាធំហើយ ប៉ុន្តែលូនោះមិនគ្រប់ មិនធន់ល្មមជាមួយនឹងទឹកធ្លាក់ពីខាងលើខ្លាំង។ **នៅទីក្រុងភ្នំពេញនេះ យើងធ្វើ(លូដោយ)ខ្លួនឯងផង ជប៉ុនជួយធ្វើផង (ទើប)បានប៉ុណ្ណឹង។ បើនិយាយពីអតីតកាល ដោយធ្លាប់នៅក្នុងទីក្រុងនេះច្រើនឆ្នាំដែរ ម៉ុំផ្លូវកម្ពុជាក្រោម ម៉ុំសណ្ឋាគារប្រេស៊ីដង់ ពីដើមជាក់ស្តែងដើរទេ។ ផ្លូវកម្ពុជាក្រោម ឬផ្លូវ ៣០ម៉ែត្រហ្នឹង សងខាងផ្លូវហ្នឹងទឹកលិចទេ ហើយមិនមែនមួយថ្ងៃពីរថ្ងៃទេ។ លិចរាប់ខែ ... ហ្នឹងនិយាយឲ្យវាសច្ចធម៌ ...**។

៤០. បរិមាណទឹកភ្លៀងឬពីផ្នែកណាមួយលើសពីសមត្ថភាពរំដោះរបស់លូទើបមានជំនន់

បើកការដ្ឋានសាងសង់សំណង់ផ្សេងៗ ក្នុងគម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយលូ ក្នុងរាជធានីភ្នំពេញ ជំហានទី៤, ៤ មីនា ២០១៩

... នៅទីក្រុងភ្នំពេញរបស់យើងនេះ វាងាយ(លិច)ណាស់ ពេលដែលទឹកធ្លាក់មកលើសកម្រិតនៃការទទួលបាន ឬលើសចំណុះដែលលូអាចស្រូបយកបាន។ ប្រទេសជប៉ុនឆ្នាំទៅ នៅទីក្រុងណាមួយនោះ មានស្លាប់មនុស្ស(ដោយសារជំនន់)ក្នុងទីក្រុងតែម្តង។ នេះសមត្ថភាពរបស់ជប៉ុនផង ... ប្រទេសជប៉ុនមានលូធំៗដែលអាចរំដោះទឹកបានលឿន ប៉ុន្តែពេលត្រូវរាយប្រហារដោយជំនន់ទឹកភ្លៀង(ក្នុងបរិមាណច្រើន)ក៏(លិចលង់)ធ្វើឲ្យមានមនុស្សស្លាប់។ (ករណីជន់លិចនេះក៏មាន)នៅបារាំង នៅអ៊ីតាលី នៅប្រទេសនានារាប់ទាំងសហរដ្ឋអាមេរិក ... **សួរថាជំនន់នោះកើតមកពីអី ? វាកើតមកពី(បរិមាណ)ធ្លាក់ចុះនៃទឹកភ្លៀង ឬក៏ទឹកមកពីផ្នែកណាមួយ វាទៅផុតពីសមត្ថភាព នៃការទទួលបាន។ ជាអកុសលនៅកម្ពុជាខ្វះសុចរិតភាពនៃការធ្វើអត្ថាធិប្បាយត្រង់ថា ពេលដែលភ្លៀងធ្លាក់ហួសកម្រិតសមត្ថភាព(លូ) ជួនកាលលេងក្នុងមួយថ្ងៃមួយយប់ ៣០០មីលីម៉ែត្រអី ... បែរជាមានអ្នកបង្ហោះហ្វេសប៊ុកព្រោងព្រាត ឌឺពីសមត្ថភាពគ្រប់គ្រងរបស់ ហ៊ុន សែន សមត្ថភាពគ្រប់គ្រងរបស់ ប៉ា សុជាតិវង្ស ហើយចុងក្រោយនេះពីសមត្ថភាពគ្រប់គ្រងរបស់ ឃួង ស្រេង។ ខ្ញុំទទួលយក ប៉ុន្តែសុំធ្វើការវិនិច្ឆ័យដោយសុចរិតភាព ...**។

៤១. ជប៉ុនជួយគម្រោងការពារទឹកជំនន់ កែលំអប្រព័ន្ធប្រឡាយលូ ៤ដំណាក់កាលហើយ

បើកការដ្ឋានសាងសង់សំណង់ផ្សេងៗ ក្នុងគម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយលូ ក្នុងរាជធានីភ្នំពេញ ជំហានទី៤, ៤ មីនា ២០១៩

... ដោយសារតែយើងទទួលស្គាល់ថា កម្រិតសមត្ថភាពនៃការទទួលទឹកវាមិនគ្រប់គ្រាន់នេះហើយ បានជាយើងស្នើសុំឲ្យមានការសិក្សាពី JICA ពីរដ្ឋាភិបាលជប៉ុន។ **សំរាប់ទីក្រុងភ្នំពេញនេះ អ្នកដែលផ្តល់ជំនួយតាំងពីដំណាក់ទី១ ទី២ ទី៣ និងទី៤ នៅថ្ងៃនេះ គឺមិត្តជប៉ុន។ ដំណាក់កាលទាំងនេះសុទ្ធសឹងមានការសិក្សាជាក់លាក់ពីអង្គការសហប្រតិបត្តិការអន្តរជាតិរបស់ជប៉ុន JICA។** យើងត្រូវ

ពង្រីកបន្ថែមប្រព័ន្ធលូ បញ្ចៀសការទម្លាក់ទឹកស្អុយពីទីក្រុងភ្នំពេញចូលទៅទន្លេមេគង្គ ទន្លេសាប ...។

៤២. សុំជំនួយពីក្រៅផងវិនិយោគខ្លួនឯងផង ដើម្បីធ្វើលូរំដោះនិងទាញទឹកចេញពីទីក្រុង

បើកការដ្ឋានសាងសង់សំណង់ផ្សេងៗ ក្នុងគម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយលូ ក្នុងរាជធានីភ្នំពេញ ដំហានទី៤, ៤ មីនា ២០១៩

... នៅតំបន់នេះ ទឹកដែលធ្លាក់ទៅទន្លេពិតប្រាកដ គឺមានខាងទន្លេសាប ហើយក៏មានខាងទន្លេបាសាក់។ ឯទន្លេមេគង្គងាកទៅម្ខាង ព្រោះយើងស្ថិតនៅចំទន្លេបួនមុខ ... ដែលទន្លេមេគង្គស្ថិតនៅត្រើយម្ខាងនោះ ឯទន្លេសាបស្ថិតនៅខាងនេះ និងទន្លេបាសាក់ស្ថិតនៅខាងក្រោមព្រះបរមរាជវាំង។ យើងត្រូវទទួលស្គាល់ថា សមត្ថភាពប្រព័ន្ធលូរបស់យើងមិនទាន់គ្រប់ទេ។ **ដូច្នេះហើយបានជាយើងមានតម្រូវការកសាងបន្ថែម ដោយស្នើសុំជំនួយពីជប៉ុន។ (យើងត្រូវ)ស្នើសុំជំនួយ ឬរកថវិកាតាមរយៈហិរញ្ញប្បទានពីប្រទេសក្រៅមកធ្វើលូរំដោះទឹកបន្ថែមទៀត បូកបន្ថែមទៅដោយការវិនិយោគខ្លួនឯង ដើម្បីទាញទឹកចេញពីក្នុងទីក្រុង**។ យើងបានរៀបចំម៉ាស៊ីនបូមទឹកមួយចំនួន បូមទឹកទម្លាក់ចេញទៅខាងក្រៅកប់ស្រូវឯណោះ ដើម្បីកុំឲ្យទឹកបុកធ្លាក់ចូលមកក្នុងទីក្រុងភ្នំពេញ ...។

៤៣. រំដោះទឹកចេញពីក្រុង ដោយលូនិងដោយការបូម ក្រោយឆ្លងកាត់ប្រព្រឹត្តកម្ម

បើកការដ្ឋានសាងសង់សំណង់ផ្សេងៗ ក្នុងគម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយលូ ក្នុងរាជធានីភ្នំពេញ ដំហានទី៤, ៤ មីនា ២០១៩

... យើងត្រូវបន្ត**បង្កើនសមត្ថភាពធ្វើប្រព័ន្ធលូរំដោះទឹក(ចេញពីក្រុង) ដែលមួយផ្នែក ត្រូវសម្អាតទឹកនេះឲ្យហើយស្រចមុននឹងទម្លាក់ទៅទន្លេ និងមួយផ្នែកទៀតត្រូវបូមវាចេញទៅខាងក្រៅដែលធ្លាក់ទៅខាងទំនប់កប់ស្រូវ និងបឹងតាមោក ហើយក៏ត្រូវតែចម្រាញ់ឲ្យវាស្អាតដើម្បីបូមវាចេញ។** ទៅខាងបឹងទំពុន បឹងជើងឯក ក៏មានផ្នែកមួយចំនួន ដែលខ្ញុំធ្លាប់បានទៅជាមួយឯកឧត្តម ភូមីអាគី តាកាហាស៊ី ក្នុងរង្វង់ឆ្នាំ២០០៦ ឬ២០០៧ សម្ពោធដាក់ឲ្យប្រើប្រាស់នូវ(ប្រព័ន្ធ)ទាញទឹកទំលាក់ទៅខាងហ្នឹង។ យើង**មិនអាចមើលរំលងបញ្ហាទាំងឡាយ ដែលទាក់ទងជាមួយប្រព័ន្ធ(ទទួលនិង)បញ្ចេញទឹកក្នុងពេលភ្លៀងធ្លាក់ និងការបញ្ចេញទឹកទាំងទៅកាន់ទន្លេ និងទៅកាន់ខាងទំនប់កប់ស្រូវ បឹងតាមោក និងទៅខាងបឹងទំពុនជើងឯក គឺឲ្យក្លាយទៅជាទឹកស្អាត ដែលមានការចម្រោះត្រឹមត្រូវ** ...។

៤៤. កង្វះការថែទាំ/ពិនិត្យបានហួត់ចត់ សំរាមធ្វើឲ្យស្ទះ បន្តយសមត្ថភាពលូស្រូបទឹក

បើកការដ្ឋានសាងសង់សំណង់ផ្សេងៗ ក្នុងគម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយលូ ក្នុងរាជធានីភ្នំពេញ ដំហានទី៤, ៤ មីនា ២០១៩

... មួយផ្នែកទៀត ទន្ទឹមនឹងការធ្វើ(ប្រព័ន្ធលូទាំង)ហ្នឹងហើយ ប្រសិនបើប្រជាពលរដ្ឋរបស់យើងនៅតែមិនបានយកចិត្តទុកដាក់ ចូលរួមសហការទេ ដូចជាយក**សំរាមទៅចាក់ចូលលូជាដើម វានឹងបង្កើតជាការកកស្ទះ ព្រោះក្នុងប្រទេសយើងមានលូធំនិងលូតូច។ លូធំសម្រាប់ទទួលទឹកពីលូតូចៗ ... ដើម្បីយកទឹកមកកាន់លូធំនេះ លូតូចៗ ត្រូវទំនាក់ទំនងជាមួយលូធំ។ ប៉ុន្តែនៅពេលដែលប្រជាពលរដ្ឋយកសំរាមទៅចាក់ក្នុងលូតូចៗនោះ វាធ្វើឱ្យងាយស្ទះ ធ្វើឲ្យលិចលង់ទៅលើផ្ទះសម្បែងរបស់ប្រជាពលរដ្ឋមួយចំនួន។ ជួនកាល យើងមិនបានថែទាំវា ពិនិត្យវាឲ្យបានហ្មត់ចត់ ធ្វើឲ្យស្ទះសំរាម នាំដល់សមត្ថភាពស្រូបយកទឹកមានល្បឿនយឺតធៀបជាមួយទឹកដែលមាននិងជាកត្តាអត្តនោម័តិ** ... ទឹកភ្លៀងល្មម ក៏បង្កើតទៅជាការលិចលង់ដែរ។ នេះជាចំណុចខ្វះខាតដែលយើងបានបង្កើតដោយខ្លួនឯង ...។

៤៥. ក្រៅពីផ្លូវ មានរៀបចំប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ មុនបញ្ចេញទឹកទៅសមុទ្រ

សម្ពោធដាក់ឲ្យប្រើប្រាស់ ផ្លូវ ៣៧ ខ្សែ ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ និងសមិទ្ធផលនានា ក្នុងក្រុង/ខេត្តព្រះសីហនុ, ២ ធ្នូ ២០២១

... ខេត្តព្រះសីហនុបានប្រែប្រួលមុខមាត់យ៉ាងធំ។ អគារកម្ពស់រាប់សិបជាន់បានកើតយ៉ាងច្រើនក្នុងទីក្រុងមួយនេះ។ វាសក្តិសមនឹងការដែលយើងត្រូវធ្វើហេដ្ឋារចនាសម្ព័ន្ធឱ្យបានរឹងមាំ **ដែលវាមិនត្រឹមតែជាតម្រូវការផ្លូវប៉ុណ្ណោះទេ។ យើងបានរៀបចំប្រព័ន្ធ(បង្ហូរទឹក) ... មានលូបញ្ចេញទឹក បង្ហូរទឹកតាមផ្លូវថ្នល់នានា និងបានតភ្ជាប់ចូលទៅស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ មុនចាក់ចូលក្នុងសមុទ្រ។ ម្សិលមិញនេះ ខ្ញុំបានទៅ(ភាគខាង)លើ និងបានឃើញថា ទឹកកខ្វក់ចេញពីផ្ទះប្រជាពលរដ្ឋ (នៅ)ដំណាក់កាលចុងក្រោយ មុនពេលដែលចាក់ចូលទៅក្នុងសមុទ្រ ទឹកនោះអាចចិញ្ចឹមត្រីបាន** ... យើងទុកទឹកសម្រាប់បម្រើឱ្យ

សេចក្តីត្រូវការនៃជីវភាព។ ប្រជាពលរដ្ឋអាចយកទឹកនោះមកប្រើប្រាស់ស្រោចដំណាំដាំដុះ ប្រសិនបើមានតម្រូវការ ហើយមិនមានការយកប្រាក់ថ្លៃទឹកទេ ...៕

៤៦. ស្នើចិនជួកជំនួយឥតសំណង ១៣០លានរៀបគម្រោងចម្រោះទឹកមុនបង្ហូរចូលសមុទ្រ

បើកការដ្ឋានស្ថាបនាផ្លូវ ៣៤ ខ្សែ តម្លៃ ២៩៤ លានដុល្លារ ក្នុងខេត្តព្រះសីហនុ, ១៦ វិច្ឆិកា ២០១៩

... កាលពីឆ្នាំ២០០៦ ខ្ញុំបានមកសម្ពោធឱ្យប្រើប្រាស់អាងចម្រោះទឹករបស់ ADB។ កាលនោះ យើងសម្ពោធទាំងភ្លៀង។ ឥឡូវ យើងបានពង្រីកសមត្ថភាពបន្ថែម ក៏ប៉ុន្តែនៅតែមិនទាន់គ្រប់គ្រាន់ទេ។ យើងត្រូវរៀបចំប្រព័ន្ធប្រព្រឹត្តិកម្មយ៉ាងម៉េច ឱ្យមុនទឹកទាំងហ្នឹងចូលទៅក្នុងសមុទ្រ ត្រូវមានឆ្លងកាត់ចម្រោះសិន។ **យើងបានលើកសំណើសុំមិត្តចិនឱ្យជួយជាកញ្ចប់ ហើយមិត្តចិនបានយល់ស្របផ្តល់នូវហិរញ្ញប្បទានជាជំនួយឥតសំណងសម្រាប់ការអភិវឌ្ឍគម្រោងនេះ។ យើងកំពុងចរចាជាមួយមិត្តចិន ប្រើប្រាស់ប្រាក់ដែលរដ្ឋាភិបាលចិនបានផ្តល់ជាជំនួយឥតសំណងជាង ៦០០លានដុល្លារសហរដ្ឋអាមេរិក ដោយអាចដកប្រមាណជា ១៣០លាន មកប្រើប្រាស់នៅខេត្តព្រះសីហនុ ដើម្បីធានាថាទឹកសំអុយមិនធ្លាក់ទៅបំពុលបរិស្ថានទឹកសមុទ្រ** ហើយប្រជាជននៅតែមុជទឹកសមុទ្របាន ...៕

៤៧. ធ្វើឯកជនូបនីយ៍កម្មដើម្បីយកលុយធ្វើផ្លូវរថភ្លើង ទីបំផុតមិនកើតជាប្រយោជន៍

សម្ពោធចំណតផែពហុបំណង នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ, ២៥ មិថុនា ២០១៨

... ឲ្យតែនិយាយដល់រឿងហ្នឹង នឹកឃើញការដែលគេប្រមាថកាលពេលហ្នឹង។ គេថាទាល់តែយើងធ្វើ(តាមការណែនាំ)ហ្នឹង បានគេឲ្យចាយលុយនោះ។ គេដាក់អញ្ចឹងមកតែម្តង។ គេដាក់លក្ខខណ្ឌ ... **ឲ្យយើងធ្វើឯកជនូបនីយកម្មចម្ការកៅស៊ូទាំងអស់ ក្រុមហ៊ុននេសាទ និងក្រុមហ៊ុនជីរបស់ក្រសួងកសិកម្ម ដើម្បីយើងចាយលុយហ្នឹងធ្វើផ្លូវរថភ្លើង។ ទីបុងបំផុត ផ្លូវរថភ្លើងក៏វានៅតែជាផ្លូវរថភ្លើង មិនបានកើតជាប្រយោជន៍អី។ ចងមុងដេញថ្លៃ។ អត់ឲ្យក្រុមហ៊ុនផ្សេងដែលមានការពាក់ព័ន្ធជាមួយរដ្ឋចូលដេញថ្លៃទេ។ វាស្មើនឹងបរាជ័យ។ ទីបុងបំផុត យើងត្រូវប្រើងខ្លួនឯងតភ្ជាប់ផ្លូវរថភ្លើងមកដល់កំពង់សោម មកដល់ក្រុងព្រះសីហនុ ដែលខ្ញុំក៏បានធ្វើដំណើរអមព្រះករុណាជាអង្គម្ចាស់ ក៏ដូចជាហ្លួងម៉ែ មកកាន់កំពង់សោមកាលពីឆ្នាំទៅ។ មួយទិសទៀតពីបោយប៉ែត មកភ្នំពេញ** ... យើងបានបើកពីបោយប៉ែតមកបាត់ដំបង ពីបាត់ដំបង មកដល់ពោធិ៍សាត់ ហើយប៉ុន្មានថ្ងៃខាងមុខនេះ នឹងបើកតភ្ជាប់មកទីក្រុងភ្នំពេញ ...៕

៤៨. នាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីដឹកជញ្ជូនថៃ ឆ្លើយតបជាវិជ្ជមានផ្តល់ផ្លូវដែក ១៤០គម

បើកការដ្ឋានសាងសង់អាគារច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ និងផ្លូវតភ្ជាប់ទៅផ្លូវជាតិលេខ ៥, ២២ មេសា ២០១៩

... **តាមរយៈសំណើរបស់ខ្ញុំជូនចំពោះនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ ឯកឧត្តម ប្រាយុទ្ធ ចាន់អូចា និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងដឹកជញ្ជូនថៃនោះ យើងបានទទួលការឆ្លើយតបជាវិជ្ជមាន ដោយមិត្តថៃសល់ផ្លូវដែកចាស់ៗ ដែលគេបានដោះចេញ និងជំនួសដោយដែកថ្មី ១៤០គីឡូម៉ែត្រ។ ចាស់របស់ថៃ ប៉ុន្តែថ្មីនៅកម្ពុជា។** ផ្លូវដែករបស់យើងនៅនេះក៏ដូចគ្នាដែរ ចាស់នៅម៉ាឡេស៊ី ប៉ុន្តែមកថ្មីនៅកម្ពុជា។ ម៉ាឡេស៊ីអ្នកផ្តល់ឲ្យផ្លូវដែកចំនួន ២០០គោន។ ឯកឧត្តមនាយករដ្ឋមន្ត្រី ស៊ូរ៉ាយុទ្ធ ជូឡានន្ត បានជួយដឹកជញ្ជូនពីប្រទេសម៉ាឡេស៊ីមកកម្ពុជា។ ឥឡូវដោយថៃនៅសល់ផ្លូវដែក ១៤០គីឡូម៉ែត្រនេះ ខ្ញុំបានស្នើសុំឲ្យគាត់ជួយផ្តល់ផ្លូវដែកនេះ ព្រោះគាត់ឈប់ប្រើតទៅទៀត។ យើងយកមកប្រើតភ្ជាប់បន្ថែមកន្លែងដែលយើងខ្វះផ្លូវដែក។ ថ្ងៃនេះយើងក៏ទទួលក្បាលរថភ្លើងនិងទូរថភ្លើងមួយចំនួនពីព្រះរាជាណាចក្រថៃផងដែរ ...៕

៤៩. ពិចារណាពីផ្លូវរថភ្លើងល្បឿនលឿន និងផ្លូវពីសៀមរាបទៅបាត់ដំបង

សម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវចំនួន ៣៨ខ្សែ និងសមិទ្ធផលនៃការស្តារកែលម្អដងស្ទឹងសៀមរាប, ៤ មេសា ២០២២

... យើងកំពុងពិចារណាផងដែរ អំពីហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក **តើគួរឬមិនគួរជំនួសប្រព័ន្ធផ្លូវដែកដែលមានស្រាប់ ដែលជាប្រព័ន្ធហួសសម័យ ធ្វើដំណើរបានត្រឹមតែ ២០ឬ ៣០គីឡូម៉ែត្រម៉ាង ដោយផ្លូវដែកល្បឿនលឿននៅទាំងពីរទិស** ជាមួយការរៀបចំបន្ថែមទៀត ជាខ្សែរថភ្លើងសម្រាប់ការដឹកជញ្ជូនក្នុងប្រទេស និងការតភ្ជាប់ជាមួយប្រទេសជិតខាង។ ឥឡូវយើងមានខ្សែរថភ្លើងទាំង២ទិសពីប៉ោយប៉ែតរហូតមកទីក្រុងភ្នំពេញ និងពីទីក្រុងភ្នំពេញទៅខេត្តព្រះសីហនុ។ **យើងកំពុង**

ពិចារណារកដៃគូធ្វើផ្លូវរថភ្លើងល្បឿនលឿនលើផ្លូវរថភ្លើងចាស់ដដែលហ្នឹង ... បើទុកជំណើរការខឹកៗ អញ្ចឹង វាតាមមិនទាន់សភាពការណ៍ទេ ... យើងត្រូវរៀបចំផ្លូវតភ្ជាប់រវាងខេត្តសៀមរាបជាមួយខេត្តបាត់ដំបង ដោយឆ្លងកាត់ទន្លេសាបគឺពីខេត្តសៀមរាបចេញពីសសរស្តម្ភ ទៅកាន់ខេត្តបាត់ដំបងចំតំបន់អូរតាគីប្រវែងជាង ៧០គីឡូម៉ែត្រ។ កំពុងសិក្សានិងរកថវិកាសាងសង់។ នៅមានកិច្ចការច្រើនដែលយើងត្រូវធ្វើតាមតម្រូវការរបស់ប្រជាពលរដ្ឋ ...៕

៥០. រថភ្លើងក្រោមដីអាចជាជំរើសសម្រាប់កម្ពុជាទៅអនាគត

បើកការដ្ឋានសាងសង់ស្ពានអាកាស២ ដោយប្រសិទ្ធនាមថាស្ពានអាកាសព្រះមុន្នីវង្ស និងស្ពានអាកាសសម្តេចចៅហ្វាវាំង គង់ សំអុល, ៣១ សីហា ២០២២

... កាលពីមុន ការធ្វើផ្លូវក្រោមដីវាមិនទាន់ត្រូវ។ ឥឡូវនេះ **មានតម្រូវការធ្វើផ្លូវក្រោមដីហើយ។ ទីក្រុងភ្នំពេញ លទ្ធភាពដែលមានពិតប្រាកដ ... មុននេះ JICA បានសិក្សា ហើយយើងក៏បានចរចាជាមួយជប៉ុន។ ជប៉ុនគ្រោងតែនឹងជួយទេ ក៏ប៉ុន្តែបើយើងយកលុយ ១៨០០លានដុល្លារ ធ្វើរថភ្លើងលើអាកាស វាកាត់លើដំបូលផ្ទះ ក៏វានៅតែទើស។ វេទនាណាស់។ អញ្ចឹងទេ ប្រហែលជាជម្រើសថ្ងៃក្រោយ គឺរថភ្លើងក្រោមដីវិញទេ។ រថភ្លើងក្រោមដីអាចភ្ជាប់គ្នាតាំងពីក្រុងភ្នំពេញចេញទៅខេត្តកណ្តាល ចេញទៅ(ខេត្តផ្សេងៗ) រត់ជាប់គ្នានៅទីក្រុងភ្នំពេញ។ ដូចនេះប្រហែលជា(ធ្វើផ្លូវរថភ្លើង)នៅខាងក្រោម។** វិស្វករវ័យក្មេងបច្ចុប្បន្នអាចនៅរស់(បានយូរ)ជាងពួកយើង ...៕

៥១. មិនចង់ប្រើធនធានច្រើនលើរថភ្លើងអាកាស ក្នុងពេលជនបទកំពុងមានតម្រូវការ

បើកការដ្ឋានសាងសង់ស្ពានអាកាស២ ដោយប្រសិទ្ធនាមថាស្ពានអាកាសព្រះមុន្នីវង្ស និងស្ពានអាកាសសម្តេចចៅហ្វាវាំង គង់ សំអុល, ៣១ សីហា ២០២២

... ជប៉ុននាំខ្ញុំជិះរថភ្លើងលើអាកាស ដើម្បីយកមកធ្វើការប្រៀបធៀបសម្រាប់ការសាង**សង់រថភ្លើងលើអាកាស។ ប៉ុន្តែ យើងបានគិតថា បើតម្លៃជិត ២០០០ លានដុល្លារ ឬហោចបំផុត ១៨០០លានដុល្លារ យកមកប្រើត្រឹមតែទីក្រុងភ្នំពេញមួយ វានឹងកើតជាស្ថានភាព "វិសមភាព" ដោយប្រើប្រាស់ធនធានច្រើនជ្រុលលើទីក្រុងភ្នំពេញ ក្នុងពេលដែលជនបទមានតម្រូវការស្ពានឆ្លងតាមដងទន្លេច្រើន។**

ចំណុចនេះយើងត្រូវគិត។ អញ្ចឹងវិធីដោះស្រាយបច្ចុប្បន្ននេះ មានតែបន្ថែមស្ពានអាកាសនៅចំណុចនេះៗ ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ...៕

៥២. លើកទឹកចិត្តឱ្យចូលរួមអភិវឌ្ឍផ្លូវរថភ្លើងល្បឿនលឿន តាមរបៀប B.O.T

ពិធីចែកសញ្ញាបត្រជូននិស្សិត/គរុនិស្សិត នៃវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស, ២៧ កុម្ភៈ ២០២៣

... យើងត្រូវតែធ្វើឱ្យផ្លូវរទេះភ្លើងរបស់យើងក្លាយទៅជារទេះភ្លើងល្បឿនលឿនទាំងអស់។ នៅទីនេះ **យើងក៏អំពាវនាវ(និង)លើកទឹកចិត្តឱ្យប្រទេសនានាចូលរួមរៀបចំតាមរបៀប B.O.T ត្បិតយើងមិនចង់ខ្ជីប្រាក់ក្នុងរង្វង់មួយដ៏ធំធ្វើផ្លូវរថភ្លើងល្បឿនលឿនពីភ្នំពេញទៅប៉ោយប៉ែត(និង)ពីភ្នំពេញទៅក្រុងព្រះសីហនុ ជំនួសឱ្យដែកផ្លូវចាស់ ដែលសព្វថ្ងៃនេះរត់បានត្រឹមតែ ៣០គីឡូម៉ែត្រក៏ម៉ាង ក្នុងពេលផ្លូវល្បឿនលឿនអាចរត់ទៅដល់ ១៣០គីឡូម៉ែត្រក៏ម៉ាង ដែលធ្វើឱ្យមានការចំណេញទៅលើការដឹកជញ្ជូន។** រដ្ឋមន្ត្រីប្រតិភូបារាំងបានលើកទឹកចិត្តថា សូមអ្នកឯងសិក្សាទៅរួចហើយអាចឱ្យក្រុមហ៊ុនបារាំងធ្វើ B.O.T ... យើងមិនចង់ខ្ជីលុយគេមកធ្វើទេ។ បើគេធ្វើ B.O.T បាន គឺវាល្អ ...៕

៥៣. ចិនជួយផ្លូវលេខ៥ និង៥១ ហើយនឹងសុំចិនធ្វើផ្លូវពីសំឡូតទៅកោះកុង

សម្ពោធកំណាត់ផ្លូវជាតិលេខ៦ ពីជ្រោយចង្វាទៅថ្នល់កែង, ៦ មេសា ២០១៧

... **ផ្លូវជាតិលេខ៥ បានតភ្ជាប់ទីក្រុងភ្នំពេញទៅគល់ស្ពានព្រែកក្តាមហើយតាមរយៈនៃហិរញ្ញប្បទាននោះ អនុញ្ញាតឲ្យយើងបានកសាងស្ពានព្រែកក្តាម ដែលមុននេះ ការធ្វើដំណើរមានការលំបាក ដោយយើងត្រូវឆ្លងសាឡាងនៅផ្លូវស្ពានព្រែកក្តាមផងនិងស្ពានព្រែកតាមាក់ផង។** វិលមកម្ខាងទៀត ថ្ងៃមុនយើងបានបើកការដ្ឋានសាងសង់ផ្លូវខ្សែក្រវាត់រាជធានីភ្នំពេញមួយស្រទាប់នៅផ្នែកខាងក្នុង ដោយហិរញ្ញប្បទានរបស់មិត្តចិន ដើម្បីផ្សារភ្ជាប់នឹងស្ពានមិត្តភាពកម្ពុជា-ចិននៅឯតាខ្មៅ។ មួយផ្នែកទៀត កាលពីថ្ងៃទី១៤ (មេសា ២០១៧)កន្លងទៅ សម្តេចក្រឡាហោម ស ខេង ... **បានទៅបើកការដ្ឋានស្ថាបនាឡើងវិញនូវផ្លូវជាតិ៥១ ដែលតភ្ជាប់ផ្លូវជាតិលេខ៥ ទៅកាន់ផ្លូវជាតិលេខ៤ ... មើលក្នុងផែនទី មានសំណើ**

(សង់ផ្លូវ)ព័ទ្ធជុំវិញតាមព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង ... ឥឡូវនេះ ការតភ្ជាប់ដែលយើងមិនទាន់មានគឺពីសំឡូត កាត់មកថ្មដា ចេញទៅកោះកុង និងទៅកំពង់សោម។ ច្បាស់ជាស្វែងរកជំនួយពីមិត្តចិនសង់កំណាត់ផ្លូវហ្នឹងទៀតហើយ ...។

៥៤. ផ្លូវរវាងកំពង់ធំនិងក្រចេះ ជាបេក្ខភាពគំរោងជូនសាធារណរដ្ឋប្រជាមានិតចិន ឯផ្លូវរវាងកំពង់ឆ្នាំងនិងកំពង់ធំ ចាំសិក្សាពីផលប៉ះពាល់ដល់ទន្លេសាបសិន

សម្ពោធផ្លូវជាតិលេខ៦ ថ្នល់កែង-អង្គ្រង ខេត្តសៀមរាប, ១១ មិថុនា ២០១៨

... មុននេះ ខ្ញុំធ្លាប់បាននិយាយថា **យើងនឹងមានផ្លូវ ២ខ្សែបន្ថែមទៀតដែលតភ្ជាប់ពីខេត្តកំពង់ធំទៅខេត្តក្រចេះ តាមស្រុកសណ្តាន់ ហើយដែលត្រូវធ្វើស្ពានឆ្លងកាត់ទន្លេមេគង្គនៅឯទីរួមខេត្តក្រចេះ ដើម្បីងាយស្រួលតភ្ជាប់រវាងក្រចេះ និងខេត្តកំពង់ធំ ក្នុងរង្វង់តែជាង ១០០គីឡូម៉ែត្រប៉ុណ្ណោះ ... ផ្លូវនេះជាបេក្ខភាពគំរោង ដែលយើងដាក់ជូនសាធារណរដ្ឋប្រជាមានិតចិន។ ឯផ្លូវ ១ខ្សែទៀត តភ្ជាប់ពីខេត្តកំពង់ឆ្នាំងមកខេត្តកំពង់ធំ ម្តុំកំពង់ឬ ខ្ញុំក៏ធ្លាប់បានប្រកាស ក៏ប៉ុន្តែសូមញាតិញោមព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គនិងបងប្អូនជនរួមជាតិ ដែលរស់ក្នុងនៅខេត្តកំពង់ធំក្តី រស់នៅក្នុងខេត្តកំពង់ឆ្នាំងក្តី មេត្តាយោគយល់អធ្យាស្រ័យអំពីការដែលមិនទាន់មានលទ្ធភាពសាងសង់ទៅបាន**។ ការពិតក្រុមហ៊ុនសាងសង់បានធ្វើការសិក្សាហើយ រាប់ទាំងតម្លៃនៃការសាងសង់ ដែលត្រូវចំណាយអស់ប៉ុន្មានជាង ១០០លានដុល្លារអាមេរិក។ ក៏ប៉ុន្តែសូមញាតិញោមពិចារណាមើលថាគួរសាងសង់ ឬទេ? ព្រោះអ្វី? **យើងត្រូវសាងសង់កាត់ទន្លេសាប អញ្ចឹងផលប៉ះពាល់ទៅលើទន្លេសាបយ៉ាងណា យើងមិនទាន់បានសិក្សាលម្អិតនៅឡើយ**...។

៥៥. បើសិក្សាផ្លូវ/ស្ពានកំពង់ធំ/កំពង់ឆ្នាំងឡើងវិញ ត្រូវយកក្បាមន្ត Shenzhen

សម្ពោធផ្លូវជាតិលេខ ៦ ពី ថ្នល់កែង-អង្គ្រង ខេត្តសៀមរាប, ១១ មិថុនា ២០១៨

... សូម្បីតែពី Shenzhen របស់ចិន ទៅហុងកុង គេធ្វើស្ពានឆ្លងសមុទ្រតែម្តង។ គេធ្វើបាន។ **ប្រសិនបើការសិក្សាស្ពានរវាងកំពង់ឆ្នាំងនិងកំពង់ធំធ្វើតាមរូបមន្ត Shenzhen ប្រហែលជាប្រជាជនមិនជេរទេ ព្រោះសុទ្ធតែសរសើរ។ កន្លែងណាដែលកាណូតកប៉ាល់ឆ្លងកាត់ យើងធ្វើអោយខ្ពស់ កន្លែងណាដែលធម្មតា យើងអោយ**

វានៅធម្មតា ... ធ្វើម៉េចអោយខ្ពស់ជាងកំពស់ទឹកជំនន់ឆ្នាំ២០០០ ... នេះគ្រាន់តែជាអនុសាសន៍ដើម្បីសិក្សាឡើងវិញ ប្រសិនបើយើងចង់ធ្វើ។ មិនអាចលើកទំនប់បិទទេ។ រឿងនេះបង្កើតទៅជាការស្ទះចរន្តទឹក ការធ្វើចរាចរបស់ត្រី ជាពិសេសការធ្វើចរាចរបស់ប្រជាពលរដ្ឋ។ យើងធ្វើស្ពានអោយគាត់ងាយស្រួល ក៏ប៉ុន្តែអ្នកក្នុងទឹកបែរជាបន្ទោសថា មកពីធ្វើស្ពានបានជាគាត់មិនមានកន្លែងឆ្លង ...។

៥៦. សូមចិនគាំទ្រគម្រោងផ្លូវតភ្ជាប់ពីកោះកុង ទៅកាន់ថ្មដា និងទៅកាន់សំឡូត

សម្ពោធផ្លូវជាតិលេខ៦ ថ្នល់កែង-អង្គ្រង ខេត្តសៀមរាប, ១១ មិថុនា ២០១៨

... សូមឯកឧត្តមអគ្គរដ្ឋទូតបានជ្រាបផង **យើងខ្ញុំនឹងដាក់ជាគម្រោងចាប់ៗនេះក្នុងបំណងសូមការគាំទ្រជាបេក្ខភាពគម្រោងសម្រាប់ឆ្នាំនេះនិងឆ្នាំក្រោយ ផ្លូវតែភ្ជាប់ពីកោះកុង ទៅកាន់ថ្មដា និងទៅកាន់សំឡូត ដើម្បីភ្ជាប់ព្រំដែនកម្ពុជា-ថៃ**។ មួយជុំវិញ(ប្រទេស) នៅចន្លោះតែផ្លូវកន្លែងហ្នឹងទេ។ ក្រៅពីនោះ មិត្តចិនបានជួយសឹងតែជុំវិញហើយ ... នៅមិនដល់ ២០០គីឡូម៉ែត្រទេ។ តម្លៃប្រហាក់ប្រហែល ២០០លានដុល្លារសហរដ្ឋអាមេរិក។ តំបន់នោះ សុទ្ធតែតំបន់មានការប្រយុទ្ធ។ ប៉ុន្តែឥឡូវនេះ តាំងពីម៉ាឡៃមកដល់ប៉ៃលិន មកដល់សំឡូត យើងមានផ្លូវ។ ពីពេធ៌សាត់ មានផ្លូវហើយ ប៉ុន្តែរវាងថ្មដានិងសំឡូត រវាងថ្មដានិងកោះកុង មិនទាន់មានផ្លូវក្រាលកៅស៊ូទេ។ យើងចង់ឱ្យមានផ្លូវក្រាលកៅស៊ូតាមនេះ ...។

៥៧. គោលនយោបាយតភ្ជាប់ផ្ទៃក្នុងប្រទេសផង និងជាមួយប្រទេសជិតខាងផង

បើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុង ខ្សែទី៣(ផ្លូវជាតិលេខ៤ ដល់១), ១៤ មករា ២០១៩

... ឯកឧត្តម អគ្គរដ្ឋទូតចិនបានលើកឡើងអម្បាញ់មិញ ... ចិនមានភាសាមួយកាលពីដំនាន់ដើមរបស់គាត់ថា "បើចង់ធ្វើអ្នកមាន ឲ្យធ្វើផ្លូវមុន"។ កម្ពុជាក៏មានភាសាអំពីផ្លូវនេះដែរ។ "មានផ្លូវ មានសង្ឃឹម"។ យើងស្រាស្រទេញក្នុងការធ្វើផ្លូវ។ ពេលដែលយើងប្រកាសអាទិភាពគោលនយោបាយវិនិយោគ កាលពីឆ្នាំ១៩៨៧ គឺ ៣២ឆ្នាំមុន យើងបានដាក់ចេញនូវអាទិភាព៤ យ៉ាងសម្រាប់វិនិយោគ រួមមានទឹក ផ្លូវ ភ្លើង មនុស្ស។ **តាំងពីឆ្នាំ២០១៣ រហូតមកដល់ពេលនេះ យើងប្រើពាក្យមនុស្ស ទឹក ផ្លូវ ភ្លើង។ ជាទស្សនទានដដែលទេ។ គ្រាន់តែលំដាប់អាទិភាពនៃការបណ្តុះបណ្តាលធនធានមនុស្សត្រូវដើរមួយជំហានមុន ... គោលនយោបាយតភ្ជាប់**

នេះ មិនមែនគ្រាន់តែជាការតភ្ជាប់ធម្មតានោះទេ ក៏ប៉ុន្តែក្នុងសម័យបច្ចុប្បន្ននេះ គឺតភ្ជាប់ក្នុងផ្ទៃក្នុងប្រទេសខ្លួនឯងផង និងតភ្ជាប់ជាមួយប្រទេសជិតខាង ដែលជាប់ជាមួយយើងផង ...។

៥៨. មិត្តភាពនិងការជឿទុកចិត្ត នាំអោយចាប់ផ្តើមគំរោងហេដ្ឋារចនាសម្ព័ន្ធ P3

បើកការដ្ឋានសាងសង់ផ្លូវល្បឿនលឿន ក្រុងភ្នំពេញ-ខេត្តព្រះសីហនុ, ២២ មីនា ២០១៩

... ខ្លួនខ្ញុំផ្ទាល់បានធ្វើការជាមួយឯកឧត្តម ប្រធានាធិបតី ស៊ី ជីងពីន និងឯកឧត្តម នាយករដ្ឋមន្ត្រី លី ខឺឈាង ដើម្បីរកដំណោះស្រាយ។ ក្នុងនោះ មិត្តចិនបានផ្តល់មកឲ្យយើង ១៥០លានដុល្លារសហរដ្ឋអាមេរិកជួយទ្រទ្រង់គម្រោង(ផ្លូវល្បឿនលឿន)នេះ (អោយ)អាចអនុវត្តទៅបាន។ **ប្រសិនបើគ្មានទំនាក់ទំនងជឿទុកចិត្តដ៏ល្អ គ្មានចរិតមិត្តភាពជាមួយគ្នាទេ ផ្លូវមួយខ្សែនេះពិតជាមិនអាចសម្រេចបានទេ។ នេះជាគំរោងមួយដ៏ធំ ប្រើទឹកប្រាក់ធំណាស់ ហើយនេះក៏អាចចាត់ទុកថាជាការចាប់ផ្តើមដំបូងក្នុងទ្រង់ទ្រាយធំអំពីភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធដែលគេហៅថា P3 គឺ Public-Private Partnership** ... មុននេះយើងមានគម្រោងតូចៗមួយចំនួន ប៉ុន្តែនេះជាគម្រោងដ៏ធំដែលវិនិយោគដោយឯកជនមកពីសាធារណរដ្ឋប្រជាមានិតចិន ...។

៥៩. ស្នើបើកច្រកព្រំដែន៤ ជាមួយថៃគឺ អានសេះ, ជប់គគី, ភ្នំដី និងថ្មដា

បើកការដ្ឋានសាងសង់អាគារច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ និងផ្លូវតភ្ជាប់ទៅផ្លូវជាតិលេខ៥, ២២ មេសា ២០១៩

... ពាណិជ្ជកម្មរវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃមានទំហំធំណាស់ គឺជាង ៦ពាន់លានដុល្លារសហរដ្ឋអាមេរិកឯណោះ។ អញ្ចឹងទេ យើងមានតម្រូវការតភ្ជាប់ ហើយដែលសំខាន់គឺទំនាក់ទំនងជិតខាងល្អ ដែលយើងបានធ្វើជាមួយគ្នា។ មុនពេលពិធីចាប់ផ្តើម ខ្ញុំ**បានចរចាជាមួយឯកឧត្តមប្រាយុទ្ធ ចាន់អូចា នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ ដោយស្នើបើកច្រកព្រំដែន៤ កន្លែងផ្សេងទៀត រួមមានច្រកអានសេះ រវាងខេត្តព្រះវិហារ និងខេត្តអ៊ូបុន ជប់គគី ដែលម្ខាងនៅឧត្តរមានជ័យ និងម្ខាងទៀត បុរីរ៉ាំ ឯមួយទៀតនៅភ្នំដី និងមួយទៀតនៅថ្មដា។**

កាលណាដែលច្រកព្រំដែនត្រូវបានបើក វានឹងសម្រួលដល់ការធ្វើពាណិជ្ជកម្មរវាងប្រជាជននិងប្រជាជន ...។

៦០. ក្រោយចប់កុងត្រា ផ្លូវល្បឿនលឿន BOT ជាផ្លូវរបស់រដ្ឋ

បើកការដ្ឋានសាងសង់ផ្លូវល្បឿនលឿន ក្រុងភ្នំពេញ-ខេត្តព្រះសីហនុ, ២២ មីនា ២០១៩

... ផ្លូវនេះ ធ្វើតាមរយៈការសាងសង់ ធ្វើអាជីវកម្ម និងផ្ទេរ ដែលភាសាអង់គ្លេសថា Build, Operate និង Transfer (BOT)។ អញ្ចឹងទេ **សូមបងប្អូនប្រជាពលរដ្ឋកុំឲ្យលង់ទៅដោយការឃោសនាអកុសលដែលថា យើងទិញដីធ្លីឲ្យទៅក្រុមហ៊ុនចិន។ ខ្ញុំយល់ច្បាស់ថា ពួកវានឹងធ្វើការឃោសនាបែបនេះ។ ខ្ញុំសូមបញ្ជាក់ជូនប្រជាពលរដ្ឋឲ្យបានជ្រាបថា ពាក្យថា កសាង អាជីវកម្ម និងផ្ទេរ មានន័យថា ដីនៅតែជាដីខ្មែរ។ បន្ទាប់ពីផុតកុងត្រា បន្ទាប់ពីការធ្វើអាជីវកម្មរួចហើយ ផ្លូវនេះក្លាយទៅជាផ្លូវរបស់រដ្ឋ។ បានសេចក្តីថា ក្រុមហ៊ុនបានបញ្ចប់ដំណើរការ ហើយប្រគល់ផ្លូវនេះមកឲ្យរដ្ឋ។ ពេលនោះ រដ្ឋនឹងប្រើប្រាស់របៀបណា ចាត់ចែងរបៀបណា គឺទៅតាមតម្រូវការរបស់រដ្ឋ។** ជួនកាលគេអាចនឹងឃោសនាថា ... វាស់ដី ទិញដីពីប្រជាជនប្រគល់ទៅឲ្យក្រុមហ៊ុនចិន។ ចិនមកធ្វើអាណានិគមនៅស្រុកខ្មែរ ...។

៦១. ត្រូវការផ្លូវល្បឿនលឿនតភ្ជាប់ជាមួយវៀតណាមនិងថៃ

បើកការដ្ឋានសាងសង់ផ្លូវល្បឿនលឿន ក្រុងភ្នំពេញ-ខេត្តព្រះសីហនុ, ២២ មីនា ២០១៩

... គប្បីបញ្ជាក់ជូននៅទីនេះអំពីអាទិភាពដែលយើងត្រូវបន្ត។ ថ្ងៃនេះ យើងបើកត្រឹមតែភ្នំពេញទៅក្រុងព្រះសីហនុ ប៉ុន្តែ**យើងមានតម្រូវការផ្លូវល្បឿនលឿនបន្ថែមទៀតដូចជាតភ្ជាប់ទៅសាធារណរដ្ឋសង្គមនិយមវៀតណាម។** បើនិយាយពីវៀតណាម គាត់ធ្វើផ្លូវច្រើនណាស់ ... ផ្លូវពីមុនដែលជាផ្លូវជាតិតូចៗ ឥឡូវវៀតណាមពង្រីកទៅជាហាយវេយ៍ ផ្លូវល្បឿនលឿនអស់ហើយ។ យើងត្រូវតភ្ជាប់(ផ្លូវល្បឿនលឿន)ពីភ្នំពេញទៅបាវិត និងជាមួយវៀតណាមបន្ថែមទៀត ... **យើងត្រូវតភ្ជាប់ជាមួយវៀតណាម ជាមួយថៃ គឺតភ្ជាប់ផ្ទៃក្នុងខ្លួនឯងហើយត្រូវតភ្ជាប់ជាមួយនឹងប្រទេសជិតខាង។** យើងបានតភ្ជាប់គ្នារវាងផ្លូវជាតិលេខ២១ ដែលកាត់ខេត្តកណ្តាលទៅជ្រៃធំ និងបានធ្វើស្ពានរួមគ្នាឆ្លងកាត់ដីកជញ្ជុំនៅប៉ែកម្ខាង។ យើងមានរបៀងមាត់សមុទ្រមួយហើយ សម្រាប់តភ្ជាប់ពីកោះកុងទៅខេត្តព្រះសីហនុ និង

ទៅព្រៃចាក ចូលទៅហាទៀងខាងវៀតណាមដែលហៅថា ហាយវ៉េអាស៊ាន តភ្ជាប់រវាងភ្នំពេញនិងក្រុងហូជីមិញ ហើយតភ្ជាប់រវាងភ្នំពេញនិងក្រុងបាងកក ...៕

៦២. ស្វែងរកឥណទាន ជំនួយឥតសំណង និងការវិនិយោគ កសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវស្ពាន

បើកការដ្ឋានសាងសង់ផ្លូវល្បឿនលឿន ក្រុងភ្នំពេញ-ខេត្តព្រះសីហនុ, ២២ មីនា ២០១៩

... យើងកំពុងកសាង(ពង្រីកផ្លូវជាតិលេខ៥)បន្តពីព្រែកក្តាមទៅកាន់ប្រទេសថៃ ដោយហិរញ្ញប្បទានពីប្រទេសជប៉ុន។ យើងរកដៃគូច្រើនមកធ្វើ។ ផ្លូវខ្លះ យើងធ្វើដោយស្វែងរកនូវឥណទាននិងជំនួយឥតសំណងពីមិត្តភក្តិ ប៉ុន្តែផ្លូវខ្លះដូចជាផ្លូវ(ល្បឿនលឿន)នេះ យើងត្រូវធ្វើជាផ្លូវតាមរបៀបសាងសង់អាជីវកម្មនិងផ្ទេរ ... នោះជាគោលនយោបាយដែលយើងបានដាក់ចេញ ជំរុញតាមរយៈអន្តរសេកម្មនៃវិស័យដឹកជញ្ជូន ធ្វើឲ្យយើងដោះស្រាយបានបញ្ហាច្រើន មិនមែនគ្រាន់តែការដឹកជញ្ជូនទេ។ ក្មេងៗជាន់ក្រោយមិនសូវបានដឹងរឿងចាស់ទេ ក៏ប៉ុន្តែអ្នកមានវ័យចំណាស់ពី ៥៥ឆ្នាំឡើង អាចនៅចាំបានថាកម្ពុជាមានដំណាក់កាលច្រើនណាស់។ ដំណាក់កាលកង់ជិះមនុស្ស មនុស្សជិះកង់ ... តែពេលនោះវាមានស័ក្តិសមនឹងពេលនោះ។ យើងចេញមកបាតដៃទទេ។ មានកង់មួយស្មើនឹង មានម៉ូតូមួយ មានម៉ូតូមួយស្មើនឹងមានឡាន មានឡានសម័យនោះស្មើនឹងមានយន្តហោះ ...៕

៦៣. ស្នើកូរ៉េពិចារណាកសាងស្ពានមិត្តភាពកម្ពុជាកូរ៉េ ពីជ្រោយចង្វារទៅស្វាយជ្រុំ

បើកការដ្ឋានធ្វើឲ្យប្រសើរឡើងវិញនូវផ្លូវជាតិលេខ២ និងផ្លូវជាតិលេខ២២
ប្រវែងជាង ៧២គីឡូម៉ែត្រ, ១១ កុម្ភៈ ២០២០

... លើកនេះខ្ញុំបាននិយាយផ្ទាល់ជាមួយឯកឧត្តម Moon Jae-in តែម្តង។ ខ្ញុំថា "ឯកឧត្តម! កម្ពុជាមានស្ពានមិត្តភាពជប៉ុន-កម្ពុជាហើយ មានស្ពានមិត្តភាពចិន-កម្ពុជាហើយ ក៏ប៉ុន្តែនៅខ្វះស្ពានមិត្តភាពកម្ពុជា-កូរ៉េ"។ អញ្ចឹង ខ្ញុំបានស្នើឲ្យប្រធានាធិបតីកូរ៉េ Moon Jae-in ពិចារណាជួយកសាងស្ពាននៅកន្លែងណាមួយ។ បើយើងគ្រោងទុក គឺស្ពានតភ្ជាប់ជ្រោយចង្វារទៅស្វាយជ្រុំរបស់ខេត្តកណ្តាល។ ប្រធាន KOICA នឹងមកទស្សនកិច្ចនៅចុងខែកុម្ភៈនេះ។ ពេលនោះ អាចនាំប្រធាន KOICA ទៅមើលដើម្បីឲ្យគាត់សិក្សា។ ឥឡូវនេះ ត្រើយម្ខាងខាងអរិយក្សត្រាវាទៅជាក្រុងរណបមួយដ៏ធំនៅកន្លែងនោះ។ ខាងលើ យើងមាន(ស្ពាន)ព្រែកតាមាក់

ឆ្លងទៅហើយ ប៉ុន្តែដែលចំណេញពេលគឺយើងទៅដល់ជ្រោយចង្វារហើយឆ្លងស្ពានមួយតទៀតទៅស្វាយជ្រុំ/អរិយក្សត្រ ... យើងនឹងមានផ្លូវស្ពានមួយខ្សែទៀតពីក្តីតាកុយផ្លូវជាតិលេខ១ ទៅត្រើយម្ខាងទៀត ព្រោះបើត្រូវវង់ចាំឆ្លងស្ពានព្រែកតាមាក់ វាក៏ប្រើពេលយូរ។ ហើយម្ខាងទៀត ទៅឆ្លងនៅស្ពានអ្នកលឿង បានធ្វើដំណើរឡើងមកវិញ ក៏វាយូរ ...៕

៦៤. ចិនរួមចំណែកសង់ផ្លូវ ៣០០០/១៥០០០ គីឡូម៉ែត្រ និង១០/២០ស្ពាន

ដាក់ឱ្យប្រើប្រាស់ស្ពានមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រង់-ក្រូចឆ្មារ (ស្ពានភ្ជាប់និស្សរ័យ)
និងការប្រកាសបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ 71C, ២៣ វិច្ឆិកា ២០២១

... មិត្តចិនបានចូលរួមចំណែកក្នុងការតភ្ជាប់ផ្លូវឡើងដល់ជាង ៣០០០ គីឡូម៉ែត្រ ... ក្នុងចំណោមផ្លូវ ១ម៉ឺន ៥ពាន់គីឡូម៉ែត្រ មានផ្លូវចិនប្រវែង ៣០០០ គីឡូម៉ែត្រ។ ក្នុងចំណោមស្ពាន២០ ស្ពានដែលកសាងដោយហិរញ្ញប្បទានពីមិត្តចិនមានចំនួន១០។ យើងនឹងបើកការដ្ឋានបន្តបន្ទាប់ទៀត។ យើងដាក់គម្រោងស្នើ។ ស្ពានដែលមិត្តចិនជួយសាងសង់ នៅសល់ស្ពានក្រចេះមួយ (និង)គម្រោងស្ពានតភ្ជាប់កំពង់ឆ្នាំងជាមួយខេត្តកំពង់ធំ។ ស្ពានដែលស្ថិតនៅចន្លោះរវាងតាខ្មៅនិងស្ពានព្រះមុនីវង្ស នឹងត្រូវដាក់ជាគម្រោងបេក្ខភាពថ្មីមួយទៀត។ (យើង)កំពុងតែសិក្សា(ផ្លូវ)តភ្ជាប់រវាងបាត់ដំបង-សៀមរាប ...៕

៦៥. សិក្សាគម្រោងផ្លូវពីស្រុកល្វាឯមទៅផ្លូវជាតិលេខ១១ និងទៅព្រំដែនកម្ពុជាវៀតណាម

សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផ្លូវជាតិលេខ១១ តភ្ជាប់រវាងខេត្តព្រៃវែង
ទៅខេត្តត្បូងឃ្មុំ, ៦ ធ្នូ ២០២១

... តាមសំណើរបស់សម្តេចក្រឡាហោម ស ខេង ខ្ញុំបានចា**ឱ្យសិក្សាមួយកំណាត់ផ្លូវភ្ជាប់ពីល្វាឯម មកកាន់ផ្លូវជាតិលេខ១១ នេះ ... តើអស់តម្លៃប៉ុន្មាន? បន្ទាប់ទៅឱ្យតភ្ជាប់ពីហ្នឹងទៅទល់ព្រំដែនកម្ពុជាវៀតណាម ... ផ្លូវត្រឹមតែ ២៩ គីឡូម៉ែត្រ ត្រូវចំណាយប្រមាណជាង ៧០លានដុល្លារឯណោះ។ ព្រោះអី? ត្រូវធ្វើផ្លូវនិងធ្វើស្ពាន។ ផ្លូវនោះនៅក្នុងទឹក ៥ម៉ែត្រ ឬ១០ម៉ែត្រឯណោះ។ វាជ្រៅ។** ប៉ុន្តែយ៉ាងណាក៏ដោយ យើងមិនបោះបង់ចោលគម្រោងនេះទេ។ យើងត្រូវរកថវិកា ធ្វើ។ **បើយើងតភ្ជាប់នឹងខ្សែក្រវាត់ក្រុងទី៣ ពីស្រុកល្វាឯម មកកាន់ខេត្ត**

ព្រៃវែងនេះ វាមានចម្ងាយមិនដល់ ៣០គីឡូម៉ែត្រទេ ដែលវាអាចកាត់បន្ថយនូវការលំបាករបស់ប្រជាជននៅក្នុងតំបន់នោះ។ យើងនឹងតភ្ជាប់។ បើគិតរយៈចម្ងាយពីទីនេះ ទៅដល់ព្រំដែនកម្ពុជាវៀតណាម មានចម្ងាយផ្លូវវែងជាង។ ក៏ប៉ុន្តែការប៉ាន់ស្មានតម្លៃគឺ(ចំណាយ)តិចជាង ... យើងនឹងពិភាក្សាអំពីបញ្ហានេះ (អាចថាធ្វើ) តាមរយៈការបញ្ចុះទុនជាដំណាក់ៗ។ ធម្មតា ធ្វើផ្លូវបែបនេះមិនមែនធ្វើមួយឆ្នាំស្រូបយកអស់លុយនោះទេ។ យើងអាចកាត់ជាឆ្នាំទី១ ធ្វើអ្វីខ្លះ? អស់ប៉ុន្មាន? ឆ្នាំទី២ អស់ប៉ុន្មាន? ... យើងនឹងពិនិត្យប្រភពធនធានដែលយើងមាន ...៕

៦៦. ផ្លូវជាតិ៤៨ ជារបៀងសមុទ្រតភ្ជាប់ផ្ទៃក្នុងនិង រវាងថៃនិងវៀតណាម កាត់កម្ពុជា

បើកការដ្ឋានគម្រោងលើកកម្រិតគុណភាពផ្លូវជាតិលេខ៤៨ (ឥណទាន មូលនិធិកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ច EDCF នៃសាធារណរដ្ឋកូរ៉េ), ៣ មករា ២០២២

... (យើងបានឆ្លងកាត់ការប្រឹងប្រែងជាច្រើន) ដើម្បីធ្វើឱ្យកោះកុងមានការរីកចម្រើនឡើង ដោយតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ តាំងពីផ្លូវដី ឆ្លងទូកដរហូតមកដល់ដំណាក់កាលធ្វើផ្លូវកៅស៊ូ និងមានស្ពានបេតុង។ ឥឡូវនេះ ចាប់ផ្តើមពង្រីកទៅជាចាក់បេទីម។ ផ្លូវនេះក្លាយជាផ្លូវមួយដ៏សំខាន់។ មិនត្រូវភ្លេចទេថា **ផ្លូវនេះគឺជារបៀងមាត់សមុទ្រដែលមិនត្រឹមតែបម្រើជាទំនាក់ទំនងផ្ទៃក្នុងកម្ពុជាទេ ប៉ុន្តែក៏វាជារបៀងមាត់សមុទ្របម្រើឱ្យទំនាក់ទំនងរវាងប្រទេសថៃ និងវៀតណាម ដែលឆ្លងកាត់កម្ពុជា។ បើសិនវៀតណាមចង់យកទំនិញទៅប្រទេសថៃ ឆ្លងកាត់តាមផ្លូវនេះ ក៏វារហ័ស។ ថៃនាំទំនិញឆ្លងកាត់ទៅវៀតណាមឆ្លងកាត់តាមផ្លូវនេះក៏រហ័ស** ...៕

៦៧. តភ្ជាប់ផ្លូវជាតិលេខ៧ ទៅព្រំដែនឡាវ សង់ស្ពានក្បែរក្រុងក្រចេះនិងផ្លូវទៅកំពង់ធំ

សម្ពោធកំណាត់ផ្លូវជាតិលេខ ៧ ប្រវែង ៩៣,៦៤ គីឡូម៉ែត្រ ពីរង្វង់មូលខ្លាស្នុះទៅឃុំមោត ខេត្តក្រចេះ, ៧ កុម្ភៈ ២០២២

... សម្រាប់ខេត្ត(ក្រចេះ)នេះ ឯកឧត្តម Wang Wentian និយាយថា "ចិនជំពាក់" ... ប៉ុន្តែមិត្តចិនត្រូវមានកាតព្វកិច្ច២ បន្ថែមទៀត។ **កាតព្វកិច្ចទី១ តភ្ជាប់ផ្លូវលេខ៧ តភ្ជាប់ទៅព្រំដែនឡាវ ដើម្បីពង្រីកនិងពង្រឹងគុណភាពរបស់វា ... យើងបានធ្វើម្តងរួចជាមួយគ្នា ប៉ុន្តែឥឡូវវាខូច ... កាតព្វកិច្ចទី២ នៅឆ្នាំ ២០២៣ នេះគឺនឹងសម្ពោធបើកការដ្ឋានសាងសង់ស្ពាននៅម្តុំក្បែរទីរួមខេត្តក្រចេះ ដើម្បីយើងតភ្ជាប់ទៅកំពង់ធំ។** កុំនឹកស្មានថា ហ៊ុន សែន ភ្លេចខេត្តក្រចេះឲ្យសោះ។ មិនភ្លេចទេ។ ការតភ្ជាប់ស្ពានក្នុងខេត្តក្រចេះនេះ មិនមែនគ្រាន់តែសម្រាប់ចម្ងងពីត្រើយម្ខាងទៅត្រើយម្ខាងទេ ក៏ប៉ុន្តែយើងសង់ផ្លូវមួយខ្សែទៅដល់កំពង់ឬ ឯខេត្តកំពង់ធំ ឯណោះ ... មិត្តចិនកាលណាគាត់និយាយហើយ គាត់ធ្វើលឿនជាងផែនការកំណត់។ នេះគឺជាទម្លាប់របស់ចិន។ គាត់និយាយតិច ប៉ុន្តែគាត់ធ្វើច្រើន។ មិត្តចិនជួយកិច្ចការនៅខេត្តក្រចេះ តភ្ជាប់ទៅស្ទឹងត្រែង និងតភ្ជាប់ខេត្តកំពង់ធំ ...៕

៦៨. អាស៊ាន Highway ហូជីមិញ/ភ្នំពេញ/បាងកក ក្លាយជាការពិត

បើកការដ្ឋានសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-បាវិត, ៧ មិថុនា ២០២៣

... ឃើញពីសារៈសំខាន់នៃផ្លូវល្បឿនលឿន យើងក៏ចរចាជាមួយមិត្តចិនគឺក្រុមហ៊ុនសាជីវកម្មស្ពានថ្ពល់ ដែលបានអនុវត្តគម្រោង**ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ ដើម្បីតភ្ជាប់រវាងទីក្រុងភ្នំពេញជាមួយក្រុងបាវិត និងតភ្ជាប់ទៅផ្លូវល្បឿនលឿនរបស់វៀតណាម ... វៀតណាមក៏នឹងកសាងផ្លូវល្បឿនលឿនពីទីក្រុងហូជីមិញ មកភ្ជាប់ផ្លូវល្បឿនលឿនជាមួយយើង។ នេះចាត់ទុកថាជាការតភ្ជាប់ដ៏មានសារៈសំខាន់ ជាផ្នែកមួយនៃការអនុវត្តគម្រោង Highway អាស៊ាន ដែលមុននេះមានតែគំនិតផ្តួចផ្តើម ប៉ុន្តែគ្មានលុយអនុវត្តទេ។ ឥឡូវនេះ តាមរយៈនៃការចូលរួមពីផ្នែកឯកជន កម្ពុជាតភ្ជាប់អាស៊ាន Highway រវាងកម្ពុជានិងវៀតណាម រវាងហូជីមិញ ភ្នំពេញនិងទីក្រុងបាងកក ឱ្យក្លាយទៅជាការពិត** ...៕

៦៩. រាល់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ត្រូវស្វែងរកមីននិង/ឬយុទ្ធភណ្ឌមិនទាន់ផ្ទុះ

បើកការដ្ឋានសង់ផ្លូវជាតិលេខ១១ ស្ពានអ្នកលឿង-ថ្នល់ទទឹង(ផ្លូវជាតិលេខ៧), ២៣ មីនា ២០១៨

... ប្រទេសរបស់យើងអភ័ព្វ។ សាងសង់(អ្វីមួយ) ក៏ត្រូវរុករកមីននិងគ្រាប់មិនទាន់ផ្ទុះនៅកន្លែងនោះសិន។ ដោយសារអី? សង្គ្រាមរវាងឆ្នាំ១៩៧០ និង ១៩៧៥ គឺជាសង្គ្រាមដែលរាយសាយពីលើអាកាសមកកាន់ទឹកដី ... មានការបាញ់ផ្លោងពេញដី មិនមែនគ្រាន់តែអាវុធធម្មតាទេ។ **គ្រប់ទីកន្លែងគំរោង យើងត្រូវប្រើដើមទុនច្រើន។ បើយើងមិនមានប្រាក់ដោះមីនដោយខ្លួនឯង និងប្រាក់ដោះស្រាយផលប៉ះពាល់ទេ គម្រោងផ្លូវនានាមិនអាចកើតឡើងបានដែរ។ ហេដ្ឋារចនាសម្ព័ន្ធ**

ប្រឡាយទឹកស្តីៗ ក៏ត្រូវបំផ្លាញគ្រាប់មីនជាមុន។ បើមិនដូច្នេះទេ ការផ្ទុះមីន និង/ឬយុទ្ធភណ្ឌដែលមិនទាន់ផ្ទុះ ក្នុងពេលកំពុងសាងសង់ ធ្វើឲ្យគ្រោះថ្នាក់។ នេះជាអតីតកាលដែលបន្សល់ការឈឺចាប់។ ខ្ញុំតែងបានអំពាវនាវថាដើម្បីបន្តការអភិវឌ្ឍជម្រើសល្អតែមួយគត់គឺត្រូវបន្តរក្សាសន្តិភាពឲ្យខានតែបាន។ គ្មានសន្តិភាព មានត្រឹមតែគ្មានការអភិវឌ្ឍទេ។ របស់ដែលមានស្រាប់ក៏ត្រូវបំផ្លាញចោលដែរ។ ដាច់ផ្លូវ ដាច់ស្ពាន ខូចសាលារៀន មន្ទីរពេទ្យ វត្តអារាម ខូចខ្ទេច ខូចខ្ទី ...៕

៧០. ៩០%សម្រេចបានជាតំបន់ព្រំដែនអភិវឌ្ឍនិងទីផ្សារ នៅ១០% រារាំងដោយមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់សេដ្ឋកិច្ចពិសេសនាងកុក ខេត្តកោះកុង, ១៣ មីនា ២០១៩

... ខ្ញុំចង់គូសបញ្ជាក់នៅទីនេះប្រាប់ថា យុទ្ធសាស្ត្រ២ បន្ទាប់ពីនយោបាយឈ្នះឈ្នះ ដែល ហ៊ុន សែន បានដាក់ចេញ និងដឹកនាំ។ **យុទ្ធសាស្ត្រទី១ គឺការប្រែក្លាយតំបន់អតីតសមរភូមិទាំងអស់ឲ្យទៅជាតំបន់អភិវឌ្ឍន៍ និងទៅជាទីផ្សារ បាននិងកំពុងទទួលជោគជ័យ អាចនិយាយបានថា៩០% រួចហើយ។ នៅសល់១០% មិនមែនរារាំងដោយនយោបាយទេ តែដោយឃាតករលាក់គឺគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ដែលចាំបាច់ត្រូវដោះបំផ្លាញចោលដើម្បីឲ្យទីនោះក្លាយទៅជាតំបន់ជាំដុះរបស់កសិកររបស់យើង។** ឯទី២ នយោបាយកសាងខ្សែព្រំដែនជាមួយប្រទេសជិតខាង ឲ្យទៅជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ បាននិងកំពុងទទួលជោគជ័យហើយ។ មានចំណុចនោះសេសសល់បន្តិចបន្តួច ដែលវាជារឿងធម្មតារវាងប្រទេសមួយនិងប្រទេសមួយ។ យើងអត់ធ្មត់ដោះស្រាយបញ្ហាជាមួយគ្នាដោយសន្តិវិធី ...៕

៧១. ការដឹកជញ្ជូនមានតម្លៃខ្ពស់ ក្នុងក្របខ័ណ្ឌបណ្តាប្រទេសក្នុងតំបន់

សម្ពោធចំណតផែពហុបំណង នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ, ២៥ មិថុនា ២០១៨

... សព្វថ្ងៃ ការដឹកជញ្ជូននៅក្នុងប្រទេសរបស់យើងមានការលំបាក។ យើងមិនមែនជាប្រទេសដែលគ្រាន់តែទទួលជំនួយពីខាងក្រៅ ដែលដឹកជញ្ជូនប៉ុន្មានពាន់តោនមកកំពង់ផែនេះ ឬការនាំទំនិញចេញ(តិចតួច)ដូចកាលពីពេលមុននោះ

ទេ។ ឥឡូវនេះ **វាមានទាំងការនាំទំនិញចេញនិងការនាំទំនិញចូល។ កន្លងទៅការដឹកជញ្ជូនរបស់យើងមានការលំបាក ដែលអាចចាត់ទុកថាជាការដឹកជញ្ជូនដែលមានតម្លៃខ្ពស់នៅក្នុងក្របខណ្ឌនៃបណ្តាប្រទេសក្នុងតំបន់** ... កប៉ាល់ធំៗ ដែលទទួលទំនិញពីកម្ពុជា ស្នាក់នៅឯប្រទេសវៀតណាម ឬសិង្ហបុរីឯណោះ ហើយយើងត្រូវដឹកតាមកប៉ាល់តូចៗ កប៉ាល់ល្មមទៅផ្ទេរទំនិញនៅទីនោះ។ បើដឹកចូលត្រឡប់មកវិញ កប៉ាល់ដឹកលើសពី ១ម៉ឺនតោនត្រូវផ្ទេរទៅកប៉ាល់(តូច ឬល្មម)ដូច្នេះការលើកដាក់ត្រូវប្រើពេលវេលាដល់ទៅ ២ដង គឺម្តងនៅកំពង់ផែ តែម្តងទៀតការលើកដាក់ផ្ទេរទំនិញនៅប្រទេសវៀតណាម ឬសិង្ហបុរី ឬថៃ ... **ចាប់ពីពេលនេះតទៅ កប៉ាល់ចំណុះត្រឹម ៥ ម៉ឺនតោន ចុះក្រោម អាចចូលមកដល់កំពង់ផែនេះតែម្តង ដោយគ្មានការចាំបាច់ដើម្បីនឹងការផ្ទេរទំនិញនោះទេ** ...៕

៧២. គិតគូរភូមិសាស្ត្រប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនដើម្បីផលចំណេញខាងសេដ្ឋកិច្ច

បើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុង ខ្សែទី៣ (ផ្លូវជាតិលេខ៤ ដល់១), ១៤ មករា ២០១៩

... ពីមុន យើងបានគិតគូរលើភូមិសាស្ត្រនៃវិស័យអប់រំ ភូមិសាស្ត្រនៃវិស័យសុខាភិបាល ... ឥឡូវនេះ **យើងត្រូវតែគិតគូរឲ្យបានហ្មត់ចត់អំពីភូមិសាស្ត្រប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនដើម្បីភាពចំណេញរបស់ប្រជាជន និងក្នុងវិស័យសេដ្ឋកិច្ច** ... កន្លងទៅ យើងត្រូវរកទុនបន្ថែមពីមិត្តចិនស្ថាបនាស្ពានមួយដែលនឹងភ្ជាប់រវាងម្ខាងស្រុកស្ទឹងត្រង់របស់ខេត្តកំពង់ចាម និងម្ខាងទៀតរវាងស្រុកក្រូចឆ្មារ របស់ត្បូងឃ្មុំ ... រវាងផ្លូវជាតិលេខ៧ ទៅផ្លូវជាតិលេខ៦ ខាងខេត្តកំពង់ធំ ... យើងកំពុងតែសិក្សាតភ្ជាប់ខេត្តក្រចេះជាមួយខេត្តកំពង់ធំ ជាមួយស្ពានមួយទៀត នៅទីរួមខេត្តក្រចេះ ... យើងកំពុងតែរកទុនកសាងផ្លូវភ្ជាប់ពីខេត្តកោះកុង ទៅឋដា នៃខេត្តពោធិ៍សាត់ ព្រំដែនកម្ពុជា-ថៃ ហើយចេញពីព្រំដែនកម្ពុជា-ថៃ ទៅសំឡូត នៃខេត្តបាត់ដំបង ភ្ជាប់ជារបៀង កុំឲ្យអ្នកកោះកុងលំបាកធ្វើដំណើរចេញមកតាមផ្លូវជាតិលេខ៤ មកដល់ភ្នំពេញ បានកាត់ទៅខេត្តពោធិ៍សាត់ កាត់ទៅខេត្តបាត់ដំបង ...៕

៧៣. នឹងអាចសង់ព្រលានយន្តហោះមួយទៀតនៅភាគឦសាន

បើកការដ្ឋានសាងសង់ផ្លូវល្បឿនលឿន ក្រុងភ្នំពេញ-ខេត្តព្រះសីហនុ, ២២ មីនា ២០១៩

... ត្រូវធានាថាប្រទេសរបស់យើងមានការអភិវឌ្ឍ ហើយជាគោលដៅរបស់យើង **គ្រាន់តែនៅភ្នំពេញក៏ត្រូវធ្វើព្រលានយន្តហោះថ្មី សៀមរាបក៏ត្រូវធ្វើព្រលានយន្តហោះថ្មី ហើយក៏កំពុងតែពិនិត្យមើលលទ្ធភាពជាក់ព្រលានយន្តនៅទិសឦសាន។ ពីដើម មិនសូវមានអ្នកមានលុយជិះយន្តហោះទេ។ ឥឡូវនេះ ភ្នំពេញ-សៀមរាបមនុស្សពេញៗ។ ភ្នំពេញ-កំពង់សោមមិនទាន់ឃោសនាច្រើនទេ ... ខ្ញុំគិតថានៅចន្លោះមណ្ឌលគិរីនិងរតនគិរី។ អាចនៅក្នុងតំបន់ហ្នឹង។ អាចធ្វើព្រលានយន្តហោះក្នុងប៉ូលសេដ្ឋកិច្ចមួយសំខាន់នៅទិសឦសានរបស់ប្រទេស**។ ក្នុងហ្នឹងវាទៅទាំងសំណុំ គឺទាំងកសិឧស្សាហកម្ម កសិទេសចរណ៍ និងផ្នែកដទៃទៀត ដើម្បីជម្រុញពីប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបពេលនេះ ឲ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងសំរេចក្នុវិស័យ ប្រាក់ចំណូលកម្រិតខ្ពស់នៅឆ្នាំ ២០៥០ ...។

៧៤. ធ្វើព្រលានថ្មីទទួលយន្តហោះធុនធំនៅសៀមរាប ភ្នំពេញ និងពង្រីក Piste នៅខេត្តព្រះសីហនុ

ពិនិត្យការងារជាក់ស្តែងនៅការដ្ឋានអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ, ៣ មេសា ២០២២

... សូមយកឱកាសនេះជម្រាបជូនប្រជាពលរដ្ឋកម្ពុជារបស់យើងឱ្យបានជ្រាបថា ... នៅសៀមរាប មានព្រលានយន្តហោះហើយ តើចាំបាច់អ្វីកសាងព្រលានយន្តហោះមួយទៀត? ព្រលានយន្តហោះសៀមរាប ដែលយើងប្រើរយៈពេលកន្លងទៅ និងកាលពីមុនចាត់ទុកថាជាព្រលានធំ **តែនៅពេលដែលយន្តហោះ (ត្រូវបានសង់) កាន់តែធំ (ធ្វើឲ្យ) ព្រលានយន្តហោះរបស់យើងមិនអាចទទួលយន្តហោះធុនធំចុះចតបាន។ ម្ខាងគឺផ្លូវរត់ (មានចម្ងាយ) ខ្លី និងមិនអាចទ្រទម្ងន់យន្តហោះខ្នាតធំបាន។ ម្ខាងទៀត អ្នកបច្ចេកទេសមានកង្វល់ពាក់ព័ន្ធនឹងបេតិកភណ្ឌប្រវត្តិសាស្ត្រគឺប្រាង្គប្រាសាទអង្គរវត្ត**។ (អាកាសយានដ្ឋានថ្មី) ជាកន្លែងដែលយន្តហោះធុនធំ ធ្វើដំណើរលើសពី ១០ម៉ោង អាចចុះចតបាន ... ទីក្រុងភ្នំពេញក៏ដូចគ្នា។

ព្រលានយន្តហោះចាស់ទទួលឲ្យចុះចតបានយន្តហោះធុនធំហើយ ក៏ប៉ុន្តែសមត្ថភាពទទួលភ្ញៀវមិនគ្រប់។ ដូច្នេះ យើងកំពុងធ្វើព្រលានយន្តហោះមួយទៀតនៅខេត្តកណ្តាល ... **លើកលែងតែខេត្តព្រះសីហនុ ដែលមានតម្រូវការធ្វើពីស (piste) បន្ថែម សម្រាប់ការចុះចតយន្តហោះធុនធ្ងន់** ...។

៧៥. "តារាងនៅទិសឧត្តរ" អាស្រ័យវឌ្ឍនភាពសាងសង់អាកាសយានដ្ឋានអន្តរជាតិសៀមរាប ...

ពិនិត្យការងារជាក់ស្តែងនៅការដ្ឋានអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ, ៣ មេសា ២០២២

... យើងទាំងអស់គ្នាមកពិនិត្យវឌ្ឍនភាពនៃការកសាងអាកាសយានដ្ឋានអន្តរជាតិសៀមរាប-អង្គរ ហើយនៅថ្ងៃស្អែកសម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវ (ចំនួន) ៣៨ ខ្សែនៅឯទីក្រុងសៀមរាប។ ខ្ញុំគិតថា **ល្មមដល់ពេលដែលយើងប្រកាសថា "តារាងនៅទិសឧត្តរ" បន្ទាប់ពីយើងបានប្រកាស "តារាងនៅទិសនិរតី" ដែលសំដៅលើតំបន់ឆ្នេរជាតំបន់ទេសចរណ៍ ... បន្ទាប់ពីបានឃើញផ្ទាល់ភ្នែកនូវការដ្ឋានដែលបានសាងសង់រួចមកហើយ ជាពិសេសផ្លូវរត់និងការដ្ឋានមួយចំនួនផ្សេងទៀត យើងមានការជឿជាក់ចំពោះវឌ្ឍនភាពដែលបានកើតឡើង បើទោះបីជាមានការលំបាកនៅក្នុងដំណាក់កាលកូវីដ-១៩ ដែលធ្វើឱ្យពាំងស្ទះដល់ការដឹកជញ្ជូនសម្ភារបរិក្ខារមកកាន់ទីនេះ** ... ក្រុមហ៊ុនក៏ដូចជា គណៈកម្មការសាងសង់នៅតែខិតខំសំរេចឱ្យបានតាមមការគ្រោងទុក ឈានទៅបើកឱ្យប្រើប្រាស់នៅក្នុងឆ្នាំ ២០២៣ ខាងមុខ។ នេះមិនមែនជាគម្រោងតូចតាចទេ។ ជាគម្រោងទំហំធំ ដែលការចុះហត្ថលេខានោះ (ប្រព្រឹត្តទៅ) ក្រោមអធិបតីភាពរបស់ប្រធានាធិបតី Xi Jinping ជាមួយនឹងខ្ញុំ ក្នុងដំណើរទស្សនកិច្ចរបស់គាត់នៅព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ២០១៦ ...។

៧៦. ចាប់ឡានដឹកលើសទម្ងន់ និងមិនឱ្យឡានតម្រុងខុសបច្ចេកទេសមានវត្តមានលើផ្លូវ

បើកការដ្ឋានសង់ស្ពានឆ្លងកាត់ទន្លេមេគង្គ ពីស្ទឹងត្រង់ទៅក្រូចឆ្មារ, ៩ កុម្ភៈ ២០១៨

... គ្រោះថ្នាក់ចរាចរណ៍នៅប្រទេសយើងច្រើន។ ម្យ៉ាងទៀត រឿងរថយន្តដឹកលើសទម្ងន់នេះ ខ្ញុំ**សូមដាក់ចេញនូវបទបញ្ជាអនុវត្តឲ្យបានម៉ឺងម៉ាត់បំផុត។ អំពី**

ក្រុមហ៊ុនដែលដឹកជញ្ជូនលើសទម្ងន់ យើងកោះប្រជុំក្រុមហ៊ុន ដើម្បីនិយាយគ្នា។ ប្រសិនជាមាន (ទី១)យើងអាចចាប់រថយន្ត ហើយបិទក្រុមហ៊ុនទៀត។ បើទោះក្រុមហ៊ុនសោដឹកជញ្ជូនណាក៏ដោយ ... ព្រោះថាអ្នកឯងបានបង្កការបាត់បង់ជីវិតមនុស្សបំផ្លាញផ្លូវ ... បើអ្នកឯងមិនកែ ខ្ញុំបិទក្រុមហ៊ុនចោល ... **ទី២ រឿងកាត់ឡានត(ទ្រុង)។ ខ្ញុំសូមបញ្ជាក់ ចាប់ពីម៉ោង០ យប់នេះទៅ ឡានតទ្រុងទាំងប៉ុន្មានមិនត្រូវមានវត្តមានលើផ្លូវទេ។** បើមានវត្តមានលើផ្លូវនៅក្នុងខេត្តណា ស្រុកណា ចៅហ្វាយខេត្តនោះ ចៅហ្វាយស្រុកនោះទទួលខុសត្រូវ។ យើងចាប់ទាំងអស់ កាត់ទាំងអស់ ... ខ្ញុំនឹងតាមមើល ...។

៧៧. ៦ចំណុចឆ្លើយតបទៅការចុះផ្សាយមួលបង្កាច់ស្តីពីព្រែកជីកហ្វូណានតេជោ

ដកស្រង់ពីហ្វេសប៊ុកផេច សម្តេចតេជោ ហ៊ុន សែន, ៩ មេសា ២០២៤

... បន្ទាប់ពីការចុះផ្សាយមួលបង្កាច់ជាបន្តបន្ទាប់អំពីវត្តមានកងទ័ពចិន នៅមូលដ្ឋានកងទ័ពជើងទឹករាម ពេលនេះគេប្រឌិតរឿង ព្រែកជីកតេជោហ្វូណានម្តងដោយលើកឡើងទាំងលិតលង់ថា ព្រែកជីកដែលនៅជិតព្រំដែនវៀតណាមនេះនឹងសម្រួលដល់កងទ័ពជើងទឹកចិន ក្នុងពេលដែលព្រែកជីកកំពុងស្ថិតនៅជាគំរោងនៅឡើយ។ ថ្ងៃនេះ ខ្ញុំចង់ជាស់តឿនអ្នកជាមិត្តភក្តិ និងអ្នកមិនមែនមិត្តភក្តិ លើចំណុចមួយចំនួនដូចខាងក្រោម៖ **១. តើកម្ពុជាត្រូវការកងទ័ពចិនមកធ្វើអ្វី? និងដើម្បីអ្វី? ២. កម្ពុជានិងវៀតណាម ជាប្រទេសជិតខាងប្រកបដោយមិត្តភាព និងសហប្រតិបត្តិការល្អលើគ្រប់វិស័យ។ ៣. ចិន និងវៀតណាម មានទំនាក់ទំនងល្អ និងជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ។ ៤. តើកម្ពុជាឆោតល្ងង់រហូតដល់យកកងទ័ពចិន មកនៅក្នុងប្រទេសរបស់ខ្លួន ដែលវាផ្ទុយជាមួយរដ្ឋធម្មនុញ្ញរបស់ខ្លួនឬ? និង តើចិនឆោតល្ងង់រហូតយកកងទ័ពខ្លួនមកនៅកម្ពុជា ដែលវាផ្ទុយជាមួយគោលការគោរពឯករាជ្យភាពកម្ពុជា ពីសំណាក់ចិនឬ?។ ៥.ក្រៅពីមាត្រា៥៣ នៃរដ្ឋធម្មនុញ្ញ ដែលហាមឃាត់មិនឲ្យកម្ពុជាមានមូលដ្ឋានយោធាបរទេសលើទឹកដីរបស់ខ្លួន នៅមានមាត្រាទី៥៥ ចែងច្បាស់ថា (សន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងឡាយណា ដែលមិនស្របនឹងឯករាជ្យ អធិបតេយ្យបូរណភាពទឹកដី អព្យាក្រឹតភាព និងឯកភាពជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល)។ ចំណុចនេះបានបញ្ជាក់ច្បាស់ថា គ្មានកិច្ចព្រមព្រៀងណាមួយអនុវត្តបានទេ ប្រសិនវាមិន**

ស្របជាមួយឯករាជ្យអធិបតេយ្យភាពកម្ពុជា ... ៦.ព្រែកជីកហ្វូណានតេជោ ជាផលប្រយោជន៍សេដ្ឋកិច្ចសង្គមសុទ្ធសាធ ជួយឲ្យកម្ពុជាមានផ្លូវទឹកដឹកជញ្ជូនទៅកាន់សមុទ្រ បន្ថែមលើផ្លូវដឹកជញ្ជូនតាមដងទន្លេមេគង្គដែលមានស្រាប់ ...។ល។

៧៨. ត្រូវការប្រជាជនគាំទ្រជាចលនាជាតិ ដើម្បីសម្រេចបានព្រែកជីកហ្វូណានតេជោ

សំណេះសំណាល និងពិសាបាយជាមួយសមាគមអ្នកឧកញ៉ា/ឧកញ៉ា, ២៦ មេសា ២០២៤

... សូមនិយាយបន្តិចអំពីប្រធានបទ ព្រែកជីកហ្វូណាន-តេជោ ... នេះគឺជាការសម្រេចចិត្តនៃគណៈរដ្ឋមន្ត្រីដែលដឹកនាំដោយ ហ៊ុន សែន។ ឥឡូវ ហ៊ុន សែន ត្រូវចេញការពារនិក្ខេបបទនេះ និងបកស្រាយត្រឡប់ទៅវិញ ជូនទៅមិត្តភក្តិក្នុងតំបន់ និងលើពិភពលោក ជាពិសេសជូនជនរួមជាតិកម្ពុជាឲ្យបានជ្រាបអំពីសារៈសំខាន់នៃព្រែកជីកហ្វូណាន-តេជោ។ ប៉ុន្មានថ្ងៃមុន ខ្ញុំបានប្រតិកម្មតាមហ្វេសប៊ុកទៅនឹងអ្នកលើកឡើងថា ព្រែកជីកហ្វូណាន-តេជោ នឹងបង្កលក្ខណៈឲ្យចិនប្រើប្រាស់កងទ័ពជើងទឹក(នៅកម្ពុជា)។ ពេលនេះ ខ្ញុំត្រូវបង្ហាញ(ទឡ្លីករណ៍អោយបានច្បាស់លាស់)។ ខ្ញុំមិនអនុញ្ញាតឲ្យអ្នកណាជុតផ្ទះរបស់ខ្ញុំ ដើម្បីចម្អិនពងមាន់មួយទេ។ មិនថាមិត្តមិនថាសត្រូវ។ មិនថាប្រទេសអ្នកឯងជានរណា ខ្ញុំត្រូវតែការពារជាតិរបស់ខ្ញុំ។ សូមអ្នកទាំងឡាយ **កុំឆ្មៀតជុតផ្ទះរបស់ខ្ញុំដើម្បីគ្រាន់តែចម្អិនសាច់មួយដុំរបស់អ្នក។ ពួកអ្នកត្រូវយល់ ត្រូវទទួលស្គាល់អំពីផលប្រយោជន៍របស់កម្ពុជា។ សំខាន់ជាងនេះទៀត ខ្ញុំត្រូវការការយល់និងការគាំទ្រពីប្រជាជនកម្ពុជា ឲ្យក្លាយជាចលនាជាតិដើម្បីសម្រេចឱ្យបាននូវព្រែកជីកហ្វូណានតេជោ** ...។

៧៩. ផលប្រយោជន៍៤ យ៉ាង នៃព្រែកជីកហ្វូណានតេជោ

សំណេះសំណាលនិងពិសាបាយជាមួយសមាគមអ្នកឧកញ៉ា/ឧកញ៉ា, ២៦ មេសា ២០២៤

... តើព្រែកជីកហ្វូណានតេជោ ជើរតួនាទីអ្វីខ្លះ? ផ្តល់ផលប្រយោជន៍អ្វីខ្លះ? ខ្ញុំមិននិយាយជំនួស(ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីសាធារណការនិងដឹកជញ្ជូន) ស៊ុន ចាន់ថុល ដែលទទួលបន្ទុកដឹកនាំសិក្សាគម្រោងនេះ រហូតដល់មានការអនុម័តពីគណៈរដ្ឋមន្ត្រី ដែលពេលនោះខ្ញុំនៅជានាយករដ្ឋមន្ត្រីនៅឡើយនោះ

ទេ ... តើយើងនឹងទទួលផលប្រយោជន៍បែបណាពីព្រែកជីកនេះ? **(ផលប្រយោជន៍)ទី១ វាផ្តល់នូវការងាយស្រួលសម្រាប់ការដឹកជញ្ជូននៅក្នុងប្រទេសតភ្ជាប់ទៅសមុទ្រដោយផ្ទាល់ ដោយមិនឆ្លងកាត់ប្រទេសផ្សេង។** វានឹងធ្វើឲ្យសេដ្ឋកិច្ចរីកចម្រើន មិនត្រឹមតែនៅភាគនិរតីប៉ុណ្ណោះទេ ក៏ប៉ុន្តែនៅទូទាំងប្រទេសផងដែរ។ ផលកសិកម្មរបស់យើង ដែលមានតាំងពីក្រចេះ ស្ទឹងត្រែង កំពង់ចាម អាចដឹកជញ្ជូនចេញទៅក្រៅប្រទេស។ អ្នកខាងសៀមរាប ខាងកំពង់ឆ្នាំង ដែលមានលទ្ធភាពដឹកជញ្ជូនតាមផ្លូវទឹកអាចចូលទៅតាមច្រកនេះដើម្បីចេញទៅសមុទ្រ។ ប្រព័ន្ធដឹកជញ្ជូនបែបនេះ វានឹងបង្កនូវការទាក់ទាញវិនិយោគិនមកកម្ពុជា ... **ផលប្រយោជន៍ទី២ នៅទិសនិរតីរបស់កម្ពុជានឹងមានប្រព័ន្ធស្រោចស្រពមួយ ជំនួសឲ្យការខ្វះទឹក។** ដូចជាពេលនេះ រាំងស្ងៀង ៦ឬ៧ខែ អត់ទាន់មានស្លៀងធ្លាក់ទេ។ ប្រភពទឹកទាំងឡាយ សូម្បីតែទឹកស្អាតនៅតាកែវក៏ខ្វះ ... ផ្ទៃស្រែនៅទិសនិរតីនឹងផ្ទេរពីការធ្វើស្រូវម្តងទៅជាពីរឬបីដង ... **ផលប្រយោជន៍ទី៣ គឺការរំដោះទឹកជំនន់នៅពេលដែលទឹកជំនន់វាយលុកនៅទិសនិរតី។ កន្លងទៅយើងជួបការលំបាក។** ទីក្រុងកំពត កាលពីមុន តែងតែលិច ដោយសារតែវាអត់មានកន្លែងជម្លៀសទឹក ... និង**ផលប្រយោជន៍ទី៤ យើងនិយាយពីវារីវប្បកម្ម គឺកំណើនត្រីក្នុងទន្លេ ក្នុងព្រែកជីក** បន្ថែមលើនោះ ប្រជាជនអាចនឹងធ្វើវារីវប្បកម្ម ចិញ្ចឹមត្រី ចិញ្ចឹមបង្កង ...។

៨0. ប្រព័ន្ធដឹកជញ្ជូនព្រែកជីកហ្វូណនតេជោ ប្រទាក់ក្រឡាវាងផ្លូវទឹកនិងផ្លូវគោក

សំណេះសំណាល និងពិសាបាយជាមួយសមាគមអ្នកឧកញ៉ា/ឧកញ៉ា,
២៦ មេសា ២០២៤

... **បង្កើតបានប្រព័ន្ធដឹកជញ្ជូននេះ វាប្រទាក់ក្រឡាវាងផ្លូវទឹកនិងផ្លូវគោករបស់យើង បង្កើតនូវភាពងាយស្រួលសម្រាប់ប៉ែកនិរតីរបស់ប្រទេស។ លើសពីនេះទំនិញកម្ពុជាដែលមកពីគ្រប់កន្លែងអាចចូលទៅតាមច្រកទឹកនេះ។** ឡានមួយគ្រឿងដឹកបានតែមួយកុងតែន័រទេ តែកប៉ាល់ឬសាឡង់ ដែលដឹកតាមផ្លូវនេះ មួយសាឡង់ៗ អាចច្រើនកុងតែន័រ។ ដូច្នេះ វាកាត់បន្ថយការចំណាយថ្លៃដឹកជញ្ជូន ធ្វើឲ្យកម្ពុជាចំណេញប្រាក់ ... សង្ឃឹមថា មេដឹកនាំវៀតណាមនឹងយល់ពីអ្វីដែលជាតម្រូវការដែលខ្ញុំនិយាយថ្ងៃនេះ។ ពីរបីថ្ងៃនេះ មានការសិក្សា។ ខ្ញុំនឹងនិយាយដល់ការសិក្សានោះពីវិទ្យាស្ថាន កាន់ចឺ របស់វៀតណាម ...។

៨១. ព្រែកជីកហ្វូណនតេជោ នឹងបង្កើតបានជាប្រព័ន្ធ ecology

សំណេះសំណាល និងពិសាបាយជាមួយសមាគមអ្នកឧកញ៉ា/ឧកញ៉ា,
២៦ មេសា ២០២៤

... **ព្រែកជីកហ្វូណនតេជោហ្នឹង មិនមានប៉ះពាល់អីនឹងប្រព័ន្ធ ecology ទេ។ ផ្ទុយទៅវិញ វានឹងបង្កើតប្រព័ន្ធ ecology មួយតភ្ជាប់ពីទន្លេបាសាក់ទៅកាន់ដៃសមុទ្រ ពីស្ថានភាពដែលគ្មានទឹកទៅជាស្ថានភាពដែលមានទឹក។** ខ្ញុំមិនមែនរុញឲ្យប្រជាជនកម្ពុជាស្អប់ប្រជាជនវៀតណាមទេ ប៉ុន្តែក៏សូមអង្វរករប្រជាជនវៀតណាមធ្វើករណីដូចគ្នា ហើយឲ្យគិតគូរផលប្រយោជន៍ពីគ្នា ... ជារួម វៀតណាមបង្កបង្កើនផលបានល្អណាស់ តែគាត់មានវិធីសាស្ត្រការពារ។ គាត់ធ្វើទំនប់ច្រើនការពារ។ កាលណាប្រជាជនមិនទាន់ទទួលផលទេ ជំនន់ចុងខែកក្កដានិងដើមខែសីហា គាត់បិទទំនប់ទាំងអស់ដើម្បីការពារស្រូវ ការពារផលដំណាំរបស់គាត់។ កម្ពុជាទេដែលជាជនរងគ្រោះដោយសារទំនប់របស់វៀតណាមនៅខាងក្រោម ...។

៨២. បើមិនធ្វើព្រែកជីកហ្នឹង កម្ពុជានៅតែពឹងដង្ហើមគេដក មិនអាចប្រកួតប្រជែងបាន

សំណេះសំណាល និងពិសាបាយជាមួយសមាគមអ្នកឧកញ៉ា/ឧកញ៉ា,
២៦ មេសា ២០២៤

... ខ្ញុំសូមទូន្មានប្រទេសមួយចំនួនដែលយកបញ្ហា(ព្រែកជីក)ហ្វូណនតេជោនេះជាការប្រឆាំងនឹងកម្ពុជា។ សូមបញ្ឈប់ទៅ។ គួរតែគោរពដល់ព្រះរាជតម្រិះរបស់ព្រះបាទអង្គឌួង។ នៅចាំបានទេ ផ្លូវ៨១ គឺជាផ្លូវរបស់អង្គឌួងធ្វើទៅកាន់មាត់សមុទ្រ។ ព្រះអង្គក៏មានព្រះរាជតម្រិះអំពីជីកព្រែកហ្នឹងដែរ ប៉ុន្តែធ្វើមិនបាន។ មកដល់ដំនាន់នេះ យើងត្រូវធ្វើហើយ ... **បើមិនធ្វើព្រែកជីកហ្នឹងទេ កម្ពុជានៅតែពឹងដង្ហើមគេដក ដែលបើគេត្រូវផ្តាច់ក៏ផ្តាច់ គេឲ្យក៏ឲ្យ។ នេះក៏ជាសារសំរាប់វៀតណាមថា មូលហេតុអ្វីដែលកម្ពុជាសម្រេចថាត្រូវធ្វើព្រែកជីកនេះ។ កម្ពុជាត្រូវបង់ថ្លៃដែលដាក់សម្ពាធលើសមត្ថភាពប្រកួតប្រជែង។** បានព្រែកជីកនេះ ថ្លៃដឹកជញ្ជូនភ្លើង ពលកម្ម អាចឱ្យយើងប្រកួតប្រជែងបាន ...។

៨៣. ទ្វារទឹក៣ ធានាទឹកសាបមិនចេញទៅសមុទ្រ ហើយទឹកប្រៃមិនចូលមកក្នុងព្រែក

សំណេះសំណាល និងពិសាបាយជាមួយសមាគមអ្នកឧកញ៉ា/ឧកញ៉ា,
២៦ មេសា ២០២៤

... កម្ពុជាត្រូវតែធានាថាមិនត្រូវខ្វះទឹកហូរពីលើទៅ។ ខ្លួនឯងខ្វះទឹកក្នុងទន្លេបាសាក់ ហើយបែរជាឱ្យទឹកប្រៃហូរចូលមកក្នុងព្រែកនេះដល់កំពត ដល់កែប ដល់តាកែវ ... កម្ពុជាមិនល្ងង់ទេ។ ខ្ញុំធ្វើសេចក្តីសម្រេចមក ៤៧ឆ្នាំ, ហ៊ុន សែន មិនដែលសម្រេចចិត្តខុសម្តងណាទេ។ **បើនិយាយពីទឹក ការដែលយើងជីកព្រែកនេះ គ្រាន់តែទឹកភ្លៀងវាគ្រប់គ្រាន់ហើយ។ តើវានឹងបាត់ទឹកទៅណា។ យើងមានទ្វារទឹកហូតទៅដល់ ៣។ ធានាថាមិនឱ្យទឹកសាបចេញទៅសមុទ្រ ហើយក៏ធានាថាមិនឱ្យទឹកប្រៃពីសមុទ្រចូលមកក្នុងព្រែកនេះដែរ។ កម្ពុជាចេះការពារផលប្រយោជន៍របស់ខ្លួន មិនចាំបាច់វៀតណាមមានកង្វល់ទេ** ... ការសិក្សាបែបនេះ យើងទទួលយកមិនបានទេ។ មានអ្នកសិក្សា ២នាក់ទៀតរបស់វៀតណាមបានបញ្ជូន(អត្ថបទ)ទៅឱ្យ The Straits Times របស់សិង្ហបុរីចុះផ្សាយ ...៕

៨៤. ឆ្នាំ២០១៦ ទឹកសមុទ្រហូរចូលវៀតណាម គឺជាគ្រោះធម្មជាតិ មិនមែនមកពីកម្ពុជាទេ

សំណេះសំណាលនិងពិសាបាយជាមួយសមាគមអ្នកឧកញ៉ា/ឧកញ៉ា,
២៦ មេសា ២០២៤

... កងទ័ពបរទេសទាំងអស់ មិនអាចមកឈរជើងនៅក្នុងស្រុកខ្មែរទេ លើកលែងតែអនុពន្ធយោធា។ ខ្ញុំដាក់ទៅប្រទេសអ្នកឯង អ្នកឯងដាក់មកប្រទេសខ្ញុំ។ មានកិច្ចព្រមព្រៀងស្តីសមយុទ្ធ សូមអញ្ជើញមក ប៉ុន្តែមិនអាចធ្វើសមយុទ្ធហើយបោះទីតាំងនៅហ្នឹងបានទេ។ សូមទៅវិញ។ សមយុទ្ធមានរយៈពេលវែង រយៈពេលខ្លី។ សូមអ្នកសរសេរនិងបញ្ជូនអត្ថបទទៅ The Straits Times ដឹងខ្លួន។ **ខ្ញុំសូមឆ្លើយតបទៅអ្នកសិក្សានៅ CAN THO ថា ទឹក៧០% ដែលថាបាត់នោះ វាអត់ទៅណា ហើយមិនធ្វើឱ្យទឹកប្រៃចូលទៅដីសណ្តោទន្លេមេគង្គទេ។ ឆ្នាំ២០១៦ កម្ពុជាក៏ខ្វះទឹកដែរ ... ទន្លេទាំងអស់វាទាប។ ទឹកសមុទ្រហូរចូលប្រទេសវៀតណាមស្ទើរពាក់កណ្តាលខាងក្រោម។ នោះវាជាគ្រោះធម្មជាតិ វាមិនមែនមកពីកម្ពុជាទេ** ...៕

៨៥. ការប្រើប្រាស់ដៃទន្លេមេគង្គ មិនតំរូវឲ្យពិគ្រោះយោបល់ឬយល់ព្រមពីប្រទេសហាត្តលេខី

សំណេះសំណាល និងពិសាបាយជាមួយសមាគមអ្នកឧកញ៉ា/ឧកញ៉ា,
២៦ មេសា ២០២៤

... យើងធ្វើកោះនរា នាយករដ្ឋមន្ត្រីខំចេញមកទស្សនកិច្ចលើកពីផលប៉ះពាល់នៃការកសាងកោះនរា។ បានខ្ញុំពន្យល់ថា អ្នកណាទៅរាយការណ៍ឲ្យឯកឧត្តម។ កោះនរាហ្នឹងមានតាំងពីដើម។ ប៉ុន្តែកោះហ្នឹង វាបានបាក់។ ឥឡូវហ្នឹង យើងខ្ញុំធ្វើកោះហ្នឹងឡើងវិញ។ កោះនរានៅក្បែរភ្នំពេញឯងសោះ រឿងអីទៅទើសដល់វៀតណាម។ វាមានអាធុនទៅឱ្យឺបដាក់ត្រចៀកហ្នឹងទៅទៀត។ ខ្ញុំអត់ថយក្រោយទេ។ សូមបញ្ជាក់ថាគ្មានត្រូវការចរចាអីទៀតទេ។ និយាយគ្នាត្រង់ៗ កុំហៅកម្ពុជាទៅចរចា ... ខ្ញុំឲ្យ (ឯកឧត្តម) ស៊ុន ចាន់ថុល បញ្ជាក់ឲ្យខ្ញុំ។ ឥឡូវខ្ញុំ note យកមកក្នុងនេះ។ **កិច្ចព្រមព្រៀងមេគង្គ ១៩៩៥ តម្រូវឲ្យភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងជូនដំណឹងដល់គណៈកម្មការទន្លេមេគង្គ មុនពេលចាប់ផ្តើមគម្រោង។ កិច្ចព្រមព្រៀងមិនតម្រូវឲ្យភាគីហត្ថលេខីស្វែងរកការពិគ្រោះយោបល់ ឬក៏ការយល់ព្រមពីប្រទេសហត្ថលេខីផ្សេងទៀតទេ ប្រសិនបើយើងប្រើប្រាស់ដៃទន្លេមេគង្គ** ...៕

៨៦. មិនបាច់ពិគ្រោះយោបល់អ្នកណាទេ ព្រោះកម្ពុជាប្រើប្រាស់ដៃនៃដៃទន្លេមេគង្គ

សំណេះសំណាល និងពិសាបាយជាមួយសមាគមអ្នកឧកញ៉ា/ឧកញ៉ា,
២៦ មេសា ២០២៤

... **យើងអត់បានប្រើប្រាស់ដៃទន្លេមេគង្គទេ។ យើងប្រើប្រាស់ដៃនៃដៃទន្លេមេគង្គ។ បើនិយាយទៅថា អ្នកដែលមានម្រាម៦ កូនដៃព្រែក។ ឥឡូវ ទន្លេបាសាក់វាជាដៃទន្លេមេគង្គ។ ដល់តែយើងជីកវា ជីកទៅលើដៃទន្លេមេគង្គទេ។ ប៉ុន្តែនៅក្នុងទីនេះ គេមិនចាំបាច់ឲ្យអ្នកណាពិគ្រោះយោបល់ពីអ្នកណាទេ**។ បើគ្រាន់តែប្រើ(ដៃនៃ)ដៃទន្លេមេគង្គ។ កម្ពុជាបានជូនដំណឹងទៅគណៈកម្មការទន្លេមេគង្គតាំងពីខែសីហាឆ្នាំទៅ។ សូមកុំហៅកម្ពុជាទៅពិគ្រោះយោបល់ជាមួយអ្នកណា ... អ្នកបច្ចេកទេសជាង ៤០នាក់បានមកសិក្សា ... សួរថា កិច្ចព្រមព្រៀងទន្លេមេគង្គហ្នឹងនៅមានសុពលភាពឬអត់ ? បើវានៅសុពលភាព មិនបាច់ខ្វល់ចរចាជាមួយអ្នកណាទាំងអស់។ បើចង់ ទៅមើលឯកសារនៅឯគណៈកម្មការមេគង្គទៅ។ បើខ្វះ

ខាតឯកសារអីសំណូមពរមក យើងអាចផ្ញើឯកសារជូនបន្ថែម ...៕

៨៧. ព្រែកជីកហ្វូណន-តេជោ ជាការផ្តើមគំនិតរបស់កម្ពុជា មិនមែនគំនិតផ្តើមក្របខ័ណ្ឌខ្សែក្រវាត់និងផ្លូវទេ

សារសម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា ស្តីពីគំរោងកសាង
ព្រែកជីកហ្វូណនតេជោ, ១៦ ឧសភា ២០២៤

... ខ្ញុំព្រះករុណាខ្ញុំ សូមទាក់ទាញការចាប់អារម្មណ៍អ្នកកាសែតបរទេសដែលខ្ញុំមិនដឹងថាអ្នកកាសែតបរទេសនោះ មាននិន្នាការប្រកេទណានោះទេ ក៏ប៉ុន្តែ(គឺតបដោយ)យោងទៅលើការដែលនិយាយចេញមកថា "ព្រែកជីកហ្វូណនតេជោគឺជាគំនិតផ្តួចផ្តើមរបស់ចិនក្នុងក្របខ័ណ្ឌខ្សែក្រវាត់និងផ្លូវ"។ **ខ្ញុំព្រះករុណាខ្ញុំ គ្រាន់តែគូសបញ្ជាក់ថា "ព្រែកជីកហ្វូណនតេជោ ជាព្រែកជីកដែលផ្តួចផ្តើមគំនិតទាំងស្រុងដោយភាគីកម្ពុជា"។ ចិនមិនបានដឹងរឿងនេះទេ។ យើងគ្រាន់តែបានពិភាក្សា និងឱ្យមានការចូលរួមក្នុងការសិក្សា។ យើងស្វះស្វែងរកក្រុមហ៊ុនចិនមកវិនិយោគរួមគ្នាជាមួយកម្ពុជាដើម្បីបង្កើតឡើងព្រែកជីកមួយនេះ**។ ដូច្នេះ សូមអ្នកដែលតែងតែចោទប្រកាន់យើងអំពីក្របខ័ណ្ឌភូមិសាស្ត្រនយោបាយ ដោយមានទំនោរឆ្ពោះទៅរកការប្រឆាំងចិន បញ្ឈប់រឿង(ចោទប្រកាន់)នេះទៅ។ វាជាការធោតល្ងង់ដែលអ្នកទាំងនោះលើកឡើងដោយមិនដឹងឫសគល់នៃបញ្ហា ...៕

៨៨. ទទឹង ១០០ម៉ែត្រ ជម្រៅទឹក ៥ម៉ែត្រ មិនឆ្លើយតបតម្រូវការចល័តកងទ័ពជើងទឹកទេ

សារសម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា ស្តីពីគំរោងកសាង
ព្រែកជីកហ្វូណន-តេជោ, ១៦ ឧសភា ២០២៤

... នេះជាគំនិតផ្តួចផ្តើមរបស់កម្ពុជា ដើម្បីផលចំណេញខាងសេដ្ឋកិច្ចនិងឯករាជ្យភាពខាងនយោបាយ លើការដឹកជញ្ជូនផ្លូវទឹក។ ម៉្យាងទៀត ខ្ញុំព្រះករុណាខ្ញុំសូមយកឱកាសនេះបញ្ជាក់ឡើងវិញ និងជំទាស់ចំពោះជនល្ងង់ខ្លៅមួយចំនួនដែលចាត់ទុកព្រែកជីកហ្វូណនតេជោថា នឹងត្រូវបានប្រើដោយកងទ័ពជើងទឹករបស់ចិន។ ខ្ញុំគិតថា វាមានការគួរឱ្យខ្មាសអៀនណាស់សម្រាប់ជនទាំងឡាយណាដែលបានលើកគំនិតបែបនេះ។ **សម្រាប់នាវាចម្បាំង បើទោះបីជាទន្លេមេគង្គកាលពីសម័យមុន ដែលមានកន្លែងខ្លះជាង ១០០០ម៉ែត្រ កន្លែងខ្លះ ១៥០០ម៉ែត្រ ឬ**

យ៉ាងតិច ៨០០ម៉ែត្រ ក៏គង់(នាវាម៉ារីន)ត្រូវបាញ់លិច។ ចុះទម្រាំធ្វើកូនព្រែកជីកមួយដែលមានទទឹងត្រឹមតែ ១០០ម៉ែត្រ ផ្នែកខាងក្រោមមានត្រឹមតែ ៨០ម៉ែត្រ និងជម្រៅទឹកពី ៤ទៅ ៥ម៉ែត្រប៉ុណ្ណេះ តើវា(អាចឆ្លើយតបបានតាម)តម្រូវការក្នុងការចល័តកងទ័ពតាមជើងទឹកឬទេ? ... ប្រសិនអស់លោកមានមេទ័ពបែបនេះ គឺកងទ័ពនោះនឹងបរាជ័យ ...៕

៨៩. ៨០គម នៃព្រែក ជាប្រឡាយលេខ១៥ កំពុងប្រើជាប្រព័ន្ធស្រោចស្រព និងដឹកជញ្ជូន

សារសម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា ស្តីពីគំរោងកសាង
ព្រែកជីកហ្វូណន-តេជោ, ១៦ ឧសភា ២០២៤

... ខ្ញុំព្រះករុណាខ្ញុំក៏គួរតែបញ្ជាក់ថា នៅក្នុង(ប្រវែងសរុប) ១៨០គីឡូម៉ែត្រនៃព្រែកជីក មាន ៨០គីឡូម៉ែត្រហើយ ដែលខ្ញុំព្រះករុណាខ្ញុំ បានដឹកនាំធ្វើក្នុងក្របខ័ណ្ឌ(នៃរាជរដ្ឋាភិបាលមុន)។ ឯកឧត្តម ប៉ុល សារឿន ដែលពេលនេះជាទីប្រឹក្សារាជរដ្ឋាភិបាល និងជាអភិបាលខេត្តតាកែវ(ជាអ្នកអនុវត្ត)។ **ប្រឡាយលេខ១៥ ប្រវែង ៨០គីឡូម៉ែត្រនេះ គឺខ្ញុំព្រះករុណាខ្ញុំបានដឹកនាំធ្វើ។ គឺប្រឡាយ ៨០គីឡូម៉ែត្រនោះហើយ ដែលបច្ចុប្បន្នកំពុងប្រើប្រាស់ជាប្រព័ន្ធស្រោចស្រពផង និងជាប្រព័ន្ធដឹកជញ្ជូនផង។ យើងគ្រាន់តែត្រូវពង្រីកវាតែប៉ុណ្ណោះ**។ វានឹងក្លាយទៅជាប្រព័ន្ធដឹកជញ្ជូនដ៏ល្អ ... កាលពីឆ្នាំ១៩៩៣ មានការយោសនាថា ប្រឡាយលេខ១៥ នឹងក្លាយជាព្រំដែនកម្ពុជាវៀតណាម ... នេះជា(ការថ្លែងនៃ)ជនជាតិខ្មែរដែលនិរទេសខ្លួនទៅក្រៅប្រទេស។ ខ្ញុំគ្រាន់តែសួរទៅអ្នកវិញថា បើព្រែកជីកនេះដីកួចហើយវាក្លាយទៅជាព្រំដែនវៀតណាមនិងកម្ពុជា ហេតុអីបានវៀតណាមចាំបាច់មានកង្វល់? ...៕

៩០. ថា "ព្រែកជីកហ្វូណនតេជោ" នឹងធ្វើឱ្យបាត់ទឹកពីទន្លេមេគង្គ៥០% ជាការមិនត្រឹមត្រូវ

សារសម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា ស្តីពីគំរោងកសាង
ព្រែកជីកហ្វូណន-តេជោ, ១៦ ឧសភា ២០២៤

... ថ្ងៃមុន ខ្ញុំព្រះករុណាខ្ញុំនិយាយ(ថា មានការលើកឡើងថានឹងបាត់ទឹកពីទន្លេមេគង្គ)ដល់ទៅ៧០%។ តែដល់មើលទិន្នន័យនៃការសិក្សា គេផ្សព្វផ្សាយពីវិទ្យាស្ថាន កាន់ចឺ គេថា(ការបាត់បង់មាន)៥០%។ ខ្ញុំបានចោទសួរត្រឡប់ទៅវិញ

ថា តើទឹកដែលបាត់៥0% នោះទៅណា? ខ្ញុំព្រះករុណាខ្ញុំទទួលយក(ការទទួលខុសត្រូវ) ប្រសិនបើកម្ពុជាខ្លួនឯងជីកព្រែកនេះ ដោយគ្មានទ្វារទឹក ហើយទុកឲ្យទន្លេមេគង្គក៏ហូរ ទន្លេបាសាក់ក៏ហូរ តាមព្រែកជីកហ្វូណានតេជោ ធ្លាក់ទៅសមុទ្រ ដែលវានឹងធ្វើឲ្យបាត់បង់ទឹក ដែលវាមិនមែនប៉ះពាល់ត្រឹមតែវៀតណាមឯណា វាប៉ះពាល់ដល់ទាំងកម្ពុជាខ្លួនឯង ប៉ះពាល់ដល់ទន្លេសាប ដល់ខេត្តកណ្តាល ខេត្តព្រៃវែងនៅជាប់នឹងព្រំដែនវៀតណាម។ ប៉ុន្តែ **កម្ពុជាមិនល្ងង់រហូតទាញទឹកប្រៃពីកែប យកមកទម្លាក់នៅកែប កំពត តាកែវ និងមកដល់ខេត្តកណ្តាលទេ ... ព្រោះវានាំគ្រោះថ្នាក់ដល់ប្រជាជនកម្ពុជា។ យើងត្រូវការទឹកសាប។ ដូច្នេះហើយយើងត្រូវមានសន្ទះទឹក។ នៅពេលខែប្រាំង យើងបិទទឹកសាបមិនឲ្យចូលទៅក្នុងសមុទ្រ ហើយមិនឲ្យទឹកសមុទ្រចូលមកក្នុងព្រែកទឹកសាបទេ។ ដូច្នេះ ការលើកឡើងថានឹងបាត់ទឹក៥0% គឺមិនត្រឹមត្រូវ** ...។

៩១. កត្តា៦ ធ្វើអោយការជីកទំនិញឆ្លងកាត់វៀតណាមបង្កការខាតបង់

សារសម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា ស្តីពីគំរោងកសាង
ព្រែកជីកហ្វូណាន-តេជោ, ១៦ ឧសភា ២0២៤

... (យើង)មិនអាចថាជាទន្លេរបស់កម្ពុជាទេ។ វាជាទន្លេអន្តរជាតិ។ ប៉ុន្តែវានៅក្នុងទឹកដីវៀតណាម។ អញ្ចឹង យើងត្រូវមានកិច្ចព្រមព្រៀង ដែលសព្វថ្ងៃកំពុងតែ(ស្ថិតក្នុង)នីតិវិធី។ **ទី១ បំពេញបែបបទស្នើសុំការអនុញ្ញាតឆ្លងកាត់ទំនិញ និងនាវាជាច្រើនដំណាក់កាល និងច្រើនប្រភេទ។ ទី២ តម្រូវឲ្យសុំការអនុញ្ញាតជាមុនពីអាជ្ញាធរវៀតណាមក្រុងហាណូយ ឬហូជីមិញ។ ទី៣ តម្រូវឲ្យមានការត្រួតពិនិត្យគ្រប់ប្រភេទកុងតឺន័រដែលឆ្លងកាត់។ ទី៤ តម្រូវឲ្យមានការលើកជាក់ច្រើនដង។ ទី៥ អនុវត្តនីតិវិធីស្មុគស្មាញ ប្រើប្រាស់ពេលវេលាយូរ និងចំណាយថវិកាច្រើន។ ទី៦ ករណីមានការរឹតបន្តឹងនីតិវិធីត្រួតពិនិត្យទំនិញឆ្លងកាត់ ក៏ត្រូវឆែកគ្រប់ទូរកុងតឺន័រពន្យារពេលធ្វើដំណើរពី១0ទៅ១៤ថ្ងៃ និងចំណាយថវិកាច្រើន** ... ពេលដែលទឹកនាច នាវាត្រូវរង់ចាំទឹកដោះទើបធ្វើដំណើរ។ ដូច្នេះវាត្រូវកកស្ទះទាំងនាវាវៀតណាមទាំងនាវាកម្ពុជា ...។

៩២. គួរធ្វើដំណើរដោយសុំច្បាប់/បែបបទរាល់ពេល ឬមិនបាច់សុំច្បាប់ក្នុងទឹកដីឯង

សារសម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា ស្តីពីគំរោងកសាង
ព្រែកជីកហ្វូណាន-តេជោ, ១៦ ឧសភា ២0២៤

... ប្រសិនបើយើងធ្វើរួចហើយ អនុវត្តនីតិវិធីថ្មី ការបំពេញបែបបទស្នើសុំការអនុញ្ញាតឆ្លងកាត់ និងនាវាតែមួយកន្លែងក្នុងទឹកដីកម្ពុជា ... ព្រោះ**តាមនីតិវិធីផ្ទៃក្នុងកម្ពុជា មិនមានការលើកជាក់ទំនិញច្រើនដង ហើយនាវាអាចធ្វើដំណើរបានទាំងថ្ងៃទាំងយប់ក្នុងទឹកដីរបស់យើង។ ឥឡូវ សូមអ្នកដែលប្រឆាំងនឹងគម្រោងនេះជ្រើសរើសទៅរវាងម្ខាងពេលធ្វើដំណើរត្រូវសុំច្បាប់ ធ្វើបែបបទនិងម្ខាងទៀតពេលធ្វើដំណើរមិនបាច់សុំច្បាប់ទេ ព្រោះជាទឹកដីខ្លួនឯង។ ម្ខាងត្រូវបង់លុយឲ្យគេដើម្បីបានឆ្លងកាត់និងម្ខាងទៀតមិនចាំបាច់បង់លុយទេ។** ការបង់ថ្លៃដឹកជញ្ជូនវាត្រូវតែធ្វើ ព្រោះត្រូវរកលុយជីកព្រែកហ្នឹង។ ត្រូវអស់ ១៧00 លានដុល្លារ។ ការធ្វើដំណើរវាត្រូវតែមានការបង់ថ្លៃដើម្បីរំលស់ថ្លៃវិនិយោគនឹងមកវិញ។ អញ្ចឹង អ្នកដែលប្រឆាំងនឹង(ការកសាង)ព្រែកជីកនេះ អ្នកឯងមានបំណងអីពិតប្រាកដ? អ្នកទាំងនោះជាជនជាតិខ្មែរផង។ បើជាជនបរទេស ខ្ញុំក៏មិនថា ...។

៩៣. ជាផលប្រយោជន៍សេដ្ឋកិច្ចនិងសង្គម តែក៏ឯការជ្យភាពលើការជីកជញ្ជូនផ្លូវទឹក

សារសម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា ស្តីពីគំរោងកសាង
ព្រែកជីកហ្វូណាន-តេជោ, ១៦ ឧសភា ២0២៤

... **រឿងអភិវឌ្ឍសេដ្ឋកិច្ច-សង្គម វាជាបញ្ហាមួយហើយ ដែលខ្ញុំបានលើកប្រៀបធៀប ប៉ុន្តែសូមប្រជាជនកម្ពុជាចាំឲ្យច្បាស់ សម្តីរបស់ហ៊ុន សែន ថ្ងៃនេះ គឺចង់ចង្អុលបង្ហាញឲ្យទៅឆ្ងាយជាងសេដ្ឋកិច្ចនិងសង្គម នោះគឺឯការជ្យភាពខាងនយោបាយលើបញ្ហាជីកជញ្ជូនផ្លូវទឹក។** ហេតុអីបានខ្ញុំនិយាយអញ្ចឹង? ចោទចេញជាសំណួរមួយកាលពីក្នុងទសវត្សរ៍៦0 ក្នុងពេលដែលវៀតណាមខាងត្បូងរបស់ធៀវ គី (Thiệu-Kỳ) Nguyễn Văn Thiệu, Ngô Đình Diệm ... មិនត្រូវរ៉ូវជាមួយកម្ពុជាដែលដឹកនាំដោយសម្តេចព្រះនរោត្តម សីហនុ តើយើងដឹកជញ្ជូនផ្លូវទឹកបានឬអត់? ចាំទេកន្លែងហ្នឹង? សូម្បីឥឡូវនេះ យើងមានកិច្ចព្រមព្រៀងដឹកជញ្ជូនផ្លូវទឹក ក៏យើងនៅតែពិបាកដែរ។ ទោះបីមេដឹកនាំវៀតណាមនិងខ្ញុំមានការស្រុះស្រួល

គ្នាយ៉ាងណាក៏ដោយ ក៏ប៉ុន្តែនៅពេលភ្នាក់ងារនៅខាងក្រោមអនុវត្តជ្រុល ក៏ធ្វើឲ្យយើងលំបាក។ ខ្ញុំនិយាយនេះ សូមបញ្ជាក់បញ្ញវន្តយើងខ្លះ មន្ត្រីយើងខ្លះ ឬក៏មតិសាធារណៈខ្លះលើកឡើងត្រឹមតែផលចំណេញខាងសេដ្ឋកិច្ចថា វៀតណាមខ្លាចខាតបង់សេដ្ឋកិច្ច។ ខ្ញុំគួរតែការពារវៀតណាមត្រង់ហ្នឹងបន្តិចចុះ។ វៀតណាមជាប្រទេសលូតលាស់ខាងសេដ្ឋកិច្ច។ មិនយូរប៉ុន្មានវៀតណាមក្លាយទៅជាប្រទេសក្នុងក្របខ័ណ្ឌប្រទេស២០ គេហៅថា G20។ ដូច្នេះ វៀតណាមមិនពឹងផ្អែកទៅលើចំណូលបានមកពីការដឹកជញ្ជូនរបស់កម្ពុជាទេ ...។

៩៤. ព្រែកជីកហ្វូណានតេជោ បង្ការវិបាកដឹកជញ្ជូនពីកត្តាធម្មជាតិ នីតិវិធីនិងទំនាក់ទំនង

សារសេម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា ស្តីពីគំរោងកសាង
ព្រែកជីកហ្វូណាន-តេជោ, ១៦ ឧសភា ២០២៤

... ពីមុនថាយើងអត់មានលទ្ធភាពធ្វើ **ចុះពេលនេះមានលទ្ធភាពធ្វើ ម៉េចក៏មិនធ្វើ? ខ្ញុំលើកឧទាហរណ៍ត្រង់ចំណុចតែមួយ។ ជម្រៅទឹកវាក់ខាងកាគីវៀតណាមវានាចត្រូវរង់ចាំពេលវេលាទឹកជោរដើម្បីធ្វើដំណើរ។ ការនេះធ្វើឲ្យកកស្ទះ និងខាតពេលវេលា។ ហ្នឹងរឿងឧបសគ្គខាងផ្នែកធម្មជាតិ។ ប៉ុន្តែ ខ្ញុំលើកបកត្រឡប់មកវិញ។ ខ្ញុំសូមបន់ស្រន់ថា កុំឲ្យមានរឿង(មិនចុះសំរុងគ្នា)កើតឡើងនៅថ្ងៃអនាគត។ តែបើនៅពេលណាមួយ ទំនាក់ទំនងរវាងប្រទេសទាំង២ មានបញ្ហា តើអ្នកឯងអាចដឹកជញ្ជូនចេញតាមវៀតណាមរួចទេ?** ... ថ្ងៃនេះវាអត់មានបញ្ហាទេ។ ប៉ុន្តែសម្លឹងមើលទៅ ៥០ឆ្នាំ ១០០ឆ្នាំទៀត ... ប្រទេសត្រូវតែមានសន្តិភាព មិត្តភាព សហប្រតិបត្តិការជាមួយគ្នា មិនអាចធ្វើជាសត្រូវជាមួយគ្នាទេ ប៉ុន្តែការប៉ះទង្គិចណាមួយ វាដូចអណ្តាតនិងធ្មេញអញ្ចឹង ... តើយើងកាត់អណ្តាតនិង/ឬវាយធ្មេញបំបាក់គ្រាត់ចោល ឬក៏ត្រូវសំរួលថាកុំឲ្យធ្មេញខាំអណ្តាតតទៅទៀត? ... ខ្ញុំចង្អុលបង្ហាញនេះគឺក្នុងគោលដៅរយៈពេលវែង ...។

៩៥. "ព្រែកជីកហ្វូណានតេជោ នឹងបន្តយឥទ្ធិពលវៀតណាមលើកម្ពុជា" ជាការពិត

សារសេម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា ស្តីពីគំរោងកសាង
ព្រែកជីកហ្វូណាន-តេជោ, ១៦ ឧសភា ២០២៤

... ខ្ញុំសូមអរគុណចំពោះអ្នកវិទ្យាសាស្ត្រវៀតណាម ដែលបានចេញមកអះអាងថា បើព្រែកជីកនេះដំណើរការ វា(នឹងអស់បរិមាណទឹកដែលហូរចូលសមុទ្រ)ចំនួនតូចណាស់ បើប្រៀបធៀបជាមួយនឹងទឹកទន្លេមេគង្គដែលកំពុងហូរ(សព្វថ្ងៃដោយធម្មជាតិ)។ ក្នុងករណីដែលការបង្កបង្កើនផលកើន ក៏វាមានចំនួនតូចដែរ បើប្រៀបធៀបជាមួយនឹងទន្លេមេគង្គដែលកំពុងហូរ។ វានឹងមិនបាត់ដល់ទៅ ៥០% ដូចដែលវិទ្យាស្ថាន កាន់ចឺ បានធ្វើការអះអាងទេ។ ខ្ញុំជំទាស់(ពីការគណនារបស់វិទ្យាស្ថាន កាន់ចឺ និង) ត្រូវតែជូនសារទៅប្រជាពលរដ្ឋ។ ពិតហើយ ខ្ញុំនៅមាន ១០ឆ្នាំ ២ដងកន្លះ ឬក៏ ៣ដងទៀត ក៏ប៉ុន្តែខ្ញុំត្រូវតែនិយាយពីពេលនេះដើម្បីជំរុញការអនុវត្តជាក់ស្តែងលើការ(កសាងហេដ្ឋារចនាសម្ព័ន្ធ) ដឹកជញ្ជូនផ្លូវទឹក។ សូមប្រជាពលរដ្ឋខ្មែរមើលឱ្យហួសពីព្រំដែននៃផលចំណេញខាងសេដ្ឋកិច្ច និងសង្គម ទៅជាផលចំណេញនៃឯករាជ្យខាងនយោបាយលើការដឹកជញ្ជូនផ្លូវទឹក។ **ជនបរទេសមួយចំនួនបានសរសេរ (ខ្ញុំគិតថាគេសរសេរត្រូវ) ថា បើកម្ពុជាដឹកបានព្រែកជីកនេះបាន ឥទ្ធិពលរបស់វៀតណាមមកលើកម្ពុជានឹងត្រូវបានកាត់បន្ថយ។ វាជារឿងពិត។ ខ្ញុំទទួលស្គាល់។ តែកាលណាយើងពឹងដង្ហើមគេ ពឹងផ្លូវរបស់គេ ជំពាក់ត្រូវតែសម្រុះសម្រួល។ គេទារថ្លៃ យើងឱ្យថ្លៃ។ ប៉ុន្តែ ក៏មិនដល់កម្រិតទាមទារមិនសមហេតុសមផលទេ។ ពេលខ្លះ យើងក៏ត្រូវតែយល់** ...។

៩៦. ដោយសារសន្តិភាពគ្មានស្តិរភាព សង្គ្រាមនិងប្រល័យពូជសាសន៍ ដីកព្រែកមិនបាន

សារសេម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា ស្តីពីគំរោងកសាង
ព្រែកជីកហ្វូណាន-តេជោ, ១៦ ឧសភា ២០២៤

... ខ្ញុំតែងនិយាយថា កុំពឹងលើអ៊ុកស៊ីសែនគេយកមកដាក់ឱ្យ។ គេចង់ឱ្យក៏ឱ្យ គេមិនចង់ឱ្យក៏ផ្តាច់។ ចុះពីមុនក៏មិនធ្វើ? ... ឆ្នាំ១៩៥៣ ក្នុងមួយពេលឯករាជ្យហ្នឹង បោះឆ្នោតឆ្នាំ១៩៥៥ រហូតដល់ឆ្នាំ១៩៧០។ **ថាយៈពេលពីឆ្នាំ ១៩៥៤ ទៅចុះមាន ១៦ឆ្នាំ។ តើមានអ្វីខ្លះពេលនោះ? លទ្ធភាពធ្វើបានប៉ុណ្ណឹង ជំនាន់សម្តេចឪ វាច្រើនណាស់ ទុកឱ្យកូនចៅជំនាន់ក្រោយបានទទួលផលពីសន្តិភាព តែខ្វះស្ថិរភាព ... ដោយសារវាមានពួកក្រហម ពួកខៀវ ពួកស ធ្វើបាបព្រះអង្គ។ ខ្មែរក្រហមនៅពេញព្រៃ។ ពួកខ្មែរខៀវនៅតាមព្រំដែនជាមួយថៃ។ ពួកខ្មែរសនៅតាមព្រំដែនជាមួយវៀតណាម ... កម្ពុជាធ្លាក់ក្នុងសង្គ្រាមហែកហួរឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥**

ក្រោយរដ្ឋប្រហារ។ បន្ទាប់ទៅយើងធ្លាក់ទៅក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ទម្រាំតែរើបម្រាស្លចពីរបបប្រល័យពូជសាសន៍ ត្រូវប្រើពេលប៉ុន្មានទៀត? សុំមើលរូបភាពពីអតីតកាលឆ្នាំ១៩៧៩ យើងមានអីខ្លះ? តើត្រូវការជីកព្រែក ឬត្រូវការរកបាយឱ្យប្រជាជនស៊ី? ...។

២៧. សុខាតច្ចាល

១	ក្រមសីលធម៌ សម្ភារៈឧបទេសក៍ នាំដល់ប្រសិទ្ធភាពជួយជីវិតមនុស្ស	៥៨៣
២	បច្ចេកវិទ្យាកាន់តែទំនើប កាន់តែខិតខំបង្កើនសមត្ថភាព	៥៨៣
៣	ពេទ្យនិងគ្រូបង្រៀន ជាវិស័យជន្ទល់សំរាប់ការអភិវឌ្ឍមនុស្ស	៥៨៣
៤	សម្បត្តិធនធានមនុស្សដ៏មានតម្លៃសម្រាប់កម្ពុជា គឺសុខភាព និងការអប់រំល្អ	៥៨៤
៥	គណបក្សប្រជាជន ផ្តោតការយកចិត្តទុកដាក់លើសុខុមាលភាពជាចម្បង	៥៨៤
៦	គ្រូពេទ្យ៧0% បម្រើប្រជាជន៣0% នៅទីប្រជុំជន និងបញ្ហាសមកវិញនៅជនបទ	៥៨៤
៧	ចំណាយលើមនុស្សមានទំហំ ៣ដង នៃថវិការការពារនិងសន្តិសុខជាតិ	៥៨៥
៨	ភូមិសាស្ត្រសុខាភិបាល មិនខុសគ្នានឹងភូមិសាស្ត្រវិស័យអប់រំ	៥៨៥
៩	កុំឱ្យ៧៣% នៃបុគ្គលិកសុខាភិបាលផ្តុំនៅតែក្របខណ្ឌខេត្ត មិនទៅស្រុក/ឃុំ	៥៨៦
១0	ការបែងចែកពេទ្យត្រូវទៅជាមួយនឹងការវិនិយោគជាក្របខណ្ឌមន្ទីរពេទ្យ	៥៨៦
១១	មោទនភាពដោយបានភ្ជាប់ខ្លួនជាមួយវិស័យសុខាភិបាលតាំងពីចាប់ផ្តើមដំបូង	៥៨៧
១២	ប្រលងចូលសាលាពេទ្យ មិនកំណត់និទ្ទេស តែមិនបន្ទូរបន្តុយវិញ្ញាសា	៥៨៧
១៣	ការពិនិត្យសុខភាពជាឧបសគ្គដល់អ្នកប្រឡងចូលក្របខណ្ឌ បង្កើតអំពើពុករលួយ	៥៨៧
១៤	ទទួលបានការបណ្តុះបណ្តាលនៅក្រៅប្រទេស ជួយចែករំលែកដល់អ្នកក្នុងប្រទេស	៥៨៨
១៥	អតីតកាលដ៏ឈឺចាប់ នាំឱ្យផ្តើមគំនិតបង្កើតសមាគមគ្រូពេទ្យស្ម័គ្រចិត្តគេជោ	៥៨៨
១៦	ក្រុមគ្រូពេទ្យនៃថ្នាក់ដឹកនាំគណបក្សប្រជាជនចុះជួយប្រជាជនតាមមូលដ្ឋាន	៥៨៩
១៧	មោទនភាពចំពោះ យុវគ្រូពេទ្យស្ម័គ្រចិត្ត រួមដំណើរជាមួយ TYDA	៥៨៩
១៨	មិនត្រូវមានពេទ្យនៅក្រៅបញ្ជីក្របខណ្ឌ ដែលច្បាប់ទទួលស្គាល់ទេ	៥៩0
១៩	រៀននៅសាលាឯកជនក្តីឬសាលារដ្ឋក្តី ត្រូវខិតខំឱ្យទៅជាប្រព័ន្ធឯកភាពមួយ	៥៩0
២0	ខេត្តក្បែងឃ្លុំនឹងទទួលបានសាកលវិទ្យាល័យមួយនិងមន្ទីរពេទ្យមួយ	៥៩១
២១	ក្នុងវិស័យសុខាភិបាល ចេះដឹងមិនគ្រប់គ្រាន់ ព្យាបាលមិនបានទេ	៥៩១
២២	ព្យាបាលជំងឺមិនប្រកាន់បក្ខពួក ធើសអើងសញ្ជាតិ សាសនា ពណ៌សម្បុរនយោបាយ	៥៩២
២៣	ចូលរួមសន្ទិបាតសុខាភិបាល ៣៨/៣៩លើក តាមមើលការវិវឌ្ឍរៀបចំធនធានមនុស្ស	៥៩២
២៤	ឲ្យអាទិភាពអ្នកមានវិជ្ជាពេទ្យនៅខេត្ត និងស្ម័គ្រចិត្តទៅខេត្តនោះវិញ	៥៩២
២៥	បើផ្ទេរទៅកងទ័ព គ្រូពេទ្យស៊ីវិលត្រូវចេះក្បួនសង្គ្រោះលើសមរភូមិ	៥៩៣

២៦	ពីរឯការបន្ទុះបង្គាប់ ក្លាយជានិមិត្តរូបនៃវីរភាព ឬកងទ័ពអាវុស	៥៩៤
២៧	ជ្រើសរើសគ្រូពេទ្យ ៤២០០នាក់ បង្កើនកម្លាំងទ្រទ្រង់ប្រយុទ្ធនឹងកូវីដ១៩	៥៩៤
២៨	ការពិគ្រោះជំងឺអាចធ្វើតាមមធ្យោបាយទំនាក់ទំនងឌីជីថល	៥៩៤
២៩	ការពារប្រសើរជាងព្យាបាល បើចេះការពារខ្លួន កាត់បន្ថយបានការឈឺថ្កាត់	៥៩៥
៣០	មន្ទីរពេទ្យទាំងរដ្ឋ/ជន កុំដណ្តើមអ្នកជំងឺគ្នា និងទទួលខុសត្រូវពីដើមដល់ចប់	៥៩៥
៣១	មន្ទីរពេទ្យទាំងរដ្ឋទាំងឯកជន ធ្វើសកម្មភាពឱ្យស្របនឹងសីលធម៌សង្គ្រោះជីវិត	៥៩៦
៣២	គោរពគុណធម៌ "គ្រូពេទ្យកោសខ្យល់" កុំឃើញប្រាក់ថ្លៃជាងការសង្គ្រោះជីវិត	៥៩៦
៣៣	មន្ទីរពេទ្យត្រូវធានានិរន្តរភាព អភិវឌ្ឍនិងបំពាក់សម្ភារបច្ចេកវិទ្យាទាន់សម័យ	៥៩៧
៣៤	រៀបចំមន្ទីរពេទ្យឱ្យមានកន្លែងឯកទេសព្យាបាលកីឡាករ/ការិនី	៥៩៧
៣៥	យកចិត្តទុកដាក់លើការរស់នៅរបស់គ្រូពេទ្យ ដូចជាការរស់នៅរបស់គ្រូបង្រៀន	៥៩៨
៣៦	៩២% នៃមណ្ឌលសុខភាពមានអគ្គិសនីប្រើប្រាស់	៥៩៨
៣៧	កង្វះកិច្ចសហការរវាងក្របខណ្ឌ រវាងអាជ្ញាធរខ្លួនឯងលើបញ្ហាឱសថក្លែងក្លាយ	៥៩៨
៣៨	គណៈកម្មាធិការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ ... មានសមាជិកពី ១៤ស្ថាប័ន	៥៩៩
៣៩	គួរជំរុញគំនិតផ្តួចផ្តើមភ្នំពេញស្តីពី "ឱសថក្លែងក្លាយនិងអន់គុណភាព"	៦០០
៤០	យកប្រធានបទឱសថក្លែងក្លាយដាក់ក្នុងប្រជុំអាស៊ីអឺរ៉ុប ហ្វ្រង់កូហ្វួន ឬ ICAPP	៦០០
៤១	ស្នើប្រធានាធិបតីបារាំងចាប់អារម្មណ៍វិធានការពាក់ព័ន្ធសុខភាពសាធារណៈ	៦០១
៤២	"គ្រូពេទ្យ São Tomé and Príncipe កំពុងរៀននៅកម្ពុជា"	៦០១
៤៣	ពេទ្យស្ម័គ្រចិត្ត ៤២២ថែមលើ ២ពាន់នាក់ ពេទ្យទាហាន នគរបាលប្រយុទ្ធនឹងកូវីដ-១៩	៦០២
៤៤	ខ្សោយតែវិធានការហ្មត់ចត់, ខ្លាំងតែមើលស្រាលសភាពការណ៍និងឆ្លើយតបយឺត	៦០២
៤៥	ប្រើពេទ្យ ៤ប្រភេទ, ដើរដល់ណាគ្រប់គ្រងដល់នោះ និងគ្រប់គ្រងមួយជំហានមុន	៦០៣
៤៦	វ៉ាក់សាំងជាយុទ្ធសាស្ត្រគន្លឹះ វិធានការ ៣ការពារ ៣កុំ ជាអន្តរកាលរយៈពេលវែង	៦០៣
៤៧	ត្រូវការជំនួយវ៉ាក់សាំងពីគ្រប់ប្រទេស ឲ្យតែសមស្របនឹងស្ថានភាពកម្ពុជា	៦០៤
៤៨	ទទួលស្គាល់សិទ្ធិទាំងអស់ តែផ្តល់អាទិភាពមុនគេដល់សិទ្ធិរស់នានមានជីវិត	៦០៤
៤៩	យុទ្ធសាស្ត្រ៣ ស្វែងរក និងចាក់វ៉ាក់សាំងទប់ទល់កូវីដ១៩	៦០៥
៥០	ផ្តល់មធ្យោបាយធ្វើតេស្តហ័សគ្រប់ច្រកព្រំដែន	៦០៥
៥១	សង្គ្រាមជាមួយ កូវីដ-១៩ មានតែចាញ់ច្រើនឬតិច គ្មានទេពាក្យថាឈ្នះ	៦០៥
៥២	សហប្រតិបត្តិការជាមួយគ្រប់ដៃគូ ជានយោបាយការបរទេសចំរុះពណ៌របស់កម្ពុជា	៦០៦
៥៣	កត្តា៥ ជំរុញល្បឿនចាក់វ៉ាក់សាំង	៦០៦
៥៤	ផលប្រយោជន៍៤ នៃការចាក់វ៉ាក់សាំងដល់ក្មេងជំទង់វ័យ១២ ដល់ក្រោម ១៨ឆ្នាំ	៦០៧
៥៥	ប្រភពចំណូល៥ ជួយទ្រទ្រង់ការចំណាយក្នុងបរិបទកូវីដ១៩	៦០៧
៥៦	យុទ្ធសាស្ត្រ ៦ ក្នុងយុទ្ធនាការចាក់វ៉ាក់សាំង	៦០៨
៥៧	ឆ្លងដំណាក់កាល៤ ទប់ស្កាត់ គ្រប់គ្រងការឆ្លង បង្កើតភាពស៊ាំ ដំណើរការតាមគន្លងថ្មី	៦០៩
៥៨	យុទ្ធសាស្ត្រជាតិរស់នៅ តាមគន្លងថ្មីក្នុងបរិបទកូវីដ-១៩ ស្របតាមអភិក្រម៣	៦០៩
៥៩	វៀតណាម/ថៃមានចំនួនស្លាប់ច្រើនជាងយើង តែប្រជាជនប្រទេសទាំងពីរច្រើន	៦១០
៦០	យកចិនជាបង្អែកប្រកពាក់សាំង ក្រៅពីនោះជាប្រភពគាំទ្រ	៦១០
៦១	ចាក់វ៉ាក់សាំង តាមអភិក្រម "ផ្កាវីក"	៦១១
៦២	ទិញផ្គាល់ ២៨លានដូស ក្នុងចំនួនវ៉ាក់សាំងសន្យា ៣៨.៧២៩.៩០០ដូស	៦១១
៦៣	មិនទុកឲ្យអ្នកជំងឺកូវីដ១៩ មកដល់ពេទ្យរកបាយទទួលទានមិនបានទេ	៦១២
៦៤	ជាប្រទេសក្រីក្រ តែកម្ពុជារកបានវ៉ាក់សាំងគ្របដណ្តប់៨៥%	៦១២
៦៥	កម្ពុជាឈរទី១ នៅអាស៊ី និងទី៥ លើពិភពលោក ដែលចាក់វ៉ាក់សាំងបានច្រើន	៦១៣
៦៦	រាជរដ្ឋាភិបាលទទួលធ្វើតេស្តជូន, ប្រជាពលរដ្ឋម្ចាស់ការរកការធ្វើតេស្ត	៦១៣
៦៧	ចលនាជាតិ ជួយរាជរដ្ឋាភិបាល ដោះស្រាយ កូវីដ-១៩	៦១៣
៦៨	វ៉ាក់សាំង ពិតជាបានជួយជីវិតមនុស្ស	៦១៤
៦៩	សូមមិត្តចិនចែករំលែកការផលិតវ៉ាក់សាំង Sinovac ជាផលិតផលសំរេច	៦១៥
៧០	ផ្ទេរចំណែកវ៉ាក់សាំងរបស់កម្ពុជាក្នុងមូលនិធិអាស៊ាន ជូនទៅប្រជាជនមីយ៉ាន់ម៉ា	៦១៥
៧១	វ៉ាក់សាំងកាតព្វកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ និងអាស៊ាន	៦១៦
៧២	ចាក់វ៉ាក់សាំងដោយមិនគិតប្រាក់ដល់ជនបរទេសនៅស្រុកខ្មែរ	៦១៦
៧៣	សូមអ្នកលក់ថ្នាំព្យាបាលកូវីដ១៩ កុំដំឡើងថ្លៃ និងកុំក្លែងក្លាយ	៦១៧
៧៤	ព្យាបាល/ចិញ្ចឹមអ្នកជំងឺនៅមណ្ឌលចត្តាឡីស័ក ឧបត្ថម្ភអ្នកក្រីក្រងាយរងគ្រោះ	៦១៧
៧៥	គ្រោកូវីដ១៩ វិស័យសុខាភិបាលប្រយុទ្ធនឹងមុខព្រួញ៣ ក្នុងពេលតែមួយ	៦១៨
៧៦	បានចាក់វ៉ាក់សាំងជាង៩២% នៃចំនួនត្រូវចាក់ ១៤,៨ ក្នុងចំណោម ១៦លាននាក់	៦១៨
៧៧	មេបញ្ជាការក្នុងការប្រយុទ្ធជាមួយកូវីដ-១៩ មិនបំភ័យកូនទាហានខ្លួនទេ	៦១៩
៧៨	ទើបតែឈ្នះសមរភូមិ Delta, Alpha, Omicron ប៉ុន្តែមិនទាន់ឈ្នះកូវីដ-១៩	៦១៩
៧៩	មិនមានអ្នកជំងឺកូវីដ-១៩ ដេកតាមចិញ្ចើមផ្លូវ ឬសពបូជាដោយគ្មានមឈូស	៦២០

៨០	ក្រសួងសុខាភិបាលរួមទាំងកងទ័ព ជួយបង្កើតកន្លែងផលិតអុកស៊ីសែន	៦២០
៨១	ឆ្លងវាលសង្គ្រាម និងវាលឧស្ម័ក្រញ្ជួចហើយ កំពុងឆ្លងវាលទីបីគឺជំងឺដង្កាត់	៦២១
៨២	បើផ្ទេរលុយផលិតអាវុធ មកផលិតថ្នាំ/ឧបករណ៍ពេទ្យ ប្រជាជននឹងបានផលធំ	៦២១
៨៣	ទប់ទល់ជំងឺកូវីដ១៩ គ្រោះមហន្តរាយ ផលនៃកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការ	៦២២
៨៤	គ្រប់គ្រងកូវីដ១៩ កែទំរង់វិស័យសុខាភិបាល ផ្ទេរអំណាច ថវិកានិងមន្ត្រីទៅមូលដ្ឋាន	៦២២
៨៥	អាហារូបត្ថម្ភ/កុមារលូតលាស់ប្រសើរ បន្ថយអត្រាមរណភាពនៃមាតានិងទារក	៦២៣
៨៦	គោលនយោបាយគាំពារសង្គមជាអម្រែកនៃលោកគ្រូពេទ្យ/មន្ទីពេទ្យរដ្ឋ	៦២៣

១. ក្រមសីលធម៌ សម្ភារៈឧបទេសក៍ នាំដល់ប្រសិទ្ធភាពជួយជីវិតមនុស្ស

សម្ពោធអគារ «អគារតេជោសន្តិភាព» នៅមន្ទីរពេទ្យកាល់ម៉ែត,
១៥ មករា ២០១៨

... ធនធានមនុស្សដែលនៅសេសសល់បន្តិចបន្តួចកាលពីពេលមុនហើយក្លាយជាគ្រូ ក្រោយមកនេះ ក៏មានវ័យចំណាស់ហើយ។ **សង្ឃឹមថា ក្មួយៗនឹងបន្តក្លាយទៅជា គ្រូពេទ្យ ដែលជួយទៅដល់ជីវិតមនុស្ស។ រឿងធំជាងនេះទៅទៀត បើគ្រាន់តែមានសម្ភារៈល្អ ប៉ុន្តែខ្វះក្រមសីលធម៌វិជ្ជាជីវៈគ្រូពេទ្យ វាពិតជាមិនអាចនាំមកនូវប្រសិទ្ធភាពបានទេ។ ការយកចិត្តទុកដាក់ទៅលើជីវិតអ្នកជំងឺ ទៅលើសុខទុក្ខអ្នកជំងឺជារឿងចាំបាច់ ... ដូចនេះ សូមអំពាវនាវគ្រូពេទ្យបង្កើននូវស្មារតីទទួលខុសត្រូវ និងលើកកម្ពស់សីលធម៌វិជ្ជាជីវៈ ... ។**

២. បច្ចេកវិទ្យាកាន់តែទំនើប កាន់តែខិតខំបង្កើនសមត្ថភាព

សម្ពោធអគារ «អគារតេជោសន្តិភាព» នៅមន្ទីរពេទ្យកាល់ម៉ែត,
១៥ មករា ២០១៨

.. សូមអរគុណចំពោះការផ្តល់ជំនួយនៃសមាគមផ្នែកនុយក្លេអ៊ែ ... យើងបានឈានដល់ដំណាក់កាលនេះ ប៉ុន្តែក៏សូមកុំភ្លេចថា **បច្ចេកវិទ្យាកាន់តែលឿន តម្រូវឲ្យយើងពង្រឹងសមត្ថភាពកាន់តែប្រសើរ។ ឧបករណ៍ដែលទំនើបមានហើយ ប៉ុន្តែបើយើងមិនចេះប្រើប្រាស់ឧបករណ៍នោះ វាក៏មិនបានដែរ។ សង្ឃឹមថា គ្រូពេទ្យរបស់យើងនឹងខិតខំបង្កើនសមត្ថភាព ដើម្បីប្រើប្រាស់ឧបករណ៍ដែលមានតម្លៃនេះជួយសង្គ្រោះជីវិតប្រជាជនយើង។** ត្រូវធ្វើការបណ្តុះបណ្តាលទាំងជំនាញជាក់ស្តែងដែលយើងមាន ក្នុងដួរគ្រូពេទ្យថ្មី ...។

៣. ពេទ្យនិងគ្រូបង្រៀន ជាវិស័យជន្ទល់សំរាប់ការអភិវឌ្ឍមនុស្ស

ពិធីសម្ពោធអគារថ្មីនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត, ៤ មករា ២០១៨

... **យើងបានបង្កើនបៀវត្សរ៍ក្នុងក្របខណ្ឌមន្ត្រីពេទ្យដែរ។ ប្រាក់បៀវត្សរ៍ក្របខណ្ឌមន្ត្រីពេទ្យនិងក្របខណ្ឌគ្រូបង្រៀនខ្ពស់ជាងគេ។ (ការអនុវត្តបែបនេះគឺ) ក្នុងគោលដៅយកផ្នែកគ្រូបង្រៀននិងពេទ្យនេះ ជាវិស័យជន្ទល់ជំរុញ(ការវិនិយោគមើលថែមូលធន)មនុស្ស** ... បើមានតែមន្ទីរពេទ្យល្អ មានតែឧបករណ៍ល្អ ទទួល

បានការបណ្តុះបណ្តាលល្អក៏ដោយចុះ បើយើងខ្វះស្មារតីទទួលខុសត្រូវការក្នុងព្យាបាលជំងឺ រឿងវានៅតែដដែល ... ខ្ញុំអំពាវនាវមន្ត្រីសុខាភិបាល ឬមន្ត្រីគ្រប់ផ្នែកខិតខំស្រាវជ្រាវ និងយកចិត្តទុកដាក់បង្កើននូវចំណេះដឹង ...៕

៤. សម្បត្តិធនធានមនុស្សដ៏មានតម្លៃសម្រាប់កម្ពុជា គឺសុខភាព និងការអប់រំល្អ

ពិធីសម្ពោធអគារថ្មីនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត, ៤ មករា ២០១៨

... **អ្វីដែលយើងយកចិត្តទុកដាក់ធ្វើរួមគ្នា និងបង្កើតជាសមិទ្ធផលសម្បត្តិធនធានមនុស្សដ៏មានតម្លៃសម្រាប់កម្ពុជា គឺសុខភាពនិងការអប់រំល្អ** ... មានកម្មវិធីច្រើនណាស់ កិច្ចការច្រើនណាស់ ដែលយើងត្រូវចាត់ជាបញ្ហាប្រឈម។ ខ្ញុំទទួលយកការទិតៀនស្តាបនា ប៉ុន្តែខ្ញុំមិនអាចទទួលយកបានដែរនូវការទិតៀនបែបជាន់ពន្លិច មាក់ងាយចំពោះគ្រូពេទ្យរបស់យើងថា ៩០ភាគរយអាក្រក់ និងមានតែ ១០ ភាគរយល្អ(នោះទេ) ... សូមអំពាវនាវឲ្យព្យាយាមចៀសវាងការបង្កើតឡើងនូវស្ថានភាពជាជំងឺដង្កាត់ ឬការគ្រោះថ្នាក់ផ្សេងៗ បណ្តាលពីការទទួលទានខ្វះអនាម័យ ការធ្វើដំណើរមិនគោរពច្បាប់ ក៏ដូចជាការខ្វះសុវត្ថិភាពឯទៀត ...៕

៥. គណបក្សប្រជាជន ផ្តោតការយកចិត្តទុកដាក់លើសុខុមាលភាពជាចម្បង

ពិធីសម្ពោធអគារថ្មីនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត, ៤ មករា ២០១៨

... ក្នុងសន្និបាតលើកទី១ (នៃការងារសុខាភិបាល) យើងបានធ្វើនៅឯសាលាពេទ្យ។ **ថ្ងៃនោះជាថ្ងៃដែលយើងបើក(អោយដំណើរការ)សាលាពេទ្យជាលើកដំបូង។ សាកលវិទ្យាល័យ/ឧត្តមសិក្សាដែលបើកដំបូងគេគឺសាលាពេទ្យនេះឯង។ នេះបញ្ជាក់បានថា គណបក្សប្រជាជនកម្ពុជា បានផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាសុខុមាលភាពជាចម្បងរួចស្រេច** ... តាមខ្ញុំចាំ យើងបានបិទសន្និបាតក្នុងពេលល្ងាច។ ពេលនោះ ឯកឧត្តម នូ បេង ជារដ្ឋមន្ត្រី។ ឯកឧត្តម យិត គឹមសេង, ឯកឧត្តម នុត សារឿន ជាឧបការីទេ។ បង យិត គឹមសេង ជាអនុរដ្ឋមន្ត្រីសុខាភិបាល, លោកជំទាវ ជំយ កញ្ញា ជាអនុរដ្ឋមន្ត្រី ...៕

៦. គ្រូពេទ្យ៧០% បម្រើប្រជាជន៣០% នៅទីប្រជុំជន និងបញ្ច្រាសមកវិញនៅជនបទ

សំណេះសំណាលជាមួយសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ, ២ មីនា ២០១៨

... ក្នុងរង្វង់ឆ្នាំ ១៩៩៥/១៩៩៦ ខ្ញុំបានឲ្យសាកល្បងសិក្សាពីការបែងចែកធនធានមនុស្ស ... **គ្រូពេទ្យ៧០% បម្រើប្រជាជន៣០% នៅទីប្រជុំជន និងនៅទីក្រុង ឯគ្រូពេទ្យ៣០% ទៀត បម្រើប្រជាជន៧០% នៅជនបទទៅវិញ។ (មានកត្តា)ភ័យខ្លាចសម្រាប់គ្រូពេទ្យយើងដែរ។** សម័យកាលនោះ មិនទាន់ចប់សង្គ្រាមទេ។ មិនមែនគ្រាន់តែគ្រូពេទ្យខាងយោធាទេ **គ្រូពេទ្យស៊ីវិលក៏ត្រូវបានបញ្ជូនទៅចូលរួមព្យាបាលរបួសសម្រាប់កងទ័ព និងប្រជាជននៅឯសមរភូមិមុខ។ ខ្ញុំនៅចាំបានថាចំពោះគ្រូពេទ្យដែលចេញពីទីក្រុងភ្នំពេញ ... ខ្មែរក្រហមបាញ់ប្លោងឯជិតម៉ាខ្សែឯណោះ គាត់ក្រាបនៅឯស៊ីសុផុន ...៕**

៧. ចំណាយលើមនុស្សមានទំហំ ៣ដង នៃថវិកាការពារនិងសន្តិសុខជាតិ

សំណេះសំណាលជាមួយសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ, ២ មីនា ២០១៨

... រឿងវ៉ាវទាំងអស់នេះ ធ្វើអោយការអនុវត្តក្នុងវិស័យសុខាភិបាល នាដំណាក់កាលនោះមានកម្រិត។ កង្វះធនធានមនុស្ស សម្ភារៈបច្ចេកទេស ថ្នាំពេទ្យ(កើតមាន)ក្នុងពេលដែលយើងមានតម្រូវការចំណាយលើវិស័យការពារជាតិ និងសន្តិសុខធំជាង។ ការចំណាយលើវិស័យសុខាភិបាលមានកម្រិតខ្លាំងណាស់។ ប៉ុន្តែ ឥឡូវនេះ **បើគិតអំពីចំណាយដោយយកគោលដៅមនុស្សធ្វើជាស្នូល យើងបានប្រើប្រាស់ធនធានថវិកាធំជាង៣វិស័យការពារជាតិ និងសន្តិសុខរហូតទៅដល់ ៣ដង ឯណោះ** ... ដោយឡែកតែផ្នែកអប់រំស្ទើរតែ ១៣ន់លានដុល្លារ ...៕

៨. ភូមិសាស្ត្រសុខាភិបាល មិនខុសគ្នានឹងភូមិសាស្ត្រវិស័យអប់រំ

បិទសន្និបាតសុខាភិបាលលើកទី៤០, ១២ មីនា ២០១៩

... ពេលដែលយើងបានចុះវាស់វែងដីធ្លីជូនប្រជាជននៅឆ្នាំ២០១២ យើងបានមើលឃើញអំពីបញ្ហាប្រឈមនានា ដែលប្រជាពលរដ្ឋ(កំពុងជួបប្រទះក្នុងការ)ទៅតាំងទីលំនៅថ្មី(លើដីធ្លី)យើងបានផ្តល់ឲ្យពួកគាត់។ ក្នុងចំណោមបញ្ហាទាំង ៤ ដែលត្រូវដោះស្រាយជូននោះ មានមួយពាក់ព័ន្ធនឹងសុខាភិបាល។ **ការប្រឈម ៤នោះរួមមានផ្លូវថ្នល់តភ្ជាប់ចូលទៅភូមិរបស់គាត់ ... ទឹក អប់រំ និងសុខាភិបាល។ យើងមិនអាចពង្រាយ(សេវាទាំងនេះ)ទៅតាមភូមិនីមួយៗ ទាំងអស់ទេ ក៏ប៉ុន្តែ**

ត្រូវពិនិត្យឡើងវិញភូមិសាស្ត្រវិស័យសុខាភិបាល ដែលវាមិនខុសគ្នានឹងភូមិសាស្ត្រវិស័យអប់រំទេ។ យើងបាននិយាយពីភូមិសាស្ត្រវិស័យអប់រំថាត្រូវកំណត់កន្លែងដាក់បឋមសិក្សា កន្លែងដាក់អនុវិទ្យាល័យ និងកន្លែងដាក់ជាវិទ្យាល័យ។ ករណីដូចគ្នានេះ ត្រូវពិនិត្យមើលអំពីការរៀបចំជាបណ្តាញសុខាភិបាលដែលអាចគ្របដណ្តប់ភូមិសាស្ត្រជួយដល់ប្រជាជន ...៕

៩. កុំឱ្យ៧៣% នៃបុគ្គលិកសុខាភិបាលប្រមូលផ្តុំនៅតែក្របខណ្ឌខេត្ត មិនទៅស្រុក/ឃុំ

ពិធីបិទសន្និបាតក្រសួងសុខាភិបាលលើកទី៣៩, ២៧ មីនា ២០១៨

...ខ្ញុំក៏បាននិយាយនៅក្នុងសន្និបាត(សុខាភិបាល)**អំពីការសិក្សាដែលបានធ្វើប្រហែលជាជិតប្រមាណ ២០ឆ្នាំមុន ស្តីពីការគ្រប់គ្រង និងការបែងចែងធនធានមនុស្ស ...** ក្នុងនោះមាននិយាយត្រឹមពី**បុគ្គលិកសុខាភិបាលបម្រើការងារនៅថ្នាក់ខេត្តចំនួន ១៨.៥៨៤នាក់ ឬស្មើនឹង៧២,៩៩% នៃបុគ្គលិកសុខាភិបាលសរុបនៅឆ្នាំ២០១៧ ... និយាយលេខគត់, ក្រែងលោ ៧៣% ជាទំហំប្រមូលផ្តុំនៅក្របខណ្ឌខេត្ត ដែលមិនបានពង្រាយចុះទៅតាមបណ្តាមន្ទីរពេទ្យនៅតាមស្រុកតាមឃុំ ... ខ្ញុំស្នើឲ្យយកចិត្តទុកដាក់លើការបែងចែកគ្រូពេទ្យ ដើម្បីបំរើឲ្យសេចក្តីត្រូវការរបស់ប្រជាជននៅឯជនបទ ...**៕

១០. ការបែងចែកពេទ្យត្រូវទៅជាមួយនឹងការវិនិយោគជាក្របខណ្ឌមន្ទីរពេទ្យ

ពិធីបិទសន្និបាតសុខាភិបាលប្រចាំឆ្នាំលើកទី៣៩, ២៧ មីនា ២០១៨

... យើងមិនអាចបែងចែកគ្រូពេទ្យ ដោយខ្វះឧបករណ៍ សម្ភារៈ និងថ្នាំពេទ្យទៅជាមួយទេ។ យើងត្រូវបែងចែកគ្រូពេទ្យ កាលណាមានមន្ទីរពេទ្យ។ បើអត់មានមន្ទីរពេទ្យ ហើយយើងបែងចែកពេទ្យទៅ ក៏វាអត់បានការអីដែរ។ **ការបែងចែកពេទ្យត្រូវទៅជាមួយការវិនិយោគជាក្របខណ្ឌមន្ទីរពេទ្យ ការបំពាក់ជាឧបករណ៍នានា ឲ្យស្របជាមួយបច្ចេកទេសនៃគ្រូពេទ្យដែលបានរៀនសូត្រនេះផងដែរ។** ឧទាហរណ៍ មន្ទីរពេទ្យហ្នឹងមិនមានកន្លែងវះកាត់ទេ ក៏ប៉ុន្តែយើងយកគ្រូពេទ្យវះកាត់ទៅដាក់នៅទីនោះ ... ដូច្នេះ ត្រូវយកចិត្តទុកដាក់បន្ថែមទៀតលើការបែងចែក(អ្នកជំនាញឯកទេស) ...៕

១១. មោទនភាពដោយបានភ្ជាប់ខ្លួនជាមួយវិស័យសុខាភិបាលតាំងពីចាប់ផ្តើមដំបូង

ប្រគល់សញ្ញាបត្រដល់និស្សិត សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល, ១៦ ធ្នូ ២០១៩

... គឺជាមោទនភាព ដោយបានភ្ជាប់ខ្លួនជាមួយសាកលវិទ្យាល័យ(វិទ្យាសាស្ត្រសុខាភិបាល) តាំងពីចាប់ផ្តើមដំបូង។ ពេលនោះមានរដ្ឋមន្ត្រីមានស្តីហើយ ក៏ប៉ុន្តែ ទោះបីជារដ្ឋមន្ត្រីក្រសួងការបរទេសនៅឡើយក្តី ខ្ញុំក៏នៅក្នុងគណអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា គឺជារដ្ឋាភិបាលជំនាន់នោះ ហើយក៏ត្រូវបានឯកឧត្តម នូ បេ ជារដ្ឋមន្ត្រី អញ្ជើញឱ្យទៅចូលរួមបិទសន្និបាត និងបើក(អោយដំណើរការ)សាលាពេទ្យឡើងវិញ។ ជារៀងរាល់ឆ្នាំ **លើកលែងតែឆ្នាំទៅទេដែលខ្ញុំបានអាក់ខាន ខ្ញុំតែងបានភ្ជាប់ខ្លួនជាមួយវិស័យសុខាភិបាលនេះ (ដោយចូលរួមក្នុង)សន្និបាតសុខាភិបាល។ ជាទូទៅយើងបានធ្វើកំណែទម្រង់ និងជំរុញវឌ្ឍនភាព ទាក់ទិននឹងការបណ្តុះបណ្តាលធនធានមនុស្ស ក្នុងវិស័យវេជ្ជសាស្ត្រ ...**៕

១២. ប្រលងចូលសាលាពេទ្យ មិនកំណត់និទ្ទេស តែមិនបន្ទូរបន្តយវិញ្ញាសា

សម្ពោធអគារ «អគារតេជោសន្តិភាព» នៅមន្ទីរពេទ្យកាល់ម៉ែត, ១៥ មករា ២០១៨

... សាកលវិទ្យាល័យពេទ្យ បានធ្វើការតម្រូវអោយមានការប្រលងដោយយកតាមនិទ្ទេស ... និយាយតាមបារាំង A, B, C ដល់ D និង E ... និសិត្សដែលចង់ប្រលងចូល បានស្នើសុំមកខ្ញុំជាខម្មិនក្នុង INBOX និងតាម Messenger ... ខ្ញុំបានបញ្ជូន(សំណើទាំងនោះ)តាម WhatsApp មកអោយ ឯកឧត្តមរដ្ឋមន្ត្រី ម៉ម ប៊ុនហេង ... ពេលមានការឯកភាពហើយ ខ្ញុំក៏បានឆ្លើយតបជាមួយក្មួយៗ ថា "យើងអនុញ្ញាតអោយចូលប្រលងគ្រប់និទ្ទេសទាំងអស់ ... **យើងបើកឱកាសអោយ ចូលប្រលងតែត្រូវតែមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ"។ បែរជាមានខម្មិនមួយមកទៀតថា សូមបន្ទូរបន្តយវិញ្ញាសាប្រលង ... សូមឆ្លើយថា ខ្ញុំធ្វើអត់បានទេរឿងហ្នឹង ...**៕

១៣. ការពិនិត្យសុខភាពជាឧបសគ្គដល់អ្នកប្រឡងចូលក្របខណ្ឌនិងបង្កើតអំពើពុករលួយ

ប្រគល់សញ្ញាបត្រដល់និស្សិត សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល, ១៦ ធ្នូ ២០១៩

... សូមបញ្ជាក់សាជាថ្មី ពេលដែលក្រសួងសុខាភិបាលស្នើសុំឱ្យមានការត្រួតពិនិត្យ(សុខភាពអ្នកដែលប្រឡងចូលជាក្របខណ្ឌមន្ត្រី) ខ្ញុំអត់យល់ព្រមទេ។ ខ្ញុំបានបដិសេធ។ មូលហេតុមិនយល់ព្រមគឺ បើសិនជាខ្ញុំយល់ព្រម វានឹងបង្កើតជាឧបសគ្គសម្រាប់និស្សិតដែលប្រឡងចូលក្របខណ្ឌរដ្ឋហ្នឹងទី១។ ទី២ បង្កើតជាសំបុកពុករលួយតែម្តង។ ចង់បានលិខិតពិនិត្យសុខភាព ... ឱ្យលុយប៉ុណ្ណោះ (ប៉ុណ្ណោះមក) មិនបាច់ពិនិត្យទេ ឱ្យតែម្តង។ ហ្នឹងជាសំបុកពុករលួយដែលនាំឱ្យខូចឈ្មោះ។ អ្នកដែលចូលធ្វើការ/ស្អីៗ គេត្រូវមានលិខិតថ្កោលទោស។ អត់មានយកលុយ/កាក់អីទេ គ្រាន់តែធ្វើយឺតក៏មានបញ្ហាដែរ ...។

១៤. អ្នកទទួលបានការបណ្តុះបណ្តាលនៅក្រៅប្រទេស ជួយចែករំលែកអ្នកនៅក្នុងប្រទេស

ប្រគល់សញ្ញាបត្រដល់និស្សិត សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល,
១៦ ធ្នូ ២០១៩

... ពិនិត្យតួលេខអ្នកដែលបានទទួលការបណ្តុះបណ្តាល ក្នុងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលចាប់តាំងពីឆ្នាំ១៩៨០-៨១ រហូតមកដល់២០១៨-១៩ មានចំនួន ២៧៥៥៩ នាក់ ក្នុងនោះនិស្សិតអាហារូបករណ៍មានចំនួន ១៤០២០ នាក់ និងការរៀនបង់ថ្លៃមានចំនួន ១៣៥៣៩នាក់ ហើយនិស្សិតដែលកំពុងសិក្សាបន្តមានចំនួន ៥៥១៣នាក់ ... **តាមរបាយការណ៍របស់ឯកឧត្តម ម៉ម ប៊ុនហេង និស្សិតដែលយើងបានបញ្ជូនទៅធ្វើកម្មសិក្សា និងបន្តបរិញ្ញាបត្រជាន់ខ្ពស់ថ្នាក់វេជ្ជបណ្ឌិតឯកទេសនៅក្រៅប្រទេស មានប្រទេសបារាំង អាមេរិក អូស្ត្រាលី ជប៉ុន កូរ៉េ ចិលហ្សិក មានចំនួន ៩៧៨នាក់។ នេះជាចំនួនដែលយើងបានទទួលត្រឡប់មកវិញ។ មិនមែន(ជាជោគជ័យ)សម្រាប់សាមីខ្លួនទេ ក៏ប៉ុន្តែសាមីខ្លួនដែលបានទទួលការបណ្តុះបណ្តាលឯកទេស អាចយកមកចែករំលែកនៅក្នុងសាលា/មន្ទីរពេទ្យរបស់យើងផងដែរ ...។**

១៥. អតីតកាលដ៏ឈឺចាប់ នាំដល់ការផ្តើមគំនិតបង្កើតសមាគមគ្រូពេទ្យស្ម័គ្រចិត្តតេជោ

ពិធីសំណេះសំណាលជាមួយសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ,
២ មីនា ២០១៨

... ខ្ញុំមិនដែលភ្លេចពីអតីតកាល ដែលពោរពេញទៅដោយការឈឺចាប់សម្រាប់ខ្លួនខ្ញុំផ្ទាល់ក្តី ឬក៏សម្រាប់ប្រជាជនកម្ពុជាក្តី។ ដូច្នេះហើយ ជាមួយសកម្មភាពដឹកនាំក្នុងក្របខណ្ឌនៃការចំណាយថវិកាជាតិ ក៏ត្រូវមានគំនិតផ្តួចផ្តើមធ្វើសកម្មភាពទាំងឡាយតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ក្នុងន័យនេះ សមាគមគ្រូពេទ្យស្ម័គ្រចិត្តសម្តេចតេជោ ហៅកាត់ថា TYDA ... បានពង្រាយទៅខេត្តក្រុងច្រើនកន្លែង ដែលខ្ញុំគិតថាជាសកម្មភាពដែលមានការពូនផ្តុំដោយគ្រូពេទ្យស្ម័គ្រចិត្ត ហើយក៏បានពូនផ្តុំដោយសប្បុរសជននានា ដែលបានចូលរួមជួយជាថវិកា សម្ភារៈដើម្បីឲ្យសកម្មភាពរបស់ក្រុមគ្រូពេទ្យដំណើរការទៅ ... ដំណាក់កាលនេះ ប្អូនៗក្មួយៗ ធ្វើសកម្មភាពក្នុងក្របខណ្ឌមនុស្សធម៌គឺជួយមនុស្ស ...។

១៦. ក្រុមគ្រូពេទ្យនៃថ្នាក់ដឹកនាំគណបក្សប្រជាជនចុះជួយប្រជាជនតាមមូលដ្ឋាន

ពិធីសំណេះសំណាលជាមួយសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជន សម្តេចតេជោ,
២ មីនា ២០១៨

... ទោះបីស្ថានភាពនេះបានកែលំអមួយកម្រិតហើយក្តី យើងនៅមានបញ្ហាប្រឈមមួយកម្រិតទៀត និងបន្តទៀត ដែលវាមិនគ្រាន់តែត្រូវការអន្តរាគមន៍ពីមន្ទីរពេទ្យរដ្ឋ និងស្ថាប័នរបស់រដ្ឋនោះទេ។ **វាក៏តម្រូវអោយបន្តអនុវត្តវប្បធម៌នៃការចែករំលែក ឬសិល្បៈនៃការចែករំលែក ដូចជាបង្កើតក្រុមគ្រូពេទ្យនានា មានដូចជាក្រុមគ្រូពេទ្យសម្តេច ជា ស៊ីម ក្រុមគ្រូពេទ្យសម្តេច ហេង សំរិន ក្រុមគ្រូពេទ្យសម្តេច ស ខេង ក្រុមគ្រូពេទ្យថ្នាក់ដឹកនាំនេះថ្នាក់ដឹកនាំនោះ ... សូមយកឱកាសនេះធ្វើការកោតសរសើរ និងអរគុណចំពោះក្រុមគ្រូពេទ្យទាំងអស់ដែលបានខិតខំក្នុងរយៈពេលកន្លងទៅចុះពិនិត្យព្យាបាលជំងឺប្រជាជន ...។**

១៧. មោទនភាពចំពោះយុវគ្រូពេទ្យស្ម័គ្រចិត្ត រួមដំណើរជាមួយ TYDA

ពិធីសំណេះសំណាលជាមួយសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ,
២ មីនា ២០១៨

... ប្រសិនបើមិនមានវត្តមានរបស់ពួកយើងទេ តើអ្នកទាំងនេះទទួលជោគវាសនាបែបណាទៅហើយ? យើងត្រូវមើលឃើញចំនុចនេះ ... **ខ្ញុំមានមោទនភាពចំពោះយុវជនយើង ដែលបានចូលរួមក្នុងកិច្ចការមនុស្សធម៌ដ៏មានសារៈសំខាន់**

នេះហើយសង្ឃឹមថា យុវជនយើងនឹងបន្តរួមដំណើរជាមួយ TYDA បន្តទៀត។ យើងនៅមានកិច្ចការច្រើនជួយដល់ប្រជាពលរដ្ឋ ដើម្បីធ្វើអោយពួកគាត់មានសុខភាពកាន់តែប្រសើរ ជម្នះបានជំងឺជង្គាត់នានា។ សូមអរគុណចំពោះសប្បុរសជនទាំងឡាយដែលបានចូលរួមជាវិភាគទាន ថវិកា ជាសម្ភារៈ ជួយដល់បេសកកម្មនៃក្រុមគ្រូពេទ្យនេះ។ នេះបង្ហាញអោយឃើញទឹកចិត្តថា យើងបានរួមគ្នាកសាងប្រទេសនេះដោយមិនពឹងផ្អែករង់ចាំតែដំណក់អុកស៊ីសែន ដែលគេបន្តក់អោយយើង ...៕

១៨. មិនត្រូវមានពេទ្យនៅក្រៅបញ្ជីក្របខណ្ឌ ដែលច្បាប់ទទួលស្គាល់ទេ

ចែកសញ្ញាបត្រដល់និស្សិត នៃសាកលវិទ្យាល័យពុទ្ធិសាស្ត្រ, ៦ មិថុនា ២០១៩

... ទន្ទឹមនឹងការរីកចម្រើននៃសាកលវិទ្យាល័យ(ពុទ្ធិសាស្ត្រ)នេះ មានចំណុចមួយដែលខ្ញុំសូមផ្តល់ជាអនុសាសន៍ សម្រាប់សាកលវិទ្យាល័យផង សម្រាប់និស្សិតផង ហើយក៏សម្រាប់ក្រសួងសុខាភិបាល ដែលមានឯកឧត្តម ម៉ម ប៊ុនហេង នៅទីនេះស្រាប់។ សាកលវិទ្យាល័យនេះមានរៀនផ្នែកវេជ្ជសាស្ត្រ និងឱសថសាស្ត្រ និយាយរួមគឺទាក់ទងនឹងផ្នែកពេទ្យ។ **យើងបានធ្វើការសម្របសម្រួលបញ្ហានេះក្នុងក្របខណ្ឌនៃការប្រជុំរវាងគ្រឹះស្ថានឧត្តមសិក្សា ជាមួយរដ្ឋាភិបាល ថាត្រូវយកចិត្តទុកដាក់លើបញ្ហាមុខវិជ្ជានេះ ព្រោះទាក់ទងជាមួយជីវិតមនុស្ស។ ប្រសិនបើមិនច្បាស់លាស់ទេ ក្រសួងសុខាភិបាលត្រូវធ្វើការតម្រង់ទិស ព្រោះមិនអាចទទួលបានការបណ្តុះបណ្តាលហើយ ទុកឱ្យមានពេទ្យក្រៅក្របខណ្ឌ ហើយដែលទទួលស្គាល់ដោយច្បាប់ទេ** ...៕

១៩. រៀននៅសាលាឯកជនក្តីឬសាលារដ្ឋក្តី ត្រូវខិតខំឱ្យទៅជាប្រព័ន្ធឯកភាពមួយ

ចែកសញ្ញាបត្រដល់និស្សិត នៃសាកលវិទ្យាល័យពុទ្ធិសាស្ត្រ, ៦ មិថុនា ២០១៩

... ទោះបីថាយើងមានការខិតខំច្រើនណាស់ហើយក៏ដោយ ក៏ថ្មីៗនេះ បណ្តាញសារព័ត៌មានមួយចំនួនបានចុះ(ផ្សាយពីការខ្វះចន្លោះក្នុងការគ្រប់គ្រង ក្នុងវិស័យសុខាភិបាល ទាក់ទងនឹងករណី)ដែលមានគ្រូពេទ្យមួយចំនួនដើរចាក់ថ្នាំតាមភូមិ/ឃុំមួយចំនួនក្នុងផ្ទៃប្រទេស ដោយគ្មានសញ្ញាបត្រ និងគ្មានការទទួលស្គាល់ពីផ្នែកសុខាភិបាល។ ហើយវាជារឿងពិត។ ឥឡូវ **នៅតាមសាកលវិទ្យាល័យឯកជនមួយចំនួន ក៏មានការបណ្តុះបណ្តាលផ្នែកវេជ្ជសាស្ត្រ ពិសេសផ្នែកឱសថសាស្ត្រនេះតែម្តង។ ដូច្នេះ ត្រូវខិតខំសម្របសម្រួលឱ្យក្លាយទៅជាប្រព័ន្ធមួយឯកភាព ដែលបើទោះបីជាសិក្សានៅសាលារដ្ឋក្តី សិក្សានៅសាលាឯកជនក្តី ក៏គប្បីមានការទទួលស្គាល់ឱ្យបានច្បាស់ ព្រោះជាមុខវិជ្ជាទាក់ទងនឹងជីវិតមនុស្ស** ...៕

២០. ខេត្តត្បូងឃ្មុំនឹងទទួលបានសាកលវិទ្យាល័យមួយនិងមន្ទីរពេទ្យមួយ

សម្ពោធដាក់អោយប្រើប្រាស់នូវអគារសាលាខេត្ត និងមន្ទីរជំនាញប្រមូលផ្តុំជុំវិញខេត្តត្បូងឃ្មុំ, ៩ ឧសភា ២០១៧

... ពិនិត្យពីអតីតកាលដ៏ជូរចត់មកដល់ពេលនេះ យើងបានដើរឆ្ងាយណាស់ហើយពីស្ថានភាពដ៏លំបាកលំបិន។ **សមិទ្ធផលនានាបានកើតចេញជារូបរាងហើយ ក្នុងនោះវាក៏ជាកត្ថសំណាងមួយរបស់ខេត្តត្បូងឃ្មុំ ទន្ទឹមនឹងការកើតនូវទីរួមខេត្តនេះ ដែលយើងបានបង្កើតជាសាកលវិទ្យាល័យសម្រាប់ផ្តល់ឱ្យយុវជនបានសិក្សានៅសាកលវិទ្យាល័យនៅជិតនេះ។** នៅពេលខាងមុខ សាធារណរដ្ឋប្រជាមានិតចិននឹងកសាងមន្ទីរពេទ្យ ដែលមានលក្ខណៈជាមន្ទីរពេទ្យបង្អែកធំមួយ។ដែលមុននេះ យើងធ្លាប់ដឹកអ្នកជំងឺទៅកាន់ទីរួមខេត្តកំពង់ចាម ខ្ញុំបានលើកសំណើចំពោះប្រធានាធិបតីចិន ស៊ី ជីនពីង ឲ្យជួយកសាងមន្ទីរពេទ្យសម្រាប់ការព្យាបាលប្រជាពលរដ្ឋនៅទីនេះ ...៕

២១. ក្នុងវិស័យសុខាភិបាល ចេះដឹងមិនគ្រប់គ្រាន់ ព្យាបាលមិនបានទេ

សំណេះសំណាលជាមួយសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ, ២ មីនា ២០១៨

... បើនិយាយក្នុងវិស័យអប់រំ យើងថាអ្នកចេះច្រើនបង្រៀនអ្នកចេះតិច ឯអ្នកចេះតិច បង្រៀនអ្នកមិនចេះ។ ប៉ុន្តែ **សម្រាប់វិជ្ជាជីវៈពេទ្យមិនដូច្នោះទេ។ អ្នកចេះតិច មិនអាចចាក់ថ្នាំឲ្យអ្នកជំងឺទេ។ ក៏មានកន្លែងខ្លះប្រជុំយប្រថានដែរ។ រៀនសូត្រវេជ្ជសាស្ត្របានតិចតួច ហើយដោយសារខ្វះពេទ្យ ក៏បង្កើតទៅជាស្ថានភាពពេទ្យឯកជន ដើរចាក់ថ្នាំព្យាបាលជំងឺនឹងគេនឹងឯង** ... រឿងរ៉ាវដែលបានកើតឡើងចំពោះយើងគឺកំសត់។ ពេលនោះ ការផ្តល់ជំនួយមកកម្ពុជាមិនគ្រប់នឹងប្រើ។

ប្រជាពលរដ្ឋខ្វះថ្នាំសង្កូវ ការពិនិត្យព្យាបាលជំងឺតាមមន្ទីរពេទ្យរដ្ឋ មានឧបករណ៍សម្ភារៈខ្សត់ខ្សោយ ជាមួយនឹងធនធានមនុស្សមានកម្រិត ...៕

២២. ការព្យាបាលជំងឺគ្មានការប្រកាន់បក្ខពួក រើសអើងសញ្ជាតិ សាសនា ពណ៌សម្បុរ នយោបាយ

ពិធីសំណេះសំណាលជាមួយសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ, ២ មីនា ២០១៨

... **សូមហាមការប្រកាន់និន្នាការនយោបាយ ហាមស្តីបន្ទោសឲ្យបក្សណា ឬគាំទ្របក្សណា។ ទោះអ្នកនោះគាំទ្របក្សណាក៏ដោយ ត្រូវតែពិនិត្យព្យាបាលដោយគ្មានការរើសអើង។ នេះជាតំណែម នៃគ្រូពេទ្យស្ម័គ្រចិត្ត TYDA**។ TYDA ត្រូវមានតំណាមមួយនេះ បើទោះបីគេធ្លាប់ជេរបញ្ឆោរយើងយ៉ាងម៉េចក៏ដោយ។ ពេលដែលមកយកសេវាសុខាភិបាលពីយើងៗ ត្រូវព្យាបាលឲ្យពេញចិត្តឲ្យជា ... **នយោបាយជារឿងមួយ ឯរឿងសុខភាព និងកិច្ចការមនុស្សធម៌គឺជារឿងមួយដែលគ្មានការប្រកាន់បក្ខពួក គ្មានរើសអើងសញ្ជាតិ គ្មានរើសអើងសាសនា ពណ៌សម្បុរ នយោបាយ** ...៕

២៣. ចូលរួមសន្និបាត ៣៨/៣៩លើក តាមដានការវិវឌ្ឍស្តីពីការរៀបចំធនធានមនុស្ស

ពិធីបិទសន្និបាតសុខាភិបាលប្រចាំឆ្នាំលើកទី៣៩, ២៧ មីនា ២០១៨

... សូមបញ្ជាក់ឡើងវិញថា **ក្នុង ៣៩ឆ្នាំនេះ មានតែឆ្នាំទៅមួយគត់ ដែលខ្ញុំអត់បានចូលរួម។ សន្និបាតសុខាភិបាលរយៈពេល ៣៩ឆ្នាំ គឺខ្ញុំបានចូល ៣៨ឆ្នាំ/ជង។ បានសេចក្តីថា សន្និបាតទី១ នៅដើមឆ្នាំ១៩៨០ ដំណើរការបើកត្រឹមសាលាពេទ្យរួចហើយខ្ញុំចូលគ្រប់ពេលនៃសន្និបាត។ ដូច្នេះបានជាខ្ញុំតាមដានសិក្សាការវិវឌ្ឍប្រៃប្រួលតាំងពីការរៀបចំធនធានមនុស្ស។ អញ្ចឹងកុំឲ្យ ៧៣%, ៧២,៩៩% វានៅកកកុញ ប្រមូលផ្តុំតែនឹងនៅខេត្ត** ហើយដឹងថាខេត្តមានស្រុក មានឃុំ ផង ...៕

២៤. ឲ្យអាទិភាពអ្នកមានវិជ្ជាពេទ្យនៅខេត្ត និងស្ម័គ្រចិត្តទៅខេត្តនោះវិញ

បិទសន្និបាតសុខាភិបាលលើកទី៤០, ១២ មីនា ២០១៩

... ការជ្រើសរើសគ្រូពេទ្យទៀតសោត កុំធ្វើដូចជាទស្សវត្សរ៍ទី៨០ ... ពេលដែលយើងឲ្យទទួលនិស្សិតមកពីបណ្តាខេត្ត តំបន់ជនជាតិក៏មក(រៀនវេជ្ជសាស្ត្រ) សុទ្ធតែចុះហត្ថលេខាអះអាងថា "រៀនចប់ពេទ្យហើយត្រូវបម្រើរដ្ឋ"។ (លើការជាក់ស្តែង) ... មិនមែនអ្នករតនគិរី មណ្ឌលគិរី ស្ទឹងត្រែង កោះកុង ព្រះវិហារមករៀន (ទេ តែជា)កូនអ្នកភ្នំពេញ។ ដាក់ឈ្មោះថាជាកូនអ្នកមណ្ឌលគិរី រតនគិរីទៅវិញ។ ដល់ទៅរៀនហើយស្រេចតែវាមិនទៅ ... ឥឡូវដូចគ្នាដែរ អ្នកចង់ធ្វើគ្រូពេទ្យ ច្រើនគ្នាណាស់។ បើត្រូវរើស សូមកុំសំដៅមន្ទីរពេទ្យក្នុងទីក្រុងភ្នំពេញ លើកលែងតែឯកទេសសំខាន់ដែលយើងខ្វះ។ **បើសិនជាយើងត្រូវរើសគ្រូពេទ្យដើម្បីបំពេញឲ្យខេត្តណាមួយ ត្រូវតែឲ្យអាទិភាពទៅអ្នកដែលមានវិជ្ជាពេទ្យ ប៉ុន្តែគេនៅខេត្តនោះ ហើយស្ម័គ្រចិត្តទៅខេត្តនោះ ចាំយើងទទួល។ ធ្វើបែបនេះ ទើបយើងអាចបំពេញនូវតម្រូវការនៅតាមខេត្តដែលខ្វះគ្រូពេទ្យបាន** ...។

២៥. បើផ្ទេរទៅកងទ័ព គ្រូពេទ្យស៊ីវិលត្រូវចេះក្បួនសង្គ្រោះលើសមរភូមិ

ប្រគល់សញ្ញាបត្រដល់និស្សិត សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល, ១៦ ធ្នូ ២០១៩

... សូមកោតសរសើរចំពោះសាកលវិទ្យាល័យ គណៈគ្រប់គ្រង សាស្ត្រាចារ្យដែលបានបង្ហាត់បង្ហាញ**សាកលវិទ្យាល័យការពារជាតិ ក៏ដូចជាផ្នែកវិទ្យាស្ថានសុខាភិបាលរបស់ក្រសួងការពារជាតិ ... ការបណ្តុះបណ្តាលឯកទេសមួយចំនួនដែលខាងយើងមិនមានការចាំបាច់ ខាងនោះគេមានការចាំបាច់ តាំងពីក្បួនសង្គ្រោះនៅក្នុងសមរភូមិស្តីៗថែមទៀត។ ខាងគ្រូពេទ្យស៊ីវិល បើកាលណា Transfer ទៅខាងគ្រូពេទ្យយោធា ក៏ត្រូវតែចេះវិធីសាស្ត្រហ្នឹងដែរ ព្រោះពេលចូលសមរភូមិ ខុសពីមន្ទីរពេទ្យយោធាទេ។ បើទោះបីឥឡូវអត់មានសង្គ្រាមក៏ដោយ** ... ជួនកាលអ្នករបួសមិនអាចយកចេញពីសមរភូមិបាន ក៏ប៉ុន្តែពេទ្យលូនទៅចាក់ថ្នាំ។ ជំនាន់ខ្ញុំ មិនមែនដោះអាវឱ្យចាក់ទេ ដូចជាថ្នាំយាត់ឈាមជាដើម គឺចាក់ទាំងពីលើ(ក្រណាត់អាវតែម្តង) ...៕

២៦. ពីរឆាការបន្ទុះបង្អាប់ ក្លាយជានិមិត្តរូបនៃវីរភាព ឬកងទ័ពអាវសៃ

ប្រសាសន៍ក្នុងសន្និសីទសារព័ត៌មាន បើកយុទ្ធនាការចាក់វ៉ាក់សាំងការពារ កូវីដ-១៩ ជូនជនវ័យជំទង់ អាយុពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ, ១ សីហា ២០២១

... យើងមានធនធានមនុស្ស ទាំងគ្រូពេទ្យយោធាទាំងគ្រូពេទ្យស៊ីវិល ទាំងគ្រូពេទ្យស្ម័គ្រចិត្ត សម្រាប់ដំណើរការចាក់វ៉ាក់សាំង។ ថ្នាក់ដឹកនាំតាមស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិ មានការទទួលខុសត្រូវដឹកនាំអនុវត្ត។ **ពីមុននេះ គ្រូពេទ្យត្រូវបានគេបន្ទុះបង្អាប់។ ប៉ុន្តែ (ក្នុងការប្រយុទ្ធជាមួយ)កូវីដ-១៩នេះ គ្រូពេទ្យក្លាយទៅជានិមិត្តរូបនៃវីរភាព ហួតគេប្រសិទ្ធិនាមថាកងទ័ពអាវសៃ។** មួយឆ្នាំកន្លះជាងនេះ គ្រូពេទ្យរបស់យើងអត់សូវបានជួបប្រពន្ធជួបកូនទេ។ ទៅមន្ទីរពេទ្យ ផុតពីមន្ទីរពេទ្យ មកធ្វើចត្តាឡីស័ក ដើម្បីសម្រាក។ ធ្វើចត្តាឡីស័ក អត់ហ៊ានទៅជួបកូនប្រពន្ធ។ បើថាស្រីអត់បានទៅជួបប្តីជួបកូន។ រស់នៅបែកគ្នាសិន ...៕

២៧. ជ្រើសរើសគ្រូពេទ្យ ៤២០០នាក់ បង្កើនកម្លាំងទ្រទ្រង់ប្រយុទ្ធនឹងកូវីដ១៩

បិទយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់អ្នកមានអាយុ ៦ឆ្នាំឡើងនិង បើកយុទ្ធនាការចាក់វ៉ាក់សាំងសម្រាប់ក្មេងអាយុ ៥ឆ្នាំ, ១ វិច្ឆិកា ២០២១

... យើងក៏ត្រូវបំប៉នគ្រូពេទ្យក្នុងការប្រយុទ្ធជាមួយកូវីដ-១៩ ស្អិតទាំងអ្នកយកសំណាកស្តី។ ក៏ដេកពួនមិនបានប៉ុន្មាន។ បើទោះបីជាគ្រូពេទ្យហ្នឹងការហើយក៏គ្មានកូនដែរព្រោះវាអត់បានជួបគ្នា។ **អនុញ្ញាតឲ្យជ្រើសរើសថែមគ្រូពេទ្យ៤.២០០នាក់ ព្រោះវាចំជំនាញដែលយើងត្រូវការបង្កើនកម្លាំងគ្រូពេទ្យ។ ពេលហ្នឹងហើយដែលគ្រូពេទ្យយើងមានពិសោធន៍ទ្រាំទ្រប្រយុទ្ធជាមួយកូវីដ-១៩។** ក្នុងបទចំរៀងមានការលើកសរសើរពេទ្យថាជាកងទ័ពអាវសៃ។ កាលពីមុនដេរពេទ្យ។ ពេលទឹកដល់ច្រមុះ នាំគ្នាសរសើរពលីកម្មរបស់គ្រូពេទ្យ។ រឿងហ្នឹងជារឿងពិត ...៕

២៨. ការពិគ្រោះជំងឺអាចធ្វើតាមមធ្យោបាយទំនាក់ទំនងឌីជីថល

សម្ពោធដាក់ឲ្យប្រើប្រាស់មន្ទីរពេទ្យបង្អែកស្រុកក្រូចឆ្មារ, ខេត្តត្បូងឃ្មុំ, ៣ មេសា ២០២៣

... នេះជាសម័យអនឡាញ សម័យឌីជីថល សម័យបច្ចេកវិទ្យាព័ត៌មាន។ យើងត្រូវរុញបច្ចេកទេសមកទីនេះ។ ឥឡូវនេះ **ការពិគ្រោះជំងឺអាចធ្វើបានតាមរយៈនៃបណ្តាញព័ត៌មានវិទ្យា។ គេអាចប្រើ Zoom ពិគ្រោះ ឬក៏តាមមធ្យោបាយផ្សេងណាមួយ។ គេអាចពិគ្រោះជំងឺពីចំងាយ ដោយមិនចាំបាច់ហៅពេទ្យពីភ្នំពេញមកទីនេះទេ។ នៅពេលណាដែលគ្រូពេទ្យនៅកន្លែងនេះមានការលំបាក គេអាចភ្ជាប់ទំនាក់ទំនងទៅគ្រូពេទ្យជំនាញនៅកន្លែងណាមួយ។** ខាងនោះគេអាចផ្តល់មតិមក... ដូចជាជំងឺរបស់ខ្ញុំជារដើម គ្រូពេទ្យដែលព្យាបាលឱ្យខ្ញុំ តែងពិគ្រោះជាមួយគ្រូពេទ្យដទៃ ប៉ុន្តែគេមិនចាំបាច់ឱ្យគ្រូពេទ្យដទៃនោះមកជួបជាមួយខ្ញុំទេ។ សូមឱ្យអ្នកទទួលខុសត្រូវយកចិត្តទុកដាក់ពង្រឹងសមត្ថភាព ...៕

២៩. ការពារប្រសើរជាងព្យាបាល បើចេះការពារខ្លួន កាត់បន្ថយបានការឈឺថ្កាត់

សម្ពោធអគារព្យាបាល មហារីកនិងសម្ភព «អគារតេជោសន្តិភាព» មន្ទីរពេទ្យកាល់ម៉ែត, ១៥ មករា ២០១៨

... ថ្ងៃមុន មានការមិនយល់អស់អំពីអ្វីដែលខ្ញុំចង់និយាយ។ ខ្ញុំចង់និយាយថា **យើងគួរធ្វើពហិការកុំទិញទំនិញដែលប្រើជាតិគីមី និងសូមឲ្យប្រជាពលរដ្ឋខ្លួនឯងលោកចេះទទួលខុសត្រូវក្នុងការពិនិត្យផង។ បែរជាយករឿងហ្នឹងធ្វើជាការវាយប្រហារខ្ញុំ ... ខ្ញុំនៅតែបន្តនិយាយថា "ការពារប្រសើរជាងព្យាបាល"។ បើជម្ងឺកើតហើយ គឺវាត្រូវការព្យាបាល។ ប៉ុន្តែ បើយើងចេះការពារ ក៏វាកាត់បន្ថយបាននូវការឈឺថ្កាត់សម្រាប់ខ្លួនយើង។ គ្មានអ្នកណាមកឈឺជាមួយយើងទេ។** ខ្ញុំដាក់ជាកម្មវិធីការពារខ្លួនឯង។ សូម្បីតែប្រពន្ធខ្ញុំ កូនខ្ញុំក៏មិនអាចមកឈឺជំនួសខ្ញុំកើតដែរ។ ដូចនេះ ជម្រើសដែលល្អមានតែមួយគត់គឺការពារខ្លួនឯង តាំងពីទទួលទាន តាំងពីការហាត់ប្រាណ មិនមានអ្នកណាមកធ្វើជំនួសទេ ...៕

៣០. សូមមន្ទីរពេទ្យទាំងរដ្ឋ/ជន កុំជណ្តើមអ្នកជំងឺគ្នា និងទទួលខុសត្រូវពីដើមដល់ចប់

ប្រគល់សញ្ញាបត្រដល់និស្សិត សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល, ១៦ ធ្នូ ២០១៩

... ខ្ញុំសុំឱ្យយកចិត្តទុកដាក់លើការគ្រប់គ្រងគ្លីនិកឯកជន ក៏ដូចជាការលក់ឱសថឱ្យបានច្បាស់ ... ខ្ញុំសុំសំណូមពរអញ្ចេះ។ **យើងមានមន្ទីរពេទ្យទាំងរដ្ឋទាំងឯកជនក៏ប៉ុន្តែសូមកុំជណ្តើមអ្នកជំងឺគ្នា។ បើជណ្តើមអ្នកជំងឺគ្នា ក៏សូមឱ្យមានការទទួលខុសត្រូវពីដើមដល់ចប់។ កុំឱ្យដល់ថ្នាក់សង្គ្រោះលែងបានហើយបញ្ជូនទៅមន្ទីរពេទ្យរដ្ឋ។ ដល់តែងាប់ៗ ឯមន្ទីរពេទ្យរដ្ឋ។ ដែលធ្ងន់ធ្ងរជាងគេគឺកាល់ម៉ែតតែម្តង។**

មន្ទីរពេទ្យឯកជនដទៃដោះស្រាយមិនចេញ ក៏ថាទៅកាល់ម៉ែតអាចសង្គ្រោះបាន។ ទៅដល់កាល់ម៉ែត(ងាប់)។ ហ្នឹងក៏ត្រូវពិនិត្យ។ (ត្រូវ)ធ្វើការជាមួយវិស័យឯកជន (និង/ឬ)គ្រូពេទ្យឯកជន។ បើអ្នកឯង(មិនអាចទទួលខុសត្រូវ)ពីដើមរហូតដល់ចប់(ទេ) គឺត្រូវបញ្ជូនទៅមន្ទីរពេទ្យរដ្ឋ ឱ្យមន្ទីរពេទ្យរដ្ឋ(ព្យាបាល) ...។

៣១. មន្ទីរពេទ្យទាំងរដ្ឋទាំងឯកជន ធ្វើសកម្មភាពឱ្យស្របនឹងសីលធម៌សង្គ្រោះជីវិត

ប្រគល់សញ្ញាបត្រដល់និស្សិត សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល,
១៦ ធ្នូ ២០១៩

... ទោះបីជាគ្រូពេទ្យក្នុងផ្នែករដ្ឋឬវិស័យឯកជន សូមកុំយកលុយជាធំ ត្រូវយកជីវិតប្រជាជនធ្វើជាធំ។ រឿងលុយ/កាក់ទុកក្រោយ។ ធ្វើម៉េចដោះស្រាយការព្យាបាលឱ្យអ្នកជំងឺសិន។ កុំឃើញថាគាត់អត់មានប្រាក់ ត្រូវបញ្ជូនទៅកន្លែងផ្សេង ... អ្នកដែលអត់ប្រាក់ ឱ្យទៅរកគេផ្សេង។ អ្នកដែលមានប្រាក់ ដណ្តើមយកទុក។ ដល់ទៅសង្គ្រោះមិនបាន បញ្ជូនទៅមន្ទីរពេទ្យរដ្ឋ។ **សូមគ្រប់មន្ទីរពេទ្យ ទាំងមន្ទីរពេទ្យរដ្ឋ ទាំងមន្ទីរពេទ្យឯកជន ធ្វើសកម្មភាពឱ្យស្របនឹងសីលធម៌សង្គ្រោះជីវិតមនុស្សជាធំ។ មិនមែនបញ្ហាលុយកាក់ទេ។ យើងអាចធ្វើបាន ដោយយើងរៀនសូត្រជាគ្រូពេទ្យ ត្បិតចង់សង្គ្រោះជីវិតមនុស្ស។** ធ្វើសម្ភាសន៍លើគ្រូពេទ្យ ១០០នាក់ ចម្លើយចេញមកដូចគ្នា។ ខ្ញុំចង់សង្គ្រោះជីវិតមនុស្ស ទើបខ្ញុំចង់រៀនពេទ្យ ...។

៣២. គោរពគុណធម៌ "គ្រូពេទ្យកោសខ្យល់" កុំមើលឃើញប្រាក់ថ្លៃជាងការសង្គ្រោះជីវិត

ប្រគល់សញ្ញាបត្រដល់និស្សិត សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល,
១៦ ធ្នូ ២០១៩

សួរក្រុមនិស្សិតដែលចង់ចូលរៀនពេទ្យថា ម៉េចចៅ/ក្មួយឯងចង់រៀនពេទ្យ? ថាខ្ញុំចង់ជួយជីវិតមនុស្ស។ ចុះ**ពេលដែលយើងបានទៅជាគ្រូពេទ្យហើយ ម៉េចបានយើងមិនយកចិត្តទុកដាក់ទៅលើគោលដៅដើម ដែលយើងចង់ជួយសង្គ្រោះជីវិតមនុស្ស? បែរជាយើងមើលប្រាក់ថ្លៃជាង ឬយើងប្រើតិរិយាបថមិនសមរម្យ។ ខ្ញុំនៅតែបន្តនិយាយពី "គ្រូពេទ្យកោសខ្យល់" មិនមែនជាការប្រមាថចំពោះគ្រូពេទ្យទេ ក៏ប៉ុន្តែសម័យមុនយើងមានមណ្ឌលសុខភាពច្រើន ហើយក៏មិនមានថ្នាំពេទ្យផ្តល់ឱ្យផង។ អញ្ចឹង កាយវិការនោះជាគុណធម៌របស់គ្រូពេទ្យទៅវិញទេ។**

ដល់ស្តីមិនមានៗ អញ្ចឹងគ្រូពេទ្យក្លាយជាអ្នកកោសខ្យល់ឱ្យអ្នកជំងឺ។ ខ្ញុំនិយាយពាក្យ "គ្រូពេទ្យកោសខ្យល់" សំដៅទៅលើការយកចិត្តទុកដាក់ទៅលើអ្នកជំងឺដោយសារតែពេទ្យខ្លួនឯងមិនមានមធ្យោបាយ ...។

៣៣. មន្ទីរពេទ្យត្រូវធានានិរន្តរភាព អភិវឌ្ឍនិងបំពាក់សម្ភារបច្ចេកវិទ្យាទាន់សម័យ

សម្ពោធដាក់ឱ្យប្រើប្រាស់មន្ទីរពេទ្យបង្អែកស្រុកក្រូចឆ្មារ, ខេត្តត្បូងឃ្មុំ,
៣ មេសា ២០២៣

... ធ្វើឱ្យមន្ទីរពេទ្យ(បង្អែកស្រុកក្រូចឆ្មារ)របស់យើង **ក្លាយជាមន្ទីរពេទ្យដែលធានាបាននិរន្តរភាពនោះម្ខាង តែម្ខាងទៀតអភិវឌ្ឍបច្ចេកវិជ្ជានិងបំពាក់សម្ភារទាន់សម័យបន្ថែមទៀត ... បើយើងមិនបណ្តុះបណ្តាលធនធានមនុស្សទេ យើងមិនចេះប្រើឧបករណ៍សម្ភារបច្ចេកទេសដែលគេផលិតបានថ្មីៗ ទេ។** បើយកសម្ភារមក តែមិនមានការបណ្តុះបណ្តាលបច្ចេកទេសយើងក៏មិនអាចប្រើសម្ភារបច្ចេកទេសនោះបានដែរ។ អញ្ចឹង ទាមទារឱ្យមន្ទីរពេទ្យដែលមានដៃគូជាច្រើនជាមួយនឹងមន្ទីរពេទ្យដទៃទៀត យកចិត្តទុកដាក់ដល់ឧបករណ៍សម្ភារបច្ចេកទេស ដោយទាមទារឱ្យមានការហ្វឹកហាត់តាមមន្ទីរពេទ្យដែលជាដៃគូរបស់ខ្លួន ឬក៏សម្ភារបច្ចេកទេសដែលបានបញ្ជូនមក ...។

៣៤. រៀបចំមន្ទីរពេទ្យឱ្យមានកន្លែងឯកទេសព្យាបាលកីឡាករ/ការិនី

សេចក្តីដកស្រង់ប្រសាសន៍ ក្នុងពិធីជួបជុំសំណេះសំណាល និងពិសាអាហារ
សាមគ្គីជាមួយមហាគ្រួសារកីឡាកម្ពុជា, ៣ មេសា ២០២៣

... ខ្ញុំគួរតែបញ្ជាក់ជូនកីឡាករ/ការិនីឱ្យបានជ្រាបថា រយៈពេលកន្លងទៅនេះដោយបានឃើញស្ថានភាពដ៏លំបាករបស់កីឡាករ/ការិនីក្នុងពេលប្រកួត ខ្ញុំបានសម្រេចជាមួយក្រសួងសុខាភិបាល **រៀបចំឱ្យមានមន្ទីរពេទ្យព្យាបាលកីឡាករ/ការិនីរបស់យើង ដែលមានការងារបួសបន្ទាប់ពីការប្រកួត ជាពិសេសកីឡាបាល់ទាត់និងកីឡាប្រដាល់។ ខ្ញុំមិនមែនសំដៅត្រឹមតែ ២នោះទេ។ យើងសំដៅទៅដល់កីឡាគ្រប់ប្រភេទទាំងអស់ដែលមានការពាក់ព័ន្ធ ហើយយើងនឹងមានទីកន្លែងព្យាបាលឯកទេស។ មុននេះ ខ្លះទៅព្យាបាលនៅគ្លីនិកឯកជន ខ្លះទៅព្យាបាលនៅ**

កន្លែងនេះ/នោះ មិនទៀងទាត់។ ចាប់ពីពេលនេះតទៅ យើងមានកន្លែងសម្រាប់ព្យាបាលកីឡាករ/ការិនីដើម្បីជានាឲ្យពួកគេទទួលបានការថែទាំពេញលេញ ...៕

៣៥. យកចិត្តទុកដាក់លើការរស់នៅរបស់គ្រូពេទ្យ ដូចជាការរស់នៅរបស់គ្រូបង្រៀន

ពិធីបិទសន្និបាតក្រសួងសុខាភិបាលលើកទី ៣៩, ២៧ មីនា ២០១៨

... ម៉្យាងទៀត**យើងត្រូវផ្សារភ្ជាប់យកចិត្តទុកដាក់ទៅលើបញ្ហាការរស់នៅរបស់គ្រូពេទ្យ ដូចជាការរស់នៅរបស់គ្រូបង្រៀនផងដែរ ទើបយើងពង្រាយគ្រូពេទ្យទៅបាន។** បញ្ហានេះ ក៏ត្រូវគិតគូរជាមួយនឹងក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ។ កន្លងទៅ ដែលយើងពង្រាយគ្រូទៅនៅជនបទ គឺយើងផ្តល់ប្រាក់ឲ្យគ្រូបន្ថែមទៅលើតម្លៃនៃការស្នាក់អាស្រ័យរបស់ពួកគាត់មាន ៨ម៉ឺនរៀល មាន ១០ម៉ឺនរៀល និងមាន ១២ម៉ឺនរៀល។ ចំណុចនេះ ខ្ញុំមិនដឹងថាតើការពង្រាយគ្រូពេទ្យបានផ្តល់អត្ថប្រយោជន៍និងកន្លែងស្នាក់នៅហើយឬនៅ? កំពុងតែពិភាក្សាគ្នា។ ខ្ញុំលើកទឹកចិត្តឲ្យធ្វើ។ បើមិនដូច្នោះ ពង្រាយទៅអត់ផ្ទះនៅ ហើយប្រាក់ខែវាមិនគ្រប់ជួលផ្ទះវាមានបញ្ហាទៀត ...៕

៣៦. ៩២% នៃមណ្ឌលសុខភាពមានអគ្គិសនីប្រើប្រាស់

ពិធីបិទសន្និបាតសុខាភិបាលប្រចាំឆ្នាំលើកទី៣៩, ២៧ មីនា ២០១៨

... ឥឡូវអត់ត្រូវការពេលដល់មួយអាទិត្យទេ។ ចេញតែមួយភ្លែតដល់មណ្ឌលគិរី ... ស្ថានភាពវាខុសប្លែកគ្នា ហើយម្យ៉ាងទៀត **គួរកត់សម្គាល់ថា៩២% នៃមណ្ឌលសុខភាពសរុប ១១៩០ មានបណ្តាញអគ្គិសនីប្រើប្រាស់។ ខុសគ្នាកាលពីសម័យមុនដែលប្រើចង្កៀងប្រេងកាត។ ខ្ញុំនិយាយរឿងពីមុនបន្តិច។ ពេលដែលគេខ្វេះភ្នែកខ្ញុំ គេខ្វេះនឹងពន្លឺចង្កៀងប្រេងកាតទេ។** មិនមែនមានអគ្គិសនីបញ្ចាំងភ្នែកទេ។ ខ្ញុំត្រូវគេចងដៃជាប់ ចាក់ថ្នាំងងុយដេកបន្តិច និងថ្នាំស្ពឹក ហើយខ្វេះតែម្តង។ **ឥឡូវនេះ៩២% ទៅហើយមានអគ្គិសនី ... បើមិនទាន់មាន(អគ្គិសនីពីចរន្តជាតិ) ក៏មានផ្ទាំងពន្លឺព្រះអាទិត្យ ឬអាគុយប្រើប្រាស់ដែរ ...៕**

៣៧. កង្វះកិច្ចសហការរវាងក្របខណ្ឌ រវាងអាជ្ញាធរខ្លួនឯងលើបញ្ហាឱសថក្លែងក្លាយ

សន្និសីទថ្នាក់តំបន់ស្តីពី «ការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ និងអន់គុណភាព», ៥ វិច្ឆិកា ២០១៨

... **កម្ពុជាខ្លួនឯងធ្លាប់ជួបប្រទះអំពីកង្វះកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌប្រទេសរបស់ខ្លួន នេះមិនទាន់និយាយដល់ការពាក់ព័ន្ធជាមួយប្រទេសដែលពាក់ព័ន្ធនឹងការផលិត និងការចរាចរផងទេ។** នៅទសវត្សរ៍ទី៨០ ពេលដែលក្រសួងសុខាភិបាលចុះទៅចាប់ការលក់ឱសថគ្មានសណ្តាប់ធ្នាប់ ហើយគ្មានច្បាប់ត្រឹមត្រូវ យើងក៏បានកំណត់ថាឲ្យឱសថស្ថាន ឱសថស្ថានរង ត្រូវមានច្បាប់ទម្លាប់ មានក្រុមគ្រូពេទ្យទៅនៅជាមួយថ្នាក់ណាៗ។ ម្យ៉ាងទៀត ក៏មានឱសថមួយចំនួនលក់តាមកញ្ច្រែងដាក់ហាលថ្ងៃ។ ចំណុចនេះ តាមជនបទមួយចំនួនក៏នៅមានសេសសល់នៅឡើយ។ ពេលដែលចុះទៅចាប់ការលក់មិនត្រូវច្បាប់នេះ ជានិច្ចជាកាលក្រសួងសុខាភិបាលតែងតែចាញ់អ្នកលក់ពេលដែលក្តីក្តាំគ្នាក្នុងតុលាការ។ មូលហេតុដែល(ធ្វើអោយក្រសួង)ចាញ់ក្តីអ្នកលក់នៅត្រង់ថា ផ្នែកពន្ធដារបានទៅយកពន្ធនៅកន្លែងលក់ ... ផ្អែកទៅលើប្រការដែលថារដ្ឋបាលយើងទៅយកពន្ធនោះ តុលាការត្រូវសំរេចថា អ្នកលក់ហ្នឹងស្របច្បាប់ ...៕

៣៨. គណៈកម្មាធិការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយដឹកនាំដោយរដ្ឋមន្ត្រីមហាផ្ទៃ មានសមាជិកពី ១៤ស្ថាប័ន

សន្និសីទថ្នាក់តំបន់ស្តីពី «ការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ និងអន់គុណភាព», ៥ វិច្ឆិកា ២០១៨

មូលហេតុដែលតុលាការប្រកាសថា ការលក់(ថ្នាំតាមកញ្ច្រែង)ជាការត្រឹមត្រូវតាមច្បាប់ មូលហេតុគឺមានបង្កាន់ដៃគ្រប់គ្រាន់(ដែលបញ្ជាក់)ថា ផ្នែកហិរញ្ញវត្ថុបានទៅយកពន្ធ។ បើយកពន្ធមានន័យថា យើងចាត់ទុកថាគេជាប្រកបរបរលក់ដូរស្របច្បាប់ហើយ។ ចំណុចទាំងនេះ ជាកង្វះកិច្ចសហការរវាងអាជ្ញាធរខ្លួនឯង។ ដូច្នេះហើយក្រោយមក យើងខ្ញុំ**ត្រូវមានគណៈកម្មាធិការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយនេះ ដែលមាន ១៤ស្ថាប័នចូលរួម ដឹកនាំដោយឧបនាយករដ្ឋមន្ត្រីម្នាក់ដែលជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ បើខ្វះចន្លោះកិច្ចសហប្រតិបត្តិការណាមួយយើងមិនអាចទប់ទល់ជាមួយនឹងឃាតករលាក់មុខនេះបានទេ។** ឱសថអាចមកពីប្រភពនេះមកពីប្រភពនោះ ដែលមួយផ្នែកធំគឺឱសថហួសកាលកំណត់ប្រើប្រាស់ដែលលក់ចែកចាយទៅប្រជាជន(ដែលគ្នា)ខ្វះការយល់ដឹង ...៕

៣៩. គួរជំរុញគំនិតផ្តួចផ្តើមភ្នំពេញស្តីពី "ឱសថក្លែងក្លាយនិងអន់គុណភាព"

សន្និសីទថ្នាក់តំបន់ស្តីពី «ការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ និងអន់គុណភាព», ៥ វិច្ឆិកា ២០១៨

... ដោយសារប្រទេសអភិវឌ្ឍតិចតួច និងប្រទេសកំពុងអភិវឌ្ឍក៏កំពុងជួបប្រទះចំណោទសុខុមាលភាពនិងសុខភាពសាធារណៈ ដោយសារការរងគ្រោះពីឱសថក្លែងក្លាយនិងអន់គុណភាព ខ្ញុំគិតថា វាជា**ឱកាសល្អមួយសម្រាប់(ដាក់ចេញនូវគំនិតផ្តួចផ្តើមទាក់ទិននឹងឱសថក្លែងក្លាយ)ចេញពីទីក្រុងភ្នំពេញ និងពង្រីកទៅកាន់វេទិកាដទៃទៀត**។ ដំបូងឡើយ ខ្ញុំគិតថា ដោយទីនេះមានតំណាងមកពីតាមបណ្តាប្រទេសមេគង្គ គឺមានបណ្តាប្រទេសអាស៊ាន ហើយក៏មានឯកឧត្តម លោកជំទាវ ជាអគ្គរដ្ឋទូតបណ្តាប្រទេសអាស៊ាន យើងគួរនាំយកគំនិតផ្តួចផ្តើមទាក់ទិននឹងបញ្ហាឱសថក្លែងក្លាយនេះ ចូលទៅក្នុងក្របខណ្ឌអាស៊ាន ... តែដោយការប្រជុំអាស៊ាននិងដៃគូពាក់ព័ន្ធនឹងចាប់ផ្តើមនៅអាទិត្យចុងក្រោយនេះ ហើយ ដូចនេះកិច្ចការនោះច្បាស់ជារៀបចំមិនទាន់ ...។

៤០. យកប្រធានបទឱសថក្លែងក្លាយដាក់ក្នុងប្រជុំអាស៊ីអឺរ៉ុប ហ្វ្រង់កូហ្វូន ឬ ICAPP

សន្និសីទថ្នាក់តំបន់ស្តីពី «ការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ និងអន់គុណភាព», ៥ វិច្ឆិកា ២០១៨

... ដោយសារថាកម្ពុជានឹងត្រូវធ្វើជា**ម្ចាស់ផ្ទះកិច្ចប្រជុំអាស៊ី-អឺរ៉ុបនៅឆ្នាំ២០២០ អញ្ចឹងសុំលោកជំទាវអគ្គរដ្ឋទូតបារាំង ក៏ដូចជាឯកឧត្តម ឡឺរីត សហការគ្នាពិចារណាមើលថា តើគួរយកប្រធានបទមួយនេះ(ការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ និងអន់គុណភាព)ដាក់ចូល(ជារបៀបវារៈ)ក្នុងការប្រជុំអាស៊ី-អឺរ៉ុប ឬទេ? ... ក្រៅពីនោះមានយន្តការ Francophone ដែលមួយផ្នែកមានប្រទេសនៅអាស៊ីនិងមួយផ្នែកមានប្រទេសនៅអាហ្វ្រិក** សុទ្ធតែជាប្រទេសអភិវឌ្ឍតិចតួច និងប្រទេសកំពុងអភិវឌ្ឍ ក៏ប្រហែលជាកំពុងរងគ្រោះដូចគ្នា ... តើយើងអាចស្នើសុំឲ្យ **ICAPP ដែលជាសន្និសីទអន្តរជាតិ នៃបណ្តាបក្សនយោបាយនិយមកណ្តាលអាស៊ីប៉ាស៊ីហ្វិក** មានជិតដល់រយគណបក្សនយោបាយ ទាំងគណបក្សកាន់អំណាចនិងគណបក្សប្រឆាំង ... គាំទ្រសេចក្តីថ្លែងការណ៍ក្រុងភ្នំពេញ(បានទេ) ...។

៤១. ស្នើប្រធានាធិបតីបារាំងចាប់អារម្មណ៍លើវិធានការពាក់ព័ន្ធសុខភាពសាធារណៈ

សន្និសីទថ្នាក់តំបន់ស្តីពី «ការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ និងអន់គុណភាព», ៥ វិច្ឆិកា ២០១៨

... សម្រាប់សេចក្តីថ្លែងការណ៍(ស្តីពីការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ និងអន់គុណភាព)នេះ ខ្ញុំស្នើជាយោបល់ថា គួរតែមានការអំពាវនាវឲ្យដៃគូដទៃទៀតគាំទ្រចូលរួមលើគំនិតផ្តួចផ្តើមសេចក្តីថ្លែងការណ៍ភ្នំពេញ ដើម្បីយើងមានហេតុផលជាសំអាង។ **សង្ឃឹមថាប្រធានាធិបតីបារាំង ឯកឧត្តម អេម៉ានូអែល ម៉ាក្រុង នឹងចាប់អារម្មណ៍លើវិធានការទាំងឡាយ ដែលពាក់ព័ន្ធនឹងបញ្ហាសុខុមាលភាពសាធារណៈ។ ក្រៅពីបញ្ហានេះ បារាំងជាប្រទេសដែលយកចិត្តទុកដាក់ខ្ពស់លើការប្រែប្រួលអាកាសធាតុ។ ខ្ញុំគិតថា នេះជាចំណុចដែលយើងគួរត្រូវធ្វើរួមគ្នាដើម្បីឲ្យភ្លាយទៅជាចរន្តអន្តរជាតិ។ យើងមានក្រុមហ៊ុនផលិតឱសថប៉ុន្មាន? មានប្រទេសប៉ុន្មាន? ប៉ុណ្ណោះវាមិនគ្រប់គ្រាប់ទេ។ វាត្រូវតែទៅជារួម ទាំងប្រទេសផលិត ទាំងប្រទេសមិនផលិត** ...។

៤២. "គ្រូពេទ្យ São Tomé and Príncipe កំពុងរៀននៅកម្ពុជា"

សេចក្តីដកស្រង់សង្គថាក្នុងពិធីសំណេះសំណាលជាមួយសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ, ២ មីនា ២០១៨

... យើងទទួលជោគជ័យច្រើន។ មានអ្នកមករៀនពីយើងច្រើន ក៏ប៉ុន្តែលួចរៀនស្ងាត់ៗ តាមរយៈស្ថាប័ននេះស្ថាប័ននោះរបស់អង្គការសហប្រជាជាតិ ឬស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ។ ខ្ញុំបានជួបប្រធានាធិបតី São Tomé and Príncipe ទទួលទានបាយជាមួយគ្នា។ ប្រទេស São Tomé and Príncipe គឺជាអតីតអាណានិគមព័រទុយហ្គាល់។ ខ្ញុំធ្លាប់ទស្សនកិច្ចនៅប្រទេសនោះ តាំងពីខ្ញុំនៅធ្វើជារដ្ឋមន្ត្រីការបរទេស ... ដល់មកឆ្នាំ២០០០ ពេលប្រជុំកំពូលត្បូងត្បូងនៅប្រទេសគុយបា ខ្ញុំបានអង្គុយជាប់ជាមួយប្រធានាធិបតី São Tomé and Príncipe។ **ខ្ញុំដំណាលពីដំណើរដែលខ្ញុំទស្សនកិច្ចនៅប្រទេសគាត់កាលពីឆ្នាំ១៩៨២។ គាត់តបមកវិញថា "គ្រូពេទ្យរបស់ São Tomé and Príncipe ៧នាក់ កំពុងរៀននៅកម្ពុជា"។ ខ្ញុំភ្ញាក់ព្រើត។ គាត់ថា**

"ទោះបីថាវាមិនទាន់ល្អឥតខ្ចោះក៏ដោយ កម្ពុជាជាកន្លែងដែលជោគជ័យលើបញ្ហាមួយចំនួន ដែលគប្បីចែករំលែកបទពិសោធន៍" ...៕

៤៣. គ្រូពេទ្យស្ម័គ្រចិត្ត ៤២២នាក់ ថែមលើ ២ពាន់នាក់, ពេទ្យទាហាន ពេទ្យនគរបាល ប្រយុទ្ធនឹងកូវីដ-១៩

សំណេះសំណាលជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តប្រយុទ្ធប្រឆាំងជំងឺ Covid-19, ២៥ មីនា ២០២០

... ហេតុអ្វីបានជាយើងត្រូវជ្រើសរើសគ្រូពេទ្យស្ម័គ្រចិត្ត ? ហេតុអ្វីមិនប្រើគ្រូពេទ្យទូទាំងប្រទេសដែលមានចំនួនជាង ២ម៉ឺននាក់ ? ... មិនមែនយើងមានតែអ្នកជំងឺ Covid-19 ទេ។ យើងមានអ្នកជំងឺច្រើនប្រភេទ ដែលបាននិងកំពុងសម្រាកនៅក្នុងមន្ទីរពេទ្យ នៅគ្រប់ទីកន្លែងក្នុងទូទាំងប្រទេស។ ក្នុងចំណោមគ្រូពេទ្យជាង ២ម៉ឺននាក់នេះ មានជាង ២ពាន់នាក់ជាអ្នកប្រយុទ្ធនឹងជំងឺឆ្លង ដែលបច្ចុប្បន្ននេះមិនគ្រាន់ធ្វើកិច្ចការទាក់ទងនឹង Covid-19 ទេ តែក៏ត្រូវមើលជំងឺដទៃទៀត ដូចជាគ្រុនផ្តាសាយបក្សី ឬជំងឺឆ្លងប្រភេទនេះប្រភេទនោះ ... **យើងបានប្រុងប្រៀបឱ្យក្រសួងការពារជាតិរៀបចំគ្រូពេទ្យ និងទីកន្លែងសម្រាប់ព្យាបាល។ យើងបានបញ្ជាទៅឱ្យក្រសួងមហាផ្ទៃរៀបចំគ្រូពេទ្យ ជានគរបាលជាតិបន្ថែមទៀតដើម្បីត្រៀមឆ្លើយតប។ ការដែលត្រូវជ្រើសរើសក្មួយៗបន្ថែមនេះ គឺសំដៅត្រៀមបម្រុងទុកផង និងអាចចាប់ផ្តើមដំណើរការពីឥឡូវទៅផង** ...៕**

៤៤. ខ្សោយកែវិធានការហ្មត់ចត់, ខ្លាំងកែមើលស្រាលសភាពការណ៍និងឆ្លើយតបយឺត

សំណេះសំណាលជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តប្រយុទ្ធប្រឆាំងជំងឺ Covid-19, ២៥ មីនា ២០២០

...ប្រទេសធំៗប្រទេសអ្នកមានដែលចាត់ទុកថាមានវេជ្ជសាស្ត្រខ្លាំង ដូចជា G7 ... មានប្រព័ន្ធសុខាភិបាលរឹងមាំ ប៉ុន្តែប្រទេសទាំងអស់នេះក៏មានមនុស្សស្លាប់។ ដោយឡែកអាស៊ាន ឥឡូវ(មានករណីឆ្លងនៅ)គ្រប់ទាំង១០ប្រទេសហើយ ...មិនមានប្រទេសសមាជិកអាស៊ានណាមួយដែលថាមិនទាន់កើតករណីឆ្លងទេ ... **ខ្លាំងនិងខ្សោយជាបញ្ហាងាយមើលបំផុត នៅត្រង់ថា តើប្រទេសនេះឆ្លងច្រើនប៉ុណ្ណា ហើយបណ្តោយឱ្យមនុស្សស្លាប់ច្រើនប៉ុណ្ណា ? ត្រូវមើលឱ្យឃើញកន្លែងហ្នឹង។**

ការដែលគេឱ្យនិយមន័យថា ប្រព័ន្ធសុខាភិបាលកម្ពុជាខ្សោយ ប្រព័ន្ធសុខាភិបាលភូមាខ្សោយ ប្រព័ន្ធសុខាភិបាលឡាវខ្សោយ លើការជាក់ស្តែង ឡាវទើបនឹងមានពីម្សិល ភូមាទើបនឹងមានពីម្សិលមួយថ្ងៃ ហើយក៏នៅមានតិចតួចណាស់។ អ្នកខ្សោយ(ធនធាន)មិនប្រាកដថាខ្សោយ(ទាំងការគ្រៀមខ្លួន)ទេ ដោយសារមានវិធានការហ្មត់ចត់ជាង។ ឯអ្នកខ្លាំងមិនប្រាកដថាខ្លាំងទេ ដោយសារតែការមើលស្រាលនូវសភាពការណ៍ និងការឆ្លើយតបមិនបានទាន់ពេលវេលា ...៕**

៤៥. ប្រើពេទ្យ ៤ប្រភេទ, ដើរដល់ណាគ្រប់គ្រងដល់នោះ និងគ្រប់គ្រងមួយជំហានមុន

សំណេះសំណាលជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តប្រយុទ្ធប្រឆាំងជំងឺ Covid-19, ២៥ មីនា ២០២០

... ខ្ញុំនិយាយអំពីការប្រើប្រាស់កម្លាំង។ **យើងមានកម្លាំងបួននៅពេលនេះ។ ទី១ គឺពេទ្យផ្ទៃ ទី២ ពេទ្យយោធា ទី៣ ពេទ្យនគរបាល និងទី៤ ពេទ្យស្ម័គ្រចិត្ត។ កម្លាំងរបស់យើងត្រឹមថ្ងៃនេះ មានតែ ៤២២នាក់ទេ ប៉ុន្តែនៅមានលទ្ធភាពពង្រីកបន្ត។ វាស៊ីសងថាតើយើងត្រូវការឬអត់ (និងវាអាស្រ័យ)ទៅតាមការវិឆ្ឆៃនៃស្ថានភាពជំងឺក្នុងប្រទេសយើង។ ដើរដល់ណាគ្រប់គ្រងដល់នោះ ហើយគ្រប់គ្រងមួយជំហានមុន** ... នាយករដ្ឋមន្ត្រីកាន់ការផ្ទាល់(និង)មើលផ្ទាល់ មិនមែនផ្ទាល់តែជាមួយរដ្ឋមន្ត្រីសុខាភិបាលទេ ផ្ទាល់ជាមួយទាំងចៅហ្វាយខេត្ត។ បញ្ជាតែមួយថ្ងៃ រៀបចំទាំងអស់។ ព្រលឹមឡើង Voice សម្លេង ... កុំមើលស្រាលប្រទេសដែលថាក្រប្រព័ន្ធការពារសុខភាពខ្សោយ។ គំនិតរបស់វាមិនប្រាកដថាខ្សោយទេ។ ឯប្រព័ន្ធសុខភាពខ្លាំង គំនិតមេដឹកនាំមិនប្រាកដថាខ្លាំងទេ គ្រាន់តែសំណាងល្អ អ្នកឯងបានកើតក្នុងប្រទេសអ្នកមានតែប៉ុណ្ណឹងទេ ...៕

៤៦. វ៉ាក់សាំងជាយុទ្ធសាស្ត្រគន្លឹះ វិធានការ ៣ការពារ ៣កុំ ជាអន្តរកាល តែរយៈពេលវែង

សន្និសីទសារព័ត៌មានក្រោយពិធីប្រគល់-ទទួលអំណោយវ៉ាក់សាំងកូវីដ-១៩ ពីមិត្តចិន, ៧ កុម្ភៈ ២០២១

... យុទ្ធសាស្ត្រគន្លឹះមួយ ក្នុងការគ្រប់គ្រងយកឈ្នះលើកូវីដ-១៩ នោះ គឺការចាក់វ៉ាក់សាំងការពារដល់ប្រជាជនយើង ... វ៉ាក់សាំងមិនមែនជាដំណោះស្រាយតែមួយគត់ ឬវិធានការតែមួយគត់នោះទេ។ **វិធានការដែលយើងប្រកាន់យកក្នុង**

រយៈពេលកន្លងទៅ គឺ ៣ការពារ និង ៣កុំ ... ៣ការពារ គឺទី១. ពាក់ម៉ាស់ ទី២. លាងដៃធ្វើអនាម័យ និងទី៣. រក្សាគម្លាត។ ឯ ៣កុំ គឺកុំទៅកន្លែងមានមនុស្សច្រើន, កុំទៅតំបន់បិទជិត ប្រើតែម៉ាស៊ីនត្រជាក់ ... ជាដំណោះស្រាយអន្តរកាល រយៈពេលវែង។ បើទោះបីជាមានការចាក់វ៉ាក់សាំងហើយក៏ដោយ ក៏យើងត្រូវតែប្រើនូវវិធានការនេះជាបន្ត ...៕

៤៧. ត្រូវការជំនួយវ៉ាក់សាំងពីគ្រប់ប្រទេស ឲ្យតែសមស្របនឹងស្ថានភាពកម្ពុជា

សន្និសីទសារព័ត៌មានក្រោយចាក់វ៉ាក់សាំង កូវីដ-១៩ នៅមន្ទីរពេទ្យកាល់ម៉ែត, ៤ មីនា ២០២១

... **ប្រសិទ្ធភាពវ៉ាក់សាំងណាក៏ដូចវ៉ាក់សាំងណាដែរ។ វាមានប្រសិទ្ធភាពខុសគ្នាតិចតួច ... យើងត្រូវការ(ជំនួយវ៉ាក់សាំងពី)គ្រប់ប្រទេស ទាំងចិន អង់គ្លេស អាមេរិក ក៏យក ឲ្យតែឲ្យ ហើយសមស្របជាមួយនឹងស្ថានភាពប្រទេសរបស់យើង។** អរគុណចំពោះប្រទេសនានាដែលជួយតាម COVAX ផង ជួយតាមទ្វេភាគីផង ដូចជាអូស្ត្រាលីជាដើម ... ឥណទានចេញពីធនាគារអភិវឌ្ឍន៍អាស៊ី ថវិកាជាឥណទានមកពីជប៉ុន ... ឥឡូវកុំខ្វល់ថាវ៉ាក់សាំងអី ត្រូវខ្វល់ថាមានវ៉ាក់សាំងចាក់ ឬអត់ ...៕

៤៨. ទទួលស្គាល់សិទ្ធិទាំងអស់ តែផ្តល់អាទិភាពមុនគេដល់សិទ្ធិរស់រានមានជីវិត

បិទវគ្គបណ្តុះបណ្តាលឆ្នាំ ២០២០-២០២១ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០២២ សាលាភូមិន្ទរដ្ឋបាល, ១៣ មិថុនា ២០២២

... អ្វីដែលជាវិធានការរបស់រាជរដ្ឋាភិបាលនៅពេលនោះគឺដើម្បីពេលនេះឯង។ ពេលនោះរាជរដ្ឋាភិបាលបង្ខំចិត្តត្រូវបិទទីក្រុងភ្នំពេញ តាខ្មៅ ខេត្តព្រះសីហនុ។ បន្ទាប់ទៅយើងក៏ដាក់ចេញនូវការបិទខ្ទប់តាមគោលដៅ ... យើងត្រូវធ្វើយ៉ាងណាជំនះដើម្បីកុំឲ្យប្រជាជនស្លាប់។ **យើងផ្តល់អាទិភាពមុនគេគឺសិទ្ធិរស់រានមានជីវិត ... ដោយសារតែសិទ្ធិរស់រានមានជីវិតនេះហើយ ទើបយើងអាចទៅអនុវត្តសិទ្ធិដទៃទៀត(បាន) ... បើគ្មានសិទ្ធិរស់រានមានជីវិតហើយ បានសេចក្តីថាអ្នកឯងអត់មានសិទ្ធិអ្វីទាំងអស់** ... យើងទទួលស្គាល់សិទ្ធិទាំងអស់ រាប់ទាំងសិទ្ធិ ... បោះឆ្នោត(ឃុំ សង្កាត់)។ នេះជាសិទ្ធិនៃដំណើរការប្រជាធិបតេយ្យ ប៉ុន្តែសួរថា (បើជា)ខ្មោច (តើ)វាចេះទៅបោះឆ្នោតទេ ...៕

៤៩. យុទ្ធសាស្ត្រ៣ ស្វែងរក និងចាក់វ៉ាក់សាំងទប់ទល់កូវីដ១៩

កិច្ចប្រជុំគណៈកម្មការប្រយុទ្ធនឹងកូវីដ-១៩(Zoom), ១ កក្កដា ២០២១

... យុទ្ធសាស្ត្រវ៉ាក់សាំង៣ គឺ៖ **ទី១ ត្រូវរកវ៉ាក់សាំងចាក់ឲ្យប្រជាជនឲ្យបានគ្រប់ ១០ លាននាក់ និងបន្តទៅគិតដល់ការចុះចាក់ឲ្យក្មេងអាយុក្រោម ១៨ឆ្នាំ ... ទី២ ត្រូវតែបន្តយកចិនធ្វើជាបង្គែកយុទ្ធសាស្ត្រសំរាប់ការផ្គត់ផ្គង់វ៉ាក់សាំង ឯប្រភពផ្សេងៗ គឺជាប្រភពគាំទ្រ ... ទី៣ វ៉ាក់សាំងមកដល់ ត្រូវចែកតាមតំបន់អាទិភាពឲ្យត្រឹមត្រូវ និងប្រមូលផ្តុំកម្លាំងចាក់ឲ្យបានឆាប់។** បើ(វ៉ាក់សាំង)មកដល់ត្រឹមខែ៨/សីហា ខ្ញុំគិតថាការចាក់វ៉ាក់សាំងនឹងចប់នៅខែ១១/វិច្ឆិកា ...៕

៥០. ផ្តល់មធ្យោបាយធ្វើតេស្តរហ័សគ្រប់ច្រកព្រំដែន

សង្កថាថ្លែងក្នុងកិច្ចប្រជុំគណៈកម្មការប្រយុទ្ធនឹងកូវីដ-១៩(Zoom), ១ កក្កដា ២០២១

... ពិសេសត្រូវធ្វើតេស្តរហ័សនៅតាមព្រំដែន។ ថ្ងៃនេះ **យើងនិយាយពីការធ្វើតេស្តរហ័សឱ្យច្រើនបន្តិច។ ខ្ញុំយកការសម្រេចដោយការទទួលខុសត្រូវចំពោះមុខប្រជាជាតិកម្ពុជា ដោយមិនទុកឱ្យផ្នែកសុខាភិបាលពាំជាប់ជាមួយនូវសតិអារម្មណ៍អភិរក្សនិយម គ្មានការប្រែប្រួលនោះទេ។ ខ្ញុំត្រូវយកការទទួលខុសត្រូវលើនយោបាយទូទៅទាំងក្នុងប្រទេសនិងក្រៅប្រទេស។ ត្រូវតែផ្តល់មធ្យោបាយនៃការធ្វើតេស្តរហ័ស។** គ្រប់ច្រកព្រំដែនទាំងអស់ ត្រូវមានប្រដាប់ធ្វើតេស្តរហ័ស។ ក្រៅពីការធ្វើតេស្តរហ័ស បើនៅមានករណីសង្ស័យ ត្រូវធ្វើតេស្តដោយម៉ាស៊ីនធំ ដែលហៅថា PCR ដូចមានបំពាក់នៅបាត់ដំបង នៅសៀមរាប ...៕

៥១. សង្គ្រាមជាមួយ កូវីដ-១៩ មានតែចាញ់ច្រើនឬតិច គ្មានទេពាក្យថាឈ្នះ

សន្និសីទសារព័ត៌មាន, បើកយុទ្ធនាការចាក់វ៉ាក់សាំងការពារកូវីដ-១៩ ជូនជនវ័យជំទង់អាយុពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ, ១ សីហា ២០២១

... ខ្ញុំបានប្រកាសតាំងពីដើមទីថា **សង្គ្រាមមួយនេះមានតែចាញ់ គ្មានទេពាក្យថាឈ្នះ។ គ្រាន់តែចាញ់នោះតិចឬចាញ់ច្រើនតែប៉ុណ្ណឹងទេ។ សង្គ្រាមប្រឆាំងមេរោគ កូវីដ-១៩ អត់មានថាឈ្នះទេ គ្រាន់តែកាត់បន្ថយការចាញ់ ការខូចខាតវាបានទាប។ ប៉ុន្តែ ឱ្យបញ្ឈៀសការខូចខាតទាំងស្រុងគឺមិនអាចធ្វើបានទេ។ ដំរាបណា កូវីដ-១៩ មិនទាន់ចប់ ប្រទេសណាក៏ដោយ កុំអាលធ្វើឡួយ។** ឈ្នះឬចាញ់

មិនមែនស្ថិតនៅលើបច្ចេកទេសវិទ្យាសាស្ត្រពូកែទេ តែស្ថិតផងដែរនៅត្រង់អភិបាលកិច្ចពូកែឬមិនពូកែ ... តើមានវិធានការស្អី ? បើមិនព្រមស្តាប់ទេ មានតែវិធានការអនុវត្តច្បាប់។ ត្រូវផាក ពិន័យ និងគុក។ ការធ្វើនេះប៉ះពាល់ទៅដល់សេរីភាព ក៏ប៉ុន្តែវាជានាបានជីវិតរបស់ខ្លួនឯងនិងជីវិតរបស់ក្រុមគ្រួសារ។ យើងអត់មានអីខុស ... សូមពលរដ្ឋគ្រប់រូបត្រៀមខ្លួនបង្ការ កូវីដ-១៩ ឆ្លង បើកូវីដ-១៩ មិនទាន់ចប់ ប្រទេសទាំងអស់កុំអាលទុកចិត្តថាគ្រប់គ្រងបានល្អ ...៕

៥២. សហប្រតិបត្តិការជាមួយគ្រប់ដៃគូ ជានយោបាយការបរទេសចំរុះពណ៌របស់កម្ពុជា

បើកយុទ្ធនាការ៉ាក់សាំងកូវីដ-១៩ សម្រាប់កុមារ/យុវវ័យអាយុ ១២ ដល់ក្រោម ១៨ឆ្នាំ, ១ សីហា ២០២១

... **យើងនៅតែមានទំនុកចិត្តជាមួយកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូផ្សេងទៀតដូចជា អង្គការសុខភាពពិភពលោក វិទ្យាស្ថានជាតិប៉ាស្ទ័រ CDC របស់អាមេរិក និងបណ្តាដៃគូផ្សេងទៀត UNICEF, Covax, Gavi។ យើងធ្វើទាំងអស់។ នេះហើយជានយោបាយការបរទេសចំរុះពណ៌របស់កម្ពុជា**។ ពេលនេះ លែងនិយាយអីកើតថា ហ៊ុន សែន ស្អីក៏ពឹងតែចិនដែរ ព្រោះជប៉ុនឱ្យមកក៏យក អាមេរិកឱ្យមកក៏យក អង់គ្លេសឱ្យមកក៏យក អូស្ត្រាលីឱ្យមកក៏យក ... គ្រាន់តែខ្ញុំដឹងច្បាស់ថា តើប្រភពណាជាប្រភពបង្កែកដែលផ្តត់ផ្តង់ឱ្យយើង ទាំងផ្តល់ជំនួយផងទាំងទិញបានផង ...៕

៥៣. កត្តា៥ ជំរុញល្បឿនចាក់វ៉ាក់សាំង

បើកយុទ្ធនាការ៉ាក់សាំងកូវីដ-១៩ សម្រាប់កុមារ/យុវវ័យអាយុ១២ ដល់ក្រោម ១៨ឆ្នាំ, ១ សីហា ២០២១

ទី១ គឺកត្តាដឹកនាំ ដែលបានដាក់ចេញនូវផែនការច្បាស់លាស់ ព្រមទាំងមានយន្តការអនុវត្តប្រាកដប្រជា។ យន្តការអនុវត្តនោះមានយន្តការលទ្ធកម្មវ៉ាក់សាំង និងយន្តការគណៈកម្មការចំពោះកិច្ចសម្រាប់ការចាក់វ៉ាក់សាំង ...៕

ទី២ គឺមានប្រភពផ្តត់ផ្តង់ច្បាស់លាស់។ យើងយកចិនជាបង្កែកផ្តត់ផ្តង់ជាបង្កែកយុទ្ធសាស្ត្រ ឯប្រភពផ្សេងទៀតគឺជាប្រភពគាំទ្រ ...៕

ទី៣ ... មានសាច់ប្រាក់សន្សំដែលអាចទូទាត់បានភ្លាមៗ នៅពេលដែលយើងចុះកិច្ចសន្យាទិញវ៉ាក់សាំង។ ចុះកិច្ចសន្យាភ្លាម ប្រគល់លុយឱ្យគេភ្លាម ...៕

ទី៤ ... មានធនធានមនុស្សជំណើរការចាក់ ទាំងគ្រូពេទ្យយោធា ទាំងគ្រូពេទ្យស៊ីវិល ទាំងគ្រូពេទ្យស្ម័គ្រចិត្ត។ ថ្នាក់ដឹកនាំតាមស្ថាប័ន/អាជ្ញាធរថ្នាក់ក្រោមជាតិទទួលខុសត្រូវដឹកនាំអនុវត្ត ...៕

ទី៥ ... ប្រជាជនមកទទួលវ៉ាក់សាំង និងការជួយជាថវិកាសម្រាប់ការទិញវ៉ាក់សាំង ...៕

៥៤. ផលប្រយោជន៍៤ នៃការចាក់វ៉ាក់សាំងដល់ក្មេងជំទង់វ័យ១២ ដល់ក្រោម ១៨ឆ្នាំ

បើកយុទ្ធនាការ៉ាក់សាំងកូវីដ-១៩ សម្រាប់កុមារ/យុវវ័យអាយុ១២ ដល់ក្រោម ១៨ឆ្នាំ, ១ សីហា ២០២១

ទី១ ការពារការឆ្លងក្នុងក្រុមគ្រួសារ។ បើកុមារនិងយុវវ័យមិនទាន់បានចាក់គ្រួសារទាំងមូលនឹងមិនទាន់ជឿជាក់ថាមានសុវត្ថិភាព១០០% ឡើយ ...៕

ទី២ ជានាអោយនូវទំពាំងស្នងឫស្សីមានសុខភាពរឹងមាំ។ កុមារនិងយុវវ័យ នឹងក្លាយជាទំពាំងស្នងឫស្សីនៅអនាគត ... ត្រូវមានសុខភាពបរិបូរណ៍បញ្ញាភ្លឺថ្លា ...៕

ទី៣ កាត់បន្ថយអត្រាមរណភាពកុមារនិងយុវវ័យ ... ការពារកុមារជំទង់ឲ្យចៀសផុតពីការឈឺធ្ងន់ធ្ងរ ព្យាបាលឆាប់ជា និងអត្រាបាត់បង់អាយុជីវិតតិច ...៕

ទី៤ ចូលរៀនឡើងវិញ។ យើងអាចបើកដំណើរការឡើងវិញសាលារៀន និងគ្រឹះស្ថានអប់រំនានា ហោចណាស់ពីថ្នាក់អនុវិទ្យាល័យក្នុងបវេសនកាល ២០២១-២២ ខែកញ្ញា/តុលា ...៕

៥៥. ប្រភពចំណូល៥ ជួយទ្រទ្រង់ការចំណាយក្នុងបរិបទកូវីដ១៩

បើកយុទ្ធនាការ៉ាក់សាំងកូវីដ-១៩ សម្រាប់កុមារ/យុវវ័យអាយុ១២ ដល់ក្រោម ១៨ឆ្នាំ, ១ សីហា ២០២១

ទី១ ចំណូលចរន្ត ដែលក្នុងមួយខែ មានប្រមាណជាមធ្យម ៤០០លានដុល្លារ ... អាចទ្រទ្រង់ការចំណាយ ... ដែលក្នុងមួយឆ្នាំត្រូវការប្រមាណជា ៥ពាន់លាន ...៕

ទី២ ... បានសន្សំសាច់ប្រាក់ជាង ៣៣ន់លានដុល្លារ មុនពេលកូវីដ-១៩ មក ដល់ ... មកដល់ពេលនេះ បានចាយ ១ភាគ៣ ហើយ ...៕

ទី៣ ... សប្បុរជនចូលរួម ទាំងការប្រឆាំងកូវីដ-១៩ ទាំងគ្រោះទឹកជំនន់ ... សរុប ទាំងអស់ជាង ១៤០លានដុល្លារ ...៕

ទី៤ ... មានការគាំទ្រថវិកាពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ... ទាំងប្រយុទ្ធប្រឆាំង កូវីដ-១៩ ... និងស្រាយបញ្ហាសេដ្ឋកិច្ច ...៕

ទី៥ ... ជំនួយទ្វេភាគីពីប្រទេសជាមិត្តភក្តិមួយចំនួន ...៕

៥៦. យុទ្ធសាស្ត្រ ៦ ក្នុងយុទ្ធនាការចាក់វ៉ាក់សាំង

បិទយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់អ្នកមានអាយុ ៦ឆ្នាំឡើង និងបើកយុទ្ធនាការចាក់វ៉ាក់សាំងសំរាប់ក្មេងអាយុ ៥ឆ្នាំ, ១ វិច្ឆិកា ២០២១

... ខណៈសម្រុកចាក់វ៉ាក់សាំង យើងក៏ដាក់ចេញយុទ្ធសាស្ត្រ៦ ចំណុចគឺ ...

យុទ្ធសាស្ត្រទី១ បន្តទប់ស្កាត់ការនាំចូលមេរោគកូវីដបំប្លែងថ្មី។ ពេលនោះ ហើយ ដែលនាំទៅដល់ការបិទខេត្តមួយចំនួនតាមព្រំដែនកម្ពុជា-ថៃ រៀបចំតំបន់ ធ្វើចត្តាឡីស័កនៅកន្លែងនោះ។

យុទ្ធសាស្ត្រទី២ កាត់បន្ថយទំហំតំបន់ឆ្លង និងចំនួនឆ្លងឲ្យនៅកម្រិតទាប។ ពី ដើមថាឆ្លងពេញមួយក្រុងភ្នំពេញ ឥឡូវបំព្រួញវាឲ្យកាន់តែតូចទៅៗ ...។

យុទ្ធសាស្ត្រទី៣ ខិតខំព្យាបាលអ្នកឆ្លងឲ្យជាសះស្បើយ និងកាត់បន្ថយអត្រា ស្លាប់ដោយសារកូវីដ និងឈានចូលទៅរកអត្រាសូន្យ ប៉ុន្តែអត្រាសូន្យនេះទៅមិន ទាន់ទៅរួចទេ ...។

យុទ្ធសាស្ត្រទី៤ រុករកនិងគ្រប់គ្រងករណីពាក់ព័ន្ធនឹងកូវីដ-១៩។

យុទ្ធសាស្ត្រទី៥ រៀបចំបូជានិងបញ្ចុះសពអ្នកជំងឺឲ្យបានប្រសើរ។

យុទ្ធសាស្ត្រទី៦ យុទ្ធសាស្ត្រគន្លឹះ គឺការចាក់វ៉ាក់សាំងកូវីដ-១៩។ យើងប្រើ គ្រប់មធ្យោបាយ (រាប់ទាំង)តេស្តរហ័សដើម្បីគ្រប់គ្រងសភាពការណ៍ ...៕

៥៧. ឆ្លងដំណាក់កាល៤ ទប់ស្កាត់ គ្រប់គ្រងការឆ្លង បង្កើតភាពស៊ាំ ដំណើរការឡើងវិញ តាមគន្លងថ្មី

បិទយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់អ្នកមានអាយុ ៦ឆ្នាំឡើង និង បើកយុទ្ធនាការចាក់វ៉ាក់សាំងសម្រាប់ក្មេងអាយុ ៥ឆ្នាំ, ១ វិច្ឆិកា ២០២១

... ខ្ញុំគួរតែធ្វើការបូកសរុបអំពីអ្វីដែលយើងបានខិតខំក្នុងដំណាក់កាលមួយៗ ឆ្លងកាត់កូវីដ-១៩ រហូតមកដល់ពេលនេះ។ យើងបាននិងកំពុងឆ្លងកាត់ដំណាក់ កាល៤។

ដំណាក់កាលទី១៖ គឺដំណាក់កាលប្រយុទ្ធនិងទប់ស្កាត់ការឆ្លងជំងឺចូលក្នុង សហគមន៍ ចាប់ពីខែមីនា ឆ្នាំ២០២០ រហូតដល់ខែតុលា ឆ្នាំ២០២០។

ដំណាក់កាលទី២៖ ការគ្រប់គ្រងការឆ្លងរាលដាលនៃកូវីដ-១៩ ចូលក្នុងសហ គមន៍ ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២០ ដល់ថ្ងៃទី ២០កុម្ភៈ ឆ្នាំ២០២១។

ដំណាក់កាលទី៣៖ ការបង្កើតភាពស៊ាំក្នុងសហគមន៍ តាមរយៈការអនុវត្តយុទ្ធ នាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ គួបផ្សំបន្តគ្រប់គ្រងការឆ្លងរាលដាល ជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ ចាប់ពីថ្ងៃទី ២០កុម្ភៈ ឆ្នាំ២០២១ រហូតមកដល់ ពេលបច្ចុប្បន្ននេះ ឬថាដំណាច់ខែតុលា។

ដំណាក់កាលទី៤៖ គឺចាប់ពីពេលនេះ ការបើកដំណើរការប្រទេសពេញលេញ ឡើងវិញលើគ្រប់វិស័យ និងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងថ្មី ...៕

៥៨. យុទ្ធសាស្ត្រជាតិរស់នៅតាមគន្លងថ្មីក្នុងបរិបទកូវីដ-១៩ ស្របតាមអភិក្រម៣

បិទយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់អ្នកមានអាយុ ៦ឆ្នាំឡើង និងបើកយុទ្ធនាការចាក់វ៉ាក់សាំងសំរាប់ក្មេងអាយុ ៥ឆ្នាំ, ១ វិច្ឆិកា ២០២១

... ជានាបើកដំណើរការសកម្មភាពសង្គមសេដ្ឋកិច្ចពេញលេញឡើងវិញដោយ ក្លាហានតែឈរលើស្មារតីប្រុងប្រយ័ត្នខ្ពស់ និងមិនធ្វេសប្រហែស ...រាជរដ្ឋាភិបាល កំពុងរៀបចំបញ្ចប់និងដាក់ចេញក្នុងពេលឆាប់ៗខាងមុខ នូវ**យុទ្ធសាស្ត្រជាតិ ស្តីពី ការរស់នៅតាមគន្លងថ្មីក្នុងបរិបទកូវីដ-១៩ ស្របតាមអភិក្រម ១) ការបើកឡើងវិញ តាមសភាពការណ៍ជាក់លាក់ ២) ការបើកឡើងវិញដោយប្រយ័ត្នប្រយែង ផ្អែកលើ**

វិសេសភាពនៃតំបន់ឬវិស័យឬអនុវិស័យនៃប្រភេទសកម្មភាពសង្គមសេដ្ឋកិច្ច ផ្សារភ្ជាប់ជាមួយវិធាននិងស្តង់ដារប្រតិបត្តិនៃសុវត្ថិភាពពីជំងឺកូវីដ-១៩ និង ៣) ការការពារភាពបត់បែនតាមរយៈការអនុវត្តយុទ្ធសាស្ត្របើកបិទ ស្របតាមសភាពការណ៍តម្រូវ ...៕

៥៩. វៀតណាមនិងថៃមានចំនួនស្លាប់ច្រើនជាងយើង តែប្រជាជនប្រទេសទាំងពីរច្រើន

បិទយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់អ្នកមានអាយុ ៦ឆ្នាំឡើង
និងបើកយុទ្ធនាការចាក់វ៉ាក់សាំងសម្រាប់ក្មេងអាយុ ៥ឆ្នាំ, ១ វិច្ឆិកា ២០២១

... នៅថ្ងៃ ២៧មករា ឆ្នាំ២០២០ យើងរកឃើញ ១ករណី លើជនជាតិចិនម្នាក់ដែលបានធ្វើដំណើរមកដល់ខេត្តព្រះសីហនុ ហើយយើងក៏បានព្យាបាលជា។ ការវិវត្តជាបន្តបន្ទាប់ ខ្ញុំនឹងលើកបញ្ហាក់នៅពេលក្រោយ។ គិតត្រឹមពីម្សិលមិញនេះ យើងមានអ្នកឆ្លងចំនួន ១១៨២២២ នាក់ និងមានអ្នកស្លាប់ចំនួន ២៨៨៨នាក់។ ដើម្បីចៀសវាងការអត្តនោម័តិណាមួយ ខ្ញុំសូមយកឱកាសនេះបញ្ជាក់ពីរបៀបសិក្សាប្រៀបធៀប។ ពេលខ្លះ ឃើញតួលេខនេះ បែរជាមានអ្នកនិយាយថា ស្លាប់ប៉ុណ្ណឹងឆ្លងប៉ុណ្ណឹង **វាតិចតួចណាស់បើប្រៀបធៀបនឹងប្រទេសដទៃ ឬក៏ស្លាប់ប៉ុណ្ណឹងឆ្លងប៉ុណ្ណឹង វាច្រើនបើប្រៀបធៀបជាមួយប្រទេសដទៃ ... និងថាវៀតណាមស្លាប់ច្រើនណាស់ ថៃស្លាប់ច្រើនណាស់។ វៀតណាមឆ្លងនិងស្លាប់ច្រើន តែប្រជាជនគាត់ច្រើន។ ថៃឆ្លងនិងស្លាប់ច្រើនជាងយើង តែប្រជាជនគាត់ច្រើន ...៕**

៦០. យកចិនជាបង្អែកប្រភពវ៉ាក់សាំង ក្រៅពីនោះជាប្រភពគាំទ្រ

បិទយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់អ្នកមានអាយុ ៦ឆ្នាំឡើង
និងបើកយុទ្ធនាការចាក់វ៉ាក់សាំងសម្រាប់ក្មេងអាយុ ៥ឆ្នាំ, ១ វិច្ឆិកា ២០២១

... យើងបើកយុទ្ធនាការ(ចាក់វ៉ាក់សាំង)ដំបូងនៅថ្ងៃទី ១០កុម្ភៈ សម្រាប់មន្ត្រីជួរមុខ។ អញ្ចឹង ៦០ម៉ឺនដូស ចាក់បានតែ ៣០ម៉ឺននាក់ទេ។ ក្រោយមក យើងបានទទួល AstraZeneca ពី COVAX ចំនួន ៣២ម៉ឺន ៥ពាន់ដូស។ ហ្នឹងហើយបានចាក់សម្រាប់មនុស្សចាស់ និងមន្ត្រីការទូតអីមួយចំនួន ... បន្តទទួលបាន AstraZeneca ហ្នឹងមកទៀត យើងក៏បើកយុទ្ធនាការចាក់វ៉ាក់សាំងជាបន្តបន្ទាប់។ សូមបញ្ជាក់ពេលនោះមានលុយហើយទិញវ៉ាក់សាំងមិនបាន ... **អញ្ចឹងយើងយកចិនជាបង្អែកឯក្រៅពីនោះគឺជាប្រភពគាំទ្រ។ ប្រសិនជាយើងរង់ចាំការសន្យារបស់ COVAX ចំនួន ៧លានដូស ហើយដែលមកដល់ពេលនេះ COVAX ទើបនឹងប្រគល់ឲ្យយើងបានតែ ៣២ម៉ឺន ៥ពាន់ បូកនឹង ១២ម៉ឺនថ្ងៃមុននេះ គឺវាទើបតែបានប្រហាក់ប្រហែលនឹងចំនួនវ៉ាក់សាំងដែលកម្ពុជាផ្តល់ជូនទៅឡាវទៅវៀតណាម ៤០ម៉ឺនដូស ...៕**

៦១. ចាក់វ៉ាក់សាំង តាមអភិក្រម "ផ្កាវីក"

បិទយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់អ្នកមានអាយុ ៦ឆ្នាំឡើង
និងបើកយុទ្ធនាការចាក់វ៉ាក់សាំងសម្រាប់ក្មេងអាយុ ៥ឆ្នាំ, ១ វិច្ឆិកា ២០២១

... ក្នុងពេលដែលយើងដំណើរការចាក់វ៉ាក់សាំងនេះទៀតសោត ក៏ប្រហែលជា**យើងអនុវត្តខុសគេខុសឯង ឬអាចនឹងប្រទេសខ្លះអនុវត្តដូចយើងដែរ ក៏មិនដឹង។ យើងចាប់ផ្តើមអនុវត្តតាមអភិក្រម "ផ្កាវីក" គឺវាយពីក្នុងចេញក្រៅ។ ខ្ញុំធ្លាប់បាននិយាយហើយថា បណ្តាខេត្តធ្វើលិខិត ឬវាយតាម WhatsApp មកខ្ញុំ សុំវ៉ាក់សាំងទៅចាក់ប៉ុណ្ណេះៗៗ។ ខ្ញុំបាន voice សម្លេងទៅថា "សូមកុំសុំ។ បើសិនជាទៅបន្តិចៗ ភាពស៊ាំសហគមន៍វាអត់កើតមាន។** កន្លែងណាក៏វាអត់"។ អញ្ចឹងបានរាល់ថ្ងៃនេះអត្រាឆ្លងនៅភ្នំពេញតិចតួចណាស់ ព្រោះវាស៊ាំទៅហើយៗ បើសិនជាឆ្លងក៏វាមិនធ្ងន់ដែរ។ ឥឡូវអ្នកឆ្លងខ្លះអត់ដឹងថាខ្លួនឆ្លងផង ទាល់តែធ្វើតេស្ត ...៕

៦២. ទិញផ្គាល់ ២៨លានដូស ក្នុងចំនួនវ៉ាក់សាំងសន្យា ៣៨.៧២៩.៩០០ដូស

បិទយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់អ្នកមានអាយុ ៦ឆ្នាំឡើង
និងបើកយុទ្ធនាការចាក់វ៉ាក់សាំងសម្រាប់ក្មេងអាយុ ៥ឆ្នាំ, ១ វិច្ឆិកា ២០២១

... ជាភ័ព្វសំណាង សហរដ្ឋអាមេរិក ជប៉ុននិងអង់គ្លេស បានផ្តល់ឲ្យបន្ថែម(បូកនឹង)ចិនឲ្យសរុបជាជំនួយគឺ ៣៧.៧២៩.៩០០ដូស (ហើយ)នឹងមកដល់នៅខែវិច្ឆិកានេះ ដោយមិនទាន់កំណត់ថ្ងៃទេ។ ១ លានដូសទៀតដែលជាជំនួយរបស់ចិន គឺយើងនឹងបាន ៣៨.៧២៩.៩០០ដូស ក្នុងពេលដែលការសន្យានានាមានដល់ទៅ ៤៧.២១៥.០០០ដូស ... ប៉ុន្តែខ្ញុំបានបញ្ជាក់ហើយបញ្ជាក់ទៀតជាមួយសហការីថាឲ្យប្រុងប្រយ័ត្ន។ **ជាចំណែកដែលយើងទិញផ្គាល់ មានចំនួន ២៨លានដូស។ អញ្ចឹង ក្នុង ៣៨លានដូស យើងទិញ ២៨លានដូស (និយាយលេខគត់) ដោយថវិការបស់យើង។ ជាភ័ព្វសំណាងដែលយើងសន្សំសាច់ប្រាក់។**

អ្នកដែលផ្តត់ផ្តង់ឲ្យយើង ចុះហត្ថលេខាភ្លាម បង់លុយឲ្យទាំងថ្លៃវ៉ាក់សាំងទាំងថ្លៃដឹកជញ្ជូន ទើបបានគេដឹកមកឱ្យ ... វ៉ាក់សាំងមិនទាន់ចុះដល់ដី ខ្ញុំមិនរាប់ចូលបញ្ជីទេ។ ហ្នឹងរបៀបរបស់ ហ៊ុន សែន ...។

៦៣. មិនទុកឲ្យអ្នកជំងឺកូវីដ១៩ មកដល់ពេទ្យរកបាយទទួលទានមិនបានទេ

បិទយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់អ្នកមានអាយុ ៦ឆ្នាំឡើង និងបើកយុទ្ធនាការចាក់វ៉ាក់សាំងសំរាប់ក្មេងអាយុ ៥ឆ្នាំ, ១ វិច្ឆិកា ២០២១

... ខ្ញុំមិនអាចឲ្យប្រជាជនសម្រាកនៅមន្ទីរពេទ្យស៊ីអត់ស៊ីឃ្លាននោះទេ។ បាយ ៣ ពេលពេញ ... **នៅភ្នំពេញ ថ្លៃជាងនៅតាមខេត្ត។ តាមខេត្តដូចមួយថ្ងៃ ៣ម៉ឺន ... មិនអាចឲ្យប្រជាជនទៅដល់មន្ទីរពេទ្យហើយ រកបាយទទួលទានមិនបាន (នោះទេ)។ ភរិយាខ្ញុំគាត់ធ្វើដល់កំរិត ... កាប់បកដូង ធ្វើមកតាមមន្ទីរពេទ្យ ឲ្យពេទ្យហ្នឹងមានកម្លាំងធ្វើការ។** ក្រុមពេទ្យស្ម័គ្រចិត្ត TYDA នេះ ក្រុមពេទ្យ(នៅមន្ទីរពេទ្យ) រុស្សីនេះ បើយើងដឹងថាពេទ្យគ្នាពិបាក។ យើងត្រូវបង្កើន(ការផ្តត់ផ្តង់)ឲ្យពេទ្យ។ សូម្បីតែហ្លួងម៉ែព្រះអង្គតែងតែពិនិត្យមើល ហើយព្រះអង្គតែងតែជួយ ...។

៦៤. ជាប្រទេសក្រីក្រ តែកម្ពុជារកបានវ៉ាក់សាំងគ្របដណ្តប់៨៥%

បិទយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់អ្នកមានអាយុ ៦ឆ្នាំឡើង និងបើកយុទ្ធនាការចាក់វ៉ាក់សាំងសម្រាប់ក្មេងអាយុ ៥ឆ្នាំ, ១ វិច្ឆិកា ២០២១

... កូវីដ-១៩ ក៏អញ្ចឹង ទាមទារការវាយតម្លៃច្បាស់។ ខ្ញុំមានមោទនភាពដោយសារយន្តការរបស់រាជរដ្ឋាភិបាល ដែលមានក្រសួងសុខាភិបាលជាសេនាធិការ និងផ្នែកពាក់ព័ន្ធផ្សេងទៀតចូលរួមវាយតម្លៃបានត្រឹមត្រូវ ... យើងមិនមែនធ្វើការម្នាក់ឯងនោះទេ។ យើងត្រូវមានជាតុចូលគ្រប់គ្រាន់ ... មិនមែនយើងធ្វើការដោយគ្មានការសិក្សា គ្មានទិន្នន័យក្នុងដៃនោះទេ ... សហការីខ្ញុំមានការងារដែលត្រូវផ្តល់។ ខ្លះគ្នាអត់បានដេកអត់បានពួនទេដើម្បីវាយតម្លៃឲ្យត្រូវ។ **ក្នុងស្ថានភាពហ្នឹង ត្រូវវាយតម្លៃខាងក្នុងយ៉ាងម៉េច ទិសដៅយ៉ាងម៉េច ការវិត្តយ៉ាងម៉េច សូម្បីតែវ៉ាក់សាំងហ្នឹង ប្រទេសប៉ុន្មានហើយដែលចាប់យករបៀបខុស ដែលមកដល់ម៉ោងនេះមានលុយហើយទិញមិនបាន ក្នុងពេលដែលកម្ពុជាជាប្រទេសមួយដ៏ក្រីក្រ ប្រព័ន្ធសុខាភិបាលទន់ខ្សោយ បែរជាអត្រាគ្របដណ្តប់ឡើងលើស ៨៥% ...។**

៦៥. កម្ពុជាឈរលំដាប់ទី១ នៅអាស៊ី និងទី៥ លើពិភពលោក ដែលចាក់វ៉ាក់សាំងបានច្រើន

សម្ពោធស្ពានមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រង់-ក្រូចឆ្មារ ... បើកការដ្ឋានសាងសង់ផ្លូវជាតិលេខ 71C, ២៣ វិច្ឆិកា ២០២១

... ប្រទេសនានាកំពុងមានការធ្វើបាតុកម្ម។ អឺរ៉ុបកំពុងធ្វើបាតុកម្មពេញបន្ទុក ... អឺរ៉ុបកំពុងបិទប្រទេសឡើងវិញ។ (ការបិទនេះ)បង្កើតបានចរន្ត២។ អ្នកមិនព្រមចាក់វ៉ាក់សាំងនៅតែបាតុកម្មមិនព្រមចាក់វ៉ាក់សាំង។ ដល់អ្នកដែលបានចាក់វ៉ាក់សាំងហើយថាខ្លួនបានចាក់វ៉ាក់សាំងហើយ ម៉េចក៏ហាមឃាត់ខ្លួនមិនឲ្យដើរ ... ឯយើងមានគោលការណ៍ថា **អ្នកមកពីត្រង់ណាក៏ដោយត្រូវតែចាក់ឲ្យ។ ហ្នឹងហើយជាចំណុចល្អ។ យើងប្រមូលផ្តុំកម្លាំងចាក់ ហើយនិងមានការចូលរួមរបស់ប្រជាជនច្រើនលើសលប់ ធ្វើឲ្យប្រទេសយើងស្ថិតនៅក្នុងលំដាប់ទី១ នៅអាស៊ី និងលំដាប់ទី៥ នៅលើពិភពលោក ដែលទទួលបានការចាក់វ៉ាក់សាំងច្រើនជាងគេ ...។**

៦៦. រាជរដ្ឋាភិបាលទទួលធ្វើតេស្តជូន, ប្រជាពលរដ្ឋម្ចាស់ការរកការធ្វើតេស្ត

សម្ពោធស្ពានមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រង់-ក្រូចឆ្មារ និងបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ 71C, ២៣ វិច្ឆិកា ២០២១

... រាជរដ្ឋាភិបាលបានផ្តល់នូវការទទួលខុសត្រូវជូនប្រជាពលរដ្ឋ ជូនទៅដល់អ្នកទេសចរ ដែលមកក្នុងប្រទេសរបស់យើង ... ប្រជាពលរដ្ឋត្រូវម្ចាស់ការខ្លួនឯង។ ដឹងថាខ្លួនអត់ស្រួល សូមទៅរកមន្ទីរពេទ្យដើម្បីឱ្យគេធ្វើតេស្តមើល តើមានវិជ្ជមាន COVID-19 ឬអត់ ? ក្នុងករណីរកឃើញថាមានវិជ្ជមាន COVID-19 សូមពិភាក្សាជាមួយគ្រូពេទ្យថាចង់ព្យាបាលនៅមន្ទីរពេទ្យ ឬក៏ទៅព្យាបាលនៅផ្ទះ? ... **យើងជាក់ការទទួលខុសត្រូវលើសុខភាពខ្លួនឯងនេះដល់ប្រជាពលរដ្ឋ ... យើងធ្វើតេស្តជូនគាត់ដោយ PCR ក្តីដោយតេស្តរហ័សក្តី។ អញ្ចឹងបងប្អូនត្រូវចាំលើចំណុចនេះ។ រាជរដ្ឋាភិបាលទទួលខុសត្រូវទៅលើការធ្វើតេស្ត។ បងប្អូនអាចធ្វើតេស្តខ្លួនឯងក៏បានដែរ ...។**

៦៧. ចលនាជាតិ ជួយរាជរដ្ឋាភិបាល ដោះស្រាយ កូវីដ-១៩

ជាក់ឱ្យប្រើប្រាស់ស្ពានមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រង់-ក្រូចឆ្មារ (ស្ពានក្តាប់និស្ស័យ) និងបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ 71C, ២៣ វិច្ឆិកា ២០២១

... យុទ្ធនាការប្រឆាំង COVID-19 (នៅកម្ពុជា មាន)នាយករដ្ឋមន្ត្រីជាអគ្គបញ្ជាការ។ ប៉ុន្តែយើងមិនត្រូវភ្លេចអំពីព្រះរាជតួនាទីដ៏សំខាន់របស់ព្រះមហាក្សត្រ និងសម្តេចម៉ែ ដែលព្រះអង្គគឺជាប្រភពនៃការលើកទឹកចិត្តដ៏ធំចំពោះរាជរដ្ឋាភិបាលចំពោះប្រជាពលរដ្ឋ ... ថ្វីត្បិតជាព្រះមហាក្សត្រដែលក្រជាងគេនៅលើពិភពលោកក៏ប៉ុន្តែព្រះអង្គយកព្រះទ័យទុកដាក់បំផុតចំពោះសុខទុក្ខរបស់ប្រជារាស្ត្រ ផ្ទេរព្រះរាជទ្រព្យឱ្យរាជរដ្ឋាភិបាល ឱ្យក្រសួងសុខាភិបាល ទិញមន្ទីរពេទ្យនិងវ៉ាក់សាំង។ នេះជាប្រភពលើកទឹកចិត្តធំណាស់ ... **ហ្លងម៉ែ ក៏បានធ្វើព្រះសកម្មភាពលើកទឹកចិត្ត។ បន្ថែមលើកនោះ អ្នកមានៗនៅក្នុងស្រុកខ្មែរ ជាឧកញ៉ា អ្នកឧកញ៉ា លោកឧកញ៉ា និងប្រជាពលរដ្ឋ បានចូលរួមទៅក្នុងការទិញវ៉ាក់សាំង ... មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធស្ម័គ្រចិត្តកាត់ប្រាក់ខែរបស់ខ្លួនចូលរួម(ជាមួយរាជរដ្ឋាភិបាលប្រយុទ្ធប្រឆាំង COVID-19)។ ទាំងអស់នេះបានក្លាយទៅជាចលនាជាតិមួយដ៏ធំរួមចំណែកដោះស្រាយ COVID-19 នៅកម្ពុជា** ...។

៦៨. វ៉ាក់សាំង ពិតជាបានជួយជីវិតមនុស្ស

សម្ពោធដាក់ឲ្យប្រើប្រាស់ ផ្លូវ ៣៧ខ្សែ ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់និងសមិទ្ធផលនានា ក្នុងក្រុង/ខេត្តព្រះសីហនុ, ២ ធ្នូ ២០២១

... ប្រទេសនានា ហាក់ដូចជាបានអនុវត្តទាំងអស់គ្នាហើយ។ អ្នកឯងមិនព្រមចាក់វ៉ាក់សាំង សូម្បីតែហាងក៏គេមិនឲ្យចូល ... ពីមុន គ្រាន់តែខ្ញុំចុះហត្ថលេខាលើអនុក្រឹត្យវ៉ាក់សាំងកាតព្វកិច្ចសម្រាប់មន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធ គេទិតៀនខ្ញុំ។ ឥឡូវលើលោកនេះ ប្រទេសនានាបានដាក់កម្រិតឲ្យចាក់(វ៉ាក់សាំង) ... ត្រូវតែរកកន្លែងចាក់ ... តាមក្រសួងតាមអី គេអត់ឲ្យចូលធ្វើការ។ គេកាត់ប្រាក់ខែ ... រំលោភសិទ្ធិមនុស្សទេហ្នឹង? ... **ប្រទេសរបស់យើង មានវ៉ាក់សាំងគឺថានាំគ្នាទៅចាក់ ... ពិតមែនហើយមានចលនាប្រឆាំងកុំឲ្យចាក់វ៉ាក់សាំង ក៏ប៉ុន្តែមិនមែនជីវិតរបស់ពួកគេទេ។ យើងស្រលាញ់ជីវិតយើង។ យើងទៅរកវ៉ាក់សាំងមានអីខុស? ឥឡូវទីចុងបំផុតវ៉ាក់សាំងបានជួយការពារជីវិតមនុស្ស** ...។

៦៩. សូមមិត្តចិនចែករំលែកការផលិតវ៉ាក់សាំង Sinovac ជាផលិតផលសំរេច

សម្ពោធដាក់ឲ្យប្រើប្រាស់ ផ្លូវ ៣៧ ខ្សែ ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់និងសមិទ្ធផលនានា ក្នុងក្រុង/ខេត្តព្រះសីហនុ, ២ ធ្នូ ២០២១

... ជួបជាមួយនាយករដ្ឋមន្ត្រីជប៉ុន។ **គាត់បានឲ្យវ៉ាក់សាំង AstraZeneca ចំនួន ១លានដូសមកហើយ។ ឥឡូវគាត់នឹងផ្តល់ឲ្យយើងចំនួន ៣០ម៉ឺនដូសទៀត។ គាត់និយាយថា នឹងពិនិត្យបន្តសម្រាប់ការផ្តល់ និងការប្រកាសផ្តល់ហិរញ្ញប្បទានសម្រាប់យើងក្នុងការគ្រប់គ្រង COVID-19។** ម្យ៉ាងទៀត ដោយបានចុះហត្ថលេខារវាងក្រុមហ៊ុននិងក្រុមហ៊ុន ព្រមទាំងមានការគាំទ្រពីរដ្ឋាភិបាលនៃប្រទេសទាំងពីរ យើងបានទទួលសិទ្ធិក្នុងការផលិតវ៉ាក់សាំងនៅក្នុងប្រទេស ដែលអាចផ្តល់លទ្ធភាពឲ្យអាចទិញយកវ៉ាក់សាំងជាផលិតផលសម្រេចមកប្រើប្រាស់ក្នុងស្រុក និងក្រុមហ៊ុនអាចនាំចេញទៅក្រៅប្រទេស។ **យើងអត់ដឹងថាពេលណាត្រូវចប់ទេ។ យើងស្ទះស្ទែងមិនត្រឹមតែដើររកទិញទេ តែបានស្នើសុំឲ្យមានការចែករំលែកពីមិត្តចិននូវការផលិតវ៉ាក់សាំងទៅជាផលិតផលសម្រេច ... យើងធ្វើ Sinovac ដែលយើងប្រើប្រាស់រាល់ថ្ងៃ** ...។

៧០. ផ្ទេរចំណែកវ៉ាក់សាំងរបស់កម្ពុជាក្នុងមូលនិធិអាស៊ាន ជូនទៅប្រជាជនមីយ៉ាន់ម៉ា

សម្ពោធដាក់ឱ្យប្រើប្រាស់កំណាត់ផ្លូវជាតិលេខ៥ ភាគខាងជើង ខេត្តបាត់ដំបងដល់ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ, ១០ មករា ២០២២

... ខ្ញុំត្រូវយកបទឈប់បាញ់សិន។ បើមិនឈប់បាញ់គ្នាទេ តើទៅជួបនរណា? ប្រជាជនមីយ៉ាន់ម៉ាកំពុងត្រូវការជំនួយមនុស្សធម៌។ ត្រូវសង្គ្រោះជីវិតមនុស្សជាមុនសិន។ **សង្គ្រោះជីវិតមនុស្សពីការកុំឲ្យស្លាប់ដោយការបាញ់គ្នា ដោយហិង្សា សង្គ្រោះជីវិតមនុស្សដោយការផ្តល់ឲ្យនូវស្បៀងអាហារថ្នាំពេទ្យ និងវ៉ាក់សាំង។ ខ្ញុំបានប្រាប់ Min Aung Hlaing នៅពេលបាយថា "វ៉ាក់សាំងបានពីមូលនិធិអាស៊ានជាចំណែករបស់កម្ពុជា មានតម្លៃប្រហែល ១លានដុល្លារ ខ្ញុំសូមផ្តល់ជូនមីយ៉ាន់ម៉ាទាំងអស់។ អាស៊ានមានសមាជិក ១០ប្រទេស គឺនឹងប្រើប្រាស់ចំរិះនោះចំនួន ១០លានដើម្បីទិញវ៉ាក់សាំងចែកគ្រប់ៗគ្នា។ កម្ពុជាមិនទទួលយកទេ។ សូមផ្ទេរ**

ចំណែករបស់ខ្លួនជូនទៅមីយ៉ាន់ម៉ា ... ទោះបីកម្ពុជាក្រ ប៉ុន្តែកម្ពុជាក៏មានបេះដូងធំទូលាយដែរ ...៕

៧១. វ៉ាក់សាំងកាតព្វកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ និងអាស៊ាន

បើកវេទិកាទេសចរណ៍អាស៊ាន២០២២ លើកទី៤០ ក្រោមប្រធានបទ «អាស៊ាន៖ សហគមន៍សន្តិភាព និងវាសនាតែមួយ», ១៨ មករា ២០២២

... សូមកោតសរសើរព្រះរាជាណាចក្រថៃ ដែលបានអនុវត្តជាមួយកម្ពុជា (នូវបដិការ)មិនធ្វើចត្តាឡីស័ក លើប្រជាជនកម្ពុជាដែលទៅប្រទេសថៃ ដូចគ្នាដែលយើងមិនធ្វើចត្តាឡីស័កចំពោះប្រជាជនថៃដែលមកកម្ពុជា។ ក្រោយមកយើងបើកក្របខណ្ឌទូទាំងពិភពលោក **មិនធ្វើចត្តាឡីស័កនោះទេ លើកលែងតែអ្នកមិនទទួលបានការចាក់វ៉ាក់សាំង។ វាមិនមែនជាទណ្ឌកម្មចំពោះអ្នកដែលមិនបានចាក់វ៉ាក់សាំងនោះទេ ក៏ប៉ុន្តែយើងមានតម្រូវការការពារប្រជាពលរដ្ឋ ទាំងប្រជាពលរដ្ឋកម្ពុជា ទាំងប្រជាពលរដ្ឋនៅក្នុងក្របខណ្ឌអាស៊ាន។ អ្នកណាមិនបានទទួលការចាក់វ៉ាក់សាំង អ្នកនោះមិនអាចធ្វើដំណើរបានទេ។ អាចចាត់ទុកថា ខ្ញុំជាអ្នកដែលបាននិយាយរឿងនេះដំបូងគេ គឺនិយាយអំពីវ៉ាក់សាំងកាតព្វកិច្ច** ...៕

៧២. ចាក់វ៉ាក់សាំងដោយមិនគិតប្រាក់ដល់ជនបរទេសនៅស្រុកខ្មែរ

សម្ពោធកំណាត់ផ្លូវជាតិលេខ៧ ពីរង្វង់មូលខ្លាស្នុះ ទៅឃុំរមាត ខេត្តក្រចេះ, ៧ កុម្ភៈ ២០២២

... ប្រទេសខ្លះបានឈានដល់កម្រិតអនុវត្តវិធានការរដ្ឋបាលនិងច្បាប់ ដោយមានផាកពិន័យ ឬបណ្តេញចេញពីការងារលើអ្នកដែលមិនព្រមចាក់វ៉ាក់សាំង។ នៅទីនេះ យើងបានចាក់ជូនប្រជាពលរដ្ឋដោយមិនយកប្រាក់។ **មានបងប្អូនខ្លះបានលើកយោបល់ថា ចាក់ជូសទី១ ជូសទី២ រួចហើយជូសទី៣ ដល់ជូសជំរុញ គួរយកប្រាក់។ ខ្ញុំថា សម្រាប់ប្រជាពលរដ្ឋរបស់យើងចាក់អោយទៅ កុំចាំបាច់យកលុយ ហើយបើសិនជាយកមក ក៏យើងមិនក្លាយទៅជាអ្នកមានដែរ** ... ថ្ងៃមុន ឯកអគ្គរដ្ឋទូតបារាំងបានស្នើសុំ Pfizer សម្រាប់ចាក់ ៦ពាន់នាក់ ក្នុងហ្នឹងរាប់ទាំងការចាក់ឲ្យក្មេងផង ពីជូសទី១ ... ក្នុងករណីដែលយើងមិនអាចផ្តល់ឲ្យបាន បារាំងនឹងស្នើសុំនាំចូល Pfizer និង Moderna។ **ខ្ញុំប្រាប់ទៅលោកជំទាវ ឱ វណ្ណឌីន ថាចាក់**

ឲ្យទៅ ទាំងជូសជំរុញ ទាំងជូសមូលដ្ឋាន ចាក់ឲ្យទាំង ៦ពាន់នាក់។ ខ្មែរទឹកចិត្តទូលំទូលាយ ជនបរទេសនៅស្រុកខ្មែរៗ អត់យកលុយមួយសេន ...៕

៧៣. សូមអ្នកលក់ថ្នាំព្យាបាលកូវីដ១៩ កុំដំឡើងថ្លៃ និងកុំក្លែងក្លាយ

បើកការដ្ឋានសង់ស្ពានីយប្រព្រឹត្តិកម្មទឹកកខ្វក់បឹងដើងឯក ក្របខណ្ឌហិរញ្ញប្បទានឥតសំណងប្រទេសជប៉ុន, ២២ កុម្ភៈ ២០២២

... សូមអំពាវនាវទៅអ្នកលក់ថ្នាំទាំងឡាយ ត្រូវបង្កើនសមត្ថភាពនៃការផ្គត់ផ្គង់ថ្នាំមកបន្ថែមទៀត ប៉ុន្តែសូមឱ្យ**យកចិត្តទុកដាក់ទៅលើចំណុច ២យ៉ាង អំពីបញ្ហាថ្នាំព្យាបាល។ ទី១ តម្លៃថ្នាំកុំបង្កើនទៅតាមចិត្តចង់។ ឥឡូវឃើញបន្តកន្ទុយគ្នាទៅទិញថ្នាំ ព្រោះប្រជាពលរដ្ឋមានសមត្ថភាពដើម្បីនឹងទិញថ្នាំខ្លួនឯង។ បើនៅក្នុងមន្ទីរពេទ្យ គឺពេទ្យព្យាបាលហើយមិនអីទេ។ ប៉ុន្តែ ខ្លះគេមិនចង់ទៅមន្ទីរពេទ្យ គេទិញថ្នាំ(ខ្លួនឯង)។ អញ្ចឹងកន្លែងលក់ថ្នាំដែលទទួលបានការអនុញ្ញាត កុំតម្លើងថ្លៃទៅតាមចិត្តចង់។ ទី២ ផ្នែកសុខាភិបាលត្រូវតែពិនិត្យមើលថា ថ្នាំហ្នឹងសុទ្ធ ឬមិនសុទ្ធ ព្រោះថ្នាំក្លែងក្លាយនេះកើតឡើងច្រើនណាស់**។ សូម្បីតែអាល់កុលក៏ក្លែងក្លាយដែលក៏ក្លែងក្លាយ ស្អីដាក់មកគឺវាក្លែងក្លាយទាំងអស់ ...៕

៧៤. បន្តព្យាបាល/ចាក់ថ្នាំមអ្នកជំងឺកូវីដ-១៩ នៅមណ្ឌលចត្តាឡីស័ក ឧបត្ថម្ភប្រជាពលរដ្ឋក្រីក្រងាយរងគ្រោះ

បិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ, ២៣ កុម្ភៈ ២០២២

... មិនដឹងពេលណាដែលយើងត្រូវឈប់ប្រើវ៉ាក់សាំងទេ។ យើងត្រូវមានលុយត្បិតមិនអាចខ្ចីបុលគេ ឬទៅទិញបណ្តាក់ពីគេបានទេ។ សាច់លុយទៅទាំងដុលតែម្តង។ **ប្រជាពលរដ្ឋដែលយើងត្រូវចំញឹមចំណាយក្នុងមួយខែជិត ៤០លានដុល្លារនេះ ក៏ត្រូវតែបន្តចំញឹមគាត់តទៅទៀត។ ការចំណាយលើការព្យាបាលអ្នកជំងឺនៅមណ្ឌលថែទាំជំងឺកូវីដ-១៩ និងបណ្តាមណ្ឌលចត្តាឡីស័កត្រូវតែមានការចំញឹមឲ្យបានត្រឹមត្រូវ និងមានថ្នាំ។ ឥឡូវថ្នាំកាន់តែល្អ។** យើងបញ្ជាទិញមក។ ថ្ងៃហ្នឹងឲ្យបញ្ចេញ(ចរិកា) ដោយសារតែថ្នាំដែលយើងដាក់ទៅតាមមូលដ្ឋាន តាម

ឱសថស្ថាន និងកន្លែងលក់មួយចំនួនខ្វះ ... ថ្នាំសម្រាប់អ្នកដំងឺកូវីដ-១៩ ព្រោះមិនមែនចេះតែងាយស្រួលទិញទេ។ ជួនកាលមានលុយហើយទិញមិនបានទៀត...៕

៧៥. គ្រោកូវីដ១៩ វិស័យសុខាភិបាលប្រយុទ្ធនឹងមុខព្រួញ៣ ក្នុងពេលតែមួយ

សន្និសីទសារព័ត៌មានស្តីអំពីបច្ចុប្បន្នភាពនៃជំងឺកូវីដ១៩, ៧ មេសា ២០២០

និយាយដល់ការប្រយុទ្ធ(នឹងកូវីដ១៩)បន្ត តើយើងកំពុងប្រយុទ្ធរបៀបម៉េចនៅពេលនេះ? អាចនិយាយតាមមួយបែបជារបៀបយោធា ទោះបីវាជាវិស័យវេជ្ជសាស្ត្រ។ **យើងកំពុងបន្តប្រយុទ្ធលើមុខព្រួញបីក្នុងពេលតែមួយ ... ទី១ ប្រយុទ្ធជាមួយនឹងការឆ្លងចូលមកពីខាងក្រៅ។** នេះជាបញ្ហាសំខាន់ជាងគេ។ យើងបានឃើញហើយ អ្នកឆ្លងមកដល់ពេលនេះមាន ១១៥នាក់ ក្នុងនេះជាប្រភេទនាំចូលស្ទើរតែទាំងអស់ (នាំឱ្យ)មានការឆ្លងនៅក្នុងស្រុក ... **ទី២ ប្រយុទ្ធទប់ស្កាត់កុំឱ្យឆ្លងពីអ្នកកើតទៅអ្នកមិនទាន់កើត។** នេះគឺជាវិធានការដែលយើងបាន និងកំពុងធ្វើ ហើយត្រូវបន្តធ្វើតទៅទៀត។ យើងមានវិធានការច្រើនហើយ ដូចជាការបិទសាលារៀនឱ្យវ៉ាកងមុនការកំណត់ ... ឯមុខព្រួញ**ទី៣ បន្តព្យាបាលអ្នកឆ្លងឱ្យជាសះស្បើយ។ ការងារនេះយើងធ្វើបានល្អ។** តាមខ្ញុំដឹង មានក្រុមមួយចង់សរសេរសំបុត្ររបៀបចង់ផ្ញាញ់ ទៅអង្គការសុខភាពពិភពលោក(សួរ)ថា តើកម្ពុជាប្រើថ្នាំអីបានព្យាបាលជា? ... ខ្ញុំថា "ទុកឱ្យអង្គការសុខភាពពិភពលោកឆ្លើយ" ...៕

៧៦. បានចាក់វ៉ាក់សាំងជាង៩២% នៃចំនួនត្រូវចាក់ ១៤,៨ ក្នុងចំណោម ១៦លាននាក់

សម្ពោធដាក់ឲ្យប្រើប្រាស់អគារមិត្តភាព កម្ពុជា-កូរ៉េ នៃមន្ទីរពេទ្យអង្គឌួង មន្ទីរពេទ្យសម្រាប់ការព្យាបាលត្រចៀក ច្រមុះ និងបំពង់ក, ២៨ មីនា ២០២២

...បើប្រៀបធៀបកាលពីឆ្នាំមុន យើងលំបាកណាស់ ហត់នឿយណាស់ ហើយត្រូវតាមដានជាប់សភាពការណ៍ក្នុងមួយថ្ងៃៗ ពិសេសពេលដែលអត់ទាន់មានវ៉ាក់សាំងចាក់។ យើងទើបចាប់ផ្តើមដំណើរការវ៉ាក់សាំងតិចតួចក្នុងពេលដែលមកដល់ដំបូង គឺវ៉ាក់សាំងដែលមកតាមរយៈ COVAX នៃអង្គការសុខភាពពិភពលោក។ យើងមានចំនួនតិចតួច។ យើងមាន Sinopharm មកពីចិនក្នុងចំនួនតិចតួច។ ក៏ប៉ុន្តែឥឡូវនេះ **យើងចាក់វ៉ាក់សាំងសម្រាប់ប្រជាពលរដ្ឋយើងដល់ទៅជាង ៩២% នៃចំនួនដែលយើងត្រូវចាក់គឺ ១៤លាន ៨សែននាក់ជាងក្នុងចំណោមមនុស្ស ១៦**

លាននាក់ដែលត្រូវចាក់វ៉ាក់សាំង។ ភាពស៊ាំសហគមន៍នេះបានកាត់បន្ថយការឆ្លងឬឆ្លងហើយតែវាមិននាំទៅដល់ភាពធ្ងន់ធ្ងរនោះទេ ...៕

៧៧. មេបញ្ជាការក្នុងការប្រយុទ្ធជាមួយកូវីដ-១៩ មិនបំភ័យកូនទាហានខ្លួនទេ

ជួបសំណេះសំណាលជាមួយក្រុមគ្រូពេទ្យសម្តេចតេជោប្រឆាំងកូវីដ-១៩, ១៧ ឧសភា ២០២២

... ការដែលយើងបានមកដល់ពេលនេះ មិនមែនជារឿងលេងសើចទេ។ ឆ្លងកាត់រឿងរ៉ាវច្រើន។ គេចាត់ទុកថាប្រព័ន្ធសុខាភិបាលយើងទន់ខ្សោយ ... គេបានមើលស្រាលយើង ខណៈដែលខ្ញុំធ្វើដំណើរទៅប្រទេសចិន។ បន្ទាប់ទៅខ្ញុំទទួលនាវាទេសចរ Westerdam។ សូម្បីតែកម្មវិធីគ្រោងទុកថានឹងជួបគ្នាហើយ គេអត់ជួបយើង(ទេ) ... **តើឱ្យមេបញ្ជាការខ្ពស់បំផុតក្នុងការប្រយុទ្ធជាមួយនឹងកូវីដ-១៩ បំភ័យកូនទាហានខ្លួនឯងកើតទេ? មិនដឹងកូវីដ-១៩ នៅឯណាផង នាំគ្នាពាក់ម៉ាស។ ក្នុងប្រជុំអ្នកសារព័ត៌មាន ខ្ញុំថា "នរណាពាក់ម៉ាស សូមចេញពីកន្លែងហ្នឹង"។** ពេលហ្នឹង មិនមែនជាពេលវេលាត្រូវពាក់ម៉ាសឯណា ... ខ្ញុំនិយាយដំងឺពិតប្រាកដនៅកម្ពុជា មិនមែនកូរ៉ូណាទេ។ ពេលហ្នឹងមិនទាន់មានឈ្មោះកូវីដ-១៩។ មិនមែនកូរ៉ូណាបំភ័យទេ ប៉ុន្តែ ជាដំងឺភ័យខ្លាច(ទេ)តើ ...៕

៧៨. ទើបតែឈ្នះសមរភូមិ Delta, Alpha, Omicron ប៉ុន្តែមិនទាន់ឈ្នះកូវីដ-១៩

ជួបសំណេះសំណាលជាមួយក្រុមគ្រូពេទ្យសម្តេចតេជោ ប្រឆាំងកូវីដ-១៩, ១៧ ឧសភា ២០២២

... ក្នុងវិស័យសុខាភិបាល មិនអាចធ្វើតាមដូចវិស័យអប់រំទេ។ វិស័យអប់រំ(អាចអនុវត្តអភិក្រម) "អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកអត់ចេះ"។ ចំពោះវិស័យសុខាភិបាល មិនអាចបណ្តោយ(អោយអនុវត្តអភិក្រមហ្នឹង)បានទេ ... ជាគោលការណ៍ ខ្ញុំបានផ្តាំផ្ញើតាំងពីដើមទីថា "បើគ្មានសម្ភារៈការពារខ្លួនពេញលេញទេ មិនអនុញ្ញាតឱ្យចេញប្រយុទ្ធ" ... **ដូច្នេះ តាំងពីដើមទី ខ្ញុំឱ្យទិញ(សម្ភារៈការពារ)សម្រាប់ក្រុមគ្រូពេទ្យរបស់យើង ដោយមិនអនុញ្ញាតឱ្យធ្វើតាមរបៀបក្រុមគ្រូពេទ្យប្រទេសជឿនលឿនមួយចំនួន ដែលខ្វះទាំងម៉ាសពេទ្យ**

សម្រាប់ពាក់នោះទេ ... យើងទើបនឹងឈ្នះលើសមរភូមិ Delta Alpha Omicron ប៉ុន្តែមិនទាន់ឈ្នះ កូវីដ-១៩ ទេ ...៕

៧៩. មិនមានអ្នកជំងឺកូវីដ-១៩ ដេកតាមចិញ្ចើមផ្លូវ ឬសពបូជាដោយគ្មានមឈូស

សំណេះសំណាលជាមួយសហគមន៍ខ្មែរនៅទ្វីបអឺរ៉ុប, ២១ ឧសភា ២០២២

... មានពេលមួយ ខ្ញុំព្រះករុណាខ្ញុំអាណិតប្រជាជន មិនដឹងថាត្រូវធ្វើម៉េច។ ប៉ុន្តែពាក្យថាចុះចាញ់គឺគ្មាន។ ការបិទខ្ទប់ វាមិនមែនជាការងាយស្រួលទេ ... ប៉ុន្តែយើងអត់មានជម្រើសឱ្យល្អជាងនេះ។ តម្រូវឱ្យបិទទីក្រុងភ្នំពេញ។ ផ្អាកចូលឆ្នាំឆ្នាំ២០២០ម្តង ហើយឆ្នាំ២០២១ ម្តងទៀត។ តើដើម្បីអ្វី? គឺដើម្បីការពារជីវិតប្រជាជន។ នៅក្នុងរង្វង់ម៉ោងប្រហែលជា ៩យប់ ខ្ញុំព្រះករុណាខ្ញុំបានប្រើប្រាស់ទូរស័ព្ទដើម្បីចេញសារសម្លេង ... ថាយើងកំពុងតែស្ថិតនៅមាត់ជ្រោះមរណៈហើយ សូមអំពាវនាវប្រជាពលរដ្ឋយើងយោគយល់ ... តែសូមក្រឡេកមើល**ទោះបីជាកម្ពុជាជាប្រទេសក្រ តែយើងអត់ទាន់មានអ្នកជំងឺ (កូវីដ-១៩) ដេកនៅតាមឥដ្ឋការ៉ូទេ ដេកតាមចិញ្ចើមផ្លូវទេ។ អត់មានសាកសពណាមួយដែលមិនបានធ្វើការបូជា ឬគ្មានក្តារមឈូសទេ ...៕**

៨០. ក្រសួងសុខាភិបាលរួមទាំងកងទ័ព ជួយបង្កើតកន្លែងផលិតអុកស៊ីសែន

សម្ពោធដាក់ឲ្យប្រើប្រាស់មន្ទីរពេទ្យបង្អែកស្រុកក្រូចឆ្មារ, ខេត្តត្បូងឃ្មុំ,
៣ មេសា ២០២៣

... តើនៅចាំបានទេ។ ព័ត៌មានទាក់ទងនឹងប្រជាជនឥណ្ឌា។ នៅពេលដែលផ្ទុះឡើងនូវជំងឺកូវីដ-១៩ ប្រទេសឥណ្ឌាផលិតអុកស៊ីសែនមិនទាន់សម្រាប់ឆ្លើយតបនឹង(តម្រូវការ)ប្រជាជនដែលកើតកូវីដ-១៩ ក៏ត្រូវដឹកអុកស៊ីសែនពីប្រទេសដទៃមកជួយផ្គត់ផ្គង់។ **ឃើញស្ថានភាពបែបនេះ ខ្ញុំផ្ទាល់បានផ្តល់ការណែនាំឱ្យក្រសួងសុខាភិបាល រួមទាំងកងទ័ព ចុះជួយរៀបចំដើម្បីបង្កើតទីកន្លែងផលិតអុកស៊ីសែននៅតាមទីកន្លែង ចៀសវាងការលំបាក។ តែដល់ពេលមានតម្រូវការ ហើយអ្នកជំងឺទាមទារនូវការដាក់អុកស៊ីសែនជំនួយការដេកដង្ហើម**។ បើគ្មានអុកស៊ីសែនគឺវានឹងរុញច្រានអ្នកជំងឺទៅរកមរណភាព ដែលជារឿងគួរឱ្យសោកស្តាយ។ យើងបានខិតខំពង្រឹងនូវសមត្ថភាពមន្ទីរពេទ្យនានា...។

៨១. ឆ្លងវាលសង្គ្រាម និងវាលឧស្ម័កក្បួចហើយ កំពុងឆ្លងវាលទីបីគឺជំងឺជង្គាត់

សម្ពោធអគារសម្ភពក្នុងបរិវេណនៃពេទ្យកុមារជាតិភ្នំពេញ,
២០ មេសា ២០២៣

... ក្រោយចូលឆ្នាំខ្មែរនេះ មិនមានហានិភ័យកើតឡើងទេ ក៏ប៉ុន្តែខ្ញុំនៅតែបន្តអំពាវនាវថា អ្នកដែលគិតថាខ្លួនមានបញ្ហា(សុខភាព) គួរតែពិនិត្យខ្លួនឯងយ៉ាងម៉េច។ យើងដាក់បន្ទុកទៅឱ្យសាមីខ្លួនម្នាក់ៗវិញ បូករួមនឹងការទទួលខុសត្រូវតាមដានហ្មត់ចត់ពីក្រសួងសុខាភិបាល **អំពីការវិឌ្ឍប្រែប្រួលនៃស្ថានភាពសុខភាពសាធារណៈ ... ការប្រែប្រួលអាកាសធាតុនៅលើពិភពលោក កំពុងតែបង្កើតជាបញ្ហាធំណាស់អំពីជំងឺជង្គាត់។ ចាស់ៗខ្មែរតែងពោលថា «ហែលឆ្លងវាលបី»។ យើងបានហែលឆ្លងវាលពីរួចហើយ ប៉ុន្តែវាលទីបីនេះ ខ្ញុំគិតថាមិនងាយឆ្លងរួចទេ។ ស្តីទៅវាលបីនោះ? វាលទីមួយគឺសង្គ្រាម។ យើងបានហែលឆ្លងរួចហើយ។ ឯវាលទីពីរ គឺគ្រោះទុរភិក្ស។ យើងក៏បានហែលឆ្លងការអត់ឃ្លានហើយដែរ។ ឯវាលទីបី គឺជំងឺជង្គាត់នេះឯង។ មិនងាយហែលឆ្លងរួចទេ។** សូម្បីតែអាកាសធាតុក៏ជាចំណោទដែលត្រូវយកចិត្តទុកដាក់នៅពេលខាងមុខនេះ ...៕

៨២. បើផ្ទេរលុយផលិតអាវុធ មកផលិតថ្នាំ/ឧបករណ៍ពេទ្យ ប្រជាជននឹងបានផលធំ

សម្ពោធអគារសម្ភពក្នុងបរិវេណនៃពេទ្យកុមារជាតិភ្នំពេញ,
២០ មេសា ២០២៣

... បើនៅលើពិភពលោក (ប្រទេសនានា)យកលុយទាំងឡាយដែលប្រើប្រាស់លើអាវុធ មកផលិតថ្នាំពេទ្យលក់ចែកចាយការពារសុខភាពប្រជាពលរដ្ឋ មិនដឹងថាតម្លៃឱសថនៅលើពិភពលោកនឹងធ្លាក់ចុះ(ទាបដល់ណាទេ)។ ប៉ុន្តែ ប្រទេសនិមួយៗ គិតតែរត់ប្រណាំងគ្នារឿងបង្កើនកម្លាំងទាហាន បង្កើនសព្វាវុធសម្រាប់កម្ទេចគ្នាទៅវិញទៅមក។ ចាយលុយអស់ច្រើនណាស់។ **បើសិនជាលុយហ្នឹងផ្ទេរតែ៥០ ភាគរយមកផលិតថ្នាំពេទ្យ ឧបករណ៍ពេទ្យ លក់នៅលើពិភពលោកបានថោកជាងត្រឹមតែ៥០ ភាគរយ ប្រជាជននៅលើពិភពលោកនឹងទទួលបាននូវផលប្រយោជន៍ធំណាស់។** ប៉ុន្តែ ប្រទេសនានាមិនបានគិតអញ្ចឹងទេ។ គេគិតតែពីរឿង

បើមួយពូកែខាងនេះ ត្រូវរកវិធីម៉ែចផលិតខាងនោះ ... អ្នកដែលចំណេញពិតប្រាកដគឺអ្នកផលិតអាវុធ។ ឥឡូវអាវុធវាបានដើរបំផ្លាញជីវិតមនុស្ស ...។

៨៣. ការទប់ជំងឺកូវីដ-១៩ ស្រាយគ្រោះមហន្តរាយ បង្ហាញជោគជ័យកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឬប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ

បិទវគ្គបណ្តុះបណ្តាលឆ្នាំ២០២២ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០២៣
សាលាភូមិន្នរដ្ឋបាល, ២៧ មេសា ២០២៣

... យើងបានទទួលផលជាបណ្តើរៗហើយ **ពីការកែទម្រង់មុខងារសាធារណៈ ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់ទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការ ... ជោគជ័យក្នុងដោះស្រាយជំងឺកូវីដ-១៩ គ្រោះមហន្តរាយដូចជាគ្រោះទឹកជំនន់និងរាំងស្ងួត ខ្យល់កន្ត្រាក់ បានចង្អុលបង្ហាញឱ្យឃើញថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឬហៅថា ប្រជាធិបតេយ្យថ្នាក់ក្រោមជាតិនោះ គឺបានទទួលផលហើយ**។ បើទោះបីថាវាមិនស្មើគ្នា ក៏ប៉ុន្តែអាចនិយាយបានថាជាតិទាំងមូលបានទទួលផលពីការផ្ទេរអំណាចពីថ្នាក់ជាតិទៅឱ្យថ្នាក់មូលដ្ឋាន ...។

៨៤. គ្រប់គ្រងកូវីដ១៩ កែទំរង់វិស័យសុខាភិបាល ផ្ទេរអំណាច ថវិកានិងមន្ត្រីទៅមូលដ្ឋាន

បិទវគ្គបណ្តុះបណ្តាលឆ្នាំ២០២២ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០២៣,
សាលាភូមិន្នរដ្ឋបាល, ២៧ មេសា ២០២៣

... យើងធ្វើការពិនិត្យមើល(ឡើងវិញ)។ ប្រសិនបើពេលនោះ យើងមិនធ្វើការកែទម្រង់ មិនផ្តល់ឱកាសឱ្យមូលដ្ឋានទេ សួរថា តើយើងមានលទ្ធភាពគ្រប់គ្រងសភាពការណ៍កូវីដ-១៩ បានទេ? ពិតជាមិនបានទេ។ តើថ្នាក់កណ្តាលអាចនឹងធ្វើដំណើរទៅដល់គ្រប់ទីកន្លែងទេ? ខ្ញុំព្រះករុណាខ្ញុំនៅចាំថា **ក្នុងពេលយុទ្ធនាគ្រប់គ្រងកូវីដ-១៩ យើងបានធ្វើកំណែទម្រង់ក្នុងវិស័យសុខាភិបាល ផ្ទេរអំណាចឱ្យបានកាន់តែច្រើនទៅថ្នាក់ក្រោមជាតិ។ នោះហើយជាសមិទ្ធផលដែលកើតចេញពីការកែទម្រង់ការគ្រប់គ្រង ដោយផ្ទេរអំណាចទៅឱ្យមូលដ្ឋាន ផ្ទេរទាំងថវិកា ផ្ទេរទាំងមន្ត្រីរាជការទៅឱ្យមូលដ្ឋាន។ បើសិនជាពេលនោះ យើងមិនបានមិនដោះស្រាយឱ្យហើយ អ្វីក៏ខាងលើទៅធ្វើជួស ច្បាស់ជាទៅមិនរួចទេ ...**។

៨៥. អាហារូបត្ថម្ភនិងកុមារលូតលាស់ប្រសើរ បន្តយអត្រាមរណភាពនៃមាតានិងទារក

ពិធីសំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ក្រុងតាខ្មៅ, ៧ មីនា ២០១៨

... ពួយកចិត្តទុកដាក់លើការអនុវត្ត(គោលនយោបាយសង្គម)សម្រាប់ស្ត្រីមានផ្ទៃពោះមុនគេ ប៉ុន្តែលទ្ធភាពថវិការបស់យើង អាចធ្វើបានជាមួយកម្មការិនីទាំងសេដ្ឋកិច្ចក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធជាមុន ដោយត្រូវចំណាយខ្ជង់ ១០លានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ ... **យើងនឹងពិនិត្យមើលបញ្ហានេះនៅពេលក្រោយទៀត (ដើម្បីបញ្ជាក់ថា)ការធានាសុខុមាលភាព អាហារូបត្ថម្ភ និងការរីកលូតលាស់នៃកុមារនិងទារកនឹងមានស្ថានភាពកាន់តែប្រសើរ ហើយអត្រាស្លាប់មាតានិងទារក នឹងត្រូវបានកាត់បន្ថយជាបន្តទៀត ដែលជាផ្នែកមួយនៃកិច្ចគាំពារសង្គម ឬសំណាញ់សុវត្ថិភាពសង្គម ...**។

៨៦. គោលនយោបាយគាំពារសង្គមជាអត្រែកនៃលោកគ្រូពេទ្យ/មន្ទីពេទ្យរដ្ឋ

សម្ពោធអគារ «អគារតេជោសន្តិភាព» នៅមន្ទីរពេទ្យកាល់ម៉ែត,
១៥ មករា ២០១៨

...គោលនយោបាយគាំពារសង្គមថ្មីរបស់យើងបានក្លាយទៅជាអត្រែកដ៏ធំមួយសម្រាប់គ្រូពេទ្យនៃមន្ទីរពេទ្យរដ្ឋទាំងអស់ ក្នុងការអនុវត្ត ដែលក្នុងនោះ កម្មកទាំងក្នុងនិងក្រៅប្រព័ន្ធ ប្រមាណជាជាង ៣លាននាក់ ត្រូវបានដាក់ឲ្យនៅក្រោមមូលនិធិសមធម៌ ដែលទទួលការពិនិត្យ និងព្យាបាលដោយឥតគិតថ្លៃពីមន្ទីរពេទ្យរដ្ឋ ... ប្រហែលជាទាំងអស់គ្នាអាចនៅចាំបានថា ពេលដែលសម្ពោធកម្មវិធីនយោបាយគាំពារសង្គមខ្ញុំបានទាញចំណាប់អារម្មណ៍ប្រធានគណៈកម្មការគោលនយោបាយសេដ្ឋកិច្ច ... ឲ្យយកចិត្តទុកដាក់ទៅលើស្ត្រីមានផ្ទៃពោះ ...។

២៨. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក)

១	កម្ពុជាខ្មែចខ្ចាំដោយអំពើប្រល័យពូជសាសន៍ ហើយត្រូវទណ្ឌកម្មអយុត្តិធម៌ថែមទៀត	៦២៧
២	ធ្លាប់ជួបហើយ ប្រទេសតាំងខ្លួនប្រជាធិបតេយ្យ តែគាំទ្ររដ្ឋប្រហារយោធា	៦២៧
៣	ប្រទេសធ្លាប់ទទួលស្គាល់ខ្មែរក្រហម គប្បីទទួលព្រមថានយោបាយខ្លួនខុស	៦២៨
៤	សូមបរទេស "កុំកសាងកំហុសទី៣" មកលើកម្ពុជា	៦២៨
៥	ពេលខ្មែរក្រហមខ្លាំង គ្មានអ្នកនិយាយពីកាត់ទោស ឬឈប់ទទួលស្គាល់នៅអស្សប	៦២៩
៦	កន្លែងសំគ្កិសមរបស់ខ្មែរក្រហម គឺការកាត់ទោសនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ...	៦២៩
៧	ភាគីវាយខ្មែរក្រហម រក្សាជំហរឱ្យមានការកាត់ទោសខ្មែរក្រហម តាំងពីដើមដល់ចប់	៦៣០
៨	ពី "ទប់ស្កាត់ ... របបប្រល័យពូជសាសន៍" មកត្រឹម "ទប់ស្កាត់ ... អំពើពីអតីតកាលថ្មីៗ"	៦៣០
៩	ការកាត់ទោសខ្មែរក្រហមឆ្លងកាត់ ៣អគ្គលេខាធិការអង្គការសហប្រជាជាតិ	៦៣១
១០	បើពង្រាយការចោទប្រកាន់ ការកាត់ទោសនឹងមិនអាចចប់	៦៣២
១១	សុខចិត្តឲ្យតុលាការបរាជ័យ តែមិនឲ្យប្រទេសកម្ពុជាមានសង្គ្រាមឡើងវិញទេ"	៦៣២
១២	ប៉ុល ពត ... មិនចូលរួមបោះឆ្នោត បានផ្តល់ជោគជ័យឲ្យនយោបាយឈ្នះឈ្នះ	៦៣៣
១៣	ការបញ្ចប់សង្គ្រាមដោយភាគីម្ខាងចុះចូលដល់ផ្ទះ មិនទាន់មានទេលើពិភពលោក	៦៣៤
១៤	ទទួលយកការចុះចូលនៃមេដឹកនាំខ្មែរក្រហមដល់ផ្ទះ គឺដើម្បីជូនសារ៣	៦៣៤
១៥	ការកាត់ទោសខ្មែរក្រហមមានន័យថា "កម្ពុជាមានរបបប្រល័យពូជសាសន៍ពិតមែន"	៦៣៥
១៦	ទទួលស្គាល់ការកាត់ទោសខ្មែរក្រហម បាននិយាយថាការផ្តួលរំលំ ប៉ុល ពត គ្មានអ្វីខុស	៦៣៥
១៧	យកទីបញ្ជាការកងទ័ពជើងគោកជាសាលាក្តីខ្មែរក្រហម ការពារសុវត្ថិភាពពិរុទ្ធជន	៦៣៦
១៨	កាត់ទោសមេដឹកនាំខ្មែរក្រហម ដោយកម្ពុជាធ្វើម្ចាស់ ដោយច្បាប់/តុលាការកម្ពុជា	៦៣៧
១៩	រៀបចំតុលាការតាមច្បាប់កម្ពុជា ស៊ីសង្វាក់នឹងកិច្ចព្រមព្រៀងអនុម័តដោយUNSC	៦៣៧
២០	ផ្តួលរំលំ ទប់ស្កាត់ រំលាយអង្គការចាត់តាំង ប៉ុល ពត នាំមកនូវសន្តិភាព/យុត្តិធម៌	៦៣៨
២១	ពិនិត្យការសំរេចស្តីពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បង្ហាញមហន្តរាយជាថ្មី	៦៣៨
២២	រួមគ្នាផ្សព្វផ្សាយឱ្យបានទូលំទូលាយសំណុំរឿងជំនោគជ័យនៃសាលាក្តីខ្មែរក្រហម	៦៣៩
២៣	បើមិនទទួលស្គាល់ថាមានរបប ប៉ុល ពត ស្មើនឹងជា ប៉ុល ពត	៦៣៩
២៤	បើសម្លាប់មនុស្សគ្មានកំហុសមិនមែនប្រល័យពូជសាសន៍ លើលោកនេះគ្មានច្បាប់ទេ	៦៤០
២៥	សាលក្រមតុលាការបញ្ចប់ល្បែងភ្នែលទោសទាំងខ្មែរក្រហមទាំងអ្នកវាយខ្មែរក្រហម	៦៤០

២៦	**គួរមានច្បាប់ដាក់ទោសជនណាថ្លែងថា "កម្ពុជាគ្មានអំពើប្រល័យពូជសាសន៍" ឬទេ**	**៦៤១**
២៧	**ការបញ្ចេញមតិមានចរិតគាំពារបបប្រល័យពូជសាសន៍ គួរតែត្រូវមានទោស**	**៦៤១**
២៨	**ដាក់ទោសការនិយាយមិនពិតពីប្រល័យពូជសាសន៍សំរួលការសរសេរប្រវត្តិសាស្ត្រ**	**៦៤២**

១. កម្ពុជាខ្វេចខ្វាំដោយអំពើប្រល័យពូជសាសន៍ ហើយត្រូវទណ្ឌកម្មអយុត្តិធម៌ថែមទៀត

កិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិក ឆ្នាំ២០១៩ នៅកម្ពុជា, ១៩ វិច្ឆិកា ២០១៩

... ទិដ្ឋភាពនៅទីក្រុងភ្នំពេញដ៏រស់រវើក ហាក់ដូចជាកម្ពុជាគ្មានជួបប្រទះរឿងអ្វីក្នុងអតីតកាលនោះទេ ដោយសារតែ(គេមើលថា)ជីវភាពប្រជាជនសព្វថ្ងៃធម្មតាដូចប្រទេសគេឯង។ ខ្ញុំសូមជំរាបថា នៅឆ្នាំ១៩៧៩ ពេលដែលចូលមកដល់ទីក្រុងភ្នំពេញនេះ ខ្ញុំបានជួបមនុស្សតែ ៧០នាក់ប៉ុណ្ណោះ។ ទីក្រុងទាំងអស់នៃប្រទេសកម្ពុជា គ្មានមនុស្សរស់នៅទេ។ ផ្លូវទាំងឡាយគ្មានការធ្វើចរាចរណ៍ឡើយ។ ប៉ុន្តែឥឡូវនេះ ស្ថានភាពបានផ្លាស់ប្តូរ។ យើងខ្ញុំបានចាប់ផ្តើម(កសាងប្រទេស)ពីបាតដៃទទេ **ពីការបំផ្លិចបំផ្លាញមួយដែលនៅលើពិភពលោកក្នុងចុងសតវត្សរ៍ទី២០ ពុំមានប្រទេសណាមួយទទួលការបំផ្លិចបំផ្លាញច្រើនដូចកម្ពុជា និងបន្ថែមលើនោះត្រូវទទួលទណ្ឌកម្មដ៏អយុត្តិធម៌ពីសំណាក់ប្រទេសមួយចំនួន រាប់ទាំងប្រទេសដែលតាំងខ្លួនថាជាប្រទេសប្រជាធិបតេយ្យ ដែលគាំទ្រឱ្យពួកប្រល័យពូជសាសន៍ប៉ុលពតឱ្យអង្គុយនៅអង្គការសហប្រជាជាតិពីឆ្នាំ១៩៧៩រហូតដល់ឆ្នាំ១៩៩១** ...។

២. ធ្លាប់ជួបហើយ ប្រទេសតាំងខ្លួនប្រជាធិបតេយ្យ តែគាំទ្ររដ្ឋប្រហារយោធា

កិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិក ឆ្នាំ២០១៩ នៅកម្ពុជា, ១៩ វិច្ឆិកា ២០១៩

... នេះគឺជាបទពិសោធ មិនគ្រាន់តែកម្ពុជាទេ ក៏ប៉ុន្តែ(ប្រទេសខ្លះនៅលើ)ពិភពលោកនេះ គួរតែស្វែងយល់ឱ្យបានច្បាស់អំពីឥរិយាបថរបស់ខ្លួន ដែលបានប្រព្រឹត្តក្នុងទំនាក់ទំនងជាមួយប្រទេសដទៃ។ **កម្ពុជាធ្លាប់ជួបប្រទះរួចហើយ ការដែលប្រទេសមួយចំនួនតាំងខ្លួនជាប្រទេសប្រជាធិបតេយ្យ តែបែរជាគាំទ្ររដ្ឋប្រហារយោធា។ តាំងខ្លួនប្រជាធិបតេយ្យ គោរពសិទ្ធិមនុស្ស ប៉ុន្តែបែរជាគាំទ្រឱ្យពួកកាប់សម្លាប់មនុស្ស រំលោភសិទ្ធិមនុស្ស និងប្រល័យពូជសាសន៍ អង្គុយនៅអង្គការសហប្រជាជាតិ**។ សង្ឃឹមថា បទពិសោធនៅកម្ពុជា គឺជាមេរៀនមួយដែលមិនត្រឹមតែសំរាប់ប្រជាជនកម្ពុជាខ្លួនឯងត្រូវរៀនសូត្រទេ ក៏ប៉ុន្តែក៏សំរាប់កិច្ចការនយោបាយការបរទេស ក៏ដូចជាការដកពិសោធន៍ឥរិយាបថរបស់ប្រទេសមួយចំនួនចំពោះប្រទេសដទៃទៀត ...។

៣. ប្រទេសធ្លាប់ទទួលស្គាល់ខ្មែរក្រហម គប្បីទទួលព្រមថានយោបាយចំពោះកម្ពុជាមានចំណុចខុស

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... កាលពីមុន គេនាំគ្នាបិទភ្នែកចំពោះមុខការប្រល័យពូជសាសន៍។ ក្រោយមក គេបែរជាទាមទារដោយគ្មានសមហេតុផលទាំងអស់ ឱ្យកាត់ទោសខ្មែរក្រហម ក្រោយពេលដែលខ្មែរក្រហមបានរលំរលាយទាំងអង្គការចាត់តាំង ទាំងនយោបាយ និងយោធា ... **ខ្ញុំគួរតែធ្វើជាមតិដល់ប្រទេសខ្លះ ដែលបានកសាងកំហុសដោយទទួលស្គាល់ខ្មែរក្រហម ឬក៏បិទភ្នែកចំពោះ(មុខការប្រល័យពូជសាសន៍មួយនៅកម្ពុជា) ឱ្យទទួលព្រមថា "ក្នុងជំនាន់នោះ នយោបាយខ្លួនចំពោះកម្ពុជាមានចំណុចខុស"។ មិនចាំបាច់ប្រកាសផ្សាយទេ។ គ្រាន់តែដើម្បីជាពិសោធន៍ទាំងអស់គ្នា។ រឿងនៅកម្ពុជា មិនមែនជាហេតុការណ៍ដាច់ដោយឡែកតែកម្ពុជាទេ។ វាជារឿងដែលមានការពាក់ព័ន្ធជាមួយប្រទេសជាច្រើន និងការរៀបចំគោលនយោបាយពីដំណាក់កាលនោះដែលខ្វះភាពយុត្តិធម៌និងសង្គតិភាព ...**។

៤. សូមបរទេស "កុំកសាងកំហុសទី៣" មកលើកម្ពុជា

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... ជួបជាមួយអ្នកការទូត ឬអ្នកនយោបាយនៃប្រទេសមួយចំនួន ខ្ញុំតែងរំឭកថា "សូមអ្នកកុំកសាងនូវកំហុសទី៣" (ចំពោះកម្ពុជា) ...**កំហុសទី១ ... តើមានប្រទេសប៉ុន្មានដែលបានគាំទ្រ លន់ នល់ ធ្វើរដ្ឋប្រហារ ក្នុងពេលដែលគេតាំងខ្លួនថាជាអ្នកប្រជាធិបតេយ្យ?** គេធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ តាមរូបភាពរដ្ឋប្រហារយោធា ក្នុងពេលដែលតាំងខ្លួនជាប្រទេសប្រជាធិបតេយ្យ។ បើសិនជាគេយកតរិយាបថដូចដែលគេដាក់ទណ្ឌកម្មលើយោធាមីយ៉ាន់ម៉ាពេលនេះ ប្រហែលជាកម្ពុជាមិនធ្លាក់ទៅដល់ខ្មែរក្រហមកាន់អំណាចទេ ... **កំហុសទី២ ការទទួលស្គាល់និងទុកឱ្យខ្មែរក្រហមអង្គុយ ១២ឆ្នាំនៅអង្គការសហប្រជាជាតិ**

ហើយជាក់ទណ្ឌកម្មអ្នកដែលបានប្រឹងប្រែងធើបឡើងដើម្បីប្រឆាំង ប៉ុល ពត ... ដូចនេះ សូមអ្នកកុំសាងកំហុសទី៣ មកលើកម្ពុជា ...។

៥. ពេលខ្មែរក្រហមខ្លាំង គ្មានអ្នកនិយាយពីកាត់ទោស ឬឈប់ទទួលស្គាល់នៅអង្គការសហប្រជាជាតិទេ

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតប តាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... ពេលដែលខ្មែរក្រហមខ្លាំង គ្មានអ្នកណាមួយអើតក្បាលមកនិយាយទាក់ទងនឹងរឿងកាត់ទោសខ្មែរក្រហម ឬក៏ឈប់ទទួលស្គាល់ខ្មែរក្រហមនៅអង្គការសហប្រជាជាតិទេ។ មួយឆ្នាំៗ គេនាំគ្នាបោះឆ្នោតនៅអង្គការសហប្រជាជាតិ ដែលកើតឡើងនូវរឿងពីរខុសគ្នា។ ក្រោយពីរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ភាពជាតំណាងនៅអង្គការសហប្រជាជាតិត្រូវបាន(ប្រគល់ឱ្យ)ពួក លន់ នល់ ដែលជាពួកធ្វើរដ្ឋប្រហារ។ ពេលដែលពួក **លន់ នល់ ខ្សោយទៅៗ រហូតគ្រប់គ្រងទឹកដីមិនដល់ប្រមាណ១០% ពួក លន់ នល់ ក៏នៅតែកាន់កាប់អាសនៈនៅអង្គការសហប្រជាជាតិ ដោយគេសំអាងថាពួក លន់ នល់ កាន់កាប់រដ្ឋធានី។ ក្រោយមក រដ្ឋកម្ពុជាកាន់កាប់ទឹកដីជាង៩០% ក៏យើងនៅតែនៅក្រៅអង្គការសហប្រជាជាតិ ដោយគេសំអាងថាយើងមិនស្របច្បាប់។ អញ្ចឹង គេបកស្រាយស្មានការណ៍ឱ្យត្រូវតែជាមួយនឹងអ្វីដែលគេចង់បានប៉ុននោះ។ តើអ្នកក្លាយទៅជាអ្នកដែលយុត្តិធម៌ពីពេលណាវិញ បៀបណា នៅពេលដែលអ្នកបញ្ចេញនូវជំហរបែបនេះ ...**។

៦. កន្លែងស័ក្តិសមរបស់ខ្មែរក្រហម គឺការកាត់ទោសនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ មិនមែននៅក្នុងក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទេ"

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតប តាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... នៅពេលសន្និសីទអន្តរជាតិទីក្រុងប៉ារីសចាប់ផ្តើមក្នុងឆ្នាំ ១៩៨៩ ក្នុងសុន្ទរកថាខ្ញុំបានចង្អុលថា "កន្លែងស័ក្តិសមបំផុតរបស់ខ្មែរក្រហម គឺការកាត់ទោសនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ មិនមែននៅក្នុងក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ឬ SNC

ទេ”។ពេលនោះ ភាគីរដ្ឋកម្ពុជា ដែលមានខ្ញុំជាតំណាង បានទាមទារឱ្យដាក់ពាក្យទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍។ យើងបានដើរទៅគាំងនៅចំណុចនេះ។ គេបានហាមយើងមិនឱ្យនិយាយដល់របបប្រល័យពូជសាសន៍ថែមទៀត ... កិច្ចព្រមព្រៀងទីក្រុងប៉ារីសមួយនេះ ត្រូវបានជាប់គាំង(ត្រង់ចំណុចទាក់ទងនឹងភាគីរបស់រដ្ឋកម្ពុជា ទាមទារឱ្យដាក់ពាក្យទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍) ...។

៧. ភាគីវៀយខ្មែរក្រហម រក្សាជំហរឱ្យមានការកាត់ទោសខ្មែរក្រហម តាំងពីដើមដល់ចប់

សន្និសីទ៖ “អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព”, ២២ ឧសភា ២០២៤

... កន្លែងនេះ**អាចបញ្ជាក់ថា ភាគីកម្ពុជាខាងរដ្ឋាភិបាល ឬខាងអ្នកវៀយខ្មែរក្រហមបានរក្សាគោលជំហរ “កាត់ទោសខ្មែរក្រហម” តាំងពីដើមដល់ចប់។ មិនមែនទើបនឹងនឹកឃើញទេ។ យើងបានស្នើដាក់ទៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសនូវប្រការស្តីពីការទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍។ ដោយសារតែការជាប់គាំងពេលនោះ ប្រហែលជាមានមិត្តភក្តិមួយចំនួនបានទៅពឹងពាក់ជប៉ុន**... (អ្នកដែលជាប់ពាក់ព័ន្ធគឺ) ឯកឧត្តម Owada ដែលបច្ចុប្បន្ននៅមានជីវិតនៅឡើយ និងក្រោយពេលធ្វើជាអនុរដ្ឋមន្ត្រីការបរទេស បានធ្វើជាតំណាងអចិន្ត្រៃយ៍របស់ជប៉ុននៅអង្គការសហប្រជាជាតិ និងបន្តទៅជាចៅក្រមតុលាការយុត្តិធម៌អន្តរជាតិ។ ភាគីជប៉ុន បានអញ្ជើញខ្ញុំទៅទីក្រុង តូក្យូ ក្រោមហេតុផលពិនិត្យជំងឺ ប៉ុន្តែ ការពិតគឺការចរចាមួយដើម្បីស្វែងរក(ដំណោះស្រាយសម្រាប់)ចំណុចទាក់ទងភាពជាប់គាំងនៃភាសាដែលយើងបានស្នើសុំ ...។

៨. ពី “ទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍” មកត្រឹម “ទប់ស្កាត់ការវិលត្រឡប់អំពើពីអតីតកាលថ្មីៗ”

សន្និសីទ៖ “អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព”, ២២ ឧសភា ២០២៤

... យើង(ភាគីរដ្ឋកម្ពុជានិងអ្នកសំរបសំរួលជប៉ុនបាន)មកចរចាគ្នានៅសណ្ឋាគារ New Otani គឺកន្លែងដែលខ្ញុំសម្រាក ... យើងចរចាគ្នារហូតដល់ម៉ោង២កន្លះភ្លឺលើចំណុចហ្នឹង។ ចុងក្រោយ ឯកឧត្តម Owada បានយកជោគជ័យលើគំនិតរបស់ខ្ញុំ។ គាត់បាននិយាយមកកាន់ខ្ញុំថា “សាដាំម ហ៊ូសេន, ហ្គាដាហ្វី គឺជាមនុស្សដែលត្រូវកាត់ទោសហើយ។ ក៏ប៉ុន្តែឯកឧត្តមគិតមើល **បើក្នុងកិច្ចព្រមព្រៀងនេះដាក់បញ្ចូលឃ្លា “ទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍” ខ្មែរក្រហមនិងប្រទេសមួយចំនួនគេមិនយល់ព្រម”។ យើងបានកែសម្រួលមកនៅត្រឹមពាក្យថា “ទប់ស្កាត់ការវិលត្រឡប់អំពើពីអតីតកាលថ្មីៗ”។** សូមមើលកិច្ចព្រមព្រៀងទីក្រុងប៉ារីសឡើងវិញ។ ចំណុចហ្នឹង ដើមឡើយជាចំណុចដែលកម្ពុជាបានស្នើធ្វើវិសោធនកម្ម។ ឯកឧត្តម អៀង ម៉ូលី គឺជាមនុស្សម្នាក់ក្នុងចំណោមអ្នកចូលរួមចរចាកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ ប៉ុន្តែ គ្រាន់តែ(គាត់)នៅភាគីផ្សេង។ ឥឡូវគាត់នៅភាគីរបស់គណបក្សប្រជាជនហើយ ... ភាគីភ្នំពេញនៅតែក្បាកម្រិតកាត់ទោសខ្មែរក្រហម អត់ដែលបោះបង់ចោលទេ។ នេះជាចំណុចអំពីពាក្យពេចន៍ដែលគួរតែចោទសួរនិងដែលខ្ញុំសូមបញ្ជាក់ ...។

៩. ការកាត់ទោសខ្មែរក្រហមឆ្លងកាត់ ៣អគ្គលេខាធិការអង្គការសហប្រជាជាតិ

សន្និសីទ៖ “អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព”, ២២ ឧសភា ២០២៤

... (និយាយតាមបែបម្យ៉ាង) ខ្ញុំបានយកក្បាលទៅដួរយកសន្តិភាពជូនប្រទេសនេះ។ អញ្ចឹងខ្ញុំមិនឱ្យរបូត(សន្តិភាពបាត់)ទេ។ ខ្ញុំសុខចិត្តឱ្យតុលាការកូនកាត់បរាជ័យ តែខ្ញុំមិនឱ្យប្រទេសខ្ញុំកើតសង្គ្រាមទេ។ ពេលនោះ បើសិនអង្គការសហប្រជាជាតិបង្ខំ(ឱ្យធ្វើតាមគំនិតពង្រីកការចោទប្រកាន់) តុលាការនេះនឹងបរាជ័យ ... ខ្ញុំមិនដឹងថា លោកជំទាវ (Alice Wairimu Nderitu អគ្គលេខាធិការរងនិងជាទីប្រឹក្សាពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍) តំណាងឱ្យអគ្គលេខាធិការអង្គការសហប្រជាជាតិ បានដឹងរឿងហ្នឹងឬអត់? ប៉ុន្តែ ប្រហែលឯកឧត្តម បាន គីមូន មិនបានចែករំលែកទេ។ ឯកឧត្តម បាន គីមូន នៅរស់ ... នៅកូរ៉េខាងត្បូង។ កាលពីខែមេសាកន្លងទៅនេះ យើង

បានជួបគ្នានៅ BOAO Forum ... **រឿងកាត់ទោសខ្មែរក្រហមនេះ ឆ្លងកាត់ ៣អគ្គលេខាធិការអង្គការសហប្រជាជាតិ គឺតាំងពី កូហ្វី អាណាន់ មកដល់ បាន គីមូន និងមកដល់ អាន់តូនីញ៉ូ ហ្គូទែរ៉េស (António Manuel de Oliveira Guterres) ...**៕

១០. បើពង្រាយការចោទប្រកាន់ ការកាត់ទោសនឹងមិនអាចចប់

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... គ្រាន់តែ Boutros Boutros-Ghali ជួប ខៀវ សំផន ក៏មិនបាន? ហ្នឹងគេហៅថាភាពជ្រុល។ ធ្លាប់គាំទ្រខ្មែរក្រហមឱ្យវាយយើង គាំទ្រខ្មែរក្រហមនៅអង្គការសហប្រជាជាតិ ដល់ទៅពេលខ្មែរក្រហមខ្សោយ ចាប់សង្កត់កយកតាមចិត្ត។ ខ្ញុំសូមបញ្ជាក់ **បើសិនជាកុំមានការរារាំងពីខ្ញុំ ដំណើរការកាត់ក្តីនេះមិនដឹងជាពង្រាយ (ការចោទប្រកាន់ទៅ)មនុស្សប៉ុន្មាន(នាក់ទេ)។ ចុះពីកន្លែងមួយទៅកន្លែងមួយ គឺនឹងកាត់អត់ចប់ទេ។ ពិភពលោកចាំតែរកលុយទៅ។ ប៉ុន្តែខ្ញុំបានបញ្ជាក់ប្រាប់បាន គីមូន ច្បាស់។ គេអាច(ទាក់ទងសុំ)សម្ភាសលោក បាន គីមូន បាន។ អាចនៅមានកំណត់ហេតុ ជាពិសេសអ្នកនៅសាលាក្តីខ្មែរក្រហម តំណាងឱ្យមន្ត្រីសាលាក្តីខ្មែរក្រហមអាចបានដឹងរឿងនេះ** ...៕

១១. សុខចិត្តឲ្យតុលាការបរាជ័យ តែមិនឲ្យប្រទេសកម្ពុជាមានសង្គ្រាមឡើងវិញទេ

បាឋកថាក្នុងសម័យប្រជុំពេញអង្គសភាអង្គរជាតិដើម្បីភាព អត់ឱន និងសន្តិភាព (IPTP) លើកទី១១, ២៤ វិច្ឆិកា ២០២៤

... ខ្ញុំបាននិយាយក្នុងប្រជុំ ICAPP ថ្ងៃមុន ខាងដៃគូរបស់យើងមានសំណុំរឿងរហូតដល់ទៅត្រូវយាងព្រះមហាក្សត្រ ហៅប្រធានរដ្ឋសភា ហៅប្រធានព្រឹទ្ធសភា និងអ្នកដឹកនាំដទៃទៀតចូលតុលាការ និងបើកទូលាយការកាត់ទោសដែលរីករាលដាល។ **ខ្ញុំបាននិយាយទៅកាន់អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន ថា "ខ្ញុំសុខចិត្តឲ្យតុលាការបរាជ័យ តែខ្ញុំមិនសុខចិត្តឲ្យប្រទេសកម្ពុជាមានសង្គ្រាមឡើងវិញទេ"។ ពួកគេលំអៀង។ ម្ដងទៅគាំទ្រខ្មែរក្រហម ម្ដងទៅគាំទ្រឲ្យមានសង្គ្រាម បន្ទាប់ទៅទាមទារកាត់ទោស ដោយគ្មានគិតពីចំណងទាក់ទងរវាង**

សង្គ្រាមនិងសន្តិភាព រវាងយុត្តិធម៌និងសន្តិភាព រវាងយុត្តិធម៌និងសង្គ្រាម។ មានមនុស្សខ្លះបានត្រឹមតែគិតអ្វីដែលជាការគិត តែគេមិនបានគិតពីផលប្រយោជន៍ពិតប្រាកដរបស់យើងទេ ... ខ្ញុំតែងតែទូន្មានសហការីរបស់ខ្ញុំ និងអំពាវនាវចំពោះប្រជាជនកម្ពុជាថា "អ្វីក៏ដោយ យើងត្រូវគិតថា មានតែយើងទេដែលជាម្ចាស់ប្រទេស គ្មានអ្នកណាស្គាល់យើងជាងយើងទេ។ ដូច្នេះ យើងត្រូវតែហ៊ានតស៊ូលើគ្រប់បញ្ហាដែលជាផលប្រយោជន៍របស់យើង ..."៕

១២. ប៉ុល ពត ដកខ្លួនពីកិច្ចព្រមព្រៀងប៉ារីស មិនចូលរួមបោះឆ្នោត បានផ្តល់ជោគជ័យឲ្យនយោបាយឈ្នះឈ្នះ

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... មិនដឹងថា (ក្នុងពិធី)បើក(សន្និសីទ ដែល)បន្ទាប់ទៅមានការជជែកពិភាក្សាគ្នា តើបានដាក់សំណួរក្នុងចំណោមអ្នកសិក្សាស្រាវជ្រាវទេ ថា៖ **ប្រសិនបើខ្មែរក្រហមចូលរួមការបោះឆ្នោត មានគណបក្សនយោបាយត្រឹមត្រូវ និងមានអាសនៈក្នុងសភា តើអ្នកណាជាអ្នកទទួលខុសត្រូវលើការកាត់ទោសខ្មែរក្រហម? តើមានការដាក់ចេញជាសំណួរនេះទេ? នេះយើងគួរតែអរគុណ ប៉ុល ពត ដែលបានដកខ្លួនពីការអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីស មិនចូលរួមបោះឆ្នោត។ ប៉ុល ពត បានសាងកំហុសខ្លួនឯង ដែលជាការផ្តល់ឱកាសឱ្យយើងកម្ចាត់ខ្មែរក្រហមទាំងអង្គការចាត់តាំងនយោបាយនិងយោធា តាមរយៈនយោបាយឈ្នះឈ្នះ មិនមែនតាមរយៈអ៊ុនតាក់ នោះទេ**។ ពេលដែលអ៊ុនតាក់ ដកចេញទៅ កម្ពុជានៅមានរដ្ឋាភិបាល ២ច្បាំងគ្នានៅឡើយ។ ប៉ុន្តែ តាមរយៈនៃនយោបាយឈ្នះឈ្នះ(យើងបានធ្វើដោយជោគជ័យ នូវអ្វីដែលអ៊ុនតាក់ធ្វើមិនបាន)។ ថ្ងៃនេះ (អតីត)មេខ្មែរក្រហមក៏មកដែរ។ ប៉ុន្តែ បើមិនមានមេខ្មែរក្រហម អ៊ី ឈាន និង សុខ ភាព បះបោរនាំទៅដល់ការដួលរលំរបស់ខ្មែរក្រហមទេ យើងក៏មិនដឹងទៅរកអ្នកណាបះបោរដើម្បីដំរុញចលនាទៅមុខនៃនយោយបាយឈ្នះឈ្នះរបស់យើងទេ ...៕

១៣. ការបញ្ចប់សង្គ្រាមដោយភាគីម្ខាងចុះចូលនឹងភាគីម្ខាងទៀតដល់ផ្ទះ មិនទាន់មានទេលើពិភពលោក

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... អ្វីដែលគួរឱ្យចម្លែកទៅទៀត គឺរូបភាពនៅខាងក្រៅ គេបានឃើញមនុស្ស ៤ នាក់អង្គុយជាប់នឹង ហ៊ុន សែន (នៅអង្គុយ)កណ្តាល ខាងស្តាំដៃមាន ខៀវ សំផន ឆ្វេងដៃមាន នួន ជា, និងបន្តមកទៀតមាន អៀង សារី។ ខៀវ សំផន ជាប្រមុខរដ្ឋនិង នាយករដ្ឋមន្ត្រី, នួន ជា គឺអតីតប្រធានរដ្ឋសភា និង អៀង សារី ជាអតីតឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេស។ (ឃើញរូបភាពនេះ)គេបែរជាមកធ្វើបាបខ្ញុំ ធ្វើបាបអតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ Boutros Boutros-Ghali។ **នៅលើពិភពលោក តើមានរឿងនេះកើតឡើងហើយឬនៅ ដែលការបញ្ចប់សង្គ្រាមមួយដោយភាគីម្ខាងមកចុះចូលដល់ផ្ទះមេដឹកនាំភាគីម្ខាងទៀត? រឿងបែបនេះមិនទាន់មានទេ។ នៅកម្ពុជាបានមានរួចមកហើយ។ ហេតុអីបានជាគេមកស្តីបន្ទោសយើង ស្តីបន្ទោសអតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ Boutros Boutros-Ghali** ... ៕

១៤. ទទួលយកការចុះចូលនៃមេដឹកនាំខ្មែរក្រហមដល់ផ្ទះ គឺដើម្បីជូនសារ៣

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... ខ្ញុំបានឱ្យឧទ្ធម្ភាគចក្រទៅដឹកលោក ខៀវ សំផន, នួន ជា និងអ្នកដឹកនាំដទៃទៀត។ លោក ខៀវ សំផន មកទាំងប្រពន្ធ កូន កូនប្រសារនិងចៅ។ **ខ្ញុំត្រូវមានសារ ៣ ដើម្បីផ្ញើជូនចេញទៅក្រៅក្នុងការរៀបចំជំនួបបែបនេះនៅផ្ទះរបស់ខ្ញុំ។ ទី១ ខ្ញុំចង់ផ្ញើសារទៅប្រជាជនកម្ពុជាថាសង្គ្រាមបានចប់ហើយ។ មេដឹកនាំថ្នាក់កំពូលៗបានចុះចូលដល់ផ្ទះរបស់នាយករដ្ឋមន្ត្រីហើយ។ ទី២ ខ្ញុំចង់ផ្ញើសារទៅកាន់កម្លាំងដែលនៅសេសសល់តិចតួចរបស់ខ្មែរក្រហមថា សូមបញ្ចប់ការប្រយុទ្ធព្រោះមេដឹកនាំរបស់អ្នកឯងបានមកចុះចូលហើយ។ ទី៣ ខ្ញុំចង់ផ្ញើសារទៅកាន់សហគមន៍អន្តរជាតិថា សូមមកធ្វើទេសចរណ៍និងវិនិយោគ ព្រោះកម្ពុជាបានបញ្ចប់សង្គ្រាម**

ហើយ។ (ក្នុងស្ថានភាពនោះ) ប្រទេសមួយចំនួនបែរជាថាយើងចាប់ដៃជាមួយខ្មែរក្រហម។ បានខ្ញុំព្រលះទៅវិញ "កុំភ្លេចថា មុនកិច្ចព្រមព្រៀងទីក្រុងប៉ារីស អ្នកឯងបានឱ្យខ្មែរក្រហមដើរលើព្រំក្រហម និងមាន Visa diplomatic ចូលប្រទេសអ្នកឯង។ តើអ្នកឯងថាម៉េចពេលហ្នឹង" ... ៕

១៥. ការកាត់ទោសខ្មែរក្រហមមានន័យថា "កម្ពុជាមានរបបប្រល័យពូជសាសន៍ពិតមែន"

បាឋកថាក្នុងសម័យប្រជុំពេញអង្គសភាអង្គរជោតិដើម្បីភាព អត់ឱន និងសន្តិភាព (IPTP) លើកទី១១, ២៤ វិច្ឆិកា ២០២៤

... ខ្ញុំសូមរំលេចរឿងប្រវត្តិសាស្ត្រ ដែលមិនត្រូវកាឡេឡើយ។ តើ**ការកាត់ទោសខ្មែរក្រហមមានន័យថាម៉េច? វាមានន័យថា ពិតជាមានរបបប្រល័យពូជសាសន៍នៅកម្ពុជាមែន ទើបបានជាមានការកាត់ទោសខ្មែរក្រហម។ គេមិនត្រូវលេងគណិតវិទ្យាមួយជកមួយស្មើសូន្យទេ។ គេថ្កោលទោសទាំងខ្មែរក្រហម គេថ្កោលទោសទាំងអ្នកវាយខ្មែរក្រហម។ តើជាយុត្តិធម៌សម្រាប់យើងទេ? បើគេទទួលស្គាល់ថាមានរបបប្រល័យពូជសាសន៍ តើគេត្រូវទុកឲ្យរបបប្រល័យពូជសាសន៍ស្ថិតស្ថេរតទៅ ឬក៏ផ្តួលរំលំវា?** កងទ័ពសម្ព័ន្ធមិត្តបានវាយប្រហារ Hitler ដើម្បីអ្វីទៅ? គឺដើម្បីកុំឲ្យពួក fascist Hitler ឈ្លានពានគេឯងទៀត។ អាមេរិកសម្រេចចិត្តទម្លាក់បរមាណូលើប្រទេសជប៉ុន គឺដើម្បីកុំឲ្យយោធានិយមជប៉ុនបន្តការឈ្លានពានតទៅទៀត ... ហេតុអ្វីបានជាកម្ពុជាមិនអាចធ្វើនូវរឿងមួយ ដើម្បីសង្គ្រោះអាយុជីវិតមនុស្សតាមរយៈនៃការផ្តួលរំលំរបបខ្មែរក្រហមដោយកម្លាំងកម្ពុជាផង និងកម្លាំងកងទ័ពវៀតណាមផង? ... ៕

១៦. ទទួលស្គាល់ការកាត់ទោសខ្មែរក្រហមថាត្រឹមត្រូវ បានន័យថាការផ្តួលរំលំរបប ប៉ុល ពត និងការជួយរបស់វៀតណាម គ្មានអ្វីខុស

ទិវានៃការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត គម្រប់ ៤០ ឆ្នាំ, ២១ មិថុនា ២០១៧

... អរគុណអ្នកទាំងអស់ដែលបានអញ្ជើញមកទីនេះ ដើម្បីស្គាល់នូវប្រវត្តិដើមនៃការចាប់ផ្តើម នៃតួអង្គមួយ ក្នុងចំណោមតួអង្គផ្សេងទៀត ដែលបានបង្កើតនូវ

ការរស់រានមានជីវិតរបស់ប្រជាជនកម្ពុជា ការសង្គ្រោះប្រទេសចេញពីរបបប្រល័យពូជសាសន៍ ហើយពេលនេះ ក៏កំពុងនាំពួកឧក្រិដ្ឋជនសង្គ្រាម ឧក្រិដ្ឋជនប្រល័យពូជសាសន៍ យកទៅកាត់ទោស។ **បើគេទទួលស្គាល់ថា ការកាត់ទោស(មេដឹកនាំខ្មែរក្រហមដោយអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា)នេះត្រឹមត្រូវ (វា)មានន័យថា ការតស៊ូរួមគ្នាជាមួយកម្លាំងនានា ក្រោមដំបូលរណសិរ្សសាមគ្គីសង្គ្រោះជាតិ និងការជួយរបស់វៀតណាម ដើម្បីផ្តួលរំលំរបប ប៉ុល ពត គ្មានអ្វីខុសទេ** ...។

១៧. ជ្រើសទីបញ្ជាការកងទ័ពជើងគោកជាសាលាក្តីខ្មែរក្រហម ដើម្បីបញ្ឆៀសចរាចរណ៍ និងការពារសុវត្ថិភាពពិរុទ្ធជន

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... ដើម្បីយល់ដឹងអំពីការរៀបចំទីតាំងកាត់ទោសខ្មែរក្រហម ... ព្រោះអាចនឹងមានមនុស្សមួយចំនួនមិនដឹងថា តើត្រូវធ្វើរបៀបម៉េចបង្កើតឱ្យមានទីតាំងនេះ ខ្ញុំគួរតែត្រូវរំលេចឱ្យឃើញ។ នៅដើមឆ្នាំ២០០០ ខ្ញុំបានសម្រេចឱ្យអគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទចាកចេញពីទីតាំងចាស់ មកកសាងទីតាំងថ្មីនៅទីនេះ។ ពេលនោះ មានការពិភាក្សារវាងមេបញ្ជាការជើងគោកជាមួយអគ្គបញ្ជាការ ដោយបញ្ជូនមេបញ្ជាការជើងគោកមកទីនេះ និងរក្សាទីតាំងអគ្គបញ្ជាការនៅទីបញ្ជាការជើងគោកដែលនៅជាប់ក្រសួងការពារជាតិ រើទៅភាគខាងជើងទីក្រុងភ្នំពេញ **នៅពេលដែលកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយភាគីកម្ពុជា បានចូលជាធរមាន។ ដើមឡើយ ទីតាំងនេះមួយ និងទីតាំងសាលសន្និសីទចតុមុខមួយត្រូវបានមើលឃើញថាមានភាពស័ក្តិសមនឹង (យកជាកន្លែងរៀបចំ) កាត់ទោសខ្មែរក្រហម។ ប៉ុន្តែ ចំណោទអំពីវិធានការត្រូវការពារ ជាមួយកត្តាចរាចរណ៍ពេលដែលមានសវនាការម្តងៗ ថែមដោយការការពារសុវត្ថិភាពសម្រាប់ពិរុទ្ធជនជារឿងមួយកាន់តែសំខាន់ ទើបយើងសម្រេចចិត្តយកទីកន្លែងនេះ** ...។

១៨. កាត់ទោសមេដឹកនាំខ្មែរក្រហម ដោយកម្ពុជាធ្វើម្ចាស់ ដោយច្បាប់កម្ពុជា និងក្នុងតុលាការកម្ពុជា

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... គំនិតផ្តួចផ្តើមឱ្យមានការកាត់ទោសខ្មែរក្រហមតាមរបៀបកូនកាត់នេះ បានឆ្លងកាត់ការពិគ្រោះយោបល់ច្រើន។ ខ្លះថាត្រូវយកតាមរូបមន្តអាហ្វ្រិកខាងត្បូង របស់លោកបណ្ឌិត ដេសម៉ុន្ត ទូទូ (Desmond Tutu) អំពីភាពអនុគ្រោះផ្នែកណានោះ (យោងតាមភាពជាក់ស្តែងនៃ)របប អាបាថាយ (Apartheid)។ **យើងថាមិនអាចធ្វើទៅរួចតាមរបៀបនោះទេ។ អញ្ចឹងទេ យើងជាអ្នកជាក់ចេញនូវសំណើអំពីការសាកល្បងរៀបចំដំណើរការកាត់ទោស ដែលកម្ពុជាត្រូវធ្វើម្ចាស់ ដោយច្បាប់របស់កម្ពុជា ដំណើរការក្តីនៅក្នុងតុលាការកម្ពុជា**។ យើងគួរលើកទន្ទឹងរូបមន្តរបស់ John Kerry ... ដែលបានប្រឹងប្រែងលើកិច្ចការនេះ។ ក្នុងពេលដែលខ្ញុំធ្វើដំណើរទៅ ឡាហ៊ាន/គុយបា ដើម្បីចូលរួមប្រជុំ គាត់ក៏បានធ្វើដំណើរចេញពីអាមេរិកទៅជួបខ្ញុំនៅ ឡាហ៊ាន ...។

១៩. រៀបចំតុលាការតាមច្បាប់កម្ពុជា ស៊ីសង្វាក់នឹងកិច្ចព្រមព្រៀងអនុម័តដោយ UNSC (ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ)

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... បន្ទាប់ទៅ ពេលដែលប្រធានាធិបតី គ្លីនតុន ធ្វើទស្សនកិច្ចនៅវៀតណាមឆ្នាំ ២០០០ លោក John Kerry ដែលធ្លាប់ជាអ្នកចូលរួមចម្បាំងនៅប្រទេសវៀតណាម ហើយក៏ជាអតីតឈ្លើយសឹករបស់វៀតណាម បានអមដំណើរ គ្លីនតុន មកទស្សនកិច្ច ... និងបានឆ្លៀតធ្វើដំណើរមកជួបខ្ញុំ នៅផ្ទះវិមានឯករាជ្យ ទីក្រុងភ្នំពេញ។ **តើជារូបមន្តអី ? គឺរូបមន្ត Supermajority។ មិនយកសំឡេង ២ភាគ៣ មកប្រើទេ។ រូបមន្ត Supermajority វាលើសពី ២ភាគ៣។ អញ្ចឹង ដើម្បីកុំឱ្យភាគីណាមួយប្រើសិទ្ធិជំទាស់បាន ឬក៏អនុម័តដោយឯកឯងដោយគ្មានការរាំងខ្ទប់ គឺត្រូវប្រើប្រាស់រូបមន្តនេះ។ ជារូបមន្តវៃឆ្លាត។ យើងក៏ទទួលយក**។ ពេលនោះ ដោយមានការមិន

ច្បាស់លាស់មួយចំនួន ឯកឧត្តម អូវ៉ាដា ក៏បានធ្វើដំណើរមកទៀត។ ខ្ញុំក៏បានជួបតាមទូរស័ព្ទជាមួយ Kofi Annan ធ្វើការពិគ្រោះយោបល់លើការ**រៀបចំតាមច្បាប់របស់កម្ពុជាផង និងឱ្យស៊ីសង្វាក់ជាមួយកិច្ចព្រមព្រៀងដែលនឹងត្រូវអនុម័តដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិផង** ...។

២០. ផ្តួលរំលំ ទប់ស្កាត់ រំលាយអង្គការចាត់តាំង ប៉ុល ពត នាំមកនូវសន្តិភាព និងបានសាលក្រមយុត្តិធម៌ជូនប្រជាជនកម្ពុជា

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... សូមបញ្ជាក់ថា **សាលដីកាដែលនាំមកនូវយុត្តិធម៌ វាក៏បានជួយឱ្យខ្ញុំដកខ្លួនពីអំណាចនាយករដ្ឋមន្ត្រី។ (មានន័យថា)ខ្ញុំបានដើរដល់គោលដៅរបស់ខ្ញុំ គឺផ្តួលរំលំ ប៉ុល ពត ទប់ស្កាត់ ប៉ុល ពត រំលាយអង្គការចាត់តាំង ប៉ុល ពត នាំមកនូវសន្តិភាព ហើយចុងក្រោយ សាលក្រមដែលបានចេញមកនេះ បានផ្តល់យុត្តិធម៌ឱ្យប្រជាជនកម្ពុជា**។ ពីយុវជនអាយុ ២៥ឆ្នាំម្នាក់ ដឹកនាំចលនាតស៊ូ ហើយទទួលរងការប្រមាថ ការឈឺចាប់ នៅពេលដែលខ្លួនធ្វើជារដ្ឋមន្ត្រីការបរទេស នាយករដ្ឋមន្ត្រី ដោយត្រូវគេដាក់ទណ្ឌកម្ម គេគាំទ្រខ្មែរក្រហមឱ្យវាយយើង មកដល់ពេលដែលសាលក្រមនេះបានចេញ ខ្ញុំគិតថាអ្វីដែលជាគោលដៅខ្ញុំបានសម្រេចហើយ...។

២១. ពិនិត្យការសំរេចស្តីពីការរៀបចំតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមយ៉ាងហ្មត់ចត់ បង្កាការកើតមានមហន្តរាយជាថ្មី

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... យើងគួរតែរំលឹកទៅដល់សម្តេចវិបុលបញ្ញា សុខ អាន ព្រមជាមួយសហការីជាបណ្ឌិតច្បាប់ទាំងឡាយ ដែលឥឡូវជារដ្ឋលេខាធិការនៃគណៈរដ្ឋមន្ត្រី ដែលបានទទួលធ្វើកិច្ចការនេះ។ សម្តេចវិបុលបញ្ញា សុខ អាន បានទទួលខុសត្រូវចំពោះមុខខ្ញុំលើកិច្ចការនេះ ហើយបានរៀបចំឱ្យខ្ញុំ (ពិនិត្យនៅ)មុនការសម្រេចនិមួយៗ។ លើការសម្រេចអស់ទាំងនេះ ខ្ញុំបានពិនិត្យមើលអក្សរមួយតួម្តងមួយតួ

ព្រោះមិនអាចខ្ជីខ្ជាបានទេ។ ការខ្ជីខ្ជានឹងអាចឈានទៅដល់មហន្តរាយសង្គ្រាមឡើងវិញនៅកម្ពុជា ដោយសារ(តែមានភាគីដែល)ម្តងទៅក៏គាំទ្រខ្មែរក្រហម ដល់ម្តងទៀតក៏ទាមទារកាត់ទោស ហើយក៏ទាមទារឱ្យកាត់ទោសដោយមិនគិតដល់ឫសគល់នៃបញ្ហា ...។

២២. រួមគ្នាផ្សព្វផ្សាយឱ្យបានទូលំទូលាយសំណុំរឿងដ៏ជោគជ័យនៃសាលាក្តីខ្មែរក្រហម

បាឋកថាក្នុងសម័យប្រជុំពេញអង្គសភាអង្គរជោតិដើម្បីភាព អត់ឱន និងសន្តិភាព (IPTP) លើកទី១១, ២៤ វិច្ឆិកា ២០២៤

... សូមយកឱកាសនេះអំពាវនាវមេដឹកនាំដែលអញ្ជើញចូលរួមនៅទីនេះ **រួមគ្នាបង្កើតនូវការផ្សព្វផ្សាយឱ្យបានទូលំទូលាយ តាមរយៈការរៀបចំស្ថាប័នផ្សព្វផ្សាយដែលមាននៅកម្ពុជាស្រាប់។ យើងអាចបង្កើតជាបណ្ឌិត្យសភា ... ហើយក៏មានចែងនៅក្នុងធម្មនុញ្ញនេះហើយផងដែរ។ សង្ឃឹមថា នឹងមានការរួមចំណែកដើម្បីបង្កើតឡើងទៅតាមក្របខ័ណ្ឌដែលយើងដកពិសោធន៍ ផ្តល់ការសិក្សា ហើយអ្នកស្រាវជ្រាវ និងអ្នកដែលមានបំណងចង់ដឹងពី**(សំណុំរឿងដ៏ជោគជ័យបំផុតរបស់តុលាការអន្តរជាតិប្រភេទនេះ ដែលមិនត្រឹមតែបានផ្សះផ្សាសង្គមប៉ុននោះទេ ប៉ុន្តែថែមទាំងបានទប់ស្កាត់ការសងសឹក និងការស្អប់ខ្ពើមក្នុងប្រទេសជាតិផង) មកស្វែងយល់ សិក្សា ព្រោះមានជាង ២លានទំព័រ។ ច្រើនណាស់។ អញ្ចឹងយើងអាចនឹងរៀបចំការផ្សព្វផ្សាយលើរឿងនេះ ...។

២៣. បើមិនទទួលស្គាល់ថាមានរបប ប៉ុល ពត ស្មើនឹងជា ប៉ុល ពត

ទិវានៃការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត គម្រប់ ៤០ឆ្នាំ, ២១ មិថុនា ២០១៧

... ត្រកូល ហ៊ុន មិនយកប្រទេសនេះ ធ្វើជាប្រទេសផ្ដាច់មុខរបស់ខ្លួនទេ តែត្រកូល ហ៊ុន ជានាការពារសន្តិភាពសម្រាប់ប្រទេសនេះ ការពាររាជបល្ល័ង្ក ការពាររបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ការពារព្រះមហាក្សត្រ ការពាររដ្ឋធម្មនុញ្ញ ការពារអ្វីៗ ជាសមិទ្ធផលសង្គមជាតិ។ សូមកុំញុះញង់បង្កើតចលាចល ... ខ្ញុំបានស្តាប់ឮលោកស្រីម្នាក់បាននិយាយរួចហើយ ... សូមកុំភ្លេចថា សម្លេងរបស់លោក

ស្រី(ត្រូវបានអាត់ទុក)នៅក្នុងនេះ។ លោកស្រីបាននិយាយទាក់ទិននឹងរឿងនេះ។ តើលោកស្រីដែលបានតស៊ូប្រឆាំង ប៉ុល ពត ឬទេ? **បើលោកស្រីមិនទទួលស្គាល់ថាមានរបប ប៉ុល ពត (វាមានន័យថា)លោកស្រីក៏ជា ប៉ុល ពត ឬក៏ជាគោលដៅដែលយើងត្រូវប្រុងប្រយ័ត្នជាមួយដែរ** ...។

២៤. បើសម្លាប់មនុស្សគ្មានកំហុស មិនមែនជាអំពើប្រល័យពូជសាសន៍ លើលោកនេះមិនមានច្បាប់ទេ

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតប តាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... យើងក៏ចង់ដឹងដែរ ដែលសព្វថ្ងៃ នៅតំបន់ហ្គាហ្សា ឬចូលដល់ទីក្រុងដទៃទៀតនៅប៉ាលេស្ទីន មានមនុស្សស្លាប់រាល់ថ្ងៃ តើគេគិតយ៉ាងម៉េច? មានប្រធានាធិបតីនៃប្រទេសមហាអំណាចមួយថា "រឿងនៅតំបន់ហ្គាហ្សា មិនមែនជាអំពើប្រល័យពូជសាសន៍"។ **បើការសម្លាប់មនុស្សមិនមែនជាអំពើប្រល័យពូជសាសន៍ទេ សូមកុំមកចោទគ្នាវើយ។ ទម្លាក់គ្រាប់បែកលើគេឯងគ្រប់តែកន្លែង ថាមិនប្រល័យពូជសាសន៍ទៀត មិនដឹងថាម៉េច(បានរាប់ថាប្រល័យពូជសាសន៍ទេ)។ ដល់ទៅសម្លាប់មនុស្សគ្មានកំហុសថាអត់មានបញ្ហា អញ្ចឹងនៅលើលោកវាគ្មានកម្លាំងច្បាប់ទេ។ វាមានតែកម្លាំងអាវុធ។ អ្នកណាខ្លាំងអ្នកហ្នឹងឈ្នះតែប៉ុណ្ណឹង**...។

២៥. ល្បែងថ្កោលទោសទាំងខ្មែរក្រហម ទាំងអ្នកវាយខ្មែរក្រហម ត្រូវបានបញ្ចប់ដោយសាលក្រមតុលាការកូនកាត់

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... **ល្បែងផលបូកស្មើសូន្យ ត្រូវបានបញ្ចប់ដោយសាលក្រមតុលាការកូនកាត់មួយនេះ ហើយវាបានទទួលស្គាល់ទៅដល់កម្រិតក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។** មុននេះ គេបានថ្កោលទោសខ្មែរក្រហមផងនិងក៏បានថ្កោលទោសអ្នកដែលបានផ្តួលរំលំខ្មែរក្រហមផង។ វាជាគណិតវិទ្យា ១+១ ឬ ១-១ = ០។ គេថ្កោលទោសខ្មែរក្រហម តែក៏ថ្កោលទោសអ្នកវាយខ្មែរក្រហម។ តើនេះវាជាល្បែងនយោបាយ ដើម្បីបិទបាំងតថភាពប្រវត្តិសាស្ត្រ ដែលបានកើតពិតប្រាកដលើទឹកដីកម្ពុជាឬទេ? ...។

២៦. គួរមានច្បាប់ដាក់ទោសជនណាថ្លែងថា "កម្ពុជាគ្មានអំពើប្រល័យពូជសាសន៍ឬទេ"

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... ខ្ញុំសូមស្នើឱ្យអ្នកច្បាប់(ផ្តល់យោបល់មកថា) នៅកម្ពុជា **តើអាចរៀបចំឱ្យមានច្បាប់បានឬអត់ (ដើម្បីនឹងកំណត់)ជនណាដែល(ថ្លែង)ថា កម្ពុជាគ្មានអំពើប្រល័យពូជសាសន៍ នឹងត្រូវទទួលទោស? ហេតុអ្វីបានជាខ្ញុំនិយាយអញ្ចឹង? ដំណើរការកាត់ទោសសម្រេចបានសាលក្រមតុលាការមួយថា "កម្ពុជាមានរបបប្រល័យពូជសាសន៍"។ បើសាលក្រមតុលាការចេញមកអញ្ចឹង តើយើងអាចដាក់ច្បាប់មួយដើម្បីអះអាងថា "ពិតជាមានរបបប្រល័យពូជសាសន៍នៅកម្ពុជាឬទេ?** នៅអឺរ៉ុបដូចជាមានច្បាប់ដែល(អ្នកណានិយាយ)ថា "ហ៊ីត្លែរ មិនមែនជាប្រមុខរបប Fascist ត្រូវមានទោស"។ **អញ្ចឹង នៅកម្ពុជា គួរធ្វើ(ច្បាប់នេះដែរ)ឬទេ? នេះមិនមែនជាការបំផុសឱ្យគាបសង្កត់ទៅលើការបញ្ចេញមតិទេ** ...។

២៧. ការបញ្ចេញមតិណាមានចរិតគាំពាររបបប្រល័យពូជសាសន៍គួរតែត្រូវមានទោស

សន្និសីទ៖ "អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព", ២២ ឧសភា ២០២៤

... មានរឿងអាក្រក់បែបនេះនៅកម្ពុជា។ ម្ខាងគេថ្កោលទោសខ្មែរក្រហម។ ម្ខាងទៀតថ្កោលទោសអ្នកដែលបានផ្តួលរំលំខ្មែរក្រហម។ ដូច្នេះ ល្មមដល់ពេលដែលត្រូវដាក់ច្បាប់នេះហើយ។ បើមិនអញ្ចឹងទេ ពួកអ្នកនយោបាយនៅតែលេងល្បែងដដែលៗ ធ្វើឱ្យមានភាពច្របូកច្របល់ក្នុងសង្គម។ **បើអង្គការសហប្រជាជាតិ ដែលមានលោកជំទាវ (Alice Wairimu Nderitu អគ្គលេខាធិការរង និងជាទីប្រឹក្សាពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍) ជាតំណាង បញ្ជាក់ថាសាលក្រមតុលាការមានពិត បានសេចក្តីថាវាទាល់តែមានរបបប្រល័យពូជសាសន៍បានកើតពិតមែន ទើបបានជាយើងដំណើរ**

ការកាត់ទោស។ បើកាត់ទោសរួចហើយ នៅតែមានមនុស្សនិយាយថា “គ្មានខ្មែរក្រហមឯណាទេ ហើយក៏គ្មានអ្នកណាជួយសង្គ្រោះទេ ...” អញ្ចឹងវានៅតែជារឿងច្រំដែលនៃប្រវត្តិសាស្ត្រ ... **មិនមែនជាការហាមឃាត់ការបញ្ចេញមតិទេ ក៏ប៉ុន្តែការបញ្ចេញមតិណាក៏ដោយ ដែលមានចរិតគាំពារបបប្រល័យពូជសាសន៍ គួរតែត្រូវមានទោស ... ខ្ញុំរង់ចាំ ៤៣ឆ្នាំ ... គិតពីឆ្នាំ ១៩៧៩ រហូតដល់ឆ្នាំ ២០២២ ទើបយុត្តិធម៌មួយត្រូវបានផ្តល់**។ **មិនមែនជារឿងលេងសើចទេ ...**។

២៨. ច្បាប់ដាក់ទោសអ្នកនិយាយមិនពិតពីរបបប្រល័យពូជសាសន៍ជួយសម្រួលការសរសេរ និងការអប់រំប្រវត្តិសាស្ត្រ

សន្និសីទ៖ “អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍៖ ការការពារ និងការឆ្លើយតបតាមរយៈការអប់រំនិងការថែទាំសុខភាព”, ២២ ឧសភា ២០២៤

... សូមឱ្យអ្នកច្បាប់ទាំងឡាយពិចារណារួមគ្នា តើគួរមានច្បាប់កំណត់ពីការមានទោសកំហុស ពីការពោលខុសពីការពិតស្តីពីអំពើប្រល័យពូជសាសន៍ឬទេ ដើម្បីបញ្ជាក់និងងាយស្រួលសរសេរប្រវត្តិសាស្ត្រទុកឱ្យក្មេងរៀន។ **យើងថាទប់ស្កាត់របបប្រល័យពូជសាសន៍តាមរយៈការអប់រំ, មិនអញ្ចឹងឬ។ បើតាមរយៈការអប់រំ ច្បាស់ជាត្រូវសរសេរប្រវត្តិសាស្ត្រឱ្យក្មេងរៀន? ចុះបើក្មេងកំពុងតែរៀនមនុស្សខ្លះថារឿងហ្នឹងមិនមែនអញ្ចឹងទេ (នោះវានឹងបង្កភាពច្របូកច្របល់)។ អ្នកនយោបាយនៅស្រុកខ្មែរអាក្រក់អញ្ចឹង។ ដើម្បីទប់ទល់មានតែវិធីដាក់ច្បាប់ទេ។ បើអ្នកឯងថា “នៅកម្ពុជាអត់មានរបបប្រល័យពូជ សាសន៍” តើត្រូវជាប់ទោសដូចម្តេច ត្រូវផាកពិន័យប៉ុន្មាន។ គួរធ្វើ។ ឥឡូវប្រគល់ឱ្យផ្ទៃមន្ត្រីយុត្តិធម៌ទៅ។ ខ្ញុំមិនមែននាយករដ្ឋមន្ត្រីទេ ប៉ុន្តែខ្ញុំមានសិទ្ធិប្រគល់ ... មានច្បាប់ហ្នឹងបានយើងស្រួលសរសេរប្រវត្តិសាស្ត្រ។ ច្បាប់ហ្នឹងត្រូវតែជាច្បាប់អង្គការទៅទៀត គឺ២/៣ បានកែបាន**។ កុំឱ្យឡើងមកចេះតែកែបាន(តាមចិត្ត) ...។

២៩. អប់រំ យុវជន និងកីឡា

១	មិនទុកឱ្យកូនចៅណាម្នាក់នៅក្រៅសៀវអប់រំ គ្មានជំនាញពិតប្រាកដឡើយ	៦៤៥
២	គ្មានអ្វីចែកឱ្យដែលគង់វង្សជាងចំណេះវិជ្ជាទេ	៦៤៥
៣	ស្ថាវិស័យអប់រំពីបាតដៃទទេ រហូតក្លាយជាមោទនភាពជាតិសាសន៍កម្ពុជា	៦៤៥
៤	មិនអាចបញ្ចូលចំណេះដឹងតាមឈាមទេ គឺកើតចេញពីការខិតខំដោយខ្លួនឯង	៦៤៦
៥	សេរីភាវូបនីយកម្មអប់រំ លក្ខខណ្ឌកំណត់ចូលអង្គការពាណិជ្ជកម្មពិភពលោក	៦៤៦
៦	ភាគរយនៃសិស្សពូកែមានខ្ពស់ ក្នុងចំណោមកូនអ្នកក្រីក្រ	៦៤៧
៧	ជំរុញគោលដៅខេត្តមួយសាកលវិទ្យាល័យមួយ	៦៤៧
៨	ផុតដំណាក់កាល “អ្នកចេះច្រើនបង្រៀនអ្នកចេះតិចអ្នកចេះតិចបង្រៀនអ្នកមិនចេះ”	៦៤៧
៩	ដំណាក់កាលសេដ្ឋកិច្ចចំណេះដឹង ចាំបាច់ត្រូវបណ្តុះបណ្តាលធនធានមនុស្ស	៦៤៨
១០	ចំណាយលើវិស័យអប់រំផ្តល់ផលចំណេញសេដ្ឋកិច្ចសង្គមសំរាប់អភិវឌ្ឍជាតិ	៦៤៨
១១	ត្រូវយកចិត្តទុកដាក់ជាពិសេសលើអក្សរសាស្ត្រខ្មែរ	៦៤៩
១២	កាត់បន្ថយគម្លាតខួរក្បាលរវាងបុរសនិងស្ត្រី	៦៤៩
១៣	ចប់បរិញ្ញាហើយ ស្ត្រីគប្បីបន្តទៅបរិញ្ញាបត្រជាន់ខ្ពស់	៦៥០
១៤	ស្ត្រីរៀនដល់បរិញ្ញាជាន់ខ្ពស់/បណ្ឌិត ឆ្លើយតបគោលដៅអភិវឌ្ឍសមភាពយេនឌ័រ	៦៥០
១៥	សមភាពយេនឌ័រនៅបឋម/មធ្យមសិក្សា/បរិញ្ញាបត្រ ទៅបរិញ្ញាបត្រជាន់ខ្ពស់/បណ្ឌិត	៦៥១
១៦	ត្រូវដឹងគុណគ្រូ ដោយ “គ្រូមួយថ្ងៃ គឺគ្រូមួយជីវិត”	៦៥១
១៧	គ្រូមិនអាចក្លាយជាអ្នកមាន តែបង្រៀនសិស្សឱ្យក្លាយជាអ្នកមានបាន	៦៥២
១៨	កូនរៀនអន់ ជេរគ្រូ កូនរៀនពូកែ ថាពូជខ្លួនពូកែ	៦៥២
១៩	មន្ត្រីរាជការស៊ីវិល កុំច្រណែនគ្រូបង្រៀន/គ្រូពេទ្យ ដែលមានប្រាក់ខែខ្ពស់ជាង	៦៥៣
២០	“សាលាចិញ្ចឹមសាលា” លើកកំពស់ជីវភាពសាស្ត្រាចារ្យបុគ្គលិកវឌ្ឍនភាពសាលា	៦៥៣
២១	អន្តរាសិកដ្ឋាន ទាំងគ្រូ និងសិស្ស នៅតែជាបញ្ហាប្រឈម	៦៥៣
២២	រៀនកាន់តែពូកែ បង់ប្រាក់កាន់តែតិច ជាចំណុចដែលរាជរដ្ឋាភិបាលចង់បាន	៦៥៤
២៣	សិក្សា កុំសេពគ្រឿងញៀន កុំធ្វើសកម្មភាពផ្ទុយពីដំណើរការអភិវឌ្ឍខ្លួន	៦៥៤
២៤	រៀនមួយជីវិត បើទ្រឹងនៅមួយកន្លែង ក្លាយជាជនអភិរក្សនិយម	៦៥៥
២៥	សាកលវិទ្យាល័យរដ្ឋនិងឯកជន ជួយគ្នាទទួលនិស្សិតបរទេស	៦៥៥

២៦	បើកូនរៀនខ្សោយ ត្រូវរកវិធីឱ្យកូនរៀន កុំប្រៀបធៀបជាមួយកូនអ្នកដទៃ	៦៥៥
២៧	ជំរុញចលនារៀនពេញមួយជីវិត ... មិនចេះ ត្រូវសួរ	៦៥៦
២៨	ដំណើរ ៦៣ន់ គម ចាយ ៤០០លាន ពង្រាយសាលា កសាងអន្តរាសិកដ្ឋាន	៦៥៦
២៩	ជំរុញការវិនិយោគហេដ្ឋារចនាសម្ព័ន្ធទន់និងរឹង ក្នុងនោះមានធនធានមនុស្ស	៦៥៧
៣០	សាកលវិទ្យាល័យឯកជនអាចរៀបចំតាមខេត្ត តែការសង្កេតិភាពគុណភាពអប់រំ	៦៥៧
៣១	ចំណេះរៀននៅសាលា ខុសគ្នាពីការងារជាក់ស្តែង ...	៦៥៧
៣២	ផ្តល់ការងារមិនអាស្រ័យលើកំរិតសញ្ញាបត្រ តែគុណវុឌ្ឍិ គុណសម្បត្តិ គុណភាព	៦៥៨
៣៣	គ្មាននយោបាយនៅក្នុងកីឡា, កីឡាផ្សារភ្ជាប់សាមគ្គីភាព និងមំនាក់ចំនង ...	៦៥៨
៣៤	ប្រជាជនម្នាក់ ហាត់កីឡាមួយប្រភេទ ដើម្បីប្រកួត ឬដើម្បីសុខភាព	៦៥៩
៣៥	សូមយកចិត្តទុកដាក់បង្កើតទីតាំងកីឡាកាយសម្ព័ន្ធតាមសាលា	៦៥៩
៣៦	រក្សាដីសំរាប់បណ្តុះបណ្តាលវិស័យកីឡាលេងកីឡាប្រសើរជាងជក់គ្រឿងញៀន	៦៥៩
៣៧	វិនិយោគវិស័យកីឡា ផ្នែកហេដ្ឋារចនាសម្ព័ន្ធនិងធនធានមនុស្ស កាន់តែច្រើន	៦៦០
៣៨	កីឡាមិនដើម្បីដូរប្រាក់ តែគឺរក្សាតម្លៃនិងមានការយោគយល់	៦៦០
៣៩	ប្រវត្តិកីឡាកម្ពុជា ពូកែក្នុងប្រទេស តែខ្សោយក្នុងកម្រិតអន្តរជាតិ	៦៦១
៤០	កីឡាស្ថិតលើសមត្ថភាពនៃការប្រកួត ការហឺកហាត់និងទេពកោសល្យ	៦៦១
៤១	សូមកុំប្រើប្រាស់សារធាតុហាមឃាត់ក្នុងបញ្ជត្តិកីឡា	៦៦១
៤២	នៅលើពិភពលោក មានតែកីឡាទេមានស្តង់ដារួម	៦៦២
៤៣	ទោះជានៅក្រ អាស៊ីមិនត្រូវមានភាពទន់ខ្សោយក្នុងការគ្រប់គ្រងសីលធម៌កីឡា	៦៦២
៤៤	ប្រើប្រាស់ព្រឹត្តិការណ៍ប្រកួតស៊ីហ្គេមនៅកម្ពុជា ជាចលនាកីឡាជាតិ	៦៦៣
៤៥	ពង្រីកវិសាលភាពពិនិត្យព្យាបាលកីឡាករដោយគ្មានការបង់ប្រាក់	៦៦៣
៤៦	រៀបចំគោលនយោបាយឧបត្ថម្ភកីឡាករ/ការិនីរបួសឬពិការ ...	៦៦៤
៤៧	ស៊ីហ្គេមកម្ពុជា មិនលក់សំបុត្រ មិនបង់ថ្លៃចូលមើលតាមវិញ្ញាសាប្រកួត	៦៦៤
៤៨	ផ្តល់ការទស្សនាមិនគិតថ្លៃ ផ្តល់អាហារ/ស្នាក់នៅ និងមិនលក់សិទ្ធិផ្សព្វផ្សាយ	៦៦៤
៤៩	ស្គាល់កម្ពុជាដោយសារស៊ីហ្គេម/ប៉ារ៉ាហ្គេម និងទំនិញនាំចេញ	៦៦៥

១. មិនទុកឲ្យកូនចៅណាម្នាក់នៅក្រៅសេវាអប់រំ គ្មានជំនាញពិតប្រាកដឡើយ

ទិវាគ្រូបង្រៀនឆ្នាំ ២០១៧, ៥ តុលា ២០១៧

... យើងឃើញថា បរិមាណក្នុងវិស័យអប់រំចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលតម្រូវឲ្យមានការបង្កើនសាលារៀន/គ្រូបង្រៀន (ពិសេសនៅតាមតំបន់ជាប់ស្រយាល) និងការបង្កើនមូលដ្ឋានសម្ភារៈថែមទៀតដោះស្រាយកំណើនសិស្សនិស្សិតនេះ ... **យើងត្រូវការកម្លាំងសរុបរបស់ជាតិទាំងមូល ដោយរួមគ្នាដោះស្រាយ មិនត្រូវទុកឲ្យកូនចៅយើងណាម្នាក់ស្ថិតនៅក្រៅសេវាអប់រំ ឬជាមនុស្សដែលគ្មានជំនាញពិតប្រាកដនោះឡើយ ជាពិសេសក្រុមងាយរងគ្រោះដែលត្រូវយកចិត្តទុកដាក់ជាបឋម ...**៕

២. គ្មានអ្វីចែកឱ្យដែលគង់វង្សជាងចំណេះវិជ្ជាទេ

ចែកសញ្ញាបត្រដល់និស្សិត នៃសាកលវិទ្យាល័យធនធានមនុស្ស, ២៧ មេសា ២០១៧

... **គ្មានអ្វីចែកឱ្យដែលគង់វង្សជាងការចែកចំណេះវិជ្ជាទេ។ ដំពុកម្តាយ អាចចែកជូននូវទ្រព្យសម្បត្តិឱ្យកូនចៅជាការល្អហើយ ប៉ុន្តែបើសិនជាចែកតែទ្រព្យសម្បត្តិ ហើយមើលស្រាលដល់ការចែកចំណេះវិជ្ជាគឺជាការខុសឆ្គង។ មាសប្រាក់អាចចាយវាយអស់ ខ្លះចាញ់ល្បែង ខ្លះប្រើមិនចំគោលដៅ ខ្លះត្រូវចោរលួចប្លន់ ខ្លះត្រូវភ្លើងឆេះ ក៏ប៉ុន្តែសម្រាប់ចំណេះវិជ្ជាវិញ កណ្តៀរក៏វាមិនកោរ កណ្តុរក៏វាមិនកាត់បានដែរ។** ប៉ុល ពត សម្លាប់មនុស្ស ធ្វើបាបផ្លូវចិត្តផ្លូវកាយ ប៉ុន្តែពួកគេមិនអាចយកចំណេះវិជ្ជាចេញពីខួរក្បាលមនុស្សបានទេ។ ដូច្នេះ ទាំងរដ្ឋទាំងក្រុមគ្រួសារ និងបុគ្គលម្នាក់ៗ ត្រូវបន្តការខិតខំ ...៕

៣. ស្គារវិស័យអប់រំពីបាតដៃទទេ ក្លាយជាមោទនភាពជាតិសាសន៍កម្ពុជា

ចែកសញ្ញាបត្រនិស្សិតអធិការអប់រំ ... គ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសភាសាបារាំង-ខ្មែរ, ២២ មីនា ២០១៨

... យើងអាចសង្កេតមើលការវាយតម្លៃទាំងឡាយ ដែលទាក់ទងនឹងការឈានឡើងបន្តិចម្តងៗរបស់យើងពីស្ថានភាពមួយដ៏លំបាក ... **នៅលើពិភពលោកនេះគ្មានប្រទេសណាដែលបំផ្លិចបំផ្លាញដល់ឫសគល់ទៅក្នុងវិស័យអប់រំ និងវិស័យ**

ដទៃទៀត ដូចជានៅកម្ពុជានោះទេ ... ប្រទេសខ្លះ ទោះបីមានសង្គ្រាមហែកហួរបន្ទាប់ពីបានឯករាជ្យទៅ គេបន្តលើមូលដ្ឋាននៃហេដ្ឋារចនាសម្ព័ន្ធចាស់ទាំងផ្នែកទន់និងផ្នែករឹង។ **សំរាប់យើង បន្ទាប់ពីរំដោះចេញពីរបប ប៉ុល ពត យើងគ្មានអ្វីក្រៅតែពីការខិតខំប្រមូលផ្តុំកសាងឡើងវិញពីបាតដៃទទេរនោះទេ។ ការខិតខំប្រឹងប្រែងរបស់យើងបានក្លាយជាមោទនភាពសម្រាប់ជាតិសាសន៍យើង ...៕**

៤. មិនអាចចាក់បញ្ចូលចំណេះដឹងតាមឈាមទេ គឺកើតចេញពីការខិតខំដោយខ្លួនឯង

ចែកសញ្ញាបត្រនិស្សិត នៃសាកលវិទ្យាល័យអាស៊ី-អឺរ៉ុប, ២១ មីនា ២០១៩

... បើយើងមិនជួយខ្លួនឯង គ្មានអ្នកណាជួយយើងកើតទេ សូម្បីតែធ្វើការរៀនសូត្រ។ សាស្ត្រាចារ្យបានបង្រៀននិស្សិតហើយ ក៏ប៉ុន្តែបើនិស្សិតម្នាក់ៗមិនព្រមរៀនទេ គឺមិនអាចនឹងទទួលបានជោគជ័យទេ។ គ្មានវិធីសាស្ត្រណាមួយដែលអាចឲ្យនិស្សិតទទួលបានចំណេះដឹង តាមរយៈចាក់យកឈាមរបស់សាស្ត្រាចារ្យទៅបញ្ចូលឈាមឲ្យនិស្សិត ឱ្យនិស្សិតចេះដូចសាស្ត្រាចារ្យនោះទេ។ ស្ថានភាពដូចគ្នានេះ គឺវាមិនខុសពីប្រទេសក្រៅមិនអាចមកធ្វើការសម្រេចចិត្ត និងកិច្ចខិតខំប្រឹងប្រែងជំនួសឲ្យយើងបាននោះទេ ...៕

៥. សេរីភាវូបនីយកម្មអប់រំ លក្ខខណ្ឌកំណត់ក្នុងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក

ចែកសញ្ញាបត្រនិស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រង, ២៣ មេសា ២០១៩

... ពេលកម្ពុជាសកម្មចរចាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ខ្ញុំនៅចាំបានថា ប្រទេសមួយដែលមិនទាន់ធ្វើសេរីភាវូបនីយកម្មលើបញ្ហាអប់រំដូចកម្ពុជាផង បានដាក់សំណួរមកកាន់កម្ពុជា ត្បិតថាដើម្បីបានចូលជាសមាជិកអង្គការពាណិជ្ជកម្ម សមាជិកចាស់មានសិទ្ធិដាក់សួរមកឱ្យអ្នកសុំចូលថ្មីឆ្លើយ ... ប្រទេសមួយនៅតំបន់អាមេរិកបានសួរមកកម្ពុជាថា **តើមានការធ្វើសេរីភាវូបនីយកម្មលើវិស័យអប់រំហើយឬនៅ? ក្នុងពេលដែលយើងមានសាកលវិទ្យាល័យឯកជនមត្តេយ្យសិក្សាឯកជន បឋមសិក្សាឯកជនរួចទៅហើយ ... វាស្របនឹងគោលដៅនៃអង្គការពាណិជ្ជកម្មពិភពលោកតម្រូវ ...៕**

៦. ភាគរយនៃសិស្សពូកែមានខ្ពស់ ក្នុងចំណោមកូនអ្នកក្រីក្រ

ចែកសញ្ញាបត្រដល់និស្សិត នៃសាកលវិទ្យាល័យ កូមិន្តភ្នំពេញ, ៣ មិថុនា ២០១៩

... បើវណ្ណៈកណ្តាល ឬវណ្ណៈអ្នកមាន ឬវណ្ណៈអ្នកក្រ អ្នកមានប្រាក់ចំណូលទាបអ្នកមានចំណូលមធ្យម អ្នកមានចំណូលខ្ពស់ គឺខុសៗគ្នា ប៉ុន្តែអ្វីដែលយើងអាចធ្វើទៅរួច គឺការកាត់បន្ថយគម្លាតលើបញ្ហាខួរក្បាលហ្នឹងតែម្តង ... ព្រោះមនុស្សកើតមកស្រាតដូចតែគ្នា ... **ប្រសិនបើយើងផ្តល់ឱកាសដូចគ្នា ហើយមានសាលារៀនគ្រប់ទីកន្លែង កូនអ្នកក្រនិងកូនអ្នកមានរៀននៅក្នុងកម្មវិធីដូចគ្នា (គេរៀនបានដូចគ្នា) ... នៅពេលដែលមានការប្រឡងមធ្យមសិក្សាទុតិយភូមិ យើងឃើញថា មានកុមារកំ យុវជន/នារីជាកូនអ្នកក្រីក្រប្រឡងជាប់និទ្ទេស A ច្រើន។** បើគិតជាភាគរយ គឺមានច្រើនជាងចំនួនកូនអ្នកដែលមានលទ្ធភាពទៅទៀត ...៕

៧. ជំរុញគោលដៅខេត្តមួយសាកលវិទ្យាល័យមួយ

ចែកសញ្ញាបត្រជូននិស្សិតសាកលវិទ្យាល័យឯកទេស នៃកម្ពុជា, ១១ ធ្នូ ២០១៩

... រដ្ឋាភិបាលបានដាក់ចេញគោលដៅខេត្តមួយសាកលវិទ្យាល័យមួយ ក៏ប៉ុន្តែមកដល់ពេលនេះ យើងទើបនឹងមានសាកលវិទ្យាល័យខេត្តមួយចំនួនប៉ុណ្ណោះ គឺមាននៅខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ឯក្រៅពីនោះយើងកំពុងតែខិតខំដើម្បីជម្រុញឱ្យមានសាកលវិទ្យាល័យនៅតាមខេត្ត។ ពេលដែល(មិនទាន់មាន)សាកលវិទ្យាល័យ(ស្ថាប័នសិក្សា)វិស័យឯកជន ក៏មានសាខានៅតាមខេត្តមួយចំនួន ...៕

៨. ផុតពីដំណាក់កាល "អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ"

ចែកសញ្ញាបត្រដល់អធិការអប់រំ និស្សិត គរុនិស្សិត និងគរុសិស្ស
នៃវិទ្យាស្ថានជាតិអប់រំ, ១៨ កុម្ភៈ ២០២០

... នេះគឺសម័យសេដ្ឋកិច្ចបច្ចេកវិទ្យា។ សម័យឌីជីថល។ ទាមទារឱ្យយើងខិតខំកាន់តែច្រើនក្នុងការបណ្តុះបណ្តាលធនធានមនុស្ស។ ក្រឡេកទៅក្រោយវិញ យើងឃើញថា ទីនេះជាកន្លែងបណ្តុះបណ្តាលគ្រូតាំងពីជំនាន់ឪពុកក្មេករបស់ ហង់ជួន ណារ៉ុន ធ្វើជាឧបការីរដ្ឋមន្ត្រីអប់រំ ... ឪពុកបង្កើតរបស់ ហង់ជួន ណារ៉ុន ក៏

(ធ្វើការ)នៅក្រសួងហ្នឹងដែរ ... ខ្ញុំក៏បានមកចូលរួមបង្រៀននៅទីនេះ ... បង្រៀនថ្ងៃមិនចប់ បង្រៀនយប់ទៀត ... **យើងបានឈានពីស្ថានភាពហ្នឹងឆ្ងាយមកហើយ។** ដំណាក់កាល **"អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ" ដែលយើងបានជួបនិងធ្វើនៅពេលនោះ (បានកន្លងផុតទៅហើយ)។ ឯក្របខណ្ឌគ្រូបង្រៀនវិញ កន្លែងណាធ្វើអីបានមុន ក៏ធ្វើទៅ។ នៅភ្នំពេញ យើងបើកបានតែសាលាមួយចំនួនទេ ... ឯនៅតាមជនបទវិញ ប្រជាពលរដ្ឋគាត់ម្ខាស់ការ ... ហ្នឹងនិយាយពីការរៀបចំផែនផលិតកម្ម និងវិស័យអប់រំឡើងវិញ** ...។

៩. ដំណាក់កាលសេដ្ឋកិច្ចចំណេះដឹង ចាំបាច់ត្រូវបណ្តុះបណ្តាលធនធានមនុស្ស

ដាក់ឱ្យប្រើប្រាស់អគារសិក្សាចំនួន២ ខ្នង និងប្រគល់សញ្ញាបត្រជូននិស្សិតនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ១ មីនា ២០២៣

... វឌ្ឍនភាពលើវិស័យអប់រំនេះ ឆ្លុះបញ្ចាំងអំពីការកែចម្រើនគួរឱ្យកត់សម្គាល់នៃប្រទេសជាតិរបស់យើង។ បើនិយាយពីជំនាន់ត្រឹមឆ្នាំ១៩៧៥ សួរថា អ្នកជាប់បរិញ្ញាបត្រមានប៉ុន្មាននាក់ទៅ? មានដែរ តែវាមានតិច។ ឥឡូវហ្នឹង(អ្នកចប់)បរិញ្ញាបត្រក្នុងមួយឆ្នាំៗ មានច្រើន។ **យើងមានបរិញ្ញាបត្រ យើងមានបរិញ្ញាបត្រវែង យើងមានបរិញ្ញាបត្រជាន់ខ្ពស់ យើងមានថ្នាក់បណ្ឌិត យើងមានអ្នកដែលបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីជំរុញការអភិវឌ្ឍប្រទេសជាតិ។ ដំណាក់កាលសេដ្ឋកិច្ចចំណេះដឹង ជាដំណាក់កាលដែលចាំបាច់ត្រូវបណ្តុះបណ្តាលធនធានមនុស្ស** ...។

១០. ចំណាយក្នុងវិស័យអប់រំផ្តល់ផលចំណេញសេដ្ឋកិច្ចសង្គមសម្រាប់ការអភិវឌ្ឍជាតិ

ដាក់ឱ្យប្រើប្រាស់អគារសិក្សាចំនួន២ ខ្នង និងប្រគល់សញ្ញាបត្រជូននិស្សិតនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ១ មីនា ២០២៣

... ដៃគូអាចជួយយើងបន្ថែមទៀត ជាអគារ ឬជាសាលា ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ សំរាប់ការបណ្តុះបណ្តាលធនធានមនុស្ស។ បើនៅឯក្រចេះចិនជួយសង់ជាសាកលវិទ្យាល័យក្រចេះតែម្តង។ ពេលដែលបង្កើតខេត្តត្បូងឃ្មុំ យើងកសាងនូវសាកលវិទ្យាល័យនៅត្បូងឃ្មុំតែម្តង។ **យើងមិនខ្លាចចំណាយ**

ដើមទុន(លើវិស័យអប់រំទេ) ព្រោះផលដែលទទួលបានមកវិញធំណាស់។ ការសាងសង់អគារសិក្សា រួមនឹងប្រាក់បៀវត្សសាស្ត្រាចារ្យគ្រូបង្រៀនដែលយើងត្រូវចំណាយ ដើម្បីបង្កើតចំណេះដឹងសម្រាប់យុវជន/នារី និងប្រជាពលរដ្ឋរបស់យើង វាជាផលចំណេញខាងវិស័យសេដ្ឋកិច្ចសង្គមដ៏ធំសម្រាប់ការអភិវឌ្ឍជាតិ។ ភាពធន់នៃសេដ្ឋកិច្ច មិនពឹងផ្អែកលើប្រាក់ចំណូលម្តងម្កាលទេ គឺពឹងផ្អែកលើចំណេះដឹងក្នុងដំណាក់កាលនេះ ហើយដំណាក់កាលណាក៏ដោយ ធនធានមនុស្សមិនអាចបំបាត់ចោល (និង)មិនអាចមើលរំលងបានទេ ...។

១១. ត្រូវយកចិត្តទុកដាក់ជាពិសេសលើអក្សរសាស្ត្រខ្មែរ

ទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៥ ឆ្នាំ២០២៣ និងពិធីសំណេះសំណាលជាមួយសិល្បករ/ការិនីទូទាំងប្រទេស លើកទី៤, ២ មីនា ២០២៣

... **យើងត្រូវយកចិត្តទុកដាក់ជាពិសេសលើបញ្ហាអក្សរសាស្ត្រខ្មែរ។ មកដល់ពេលនេះ ការប្រើប្រាស់ភាសាខ្មែរ (ហាក់ដូចជាមិនក្សាបាននូវអត្ថសញ្ញាណភាសាដើមត្រឹមត្រូវ)។** ខ្ញុំបានឃើញមានការសរសេរពាក្យ «ដែរ» (ដែលប្រើក្នុងឃ្លាដូចជា) "ខ្ញុំទៅដែរ" (កំពុងតែក្លាយទៅជាការសរសេរឬប្រើ "ដែល" គឺទៅជា) "ខ្ញុំទៅដែល" ទៅវិញ ... នេះអាចជាចំណុចតូចមួយនៅក្នុងចំណោម(ការយល់និងប្រើប្រាស់មិនបានត្រឹមត្រូវក្នុង)អក្សរសាស្ត្រខ្មែរដែលកំពុងតែវិវត្តន៍។ ការប្រើប្រាស់បណ្តាញសង្គមកាន់តែច្រើន ការសរសេរខុសក៏មានច្រើន។ ជាការល្អមួយដែរ ដែលនៅក្នុងទូរស័ព្ទ smart phone នីមួយៗ មានវចនានុក្រមសម្តេចព្រះសង្ឃរាជ ណាត។ យ៉ាងណាក្តី យើងត្រូវបន្តការខិតខំពង្រឹងសមត្ថភាពអក្សរសាស្ត្រខ្មែរក្នុងចំណោមប្រជាពលរដ្ឋ ...។

១២. កាត់បន្ថយគម្លាតឌូរក្បាលរវាងបុរសនិងស្ត្រី

ចែកសញ្ញាបត្រជូនដល់និស្សិត នៃសាកលវិទ្យាល័យ វេស្ទើន, ១៣ កុម្ភៈ ២០១៨

... នៅតាមខេត្តមួយចំនួនមានសកលវិទ្យាល័យហើយ ... តែមិនប្រាកដថាខេត្តដែលមានសកលវិទ្យាល័យនោះ អាចទទួលសិស្សនារីបានទាំងអស់ទេ ដោយសារតែសិស្សនៅតាមភូមិឆ្ងាយៗ ពីសកលវិទ្យាល័យនោះ។ ទាមទារឱ្យរដ្ឋធ្វើការនិ

យោគឬក៏សាលាត្រូវធ្វើការវិនិយោគថែមទៀតដើម្បីនិស្សិតជាស្ត្រីទទួលបានការបណ្តុះបណ្តាល។ **យើងត្រូវដើរព្រមៗគ្នា លើកិច្ចការដែលពាក់ព័ន្ធនឹងការបណ្តុះបណ្តាលធនធានមនុស្ស ក្នុងហ្នឹងមានការកាត់បន្ថយគម្លាតរវាងបុរសនិងស្ត្រីអំពីការងារ ជាពិសេសខ្ញុំចង់ឱ្យការកាត់បន្ថយគម្លាតខាងឧក្រិដ្ឋរវាងបុរសនិងស្ត្រីនេះ ដំណើរការទៅមុន ...។**

១៣. ចប់បរិញ្ញាហើយ ស្ត្រីគប្បីបន្តទៅបរិញ្ញាបត្រជាន់ខ្ពស់

ចែកសញ្ញាបត្រនិស្សិតនៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ១១ មីនា ២០១៩

... អំពាវនាវចំពោះស្ត្រីដែលចប់បរិញ្ញាហើយ គប្បីបន្តឈានជើងឆ្ពោះទៅរកបរិញ្ញាបត្រជាន់ខ្ពស់។ ក្នុងនោះក៏អំពាវនាវចំពោះមាតាបិតា និងអំពាវនាវចំពោះស្វាមីរបស់**ស្ត្រីដែលចង់ទទួលបាននូវបណ្តុះបណ្តាលបន្ថែមទៀត អោយបន្តការខិតខំដើម្បីលើកកម្ពស់ការស្មើភាព ទទួលបានការការបណ្តុះបណ្តាល (ហើយ) នៅក្នុងការតែងតាំងមុខតំណែង ក៏មានការតម្រូវថា ... ទាល់តែអ្នកឯងមានបរិញ្ញាជាន់ខ្ពស់ទើបទទួល ឬក៏ទទួលអោយប្រឡង ... តែយើងមានអតុល្យភាពតាំងពីក្នុងមហាវិទ្យាល័យ និងនៅក្នុងស្ថាប័ន មិនថាផ្នែកផ្ទៃ មិនថាផ្នែកឯកជននោះទេ ... ទាក់ទងជាមួយនឹងសមាសភាពយេនឌ័រ ...។**

១៤. ស្ត្រីរៀនចប់ថ្នាក់បរិញ្ញាជាន់ខ្ពស់និងបណ្ឌិត ដើម្បីឆ្លើយតបគោលដៅអភិវឌ្ឍសមភាពយេនឌ័រ

ចែកសញ្ញាបត្រនិស្សិត នៃសាកលវិទ្យាល័យ ជាតិគ្រប់គ្រង, ២៣ មេសា ២០១៩

... សូមលោកជំទាវអឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារីតាមដានឱ្យជាប់អំពីចំណុចទាក់ទិនកំណើន(អត្រាស្ត្រីបញ្ចប់ថ្នាក់បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិត) ទោះបីជាមិនទាន់ស្មើភាពគ្នាដល់ទៅ៥០% លើ៥០% ក៏ដោយចុះ ... **លើកទឹកចិត្តឱ្យមានកំណើនជាស្ត្រី ព្រោះយើងបានដាក់ចេញគោលដៅតែងតាំងមន្ត្រីជាស្ត្រី និងអ្នកធ្វើការក្នុងកម្រិតនយោបាយក្តី ក្នុងកម្រិតរដ្ឋបាលក្តី និងក្នុងកម្រិតទាក់ទិនជាមួយនឹងធុរកិច្ច** យើងលើកទឹកចិត្ត (និងផ្តល់)ឱកាសសម្រាប់ស្ត្រី ...

ដូច្នេះ ត្រូវទាក់ទាញនិងលើកទឹកចិត្តស្វាមី ឪពុកម្តាយ ផ្តល់ឱកាសដល់កូនស្រីដើម្បីបន្តការរៀនសូត្រយកកម្រិតកាន់តែខ្ពស់ ... **អត្រាកើនឡើងជាង៣១% នេះអាចចាត់ទុកជាកំណើនមួយល្អ។ រំពឹងទុកថា អត្រានៃស្ត្រីដែលជាប់ថ្នាក់បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិត មានចំនួនកាន់តែច្រើនឆ្លើយតបទៅនឹងគោលដៅស្តីពីការអភិវឌ្ឍសមភាពយេនឌ័រ ...។**

១៥. ពីសមភាពយេនឌ័រនៅកម្រិតបឋមសិក្សា មធ្យមសិក្សា និងបរិញ្ញាបត្រ ទៅបរិញ្ញាបត្រជាន់ខ្ពស់និងបណ្ឌិត

ចែកសញ្ញាបត្រដល់និស្សិត នៃសាកលវិទ្យាល័យ ពុទ្ធិសាស្ត្រ, ១៧ សីហា ២០២២

... គួរតែកត់សម្គាល់មួយទៀត មើលក្នុង(របាយការណ៍)នេះ (មាននិស្សិតស្រីច្រើនជាងនិស្សិតប្រុស) ... នៅទីនេះ ថ្នាក់បរិញ្ញាបត្ររង នារីមានទៅដល់ ៧១%។ ថ្នាក់បរិញ្ញាបត្រ នារីមានដល់ ៧៧%។ ដល់បរិញ្ញាបត្រជាន់ខ្ពស់ នារីមានត្រឹមតែ ២៤%។ ធ្លាក់ចុះ ... **យើងបានជំរុញមួយជំហានឱ្យមានសមភាពក្នុងកម្រិតបឋមសិក្សា មធ្យមសិក្សា រហូតដល់បរិញ្ញាបត្ររង និងបរិញ្ញាបត្រ ... តាមរយៈនៃការជំរុញសាលារៀនដល់មូលដ្ឋាន និងផ្តល់តម្លៃកាន់តែខ្លាំងដល់ការសិក្សារបស់ស្ត្រី។ ប៉ុន្តែចូលដល់បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ស្ត្រីដល់វ័យរៀបការ និងត្រូវមានកូន។ អញ្ចឹងទេ មួយចំនួនមិនអាចបន្តការសិក្សាតទៅទៀត។ បញ្ចប់ត្រឹមបរិញ្ញាបត្រ។ យ៉ាងណាក្តី ត្រូវលើកទឹកចិត្តឱ្យស្ត្រីជំនះបន្តការសិក្សា ទោះបីមានប្តី/កូនហើយក៏ដោយ តាមលទ្ធភាពដែលអាចធ្វើទៅបាន។ យើងត្រូវជំរុញបន្ត** ... នេះជាការកត់សម្គាល់របស់ខ្ញុំ ...។

១៦. ត្រូវដឹងគុណគ្រូ ដោយ "គ្រូមួយថ្ងៃ គឺគ្រូមួយជីវិត"

សំណេះសំណាលជាមួយសិស្សជាប់និទ្ទេស A ឆ្នាំសិក្សា ២០២០-២១, ៣ ឧសភា ២០២២

... ពេលខ្លះគ្រូអត់ទទួលបានគុណសម្បត្តិអីទេ ប៉ុន្តែបែរជាទទួលបាននូវគុណវិបត្តិទៅវិញ ... បើកូនគេពូកែ គេថាមកពីពូជគេពូកែ ... ដល់កូនរៀនមិនពូកែថាគ្រូហ្នឹងវាអន់ ... (ប្រការ)នេះត្រូវចៀសវាង។ **ត្រូវយកចិត្តទុកដាក់ទៅបញ្ហាគុណ**

គ្រូ។ តិចឃើញថា គ្រូបង្រៀនតាំងពីថ្នាក់កុមារដ្ឋានមក(មិនមានការរើកចំរើនឃើញ)នៅតែប៉ុណ្ណឹង (ខណៈ)ខ្លួនចប់បរិញ្ញាបត្រហើយ ឯគ្រូឯងនៅតែបង្រៀនថ្នាក់កុមារដ្ឋានដដែល។ នេះជាការ(គិត)ខុសស្រឡះ។ ផ្តើមចេញពីកុមារដ្ឋាននោះហើយ ធ្វើឱ្យខ្លួនឯងមានបរិញ្ញា(បត្រ) ... គ្រូបានដឹកដៃ បានបង្ហាត់បង្ហាញតាំងពីដើម។ ពួកគាត់បានលះបង់ច្រើនណាស់។ គ្រូមួយថ្ងៃ គឺគ្រូមួយជីវិត ...។

១៧. គ្រូមិនអាចក្លាយជាអ្នកមាន តែបង្រៀនសិស្សឲ្យក្លាយជាអ្នកមានបាន

ទិវាគ្រូបង្រៀនឆ្នាំ២០១៨, ៥ តុលា ២០១៨

...តើគ្រូណាមួយធ្វើអ្នកមានធ្វើសេដ្ឋី? មិនមានទេ។ បង្រៀនកូនសិស្សអោយធ្វើសេដ្ឋីបាន ប៉ុន្តែខ្លួនឯងជំពាក់ថ្លៃបោះពុម្ពសៀវភៅ។ យើងពិនិត្យមើលកន្លែងហ្នឹង។ អ្នកទាំងអស់គ្នានៅខាងលើនេះ សុទ្ធតែឯកឧត្តមលោកជំទាវគាត់សុទ្ធតែជាកូនសិស្សរបស់គ្រូ។ ប៉ុន្តែក្លាយទៅជា សម្តេច ឯកឧត្តម លោកជំទាវ អស់ទៅហើយ។ ខ្លះទៅជាសេដ្ឋី ពាណិជ្ជករអាជីវករាប់មិនអស់ទេ។ គ្រូបង្រៀននៅតែជាគ្រូបង្រៀនដដែលហ្នឹង។ **មានន័យថា គ្រូបង្រៀនបានចែកទ្រព្យសម្បត្តិឱ្យសិស្ស ហើយកូនសិស្សយកទៅធ្វើមានធ្វើបាន** ...។

១៨. កូនរៀនអន់ ជេរគ្រូ កូនរៀនពូកែ ថាពូជខ្លួនពូកែ

ចែកសញ្ញាបត្រជូនដល់និស្សិតនៃសាកលវិទ្យាល័យ វ៉េស្ទើន, ២៦ មករា ២០២៣

... យើងមានបរិមាណនិស្សិតជាប់ឧត្តមសិក្សាចូល ១០ម៉ឺននាក់/ឆ្នាំ។ ប៉ុន្តែសួរថា អ្នកដែលពូកែមានប៉ុន្មាន(នាក់)? យើងត្រូវរកចម្លើយមួយ ... ក្នុងសាលាមិនប្រាកដថាយើងពូកែទេ ប៉ុន្តែនៅពេលធ្វើការងារ ទើបជាការសាកល្បងសមត្ថភាពពិតប្រាកដ ... **មានការលើកឡើងថា គ្រូមិនសូវទទួលផលប៉ុន្មានទេ។ បើបង្រៀនកូនគេទៅរៀអន់ គេជេរគ្រូ។ គេថាគ្រូនឹងមិនចំណាប់។ ដល់កូនគេរៀនពូកែ គេថាពូជអញវាពូកែ។ គ្រូនៅតែអត់ដដែល។ កូនគេមិនពូកែ គេថាគ្រូអន់ បានជាសិស្សមិនពូកែ។** អញ្ចឹងទេ មាតាបិតាអាណាព្យាបាលត្រូវយល់កន្លែងហ្នឹង ...។

១៩. មន្ត្រីរាជការស៊ីវិល កុំច្រណែនគ្រូបង្រៀននិងគ្រូពេទ្យ ដែលមានប្រាក់ខែខ្ពស់ជាង

ចែកសញ្ញាបត្រជូនឧទ្ទេសអធិការអប់រំ និស្សិតបរិញ្ញាជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ គ្រូបរិញ្ញា+១, ២២ មីនា ២០១៧

... ពីមួយឆ្នាំទៅមួយឆ្នាំ យើងបង្កើនថវិកាតាមទំហំនៃអាទិភាពសម្រាប់វិស័យអប់រំ ជាពិសេសគឺវិស័យធនធានមនុស្សនេះ **... សូមអំពាវនាវឲ្យខាងប្រជាប់អាវុធឬក៏ផ្នែកដទៃទៀត កុំច្រណែនជាមួយនឹងគ្រូបង្រៀន ព្រោះគ្រូបង្រៀននិងគ្រូពេទ្យ ប្រាក់ខែខ្ពស់ជាង ... គាត់ត្រូវការគ្រូបង្រៀនកូនរបស់គាត់ និងចៅរបស់គាត់ ក៏ត្រូវការគ្រូពេទ្យដែរ** ... ដល់ខែនេះចូលឆ្នាំ ឯណាឡើងបៀវត្សរ៍ផង ឯណាប្រាក់ឧបត្ថម្ភម្នាក់ ៥ម៉ឺនរៀល ឯណាបើកមុនចូលឆ្នាំទៀតផង។ ប្រាក់ហូរចូលទីផ្សារធំ។ ត្រូវតែមានវិធានការទប់ទល់ ដើម្បីចៀសវាងនូវប្រាក់ចុះថោក...។

២០. យកសាលាចិញ្ចឹមសាលា លើកកម្ពស់ជីវភាពសាស្ត្រាចារ្យបុគ្គលិក និងវឌ្ឍនភាពសាកលវិទ្យាល័យ

ចែកសញ្ញាបត្រសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ២២ មិថុនា ២០១៨

... យើងបានប្រើប្រាស់វិធីសាស្ត្រយកសាលាចិញ្ចឹមសាលា។ មិនមែនគ្រាន់តែការចិញ្ចឹមដើម្បីការរស់រានមានជីវិតទេ ក៏ប៉ុន្តែ យើងបានសង្កេតឃើញថា សាកលវិទ្យាល័យទាំងឡាយ ដែលរដ្ឋបានផ្តល់ឱកាសឲ្យសាកលវិទ្យាល័យនោះ បានប្រើប្រាស់ធ្វើជាទីកន្លែងសម្រាប់ការរៀន ដោយផ្តល់ជាអាហារូបករណ៍របស់រដ្ឋផង សំរាប់ការរៀនដោយបង់ថ្លៃផង ហើយមិនគ្រាន់តែបានលើកកម្ពស់ជីវភាពសាស្ត្រាចារ្យនិងបុគ្គលិកបម្រើការនៅទីនោះទេ ក៏ប៉ុន្តែបានកសាងអគារបន្ថែមថ្មីៗ ...នោះហើយជាវិធីដើរ ដើម្បីចៀសវាងនូវការលំបាក ...។

២១. អន្តរាសិកដ្ឋាន ទាំងគ្រូនិងសិស្ស នៅតែជាបញ្ហាប្រឈម

ចែកសញ្ញាបត្រដល់អធិការអប់រំ និស្សិត គរុនិស្សិត និងគរុសិស្ស នៃវិទ្យាស្ថានជាតិអប់រំ, ១៨ កុម្ភៈ ២០២០

... ពេលដែលធ្វើដំណើរ(ជាង ៦ពាន់គីឡូម៉ែត្រ) ខ្ញុំបានធ្វើការជួបប្រាស្រ័យជាមួយលោក/អ្នកគ្រូតាមសាលាមួយចំនួន។ **ខ្ញុំបានឃើញថា អន្តរាសិកដ្ឋាន**

សំរាប់ការស្នាក់នៅរបស់លោក/អ្នកគ្រូ ឬហៅថាផ្ទះសំណាក់របស់លោក/អ្នកគ្រូ ក៏ដូចជាផ្ទះសំណាក់របស់សិស្សានុសិស្ស គឺជាបញ្ហាប្រឈមរបស់យើង។ ពេលនោះ ខ្ញុំបាន(សំរេច)ធ្វើឱ្យមានកន្លែងគ្រូស្នាក់នៅ តាមកន្លែងមួយចំនួន។ ប៉ុន្តែ វាមិនទាន់ឆ្លើយតបគ្រប់គ្រាន់ទេ។ យើងនៅប្រើប្រាស់ថវិកាសម្រាប់គ្រូបង្រៀនលើឈ្នួលផ្ទះ ដែលមានកន្លែងខ្លះបាន ៨ម៉ឺនរៀល កន្លែងខ្លះបាន ១០ម៉ឺនរៀល និង ១២ម៉ឺនរៀល ដើម្បីដោះស្រាយបញ្ហានេះ ...។

២២. សិស្សរៀនកាន់តែពូកែ បង់ប្រាក់កាន់តែតិច ជាចំណុចដែលរាជរដ្ឋាភិបាលចង់បាន

ចែកសញ្ញាបត្រសាកលវិទ្យាល័យ វេស្ទើន, ១៣ កុម្ភៈ ២០១៨

... សូមសម្តែងនូវការកោតសរសើរ ចំពោះការខិតខំទាំងអស់របស់សាកលវិទ្យាល័យ ដែលបានធ្វើក្នុងរយៈពេលកន្លងទៅ ... **លោក តែ ណូរិន បានលើកឡើងនូវចំណុចមួយថា សិស្សរៀនកាន់តែពូកែ បង់ប្រាក់កាន់តែតិច។ នេះជាចំណុចដែលយើងចង់បាន ទាក់ទងទៅនឹងគុណភាពនៃការបណ្តុះបណ្តាលរបស់យើង។** យើងនឹងមាននិស្សិតដែលជាធនធានមនុស្សសម្រាប់ជាតិបន្ថែមទៀត ... ជួយដល់ការបណ្តុះបណ្តាលធនធានមនុស្ស សម្រាប់ព្រះរាជាណាចក្រកម្ពុជា ...។

២៣. សិក្សា កុំសេពគ្រឿងញៀន កុំធ្វើសកម្មភាពផ្ទុយពីដំណើរការអភិវឌ្ឍខ្លួន

ចែកសញ្ញាបត្រសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២២ ឧសភា ២០១៨

... បន្តអំពាវនាវឲ្យខិតខំក្សាសន្តិភាព ដើម្បីជានាដល់ការអភិវឌ្ឍ ... អំពាវនាវចំពោះយុវជនឲ្យយកការសិក្សាធ្វើជាចំណុចសំខាន់ កុំសេពគ្រឿងញៀន ឬធ្វើសកម្មភាពណាដែលមិនស្របជាមួយនឹងដំណើរការអភិវឌ្ឍខ្លួន។ ការអភិវឌ្ឍណាមួយត្រូវចាប់ផ្តើមពីមនុស្សម្នាក់ៗ ... អ្នកដែលនៅទីនេះជានិស្សិតចប់បរិញ្ញា ឬបរិញ្ញាជាន់ខ្ពស់ សុទ្ធតែមានការយល់ដឹងខ្លួនឯងហើយ។ ចំណេះវិជ្ជាមិនអាចផ្ទេរពីមនុស្សម្នាក់ទៅមនុស្សម្នាក់ តាមរបៀបចាក់ខួរក្បាលមនុស្សម្នាក់ ទៅចាក់ឲ្យមនុស្សម្នាក់បានទៀតទេ បើខ្លួនគ្មានការខិតខំ ...។

២៤. រៀនមួយជីវិត បើទ្រឹងនៅមួយកន្លែង ក្លាយជាជនអកិរក្សនិយម

ចែកសញ្ញាបត្រសាកលវិទ្យាល័យ អាស៊ី-អឺរ៉ុប, ២១ មីនា ២០១៩

... និស្សិតទាំងអស់ ដែលទទួលសញ្ញាបត្រនៅថ្ងៃនេះ ទាំងព្រះសង្ឃគ្រហស្ត ត្រូវបន្តការខិតខំ មិនមែនបញ្ចប់ត្រឹម(ការទទួលសញ្ញាបត្រ)ថ្ងៃនេះទេ។ រៀនមួយជីវិត ... ធ្វើ(ជា)មេដឹកនាំ ថ្នាក់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខា ធិការ ក៏ត្រូវតែរៀនដែរ ... បច្ចេកវិទ្យាជឿនលឿនណាស់ សភាពការណ៍កាន់តែបោះជំហានលឿន ... តាមមិនទាន់ យើងនឹងក្លាយទៅជាអ្នកអកិរក្សនិយម។ ខ្ញុំបន្តអំពាវនាវឱ្យនិស្សិត បន្តការសិក្សាបន្ថែមទៀត យកជំនាញ និងការចេះដឹងកាន់តែខ្ពស់ ...។

២៥. សាកលវិទ្យាល័យរដ្ឋនិងឯកជន ជួយគ្នាទទួលនិស្សិតបរទេស

ចែកសញ្ញាបត្រដល់និស្សិត នៃសាកលវិទ្យាល័យបែលធីអន្តរជាតិ, ២ តុលា ២០១៩

... និស្សិតបរទេសកាន់តែច្រើនហើយ ដែលបានមករៀននៅកម្ពុជា។ កន្លងទៅនេះ ក្នុងពេលដែលទីប្រឹក្សារដ្ឋ លោកជំទាវ អោង សានស៊ូយ្យី របស់មីយ៉ាន់ម៉ាមកទស្សនកិច្ច ខ្ញុំក៏បានផ្តល់អាហារូបករណ៍ចំនួន ១០កន្លែងសម្រាប់និស្សិតពីសហភាពមីយ៉ាន់ម៉ា ... **ផ្តែកទៅលើ(ការរីកចំរើននៃ)សាកលវិទ្យាល័យរបស់រដ្ឋ និងសាកលវិទ្យាល័យឯកជន ខ្ញុំសង្ឃឹមថា ថ្ងៃក្រោយនឹងមានឱកាសផ្តល់អាហារូបករណ៍ សម្រាប់និស្សិតបរទេសផ្សេងទៀត ... និងថាគ្រឹះស្ថានឧត្តមសិក្សាឯកជនជួយរួមគ្នាដើម្បីទទួលយកនិស្សិតបរទេស ...។**

២៦. បើកូនរៀនខ្សោយ ត្រូវរកវិធីឱ្យកូនរៀន កុំប្រៀបធៀបជាមួយកូនអ្នកដទៃ

សំណេះសំណាលជាមួយសិស្សជាប់និទ្ទេស A ឆ្នាំសិក្សា ២០២០-២១, ០៣ ឧសភា ២០២២

... ខ្ញុំគួរតែរំលឹកបញ្ហាមួយ ដែលមាតាបិតា អាណាព្យាបាល គួរត្រូវបានយកចិត្តទុកដាក់។ សូមកុំបង្ខាំកូនខ្លួនឯង ដោយប្រៀបធៀបជាមួយកូនអ្នកដទៃ។ នេះជាការរើយប្រហារធ្ងន់ណាស់ទៅលើចិត្តសាស្ត្ររបស់កូន។ បទពិសោធន៍របស់ខ្ញុំក្នុងការគ្រប់គ្រង (និង/ឬ)បណ្តុះបណ្តាលកូន ចាត់ទុកថាខ្ញុំបានទទួលជោគជ័យ

ហើយ តែខ្ញុំនៅមានកាតព្វកិច្ចរួមចំណែកជាមួយកូនខ្ញុំ ដើម្បីបណ្តុះបណ្តាលចៅរបស់ខ្ញុំ។ តំណាមដែលខ្ញុំឱ្យកូនរបស់ខ្ញុំតម គឺជាច់ខាតកុំថា “ឯងមួយថ្ងៃៗ គិតតែលេងហ្គេមមើលកូនគេៗរៀន ... ឯងរៀនមិនពូកែ ឯងមើលកូនគេៗពូកែ” ... បើដឹងថាកូនរៀនខ្សោយ ត្រូវរកវិធីដើម្បីឱ្យកូនរៀន ... (កុំ)លើកកូនអ្នកដទៃ បន្តុះបង្អាប់កូនយើង ...។

២៧. ជំរុញចលនារៀនពេញមួយជីវិត ... មិនចេះ ត្រូវសួរ

ចែកសញ្ញាបត្រ និស្សិត នៃសាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ, ២៤ កុម្ភៈ ២០២៣

... យើងត្រូវបន្តការលើកកម្ពស់គុណភាព(ចំណេះដឹង) ដោយបន្តការរៀនសូត្រផ្ទាល់ **ដែលយើងកំពុងជំរុញចលនា “រៀនមួយជីវិត” ព្រោះ(ការ)រៀនគ្មានថ្ងៃបញ្ចប់នោះទេ ... សូម្បីតែមន្ត្រីជាន់ខ្ពស់ក៏ត្រូវតែរៀនដែរ ... (កាល)ទស្សវត្សរ៍ ៩០ មានការចូលរួមពីបណ្តាភាគីនានា ... ចាប់ផ្តើមឡើងចូលទៅធ្វើជារដ្ឋមន្ត្រី រដ្ឋ/អនុរដ្ឋលេខាធិការ ឬអភិបាល/រងខេត្តតែម្តង ដោយសារខ្លាចខ្មាសអៀន (កូនចៅ) សួរគេទៅខ្លាចអន់ ... អញ្ចឹង មនុស្សហ្នឹងនៅតែមិនចេះរហូត ... កុំខ្លាច/អៀនសួរគេទៅ។ សូម្បីតែសព្វថ្ងៃនេះខ្ញុំត្រូវតែរៀន ...។**

ហេដ្ឋារចនាសម្ព័ន្ធ/ភូមិសាស្ត្រសិក្សាធិការ

២៨. ដំណើរជាង ៦៣ន់ គម ចាយ ៤០០លាន ពង្រាយសាលា កសាងអន្តរាសិកដ្ឋាន

សំណេះសំណាលជាមួយសិស្សនិទ្ទេស A ចំនួន ១,០៤៩នាក់ សម្រាប់ឆ្នាំសិក្សា ២០២១-២០២២, ២ កុម្ភៈ ២០២៣

... យើងមើលឃើញតំបន់អតីតសមរភូមិ គឺមានវិទ្យាល័យល្អៗ។ ក្នុងដំណើរជាង ៦៣ន់គីឡូម៉ែត្រនៃការធ្វើដំណើររបស់ខ្ញុំតាមបណ្តាខេត្តនានា ខ្ញុំបានផ្តល់សាលាដែលមានស្តង់ជាថ្មី ដែលសាលានោះយើងក៏បានប្រើប្រាស់វាសម្រាប់ដាក់(អ្នកជំងឺ)កូវីដ-១៩ ... ជំនាន់នោះដូចជាចាយលុយប្រហែលជាជិត ៤០០លានដុល្លារ ហើយសាលានីមួយៗ សុទ្ធតែមានផ្ទះគ្រូបង្រៀននិងសិស្សទៀត។ អញ្ចឹងយើងពង្រាយសាលាបន្ថែមបានមួយចំនួនថែមទៀត និងការកសាងថ្មីៗបន្តបន្ទាប់តាមរយៈថវិកាជាតិក្តី តាមរយៈសប្បុរសជនក្តី ...។

២៩. ជំរុញការវិនិយោគហេដ្ឋារចនាសម្ព័ន្ធទាំងទន់ទាំងរឹងក្នុងនោះមានធនធានមនុស្ស

ជាក់ឱ្យប្រើប្រាស់អគារសិក្សាចំនួន២ ខ្នង និងប្រគល់សញ្ញាបត្រជូននិស្សិតនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ១ មីនា ២០២៣

... វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បានឆ្លងកាត់ពីដំណាក់កាលមួយទៅកាន់ដំណាក់កាលមួយ ដោយនៅដំណាក់កាលស្តារឡើងវិញ ចាប់ផ្តើមពីការលំបាកដែលពេលនោះត្រូវទទួលជំនួយពីសហភាពសូវៀត ... នៅពេលដែលសហភាពសូវៀតដួលរលំ យើងក៏ត្រូវរកអ្នកមកជំនួស ... **យើងបានប្រឹងប្រែងបន្តិចម្តងៗរហូតមកដល់ពេលនេះ ... យើងកំពុងតែជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទាំងរឹង/ទន់។ ធនធានមនុស្សក៏ជាហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់មួយដែរ ដែលយើងកំពុងតែយកចិត្តទុកដាក់។ សូមយកឱកាសនេះ អរគុណចំពោះជំនួយឧបត្ថម្ភធ្វើឡើងដោយធនាគារអភិវឌ្ឍអាស៊ី រួមនឹងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល ... សាងសង់អគារសិក្សា និងបំពាក់បរិក្ខារឱ្យបានល្អជំរុញការអភិវឌ្ឍធនធានមនុស្ស ...។**

៣០. សាកលវិទ្យាល័យឯកជនអាចរៀបចំឧត្តមសិក្សានៅតាមខេត្ត តែត្រូវរក្សាសង្គតិភាពគុណភាពអប់រំ

ចែកសញ្ញាបត្រនិស្សិតនៃសាកលវិទ្យាល័យបៀលប្រាយ, ១៦ មីនា ២០២៣

... យើងលើកទឹកចិត្តឱ្យសាកលវិទ្យាល័យឯកជនចូលរួមរៀបចំបណ្តាញឧត្តមសិក្សានៅតាមខេត្ត ដែលវាជាការកាត់បន្ថយការលំបាករបស់និស្សិត ដែលត្រូវបន្តការសិក្សា ហើយគ្មានកន្លែងស្នាក់នៅនៅទីក្រុងភ្នំពេញ។ ប៉ុន្តែ អ្វីដែលខ្ញុំសំណូមពរ គឺគុណភាពត្រូវតែដូចគ្នា រវាងអ្នករៀននៅភ្នំពេញ និងអ្នករៀនតាមបណ្តាខេត្ត ... ដូចនេះហើយបានជាយើងត្រូវតែបណ្តុះបណ្តាលសាស្ត្រាចារ្យ ដែលមានកម្រិតដូចគ្នាបញ្ជូនទៅបង្រៀននៅតាមសាកលវិទ្យាល័យនានានៅឯតាមខេត្ត ...។

៣១. ចំណេះរៀននៅសាលា ខុសគ្នាពីការងារជាក់ស្តែង៖ វិធីសាស្ត្រ៣ ដឹកនាំនិងធ្វើការងារ

ចែកសញ្ញាបត្រសាកលវិទ្យាល័យ វ៉េស្ទើន, ១៨ ធ្នូ ២០១៩

... **ចំណេះដែលរៀននៅក្នុងសាលា និងពេលដែលបំពេញការងារពិតប្រាកដមានចំណុចខុសគ្នា។** យើងទទួលបានចំណេះដឹងនៅក្នុងក្របខណ្ឌមួយ ប៉ុន្តែ

នៅពេលដែលយើងចេញធ្វើសកម្មភាពជាក់ស្តែង វាលេចឡើងនូវកត្តាជាច្រើន។ **ការដឹកនាំមួយត្រូវតែមានផែនការជាក់លាក់** ... ចាត់ទុកថាសម្រេចបាន៣០% នៃការងារដែលយើងត្រូវធ្វើ ... **ការដែលរៀបចំផែនការបានហើយ ត្រូវតែចាត់តាំងអនុវត្ត** ... (ចាំថា)ឆន្ទៈមិនអាចមានរំលងលទ្ធភាពបានទេ។ ការចាត់តាំងអនុវត្តល្អ ក៏ទើបនឹងបាន៣០% ដែរ ... ឯ**៤០% ទៀត ចំណុះលើកត្តាចៃដន្យ** ដែលឆ្លុះបញ្ចាំងពីសមត្ថភាពដោះស្រាយបញ្ហា ...៕

៣២. ការផ្តល់ការងារមិនអាស្រ័យលើកម្រិតសញ្ញាបត្រ តែគុណវុឌ្ឍិ គុណសម្បត្តិ និងគុណភាព

ចែកសញ្ញាបត្រនិស្សិត នៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ, ២៥ មីនា ២០១៩

... ជាឧទាហរណ៍ យើងទៅរកការងារធ្វើ។ អ្នកពិនិត្យផ្តល់ការងារឲ្យយើងធ្វើ ... មិនមែនល្ងង់ខ្លៅទេ។ គេច្បាស់ជាដឹងថា សមត្ថភាពរបស់យើងដល់កម្រិតណា។ កុំចាំបាច់ស្តាយសញ្ញាបត្រថាខ្ញុំមានសញ្ញាបត្រប៉ុណ្ណេះ ហេតុអ្វីក៏មិនផ្តល់ការងារឲ្យខ្ញុំ? **នៅតាមស្ថាប័នខ្លះមានការលើកឡើងថាអ្នកនោះរៀនត្រឹមតែបរិញ្ញាសោះ មកត្រួតឯងថ្នាក់ដល់បណ្ឌិត ... ការនេះវាមិនចំណុះលើ(សញ្ញាបត្រ)នោះទេតែវាចំណុះលើគុណវុឌ្ឍិ គុណសម្បត្តិ គុណភាពការងារពិតប្រាកដ**។ មិនមែនទាល់តែថ្នាក់បណ្ឌិត ទៅត្រួតបរិញ្ញាជាន់ខ្ពស់ បរិញ្ញាជាន់ខ្ពស់ ទៅត្រួតបរិញ្ញានោះទេ អាហ្នឹងសំខាន់បំផុតពិសោធន៍ការងាររបស់វានៅទីនោះ ...៕

៣៣. គ្មាននយោបាយនៅក្នុងកីឡា, កីឡាផ្សារភ្ជាប់សាមគ្គីភាព ទំនាក់ទំនងគ្រប់ប្រទេស

សំណេះសំណាលជាមួយកីឡាករ និងពិសាអាហារសាមគ្គី, ៤ មេសា ២០១៦

...ឆ្នាំ២០២៣នៅមិនឆ្ងាយ**ទេ។ យើងទាំងអស់គ្នាត្រូវប្រឹងដើម្បី ... ទទួលបាននូវកិត្តិយសសម្រាប់ជាតិនិងប្រជាជនរបស់យើង។ កីឡាគ្មាននយោបាយនៅក្នុងហ្នឹងទេ។** ដូច្នេះសង្ឃឹមថាយើងទាំងអស់គ្នានឹងរួមគ្នាដើម្បីធ្វើឲ្យជាតិរបស់**យើងមានសកម្មភាពរស់រវើក ផ្សារភ្ជាប់សាមគ្គីភាពជាមួយនឹងកីឡានិងគ្រប់ប្រភេទនៃកីឡា និងផ្សារភ្ជាប់នឹងកីឡានៃបណ្តាប្រទេសក្នុងតំបន់ ទំនាក់ទំនងរវាងប្រជាជន**

និងប្រជាជននឹងត្រូវបានលើកកំពស់ជាមួយប្រជាជននៃប្រទេសរបស់យើង និងប្រទេសដទៃ ពិសេសយុវជន គឺតាមរយៈនៃកីឡានេះឯង ...៕

៣៤. ប្រជាជនម្នាក់ ហាត់កីឡាមួយប្រភេទ ដើម្បីប្រកួត ឬដើម្បីសុខភាព

ពិធីបិទកីឡាជាតិលើកទី១, ៥ វិច្ឆិកា ២០១៦

... ខ្ញុំសូមអំពាវនាវសាជាថ្មីចំពោះប្រជាពលរដ្ឋរបស់យើង ក៏ដូចជាចំពោះយុវជននិងកុមារពិសេស **សូមខិតខំយកចិត្តទុកដាក់ហ្វឹកហាត់កីឡាមួយយ៉ាងតិច ដែលអាចចាត់ទុកថាជាប្រភេទកីឡាដែលមានលក្ខណៈជាការប្រកួតផង ហើយជាផ្នែកនៃបញ្ហាទាក់ទងនឹងបញ្ហាសុខភាពរបស់ប្រជាពលរដ្ឋផង**។ សូមជៀសឲ្យឆ្ងាយពីគ្រឿងញៀន ហើយចាប់យកកីឡាធ្វើជាសកម្មភាពដើម្បីសាមគ្គីភាព សហប្រតិបត្តិការនិងការយោគយល់គ្នា តាមរយៈវិស័យកីឡា ...៕

៣៥. សូមយកចិត្តទុកដាក់បង្កើតទីតាំងកីឡាកាយសម្ព័ន្ធតាមសាលា

សន្និបាតអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៥-២០១៦
និងទិសដៅឆ្នាំ ២០១៦-២០១៧, ២៣ មីនា ២០១៧

... ខ្ញុំឃើញថា **កីឡានៅតាមសាលា ភាគច្រើនយកចិត្តទុកដាក់តែបីផ្នែកទេ បាល់ទាត់ បាល់ទះ បាល់បោះ។ នៅក្នុងដំណើរ(ជាង ៦ពាន់គីឡូម៉ែត្រ)របស់ខ្ញុំមានទីកន្លែងមួយធ្វើឲ្យភ្ញាក់ផ្អើល ហើយដែលត្រូវកែសម្រួលឡើងវិញ។ ទៅដល់ខេត្តព្រៃវែងចុងក្រោយនេះ គ្រូកីឡាបានមកស្នើសុំថា ក្រៅពីតារាងបាល់ទាត់ តារាងបាល់ទះ និងតារាងបោះ គាត់ស្នើសុំកីឡាកាយសម្ព័ន្ធ**។ នេះជាការខ្វះការយកចិត្តទុកដាក់របស់យើង ... គិតតែពីរឿងបាល់ទាត់ បាល់ទះ និងបាល់បោះ ប៉ុន្តែយើងខ្វះការយកចិត្តទុកដាក់នឹងកាយសម្ព័ន្ធ ដូចជាលោតចម្ងាយ លោតកម្ពស់ ឬចោលដុំដែកទៅវិញ ...៕

៣៦. រក្សាជើងនៅមូលដ្ឋានបណ្តុះបណ្តាលវិស័យកីឡាលេងកីឡាប្រសើរជាងជក់គ្រឿងញៀន

បិទសន្និបាត ក្រសួង អប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៥-២០១៦
និងទិសដៅឆ្នាំ ២០១៦-២០១៧, ២៣ មីនា ២០១៧

... មិនមែនគ្រាន់តែនឹងចាងហ្វាង ឬក៏គ្រូប៉ុណ្ណឹងទេ តែវាទាក់ទងទៅនឹងការទទួលខុសត្រូវ(របស់)អាជ្ញាធរថ្នាក់ក្រោមជាតិ និងការចូលរួមនានាពីសប្បុរសជន និងពីគ្រប់តួអង្គដែលមានការពាក់ព័ន្ធ។ នៅតាមមូលដ្ឋាន ហោចណាស់**ក្សាជីទុកឲ្យបានធំដើម្បីការបណ្តុះបណ្តាលវិស័យកីឡានេះ។ បើយើងឲ្យយុវជន និងកុមារលេងកីឡាកាន់តែច្រើន រឿងផ្តេសផ្តាស (ដូចជា)សេពគ្រឿងញៀននេះ វានឹងកាត់បន្ថយ ដោយសារតែជក់នឹងកីឡា។ សុខចិត្តឲ្យជក់នឹងកីឡា ឲ្យលេងកីឡា ប្រសើរជាងឲ្យទៅជក់គ្រឿងញៀន ជើរលេងផ្តេសផ្តាស** ...៕

៣៧. វិនិយោគវិស័យកីឡា ផ្នែកហេដ្ឋារចនាសម្ព័ន្ធនិងធនធានមនុស្ស កាន់តែច្រើន

សំណេះសំណាលជាមួយប្រតិភូកីឡាករ/វិនិចូលរួម SEA Games ទី២៩
នៅគួឡាឡំពួរ ម៉ាឡេស៊ី, ៣ សីហា ២០១៧

... ការត្រៀមលក្ខណសម្បត្តិពីមួយឆ្នាំទៅមួយឆ្នាំរបស់យើង កាន់តែប្រសើរឡើង ... ទាំងលក្ខណសម្បត្តិទាំងលក្ខខណ្ឌតម្រូវ ពាក់ព័ន្ធនឹងការហ្វឹកហាត់សម្រាប់ជម្រើសជាតិ ... ហើយ**ការវិនិយោគក្នុងវិស័យកីឡានេះ ក៏កាន់តែច្រើនទៅៗ ... ទាំងហេដ្ឋារចនាសម្ព័ន្ធទាំងធនធានមនុស្ស ... ខ្ញុំមានការរីករាយចំពោះវឌ្ឍនភាពទាំងឡាយ ... ដែលមិនត្រឹមតែសំរាប់ការប្រកួតស៊ីហ្គេមម្តងៗទេ ក៏ប៉ុន្តែពីដំណាក់កាលមួយទៅកាន់ដំណាក់កាលមួយ មានការប្រកួតច្រើនវិញ្ញាសាខុសគ្នាៗ និងនៅតាមទីកន្លែងខុសៗគ្នា ដែលបាននាំមកនូវមេដាយសំរាប់ជាតិ ...**៕

៣៨. កីឡាមិនដើម្បីដូរប្រាក់ តែគឺរក្សាតម្លៃនិងមានការយោគយល់

ប្រគល់ប្រាក់រង្វាន់ជូនជ័យលាភីមេដាយមាសប្រកួតជាលក្ខណៈអន្តរជាតិ,
១៥ ធ្នូ ២០១៧

...កីឡានាំមកនូវវឌ្ឍនភាព ... តំណាទានថវិកាដែលបានត្រៀមបម្រុងគឺមិនគ្រប់គ្រាន់។ យើងបានចាយលើសពី ៣ពាន់លានរៀល ឡើងដល់ជាង ១២ពាន់លានរៀល ហើយក៏មិនទាន់គ្រប់ ... ក្នុងពេលដែលខ្ញុំអបអរសាទរកីឡាករ/ការិនីដែលជាជ័យលាភីនៅទីនេះ សូមនិយាយទៅកាន់ក្មួយៗ ក៏ដូចជាអ្នកគាំទ្រ ... **សូមតាំងខ្លួនជាអ្នកកីឡាស្អាតស្អំ គឺអាជីពកីឡាមិនមែនដើម្បីដូរប្រាក់(នោះទេ)។ រយៈពេលកន្លងទៅ ខ្ញុំបានឃើញនូវការបង្ហោះសារតាមហ្វេសប៊ុកមួយចំនួន ដែលសារទាំងនេះ ជាការទម្លាក់តម្លៃខ្លួនរបស់ក្មួយៗ ឬក៏អ្នកគាំទ្រក្មួយៗទៅវិញទេ** ...៕

៣៩. ប្រវត្តិកីឡាកម្ពុជា ពូកែក្នុងប្រទេស តែខ្សោយក្នុងកម្រិតអន្តរជាតិ

ជួបប្រតិភូកីឡាករកម្ពុជាចូលរួមប្រកួតកីឡាអាស៊ីទី១៨ ឥណ្ឌូនេស៊ី,
៦ សីហា ២០១៨

... យើងបានឈានឡើងជាដំណាក់ៗ។ កាលមុននេះ មិនបានសិក្សាអស់ ក៏ចេះតែជឿគេជឿឯងអញ្ចឹងទៅថាខ្មែរពូកែខ្លាំងណាស់។ ដល់ទៅមើលប្រវត្តិកីឡារបស់ឯង ... **យើងល្បីតែគ្នាឯងក្នុងស្រុកហ្នឹង។ ដល់ប្រភេទកីឡានាំមេដាយពីខាងក្រៅមកមានតិចតួច។ មិនមែនបានសេចក្តីថាយើងបំភ្លេចចោលពីការខិតខំពី ជំនាន់ចាស់ទេ ក៏ប៉ុន្តែការគិតស្មានថា កម្ពុជាមានប្រភេទកីឡាខ្លាំងនោះ គឺមិនទាន់ខ្លាំងក្នុងការទៅប្រកួតកម្រិតអន្តរជាតិទេ។** យើងត្រូវមានការខិតខំបន្ថែម ...៕

៤០. កីឡាស្ថិតលើសមត្ថភាពនៃការប្រកួត ការហ្វឹកហាត់និងទេពកោសល្យ

ប្រគល់រង្វាន់លើកទឹកចិត្តម្ចាស់ជ័យលាភីមេដាយមាសកីឡាប៉េតង់ជើងឯកពិភពលោក
(នៅអេស្ប៉ាញ) កីឡាការិនីជម្រើសជាតិ អ៊ុក ស្រីមុំ, ៥ មករា ២០២២

... យើងចាប់ផ្តើមខិតខំឡើងវិញ ដើម្បីឈានឆ្ពោះទៅមុខក្នុងវិស័យកីឡា បើទោះបីថាយើងជាប្រទេសតូចមួយ ... កីឡាមិនប្រកាន់ថាប្រទេសតូច/ធំទេ។ សូមសង្កេតមើល។ ប្រទេសខ្លះតូច មានប្រជាជនតិច ប៉ុន្តែអាចចូលដល់ World Cup បាន។ ប្រទេសធំមានប្រជាជនច្រើន មិនអាចចូលដល់ World Cup បាន។ ឧ. ចិន/ឥណ្ឌា មានប្រជាជនប្រមាណជិត ៣ពាន់លាននាក់ ប៉ុន្តែប្រទេសពីរនេះរើសមនុស្សមិនបាន ១១នាក់ជាជម្រើសជាតិធ្វើការប្រកួតបានចូលទៅ World Cup ហ្នឹងគេទេ ... អញ្ចឹង **កីឡាមិនស្ថិតនៅលើប្រទេសធំ/តូចទេ គឺស្ថិតនៅត្រង់បញ្ហាសមត្ថភាពនៃការប្រកួត ការហ្វឹកហាត់ ក៏ប៉ុន្តែដោយទេពកោសល្យ** ...៕

៤១. សូមកុំប្រើប្រាស់សារធាតុហាមឃាត់ក្នុងបញ្ញត្តិកីឡា

សំណេះសំណាលកីឡាករ/ការិនីអត្តពលិក ៥៨០នាក់ មុនចេញទៅប្រកួតស៊ីហ្គេម
នៅប្រទេសវៀតណាម, ២៨ មេសា ២០២២

… **កីឡាករ/ការិនីត្រូវដឹងឱ្យច្បាស់ថា ការ(ចេញ)ទៅប្រកួត គឺកាន់ទង់ជាតិព្រះរាជាណាចក្រកម្ពុជាទៅជាមួយ ដូច្នេះនៅជាប់ហ្នឹងខ្លួនក្មួយៗ មានតួអង្គព្រះមហាក្សត្រ មានតួអង្គនីតិបញ្ញត្តិ/ប្រតិបត្តិ ជាពិសេស មានប្រជាជនជិត ១៧លាននាក់ នៅជាមួយនឹងក្មួយ។** កិត្តិយស និងសេចក្តីថ្លៃថ្នូរសំខាន់ណាស់សម្រាប់ប្រទេសជាតិយើង … ការប្រកួតអាចមានការខ្លោះឆ្លាយដោយអចេតនា ប៉ុន្តែសម្រាប់**ការប្រើប្រាស់សារធាតុលើកកម្លាំងខុសអំពីបំរាម គឺជាចេតនាពិតប្រាកដ … ខ្ញុំសូមស្នើឱ្យមានការយកចិត្តទុកដាក់បំផុត ទៅលើវិន័យកីឡា ក្នុងនោះការ(ប្រើ)សារធាតុលើកកម្លាំងខុសបទបញ្ញត្តិ ត្រូវតែជានាថាគ្មាននៅក្នុងកីឡារបស់យើង …**៕

៤២. នៅលើពិភពលោក មានតែកីឡាទេមានស្តង់ដារួម

សំណេះសំណាលកីឡាករ/ការិនីអត្តពលិក ៥៨០នាក់ មុនចេញទៅប្រកួតស៊ីហ្គេមនៅប្រទេសវៀតណាម, ២៨ មេសា ២០២២

… ខ្ញុំធ្លាប់បាននិយាយហើយថា មានតែកីឡាទេដែលមានស្តង់ដារួម។ កុំនិយាយពីស្តង់ដារអន្តរជាតិលើលទ្ធិប្រជាធិបតេយ្យ និង/ឬសិទ្ធិមនុស្ស ឬលើបញ្ហានេះ/នោះ។ គ្មានទេ។ ស្តង់ដារអន្តរជាតិមានតែក្នុងវិស័យកីឡាហ្នឹងប៉ុណោះ …បញ្ហានយោបាយ … ប្រជាធិបតេយ្យ/សិទ្ធិមនុស្សអី គឺអត់មានស្តង់ដារអន្តរជាតិទេ … លឺសូរខ្ញុំនិយាយអញ្ចឹង មិនបានពិចារណាឱ្យបានច្បាស់ អ្នកខ្លះអាចពេបជ្រាយ ឬវាយបកមកលើខ្ញុំ។ តែខ្ញុំមិនខ្វល់ទេ អ្នកណាចង់ថាអីក៏ថាទៅ។ នេះជាសិទ្ធិ របស់ខ្ញុំក្នុងការធ្វើអត្ថាធិប្បាយ …៕

៤៣. ទោះជានៅក្រៅ អាស៊ីមិនត្រូវមានភាពទន់ខ្សោយក្នុងការគ្រប់គ្រងសីលធម៌កីឡាទេ

បើកមហាសន្និបាតក្រុមប្រឹក្សាកីឡាអូឡាំពិកអាស៊ីលើកទី៤១, ៤ តុលា ២០២២

… **(គប្បីមាន)វិធានការពង្រឹងក្រមសីលធម៌នៃការប្រកួត(កីឡា)។ ហេតុអ្វីទៅ? យើងឃើញថាសោកនាដកម្មមួយចំនួនបានកើតឡើង(ក្នុងការប្រកួត) ជាពិសេសថ្មីៗនេះនៅឥណ្ឌូនេស៊ី មានអំពីហិង្សានិងការរត់ជាន់គ្នាស្លាប់** … ជាការចាំបាច់ណាស់ ត្រូវពង្រឹងនូវក្របខណ្ឌក្រមសីលធម៌អំពីការប្រកួតដែលវាមិនមែនគ្រាន់តែដើម្បីការឈ្នះទេ ប៉ុន្តែ(បែរជាមានការ)រំលោភបំពានទៅលើលក្ខខណ្ឌនៃការប្រកួត ឬប្រើអំពើហិង្សា … **ទោះបីតំបន់អាស៊ីរបស់យើងមានភាពទន់ខ្សោយខាងកីឡាក៏ដោយចុះ ក៏យើងមិនត្រូវមានភាពទន់ខ្សោយក្នុងផ្នែកសីលធម៌ក្នុងការគ្រប់គ្រងខាងកីឡាទេ …**៕

៤៤. ប្រើប្រាស់ព្រឹត្តិការណ៍ប្រកួតស៊ីហ្គេមនៅកម្ពុជា ជាចលនាកីឡាជាតិ

ចែកសញ្ញាបត្រជូនដល់និស្សិតនៃសាកលវិទ្យាល័យ វេស្ទើន, ២៦ មករា ២០២៣

… សូមប្រជាពលរដ្ឋរបស់យើងចូលរួមនៅក្នុងដំណើរការនៃស៊ីហ្គេមដែលយើងរង់ចាំជាង ៦០ឆ្នាំហើយ។ **តាមប្រវត្តិនៃការរៀបចំគឺ ៦៤ឆ្នាំដែលយើងរង់ចាំ។ សូមឱ្យប្រជាពលរដ្ឋយើងប្រើប្រាស់ឱកាសនៃការប្រកួតស៊ីហ្គេមនៅកម្ពុជា ក្លាយជាទៅជាចលនាជាតិ មិនមែនជាគោលដៅជាប់ជាច់ដោយខ្សែកវរបស់វិស័យកីឡានៅទីក្រុងភ្នំពេញទេ តែធ្វើម៉េចឱ្យប្រទេសរបស់យើងស្អាត**។ មនុស្សរាប់ម៉ឺននាក់នឹងមកកាន់ទីក្រុងភ្នំពេញ។ គ្រាន់តែកីឡាករ/ការនីជិតម៉ឺន(នាក់)ទៅហើយ ដៃលមកប្រកួត។ អញ្ចឹង អ្នកគាំទ្រដទៃទៀតក៏គេមកដែរ …៕

៤៥. ពង្រីកវិសាលភាពពិន្យព្យាបាលកីឡាការដោយគ្មានការបង់ប្រាក់

ប្រគល់វិញ្ញាបនបត្រ និងសញ្ញាបត្រជូនដល់សិស្សថ្នាក់វិជ្ជាជីវៈ និងនិស្សិតនៃសាកលវិទ្យាល័យ ធនធានមនុស្ស, ២០ កុម្ភៈ ២០២៣

… កន្លងទៅខ្ញុំបានពិភាក្សាជាមួយឯកឧត្តម ម៉ម ប៊ុនហេង និងលោកជំទាវ យក់ សម្បត្តិ ឱ្យរៀបចំកន្លែងព្យាបាលអ្នកកីឡា។ ខ្ញុំបង្ហោះតាមហ្វេសប៊ុកថាយើងរៀបចំប្រមាណ២០០ ត្រែ។ យើងគ្របដណ្តប់ទាំងការប្រកួតនិងការហ្វឹកហាត់ដែលត្រូវរបួស ហើយត្រូវ ពង្រីកវិសាលភាពសម្រាប់ការពិនិត្យព្យាបាលកីឡាករ/ការិនីរបស់ យើង … ជួនកាលអ្នកកីឡាឈឺធម្មតា ប៉ុន្តែទៅព្យាបាលនៅកន្លែងនេះ/នោះដោយខ្វះឯកទេស … ទៅជារឿងប្រកួតអត់កើតនៅថ្ងៃ ក្រោយ … (ការគិតគូរនេះ)មិនមែនតែកីឡាអាជីពទេ … (យើងគ្របដណ្តប់អ្នកលេងកីឡាទាំងអស់) … **បញ្ជូនមកមន្ទីរពេទ្យនេះ យើងទទួលព្យាបាលដោយគ្មានការបង់ប្រាក់ …**៕

៤៦. រៀបចំគោលនយោបាយឧបត្ថម្ភកីឡាករ/ការិនីរបួសឬពិការធានាភាពជឿជាក់ក្រោមក្របខណ្ឌជាតិ

សំណេះសំណាលនិងពិសាអាហារសាមគ្គីជាមួយមហាគ្រួសារកីឡាកម្ពុជា, ៣ មេសា ២០២៣

... សូមក្រសួងដែលមានការពាក់ព័ន្ធ ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មាធិការរៀបចំកីឡាអូឡាំពិកកម្ពុជា សូមធ្វើការរួមគ្នាពិនិត្យលក្ខខណ្ឌខ្លះទាក់ទងទៅនឹងកីឡា។ ពេលដែលមានការប្រកួត ហើយត្រូវរបួស កីឡាករ/ការិនីក្លាយខ្លួនជាជនពិការ។ តើពួកគាត់ត្រូវទទួលបានអ្វីខ្លះ? **...នៅពេលចូលប្រកួតកីឡាករ/ការិនីតំណាងឲ្យកិត្តិយសជាតិ ឬក៏ប្រកួតនៅក្នុងក្របខណ្ឌនៃការទទួលខុសត្រូវរបស់យើង។ នៅពេលដែលមានរបួស ឬពិការ តើត្រូវរៀបចំគោលនយោបាយចំពោះពួកគេដូចម្តេច? ... ដើម្បីធានាភាពជឿជាក់របស់កីឡាករ/ការិនី ក្នុងការឈានឡើងទៅរកភាពខ្លាំងរបស់ខ្លួន ក្រោមក្របខណ្ឌជាតិរបស់យើង** ...។

៤៧. ស៊ីហ្គេមកម្ពុជា មិនលក់សំបុត្រ មិនបង់ថ្លៃចូលមើលតាមវិញ្ញាសាប្រកួត

សារបទបញ្ជាមិនឱ្យមានការលក់សំបុត្រចូលទស្សនាការប្រកួតស៊ីហ្គេម, ៣០ មីនា ២០២៣

... បានទទួលព័ត៌មានតាមសម្តេចពិជ័យសេនា ទៀ បាញ់ ថាមានការផ្សព្វផ្សាយពីការលក់សំបុត្រចូលពិធីបើក/បិទស៊ីហ្គេម។ ករណីនេះ ទាមទារឱ្យខ្ញុំចេញសារជាបន្ទាន់ជម្រាបជូនទៅអ្នកទទួលខុសត្រូវ ទាក់ទងនឹងការប្រកួតស៊ីហ្គេមពេលខាងមុខ ... ខ្ញុំសូមដាក់ចេញនូវបទបញ្ជា **ទី១ មិនឱ្យមានការលក់សំបុត្រ ទាំងការបើក/បិទ(ព្រឹត្តិការណ៍កីឡាស៊ីហ្គេម), ទី២ ឱ្យបងប្អូនចូលទស្សនាដោយសេរី ដោយគ្មានការបង់ប្រាក់ និងទី៣ ការប្រកួតតាមវិញ្ញាសានានាក៏មិនត្រូវបានបង់ថ្លៃណាមួយនោះឡើយ។** ក្រុមណាអនុវត្តខុសពីនេះ ទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី ...។

៤៨. ផ្តល់ការទស្សនាមិនគិតថ្លៃ ទទួលអាហារ/ស្នាក់នៅ និងមិនលក់សិទ្ធិផ្សព្វផ្សាយ

សំណេះសំណាលប្រគិតកូកីឡាមុនចូលរួមប្រកួត SEA Games លើកទី៣២នៅកម្ពុជា, ១ ឧសភា ២០២៣

... ដូចខាងគណៈកម្មការកីឡាបានលើកឡើង ជាលើកដំបូងក្នុងប្រវត្តិសាស្ត្រនៃការប្រកួត ដែលកម្ពុជា **<u>ទី១</u> មិនលក់សំបុត្រសម្រាប់ប្រជាពលរដ្ឋខ្លួនឯង និងសម្រាប់អ្នកគាំទ្រពីបណ្តាប្រទេសជិតខែ ដែលមកគាំទ្រ, <u>ទី២</u> ទទួលរ៉ាប់រងការស្នាក់នៅនិងហូបចុករបស់កីឡាករ/ការិនីពីបណ្តាប្រទេសនានា ដែលយើងត្រូវចំណាយបន្ថែមប្រមាណ ៧លានដុល្លារ ... <u>ទី៣</u> (នៅព្រឹត្តិការណ៍មុនៗ) គេទិញសិទ្ធិផ្សព្វផ្សាយ។** តែនៅកម្ពុជា ឱ្យសិទ្ធិយកទៅផ្សាយទៅគ្រប់ប្រទេស ...។

៤៩. ស្គាល់កម្ពុជាដោយសារស៊ីហ្គេម/ប៉ារ៉ាហ្គេម និងទំនិញនាំចេញ

សំណេះសំណាលកីឡាករ គ្រូបង្វឹក អ្នកដឹកនាំកីឡាមុនព្រឹត្តិការណ៍ ASEAN Para Games ទី១២, ២៦ ឧសភា ២០២៣

... ពីមុនគេមិនស្គាល់កម្ពុជាទេ។ គេស្គាល់ ប៉ុល ពត។ ឥឡូវ គេស្គាល់កម្ពុជាតាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់យើង ក៏ដូចជាតាមរយៈស៊ីហ្គេមនិងអាស៊ានប៉ារ៉ាហ្គេម។ គេស្គាល់កម្ពុជាតាមរយៈទំនិញទៅដល់ ... ៧៣ ប្រទេស ស៊ីអង្គរ កម្ពុជាដែលនាំចេញ។ ចង់មិនចង់គេដឹងថាកម្ពុជាជាប្រទេសផលិតមួយដែរ។ មានផលិតផលដទៃទៀត រាប់ទាំងសំលៀកបំពាក់កីឡាដែលផលិតនៅកម្ពុជា ហើយចែកចាយទៅកាន់ទីផ្សារពិភពលោកដែលគេស្គាល់ ជាក់ចិត្តគំនិតកំណែទម្រង់ស្តីពីស៊ីហ្គេមនិងអាស៊ានប៉ារ៉ាហ្គេមធ្វើម្ចាស់ផ្ទះ ហើយមិនយកលុយ ...។

៣0. អភិវឌ្ឍន៍ជនបទ

១	ផ្តល់អំណាចកាន់តែច្រើនឲ្យមូលដ្ឋាន ប្រើប្រាស់ថវិកាបម្រើការអភិវឌ្ឍនៅមូលដ្ឋាន	៦៦៩
២	និយាយពីការអភិវឌ្ឍនៅទីក្រុង ឯនៅជនបទក៏មានការអភិវឌ្ឍ	៦៦៩
៣	គ្មានវិនិយោគនៅជនបទ ឬមួយទៅកន្លែងដទៃរកការងារធ្វើ ឬមួយនៅធ្វើកសិកម្ម	៦៦៩
៤	រាជរដ្ឋាភិបាលសន្សំលុយ បម្រើសេចក្តីត្រូវការរបស់ប្រជាជន	៦៧0
៥	តំបន់អតីតសមរភូមិមិនតិចជាង៩0% ក្លាយជាតំបន់អភិវឌ្ឍនិងទីផ្សារ	៦៧0
៦	ពីមុនវត្តមានតាមតំបន់សង្គ្រាម ដោះស្រាយបញ្ហាទំពនិងប្រជាពលរដ្ឋរងគ្រោះ	៦៧១
៧	វត្តមាននៅវាលស្រែ ជួយជកស្នូងនិងវេទិកាសាធារណៈជាមួយប្រជាពលរដ្ឋ	៦៧១
៨	អត្ថិភាពបច្ចុប្បន្ន ដោយសារមានសន្តិភាព មិនមែនដោយសារសង្គ្រាមទេ	៦៧២
៩	ខេត្ត/ស្រុក/ឃុំឆ្លាត ធ្វើផ្ទះគ្រូ ដើម្បីបានគ្រូល្អ គ្រូពូកែ	៦៧២
១0	មានលទ្ធភាពគ្រប់គ្រងប្រទេស ត្រូវធ្វើឱ្យវិស័យអប់រំបានទៅដល់មូលដ្ឋាន	៦៧៣
១១	ប្រទេសយើងមានដំណាក់កាលរកដី រត់ចោលដី ស្តារដី និងដណ្តើមដី	៦៧៣
១២	កសិកម្មដើម្បីសេដ្ឋកិច្ចជនបទ និងផ្គត់ផ្គង់និងស្មោកម្មស្បៀង	៦៧៤
១៣	បាត់ព្រៃឈើ តែកើនផ្ទៃដីដាំដុះពី ១,៨លាន ដល់ ៤លានហិកតា	៦៧៤
១៤	ឃុំប៉ោយចារនិងអាងត្រពាំងថ្ម អាចប្រកាសជាតំបន់គ្មានមីននៅចុងឆ្នាំ២0២២	៦៧៥
១៥	មន្ទីរពេទ្យបង្អែកស្រុកក្រូចឆ្មារ ការខិតខំសម្រាប់សុខភាពប្រជាជននៅទីជនបទ	៦៧៥
១៦	វ៉ាក់សាំងកូវីដ១៩ បានរាយទៅដល់ទីជនបទដាច់ស្រយាល	៦៧៦
១៧	ចង់ឱ្យការយល់ដឹងនិងអនុវត្តអនាម័យបានលាតសន្ធឹងទៅទីជនបទ/តាមភូមិឃុំ	៦៧៦
១៨	គ្មានអគ្គិសនី ទឹកស្អាត សាលា មន្ទីរពេទ្យ មិនអាចបន្តយគំលាតទីក្រុងនិងជនបទ	៦៧៧
១៩	ដោះស្រាយទឹកដោយជីកអណ្តូងនៅនឹងកន្លែង ប្រសើរជាងដឹកទឹកពីចម្ងាយ	៦៧៧
២0	តភ្ជាប់អគ្គិសនីដើម្បីបម្រើផលិតកម្មកសិកម្ម កាត់បន្ថយថ្លៃដើមផលិត	៦៧៨
២១	ទម្លាក់ថ្លៃអគ្គិសនី/ផលិតជីក្នុងស្រុក បន្ថយថ្លៃដើមផលិតក្នុងវិស័យកសិកម្ម	៦៧៨
២២	ភូមិ៩៩% និងផ្ទះ៩0% ទូទាំងប្រទេសបានភ្ជាប់បណ្តាញអគ្គិនីរួចរាល់	៦៧៩
២៣	មិនដំឡើងថ្លៃអគ្គិសនី ខណៈ៩៧% ទៅ៩៩% នៃភូមិទូទាំងប្រទេសមានអគ្គិសនី	៦៧៩
២៤	ភូមិ100% នៅកំពង់ស្តឹមានអគ្គិសនីប្រើប្រាស់	៦៨0
២៥	មានផ្លូវចាក់កៅស៊ូយ៉ាងមាំតភ្ជាប់គ្នាគ្រប់ភូមិ/តំបន់តាមដងទន្លេមេគង្គ	៦៨0

២៦	ហេដ្ឋារចនាសម្ព័ន្ធកាត់បន្ថយគម្លាតរវាងទីក្រុងនិងជនបទ	៦៨០
២៧	ត្រូវវិនិយោគច្រើនទៀត កញ្ចាប់ជនបទពីស្រុកមួយទៅស្រុកមួយនៅព្រៃវែង	៦៨១
២៨	សិក្ខាការកញ្ចាប់ឆ្លងស្នឹងបញ្ហាលក្នុងថវិការក្រសួងអភិវឌ្ឍន៍ជនបទឆ្នាំ២០២៣	៦៨១
២៩	កសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នៅប៉ែលទាំង៣ ដើម្បីការលូតលាស់សេដ្ឋកិច្ចជាតិ	៦៨២
៣០	ចាប់ពីពេលនេះតទៅ ធ្វើផ្លូវពីបេតុងដើម្បីអោយរឹងមាំ	៦៨២
៣១	កំពង់ស្ពឺក្លាយជាខេត្តមានផ្លូវឆ្លងកាត់ច្រើន	៦៨២

១. ផ្តល់អំណាចកាន់តែច្រើនឲ្យមូលដ្ឋាន ប្រើប្រាស់ថវិកាបម្រើការអភិវឌ្ឍនៅមូលដ្ឋាន

បើកការដ្ឋានស្ពានអាកាស និងផ្លូវក្រោមដីរង្វង់មូលចោមចៅ, ២៩ មិថុនា ២០១៨

... ខ្ញុំអរគុណចំពោះការគាំទ្រដល់របៀបចាត់ចែងក្នុងការអភិវឌ្ឍ ដែលខ្ញុំបានដាក់ចេញជាទិសដៅនេះ។ សូម្បីរបៀបយក **"ស្លឹកឆ្នោតខ្ចប់ស្ករឆ្នាត" បានជម្រុញឲ្យមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធចាំបាច់សម្រាប់ទីក្រុង ដូចជាលូទឹក ផ្លូវថ្នល់ស្ពាន និងស្ពានអាកាសដែលយើងបាននិងកំពុងធ្វើសព្វថ្ងៃ។ ប្រសិនបើយើងមិនប្រើប្រាស់វិធីនេះទេ ថវិកាទាំងអស់ដែលក្រុងប្រមូលបាន ត្រូវឱ្យទៅថវិកាជាតិ។ ទម្រាំបើកពីថវិកាជាតិត្រឡប់មកវិញ វាយឺត។ អញ្ចឹងត្រូវមានរបៀបចាត់ចែងថវិកាមួយ ដែលផ្តល់អំណាចកាន់តែច្រើនទៅឲ្យមូលដ្ឋាន។ មូលដ្ឋានត្រូវប្រើប្រាស់នូវថវិកានោះបម្រើទៅដល់ការអភិវឌ្ឍនៅមូលដ្ឋាន**។ រឿងនេះវាជាផលប្រយោជន៍ប្រជាជន មិនមែនជាផលប្រយោជន៍ដាច់ដោយឡែករបស់រាជរដ្ឋាភិបាលទេ។ អ្នកដែលប្រើប្រាស់ពិតប្រាកដគឺប្រជាពលរដ្ឋ ...៕

២. និយាយពីការអភិវឌ្ឍនៅទីក្រុង ឯនៅជនបទក៏មានការអភិវឌ្ឍ

បើកការដ្ឋានស្ពានអាកាស និងផ្លូវក្រោមដីរង្វង់មូលចោមចៅ, ២៩ មិថុនា ២០១៨

... ទន្ទឹមនឹងការនិយាយពីការអភិវឌ្ឍទីក្រុង យើងក៏និយាយដល់ការអភិវឌ្ឍនៅឯជនបទផងដែរ។ រវាងទីក្រុងនិងជនបទបច្ចុប្បន្ន មិនខុសគ្នាឆ្ងាយប៉ុន្មានទេ។ បើនិយាយពីវិស័យឧស្សាហកម្ម ក្នុងពេល ២ថ្ងៃជាប់គ្នា ខ្ញុំទៅខេត្តកំពង់ឆ្នាំងជួបកម្មករជាង ៤ម៉ឺននាក់ និងទៅជួបកម្មករជិត ៥ម៉ឺននាក់នៅឯបាវិត/ស្វាយរៀង និងប្រមាណ ៤ម៉ឺននាក់នៅឯកំពង់សោម ... បន្ទាប់ទៅផ្អាកសិន ព្រោះចូលដល់យុទ្ធនាការបោះឆ្នោត។ ដល់បោះឆ្នោតរួចហើយ ដើរសួរសុខទុក្ខកម្មកររទៀត។ សង្ឃឹមថាមានការជឿជាក់ នឹងបន្តបោះឆ្នោតជូនគណបក្សប្រជាជន ដែលមានសញ្ញាទេវតាបាចផ្កា និងមានលេខរៀងទី ២០ ជាបន្តទៀត ...៕

៣. បើគ្មានវិនិយោគនៅជនបទ ឬមួយទៅកន្លែងដទៃរកការងារធ្វើ ឬមួយនៅធ្វើកសិកម្ម

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកត្រាំកក់ ខេត្តតាកែវ, ៩ មករា ២០១៩

... ក្មួយៗអាចចោទចេញជាសំណួរនៅកន្លែងហ្នឹងថា **ប្រសិនបើពុំមានអ្នកវិនិយោគចំនួន ១២រោងចក្រ ដែលយើងកំពុងជួបគ្នានៅថ្ងៃនេះ** តើពេលនេះ ក្មួយៗទាំង ១៨២៧៣ នាក់កំពុងធ្វើអ្វី? ចម្លើយមានតែ២ ទេក្មួយ។ **ទី១ ក្មួយៗ មួយចំនួនកំពុងស្ថិតនៅកន្លែងផ្សេង មិនមែននៅក្នុងទឹកដីរបស់ខេត្តតាកែវទេ។ ប្រហែលជាកំពុងនៅទីក្រុងភ្នំពេញ ឬនៅកន្លែងណាដែលមានការងារធ្វើ ... ព្រោះបើគ្មានរោងចក្រនៅទីនេះ ហើយយើងចង់ធ្វើការរោងចក្រនោះយើងត្រូវទៅកន្លែងផ្សេង ... ឯទី២ ចម្លើយគឺពេលនេះម៉ោងនេះ កំពុងស្ថិតនៅជាមួយក្រុមគ្រួសារ ជាមួយឪពុកម្តាយ កំពុងធ្វើការងារនៅក្នុងវិស័យកសិកម្ម** ...។

៤. រាជរដ្ឋាភិបាលសន្សំលុយ បម្រើសេចក្តីត្រូវការរបស់ប្រជាជន

បើកការដ្ឋានសាងសង់ផ្លូវល្បឿនលឿន ក្រុងភ្នំពេញ-ខេត្តព្រះសីហនុ, ២២ មីនា ២០១៩

... រាជរដ្ឋាភិបាល ឧបនាយករដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ចៅហ្វាយខេត្តស្អីៗ ដែលធ្វើការក្នុងរដ្ឋបាលរបស់ហ៊ុនសែន សូមកុំសង្ឃឹមថាអស់លោកបានទទួលលុយទិញឡានជិះ។ គ្មានលុយឲ្យអស់លោកទិញឡានជិះទេ។ សូមកុំធ្វើសំណើសុំ។ សំណាងជាងគេនៅរដ្ឋសភានិងព្រឹទ្ធសភា។ ឡើងធ្វើប្រធានគណៈកម្មការទៅឡាន។ **នៅខាងរាជរដ្ឋាភិបាល មិនមានឲ្យឡានទេ។ មុនធ្វើរដ្ឋមន្ត្រីលោកឯងជិះអី លោកឯងជិះហ្នឹងតទៅទៀតទៅ។ ខ្ញុំត្រូវការយកលុយទៅធ្វើផ្លូវ ទៅធ្វើប្រឡាយទឹក ទៅធ្វើសាលារៀន ទៅធ្វើមន្ទីរពេទ្យ បម្រើសេចក្តីត្រូវការរបស់ប្រជាជន**។ លុយមិនមែនសម្រាប់អស់លោក(ទិញឡាន)ជិះទៅធ្វើការ ចងក្រវាត់កទេ ...។

៥. តំបន់អតីតសមរភូមិ មិនតិចជាង៩០% ក្លាយជាតំបន់អភិវឌ្ឍនិងទីផ្សារ

បើកការដ្ឋានសាងសង់អាគារច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ និងផ្លូវតភ្ជាប់ទៅផ្លូវជាតិលេខ៥, ២២ មេសា ២០១៩

... ក្រៅពីគ្មានការប្រយុទ្ធគ្នា តំបន់ទាំងនេះជាតំបន់ដែលមានផ្លូវក្រាលកៅស៊ូល្អ។ នេះគឺការតភ្ជាប់ផ្ទៃក្នុងរបស់យើង។ **ដីដែលធ្លាប់តែធ្វើចម្បាំងរាំងជល់ក៏ក្លាយទៅជាដីដែលមានការអភិវឌ្ឍ ទាំងវិស័យកសិកម្មទាំងវិស័យសេវា និងវិស័យជំទៃទៀតតាមលទ្ធភាពដែលអាចធ្វើទៅរួច។ នៅសល់តិចតួចទេដែលកំពុងតែ**

ដោះស្រាយបញ្ហាគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ ដើម្បីយកដីធ្លីនោះជូនប្រជាជនបង្កបង្កើនផល។ ចាត់ទុកថាជាគោលដៅដែល ២០ឆ្នាំក្រោយក្នុងរង្វង់មិនតិចជាង ៩០% ទេ តំបន់អតីតសមរភូមិទាំងឡាយ នឹងក្លាយទៅជាតំបន់អភិវឌ្ឍនិងទៅជាទីផ្សារ។ តំបន់ប៉ោយប៉ែត ដែលពីមុនជាតំបន់ប្រយុទ្ធ បានក្លាយជាទីផ្សារនិងជាតំបន់កំសាន្ត ជាតំបន់ដែលមានសេវា ...។

៦. ពីមុនវត្តមានតាមតំបន់មានសង្គ្រាម ដោះស្រាយបញ្ហាទំពនិងប្រជាពលរដ្ឋរងគ្រោះ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល, ២០ កុម្ភៈ ២០១៩

... មិនមែនជារឿងចៃដន្យទេ ដែលយើងដាក់ចេញគោលដៅតាមដំណាក់កាលមួយៗ។ ក្មួយៗ បានឃើញថាក្នុងរយៈពេល ៣ឆ្នាំចុងក្រោយនេះ ពូបានធ្វើសកម្មភាពចូលជ្រៅជាមួយកម្មករ បន្ទាប់ពីការចូលជ្រៅជាមួយកសិករអស់រយៈកាលប្រមាណជាង ៣០ឆ្នាំ ... ក្មួយៗអាចចោទជាសំណួរថា ហេតុអ្វីបានជាឆ្នាំ២០១៧ ទើបលោក ហ៊ុន សែន ចាប់ផ្តើមជួបជាមួយកម្មករ? ការងារអ្វីក៏ដោយសុទ្ធតែមានជំហានរបស់វា និងទៅតាមអាទិភាពរបស់វា។ **សម័យក្រោយរំដោះ កិច្ចការពេលនោះ ត្រូវទប់ស្កាត់ការរំលៃត្រឡប់របបប្រល័យពូជសាសន៍ ប៉ុល ពត ម្ខាង។ ម្ខាងទៀត ត្រូវស្តារឡើងវិញនូវជីវភាពរបស់ប្រជាពលរដ្ឋ ដោយយកកសិកម្មជាវិស័យស្នូល។ ដូច្នេះ ក្មួយៗពិតជាបានឃើញពូនៅពាក់ឯកសណ្ឋានយោធា ធ្វើដំណើរទៅកាន់តំបន់ដែលមានសង្គ្រាម ដើម្បីដោះស្រាយនូវបញ្ហារបស់កងទ័ព និងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារតែសង្គ្រាមនោះ** ...។

៧. វត្តមាននៅវាលស្រែ ជួយដកស្ទូងនិងវេទិកាសាធារណៈជាមួយប្រជាពលរដ្ឋ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល, ២០ កុម្ភៈ ២០១៩

... ក្មួយៗ ក៏បានឃើញរូបភាព**ពូចុះទៅតាមទីកន្លែងនានាដកស្ទូង ធ្វើវេទិកាសាធារណៈ (ជាមួយប្រជាពលរដ្ឋ)។ សូម្បីតែក្នុងស្រុកអង្គស្នួលក៏មានរូបភាពដែលខ្ញុំចុះមកស្ទូង បើកគោយន្ត** ... ទៅម្ខាងខាងផ្លូវនោះ គឺគោកព្រិច លំហាច ... យើងធ្វើប្រឡាយទាញទឹកពីរលាំងជ្រៃ ... ពូស្គាល់ភូមិសាស្ត្រ ព្រោះពូទៅដាក់

ម៉ាស៊ីនបូមទឹក ហើយពិភាក្សាជាមួយ ឯកឧត្តម លឹម គានហោ ត្រូវធ្វើយ៉ាងម៉េច។ តាំងពីនៅជំនាន់ប្រើអង្ករពលកម្មឯណោះ ... យើងធ្វើប្រឡាយមេដោយគ្រឿងចក្រ ឯប្រឡាយរងយើងធ្វើដោយអង្ករពលកម្ម។ ពេលនោះយើងខ្វះអង្ករ។ ដល់ឆ្នាំ ២០០២ យើងទទួលបានជំនួយពីសាធារណរដ្ឋឥណ្ឌា ២ម៉ឺនតោនអង្ករ ដែលមួយផ្នែកប្រើប្រាស់សង្គ្រោះប្រជាពលរដ្ឋនិងមួយផ្នែកទៀតធ្វើជាអង្ករដូរពលកម្ម ...៕

៨. អត្ថិភាពបច្ចុប្បន្ន ដោយសារមានសន្តិភាព មិនមែនដោយសារសង្គ្រាមទេ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅរោងចក្រចំនួន៨១ ក្នុងតំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់ គ្រុប ភ្នំពេញ, ២៧ ឧសភា ២០២៣

... **សូមអំពាវនាវឲ្យក្មួយៗ និងអ្នកទាំងអស់នៅទីនេះ ចូលរួមរក្សាសន្តិភាពឲ្យខាងតែបាន។ លើការជាក់ស្តែង យើងស្ថិតនៅទីនេះបានដោយសារអ្វី ? គឺដោយសារសន្តិភាព មិនមែនដោយសារមានសង្គ្រាមទេ។** ពេលប្រទេសកើតសង្គ្រាម ដីធ្លីអ្វីៗ ត្រូវបានបំផ្លិចបំផ្លាញ ... លើកនេះមកចំផ្លូវក្រវាត់ក្រុងទី៣ ងាកខាងឆ្វេងដៃឃើញរោងចក្រពីម្សិល។ រោងចក្រហ្នឹងធំ ហើយស្អាត។ ខ្ញុំស្មានតែសណ្ឋាគារ។ ហ្នឹងផ្ទះសម្រាប់កម្មករនៅ ប៉ុន្តែដូចសណ្ឋាគារ ... បើសិនជាគ្រប់ទីកន្លែងអាចធ្វើដូចអញ្ចឹងបានវាជាការល្អ ហើយកាត់បន្ថយការជួលផ្ទះ។ ប៉ុន្តែហ្នឹងវាអាស្រ័យទៅតាមលទ្ធភាពរបស់រោងចក្រនីមួយៗ ...៕

៩. ខេត្ត/ស្រុក/ឃុំឆ្លាត ធ្វើផ្ទះគ្រូ ដើម្បីបានគ្រូល្អ គ្រូពូកែ

ប្រគល់សញ្ញាបត្រជូនគរុសិស្ស គរុនិស្សិត និស្សិត និងបុគ្គលិកអប់រំ នៃវិទ្យាស្ថានជាតិអប់រំ, ២៥ មេសា ២០២៣

... សូមអំពាវនាវចំពោះអ្នកដែលជួយកសាងសាលា ជួយកសាងផ្ទះគ្រូបង្រៀននៅតាមសាលានានាឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន ... នៅច្រើនកន្លែង តែកន្លែងដែលខ្ញុំដាក់សាលា ខ្ញុំដាក់អន្តេវាសិកនៅកន្លែងនោះ សម្រាប់សិស្សស្នាក់នៅផងនិងសម្រាប់កន្លែងគ្រូបង្រៀនស្នាក់នៅផង ... **ត្រូវវិនិយោគបន្ថែមទៀតលើការកសាងអគារសិក្សា និងការកសាងផ្ទះគ្រូបង្រៀន។ ធ្វើដូច្នេះ យើងទាញបានគ្រូព្រោះយើងមានផ្ទះស្នាក់នៅ។ បើសិនខេត្តណាឆ្លាត ស្រុក ឬឃុំណាឆ្លាត គឺប្រឹងប្រែងធ្វើរបស់ទាំងហ្នឹង។ បើចង់បានគ្រូល្អ គ្រូពូកែ ត្រូវមានផ្ទះឱ្យគ្រូនៅ** ...៕

១០. មានលទ្ធភាពគ្រប់គ្រងប្រទេស ធ្វើឱ្យវិស័យអប់រំបានទៅដល់មូលដ្ឋាន

ប្រគល់សញ្ញាបត្រជូនគរុសិស្ស គរុនិស្សិត និស្សិត និងបុគ្គលិកអប់រំ នៃវិទ្យាស្ថានជាតិអប់រំ, ២៥ មេសា ២០២៣

... អតីតកាលវាបានកន្លងហួស ប៉ុន្តែវាបានផ្តល់មេរៀនច្រើនសម្រាប់យើង។ ដើម្បីយើងឈានទៅមុខទាំងអស់គ្នា ត្រូវពង្រឹងសមត្ថភាពធនធានមនុស្សរបស់កម្ពុជា។ កុំឲ្យកម្ពុជាអភ័ព្វដូចខ្ញុំកាលពីកុមារ ដែលត្រឹមតែអាយុ ១៣ឆ្នាំត្រូវបែកពីឪពុកម្តាយ។ ជារឿងកម្សត់។ ហេតុនេះហើយ បានជា**នៅដំណាក់កាលដែលខ្ញុំមានលទ្ធភាពគ្រប់គ្រងប្រទេស ខ្ញុំខិតខំធ្វើឱ្យវិស័យអប់រំបានទៅដល់មូលដ្ឋាន ជាមួយហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ ដើម្បីឲ្យកូនសិស្សងាយទៅកាន់សាលារៀនដោយមានផ្លូវល្អ និងសុវត្ថិភាព។ ហ្នឹងហើយជាក្របខណ្ឌគោលនយោបាយបែងចែកផ្លែផ្កានៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌**។ ចង់អនុវត្តដោយជោគជ័យគោលនយោបាយបែងចែកផ្លែផ្កាកំណើនសេដ្ឋកិច្ចដោយសមធម៌ គឺត្រូវវិនិយោគលើអ្វីដែលជាសេចក្តីត្រូវការរបស់ប្រជាជន ...៕

១១. ប្រទេសយើងមានដំណាក់កាលរកដី រត់ចោលដី ស្តារដី និងដណ្តើមដី

សម្ពោធស្ពានមិត្តភាពកម្ពុជា-ចិន កោះធំ, ១៣ កុម្ភៈ ២០១៧

... រឿងធំជាងគេ គឺរឿងសន្តិភាព។ បើអត់មានភាពទេ កុំសង្ឃឹមនិយាយពីរឿងអភិវឌ្ឍន៍ ... អ្នកនៅទីនេះ មួយភាគធំបានជួបប្រទះកាលពីសម័យកាលសង្គ្រាមហើយ តើយើងបានបាត់បង់អ្វីខ្លះ ... មិនត្រឹមតែគ្មានឱកាស ថែមទាំងបាត់បង់ឱកាស។ **ស្រុកយើងមានដំណាក់កាលរកដី ដំណាក់កាលរត់ចោលដី ដំណាក់កាលស្តារដី និងដំណាក់កាលដណ្តើមដី។ ដំណាក់កាលរត់ចោលដី គឺដំណាក់កាលអាមេរិកទម្លាក់គ្រាប់បែក។ នៅចុងសម័យសង្គមរាស្ត្រនិយម ប្រជាពលរដ្ឋបានទៅរកដីថ្មីដើម្បីអភិវឌ្ឍវិស័យកសិកម្ម ប៉ុន្តែដល់អាមេរិកឈ្លានពាន រត់ចោលដីអស់។ សម័យ ប៉ុល ពត ធ្វើបដិវត្តដីស្រែ ប្រមូលដាក់ជាដីរដ្ឋ ដីសហការ។ ដល់រំដោះហើយ ត្រូវឲ្យលុយប្រជាពលរដ្ឋទៅស្តារដី។ ឥឡូវដល់ដំណាក់កាលដណ្តើមដីគ្នា។** កុំថាដល់ទៅដីធម្មតា គ្រាន់តែដីចាក់លុបគ្រលុកក៏ថ្លៃដែរ។ ធ្វើផ្លូវមួយខ្សែៗ គ្រាន់តែទិញដីមកចាក់មិនតិចទេ ...៕

១២. កសិកម្មដើម្បីសេដ្ឋកិច្ចជនបទ និងផ្គត់ផ្គង់និងស្តេរកម្មស្បៀង

សំណេះសំណាលជាមួយកម្មករ និយោជិត នៅរោងចក្រចំនួន៨១ ក្នុងតំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់ គ្រុប ភ្នំពេញ, ២៧ ឧសភា ២០២៣

... ហេតុអីរាជរដ្ឋាភិបាលចង់បាននិងខិតខំទាក់ទាញវិនិយោគទាំងក្នុងប្រទេសនិងក្រៅប្រទេស? ... (ពីព្រោះថាបើ)ធ្វើតែកសិកម្មតែមួយមុខ មិនអាចក្លាយទៅជាប្រទេសអ្នកមានបានទេ មិនអាចអភិវឌ្ឍបានទេ។ ទ្រឹស្តី ប៉ុល ពត (ដែលថា) មានស្រូវគឺមានអ្វីៗទាំងអស់ ឬមួយហិកតា ៣តោន មួយហិកតា ៦តោន ... (បានបង្ហាញហើយថា)ទីចុងបំផុតប្រជាជនអត់បាយ ... **យើងកំពុងអភិវឌ្ឍលើគ្រប់ផ្នែក។ កសិកម្មនៅបន្ត(រួមចំណែក)ដើម្បីការលូតលាស់សេដ្ឋកិច្ចជនបទ ហើយសម្រាប់ការផ្គត់ផ្គង់(ធ្វើឱ្យមាន)ស្តេរភោពស្បៀងនៅក្នុងប្រទេស។ ទន្ទឹមនឹងនោះវិស័យឧស្សាហកម្មនិងសេវាត្រូវបានយកចិត្តទុកដាក់** ...។

១៣. បាត់ព្រៃឈើ តែកើនផ្ទៃដីដាំដុះពី ១,៨លានដល់ ៤លានហិកតា

ទិវាមច្ឆជាតិ អាងទឹកត្រពាំងថ្ម ភូមិត្រពាំងថ្ម ឃុំប៉ោយចារ ខេត្តបន្ទាយមានជ័យ, ១ កក្កដា ២០២២

... ខ្លះនិយាយហើយ និយាយទៀតច្រំដែលៗ ថា ព្រៃឈើបាត់ទៅណា? បើសិនកុំមានប្រជាជនកើនឡើង ព្រៃឈើក៏មិនមានបាត់ទៅណាទេ។ វានៅដដែលហ្នឹង។ វាបាត់ព្រៃ ប៉ុន្តែវានៅដី។ ហេតុអ្វីបានកាប់ព្រៃ ដោយសារតែតម្រូវការដីធ្លីសម្រាប់ការបង្កបង្កើនផលហ្នឹងហើយ ... មួយផ្នាំៗ យើងកាត់ពីគម្របព្រៃឈើដើម្បីចែកជូនប្រជាជនមិនតិចទេ។ **ក្នុងឆ្នាំ១៩៧៩ ប្រជាជនយើងបង្កបង្កើនផលក្នុងរង្វង់ប្រមាណពី ១លាន ៦សែន ទៅ ១លាន ៨សែនហិកតាប៉ុណ្ណោះ។ ឥឡូវផ្ទៃដីបង្កបង្កើនផលទាំងស្រែទាំងចំការ មានរហូតដល់ជាង ៤លានហិកតាទៅហើយ ... វាបាត់ព្រៃឈើ ប៉ុន្តែវាដុះមក(វិញនូវ)កោគផលដំណាំសម្រាប់ប្រជាពលរដ្ឋដដែលទេ ... ដីព្រៃរេចរឹលត្រូវបានកាប់ និងជំនួសមកវិញដោយដើមកៅស៊ូដោយដូងប្រេង ដោយស្វាយចន្ទី** ...។ល។

១៤. ឃុំប៉ោយចារនិងអាងត្រពាំងថ្ម អាចប្រកាសជាតំបន់គ្មានមីននៅចុងឆ្នាំ២០២២

ទិវាមច្ឆជាតិ អាងទឹកត្រពាំងថ្ម ភូមិត្រពាំងថ្ម ឃុំប៉ោយចារ ខេត្តបន្ទាយមានជ័យ, ១ កក្កដា ២០២២

... យើងមិនទាន់មានសុវត្ថិភាពគ្រប់គ្រាន់ទេ។ ខ្ញុំទទួលបានរបាយការណ៍ពីឯកឧត្តម លី ធុជ អនុប្រធានទី១ នៃអាជ្ញាធរមីន ថា ឃុំប៉ោយចារ ស្រុកភ្នំស្រុក អាងត្រពាំងថ្ម មានផ្ទៃដីបោសសម្អាតមីនរួចចំនួន ១,២៣ គីឡូម៉ែត្រក្រឡា ... ស្មើនឹងចំការមីន៦ ឬប្រមាណ៩៨% នៃផ្ទៃដីមានមីននៅទូទាំងស្រុកភ្នំស្រុក ... ខ្ញុំសុំឱ្យដោះមីនដែលនៅសេសសល់លើផ្ទៃដីផ្តាច់ព្រ័ត្រ។ សូមឯកឧត្តម អ៊ំ រាត្រី ធ្វើការភ្លាមជាមួយអាជ្ញាធរមីន **បញ្ជូនកម្លាំងចុះដោះឱ្យអស់ ហើយប្រកាសឃុំប៉ោយចារ ក៏ដូចជាអាងត្រពាំងថ្មនេះជាតំបន់គ្មានមីនតែម្តង។ ដោយតម្លៃណាក៏ដោយត្រូវតែដោះមីននៅតំបន់នេះ ហើយនៅចុងឆ្នាំនេះយ៉ាងយូរ ត្រូវតែប្រកាសតំបន់នេះជាតំបន់គ្មានមីន ដើម្បីធានាសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋ** ...។

១៥. មន្ទីរពេទ្យបង្អែកស្រុកក្រូចឆ្មារ ការខិតខំសម្រាប់សុខភាពប្រជាជននៅទីជនបទ

ដាក់ឲ្យប្រើប្រាស់ មន្ទីរពេទ្យបង្អែក ស្រុកក្រូចឆ្មារ, ខេត្តត្បូងឃ្មុំ, ៣ មេសា ២០២៣

... រីករាយបានមកចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់នូវមន្ទីរពេទ្យបង្អែកស្រុកក្រូចឆ្មារ ដែលស្ថិតនៅទីកន្លែង(ដែលពោរពេញដោយ)អនុស្សាវរីយ៍ ... សូមថ្លែងអំណរគុណចំពោះឯកឧត្តម ជា សុផារ៉ា ដែលបានដឹកនាំកសាងនូវមន្ទីរពេទ្យដ៏ធំមួយនេះ។ ដូចដែលឯកឧត្តមរដ្ឋមន្ត្រី ម៉ម ប៊ុនហេង បានធ្វើរបាយការណ៍ ... វាជាការខិតខំដើម្បី**បង្កើតឡើងនូវស្ថានភាពដ៏ល្អប្រសើរសំរាប់ជីវភាពសុខភាពប្រជាជននៅទីជនបទ។ ពីដើមឡើយ ស្រុកក្រូចឆ្មារ គឺជាទីជនបទ ... ទោះបីមានការបែងចែកថាអ្នកទន្លេជាអ្នកកំពង់ក៏ដោយ ក៏អ្នកកំពង់នេះស្ថិតនៅជាអ្នកជនបទ។ យើងនៅក្នុងស្ថានភាពដ៏លំបាកលំបិន។** ជំងឺមិនស្លាប់ក៏គង់ស្លាប់បានដោយសារយើងខ្វះមន្ទីរពេទ្យ ខ្វះគ្រូពេទ្យ ខ្វះថ្នាំពេទ្យ ហើយវាកាន់តែលំបាកទៅទៀត នៅពេលដែលយើងគ្មានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនអ្នកជំងឺទៅកាន់មន្ទីរពេទ្យ ...។

១៦. វ៉ាក់សាំងកូវីដ១៩ បានរាយទៅដល់ទីជនបទដាច់ស្រយាល

ប្រគល់សញ្ញាបត្រជូនគរុសិស្ស គរុនិស្សិត និស្សិត និងបុគ្គលិកអប់រំ
នៃវិទ្យាស្ថានជាតិអប់រំ, ២៥ មេសា ២០២៣

... **នៅពេលដែលកូវីដ១៩ រាតត្បាត រឿងដែលធ្វើឱ្យខ្ញុំធូរក្នុងចិត្តបំផុតគឺ វ៉ាក់សាំងរបស់យើង មិនស្ថិតនៅតែទីក្រុងភ្នំពេញទេ។ វ៉ាក់សាំងរបស់យើងបានរាយទៅដល់ជនបទ** ... ពេលឃើញការបង្ហោះតាមហ្វេសប៊ុកនូវរូបក្មេងប្រុសតូចម្នាក់ ជាកូនសិស្សនៅទីជនបទដ៏ឆ្ងាយ បានទទួលវ៉ាក់សាំង ហើយពាក់កាតចាក់វ៉ាក់សាំងនៅក ... បានធ្វើឱ្យប្រាកដក្នុងចិត្តថា **វ៉ាក់សាំងរបស់យើងបានដើរទៅដល់គ្រប់ទិសទី ធ្វើឲ្យពលរដ្ឋទទួលបានមិនថាទីក្រុង មិនថាជនបទ ... អ្វីដែលខ្ញុំសប្បាយចិត្តគឺបទបញ្ជាដែលបានដាក់ចេញទៅ ត្រូវបានប្រតិបត្តិការទាំងអស់ធ្វើសកម្មភាពគ្រប់ច្រកល្ហក និងទទួលបានជោគជ័យ។** គ្រូពេទ្យមិនប្រមូលផ្តុំនៅតែភ្នំពេញទេ តែបានចុះទៅដល់ជនបទចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋ ...។

១៧. ចង់ឱ្យការយល់ដឹងនិងអនុវត្តអនាម័យបានលាតសន្ធឹងទៅទីជនបទ/តាមភូមិឃុំ

ទិវាជាតិទីក្រុងស្អាតលើកទី១១ ឆ្នាំ២០២៣, ២៧ កុម្ភៈ ២០២៣

... យើងបានខិតខំច្រើនអំពីយុទ្ធនាការសម្រាប់អនាម័យ ... យើងនៅតែសេសសល់បញ្ហាមួយចំនួន ដែលយើងត្រូវយកចិត្តទុកដាក់ធ្វើការអប់រំឲ្យប្រជាពលរដ្ឋបានយល់ដឹងថា នេះជាទឹកដីរបស់ពួកគាត់។ អ្វីៗគឺជារបស់ពួកគាត់។ ពួកគាត់ត្រូវចូលរួម។ អ្នកណាក៏ដោយ ចាប់តាំងពីប្រជាជនធម្មតា រហូតដល់អ្នកមុខអ្នកការជាន់ខ្ពស់ត្រូវតែចូលរួម ... **ប្រហែលជាប្រមាណ ២ទសវត្សរ៍ ឬក៏ ៣ទសវត្សរ៍មុន យើងប្រើពាក្យស្លោក «ភូមិស្អាត ស្រែល្អ» ... សំដៅទៅការធ្វើអនាម័យ បង្ការជំងឺមួយចំនួន ដូចជាគ្រុនឈាមជាដើម ដែលវាបានកើតចេញពីការខ្វះអនាម័យនៅជនបទ ... ខ្ញុំចង់ឲ្យការយល់ដឹងនិងអនុវត្តស្តីពីអនាម័យលាតសន្ធឹងទៅកាន់ទីជនបទ នាំដល់ស្ថានភាពល្អប្រសើរតាមភូមិឃុំរបស់គាត់ និងទាក់ទាញបានទេសចរថែមទៀតផង** ...។

១៨. គ្មានអគ្គិសនី ទឹកស្អាត សាលា មន្ទីរពេទ្យ មិនអាចបន្តយគំលាតទីក្រុងនិងជនបទ

សម្ពោធកំណាត់ផ្លូវជាតិលេខ ៧ ប្រវែង ៩៣,៦៤ គីឡូម៉ែត្រ ពីរង្វង់មូលខ្លាស្ទុះ
ទៅឃុំរមាត ខេត្តក្រចេះ, ៧ កុម្ភៈ ២០២២

... មើលតាមស្ថិតិ ក្រចេះដែលមាន ៥ស្រុក មានសាកលវិទ្យាល័យចំនួន១ មានវិទ្យាល័យ១២។ បានសេចក្តីថា បើគិតជាមធ្យមភាគ ក្នុងមួយស្រុកមានវិទ្យាល័យ ២ មានអនុវិទ្យាល័យ៤៣ ក្នុងពេលដែលខេត្តនេះ មាន ៤៣ឃុំ/សង្កាត់ ... ថ្ងៃក្រោយអាចឈានទៅមាន ២ ឬ៣ (អនុវិទ្យាល័យ)តាមឃុំតូច/ធំ។ ឯសាលារៀនគឺបឋមសិក្សាមាន ២៨៦សាលា ក្នុងពេលដែលយើងមានភូមិ២៩៥។ នៅខ្វះភូមិមួយចំនួន ប៉ុន្តែភូមិខ្លះប្រហែលតូចៗ និងមានមត្តេយ្យចំនួន ១០២ កន្លែង។ **នេះហើយការកាត់បន្ថយគម្លាតរវាងទីក្រុងនិងជនបទ។ បើទុកឱ្យជនបទនៅតែបន្តដើរក្នុងកក់ជ្រាំ បើយើងទុកឱ្យជនបទពុំមានអគ្គិសនីប្រើប្រាស់ ទុកឱ្យជនបទមិនមានទឹកស្អាត មិនមានសាលារៀន មន្ទីរពេទ្យគ្រប់គ្រាន់ ការកាត់បន្ថយគម្លាតរវាងទីក្រុង និងជនបទ នៅតែធ្វើមិនបាន** ...។

១៩. ដោះស្រាយទឹកដោយជីកអណ្តូងនៅនឹងកន្លែង ប្រសើរជាងដឹកទឹកពីចម្ងាយ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកក្រគរ ខេត្តពោធិសាត់,
២០ មីនា ២០១៩

... ប្រទេសរបស់យើងកំពុងមានបញ្ហាខ្វះទឹកផឹក ទោះបីមិនទាន់ដល់កម្រិតឆ្នាំ ២០១៦ ក៏ដោយ។ កាលពីឆ្នាំ២០១៦ កំពស់ទឹកតាមអណ្តូងនានារីងធ្លាក់ទៅ (នៅកំរិតទាប)។ អត់មានទឹកទេ។ ឥឡូវនេះ អណ្តូងយើងនៅមានទឹក។ ប៉ុន្តែកន្លែងដែលធ្លាប់មានប្រភពទឹក ឥឡូវទឹកហ្នឹងរារីង។ អញ្ចឹង **សុំឲ្យយកចិត្តទុកដាក់ដោះស្រាយទឹក រកវិធីជីកអណ្តូង ប្រសើរជាងដឹកទឹកទៅចែកប្រជាពលរដ្ឋ។ ដឹកទឹកទៅបានតែក្នុងមួយរយៈទេ ប៉ុន្តែបើយើងជាក់អណ្តូងនៅហ្នឹងបានរាប់ឆ្នាំតកូន ភ្ញៀ តជំនាន់។ អញ្ចឹងទេ រកវិធីសាស្ត្រជីកអណ្តូង ប្រសើរជាងការដឹកទឹក**។ ពិតហើយ ពេលខ្លះយើងក៏មានតម្រូវការដឹកទឹកពេលដែលជីកអណ្តូងមិនចេញ ...។

២០. ឥវ៉ាប់អគ្គិសនីដើម្បីបម្រើផលិតកម្មកសិកម្ម កាត់បន្ថយថ្លៃដើមផលិត

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល, ២០ កុម្ភៈ ២០១៩

... ក្រោយមកដើម្បីជម្រុញផលិតកម្មកសិកម្ម យើងបានដាក់ចេញគោលនយោបាយផលិតស្រូវនិងការនាំចេញអង្ករ។ **ក្នុងចំណោមគោលដៅ២ យើងសម្រេចបានជោគជ័យលើគោលដៅ១។ គោលដៅទី១ ជម្រុញផលិតកម្មស្រូវ និងទី២ នាំចេញអង្ករ។ យើងធ្វើពីស្ថានភាពនៃការខ្វះអង្ករទទួលទានទៅជាប្រទេសដែលមានស្រូវនាំចេញ។ ឆ្នាំទៅនេះ យើងនៅសល់ស្រូវ ៥លាន ៥សែនតោន ... ឆ្នាំនេះស្រូវនៅសល់នឹងកើនដល់ ៦លានតោន។ ប៉ុន្តែ ការនាំចេញអង្ករឲ្យបាន១ លានតោននៅមិនទាន់សម្រេចគោលដៅនៅឡើយទេ** ដោយសារយើងមានដៃគូប្រកួតប្រជែងដ៏ខ្លាំង ... ទៅខាងមុខនេះ **យើងនឹងដាក់ចេញនូវគោលនយោបាយថែមទៀតដើម្បីជម្រុញវិស័យកសិកម្ម ដូចជាការតភ្ជាប់អគ្គិសនីទៅកាន់ចំណុចដែលមានប្រភពទឹក ដើម្បីប្រជាពលរដ្ឋអាចប្រើប្រាស់ម៉ូទ័របូមទឹក ជំនួសឲ្យម៉ាស៊ីនបូមទឹក ប្រើប្រេងឥន្ធនៈដែលនាំដល់ថ្លៃដើមខ្ពស់** ...។

២១. ទម្លាក់ថ្លៃអគ្គិសនី/ផលិតជីក្នុងស្រុក បន្ថយថ្លៃដើមផលិតក្នុងវិស័យកសិកម្ម

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល, ២០ កុម្ភៈ ២០១៩

... រាជរដ្ឋាភិបាលត្រូវ**គិតនិងចង្អុលណែនាំទៅអាជ្ញាធរអគ្គិសនី ដើម្បីជម្រុញឲ្យក្រុមហ៊ុនអគ្គិសនីតបណ្តាញទៅកាន់តំបន់ដែលមានប្រភពទឹក ឱ្យប្រជាពលរដ្ឋប្រើប្រាស់ម៉ូទ័របូមទឹក ជំនួសឲ្យការប្រើម៉ាស៊ីន ... យើងផ្ទេរពីការដែលយើងចាក់ប្រេង ទៅជាការប្រើភ្លើងជំនួសវិញ ដោយសម្រាប់ការបូមទឹកការប្រើប្រាស់អគ្គិសនីមានតម្លៃក្នុងរង្វង់តែ ៨១០រៀលប៉ុណ្ណោះ នៅពេលក្បែរភ្លឺ។ អញ្ចឹង ពេលណាដែលតម្លៃអគ្គិសនីធ្លាក់ចុះ យើងឆ្លៀតបូមពេលហ្នឹង**។ កុំបូមពេលថ្ងៃ សូមបូមពេលយប់ ... នេះគឺជាការពង្រឹងការប្រកួតប្រជែងដើម្បីធ្វើឲ្យថ្លៃដើមនៃការផលិតក្នុងវិស័យកសិកម្ម (ត្រូវបាន)កាត់បន្ថយ។ **(ការគិតគូទាំងនោះមាន) រាប់ទាំងការសិក្សាស្វែងរកវិធីសាស្ត្រផលិតជីក្នុងស្រុក ដើម្បីឲ្យប្រជាជនបានជីប្រើប្រាស់ក្នុងតម្លៃថោកជាង** ...។

២២. ភូមិ៩៩% និងផ្ទះ៩០% ទូទាំងប្រទេសបានភ្ជាប់បណ្តាញអគ្គិនីរួចរាល់

សំណេះសំណាលជាមួយប្រជាពលរដ្ឋ និងពិនិត្យការដ្ឋានសំណង់វារីអគ្គិសនីស្ទឹងពេធ៏សាត់ ១ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពេធ៏សាត់, ១៤ មីនា ២០២៣

... ពេលដែលយើងធ្វើវារីអគ្គិសនីនេះ តិចឬច្រើនគឺមានផលប៉ះពាល់ហើយ។ តើយើងត្រូវដោះស្រាយផលប៉ះពាល់នោះរបៀបម៉េច។ ការជួបជុំថ្ងៃនេះក៏បញ្ជាក់អំពីរបៀបដែលយើងដោះស្រាយ(ផលប៉ះពាល់) ដូចដែល ឯកឧត្តម ខូយ រីដា បានធ្វើរបាយការណ៍អម្បាញ់មិញ ... គឺទៅតាមជម្រើសរបស់ប្រជាជន។ ឥឡូវនេះ**នៅទូទាំងប្រទេស ភូមិដែលភ្ជាប់ជាមួយបណ្តាញជាតិរួចមានដល់ទៅ៩៩% ... ឯផ្ទះប្រជាពលរដ្ឋភ្ជាប់ជាមួយបណ្តាញជាតិរួចហើយមានដល់ទៅ៩០%។** នេះគឺជាសម័យប្រើអគ្គិសនី មិនមែនសម័យដុតចន្លុះ ភ្លើងទៀន/ចង្កៀងទៀតទេ ...។

២៣. មិនដំឡើងថ្លៃអគ្គិសនី ខណៈពី៩៧% ទៅ៩៩% នៃភូមិទូទាំងប្រទេសមានអគ្គិសនី

សំណេះសំណាលជាមួយកម្មករ នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល, ១០ មិថុនា ២០២៣

... បើទោះបីថាប្រទេសដទៃក្នុងតំបន់ដំឡើងថ្លៃប្រើប្រាស់អគ្គិសនី ក៏**កម្ពុជាមិនដំឡើងថ្លៃទេ។ បើយើងដំឡើងថ្លៃវានឹងប៉ះពាល់ភ្លាមដល់វិស័យឧស្សាហកម្ម វិស័យទេសចរណ៍ វិស័យសេវាកម្មនានា ជាពិសេសអ្នកប្រើប្រាស់ភ្លើងទាំងអស់តែម្តង**។ កើតមកសម័យនេះ ក្មួយៗអត់ជួបប្រទះការដុតចន្លុះ ដុតជំរ ឬចង្កៀងប្រេងកាតទេ។ ហោចណាស់ក្មួយៗមានអាគុយ និងជាទូទៅប្រហែលជាក្មួយៗមិនប្រើអាគុយទេ ព្រោះមានអគ្គិសនី។ **ប្រមាណជា៩៧% ឬ៩៩% ទៅហើយនៃភូមិនៅទូទាំងប្រទេសមានអគ្គិសនីប្រើប្រាស់ ... យើងមិនដំឡើងថ្លៃភ្លើងទេ ទោះបីថាក្រុមហ៊ុនអគ្គិសនីជួបការលំបាកបន្តិច** ដែលមិនមានប្រាក់គ្រប់គ្រាន់សម្រាប់វិនិយោគលើបណ្តាញចែកចាយបន្ត ...។

២៤. ភូមិ១០០% នៅកំពង់ស្ពឺមានអគ្គិសនីប្រើប្រាស់

សំណេះសំណាលជាមួយកម្មករសាងចក្រនៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ, ២៧ មិថុនា ២០២៣

... **ភូមិនៅខេត្តកំពង់ស្ពឺ១០០% ហើយដែលមានអគ្គិសនីប្រើប្រាស់។ មុននោះ កំពង់ស្ពឺជុតចន្លុះ ជុតចង្កៀងប្រេងកាត។ ឥឡូវ ចន្លុះនិងចង្កៀងប្រេងកាតទៅបាត់ហើយ។ បើទោះបីថា កន្លែងខ្លះទើបនឹងទៅធ្វើផ្ទះនៅ ខ្សែបណ្តាញអគ្គិសនីមិនទាន់ទៅដល់ ក៏គេប្រើ solar ដែរ។** ប្រើពន្លឺព្រះអាទិត្យ ឬក៏ប្រើធុងអាគុយ ... ពេលដែលយើងប្រជុំអាស៊ានឆ្នាំ២០០២ យើងមានសណ្ឋាគារផ្កាយប្រាំត្រឹមតែ២ គឺមួយនៅ Raffles មួយទៀតនៅ Intercontinental ធ្វើជាកន្លែងប្រជុំ។ ចេះតែគិតថា តើប្រទេសនានាវាយតម្លៃប្រទេសយើងយ៉ាងម៉េច? ... ដល់មកធ្វើប្រធានអាស៊ាន ឆ្នាំ២០១២ រាងគ្រាន់បើបន្តិច។ ពេលមកធ្វើប្រធានអាស៊ាននៅឆ្នាំ២០២២ ចាប់ផ្តើមដូចគេដូចឯង ...។

២៥. មានផ្លូវចាក់កៅស៊ូយ៉ាងមាំតភ្ជាប់គ្នាគ្រប់ភូមិ/តំបន់តាមដងទន្លេមេគង្គ

បើកការដ្ឋានសង់ស្ពានឆ្លងកាត់ទន្លេមេគង្គ ពីស្ទឹងត្រង់ ទៅក្រូចឆ្មារ, ៩ កុម្ភៈ ២០១៨

... មកតាមនេះ **ឃើញផ្លូវចាក់កៅស៊ូយ៉ាងមាំតភ្ជាប់គ្នាអស់ហើយ ពីទន្លេចិចេញមកដូចជានៅសល់ប៉ុន្មានគន្លាក់ទេ។ សួរថា អ្នកពាមកោះស្នា អ្នកព្រៃសង្កែ អ្នកឧលរកា ពីដើមស្រមៃឃើញផ្លូវបែបហ្នឹងទេ។ ពីដើមយើងបារ៉ាទេ៖ លើផ្លូវដែលយើងដើរផង ជិះកង់ផង។ តើអ្នកពាមកោះស្នា អ្នកឧលរកា អ្នកព្រះអណ្តូង អ្នកអន្លង់សំឡី អ្នកព្រៃប្រសព្វ អ្នកស្ពឺឡើងរហូតដល់ក្រចេះ ស្រមៃនឹកឃើញថាមានផ្លូវហ្នឹងទេកើតឡើងទេ?** ច្បាស់ជាមិននឹកទេ។ មានអគ្គីសនីប្រើប្រាស់ទេ? វាអត់ទេ។ ឥឡូវមាន(ដល់ទៅ)ទូរទស្សន៍ខ្សែកាប្លិ៍មើលទៀត ... តើដូរទៅណាទៀត ...។

២៦. ហេដ្ឋារចនាសម្ព័ន្ធកាត់បន្ថយគម្លាតរវាងទីក្រុង និងជនបទ

សម្ពោធស្ពានកោះកំពង់ត្រុំ/កោះប៉ែន, ១៤ មីនា ២០១៨

... **ការប្រើប្រាស់ថវិកាកសាងហេដ្ឋារចនាសម្ព័ន្ធបម្រើប្រជាជន គឺជាការបែងចែកផ្លែផ្កាប្រកបដោយសមធម៌បំផុត ហើយការតភ្ជាប់បណ្តាញផ្លូវគមនាគមន៍ពីទីក្រុងទៅជនបទ ជាការកាត់បន្ថយគម្លាតរវាងទីក្រុងនិងជនបទ។** ពីមុននេះ រវាង

អ្នកទីរួមខេត្តកំពង់ចាម និងអ្នកកោះកំពង់ត្រុំ កោះប៉ែននេះ មើលទៅដូចជាមានការខុសគ្នា រវាងម្ខាងខាងនោះគឺទីក្រុង ឯម្ខាងខាងនេះគឺជនបទ។ ឥឡូវនេះ តាមរយៈស្ពានមួយនេះ អ្នកខាងនេះមានលទ្ធភាពប្រើប្រាស់ម៉ូតូ ប្រើប្រាស់ឡាន។ ពីមុន បើទោះបីជាមានឡានក៏មិនដឹងថាបើកទៅណា។ ឥឡូវធ្វើដំណើរដូចគេដូចឯង អាចទៅរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ កន្លែងដទៃ រហូតទៅដល់តំបន់ដែលមានសមាហរណកម្ម តាមរយៈនយោបាយឈ្នះឈ្នះ តាំងពីប៉ែលិនកំរៀងភ្នំព្រឹកម៉ាឡៃទៅអន្លង់រវែងទៅកន្លែងដទៃទៀត គឺស្ថានភាពផ្លូវល្អប្រសើរ ...។

២៧. ត្រូវវិនិយោគច្រើនទៀត តភ្ជាប់ជនបទពីស្រុកមួយទៅស្រុកមួយនៅព្រៃវែង

បើកការដ្ឋានសង់ផ្លូវជាតិលេខ ១១ ស្ពានអ្នកលឿង-ថ្ពល់ទទឹង(ផ្លូវជាតិលេខ៧), ២៣ មីនា ២០១៨

... បើនិយាយពីខេត្តព្រៃវែង **ប្រព័ន្ធផ្លូវអាចនិយាយបានថាច្រើនជាងគេ ប្រៀបធៀបទៅនឹងបណ្តាខេត្តនានា។ ទឹកដីខេត្តព្រៃវែងមានខ្នែងផ្លូវច្រើនជាងគេបង្អស់ ប្រៀបធៀបជាមួយខេត្តដទៃ។ យ៉ាងណាក្តី យើងនៅត្រូវវិនិយោគច្រើនទៀតសម្រាប់សម្រាប់ផ្លូវជាតិខេត្តព្រៃវែង និងនៅមានផ្លូវតភ្ជាប់ជនបទពីស្រុកមួយទៅកាន់ស្រុកមួយ។ មានផ្លូវច្រើន។ អាចចាត់ទុកថាជាខេត្តដែលមានខ្នែងផ្លូវច្រើនជាងគេ។ ទាមទារនូវការវិនិយោគបន្ថែមទៀត។** អ្នកខ្លះបន្តុះបង្អាប់ខ្ញុំដែលប្រើពាក្យថា ជំហានគីង្គក់។ ខ្លះថា ត្រូវប្រើ ជំហានយក្ស។ បើលោកឯងធ្វើជំហានយក្សកើតក៏ធ្វើទៅ។ ឯខ្ញុំធ្វើជំហានគីង្គក់ ប៉ុន្តែធ្វើម្តង ១០០គីឡូម៉ែត្រ ធ្វើម្តង ២០០ គីឡូម៉ែត្រ ធ្វើម្តង ៥០ គីឡូម៉ែត្រ ធ្វើស្ពានមួយ ធ្វើស្ពានពីរ ...។

២៨. សិក្ខាការតភ្ជាប់ឆ្លងស្ទឹងបញ្ចូលក្នុងថវិកាក្រសួងអភិវឌ្ឍន៍ជនបទឆ្នាំ២០២៣

ទិវាមច្ឆជាតិ អាងទឹកត្រពាំងឫស្សី ភូមិត្រពាំងឫស្សី ឃុំប៉ោយចារ ខេត្តបន្ទាយមានជ័យ, ១ កក្កដា ២០២២

... កាលពីទឹកជំនន់ឆ្នាំ២០០០ យើងមានបាក់ស្ពានឈើមួយ។ **ស្ពានឈើនោះឆ្លងស្ទឹងតភ្ជាប់ភូមិ៣ ភូមិ៤ ទៅភូមិព្រះពន្លា ឃុំព្រៃឫស្សី សង្កាត់ព្រះពន្លា និងសង្កាត់កោះពងសត្វ។ ខ្ញុំស្នើឲ្យមានការសិក្សាអំពីធ្វើស្ពាននេះ ហើយបញ្ចូលគំរោងទៅក្នុងថវិកាក្រសួងអភិវឌ្ឍន៍ជនបទឆ្នាំ២០២៣។** យើងចាយលុយក៏ត្រូវ

មានការប្រុងប្រយ័ត្ន ពិតមែនតែឥឡូវចំណូលចាប់ផ្តើមងើប ... កំណើនសម្រាប់តម្រូវការក្នុងស្រុកនិងកំណើននៃការនាំចូលមានការកើនឡើង ...។

២៩. កសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នៅប៉ូលទាំង៣ ដើម្បីការលូតលាស់សេដ្ឋកិច្ចជាតិ

ជាក់ឱ្យប្រើប្រាស់នូវផ្លូវលេខ ១៤៦ បេ ហៅថាវិថីសម្តេចព្រះសង្ឃរាជ ទេព វង្ស និងផ្លូវលេខ ១៤៨ ហៅថាតីវិថីសម្តេចតេជោ ហ៊ុន សែន, ២២ ធ្នូ ២០២២

... **ប៉ូលសេដ្ឋកិច្ចទាំង៣ របស់កម្ពុជា ដែលត្រូវបានកសាងនោះគឺ ទី១ ប៉ូលទីក្រុងភ្នំពេញ, ទី២ ខេត្តព្រះសីហនុ និងទី៣ ខេត្តសៀមរាប។ ប៉ូលទាំង៣ ត្រូវបានជំរុញកសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីបម្រើឱ្យការរីកលូតលាស់របស់ជាតិ និងប្រជាជន**។ ជាពិសេស ប្រជាជនដែលរស់នៅក្នុងខេត្តទាំងនោះតែម្តង។ វាមិនមែនជាផលប្រយោជន៍ដាច់ដោយឡែកសំរាប់តែប្រជាជន ដែលរស់នៅក្នុងខេត្តព្រះសីហនុ ឬខេត្តសៀមរាប ឬទីក្រុងភ្នំពេញទេ ក៏ប៉ុន្តែវា**ជំរុញឱ្យមានការរីកលូតលាស់ឡើងនូវល្បឿនសេដ្ឋកិច្ច សម្រាប់ប្រជាជននៅទូទាំងប្រទេស** ...។

៣០. ចាប់ពីពេលនេះតទៅ ធ្វើផ្លូវពីបេតុងដើម្បីអាយុវែងមាំ

ជាក់ឱ្យប្រើប្រាស់នូវផ្លូវលេខ១៤៦បេ ហៅថាវិថីសម្តេចព្រះសង្ឃរាជ ទេព វង្ស និងផ្លូវលេខ១៤៨ ហៅថាតីវិថីសម្តេចតេជោ ហ៊ុន សែន, ២២ ធ្នូ ២០២២

... ខ្ញុំនៅតែបន្តនយោបាយអទិភាពលើការតភ្ជាប់ និងដៃលការតភ្ជាប់លើកនេះ ខុសពីការតភ្ជាប់ក្នុងពេលក្រលំបាក ដែលពេលនោះទាំងដៃគូអន្តរជាតិរបស់យើងសុទ្ធតែបានមកធ្វើការជាមួយយើងថា "**លុយតិចតែធ្វើផ្លូវឱ្យបានវែង**"។ **នេះជារឿងនៅក្នុងទសវត្សរ៍៩០ ... ផ្លូវច្រើនដែលយើងបានទទួលលុយពីធនាគារអភិវឌ្ឍអាស៊ីពីដៃគូអភិវឌ្ឍផ្សេងទៀត យកមកសាងសង់ ប៉ុន្តែ(ការអនុវត្តតាមអភិក្រម)លុយតិចកសាងផ្លូវឱ្យបានវែង ទីចុងបំផុតយើងប្រើ(ផ្លូវទាំងនោះ)បានតែក្នុងមួយរយៈកាលខ្លី។ បន្ទាប់ទៅត្រូវជួសជុលអស់លុយច្រើនណាស់។ អញ្ចឹង ខ្ញុំចង្អុលបង្ហាញថា ចាប់ពីពេលនេះតទៅ បើសិនជាត្រូវធ្វើ លេងបេតុង ធ្វើម៉ែច(ឱ្យវែងមាំ)** ...។

៣១. កំពង់ស្ពឺក្លាយជាខេត្តមានផ្លូវឆ្លងកាត់ច្រើន

សំណេះសំណាលជាមួយកម្មកររោងចក្រនៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ, ២៧ មិថុនា ឆ្នាំ២០២៣

... កម្មករ/ការិនីនៅទីនេះត្រូវរួមគ្នារក្សាសន្តិភាពដើម្បីធានាការអភិវឌ្ឍ។ យើងមិនត្រូវអត់ឱនឲ្យទង្វើណាក៏ដោយដែលបំផ្លាញសន្តិភាពរបស់ប្រទេស។ យើងបានឆ្លងកាត់សោកនាដកម្មដោយសារសង្គ្រាមនេះ ... យើងមានដៃលធ្លាប់ស្គាល់ផ្លូវលេខ៤៤នេះទេ? យើងបានសិក្សាដើម្បីបង្កើត(ផ្លូវនេះឡើង)។ **ទីបំផុតកំពង់ស្ពឺក្លាយជាតំបន់ដែលមានផ្លូវធ្វើច្រើនជាងគេ។ ផ្លូវ៥១ ក៏កាត់កំពង់ស្ពឺពីខាងកំពង់ឆ្នាំង ពីខាងកណ្តាល កាត់កំពង់ស្ពឺ ... ផ្លូវ៤១ ក៏កាត់កំពង់ស្ពឺ, ផ្លូវ៤៤ ចេញទៅឧដុង្គ ... ទៅឱរ៉ាល់ក៏មានខ្នែងភ្ជាប់ទៅ** ... ដោយមិនចាំបាច់លំបាកធ្វើដំណើរឆ្លងកាត់ការកកស្ទះ គេអាចធ្វើដំណើរពីម្តុំរាំងចាស់ តាមផ្លូវជាតិលេខ៤៤ មកចេញនៅកំពង់ស្ពឺ វារហ័សជាង ហើយប្រើប្រេងតិចជាង ...។

៣១. ឧស្សាហកម្ម ឥទ្ធិសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

១	បដិវត្តឧស្សាហកម្មទី៤ ធ្វើឱ្យបារម្ភថាគ្រឿងយន្តធ្វើឱ្យមនុស្សបាត់បង់ការងារ	៦៨៧
២	ឧស្សាហកម្មមានចំណែកទៅដល់ ៣០% នៅក្នុងផលទុនជាតិ	៦៨៧
៣	សម័យបដិវត្តឧស្សាហកម្មទី៤ មនុស្សប្រឈមនឹងបាត់បង់ការងារ	៦៨៧
៤	គួរគិតវិធានការទុកមុន ការធានាការបាត់បង់ការងារដោយសារបច្ចេកវិទ្យា	៦៨៨
៥	ឧស្សាហកម្មជាក្បាលម៉ាស៊ីនទាញកសិកម្មឲ្យរីកលូតលាស់	៦៨៨
៦	ទាក់ទាញវិនិយោគផ្នែកឧស្សាហកម្មឱ្យមកកែច្នៃលើវត្ថុធាតុដើមក្នុងស្រុក	៦៨៩
៧	រៀបចំបង្កើតធនាគារគាំទ្រសហគ្រាសធុនតូច/មធ្យម	៦៨៩
៨	អភិវឌ្ឍសហគ្រាសធុនតូច/មធ្យម ដោយសហការរវាងវិស័យសាធារណៈ/ឯកជន	៦៨៩
៩	ឱកាសបានមកដល់សំរាប់ការជំរុញវិស័យឧស្សាហកម្ម	៦៩០
១០	សហគ្រាសធុនតូចនិងមធ្យមចុះបញ្ជីនិងកាន់បញ្ជីការគណនេយ្យឱ្យបានត្រឹមត្រូវ	៦៩០
១១	គោលនយោបាយទាក់ទាញឧស្សាហកម្មកែច្នៃ និងឧស្សាហកម្មបច្ចេកវិទ្យា	៦៩០
១២	កម្ពុជាត្រូវចូលទៅក្នុងសង្វាក់ផលិតកម្មដែលមានចរិតសកល	៦៩១
១៣	ទាក់ទាញឧស្សាហកម្មប្រើវត្ថុធាតុដើមក្នុងស្រុក ធ្វើផលិតផលសម្រេចនាំចេញ	៦៩១
១៤	ក្រៅពីអតិពលកម្ម ចង់ទាញយកឧស្សាហកម្មបច្ចេកវិទ្យាទំនើប/សកល	៦៩១
១៥	បដិវត្តន៍ឧស្សាហកម្មទី៤ កំពុងជាបញ្ហាប្រឈមរបស់ពិភពលោក	៦៩២
១៦	កែជាក្រសួងឧស្សាហកម្ម បច្ចេកវិទ្យានិងនវានុវត្តន៍ ឱ្យទាន់បដិវត្តឧស្សាហកម្ម ៤.០	៦៩២
១៧	គោលនយោបាយឧស្សាហកម្ម ២០១៥-២៥ របស់ "ហ៊ុន សែន"	៦៩៣
១៨	វិទ្យាសាស្ត្របច្ចេកទេសគ្មានក្រមសីលធម៌គ្រប់គ្រងអាចនាំទៅដល់គ្រោះថ្នាក់	៦៩៣
១៩	បន្តយុទ្ធសាស្ត្រយោធាពិភពលោក បំរើសេដ្ឋកិច្ចសង្គម បន្ទាបថ្លៃថ្នាំ/ឧបករណ៍ពេទ្យ	៦៩៤
២០	២៤ឆ្នាំមុន(១៩៩៩) ពង្រាយរោងចក្រតាមខេត្ត បង្កើនចំនួនកស្រុករកការងារ	៦៩៤
២១	កំពង់ចាមនឹងមានរោងចក្រច្រើនប្រើប្រាស់វត្ថុធាតុដើមមានស្រាប់	៦៩៥
២២	ដំណាំឧស្សាហកម្មផ្តល់ប្រយោជន៍សេដ្ឋកិច្ចនិងព្រៃឈើគ្របដណ្តប់	៦៩៥
២៣	ថយផ្នែកសម្លៀកបំពាក់និងស្បែកជើង កើនកម្មន្តសាលមិនមែនសម្លៀកបំពាក់	៦៩៥
២៤	គម្រោងឧស្សាហកម្មបច្ចេកវិទ្យាប្រើថាមពលបៃតង និងលំនៅដ្ឋានតម្លៃសមរម្យ	៦៩៦
២៥	ថ្មក្រោមដីអាចផលិតស៊ីម៉ង់ត៍នឹងធ្វើឱ្យកំពង់ស្តីមានឧស្សាហកម្មធុនធ្ងន់	៦៩៦

២៦ កំពង់ស្តីនិយាយដោយខ្មែក នីតីប្រទេសនិយាយរួម មានសក្តានុពលឧស្សាហកម្ម ៦៩៧

២៧ ប្រើបច្ចេកវិទ្យាព័ត៌មានជំរុញល្បឿនការងារនិងប្រយុទ្ធប្រឆាំងអំពើពុករលួយ ៦៩៧

១. បដិវត្តឧស្សាហកម្មទី៤ ធ្វើឱ្យបារម្ភថាគ្រឿងយន្តធ្វើឱ្យមនុស្សបាត់បង់ការងារ

ពិធីចែកសញ្ញាបត្រសាកលវិទ្យាល័យ ឯកទេសនៃកម្ពុជា, ៩ តុលា ២០១៧

... សភាពការណ៍នៅលើពិភពលោកវិវឌ្ឍលឿនណាស់ សូម្បីតែវេទិកាសេដ្ឋកិច្ចពិភពលោក រាប់ទាំងវេទិកាអាស៊ានធ្វើនៅទីក្រុងភ្នំពេញ កាលពីខែឧសភាកន្លងទៅ (សុទ្ធតែបានបង្ហាញ)កង្វល់មួយចំនួនពាក់ព័ន្ធនឹងឧស្សាហកម្មទី៤ ដែលថាអាចប្រើប្រាស់គ្រឿងយន្តជំនួសមនុស្ស។ វាជាដំណើរជឿនលឿននៃបច្ចេកទេសហើយ ក៏ប៉ុន្តែអ្វីដែលវាបានបាត់ទៅវិញគឺការងារធ្វើរបស់ប្រជាជន។ នេះជាចំណុចដែលមានកង្វល់ច្រើនបំផុត សម្រាប់ប្រទេសកំពុងអភិវឌ្ឍ ពិសេសប្រទេសក្រីក្រដែលមានពលកម្មវ័យក្មេងច្រើន ដែលមានតម្រូវការការងារធ្វើ ប៉ុន្តែបែរជាប្រឈមនឹងត្រូវបានជំនួសដោយគ្រឿងយន្ត ...៕

២. ឧស្សាហកម្មមានចំណែកទៅដល់ ៣០% នៅក្នុងផលទុនជាតិ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅតំបន់ព្រៃទា, ២៨ មីនា ២០១៨

... ក្នុងដំណើរលូតលាស់នៃសេដ្ឋកិច្ចរបស់យើង ពិសេសក្នុងដំណាក់កាលដែលរាជរដ្ឋាភិបាលដាក់ចេញ គោលនយោបាយឧស្សាហកម្ម២០១៥-២០២៥, ដែលមុននោះ មានចំណែកត្រឹមតែ៤% ទៅ៥% ... ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ នងដោយឡែកក្នុង**ឆ្នាំ២០១៨ វិស័យឧស្សាហកម្ម បានរួមចំណែកនៅក្នុងសេដ្ឋកិច្ចជាតិរហូតទៅដល់៣០% ក្នុងពេលដែលវិស័យកសិកម្មនៅសល់ ២៥% និងផ្នែកសេវាកម្មឡើងដល់ ៤៥% នៃសេដ្ឋកិច្ចជាតិ ...៕**

៣. សម័យបដិវត្តឧស្សាហកម្មទី៤ មនុស្សប្រឈមនឹងបាត់បង់ការងារ

បើកសន្និសីទស្តីពីប្រធានបទ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សម្រាប់ឧស្សាហូបនីយកម្ម កំណើនសេដ្ឋកិច្ច និងអភិវឌ្ឍប្រទេសកម្ពុជា, ១៥ មីនា ២០១៨

... បច្ចេកវិទ្យាវាលឿន ហើយច្បាស់ជាជម្រុញទៅដល់កំណើនសេដ្ឋកិច្ចនិងការលូតលាស់នៃប្រទេសនានា ក៏ប៉ុន្តែបញ្ហាត្រូវតែគិតនៅត្រង់ចំណុចថា បើមនុស្សយន្តវាធ្វើការជំនួសមនុស្ស(ទៅ)ហើយ តើមនុស្សមានការងារធ្វើពីណាទៀត? នោះហើយជាបញ្ហាសង្គម ដែលវានឹងកើតឡើងនៅក្នុងសម័យបដិវត្ត

ឧស្សាហកម្មទី៤ ... ជាបញ្ហាប្រឈមមួយក្នុងបញ្ហាទាក់ទងជាមួយនឹងសំណាញ់សុវត្ថិភាពសង្គម ... ប្រទេសខ្លះឈានដល់ប្រើមនុស្សយន្តលើកម្លុបហើយ ...។

៤. គួរគិតវិធានការទុកមុន ការធានាការបាត់បង់ការងារដោយសារបច្ចេកវិទ្យា

បើកសន្និសីទស្តីពីប្រធានបទ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សម្រាប់ឧស្សាហូបនីយកម្ម កំណើនសេដ្ឋកិច្ច និងអភិវឌ្ឍប្រទេសកម្ពុជា, ១៥ មីនា ២០១៨

... ឧស្សាហកម្មនៅប្រទេសរបស់យើងកំពុងតែដំណើរការតាមបែបអតិពលកម្ម ព្រមពេលដែលយើងដាក់គោលនយោបាយឧស្សាហកម្មថ្មី ២០១៥-២៥ ដែលមានទិសដៅទាញយកនូវឧស្សាហកម្មមានការកែច្នៃ និងមានតម្លៃបន្ថែម និងឧស្សាហកម្មមានកម្រិតបច្ចេកវិទ្យាខ្ពស់ ... **ការរីកលូតលាស់នៃបច្ចេកវិទ្យាអាចនាំមកនូវផែលវិបាកដែលចៀសមិនរួចលើមនុស្សជាច្រើន (ដូចជាការ)ដែលត្រូវកាត់ចេញពី(ការងារតាម)បណ្តាក្រុមហ៊ុន ដែលមានបច្ចេកវិទ្យាខ្ពស់ ... យើងគប្បីគិតគូរទុកជាមុនអំពីវិធានការណ៍ទាំងឡាយ ដើម្បីធានាថាពលរដ្ឋដែលបាត់បង់ការងារដោយសារបច្ចេកវិទ្យា នឹងមិនត្រូវបានជាក់អោយនៅក្រៅដំណើរការនៃការរីកលូតលាស់នៃសង្គមទេ ...។**

៥. ឧស្សាហកម្មជាក្បាលម៉ាស៊ីនទាញកសិកម្មឲ្យរីកលូតលាស់

សំណេះសំណាលជាមួយកម្មករ និយោជិត ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ, ៨ សីហា ២០១៨

... មិនមែនបានសេចក្តីថា **ធ្វើនយោបាយឧស្សាហកម្ម យើងបំភ្លេចចោលកសិកម្មនោះទេ។ យើងចង់ធ្វើឱ្យនយោបាយឧស្សាហកម្មធ្វើជាក្បាលម៉ាស៊ីនទាញកសិកម្មឲ្យមានការរីកលូតលាស់ឡើង តាមរយៈនយោបាយការជំរុញកសិ-ឧស្សាហកម្មជាការតភ្ជាប់។ ការដែលយើងដាក់ចេញគោលនយោបាយកសិ-ពាណិជ្ជកម្ម បានសេចក្តីថាកសិករមិនផលិតសំរាប់តែចិញ្ចឹមខ្លួនទេ តែគឺដើម្បីលក់នៅក្នុងប្រទេសនិងលក់ចេញទៅក្រៅប្រទេស។** បច្ចុប្បន្ន ហោចណាស់យើងនាំចេញនៅនឹងកន្លែងក្នុងពេលដែលយើងមានទេសចរជាង ៥លាននាក់ ... ។

៦. ទាក់ទាញវិនិយោគផ្នែកឧស្សាហកម្មឱ្យមកកែច្នៃលើវត្តធាតុដើមក្នុងស្រុក

សំណេះសំណាលជាមួយកម្មករនិយោជិត នៅខេត្តកំពង់ឆ្នាំង, ២៧ មិថុនា ២០១៨

... **យើងមានកៅស៊ូ/ដំឡូងមី និងមានវត្តុធាតុដើមកសិកម្មជាទៃទៀត។ យើងកំពុងខិតខំទាញវិនិយោគមកកែច្នៃទៅលើវត្តុធាតុដើម ដែលចេញពីផលិតផលក្នុងប្រទេស ... ដើម្បីរុញវិស័យឧស្សាហកម្មក្នុងប្រទេស ...** យើងកំពុងដាក់ (ឱ្យដំណើរការ)រោងចក្រផលិតស្ករស ដើម្បីឱ្យប្រជាពលរដ្ឋដាំអំពៅផ្គត់ផ្គង់ឱ្យរោងចក្រ។ យើងដាក់(ឱ្យដំណើរ)រោងចក្រផលិតម្សៅមី ដើម្បីឱ្យប្រជាពលរដ្ឋដាំដំឡូង រួចហើយលក់ឱ្យរោងចក្រផលិតទៅជាម្សៅមី រួចហើយអាចឈានទៅផលិតជាផលិតផលសម្រេច ដូចជាការធ្វើមីកញ្ចប់ និងអ្វីផ្សេងៗ ដែលផលិតចេញពីវត្តុធាតុដើមជាម្សៅមី ...។

៧. រៀបចំបង្កើតធនាគារគាំទ្រសហគ្រាសធុនតូច/មធ្យម

សំណេះសំណាលជាមួយកម្មករនិយោជិត នៅខេត្តកំពង់ឆ្នាំង, ២៧ មិថុនា ២០១៨

... ប្រទេសជប៉ុនមកដាំនិងវេចខ្ចប់ម្រេចនៅកម្ពុជា ហើយនាំទៅប្រទេសជប៉ុន។ យើងលើកទឹកចិត្តឱ្យមានការធ្វើបែបនេះ ... **យើងនឹងរុញការវិនិយោគនេះតាមរយៈនៃការបង្កើតនូវធនាគារ គាំទ្រដល់ការវិនិយោគក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម ដែលគេហៅថា សហគ្រាសធុនតូច/មធ្យម សម្រាប់ប្រទេសរបស់យើង។** វានឹងបង្កើតនូវមុខរបរឱ្យប្រជាពលរដ្ឋ ... (និង)ផ្តល់ប្រាក់ឈ្នួលឱ្យប្រជាពលរដ្ឋយើងផងដែរ ...។

៨. អភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ដោយសហការរវាងវិស័យសាធារណៈនិងឯកជន

បើកវេទិកាសេដ្ឋកិច្ច និងធុរកិច្ចអាស៊ី-អឺរ៉ុប លើកទី១, ២៤ វិច្ឆិកា ២០២១

... ទាមទារការ**លើកកម្ពស់កិច្ចសហការរវាងវិស័យសាធារណៈនិងឯកជន ក្នុងក្របខណ្ឌទ្វេភាគីនិងពហុភាគី ដើម្បីទាក់ទាញការវិនិយោគអភិវឌ្ឍធនធានមនុស្សនិងជំរុញឱ្យមានការផ្ទេរចំណេះដឹងនិងបច្ចេកវិទ្យាស្របតាមគន្លងប្រក្រតីថ្មី ផ្តោតជាសំខាន់លើការចាប់យកសក្តានុពលពីបដិវត្តន៍ឧស្សាហកម្មទី៤ ការលើកកំពស់ឋិរវត្តកម្មឌីជីថលនិងការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាដើម ...។**

៩. ឱកាសបានមកដល់សំរាប់ការជំរុញវិស័យឧស្សាហកម្ម

សំណេះសំណាលជាមួយកម្មករ និយោជិត នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល, ២៨ វិច្ឆិកា ២០១៨

... ជំនួបនេះមិនបញ្ចប់ត្រឹមឆ្នាំ២០១៨-២០១៩ ឬ២០២០ នោះទេ។ ធ្វើរហូតដល់ពួឈប់ធ្វើជានាយករដ្ឋមន្ត្រី ... **ពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យឧស្សាហកម្ម សំរាប់រយៈពេលពី២០១៥ដល់២០២៥ ហើយក៏បន្តទៀត ក៏យើងមិនភ្លេចកសិការនោះទេ ... ប៉ុន្តែឱកាសបានមកដល់សម្រាប់ការជម្រុញវិស័យឧស្សាហកម្ម**។ ពិតហើយ ការជួបជាមួយកម្មករមិនមែនជារឿងថ្មីដែលទើបនឹងកើតក្នុងរយៈកាលឆ្នាំ ២០១៧-២០១៨ នោះទេ។ ពួបានជួបជាមួយហ្នឹងកម្មកររាល់ឆ្នាំ ក៏ប៉ុន្តែជំនួបនោះវាមិនគ្រប់គ្រាន់។ ឥឡូវពួយកកិច្ចការនេះធ្វើជាគោលដៅ សកម្មភាពរបស់នាយករដ្ឋមន្ត្រី ...៕

១០. សហគ្រាសធុនតូចនិងមធ្យមចុះបញ្ជីនិងកាន់បញ្ជីការគណនេយ្យឱ្យបានត្រឹមត្រូវ

មតិបូកសរុប ថ្លែងក្នុងវេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន លើកទី១៨, ២៩ មីនា ២០១៩

... អ្វីដែលរាជរដ្ឋាភិបាលចង់បានពីសហគ្រាសធុនតូចនិងមធ្យម មកវិញគឺការទៅចុះបញ្ជី និងកាន់បញ្ជីការគណនេយ្យអោយបានត្រឹមត្រូវ ... សហគ្រាសធុនតូចនិងមធ្យមទាំងអស់ បើមិនបានចុះបញ្ជីទេ មិនអាចទទួលបានការលើកទឹកចិត្តតាមលំដាប់ដែលយើងបានកំណត់ ហើយក៏គ្មានសិទ្ធិដើម្បីនឹងខ្ចីប្រាក់ពីធនាគារដែរ។ **ដូច្នេះ សហគ្រាសធុនតូចនិងមធ្យម គប្បីចុះបញ្ជី និងកាន់បញ្ជីការអោយបានត្រឹមត្រូវ ដើម្បីទទួលបានអត្ថប្រយោជន៍ពីការអនុគ្រោះពន្ធ និងទទួលបានអត្ថប្រយោជន៍ពីកម្ចីដែលធនាគារត្រូវផ្តល់ ...៕**

១១. គោលនយោបាយទាក់ទាញឧស្សាហកម្មកែច្នៃ និងឧស្សាហកម្មបច្ចេកវិទ្យា

ចែកសញ្ញាបត្រដល់និស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ, ២៦ ធ្នូ ២០១៩

... គោលនយោបាយឧស្សាហកម្មទាក់ទាញ **ទី១ ឧស្សាហកម្មកែច្នៃផលិតផលកសិកម្មដែលមានស្រាប់របស់កម្ពុជា ...** វាមិនទាមទារទុនធំពេកទេ ត្រូវដំណើរការ

សហគ្រាសធុនតូចនិងមធ្យម ទាំងអ្នកក្នុងស្រុកនិងក្រៅស្រុក ... **ទី២ ទោះនៅរក្សាឧស្សាហកម្មអតិពលកម្មគឺឧស្សាហកម្មដែលប្រើកម្លាំងពលកម្មច្រើន ដូចជាវិស័យកាត់ដេរជាដើម ក៏យើងត្រូវទាញយកការវិនិយោគទៅលើឧស្សាហកម្មបច្ចេកវិជ្ជាឬឧស្សាហកម្មជំនាញខ្ពស់ ...៕**

១២. កម្ពុជាត្រូវចូលទៅក្នុងសង្វាក់ផលិតកម្មដែលមានចរិតសកល

ចែកសញ្ញាបត្រដល់និស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ, ២៦ ធ្នូ ២០១៩

... មនុស្សស្ទើរតែគ្រប់គ្នា មានលទ្ធភាពទិញខោអាវ ស្បែកជើងកីឡាសំរាប់ដើរហាត់ប្រាណ លេងកីឡា និងគ្រាន់តែប្រដាប់វាយកូនគោលមួយឆ្នាំៗមិនដឹងប៉ុន្មានទេ ... ដោយហេតុនេះហើយបានជាប្រទេសយើងចូលទៅក្នុងសង្វាក់ផលិតកម្មដែលមានចរិកសកល។ ក្រុមហ៊ុនរថយន្ត ម៉ូតូ ក៏ចូលមកផ្តុំនៅស្រុកខ្មែរផ្តត់ផ្តង់ទីផ្សារក្នុងស្រុកនិងនាំចេញ។ យើងមិនទាន់មានលទ្ធភាពផលិតរថយន្តតែទោះបីមានលទ្ធភាពផលិតរថយន្ត ក៏ប្រហែលគ្មានជាមានអ្នកទិញទេ ...៕

១៣. ទាក់ទាញឧស្សាហកម្មប្រើវត្ថុធាតុដើមក្នុងស្រុក ធ្វើផលិតផលសម្រេចនាំចេញ

សំណេះសំណាលជាមួយកម្មករ និយោជិត នៅខេត្តកំពត, ២៥ មករា ២០១៩

... យើងត្រូវរកវិធី**គួបផ្សំគ្នារវាងការជំរុញការផលិតក្នុងវិស័យកសិកម្ម និងការអភិវឌ្ឍក្នុងវិស័យឧស្សាហកម្ម ដើម្បីគួបផ្សំគ្នា ធ្វើឲ្យខឿនសេដ្ឋកិច្ចយើងរឹងមាំ**ឡើង។ ក្នុងចំណោកនៃការអនុវត្តទាំងនោះ មានដូចជាការទាក់ទាញឧស្សាហកម្មដែលប្រើវត្ថុធាតុដើមក្នុងស្រុក។ យើងមានដំឡូងមី យើងត្រូវខិតខំធ្វើយ៉ាងម៉េចទាញយករោងចក្រដែលប្រើប្រាស់វត្ថុធាតុដើមចេញពីដំឡូងមី ... យើងមានកៅស៊ូជាវត្ថុធាតុដើម យើងចង់ឲ្យគេមកផលិតមិនមែនគ្រាន់តែជាកៅស៊ូក្រៃបទេ តែជាផលិតផលសម្រេច ដូចជាគ្រឿងបង្គុំរថយន្តខ្លះធ្វើពីកៅស៊ូ ...៕

១៤. ក្រៅពីអតិពលកម្ម ចង់ទាញយកឧស្សាហកម្មបច្ចេកវិទ្យាទំនើប/សកល

សំណេះសំណាលជាមួយកម្មករ និយោជិត នៅខេត្តកំពត, ២៥ មករា ២០១៩

... ក្នុងវិស័យកសិកម្ម មិនមែនធ្វើតែមួយមុខទេ។ ធ្វើច្រើនមុខ/ច្រើនផ្នែក។ **យើងទាញយកឧស្សាហកម្ម មិនមែនតែឧស្សាហកម្មអតិពលកម្មឬដែលប្រើពល**

កម្មច្រើន ដូចដែលយើងកំពុងធ្វើនេះទេ។ យើងចង់ទាក់ទាញយកឧស្សាហកម្ម ដែលប្រើបច្ចេកវិទ្យាទំនើបចូលមកកាន់ប្រទេសយើង។ ដូចជាខ្ញុំទៅតាកែវ ខ្ញុំ ហៅថាបុប្ផាលាក់ខ្លួននៅតាកែវ។ ដោយសារអី? គ្រឿងបង្គុំផ្នែកទូរស័ព្ទស្មាត ហ្វូន ត្រូវបានផលិតនៅខេត្តតាកែវ រួចហើយយកទៅផ្គុំចេញជាទូរស័ព្ទស្មាតហ្វូន ម៉ាកនេះម៉ាកនោះ ... យើងងក៏ចង់បានឧស្សាហកម្មខ្នាតសកល ដូចជានៅតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង របស់ប្រទេសយើងមានរោងចក្រមួយចំនួន ផលិតខួរក្បាលឡាន ...៕

១៥. បដិវត្តន៍ឧស្សាហកម្មទី៤ កំពុងជាបញ្ហាប្រឈមរបស់ពិភពលោក

សំណេះសំណាលជាមួយកម្មករ និយោជិត នៅខេត្តកំពត, ២៥ មករា ២០១៩

... ពេលដែលពូនិយាយជាមួយកម្មករ/ការិនី មានអ្នកខ្លះថា "និយាយឡើងឲ្យតែកូនខ្មែរធ្វើខ្ញុំគេ" ... ចុះបើយើងមិនធ្វើការ សួរថាអ្នកណាឲ្យប្រាក់ខែយើង? ពេលដែលពួកគេកាន់អំណាចទៅ បែបជាធ្វើដូច ប៉ុល ពត ទៀតហើយ (បើថានិយាយវិញ គឺមានតាំងពី)ប្រដាប់បញ្ចុកបាយ។ តែ(ការជាក់ស្តែង)រកអីស៊ីមិនបានផង ... **ប៉ុន្តែឥឡូវគេមាន robot សម្រាប់លើកម្តុប។ ទៅប្រទេសចិនកន្លងទៅ (ឃើញថា)បន្តិចទៀតអ្នកជំងឺត្រូវប្រើ robot យកស្ពឺៗ ឲ្យ។ បច្ចេកវិទ្យាបច្ចុប្បន្នកាត់បន្ថយការប្រើមនុស្សដែលនោះជាការប្រឈមរបស់ពិភពលោក។ មនុស្សផ្លាប់មានការងារធ្វើ ប៉ុន្តែបដិវត្តន៍ឧស្សាហកម្មទី៤ បង្កើតគ្រឿងយន្តធ្វើជំនួស** ...៕

១៦. កែជាក្រសួងឧស្សាហកម្ម បច្ចេកវិទ្យានិងនវានុវត្តន៍ ឱ្យទាន់បដិវត្តឧស្សាហកម្ម៤.0

បិទសន្និបាតប្រចាំឆ្នាំរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងប្រកាសធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ ឆ្នាំ២០២០, ៣១ មករា ២០២០

... មានប្រទេសជាច្រើនដែលបានបង្កើតឡើងនូវក្រសួងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ដូច្នេះ ខ្ញុំបានសម្រេចឱ្យមានការកែតម្រូវក្រសួងឧស្សាហកម្ម និងសិប្បកម្ម ទៅជា**ក្រសួងឧស្សាហកម្ម បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធិ នឹងដឹកនាំធ្វើកិច្ចការងារនេះ ហើយកែប្រែច្បាប់នៅឯរដ្ឋសភា ជា**

មួយអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង ដោយបង្កើតជាអង្គភាពសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស និងប្រមូលផ្តុំឱ្យបានតាមឱ្យទាន់នូវសភាពការណ៍ដែលកំពុងវិវឌ្ឍ និងប្រែប្រួល។ យើងមិនទាន់មានការប្រមូលផ្តុំនៅកន្លែងណាមួយទេ។ យើងនៅបែកខ្ញែក។ ដូច្នេះ ត្រូវមានការកែតម្រូវក្នុងរដ្ឋាភិបាល ដើម្បីដើរឱ្យទាន់សម័យកាលនៃបដិវត្តន៍ឧស្សាហកម្ម ៤.0 ...៕

១៧. គោលនយោបាយឧស្សាហកម្ម ២០១៥-២៥ របស់ "ហ៊ុន សែន"

ចុះពិនិត្យការបង្កបង្កើនផលស្រូវ និងសំណេះសំណាលជាមួយប្រជាកសិករ ស្រុកព្រៃកប្បាស ខេត្តតាកែវ, ២១ កក្កដា ២០២០

... **រាស៊ីសង្វាក់ជាមួយដំណើរការគោលនយោបាយឧស្សាហកម្ម ២០១៥-២០២៥ ដែលផ្តល់អាទិភាពទាញឧស្សាហកម្មពីក្រៅមកតម្រង់ឆ្ពោះការកែច្នៃវត្ថុធាតុដើមដែលមានក្នុងស្រុក។ នេះជាគោលនយោបាយឧស្សាហកម្មរបស់រាជរដ្ឋាភិបាល ឬថារបស់ ហ៊ុន សែន ទៅចុះ ព្រោះថា ហ៊ុន សែន ជាអ្នកដឹកនាំ**។ មានម្នាក់នោះថា ហ៊ុន សែន ពូកែជាងអ្នកនេះអ្នកនោះ ... ខ្ញុំអត់តាំងខ្លួនពូកែជាងអ្នកណាទេ។ អ្វីដែលខ្ញុំបានធ្វើគឺគ្រាន់តែដឹកនាំប្រទេសកម្ពុជាពីវាលពិយាដមកកាន់ការអភិវឌ្ឍប៉ុណ្ណឹងទេ ... ធ្វើតាំងពីខ្មែរអត់អង្ករស៊ី ឥឡូវសល់អង្ករជាង ៤លានតោនដែលអាចក្លាយជាអ្នកផ្គត់ផ្គង់ក្នុងតំបន់និងនៅក្រៅតំបន់ ...៕

១៨. វិទ្យាសាស្ត្របច្ចេកទេសគ្មានក្រមសីលធម៌គ្រប់គ្រងអាចនាំទៅដល់គ្រោះថ្នាក់

ប្រគល់សញ្ញបត្រ និស្សិត សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល, ១៨ ឧសភា ២០២៣

គ្មានវិធីណាល្អជាងហ្នឹងទេ។ **វិទ្យាសាស្ត្របច្ចេកទេស បើគ្មានក្រមសីលធម៌គ្រប់គ្រងទេ វិទ្យាសាស្ត្របច្ចេកទេសនោះនឹងនាំទៅដល់គ្រោះថ្នាក់ថែមទៀត ... ឧទាហរណ៍ ខាងឱសថសាស្ត្រ។ ខ្លះរៀនសូត្របាន ប៉ុន្តែបែរជាបែក មិនគិតពីការស្រាវជ្រាវផលិតថ្នាំដើម្បីព្យាបាលជំងឺឯណា ទៅជាស្រាវជ្រាវផលិត គ្រឿងញៀនទៅវិញ**។ អ្នកផលិតគ្រឿងញៀនដែលយើងកំពុងតែប្រយុទ្ធប្រឆាំងរាល់ថ្ងៃនេះ មិនមែនអ្នកធម្មតាទេ។ ពួកហ្នឹងសុទ្ធតែពួកវិទ្យាសាស្ត្រ ដែលអាចផលិតសារធាតុ

ញៀនបាន។ ហ្នឹងហើយដែលវិទ្យាសាស្ត្របច្ចេកទេសត្រូវតែមានការគ្រប់គ្រង។ អ្នកវិទ្យាសាស្ត្រមួយចំនួនស្រាវជ្រាវតែពីរឿងអាវុធសម្រាប់សម្លាប់គ្នា ...៕

១៩. បន្តយចំណាយយោធាពិភពលោក បំពើសេដ្ឋកិច្ចសង្គម បន្ទាបថ្លៃថ្នាំ/ឧបករណ៍ពេទ្យ

ប្រគល់សញ្ញបត្រ និស្សិត សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល, ១៨ ឧសភា ២០២៣

... ពេលប្រជុំអាស៊ានកន្លងទៅ ក្នុងកិច្ចសន្ទនារវាងអាស៊ាននិងAIPA (ASEAN Inter-Parliamentary Assembly), អាស៊ាននិងយុវជន និងអាស៊ាននិងផ្នែកធុរកិច្ច ដែលមានប្រមុខរដ្ឋប្រមុខរដ្ឋាភិបាល និងគណៈប្រតិភូចូលរួម ជាពិសេសខាងផ្នែកធនធាន/ឧរក្សាលខាងស្រាវជ្រាវ ខ្ញុំបានលើកជាមតិខ្លីថា **"បើសិនជាពិភពលោកកាត់បន្តយចំណាយលើយោធាត្រឹមតែ៥០% ហើយបង្វិលវាយកមកបំពើឱ្យវិស័យសេដ្ឋកិច្ចនិងសង្គម នោះថ្នាំពេទ្យក៏ចុះថ្លៃ ឧបករណ៍ពេទ្យក៏នឹងចុះថ្លៃ"**។ ប៉ុន្តែសព្វថ្ងៃគេនាំគ្នារត់ប្រណាំងគ្នាបង្កើតសព្វាវុធសម្លាប់គ្នា ជាជាងការស្រាវជ្រាវផលិតថ្នាំពេទ្យឱ្យបានថោក ឧបករណ៍ពេទ្យអោយបានថោក" ...៕

២០. ២៨ឆ្នាំមុន(១៩៩៥) អនុវត្តគោលនយោបាយពង្រាយរោងចក្រតាមខេត្តបង្ការចំនាកស្រុករកការងារ

សំណេះសំណាលជាមួយកម្មករ នៅស្រុកជើងព្រៃ ខេត្តកំពង់ចាម, ១៦ មិថុនា ២០២៣

... **ការដោះស្រាយការងារធ្វើសម្រាប់ក្មួយៗនៅជនបទបើយើងគិតតាំងពីឆ្នាំ ១៩៩៩ មកដល់ឥឡូវ វាជាការចង្អុលទិសមក២៤ ឆ្នាំហើយ។ ពួនៅចាំបានថា វេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន ដែលប្រជុំនៅសណ្ឋាគារ Intercontinental ចំនួន ២លើក និងបន្ទាប់ទៅបានទៅប្រជុំនៅវត្តភ្នំ បានចង្អុលទិសថា មិនត្រឹមតែទាក់ទាញវិនិយោគសម្រាប់ទីក្រុងភ្នំពេញទេ ក៏ប៉ុន្តែត្រូវមានការរៀបចំពង្រាយរោងចក្រទៅបណ្តាខេត្ត ដើម្បីចៀសវាងនូវការធ្វើចំណាកស្រុកចេញពីខេត្តទៅកាន់រាជធានីភ្នំពេញ ឬចេញពីខេត្តមួយទៅកាន់ខេត្តមួយរកការងារធ្វើ** ។តាំងពីនោះមក អ្នកវិនិយោគមានវត្តមានជាបន្តបន្ទាប់តាមបណ្តាខេត្ត ...៕

២១. កំពង់ចាមនឹងមានរោងចក្រច្រើនប្រើប្រាស់វត្ថុធាតុដើមមានស្រាប់

សំណេះសំណាលជាមួយកម្មករ នៅស្រុកជើងព្រៃ ខេត្តកំពង់ចាម, ១៦ មិថុនា ២០២៣

... នាអនាគត **កំពង់ចាមនឹងមានរោងចក្រច្រើនទៀត ដែលអាចជារោងចក្រប្រើប្រាស់វត្ថុធាតុដើមមានស្រាប់ក្នុងខេត្ត។ កៅស៊ូក៏មាននៅទីនេះ ស្វាយចន្ទីក៏មាននៅទីនេះ។ បើនិយាយពីចេកវិញគឺច្រើន ... ប្រទេសតូចមួយដែលអាចនាំចេញបានក្នុងកម្រិតជិត ៣០ពាន់លាន ឬ២៩ពាន់លានដុល្លារ មិនមែនជារឿងតូចទេ**។ ពីមុននេះ យើងគិតតែពីនាំចូល អត់មានអីនាំចេញទេ។ ឥឡូវនេះ យើងផ្ទេរពីប្រទេសមួយដែលនាំចូលទៅជាការនាំចេញ។ ទំហំសរុបនៃពាណិជ្ជកម្មមាន ៥២ ពាន់លានដុល្លារនៅឆ្នាំ២០២២។ ក្នុង ៥២ពាន់លាននេះ យើងនាំចេញបាន ២៩ ពាន់លាន។ បើគិតទៅវាមានអតិរេកប្រហែលជា ៤ពាន់លាន ...៕

២២. ដំណាំឧស្សាហកម្មផ្តល់ប្រយោជន៍សេដ្ឋកិច្ចនិងព្រៃឈើគ្របដណ្តប់

សំណេះសំណាលជាមួយកម្មករ នៅស្រុកជើងព្រៃ ខេត្តកំពង់ចាម, ១៦ មិថុនា ២០២៣

... យើងមានការដាំដុះខ្លួនឯង។ គ្រាន់តែដើមឆ្នាំនេះ យើងផលិត(ស្វាយចន្ទី) បានដល់ទៅ ១ ១៨០ ០០០ តោន ក្នុងពេលដែល Côte d'Ivoire ជាប្រទេសផលិតធ្លាប់បានច្រើនដែរ ផលិតបានតែ ១លាន ១សែន តោនទេ។ យើងនៅសល់ដីច្រើនទៀត។ ស្វាយចន្ទីខ្លះវាទើបនឹងធំ។ វាទើបនឹងផ្លែ។ **កសិករយើងមួយចំនួនអាចយកដីដែលធ្វើចម្ការបានផលតិចតួចទៅដាំជាស្វាយចន្ទី ឬដាំជាស្វាយ ឬដាំដំណាំឧស្សាហកម្មនានា ដើម្បីបានផ្តល់ផលសេដ្ឋកិច្ចខ្ពស់។ ស្ថានភាពនោះធ្វើឱ្យប្រទេសយើងគ្របដណ្តប់ទៅដោយព្រៃឈើថែមទៀត ក្លាយជាប្រទេសមានការអភិវឌ្ឍបៃតង ជាការពេញនិយមសម្រាប់ពិភពលោកនៅពេលបច្ចុប្បន្ន** ...៕

២៣. ថយផ្នែកសម្លៀកបំពាក់និងស្បែកជើង កើនកម្មន្តសាលមិនមែនសម្លៀកបំពាក់

សំណេះសំណាលជាមួយកម្មកររោងចក្រនៅតំបន់សេដ្ឋកិច្ចពិសេស Manhattan ក្រុងបាវិត ខេត្តស្វាយរៀង, ២៥ មិថុនា ២០២៣

... ការជះឥទ្ធិពលវាមិនអត់ទេ។ ដារាបណាសង្គ្រាមអ៊ុយក្រែន-រុស្ស៊ីមិនទាន់ចប់ នយោបាយដាក់ទណ្ឌកម្មជាឯកតោភាគីមិនទាន់ត្រូវបានបញ្ចប់ ភាពមិនច្បាស់

លាស់នៃសេដ្ឋកិច្ចសកលនៅតែមាន។ តែយើងត្រូវតែជម្នះ។ ការថមថយនៅផ្នែកមួយ វាមានផ្នែកមួយកើន។ **នេះយើងមានការថមថយផ្នែកវាយនកណ្ដា ការកាត់ដេរសម្លៀកបំពាក់និងស្បែកជើង ប៉ុន្តែវាកើនកម្មន្តសាលដែលមិនមែនជាសម្លៀកបំពាក់ ដូចជាបង្គុំនៃគ្រឿងអេឡិកត្រូនិក។ អញ្ចឹង ទំហំនៃការនាំចេញរបស់យើងក៏កើនដែរ។** ប្រទេសកម្ពុជាតូចមួយ ប៉ុន្តែទំហំនៃការនាំចេញមាន ២៩ ០០០ លានដុល្លារ ...។

២៤. គម្រោងឧស្សាហកម្មបច្ចេកវិទ្យាប្រើថាមពលបៃតង និងលំនៅដ្ឋានតម្លៃសមរម្យ

សំណេះសំណាលជាមួយកម្មកររោងចក្រនៅតំបន់សេដ្ឋកិច្ចពិសេស Manhattan ក្រុងបាវិត ខេត្តស្វាយរៀង, ២៥ មិថុនា ២០២៣

... សូម Clement Yang បន្តទាក់ទាញវិនិយោគចូលតំបន់សេដ្ឋកិច្ចពិសេស Manhattan។ គិតពីពេលស្គាល់គ្នាមកដល់ពេលនេះ មានរយៈពេល ២៤ ឆ្នាំ ហើយ ... យើងបានជួបពិភាក្សាគ្នានៅ Manila ពេលខ្ញុំទៅទស្សនកិច្ចនៅហ្វីលីពីន ឥឡូវ **Clement Yang មានគម្រោងដែលគួរឲ្យចាប់ចិត្ត ដែលទី១ ទស្សនៈវិស័យ «មួយទសវត្សរ៍ក្នុងការប្រែក្លាយតំបន់សេដ្ឋកិច្ចពិសេសទៅជាតំបន់ឧស្សាហកម្មបច្ចេកវិទ្យាជាន់ខ្ពស់ប្រើប្រាស់ថាមពលបៃតង» ... ទី២ គម្រោងលំនៅដ្ឋានតម្លៃសមរម្យចាប់ផ្តើមពី ៤០០ខ្នងផ្ទះ ហើយនឹងបន្តទៅ ១៣ន់ខ្នងផ្ទះក្នុងមួយឆ្នាំ** ...។

២៥. ថ្មក្រោមដីអាចផលិតស៊ីម៉ង់ត៍នឹងធ្វើឱ្យកំពង់ស្ពឺមានឧស្សាហកម្មធុនធ្ងន់

សំណេះសំណាលជាមួយកម្មកររោងចក្រនៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ, ២៧ មិថុនា ២០២៣

... ខេត្តកំពង់ស្ពឺមិនមែនគ្រាន់តែមានរោងចក្រផ្នែកកាត់ដេរ និងវាយនកណ្ដាកាត់ដេរនិងដេរស្បែកជើងទេ។ ខេត្តកំពង់ស្ពឺមានឧស្សាហកម្មផ្សេងទៀត ជាការកែច្នៃផ្នែកកសិផល រាប់ទាំងដំឡូងមី រាប់ទាំងស្ករស។ **ទៅអនាគត កំពង់ស្ពឺនឹងមានឧស្សាហកម្មធុនធ្ងន់មួយ ដែលនឹងអាចផលិតស៊ីម៉ង់ត៍ក្នុងមួយឆ្នាំប្រមាណជា ២លានតោន។ កំពង់ស្ពឺនឹងក្លាយទៅជាខេត្តដែលរួមចំណែកក្នុងការផ្គត់ផ្គង់សម្ភារសំណង់ទូទាំងប្រទេស ព្រោះបានផ្តល់ការអនុញ្ញាតសម្រាប់ការវិនិយោគ**

ហើយ។ វាមិនមែនជាការយក(ថ្មពី)ភ្នំទេ ប៉ុន្តែបែរជាមានថ្មដែលអាចធ្វើស៊ីម៉ង់ត៍បាននៅឯក្រោមដីទៅវិញ ...។

២៦. កំពង់ស្ពឺនិយាយដោយឡែកភាគនីតិប្រទេសនិយាយរួមមានសក្តានុពលឧស្សាហកម្ម

សំណេះសំណាលជាមួយកម្មកររោងចក្រនៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ, ២៧ មិថុនា ២០២៣

... ខេត្តកំពង់ស្ពឺគឺជាខេត្តនៅសេសសល់សក្តានុពលច្រើន ប្រសិនបើយោងទៅអ្វីដែលខ្ញុំធ្លាប់បានថ្លែងកាលពីពេលមុនៗ ថាចង់ផ្សារភ្ជាប់ប៉ូលសេដ្ឋកិច្ចទី១ និងប៉ូលសេដ្ឋកិច្ចទី២ តាមរយៈផ្លូវជាតិលេខ៤ ឲ្យក្លាយទៅជាតំបន់រោងចក្រនិងតំបន់កសិឧស្សាហកម្ម។ **គេអាចមើលឃើញថាចក្ខុវិស័យរបស់ ហ៊ុន សែន មិនមែនកញ្ចក់កណ្តៀតទេ។ ជាចក្ខុវិស័យដែលមានយូរមកហើយ។ យើងបាននិងកំពុងតភ្ជាប់បណ្តារោងចក្រពីទីក្រុងភ្នំពេញ ចេញមកអង្គស្នួលរបស់ខេត្តកណ្តាល និងតភ្ជាប់មកខេត្តកំពង់ស្ពឺច្បារមន ហើយចេញពីច្បារមន តទៅខេត្តព្រះសីហនុ នៅទីកន្លែងមួយចំនួនសុទ្ធតែជាតំបន់សេដ្ឋកិច្ច។ បើនិយាយដោយឡែក ខេត្តកំពង់ស្ពឺ ប៉ុន្តែនិយាយជារួមគឺទិសនិតីរបស់យើងមានសក្តានុពលទាក់ទាញវិនិយោគនៃបណ្តារោងចក្រសហគ្រាស ... ឱ្យទៅជាបណ្តាខេត្តពហុបំណងដែលកសិកម្មក៏មាន ឧស្សាហកម្មក៏មាន ទេសចរណ៍ក៏មាន** ...។

២៧. ប្រើបច្ចេកវិទ្យាព័ត៌មានជំរុញល្បឿនការងារនិងប្រយុទ្ធប្រឆាំងអំពើពុករលួយ

ចែកសញ្ញាបត្រជូនដល់និស្សិត នៃសាកលវិទ្យាល័យ ឯកទេសនៃកម្ពុជា, ២៣ មករា ២០២៣

... កូវីដ-១៩ ជាដំណាក់កាលលោតផ្លោះនៃបច្ចេកវិទ្យាឌីជីថលនៅកម្ពុជា។ រឿងនេះយើងត្រូវមើលឃើញអំពីចំណុច(វិជ្ជមានរបស់វា)។ មានសិស្ស/និស្សិត ៣លាននាក់ប្តាយរៀនតាមអនឡាញ។ ហ្នឹងហើយ(ជាចំណុចគួរជាទីមោទនក្នុងប្រព័ន្ធអប់រំរបស់យើង)។ ឥឡូវ គេចាប់ផ្តើមទូទាត់ទំនិញអីជាមួយគ្នាតាមរយៈទូរស័ព្ទទេតើ មិនមែនរាប់លុយម្តង ១រៀលឯណា? ... **ប្រើបច្ចេកវិទ្យាដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយផង។ បើកលុយសុទ្ធ ឯណាសុវត្ថិភាពនៃការដើក**

លុយកទៅតាមរតនាគារទាំងអស់ រួចបញ្ចេញពីរតនាគារត្រូវ (តម្រូវឱ្យ) អ្នកពីអង្គភាព ឧទាហរណ៍អង្គភាពកងទ័ព ឬស្ថាប័នណាមួយ ត្រូវបើក លុយចេញពីធនាគារយកទៅចែក(មន្ត្រីនៅស្ថាប័ននោះ) រាប់ៗកាត់ក្បាលលុយហ្នឹងមួយទៅ។ មួយទៀតបង្កើតជាមន្ត្រី/ទាហានខ្មោច ដែលមិនមែនទើបនឹងមានឥឡូវនេះទេ គឺតាំងពីជំនាន់ លន់ នល់ ច្រើនជាងគេ។ បន្ទាប់ទៅ ខាងយើងក៏មានដែរ ...។

ជកស្រង់ខ្លឹមសារ

នេត បញ្ញា, ហ៊ិត សេងហោ, ប៊ុន ស៊ីណា, ម៉ែន ចរិយា, លន់ ម៉ាឡែន, សម ពេជ្របញ្ញា, ឆេង សុគន្ធី, អ៊ុត ធាវ៉ា

បណ្ណាធិការនិងសហការ

រស់ កុសល, រាល ម៉ារ៉ាវី, អៀង សិរីវង្ស, សុខ សុផល

ខុទ្ទកាល័យសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
ក្រុមការងារវិបសាយត៍និងទិន្នន័យដ្ឋាន **កម្ពុជាឆ្ពោះទៅមុខ**
បោះពុម្ពលើកទីមួយ - មិថុនា ២០២៥

រោងពុម្ព JSRC 2025

ការងារ
ហដ្ឋារចនាសម្ព័ន្ធ
ការបិទខ្ទប់
អ្នកបន្តវេន
ទេសចរណ៍
ព្រៃកជីកហ្វូណនតេជោ
កូវីដ-១៩
ប្រជាធិបតេយ្យ
អត្ថប្រយោជន៍កម្មករ
សង្គមកិច្ច
នាំចេញអង្ករ
អាស៊ាន
សាធារណការ
វិនិយោគ
ប៉ារ៉ាហ្គែម
ស៊ីហ្គែម
ថាមពល
អភិក្រមផ្កាវីក
ផ្លូវលឿនលឿន
សន្តិភាព
សុខាភិបាល
បោះឆ្នោត
ចិន
វ៉ាក់សាំង
មន្ទីរពេទ្យ
ព្រៃឈើ
ជលផល
ទឹកជំនន់
ការបរទេស
ចរាចរណ៍
ប្រពៃណី
បាត់ដំបង
ពុទ្ធចក្រ
គ្រោះធម្មជាតិ
កែទម្រង់
ការពារជាតិ
ធនធានទឹក
ដឹកជញ្ជូន
ហិរញ្ញវត្ថុ
ឡូត៍នេសាទ
ប្បធម៌
សមាហរណកម្ម
ស្រូវ
ស្ពាន
ពាណិជ្ជកម្ម
នេសាទ
សភា
ជប៉ុន
ផ្លូវ
អាមេរិក
កម្មសិទ្ធដីធ្លី
កម្មករ
ជនពិការ
ទឹក
សហគមន៍
ទំនៀមទម្លាប់
កសិឧស្សាហកម្ម
ខ្មែរក្រហម
ជម្លោះព្រំដែន
កិច្ចការនារី
កម្លាំងប្រដាប់អាវុធ
រដ្ឋប្រហារ
វិស័យឯកជន
កំពង់ឆ្នាំង
ប្រកួតប្រជែង
ទឹកស្អាត
ព្រៃលិចទឹក
មជ្ឈិមបូព៌ា
យុទ្ធសាស្ត្រចតុកោណ
តារាវ
ប្រាសាទព្រះវិហារ
ព្រំដែន
តុលាការ
អង្គការក្រៅរដ្ឋាភិបាល
កសិក
អគ្គិសនី
កំពង់ចាម
ប្រៃប្រួលអាកាសធ
ដីធ្លី
វិមជ្ឈការ
មនុស្សធម៌
ការទូត
មហាផ្ទៃ
និស្សិតបរទេស
នីតិរដ្ឋ
គ្រប់គ្រងដីធ្លី
ភ្នំពេញ
បរិស្ថាន
ត្រី
ព្រំដែនកម្ពុជា-ថៃ
ព្រៃវែង
បេតិកភណ្ឌពិភពលោក
សេវាសាធារណៈ
ប្រជាធិបតេយ្យ
ជលផល
វិទ្យាល័យ
បារាំង
ក្រចេះ
ព្រះមហាក្សត្រ
ច្បាប់
អភិវឌ្ឍ
ឧស្សាហកម្ម
វត្ត
ការទូត
ការបរទេស
ចរាចរណ៍
ប្រពៃណី
ផ្លូវលឿនលឿន
ការសហប្រជាជាតិ
ការងារ
ការបិទខ្ទប់
នាំចេញអង្ករ
សុខាភិបាល
អាស៊ាន
សាធារណការ
អ្នកបន្តវេន
វិនិយោគ
ទេសចរណ៍
ព្រៃកជីកហ្វូណនតេជោ
ប៉ារ៉ាហ្គែម
ស៊ីហ្គែម
ថាមពល
អភិក្រមផ្កាវីក
ប្រជាធិបតេយ្យ
អត្ថប្រយោជន៍កម្មករ
សង្គមកិច្ច
សន្តិភាព
បោះឆ្នោត
ចិន
វ៉ាក់សាំង
មន្ទីរពេទ្យ
ផ្លូវលឿនលឿន